# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៣៦

បាលីប្រែ ៥៣

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

## បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ខុទ្ទកបាឋ ឥតិវុត្តក

## ទុតិយភាគ

# ៣៦

## បាលីប្រែ ៥៣



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣៦

# សុត្តន្តបិដក ចាលីប្រែ -៥៣

# ខុទ្ទកនិកាយ ឥតិវុត្តក

## ទុតិយភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ឯកនិបាត បឋមវគ្គ

### លោភសូត្រ

*[ ១ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺលោភៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា*

*សត្វទាំងឡាយ ល្មោភហើយ ព្រោះលោភៈណា តែង*
*ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង*
*ដោយបញ្ញា ដ៏ប្រពៃហើយ រមែងលះបង់លោភៈនោះ*

បាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោក

នេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រ ទី ១ ។

# អដ្ឋកថា

# ខុទ្ទកនិកាយ ឈ្មោះ បរមត្ថទីបនី

## ឥតិវុត្តកវណ្ណនា

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*ខ្ញុំព្រះករុណាសូមវន្ទាព្រះមានព្រះភាគ ទ្រង់ជាទីពឹង ទ្រង់មានព្រះហឫទ័យ ប្រកបដោយមហាករុណាទិគុណ យាងដល់ត្រើយនៃសាគរ គឺញេយ្យធម៌បានហើយ ទ្រង់មានទេសនាន័យដ៏វិចិត្រសុខុមគម្ភីរភាព ។*

*ខ្ញុំព្រះករុណាសូមវន្ទាព្រះធម៌នោះ ជាធម៌ឧត្តម ដែលព្រះសម្មាសម្ពុទ្ធទ្រង់បូជា ដែលនាំព្រះអរិយសាវកទាំងឡាយ សម្បូរដោយវិជ្ជា និងចរណៈ ឲ្យឆ្លងផុតអំពីលោក ។*

*ខ្ញុំព្រះករុណាសូមវន្ទាព្រះសង្ឃ ដែលជាព្រះអរិយៈនោះ លោកតាំងមាំក្នុងមគ្គ និងផល សម្បូរដោយសីលាទិគុណ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។*

*ដោយតេជានុភាពនៃបុណ្យដែលកើតអំពីការនមស្ការព្រះរតនត្រ័យ ដូចបានពណ៌នាមកនេះ សូមភ័យដែលកើតអំពីអន្តរាយរួចផុតដល់ខ្ញុំសព្វកាល ។*

*ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ដែលចាំវស្សាក្នុងបុរីមានប្រក្រតីស្វែងរកគុណធំ បានរួបរួមព្រះសូត្រទាំងឡាយ ដែលលោកអ្នកស្វែងរកគុណធំសម្តែងហើយ ដោយចែកជានិបាត មានឯកនិបាតជាដើម ដែលសម្តែងដល់*

ការលះកិលេសទាំងឡាយ មានលោភៈជាដើមយ៉ាងវិសេស រត់ជួរតែមួយ ហើយចងក្រងដោយបទអក្ខរៈ ដូចពោលមកនេះ ដោយដាក់ឈ្មោះថា **ឥតិ-វុត្តក។** សេចក្ដីពិត ការចងអដ្ឋកថាពណ៌នាលំដាប់បទ មានអត្ថដ៏ជ្រាលជ្រៅក្នុងខុទ្ទកនិកាយ ជារបស់ដែលខ្ញុំធ្វើបានលំបាក ព្រោះជាអត្ថដែលឈមចុះបានដោយបញ្ញាដ៏ជ្រាលជ្រៅ តែព្រោះអដ្ឋកថាជួយទ្រទ្រង់នូវព្រះសាសនារបស់ព្រះសាស្ដាបាន ទាំងជាវិនិច្ឆ័យនៃបុព្វាចារ្យ ដែលប្រៀបដូចជារាជសីហ៍ បានមុជចុះហើយផង ដូច្នោះ ខ្ញុំនឹងចងអដ្ឋកថាឥតិវុត្តកៈឲ្យល្អតាមកម្លាំង ដោយទាញយកវិនិច្ឆ័យនៃបុព្វាចារ្យទាំងនោះជាគោល កាន់យក ៥ និកាយជាគំរូ អាស្រ័យន័យអំពីអដ្ឋកថាបុរាណ សូម្បីត្រឹមតែជាពាក្យពោលរបស់និស្សិតតែក៏បរិសុទ្ធ មិនឃ្លៀងឃ្លាត ជាកិច្ចវិនិច្ឆ័យអត្ថដែលល្អិតល្អន់នៃបុព្វាចារ្យគណៈមហាវិហារ ហើយវៀរពាក្យដដែលៗ ចោលខ្លះ ។

សាធុជនទាំងឡាយ ចូរអ្នកទាំងឡាយ តាំងចិត្តស្ដាប់កិច្ចពណ៌នាអត្ថនៃអដ្ឋកថាឥតិវុត្តកៈនោះរបស់ខ្ញុំ ដែលបំណងឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ និងចែកអត្ថដូចតទៅនេះ ។

## អធិប្បាយ ឥតិវុត្តកៈ

ក្នុងគាថានោះ ឈ្មោះថា **ឥតិវុត្តក** ចាត់ជា ៤ និបាត គឺឯកនិបាត ទុកនិបាត តិកនិបាត ចតុក្កនិបាត ។ ឥតិវុត្តកៈនោះ ទាក់ទងក្នុងសុត្តន្តបិដក ក្នុងបិដកទាំង ៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ។ ទាក់ទងក្នុងខុទ្ទកនិកាយ ក្នុង ៥ និកាយ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ

អង្គុត្តរនិកាយ ខុទ្ទកនិកាយ ។ ចាត់ជាឥតិវុត្តកៈ ក្នុងនវង្គសត្ថុសាសនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម៌ វេទល្លៈ ។ សង្គ្រោះចូលក្នុងធម្មក្ខន្ធបន្តិចបន្តួច បណ្ដាធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទត្ថេរ ជាធម្មភណ្ឌាគារិកប្ដេជ្ញាយ៉ាងនេះថា

ធម៌ឯណាដែលប្រព្រឹត្តទៅដល់ខ្ញុំ ធម៌ទាំងនោះ ខ្ញុំរៀនមកអំពីព្រះពុទ្ធ ៨២០០០ ព្រះធម្មក្ខន្ធ រៀនអំពីភិក្ខុ ២០០០ ព្រះធម្មក្ខន្ធ រួមជា ៨៤០០០ ព្រះធម្មក្ខន្ធ ។ ដោយព្រះសូត្រ រួមព្រះសូត្រជា ១១២ សូត្រ គឺក្នុងឯកនិបាត ២៧ សូត្រ ក្នុងទុកនិបាត ២២ សូត្រ ក្នុងតិកនិបាត ៥០ សូត្រ ក្នុងចតុក្កនិបាត ១៣ សូត្រ ។ ឥតិវុត្តកៈនោះ ក្នុងបណ្ដានិបាត មានឯកនិបាតជាបឋម ក្នុងបណ្ដាវគ្គ មានបាដិកោគវគ្គ ជាវគ្គដំបូង ក្នុងបណ្ដាសូត្រ មានលោភសូត្រជាសូត្រទី ១ ។ ម្យ៉ាងទៀត ឥតិវុត្តកៈនោះ មានពាក្យផ្ដើមដែលព្រះអានន្ទពោលក្នុងកាលធ្វើមហាសង្គាយនាលើកទី ១ មានពាក្យថា **វុត្តំ ហេតំ ភគវា** ជាពាក្យផ្ដើម ។ ការសង្គាយនាលើកទី ១ នោះ លើកណា ដែលគប្បីពោលដើម្បីនឹងបានយល់ក្នុងពាក្យផ្ដើមក្នុងទីនេះ កថាមគ្គនោះក៏បានពោលហើយដោយពិស្ដារ ក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលក្នុងអដ្ឋកថានោះចុះ ។ ដោយសេចក្ដីគោរព ដោយសេចក្ដីពិតនោះឯង សមដូចដែលលោកពោលក្នុងទុកនិបាតថា

# និទានវណ្ណនា

ឥតិវុត្តកៈមានពាក្យផ្ដើមថា **វុត្តំ ហេតំ ភគវតា** និងព្រះសូត្រជាដើម ថា **ឯកធម្មំ ភិក្ខវេ បជហថ** នេះ ពាក្យនេះ ជាពាក្យផ្ដើមព្រះសូត្រនោះ បទ ទាំងឡាយថា **វុត្តំ ភគវតា** ជាដើមជានាមបទ ។ បទថា **ឥតិ** ជា បទនិបាត បទថា **ប** ក្នុងបទថា **បជហថ** នេះ ជាបទឧបសគ្គ ។ បទថា **ជហថ** ជាបទអាខ្យាត ។ គប្បីជ្រាបការចែកបទក្នុងទីគ្រប់អន្លើតាមន័យនេះ ។

## អធិប្បាយ វុត្ត សព្ទ

ម្យ៉ាងទៀត ដោយអត្ថវុត្តសព្ទ ដែលមានឧបសគ្គ និងមិនមានឧបសគ្គ រមែងប្រាកដក្នុងអត្ថទាំងឡាយ មានពាក្យថា ការព្រោះពូជ ការធ្វើពូជដែលព្រោះឲ្យស្មើគ្នា ការកោរសក់ ការចិញ្ចឹមជីវិត ការរួចផុត ការប្រព្រឹត្តទៅ ដោយភាពជាបាវចនា ការរៀនសូត្រ ការពោល ។

ពិតហើយ **វុត្ត** សព្ទ មកក្នុងការព្រោះពូជ ដូចក្នុងប្រយោគជាដើមថា

**គាវោ តស្ស បជាយន្តិ ខេត្តេ វុត្តំ វិរូហតិ**
**វុត្តានំ ផលមស្នាតិ យោ មិត្តានំ ន ទុព្ភតិ ។**

បុគ្គលណា មិនប្រទូស្តមិត្តទាំងឡាយ គោទាំងឡាយ របស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះ សាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែ នៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ ។

មកក្នុងការធ្វើពូជដែលព្រោះឲ្យស្មើគ្នាដោយវត្ថុទាំងឡាយ មានរនាស់ ជាដើម ដូចក្នុងប្រយោគជាដើមថា **នោ ច ខោ បដិវុត្តំ ។** មកក្នុងការ

កោរសក់ ដូចក្នុងប្រយោគជាដើមថា **កាបដិកោ នាម មាណវោ ទហរោ វុត្តសិរោ** មាណពកំលោះម្នាក់ ឈ្មោះកាបទិកៈ មានក្បាលកោរហើយ ។ មកក្នុងការចិញ្ចឹមជីវិត ដូចក្នុងប្រយោគជាដើមថា **បណ្ណលោមោ បរទត្តវុត្តោ មិគភូតេន ចេតសា វិហរាមិ** ជាមនុស្សស្រួលបរោម ចិញ្ចឹមជីវិតដោយចតុប្បច្ច័យ ដែលបុគ្គលដទៃឲ្យ មានចិត្តដូចជាពួកសត្វម្រឹគ ។ មកក្នុងការរួចផុតអំពីចំណង ដូចក្នុងប្រយោគជាដើមថា **សេយ្យថាបិ នាម បណ្ឌុបលាសោ ពន្ធនា បវុត្តោ អភព្វោ ហរិតត្ថាយ** ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចត្រឡប់ទៅជាមានពណ៌ខៀវវិញបាន ដូចម្ដេចមិញ ។ មកក្នុងការប្រព្រឹត្តទៅ ដោយភាពជាបាវចនា ដូចក្នុងប្រយោគជាដើមថា **យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ** ឥសីទាំងឡាយណា ដែលជាបុព្វបុរសរបស់ព្រាហ្មណ៍ទាំងឡាយ ជាអ្នកកសាងមន្ត ជាអ្នករាយមន្ត លម្អានៃមន្តបុរាណនេះ ដែលពួកឥសីណាបាន ( ស្វាធ្យាយ ) មកហើយ បានសូត្រមកហើយ បានសន្សំមកច្រើនហើយ ឥឡូវនេះ ព្រាហ្មណ៍ទាំងនោះ តែងច្រៀង(ស្វាធ្យាយ) ... ។ មកក្នុងការសូត្ររៀន ដូចក្នុងប្រយោគជាដើមថា **វុត្តោ គណោ វុត្តោ ធារយតោ** ឯគុណដែលសូត្ររៀនក្នុងលោក ជាគុណដែលត្រូវសូត្ររៀនតទៅ ។ មកក្នុងការពោល ដូចក្នុងប្រយោគជាដើមថា **វុត្តំ ខោ បនេតំ ភគវតា ធម្មទាយាទា មេ ភិក្ខវេ ភវថ មា អាមិសទាយាទា** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។

*តែក្នុងទីនេះ* **វុត្ត** *សព្ទ គប្បីឃើញថា ប្រើក្នុងការពោល ព្រោះហេតុនោះ ទើបមានអត្ថថា ពោល ប្រាប់ និទាន ។ ឯ* **វុត្ត** *សព្ទទី ២ គប្បីជ្រាបថា ប្រើក្នុងពាក្យពោល និងក្នុងភាវៈដែលប្រព្រឹត្តហើយ ។*

## អធិប្បាយ ហិ និង ឯតំ សព្ទ

*សព្ទថា* **ហិ** *ជានិបាត ប្រើក្នុងអត្ថថា ពិត ជាក់ច្បាស់ ។ សព្ទនោះ ធ្វើបញ្ជាក់នូវអត្ថថា សូត្រដែលពោលក្នុងឥឡូវនេះ ជាសូត្រដែលព្រះមានព្រះភាគ ត្រាស់យ៉ាងជាក់ច្បាស់ ។ និបាតទាំងឡាយ ប្រកបដោយការប្រជុំព្រម នៃសព្ទដែលប្រាប់អត្ថ ។ ពិតហើយ និបាតទាំងនោះ ជួយពង្រីកសេចក្ដីដែលគប្បីពោលឲ្យច្បាស់ឡើង ។*

**ឯតំ** *សព្ទ ក្នុងបទថា* **ឯតំ** *នេះ មកក្នុងអត្ថថា ជាក់ច្បាស់ក្នុងទីជិតតាមដែលពោលហើយ ដូចក្នុងប្រយោគជាដើមថា*

*លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយសច្ច ១ និរោធសច្ច ១ គន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីរម្ងាប់ទុក្ខ ១ ដោយប្រាជ្ញាដ៏ប្រពៃ នេះឯងជាទីពឹងដ៏ក្សេម នេះឯងជាទីពឹងដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។*

*តែដែលមកក្នុងអត្ថថា ប្របក្ស ជាក់ច្បាស់ក្នុងទីជិតដែលកំពុងពោលដល់ ដូចក្នុងប្រយោគជាដើមថា* **អប្បមត្តកំ ខោ បនេតំ ភិក្ខវេ ឱរមត្តកំ**

**សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ** *ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលបើពោលសរសើរគុណរបស់តថាគត តែង សរសើរដោយគុណជាតណា គុណជាតនុ៎ះ មានប្រមាណតិច មានប្រមាណ ស្តួចស្តើង បានត្រឹមតែសីលប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងទីនេះ* **ឯតំ** *សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថា ប្រចក្សច្បាស់ក្នុងទីជិតដែលកំពុងពោលដល់ នោះឯង ព្រោះថា សូត្រដែលកំពុងពោលដល់ ដោយអំណាចនៃការពិចា- រណា ព្រះអានន្ទត្ថេរដែលជាធម្មភណ្ឌាគារិក តាំងនៅហើយក្នុងវុឌ្ឍិធម៌ ពោលក្នុងគ្រាដំបូងថា* **ឯតំ** *ដូច្នេះ ។*

## អធិប្បាយពាក្យថា ភគវា

*ក្នុងបទថា* **ភគវតា** *នេះ គប្បីជ្រាបអធិប្បាយដូច្នេះ បទថា* **ភគវា** *ជាពាក្យហៅបុគ្គលដែលជាទីគោរព ។ សេចក្តីពិត មនុស្សទាំងឡាយក្នុងលោក រមែងហៅបុគ្គលជាទីគោរពថា* **ភគវា** *។ ព្រះតថាគត ឈ្មោះថា ជាទីគោរព នៃសត្វទាំងឡាយ ព្រោះទ្រង់វិសេសដោយគុណសព្វយ៉ាង ព្រោះហេតុនោះ គប្បីជ្រាបថា* **ភគវា** *។ សូម្បីបុរាណាចារ្យទាំងឡាយ ក៏បានពោលថា*

> *ពាក្យថា* **ភគវា** *ជាពាក្យប្រសើរបំផុត ពាក្យថា* **ភគវា** *ជាពាក្យ*
> *ឧត្តម ព្រះតថាគតនោះ ទ្រង់ដល់នូវភាពជាបុគ្គលគួរគោរពក្រៃលែង*
> *ដោយហេតុនោះ ទើបថ្វាយព្រះនាមថា* **ភគវា** *។*

*ពិតហើយ វាចាដែលប្រារព្ធដល់បុគ្គលដ៏ប្រសើរបំផុត ពោលថា ប្រសើរ បំផុត ព្រោះប្រព្រឹត្តទៅជាមួយគុណដ៏ប្រសើរ ម្យ៉ាងទៀត ដែលឈ្មោះថា*

**វចន** ព្រោះអត្ថថា ដែលបុគ្គលពោល បានដល់ អត្ថ ។ ព្រោះហេតុនោះ ក្នុងបទថា **ភគវាតិ វចនំ សេដ្ឋំ** ទើបមានអត្ថថា អត្ថណាដែលគប្បីពោល ដោយពាក្យថា **ភគវា** នេះ អត្ថនោះប្រសើរបំផុត ។ ក្នុងបទថា **ភគវាតិ វចនមុត្តំ** នេះ ក៏ន័យនេះឯង ។ បទថា **គារវយុត្តោ** បានដល់ ឈ្មោះថា ទ្រង់ជាបុគ្គលគួរដល់សេចក្តីគោរពកោតក្រែង ព្រោះទ្រង់ប្រកបដោយគុណ របស់បុគ្គលដែលជាទីគោរព ។ម្យ៉ាងទៀត ព្រះតថាគត ឈ្មោះថា ទ្រង់គួរ ដល់ការគោរព ព្រោះទ្រង់គួរដល់ការធ្វើសេចក្តីគោរពយ៉ាងក្រៃលែង ដោយ អត្ថថា ទ្រង់គួរដល់សេចក្តីគោរព កាលបើដូច្នោះ ពាក្យថា **ភគវា** នេះ ជា ពាក្យហៅបុគ្គលដែលវិសេសដោយគុណ បុគ្គលដែលឧត្តមជាងសត្វ និង បុគ្គលដែលជាទីគោរពកោតក្រែង ដូច្នេះឯង ។

មួយប្រការទៀត គប្បីជ្រាបអត្ថនៃបទថា **ភគវា** តាមន័យដែលមក ក្នុងនិទ្ទេសថា

ព្រះពុទ្ធនោះ បណ្ឌិតថ្វាយព្រះនាមថា **ភគវា** ព្រោះទ្រង់មាន ភគធម៌ ១ ព្រោះទ្រង់មានប្រក្រតីសេពភគធម៌ ១ ទ្រង់មាន ភាគធម៌ ១ ទ្រង់ចែកនូវភាគធម៌ ១ ទ្រង់ទម្លាយនាមរូប ១ ទ្រង់ ជាទីគោរព ១ ទ្រង់មានភាគ្យធម៌ ១ ទ្រង់មានព្រះកាយអប់រំល្អ ហើយ ដោយញាយធម៌ជាច្រើន ១ ទ្រង់ដល់ទីបំផុតនៃភព ១ ។ ម្យ៉ាងទៀត ដោយអំណាចនៃគាថានេះថា

ព្រោះទ្រង់មានភាគ្យធម៌ ១ ទ្រង់មានភគ្គធម៌ ១ ទ្រង់ប្រកប

ដោយកគ្គធម៌ ១ ទ្រង់ចែកនូវកគ្គធម៌ ១ ទ្រង់មានបុគ្គលកក្តី ១ ទ្រង់ខ្ជាក់ចោលនូវការទៅក្នុងភពទាំងឡាយ ១ ដូច្នោះ ទើបបាន ទទួលព្រះនាមថា **ភគវា** ។

អត្ថនោះបានពោលហើយ ក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងវិសុទ្ធិមគ្គ យ៉ាង គ្រប់គ្រាន់ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គនោះចុះ ។

## អត្ថនៃភគវាដោយន័យម្យ៉ាងទៀត

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានភាគធម៌

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់អប់រំពុទ្ធការកធម៌

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភាគធម៌

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភគធម៌

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានបុគ្គលកក្តី

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភគធម៌

ព្រះនាមថា **ភគវា** ព្រោះអត្ថថា ព្រោះទ្រង់ខ្ជាក់ចោលនូវភាគធម៌ ព្រះជិនស្រីទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានភាគធម៌ ១ ទ្រង់អប់រំពុទ្ធការកធម៌ ១ ទ្រង់សេពនូវភាគធម៌ ១ ទ្រង់ សេពនូវភគធម៌ ១ ទ្រង់មានបុគ្គលកក្តី ១ ទ្រង់ខ្ជាក់នូវភគធម៌ ១ ទ្រង់ខ្ជាក់ចោលនូវភាគធម៌ ១ ។

ក្នុងអត្ថទាំងនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

## ទ្រង់មានភាគធម៌

ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានភាគធម៌ដូចម្តេច គឺគំនរធម៌ បានដល់ ចំណែកនៃគុណ មានសីលជាដើម ដែលវិសេសក្រៃលែង មិនទូទៅដល់បុគ្គលដទៃមាន គឺបានចំពោះដល់ព្រះតថាគតប៉ុណ្ណោះពិតហើយ ព្រះតថាគតនោះ ទ្រង់មាន គឺទ្រង់បានភាគៈនៃគុណ បានដល់ចំណែកនៃគុណដែលជានិរត្តិវិស័យ ( មិនមានចំណែកនៃគុណដទៃក្រៃលែងជាង ) មិនកំណត់ប្រភេទ មិនមានទីបំផុត មិនទូទៅដល់បុគ្គលដទៃ មាន សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តញ្ញាណទស្សនៈ ហិរិ ឱត្តប្បៈ សទ្ធា វិរិយៈ សតិ សម្បជញ្ញៈ សីលវិសុទ្ធិ ចិត្តវិសុទ្ធិ ទិដ្ឋិវិសុទ្ធិ សមថៈ វិបស្សនា កុសលមូល ៣ សុចរិត ៣ សម្មាវិតក្ក ៣ អនវជ្ជសញ្ញា ៣ ធាតុ ៣ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ អរិយមគ្គ ៤ អរិយផល ៤ បដិសម្ភិទា ៤ ញាណកំណត់ដឹងកំណើត ៤ អរិយវង្ស ៤ វេសារជ្ជញ្ញាណ ៤ អង្គរបស់ភិក្ខុដែលបំពេញព្យាយាម ៥ សម្មាសមាធិមានអង្គ ៥ សម្មាសមាធិ មានញាណ ៥ ឥន្ទ្រិយ ៥ ពល ៥ និស្សារណីយធាតុ ៥ វិមុត្តាយតនញ្ញាណ គឺញាណដែលជាប្រកពកើតនៃវិមុត្តិ ៥ វិមុត្តិបរិបាចនីយបញ្ញា គឺបញ្ញាជាគ្រឿងអប់រំបន្ទុំវិមុត្តិ ៥ អនុស្សតិដ្ឋាន គឺទីតាំងនៃអនុស្សតិ ៦ គារវៈ ៦ និស្សារណីយធាតុ ៦ សត្តវិហារធម៌ ៦ អនុត្តរិយៈ ៦ និព្វេធភាគិយសញ្ញា ៦ អភិញ្ញា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧

អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និទ្ទសវត្ថុ ៧ សញ្ញា ៧ ទេសនាពោលដោយទក្ខិណេយ្យបុគ្គល ៧ ទេសនាពោលដោយពលធម៌របស់ព្រះខីណាស្រព ៧ ទេសនាពោលដោយហេតុបាននូវបញ្ញា ៨ សម្មត្តធម៌ ៨ លោកុត្តរធម៌ ៨ អារម្ភវត្ថុ ៨ អក្ខណៈទេសនា គឺទេសនាពោលដោយខណៈដែលមិនអាចប្រព្រឹត្តព្រហ្មចរិយៈបាន ៨ មហាបុរិសវិតក្ក ៨ ទេសនាពោលដោយអភិភាយតនៈ ៨ វិមោក្ខ ៨ ធម៌ដែលមានយោនិសោមនសិការជាមូល ៩ អង្គនៃភិក្ខុអ្នកបំពេញព្យាយាមដើម្បីសេចក្ដីបរិសុទ្ធ ៩ ទេសនាពោលដោយសត្តាវាស ៩ ឧបាយកម្ចាត់អាឃាតវត្ថុ ៩ សញ្ញា ៩ នានត្តធម៌ ៩ អនុបុព្វវិហារធម៌ ៩ នាថករណធម៌ ១០ កសិណាយតនៈ គឺប្រភពកើតនៃកសិណ ១០ កុសលកម្មបថ ១០ សម្មត្តធម៌ ១០ អរិយវាសធម៌ ១០ អសេក្ខធម៌ ១០ តថាគតពល ១០ អានិសង្សមេត្តា ១១ អាការធម្មចក្រ ១២ ធុតង្គគុណ ១៣ ពុទ្ធញាណ ១៤ វិមុត្តិបរិបាចនីយធម៌ ១៥ អានាបានស្សតិ ១៦ អគបនីយធម៌ ១៦ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញាណ ១៩ ញាណវត្ថុ ៤៤ ឧទយព្វយញ្ញាណ ៥០ កុសលធម៌ច្រើនជាង ៥០ ញាណវត្ថុ ៧៧ សមាបត្តិ ២ លាន ៤ សែនកោដិ មហាវជិរញ្ញាណ ៥ ទេសនាន័យពោលដោយការពិចារណាបច្ច័យ ក្នុងអនន្តនយសមន្តប្បដ្ឋានប្បករណៈ និងញាណសម្ដែងដល់អាសយជាដើម នៃសត្វទាំងឡាយ ដែលមិនមានទីបំផុតក្នុងលោកធាតុដែលមិនមានទីបំផុត ។ ព្រោះហេតុនោះ កាលគួរថ្វាយព្រះនាមថា **ភាគវា** ព្រោះទ្រង់មានភាគៈនៃគុណតាមដែលពោលចែកហើយ លោក

ក៏ថ្វាយព្រះនាមថា **ភគវា** ដោយស្រះ **អា** អក្ខរៈ ជា **អ** អក្ខរៈ ។ ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានភាគធម៌ ដូចពណ៌នាមកនេះ ។

ព្រោះហេតុដែលភាគៈនៃគុណទាំងអស់ មានសីលជាដើម
មានក្នុងព្រះសុគតយ៉ាងគ្រប់គ្រាន់ ដូច្នោះ បណ្ឌិតគប្បី
ថ្វាយព្រះនាមទ្រង់ថា **ភគវា** ។

# ទ្រង់អប់រំពុទ្ធការកធម៌

ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់អប់រំពុទ្ធការកធម៌ ដូចម្ដេច គឺពុទ្ធការកធម៌ទាំងនោះ មានបារមី ១០ បានដល់ ទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី ។ ឧបបារមី ១០ និងបរមត្ថបារមី ១០ រួមជាបារមី ៣០ សង្គហវត្ថុ ៤ មានទានជាដើម អធិដ្ឋានធម៌ ៤ មហាបរិច្ចាគ ៥ គឺបរិច្ចាគរាងកាយ ១ មានភ្នែកជាដើម បរិច្ចាគទ្រព្យ មានលះរាជសម្បត្តិជាដើម បរិច្ចាគបុត្រ និងភរិយា បុព្វប្បយោគ បុព្វចរិយា ធម្មក្ខាន គឺការពោលធម៌ លោកត្ថចរិយា ញាតត្ថចរិយា ពុទ្ធចរិយា ដែលព្រះមហាសត្វទាំងឡាយដល់នូវការខ្វល់ខ្វាយ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងមូល ដែលសមោធានធម៌ ៨ ប្រការ មានភាពជាមនុស្សជាដើមដល់ព្រមហើយ ធ្វើមហាភិនីហារដើម្បីសម្រេចសម្មាសម្ពោធិញ្ញាណ បំពេញឲ្យបរិបូណ៌ ឬបើពោលដោយសង្ខេប ពុទ្ធការកធម៌ជាហេតុ គប្បីបំពេញ

បុណ្យបន្ថែមនូវញាណ ពុទ្ធការកធម៌ទាំងនោះ ដែលទ្រង់បំពេញ គឺសន្សំមក ដោយគោរព គ្រប់គ្រាន់មិនដាច់ អស់កាល ៤ អសង្ខេយ្យ និង ១ សែន កប្ប រាប់អំពីមហាភិនីហារទៀបបាទមូលព្រះពុទ្ធទីបង្ករមក ពុទ្ធការកធម៌ទាំងនោះ មិនបាននៅក្នុងភាគៈនៃសេចក្តីវិនាស មិនបាននៅក្នុងភាគៈនៃសេចក្តីសៅហ្មង ឬមិនបាននៅក្នុងភាគៈឈប់តាំង ដោយពិត នៅក្នុងភាគៈ ជាគុណវិសេសក្រៃលែងឡើងៗ មានដល់ព្រះអង្គ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **ភគវា** គឺអ្នកបំពេញពុទ្ធការកធម៌ ដូច្នោះ កាលគួរថ្វាយព្រះនាមថា **ភតវា** តែបែរជាថ្វាយថា **ភគវា** ព្រោះផ្លាស់ **ត** អក្ខរៈ ឲ្យជា **គ** អក្ខរៈ តាមន័យនៃនិរុត្តិសាស្ត្រ ។ ម្យ៉ាងទៀត បទថា **ភតវា** សេចក្តីថា ទ្រង់សន្សំ គឺអប់រំ បានដល់ បំពេញពុទ្ធការកធម៌តាមដែលពោលមកហើយនោះឯង ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សម្រេចពុទ្ធការកធម៌ ដោយប្រការដូច្នេះ ។

ព្រោះហេតុដែលព្រះលោកនាថ ទ្រង់អប់រំសម្ភារធម៌ទាំងអស់

មានទានបារមីជាដើម ដើម្បីសម្មាសម្ពោធិញ្ញាណ ដូច្នោះ ទើប

ថ្វាយព្រះនាមថា **ភគវា**ៗ

## ទ្រង់សេពភាគធម៌

ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភាគធម៌ ដូចម្តេច គឺចំណែកនៃសមាបត្តិដែលប្រើរាល់ថ្ងៃ ប្រមាណ ២ ម៉ឺន ៤ ពាន់ កោដិពួកណាមាន ព្រះសម្ពុទ្ធទ្រង់ប្រើប្រាស់ ទ្រង់គប់រក ទ្រង់សេព បានដល់

ទ្រង់ធ្វើឲ្យច្រើនជានិច្ច នូវចំណែកនៃសមាបត្តិទាំងនោះ មិនមានសេសសល់ ដើម្បីជាប្រយោជន៍ដល់សត្វលោក ដើម្បីប្រថាប់នៅជាសុខក្នុងបច្ចុប្បន្នរបស់ព្រះអង្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភាគធម៌ ។ មួយប្រការទៀត ក្នុងធម៌ទាំងឡាយដែលគួរដឹងក្រៃលែង មានកុសលជាដើម និងមានខន្ធជាដើម ធម៌ពួកណា ជាចំណែកដែលគួរដឹងក្រៃលែង ដោយអំណាចជាធម៌គួរកំណត់ដឹងជាដើម ឬជាចំណែកដែលគួរដឹងក្រៃលែង ដោយសង្ខេបក៏មាន ៤ យ៉ាង តែបើពោលដោយពិស្តារ គឺធម៌ទាំងឡាយជាចំណែកដែលគួរកំណត់ដឹងច្រើនប្រភេទ ដោយន័យជាដើមថា ចក្ខុជាធម៌គួរកំណត់ដឹង ។បេ។ ជរា និងមរណៈជាធម៌ដែលគួរកំណត់ដឹង ១ ធម៌ទាំងឡាយជាចំណែកដែលត្រូវលះច្រើនប្រភេទ ដោយន័យជាដើមថា ហេតុកើតនៃចក្ខុត្រូវលះ ។បេ។ ហេតុកើតនៃជរា និងមរណៈត្រូវលះ ១ ធម៌ទាំងឡាយជាចំណែកត្រូវធ្វើឲ្យជាក់ច្បាស់ច្រើនប្រភេទ ដោយន័យជាដើមថា ការរលត់នៃចក្ខុត្រូវធ្វើឲ្យជាក់ច្បាស់ ។បេ។ ការរលត់នៃជរា និងមរណៈត្រូវធ្វើឲ្យជាក់ច្បាស់ ធម៌ទាំងឡាយជាចំណែកត្រូវធ្វើឲ្យចម្រើនច្រើនប្រភេទ ដោយន័យជាដើមថា បដិបទាដែលមានប្រក្រតីឲ្យដល់នូវការរលត់នៃចក្ខុ ត្រូវចម្រើន ។បេ។ សតិប្បដ្ឋាន ៤ ត្រូវចម្រើន ១ ធម៌ទាំងអស់ ព្រះពុទ្ធទ្រង់ប្រើប្រាស់ ទ្រង់គប់រក ទ្រង់សេព ដោយអំណាចអារម្មណ៍ ភាវនា និងអាសេវនៈតាមគួរ ។ ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភាគធម៌ ដូចពណ៌នាមក ដូច្នេះ ។

មួយប្រការមួយទៀត ព្រះពុទ្ធទ្រង់សេព ទ្រង់ប្រាថ្នា ដោយព្រះមហាករុណាថា ពួកធម៌ មានសីលជាដើមជាចំណែកនៃគុណ គឺភាគៈនៃគុណដែលទូទៅ ធ្វើម្តេចហ្ន៎ធម៌ទាំងនោះ គប្បីតាំងមាំក្នុងសន្តាននៃវេនេយ្យសត្វ ហើយសេចក្តីប្រាថ្នានោះរបស់ព្រះអង្គ ក៏បាននាំផលមកឲ្យសមបំណង ទើបទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភាគធម៌ ដូចពណ៌នាមកដូច្នេះ

ព្រោះហេតុដែលព្រះតថាគតទ្រង់សេព ទ្រង់ប្រាថ្នាភាគៈនៃគុណ
គឺការសម្រេចញេយ្យធម៌ ដើម្បីជាប្រយោជន៍ដល់សត្វទាំងឡាយ
ដូច្នោះ ទើបទ្រង់ព្រះនាមថា **ភគវា**។

## ទ្រង់សេពភគធម៌

ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពភគធម៌ដូចម្តេច គឺពោលដោយសង្ខេបមុន សម្បត្តិទាំងឡាយដែលជាលោកិយ និងលោកុត្តរ ឈ្មោះថា **ភគ** ព្រោះបុគ្គលទាំងឡាយដែលបានធ្វើបុណ្យហើយដល់ព្រមដោយប្រយោគ សេពបានតាមគួរដល់សម្បត្តិ ។ ជាបឋម ក្នុងភគធម៌ទាំង ២ នោះ ភគធម៌ដែលជាលោកិយដ៏ខ្ពង់ខ្ពស់យ៉ាងក្រៃលែង ព្រះតថាគតកាលនៅជាព្រះពោធិសត្វ មុននឹងបានត្រាស់ដឹង ក៏បានសោយ បានគប់រក បានសេពមកហើយ ដែលទ្រង់តាំងនៅហើយ ទើបពិចារណាពុទ្ធការកធម៌យ៉ាងគ្រប់គ្រាន់ បន្ទុំនូវពុទ្ធធម៌ឲ្យពេញ លុះកាលបានជាព្រះពុទ្ធទ្រង់ក៏សោយ គប់រក សេពនូវភគធម៌ទាំងនោះ ដែលជាលោកុត្តរ ប្រកបដោយភាវៈដែលមិនមានទោស ដែលមិនទូទៅដល់បុគ្គលដទៃ ។ បើពោល

ដោយពិស្តារ ព្រះតថាគត កាលនៅជាព្រះពោធិសត្វ ក៏បានសោយ គប់រក សេពកគធម៌ ដែលជាលោកិយ ដែលមិនទូទៅដល់បុគ្គលដទៃច្រើនយ៉ាង គឺភាពជាស្តេចបទេសរាជ ជាស្តេចឯករាជ ចក្រពត្តិរាជ និងទេវរាជជាដើម កាលបានជាព្រះពុទ្ធ ទ្រង់ក៏សោយ គប់រក សេពនូវភគធម៌ ដែលជាលោកុត្តរ មិនទូទៅដល់បុគ្គលដទៃច្រើនយ៉ាង គឺឧត្តរិមនុស្សធម៌ មានឈាន វិមោក្ខ សមាធិ សមាបត្តិ ញាណទស្សនៈ ការចម្រើនមគ្គ និងធ្វើផលឲ្យជាក់ច្បាស់ជាដើម ។

ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់សេពនូវភគធម៌ដូចពណ៌នាមក ដូច្នេះ ។

ព្រោះហេតុដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សេពនូវលោកិយសម្បត្តិ
និងលោកុត្តរសម្បត្តិជាច្រើន ដូច្នោះ ទើបបានទទួលព្រះនាមថា
**ភគវា**។

## ទ្រង់មានបុគ្គលភក្តី

ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានបុគ្គលភក្តីដូចម្តេច គឺទ្រង់មានបុគ្គលភក្តី គឺមានបុគ្គលភក្តីយ៉ាងមាំទាំច្រើន ព្រោះហេតុនោះទើបឈ្មោះថា ទ្រង់មានបុគ្គលភក្តី ។ សេចក្តីពិត ព្រះតថាគត ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះដល់ព្រមដោយគុណវិសេស ដែលមានអំណាចមិនមានអ្វីប្រៀប គឺប្រមាណមិនបាន អាទិនៃព្រះមហាករុណា និងព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះទ្រង់មានឧបការៈយ៉ាងក្រៃលែង

ក្នុងពួកសត្វ ទេវតា និងមនុស្សដោយបយោគសម្បត្តិដ៏កំពូល និវត្តិស័យ មានការបំបាត់នូវវត្ថុដែលមិនជាប្រយោជន៍ មានការបោត់វត្ថុដែលជាប្រ-យោជន៍ឲ្យគ្រប់គ្រាន់ជាខាងមុខ ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះទ្រង់មានរូបកាយ ប្រដាប់ដោយគុណវិសេស ដែលមិនជាសាធារណៈដល់បុគ្គលដទៃ ដូចជាមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងរស្មីដែលផ្សាយចេញទៅ ប្រមាណមួយព្យាមជាដើម ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះទ្រង់ប្រកបដោយសំឡេងសរសើរដ៏បរិបូណ៌បរិសុទ្ធ ផ្សាយទៅក្នុងត្រៃលោកប្រព្រឹត្តទៅ ដោយន័យជាដើមថា **ឥតិបិសោ ភគវា** ដែលទ្រង់បានមកអំពីព្រះគុណតាមសេចក្ដីពិត ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះទ្រង់តាំងមាំក្នុងគុណ មានការប្រាថ្នាតិច និងសន្ដោសជាដើម ដែលដល់លំដាប់ជាបារមីដ៏ឧត្តម ឈ្មោះថា ឧត្តមជាងសព្វសត្វ ព្រោះទ្រង់ប្រកបដោយគុណវិសេសដែលក្រៃលែង មានទសពលញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ឈ្មោះថា ទ្រង់ជាកំពូល គឺទ្រង់អធិដ្ឋានឲ្យកើតនូវការស្រឡាញ់រាប់អានដ៏ក្រៃលែង ព្រោះទ្រង់ជាទីកើតនៃសេចក្ដីអើពើ ការរាប់អាន និងការគោរពកោតក្រែងយ៉ាងច្រើនរបស់សត្វទាំងឡាយមិនកំណត់ រួមទាំងទេវតា និងមនុស្ស ព្រោះទ្រង់ជាបុគ្គលដែលគួរជ្រះថ្លា ដោយទ្រង់នាំនូវការជ្រះថ្លាមកឲ្យដោយប្រការទាំងពួងក្នុងលោកសន្និវាស បុគ្គលកាន់យកប្រមាណ ៤ យ៉ាង គឺបុគ្គលកាន់យករូបជាប្រមាណ ក៏ជ្រះថ្លាក្នុងរូប ១ បុគ្គលកាន់យកសំឡេងជាប្រមាណ ក៏ជ្រះថ្លាក្នុងសំឡេង ១ បុគ្គលកាន់យកការសៅហ្មងជាប្រមាណ

ក៏ជ្រះថ្លាក្នុងការសោហ្មង ១ បុគ្គលកាន់យកធម៌ជាប្រមាណ ក៏ជ្រះថ្លាក្នុងធម៌ ១ បុគ្គលពួកណាតាំងនៅក្នុងឱវាទរបស់ព្រះអង្គ ប្រកបព្រមដោយការជ្រះថ្លា ដែលមិនញាប់ញ័រ ការកក្តីរបស់បុគ្គលទាំងនោះ ដែលបុគ្គលណាម្នាក់ ជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ក៏លួចទៅមិនបាន សេចក្តីពិត បុគ្គលទាំងនោះ សូម្បីខ្លួនឯង ទោះត្រូវលះបង់ជីវិត ក៏មិនព្រមបោះបង់សេចក្តីជ្រះថ្លាក្នុងព្រះសម្ពុទ្ធ ឬពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ក៏ព្រោះមានកក្តីយ៉ាងមាំទាំ ដោយហេតុនោះឯង ទើបព្រះសម្ពុទ្ធត្រាស់នៅក្នុងសរភង្គជាតកថា

បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្រល្អ មានការសេព គប់មាំ ... ។

និងពុទ្ធដីកាដែលត្រាស់នៅក្នុងវិនយបិដកចុល្លវគ្គថា

ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ដូចមហាសមុទ្រ ដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើងឬជោរហួសច្រាំងទៅបាន ដូច្នោះឯង ។

ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានមនុស្សភក្តីដូចពណ៌នាមកដូច្នេះ កាលគួរថ្វាយព្រះនាមថា **ភត្តវា** តែត្រឡប់ជាថ្វាយព្រះនាមថា **ភគវា** ដោយលុប **ត** អក្ខរៈ ១ ហើយផ្លាស់ **ត** អក្ខរៈ ១

ទៀត ឲ្យជា **គ** អក្ខរៈ តាមន័យនៃនិរុត្តិសាស្ត្រ ។

ព្រោះហេតុដែលព្រះសាស្ដា ជាអ្នកប្រកបដោយព្រះគុណដ៏ក្រៃលែង ទ្រង់មានប្រក្រតីស្វែងរកប្រយោជន៍ដល់សត្វលោក ទ្រង់មានបុគ្គលកក្ដីច្រើន ដូច្នោះ ទើបបានទទួលព្រះនាមថា **ភគវា**។

# ទ្រង់ខ្ជាក់ចោលនូវភគធម៌

ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភគធម៌ ដូចម្ដេច គឺព្រោះហេតុដែលព្រះតថាគត កាលនៅជាព្រះពោធិសត្វទ្រង់បំពេញបារមីក្នុងអតីតជាតិ ទ្រង់បានខ្ជាក់ចោលនូវសិរី និងឥស្សរិយយស ដែលហៅថា **ភគ** ដោយមិនជាប់ជំពាក់ ដូចទ្រង់ខ្ជាក់ចោលនូវដុំទឹកមាត់ដូច្នោះ ពិតហើយ អត្តភាពដែលទ្រង់លះបង់រាជសម្បត្តិ ដូចជារាជសម្បត្តិរបស់ទេវតា ដោយអំណាចការបំពេញនេក្ខម្មបារមី កំណត់ចំនួនមិនបានក្នុងជាតិទាំងឡាយ មានយ៉ាងនេះ គឺក្នុងគ្រាកើតជាសោមនស្សកុមារ ក្នុងគ្រាកើតជាហត្ថិបាលកុមារ ក្នុងកាលកើតជាអយោឃរបណ្ឌិត ក្នុងកាលកើតជាមូគបក្ខបណ្ឌិត ( តេមិយ ) ក្នុងកាលកើតជាព្រះបាទចូឡសុតសោម ក្នុងអត្តភាពមុនៗ ទ្រង់មិនបានសម្គាល់សិរីរបស់ស្ដេចចក្រពត្តិរាជ ដែលមានភាពជាធំក្នុងទ្វីបទាំង ៤ ដែលដូចគ្នានឹងភាពជាធំក្នុងទេវលោក និងយសដ៏ត្រកាលដោយរតនៈ ៧ ដែលជាទីអាស្រ័យសម្បត្តិរបស់ស្ដេចចក្រពត្តិ ទ្រង់លះបង់ចោលទៅ ដោយមិនជាប់ជំពាក់ ហើយចេញអភិនិស្ក្រមណ៍ រហូតបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ទើបទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភគធម៌ មាន

សិរីជាដើម ដូចពណ៌នាមកដូច្នេះ ម្យ៉ាងទៀត ធម៌ទាំងឡាយ ឈ្មោះថា **ភគ** ព្រោះជាគ្រឿងទៅ គឺទៅស្មើនៃនក្ខត្តឫក្សទាំងឡាយ ដែលឈ្មោះថា **ភា** ដែលអាស្រ័យលោកវិសេស ដែលបែកនូវភ្នំសិនេរុ យុគន្ធរ ឧត្តរកុរុទ្វីប និងភ្នំហិមពាន្តជាដើម ឈ្មោះថា **សោភា** ព្រោះមានទីតាំងមាំ រហូតអស់កប្ប ព្រះមានព្រះភាគទ្រង់ខ្ជាក់ គឺទ្រង់លះបង់នូវភគធម៌ទាំងនោះ ដោយការលះឆន្ទរាគៈ ដែលពាក់ព័ន្ធក្នុងភគធម៌នោះ ព្រោះឈានកន្លងនូវសត្តាវាស ដែលនៅអាស្រ័យភគធម៌នោះ ។ ព្រះពុទ្ធព្រះនាមថា **ភគវា** ព្រោះទ្រង់ខ្ជាក់ចោលនូវភគធម៌ទាំងឡាយ ដោយប្រការដូច្នេះ ។

ព្រះសុគតព្រះនាមថា **ភគវា** ព្រោះទ្រង់លះបង់នូវចក្រពត្តិ សិរី
យស ឥស្សរិយៈ សុខ និងការសន្សំនូវលោក ។

## ទ្រង់ខ្ជាក់ចោលនូវភាគធម៌

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់នូវភាគ-ធម៌ដូចម្ដេច គឺឈ្មោះថា **ភាគ** បានដល់ កោដ្ឋាសទាំងឡាយ កោដ្ឋាសទាំងនោះមានច្រើនយ៉ាង ដោយអំណាចខន្ធ អាយតនៈ ធាតុជាដើម សូម្បីខន្ធ អាយតនៈ ធាតុជាដើមនោះ ក៏មានកោដ្ឋាសច្រើនយ៉ាង ដោយអំណាចខន្ធ មានរូប វេទនាជាដើម ដោយអំណាចខន្ធដែលជាអតីតជាដើម ។ ព្រះមានព្រះភាគទ្រង់កាត់នូវបបញ្ចកិលេស យោគកិលេស គន្ថកិលេស សំយោជន-កិលេស ទើបសម្រេចអមតធាតុ ទ្រង់ខ្ជាក់ចោលនូវភាគធម៌ទាំងនោះ ដោយទ្រង់មិនត្រេកអរ គឺមិនវិលត្រឡប់មករកភាគធម៌ទាំងនោះ ។ ពិតហើយ ទ្រង់

ខ្ជាក់ទ្រង់រើចេញ ទ្រង់លះបង់ចោលនូវចំណែកនៃធម៌ទាំងអស់នោះឯង ដោយមិនមានចំណែកសេសសល់ សូម្បីដោយការចែកធម៌តាមលំដាប់បទ គឺបឋវី អាបោ តេជោ វាយោ ដែលមាននៅក្នុងទីគ្រប់អន្លើ ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ ចក្ខុសម្ផស្ស ។បេ។ មនោសម្ផស្ស ចក្ខុសម្ផស្សជាវេទនា ។បេ។ មនោសម្ផស្សជាវេទនា ចក្ខុសម្ផស្សជាសញ្ញា ។បេ។ មនោសម្ផស្សជាសញ្ញា ចក្ខុសម្ផស្សជាចេតនា ។បេ។ មនោសម្ផស្សជាចេតនា រូបតណ្ហា ។បេ។ ធម្មតណ្ហា រូបវិតក្ក ។បេ។ ធម្មវិតក្ក រូបវិចារៈ ។បេ។ ធម្មវិចារៈគ្រប់អន្លើ ។ ពិតហើយ សមដូចព្រះតម្រាស់ត្រាស់ក្នុងមហាបរិនិព្វានសូត្រថា ម្នាលអានន្ទ មួយទៀត ធម្មជាតណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ អាយុសង្ខារ តថាគតដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វាននៃតថាគត មិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតនោះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ ( ដោយហេតុណា ) ហេតុនុ៎ះមិនមានឡើយ ។ ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភាគធម៌ដូចពោលមកនេះ ។

ម្យ៉ាងទៀត បទថា **ភាគេ វមិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ខ្ជាក់ទ្រង់រើ ទ្រង់លះ ទ្រង់ចោលនូវធម៌ទាំងអស់ គឺកុសលធម៌ និងអកុសលធម៌

ដែលមានទោស និងមិនមានទោស ធម៌ដែលអាក្រក់ និងប្រណីត ធម៌ដែលមានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស ដោយព្រះឱស្ឋ គឺអរិយមគ្គ-ញាណ ហើយទ្រង់សម្តែងធម៌ ដើម្បីភាពជាយ៉ាងនោះ ដល់បុគ្គលពួកដទៃសមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់នៅក្នុងអលគទ្ទូបមសូត្រថា

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ដឹងច្បាស់នូវធម៌មានឧបមាដូចក្បូន ដែលតថាគតសម្តែងហើយ គប្បីលះបង់ធម៌ទាំងឡាយចេញ នឹងចាំបាច់ពោលទៅថ្វីដល់អកុសលធម៌ ។

ព្រះពុទ្ធទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់ខ្ជាក់ចោលនូវភាគធម៌ ដូចពណ៌នាមកដូច្នេះ ។

ព្រោះហេតុធម៌ខ្មៅ និងធម៌ស ដែលចែកជាខន្ធ ធាតុ អាយតនៈជាដើម ដែលព្រះពុទ្ធទ្រង់ស្វែងរកគុណធំ ទ្រង់ខ្ជាក់បានហើយដូច្នោះ ទើបបានទទួលព្រះនាមថា **ភគវា**។

ព្រោះហេតុនោះ ទើបបុរាណាចារ្យបានពោលថា

ព្រះជិនស្រី ទ្រង់ព្រះនាមថា **ភគវា** ព្រោះអត្ថថា ទ្រង់មានភាគធម៌ ទ្រង់អប់រំពុទ្ធការកធម៌ ទ្រង់សេពនូវភាគធម៌ ទ្រង់មានភគធម៌ ទ្រង់មានបុគ្គលភក្តី ទ្រង់ខ្ជាក់នូវភគធម៌ ទ្រង់ខ្ជាក់ចោលនូវភាគធម៌ ដោយប្រការដូច្នេះ ។

## អត្ថរបស់អរហំ

បទថា **អរហាតា** សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា ជាអរហន្ត

ព្រោះទ្រង់ឆ្ងាយចាកកិលេសទាំងឡាយ ១ ព្រោះទ្រង់ទម្លាយនូវសត្រូវ គឺកិលេស មិនមានចំណែកសេសសល់ ១ ព្រោះទ្រង់កាច់បំបាក់នូវកាំនៃសង្សារចក្រ ១ ព្រោះទ្រង់គួរដល់បច្ច័យជាដើម ១ ព្រោះទ្រង់មិនធ្វើបាបក្នុងទីស្ងាត់ ១ នេះ គឺសេចក្ដីសង្ខេបក្នុងបទនេះ ឯសេចក្ដីពិស្ដារគប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងវិសុទ្ធិមគ្គ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **ភគវតា** នេះ លោកសម្ដែងការដល់ព្រមដោយព្រះរូបកាយ ដែលមិនជាទូទៅដល់បុគ្គលដទៃ ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងព្រះកេតុមាលា មានរស្មីផ្សាយទៅមួយព្យាមរបស់ព្រះមានព្រះភាគអង្គនោះ ទ្រង់ឈ្មោះថា ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ទ្រង់មានបុញ្ញសម្ភារ ដែលទ្រង់សន្សំច្រើនអសង្ខេយ្យកប្ប ដោយការសម្ដែងថាព្រះអង្គទ្រង់ខ្ទាក់ចោលនូវភាគធម៌បានហើយ ដោយបទថា **អរហតា** នេះ លោកសម្ដែងដល់ការដល់ព្រមដោយធម្មកាយ ដែលជាអចិន្តេយ្យ មានពលញ្ញាណ ១០ វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ និងអាវេណិកពុទ្ធធម៌ គឺធម៌មានចំពោះតែព្រះពុទ្ធ ១៨ ជាដើម ព្រោះទ្រង់សម្ដែងការសម្រេចសព្វញ្ញុតញ្ញាណ មានការអស់អាសវៈជាបទដ្ឋាន ដោយការសម្ដែងនូវការលះកិលេស ដែលមិនមានចំណែកសេសសល់ ។ ដោយបទទាំង ២ លោកសម្ដែងដល់ភាពដែលទ្រង់ជាអ្នកប្រាជ្ញ សត្វលោករាប់អានច្រើន ១ ភាពដែលទ្រង់ជាបុគ្គលដែលគ្រហស្ថ និងបព្វជិតចូលទៅរក ១ តាមដែលទ្រង់

អាចក្នុងការកម្ចាត់នូវទុក្ខផ្លូវចិត្តរបស់គ្រហស្ថ និងបព្វជិតទាំងនោះ ចូលទៅរក ១ តាមដែលទ្រង់មានឧបការៈដោយអាមិសទាន និងធម្មទាន ភាពដែលទ្រង់អាចក្នុងការដឹកនាំមហាជន ឲ្យប្រកបដោយគុណដែលជាលោកិយ និងលោកុត្តរ ។ ម្យ៉ាងទៀត ដោយបទថា **ភគវតា** នេះ លោកសម្តែងការដល់ព្រមទៅដោយចរណៈ ដោយសម្តែងការប្រកបព្រម ជាមួយវិហារធម៌ដ៏វិសេស មានទិព្វវិហារធម៌ជាដើម ដែលជាកំពូលក្នុងបណ្តាចរណធម៌ទាំង-ឡាយ ។ ដោយបទថា **អរហតា** នេះ លោកសម្តែងការដល់ព្រមដោយវិជ្ជា ដោយសម្តែងការសម្រេចនូវអាសវក្ខយញ្ញាណដ៏កំពូល ក្នុងវិជ្ជាគ្រប់ប្រការ ។ ម្យ៉ាងទៀត ដោយបទដំបូង គឺបទថា **ភគវតា** លោកប្រកាសដល់ការប្រកបដោយវេសារជ្ជញ្ញាណខាងក្រោយ ២ ប្រការ ដោយសម្តែងភាពដែលអន្តរាយិកធម៌ និងនិយ្យានិកធម៌ ដែលទ្រង់ចែកមិនមានភ្លាំងភ្លាត់ ។ ដោយបទក្រោយ គឺអរហតា លោកប្រកាសដល់ការប្រកបដោយវេសា-រជ្ជញ្ញាណ ២ ប្រការខាងដើម ដោយសម្តែងការលះកិលេស ព្រមទាំងវាសនា មិនមានសេសសល់ ។

ម្យ៉ាងទៀត ដោយបទដំបូង គឺ **ភគវតា** លោកប្រកាសដល់ភាពបរិបូណ៌នៃអធិដ្ឋានធម៌ គឺសច្ចៈ និងអធិដ្ឋានធម៌ គឺចាគៈ ដោយសម្តែងដល់បញ្ញាសច្ចៈ វចីសច្ចៈ និងញាណសច្ចៈរបស់តថាគត ដោយសម្តែងដល់ការលះបង់កាមគុណ ភាពជាធំក្នុងផ្លូវលោក យស លាភ និងសក្ការៈជាដើម និងដោយសម្តែងដល់ការលះបង់អភិសង្ខារ គឺកិលេសមិនមានសេសសល់ ។

*ដោយបទទី ២ គឺបទថា* ***អរហាតា*** *លោកប្រកាសដល់ការបរិបូណ៌នៃ អធិដ្ឋានធម៌ គឺឧបសម និងអធិដ្ឋានធម៌ គឺបញ្ញា ដោយសម្តែងដល់ការ បានសម្រេច ការស្ងប់រម្ងាប់សង្ខារទាំងអស់ និងដោយសម្តែងដល់ការសម្រេច សម្មាសម្ពោធិញ្ញាណ ។*

*ពិតហើយ ការមានអធិដ្ឋានធម៌ គឺសច្ចៈ ជាបារមីរបស់ព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វ បានធ្វើអភិនីហារក្នុងលោកុត្តរគុណ ដល់នូវភាព បរិបូណ៌ ព្រោះទ្រង់បំពេញបារមីគ្រប់ប្រការតាមបដិជ្ញា ទាក់ទងការប្រកប ដោយព្រះមហាករុណាទិគុណ ការមានអធិដ្ឋានធម៌ គឺចាគៈជាបារមី ដល់នូវ ភាពបរិបូណ៌ ព្រោះទ្រង់លះបង់នូវវត្ថុដែលជាសត្រូវ ការមានអធិដ្ឋានធម៌ គឺ ឧបសមជាបារមី ដល់នូវភាពបរិបូណ៌ ព្រោះធ្វើចិត្តឲ្យស្ងប់ដោយគុណទាំង- ឡាយ សេចក្តីថា អធិដ្ឋានធម៌ គឺបញ្ញា ដល់នូវភាពបរិបូណ៌ ព្រោះភាពដែល ទ្រង់ឈ្លាសក្នុងឧបាយដែលជាប្រយោជន៍ដល់អ្នកដទៃ ដូចពណ៌នាមកដូច្នេះ ឯង ។ ម្យ៉ាងទៀត អធិដ្ឋានធម៌ គឺសច្ចៈ ដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ បដិជ្ញាថា នឹងមិនធ្វើឲ្យជនអ្នកសូមឲ្យឃ្លៀងឃ្លាត គឺអស់សង្ឃឹម គឺទ្រង់ឲ្យ ដោយមិនធ្វើបដិជ្ញាឲ្យឃ្លៀងឃ្លាត អធិដ្ឋានធម៌ គឺចាគៈ ដល់នូវភាពបរិបូណ៌ ព្រោះទ្រង់លះនូវទេយ្យធម៌ អធិដ្ឋានធម៌ គឺឧបសម ដល់នូវភាពបរិបូណ៌ ព្រោះទ្រង់រម្ងាប់ភ័យ គឺលោភៈ ទោសៈ មោហៈ បានក្នុងកាលបុគ្គលទទួល ទេយ្យធម៌មិនមាន ហើយទេយ្យធម៌ គឺទានអស់ទៅ អធិដ្ឋានធម៌ គឺបញ្ញា ដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ឲ្យតាមគួរដល់កាលផង តាមវិធីផង ព្រោះ*

ទ្រង់ក្រៃលែងដោយបញ្ញាផង ។ ការបរិបូណ៌នៃអធិដ្ឋានធម៌ ៤ ក្នុងបារមី ដ៏សេស ក៏គប្បីជ្រាបតាមន័យនេះ ។ បារមីទាំងអស់អប់រំធ្វើឲ្យកើតមាន ដោយសច្ចៈ ជាក់ច្បាស់ដោយចាគៈ កពូនដោយឧបសម បរិសុទ្ធដោយ បញ្ញា សេចក្តីថា អធិដ្ឋានធម៌ គឺសច្ចៈរបស់ព្រះតថាគត ដែលប្រកបព្រម ដោយអធិដ្ឋានធម៌ ៤ ដល់នូវភាពបរិបូណ៌ ដូចពណ៌នាមកនេះ ។

សីលវិសុទ្ធិ ដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ អាជីវបារិសុទ្ធិដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ប្រកបដោយអធិដ្ឋាន-ធម៌ គឺចាគៈ ចិត្តវិសុទ្ធិដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ប្រកបដោយអធិដ្ឋាន-ធម៌ គឺឧបសម ទិដ្ឋិវិសុទ្ធិដល់នូវភាពបរិបូណ៌ ព្រោះទ្រង់ប្រកបដោយអធិដ្ឋាន-ធម៌ គឺបញ្ញា ម្យ៉ាងទៀត សីលរបស់ព្រះតថាគតនោះ គប្បីជ្រាបដោយការ នៅរួមគ្នា ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ ។ ការស្អាត គប្បី ជ្រាបដោយការផ្លាស់ប្តូរវោហារ ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺចាគៈ ។ កម្លាំងចិត្ត គប្បីជ្រាបក្នុងកាលមានអន្តរាយទាំងឡាយ ព្រោះទ្រង់ប្រកបដោយ អធិដ្ឋានធម៌ គឺឧបសម ។ បញ្ញា គប្បីជ្រាបក្នុងការសន្ទនា ព្រោះទ្រង់ប្រកប ដោយអធិដ្ឋានធម៌ គឺបញ្ញា ។ ម្យ៉ាងទៀត ព្រះតថាគត កាលទោសៈ ប្រទូស្តមិនបាន ទ្រង់ញុំាងព្រះហឫទ័យឲ្យនៅលើទោសៈបាន ព្រោះទ្រង់ប្រកប ដោយអធិដ្ឋានធម៌ គឺសច្ចៈ ។ ព្រះតថាគត កាលលោភៈឲ្យចង់មិនបាន ទ្រង់ សេពនូវបច្ច័យ ព្រោះប្រកបដោយអធិដ្ឋានធម៌ គឺចាគៈ ។ ព្រះតថាគត ដែលភ័យធ្វើឲ្យតក់ស្លុតមិនបាន ទ្រង់ចៀសវាងបាន ព្រោះទ្រង់ប្រកបដោយ

អធិដ្ឋានធម៌ គឺឧបសម ។ ព្រះតថាគត កាលមោហៈឲ្យវង្វេងមិនបាន ទ្រង់កម្ចាត់មោហៈបាន ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺបញ្ញា ។

ម្យ៉ាងទៀត ការដែលទ្រង់សម្រេចនេក្ខម្មសុខនោះ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ ។ ការដែលទ្រង់សម្រេចដល់បវិវេកសុខ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺចាគៈ ។ ការដែលទ្រង់សម្រេចដល់ឧបសមសុខ លោកសម្ដែង ព្រោះប្រកបដោយអធិដ្ឋានធម៌ គឺឧបសម ។ ការដែលទ្រង់សម្រេចដល់សម្ពោធិសុខ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺបញ្ញា ។

ម្យ៉ាងទៀត ការដែលទ្រង់ដល់នូវបីតិ និងសុខ ដែលកើតអំពីវិវេក លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ ។ ការដែលទ្រង់សម្រេចដល់បីតិ និងសុខ ដែលកើតអំពីសមាធិ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺចាគៈ ។ ការដែលទ្រង់សម្រេចដល់សុខផ្លូវកាយដែលកើតអំពីបីតិ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺឧបសម ។ ការដែលទ្រង់សម្រេចដល់ឧបេក្ខា និងសុខដែលកើត អំពីសេចក្ដីបរិសុទ្ធនៃសតិ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺបញ្ញា ។

ម្យ៉ាងទៀត ការដែលទ្រង់ប្រកបដោយសេចក្ដីសុខ ដែលកើតអំពីបច្ច័យដែលមានបរិវារសម្បត្តិជាលក្ខណៈ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ ព្រោះទ្រង់មិនត្រាស់ឲ្យឃ្លៀងឃ្លាត ។ ការដែលទ្រង់ប្រកបដោយសេចក្ដីសុខតាមសភាវៈ ដែលមានការសន្ដោសជាលក្ខណៈ ព្រោះ

ទ្រង់ប្រកបដោយអធិដ្ឋាន គឺចាគៈ ព្រោះទ្រង់មិនមានលោភៈ ។ ការដែលទ្រង់ប្រកបដោយសេចក្ដីសុខដែលកើតអំពីហេតុ មានភាពជាបុគ្គលមានបុណ្យបានធ្វើហើយជាលក្ខណៈ លោកសម្ដែង ព្រោះប្រកបដោយអធិដ្ឋានធម៌ គឺឧបសម ព្រោះទ្រង់មិនត្រូវកិលេសគ្របសង្កត់ ។ ការដែលទ្រង់ប្រកបដោយសេចក្ដីសុខដែលកើតអំពីការស្ងប់រម្ងាប់ទុក្ខ ដែលមានវិមុត្តិសម្បត្តិជាលក្ខណៈ លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺបញ្ញា ព្រោះទ្រង់សម្រេចនិព្វានបានដោយញាណសម្បត្តិ ។

ម្យ៉ាងទៀត ការដែលត្រាស់ដឹង និងចាក់ធ្លុះនូវសីលក្ខន្ធ ដែលជាអរិយៈបានសម្រេច លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺសច្ចៈ ការដែលត្រាស់ដឹង និងចាក់ធ្លុះសមាធិក្ខន្ធ ដែលអរិយៈបានសម្រេច លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺចាគៈ ។ ការដែលត្រាស់ដឹងនិងចាក់ធ្លុះនូវបញ្ញាខន្ធ ដែលអរិយៈបានសម្រេច លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺបញ្ញា ។ ការដែលត្រាស់ដឹង និងចាក់ធ្លុះនូវវិមុត្តិក្ខន្ធ ដែលអរិយៈបានសម្រេច លោកសម្ដែង ព្រោះទ្រង់ប្រកបដោយអធិដ្ឋានធម៌ គឺឧបសម ។ ការសម្រេចនៃបច្ច័យ ៤ លោកសម្ដែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺសច្ចៈ ។ ការសម្រេចនៃការលះបង់ទាំងពួង លោកសម្ដែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺចាគៈ។ ការសម្រេចនៃឥន្ទ្រិយសំវរៈ លោកសម្ដែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺឧបសម ។ ការសម្រេចនៃពុទ្ធិ លោកសម្ដែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺបញ្ញា និងសេចក្ដីសម្រេច

នៃនិព្វាន លោកក៏សម្តែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺបញ្ញានោះ ។ ម្យ៉ាងទៀត ការបានត្រាស់ដឹងនូវអរិយសច្ច ៤ លោកសម្តែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺសច្ចៈ ។ ការបានអរិយវង្ស ៤ លោកសម្តែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺចាគៈ ។ ការបានអរិយវិហារធម៌ ៤ លោកសម្តែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺឧបសម ។ ការបានអរិយវោហារ ៤ លោកសម្តែង ព្រោះទ្រង់បំពេញអធិដ្ឋានធម៌ គឺបញ្ញា ។

ម្យ៉ាងទៀត លោកប្រកាសមហាករុណារបស់ព្រះតថាគត ដោយសម្តែងការដែលទ្រង់ប្រាថ្នាលោកិយសម្បត្តិ និងលោកុត្តរសម្បត្តិ ដល់សត្វទាំង-ឡាយ ដោយបទថា **ភគវតា** នេះ ។ ប្រកាសបហានបញ្ញា ដោយសម្តែងការដែលទ្រង់សម្បូរដោយការលះ ដោយបទថា **អរហតា** នេះ ។ បណ្តាបញ្ញា និងករុណាទាំង ២ នោះ ប្រកាសការដែលទ្រង់សម្រេចភាពជាសព្វញ្ញូជា ដោយព្រះបញ្ញា ប្រកាសការដែលទ្រង់ចែកធម៌យ៉ាងល្អ ដោយព្រះករុណា ប្រកាសការដែលទ្រង់នឿយណាយក្នុងសង្សារទុក្ខ ដោយព្រះបញ្ញា ប្រកាសការដែលទ្រង់រម្ងាយនូវសង្សារទុក្ខ ដោយព្រះករុណា ។ ប្រកាសការដែលទ្រង់កំណត់ដឹងសង្សារទុក្ខ ដោយព្រះបញ្ញា ប្រកាសការដែលទ្រង់ផ្តើមដោះស្រាយនូវទុក្ខរបស់បុគ្គលដទៃ ដោយព្រះករុណា ប្រកាសការដែលទ្រង់មានព្រះហឫទ័យ ប្រាថ្នាចំពោះបរិនិព្វាន ដោយព្រះបញ្ញា ប្រកាសការដែលទ្រង់សម្រេចបរិនិព្វាននោះ ដោយព្រះករុណា ប្រកាសការដែលទ្រង់ឆ្លងនូវសង្សារ ដោយព្រះអង្គឯង ដោយព្រះបញ្ញា ប្រកាសការ

ដែលទ្រង់ញ៉ាំងបុគ្គលដទៃឲ្យឆ្លងផុតសង្សារ ដោយព្រះករុណា ប្រកាសនូវការសម្រេចភាពជាពុទ្ធៈ ដោយព្រះបញ្ញា ប្រកាសការសម្រេចនៃពុទ្ធកិច្ចដោយព្រះករុណា ។

មួយប្រការទៀត ប្រកាសភាវៈដែលទ្រង់ធ្លាក់នៅក្នុងសង្សារ ក្នុងភូមិនៃព្រះពោធិសត្វ ដោយព្រះករុណា ប្រកាសការដែលទ្រង់ត្រេកអរក្នុងសង្សារនោះ ដោយព្រះបញ្ញា ។ ម្យ៉ាងទៀត ប្រកាសការដែលទ្រង់ធ្វើបុគ្គលដទៃឲ្យបានទទួលអភិសេក ដោយទឹកអមតៈ ដោយព្រះករុណា ប្រកាសការដែលទ្រង់មិនញាប់ញ័រ តក់ស្លុតក្នុងបុគ្គលដទៃ ដោយព្រះបញ្ញា ។ កាលរក្សាអ្នកដទៃ ក៏ឈ្មោះថា រក្សាខ្លួនដោយព្រះករុណា ការរក្សាខ្លួន ក៏ឈ្មោះថា រក្សាបុគ្គលដទៃ ដោយព្រះបញ្ញា ។ ម្យ៉ាងទៀត ប្រកាសការដែលទ្រង់មិនធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ដោយព្រះករុណា ប្រកាសការដែលទ្រង់មិនធ្វើព្រះអង្គឯងឲ្យក្តៅក្រហាយ ដោយព្រះបញ្ញា ដោយការដែលទ្រង់មិនធ្វើព្រះអង្គឯងឲ្យក្តៅក្រហាយនោះ ទើបជាការសម្រេចភាវៈ ជាបុគ្គលទី ៤ គឺព្រះអរហន្តក្នុងបណ្តាបុគ្គលអ្នកបដិបត្តិ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯងជាដើម ។ ម្យ៉ាងទៀត ប្រកាសភាពដែលទ្រង់ជាទីពឹងរបស់លោក ដោយព្រះករុណា ប្រកាសភាពដែលទ្រង់ជាទីពឹងរបស់ព្រះអង្គឯង ដោយព្រះបញ្ញា ម្យ៉ាងទៀត ប្រកាសភាវៈដែលទ្រង់មិនមានការស្រុតចុះ ដោយអំណាចនៃការខ្ជិលច្រអូស ដោយព្រះករុណា ប្រកាសភាវៈដែលទ្រង់មិនមានការប៉ោងឡើង ដោយអំណាចនៃកិលេស ដោយព្រះបញ្ញា ។

ម្យ៉ាងទៀត ក្នុងបណ្តាសព្វសត្វ ការដែលទ្រង់អនុគ្រោះពួកជនរបស់ព្រះតថាគត មានព្រោះព្រះករុណា តែព្រះតថាគតក៏មិនមានព្រះហឫទ័យប្រាសចាកសេចក្តីករុណាក្នុងទីគ្រប់អន្លើឡើយ ព្រោះទ្រង់អនុលោមតាមព្រះបញ្ញា ទ្រង់មានព្រះហឫទ័យអនុលោមក្នុងធម៌ទាំងពួង ដោយព្រះបញ្ញា តែទ្រង់ក៏មិនបានប្រព្រឹត្តដើម្បីអនុគ្រោះសត្វគ្រប់ប្រភេទឡើយ ព្រោះទ្រង់អនុ-លោមតាមព្រះករុណា ។ ព្រះករុណារបស់ព្រះតថាគត វៀរចាកសេចក្តីស្នេហា និងសេចក្តីសោក យ៉ាងណា ព្រះបញ្ញារបស់ព្រះអង្គក៏ដូច្នោះ គឺផុតចាកអហង្ការ និងមមង្ការ សេចក្តីថា ព្រះករុណា និងបញ្ញារបស់ព្រះអង្គជម្រះគ្នានិងគ្នាឲ្យបរិសុទ្ធ ទើបគួរឃើញថា ជាព្រះគុណបរិសុទ្ធដ៏យ៉ាងក្រៃលែង ។ បណ្តាព្រះករុណា និងព្រះបញ្ញាទាំង ២ នោះ ព្រំដែននៃបញ្ញាជាពល ព្រំដែននៃករុណា ជាវេសារជ្ជៈ ។ បណ្តាពល និងវេសារជ្ជៈទាំង ២ នោះ ព្រោះទ្រង់ប្រកបដោយពល ព្រះតថាគតក៏មិនត្រូវអ្នកដទៃគ្របសង្កត់ ព្រោះទ្រង់ប្រកបដោយវេសារជ្ជៈ ទើបទ្រង់គ្របសង្កត់អ្នកដទៃបាន ។ ការសម្រេចនូវសត្ថុសម្បទារបស់ព្រះអង្គ មានព្រោះពលទាំងឡាយ ការសម្រេចនៃសាសនសម្បទា មានព្រោះវេសារជ្ជៈទាំងឡាយ ។ ម្យ៉ាងទៀត ការសម្រេចនៃពុទ្ធរតនៈ មានព្រោះពលទាំងឡាយ ការសម្រេចនៃធម្មរតនៈ មានព្រោះវេសារជ្ជៈទាំងឡាយ នេះជាកាលសម្តែងត្រឹមតែគន្លងនៃការពង្រីកសេចក្តីនៃបទទាំង ២ គឺ **ភគវតា** និង **អរហតា** ក្នុងទីនេះ ។

# ហេតុផលដែលពោលវុត្តំទុក ២ ដង

សួរថា ព្រោះហេតុអ្វី ក្នុងទីនេះ លោកពោលពាក្យថា **វុត្តំ ហេតំ ភគវតា** ហើយ ទើបពោលពាក្យថា **វុត្តំ** ទៀត ឆ្លើយថា លោកពោលពាក្យថា **វុត្តំ** ទៀត ដើម្បីសម្តែងសេចក្តីពិតប្រាកដ ដោយបដិសេធការបានស្តាប់តាមគ្នាមក ។ ដូចបុគ្គលពួកខ្លះ បានស្តាប់មកពីអ្នកដទៃ ហើយពោលបើរឿងនោះអ្នកដទៃមិនបានពោលឯង គឺអ្នកដទៃនោះមិនបាននិយាយខ្លួនឯង ព្រោះមានអ្នកដទៃពោលម្តងទៀត ហើយរឿងនោះ អ្នកដទៃនោះ ក៏មិនបានពោលឯងដោយពិត បានស្តាប់មកបន្ត យ៉ាងណា ក្នុងទីនេះ មិនមែនដូច្នោះឡើយ សេចក្តីពិត ព្រះមានព្រះភាគទ្រង់មិនបានស្តាប់មកអំពីអ្នកដទៃ ត្រាស់វត្ថុដែលទ្រង់សម្រេចដោយព្រះអង្គឯង ដោយសយម្ភូញ្ញាណ ព្រោះហេតុនោះ ដើម្បីសម្តែងសេចក្តីប្លែកគ្នានៃ **វុត្តំ** ២ ពាក្យនេះ ទើបលោកបានពោលពាក្យថា **វុត្តំ** ត្រួតដល់ទៅ ២ ដង ។ មានពាក្យអធិប្បាយថា សេចក្តីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សេចក្តីនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ មិនមែនអ្នកដទៃពោល មិនមែនទ្រង់ស្តាប់មកពីអ្នកដទៃឡើយ ។ ពិតហើយ ការពោលដដែល រមែងជួយឲ្យយល់អត្ថនៃគ្នានិងគ្នា ព្រោះហេតុនោះ ទើបមិនមានការខូចសេចក្តី ព្រោះការពោល ២ ដង ក្នុងទីដទៃ ក៏មានន័យយ៉ាងនេះដូចគ្នា ។

ម្យ៉ាងទៀត លោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្តែងថា មិនមានការរចនា ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សម្តែងធម៌បានសមគួរដល់អធ្យាស្រ័យរបស់បរិស័ទដែលមកប្រជុំគ្នា ព្រោះទ្រង់មានបដិភាណកើតឡើង

យ៉ាងវិសេសរាន់ ព្រោះទ្រង់ជាព្រះសម្មាសម្ពុទ្ធ អ្នកត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯង ។

ព្រះមានព្រះភាគអង្គនោះ មិនមានកិច្ចរចនាត្រៀមទុកមុន ប្រៀបដូចទានជាដើម ក៏រចនា គឺបង្ហាញទៅតាមហេតុការណ៍ ។ ដោយហេតុនោះ ទើបលោកសម្តែងពាក្យនេះថា រឿងនេះ ព្រះមានព្រះភាគត្រាស់ហើយ ឯរឿងនោះ ទ្រង់មិនបានប្រមូលមកដោយតក្ក គិតពិចារណាមុន ដោយការរចនាទុកមុនឡើយ ដោយពិតនោះ ទ្រង់ត្រាស់មកភ្លាមៗ សមគួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វនោះឯង ។

ម្យ៉ាងទៀត លោកពោលពាក្យថា **វុត្តំ** ក្នុងបទដំបូង ដើម្បីសម្តែងថា ព្រះតម្រាស់ មិនមានអ្នកណាបដិបត្តិបានឡើយ ។ សេចក្តីពិត ព្រះតម្រាស់ណា ដែលព្រះមានព្រះភាគត្រាស់ហើយ ជាការត្រាស់ហើយនោះឯង បុគ្គលណាម្នាក់មិនអាចជំទាស់នឹងព្រះតម្រាស់នោះបាន ព្រោះអក្ខរៈសម្បូរ អត្ថក៏សម្បូរ សមដូចព្រះមានព្រះភាគពោលក្នុងធម្មចក្កប្បវត្តនសូត្រដូច្នេះថា

> ធម្មចក្កនុ៎ះ មិនមានចក្រដទៃក្រៃលែងជាង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនឯណានីមួយក្តី ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ( ឥឡូវ ) ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

លោកពោលនូវន័យម្យ៉ាងទៀតថា ម្នាលភិក្ខុទាំងឡាយ សមណៈក្តី

ព្រាហ្មណ៍ក្ដី គប្បីមកពោលក្នុងទីនេះថា ទុក្ខណាដែលព្រះសមណគោតម បញ្ញត្ត ទុក្ខនេះ មិនមែនអរិយសច្ច ការដែលតថាគតវៀរទុក្ខអរិយសច្ចនេះ ហើយ បញ្ញត្តទុក្ខដទៃថា ជាអរិយសច្ច មិនមែនជាឋានៈឡើយ ដូច្នេះ ជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **វុត្តំ** ជា ២ ដង ដើម្បីសម្ដែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ មិនមានអ្នកណាបដិបត្តិ បាន ។ ម្យ៉ាងទៀត លោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្ដែងការៈ ដែលនឹងឲ្យសម្រេចប្រយោជន៍ដល់អ្នកស្ដាប់ទាំងឡាយ ។ សេចក្ដីពិត បុគ្គល មិនមែនសព្វញ្ញូ មិនដឹងអាសយជាដើមនៃបុគ្គលដទៃ ពោលពាក្យណាមិន ត្រូវកាលៈទេសៈ ពាក្យនោះ ជាពាក្យពិត ក៏មិនឈ្មោះថា ពោលឡើយ ព្រោះមិនអាចក្នុងការឲ្យសម្រេចប្រយោជន៍ដល់អ្នកស្ដាប់ទាំងឡាយ នឹងពោល ទៅថ្វីដល់ពាក្យមិនពិតនោះ ។ តែព្រះមានព្រះភាគ ទ្រង់ជ្រាបអាសយជាដើម របស់បុគ្គលដទៃ កាលៈ និង ទេសៈ និងការសម្រេចប្រយោជន៍យ៉ាងត្រឹម ត្រូវនោះឯង ព្រោះទ្រង់ជាព្រះសម្មាសម្ពុទ្ធ បានត្រាស់ព្រះតម្រាស់ណា ព្រះ តម្រាស់នោះ ឈ្មោះថា ត្រាស់ស្រេចហើយនោះឯង ព្រោះឲ្យសម្រេច ប្រយោជន៍តាមដែលបំណងដល់អ្នកស្ដាប់ទាំងឡាយ ដោយចំណែកមួយ ការ បញ្ចិតបញ្ចៀងនៃព្រះតម្រាស់នោះមិនមាន ព្រោះទ្រង់មិនបានត្រាស់ ។ ព្រោះ ហេតុនោះ លោកពោលពាក្យថា **វុត្តំ** ២ ដង ក៏ដើម្បីសម្ដែងការៈដែល សម្រេចប្រយោជន៍ដល់អ្នកស្ដាប់ទាំងឡាយ ។

មួយប្រការទៀត ពាក្យដែលមានអត្ថដែលបុគ្គលណាម្នាក់ យល់មិន

បាន និងពាក្យដែលបុគ្គលណាម្នាក់ បដិបត្តិដើម្បីភាពជាយ៉ាងនោះមិនបាន មិនឈ្មោះថា ស្តាប់សម្រេចហើយ យ៉ាងណា ពាក្យដែលបុគ្គលណាម្នាក់ ទទួលដោយល្អមិនបាន មិនឈ្មោះថា ពោលហើយដូច្នោះ ។ បរិស័ទ ៤ ទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគដោយល្អហើយ នាំគ្នាបដិបត្តិដើម្បី ភាពយ៉ាងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្តែងថា ព្រះតម្រាស់របស់ព្រះអង្គ សាវកទទួលល្អហើយ ។

ម្យ៉ាងទៀត លោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្តែងថា ព្រះតម្រាស់របស់ព្រះសម្ពុទ្ធ មិនជំទាស់នឹងព្រះអរិយៈទាំងឡាយ ។ ដូចព្រះមានព្រះភាគត្រាស់ចែកប្រភេទជាកុសល អកុសល សាវជ្ជៈ និងអនវជ្ជៈ បវត្តិ និវត្តិ សម្មុតិសច្ច និងបរមត្ថសច្ច មិនឃ្លៀងឃ្លាត យ៉ាងណា សូម្បីព្រះជិនៈទាំងឡាយ មានព្រះធម្មសេនាបតីជាដើម ក៏ដូច្នោះ កាលព្រះមានព្រះភាគគង់ព្រះជន្មនៅក្តី បរិនិព្វានហើយក្តី ក៏ពោលអនុលោមតាមទេសនារបស់ព្រះមានព្រះភាគ មិនមានវាទៈផ្សេងគ្នា ក្នុងទេសនានោះឡើយ ព្រោះហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគជាព្រះអរហន្តត្រាស់ហើយ ក្នុងកាលបន្ទាប់អំពីនោះ សូម្បីព្រះអរិយសង្ឃ ដែលជាព្រះអរហន្តក៏ពោលលោកពោលពាក្យថា **វុត្តំ** យ៉ាងនោះ ២ ដង ក៏ដើម្បីសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគមិនជំទាស់នឹងព្រះអរិយៈទាំងឡាយ ដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត លោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ មានន័យដូចព្រះសម្មាសម្ពុទ្ធអង្គមុនៗ ។

ទោះបីមានការផ្សេងគ្នាក្នុងរឿងជាតិ គោត្រ និងចំនួនព្រះជន្មជាដើម តែព្រះសម្ពុទ្ធទាំងឡាយ ក៏មិនមានការប្លែកគ្នាដោយព្រះធម្មទេសនា ដូចគ្នានឹងទ្រង់មិនមានការផ្សេងគ្នាដោយព្រះគុណ មានទសពលញ្ញាណជាដើម ។ ព្រះសម្មាសម្ពុទ្ធទាំងនោះត្រាស់មិនជំទាស់គ្នា នឹងត្រាស់ពាក្យមុន មិនជំទាស់នឹងពាក្យក្រោយ ដោយព្រះអង្គឯង ព្រោះហេតុនោះ ទើបសមនឹងពាក្យដែលលោកពោលដូច្នេះថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ និងព្រះមានព្រះភាគនៃយើងទាំងឡាយ ក្នុងបច្ចុប្បន្នត្រាស់ហើយ ដោយព្រះអង្គឯង កាលមុន យ៉ាងណា ព្រះមានព្រះភាគជាព្រះអរហន្តក៏ត្រាស់ពាក្យនេះ ដូច្នោះ ។ លោកពោលពាក្យថា **វុត្តំ** ២ ដង ដើម្បីសម្ដែងថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មានន័យដូចគ្នាជាមួយព្រះពុទ្ធអង្គមុនៗ ត្រាស់ និងមានន័យដូចគ្នា ដូចព្រះអង្គឯងត្រាស់ក្នុងព្រះសូត្រដទៃៗ ដូចពណ៌នា មកដូច្នោះ ។ ការមិនជំទាស់គ្នានៃទេសនារបស់ព្រះពុទ្ធទាំងឡាយ ក្នុងទីគ្រប់អន្លើ ជាការសម្ដែងហើយដោយពាក្យនោះ ។

ម្យ៉ាងទៀត ពាក្យថា **វុត្តំ** ពាក្យទី ២ គប្បីឃើញថាជាពាក្យពោលដល់សការៈ គឺភាពជាធំ ។ មានសេចក្ដីអធិប្បាយដូច្នេះថា ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយ បានដល់ ពាក្យដែលនឹងពោលតទៅនេះ មានពាក្យថា **ឯកធម្មំ ភិក្ខវេ** ព្រះមានព្រះភាគដ៏ជាអរហន្តត្រាស់ហើយ ។ មួយប្រការទៀត ពាក្យថា **វុត្តំ** នេះ សំដៅដល់ ពោលដល់បទទី ២ ទៀត ដោយពិតគប្បីឃើញថា មានអត្ថ គឺសំដៅដល់ការពោល ដោយហេតុនោះ ទើប

លោកសម្តែងយ៉ាងនេះថា ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយ ពាក្យនោះ មិនមែនត្រឹមតែត្រាស់ហើយទេ គឺមិនមែនត្រឹមតែត្រាស់ហើយ ដោយពិត ទ្រង់សំដៅដល់កុសលមូលរបស់វេនេយ្យសត្វទាំងឡាយ ។

មួយប្រការទៀត ពាក្យថា **វុត្តំ** ដែលជាបទទី ២ នេះ មានអត្ថថា ប្រព្រឹត្ត ។ បទនេះមានអធិប្បាយដូច្នេះថា ពាក្យនេះ ព្រះមានព្រះភាគជាព្រះអរហន្តបានត្រាស់ហើយ ពាក្យនោះ មិនមែនត្រឹមតែត្រាស់ហើយទេ ដែលពិត ពាក្យនោះ ទ្រង់បំពេញ គឺទ្រង់ប្រព្រឹត្តរហូតកើតប្រយោជន៍ ដោយហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគ មានប្រក្រតីត្រាស់យ៉ាងណា ក៏មានប្រក្រតីធ្វើយ៉ាងនោះ ។ មួយប្រការទៀត មានអត្ថថា ពាក្យនោះ ជាពាក្យដែលព្រះមានព្រះភាគ គឺបុគ្គលគួរហៅថា ព្រះអរហន្តត្រាស់ហើយ ។ មួយប្រការទៀត លោកពោលពាក្យថា **វុត្តំ** ដែលជាពាក្យទី ១ សំដៅដល់ការលើកឡើងសម្តែងដោយសង្ខេប ។ ពោលពាក្យថា **វុត្តំ** ដដែលទៀត សំដៅដល់ការសម្តែងពង្រីកពាក្យដោយពិស្តារ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ទាំងដោយសង្ខេប និងដោយពិស្តារ ។

មួយប្រការទៀត លោកពោលពាក្យថា **វុត្តំ ហេតំ ភគវតា** ហើយក៏ពោលពាក្យថា **វុត្តំ** ទៀត ដើម្បីសម្តែងថា មិនមានពាក្យដែលព្រះមានព្រះភាគត្រាស់មិនល្អ ។ សេចក្តីពិត ព្រះមានព្រះភាគទ្រង់លះទោសគ្រប់យ៉ាង ព្រមទាំងវាសនាហើយ មានគន្លងវាចាមិនខុសភ្លាំងភ្លាត់ ទើបមិនមានពាក្យដែលមិនល្អ ក្នុងកាលណាឡើយ ព្រោះទ្រង់មានវចីកម្ម អនុលោមតាម

ញាណសព្វកាល ។ ដូចបុគ្គលខ្លះក្នុងលោក និយាយពាក្យណាមួយចេញទៅព្រោះធ្លាំធ្លង ឬព្រោះភាពសុខស្រួល ដោយការភ្លេចសតិ បន្ទាប់មក ដឹងខ្លួនក៏ធ្វើពាក្យដែលពោលទៅហើយ ឲ្យជាការមិនបានពោល អបសួបពាក្យពោលខ្លះ មិនអបសួបខ្លះ យ៉ាងណា ព្រះមានព្រះភាគមិនមែនដូច្នោះឡើយ ។

ព្រះមានព្រះភាគ ទ្រង់មានព្រះហឫទ័យមាំទាំអស់កាលជានិច្ច មានការមិនភ្លេចសតិជាធម្មតា និងមានការមិនឃ្លៀងឃ្លាតជាធម្មតា កាលទ្រង់ប្រកាសអរិយសច្ច ៤ ដែលជាសវនានុត្តរិយៈ មានសារៈដែលគួរស្តាប់ ឲ្យដូចគ្នានឹងបាចសាចភ្លៀងអមតៈដល់វេនេយ្យសត្វទាំងឡាយ ដែលកំពុងស្តាប់អត្ថ ដែលបង្អោននាំចូលទៅដោយបដិភាណប្បដិសម្ភិទា ដែលព្រះសព្វញ្ញុតញ្ញាណផ្គងហើយ ដែលជាសោតាយតនៈ និងរសាយតនៈ ព្រោះករណវិញ្ញូដ៏វិសេសដែលផូរផង់ និងបរិសុទ្ធ ដែលមិនទូទៅដល់បុគ្គលដទៃ ដែលកើតមកអំពីបុញ្ញសម្ភារ ដែលសន្សំហើយ អស់កាលប្រមាណមិនបាន បានត្រាស់ព្រះតម្រាស់ សមគួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វ ដោយភាសាដែលសមគួរដល់សភាវៈ ដោយព្រះសូរសៀងដ៏ខ្ទរខ្ទារ ដូចសំឡេងស្រែករបស់សត្វករវិក ។ ក្នុងព្រះតម្រាស់នោះ មិនមានខុសក្លាំងក្លាត់សូម្បីប៉ុនចុងរោមទ្រាយ ហើយឱកាសដែលនឹងត្រាស់ពាក្យមិនល្អ នឹងមានមកអំពីណា ព្រោះហេតុនោះ ដើម្បីសម្តែងថា ពាក្យណាដែលព្រះមានព្រះភាគត្រាស់ហើយពាក្យនោះ ក៏ជាការត្រាស់ហើយនោះឯង មិនមានព្រះតម្រាស់ដែលមិនបានត្រាស់ ឬត្រាស់មិនល្អក្នុងកាលណាឡើយ ទើបលោកពោលថា ពាក្យនេះ

ព្រះមានព្រះភាគត្រាស់ហើយ ដូច្នេះហើយ ពោលទៀតថា ព្រះអរហន្ត ពោលហើយ ព្រោះហេតុនោះ ក្នុងទីនេះ ទើបមិនមានទោសនៃពាក្យដែលពោលដដែលទៀត ។ គប្បីជ្រាបថា សព្ទដែលពោលត្រួតម្ដងទៀត មានប្រយោជន៍ក្នុងទីនេះ ដូចពណ៌នាមកដូច្នេះ ។

## អធិប្បាយ ឥតិ សព្ទ

**ឥតិ** សព្ទនេះ ក្នុងបទថា **ឥតិ មេ សុតំ** នេះ ផ្សេងគ្នាដោយអត្ថជាអនេក គឺដោយអត្ថថា ហេតុ ដោយអត្ថថា **បរិសមាបណ្ណ** ដោយអត្ថថា ជាខាងដើម ដោយអត្ថថា **បទត្ថបរិយាយ** គឺការបរិយាយនៃបទ ដោយអត្ថថា បការៈ ដោយអត្ថថា និទស្សនៈ ដោយអត្ថថា និធារណៈ ។ ពិតហើយ **ឥតិ** សព្ទនោះ ប្រាកដក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **រុប្បតីតិ ខោ ភិក្ខវេ តស្មា រូបន្តិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលហៅថា រូប ព្រោះបែកធ្លាយ ។ ប្រាកដក្នុងអត្ថ **បរិសមាបន្ន** ដូចក្នុងប្រយោគជាដើមថា **តស្មាតិហ មេ ភិក្ខវេ ធម្មទាយាទា ភវថ មា អាមិសទាយាទា អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ នោ អាមិសទាយាទ** ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងកាលឥឡូវនេះ ចូរអ្នកទាំងឡាយយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ តថាគតមានសេចក្ដីអនុគ្រោះចំពោះអ្នកទាំងឡាយថា ធ្វើម្ដេចហ្ន៎ ពួកសាវ័ករបស់តថាគត គួរយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ ។ ប្រាកដក្នុងអត្ថថា ជាខាងដើម ដូចក្នុងប្រយោគជាដើមថា

**ឥតិ វា ឥតិ ឯវរូបា វិសូកទស្សនា បដិវិរតោ** ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្ដាប់ និងការមើលនូវ ដែលជាសត្រូវដល់កុសលធម៌មានសភាពដូច្នេះឯង ។ ប្រាកដក្នុងអត្ថថា **បនដ្ឋបរិយាយ** ដូចក្នុងប្រយោគជាដើមថា **មាគន្ទិយោតិ តស្ស ព្រាហ្មណស្ស នាមំ សង្ខា សមញ្ញា វោហារោតិ ឥតិ មាគន្ទិយោ** ពាក្យថា មាគន្ទិយៈជានាម ជាកិរិយារាប់ ជាឈ្មោះ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ មានពាក្យថា មាគន្ទិយ-ព្រាហ្មណ៍ពោល ដូច្នេះ ប្រាកដក្នុងអត្ថថា បការៈ ដូចក្នុងប្រយោគជាដើមថា **ឥតិ ខោ ភិក្ខវេ សប្បដិភយោ ពាលោ អប្បដិភយោ បណ្ឌិតោ សឧបទ្ទវោ ពាលោ អនុបទ្ទវោ បណ្ឌិតោ សឧបសគ្គោ ពាលោ អនុបសគ្គោ បណ្ឌិតោ** ម្នាលភិក្ខុទាំងឡាយ ជនពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ ជនពាលប្រកបដោយឧបទ្រព បណ្ឌិតមិនមានឧបទ្រពទេ ជនពាលប្រកបដោយឧបសគ្គ បណ្ឌិតមិនមានឧបសគ្គទេ ។ ប្រាកដក្នុងអត្ថថា និទស្សនៈ ដូចក្នុងប្រយោគជាដើមថា **សព្វមត្ថីតិ ខោ កច្ចាន អយមេកោ អន្តោ សព្វំ នត្ថីតិ អយំ ទុតិយោ អន្តោ** ម្នាលកច្ចានៈ ទីបំផុតទី ១ នេះថា វត្ថុទាំងពួងមាន ទីបំផុតទី ២ នេះថា វត្ថុទាំងពួង

---

១- ក្នុងអដ្ឋកថាបាលីជា មាគន្ទិយោតិ វា តស្ស ព្រាហ្មណស្ស សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យ និរុត្តិ ព្យញ្ជនមភិនាបោ តែក្នុងបិដកខ្មែរ លេខ ៦៥ ទំព័រ ១០ បាលីមានត្រឹមតែ វោហារោតិ ប៉ុណ្ណោះ តែក្នុងបិដកខ្មែរលេខ ៦៤ ទំព័រ ២៣៤ បាលីមានដូចគ្នានឹងអដ្ឋកថា តែមិនមានពាក្យថា មាគន្ទិយោតិ មានពាក្យថា បុរិសោតិ ជំនួសទៅវិញ ។

មិនមាន ។ ប្រាកដក្នុងអត្ថថា អវធារណៈ អធិប្បាយថា ក្នុងការសម្រេចចិត្ត ដូចក្នុងប្រយោគជាដើមថា **អត្ថិ ឥទប្បច្ចយា ជរាមរណន្តិ ឥតិ បុដ្ឋេន សតា អានន្ទ អត្ថីតិស្ស វចនីយំ កឹ បច្ចយា ជរាមរណន្តិ ឥតិ ចេ វទេយ្យ ជាតិប្បច្ចយា ជរាមរណន្តិ ឥច្ចស្ស វចនីយំ** ម្នាលអានន្ទ កាលបើមានគេសួរថា ជរា និងមរណៈកើតមាន ព្រោះធម៌នេះ មានដែរឬ គប្បីឆ្លើយតបថា មាន ។ បើគេសួរទៀតថា ជរា និងមរណៈកើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា ជរា និងមរណៈកើតមានព្រោះជាតិជាបច្ច័យ ។ ក្នុងទីនេះ **ឥតិ** សព្ទនោះ គប្បីឃើញថា ប្រាកដក្នុងអត្ថថា បការៈ គឺប្រការ ១ និទស្សនៈ ១ និងអវធារណៈ ១ ។ បណ្ដាអត្ថទាំង ៣ យ៉ាងនោះ ដោយ **ឥតិ** សព្ទ ដែលមានអត្ថថា បការៈ ព្រះអានន្ទត្ថេរ ក៏សម្ដែងអត្ថនេះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ មានអត្ថល្អិតល្អន់ ដោយន័យផ្សេងៗ មានសមុដ្ឋាន មកអំពីអជ្ឈាស្រ័យជាអនេក សម្បូរដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ជ្រាលជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មកប៉ះខ្ទប់ត្រចៀក នៃសោតប្បសាទរបស់សព្វសត្វ តាមសមគួរដល់ភាសារៀងៗខ្លួនថា អ្នកណានឹងអាចយល់បានគ្រប់ប្រការ ខ្ញុំសូមប្បីនៅជាបុគ្គលបំណងនឹងស្ដាប់ ឲ្យកើតឡើងដោយកម្លាំងទាំងអស់ ក៏ស្ដាប់មកហើយយ៉ាងនេះ គឺខ្ញុំស្ដាប់មកដោយប្រការមួយ ។

## អធិប្បាយ បទថា ឆានានយនិបុណំជាដើម

ក្នុងបទថា **ឆានានយនិបុណំ** ជាដើមនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

*ន័យផ្សេងគ្នា ដោយចែកតាមអារម្មណ៍ជាដើម ពោល គឺឯកត្តន័យ នានត្ត-ន័យ អព្យាបារន័យ និងធម្មតាន័យ នឹងពោល គឺនន្ទិយាវដ្តន័យ តិបុក្ខលន័យ សីហវិក្កិឡិតន័យ ទិសាលោចនន័យ និងអង្កុសន័យ ឈ្មោះថា នានានយៈ គឺន័យផ្សេងៗ មួយវិញទៀត ន័យទាំងឡាយ បានដល់ គតិនៃបាលី ហើយ គតិនៃបាលីទាំងនោះ ក៏មានប្រការផ្សេងៗ គ្នា ដោយអំណាចបញ្ញត្តិន័យ និង អនុប្បញ្ញត្តិន័យជាដើម ដោយអំណាចសង្កិលេសភាគិយាទិន័យ លោកិយា-ទិន័យ និងតទុកយវោមិស្សតាន័យជាដើម ដោយអំណាចកុសលន័យជាដើម ដោយអំណាចខន្ធន័យជាដើម ដោយអំណាចសង្គហន័យជាដើម ដោយ អំណាចសមយវិមុត្តិន័យជាដើម ដោយអំណាចឋបនន័យជាដើម ដោយ អំណាចកុសលន័យជាដើម និងដោយអំណាចតិកបដ្ឋានន័យជាដើម ព្រោះ ហេតុនោះ ទើបឈ្មោះថា នានាន័យ មានន័យផ្សេងគ្នា ។ អត្ថដែលឈ្មោះថា ល្អិតដោយន័យផ្សេងៗ ព្រោះអត្ថថា ល្អិត គឺល្អិតល្អន់ បានដល់ សុខុមដោយ ន័យទាំងនោះ ។ អាសយនោះឯង ឈ្មោះថា* **អជ្ឈាសយ** *អជ្ឈាសយនោះ ក៏មានច្រើនយ៉ាង ដោយចែកជាសស្សតទិដ្ឋិជាដើម និងដោយចែកជាបុគ្គល មានធូលី គឺកិលេសក្នុងចក្ខុតិចជាដើម ទើបឈ្មោះថា* **អនេកជ្ឈាសយ** *គឺ មានអធ្យាស្រ័យមិនមែនតែមួយ ។ មួយប្រការទៀត អជ្ឈាសយជាអនេក មានអធ្យាស្រ័យរបស់ខ្លួនជាដើម ឈ្មោះថា* **អនេកជ្ឈាសយ** ។ *អនេកជ្ឈា-សយនោះជាសមុដ្ឋាន គឺជាដែនកើត បានដល់ ជាហេតុនៃពុទ្ធវចនៈនោះ ព្រោះហេតុនោះ ទើបពុទ្ធវចនៈនោះ ឈ្មោះថា មានអនេកជ្ឈាសយជាសមុដ្ឋាន*

ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះមានការដល់ព្រមដោយអត្ថ មានកុសល ជាដើម ទើបប្រកបដោយអត្ថ ៦ បទ គឺសង្កាសនៈ ១ បកាសនៈ ១ វិវរណៈ ១ វិភជនៈ ១ ឧត្តានីករណៈ ១ បញ្ញត្ត ១ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះកាលមានការដល់ព្រមដោយព្យញ្ជនៈ ដែលប្រកាសអត្ថនោះឲ្យជាក់ច្បាស់ ទើបប្រកបដោយបទនៃព្យញ្ជនៈ ៦ គឺអក្ខរៈ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេស ។ ឈ្មោះថា មានបាដិហារ្យផ្សេងគ្នា ព្រោះអត្ថថា មានបាដិហារ្យផ្សេងៗ គឺច្រើនយ៉ាង ដោយចែកជាឥទ្ធិប្បាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ និងដោយបាដិហារ្យទាំង ៣ នោះ បាដិហារ្យតែមួយ ក៏ផ្សេងគ្នាទៅតាមអារម្មណ៍ជាដើម ។

## អធិប្បាយបទថា ចាដិហារិយ

ក្នុងបទថា **វិវិធចាដិហារិយំ** នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដែលឈ្មោះថា ជាបាដិហារ្យ ព្រោះនាំទៅនូវកិលេសដែលជាសត្រូវ គឺព្រោះកម្ចាត់កិលេស មានរាគៈជាដើម កាលអត្ថមានដូចពោលមកនេះ ព្រះមានព្រះភាគក៏មិនមានកិលេសទាំងឡាយ មានរាគៈជាដើមជាបាដិហារ្យដែលនឹងត្រូវនាំទៅកម្ចាត់ សូម្បីសម្រាប់បុថុជ្ជនទាំងឡាយ កាលចិត្តប្រាសចាកឧបក្កិលេសប្រកបដោយគុណ ៨ ប្រការ កម្ចាត់កិលេសដែលជាបដិបក្ខបានហើយ ឥទ្ធិវិធី គឺការសម្តែងឫទ្ធិបានក៏ប្រព្រឹត្តទៅ ព្រោះហេតុនោះ តាមវោហារដែលប្រព្រឹត្តទៅក្នុងទីនោះ បុគ្គលណាម្នាក់ក៏មិនអាចពោលថា ជាបាដិហារ្យក្នុងទីនេះ តែព្រោះហេតុដែលព្រះមានព្រះភាគ ជាបុគ្គលមានមហាករុណាទិគុណ

ទ្រង់មានកិលេសដែលមាននៅក្នុងវេនេយ្យសត្វ ជាបដិបក្ខ ដូច្នោះ ទើបឈ្មោះថា ជាបាដិហារ្យ ព្រោះនាំកម្ចាត់កិលេសទាំងនោះទៅ ។

មួយប្រការទៀត ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ មានពួកតិរ្ថិយជាបដិបក្ខ ឈ្មោះថា ជាបាដិហារ្យ ក៏ព្រោះនាំ គឺកម្ចាត់តិរ្ថិយទាំងនោះ អធិប្បាយថា តិរ្ថិយទាំងនោះ ត្រូវព្រះមានព្រះភាគនាំ គឺកម្ចាត់ដោយឥទ្ធិប្បាដិហារ្យ អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ ព្រោះមិនអាចប្រកាសទិដ្ឋិ ដោយកម្ចាត់ទិដ្ឋិបាន ។ មួយប្រការទៀត បទថា **បដិ** សេចក្តីថា ខាងក្រោយ ព្រោះហេតុនោះ ដែលឈ្មោះថា ជាបាដិហារ្យ ព្រោះអត្ថថា ជាវត្ថុដែលលោកធ្វើកិច្ចស្រេចហើយ គប្បីនាំទៅ គឺគប្បីឲ្យប្រព្រឹត្តទៅខាងក្រោយ ក្នុងកាលចិត្តតាំងមាំ ប្រាសចាកឧបក្កិលេសហើយ ។ មួយប្រការទៀត កាលឧបក្កិលេសទាំងឡាយរបស់ខ្លួន ត្រូវមគ្គដែលប្រកបដោយឈានទី ៤ នាំទៅហើយ ការនាំទៅក្នុងកាលជាក្រោយ ឈ្មោះថា **បាដិហារ្យ**។

បាដិហារ្យទាំងឡាយមាន ក៏ព្រោះហេតុដែលឥទ្ធិវិធិ ទេសនាវិធិ និងអនុសាសនីវិធិ ដែលលោកអ្នកប្រាសចាកឧបក្កិលេស និងធ្វើកិច្ចស្រេចហើយ គប្បីឲ្យប្រព្រឹត្តទៅទៀត ដើម្បីជាប្រយោជន៍ដល់សត្វ និងព្រោះកាលនាំឧបក្កិលេសទាំងឡាយរបស់ខ្លួនចេញបានហើយ ទើបនាំឧបក្កិលេសក្នុងសន្តានរបស់បុគ្គលដទៃចេញ ។ បាដិហារ្យនោះឯង ឈ្មោះថា បាដិហារ្យ ។ មួយប្រការទៀត គុណជាតតែមួយ ដែលមានព្រោះបាដិហារ្យដែលកើតអំពីឥទ្ធិវិធិ អាទេសនាវិធិ និងអនុសាសនីវិធិ លោកហៅថា បាដិហារ្យ ។ មួយ៉ាងទៀត

ឈានទី ៤ និងមគ្គ ក៏ឈ្មោះថា បាដិហារ្យ ព្រោះនាំទៅនូវកិលេសដែលជាសត្រូវ ។ គុណជាតដែលឈ្មោះថា បាដិហារ្យ ព្រោះកើតក្នុងឈានទី ៤ និងមគ្គនោះ ព្រោះជានិមិត្តក្នុងឈានទី ៤ និងមគ្គនោះខ្លះ ព្រោះមកអំពីឈានទី ៤ និងមគ្គនោះខ្លះ ។ ព្រោះហេតុតន្តិតន្តិទេសនា និងអត្ថតន្តិទេសនា ពោល គឺការសម្រេចបាដិហារ្យនោះ ឬពោល គឺការចាក់ធ្លុះនូវហេតុផល និងបញ្ញត្តហេតុផលទាំង ២ នោះ ដែលជ្រាលជ្រៅដោយហេតុផល ទេសនា និងបដិវេធ ដែលបុគ្គលមិនបានសន្សំកុសល ឈមចុះបានលំបាក ប្រៀបដូចមហាសមុទ្រ ដែលសត្វទាំងឡាយ មានទន្សាយជាដើម ប៉ាន់ប្រមាណបានលំបាកដូច្នោះ និងមិនមានទីពឹង ដល់បុគ្គលទាំងនោះ ដូច្នោះ ទើបឈ្មោះថា ជ្រាលជ្រៅដោយហេតុផល ទេសនា និងបដិវេធ ព្រោះប្រកបដោយគម្ភីរភាពទាំង ៤ នោះ ។ សំឡេងសម្តែងធម៌របស់ព្រះមានព្រះភាគតែម្យ៉ាងប៉ុណ្ណោះ ដែលប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា ជាសំឡេងដែលសត្វទាំងឡាយដែលមានភាសាផ្សេងៗ គ្នា ស្តាប់បានព្រមគ្នាតាមភាសារៀងខ្លួន តែងប្រព្រឹត្តទៅដើម្បីឲ្យយល់សេចក្តីបាន ។ ព្រោះថា ពុទ្ធានុភាពជាអចិន្តេយ្យ ។ អ្នកសិក្សាគប្បីយល់ថា សំឡេងសម្តែងធម៌របស់ព្រះមានព្រះភាគ មកកាន់គន្លងនៃសោតប្បសាទរបស់សព្វសត្វ តាមគួរដល់ភាសារៀងៗ ខ្លួន ។

ដោយ **ឥតិ** សព្ទ ដែលមានអត្ថថា និទស្សនៈ ព្រះអានន្ទត្ថេរ កាលនឹងបង្ហាញខ្លួនថា ខ្ញុំមិនមែនសយម្ភូ សូត្រនេះ ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ទើបពោលថា ខ្ញុំបានស្តាប់មកយ៉ាងនេះ គឺខ្ញុំឯងក៏បានស្តាប់មក

យ៉ាងនេះ ។ ព្រះអានន្ទត្ថេរសម្តែងពង្រីកសូត្រទាំងអស់ ដែលគប្បីពោលក្នុងឥឡូវនេះ ដោយ **ឥតិ** សព្ទ ដែលមានអត្ថថា និទស្សនៈនេះ ។

**ឥតិ** សព្ទ ដែលមានអត្ថថា អវធារណៈ ព្រះអានន្ទត្ថេរ កាលនឹងសម្តែងកម្លាំងនៃការចងចាំរបស់ខ្លួន ដែលសមគួរដល់ការៈ ដែលព្រះមានព្រះភាគ ទ្រង់សរសើរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន អ្នកមានស្មារតី អ្នកមានគតិ អ្នកមានប្រាជ្ញា អ្នកជាឧបដ្ឋាកដែលជាសាវ័ករបស់តថាគត ស្រេចនឹងអានន្ទ ប្រសើរជាងគេ ។ អានន្ទនេះជាកំពូល និងសមគួរដល់ការៈដែលព្រះធម្មសេនាបតីសរសើរយ៉ាងនេះ ក្នុងអង្គុត្តរនិកាយបញ្ចកនិបាតថា យើងនឹងចាំទុកនូវព្រះអានន្ទដ៏មានអាយុថា ជាអ្នកប្រកបដោយធម៌ ៥ យ៉ាងនេះ គឺអានន្ទដ៏មានអាយុ ជាអ្នកឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងដើមទាំងចុង ១ ។ ទើបញុំាងភាពជាបុគ្គលប្រាថ្នានឹងស្តាប់ឲ្យកើតដល់សត្វទាំងឡាយថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ឯសូត្រនោះ មិនលើស មិនខ្វះ ទាំងអត្ថ ទាំងព្យញ្ជនៈ គប្បីឃើញថា យ៉ាងនេះឯង មិនគប្បីឃើញដទៃឡើយ ។ បទថា **អញ្ញថា** សេចក្តីថា ដទៃចាកអាការដែលបានស្តាប់មកចំពោះព្រះភក្ត្ររបស់ព្រះសាស្តា តែមិនមែនដទៃចាកអាការដែលព្រះមានព្រះភាគទ្រង់សម្តែង ។ ទេសនារបស់ព្រះមានព្រះភាគ មានអានុភាពជាអាចិន្តេយ្យ ទេសនានោះ បុគ្គលណាម្នាក់ មិនអាចយល់បានគ្រប់យ៉ាង សេចក្តីនេះ លោកពោលដូចពណ៌នាមកនេះឯង ។ ឯការដែលមិន

ខុសក្លាំងក្លាត់ចាកអាការដែលបានស្តាប់មក ជាកម្លាំងនៃការចងចាំ ។ ក្នុងទីនេះ មិនមានការប្រើអត្ថដទៃ ព្រោះអត្ថទាំង ២ មានវិស័យតែមួយ ព្រោះបើពោលដោយប្រការក្រៅអំពីនេះ ព្រះថេរៈក៏នឹងត្រូវជាអ្នកអាច ឬមិនអាចក្នុងការទទួលទេសនារបស់ព្រះមានព្រះភាគ ដោយប្រការទាំងពួង ។

## មេ សទ្ទ ប្រើក្នុងអត្ថ ៣ យ៉ាង

**មេ** សព្ទ ប្រាកដក្នុងអត្ថ ៣ យ៉ាង ។ ពិតហើយ **មេ** សព្ទនោះ មានអត្ថថា **មយា** ( ដែលខ្ញុំ ) ដូចក្នុងប្រយោគជាដើមថា **គាថាភិគីតម្មេ-អភោជនីយំ** ភោជនដែលតថាគតពោលហើយដោយគាថា ( ច្រៀង ) ជាវត្ថុមិនគួរដល់ការបរិភោគទេ ។ មានអត្ថថា **មយ្ហំ** ( ដល់ខ្ញុំ ) ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអារាធនា សូមព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ។ មានអត្ថថា **មម** គឺរបស់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌កចុះ ។ តែក្នុងទីនេះ ប្រកបក្នុងអត្ថ ២ យ៉ាង គឺដែលខ្ញុំបានស្តាប់មកហើយ និងការស្តាប់មករបស់ខ្ញុំ ។ ក្នុងទីនេះ **មេ** សព្ទទាំង ៣ យ៉ាង ទោះបីប្រាកដក្នុងអត្ថតែមួយ ព្រោះក្នុងកាលគួរនឹងពោលយ៉ាងនេះថា បុគ្គលណា មិនមែនបុគ្គលដទៃ បុគ្គលនោះ គឺខ្លួនខ្ញុំ ក៏ត្រឡប់ប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ពោល គឺកើតក្នុងខ្លួនសោត តែ **មេ** សព្ទនោះក៏នៅមានអត្ថដែលផ្សេងគ្នានេះឯង ពោល គឺផ្សេងគ្នាដោយជាតតិយាវិភត្តិ

និងចតុត្ថវិភត្តិជាដើម ព្រោះហេតុនោះ ទើបលោកពោលថា **មេ** សព្ទ ប្រាកដក្នុងអត្ថ ៣ យ៉ាង ។

## អធិប្បាយ សុត សព្ទ

**សុត** សព្ទ ក្នុងបទថា **សុតំ** នេះ ដែលមានឧបសគ្គក៏មាន មិនមានឧបសគ្គក៏មាន ផ្សេងដោយអត្ថជាអនេក គឺ **គមន** ការទៅ ១ **វិស្សុត** ស្តាប់ ១ **កិលិន្ន** សើម ១ **ឧបចិត** សន្សំ ១ **អនុយុត្ត** តាមប្រកប ឬបំពេញ ១ **សុតវិញ្ញេយ្យ** ដឹងបានតាមសោតៈ ១ **សោតទ្វារានុសារវិញ្ញាត** ដឹងបានតាមក្រសែនៃសោតទ្វារ ១ អធិប្បាយថា ឧបសគ្គ ជាតួពង្រីកកិរិយា ឲ្យមានអត្ថវិសេសចេញទៅក៏ពិត តែទោះជាដូច្នោះ កាលឧបសគ្គនោះមាន ព្រោះពង្រីកការឲ្យ **សុត** សព្ទនោះឯង ក៏នៅតែពោលដល់អត្ថនោះៗ ព្រោះហេតុនោះ ក្នុងការលើកអត្ថនៃ **សុត** សព្ទ ដែលមិនមានឧបសគ្គឡើងមកជាគំរូ ទើបលោកលើកយក **សុត** សព្ទ ដែលមានឧបសគ្គឡើងមកជាគំរូផង ។

ក្នុង **សុត** សព្ទនោះ មានអត្ថដូចតទៅនេះថា មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា **សេនាយ បសុតោ** ទៅហើយដោយសេនា សេចក្តីថា ទ័ពដើរទៅ ។ មានអត្ថថា ស្តាប់ ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** បុគ្គលមានធម៌ស្តាប់ហើយ បានឃើញច្បាស់ សេចក្តីថា ជាអ្នកមានធម៌ប្រាកដហើយ ។ មានអត្ថថា សើម ឬជោកជាំ ដូចក្នុងប្រយោគជាដើមថា **អវស្សុតា អវស្សុតស្ស** ( សុន្ទរីនន្ទាជាម្ចាស់ ) មានតម្រេកមិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេក ...ដូច្នេះ សេចក្តីថា ភិក្ខុនី

មានចិត្តទទឹកដោយតម្រេក ត្រេកអរដោយបុរស ដែលមានចិត្តតម្រេក ស្ទាបអង្អែលកាយ ។ មានអត្ថថា សន្សំ ដូចក្នុងប្រយោគជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** បុណ្យ ឈ្មោះថា បានសន្សំមិនមែនតិចឡើយ សេចក្តីថា ចូលទៅសន្សំហើយ ។ មានអត្ថថា តាមប្រកប ឬបំពេញ ដូចក្នុងប្រយោគជាដើមថា **យេ ឈានប្បសុតា ធីរា** អ្នកប្រាជ្ញពួកណា ជាអ្នកប្រកបរឿយៗ ក្នុងឈាន សេចក្តីថា ខ្វល់ខ្វាយរឿយៗ ក្នុងឈាន ។ មានអត្ថថា ដឹងបានតាមសោតៈ ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋំ សុតំ មុតំ** ឃើញហើយ ស្តាប់ហើយ ប៉ះពាល់ហើយ សេចក្តីថា សទ្ទារម្មណ៍ដែលដឹងដោយសោតៈ ។ មានអត្ថថា ដឹងបានតាមក្រសែនៃសោតទ្វារ ដូចក្នុងប្រយោគជាដើមថា **សុតធរោ សុតសន្និចយោ** ( កិក្កក្នុងសាសនានេះ ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ សេចក្តីថា ទ្រទ្រង់នូវធម៌ដែលដឹងតាមសោតទ្វារ ។

តែក្នុងទីនេះ **សុត** សព្ទនោះ មានអត្ថថា ទ្រទ្រង់ទុកតាមគន្លងនៃសោតទ្វារ ឬការចាំទុកតាមគន្លងនៃសោតទ្វារ កាល **មេ** សព្ទ មានអត្ថស្មើគ្នានឹង **មយា** ទើបមានអត្ថថា ដែលខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺដែលខ្ញុំទ្រទ្រង់ហើយ តាមគន្លងនៃសោតទ្វារ កាល **មេ** សព្ទ មានអត្ថស្មើគ្នានឹង **មម** ទើបមានអត្ថថា ការស្តាប់របស់ខ្ញុំ គឺការទ្រទ្រង់តាមគន្លងនៃសោតទ្វារយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំង ៣ នេះ យ៉ាងនេះថា ព្រោះហេតុដែល

**ឥតិ** សព្ទនោះ គប្បីជាសព្ទដែលអមអត្ថរបស់ **សុត** សព្ទ និងគប្បីជាសព្ទដែលពង្រីកសេចក្តីនៃកិរិយា គឺការស្តាប់ ដូច្នោះ ទើបបទថា **ឥតិ** សម្តែងដល់កិច្ចរបស់វិញ្ញាណជាដើម ។ បទថា **មេ** សម្តែងដល់បុគ្គលដែលដល់ព្រមដោយវិញ្ញាណដូចពោលហើយ ។ គ្រប់ពាក្យ ទើបប្រកបដោយអត្ថរបស់ **ឯវំ** សព្ទនោះឯង ព្រោះមានអវធារណៈជាផល ដោយហេតុនោះ បទថា **សុតំ** ទើបជាពាក្យសម្តែងដល់ការទទួលយកមកមិនខ្វះខាត និងមិនក្លាំងក្លាត់ ព្រោះបដិសេធភាវៈ គឺការមិនបានស្តាប់ ។ ប្រៀបដូចវត្ថុដែលបានស្តាប់មកហើយ រមែងគួរជាវត្ថុដែលគប្បីពោលថា បានស្តាប់មកហើយយ៉ាងណា ការស្តាប់មកដោយល្អនោះ ទើបជាការទទួលយកមកមិនខ្វះខាត និងជាការទទួលយកមកមិនក្លាំងក្លាត់ ដូច្នេះ ។ មួយប្រការទៀត សព្ទរមែងប្រាប់អត្ថ ដោយមិនឲ្យវង្វេងក្នុងអត្ថនៃសព្ទដទៃ ។ ព្រោះហេតុដែលបទថា **សុតំ** នេះ មានអត្ថដូច្នេះថា មិនបានស្តាប់មកក៏មិនមែន ដូច្នោះ ទើបបទថា **សុតំ** ឈ្មោះថា សម្តែងការទទួលយកមកមិនខ្វះខាត និងមិនវិបរិត ព្រោះបដិសេធភាវៈ គឺការមិនបានស្តាប់ មានពាក្យអធិប្បាយដូច្នេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺខ្ញុំមិនបានឃើញឯង មិនបានធ្វើឲ្យជាក់ច្បាស់ដោយសយម្ភូញាណ ឬមិនមែនបានមកដោយប្រការដទៃ ហើយការស្តាប់នោះ ជាការស្តាប់ដោយល្អនោះឯង ។ មួយប្រការទៀត **ឥតិ** សព្ទ មានអវធារណៈជាអត្ថ គឺអត្ថហាមអត្ថដទៃ មានការប្រកបដូចពណ៌នាមកនេះ ព្រោះហេតុនោះ **សុត** សព្ទ ដែលសម្ព័ន្ធដល់ **ឥតិ** សព្ទនោះ ទើបមានអត្ថថា

កំណត់ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបការដែល **សុត** សព្ទ បដិសេធភាវៈ គឺការមិនបានស្តាប់ និងការដែល **សុត** សព្ទ សម្តែងការទទួលយកមកមិនខ្វះខាត និងមិនវិបរិត ។

អ្នកសិក្សាគប្បីឃើញថា លោកចង់អត្ថយោជនានៃបទទាំង ៣ គឺ **ឯវម្មេ សុតំ** ដោយអំណាចហេតុនៃការស្តាប់ និងការប្រែកគ្នានៃការស្តាប់ដូចពណ៌នាមកនេះ ។

ម្យ៉ាងទៀត បទថា **ឯវំ** ឈ្មោះថា ប្រកាសដល់ភាវៈ គឺការប្រព្រឹត្តទៅក្នុងអារម្មណ៍ មានប្រការផ្សេងៗ ព្រោះវិញ្ញាណវិថីប្រព្រឹត្តទៅតាមគន្លងនៃសោតទ្វារ ទទួលយកអត្ថ និងព្យញ្ជនៈផ្សេងៗ គ្នា ព្រោះធ្វើការអធិប្បាយថា **ឯវំ** សព្ទ មានអត្ថដល់អាការ ។ បទថា **មេ** ប្រកាសដល់ខ្លួន ។ បទថា **សុតំ** ឈ្មោះថា ប្រកាសដល់ធម៌ ព្រោះវិញ្ញាណវិថីតាមដែលពោលហើយមានបរិយត្តិធម៌ជាអារម្មណ៍ ។

ក្នុងបទនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ខ្ញុំអានន្ទ មិនបានធ្វើវត្ថុដទៃ គឺខ្ញុំបានស្តាប់ធម៌នេះដោយវិញ្ញាណវិថី ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មានប្រការផ្សេងៗ ដែលជាតួហេតុ ។ ម្យ៉ាងទៀត បទថា **ឯវំ** ឈ្មោះថា ប្រកាសដល់វត្ថុដែលបានសម្តែងមកហើយ ព្រោះវត្ថុដែលគប្បីសម្តែង ក៏មិនមានភាវៈដែលគប្បីសម្តែង ព្រោះអធិប្បាយថា **ឯវំ** សព្ទ មាននិទស្សនៈជាអត្ថ ព្រោះហេតុនោះ គប្បីជ្រាបថា លោកពោលដល់សូត្រទាំងឡាយដោយ **ឯវំ** សព្ទ ។ បទថា **មេ** ប្រកាសដល់បុគ្គល ។ បទថា **សុតំ** ប្រកាសដល់

កិច្ចរបស់បុគ្គល ។ កិរិយា គឺការស្តាប់ ដែលបានមកដោយសំឡេងដែលបាន ឮមក ទាក់ទងនឹងចំណែកនៃវិញ្ញាណ គឺវិញ្ញាណក្នុងការស្តាប់ក្នុងធម្មបពន្ធ: ដែលប្រកបដោយការពោលដល់បុគ្គលនោះ រមែងបានកិរិយា គឺការស្តាប់ ។ បទនោះ មានអត្ថដូច្នេះថា ខ្ញុំអានន្ទ នឹងសម្តែងសូត្រណា សូត្រនោះ ខ្ញុំបាន ស្តាប់មកហើយយ៉ាងនេះ ។

ម្យ៉ាងទៀត បទថា **ឯវំ** ជាបទមានការទទួលយកអត្ថ និងព្យញ្ជនៈ ផ្សេងៗ គ្នា ព្រោះការប្រព្រឹត្តទៅនៃចិត្តសន្តានណា ដែលមានអារម្មណ៍ផ្សេងៗ គ្នា ។ បទថា **ឯវំ** ក៏សម្តែងដល់អាការផ្សេងៗ គ្នានៃចិត្តសន្តាននោះ ព្រោះ ធ្វើអធិប្បាយថា **ឯវំ** សព្ទ មានអត្ថដល់អាការ ។ ដោយសព្ទថា **ឯវំ** នេះ ឈ្មោះថា ជាកិច្ចបញ្ញត្តដល់អាការ ព្រោះធម៌ទាំងឡាយ មានសភាវៈដែល ត្រូវបញ្ញត្ត ដោយអាស្រ័យអាការ គឺការប្រព្រឹត្តទៅនោះៗ ។ បទថា **មេ** សម្តែងដល់កត្តា ។ បទថា **សុតំ** សម្តែងដល់អារម្មណ៍ ព្រោះថា ធម៌ដែល ត្រូវស្តាប់ រមែងជាឋានៈឲ្យបុគ្គលអ្នកធ្វើប្រព្រឹត្តទៅដោយអំណាចកិរិយា គឺ ការស្តាប់ដោយពាក្យមានប្រមាណប៉ុណ្ណេះ ដែលលោកសម្តែងដល់ការសម្រេច ចិត្ត ក្នុងការទទួលអារម្មណ៍របស់អ្នកធ្វើ ដែលដល់ព្រមដោយកិរិយា គឺការ ស្តាប់នោះ ដោយចិត្តសន្តានដែលប្រព្រឹត្តទៅហើយ ដោយប្រការផ្សេងៗ ។

មួយប្រការទៀត បទថា **ឯវំ** សម្តែងដល់កិច្ចរបស់បុគ្គល អធិប្បាយ ថា ពិតហើយ ធម្មតាកិច្ចរបស់បុគ្គល ឈ្មោះថា ព្រះអានន្ទត្រូវសម្តែងហើយ ដោយ **ឯវំ** សព្ទ ដែលមានភាវៈប្រកាសអត្ថថា និទស្សនៈ ឬអវធារណៈ

ដែលមានអាការនៃធម៌ទាំងឡាយ ដែលបានស្តាប់មកហើយ ដែលខ្ជួនទទួលហើយ ព្រោះការទ្រទ្រង់ចាំអាការនោះជាដើម ជាការខ្វល់ខ្វាយក្នុងធម៌ ដោយការប្រកាន់មាំក្នុងវោហារថា បុគ្គល ។ បទថា **សុតំ** សម្តែងដល់កិច្ចរបស់វិញ្ញាណ អធិប្បាយថា ពិតហើយ កិរិយា គឺការស្តាប់របស់បុគ្គលដែលមានវាទៈថា បុគ្គលមិនសម្ងឹងដល់វិញ្ញាណក៏មិនមែន ។ បទថា **មេ** សម្តែងដល់បុគ្គលដែលប្រកបដោយកិច្ចទាំង ២ អធិប្បាយថា ពិតហើយ ការប្រព្រឹត្តទៅនៃសព្ទថា **មេ** មានធម៌ដ៏វិសេស ដែលបានស្តាប់មកហើយជាអារម្មណ៍ ដោយចំណែកមួយប៉ុណ្ណោះ ហើយកិច្ចរបស់វិញ្ញាណក៏គប្បីតាំងនៅក្នុងអារម្មណ៍នោះឯង ។ តែក្នុងទីនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ខ្ញុំអានន្ទ គឺដែលបុគ្គលដល់ព្រមដោយវិញ្ញាណដែលមានកិច្ចស្តាប់ បានស្តាប់មកហើយ ដោយអំណាចនៃវិញ្ញាណដែលបានវោហារថា ជាអ្នកមានកិច្ចស្តាប់ ។

ម្យ៉ាងទៀត បទថា **ឥតិ** និងបទថា **មេ** ជាអវិជ្ជមានបញ្ញត្តិ ដោយអំណាចសច្ចិកត្ថបរមត្ថនៃអត្ថដែលជាក់ច្បាស់ និងអត្ថដ៏កំពូល ព្រោះថា អត្ថដែលគប្បីយល់បានដោយសំឡេងទាំងអស់ក្តី បញ្ញត្តទាំងមូល ព្រោះត្រូវបដិបត្តិតាមគន្លងនៃបញ្ញត្តនោះឯងក្តី រមែងមិនជំទាស់គ្នាក្នុងបញ្ញត្តទាំង ៦ នោះឯង មានវិជ្ជមានបញ្ញត្តិជាដើម ព្រោះហេតុនោះ អត្ថឯណាជាច្រើន ដែលមានពិត ដូចកលមាយា និងថ្ងៃបណ្តើរកូនជាដើម និងមិនមែនជាអត្ថដែលមិនប្រសើរ ដូចអត្ថដែលត្រូវទទួលដោយការស្តាប់តៗ មកជាដើម អត្ថជាបរមត្ថសភាវៈ មានសទ្ទរូប គឺសំឡេងជាដើម និងមានការបែកធ្លាយ មានការ

សោយអារម្មណ៍ជាដើម មានដោយអំណាចសច្ចិកត្ថបរមត្ថ ឯអត្ថណា មានអត្ថដល់អាការជាដើម ដែលកំពុងពោលថា **ឥតិ** និងថា **មេ** អត្ថនោះ មិនមែនបរមត្ថសភាវៈ គឺមិនបានដោយអំណាចសច្ចិកត្ថបរមត្ថ ឈ្មោះថា អវិជ្ជ-មានប្បញ្ញត្តិ ។ សួរថា បណ្តាបទទាំង ៣ នេះ បទណាគប្បីបានការសម្តែងអាងថា **ឥតិ** ឬថា **មេ** បទនោះ មានដោយបរមត្ថឬ ឆ្លើយថា បទថា **សុតំ** ជាវិជ្ជមានប្បញ្ញត្តិ អធិប្បាយថា អារម្មណ៍ដែលបានទទួលតាមសោតប្បសាទនោះ មានដោយបរមត្ថ ។

ម្យ៉ាងទៀត បទថា **ឥតិ** ចាត់ជាឧបាទាយប្បញ្ញត្តិ ព្រោះគប្បីពោលដោយអំណាចការពឹងផ្អែកដល់អាការទាំងឡាយ មានអាការដែលទ្រទ្រង់ទុកជាដើមនោះបាន ក៏ដោយអាស្រ័យធម៌ទាំងឡាយ ដែលមកប៉ះខ្ទប់សោតៈ ។ បទថា **មេ** ឈ្មោះថា ជាឧបាទាយប្បញ្ញត្តិ ព្រោះនឹងត្រូវពោលដល់ដោយអាស្រ័យខន្ធទាំងឡាយ ដែលទាក់ទងក្នុងសន្តតិដែលឧត្តមដោយពិសេសមានការណៈជាដើម ។ បទថា **សុតំ** ឈ្មោះថា ជាឧបនិធាយប្បញ្ញត្តិ ព្រោះត្រូវពោលដល់ដោយប្រៀបធៀបជាមួយអារម្មណ៍ទាំងឡាយ មានរូបដែលបានឃើញជាដើម ហៅហារថា **សុតៈ** សូម្បីប្រព្រឹត្តទៅក្នុងសទ្ទាយតនៈ ដែលវៀរចាកសភាវៈរបស់រូប ដែលបានឃើញជាដើម និងត្រូវពោលដល់ ដោយប្រៀបធៀបនឹងរូបដែលបានឃើញជាដើម ព្រោះជាវត្ថុដែលគប្បីដឹងច្បាស់ថា វត្ថុណាមិនប្រាថ្នាដល់រូបដែលបានឃើញ ក្លិន រស ផោដ្ឋព្វៈ ដែលបានជ្រាបនិងអារម្មណ៍ដែលបានដឹងច្បាស់ វត្ថុនោះ ចាត់ជា **សុតៈ** ប្រៀបដូចហៅហារថា

*ទុតិយជ្ឈាន តតិយជ្ឈានជាដើម នឹងត្រូវពោលដល់ដោយអាស្រ័យបឋមជ្ឈាន ជាដើម ដូច្នោះ ព្រោះហេតុនោះ ទើបលោកប្រកាសអត្ថនេះថា ឈ្មោះថា* **សុត** *ព្រោះមិនមែនមិនបានស្តាប់មក ។*

*ម្យ៉ាងទៀត ក្នុងទីនេះ លោកសម្តែងដល់ការមិនវង្វេង ដោយពាក្យថា* **ឥតិ** *អធិប្បាយថា ប្រការដែលផ្សេងគ្នានៃអត្ថដែលព្រះអានន្ទអាស្រ័យដល់ ក្នុងបទថា* **ឥតិ** *នេះ លោកចាក់ធ្លុះហើយ ការមិនវង្វេងរបស់លោក ទើប ឈ្មោះថា លោកសម្តែងហើយ ដោយពាក្យថា* **ឥតិ** *នោះ ជាការពិត បុគ្គល វង្វេងរមែងមិនអាចចាក់ធ្លុះប្រការផ្សេងៗ បាន ប្រការផ្សេងៗ គឺការលះលោកៈ ជាដើម និងប្រការដែលចាក់ធ្លុះមិនល្អ លោកសម្តែងថាជា* **សុត** *។ លោក សម្តែងថា ការមិនលះបង់ ដោយពាក្យថា* **សុត** *ព្រោះអាការនៃ* **សុត** *ជា អាការដែលឃើញតាមសេចក្តីពិត ។ ពិតហើយ បុគ្គលណា មាន* **សុត** *ភ្លេច ហើយ បុគ្គលនោះរមែងមិនអាចប្តេជ្ញាបានថា ខ្ញុំបានស្តាប់មកហើយ ព្រោះ ការមិនភ្លេចភ្លាំង ឬព្រោះបញ្ញា ដែលកើតក្នុងពេលស្តាប់របស់ព្រះអានន្ទនោះ ឯង ទើបមានការសម្រេចនៃបញ្ញាក្នុងកាលដទៃបន្ទាប់អំពីនោះ ដូចពណ៌នា មកដូច្នេះ ។ ម្យ៉ាងទៀត ព្រោះការមិនឃ្លៀងឃ្លាត ទើបមានការសម្រេចនៃ សតិ ។ បណ្តាបញ្ញា និងសតិទាំង ២ នោះ ព្រោះសតិដែលជាតួនាំបញ្ញា ទើបមានការអាចចងចាំនូវព្យញ្ជនៈបាន ព្រោះថា អាការនៃព្យញ្ជនៈទាំង- ឡាយដែលគប្បីចាក់ធ្លុះ មិនជ្រាលជ្រៅពេក ទ្រទ្រង់តាមដែលបានស្តាប់មក នោះឯង ជាករណីយកិច្ចក្នុងរឿងនេះ ព្រោះហេតុនោះ ទើបការប្រាកដរបស់*

សតិ ជារបស់សំខាន់ បញ្ញាជាគុណក្នុងសេចក្តីនោះ ព្រោះសតិជាប្រធានរបស់បញ្ញា ។ ព្រោះថា បញ្ញាជាប្រធានរបស់សតិ ទើបអាចក្នុងការចាក់ធ្លុះបាន ។ ព្រោះថា អាការនៃអត្ថដែលគប្បីចាក់ធ្លុះជារបស់ជ្រាលជ្រៅ ព្រោះហេតុនោះ ការខ្វល់ខ្វាយរបស់បញ្ញា ទើបជារបស់សំខាន់ សតិជាគុណធម៌ក្នុងសេចក្តីនោះ ព្រោះហេតុដែលបញ្ញាជាប្រធានរបស់សតិ ព្រោះប្រកបដោយអំណាចទាំង ២ នោះ ទើបព្រះអានន្ទមានការសម្រេចនៃភាពជាភណ្ឌាគារិក ព្រោះលោកអាចតាមរក្សាឃុំធម៌ដែលសម្បូរដោយអត្ថ និងព្យញ្ជនៈបាន ។

ម្យ៉ាងទៀត ព្រះអានន្ទសម្តែងការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយពាក្យថា **ឯវំ** ព្រោះអត្ថនៃអាការ និទស្សនៈ និងអវធារណៈដែលពោលដោយពាក្យថា **ឯវំ** នោះ ដែលនឹងពោលខាងមុខ ដែលធ្លុះបញ្ចាំងដល់ការចាក់ធ្លុះ ដោយប្រការផ្សេងៗ ជាអត្ថមិនវិបរិត ក៏មានសទ្ទដែលមិនវិបរិតជាអារម្មណ៍ អធិប្បាយថា ការចាក់ធ្លុះធម៌ ដោយប្រការផ្សេងៗ រមែងមិនមានដល់បុគ្គល ដែលមិនដាក់ចិត្តដោយឧបាយ ។ ព្រះអានន្ទសម្តែងការមិនរាយមាយដោយពាក្យថា **សុតំ** ការស្តាប់សូត្រដែលកំពុងពោល ដែលចាត់ជាបករណ៍ ដោយអំណាចនិទាន និងបុច្ឆា វៀរសមាធិចេញ រមែងមិនមាន ព្រោះបុគ្គលមានចិត្តរាយមាយ នឹងស្តាប់មិនបាន ។ សេចក្តីពិត បុគ្គលដែលមានចិត្តរាយមាយ ដែលព្រះធម្មកថិកពោលដោយសម្បត្តិទាំងពួង ក៏តែងពោលថា ខ្ញុំមិនបានស្តាប់ សូមលោកម្ចាស់ពោលម្តងទៀត ។ ម្យ៉ាងទៀត

*ក្នុងទីនេះ បុគ្គលឲ្យអត្តសម្មាបណិធិ និងបុព្វេកតបុញ្ញតាសម្រេចបាន ក៏ដោយយោនិសោមនសិការ ព្រោះបុគ្គលដែលមិនបានតម្កល់ខ្លួនដោយប្រពៃ ឬមិនបានធ្វើបុណ្យក្នុងជាតិមុន នឹងមានយោនិមនសិការនោះមិនបាន បុគ្គលនឹងឲ្យសទ្ធម្មស្សវនៈ និងសប្បុរិសូបសំសេវៈសម្រេចបាន ក៏ដោយការមិនរាយមាយ ព្រោះបុគ្គលដែលមិនបានស្តាប់ធម៌ ជាអ្នកវៀរចាកការចូលទៅអង្គុយជិតសប្បុរស នឹងមានការរាយមាយ ។ សេចក្តីពិត បុគ្គលមានចិត្តរាយមាយមិនអាចស្តាប់ធម៌បានឡើយ បុគ្គលមិនចូលទៅអង្គុយជិតសប្បុរស នឹងមិនមានការស្តាប់ធម៌ ។*

*ម្យ៉ាងទៀត ព្រោះចិត្តសន្តានណាប្រព្រឹត្តទៅដោយអាការផ្សេងៗ គ្នា ទើបមានការទទួល គឺយល់អត្ថ និងព្យញ្ជនៈផ្សេងៗ បាន ទើប* **ឥតិ** *សព្ទលោកពោលថា ជាសព្ទសម្តែងអាការផ្សេងៗ របស់ចិត្តសន្តាននោះ ។ ព្រោះហេតុដែលអាការនៃព្រះតម្រាស់របស់ព្រះមានព្រះភាគ ដែលល្អក្រៃលែងយ៉ាងនេះ ជាហេតុឲ្យប្រយោជន៍របស់បុគ្គលដទៃបរិបូណ៌បានគ្រប់គ្រាន់ ដោយធ្វើឲ្យអ្នកដទៃនោះ ឈមចុះកាន់ភាពសម្បូរនៃព្រះសាសនាទាំងមូល ដោយកំណត់ប្រភេទនៃអត្ថ និងព្យញ្ជនៈបាន រមែងមិនមានដល់បុគ្គល ដែលមិនបានតម្កល់ខ្លួនដោយប្រពៃ ឬមិនបានធ្វើបុណ្យក្នុងជាតិមុន ដូច្នោះ ព្រះអានន្ទក៏សម្តែងដល់ការដល់ព្រមនៃចក្រ ២ ខាងក្រោយរបស់ខ្លួន ដោយអាការដ៏ស្អាត ដោយពាក្យនេះថា* **ឥតិ។** *ព្រះអានន្ទសម្តែងដល់ការដល់ព្រមនៃចក្រ ២ ខាងដើម ព្រោះប្រកបដោយការស្តាប់ ដោយពាក្យថា* **សុតំ** *អធិប្បាយ*

ថា ការស្តាប់ធម៌ រមែងមិនមានដល់បុគ្គលដែលនៅក្នុងប្រទេសមិនសមគួរ ឬដែលវៀរចាកការចូលទៅអង្គុយជិតសប្បុរស ព្រោះចក្រ ២ ខាងក្រោយរបស់ព្រះអានន្ទនោះសម្រេច សេចក្តីបរិសុទ្ធនៃអាសយ ទើបជាការសម្រេចដោយប្រការដូចពណ៌នាមកដូច្នេះ ។ បុគ្គលដែលតម្កល់ខ្លួនដោយប្រពៃ និងបានធ្វើបុណ្យក្នុងជាតិមុន ឈ្មោះថា ជាបុគ្គលមានអាសយបរិសុទ្ធ ព្រោះកិលេសទាំងឡាយ ដែលជាហេតុឲ្យអាសយមិនបរិសុទ្ធនោះនៅឆ្ងាយ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ក្នុងធម្មបទយ៉ាងនេះថា ចំណែកខាងចិត្តដែលបុគ្គលតម្កល់ត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។ និងដោយព្រះតម្រាស់ក្នុងមហាបរិនិព្វានសូត្រថា ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យហើយ ចូរប្រកបព្យាយាមរឿយៗ ចុះនឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់ ។ និងព្រោះចក្រ ២ ខាងដើមសម្រេច ការបរិសុទ្ធនៃប្រយោគ ក៏សម្រេចដែរ អធិប្បាយថា ព្រះអានន្ទឈ្មោះថា ជាបុគ្គលមានប្រយោគបរិសុទ្ធ ដោយសាធុជនទាំងឡាយកាន់យកជាគំរូបាន ព្រោះការនៅក្នុងប្រទេសដ៏សមគួរ និងព្រោះការចូលទៅអង្គុយជិតសប្បុរស ។ ព្រោះអាសយបរិសុទ្ធនោះ ការឈ្លាសក្នុងអធិគមសម្រេចបាន និងព្រោះជាគ្រឿងសៅហ្មង គឺតណ្ហា និងទិដ្ឋិ ត្រូវជម្រះឲ្យបរិសុទ្ធហើយក្នុងកាលមុននោះឯង ព្រោះប្រយោគបរិសុទ្ធ ការឈ្លាសក្នុងអាគមក៏សម្រេចបាន អធិប្បាយថា ព្រះអានន្ទមានកាយប្បយោគ និងវចីបយោគបរិសុទ្ធ មានចិត្តមិនរាយមាយ ព្រោះមិនមានវិប្បដិសារៈ ទើបជាបុគ្គលដែលក្លៀវក្លាក្នុង

បរិយត្តិ ពាក្យរបស់ព្រះអានន្ទដែលមានប្រយោគ និងអាសយបរិសុទ្ធ សម្បូរ ដោយអាគម និងអធិគមដូចពោលមកនេះ សមគួរជាអ្នកនាំព្រះតម្រាស់ របស់ព្រះមានព្រះភាគ ដូចអរុណរះ គួរមានមកអំពីមុនព្រះអាទិត្យរះ យោនិសោមនសិការ គួរកើតឡើងមុនកុសលកម្ម ព្រោះហេតុនោះ ព្រះ អានន្ទកាលនឹងតាំងនិទាន គឺពាក្យខាងដើមក្នុងទីដែលគួរ ទើបពោលពាក្យថា **ឯតំ មេ សុតំ** ជាដើម ។

ម្យ៉ាងទៀត ព្រះអានន្ទសម្ដែងការកើតមាននៃសម្បត្តិ គឺអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យថា **ឯតំ** នេះ ដែលសម្ដែង ដល់ការចាក់ធ្លុះ ដោយប្រការផ្សេងៗ តាមន័យដែលពោលហើយ ក្នុងកាល មុន ។ ព្រះអានន្ទសម្ដែងការកើតមាននៃសម្បត្តិ គឺធម្មប្បដិសម្ភិទា និរុត្តិប្ប-ដិសម្ភិទា ដោយពាក្យថា **សុតំ** នេះ គឺសម្ដែងដល់ការចាក់ធ្លុះ ដែលផ្សេង អំពីវត្ថុដែលគួរស្ដាប់ ព្រោះអបសួបអត្ថនៃ **ឯតំ** សព្ទ ឬព្រោះប្រាថ្នាដល់ រឿងដែលកំពុងពោល ។ ម្យ៉ាងទៀត ព្រះអានន្ទពោលពាក្យនេះថា **ឯតំ** ដែល សម្ដែងដល់យោនិសោមនសិការ តាមន័យដែលពោលហើយនោះឯង ទើប ស្មើគ្នានឹងការសម្ដែងថា ធម៌ទាំងនេះ ខ្ញុំបានសម្លឹងដោយចិត្ត គិតគូរហើយ ដោយទិដ្ឋិ ។ អធិប្បាយថា បរិយត្តិធម៌ទាំងឡាយ ដែលបុគ្គលតាមសម្លឹង ដោយចិត្ត ដោយន័យជាដើមថា ព្រះមានព្រះភាគត្រាស់ក្នុងសូត្រនេះ ត្រាស់ សមាធិក្នុងសូត្រនេះ ត្រាស់បញ្ញាក្នុងសូត្រនេះ ក្នុងសូត្រនេះ មានអនុសន្ធិ ប៉ុណ្ណោះ ដែលបុគ្គលកំណត់រូបធម៌ និងអរូបធម៌ ដែលពោលក្នុងសូត្រនោះៗ

ដោយល្អ ដោយន័យជាដើមថា រូបយ៉ាងនេះ រូបមានប៉ុណ្ណេះ ហើយគិតដោយទិដ្ឋិ ដែលទាក់ទងនឹងការត្រិះរិះទៅតាមអាការដែលបានស្តាប់តមក ដែលអត់ធន់ចំពោះការសម្លឹងពិនិត្យនៃធម៌ ពោល គឺញាតបរិញ្ញា រមែងនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យ ទាំងដល់ខ្លួន និងដល់អ្នកដទៃ ។ ព្រះអានន្ទកាលពោលពាក្យថា **សុតំ** នេះ ដែលសម្តែងដល់ការប្រកបក្នុងការស្តាប់ ទើបស្មើគ្នានឹងការសម្តែងធម៌ជាច្រើន ដែលខ្ញុំស្តាប់ រួចទ្រទ្រង់ បានសន្សំដោយវាចាហើយ អធិប្បាយថា ការស្តាប់ ការចាំ និងការសន្សំបរិយត្តិធម៌ ទាក់ទងនឹងការផ្ទៀងសោតៈស្តាប់ ។ ព្រះអានន្ទសម្តែងការបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ដោយធម្មសភាវៈដែលព្រះមានព្រះភាគត្រាស់ល្អហើយទាំង ២ នោះ ទើបធ្វើឲ្យអ្នកស្តាប់កើតនូវការអើពើក្នុងការស្តាប់ ។ ពិតហើយ បុគ្គលកាលមិនស្តាប់ធម៌ ដែលបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ជាបុគ្គលឆ្ងាយចាកប្រយោជន៍ធំ ព្រោះហេតុនោះ អ្នកសិក្សាគប្បីញុំាងសេចក្តីអើពើឲ្យកើត ហើយស្តាប់ធម៌ចុះ ។

ដោយពាក្យទាំងអស់នេះថា **ឥតិ មេ សុតំ** ព្រះអានន្ទ កាលមិនតាំងធម៌វិន័យដែលព្រះតថាគតប្រកាសហើយ ដើម្បីខ្លួនឯង ឈ្មោះថា ឈានចុះកាន់ភូមិរបស់អសប្បុរស កាលប្តេជ្ញាភាពជាសាវក ឈ្មោះថា ឈានចុះកាន់ភូមិរបស់សប្បុរស ដោយប្រការនោះ ព្រះអានន្ទឈ្មោះថា ញុំាងចិត្តឲ្យចេញចាកអសទ្ធម្ម ឈ្មោះថា ញុំាងចិត្តឲ្យស្ថិតនៅក្នុងសទ្ធម្ម ។ ម្យ៉ាងទៀត ព្រះអានន្ទកាលសម្តែងថា ពាក្យនោះ គឺព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ

ឯង ដែលខ្ញុំបានស្តាប់មកហើយទាំងអស់នោះឯង ឈ្មោះថា ដោះខ្លួន អាង ព្រះសាស្តា លើកស្ទួយពាក្យរបស់ព្រះជិនស្រី តាំងជាបែប ជាទំនៀម ។ ម្យ៉ាងទៀត ដោយពាក្យថា **ឥតិ មេ សុតំ** ព្រះអានន្ទកាលមិនប្ដេជ្ញាថា ធម៌ខ្លួនឯងឲ្យកើតឡើង បើកផ្លូវនូវពាក្យផ្ដើម គឺបុរិមវចនៈថា ពាក្យនេះ គឺខ្ញុំទទួលមកចំពោះព្រះភក្ត្រព្រះមានព្រះភាគអង្គនោះ ដែលក្លៀវក្លាដោយវេសារជ្ជញ្ញាណ ៤ ដែលទ្រទ្រង់នូវទសពលញ្ញាណ ដែលតាំងនៅក្នុងឋានៈនៃបុគ្គលអង់អាច ដែលទ្រង់មានប្រក្រតីបន្លឺសីហនាទ ឧត្តមជាងសព្វសត្វ ដែលទ្រង់ជាព្រះធម្មិស្សរៈ ជាធម្មរាជា ធម្មាធិបតី ជាធម្មទីប ជាធម្មសារណៈ ជាអ្នកបង្វិលនូវចក្រ គឺព្រះសទ្ធម្មដ៏ប្រសើរ ដែលជាសម្មាសម្ពុទ្ធ អ្នកទាំងឡាយ មិនគួរធ្វើសេចក្ដីសង្ស័យ ឬការងឿងឆ្ងល់ក្នុងអត្ថ ឬធម៌ ក្នុងបទ ឬព្យញ្ជនៈនេះ ដូច្នេះ ឈ្មោះថា ញុំាងភាពជាបុគ្គលមិនមានសទ្ធាក្នុងធម៌វិន័យនេះឲ្យវិនាស ញុំាងសទ្ធាសម្បទាឲ្យកើតឡើង ។ ដោយហេតុនោះ ទើបលោកពោលប្រព័ន្ធនេះថា

សាវ័ករបស់ព្រះគោតម កាលពោលថា **ឯវម្មេ សុតំ**
ដូច្នេះ ឈ្មោះថា ញុំាងអសទ្ធាឲ្យវិនាស ញុំាងសទ្ធាក្នុង
ព្រះសាសនាឲ្យចម្រើន ។

ក្នុងទីនេះ អាចារ្យពួកខ្លះពោលថា ព្រោះហេតុអ្វី ទើបក្នុងសូត្រនេះ លោកមិនពោលពាក្យនិទាន ដូចក្នុងសូត្រដទៃៗ ដែលព្រះអានន្ទពោលពាក្យនិទានអាងកាលៈទេសៈ ដោយន័យជាដើមថា **ឯវម្មេ សុតំ ឯកំ សមយំ** ផង

ឆ្លើយថា ព្រោះអាចារ្យពួកដទៃ បានពោលហើយ ។ ពាក្យនិទានក្នុងសូត្រនេះ ព្រះថេរៈមិនបានពោល ព្រោះមានអ្នកពោលហើយ អធិប្បាយថា ពាក្យនិទាននេះ ព្រះអានន្ទមិនបានពោល តែនាងខុជ្ជុត្តរា ដែលព្រះមានព្រះភាគតែងតាំងក្នុងឯតទគ្គៈ ព្រោះក្នុងបណ្ដាឧបាសិកា នាងជាពហុស្សូត ជាអរិយសាវិកា បានសម្រេចសេក្ខប្បដិសម្ភិទា ពោលមុនហើយដល់ស្ត្រី ៥០០ ដែលមានព្រះនាងសាមាវតីជាប្រធាន ។ ក្នុងរឿងនោះ មានការពោលជាលំដាប់តទៅនេះ

## ប្រវត្តិនាងខុជ្ជុត្តរា

បានឮថា រាប់អំពីនេះក្នុងខាងចុងសែននៃកប្ប ព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ បានកើតឡើងក្នុងលោក ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរ ហើយប្រថាប់នៅក្នុងក្រុងហង្សវតី ថ្ងៃមួយ កុលធីតាម្នាក់ ក្នុងនគរហង្សវតី ទៅកាន់អារាម មួយអន្លើដោយឧបាសិកាដែលកំពុងទៅស្ដាប់ទេសនា របស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់តែងតាំងឧបាសិកាម្នាក់ ក្នុងឯតទគ្គៈថា ជាកំពូលជាងឧបាសិកាទាំងឡាយខាងពហុស្សូត ធ្វើបុណ្យហើយ ប្រាថ្នាតំណែងនោះ ។

ឯព្រះសាស្ដាទ្រង់ព្យាករឧបាសិកានោះថា ក្នុងអនាគតកាល នាងបានជាឧបាសិកា ជាសាវិការបស់ព្រះសម្មាសម្ពុទ្ធព្រះនាមគោតម ជាកំពូលក្នុងបណ្ដាឧបាសិកាដែលជាពហុស្សូតដូចគ្នា ។ នាងធ្វើកុសលជាបដល់អស់ជីវិត ទៅកើតក្នុងទេវលោក ចុតិអំពីទេវលោកហើយ ក៏មកកើតក្នុងពួកមនុស្សទៀត នាងអន្ទោលទៅក្នុងទេវលោក និងមនុស្សលោកយ៉ាងនេះ បាន

មួយសែនកប្ប ក្នុងភទ្ទកប្បនេះ ក្នុងកាលព្រះមានព្រះភាគនៃយើង នាង បានចុតិអំពីទេវលោក បដិសន្ធិក្នុងផ្ទៃនៃស្រីកំលៀង ក្នុងផ្ទះរបស់ឃោសកសេដ្ឋី ជនទាំងឡាយបានដាក់ឈ្មោះនាងថា ឧត្តរា ក្នុងកាលដែលនាងកើតមក ដោយនាងជាស្រីគម ព្រោះហេតុនោះ ទើបប្រាកដឈ្មោះថា ខុជ្ជុត្តរា ។ តមក ក្នុងកាលដែលឃោសកសេដ្ឋី ថ្វាយនាងសាមាវតីដល់ព្រះបាទឧទេន នាងខុជ្ជុត្តរានោះ ក៏ត្រូវលើកឲ្យជានាងបរិចារិការបស់នាងសាមាវតីនោះ នៅក្នុងរាជសម្នាក់របស់ព្រះបាទឧទេន សម័យនោះ ឃោសិតសេដ្ឋី កុក្កុដសេដ្ឋី និងបាវារិកសេដ្ឋី ក្នុងក្រុងកោសម្ពី បាននាំគ្នាសាងវិហារ ៣ កន្លែង ឧទ្ទិសចំពោះព្រះមានព្រះភាគ កាលព្រះតថាគតទ្រង់ចារិកទៅក្នុងជនបទ ដល់ព្រះនគរកោសម្ពី បានថ្វាយវិហារដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ហើយនាំគ្នាបំពេញមហាទាន ។ ប្រមាណមួយខែកន្លងផុតទៅ គ្រានោះ សេដ្ឋីទាំងនោះគិតដូច្នេះថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់អនុគ្រោះលោកទាំងអស់ ពួកយើងនឹងឲ្យឱកាសដល់អ្នកដទៃខ្លះ ។ សូម្បីបុគ្គលដែលនៅក្នុងក្រុងកោសម្ពី ក៏បានបើកឱកាសឲ្យដល់មហាជនទូទៅ ។ តាំងអំពីនោះមក ពួកអ្នកក្រុងក៏នាំគ្នាថ្វាយមហាទាន ដោយរួមមនុស្សក្នុងវិថីជាមួយគ្នាខ្លះ ដោយរួមគ្នាជាគណៈខ្លះ ថ្ងៃមួយ ព្រះសាស្តាដែលភិក្ខុសង្ឃចោមរោមហើយ គង់ប្រថាប់ក្នុងផ្ទះនៃនាយមាលាការ ដែលជាប្រធាន ។

ខណៈនោះ នាងខុជ្ជុត្តរាបានទទួលទ្រព្យ ៨ កហាបណៈ ហើយទៅកាន់ផ្ទះនោះដើម្បីទិញផ្កាឲ្យនាងសាមាវតី ។ នាយមាលាការដែលជាប្រធាន

ឃើញនាងហើយ ក៏ពោលថា នែនាងឧត្តរា ថ្ងៃនេះ ខ្ញុំមិនមានពេលលក់ផ្កាឲ្យនាងទេ ខ្ញុំកំពុងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន នាងក៏ចូរជាសម្លាញ់ក្នុងការអង្គាសចុះ កាលធ្វើយ៉ាងនេះហើយ នាងក៏នឹងផុតអំពីការបម្រើបុគ្គលដទៃនោះឯង ។ គ្រានោះ នាងខុជ្ជុត្តរាក៏បានធ្វើការបម្រើព្រះពុទ្ធទាំងឡាយក្នុងរោងចុងភៅ នាងបានរៀនធម៌ទាំងអស់ ដែលព្រះសាស្តាត្រាស់ហើយ ដោយអំណាចជាឧបនិសិន្នកថា តមក បានស្តាប់អនុមោទនាកថា ហើយបានសម្រេចសោតាបត្តិផល ។ ក្នុងថ្ងៃដទៃៗ នាងឲ្យ ៤ កហាបណៈប៉ុណ្ណោះ ហើយទទួលយកផ្កាទៅ តែក្នុងថ្ងៃនោះ ព្រោះបានឃើញសច្ចៈ នាងមិនញ៉ាំងចិត្តឲ្យកើតក្នុងវត្ថុរបស់បុគ្គលដទៃ ឲ្យអស់ទាំង ៨ កហាបណៈ ហើយបានទទួលយកផ្កាទៅកាន់សម្នាក់របស់នាងសាមាវតី ។

លំដាប់នោះ ព្រះនាងសាមាវតីនោះ បានសួរនាងថា នែឧត្តរា ក្នុងថ្ងៃដទៃៗ នាងនាំផ្កាមកឲ្យមិនច្រើន តែថ្ងៃនេះ នាំមកច្រើន ព្រះរាជារបស់យើងទាំងឡាយ ទ្រង់ជ្រះថ្លាច្រើនឡើងឬ នាងបានទូលរឿងទាំងអស់មិនបិទបាំងសូម្បីរឿងដែលខ្លួនបានធ្វើហើយ ព្រោះមិនអាចពោលកុហកបាន កាលនាងត្រូវសួរថា បើដូច្នោះ ព្រោះហេតុអ្វី ទើបថ្ងៃនេះ នាងនាំផ្កាមកច្រើន ក៏ទូលតបថា ថ្ងៃនេះ ខ្ញុំបានស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធ ហើយបានធ្វើឲ្យជាក់ច្បាស់នូវអមតៈ ព្រោះហេតុនោះ ទើបខ្ញុំម្ចាស់មិនភូតកុហកព្រះនាង ។ ព្រះនាងសាមាវតីស្តាប់ពាក្យនោះហើយ ក៏មិនបានពោលពាក្យអាក្រក់ថា នែទាសីអាក្រក់ ចូរហែងសងកហាបណៈ ដែលនាងយកទៅអស់កាលមានប្រមាណ

ប៉ុណ្ណោះ កាលបុព្វហេតុជាស់តឿនក៏ត្រាស់ថា នែនាង ចូរនាងឲ្យពួកយើងផឹក នូវអមតៈ ដែលនាងបានផឹកហើយ ដល់យើងខ្លះ កាលនាងខុជ្ជុត្តរាទូលថា បើដូច្នោះ សូមព្រះនាងឲ្យខ្ញុំម្ចាស់នូវតទឹកសិន ព្រះនាងក៏ឲ្យនាងនូវតទឹក ដោយទឹកក្រអូប ១៦ ក្អម ហើយត្រាស់ឲ្យប្រទានសំពត់សាច់រអិល ២ ផ្ទាំង ។

នាងខុជ្ជុត្តរានោះស្លៀកមួយផ្ទាំង ពាទាមួយផ្ទាំង ហើយក្រាលអាសនៈ លើអាសនៈ កាន់ផ្ចិតដ៏វិចិត្រ ហៅមាតុគ្រាមទាំង ៥០០ ដែលអង្គុយលើអាសនៈទាបជាង តាំងនៅក្នុងសេក្ខប្បដិសម្ភិទា សម្ដែងធម៌ដល់ស្រីទាំងនោះ តាមនិយាមដែលព្រះសាស្ដាទ្រង់សម្ដែងហើយនោះឯង ក្នុងកាលចប់ទេសនា ស្រីទាំងឡាយនោះ បានសម្រេចសោតាបត្តិផល ស្រីទាំងនោះថ្វាយបង្គំនាងខុជ្ជុត្តរាបណ្ដើរ ពោលថា បពិត្រអ្នកនាង តាំងអំពីថ្ងៃនេះទៅ សូមនាងកុំធ្វើការងាររថោកទាបតទៅទៀតឡើយ សូមនាងតាំងនៅក្នុងឋានៈជាម្ដាយ ក្នុងឋានៈជាអាចារ្យរបស់យើងទាំងឡាយចុះ ដូច្នេះហើយ បានតាំងនាងក្នុងឋានៈជាទីគោរព ។

សួរថា ព្រោះហេតុអ្វី ទើបនាងខុជ្ជុត្តរានេះកើតជាទាសី ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ នាងកើតជាធីតារបស់សេដ្ឋី ក្នុងក្រុងពារាណសី កាលព្រះថេរីខីណាស្រពមួយរូប ទៅកាន់ត្រកូលឧបដ្ឋាក ក៏ប្រាប់ថា បពិត្រអ្នកនាងម្ចាស់ សូមអ្នកនាងម្ចាស់ ហុចកញ្ច្រែង គ្រឿងប្រដាប់ដល់ខ្ញុំ ដូច្នេះហើយ ក៏ប្រាប់ឲ្យអ្នកបម្រើធ្វើការបម្រើព្រះថេរី ចំណែកព្រះថេរីគិតថា បើអញមិនហុចឲ្យ នាងនឹងចងអាឃាត ស្លាប់ហើយ

នឹងធ្លាក់នរក បើអញហុយឲ្យ នាងនឹងកើតជាទាសីរបស់អ្នកដទៃ កាលនាងកើតជាទាសី ល្អជាងការឆេះក្នុងនរក ដូច្នេះហើយ អាស្រ័យសេចក្ដីករុណា ទើបបានធ្វើតាមពាក្យរបស់នាង ។ ដោយកម្មនោះ នាងបានកើតជា ទាសីរបស់អ្នកដទៃ ៥០០ ជាតិ ។

សួរថា ព្រោះហេតុអ្វី ទើបនាងបានជាស្រីគម ឆ្លើយថា បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើង នាងនៅក្នុងព្រះរាជវាំង របស់ព្រះបាទពារាណសី ឃើញព្រះបច្ចេកពុទ្ធ ដែលជាកុលុបកៈមួយអង្គ ខ្នងគមបន្តិច កាលនឹងធ្វើការលេងចំពោះស្រីដែលនៅជាមួយខ្លួន ទើបសម្ដែងអាការធ្វើដូចជាខ្នងគមសើចលេង ព្រោះហេតុនោះ ទើបនាងកើតជាស្រីគម ។

សួរថា នាងធ្វើកម្មអ្វី ទើបកើតជាស្រីមានបញ្ញាច្រើន ឆ្លើយថា កាលព្រះពុទ្ធមិនទាន់កើតឡើង នាងនៅក្នុងព្រះរាជវាំង របស់ព្រះបាទពារាណសី ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ឱបបាត្រដែលពេញដោយបាយាសក្ដៅអំពីព្រះរាជវាំង បានថ្វាយកងដៃ ៨ ដែលជារបស់ខ្លួន ដោយពិតថា សូមលោកម្ចាស់ដាក់បាត្រលើកងដៃនេះ ហើយឱបបាត្រចុះ ព្រះបច្ចេកពុទ្ធទាំងនោះធ្វើតាមនោះ ហើយសម្លឹងមើល នាងប្រាប់ថា កងដៃនេះ ខ្ញុំប្រគេនដល់លោកម្ចាស់ សូមលោកម្ចាស់កាន់យកចុះ ព្រះបច្ចេកពុទ្ធទាំងនោះ បានទៅកាន់ញកភ្នំនន្ទមូលក៍ សូម្បីក្នុងថ្ងៃនេះ កងដៃនោះ មិនទាន់ពុកផុយឡើយ នាងបានជាស្រីមានបញ្ញាច្រើន ព្រោះផលនៃកម្មនោះ ។

តមក ស្ត្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន បានពោលនឹងនាង

ថា នែនាង សូមនាងទៅកាន់សម្នាក់របស់ព្រះសាស្តារាល់ថ្ងៃ ស្តាប់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ មកសម្តែងដល់ខ្ញុំផង នាងក៏បានធ្វើតាមនោះ ។ ក្នុងកាលតមក នាងក៏បានក្លាយជាអ្នកចាំព្រះត្រៃបិដក ។ ព្រោះហេតុនោះ ព្រះសាស្តាក៏តាំងនាងក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកា អ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា ប្រសើរជាងគេ ។ ឧបាសិកាខុជ្ជុត្តរា ជាអរិយសាវិកា បានសម្រេចបដិសម្ភិទា ដែលព្រះសាស្តាទ្រង់ស្ថាបនាក្នុងឯតទគ្គៈ ព្រោះជាពហុសូត គ្រាព្រះសាស្តាប្រថាប់នៅក្នុងក្រុងកោសម្ពី បានទៅកាន់សម្នាក់ព្រះសាស្តា តាមកាលដ៏សមគួរ បានស្តាប់ធម៌ហើយ ត្រឡប់ទៅកាន់រាជសម្នាក់ កាលនឹងពោលធម៌តាមដែលបានស្តាប់មកតាមនិយាមដែលព្រះសាស្តាទ្រង់សម្តែង ដល់ស្ត្រីអរិយសាវិកា ៥០០ នាក់ មានព្រះនាងសាមាវតីជាប្រធាន កាលនឹងដោះខ្លួន ប្រកាសភាពដែលធម៌ខ្លួនបានស្តាប់ក្នុងសម្នាក់ព្រះសាស្តា ទើបលើកនិទានឡើងថា ខ្ញុំបានស្តាប់មកហើយថា ពាក្យនេះ ព្រះមានព្រះភាគបានត្រាស់ហើយ គឺព្រះអរហន្តត្រាស់ហើយ ដូចពណ៌នាមក ដូច្នេះ ។

ព្រោះនាងខុជ្ជុត្តរានោះ បានស្តាប់មកចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគក្នុងនគរនោះឯង ហើយពោលដល់ស្ត្រីទាំងនោះ ក្នុងថ្ងៃនោះ ដូច្នោះ ទើបមិនមានប្រយោជន៍ ដោយអាងពេល និងទីកន្លែងថា សម័យមួយ ព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងកោសម្ពី ព្រោះពេលវេលា និងទីកន្លែង ប្រាកដច្បាស់ហើយ ។

ឯភិក្ខុនីទាំងឡាយ បានរៀនយកសូត្រទាំងនេះ ក្នុងសម្នាក់នាងខុជ្ជុត្តរា នោះ សូម្បីក្នុងពួកភិក្ខុ និទានដែលនាងខុជ្ជុត្តរានោះលើកឡើង ក៏ប្រាកដបន្ត គ្នាមកយ៉ាងនេះ ។ តមក ព្រះអានន្ទអង្គុយសង្គាយនាធម៌ត្រង់កណ្ដាលគណៈ ព្រះថេរៈដែលជាអ្នកជំនាញ មានព្រះមហាកស្សបត្ថេរជាប្រធាន ក្នុងសន្ធម្ម មណ្ឌប ដែលព្រះបាទអជាតសត្តុទ្រង់សាងឡើង ត្រង់សត្តបណ្ណគុហាខាង ក្រោយ អំពីកាលព្រះតថាគតបរិនិព្វាន កាលនឹងចៀសវាងនិទាននៃសូត្រ ទាំងនោះ ក៏មាន ២ និទាន ទើបលើកនិទានឡើងតាមនិយាម ដែលនាង ខុជ្ជុត្តរានោះលើកនោះឯង ។ តែអាចារ្យពួកខ្លះ ពង្រីកប្រការក្នុងទីនេះ ឲ្យ ច្រើនចេញទៅ ។ ប្រយោជន៍អ្វីដោយប្រការទាំងនោះ ។

## ឥតិវុត្តកៈមាន ១០២ សូត្រ

ម្យ៉ាងទៀត ព្រះសង្គីតិកាចារ្យទាំងឡាយ សង្គាយនាព្រះធម្មវិន័យ ដោយន័យផ្សេង ។ ពិតហើយ ព្រះមហាថេរៈដែលសង្គាយនាព្រះធម៌ជា អនុពុទ្ធ ។ ព្រះមហាថេរៈទាំងនោះ ដឹងអាការសង្គាយនាព្រះធម៌វិន័យដោយ ប្រពៃនោះឯង ក្នុងទីខ្លះ ទើបតាំងនិទាន ដោយន័យជាដើមថា **ឯវំ មេ សុតំ** ក្នុងទីខ្លះ តាំងនិទានដោយន័យជាដើមថា **តេន សមយេន** ក្នុងទីខ្លះ តាំង និទានដោយគាថាព័ន្ធ តែក្នុងទីខ្លះ មិនតាំងនិទានទាំងអស់ឡើយ សង្គាយនា ព្រះធម្មវិន័យ ដោយចែកជាវគ្គសង្គហៈជាដើម ។ បណ្ដាអាគតដ្ឋានទាំងនោះ ក្នុងទីនេះ ព្រះសង្គីតិកាចារ្យតាំងនិទានដោយន័យជាដើម **វុត្តំ ហេតំ** ហើយ សង្គាយនា ។ ពុទ្ធវចនៈនេះ មានអង្គ ៩ ដោយចែកជាសុត្តៈ គេយ្យៈជាដើម

នៃព្រះពុទ្ធគ្រប់អង្គ ក៏ដូចព្រះពុទ្ធវចនៈមានអង្គ ៩ នោះ សមដូចពាក្យដែលលោកពោលដូច្នេះថា ព្រះពុទ្ធវចនៈមានអង្គ ៩ គឺសុត្តៈ គេយ្យៈ ។បេ។ របស់ព្រះពុទ្ធទាំងនោះមានតិចជាដើម ។ ក្នុងបណ្ដាអង្គទាំងនោះ អង្គ គឺឥតិវុត្តកៈ មិនប្រាកដនិទានណាមួយដទៃឡើយ វៀរលែងពាក្យនេះថា **វុត្តំ ហេតំ ។បេ។ មេ សុតំ** ដែលជាគ្រឿងសម្គាល់នៃឥតិវុត្តកៈនោះ ។ ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា សូត្រ ១១២ សូត្រ ដែលប្រព្រឹត្តទៅ ដោយន័យជាដើមថា **វុត្តំ ហេតំ ភគវតា** ចាត់ជាឥតិវុត្តកៈ ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ឬព្រះអរិយសាវិកា អ្នកបំណងរបស់ព្រះសាស្ដា ក៏បានតាំងនិទានដោយន័យនេះឯង កាលនឹងដឹងថា សូត្រទាំងនេះ នឹងជាអង្គ គឺឥតិវុត្តកៈ ។

សួរថា ព្រះអានន្ទ កាលធ្វើការប្រមូលព្រះធម៌ ព្រះវិន័យ បានពោលពាក្យនិទានដើម្បីអ្វី លោកគួរធ្វើការរួបរួមព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់មិនមែនឬ ខ្ញុំនឹងឆ្លើយថា ព្រះអានន្ទពោលពាក្យនិទានដើម្បីញ៉ាំងនូវការតាំងមាំ ការមិនឃ្លៀងឃ្លាត និងភាពជារបស់គួរជឿនៃទេសនាឲ្យដល់ព្រម ។ សេចក្ដីពិត ទេសនាដែលពាក់ព័ន្ធជាមួយនឹងមាតិកា គឺកាលៈ ( ពេលវេលា ) ទេសៈ ( ទីកន្លែង ) អ្នកសម្ដែង និងបរិស័ទ រមែងជាទេសនាតាំងនៅបានមាំទាំ មិនឃ្លៀងឃ្លាត និងជាទេសនាគួរជឿ ។ កិច្ចវិនិច្ឆ័យវោហារ ដូចជាពាក់ព័ន្ធជាមួយគ្រឿងចំណាំ គឺទេសៈ កាលៈ កត្តា ( អ្នកធ្វើ ) និងសោតា ( អ្នកស្ដាប់ ) ក៏ព្រះអានន្ទដែលជាភណ្ឌាគារិកនោះ

៦៨ កាលព្រះមហាកស្សបៈធ្វើការបុច្ឆាដល់ទេសៈជាដើមនៃព្រហ្មជាលសូត្រ និងមូលបរិយាយសូត្រជាដើម និងធ្វើការវិសជ្ជនាបុច្ឆាទាំងនោះ ទើបពោលពាក្យនិទាន ដោយន័យជាដើមថា **ឯវមេ្ម សុតំ** តែក្នុងទីនេះ លោកពោលហេតុហើយ ព្រោះប្រារព្ធដល់កាលៈ និងទេសៈ ។

មួយប្រការទៀត ពាក្យនិទាន លោកពោលដើម្បីប្រកាសសម្បត្តិរបស់ព្រះសាស្តា ។ ពិតហើយ ព្រះមានព្រះភាគជាព្រះតថាគត ទ្រង់សម្រេចភាពជាព្រះសម្មាសម្ពុទ្ធបាន ព្រោះមិនមានការរចនាមុន មិនមានការអនុមាន និងមិនមានតក្កក្នុងបរិយត្តិ ។ ព្រះសម្មាសម្ពុទ្ធមិនមានរចនាមុនជាដើម ព្រោះទ្រង់មានញាណចុះបញ្ចាំងទៅ មិនមានទើសទាក់ក្នុងធម៌ទាំងពួង និងព្រោះទ្រង់មានប្រមាណក្នុងញេយ្យធម៌ទាំងឡាយ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់សម្រេចជាព្រះខីណាស្រពបាន ព្រោះមិនមានកណ្តាប់ដៃរបស់អាចារ្យ គឺការកំណាញ់ធម៌ និងការត្រេកអរ សូម្បីតិចតួច ក្នុងអ្នកស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ព្រោះថា ធម៌ទាំងនោះកើតឡើងដល់ព្រះខីណាស្រពសព្វកាលក៏មិនមែន ព្រោះដូច្នោះ ព្រឹត្តិកម្មដែលអនុគ្រោះអ្នកដទៃ ទើបកើតដល់ព្រះមានព្រះភាគ ដែលទ្រង់បរិសុទ្ធក្រៃលែង ។ ការសម្រេចវេសារជ្ជញាណ ២ ខាងដើមរបស់ព្រះមានព្រះភាគ គឺសម្មាសម្ពុទ្ធបដិញ្ញា ១ ខីណាសវបដិញ្ញា ១ មានដោយសម្ពុទ្ធភាវៈ និងវិសុទ្ធិភាវៈ ដែលចង្អុលដល់ការមិនមានអវិជ្ជា និងតណ្ហា ដែលជាគ្រឿងប្រទូស្ត ទិដ្ឋិសម្បទា និងសីលសម្បទា ជាសង្កិលេសរបស់អ្នកសម្តែង និងដែលធ្វើនូវញាណសម្បទា និង

បហានសម្បទាឲ្យប្រាកដ និងសេចក្ដីសម្រេចវេសារជ្ជញាណ ២ ខាងក្រោយ គឺអន្តរាយិកធម្មវាទ ១ និយ្យានិកធម្មទេសនា ១ មានព្រោះទ្រង់សម្រេចការមិនវាងវៃក្នុងអន្តរាយិកធម៌ និងនិយ្យានិកធម៌នោះ ព្រោះហេតុនោះ ដោយពាក្យនិទាន ឈ្មោះថា ព្រះអានន្ទត្ថេរប្រកាសការដែលព្រះមានព្រះភាគ ទ្រង់ប្រកបដោយវេសារជ្ជញាណ ៤ យ៉ាង ដែលជាទីអាស្រ័យបំពេញនូវប្រយោជន៍ដើម្បីព្រះអង្គ និងប្រយោជន៍ដើម្បីអ្នកដទៃ ព្រោះទ្រង់សម្ដែងព្រះធម្មទេសនាដោយបដិភាណដែលកើតឡើងតាមឋានៈដែលគួរ ព្រោះសមគ្នានឹងអធ្យាស្រ័យរបស់បរិស័ទដែលជួបហើយក្នុងទីនោះៗ ។ តែក្នុងទីនេះ គួរប្រកបពាក្យពោលថា ការលះទោសរបស់កាមដោយមិនមានសេសសល់ និងដោយការសម្ដែងព្រះធម្មទេសនាតាមវិធី ដោយហេតុនោះ ទើបលោកពោលថា លោកពោលនិទានវចនៈ ដើម្បីប្រកាសគុណសម្បត្តិរបស់ព្រះសាស្ដា ។

ម្យ៉ាងទៀត ក្នុងរឿងនេះ លោកសម្ដែងដល់ការប្រកាសអត្ថឲ្យជាក់ច្បាស់ តាមដែលបានពោលមកហើយ ខាងដើមនោះឯង ដោយបទនេះថា **ភគវតា អរហតា** ។ ម្យ៉ាងទៀត ព្រះអានន្ទត្ថេរពោលពាក្យនិគមដើម្បីប្រកាសគុណសម្បត្តិរបស់ព្រះសាសនា ព្រោះថា បដិបទារបស់ព្រះមានព្រះភាគ ដែលទ្រង់មានកិរិយាសព្វយ៉ាង ដែលញាណ និងព្រះករុណាផ្គងទុកដែលឥតប្រយោជន៍ ឬជាប្រយោជន៍ដល់ព្រះអង្គប៉ុណ្ណោះ គឺការឃើញដល់ខ្លួន មិនមាន ព្រោះដូច្នោះ កាយកម្ម វចីកម្ម និងមនោកម្មទាំងអស់របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះកិរិយាសព្វយ៉ាងដែលប្រព្រឹត្តទៅហើយ ដើម្បី

ជាប្រយោជន៍ដល់អ្នកដទៃនោះឯង ដែលកំពុងពោលដល់ តាមដែលប្រព្រឹត្តទៅហើយ ឈ្មោះថា ជាពាក្យប្រៀនប្រដៅដូចគ្នា ព្រោះអត្ថថា ជាហេតុទូន្មាននូវសត្វទាំងឡាយបានរឿយៗ តាមសមគួរដល់ប្រយោជន៍ជាតិនេះ និងប្រយោជន៍ជាតិខាងមុខ និងប្រយោជន៍ដែលជាបរមត្ថ មិនមែនព្រោះវចនាទាំងអស់ទេ លោកប្រកាសចរិតរបស់ព្រះសាស្តាតាមសមគួរ ដោយនិទាន-វចនៈទាំងឡាយ ដែលអាស្រ័យកាលៈទេសៈ អ្នកសម្តែង និងបរិស័ទ ។ តែក្នុងទីនេះ គួរប្រកបពាក្យថា ដែលអាងដល់បុគ្គលសម្តែង និងបរិស័ទ ដោយហេតុនោះ ទើបលោកពោលថា **សាសនសម្បត្តិប្បកាសនត្ថំ និទានវចនំ** លោកពោលនិទានវចនៈ ដើម្បីប្រកាសគុណសម្បត្តិរបស់ព្រះសាសនា ។

ម្យ៉ាងទៀត លោកពោលនិទានវចនៈដើម្បីសម្តែងថា ពាក្យប្រៀនប្រដៅយកជាប្រមាណបាន ព្រោះប្រកាសថា ព្រះសាស្តាយកជាប្រមាណបាន ឯការសម្តែងថា ពាក្យប្រៀនប្រដៅនេះ យកជាប្រមាណបាននោះ គប្បីជ្រាបថា បានប្រកាសហើយ ដោយបទទាំងនេះថា **ភគវតា អរហតា** តាមគន្លងរបស់ន័យដែលបានពោលហើយខាងដើម ក្នុងទីនេះ ពាក្យសម្តែងត្រឹមឱកាសរបស់ប្រយោជន៍នៃពាក្យនិទានប៉ុណ្ណោះ ដូច្នេះឯង ។

**និទានវណ្ណនា ចប់**

# អដ្ឋកថា
# ពណ៌នា ឯកនិបាត
## លោភសូត្រ

[ ១ ] ឥឡូវនេះ ដល់ឱកាសនៃកិច្ចពណ៌នាព្រះសូត្រ ដែលព្រះមានព្រះភាគ ទ្រង់លើកឡើងដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ ដូច្នេះ ។ ឯកិច្ចពណ៌នានេះ ព្រោះជាការប្រាកដដែលលោកពោលវិភាគ ដល់និក្ខេបទរបស់ព្រះសូត្រ ដូច្នោះ យើងនឹងវិភាគនិក្ខេបទរបស់សូត្រ ។

ពិតហើយ និក្ខេបទមាន ៤ យ៉ាង គឺអត្តជ្ឈាសយ ១ បរជ្ឈាសយ ១ បុច្ឆាវសិក ១ អត្ថុប្បត្តិក ១ ។ សេចក្តីពិត ព្រះសូត្រទាំងឡាយ សូម្បីមានប្រភេទរាប់សែនមិនមែនតិច ក៏មិនលើស ១៦ យ៉ាង ដោយបដ្ឋានន័យ មានសន្និលេសភាគិយជាដើម យ៉ាងណា ព្រះសូត្រទាំងឡាយ រមែងមិនលើស ៤ យ៉ាងទៅបាន ដោយនិក្ខេបទរបស់សូត្រ មានអត្តជ្ឈាសយជាដើម ដូច្នោះ ដោយប្រការដូច្នេះ ។ ក្នុង ៤ យ៉ាងនោះ អត្តជ្ឈាសយ និងអត្ថុប្បត្តិ តែងមានការជាប់ជំពាក់ជាមួយបរជ្ឈាសយ និងបុច្ឆា ព្រោះមានការបន្តនៃអត្តជ្ឈាសយ និងបុច្ឆា គឺអត្តជ្ឈាសយ និងបរជ្ឈាសយ អត្តជ្ឈាសយ និងបុច្ឆាវសិក អត្ថុប្បត្តិក និងបរជ្ឈាសយ អត្ថុប្បត្តិក និងបុច្ឆាវសិក យ៉ាងណា សេចក្តីពិត អត្ថុប្បត្តិ រមែងមានការជាប់ទាក់ទងដោយអត្តជ្ឈាសយ ដូច្នោះ តែអត្ថុប្បត្តិ មិនមានការជាប់ទាក់ទងដោយអត្តជ្ឈាសយជាដើម ដែលកើត

ឡើងដល់ខ្លួន ព្រោះដូច្នោះ បដ្ឋានន័យដែលមិនមានសេសសល់ រមែងមិនកើត ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលដល់និក្ខេបទរបស់ព្រះសូត្រ ៤ យ៉ាង ដោយតាំងមាតិកានៃនិក្ខេបទដ៏សេស ដែលកើតឡើងព្រោះឈមចុះខាងក្នុងរបស់ន័យនោះ ។

គប្បីជ្រាបអត្ថក្នុងសូត្រនោះដូចតទៅនេះ ឈ្មោះថា និក្ខេប ព្រោះអត្ថថា ដែលគេតាំង ។ និក្ខេបទ គឺព្រះសូត្រ ឈ្មោះថា សុត្តនិក្ខេប ម្យ៉ាងទៀត ការតាំងសេចក្តី ឈ្មោះថា និក្ខេប ។ ការតាំងសេចក្តីនៃព្រះសូត្រ ឈ្មោះថា សុត្តនិក្ខេប អធិប្បាយថា សម្តែងព្រះសូត្រ ។ អធ្យាស្រ័យរបស់ខ្លួន ឈ្មោះថា អត្តជ្ឈាសយ ។ ឈ្មោះថា អត្តជ្ឈាសយ ព្រោះជាហេតុផលរបស់ខ្លួននោះ ។ ម្យ៉ាងទៀត ឈ្មោះថា អត្តជ្ឈាសយ ព្រោះមានអធ្យាស្រ័យរបស់ខ្លួន សូម្បីក្នុងបរជ្ឈាសយ ក៏មានន័យដូចគ្នា ឈ្មោះថា បុច្ឆាវស ព្រោះអំណាចនៃពាក្យសួរ ឈ្មោះថា បុច្ឆាវសិក ព្រោះមានអំណាចនៃពាក្យសួរ ។ រឿងរ៉ាវដែលជាហេតុសម្តែងព្រះសូត្រកើតឡើង ឈ្មោះថា អត្ថុប្បត្តិៗ នោះឯង ឈ្មោះថា អត្ថុប្បត្តិក ។ ឈ្មោះថា អត្ថុប្បត្តិក ព្រោះមានរឿងកើតឡើង ។ ម្យ៉ាងទៀត ឈ្មោះថា និក្ខេប ព្រោះមានគ្រឿងលើកព្រះសូត្រឡើង បានដល់អត្តជ្ឈាសយជាដើមនោះឯង ។

ក្នុងអត្ថវិកប្បនេះ អធ្យាស្រ័យរបស់ខ្លួន ឈ្មោះថា **អត្តជ្ឈាសយ** អធ្យាស្រ័យរបស់អ្នកដទៃ ឈ្មោះថា **បរជ្ឈាសយ** ឈ្មោះថា **បុច្ឆា** ព្រោះត្រូវសួរ បានដល់ អត្ថដែលគួរសួរ ។ ពាក្យរបស់អ្នកទទួលធម៌ ដែលប្រព្រឹត្ត

ទៅដោយពាក្យសួរ ឈ្មោះថា **បុច្ឆាវស** ។ ពាក្យនោះ លោកពោលដោយនបុំសកលិង្គថា **បុច្ឆាវសិកោ** ព្រោះសម្ព័ន្ធដល់និក្ខេបសព្ទ ។ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទនេះថា រឿងរ៉ាវដែលកើតឡើងនោះឯង ឈ្មោះថា អត្តុប្បត្តិក ។

ម្យ៉ាងទៀត ភាពដែលអត្តជ្ឈាសយ ជានិក្ខេបរបស់ព្រះសូត្រ តម្កល់គួរហើយ ព្រោះមិនបានសម្ព័ន្ធដល់ហេតុ មានសេចក្តីក្លៀវក្លានៃឥន្ទ្រិយជាដើមរបស់បុគ្គលដទៃ សមដូចលោកពោលថា ដោយអធ្យាស្រ័យរបស់ខ្លួនតែម្យ៉ាងដូច្នេះ ។ ព្រោះឲ្យទេសនាប្រព្រឹត្តទៅដើម្បីតាំងបែបផែននៃធម៌ ។ សេចក្តីនេះមិនគួរចោទសួរថា ការមិនទាស់ទែងគ្នាដោយអធ្យាស្រ័យ និងបុច្ឆារបស់អ្នកដទៃ ដែលជាបរជ្ឈាសយ និងបុច្ឆាវសិកដែលជាហេតុរបស់ទេសនានិមិត្តដែលប្រព្រឹត្តទៅហើយក្នុងឧបបត្តិ ក្នុងអត្តុប្បត្តិបានដូចម្តេច ឬការមិនបៀតបៀនគ្នារបស់បុច្ឆាវសិក និងអត្តុប្បត្តិកដែលប្រព្រឹត្តទៅហើយ ដោយមិនចូលទៅបៀតបៀនបរជ្ឈាសយ ក្នុងបរជ្ឈាសយបានដូចម្តេច ។ ជាការញែកកាន់យកនៃបរជ្ឈាសយ និងបុច្ឆាវសិក ព្រោះកាន់យកដោយភាពជាអត្តុ-ប្បត្តិហេតុនៃការកើតរបស់ហេតុសម្តែងព្រះសូត្រ ដែលក្រៅអំពីអភិនីហារ និងការសាកសួរជាដើម ។ ជាការពិត ការសម្តែងគុណ ទោស និងការកើតនៃអាមិសជាដើមរបស់ព្រហ្មជាលសូត្រ និងធម្មទាយាទសូត្រជាដើម លោកហៅថា និមិត្ត ។ លោកសម្តែងបរជ្ឈាសយ ធ្វើអជ្ឈាសយ វៀរចាកពាក្យសួររបស់អ្នកដទៃឲ្យជានិមិត្ត លោកសម្តែងបុច្ឆាវសិក ដោយអំណាចនៃពាក្យសួរ

ព្រោះហេតុនោះ អត្ថនេះ ប្រាកដជាក់ច្បាស់ហើយ ។ ព្រះមានព្រះភាគ កាលអ្នកដទៃមិនបានទូលអារាធនា ត្រាស់ព្រះសូត្រទាំងឡាយណា ដោយអធ្យាស្រ័យរបស់ព្រះអង្គតែម្យ៉ាងប៉ុណ្ណោះ ដូចជាអាកង្ខេយ្យសូត្រ តុវដ្តកសូត្រជាដើម អត្តជ្ឈាសយជាការតាំងរបស់សូត្រទាំងនោះ ព្រះសូត្រពួកណា ដែលព្រះមានព្រះភាគទ្រង់ប្រមើលមើលអធ្យាស្រ័យ ការអត់ធន់ អភិនីហារ និងបញ្ញារបស់អ្នកដទៃថា ធម៌ដែលចាស់ក្លាដែលអប់រំរាហុល ឲ្យរួចផុតមានតថាគតគប្បីនាំរាហុលទៅ ក្នុងការអស់អាសវៈឲ្យក្រៃលែង ដូចជារាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រជាដើម ដោយបរជ្ឈាសយៗ ជានិក្ខេបបទនៃព្រះសូត្រទាំងនោះ ។

ពួកទេវតា និងមនុស្ស បរិស័ទ ៤ វណ្ណៈ ៤ ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហាយ៉ាងនោះៗ ព្រះសូត្រពួកណា មានពោជ្ឈង្គសំយុត្តជាដើម ដែលព្រះមានព្រះភាគមានអ្នកទូលសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ត្រាស់ពោជ្ឈង្គៗ សូមទ្រង់ត្រាស់នីវរណៈៗ ដូច្នេះជាដើម ហើយត្រាស់បុច្ឆាវសិក ជានិក្ខេបបទរបស់ព្រះសូត្រទាំងនោះ ។ ព្រះសូត្រពួកណា ដែលព្រះមានព្រះភាគត្រាស់អាស្រ័យហេតុកើតឡើងហើយ ដូចជាធម្មទាយាទសូត្រ បុត្តមំសូបមសូត្រ ទារុក្ខន្ធូបមសូត្រជាដើម អត្ថុប្បត្តិកជានិនេក្ខបបទរបស់សូត្រទាំងនោះ ។ ក្នុងការតាំងព្រះសូត្រទាំង ៤ នេះ បរជ្ឈាសយជានិក្ខេបបទរបស់ព្រះសូត្រនេះ ដោយប្រការដូច្នេះ ។ ពិតហើយ លោកលើកសូត្រនេះឡើង ដោយអំណាចបរជ្ឈាសយ សួរថា លោក

លើកឡើងដោយអជ្ឈាសយនៃបុគ្គលពួកណា ឆ្លើយថា ដោយអជ្ឈាសយនៃ បុគ្គលដែលមិនឃើញទោសក្នុងលោកៈ តែអាចារ្យពួកខ្លះពោលថា ជាអត្ត-ជ្ឈាសយ ។

**ឯក** សព្ទ ក្នុងបទជាដើមថា **ឯកធម្មំ ភិក្ខវេ** នេះ **ឯក** សព្ទ មកក្នុងអត្ថថា ដទៃ ដូចក្នុងប្រយោគជាដើមថា **សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទំ** គឺសមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសភាវៈទៀង ការយល់ឃើញនេះឯង ត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ រមែងមានក្នុងការប្រសើរ ដូចក្នុងប្រយោគជាដើមថា **ចេតសោ ឯកោទិភាវំ** មានសភាពជាចិត្តខ្ពស់ឯក ។ មកក្នុងអត្ថថា មិនមានសម្លាញ់ ដូចក្នុងប្រយោគជាដើមថា **ឯកោវូបកដ្ឋោ** ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ។ មានអត្ថថា ការរាប់ ដូចក្នុងប្រយោគជាដើមថា **អយំ ភិក្ខវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។ ក្នុងសូត្រនេះ **ឯក** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថថារាប់ ។

**ធម្ម** សព្ទ រមែងប្រាកដក្នុងអត្ថទាំងឡាយដូចជាបរិយត្តិ សច្ចៈ សមាធិ បញ្ញា បកតិ បុញ្ញ អាបត្តិ សុញ្ញតា ញេយ្យ សភាវៈជាដើម ។

មកក្នុងអត្ថថា បរិយត្តិ ដូចក្នុងប្រយោគជាដើមថា **ឥធ ភិក្ខុ ធម្មំ បរិ-យាបុណាតិ សុត្តំ គេយ្យំ** ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក□ិក្ខុក□

សាសនានេះ រៀនទូវធម៌ គឺសុត□គយ□ ។បេ។

មកក្នុងអត្ថថា សច្ចៈ ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋធម្មោ** ឃើញធម៌ហើយ ។

មកក្នុងអត្ថថា សមាធិ ដូចក្នុងប្រយោគជាដើមថា **ឯវំ ធម្មា តេ ភគវន្តោ អហេសុំ** ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះខ្វះ ។

មកក្នុងអត្ថថា បញ្ញា ដូចក្នុងប្រយោគជាដើមថា **សច្ចំ ធម្មោ ធិតិ ចាគោ សវេ បេច្ច ន សោចតិ** ធម៌ទាំង ៤ នេះ គឺសច្ចៈ ១ ធម្មៈ ( បញ្ញា ) ១ ធីតិ ( ព្យាយាម ) ១ ចាគៈ ( ការបរិច្ចាគ ) ១ ... មិនសោយសោកក្នុងលោកខាងមុខ ។

មកក្នុងអត្ថថា ប្រក្រតី ដូចក្នុងប្រយោគជាដើមថា **ជាតិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ** ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា ( ប្រក្រតី ) តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ... ។

មកក្នុងអត្ថថា បុណ្យ ដូចក្នុងប្រយោគជាដើមថា **ធម្មោ ហវេ រក្ខតិ ធម្មចារី** ធម៌ ( បុណ្យ ) រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ។

មកក្នុងអត្ថថា អាបត្តិ ដូចក្នុងប្រយោគជាដើមថា **តិណ្ណំ ធម្មានំ អញ្ញតរេន វទេយ្យ បារាជិកេន វា សង្ឃាទិសេសេន វា បាចិត្តិយេន វា** ហើយគប្បីចោទដោយអាបត្តិបីយ៉ាង ចំពោះអាបត្តិណាមួយ គឺអាបត្តិបារាជិកក្តី សង្ឃាទិសេសក្តី បាចិត្តិយៈក្តី ។

មកក្នុងអត្ថថា សុញ្ញតា ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន**

**សមយេ ធម្មា ហោន្តិ** ពួកធម៌ កើតមានក្នុងសម័យនោះ ។

មកក្នុងអត្ថថា ញេយ្យ ( ធម៌ដែលគួរដឹង ) ដូចក្នុងប្រយោគជាដើមថា **( អតីតានាគតបច្ចុប្បន្នំ ឧទាទាយ ) សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ** ធម៌ទាំងអស់ ( រាប់ទាំងអតីត អនាគត បច្ចុប្បន្ន ) រមែងមកកាន់គន្លងចំមុខព្រះញាណនៃព្រះពុទ្ធមានព្រះភាគ ដោយអាការទាំងពួង ។

មកក្នុងអត្ថថា សភាវៈ ដូចក្នុងប្រយោគជាដើមថា **កុសលា ធម្មា អកុសលា ធម្មា** ធម៌ទាំងឡាយជាកុសល ធម៌ទាំងឡាយជាអកុសល ។ គប្បីជ្រាបថា ធម៌ក្នុងទីនេះ បានដល់ សភាវធម៌ ។ ព្រោះដូច្នោះ បទថា **ឯកធម្មំ** បំណងយកសភាវធម៌ដែលសៅហ្មងតែម្យ៉ាង ។ ឈ្មោះថា ឯកធម៌ ព្រោះអត្ថថា ជាធម៌ ១ ។ ចូរពួកអ្នកលះនូវធម៌ ១ នោះ ។

ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា **ភិក្ខវេ** ដូច្នេះ សួរថា កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ រមែងត្រាស់ហៅភិក្ខុទាំងឡាយ ទ្រង់មិនសម្តែងធម៌តែម្តង ដើម្បីអ្វី ឆ្លើយថា ដើម្បីឲ្យកើតសតិ ។ ដ្បិតថា ភិក្ខុទាំងឡាយនោះ គិតទៅទីផ្សេងៗខ្លះ អង្គុយពិចារណាធម៌ខ្លះ អង្គុយមនសិការកម្មដ្ឋានខ្លះ កាលព្រះមានព្រះភាគមិនត្រាស់ហៅមុន ទ្រង់សម្តែងធម៌តែម្តង ភិក្ខុទាំងឡាយមិនអាចកំណត់បានថា ទេសនានេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ លុះណា ព្រះមានព្រះភាគត្រាស់ហៅហើយ ទើបភិក្ខុទាំងឡាយកំណត់បាន ព្រោះដូច្នោះ ព្រះមានព្រះភាគ ដើម្បីឲ្យភិក្ខុទាំងឡាយកើតសតិ

ទើបត្រាស់ហៅថា **ភិក្ខវេ** ដូច្នេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសគោលបដិបត្តិដែលជនសេពធូរថយ ឬក្រៃលែង ដោយអំណាចការប្រកបគុណមានភាពជាបុគ្គលមានសីលជាដើមដល់ភិក្ខុទាំងនោះ ទើបទ្រង់ធ្វើការពញ្ញាក់ស្មារតី ក្នុងកាលដែលចិត្តបង្អោនទៅក្នុងការរាយមាយ ។ ព្រះមានព្រះភាគទ្រង់ធ្វើភិក្ខុទាំងនោះឲ្យបែរមុខចំពោះព្រះអង្គ ដោយព្រះតម្រាស់ដែលផ្សាយទៅដោយព្រះករុណា ទឹកព្រះហឫទ័យត្រជាក់ មានកែវភ្នែកបែរមករកជាខាងដើម ទ្រង់ឲ្យភិក្ខុទាំងនោះកើតនូវសេចក្ដីប្រាថ្នាដើម្បីស្ដាប់ ដោយព្រះតម្រាស់ដែលសម្ដែងដល់ភាពជាបុគ្គលប្រាថ្នាដើម្បីនឹងពោលនោះឯង ទ្រង់ដឹកនាំឲ្យតាំងចិត្តស្ដាប់ដោយល្អ ដោយប្រាថ្នាឲ្យកើតការដឹងនោះឯង ។ ពិតហើយការដល់ព្រមដោយពាក្យប្រៀនប្រដៅ អាស្រ័យការតាំងចិត្តស្ដាប់ ។ សួរថា កាលទេវតា និងមនុស្សពួកដទៃដែលទាក់ទងដោយបរិស័ទមាន ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហៅតែភិក្ខុទៅវិញ ឆ្លើយថា ព្រោះភិក្ខុទាំងឡាយជាបុគ្គលចម្រើន ជាបុគ្គលប្រសើរ ជាអ្នកអង្គុយជិត ជាអ្នកជិតស្និទ្ធសព្វកាល ពិតហើយ ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ រមែងសាធារណៈដល់បរិស័ទទាំងពួង ។ ភិក្ខុទាំងឡាយ ឈ្មោះថា ចម្រើនបំផុតក្នុងបរិស័ទ ព្រោះជាអ្នកកើតមុន ឈ្មោះថា ប្រសើរបំផុត ព្រោះបដិបត្តិតាមចរិយារបស់ព្រះសាស្ដា ផ្ដើមតាំងអំពីការចេញបួសជាដើម និងព្រោះទទួលពាក្យប្រៀនប្រដៅទាំងអស់ ឈ្មោះថា ជាអ្នកជិត ព្រោះកាលភិក្ខុទាំងឡាយអង្គុយក្នុងទីនោះ ជាអ្នកអង្គុយជិត ។ ឈ្មោះថា ជាអ្នកជិតសព្វកាល ព្រោះជាអ្នកនៅ

ក្នុងសម្នាក់ព្រះសាស្តា ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយ ឈ្មោះថា ជាអ្នកជិតស្និទ្ធសព្វកាល ព្រោះជាអ្នកបដិបត្តិតាមពាក្យប្រៀនប្រដៅ ដែលជាទីតាំងនៃព្រះធម្មទេសនា និងព្រោះជាអ្នកមានការវិសេស ។ ទេសនានេះ សំដៅដល់ភិក្ខុពួកខ្លះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងនោះ ។

## អធិប្បាយ បហាន ៥ យ៉ាង

ឈ្មោះថា **បហាន** ក្នុងបទថា **បជហាថ** មាន ៥ យ៉ាង គឺតទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ។ ក្នុងបហាន ៥ យ៉ាងនោះ ការលះលោភៈជាដើម ដោយការមិនលោភជាដើម ការលះវត្ថុមិនមានប្រយោជន៍នោះៗ ដោយវិបស្សនាញាណ មានការកំណត់នាមរូបជាដើម ព្រោះជាបដិបក្ខនឹងគ្នា ដូចការកម្ចាត់ងងឹត ដោយពន្លឺប្រទីប ដូច្នោះ ដូចការលះមន្ទិល មានលោភៈជាដើម ដោយបរិច្ចាគ លះនូវការទ្រុស្តសីល មានបាណាតិបាតជាដើមដោយសីល លះការមិនមានសទ្ធាជាដើម ដោយសទ្ធា លះនូវសក្កាយទិដ្ឋិ ដោយកំណត់នាមរូប លះទិដ្ឋិដែលជាអហេតុកៈ និងវិសមហេតុ ដោយការកំណត់បច្ច័យ លះនូវសេចក្តីសង្ស័យ ដោយឆ្លងផុតសេចក្តីសង្ស័យដទៃៗ ចេញបាន ការលះនូវការប្រកាន់មាំថាអញ ថាជារបស់អញ ដោយការពិចារណាឃើញជាកលាបៈ លះរបស់ដែលមិនមែនជាមគ្គ ថាជាមគ្គ ដោយកំណត់មគ្គ និងអមគ្គ លះឧច្ឆេទទិដ្ឋិ ដោយការឃើញការកើត និងការលះសស្សតទិដ្ឋិ ដោយឃើញការវិនាស លះការសម្គាល់វត្ថុដែលជាភ័យ ថាមិនជាភ័យ ដោយការ

ឃើញភ័យ លះការសម្គាល់ក្នុងវត្ថុដែលពេញចិត្ត ដោយការឃើញទោស លះនូវការសម្គាល់ក្នុងវត្ថុដែលគួរអភិរម ដោយការពិចារណាដល់ការនឿយណាយ លះនូវការមិនចង់រួចផុតដោយញាណ គឺការចង់ផុត ការលះនូវការមិនព្រងើយកន្តើយ ដោយឧបេក្ខាញាណ ការលះធម្មដ្ឋិតិ ដោយអនុលោម លះភាពជាបដិលោម ដោយនិព្វាន លះនូវភាពជាសង្ខារនិមិត្ត ដោយគោត្រភូ ការលះនេះ ឈ្មោះថា **តទង្គប្បហាន ។**

ការលះនូវធម៌មាននីវរណៈជាដើមនោះៗ ដោយឧបចារសមាធិ និងអប្បនាសមាធិ ដូចការកម្ចាត់ចកលើទឹក ដោយការផ្គាប់ឆ្នាំងចុះទៅ ព្រោះហាមនូវការប្រព្រឹត្តទៅ ការលះនេះ ឈ្មោះថា វិក្ខម្ភនប្បហាន ។

ការកាត់នូវគំនរកិលេស ដែលជាចំណែកឲ្យតណ្ហាកើត ដែលលោកពោលដោយន័យជាដើមថា ដើម្បីលះនូវទិដ្ឋិក្នុងសន្តានរបស់ខ្លួន ដែលមានមគ្គនោះៗ ព្រោះចម្រើនអរិយមគ្គ ៤ បានហើយ ការលះនេះ ឈ្មោះថា សមុច្ឆេទប្បហាន ។

ការលះកិលេសទាំងឡាយ ដែលជាការស្ងប់ក្នុងខណៈនៃផល ការលះនេះ ឈ្មោះថា បដិបស្សទ្ធិប្បហាន គឺលះដោយការស្ងប់កិលេស ។ ការរម្ងាត់ដែលលះគ្រឿងតាក់តែងទាំងអស់បានហើយ ព្រោះលះនូវគ្រឿងតាក់តែងទាំងអស់បាន នេះឈ្មោះថា និស្សរណប្បហាន គឺលះដោយការរលាស់ចេញ ។ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា បានដល់ សមុច្ឆេទប្បហាន ព្រោះលោកបំណងយកការលះដែលធ្វើឲ្យជាព្រះអនាគាមី ដោយការលះ ៥ យ៉ាង

ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ បទថា **បជហថ** ទើបមានសេចក្តីថា អ្នកទាំងឡាយ ចូរលះបង់ ចូរកាត់ផ្តាច់ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់អាងដល់ខ្លួនរបស់ទ្រង់ ដោយពាក្យថា **អហំ**។ បទថា **វោ** មានវិនិច្ឆ័យដូច្នេះថា **វោ** សព្ទនេះ ប្រាកដក្នុងបឋមាវិភត្តិ ទុតិយាវិភត្តិ តតិយាវិភត្តិ ឆដ្ឋីវិភត្តិ បទបូរណៈ និងចតុត្ថីវិភត្តិ ។ **វោ** សព្ទ មកក្នុងបឋមាវិភត្តិ ក្នុងបទជាដើមថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា** ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូច្នេះ ។

មកក្នុងទុតិយាវិភត្តិ ក្នុងបទជាដើមថា **គច្ឆថ ភិក្ខវេ បណាមេមិ វោ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទៅ តថាគតបណ្តេញអ្នកទាំងឡាយ ដូច្នេះ ។

មកក្នុងតតិយវិភត្តិ ក្នុងបទជាដើមថា **ន វោ មម សន្តិកេ វត្ថព្វំ** អ្នកទាំងឡាយមិនគួរនៅក្នុងសម្នាក់តថាគតទេ ដូច្នេះ ។

មកក្នុងឆដ្ឋីវិភត្តិ ក្នុងបទជាដើមថា **សព្វេសំ វោ សារិបុត្ត សុភាសិតំ** ម្នាលសារីបុត្ត បើដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ដូច្នេះ ។

មកក្នុងបទបូរណៈ ក្នុងបទជាដើមថា **យេ ហិ វោ អរិយា បរិសុទ្ធកាយកម្មន្តា** ព្រះអរិយៈទាំងឡាយណា ដែលមានកាយកម្មបរិសុទ្ធ ដូច្នេះ ។

មកក្នុងបតុត្ថីវិភត្តិ ក្នុងបទជាដើមថា **វទបត្ថបរិយាយំ វោ ភិក្ខវេ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវហេតុនៃការនៅក្នុងព្រៃដល់អ្នកទាំងឡាយ ។ ក្នុងទីនេះ គប្បីជ្រាបថា **វោ** សព្ទ មកក្នុងបតុត្ថីវិភត្តិ ។

បទថា **ចាដិភោគោ** បានដល់ ជាអ្នកធានា ពិតហើយ បុគ្គលនោះអាស្រ័យអ្នកធានា ខ្ចីទ្រព្យអ្នកមានទ្រព្យ ផ្ញើទុកដល់អ្នកធានា កាលដល់គ្រាប្រើប្រាស់ ក៏នាំទ្រព្យអំពីអ្នកធានានោះមកប្រើ ព្រោះដូច្នោះ ទើបឈ្មោះថា **បដិភោគោ** គឺអ្នកធានា ។ អ្នកទទួលនោះឯង ឈ្មោះថា **ចាដិភោគោ** ។ បទថា **អនាគាមិតាយ** បានដល់ ដើម្បីភាពជាព្រះអនាគាមី ។ ឈ្មោះថា **អនាគាមី** ព្រោះមិនមកកាន់កាមភពដោយបដិសន្ធិ ។ មគ្គទី ៣ មួយអន្លើដោយផល ឈ្មោះថា **អនាគាមី** លោកហៅថា **អនាគាមី** ព្រោះសម្រេចនូវធម៌នោះ ។

ព្រះមានព្រះភាគ ទ្រង់ឈ្លាសក្នុងការទូន្មានវេនេយ្យសត្វ ទ្រង់សម្ដែងធម៌ដ៏ក្រៃលែង គឺតតិយមគ្គ ដែលអនុកូលដល់អធ្យាស្រ័យរបស់វេនេយ្យសត្វ ទ្រង់ធ្វើឲ្យធ្ងន់ ដោយការបរិបូណ៌ក្នុងធម៌ឯណាមួយ ដោយឧបាយធាប់រួសរាន់ ទើបសមជាព្រះសម្មាសម្ពុទ្ធ ដោយប្រការដូច្នេះ ។ ពិតហើយ កិលេសទាំង-ឡាយ ដែលតតិយមគ្គគប្បីទម្លាយ មានបដិឃសំយោជនៈជាដើម សូម្បីប្រព្រឹត្តទៅក្នុងភូមិដទៃក៏មិនរួចផុតចាកការលះកាមច្ឆន្ទៈបានឡើយ ។

សួរថា ព្រោះហេតុអ្វី ទើបក្នុងសូត្រនេះ ព្រះមានព្រះភាគ ទ្រង់តាំងខ្លួន

ព្រះអង្គក្នុងភាពជាអ្នកធានាអះអាងទៅវិញ ឆ្លើយថា ដើម្បីឲ្យភិក្ខុទាំងនោះ កើតនូវឧស្សាហ៍ក្នុងការសម្រេចអនាគាមិមគ្គ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា កាលតថាគតពោលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ លះធម៌ឯណានីមួយបាន តថាគតជាអ្នកធានាដល់អ្នកទាំងឡាយ ដើម្បីភាពជា ព្រះអនាគាមី ដូច្នេះ ។ ភិក្ខុទាំងឡាយនោះ អាចលះនូវធម៌ឯណានីមួយ ហើយដល់គតិយភូមិបានពិតប្រាកដ និងកើតសេចក្ដីឧស្សាហ៍ថា ព្រះធម្មសាមី ត្រាស់ដំបូងថា តថាគតជាអ្នកធានា ដូច្នេះ ព្រោះហេតុនោះ នឹងសម្គាល់ដល់ បទដែលគួរបដិបត្តិ ដូច្នេះ ។ ដើម្បីឲ្យភិក្ខុទាំងឡាយកើតឧស្សាហ៍ ទើបទ្រង់ តាំងខ្លួនក្នុងភាពជាអ្នកធានាដល់ភិក្ខុទាំងនោះ ដើម្បីភាពជាព្រះអនាគាមី ។

## អធិប្បាយ បុច្ឆា ៥ យ៉ាង

បទថា **កតមំ** ក្នុងបទថា **កតមំ ឯកធម្មំ** នេះ ជាពាក្យសួរ ធម្មតា ពាក្យសួរមាន ៥ យ៉ាង គឺអទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ អនុមតិបុច្ឆា ១ កថេតុកម្យតាបុច្ឆា ១ ។

ក្នុងពាក្យសួរទាំងនោះ តាមប្រក្រតី មនុស្សយើងមិនទាន់ដឹង មិនឃើញ មិនពិចារណា មិនត្រិះរិះ មិនយល់ មិនជាក់ច្បាស់ មិនប្រាកដដល់លក្ខណៈ ទើបសួរបញ្ហា ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រិះរិះ ដើម្បីពិចារណា ដើម្បី យល់ ដើម្បីជាក់ច្បាស់ដល់លក្ខណៈនោះ នេះឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** គឺសួរដើម្បីដឹងក្នុងវត្ថុដែលខ្លួនមិនដឹង ។ តាមប្រក្រតី បុគ្គលដឹងហើយ ឃើញ ហើយ ពិចារណាហើយ ត្រិះរិះហើយ យល់ហើយ ជាក់ច្បាស់ហើយនូវ

លក្ខណៈ គេសួរបញ្ហា ដើម្បីប្រៀបធៀបបណ្ឌិតដទៃ នេះឈ្មោះថា **ទិដ្ឋសំ-សន្ទនាបុច្ឆា** គឺសួរដើម្បីផ្ទៀងផ្ទាត់ ។ តាមប្រក្រតី បុគ្គលធ្លាក់នៅក្នុងសេចក្តីសង្ស័យ ក្នុងការមិនដឹង ក្នុងការងឿងឆ្ងល់ថា យ៉ាងនេះឬហ្ន៎ មិនមែនទេដឹងហ្ន៎ ជាអ្វីហ្ន៎ ដូចម្តេចហ្ន៎ ដូច្នេះ ទើបគេសួរបញ្ហាដើម្បីកាត់សេចក្តីសង្ស័យ នេះឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** គឺសួរដើម្បីកាត់សង្ស័យ ។

ពិតហើយ ព្រះមានព្រះភាគ ត្រាស់សួរបញ្ហាដើម្បីអនុលោមតាមការឃើញ ដោយព្រះតម្រាស់ជាដើមថា **តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វា** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង នេះឈ្មោះថា **អនុមតិបុច្ឆា** គឺសួរដើម្បីស្របតាម ។ ព្រះមានព្រះភាគត្រាស់សួរបញ្ហា ព្រោះមានបំណងដើម្បីត្រាស់ប្រាប់ដល់ភិក្ខុទាំងឡាយថា **ចត្តារោ មេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ កតមេ ចត្តារោ** ម្នាលភិក្ខុទាំងឡាយ អាហារ ៤ នេះ ប្រព្រឹត្តទៅដើម្បីការតាំងនៅបាន នៃពួកភូតសត្វផង ដើម្បីអនុគ្រោះដល់ពួកសម្ភវេសីសត្វផង ។ អាហារ ៤ តើដូចម្តេច ។ នេះឈ្មោះថា **កថេតុ-កម្យតាបុច្ឆា** គឺសួរដើម្បីបំណងនឹងប្រាប់ ។

ក្នុងពាក្យសួរ ៥ យ៉ាងនោះ ពាក្យសួរ ៣ ខាងដើម មិនមានដល់ព្រះសម្ពុទ្ធទាំងឡាយ ។ សួរថា ព្រោះហេតុអ្វី ទើបមិនមាន ឆ្លើយថា ព្រោះថាក្នុងផ្លូវទាំង ៣ សង្ខតធម៌ណាមួយ ឬអសង្ខតធម៌ ផុតចាកផ្លូវទៅហើយដែលមិនឃើញ មិនពិចារណា មិនត្រិះរិះ មិនយល់ មិនជាក់ច្បាស់ មិន

មានដល់ព្រះសម្មាសម្ពុទ្ធទាំងឡាយឡើយ ដោយហេតុនោះ ពាក្យសួរដើម្បីជាក់ច្បាស់ក្នុងវត្ថុដែលមិនឃើញ មិនមានដល់ព្រះសម្ពុទ្ធទាំងនោះឡើយ ការប្រៀបធៀបជាមួយនឹងសមណៈ ឬព្រាហ្មណ៍ ទេវតា មារ ព្រហ្មដទៃនៃសន្ធតធម៌ និងអសន្ធតធម៌ ដែលព្រះសម្មាសម្ពុទ្ធទាំងនោះទ្រង់ចាក់ធ្លុះហើយដោយញាណរៀងៗ ខ្លួនមិនមាន ដោយហេតុនោះ សូម្បីសួរដើម្បីប្រៀបធៀបក្នុងវត្ថុដែលឃើញហើយ ទើបមិនមានដល់ព្រះសម្មាសម្ពុទ្ធទាំងនោះ ។ ព្រោះព្រះមានព្រះភាគដ៏ជាពុទ្ធៈទាំងឡាយ មិនមានសន្ទិះសង្ស័យ ធ្លងផុតវិចិកិច្ឆា ប្រាសចាកសេចក្តីសង្ស័យក្នុងធម៌ទាំងនោះ ដូច្នោះ ទើបពាក្យសួរដើម្បីកម្ចាត់សេចក្តីសង្ស័យ មិនមានដល់ព្រះសម្ពុទ្ធទាំងនោះ ។ ឯពាក្យសួរ ២ ទៀតនោះ មានក្នុងពាក្យសួរ២នោះ គប្បីជ្រាបថា ពាក្យនេះ សំដៅដល់កថេតុកម្យតាបុច្ឆា ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលទ្រង់ត្រាស់សួរដោយពាក្យនោះ ដោយសរុប ទើបត្រាស់ព្រះតម្រាស់ជាដើមថា **លោភំ ភិក្ខវេ ឯកធម្មំ** ដូច្នេះ ។

ក្នុងបទថា **លោភំ** នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **លោភ** ដោយអត្ថថា ជាគ្រឿងចង់បាន ឬចង់បានឯង ឬត្រឹមតែចង់បានប៉ុណ្ណោះ គប្បីឃើញថា មានលក្ខណៈទាញយកនូវអារម្មណ៍ ដូចស្វាជាប់ជ័រព្រោះមានការជាប់ស្អិតក្នុងអារម្មណ៍ជាកិច្ច ដូចដុំសាច់ដែលគេដាក់ក្នុងអំបែងក្តៅ មានការមិនបរិច្ចាគជាផល ដូចពណ៌នៃប្រេង និងថ្នាំបន្តក់ភ្នែក មាន

ទស្សនៈក្នុងការត្រេកអរក្នុងធម៌ជាគ្រឿងចងចាក់ ជាទីប្រកាន់ ជាហេតុជិត កើតឡើង ចម្រើនផុសឡើង ដូចស្ទឹង គឺតណ្ហា បក់នាំសត្វទៅអបាយ ដូចស្ទឹងមានក្រសែហូរខ្លួលខ្លាញ់ កួចនាំសត្វទៅកាន់មហាសមុទ្រ ដូច្នោះ **លោភ** សព្ទនេះ ជាពាក្យសាមញ្ញ ដែលពោលដោយការលោភទាំងពួងក៏ពិតមែន ហើយ តែក្នុងទីនេះ គប្បីជ្រាបថា ជាពាក្យដែលពោលដោយតម្រេកក្នុងកាម ព្រោះសេចក្ដីលោភនោះ ត្រូវអនាគាមិមគ្គសម្លាប់ ។

បទថា **ភិក្ខវេ** នេះ ជាពាក្យហៅដើម្បីឲ្យភិក្ខុដែលបែរមុខទទួលធម៌ កើតនូវការយកចិត្តទុកដាក់ក្នុងធម៌នោះ ។

ព្រះមានព្រះភាគ ទ្រង់ដាក់គោលនៃការសម្រេចបហាន ដោយបទថា **បជហាថ** នេះ ម្យ៉ាងទៀត ការសម្រេចបហាននេះ រមែងប្រព្រឹត្តទៅ ដោយការសម្រេចបរិញ្ញា សច្ឆិកិរិយា និងភាវនាមិនបែកគ្នាឡើយ ។ ឈ្មោះថា លោកចាត់កិច្ចនៃសម្មាទិដ្ឋិ ៤ យ៉ាងចូលក្នុងអរិយសច្ច ៤ នោះឯង ម្យ៉ាងទៀត កាលព្រះមានព្រះភាគត្រាស់ថា ពួកអ្នកលះលោភៈ ដូច្នេះ ឈ្មោះថា ត្រាស់ដល់ការលះទោសៈជាដើមផងដែរ ព្រោះមានភាពតែមួយ ដូចគ្នានឹងបហាន ដោយអត្ថ យ៉ាងណា កាលព្រះមានព្រះភាគដល់នូវការសម្រេចបហាន ដែលជាកិច្ចនៃសម្មាទិដ្ឋិ ដែលជាលក្ខណៈនៃសមុទយសច្ចក៏ដូច្នោះ ឈ្មោះថា ទ្រង់ត្រាស់ដល់លក្ខណៈ និងកិច្ចរបស់សមុទយៈ សូម្បីនៃអដ្ឋង្គមគ្គដ៏សេស មានសម្មាសង្កប្បជាដើម ដែលជាហេតុធ្វើរួមគ្នានៃសម្មាទិដ្ឋិនោះឯង ព្រោះហេតុនោះ គប្បីឃើញថា ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ដល់ការខ្វល់ខ្វាយក្នុង

អរិយមគ្គដែលគ្រប់គ្រាន់ហើយ ។ ភាពដែលលោកពោលដល់ការខ្វល់ខ្វាយក្នុងពោធិបក្ខិយធម៌ មានសតិប្បដ្ឋានជាដើមក្នុងទីនេះ រមែងមានដោយន័យនេះ ។ គប្បីឲ្យពិស្តារតាមសមគួរ ។

ម្យ៉ាងទៀត ក្នុងសូត្រនេះ លោកពោលដល់បហានប្បរិញ្ញា គឺកំណត់ដឹងដោយការលះ ដោយបទថា **បជហាធ** នេះ ដែលលោកត្រាស់ដឹងបរិញ្ញាទាំង ៣ ដោយភាពជាអធិដ្ឋាន គឺបហានប្បរិញ្ញានោះ មានតីរណប្បរិញ្ញាជាអធិដ្ឋាន ឯតីរណប្បរិញ្ញានោះ មានញាតប្បរិញ្ញាជាអធិដ្ឋាន ។ ក្នុងទីនេះគប្បីឃើញយ៉ាងនេះថា លោកប្រកាសធ្វើចតុសច្ចកម្មដ្ឋានឲ្យបរិបូណ៌ មួយអន្ទើដោយផល ។ ម្យ៉ាងទៀត លោកសម្តែងញាណទស្សនវិសុទ្ធិ មួយអន្ទើដោយផល ។ ឯញាណទស្សនវិសុទ្ធិនោះ មានបដិបទាញាណទស្សនវិសុទ្ធិជាទីអាស្រ័យ ។បេ។ ចិត្តវិសុទ្ធិ មានសីលវិសុទ្ធិជាទីអាស្រ័យ ព្រោះហេតុនោះ គប្បីជ្រាបថា លោកសម្តែងវិសុទ្ធិ ៧ មួយអន្ទើដោយផល ដោយភាពដែលមានលំដាប់ផ្សេងៗ គ្នា ។ ដែលបុគ្គលបំណងនឹងលះលោកៈ ដោយការបំពេញបរិញ្ញា ៣ ដើម្បីបំពេញនូវបរិសុទ្ធនេះ គប្បីពិចារណាដល់ទោសរបស់សេចក្តីលោក ហើយបដិបត្តិដើម្បីលះសេចក្តីលោកនោះ ដោយន័យផ្សេងៗ តាមបែបព្រះសូត្រ មានជាដើមយ៉ាងនេះថា

លោកៈ ជាធម៌ញុំាងសេចក្តីវិនាសឲ្យកើត លោកៈ ជាធម៌ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះឡើយ ។ បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍ បុគ្គល

អ្នកលោក រមែងមិនឃើញធម៌ សេចក្ដីលោភ គ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកម្លាំង ក៏កើតឡើងក្នុងកាលនោះ ។

បុគ្គលដែលត្រូវរាគៈគ្របសង្កត់ មានចិត្តប្រកាន់ហើយ រមែងសម្លាប់សត្វខ្លះ លួចទ្រព្យខ្លះ កាត់នូវទី-តខ្លះ ប្លន់ស្រុកខ្លះ ប្លន់មនុស្សក្នុងផ្ទះមួយខ្លះ ធ្លាក់នៅក្នុងអន្តរាយខ្លះ ល្មើសនឹងភរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ តណ្ហានោះ កាលសមណព្រាហ្មណ៍ធ្វើឲ្យបម្រើន មិនដឹង មិនឃើញ មិនយល់ ធ្លាក់នៅក្នុងតណ្ហា ក៏ធ្វើឲ្យតក់ស្លុតបានដូចគ្នា ដូចលោកពោលនៅក្នុងឥតិវុត្តកៈនេះថា ។

បុរសមានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារ អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ដ ដែលមានសភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ... ។

និងពោលក្នុងធម្មបទថា ភ្លើង ស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ... ។

និងពោលក្នុងសំយុត្តនិកាយសគាថវគ្គថា ខ្ញុំក្ដៅដោយកាមរាគៈ ចិត្តរបស់ខ្ញុំក្ដៅក្រហាយណាស់ ... ។

និងដូចលោកបានពោលក្នុងធម្មបទថា ជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួន ចុះកាន់សំណាញ់ ដែលធ្វើហើយដោយខ្លួនឯង ដូច្នោះ ។

ម្យ៉ាងទៀត ធម៌ទាំងឡាយ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមរាគៈបាន គឺកាន់យកអសុភនិមិត្ត ១ ការបំពេញអសុភភាវនា ១ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ការស្គាល់ប្រមាណក្នុងភោជន ១ ការគប់មិត្តល្អ ១ ការសន្ទនាជាទីសប្បាយ ១ ។ ពិតហើយ កាលកាន់យកអសុកនិមិត្ត ១០ ក៏លះកាមរាគៈបាន កាលខ្វល់ខ្វាយបំពេញអសុភភាវនាក្នុងអសុភដែលមានវិញ្ញាណ ដោយការចម្រើនកាយគតាសតិ ក្នុងអសុភដែលឥតវិញ្ញាណ ដោយពិចារណាសាកសព ដែលហើមប៉ោងជាដើម ក៏លះកាមរាគៈបាន សូម្បីបិទទ្វារដោយទ្វារ គឺសតិ ដោយសង្រួមក្នុងឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ក៏លះកាមរាគៈបាន កាលមានឱកាសលេបបាយ ៤-៥ ពំនូតទៀតនឹងឆ្អែត ហើយឈប់ ផឹកទឹកបន្ថែម ដឹងប្រមាណក្នុងភោជន ត្រឹមតែដើម្បីឲ្យជីវិតបានប្រព្រឹត្តទៅតាមប្រក្រតី ក៏លះកាមរាគៈបាន សមដូចលោកពោលក្នុងថេរគាថាថា

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត )
ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ
នៃភិក្ខុអ្នកមានចិត្តស្ងប់ ទៅរក ( ព្រះនិព្វាន ) ។

សូម្បីការគប់រកកល្យាណមិត្រ ដែលជាអ្នកត្រេកអរក្នុងការចម្រើនអសុភកម្មដ្ឋាន ក៏លះកាមរាគៈបាន ក្នុងការសន្ទនាជាទីសប្បាយដល់រឿងអសុភ ១០ ក៏លះកាមរាគៈបាន សមដូចព្រះតម្រាស់ត្រាស់នៅក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ មានតែអសុភនិមិត្ត និងការធ្វើ

នូវយោនិសោមនសិការឲ្យច្រើន ក្នុងអសុភនិមិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់កាមច្ឆន្ទៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់កាមច្ឆន្ទៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។ ភិក្ខុបដិបត្តិដើម្បីលះលោភៈដែលបានដល់កាមរាគៈ ក្នុងចំណែកខាងដើមយ៉ាងនេះ ខ្វល់ខ្វាយវិបស្សនារមែងកាត់នូវលោភៈនោះដោយតតិយមគ្គ មិនមានសេសសល់ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **លោភំ ភិក្ខវេ ឯកធម្មំ បជហថ អហំ វោ បាដិភោគោ អនាគាមិតាយ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះបង់ធម៌ ១ គឺលោភៈ តថាគតជាអ្នកធានាដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។

ក្នុងសេចក្តីនេះ គេចិអាចារ្យពោលថា លោភៈដែលលះក្នុងសូត្រនេះដូចម្តេច ជាលោភៈក្នុងអតីត ឬអនាគត ឬបច្ចុប្បន្ន ។ ពិតហើយ លោភៈក្នុងសូត្រនេះ គប្បីលះ មិនមែនអតីត មិនមែនអនាគត ព្រោះមិនមានក្នុងអតីត និងអនាគតទាំងនោះ ។ លោកពោលថា សេចក្តីពិត ចិត្តរលត់ហើយ ឬមិនកើតមិនមាន ម្យ៉ាងទៀត សេចក្តីព្យាយាម ក៏មិនមានផល តែងបានទទួល ដូច្នោះ ត្រូវជាលោភៈបច្ចុប្បន្នដោយប្រការយ៉ាងនេះ សេចក្តីព្យាយាមមិនមានផល មគ្គភាវនាសៅហ្មង រមែងបានទទួល ព្រោះសេចក្តីព្យាយាមបានរលាយទៅហើយ ម្យ៉ាងទៀត លោភៈដែលប្រាសចាកចិត្តគប្បីមានន័យនេះ លោកបដិសេធហើយ ។ គួរពោលថា សេចក្តីលោភដែលជាអតីត អនាគត និងបច្ចុប្បន្នលះបានដោយន័យដែលពោលហើយ ។ ដូច

*ដើមឈើតូច ដែលមិនទាន់មានផ្លែ បុរសគប្បីយកចបកាប់ដើមឈើនោះត្រង់គល់ កាលមិនមានកាប់ដើមឈើ ផ្លែណាគប្បីកើត ផ្លែទាំងនោះ ក៏មិនទាន់កើត ព្រោះដើមឈើត្រូវកាប់ និងគប្បីកើតមិនបាន យ៉ាងណា កាលសម្រេចអរិយមគ្គ សេចក្តីលោភដែលគួរកើត រមែងមិនកើត ព្រោះត្រូវកម្ចាត់ក្នុងបច្ចុប្បន្ន ដោយសម្រេចអរិយមគ្គ ។ សេចក្តីលោភនេះ លោកពោលនៅក្នុងអដ្ឋកថាថា កើតព្រោះបានភូមិ ។ ពិតហើយ បញ្ចក្ខន្ធដែលជាអារម្មណ៍វិបស្សនា ឈ្មោះថា ភូមិ ព្រោះជាឋានៈឲ្យកើតសេចក្តីលោភនោះ ។ លោកអធិប្បាយសេចក្តីនេះថា សេចក្តីលោភកើតព្រោះបានភូមិ ដូចដែលនឹងពោលថា* **សា ភូមិ តេន លទ្ធា** *ភូមិនោះ ដែលសេចក្តីលោកបានហើយ ១ កើតព្រោះកាន់យកអារម្មណ៍ ១ កើតព្រោះមិនសង្កត់សង្កិន ១ កើតព្រោះមិនដក ១ ។*

*បទថា* **តត្ថ** *គឺក្នុងសូត្រនោះ ។ ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ ១ សូត្រ ដោយចងជាគាថា ។ សួរថា អ្នកណាពោល ឆ្លើយថា ព្រះមានព្រះភាគ ក្នុងឋានៈដទៃបែបនោះ ព្រះសង្គីតិកាចារ្យជាអ្នកចងគាថា ។ តែក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់កាន់យកភាពដែលព្រះអង្គត្រាស់ដោយអជ្ឈាស្រ័យរបស់បុគ្គល ដែលពេញចិត្តគាថា ទើបត្រាស់ជាគាថា ។*

*ក្នុងបទគាថានោះថា* **យេន លោភេន លុទ្ធាសេ សត្តា គច្ឆន្តិ ទុគ្គតឹ** *សត្វទាំងឡាយ លោភហើយដោយសេចក្តីលោភណា រមែងទៅកាន់ទុគ្គតិ អធិប្បាយថា សត្វទាំងឡាយលោភដោយសេចក្តីលោភណា ដែលមានលក្ខណៈ*

តោងនូវអារម្មណ៍ មានកិច្ចជាប់ជំពាក់ តែការលោកនោះ គឺចង់បាន តែងចង ក្នុងអាយតនៈខាងក្នុង និងខាងក្រៅ ។ បទថា **សេ** ត្រឹមតែជានិបាត ។ ឯ អ្នកគិតអក្ខរៈទាំងឡាយ ត្រូវចុះ **សេ** អក្ខរៈ ក្នុងឋានៈបែបនេះ ។ សត្វ មិនប្រព្រឹត្តសុចរិតណាមួយ ក្នុងកាយសុចរិតជាដើម ព្រោះជាសេចក្តីលោភ តែម្យ៉ាងប៉ុណ្ណោះ សន្សំនូវកាយទុច្ចរិតជាដើម បានឈ្មោះថា **សត្វ** ព្រោះជា អ្នកជាប់ជំពាក់ក្នុងរូបជាដើម រមែងចូលដល់នរក តិរច្ឆាន បិត្តិវិស័យ ដែល បានឈ្មោះថា **ទុគ្គតិ** ព្រោះជាទីឲ្យកើតទុក្ខដោយអំណាចបដិសន្ធិ ។

បទថា **តំ លោកំ សម្មទញ្ញាយ បជហន្តិ វិបស្សិនោ** សេចក្តីថា ជន ឃើញច្បាស់ទាំងឡាយ ដឹងច្បាស់ដោយល្អនូវសេចក្តីលោភនោះ រមែងលះ បាន អធិប្បាយថា ជនឈ្មោះថា ជាអ្នកឃើញច្បាស់ ព្រោះឃើញឧបាទា-នក្ខន្ធ ៥ មានរូបជាដើម ដោយអាការច្រើនយ៉ាង មានការមិនទៀងជាដើម ដឹង នូវលោភៈតាមដែលពោលហើយនេះ ដោយប្រពៃតាមហេតុ ដោយញាណ ដែលមិនវិបរិត ដោយអាការទាំងនេះ គឺដោយសេចក្តីពិត ដោយការកើត ដោយការរលត់ ដោយការសរសើរ ដោយភាពជាទោស ដោយការចេញទៅ គឺដឹងដោយបញ្ញា ដែលបានដល់ ញាតបរិញ្ញា តីរណបរិញ្ញា រមែងលះនូវ កិលេសដ៏សេស ដោយមគ្គបញ្ញា ដែលជាចំណែកខាងដើមរបស់វិបស្សនា-បញ្ញា ដោយសមុច្ឆេទប្បហាន គឺមិនឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួនទៀត ឡើយ ។

បទថា **បហាយ ន បុនាយន្តិ ឥមំ លោកំ កុទាចនំ** កាលលះបាន

ហើយ រមែងមិនមកកាន់លោកនេះក្នុងកាលណាមួយឡើយ សេចក្ដីថា កាលលះលោភៈនោះ និងកិលេសដ៏សេស មួយអន្លើដោយកិលេសដែលសំខាន់លះបានហើយ នៅសេសសល់ ១ ដោយអនាគាមិមគ្គ រមែងមិនមកកាន់លោក ដែលបានដល់ កាមធាតុនេះក្នុងកាលខាងក្រោយទៀត ដោយការកាន់យកបដិសន្ធិ សូម្បីក្នុងកាលណាឡើយ ព្រោះលះឱរម្ភាគិយសំយោជនៈបានស្រេចបាច់ហើយ ។ ទើបព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនា ដោយអនាគាមិផល ដោយប្រការដូច្នេះ ។

បទថា **អយម្បិ អត្ថោ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ប្រកាសសេចក្ដីដោយព្រះសូត្រនេះ តាំងអំពីនិទានចុងក្រោយ រហូតដល់ចប់គាថា ។ **អបិ** សព្ទ ជាសព្ទប្រមូលសេចក្ដីក្នុងព្រះសូត្រ ដែលនឹងពោលក្នុងឥឡូវនេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

សមុទយសច្ច មកក្នុងព្រះសូត្រនេះដោយសរុប ។ មគ្គសច្ច មកដោយចំណែករបស់បហាន សច្ចៈ ២ ក្រៅអំពីនោះ គប្បីលើកចេញទៅ ព្រោះសច្ចៈទាំង ២ នោះជាហេតុ ។ ទុក្ខសច្ច សមុទយសច្ច រមែងជាក់ច្បាស់តាមដែលពោលហើយ ក្នុងគាថានោះឯង សច្ចៈក្រៅអំពីនោះលើកចេញទៅ ។ ក្នុងសូត្រដទៃ ក្រៅអំពីនេះក៏ន័យនេះ ។៚

**អដ្ឋកថា លោភសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទោសសូត្រ

[ ២ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូច ម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺទោសៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះ ភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រទូស្តហើយ ព្រោះទោសៈណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់ទោសៈនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត
ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ទោសសូត្រ

[ ២ ] សូត្រទី ២ មានបទផ្ដើមថា **វុត្តំ ហេតំ ។បេ។ ទោសំ** ដូច្នេះ ។ ក្នុងសូត្រទី ២ នោះ មានកិច្ចពណ៌នាបទតាមលំដាប់ដូច្នេះ ។ យើងពណ៌នាបទ ទៅតាមលំដាប់សូត្រទាំងពួង សូម្បីដទៃក្រៅអំពីសូត្រនេះ តែម្យ៉ាងជាមួយនឹងសូត្រនេះ ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់បុគ្គលដែលច្រើនដោយទោសៈ ទើបទ្រង់សម្ដែងព្រះសូត្រនេះ ដើម្បីរម្ងាប់ទោសៈ ដូច្នោះ ទើបត្រាស់ថា **ទោសំ ភិក្ខវេ ឯកធម្មំ បជហថ** ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយលះបង់ធម៌ ១ គឺទោសៈ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទោសំ** បានដល់ ការអាឃាត ដែលកើតអំពីអាឃាតវត្ថុ ១៨ យ៉ាង គឺ ៩ យ៉ាង លោកពោលក្នុងព្រះសូត្រ ដោយន័យជាដើមថា **អនត្ថំ មេ អចរីតិ អាឃាតោ ជាយតិ** អាឃាតរមែងកើតឡើងថា បុគ្គលនោះបានប្រព្រឹត្តសេចក្ដីវិនាសដល់អញ ដូច្នេះ និង ៩ យ៉ាង ដែលផ្ទុយគ្នានឹងខាងដើមថា **អត្ថំ មេ នាចរិ** គេមិនប្រព្រឹត្តវត្ថុដែលជាប្រយោជន៍ដល់អញ ដូច្នេះ និងវត្ថុដែលមិនមែនឋានៈ មានដង្គត់ និងបន្លាជាដើម រួមជា ១៩ យ៉ាងឯណានីមួយ ។ អាឃាតនោះ លោកពោលថាជាទោសៈ ព្រោះអត្ថថា ជាហេតុប្រទូស្ត ឬចាប់ផ្ដើមប្រទូស្តឯង ឬត្រឹមតែគិតប្រទូស្តប៉ុណ្ណោះ ទោសៈនោះគប្បីឃើញថា មានការកាចជាលក្ខណៈ ដូចពស់ដែលត្រូវវាយ គប្បីឃើញថា មានការជ្រួតជ្រាបទៅ ដូចត្រូវថ្នាំពិស

គប្បីឃើញថា មានការជុតទីអាស្រ័យរបស់ខ្លួនជាកិច្ច ដូចភ្លើងឆេះព្រៃ គប្បីឃើញថា មានការប្រទូស្ត ដូចសត្រូវបានឱកាសហើយ គប្បីឃើញថា មានអាឃាតវត្ថុជាបទដ្ឋាន តាមដែលពោលហើយ ដូចរបស់ផ្អូម និងទឹកមូត្រដែលគេចោលហើយ ។ បទថា **បជហាថ** បានដល់ ចូរពួកអ្នកកាត់ផ្តាច់ ។

ព្រះមានព្រះភាគ ត្រាស់អាឃាតបដិវិន័យ គឺការដោះនូវអាឃាត ៥ យ៉ាងក្នុងអង្គុត្តរនិកាយ បញ្ចកនិបាតយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិ-វិន័យនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនមេត្តាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនករុណាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនឧបេក្ខាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវប្រតិបត្តិនូវការមិនធ្វើទុកក្នុងចិត្ត ដោយស្មារតីចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវ

កម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាល ភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវតាំងទុកនូវ ភាពនៃខ្លួនជាអ្នកមានកម្មជារបស់ខ្លួន ចំពោះបុគ្គលនោះថា អ្នក នេះមានកម្មជារបស់ខ្លួន ជាអ្នកទទួលយកនូវកម្ម មានកម្មជា កំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់ អ្នកនេះនឹងធ្វើ កម្មណា ទោះល្អក្តី អាក្រក់ក្តី គង់អ្នកនោះ ទទួលយកកម្មនោះ ពុំខានឡើយ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយ ប្រការយ៉ាងនេះ ១ ដូច្នេះ ។

លោកពោលអាឃាតប្បដិវិន័យ ៥ ដោយន័យជាដើមយ៉ាងនេះទៀតថា នែអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិ-វិន័យនេះ មាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាល អាវុសោទាំងឡាយ ក្នុងលោកនេះ មានបុគ្គលខ្លះ ជាអ្នកមានការ ប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចា ដ៏បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពី បុគ្គលមានសភាពយ៉ាងនេះចេញ ១ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះសាស្តា ទ្រង់ប្រៀនប្រដៅទុកក្នុងកកចូបមសូត្រថា ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់នាំគ្នាអារ អវយវៈតូចធំរបស់អ្នកទាំងឡាយដោយរណារ ដែលមានដងទាំង

សងខាង ភិក្ខុណាមួយ ញុាំងចិត្តឲ្យប្រទូស្តចំពោះចោរទាំង អម្បាលនោះ ភិក្ខុនោះ មិនឈ្មោះថា ជាអ្នកធ្វើតាមសាសនា របស់តថាគត ដោយការមិនអត់សង្កត់នោះឡើយ ដូច្នេះ ។ ព្រោះថា អ្នកណាក្រោធតបបុគ្គលដែលក្រោធហើយ អ្នកនោះ ឯង នឹងមានសេចក្តីអាក្រក់ ព្រោះសេចក្តីក្រោធនោះឯង ឯ បុគ្គលមិនក្រោធតបនឹងអ្នកដែលក្រោធ រមែងឈ្នះសង្គ្រាម ដែល គេឈ្នះបានដោយក្រ អ្នកណាដឹងថា អ្នកដទៃក្រោធនឹងខ្លួន ជា អ្នកមានស្មារតីរម្ងាប់សេចក្តីក្រោធបាន អ្នកនោះឈ្មោះថា ប្រព្រឹត្ត នូវប្រយោជន៍ ដល់ជនទាំង ២ នាក់ គឺខ្លួន និងអ្នកដទៃ ។

និងដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយសត្តកនិបាតថា

ម្នាលភិក្ខុទាំងឡាយ ធម៌ ៧ យ៉ាងនេះ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាព ដែលមាន សេចក្តីក្រោធ ។ ធម៌ ៧ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ សត្រូវក្នុងលោកនេះ រមែងប្រាថ្នានូវហេតុយ៉ាងនេះដល់ សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ មានវណ្ណៈអាក្រក់ ។ រឿង នោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិន ត្រេកអរដល់សត្រូវ ព្រោះវណ្ណៈទេ ម្នាលភិក្ខុទាំងឡាយ បុរស បុគ្គលនេះ ( កាលបើ ) មានសេចក្តីក្រោធ មានសេចក្តីក្រោធ គ្របសង្កត់ មានសេចក្តី ក្រោធរួបរឹតហើយ បុរសបុគ្គលនោះ ទុក

ជាដូតស្អាត លាប ស្រឡាបល្អ បានកោរសក់ និងពុកមាត់ ហើយស្លៀកសំពត់ មានពណ៌សក៏មែនពិតហើយ ប៉ុន្តែ បុរសបុគ្គលនោះ ឈ្មោះថា មានវណ្ណៈអាក្រក់ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម៌ទី ១ ជាទីត្រេកអរនៃសត្រូវ ជាហេតុនៃសត្រូវ រមែងមកកាន់ស្ត្រីភាព ឬបុរិសភាពដែលមានសេចក្តីក្រោធ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នានូវហេតុយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះដេកជាទុក្ខ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះ ដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានប្រយោជន៍ច្រើនឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានភោគៈឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានយសឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ កុំមានមិត្តឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សត្រូវរមែងប្រាថ្នាយ៉ាងនេះដល់សត្រូវថា ឱហ្ន៎ សូមឲ្យបុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ គប្បីចូលទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ រឿងនោះ

ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងមិនត្រេកអរ ដល់សត្រូវ ដោយដំណើរទៅកាន់សុគតិទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែបុរសបុគ្គលនេះ មានសេចក្តីក្រោធ មានសេចក្តីក្រោធគ្រប សង្កត់ មានសេចក្តីក្រោធរួបរឹតហើយ ក៏ប្រព្រឹត្តទុច្ចរិត ដោយ កាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ។ លុះបុគ្គលដែលមានសេចក្តីក្រោធគ្របសង្កត់នោះ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយ ចិត្តហើយ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។ បុគ្គលអ្នកក្រោធ មិនដឹងនូវ សេចក្តីចម្រើន បុគ្គលអ្នកក្រោធមិន ឃើញនូវធម៌ ។បេ។ និងដូចព្រះតម្រាស់ក្នុងគម្ពីរផ្សេងៗ ទៀតថា បុគ្គលគួរលះបង់ សេចក្តីក្រោធចេញ គួរលះបង់មានះចេញ គួរកន្លងសញ្ញោជន-ធម៌ទាំងអស់ចោលចេញ ។បេ។ សេចក្តីក្រោធជាហេតុឲ្យកើត សេចក្តីវិនាស សេចក្តីក្រោធជាហេតុញ៉ាំងចិត្តកម្រើក ។បេ។ បុគ្គលកាត់បង់នូវសេចក្តីក្រោធ ទើបដេកជាសុខ បុគ្គលកាត់បង់ នូវសេចក្តីក្រោធ ទើបមិនសោយសោក ម្នាលព្រាហ្មណ៍ ពួក ព្រះអរិយៈ តែងសរសើរនូវការសម្លាប់សេចក្តីក្រោធ ដែលមាន ឫសជាពិស មានចុងដ៏ផ្អែម ព្រោះថា បុគ្គលកាត់បង់នូវសេចក្តី ក្រោធនោះបានហើយ ទើបមិនសោយសោក ។

បុគ្គលមានបញ្ញាដូចផែនដី ចូរវៀរទោសចេញ បណ្ឌិតទាំងឡាយ

មិនមានសេចក្តីក្រោធជាកម្លាំងឡើយ ។

ការទូន្មានភិក្ខុទាំងនោះ ក្នុងសេចក្តីនោះថា ចូរអ្នកទាំងឡាយពិចារណាដល់ទោសក្នុងទោសៈ និងអានិសង្សក្នុងការលះទោសៈដោយផ្សុយគ្នា ដូចបានពោលហើយដោយន័យជាដើមយ៉ាងនេះ ដោយប្រការដូច្នេះហើយ ចូរលះទោសៈក្នុងចំណែកខាងដើម ដោយតទង្គប្បហានជាដើម ហើយគប្បីខ្វល់ខ្វាយ ញុំាងវិបស្សនាឲ្យកើត ចូរកាត់ផ្តាច់ ចូរលះនូវទោសៈដោយតតិយមគ្គឲ្យអស់ទៅ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ទោសំ ភិក្ខវេ ឯកធម្មំ បជហថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺទោសៈ ដូច្នេះ ។

បទថា **ទុដ្ឋាសេ** បានដល់ ប្រទូស្ត ព្រោះមានចិត្តប្រទូស្តដោយអាឃាត បទដ៏សេសដែលគួរពោលក្នុងសូត្រទី ២ នេះ មានន័យដូចពោលហើយក្នុងអដ្ឋកថាសូត្រទី ១ នោះឯង ។

## ទោសសូត្រទី ២ ចប់

# សុត្តន្តបិដក

## មោហសូត្រ

[ ៣ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺមោហៈ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ វង្វេងហើយ ព្រោះមោហៈណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់មោហៈនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះទៀត
ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## មោហសូត្រ

*មោហសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ៣ ] បទថា* **មោហំ** *បានដល់ ការមិនដឹង ។ ពិតហើយ ការមិនដឹងនោះ មានប្រភេទច្រើនយ៉ាង វិភាគដោយន័យជាដើមថា ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងហេតុឲ្យកើតទុក្ខ ការមិនដឹងក្នុងការរម្ងត់ទុក្ខ ការមិនដឹងក្នុងបដិបទាឲ្យដល់នូវការរម្ងត់ទុក្ខ លោកពោលថា* **មោហៈ** *ព្រោះអត្ថថាជាហេតុឲ្យវង្វេង ឬវង្វេងទៅឯង ឬត្រឹមតែជាការវង្វេងប៉ុណ្ណោះ ។ គប្បីឃើញថា មោហៈនោះ មានភាពដែលចិត្តងងឹតជាលក្ខណៈ ឬមានការមិនដឹងជាលក្ខណៈ មានការមិនចាក់ធ្លុះជាកិច្ច ឬមានការបិទបាំងសភាវៈអារម្មណ៍ជាកិច្ច មានកិច្ចបដិបត្តិខុសជាអាការប្រាកដ ឬមានការងងឹតជាអាការប្រាកដ មានអយោនិសោមនសិការជាបទដ្ឋាន ជាឫសគល់នៃអកុសលទាំងពួង ។*

*ឥឡូវនេះ គប្បីឃើញសេចក្តីនៃបទថា* **បជហាថ** *ដូច្នេះថា*

*ជនអ្នកវង្វេង រមែងមិនស្គាល់ប្រយោជន៍ ជនអ្នកវង្វេង រមែងមិនឃើញធម៌ មោហៈគ្របសង្កត់នរជន ក្នុងកាលណា សេចក្តីងងឹតដ៏មានកម្លាំង ក៏កើតឡើងក្នុងកាលនោះ ... ។*

*មោហៈជាហេតុឲ្យកើតសេចក្តីវិនាស មោហៈជាហេតុញ៉ាំងចិត្តកម្រើក ។បេ។*

*ម្នាលភិក្ខុទាំងឡាយ អវិជ្ជាជាប្រធានដើម្បីចូលប្រទះ នូវអកុសលធម៌ទាំងឡាយ ... ។*

សត្វលោកមានមោហៈជាចំណង ប្រាកដដូចជាមានរូបចម្រើន...។ ម្នាលភិក្ខុទាំងឡាយ កម្មណា ដែលបុគ្គលធ្វើដោយមោហៈ កើតអំពីមោហៈ មានមោហៈជាហេតុ មានមោហៈជាបច្ច័យ អត្តភាពរបស់បុគ្គលនោះ កើតក្នុងទីណា កម្មនោះ រមែងឲ្យផលក្នុងទីនោះ ... ។

អ្នកទាំងឡាយ ចូរពិចារណាទោសក្នុងមោហៈ ដោយន័យជាដើមថា ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងត្រូវមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងជួបនូវភ័យ និងពៀរ សូម្បីក្នុងបច្ចុប្បន្ន រមែងជួបនូវភ័យ និងពៀរក្នុងភពខាងមុខ និងដោយន័យជាដើមថា ការវិនាសណាមួយ គប្បីកើតឡើងដោយធម៌សៅហ្មង មានកាមច្ឆន្ទៈជាដើម សេចក្តីវិនាសទាំងអស់នោះ មានមោហៈជាហេតុ និងអានិសង្សក្នុងការលះមោហៈ ដោយផ្ទុយគ្នានឹងទោសៈនោះ ហើយលះមោហៈ ដោយតទង្គៈជាដើម ក្នុងចំណែកខាងដើម ដោយលំដាប់ការលះកាមច្ឆន្ទៈជាដើមនោះឯង ចូរលះមោហៈ ដែលជានឹមរបស់លោកៈ និងទោសៈ តាមដែលពោលហើយ ដោយសមុច្ឆេទ ដោយអំណាចតតិយមគ្គ ។ ក្នុងព្រះសូត្រនេះ លោកបំណងយកមោហៈ ដែលអនាគាមិមគ្គគប្បីសម្លាប់នោះឯង ។

បទថា **មូឡ្ហាសេ** បានដល់ វង្វេងក្នុងប្រយោជន៍ និងមិនមែនប្រយោជន៍ មានកុសលអកុសល ទោស និងមិនមានទោសជាដើម បទដ៏សេសក៏មានន័យដូចពោលហើយនោះឯង ។៚

# សុត្តន្តបិដក

## កោធសូត្រ

[ ៤ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺសេចក្តីក្រោធ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ក្រោធហើយ ព្រោះសេចក្តីក្រោធណា
តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់សេចក្តីក្រោធ
នោះបាន លុះលះបង់បានហើយ មិនត្រឡប់មកកាន់
លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## កោធសូត្រ

*ក្នុងកោធសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ៤ ] បទថា* **កោធំ** *គឺ ទោសៈ ។ ព្រោះទោសៈនោះឯង លោកពោលយ៉ាងនេះ ដោយអធ្យាស្រ័យរបស់បុគ្គលដែលជាអ្នកដឹង ដោយបរិយាយរបស់កោធៈ ដូច្នោះ គប្បីជ្រាបសេចក្តីក្នុងសូត្រនេះ ដោយន័យដែលពោលហើយក្នុងសូត្រទី ២ នោះឯង ម្យ៉ាងទៀត គប្បីឃើញសេចក្តីក្រោធមានការអាក់អន់ជាលក្ខណៈ មានការធ្វើអាឃាតជាកិច្ច មានការវិបត្តិនៃចិត្តជាអាការប្រាកដ មានការស្អុយនៃចិត្តជាបទដ្ឋាន ។ គប្បីជ្រាបការផ្សេងគ្នាដូច្នេះ ។ល។*

**អដ្ឋកថា កោធសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## មក្ខសូត្រ

[ ៥ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូច ម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺសេចក្តី លុបគុណ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ លុះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុង សូត្រនោះថា

សត្វទាំងឡាយ លុបគុណហើយ ព្រោះសេចក្តីលុប
គុណណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នក
ឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះ
បង់សេចក្តីលុបគុណនោះបាន លុះលះបង់បានហើយ
រមែងមិនត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណា
ឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## មក្ខសូត្រ

ក្នុងមក្ខសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៥ ] បទថា **មក្ខំ** បានដល់ លុបគុណអ្នកដទៃ ។ ពិតហើយ បុគ្គលលុបគុណនោះ ដូចចាប់លាមក ហើយគ្រវែងអ្នកដទៃ កាយរបស់ខ្លួនរមែងប្រឡាក់មុន ដូច្នោះ លោកពោលថា ជាអ្នកលុបគុណអ្នកដទៃ ព្រោះធ្វើដូច្នោះ ដោយបំណងនឹងលុបគុណនៃអ្នកដទៃ ។ ជាការពិត បុគ្គលលុបគុណនោះ រមែងលុប គឺលាងនូវគុណនៃអ្នកដទៃឲ្យវិនាសទៅ ដូចសំពត់ជូតទឹក ជូតទឹកដែលជាប់ខ្លួនអ្នកងូត ដូច្នោះ ។ ពិតហើយ លោកពោលថា **មក្ខោ** ព្រោះទម្លាយ កម្ចាត់បង់នូវសក្ការៈធំ ដែលជាទីប្រាកដដល់មនុស្សពួកដទៃ ។ គប្បីឃើញថា អ្នកលុបគុណនោះ មានការលាងគុណអ្នកដទៃជាលក្ខណៈ មានការធ្វើឲ្យមនុស្សទាំងឡាយវិនាសជាកិច្ច មានការបិទបាំងគុណរបស់បុគ្គលដទៃជាអាការប្រាកដ តែដោយអត្ថ គប្បីឃើញថា បុគ្គលលុបនូវគុណ ជាអ្នកមានចិត្តប្បាទសហគតៈដោយទោមនស្ស ប្រព្រឹត្តទៅដោយអាការលុបលាងគុណរបស់អ្នកដទៃ ។ បទថា **បជហាថ** អធិប្បាយថា អ្នកទាំងឡាយ ចូរពិចារណាទោស មានប្រភេទដូចពោលហើយក្នុងមក្ខៈនោះ និងទោស មានន័យដូចពោលហើយក្នុងទោសៈ និងអានិសង្សក្នុងការលះទោសតាមដែលពោលនោះ ហើយលះដោយតទង្គៈជាដើម ក្នុងចំណែកខាងដើម ខ្វល់ខ្វាយឲ្យកើតវិបស្សនា ហើយលះមិនឲ្យមានចំណែកសេសសល់ ដោយតតិយមគ្គ ។

បទថា **មក្ខិតាសេ** បានដល់ ជាអ្នកលុបលាងគុណរបស់អ្នកដទៃ គឺធ្វើឲ្យជ្រះសេចក្តីល្អរបស់អ្នកដទៃ ។ អធិប្បាយថា ជាបុគ្គលកម្ចាត់នូវគុណរបស់ខ្លួន ចាកការដែលលុបលាងគុណរបស់អ្នកដទៃនោះផង ។ បទដ៏សេសមានន័យដូចពោលហើយនេះឯង ។៚

**អដ្ឋកថា មក្ខសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## មានសូត្រ

[ ៦ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ ចេញ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយ ជាអនាគាមី ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ធម៌ ១ គឺមានះ តថាគតជាអ្នកធានា ដើម្បីឲ្យអ្នកទាំងឡាយជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រកាន់ហើយ ព្រោះមានះណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់មានះនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះ

ទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## មានសូត្រ

ក្នុងមានសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦ ] បទថា **មានំ** បានដល់ មានចិត្តរឹងត្អឹងអាស្រ័យជាតិជាដើម ។ ព្រោះថា បុគ្គលមានចិត្តប៉ោងឡើងនោះ លោកពោលថា **មានោ** ជាអ្នកមានការប្រកាន់ខ្លួន ព្រោះអត្ថថា ជាហេតុធ្វើឲ្យសំខាន់ ដោយន័យជាដើមថា **សេយ្យោហមស្មិ** យើងជាបុគ្គលប្រសើរ ឬសម្គាល់ខ្លួនឯង ឬជាអ្នកលើកតម្កើងនូវការរាប់អាន មានះនោះមាន ៣ យ៉ាង គឺមានះថា អញជាបុគ្គលប្រសើរជាង ១ មានះថា អញជាបុគ្គលស្មើអ្នកដទៃ ១ មានះថា អញជាបុគ្គលអន់ ១ គប្បីឃើញមានះ មានការលើកតម្កើងខ្លួនជាលក្ខណៈ ៩ យ៉ាង គឺមានះថា អញជាអ្នកប្រសើរជាងអ្នកប្រសើរ ១ ស្មើគ្នានឹងបុគ្គលប្រសើរ ១ អន់ជាងបុគ្គលប្រសើរ ១ ប្រសើរជាងបុគ្គលស្មើ ១ ស្មើនឹងបុគ្គលស្មើ ១ អន់ជាងបុគ្គលស្មើ ១ ប្រសើរជាងបុគ្គលអន់ ១ ស្មើគ្នានឹងបុគ្គលអន់ ១ អន់ជាងបុគ្គលអន់ ១ មានការប្រកាន់ខ្លួនជាកិច្ច ឬមានការលើកតម្កើងជាកិច្ច

មានភាពប៉ោងឡើងជាអាការប្រាកដ ឬមានភាពជាំក្រៃលែងជាអាការប្រាកដ ដូចមនុស្សឆ្កួត មានលោកៈដែលប្រាសចាកទិដ្ឋិជាបទដ្ឋាន ។

បទថា **បជហថ** មានអធិប្បាយថា អ្នកទាំងឡាយ ចូរពិចារណាទោស មានប្រភេទជាដើមយ៉ាងនេះថា មានះទាំងអស់នោះ មានការលើកខ្លួន និង សង្កត់អ្នកដទៃជានិមិត្ត ជាហេតុ មិនធ្វើការថ្វាយបង្គំ ការទទួល អញ្ជលីកម្ម និងសាមីចិកម្មជាដើមក្នុងលោកអ្នកដែលនៅក្នុងឋានៈជាទីគោរព ជាហេតុឲ្យ ដល់នូវសេចក្តីប្រមាទ ដោយការស្រវឹងក្នុងជាតិ និងស្រវឹងក្នុងបុគ្គលជាដើម និងអានិសង្សនៃការមិនមានមានះ ដែលផ្ទុយគ្នានឹងទោសនោះ ហើយផ្តើមតាំង ចិត្តបង្អោនក្នុងសព្រហ្មចារីទាំងឡាយ ដូចចណ្ឌាលបុគ្គលចូលទៅកាន់រាជសភា ហើយលះនូវមានះនោះដោយតទង្គប្បហាន ក្នុងចំណែកខាងដើម ចម្រើន វិបស្សនា លះដោយអនាគាមិមគ្គ ។ ក្នុងសូត្រនេះ លោកបំណងយកមានះ ដែលអនាគាមិមគ្គគប្បីសម្លាប់ប៉ុណ្ណោះ ។

បទថា **មទ្ទាសេ** បានដល់ ជាអ្នកស្រវឹងដោយមានះ មានស្រវឹងក្នុង ជាតិ និងស្រវឹងក្នុងបុគ្គលជាដើម ដែលជាហេតុឲ្យដល់នូវសេចក្តីប្រមាទជា ដើម លើកតម្កើងខ្លួន ហើយស្រវឹង ។ បទដ៏សេសមានន័យដូចពោលហើយ នោះឯង ។

តែក្នុង ៦ សូត្រ ឬក្នុងគាថាទាំងឡាយតាមលំដាប់នេះ ព្រះមានព្រះភាគ ញុំាងភិក្ខុទាំងឡាយឲ្យដល់អនាគាមិផលហើយ ទើបបញ្ចប់ទេសនា ។

ក្នុងលោកអ្នកសម្រេចអនាគាមិផល បានជាព្រះអនាគាមី ៥ ដោយ

អំណាចភពដែលកើត គឺអវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ។ បណ្ដាព្រះអនាគាមី មាន ៥ លោកកើតក្នុងជាន់អវិហា ឈ្មោះថា អវិហា ។ លោកទាំងនោះមាន ៥ គឺអន្តរាបរិនិព្វាយី គឺលោកអ្នកបរិនិព្វានក្នុងចន្លោះមិនទាន់ដល់ពាក់កណ្ដាលអាយុ ១ ឧបហច្ចបរិនិព្វាយី គឺលោកអ្នកបរិនិព្វានលើសពីពាក់កណ្ដាលអាយុ ១ អសង្ខារបរិនិព្វាយី គឺលោកអ្នកបរិនិព្វានដោយមិនចាំបាច់ព្យាយាមខ្លាំងក្លា ១ សសង្ខារបរិនិព្វាយី គឺលោកអ្នកបរិនិព្វានដោយប្រើសេចក្ដីព្យាយាមខ្លាំងក្លា ១ ឧទ្ធំសោតោអកនិដ្ឋគាមី គឺលោកអ្នកមានក្រសែទៅខាងលើ គឺទៅកាន់អកនិដ្ឋក ១ ។ បុគ្គលដែលឈ្មោះថា អតប្បា សុទស្សា សុទស្សី ក៏ដូចគ្នាយ៉ាងនោះ តែលោកអ្នកដែលជាឧទ្ធំសោតោអកនិដ្ឋគាមី រមែងអស់អាយុក្នុងអកនិដ្ឋកភព ។

បណ្ដាព្រះអនាគាមីទាំង ៥ នោះ លោកអ្នកកើតក្នុងជាន់អវិហាជាដើមហើយបរិនិព្វាន ដោយការរម្ងត់កិលេស ដើម្បីសម្រេចអរហត្ត មិនលើសពីពាក់កណ្ដាលអាយុ ឈ្មោះថា អន្តរាបរិនិព្វាយី ។ លោកអ្នកបរិនិព្វានផុតពីពាក់កណ្ដាលអាយុ គឺ ៥០០ កប្ប ក្នុងជាន់អវិហាជាដើម ឈ្មោះថា ឧបហច្ចបរិនិព្វាយី ។ លោកអ្នកបរិនិព្វាន ដោយការរម្ងត់កិលេសដោយលំបាកតិចមិនចាំបាច់ធ្វើសេចក្ដីព្យាយាមខ្លាំងក្លា ឈ្មោះថា អសង្ខារបរិនិព្វាយី ។ លោកអ្នកបរិនិព្វានដោយសេចក្ដីលំបាក គឺត្រូវធ្វើសេចក្ដីព្យាយាមខ្លាំងក្លា ឈ្មោះថា សសង្ខារបរិនិព្វាយី ។ ឯលោកអ្នកដែលឈ្មោះថា ឧទ្ធំសោតោ ព្រោះមានក្រសែ គឺតណ្ហា និងក្រសែ គឺមគ្គខាងលើ ដោយកាន់យកខាងលើក្នុងជាន់

អវិហាជាដើម ។ ឈ្មោះថា អកនិដ្ឋគាមី ព្រោះមិនអាចកើតក្នុងអវិហាជាដើម ហើយសម្រេចអរហត្តបាន ទើបតាំងនៅក្នុងជាន់នោះ ដរាបដល់អស់អាយុ ហើយទើបទៅកាន់ជាន់អកនិដ្ឋា ដោយការកាន់យកបដិសន្ធិ ។

ក្នុងសូត្រនេះ គប្បីជ្រាបអកនិដ្ឋគាមី ៤ ពួក គឺឧទ្ធំសោតោអកនិដ្ឋគាមី ១ ឧទ្ធំសោតោនអកនិដ្ឋគាមី ១ អនុទ្ធំសោតោអកនិដ្ឋគាមី ១ នឧទ្ធំសោ-តោនអកនិដ្ឋគាមី ១ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា បុគ្គលដែលជម្រះទេវលោក តាំងអំពីជាន់អវិហា ហើយទៅកាន់ជាន់អកនិដ្ឋា ទើបបរិនិព្វាន ឈ្មោះថា ឧទ្ធំសោតោអកនិដ្ឋគាមី ។ លោកអ្នកជម្រះទេវលោក ៣ ហើយតាំងនៅក្នុងទេវលោកជាន់សុទស្សី ទើបបរិនិព្វាន ឈ្មោះថា ឧទ្ធំសោតោន-អកនិដ្ឋគាមី ។ លោកអ្នកទៅកាន់អកនិដ្ឋភព បន្ទាប់អំពីនោះឯង ឈ្មោះថា អនុទ្ធំសោតោអកនិដ្ឋគាមី ។ ឯបុគ្គលតាំងនៅក្នុងទេវលោក ៤ ជាន់ខាងក្រោម ហើយបរិនិព្វានក្នុងជាន់នោះៗ ឈ្មោះថា នឧទ្ធំសោតោនអកនិដ្ឋគាមី ។

បណ្តាព្រះអនាគាមីទាំងនោះ ព្រះអនាគាមី ៣ គឺពួកលោកអ្នកកើតក្នុងជាន់អវិហា ហើយបរិនិព្វានទាបជាង ១០០ កប្ប ១ លោកអ្នកបរិនិព្វានក្នុងទីបំផុត ២០០ កប្ប ១ លោកអ្នកបរិនិព្វានក្នុងកាលមិនទាន់ដល់ ៥០០ កប្ប ១ ឈ្មោះថា អន្តរាបរិនិព្វាយី ។ សមដូចលោកពោលក្នុងបុគ្គលប្បញ្ញត្តិថា **ឧប្បន្នំ វា សមនន្តរា អប្បត្តំ វា វេមជ្ឈំ** បុគ្គលនោះញ៉ាំងអរិយមគ្គឲ្យកើតឡើងក្នុងប្រមាណនៃអាយុ ដែលកើតក្នុងលំដាប់ ឬដែលមិនទាន់ដល់ពាក់កណ្តាល ... ដូច្នេះ ។ ពិតហើយ លោកអ្នកសង្គ្រោះសូម្បីមគ្គដែល

សម្រេចហើយ ដោយ វា សព្ទ ។

ព្រះអនាគាមី ជាអន្តរាបរិនិព្វាយី ៣ ពួកយ៉ាងនេះ ជាឧបហច្ចបរិនិព្វាយី ១ ពួក ជាឧទ្ធំសោតោ ១ ពួក ។ ក្នុងលោកអ្នកទាំងនោះ លោកអ្នកដែលជាអសង្ខារបរិនិព្វាយី ៥ ជាសសង្ខារបរិនិព្វាយី ៥ រួមជា ១០ ។ មួយ៉ាងទៀត សុទ្ធាវាស ៤ គឺក្នុងជាន់អតប្បា សុទស្សា សុទស្សី ជាន់នីមួយៗ មាន ១០ រួមជា ៤០ ។ ព្រោះមិនមានក្រសែខាងលើ ក្នុងជាន់អកនិដ្ឋា ទើបជាអន្តរា-បរិនិព្វាយី ៣ ជាឧហច្ចបរិនិព្វាយី ១ ជាអសង្ខារបរិនិព្វាយី ៤ ជាសសង្ខារ-បរិនិព្វាយី ៤ រួមជា ៨ ទើបជាព្រះអនាគាមី ៤៨ ដោយប្រការដូច្នេះ ។ គប្បីឃើញថា ក្នុងព្រះសូត្រនេះ លោកកាន់យកព្រះអនាគាមីទាំងអស់នោះ ដោយពាក្យមិនផ្សេងគ្នា ។ល។

**អដ្ឋកថាមានសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សព្វសូត្រ

[ ៧ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវហេតុទាំងពួង មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវហេតុទាំងនោះ មិនគួរដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹង នូវហេតុទាំងពួង ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវហេតុទាំងនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។

លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណាដឹងហេតុទាំងពួង ដោយអាការទាំងពួង មិន
ត្រេកអរក្នុងផល ( សកលកាយ ) ទាំងពួង បុគ្គល
នោះឯង កំណត់ដឹងហេតុទាំងពួង បុគ្គលនោះ ទើប
កន្លងទុក្ខទាំងពួងបាន ដោយពិត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## សព្វសូត្រ

ក្នុងសព្វសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧ ] បទថា **សព្វំ** គឺមិនមានសេសសល់ ។ **សព្វ** សព្ទនេះប្រាប់ដល់វត្ថុដែលមិនសល់ ។ **សព្វ** សព្ទនោះឯង ដល់នូវការមិនមានសេសសល់នៃសេចក្ដីទាំងអស់ ដូចជា រូបទាំងអស់ វេទនាទាំងអស់ ក្នុងធម៌ដែលទាក់ទងដោយសក្កាយទាំងអស់ ។ ម្យ៉ាងទៀត **សព្វ** សព្ទនេះមាន ២ យ៉ាង គឺសប្បទេសវិស័យ ( មានដោយចំណែកខ្លះ ) និប្បទេសវិស័យ ( មានទាំងអស់ ) ។ ពិតហើយ **សព្វ** សព្ទនេះ មានបទដែលឃើញបានក្នុងវិស័យ ៤ គឺសព្វសព្វវិស័យ បទេសសព្វវិស័យ អាយតនសព្វវិស័យ សក្កាយសព្វវិស័យ ។ ក្នុងវិស័យទាំងនោះ វិស័យដែលមកហើយ ក្នុងសព្វសព្វវិស័យ ដូចក្នុងប្រយោគជាដើមថា សព្វេ **ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថមា គច្ឆន្តិ** ធម៌ទាំងអស់ ( រាប់ទាំងអតីត អនាគត និងបច្ចុប្បន្ន ) រមែងមកកាន់វង្វង់ក្នុងប្រធាននៃព្រះញាណរបស់ព្រះពុទ្ធមានភាគ ដោយអាការសព្វគ្រប ។ មកក្នុងសព្វបទេស-វិស័យ ដូចក្នុងប្រយោគជាដើមថា ព្រះអង្គត្រាស់ថា **សព្វេសំ វោ សារិបុត្តា សុភាសិតំ បរិយាយេន** ម្នាលសារីបុត្រ បើដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ។ មកក្នុងអាយតនសព្វវិស័យ ដូចក្នុងប្រយោគជាដើមថា **សព្វំ វោ ភិក្ខវេ ទេសេស្សាមិ តំ សុណាថ។ កិញ្ច ភិក្ខវេ សព្វំ**

**ចក្ខុញ្ចេវ រូបញ្ច ។បេ។ មនញ្ចេវ ធម្មេ ច** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអាយតនៈទាំងពួងដល់អ្នកទាំងឡាយ អ្នកទាំងឡាយចាំស្តាប់នូវអាយតនៈនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង តើដូចម្តេច គឺភ្នែក ១ រូប ១ ។បេ។ ធម្មារម្មណ៍ ១ ។ មកក្នុងសក្កាយសព្វវិស័យ ដូចក្នុងប្រយោគជាដើមថា **ភគវា ឯតទវោច សព្វធម្មមូលបរិយាយំ វោ ភិក្ខវេ ទេសិស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងបរិយាយដែលជាឫសគល់នៃធម៌ទាំងពួង ប្រាប់អ្នកទាំងឡាយ ។ **សព្វ** សព្វ ដែលមកក្នុងសព្វ-សព្វវិស័យនោះ ឈ្មោះថា និប្បទេសវិស័យ ។ មកក្នុង ៣ វិស័យក្រៅអំពីនោះ ឈ្មោះថា សប្បទេសវិស័យ ។ តែក្នុងទីនេះ គប្បីជ្រាបថា មកក្នុងសក្កាយសព្វវិស័យ ។ បទថា **សព្វំ** ក្នុងទីនេះ លោកកាន់យកធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍នៃវិបស្សនា ដោយមិនមានចំណែកសេសសល់ ។

បទថា **អនភិជានំ** សេចក្តីថា ភិក្ខុមិនដឹងក្រៃលែងក្នុងធម៌ដែលគួរដឹងទាំងពួង ដោយសេចក្តីពិតមិនវិបរិត គឺមិនដឹងដោយញាណដ៏វិសេស មានជាដើមថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះមានទោស ធម៌ទាំងនេះមិនមានទោស និងមានជាដើមថា ធម៌ពួកនេះជាធាតុ ១៨ ធម៌ពួកនេះជាទុក្ខអរិយសច្ច ធម៌ទាំងនេះជាទុក្ខសមុទយអរិយសច្ច ។

បទថា **អបរិជានំ** បានដល់ មិនកំណត់ដឹង ។ ពិតហើយ បុគ្គលណាកំណត់ដឹងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ បុគ្គលនោះ រមែងដឹងដោយបរិញ្ញា

៣ គឺដោយញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។

ក្នុងបរិញ្ញា ៣ នោះ ញាតបរិញ្ញាដូចម្តេច ភិក្ខុកំណត់ដឹងនាមរូបប្រព្រឹត្តទៅក្នុងភូមិ ៣ គឺរូបមានប្រភេទជាដើមថា ភូតរូប និងបសាទរូប និងនាម មានប្រភេទជាដើមថា ផស្សៈ ថានេះរូប រូបមានប៉ុណ្ណេះ ក្រៅលែងជាងនេះមិនមាន នេះនាម នាមមានប៉ុណ្ណេះ ក្រៅលែងជាងនេះមិនមាន ។ ដោយភាពជាលក្ខណៈ រស បច្ចុប្បដ្ឋាន បទដ្ឋាន និងកំណត់បច្ច័យនៃនាមរូបនោះមានកម្ម និងអវិជ្ជាជាដើម នេះឈ្មោះថា ញាតបរិញ្ញា ។ តីរណបរិញ្ញាដូចម្តេច ភិក្ខុពិចារណាបច្ច័យទាំងអស់នោះ ធ្វើឲ្យដឹងដោយអាការ ៤២ គឺដោយការមិនទៀង ភាពជាទុក្ខ ដោយភាពជារោគជាដើម នេះឈ្មោះថា តីរណបរិញ្ញា ។ បហានបរិញ្ញាដូចម្តេច ភិក្ខុកាលពិចារណាយ៉ាងនេះហើយ លះនូវឆន្ទរាគក្នុងអាការទាំងអស់ដោយមគ្គដ៏ប្រសើរ នេះឈ្មោះថា បហានបរិញ្ញា ។ សូម្បីទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ ក៏ឈ្មោះថា ញាតបរិញ្ញា ។ មគ្គាមគ្គញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ឬបញ្ញា មានការពិចារណាធម៌ជាពួកជាក្រុមជាខាងដើម មានអនុលោមជាទីបំផុត ឈ្មោះថា តីរណបរិញ្ញា ការលះដោយអរិយមគ្គ ឈ្មោះថា បហានបរិញ្ញា ភិក្ខុណាកំណត់ដឹងធម៌ទាំងអស់ ភិក្ខុនោះ ឈ្មោះថា កំណត់ដឹងដោយបរិញ្ញាទាំង ៣ នេះ ។ តែក្នុងទីនេះ គប្បីជ្រាបថា កំណត់ដឹងដោយអំណាចនៃញាតបរិញ្ញា និងតីរណបរិញ្ញា ព្រោះការលះវិរាគៈ ទើបលោកកាន់យកផ្សេងគ្នា ដោយការបដិសេធ ។ ការមិនកំណត់ដឹង លោកពោលសំដៅដល់បុគ្គលដែលមិន

ដឹងយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ចិត្តំ អវិរាជយំ** សេចក្តីថា កិក្ខុមិនញុំាងចិត្តសន្តានរបស់ខ្លួនឲ្យប្រាសចាកតម្រេក គឺមិនប្រាសចាកតម្រេកក្នុងធម៌ ដែលគួរដឹងក្រៃលែងនោះ គឺក្នុងធម៌ដែលគួរកំណត់ដឹងយ៉ាងវិសេស អធិប្បាយថា មិនញុំាងវិរាគានុបស្សនា គឺការឃើញរឿយៗ ក្នុងវិរាគៈឲ្យកើតឡើង ដោយមិនមានរាគៈ ក្នុងធម៌ដែលគួរដឹងក្រៃលែងនោះ ។ បទថា **អប្បជហំ** បានដល់ មិនលះកិលេសវដ្ត ដែលគួរលះក្នុងធម៌ដែលគួរដឹងក្រៃលែងនោះ ដោយមគ្គប្បញ្ញា ដែលរួមជាមួយវិបស្សនាបញ្ញា ដោយមិនមានចំណែកសេសសល់ ។ គប្បីជ្រាបធម៌ដែលគួរដឹងក្រៃលែងជាដើម ដោយមគ្គដែលលាយឡំគ្នា ដូចសេចក្តីនោះ ។ គប្បីជ្រាបដោយអំណាចចិត្តផ្សេងៗ គ្នាក្នុងចំណែកខាងដើម ។ ញាណឯណានីមួយប៉ុណ្ណោះ ញុំាងធម៌ដែលគួរដឹងក្រៃលែងជាដើមឲ្យដល់ដោយលំដាប់ ដោយញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ហើយញុំាងធម៌ទាំងអស់នោះ ឲ្យសម្រេចដោយមគ្គកិច្ច ក្នុងខណៈមួយនោះឯង ដែលប្រព្រឹត្តទៅ ដោយប្រការដូច្នេះ ។ បទថា **អភព្វោ ទុក្ខក្ខយាយ** សេចក្តីថា ជាអ្នកមិនគួរ គឺមិនអាចធ្វើនូវការអស់ទុក្ខក្នុងវដ្តៈ ដោយការរម្ងាត់កិលេស ។

៥ សព្វ ក្នុងបទថា **សព្វញ្ច ខោ** នេះ ប្រព្រឹត្តទៅក្នុងអត្ថ **ព្យតិរេក** គឺមានការជំទាស់គ្នា ។ **ខោ** សព្ទ ប្រព្រឹត្តទៅក្នុងអត្ថអវធារណៈ ។ ដោយបទទាំង ២ នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ហេតុចំណែកមួយនៃការ

អស់ទុក្ខដ៏វិសេសដែលគួរបានចាកការដឹងក្រៃលែងជាដើម ។

ពាក្យណាដែលគួរពោលក្នុងពាក្យថា ការដឹងក្រៃលែងជាដើម ពាក្យនោះ លោកក៏បានពោលជាក់ច្បាស់ហើយ តែក្នុងបទនោះ លោកពោលដោយការទាក់ទងក្នុងបទនេះ គប្បីជ្រាបថាជាគោល សេចក្ដីផ្សេងគ្នា មានដូច្នេះ ។ បទថា **អភិជានំ** សេចក្ដីថា ជាអ្នកដឹងក្រៃលែង នូវសក្កាយសព្វ បានដល់ ឧបាទានក្ខន្ធ ៥ ដោយសរុប និងដោយបច្ច័យ ដោយធ្វើញាណចំពោះមុខ គឺកំណត់សក្កាយសព្វនោះ ដោយកាន់យកអាការដែលមិនមានជាដើម ដោយកំណត់តាមលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ បទថា **វិរាជយំ** សេចក្ដីថា ធ្វើចិត្តរបស់ខ្លួនឲ្យប្រាសចាកតម្រេក ដោយដឹងច្បាស់ដល់ភាពជារបស់មិនទៀងជាដើមនៃសក្កាយសព្វនោះដោយប្រពៃ និងឈានកន្លងដោយអានុភាពនៃញាណ មាននិព្វិទាញាណជាដើម មិនឲ្យតម្រេកសូម្បីត្រឹមតែតិចតួចកើតឡើងក្នុងចិត្តនោះ ។ បទថា **បជហំ** បានដល់ លះ គឺកាត់ផ្ដាច់នូវកិលេស ដែលជាចំណែករបស់សមុទយៈ ដោយមគ្គប្បញ្ញាដែលប្រកបរួមជាមួយវុដ្ឋានគាមិនីវិបស្សនា ។

បទថា **ភព្វោ ទុក្ខក្ខយាយ** បានដល់ ជាអ្នកគួរដើម្បីការអស់វិបាកវដ្ដមិនមានសេសសល់ ឬអនុបាទិសេសនិព្វានធាតុ ដែលជាការអស់ទុក្ខក្នុងសង្សារវដ្ដទាំងមូល ព្រោះលះមន្ទិល គឺកិលេសបាន និងព្រោះអស់កម្មវដ្ដ គប្បីឃើញសេចក្ដីក្នុងបទនេះយ៉ាងនេះថា ជាអ្នកគួរសម្រេចធម៌ដោយចំណែកមួយ ។

បទថា **យោ សព្វំ សព្វតោ ញត្វា** សេចក្តីថា បុគ្គលណា គឺអ្នកប្រកបសេចក្តីព្យាយាម អ្នកចម្រើនវិបស្សនា ដឹងធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួង ដោយចំណែកទាំងពួង គឺដោយចែកខន្ធ មានកុសលក្ខន្ធជាដើម និងដោយចែកការបៀតបៀន មានទុក្ខជាដើម ។ ម្យ៉ាងទៀត បទថា **សព្វតោ** បានដល់ ដឹងដោយអាការទាំងពួង គឺដោយលក្ខណៈ មានគ្រោតគ្រាត និងល្អិតជាដើម និងដោយលក្ខណៈ មានការមិនទៀងជាដើម ឬព្រោះចាក់ធ្លុះដោយមគ្គញាណ ដែលជាចំណែកខាងដើមនៃវិបស្សនា ហើយដឹងដោយវិបស្សនាញាណ ។

បទថា **សព្វត្ថេសុ ន រជ្ជតិ** បានដល់ រមែងមិនតម្រេកក្នុងសក្កាយធម៌ទាំងពួង ដែលមានប្រភេទផ្សេងគ្នាមិនតិច ដោយមានក្នុងអតីតជាដើម គឺមិនឲ្យរាគៈកើត ដោយការសម្រេចអរិយមគ្គ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការមិនមាននៃការប្រកាន់តណ្ហានោះ ដោយបទថា **សព្វត្ថេសុ ន រជ្ជតិ** នេះ ទើបទ្រង់សម្តែងដល់ការមិនមានសូម្បីការប្រកាន់ខុស ៣ ពួក គឺនេះរបស់អញ ១ នេះជាអញ ១ នេះជាខ្លួនរបស់អញ ១ របស់បុគ្គលដែលប្រកាន់ដោយទិដ្ឋិ មានះ ព្រោះមានវត្ថុនោះជានិមិត្ត បទថា **ស** ក្នុងបទថា **សវេ** នេះ ត្រឹមតែជានិបាត ។ បទថា **វេ** ជា **ព្យត្ត** គឺការប្រាកដ ។ ឬជានិបាតក្នុងសេចក្តីនេះថា **ឯកំសេន** ប្រែថា ដោយចំណែកមួយ ។ បទថា **សព្វំ បរិញ្ញា** បានដល់ ព្រោះកំណត់ដឹងនូវធម៌ទាំងពួង គឺព្រោះកំណត់ដឹងធម៌ទាំងពួង តាមដែលពោលហើយ ដោយសម្រេចបរិញ្ញា ។

បទថា **សោ** បានដល់ ព្រះយោគាវចរតាមដែលពោលហើយ ឬព្រះអរិយៈនោះឯង ។ បទថា **សព្វំ ទុក្ខំ ឧបច្ចគា** បានដល់ កន្លង គឺឈានកន្លង គឺផុតទុក្ខក្នុងវដ្ដៈបានទាំងអស់ ។៧។

**អដ្ឋកថា សព្វសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## មានបរិញ្ញាសូត្រ

[ ៨ ] ខ្ញុំបានស្ដាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវមានះ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវមានះនោះ មិនគួរដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវមានះ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវមានះនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ពួកសត្វនេះ ជាអ្នកប្រកបដោយមានះ ត្រូវមានះចាក់
ស្រេះហើយ ត្រេកអរក្នុងភព កាលមិនកំណត់ដឹងមានះ
តែងមកកាន់ភពថ្មីទៀត ចំណែកពួកសត្វណា លះបង់
មានះបានហើយ ផុតស្រឡះហើយ ព្រោះអស់មានះ

សត្វទាំងនោះ គ្របសង្កត់នូវគ្រឿងចាក់ស្រែះ គឺមានៈ
បានហើយ កន្លងបង់នូវគ្រឿងចាក់ស្រែះទាំងពួងបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនុ៎ះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## មានបរិញ្ញាសូត្រ

[ ៨ ] ក្នុងមានៈសូត្រទី ៨ មិនមានរឿងដែលមិនធ្លាប់ពោល ទេសនាប្រព្រឹត្តទៅដោយមានៈសុទ្ធ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **មានុបេតា អយំ បជា** សេចក្តីថា សត្វទាំងនេះបានឈ្មោះថា **បជា** ព្រោះកើតដោយកម្មក្កិលេសប្រកបដោយមានៈ ដែលមានការប្រកាន់ខ្លួនជាលក្ខណៈ ។ បទថា **មានគន្ថា ភវេ រតា** សេចក្តីថា សត្វទាំងឡាយត្រូវមានៈរួបរឹត គឺប្រកបដោយមានសំយោជនៈ អប់រំមកអំពីមានៈនោះអស់កាលយូរ ត្រេកអរក្នុងកាមភពជាដើម ដោយហេតុខុសក្នុងសង្ខារនោះថា ទៀង ជាសុខ មានតួខ្លួនជាដើម ព្រោះវង្វេងក្នុងសង្ខារទាំងឡាយថា នេះរបស់អញដោយការប្រកាន់ខ្លួន ។ បទថា **មានំ អបរិជានន្តា** សេចក្តីថា មិនកំណត់ដឹងនូវមានៈនោះដោយបរិញ្ញា ៣ ឬមិនផុតមានៈនោះ ដោយអរហត្តមគ្គញាណ ។ អាចារ្យ

ពួកខ្លះពោលថា **មានំ បរិញ្ញាយ** ដូច្នេះក៏មាន ។ បទថា **អាគន្តារោ បុនព្ភវំ** សេចក្ដីថា ជាអ្នកពាល់ត្រូវ គឺចូលទៅកាន់ភពដែលនឹងត្រូវកើតតទៅ ឬទៅកាន់សង្សារ ដែលបានដល់ភពថ្មី ចាកទីដែលកើតរឿយៗ ដោយការវិលវល់ទៅមក អធិប្បាយថា មិនផុតចាកភព ។

បទថា **យេ ច មានំ បហាត្វាន វិមុត្តា មានសង្ខយេ** ប្រែថា សត្វពួកណាលះនូវមានះបានហើយ បង្អោនទៅក្នុងធម៌ដែលអស់នូវមានះ អធិប្បាយថា សត្វពួកណាលះនូវមានះ ដោយប្រការទាំងពួង ដោយអរហត្តមគ្គហើយបង្អោនទៅ គឺបង្អោនទៅដោយល្អក្នុងអរហត្តផល ឬក្នុងនិព្វានដែលអស់មានះ ដោយការរួចផុតកិលេសសព្វយ៉ាង ដែលមានមានះនោះជាអ្នកដើរតួ ។ បទថា **តេ មានគន្ថាភិភុនោ សព្វំ គន្ថំ ឧបច្ចគុំ** ប្រែថា សត្វទាំងនោះគ្របសង្កត់កិលេស ជាគ្រឿងរួបរឹត គឺមានះបាន ឈានកន្លងនូវកិលេសជាគ្រឿងរួបរឹតទាំងពួង សេចក្ដីថា សត្វទាំងនោះ គឺព្រះអរហន្ត ដែលមានសំយោជនៈគឺភពអស់ទៅហើយ គ្របសង្កត់នូវកិលេស ជាគ្រឿងរួបរឹត គឺមានះ កិលេសជាគ្រឿងចងសត្វ គឺមានះបានដោយប្រការទាំងពួង ដោយសមុច្ឆេទប្បហានតាំងនៅ ឈានកន្លងនូវវដ្តទុក្ខបាន ដោយមិនមានសេសសល់ ។

ក្នុងសូត្រនេះ និងក្នុងសូត្រទី ៧ លោកពោលដល់អរហត្ត ។

**អដ្ឋកថាមានបរិញ្ញាសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## លោភបរិញ្ញាសូត្រ

[ ៩ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវលោភៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវលោភៈនោះ មិនគួរដើម្បីអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវលោភៈ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវលោភៈនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ជាប់ហើយ ព្រោះលោភៈណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់លោភៈនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះ
ទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## លោកបរិញ្ញាសូត្រ

[ ៩ ] ក្នុងលោកបរិញ្ញាសូត្រទី ៩ មិនមានរឿងដែលមិនធ្លាប់ពោល ។ មិនធ្លាប់ពោលដល់រឿងលោកៈមកហើយ ។ គប្បីឃើញថា សូត្រនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់អ្នកប្រាជ្ញដោយទេសនាវិលាស ឬដល់វេនេយ្យ-សត្វ ដោយអធ្យាស្រ័យ ។៚

**អដ្ឋកថា លោកបរិញ្ញាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទោសបរិញ្ញាសូត្រ

[ ១០ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវទោសៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវទោសៈនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវទោសៈ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវទោសៈនោះបាន ទើបគួរដើម្បីអស់ទុក្ខ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ប្រទូស្តហើយ ព្រោះទោសៈណា តែង

ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់ទោសៈនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មក កាន់លោកនេះ
ទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

## បាដិភោគវគ្គទី ១ ចប់

## ឧទ្ទាននៃបាដិភោគវគ្គនោះ គឺ

និយាយអំពីរាគៈ ១ ទោសៈ ១ មោហៈ ១ សេចក្តី
ក្រោធ ១ សេចក្តីលុបគុណ ១ មានះ ១ ហេតុទាំង
ពួង ១ មានះ ១ រាគៈ ទោសៈ ២ ទៀត អ្នកប្រាជ្ញ
ទាំងឡាយពោលថា ជាបឋមវគ្គ ។

# អដ្ឋកថា

## ទោសបរិញ្ញាសូត្រ

[ ១០ ] ក្នុងទោសបរិញ្ញាសូត្រទី ១០ មិនធ្លាប់មានរឿងដែលមិនធ្លាប់ពោល ធ្លាប់ពោលរឿងទោសៈមកហើយ ។ គប្បីឃើញថា សូត្រទាំងនោះព្រះមានព្រះភាគ ទ្រង់សម្តែងដល់អ្នកប្រាជ្ញដោយទេសនាវិលាស ឬដល់វេនេយ្យសត្វ ដោយអជ្ឈាស្រ័យ ។៚

**អដ្ឋកថា ទោសបរិញ្ញាសូត្រទី ១០ ចប់**

**ចាជិភោគវគ្គទី ១ ចប់**

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ឥតិវុត្តក ឯកនិបាត ទុតិយវគ្គ

### មោហបរិញ្ញាសូត្រ

[ ១១ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវមោហៈ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវមោហៈនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវមោហៈ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវមោហៈនោះបាន ទើបគួរនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ វង្វេងហើយ ព្រោះមោហៈណា តែង
ទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នកឃើញច្បាស់ ដឹង
ដោយបញ្ញាដ៏ប្រពៃហើយ រមែងលះបង់មោហៈនោះបាន
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះ
ទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១ ។

## កោធសូត្រ

[ ១២ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវសេចក្តីក្រោធ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវសេចក្តីក្រោធនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវសេចក្តីក្រោធ ញុំាងចិត្តឲ្យនឿយណាយ លះបង់នូវសេចក្តីក្រោធនោះបាន ទើបគួរដើម្បីនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ ក្រោធហើយ ព្រោះសេចក្តីក្រោធណា
តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយអ្នកឃើញច្បាស់ ដឹង
ដោយបញ្ញា ដ៏ប្រពៃហើយ លះបង់សេចក្តីក្រោធនោះ
លុះលះបង់បានហើយ មិនត្រឡប់មកកាន់លោកនេះ
ទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ២ ។

## មក្ខសូត្រ

[ ១៣ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងច្បាស់ មិនកំណត់ដឹងនូវសេចក្តីលុបគុណ មិនញុំាងចិត្តឲ្យនឿយណាយ មិនលះបង់នូវសេចក្តីលុបគុណនោះ មិនគួរដើម្បីនឹងអស់ទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ

បុគ្គលកាលដឹងច្បាស់ កំណត់ដឹងនូវសេចក្តីលុបគុណ ទាំងញុំាងចិត្តឲ្យនឿយណាយ លះបង់សេចក្តីលុបគុណនោះបាន ទើបគួរដើម្បីនឹងអស់ទុក្ខ ។ លុះព្រះមានព្រះភាគ សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

សត្វទាំងឡាយ លុបគុណហើយ ព្រោះសេចក្តីលុប
គុណណា តែងទៅកាន់ទុគ្គតិ សត្វទាំងឡាយ អ្នក
ឃើញច្បាស់ ដឹងដោយបញ្ញាដ៏ប្រពៃហើយ រមែងលះ
បង់សេចក្តីលុបគុណនោះបាន លុះលះបង់បានហើយ មិន
ត្រឡប់មកកាន់លោកនេះទៀត ក្នុងកាលណាឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## ទុតិយវគ្គទី ២

## មោហបរិញ្ញាសូត្រជាដើម

[ ១១-១៣ ] ក្នុងវគ្គទី ២ មោហបរិញ្ញាសូត្រទី ១ ជាដើម មានន័យដូចបានពោលមកហើយ សូម្បីហេតុនៃទេសនាក៏បានពោលមកហើយយ៉ាងនោះ ។

**អដ្ឋកថា មោហបរិញ្ញាសូត្រទី ១ ជាដើមចប់**

# សុត្តន្តបិដក

## អវិជ្ជានីវរណសូត្រ

[ ១៤ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វត្រូវនីវរណៈណា រួបរឹតហើយ តែងអន្ទោលទៅ តែងត្រាច់ទៅ អស់រាត្រីវែង ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនីវរណៈដទៃនោះ សូម្បីតែនីវរណៈមួយ ដូចអវិជ្ជានីវរណៈនេះឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុតែពួកសត្វ ត្រូវអវិជ្ជានីវរណៈ រួបរឹតហើយ ទើបបានអន្ទោលទៅ ត្រាច់ទៅ អស់រាត្រីវែង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ពួកសត្វត្រូវមោហៈដែលជាធម៌ឯក មិនមានធម៌ដទៃដូច

រូបរឹតបិទបាំងយ៉ាងនេះហើយ តែងអន្ទោលទៅអស់ថ្ងៃ
និងយប់ដ៏វែង ចំណែកសត្វទាំងឡាយណា លះបង់
មោហៈ ទម្លាយគំនរនៃងងឹតហើយ សត្វទាំងនោះ នឹង
មិនអន្ទោលទៅទៀត ព្រោះហេតុរបស់សត្វទាំងនោះ
មិនមាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## អវិជ្ជានីវរណសូត្រ

ក្នុងអវិជ្ជានីវរណសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១៤ ] ន អក្ខរៈ ក្នុងបទជាដើមថា **នាហំ ភិក្ខវេ** មានអត្ថបដិសេធ ។ ព្រះមានព្រះភាគ ទ្រង់អាងដល់ខ្លួនរបស់ទ្រង់ថា **អហំ**។ បទថា **អញ្ញំ** បានដល់ ធម៌ដទៃចាកនីវរណៈ គឺអវិជ្ជា ដែលត្រូវពោលឥឡូវនេះ ។ បទថា **ឯកនីវរណម្បិ** បានដល់ ធម៌រាំងមិនឲ្យសម្រេចសេចក្តីល្អឯណានីមួយ ។ បទថា **សមនុបស្សាមិ** បានដល់ សមនុបស្សនា ២ យ៉ាង គឺ **ទិដ្ឋិសមនុបស្សនា** ការពិចារណាឃើញដោយទិដ្ឋិ ១ **ញាណសមនុបស្សនា** ពិចារណាឃើញដោយញាណ ១ ។

ក្នុងសមនុបស្សនា ២ យ៉ាងនោះ ការពិចារណាឃើញទីមកដោយបាលីមានពាក្យ **រូបំ អត្តតោ សមនុបស្សតិ** ពិចារណាឃើញរូបដោយភាពជាតួខ្លួន នេះឈ្មោះថា ទិដ្ឋិសមនុបស្សនា ។ ឯសមនុបស្សនាដែលមកដោយបាលីមានពាក្យថា **អនិច្ចតោ សមនុបស្សតិ នោ និច្ចតោ** ពិចារណាឃើញដោយភាពជារបស់មិនទៀង មិនពិចារណាឃើញដោយភាពជារបស់ទៀង នេះឈ្មោះថា ញាណសមនុបស្សនា ។ ក្នុងព្រះសូត្រ លោកបំណងយកញាណសមនុបស្សនាតែម្យ៉ាង ។ បទថា **សមនុបស្សាមិ** ភ្ជាប់ដោយ **ន** អក្ខរៈ ។ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីតថាគតពិនិត្យមើលធម៌ទាំងពួង ដោយសមន្តចក្ខុ បានដល់ សព្វញ្ញុតញ្ញាណ ដូចផ្លែកន្ទួតព្រៃក្នុងបាតដៃ គង់មិនឃើញសូម្បីនីវរណៈមួយដទៃ ។

បទថា **យេន នីវរណេន និវុតា បជា ទីឃរត្តំ សន្ធាវន្តិ សំសរន្តិ** ប្រែថា ពួកសត្វត្រូវនីវរណៈស្ទុះទៅ អន្ទោលទៅអស់កាលយូរ សេចក្តីថា សត្វទាំងឡាយ ត្រូវនីវរណៈគ្របសង្កត់ រឹតរុំឲ្យជនឹត មិនឲ្យដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះសភាវធម៌ទាំងឡាយ ព្រោះសភាវធម៌ត្រូវបិទបាំង រមែងស្ទុះទៅ រមែងអន្ទោលទៅក្នុងសង្សារ ដែលមិនមានទីបំផុតខាងដើម និងក្នុងភពតូចភពធំ អស់កប្បកំណត់មិនបាន ដោយប្រការទាំងពួង ដោយការកើតហើយកើតទៀត ។ ការស្ទុះទៅ គឺការឈានទៅក្នុងរវាងអារម្មណ៍ ការស្ទុះទៅ គឺការឈានទៅក្នុងរវាងភព ។ ឬការស្ទុះទៅដោយកិលេស មានកម្លាំងខ្លាំងក្លា ការស្ទុះទៅដោយកិលេសមានកម្លាំងខ្សោយ ។ ឬថា ការស្ទុះទៅក្នុងជាតិមួយ

គឺស្ទាប់ទៅមួយជួរខណៈ ការស្ទុះទៅក្នុងច្រើនៗ ជាតិ គឺស្ទាប់តាមពាក្យពោល គឺការស្ទុះទៅដោយចិត្ត ។ ដូចលោកពោលថា ចិត្តរបស់បុគ្គលនោះតែង ស្ទុះទៅ អន្ទោលទៅដោយកម្ម ។ គប្បីជ្រាបការផ្សេងគ្នានៃការស្ទុះទៅ និងការអន្ទោលទៅ ដោយប្រការដូច្នេះ ។ បទថា **យថយិទំ** កាត់បទជា **យថា ឥទំ។ យ** អក្ខរៈជាបទសន្ធិ ធ្វើជាស្សរៈ ដោយវិធីសន្ធិ ។

ក្នុងបទថា **អវិជ្ជានីវរណំ** នេះ គប្បីជ្រាបសេចក្តីដូចតទៅនេះ កាយទុច្ចរិតជាដើម ឈ្មោះថា មិនគួរដឹង ដោយអត្ថថា មិនគួរបំពេញ អធិប្បាយថា មិនគួរបាន ។ ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា ដឹងវត្ថុមិនគួរដឹងនោះ ។ ដោយផ្ទុយគ្នា កាយសុចរិតជាដើម ឈ្មោះថា ជាវត្ថុគួរដឹង ។ ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា មិនដឹងវត្ថុដែលគួរដឹងនោះ ។

លោកពោលដល់គំនរខន្ធទាំងឡាយ ដែលជាគ្រឿងជាប់ចំពោះអាយតនៈទាំងឡាយ ការសូន្យនៃធាតុទាំងឡាយ ភាពជាធំនៃឥន្ទ្រិយទាំងឡាយ សេចក្តីពិតនៃសច្ចៈទាំងឡាយ ដោយការគ្របសង្កត់របស់ទុក្ខជាដើម ។ ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា មិនដឹងអត្ថ ៤ យ៉ាងនោះ ឬឈ្មោះថា អវិជ្ជា ព្រោះអត្ថថា ញុំាងពួកសត្វឲ្យស្ទុះទៅក្នុងសង្សារ ដែលមិនមានទីបំផុត ។ ឬពោលដោយបរមត្ថ ឈ្មោះថា អវិជ្ជា ព្រោះអត្ថថា រមែងស្ទុះទៅ គឺរមែងប្រព្រឹត្តទៅក្នុងអវិជ្ជមានបញ្ញត្តិទាំងឡាយ មានស្ត្រី និងបុរសជាដើម រមែងមិនស្ទុះទៅ គឺមិនប្រព្រឹត្តទៅក្នុងវិជ្ជមានបញ្ញត្តិទាំងឡាយ មានខន្ធជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា អវិជ្ជា ព្រោះបិទបាំងវត្ថុ និងអារម្មណ៍ មានចក្ខុវិញ្ញាណជាដើម

និងធម៌ គឺបដិច្ចសមុប្បាទ ។ នីវរណៈ គឺអវិជ្ជា ឈ្មោះថា អវិជ្ជានីវរណៈ ។

បទថា **អវិជ្ជានីវរណេន ហិ ភិក្ខវេ និវុតា បជា ទីឃរត្តំ សន្ធាវន្តិ សំសរន្តិ** នេះ ព្រះមានព្រះភាគ ត្រាស់ដើម្បីធ្វើភាពខាងក្នុងឲ្យធ្ងន់មុននោះឯង បទមុនថា **យថយិទំ ភិក្ខវេ អវិជ្ជានីវរណំ** ប្រែថា ដូចនីវរណៈ គឺអវិជ្ជានេះ ព្រះមានព្រះភាគត្រាស់ដើម្បីឲ្យសម្ដែងឧបមាយ៉ាងនេះ ។ បទនេះ ត្រាស់ដើម្បីសម្ដែងអានុភាពរបស់នីវរណៈ សួរថា ព្រោះហេតុអ្វី ទើបក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់អវិជ្ជាប៉ុណ្ណោះ មិនត្រាស់ដល់ធម៌ដទៃផង ឆ្លើយថា ព្រោះអវិជ្ជា ជាវិសេសប្បច្ចយនៃកាមច្ឆន្ទជាដើម ដោយការបិទបាំងទោស ។ ពិតហើយ កាមច្ឆន្ទជាដើម តែងប្រព្រឹត្តទៅក្នុងអាការរបស់ទោសៈ ដែលត្រូវអវិជ្ជានោះបិទបាំង ។

ព្រះមានព្រះភាគ ត្រាស់គាថាជាដើមថា **នត្ថញ្ញោ** ដូច្នេះ ដោយរួមអត្ថដែលត្រាស់ហើយ និងដែលមិនទាន់បានត្រាស់ ។ ក្នុងបទទាំងនោះ បទថា **និវុតា** បានដល់ គ្របដណ្ដប់ រឹតរុំ បិទបាំង ។ បទថា **អហោរត្តំ** ប្រែថា ពេលថ្ងៃ និងពេលយប់ អធិប្បាយថា សព្វកាល ។ បទថា **យថា មោហេន អាវុតា** សេចក្ដីថា ដោយប្រការដែលពួកសត្វត្រូវមោហៈ គឺអវិជ្ជានីវរណៈ រឹតរុំបិទបាំង មិនដឹងធម៌ដែលគួរដឹងដោយល្អ រមែងអន្ទោលទៅក្នុងសង្សារ គប្បីប្រកបសេចក្ដីថា ធម៌ឯណានីមួយដទៃបែបនោះក្ដី នីវរណៈឯណាមួយក្ដី រមែងមិនមាន ។ បទថា **យេ ច មោហំ បហន្ត្វាន តមោក្ខន្ធំ បទាលយុំ** ប្រែថា ព្រះអរិយសាវកពួកណា លះនូវមោហៈហើយ ទម្លាយនូវគំនរនៃ

ននឹតបានហើយ សេចក្ដីថា ព្រះអរិយសាវកពួកណាលះនូវមោហៈ ដែលមគ្គនោះៗ គប្បីសម្លាប់ដោយមគ្គខាងក្រោម ដោយតទង្គប្បហាន ក្នុងចំណែកខាងដើម ហើយទម្លាយនូវគំនរនៃងងឹត ដែលបានដល់មោហៈនោះឯង ដោយញាណ ប្រៀបដោយពេជ្រ ដែលជាញាណដ៏កំពូល គឺកាត់ផ្ដាច់ដោយមិនមានសេសសល់ ។ បទថា **ន តេ បុន សំសរន្តិ** សេចក្ដីថា ព្រះអរិយសាវក គឺព្រះអរហន្តទាំងនោះ មិនអន្ទោលទៅ គឺមិនបែរត្រឡប់ទៅក្នុងសង្សារនេះ ដែលលោកពោលថា

**ខន្ធានញ្ច បដិបាដិ ធាតុ អាយតនាន ច**
**អព្វោច្ឆិន្នំ វត្តមានា សំសារោតិ បវុច្ចតិ ។**

*លំដាប់នៃខន្ធ ធាតុ អាយតនៈ នៅប្រព្រឹត្តទៅមិន*
*ដាច់ លោកហៅថា សង្សារ ។*

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអវិជ្ជាជាដើមហេតុ ជាមូលនៃសង្សារ រមែងមិនមានដល់អរិយសាវកទាំងនោះ ព្រោះកាត់ផ្ដាច់ហើយ ដោយប្រការទាំងពួងដូច្នេះ ។

**អដ្ឋកថា អវិជ្ជានីវរណសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## តណ្ហាសូត្រ

[ ១៥ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វដែលប្រកបដោយសំយោជនៈណាហើយ តែងអន្ទោលទៅ ត្រាច់ទៅ អស់រាត្រីដ៏វែង ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសំយោជនៈដទៃនោះ សូម្បីតែសំយោជនៈមួយ ដូចជាតណ្ហាសំយោជនៈនេះឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុតែសត្វទាំងឡាយ ដែលប្រកបដោយតណ្ហាសំយោជនៈហើយ ទើបបានអន្ទោលទៅ ត្រាច់ទៅ អស់រាត្រីវែង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុរស មានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់
សង្សារ អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ត
ដែលមានសភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ភិក្ខុ
ដឹងនូវតណ្ហានេះថា ជាទោស ជាដែនកើតនៃទុក្ខហើយ
ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ ជាអ្នក
មានសតិ គប្បីវៀរបង់ចោលចេញ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## តណ្ហាសំយោជនសូត្រ

[ ១៥ ] ក្នុងតណ្ហាសំយោជនសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា សំយោជនៈ ព្រោះអត្ថថា ចងនូវបុគ្គលដែលមានសំយោជនៈដោយកម្ម និងវិបាកដែលជាទុក្ខ ឬដោយលំដាប់របស់ភពក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសជាដើម ឈ្មោះថា តណ្ហា ព្រោះអត្ថថា ជាទីមកនៃការចង់បាន ។ ឈ្មោះថា តណ្ហា ព្រោះអត្ថថា ធ្វើឲ្យតក់ស្លុត ឬញាប់ញ័រ ។ បទថា **សំយុត្តា** បានដល់ ចងភ្ជាប់ក្នុងអភិនិវេសវត្ថុ មានចក្ខុជាដើម បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

ម្យ៉ាងទៀត ក្នុងទីនេះ សូម្បីអវិជ្ជាក៏ជាសំយោជនៈ និងតណ្ហាជានីវរណៈនៅមានដោយពិត តែតណ្ហា រមែងចងនូវសត្វដោយភពដែលមានទោសដែលត្រូវអវិជ្ជាបិទបាំង ព្រោះហេតុនោះ ដើម្បីសម្តែងការផ្សេងគ្នានេះ ទើបព្រះមានព្រះភាគត្រាស់អវិជ្ជាក្នុងសូត្រមុន ដោយភាពជានីវរណៈ និងត្រាស់តណ្ហាក្នុងសូត្រនេះ ដោយភាពជាសំយោជនៈ ទាំងនេះដើម្បីឲ្យឃើញភាពជាធំនៃនីវរណៈ និងសំយោជនៈ ដូចអវិជ្ជាជាធំ និងជាប្រធាននៃធម៌សៅហ្មងទាំងឡាយ ដោយភាពជានីវរណៈ យ៉ាងណា តណ្ហាក៏ជាធំ និងជាប្រធានរបស់ធម៌សៅហ្មងទាំងនោះ ដោយភាពជាសំយោជនៈ ដូច្នោះ ព្រោះហេតុនោះដើម្បីសម្តែងភាពជាធំនៃធម៌សៅហ្មងទាំងនោះ ទើបត្រាស់ធម៌ទាំងនេះយ៉ាងនេះក្នុងសូត្រទាំង ២ ។ ម្យ៉ាងទៀត ដោយការផ្សេងគ្នា ត្រាស់អវិជ្ជាថាជានីវរណៈ ព្រោះឃាត់នូវនិព្វានសុខ ។ ត្រាស់តណ្ហាថា ជាសំយោជនៈ

ព្រោះចងសត្វដោយសង្សារទុក្ខ សូត្រទាំង ២ ត្រាស់ ២ ចំណែក ដោយធ្វើអន្តរាយដល់ការឃើញការសម្រេច ឬដោយភាពជាសត្រូវរបស់វិជ្ជា និងចរណៈ ។ អវិជ្ជា ជាសត្រូវដោយត្រង់របស់វិជ្ជា ធ្វើអន្តរាយក្រៃលែងដល់ការឃើញនិព្វាន និងការឃើញដែលមិនវិបរិត ។ តណ្ហាជាសត្រូវដោយត្រង់របស់ចរណធម៌ ដែលធ្វើអន្តរាយដល់ការសម្រេច គឺដល់កិច្ចបដិបត្តិប្រពៃ ដោយប្រការដូច្នេះ បុគ្គលនេះត្រូវអវិជ្ជារឹតរុំ ធ្វើឲ្យងងឹត រួបរឹតដោយតណ្ហាដោយប្រការទាំងពួង មិនស្អាប់ មានកិលេសក្រាស់ ចងធ្វាក់ដូចបុគ្គលខ្វាក់មិនឈានកន្លងមហាកន្តារ សង្សារកន្តារបានឡើយ ។ ដើម្បីសម្តែងធម៌ ២ ពួកដែលជាហេតុឲ្យកើតសេចក្តីវិនាស ទើបត្រាស់ធម៌ ២ ពួក ដោយចំណែក ២ ។

ពិតហើយ បុគ្គលដែលមានអវិជ្ជា រមែងសាបសូន្យប្រយោជន៍ ព្រោះភាពជាបុគ្គលល្ងង់ និងធ្វើសេចក្តីវិនាសឲ្យដល់ខ្លួន ។ បុគ្គលមិនសេពវត្ថុមិនជាសប្បាយ ធ្វើដូចបុគ្គលមិនឈ្លាស ក្តៅក្រហាយ ដូចមនុស្សមិនដឹង ធ្វើក្នុងវត្ថុមិនជាសប្បាយ ។ មក្កដាលេបោបមសូត្រ ជាគំរូក្នុងរឿងនេះ ។ ព្រះសូត្រនេះ ត្រាស់ ២ ពួកជា ២ ចំណែក ដើម្បីសម្តែងមូលហេតុនៃបដិច្ច-សមុប្បាទ ។ ដោយការផ្សេងគ្នា ព្រំដែននៃអវិជ្ជាជាអតីតដ៏យូរលង់ ព្រោះសម្មោហៈ មានកម្លាំងដ៏ខ្លាំងក្លា ។ ព្រំដែនរបស់តណ្ហាជាអនាគតយឺនយូរ ព្រោះការប្រាថ្នាមានកម្លាំងខ្លាំងក្លា ។ ពិតហើយ បុគ្គលពាល ច្រើនដោយសម្មោហៈ រមែងសោកស្តាយដល់អតីត គួរទូន្មានបុគ្គលពាល ដោយ

សម្មោហៈនោះ ឲ្យយល់ដល់បដិច្ចសមុប្បាទទាំងអស់ មាន **អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ មានអវិជ្ជាជាបច្ច័យជាដើម ។ បុគ្គលពាលច្រើនទៅដោយសេចក្តីប្រាថ្នា តែងកន្ទក់កន្ទេញដល់អនាគត គួរទូន្មានបុគ្គលពាលដែលច្រើនដោយសេចក្តីប្រាថ្នានោះ ឲ្យយល់ក្នុងបដិច្ចសមុប្បាទទាំងអស់ថា **តណ្ហាបច្ចយា ឧបាទានំ** ឧបាទានមានតណ្ហាជាបច្ច័យ ដូច្នេះ ។ ដោយបទនេះ ទ្រង់សម្តែងដល់មូលរបស់បដិច្ចសមុប្បាទតាមលំដាប់ ដោយការទាក់ទងគ្នាអំពីចំណែកខាងដើម រហូតដល់ចំណែកខាងចុង ដោយប្រការដូច្នេះ ។ ក្នុងគាថាទាំងឡាយ គប្បីជ្រាបសេចក្តីដូចតទៅនេះ បទថា **តណ្ហា ទុតិយោ** គឺជាសម្លាញ់នឹងតណ្ហា ពិតហើយ តណ្ហា ធ្វើសត្វដែលស្រេកឃ្លានគ្របសង្កត់ត្រូវសេចក្តីទុក្ខគ្របសង្កត់ខ្លះ ដែលជាកិច្ចរបស់សម្លាញ់ ដោយការពេញចិត្តនឹងការដឹកនាំ ដូចការសម្គាល់ថាទឹកក្នុងថ្ងៃបណ្តើរកូន ក្នុងទីកន្តារមិនមានទឹក ធ្វើមិនឲ្យនឿយណាយក្នុងភពជាដើម ហើយវិលត្រឡប់មក ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា តណ្ហាជាសម្លាញ់របស់សត្វ ដូច្នេះ ។ សួរថា កិលេសពួកដទៃជាដើម ជាបច្ច័យដើម្បីឲ្យកើតក្នុងភពមិនមែនឬ ឆ្លើយថា សេចក្តីនោះពិត តែបច្ច័យពិសេស មិនដូចតណ្ហា ។ ព្រោះតណ្ហា វៀរចាកកុសល អកុសល ឯបច្ច័យពិសេស វៀរចាកកាមាវចរកុសលជាដើម ដើម្បីឲ្យកើតក្នុងភព ដោយរូបាវចរកុសលជាដើម ព្រោះដូច្នោះ ទើបត្រាស់ថា **សមុទយសច្ចំ** ដូច្នេះ ។

បទថា **ឥត្ថភាវញ្ញថាភាវំ** បានដល់ ភាពជាយ៉ាងនេះ និងភាពដទៃ

ឈ្មោះថា **ឥត្ថភាវញ្ញថាភាវោ** ។ សង្សារ ឈ្មោះថា **ឥត្ថភាវញ្ញថាភាវោ** ព្រោះអត្ថថា សង្សារមានភាពយ៉ាងនេះ និងភាពដទៃ ។ ក្នុងបទនោះ ភាពជាយ៉ាងនេះ គឺភាពជាមនុស្ស ភាពដទៃ គឺលំនៅរបស់សត្វ ក្រៅអំពីភាពជាមនុស្សនោះ ឬភាពជាយ៉ាងនេះ បានដល់ អត្តភាពបច្ចុប្បន្នរបស់ពួកសត្វនោះៗ ។ ភាពដទៃ បានដល់ អត្តភាពក្នុងអនាគត ។ អត្តភាពដទៃ មានប្រក្រតីយ៉ាងនេះ ឈ្មោះថា **ឥត្ថភាវ** មិនមានប្រក្រតីយ៉ាងនេះ ឈ្មោះថា **អញ្ញថាភាវ** ។ បុរសដែលមានតណ្ហាជាសម្លាញ់ រមែងមិនឈានកន្លងសង្សារដែលមានសភាពយ៉ាងនេះ និងការប្រព្រឹត្តទៅដទៃ គឺលំដាប់ខន្ធ ធាតុ អាយតនៈបាន ។

បទថា **ឯតមាទីនវំ ញត្វា តណ្ហំ ទុក្ខស្ស សម្ភវំ** ប្រែថា ភិក្ខុដឹងតណ្ហាដែលជាដែនកើតនៃទុក្ខនេះ ដោយភាពជាទោស សេចក្តីថា ភិក្ខុដឹងតណ្ហាដែលជាដែនកើត គឺជាហេតុកើតនៃវដ្តទុក្ខទាំងមូលនេះ អធិប្បាយថា ដឹងដោយភាពជាទោស ។ ម្យ៉ាងទៀត បទថា **ឯតមាទីនវំ ញត្វា** បានដល់ ដឹងទោស គឺសេចក្តីអាក្រក់ ដែលមិនធ្វើឲ្យឈានកន្លងនូវសង្សារតាមដែលពោលហើយនោះទៅបាន ។ បទថា **តណ្ហំ ទុក្ខស្ស សម្ភវំ** បានដល់ ដឹងនូវតណ្ហាថា ជាហេតុឲ្យកើតវដ្តទុក្ខ ដោយន័យដែលពោលហើយ ។

បទថា **វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេ** ប្រែថា ភិក្ខុជាអ្នកប្រាសចាកតណ្ហា មិនប្រកាន់មាំ ជាអ្នកមានសតិ គប្បីវៀរ សេចក្តីថា ភិក្ខុកំណត់ដឹងដោយបរិញ្ញា ៣ យ៉ាងនេះ ចម្រើនវិបស្សនា ប្រាសចាកតណ្ហា

*តាមលំដាប់មគ្គ ឈ្មោះថា ជាអ្នកប្រាសចាកតណ្ហា គឺមានតណ្ហាផុតហើយ ដោយប្រការទាំងពួង ដោយមគ្គដ៏ប្រសើរ ឈ្មោះថា ជាអ្នកមិនប្រកាន់មាំ ព្រោះមិនមានធម៌ណាមួយ ក្នុងឧបាទាន ៤ ព្រោះប្រាសចាកតណ្ហានោះ ឬ ព្រោះមិនមានការប្រកាន់ដែលបានដល់ បដិសន្ធិតទៅ ឈ្មោះថា ជាអ្នកមានសតិ ព្រោះធ្វើដោយមានសតិក្នុងទីទាំងពួង ដោយមានសតិបរិបូណ៌ ជាអ្នកកម្ចាត់កិលេសបានហើយ គប្បីវៀរ គឺគប្បីប្រព្រឹត្ត ឬគប្បីចេញទៅចាកការប្រព្រឹត្តទៅរបស់សង្ខារ ដោយខន្ធបរិនិព្វាន ។*

**អដ្ឋកថាកាមសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បឋមសេក្ខសូត្រ

*[ ១៦ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើបច្ច័យខាងក្នុង ឲ្យជាហេតុ ហើយមិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើនយ៉ាងនេះ ដូចជាយោនិសោមនសិការឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលធ្វើទុកក្នុងចិត្តដោយឧបាយហើយ ទើបលះបង់អកុសល ចម្រើនកុសលបាន ។ លុះព្រះមានព្រះភាគ*

ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

យោនិសោមនសិការ ជាធម៌របស់ភិក្ខុជាសេក្ខៈ ធម៌
ដទៃ ដែលមានឧបការៈច្រើន ដើម្បីសម្រេចប្រយោជន៍
ដ៏ឧត្តមដូច្នោះមិនមានឡើយ កាលភិក្ខុផ្គងចិត្ត ដោយ
ឧបាយ ទើបដល់នូវការអស់ទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## បឋមសេក្ខសូត្រ

ក្នុងបឋមសេក្ខសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១៦ ] បទថា **សេក្ខោ** ក្នុងបទថា **សេក្ខស្ស** នេះ មានអត្ថដូចម្តេច ។ ឈ្មោះថា **សេក្ខ** ព្រោះបាននូវសេក្ខធម៌ សមដូចលោកពោលក្នុងសំយុត្តនិកាយ មហាវារវគ្គថា

បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា សេក្ខៈ សេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា សេក្ខៈនោះ ដោយហេតុប៉ុន្មានយ៉ាង ។

ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសេក្ខសម្មាទិដ្ឋិ ។បេ។

*ប្រកបដោយសេក្ខសម្មាសមាធិ ។*

*ម្នាលភិក្ខុ ដែលឈ្មោះថាសេក្ខៈ ដោយហេតុប៉ុណ្ណោះឯង ។*

*ម្យ៉ាងទៀត ឈ្មោះថា សេក្ខៈ ព្រោះនៅសិក្សានៅឡើយ ដូចព្រះតម្រាស់ដែលត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា*

*ម្នាលភិក្ខុ ព្រោះតែភិក្ខុនៅសិក្សា ហេតុនោះ បានជាតថាគតហៅថា សេក្ខៈ ។ នៅសិក្សាអ្វី ។ ម្នាលភិក្ខុ នៅសិក្សាអធិសីលផង នៅសិក្សាអធិចិត្តផង នៅសិក្សាអធិប្បញ្ញាផង ហេតុនោះ បានជាតថាគត ហៅថា សេក្ខៈ ។*

*សូម្បីបុគ្គលដែលជាកល្យាណបុថុជ្ជន ធ្វើឲ្យបរិបូណ៌ដោយអនុលោមប្បដិបទា ដល់ព្រមដោយសីល គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងភោជន ប្រកបសេចក្តីព្យាយាម ដោយមិនឃើញដល់ការដេកច្រើនជាប្រមាណ ប្រកបដោយសេចក្តីព្យាយាម ដោយការចម្រើនពោធិបក្ខិយធម៌អស់រាត្រីខាងដើម រាត្រីខាងចុង ដោយបំណងថា អញនឹងសម្រេចសាមញ្ញផលណាមួយក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែកនេះ លោកក៏ហៅថា សេក្ខៈ ព្រោះនៅសិក្សា ក្នុងសេចក្តីនេះ លោកបំណងយកព្រះសេក្ខៈ ដែលមិនទាន់បាក់ជ្លុះ ដែលពិត ក៏ជាកល្យាណបុថុជ្ជននោះឯង ។ ឈ្មោះថា* **អប្បត្ត-មានសោ** *ព្រោះអត្ថថា មិនទាន់សម្រេចអរហត្តផល ។ លោកពោលរាគៈថាជាមានសៈ ក្នុងបទនេះថា បទថា* **មានសំ** *បានដល់ រាគៈត្រាច់ទៅ ដូចសំណាញ់អណ្តែតនៅលើអាកាស ។* **មានសំ** *បានដល់ ចិត្ត ដូចក្នុងប្រយោគ*

ជាដើមថា **ចិត្តំ មនោ មានសំ** ចិត្ត មនោ មានសៈ ដូច្នេះ បានដល់ អរហត្ត ដូចក្នុងប្រយោគជាដើមថា **អប្បត្តមានសោ សេក្ខោ កាលំ កយិរា ជនេសុត** បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវករបស់ព្រះអង្គ ជាសេក្ខ-បុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរក្នុងសាសនា គប្បីធ្វើមរណ-កាលដូចម្តេចបាន ដូច្នេះ ។ ក្នុងសូត្រនេះ លោកបំណងយកអរហត្តតែម្យ៉ាង ។ ដោយហេតុនោះ ទើបពោលបានថា **អប្បត្តារហត្តស្ស** ប្រែថា មិនទាន់សម្រេចអរហត្ត ។ បទថា **អនុត្តរំ** គឺប្រសើរបំផុត អធិប្បាយថា មិនមានដូច ។ ឈ្មោះថា **យោគក្ខេមំ** ព្រោះក្សេម ព្រោះមិនត្រូវបៀតបៀនអំពីយោគៈ ៤ ។ លោកបំណងយកអរហត្តនោះឯង ។

បទថា **បត្ថយមានស្ស** បានដល់ សេចក្តីប្រាថ្នា ២ យ៉ាង គឺតណ្ហា-បត្ថនា ១ កុសលឆន្ទបត្ថនា ១ តណ្ហាបត្ថនា បានក្នុងបទនេះថា

**បជ្ជយមានស ហិ ជប្បិតានិ** សេចក្តីប្រាថ្នា គឺវិសដ្ឋិកាតណ្ហា ។ និងប្រយោគមួយទៀតថា **បវេធិតំ វាបិ បកប្បិតេសុ** សេចក្តីប្រាថ្នាតែក្នុងការប្រដាប់តាក់តែង ដូច្នេះ ។

ចំណែកកត្តុកម្យតាកុសលឆន្ទបត្ថនា ដូចក្នុងប្រយោគជាដើមថា បានកាត់កម្ចាត់ខ្សែរបស់មារ ហើយធ្វើឲ្យប្រាសចាកដើមបបុស គឺមានះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកច្រើនដោយសេចក្តីរីករាយ ចូរប្រាថ្នានូវព្រះនិព្វានជាទីក្សេមចុះ ។

ក្នុងទីនេះ លោកបំណងយកឆន្ទបត្ថនានេះឯង ដោយហេតុនោះ បទថា

**បដ្ឋយមានស្ស** ទើបមានអធិប្បាយថា ជាអ្នកប្រាថ្នាដើម្បីធ្វើសេចក្ដីក្សេមចាកយោគៈនោះ គឺបង្អោន ឱន ទោរទន់ទៅកាន់សេចក្ដីក្សេមនោះ ។

បទថា **វិហរតោ** បានដល់ កាត់ផ្ដាច់ចាកទុក្ខក្នុងឥរិយាបថមួយដោយឥរិយាបថមួយ ហើយនាំអត្តភាពដែលមិនទាន់ធ្លាក់ទៅ ។ម្យ៉ាងទៀត គប្បីឃើញសេចក្ដីក្នុងបទនេះ ដោយនិទ្ទេសន័យ គឺការចង្អុលបង្ហាញ មានពាក្យជាដើមថា ភិក្ខុបង្អោនទៅថា សង្ខារទាំងឡាយមិនទៀង រមែងនៅដោយសទ្ធា ។

បទថា **អជ្ឈត្តិកំ** បានដល់ មានខាងក្នុង គឺខាងក្នុងខ្លួន ឈ្មោះថា អជ្ឈត្តិក ។ បទថា **អង្គំ** បានដល់ ហេតុ ។ បទថា **ឥតិ ករិត្វា** គឺធ្វើយ៉ាងនេះ ។ សេចក្ដីសង្ខេបក្នុងបទនេះថា **ន អញ្ញំ ឯកង្គម្បិ សមនុបស្សាមិ** ដូច្នេះ មានន័យថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពិចារណាឃើញហេតុណាមួយដទៃធ្វើហេតុដែលមានខាងក្នុង គឺហេតុដែលតាំងនៅក្នុងសន្ដានរបស់ខ្លួនយ៉ាងនេះ ។ បទថា **ឯវំ ពហូបការំ យថយិទំ យោនិសោមនសិការោ** បានដល់ មនសិការដោយឧបាយ មនសិការតាមគន្លងធម៌ មនសិការដោយន័យក្នុងអនិច្ចលក្ខណៈជាដើមថា ជារបស់មិនទៀងជាដើម ឬការពិចារណា ការតាមពិចារណា ការរំពឹង ការជញ្ជឹង ការដាក់ចិត្ត អនុលោមក្នុងរបស់មិនទៀងនេះ ឈ្មោះថា យោនិសោមនសិការ ។

ឥឡូវនេះ ដើម្បីទ្រង់សម្ដែងដល់អានុភាពនៃយោនិសោមនសិការ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមនសិការដោយឧបាយ

រមែងលះអកុសល ចម្រើនកុសល ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យោនិសោ មនសិការោន្តោ** សេចក្ដីថា ញុំាង យោនិសោមនសិការ ឲ្យប្រព្រឹត្តទៅក្នុងអរិយសច្ច ៤ ថា នេះជាទុក្ខអរិយ-សច្ច នេះជាទុក្ខសមុទយៈ នេះជាទុក្ខនិរោធ នេះជាទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។

តទៅនេះ ជាការអធិប្បាយយ៉ាងជាក់ច្បាស់ក្នុងអរិយសច្ច ៤ នោះ ។ ព្រះសូត្រនេះ សំដៅយកសេក្ខបុគ្គល ដោយមិនប្លែកគ្នាដោយពិត តែយើងនឹងពោលកម្មដ្ឋាន ដោយអំណាចមគ្គ ៤ ផល ៤ ដោយទូទៅ ដោយសង្ខេប ។ ព្រះយោគាវចរណាបំពេញកម្មដ្ឋាន គឺអរិយសច្ច ៤ ជាអ្នកបំពេញកម្មដ្ឋាន គឺ អរិយសច្ច ៤ ក្នុងសម្នាក់អាចារ្យមកអំពីមុន យ៉ាងនេះថា ខន្ធទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានតណ្ហាជាទោស ជាទុក្ខ តណ្ហាជាហេតុឲ្យកើតទុក្ខ ការមិនប្រព្រឹត្តទៅនៃជនទាំង ២ នោះ ជាការរម្ងត់ទុក្ខ ការឲ្យដល់សេចក្ដីរម្ងត់ទុក្ខជាមគ្គ ដូច្នេះ សម័យតមក ព្រះយោគាវចរនោះ ឡើងកាន់វិបស្សនាមគ្គ រមែងពិចារណាខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយឧបាយថា នេះទុក្ខ គឺពិចារណា និងឃើញច្បាស់ដោយឧបាយ គឺដោយគន្លងធម៌ ។ សេចក្ដីពិតក្នុងសូត្រនេះ លោកពោលដល់វិបស្សនា ដោយមាតិកាមនសិការ ។ ព្រះយោគាវចររមែងមនសិការដោយឧបាយថា តណ្ហាមានក្នុងភពមុនដែលជាហេតុឲ្យកើតទុក្ខនោះ ឈ្មោះថា ទុក្ខសមុទយៈ រមែងមនសិការដោយឧបាយថា នេះទុក្ខ នេះសមុទយៈ ទុក្ខទាំងឡាយ ដល់នូវឋានៈនេះហើយ រមែងរលត់

រមែងប្រព្រឹត្តទៅ ដូច្នោះ ទើបប្រកាន់ថា និព្វាននេះ គឺទុក្ខនិរោធ ។ ព្រះយោគាវចររមែងមនសិការដោយឧបាយ រមែងពិចារណា រមែងឃើញច្បាស់នូវមគ្គមានអង្គ ៨ ដែលធ្វើឲ្យដល់ការរម្ងាប់ទុក្ខ ដោយឧបាយត្រូវគន្លងថា នេះទុក្ខនិរោធគាមិនីបដិបទា ។

ក្នុងសេចក្តីនោះ ឈ្មោះថា ប្រកាន់មាំដោយឧបាយនេះ រមែងមានក្នុងខន្ធ ៥ មិនមានក្នុងនិព្វាន ។

ព្រោះដូច្នោះ ទើបមានអធិប្បាយដូច្នេះថា ព្រះយោគាវចរទាញយកមហាភូតរូប ៤ ដោយន័យជាដើមថា បឋវីធាតុ អាបោធាតុ មាននៅក្នុងកាយនេះ និងឧបាទារូប ដោយទំនងដូចគ្នានឹងមហាភូតរូប ៤ នោះ ហើយកំណត់ថា នេះរូបក្ខន្ធ ដូច្នេះ ។ កាលឲ្យកំណត់ដូច្នោះ ទើបកំណត់ដល់ធម៌គឺចិត្ត និងចេតសិក ដែលមានរូបក្ខន្ធនោះជាអារម្មណ៍ថា ធម៌ទាំងនេះ គឺអរូបក្ខន្ធ ៤ បន្ទាប់អំពីនោះ កំណត់ថា ខន្ធទាំង ៥ នេះជាទុក្ខ ។ ខន្ធទាំង ៥ នោះដោយសង្ខេប មាន ២ ចំណែក គឺនាម និងរូប ព្រះយោគាវចររមែងកំណត់ហេតុ និងបច្ច័យថា នាមរូបនេះ មានហេតុ មានបច្ច័យ ទើបកើតឡើង អវិជ្ជា ភព តណ្ហាជាដើម នេះជាហេតុនៃនាមរូបនោះ អាហារជាដើមជាបច្ច័យរបស់នាមរូបនោះ ។ ព្រះយោគាវចរនោះកំណត់លក្ខណៈ មួយអន្លើដោយកិច្ច រស របស់បច្ច័យទាំងឡាយនោះ និងធម៌ដែលកើតដោយបច្ច័យតាមសេចក្តីពិត ហើយលើកឡើងកាន់អនិច្ចលក្ខណៈថា ធម៌ទាំងឡាយនេះមិនមានហើយ កាលមានហើយ រមែងរលត់ទៅ ព្រោះដូច្នោះ ទើបធម៌ទាំង-

ឡាយមិនទៀង រមែងលើកឡើងកាន់ទុក្ខលក្ខណៈថា ធម៌ទាំងឡាយឈ្មោះថា ជាទុក្ខ ព្រោះការកើត ការវិនាសបៀតបៀន រមែងលើកឡើងកាន់អនត្តលក្ខណៈថា ធម៌ទាំងឡាយ ឈ្មោះថា ជាអនត្តា ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ ព្រះយោគាវចរ កាលលើកឡើងកាន់ត្រៃលក្ខណ៍យ៉ាងនេះហើយ ឃើញច្បាស់ កំណត់ផ្លូវ និងមិនមែនផ្លូវថា កាលវិបស្សនូបក្កិលេសមានពន្លឺជាដើមកើតឡើងក្នុងខណៈឧទយព្វយញ្ញាណកើត នេះមិនមែនផ្លូវ ឧទយព្វយញ្ញាណប៉ុណ្ណោះជាឧបាយ គឺជាផ្លូវ ដែលជាចំណែកខាងដើមរបស់អរិយមគ្គ ញ៉ាំងឧទយព្វយញ្ញាណ និងភង្គញ្ញាណជាដើមឲ្យកើតឡើងតាមលំដាប់ រមែងបានសម្រេចសោតាបត្តិមគ្គជាដើម ។ ក្នុងខណៈនោះ ព្រះយោគាវចររមែងចាក់ធ្លុះនូវអរិយសច្ច ៤ ដោយការចាក់ធ្លុះតែម្តងប៉ុណ្ណោះ រមែងត្រាស់ដឹងដោយការត្រាស់ដឹងម្តង ។ អរិយសច្ចនោះ ព្រះយោគាវចរ រមែងចាក់ធ្លុះនូវទុក្ខ ដោយការកំណត់ដឹង រមែងត្រាស់ដឹងដោយការត្រាស់ដឹងតែម្តង ។ ក្នុងអរិយសច្ចនោះ ព្រះយោគាវចរចាក់ធ្លុះនូវទុក្ខ ដោយការកំណត់ដឹង ចាក់ធ្លុះនូវសមុទយៈដោយឧបាយ ដោយការចាក់ធ្លុះ ដោយការលះ រមែងលះអកុសលទាំងពួងបាន ។ ព្រះយោគាវចរ ចាក់ធ្លុះនូវនិរោធដោយការត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់នូវមគ្គ ដោយការត្រាស់ដឹងដោយការភាវនា តែងចម្រើនកុសលទាំងពួង ។ ពិតហើយ អរិយមគ្គ ឈ្មោះថា កុសល ព្រោះអត្ថថា កម្ចាត់នូវវត្ថុដែលគួរខ្ពើមដោយត្រង់ កាលចម្រើនអរិយមគ្គហើយ ពោធិបក្ខិយធម៌ ដែលមិនមានទោស ជាកុសលទាំងអស់ ក៏រមែងដល់នូវការ

បរិបូណ៌ដោយភាវនា ព្រោះហេតុនោះ ព្រះយោគាវចរកាលមនសិការដោយឧបាយយ៉ាងនេះ រមែងលះអកុសលចេញបាន រមែងចម្រើនធម៌ដែលជាកុសល សមដូចព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា ព្រះយោគាវចរ តែងមនសិការដោយឧបាយថា នេះទុក្ខ នេះទុក្ខសមុទយៈ ដូច្នេះ ។ កាលព្រះមានព្រះភាគត្រាស់សេចក្ដីដទៃទៀតថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុដល់ព្រមហើយដោយយោនិសោមនសិការ ភិក្ខុនឹងចម្រើនមគ្គមានអង្គ ៨ ដែលជាអរិយៈ ដែលគប្បីសង្ឃឹមបាន និងធ្វើឲ្យច្រើននូវមគ្គមានអង្គ ៨ ដែលជាអរិយៈ ដូច្នេះ ។

តអំពីនេះទៅ ជាសេចក្ដីសង្ខេបនៃគាថាថា **យោនិសោ មនសិការោ ។** ឈ្មោះថា សេក្ខៈ ព្រោះត្រូវសិក្សាសិក្ខាបទទាំងឡាយ ឬព្រោះនៅមានការសិក្សាជាប្រក្រតី ។ ឈ្មោះថា ភិក្ខុ ព្រោះឃើញភ័យក្នុងសង្សារ ។ ធម៌ណាមួយដទៃដែលមានឧបការៈច្រើន ដូចយោនិសោមនសិការ ដើម្បីឲ្យភិក្ខុដែលនៅជាសេក្ខៈនោះសម្រេចនូវអរហត្ត ដែលមានប្រយោជន៍ដ៏ឧត្ដម រមែងមិនមាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រះយោគាវចរបំណាងនឹងមនសិការដោយឧបាយប្រាជ្ញា ហើយផ្ដើមតាំងសេចក្ដីព្យាយាម ដោយសម្មប្បធាន ៤ គប្បីដល់នូវការអស់ទុក្ខបាន គឺគប្បីដល់ គប្បីសម្រេចព្រះនិព្វានដែលជាទីបំផុតនៃវដ្ដទុក្ខដ៏សៅហ្មងឥតសេសសល់ ដូច្នោះ ទើបយោនិសោមនសិការ ជាធម៌មានឧបការៈច្រើន ដូច្នេះ ។៚

**អដ្ឋកថា បឋមសេក្ខសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ទុតិយសេក្ខសូត្រ

[ ១៧ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើបច្ច័យខាងក្រៅឲ្យជាហេតុ ហើយមិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើន យ៉ាងនេះ ឲ្យដូចជាភាពនៃបុគ្គល មានកល្យាណមិត្តនេះឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត ទើបលះបង់អកុសល ចម្រើនកុសលបាន ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា មានកល្យាណមិត្ត មានសេចក្តីកោតក្រែង
ប្រកបដោយសេចក្តីគោរព ធ្វើតាមពាក្យរបស់
កល្យាណមិត្ត ជាអ្នកមានសេចក្តីដឹងខ្លួន មានស្មារតី
ភិក្ខុនោះ ទើបគួរដល់នូវកិរិយាអស់សំយោជនៈទាំង
ពួង ដោយលំដាប់បាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## ទុតិយសេក្ខសូត្រ

ក្នុងទុតិយសេក្ខសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១៧ ] បទថា **ពាហិរំ** បានដល់ ហេតុដែលមានខាងក្រៅ ចាកសន្តានខាងក្នុង ។ បទថា **កល្យាណមិត្តតា** បានដល់ បុគ្គលដែលសម្បូរដោយគុណ មានសីលជាដើម ជាអ្នកកម្ចាត់សេចក្តីអាក្រក់ ដែលជាអ្នកបន្ថែមនូវប្រយោជន៍ ជាមិត្តមានឧបការៈសព្វយ៉ាង ឈ្មោះថា កល្យាណមិត្ត ភាពជាកល្យាណមិត្តនោះ ឈ្មោះថា **កល្យាណមិត្តតា** ។ ក្នុងបទថា **កល្យាណមិត្តតា** នោះ មានអធិប្បាយដូច្នេះ តាមប្រក្រតី កល្យាណមិត្តនេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគៈ វីរិយៈ សតិ សមាធិ និងបញ្ញា ។ កល្យាណមិត្ត ព្រោះដល់ព្រមដោយសទ្ធា រមែងជឿនូវការត្រាស់ដឹងរបស់ព្រះតថាគត តែងមិនលះបង់នូវការស្វែងរកប្រយោជន៍ និងសេចក្តីសុខក្នុងសត្វទាំងឡាយដែលកើតឡើង ព្រោះការត្រាស់ដឹងប្រពៃនោះ ព្រោះដល់ព្រមដោយសីល ទើបរមែងជាទីស្រឡាញ់ និងជាទីគោរពរបស់សព្រហ្មចារីទាំងឡាយ ជាបុគ្គលគួរសរសើរ ចាំជាស់តឿន តិះដៀលនូវបាបចាំតម្រូវតម្រង់ អត់ធន់ក្នុងពាក្យសម្តី ព្រោះដល់ព្រមដោយសុតៈ ទើបជាបុគ្គលពោលនូវពាក្យជ្រាលជ្រៅ ដែលមានខន្ធ អាយតនៈ សច្ចៈ បដិច្ច-សមុប្បាទជាដើម ព្រោះដល់ព្រមដោយចាគៈ ទើបជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកមានវិវេក មិនច្រឡូកច្រឡំ ព្រោះដល់ព្រមដោយវីរិយៈ ទើបជាអ្នកព្យាយាម ក្នុងកិច្ចបដិបត្តិនូវប្រយោជន៍ដល់ខ្លួន និង

អ្នកដទៃ ព្រោះដល់ព្រមដោយសតិ ទើបជាអ្នកមាន សតិតាំងមាំ ជាអ្នកដល់ព្រមដោយជុំវិញ គឺសតិដ៏កំពូល ជាអ្នករឭកបាន ចាំបានវត្ថុដែលធ្វើពាក្យដែលពោលយូរមកហើយ ព្រោះដល់ព្រមដោយសមាធិ ទើបជាអ្នកមិនរាយមាយ ជាអ្នកមាំទាំ មានចិត្តជាឯកគ្គតា និងព្រោះដល់ព្រមដោយបញ្ញា ទើបរមែងដឹងនូវវត្ថុដែលមិនវិបរិត កល្យាណមិត្តនោះ ស្វែងរកគតិធម៌ ទាំងដែលជាកុសល និងអកុសលដោយសតិ ដឹងប្រយោជន៍របស់សត្វទាំងឡាយតាមសេចក្តីពិត ដោយបញ្ញា ជាអ្នកមានចិត្តមិនរាយមាយក្នុងអារម្មណ៍នោះ ដោយសមាធិ ហាមឃាត់នូវសត្វទាំងឡាយចាកធម៌ ដែលមិនជាប្រយោជន៍ ដោយសេចក្តីព្យាយាម រមែងណែនាំក្នុងធម៌ ដែលមានប្រយោជន៍តែម្យ៉ាង ដូចព្រះមានព្រះភាគត្រាស់ថា

កល្យាណមិត្តជាទីស្រឡាញ់ គួរគោរព គួរសរសើរ ជាអ្នកពោលជាស់តឿន អត់ធន់ក្នុងពាក្យ ( ទូន្មាន ) ជាអ្នកពោលពាក្យជ្រាលជ្រៅ មិនដឹកនាំក្នុងហេតុដែលមិនសមគួរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាកល្យាណមិត្ត រមែងលះអកុសល ចម្រើនកុសល ព្រោះហេតុនោះ បុគ្គលដែលជាកល្យាណមិត្ត អាស្រ័យភិក្ខុដែលជាកល្យាណមិត្ត ញុំាងកម្មស្សតាញាណឲ្យកើត រមែងធ្វើសទ្ធាដែលកើតឡើងហើយឲ្យមាំទាំ កើតសទ្ធាហើយក៏ចូលទៅរក កាលចូលទៅរកហើយ រមែងស្តាប់ធម៌ កាលស្តាប់ធម៌ហើយរមែងបាននូវសទ្ធាក្នុងព្រះតថាគត ដោយការបាននូវសទ្ធានោះ ទើបលះឃរាវាសចេញបួស ធ្វើនូវបារិសុទ្ធិសីល ៤ ឲ្យដល់ព្រម សមាទានធុតធម៌

*ប្រព្រឹត្តទៅតាមកម្លាំង ជាអ្នកបាននូវកថាវត្ថុ ១០ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ចូលទៅតម្កល់នូវសតិ មានសម្បជញ្ញៈ ចម្រើនពោធិបក្ខិយធម៌ អស់យប់ និងថ្ងៃ ក្នុងកាលមិនយូរ ធ្វើវិបស្សនាឲ្យកាត់ផ្តាច់នូវអកុសលទាំងអស់ ដោយការសម្រេចអរិយមគ្គ និងញុំាំងកុសលធម៌ទាំងពួងឲ្យចម្រើន ដល់នូវភាពបរិបូណ៌ដោយភាវនា ។ សមដូចព្រះមានព្រះភាគត្រាស់នៅក្នុងឧទានថា ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្តល្អ សេពគប់មិត្តល្អ ។ ម្នាលមេឃិយៈ នេះជាធម៌ទី ១ ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លាឲ្យចាស់ក្លាបាន ។ ម្នាលមេឃិយៈ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមហើយដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារនិគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។បេ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ សេពគប់មិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវកថាមានសភាពយ៉ាងនេះ គឺអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វីរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ ។បេ។ វិមុត្តិញាណទស្សនកថា ១ ដែលជាកថាជូរចត់ ជាទីសប្បាយ ទូលាយចិត្ត ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងកើតប្រាកដដល់ភិក្ខុដែលមានមិត្តល្អ*

មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ទាំងឡាយឲ្យកើតឡើង មានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលមេឃិយៈ គុណជាតនុ៎ះ រមែងមានប្រាកដដល់ភិក្ខុដែលមានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកមិត្តល្អ ព្រោះភិក្ខុនោះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងដឹងនូវការកើតឡើង និងសូន្យទៅ ជាប្រាជ្ញាដ៏ប្រសើរ អាចទម្លុះទម្លាយកិលេស ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ក្នុងសំយុត្តនិកាយ សគាថវគ្គថា ម្នាលអានន្ទ សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិ សត្វទាំងឡាយ មានជរាជាធម្មតា រមែងរួចចាកជរា ។បេ។ ក៏ព្រោះអាស្រ័យនឹងតថាគតជាមិត្តល្អ ដូច្នេះ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាកល្យាណមិត្ត រមែងលះអកុសល ចម្រើនកុសល ដូច្នេះ ។ គប្បីជ្រាបអត្ថនៃគាថាដូចតទៅនេះថា បទថា **សប្បតិស្សា** ឈ្មោះថា **សប្បដិស្ស** ព្រោះប្រព្រឹត្តទៅដោយការកោតក្រែង គឺការស្តាប់ ។ ជាអ្នកបង្អោនទទួលឱវាទនៃកល្យាណមិត្ត អធិប្បាយថា ជាអ្នកប្រដៅងាយ ។ ម្យ៉ាងទៀត អ្នកឲ្យឱវាទ ឈ្មោះ **បដិស្ស** ព្រោះប្រាថ្នាឲ្យកើតប្រយោជន៍ និងសុខ ។ ឈ្មោះថា **សប្បតិស្ស** ព្រោះប្រព្រឹត្តទៅដោយការប្រាថ្នានោះ ប្រកបដោយសេចក្តីគោរព ការអើពើ ។ ច្រើនដោយការគោរពកោតក្រែងក្នុងបុគ្គលដែលជាគ្រូ ។ បទថា **សគារវោ** បានដល់ ប្រកបដោយគារវធម៌

៦ យ៉ាង ។ បទថា **ករំ មិត្តាន វចនំ** បានដល់ ការធ្វើតាមឱវាទ គឺបដិបត្តិតាមឱវាទរបស់កល្យាណមិត្តទាំងឡាយ ។ បទថា **សម្បជានោ** បានដល់ប្រកបដោយសម្បជញ្ញៈ ៧ យ៉ាង ។ បទថា **បតិស្សតោ** បានដល់ មានសតិ គឺធ្វើដោយមានស្មារតី ដោយសតិដែលអាចឲ្យកើតការមាំទាំរបស់កម្មដ្ឋានបាន ។ បទថា **អនុបុព្វេន** បានដល់ លំដាប់នៃសីលវិសុទ្ធិជាដើម គឺដោយលំដាប់នៃវិបស្សនា និងលំដាប់នៃមគ្គក្នុងសីលវិសុទ្ធិជាដើមនោះ ។ បទថា **សព្វសំយោជនក្ខយំ** សេចក្តីថា គប្បីដល់ គឺគប្បីសម្រេចព្រះនិព្វានដែលជាអារម្មណ៍នៃអរហត្ត ដែលជាទីបំផុត ពោល គឺការអស់នូវសំយោជនៈទាំងពួង ព្រោះសំយោជនៈទាំងអស់ មានកាមរាគសំយោជនៈជាដើមអស់ ។

ក្នុងសូត្រទាំង ២ នេះ គប្បីជ្រាបថា ព្រះសាស្តាទ្រង់កាន់យកអង្គនៃការព្យាយាមរបស់ការសម្រេចអរិយមគ្គ ដោយប្រការដូច្នេះ ។

**អដ្ឋកថា ទុតិយសេក្ខសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ភេទសូត្រ

[ ១៨ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ១ តើដូចម្តេច ។ គឺសង្ឃភេទ ( ការបំបែកសង្ឃ ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការឈ្លោះប្រកែកគ្នានិងគ្នា ក៏កើតមាន ការប្រទេចផ្តាសាគ្នានិងគ្នា ក៏កើតមាន ការបោកបោះពាក្យសម្តីដល់គ្នានិងគ្នា ក៏កើតមាន ការលះបង់គ្នានិងគ្នា ក៏កើតមាន ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាក្នុងសង្ឃនោះ ក៏មិនជ្រះថ្លា ជនពួកខ្លះ ដែលជ្រះថ្លាស្រាប់ហើយ ក៏ងាកទៅជាយ៉ាងដទៃវិញ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលជាអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនឋិតក្នុង
ធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំង
នៅអស់មួយកប្ប រមែងសាបសូន្យចាកធម៌ជាទីក្សេម
ចាកយោគៈ បុគ្គលបំបែកសង្ឃ ដែលព្រមព្រៀងគ្នា
ហើយ តែងឆេះក្នុងនរកអស់មួយកប្ប ។

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។*

# អដ្ឋកថា

## ភេទសូត្រ

*ក្នុងភេទសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ១៨ ] បទថា* **ឯកធម្មោ** *បានដល់ ការតាំងឡើងនៃព្រះសូត្រនេះដូចម្តេច ។ ក្នុងសូត្រនេះ មានអត្ថុប្បត្តិហេតុសង្ខេបដូចតទៅនេះ បានឮថា ទេវទត្តបបួលព្រះបាទអជាតសត្តុឲ្យកាន់យកខុស សម្លាប់ព្រះបាទពិម្ពិសារដែលជាព្រះជនករបស់ព្រះអង្គខ្លះ បបួលនាយខ្មាន់ធ្នូឲ្យសម្លាប់ខ្លះ ធ្វើនូវលោហិតុប្បាទដោយការប្រមៀលថ្មខ្លះ ទោសនោះមិនទាន់ប្រាកដ តែប្រាកដក្នុងកាលដែលលែងដំរីនាឡាគិរី ។ គ្រានោះ មហាជនបានក្រេវក្រោធឡើងថា ព្រះរាជាទ្រង់សេពគប់មនុស្សអាក្រក់បែបនេះហើយ បានប្រកាសឲ្យល្បីខ្ចរខ្ចាយទៅ ។ ព្រះរាជាកាលបានស្តាប់ដូច្នោះ ទើបត្រាស់ឲ្យដកថាសអាហារ ៥០០ សម្រាប់ដែលទ្រង់ព្រះរាជទាន ទ្រង់មិនយាងទៅឧបដ្ឋាកទេវទត្តជាបន្តទៅទៀត ។ អ្នកនគរក៏មិនឲ្យអាហារត្រឹមតែមួយវែកដល់ទេវទត្តភិក្ខុ ដែលចូលទៅរកត្រកូល ។ ទេវទត្តនោះវិនាសចាកលាភ និងសក្ការៈ បំណងនឹងធ្វើជីវិតឲ្យតាំងនៅដោយការបោកបញ្ឆោត ទើបចូលទៅគាល់ព្រះសាស្តាទូល*

សូមវត្ថុ ៥ ប្រការ ត្រូវព្រះមានព្រះភាគទ្រង់ហាមដោយពុទ្ធតម្រាស់ថា កុំអី ទេវទត្ត ភិក្ខុណាប្រាថ្នា ភិក្ខុនោះ ចូរកាន់យកការនៅព្រៃជាវត្តចុះ ទេវទត្ត ញុំាងជនដែលជ្រះថ្លាក្នុងសេចក្ដីសៅហ្មង ជាបុគ្គលល្ងង់ខ្លៅ ឲ្យឃើញប្រពៃ ដោយវត្ថុ ៥ ប្រការនោះ ឲ្យភិក្ខុវជ្ជី ៥០០ ចាប់ស្លាក ហើយបំបែកសង្ឃឲ្យ បែកគ្នា នាំភិក្ខុនោះទៅកាន់គយាសីសបទេស ។

លំដាប់នោះ អគ្គសាវក ២ រូប ដោយព្រះពុទ្ធតម្រាស់របស់ព្រះសាស្ដា នាំគ្នាទៅកាន់គយាសីសបទេសនោះ សម្ដែងធម៌ឲ្យភិក្ខុ ៥០០ នោះ តាំងនៅ ក្នុងអរិយផល ហើយនាំត្រឡប់មក ។ ឯភិក្ខុពួកណាគាប់ចិត្តក្នុងលទ្ធិរបស់ ទេវទត្ត ដែលព្យាយាមដើម្បីបំបែកសង្ឃ ក៏នៅលើកតម្កើងដដែល កាល សង្ឃកំពុងបែក និងបែកហើយ ក៏កើតការពេញចិត្ត សេចក្ដីនោះប្រាកដដើម្បី ការមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដល់ភិក្ខុទាំងនោះ ។ មិនយូរនោះឯង ទេវទត្តក៏ត្រូវរោគបៀតបៀន អាពាធធ្ងន់ ទៀបនឹងស្លាប់ គិតថា អញនឹងថ្វាយ បង្គំព្រះសាស្ដា ទើបឲ្យគេនាំឡើងលើគ្រែ ហើយសែងទៅ ដល់ប្រាំងស្រះ បោក្ខរណី ក្បែរវត្តជេតពន ខណៈនោះ ផែនដីក៏ញែកជា ២ ទេវទត្តក៏ធ្លាក់ ទៅកើតក្នុងអវីចិមហានរក ។ សរីរៈរបស់ទេវទត្តកម្ពស់ ១០០ យោជន៍ ត្រូវលំពែងដែក ទំហំប៉ុនដើមត្នោតចាក់អស់កប្ប ។ ត្រកូលប្រមាណ ៥០០ ដែលផ្គត់ផ្គង់ទេវទត្ត ជឿក្នុងលទ្ធិរបស់ទេវទត្តនោះ មួយអន្លើដោយបក្ខពួក ក៏ទៅកើតក្នុងនរកដូចគ្នា ។ម្យ៉ាងទៀត ភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្ម- សភាថា អាវុសោទាំងឡាយ ទេវទត្តទបំបែកសង្ឃ ជាការធ្វើកម្មធ្ងន់ គ្រានោះ

*ព្រះសាស្តាក៏យាងទៅកាន់ធម្មសភា ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលឲ្យទ្រង់ជ្រាបហើយ កាលទ្រង់សម្តែងដល់ទោសក្នុងការបំបែកសង្ឃ ទើបត្រាស់ព្រះសូត្រនេះ ។ តែអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគ ឃើញការដែលទេវទត្ត និងគ្នីគ្នារបស់ទេវទត្តនោះ កើតក្នុងនរកយ៉ាងនោះហើយ កាលទ្រង់សម្តែងទោសក្នុងការបំបែកសង្ឃ ទើបទ្រង់សម្តែងសូត្រនេះ ដោយអធ្យាស្រ័យរបស់ទ្រង់នោះឯង ។*

*ក្នុងបទទាំងនោះ បទថា* **ឯកធម្មោ** *បានដល់ ធម៌ ១ មានទោសច្រើនជាអកុសល ។ បទថា* **លោកេ** *បានដល់ សត្វលោក ។ បទថា* **ឧប្បជ្ជមានោ ឧប្បជ្ជតិ** *នេះ មានអធិប្បាយថា កាលជម្លោះជាដើម ដែលប្រព្រឹត្តទៅក្នុងការបំបែកកើតឡើងក្នុងសង្ឃក្តី ពោលដោយភេទករវត្ថុ ១៨ យ៉ាង ឯណានីមួយ មានធម៌ អធម៌ ដូច្នេះក្តី ប្រកាសដើម្បីឲ្យកើតការគាប់ចិត្តក្នុងការបំបែកសង្ឃនោះក្តី កាលប្រកាសចាប់ស្លាកហើយក្តី សង្ឃភេទ ឈ្មោះថាកើតឡើង ។ កាលឲ្យចាប់ស្លាកហើយ ភិក្ខុ ៤ រូប ឬលើស ៤ រូបបែកគ្នាធ្វើឧទ្ទេស ឬសង្ឃកម្មកាលណា កាលនោះ សង្ឃភេទ ឈ្មោះថា រមែងកើតឡើង ។ កាលធ្វើសង្ឃភេទហើយ ឈ្មោះថា ការទម្លាយបានកើតឡើងហើយ ។ កម្មក្តី ឧទ្ទេសក្តី ជាការកំណត់ក្នុងហេតុនៃការបំបែកសង្ឃទាំង ៥ នេះ គឺកម្ម ឧទ្ទេស វោហារ អនុសាវនៈ ( ការប្រកាស ) សលាកគ្គាហៈ ( ការចាប់ស្លាក ) ឯវោហារ អនុសាវនៈ និងសលាកគ្គាហៈ ជាចំណែក*

ខាងដើម ។

ក្នុងបទថា **ពហុជនាហិតាយ** ជាដើម មានអត្ថជាប់គ្នា ដូច្នេះថា ធម៌ឯណានីមួយ រមែងកើតឡើងដើម្បីមិនជាប្រយោជន៍ដល់មហាជន ដោយឃាត់នូវសម្បត្តិ មានឈាន និងមគ្គជាដើម ដើម្បីមិនមែនសេចក្តីសុខ ដល់មហាជន ដោយហាមសម្បត្តិ គឺសួគ៌ ដើម្បីការវិនាសដល់មហាជន ជាហេតុឲ្យកើតក្នុងអបាយ ដើម្បីមិនជាប្រយោជន៍ដល់មហាជន ដោយអកុសលធម៌ ដើម្បីទុក្ខផ្លូវកាយ ផ្លូវចិត្ត ដែលធ្វើឲ្យកើតក្នុងសុគតិ ព្រោះមិនមានមគ្គឧបការៈ ។ បទថា **ទេវមនុស្សានំ** នេះ សម្តែងដល់បុគ្គលដ៏កំពូល ក្នុងកាលលោកពោលថា **ពហុនោ ជនស្ស** ដូច្នេះ ។

ម្យ៉ាងទៀត បទថា **ពហុជនាហិតាយ** បានដល់ ដើម្បីមិនជាប្រយោជន៍ដល់មហាជន គឺដល់ពួកសត្វច្រើន អធិប្បាយថា ដើម្បីការមិនជាប្រយោជន៍ក្នុងទិដ្ឋធម៌ និងសម្បរាយកភព ។ បទថា **អសុខាយ** បានដល់ ដើម្បីមិនមែនសេចក្តីសុខក្នុងទិដ្ឋធម៌ និងសម្បរាយកភព អធិប្បាយថា ដើម្បីភាពជាទុក្ខ ២ យ៉ាង ។ បទថា **អនត្ថាយ** បានដល់ ដើម្បីក្លាំងក្លាត់នូវបរមត្ថប្រយោជន៍ពិតហើយ ព្រះនិព្វាន ឈ្មោះថា បរមត្ថប្រយោជន៍ ។ ប្រយោជន៍ក្រៃលែងជាងព្រះនិព្វាននោះមិនមាន ។ បទថា **អហិតាយ** បានដល់ ដើម្បីក្លាំងក្លាត់ស្ថានសួគ៌ និងមគ្គ ។ ពិតហើយ ឈ្មោះថា ប្រយោជន៍ក្រៃលែងជាងមគ្គដែលជាផ្លូវឲ្យដល់នូវប្រយោជន៍ គឺព្រះនិព្វាន មិនមាន ។ បទថា **ទុក្ខាយ** បានដល់ ដើម្បីសេចក្តីទុក្ខក្នុងវដ្តៈ ។ ដោយក្លាំងក្លាត់ចាកអរិយសុខ ។ ពិត

ហើយ បុគ្គលដែលភ្លាំងភ្លាត់ចាកអរិយសុខហើយ មិនគួរសម្រេចអរិយសុខនោះ បុគ្គលនោះរមែងបង្អោនទៅក្នុងវដ្តទុក្ខ ។ ពិតហើយ ឈ្មោះថា សុខក្រៃលែងជាងអរិយសុខមិនមាន សមដូចព្រះមានព្រះភាគត្រាស់ថា **អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ អាយតិញ្ច សុខវិបាកោ** សមាធិនេះ ជាសុខក្នុងបច្ចុប្បន្នផង មានសុខជាវិបាកតទៅផង ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយសរុប បទថា **សង្ឃភេទោ** ហើយ ដើម្បីទ្រង់ប្រកាសការៈនៃសង្ឃភេទនោះ ជាហេតុនៃការមិនឧបការៈជាដើមដោយចំណែកមួយ ទើបពោលពាក្យជាដើមថា **សង្ឃេ ខោ បន ភិក្ខវេ ភិន្នេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភិន្នេ** ជាសត្តមីវិភត្តិ ក្នុងអត្ថថា និមិត្ត ដូចទ្រព្យមិនកើតឡើងដល់អ្នកមិនមានទ្រព្យ អធិប្បាយថា ព្រោះបែកគ្នា ។ បទថា **អញ្ញមញ្ញំ ភណ្ឌនានិ** បានដល់ ជជែកគ្នាថា នេះធម៌ នេះមិនមែនធម៌នៃបរិស័ទ ៤ និងរបស់ដែលជាចំណែកនៃបរិស័ទនោះ ។ ពិតហើយ វិវាទជាខាងដើមនៃជម្លោះ ។ បទថា **បរិភាសា** បានដល់ គំរាម ដោយឲ្យកើតការខ្លាចថា យើងនឹងធ្វើសេចក្តីវិនាសនេះៗ ដល់ពួកអ្នក ដូច្នេះ។ បទថា **បរិក្ខេបា** បានដល់ មើលងាយដោយជាតិជាដើម គឺជេរ និងប្រមាថដោយអក្កោសវត្ថុ ១០ ។ បទថា **បរិច្ចជនា** បានដល់ បណ្តេញឲ្យចេញទៅ ដោយធ្វើឧក្ខេបនីយកម្ម គឺការបណ្តេញជាដើម ។ បទថា **តត្ថ** បានដល់ ព្រោះសង្ឃបែកគ្នានោះ ឬព្រោះជម្លោះជាដើម ដែលជានិមិត្តនៃសង្ឃភេទនោះ ។ បទថា

**អប្បសន្នា** បានដល់ ជនដែលមិនដឹងដល់គុណរបស់ព្រះរតនត្រ័យ ។ បទថា **ឥប្បសីទន្តិ** បានដល់ មិនជ្រះថ្លាក្នុងការជ្រះថ្លាក្នុងភិក្ខុទាំងឡាយថា ភិក្ខុទាំងនេះជាអ្នកប្រព្រឹត្តធម៌ ជាអ្នកប្រព្រឹត្តស្មើជាដើម ឬមិនដាក់ចិត្តស្តាប់ និងជឿភិក្ខុទាំងនោះ ។ ម្យ៉ាងទៀត ជាអ្នកមិនជ្រះថ្លាក្នុងធម៌ និងក្នុងព្រះសាស្តាក៏ដូចគ្នា ។ បទថា **ឯកច្ចានំ អញ្ញថត្តំ** បានដល់ បុថុជ្ជនដែលមានសទ្ធាមិនទៀងក្តី ក៏ជ្រះថ្លាក្នុងទីដទៃ ។

នឹងអធិប្បាយក្នុងគាថាតទៅ ក្នុងបទថា **អាបាយិកោ** ជាដើម ឈ្មោះថា **អបាយិកោ** ព្រោះគួរទៅកើតក្នុងអបាយ ។ ឈ្មោះថា **នេរយិកោ** ព្រោះត្រូវកើតក្នុងមហានរក គឺអវីចីនោះ ។ ឈ្មោះថា **កប្បដ្ឋោ** ព្រោះតាំងនៅក្នុងមហានរកនោះអស់មួយកប្បបរិបូណ៌ ។ ឈ្មោះថា **វគ្គរតោ** ព្រោះត្រេកអរក្នុងពួកបំបែកសង្ឃផងគ្នា ។ ឈ្មោះថា **អធម្មោ** ព្រោះមិនមែនធម៌ ។ ឈ្មោះថា **អធម្មដ្ឋោ** ព្រោះតាំងនៅក្នុងអធម៌ គឺបំបែកសង្ឃដោយភេទករវត្ថុ ។ បទថា **យោគក្ខេមតោ** បានដល់ រមែងកម្ចាត់ គឺរមែងសាបសូន្យចាកធម៌ដ៏ក្សេមអំពីយោគៈនោះ ។ អរហត្ត និងព្រះនិព្វាន ឈ្មោះថា ក្សេមចាកយោគៈ ព្រោះផុតចាកយោគៈ ៤ តែមិនគួរពោលដល់ក្នុងការកម្ចាត់អរហត្ត និងព្រះនិព្វាននោះចាកធម៌ដែលក្សេមចាកយោគៈនោះ ឈ្មោះថា **សង្ឃំ** ព្រោះអត្ថថា បន្តចាកភាពជាអ្នកមានទិដ្ឋិ និងសីលស្មើគ្នា ។ ឈ្មោះ **សមគ្គំ** គឺឲ្យនូវការឧបការៈដល់គ្នានិងគ្នា ព្រោះប្រកបដោយបែបផែន មានកម្មដូចគ្នា ។ បទថា **ភេត្វាន** បានដល់ បំបែកដោយឲ្យសង្ឃបែកគ្នា ដែលមានលក្ខណៈ

ដូចបានពោលពីមុនមកហើយ ។ បទថា **កប្បំ** បានដល់ អាយុកប្ប ។ អាយុកប្ប ក្នុងទីនេះ គឺអន្តរកប្បនោះឯង ។ បទថា **និរយម្ហិ** បានដល់ អវិចីមហានរក ។ល។

**អដ្ឋកថា ភេទសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## មោទសូត្រ

[ ១៩ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីជាសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើនដល់ជនច្រើន ដើម្បីជាសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ១ តើដូចម្តេច ។ គឺសេចក្តីព្រមព្រៀងរបស់សង្ឃ ។ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការឈ្លោះប្រកែកគ្នានិងគ្នា ក៏មិនកើតមាន ការប្រទេចផ្តាសាគ្នានិងគ្នា ក៏មិនកើតមាន ការបោកបោះពាក្យសម្តីដល់គ្នានិងគ្នា ក៏មិនកើតមាន ការលះបង់គ្នានិងគ្នា ក៏មិនកើតមាន ជនទាំងឡាយដែលមិនជ្រះថ្លាក្នុងសង្ឃនោះ ក៏រមែងជ្រះថ្លា ពួកជនដែលជ្រះថ្លាស្រាប់ហើយ ក៏រឹងរឹតតែជ្រះថ្លាឡើង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រ

នោះថា

សេចក្តីព្រមព្រៀងនៃសង្ឃ ជាហេតុនាំសេចក្តីសុខមកឲ្យ ការអនុគ្រោះបុគ្គលទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា ( ជាហេតុនាំសេចក្តីសុខមកឲ្យ ) បុគ្គលត្រេកអរ ក្នុងជនដែលព្រមព្រៀងគ្នា តាំងនៅក្នុងធម៌ រមែងមិនសាបសូន្យ ចាកធម៌ជាទីក្សេម ចាកយោគៈ បុគ្គលធ្វើសង្ឃ ឲ្យព្រមព្រៀងគ្នា រមែងរីករាយ ក្នុងស្ថានសួគ៌ អស់ ១ កប្ប ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគត្រាស់ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## មោឃសូត្រ

ក្នុងមោឃសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១៩ ] បទថា **ឯកធម្មោ** បានដល់ ធម៌ ១ ជាកុសលដែលមិនមានទោស ។ បើការវិវាទគប្បីកើតឡើងក្នុងសង្ឃថា នេះធម៌ នេះមិនមែនធម៌ជាដើម ក្នុងសេចក្តីនោះ វិញ្ញូជន អ្នកប្រាថ្នាធម៌ គួរសិក្សាថា សេចក្តីនោះជាឋានៈដែលនឹងមាន គឺការវិវាទ កាលចម្រើនឡើង គប្បីប្រព្រឹត្តទៅដើម្បី

កាច់បំបាក់នៃសង្ឃ ឬដើម្បីបំបែកសង្ឃ ។ បើអធិករណ៍នោះ ខ្លួនលើកឡើងតាំងទុកឯង គួរប្រញាប់វៀរចាក អធិករណ៍នោះ ដូចជាន់ភ្លើង ដូច្នោះ ។ កាលត្រូវអ្នកដទៃលើកអធិករណ៍ឡើង បើអាចស្ងប់អធិករណ៍នោះដោយខ្លួនឯង គប្បីព្យាយាមទៅឲ្យឆ្ងាយ បដិបត្តិដូចអធិករណ៍នោះស្ងប់ ។ តែមិនអាចឲ្យស្ងប់ដោយខ្លួនឯងបាន ការវិវាទនោះរឹងរឹតតែក្រៃលែងឡើង ព្រោះមិនស្ងប់ សូមឲ្យសព្រហ្មចារីដែលប្រាថ្នាការសិក្សា ជាអ្នកសមគួរក្នុងរឿងនោះ ជួយស្រោចស្រង់ រម្ងាប់អធិករណ៍នោះដោយធម៌ ដោយវិន័យ ដោយសត្ថុ-សាសនៈ គប្បីឲ្យអធិករណ៍ស្ងប់យ៉ាងនេះ ។ កាលអធិករណ៍ស្ងប់យ៉ាងនេះ កុសលធម៌ដែលធ្វើការព្រមព្រៀងនៃសង្ឃ លោកបំណងយក **ឯកធម្ម** ក្នុងទីនេះ ។ ពិតហើយ កុសលធម៌នោះដោះនូវធម៌សៅហ្មង ដែលនាំវត្ថុដែលមិនជាប្រយោជន៍ និងសេចក្តីទុក្ខ ដែលគួរកើតរបស់ភិក្ខុទាំងឡាយ ដែលជាបក្ខពួកទាំងសងខាង កើតការសង្ស័យនឹងគ្នានៃភិក្ខុនី ឧបាសក ឧបាសិកា ដែលតាំងនៅ ដោយប្រព្រឹត្តតាមភិក្ខុទាំងនោះ របស់អារក្ខទេវតានោះ រហូតដល់ទេវតា និងព្រហ្ម ហើយនាំវត្ថុជាប្រយោជន៍ និងសេចក្តីសុខឲ្យកើតដល់សត្វលោក ព្រមទាំងទេវតា ព្រោះកុសលធម៌នោះជាហេតុនៃគំនរបុណ្យជាទីហូរចូលនៃកុសល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯកធម្មោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ ធម៌ ១ កាលកើតឡើងក្នុងលោក រមែងកើតឡើងដើម្បីឧបការៈដល់ជនជាច្រើន ។

*គប្បីជ្រាបអត្ថនៃព្រះពុទ្ធវចនៈនោះដោយផ្ទុយគ្នា តាមដែលព្រះមានព្រះភាគត្រាស់ហើយក្នុងសូត្រមុន ។ បទថា* **សង្ឃស្ស សាមគ្គី** *បានដល់ ការព្រមព្រៀងនៃសង្ឃ គឺការមិនបែកគ្នា ការមានធម៌ឯណានីមួយ និងការមានឧទ្ទេសតែមួយដូចគ្នា ។*

*ក្នុងគាថា មានអធិប្បាយដូចតទៅនេះ បទថា* **សុខា សង្ឃស្ស សាមគ្គី** *សេចក្តីថា ការព្រមព្រៀងនៃសង្ឃឲ្យកើតសុខ បានដល់ សេចក្តីសាមគ្គី លោកពោលថា ជាសេចក្តីសុខ ព្រោះសាមគ្គីជាបច្ច័យនៃសេចក្តីសុខ លោកពោលថា* **សុខោ ពុទ្ធានំ ឧប្បាទោ** *ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ ។ បទថា* **សមគ្គានញ្ចនុគ្គហោ** *បានដល់ ការអនុគ្រោះ អ្នកព្រមព្រៀងគ្នា ដោយការអនុមោទនា ក្នុងការព្រមព្រៀងគ្នា គឺអនុរូបដល់សាមគ្គី អធិប្បាយថា ការកាន់យក គឺតម្កល់ទុក បន្ថែមកម្លាំងឲ្យ ដោយការព្រមព្រៀងទាំងនោះ មិនលះនូវសាមគ្គី ។ បទថា* **សមគ្គំ កត្វាន** *បានដល់ ធ្វើពួកដែលបែកគ្នា ឬដល់នូវការប្រេះឆាឲ្យព្រមព្រៀងគ្នា គឺឲ្យមានឧបការៈដល់គ្នានិងគ្នា ។ បទថា* **កប្បំ** *បានដល់ អាយុកប្បនោះឯង ។ បទថា* **សគ្គម្ហិ មោទតិ** *បានដល់ គ្រប់សង្កត់ទេវលោកដទៃក្នុងកាមាវចរទេវលោក ដោយឋានៈ ១០ សោយទិព្វសុខ រមែងត្រេកអរ គឺរមែងសោយ រមែងលេង ដោយការសម្រេច ដែលខ្លួនប្រាថ្នាហើយ ។*

**អដ្ឋកថាមោទសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## បុគ្គលសូត្រ

[ ២០ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់ចិត្តដោយចិត្តហើយ ដឹងច្បាស់ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលមានចិត្តប្រទូស្តយ៉ាងនេះថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ មុខជាទៅកើតក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយព្រោះបុគ្គលនោះ មានចិត្តប្រទូស្ត ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែមានចិត្តប្រទូស្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត និងនរក ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះពុទ្ធទ្រង់ជ្រាបបុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលមាន
ចិត្តប្រទូស្ត ទើបទ្រង់ព្យាករសេចក្តីនុ៎ះ ក្នុងសម្នាក់ភិក្ខុ
ទាំងឡាយថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុង
សម័យនេះ មុខជាទៅកើតក្នុងនរក ព្រោះតែបុគ្គលនោះ
មានចិត្តប្រទូស្ត បុគ្គលបែបនោះ ដូចជាគេនាំយកទៅ
ទម្លាក់យ៉ាងនេះឯង សត្វទាំងឡាយ រមែងទៅកាន់ទុគ្គតិ

ព្រោះហេតុតែមានចិត្តប្រទូស្ត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

ទុតិយវគ្គ ចប់

## ឧទ្ទាននៃទុតិយវគ្គនោះ គឺ

និយាយអំពីមោហៈ ១ សេចក្តីក្រោធ ១ សេចក្តីលុប
គុណគេ ១ សេចក្តីវង្វេង ១ កាម ១ សេក្ខៈមាន
២ លើក ការបំបែក ១ សេចក្តីត្រេកអរ ១ បុគ្គល
១ លោកពោលថាជាវគ្គទី ២ ។

# អដ្ឋកថា

## បុគ្គលសូត្រ

សួរថា អ្វីជាឧប្បត្តិនៃសូត្រទី ១០ ឆ្លើយថា អត្ថុប្បត្តិក គឺមានរឿងកើតឡើង ។

[ ២០ ] បានឮថា ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នា ក្នុងធម្មសភាថា នែអាវុសោទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើបុណ្យច្រើន ពួកខ្លះ ធ្វើបាបច្រើន ពួកខ្លះ ធ្វើលាយឡំគ្នាទាំង ២ យ៉ាង ក្នុងបុគ្គលទាំង

*នោះ បុគ្គលដែលធ្វើលាយឡំគ្នាទាំង ២ យ៉ាង ភពខាងមុខ នឹងមានដូចម្តេច ។ លំដាប់នោះ ព្រះសាស្តា យាងទៅកាន់ធម្មសភា គង់ប្រថាប់លើបវរពុទ្ធាសនៈ ដែលគេក្រាល បានស្តាប់ពាក្យនោះ កាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តសៅហ្មងក្នុងកាលជិតស្លាប់ ទុគ្គតិជាទីសង្ឃឹមបាន ដូច្នេះ ទើបទ្រង់សម្តែងសូត្រនេះដោយរឿងដែលកើតឡើងនេះ ។*

*ក្នុងបទនេះ បទថា* **ឥធ** *ជានិបាត ក្នុងការចង្អុលបង្ហាញដល់លំនៅ ។ លោកពោល* **ឥធ** *និបាតនេះ ក្នុងទីខ្លះ សំដៅទីលំនៅ ក្នុងបទជាដើមថា* **ឥធេវ តិដ្ឋមានស្ស ទេវភូតស្ស មេ សតោ** *ហែសម្លាញ់រូមទុក្ខ កាលខ្ញុំកើតជាទេវតា តាំងនៅក្នុងឱកាសនេះឯង ។ ក្នុងទីខ្លះ លោកសំដៅដល់សាសនា ដូចក្នុងបទជាដើមថា* **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ** *សមណៈទី ១ មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ក្នុងទីខ្លះ ត្រឹមតែជាបទបូរណៈ ដូចក្នុងប្រយោគថា* **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** *ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគស្រេចហើយ ហាមភត្តហើយ ដូច្នេះ ។ ក្នុងទីខ្លះ សំដៅដល់លោក ក្នុងបទជាដើមថា* **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** *ព្រះតថាគតទ្រង់រមែងកើតឡើងក្នុងលោកនេះ ដូច្នេះ ។ ក្នុងព្រះសូត្រនេះ* **ឥធ** *សព្ទសំដៅដល់លោកនេះប៉ុណ្ណោះ ។*

*បទថា* **ឯកច្ចំ** *បានដល់ មនុស្សម្នាក់ គឺបុគ្គលណាម្នាក់ ។ បទថា* **បុគ្គលំ** *បានដល់ សត្វ ។ ពិតហើយ សត្វនោះ លោកហៅថា បុគ្គល ព្រោះ*

ញ៉ាំងកុសល អកុសល និងវិបាកនៃកុសល អកុសលនោះឲ្យបរិបូណ៌ តាមបច្ច័យ និងព្រោះអំណាចការស្លាប់លេបត្របាក់ ។ បទថា **បទុដ្ឋចិត្តំ** បានដល់ មានចិត្តល្អក់កករ ដោយការប្រទូស ដោយការអាឃាត ។ម្យ៉ាងទៀត បទថា **បទុដ្ឋចិត្តំ** បានដល់ មានចិត្តល្អក់កករដោយរាគៈជាដើម ដែលជាទោស ។ ម្យ៉ាងទៀត បទថា **ឯកច្ចំ** ក្នុងទីនេះ ជាវិសេសនៈនៃបុគ្គលដែលមានចិត្តល្អក់កករ ។ លោកពោលយ៉ាងនោះ ដល់បុគ្គលដែល ឲ្យបដិសន្ធិបានធ្វើហេតុឡើង ។ ម្យ៉ាងទៀត ព្រោះអកុសលដែលប្រព្រឹត្តទៅ បុគ្គលជិតស្លាប់ មិនអាចត្រឡប់ចិត្តឲ្យឈមចុះដោយកុសលបាន សម្ដែងអាការដែលគួរពោលក្នុងឥឡូវនេះ ដោយបទថា **ឯវំ** ដូច្នេះ ។ បទថា **ចេតសា** បានដល់ ដោយចិត្ត គឺដោយចេតោបរិយញ្ញាណរបស់ខ្លួន ។ បទថា **ចេតោ** បានដល់ ចិត្តរបស់បុគ្គលនោះ ។ បទថា **បរិច្ច** គឺកំណត់ដឹង ។ សួរថា នេះជាវិស័យនៃយថាកម្មូបគញ្ញាណ គឺការដឹងថា សត្វប្រព្រឹត្តទៅតាមកម្ម មិនមែនឬ ឆ្លើយថា សេចក្ដីនោះពិត តែសេចក្ដីនេះ លោកពោលដោយអំណាចអកុសលចិត្ត ដែលប្រព្រឹត្តទៅក្នុងកាលនោះ ។

បទថា **ឥមម្ហិ ចាយំ សមយេ** សេចក្ដីថា បើក្នុងកាលនេះ ឬក្នុងបច្ច័យសាមគ្គីនេះ បុគ្គលនេះគប្បីធ្វើកាលៈខាងក្រោយជវនវិថី ។ ការធ្វើកាលកិរិយា រមែងមិនមានក្នុងខណៈនៃជវនចិត្ត ។ បទថា **យថាភតំ និក្ខិត្តោ ឯវំ និរយេ** សេចក្ដីថា បុគ្គលនោះត្រូវកម្មរបស់ខ្លួនបន្សាត់ទៅ គឺតាំងទុកក្នុងនរក ដូចត្រូវនាំអ្វីមួយមកទម្លាក់ ដូច្នោះ ។ បទថា **កាយស្ស ភេទា** បានដល់

លះនូវខន្ធដែលមានចិត្តគ្រប់គ្រង ។ បទថា **បរម្មរណា** បានដល់ ក្នុងការមិនប្រកាន់ខន្ធដែលកើតក្នុងវាងនោះ ។ ម្យ៉ាងទៀត បទថា **កាយស្ស ភេទា** បានដល់ ព្រោះកាត់ផ្តាច់នូវជីវិតិន្ទ្រិយ ។ បទថា **បរម្មរណា** បានដល់ ខាងមុខអំពីចុតិ ។

បទថា **អបាយំ** ជាដើម ពាក្យទាំងនេះជាវេវចនៈនៃនរកនោះឯង ។ ពិតហើយ នរក ឈ្មោះថា **អបាយ** ព្រោះប្រាសចាកសេចក្តីសុខ ពោល គឺសេចក្តីចម្រើន ។ ម្យ៉ាងទៀត នរក ឈ្មោះថា **អបាយ** ព្រោះប្រាសចាកសេចក្តីចម្រើន ដែលឈ្មោះថាជាបុណ្យ ដែលជាហេតុនៃស្ថានសួគ៌ និងនិព្វាន ។ នរក ឈ្មោះថា **ទុគ្គតិ** ព្រោះជាទីទៅ គឺជាទីអាស្រ័យនៃទុក្ខ ។ ម្យ៉ាងទៀត ឈ្មោះថា **ទុគ្គតិ** ព្រោះជាទីដែលសត្វទាំងឡាយ ដែលច្រើនដោយទោសៈ ទៅកើតដោយកម្មអាក្រក់ នរក ឈ្មោះថា **វិនិបាត** ព្រោះជាទីដែលសត្វអស់អំណាច ធ្វើកម្មអាក្រក់ធ្លាក់ទៅ ឬជាទីដែលសត្វ វិនាសមានអវយវៈតូចធំធ្លាក់ទៅ ។ ឈ្មោះថា **និរយ** ព្រោះអត្ថថា អស់សេចក្តីត្រេកអរ ព្រោះសេចក្តីចម្រើនដែលសន្មតថា ជាសេចក្តីល្អ មិនមានក្នុងនរកនោះ ។ ម្យ៉ាងទៀត លោកពោលថា **តិរច្ឆានយោនិ** ដោយ **អបាយ** សព្ទ ។ ម្យ៉ាងទៀត **តិរច្ឆានយោនិ** ជាអបាយ ព្រោះប្រាសចាកសុគតិ នាគរាជជាដើម ជាអ្នកមានសក្តិធំកើត មិនកើតក្នុងទុគ្គតិឡើយ ឈ្មោះថា **បិត្តិវិស័យ** ដោយ **ទុគ្គតិ** សព្ទ ។ ពិតហើយ **បិត្តិវិស័យ** នោះ ជាអបាយផង ជាទុគ្គតិផង ព្រោះប្រាសចាកសុគតិ និងជាគតិរបស់ទុក្ខ មិនមែនវិនិបាត ព្រោះមិន

ធ្លាក់ទៅ ដូចគ្នានឹងពួកអសុរ ។ ឈ្មោះថា **អសុរកាយ** ដោយ **វិនិបាត** សព្ទ **អសុរកាយ** នោះ ជាអបាយផង ជាទុគ្គតិផង ព្រោះអត្ថតាមដែលពោលហើយ លោកហៅថា វិនិបាត ព្រោះធ្លាក់ទៅទាំងរាងកាយ ។ លោកពោលនរកមានប្រការសន្ធឹកសន្ធាប់ មានអវីចីជាដើម ដោយ **និរយ** សព្ទ ។ តែក្នុងទីនេះ លោកពោលដល់នរកតែម្យ៉ាង សូម្បីគ្រប់ៗ បទ ។ បទថា **ឧបបជ្ជន្តិ** បានដល់កាន់យកបដិសន្ធិ ។

គាថាទី ១ ក្នុងគាថាទាំងឡាយ ព្រះធម្មសង្គាហកត្ថេរ បានចងក្រងហើយ ក្នុងសង្គីតិកាល ។ បទថា **ញត្វាន** ជាបុព្វកាលកិរិយា ។ ពិតហើយ ញាណមុនជាព្យាករ ។ ម្យ៉ាងទៀត **ញត្វា** សព្ទ មានអត្ថជាហេតុ ដូចប្រយោគថា **សីហំ ទិស្វា ភយំ ហោតិ** ភ័យរមែងមាន ព្រោះឃើញសីហៈ ដូច្នេះ អធិប្បាយថា ព្រោះសញ្ញាជាហេតុ ។ បទថា **ពុទ្ធោ ភិក្ខូន សន្តិកេ** សេចក្តីថា ព្រោះព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់ព្យាករអត្ថតាមដែលទ្រង់ត្រាស់ ដោយគាថាខាងដើមនោះ ដល់ភិក្ខុទាំងឡាយក្នុងសម្នាក់របស់ព្រះអង្គ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។៚

## អដ្ឋកថា បុគ្គលសូត្រទី ១០ ចប់

## ទុតិយវគ្គ ចប់

# សុត្តន្តបិដក

## ឥតិវុត្តក ឯកនិបាត តតិយវគ្គ

### ចិត្តឈាយីសូត្រ

[ ២១ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់ដឹងចិត្តដោយចិត្ត ដឹងច្បាស់ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលមានចិត្តជ្រះថ្លាហើយយ៉ាងនេះថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុងសម័យនេះ នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលនោះ មានចិត្តជ្រះថ្លា ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ហេតុតែមានចិត្តជ្រះថ្លាយ៉ាងនេះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏រមែងទៅកើតឯសុគតិសួគ៌ទេវលោក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

ព្រះពុទ្ធទ្រង់ជ្រាបបុគ្គលពួកខ្លះ ដែលមានចិត្តជ្រះថ្លា ក្នុង
លោកនេះ ទើបទ្រង់ព្យាករសេចក្តីនុ៎ះ ក្នុងសម្នាក់ភិក្ខុ
ទាំងឡាយថា បើបុគ្គលនេះ ធ្វើមរណកាលទៅ ក្នុង
សម័យនេះ នឹងទៅកើតក្នុងសុគតិ ព្រោះបុគ្គលនោះ
មានចិត្តជ្រះថ្លា បុគ្គលបែបនោះ ដូចជាគេនាំយកទៅ
តម្កល់ទុក ( ក្នុងសួគ៌ ) យ៉ាងនេះឯង សត្វទាំងឡាយ

រមែងទៅកាន់សុគតិ ព្រោះហេតុតែមានចិត្តជ្រះថ្លា ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## ចិត្តឈាយីសូត្រ

ក្នុងចិត្តឈាយីសូត្រទី ១ នៃវគ្គទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ២១ ] បទថា **បសន្នចិត្តំ** បានដល់ មានចិត្តជ្រះថ្លាហើយ ដោយការជឿក្នុងព្រះរតនត្រ័យ និងដោយការជឿក្នុងផលរបស់កម្ម ។ បទថា **សុគតី** បានដល់ គតិល្អ ឬគតិនៃសុខ ដូច្នោះ ទើបឈ្មោះថា **សុគតិ** ។ បទថា **សគ្គំ** បានដល់ ប្រសើរដោយល្អ ដោយសម្បត្តិ មានរូបជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា **សគ្គ** ។ បទថា **លោកំ** បានដល់ ផលនៃបុណ្យ និងបាប ឬឈ្មោះថា **លោក** ព្រោះអត្ថថា វិនាស ។ ម្យ៉ាងទៀត ក្នុងទីនេះ សូម្បីគតិរបស់មនុស្ស ក៏សង្គ្រោះដោយ **សុគតិ** សព្ទ ។ គតិរបស់ទេវតា ក៏សង្គ្រោះដោយ **សគ្គ** សព្ទដូចគ្នា ។ បទដ៏សេសមានន័យដូចពោលហើយខាងដើមនោះឯង ៕

**អដ្ឋកថា ចិត្តឈាយីសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បុញ្ញសូត្រ

[ ២២ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំខ្លាចបុណ្យឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យថា បុណ្យនេះ ជាឈ្មោះនៃសេចក្តីសុខដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត ។ ម្នាលភិក្ខុទាំងឡាយ តថាគតស្គាល់ច្បាស់ ផលនៃបុណ្យ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត ដែលតថាគតបានហើយ អស់កាលជាអង្វែង ដែលតថាគតធ្វើហើយ អស់កាលជាអង្វែង ។ តថាគតបានចម្រើនមេត្តាចិត្ត អស់ ៧ ឆ្នាំ មិនបានមកកាន់លោកនេះទៀត អស់ ៧ សំវដ្តវិវដ្ត-កប្ប ម្នាលភិក្ខុទាំងឡាយ ដំណើរថា កាលកប្បវិនាស តថាគតបានទៅកើតក្នុងអាភស្សរព្រហ្ម កាលកប្បចម្រើន តថាគតបានចូលទៅកាន់ព្រហ្មវិមានដែលសូន្យទទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីនោះ តថាគតជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់សត្វដទៃបាន សត្វដទៃមិនអាចគ្របសង្កត់តថាគតបានទេ តថាគតឃើញហេតុសព្វគ្រប់ អាចញុំាងអំណាចឲ្យប្រព្រឹត្តទៅបានដោយពិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតបានកើតជាព្រះឥន្ទ្រ ជាធំជាងទេវតាទាំងឡាយ ៣៦ ដង បានជាស្តេចចក្រពត្តិ ធម្មិកធម្មរាជ ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម មានជនបទ ដល់នូវការមាំមួន បរិបូណ៌ដោយរតនៈទាំង ៧ ប្រការ អស់ច្រើនរយដង នឹងបាច់ពោលទៅថ្វី ដល់ប្រទេសរាជ្យ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះថា នេះជាផលកម្ម របស់អាត្មាអញ ដូចម្តេចហ្ន៎ នេះជាវិបាកនៃកម្មដូចម្តេច ដែលនាំឲ្យអាត្មាអញ មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក្នុងកាលឥឡូវនេះ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះថា នេះជាផលកម្ម ទាំងឡាយ ៣ យ៉ាង របស់អាត្មាអញ នេះជាវិបាកនៃកម្មទាំងឡាយ ៣ យ៉ាង ដែលនាំឲ្យអាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក្នុង កាលឥឡូវនេះ គឺផលទាន ១ ការទូន្មានឥន្ទ្រិយ ១ ការសង្រួម ១ ។ លុះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុង សូត្រនោះថា

កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សា គឺថា គប្បី
សេពនូវបុណ្យ ដែលមានផលបរិបូណ៌ មានវិបាកជា
សុខ គួរចម្រើនទាន ១ ការប្រព្រឹត្តស្មើ គឺសីល ១
មេត្តាចិត្ត ១ លុះចម្រើនធម៌ទាំង ៣ នេះ ដែល
មានអានិសង្សជាសុខហើយ រមែងចូលទៅកាន់លោក
ជាសុខ ឥតមានទុក្ខ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះ ព្រះមានព្រះភាគ បានត្រាស់ ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## បុញ្ញសូត្រ

ក្នុងបុញ្ញសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ២២ ] **មា** សព្ទ ក្នុងបទថា **មា ភិក្ខវេ បុញ្ញានំ** នេះ ជានិបាត ចុះក្នុងអត្ថថា បដិសេធ ។ **បុញ្ញ** សព្ទ មកក្នុងផលនៃបុណ្យ ដូចក្នុងប្រយោគជាដើមថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើង ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ ។ មកក្នុងសុចរិតដែលជាកាមាវចរ និងរូបាវចរ ដូចក្នុងប្រយោគជាដើមថា **អវិជ្ជាគតោ ភិក្ខវេ បុរិសបុគ្គលោ បុញ្ញញ្ចេ សង្ខារំ អភិសង្ខរោតិ** ម្នាលភិក្ខុទាំងឡាយ បើបុរសបុគ្គលលុះក្នុងអំណាចអវិជ្ជាហើយ រមែងតាក់តែងសង្ខារជាបុណ្យ ។ មកក្នុងឧបបត្តិភពដែលជាសុគតិវិសេស ដូចក្នុងប្រយោគជាដើមថា **បុញ្ញុបគំ ភវតិ វិញ្ញាណំ**[១] វិញ្ញាណរមែងចម្រើនដោយបុណ្យ ។ មកក្នុងកុសលចេតនា ដូចក្នុងប្រយោគជាដើមថា **តីណិមានិ ភិក្ខវេ បុញ្ញកិរិយាវត្ថូនិ កតមានិ តីណិ ទានមយំ បុញ្ញកិរិយាវត្ថុ សីលមយំ បុញ្ញកិរិយាវត្ថុ ភាវនាមយំ បុញ្ញកិរិយាវត្ថុ** ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ ។ បុញ្ញកិរិយាវត្ថុ ៣ តើដូចម្តេច ។ គឺទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ។ តែក្នុងទីនេះបុណ្យ គប្បីជ្រាបថា មកក្នុង

---

១- បិដកខ្មែរ ជា អភិសង្ខរោតិ បុញ្ញុបគំ ហោតិ វិញ្ញាណំ ប្រែថា វិញ្ញាណក៏ចូលទៅកៀកនឹងបុណ្យ ។

កុសលធម៌ក្នុងភូមិទាំង ៣ ។

ក្នុងបទថា **ភាយិត្ថ** នេះ ភ័យមាន ២ យ៉ាង គឺញាណភ័យ ១ សារជ្ជភ័យ ១ ក្នុងភ័យ ២ យ៉ាងនោះ ញាណភ័យ មកក្នុងប្រយោគយោគជាដើមថា **យេបិ តេ ភិក្ខវេ ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលា ឧច្ចេសុ វិមានេសុ ចិរដ្ឋិតិកា តេបិ តថាគតស្ស ធម្មទេសនំ សុត្វា យេភុយ្យេន ភយំ សំវេគំ សន្តាសំ** ម្នាលភិក្ខុទាំងឡាយ ពួកទេវតាណាដែលមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ស្ថិតនៅលើវិមានទាំងឡាយដ៏ខ្ពស់ អស់កាលយូរ ពួកទេវតាទាំងនោះបានស្តាប់នូវធម៌ទេសនារបស់ព្រះតថាគតហើយ ច្រើនតែកិតភ័យ សង្វេគ ញ័រចំប្រប់ ដូច្នេះ ។ សារជ្ជភ័យ មកក្នុងប្រយោគជាដើមថា **អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ** ភ័យមានហើយ ការតក់ស្លុតមានហើយ ការព្រឺរោម ព្រឺស្បែកមានហើយ ដូច្នេះ ក្នុងទីនេះ បំណងយកសារជ្ជភ័យប៉ុណ្ណោះ ។ ក្នុងទីនេះមានអធិប្បាយដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំខ្លាចចំពោះបុណ្យដែលភិក្ខុគប្បីប្រព្រឹត្តសព្វកាល គឺការសង្រួមកាយ វាចា អស់កាលយូរ ការបំពេញវត្តបដិបត្តិ ការឆាន់មួយពេល ការដេកតែម្តង ការទូន្មានឥន្ទ្រិយ ការសង្កត់ចិត្តដោយធម៌ជាគ្រឿងកម្ចាត់កិលេស មានសតិសម្បជញ្ញៈ ប្រារព្ធសេចក្តីព្យាយាម ដោយការប្រកបកម្មដ្ឋាន ពួកអ្នកកុំដល់នូវសេចក្តីខ្លាច ការតក់ស្លុត ពួកអ្នកកុំខ្លាចចំពោះបុណ្យ ដែលជាគុណនាំមកនូវសុខ ក្នុងសម្បរាយភព និងនិព្វាន ព្រោះភ័យរាំងសេចក្តីសុខក្នុងបច្ចុប្បន្នខ្ណៈ ។ ពិតហើយ

*បទនេះ ត្រឹមតែជានិបាត ចុះក្នុងអត្ថមិនមែនរបស់ខ្លួន ។*

*ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងហេតុក្នុងភាពជារបស់មិនគួរខ្លាចអំពីបុណ្យនោះ ទើបត្រាស់ជាដើមថា* **សុខស្សេតំ** *ដូច្នេះ ។* **សុខ** *សព្ទ ក្នុងបទថា* **សុខស្សេតំ** *នោះ មកក្នុងមូលរបស់សុខ ដូចក្នុងប្រយោគជាដើមថា* **សុខោ ពុទ្ធានំ ឧប្បាទោ សុខា វិរាគតា លោកេ** *ការកើតឡើងនៃព្រះពុទ្ធទាំងឡាយនាំមកនូវសេចក្តីសុខ ការប្រាសចាកតម្រេកជាសុខក្នុងលោក ដូច្នេះ ។ មកក្នុងសុខារម្មណ៍ដូចក្នុងប្រយោគជាដើមថា* **យស្មា ច ខោ មហាលិ រូបំ សុខំ សុខានុបតិតំ សុខាវក្កន្តំ** *ម្នាលមហាលិ តែរូបនេះជាសុខ មានសុខជាប់តាម មានសុខគ្របដណ្តប់ ដូច្នេះ ។ មកក្នុងឋានៈមានសុខជាបច្ច័យ ដូចក្នុងប្រយោគជាដើមថា* **យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ សុខា សគ្គាតិ** *ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនងាយនឹងធ្វើឧបមាឲ្យដល់កម្រិត ស្ថានសួគ៌ដែលមានសេចក្តីសុខបានឡើយ ដូច្នេះ ។ មកក្នុងហេតុនៃសេចក្តីសុខ ដូចក្នុងប្រយោគជាដើមថា* **សុខោ បុញ្ញស្ស ឧច្ចយោ** *ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ ដូច្នេះ ។ មកក្នុងការមិនបៀតបៀន ដូចក្នុងប្រយោគជាដើម* **ទិដ្ឋធម្មសុខាវិហារា ឯតេ ធម្មា** *ធម៌ទាំងឡាយនេះ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ដូច្នេះ ។ មកក្នុងនិព្វាន ដូចក្នុងប្រយោគជាដើមថា* **និព្វានំ បរមំ សុខំ** *ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ដូច្នេះ ។ មកក្នុងសុខវេទនា ដូចក្នុងប្រយោគជាដើមថា* **សុខស្ស ច បហានា** *ព្រោះលះបង់នូវសុខ ដូច្នេះ ។ មកក្នុងឧបេក្ខាវេទនា ដូចក្នុងប្រយោគជាដើម*

ថា **អទុក្ខមសុខំ សន្តំ សុខមិច្ចេវ ភាសិតំ** កាលមិនមានទុក្ខ មិនមានសុខ ក៏ពោលបានថា ជាសុខតែម្យ៉ាង ដូច្នេះ ។ មកក្នុងសុខដែលគួរប្រាថ្នា ដូចក្នុងប្រយោគជាដើមថា **ទ្វេបិ មយា អានន្ទ វេទនា វុត្តា បរិយាយេន សុខា វេទនា ទុក្ខាវេទនា** ម្នាលអានន្ទ វេទនាពីរ គឺសុខវេទនា និងទុក្ខវេទនា ក៏តថាគតបានសម្តែងដោយបរិយាយ ដូច្នេះ ។ មកក្នុងនិបាតដែលគួរប្រាថ្នា ដូចក្នុងប្រយោគជាដើមថា **សុខោ វិបាកោ បុញ្ញានំ** បុណ្យទាំងឡាយនាំមកនូវវិបាកជាសុខ ដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាបថា មកក្នុងវិបាកដែលគួរប្រាថ្នាប៉ុណ្ណោះ ។

ក្នុងបទថា **ឥដ្ឋស្ស** ជាដើម គប្បីជ្រាបអត្ថដូចតទៅនេះ ឈ្មោះថា គួរប្រាថ្នា ព្រោះគួរស្វែងរក និងព្រោះហាមនូវវត្ថុដែលមិនគួរប្រាថ្នា ឈ្មោះថា **កន្តស្ស** ព្រោះជាវត្ថុគួរត្រេកអរ និងព្រោះឈានចូលទៅដល់ចិត្ត ឈ្មោះថា **បិយស្ស** ព្រោះជាវត្ថុគួរស្រឡាញ់ និងព្រោះឲ្យកើតសេចក្តីត្រេកអរ ឈ្មោះថា **មនាបស្ស** ព្រោះឲ្យកើតនូវការរាប់អាន និងព្រោះជាទីពេញចិត្ត ។ បទថា **យទិទំ បុញ្ញានិ** សេចក្តីថា ពាក្យថា **បុណ្យ** នេះ ជាឈ្មោះរបស់សេចក្តីសុខ គឺវិបាកដែលគួរប្រាថ្នា សេចក្តីសុខនោះឯង គឺបុណ្យ ព្រោះហេតុនោះ ទើបលោកពោលដល់ឧបចារៈ ដែលមិនផ្សេងគ្នានៃហេតុដោយផល ដែលមិនប្រមាទ ស្តាប់ផលដែលជាក់ច្បាស់ៗ របស់បុណ្យដែលគេសន្សំមកហើយ គួរធ្វើបុណ្យដោយគោរព ព្រោះហេតុនោះ ទើបលោកបបួលក្នុងការធ្វើបុណ្យ និងឲ្យកើតការពេញចិត្តក្នុងការធ្វើបុណ្យនោះនៃបុគ្គលទាំងនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់លើកមកអាងដល់វិបាកនៃបុណ្យដែលទូលាយក្រៃលែង បិទបាំងវាំងកត សោយនូវបុញ្ញកម្មដែលទ្រង់បានធ្វើហើយក្នុងកាលនៅជាសុនេត្តអស់កាលយូរ កាលទ្រង់ធ្វើសេចក្តីនោះឲ្យប្រាកដ ទើបត្រាស់ពាក្យថា **អភិជានាមិ ខោ បនាហំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អភិជានាមិ** បានដល់ តថាគតដឹងដោយញាណដ៏វិសេសក្រៃលែង គឺដឹងដោយជាក់ច្បាស់ ។ បទថា **ទីឃរត្តំ** បានដល់ អស់កាលយូរ ។ បទថា **បុញ្ញានំ** បានដល់ កុសលធម៌ មានទានជាដើម ។ បទថា **សត្ត វស្សានិ** បានដល់ អស់ ៧ ឆ្នាំ ។

បទថា **មេត្តចិត្តំ** សេចក្តីថា ឈ្មោះថា **មេត្តា** ព្រោះអត្ថថា ស្រឡាញ់ អធិប្បាយថា ចងមេត្រី ។ ឈ្មោះថា **មេត្តា** ព្រោះជាសេចក្តីចម្រើន ប្រព្រឹត្តទៅក្នុងមិត្រ ឬសេចក្តីចម្រើននោះ ប្រព្រឹត្តទៅចំពោះមិត្រ ។ គប្បីជ្រាបវិនិច្ឆ័យមេត្តាដោយលក្ខណៈជាដើមដូចតទៅនេះថា មេត្តាមានការប្រព្រឹត្តទៅក្នុងអាការ ឲ្យនូវប្រយោជន៍ជាលក្ខណៈ មានការនាំមកនូវវត្ថុដែលជាប្រយោជន៍ជាកិច្ច មានការដោះនូវអាឃាតជាគ្រឿងប្រាកដ មានការសម្លឹងការពេញចិត្តរបស់សត្វទាំងឡាយជាបទដ្ឋាន ។ សេចក្តីស្ងប់ព្យាបាទ ជាសម្បត្តិរបស់មេត្តានោះ ការមានស្នេហាជាវិបត្តិរបស់មេត្តា ។ ឈ្មោះថា **មេត្តាចិត្តំ** ព្រោះចិត្តមានមេត្តា ។ បទថា **ភាវេត្វា** បានដល់ ព្រះមានព្រះភាគត្រាស់សមាធិដោយមាតិកានៃចិត្ត ដែលសហគតៈដោយមេត្តា ព្រោះហេតុនោះ ទើបញ៉ាំងមេត្តាសមាធិ ញ៉ាំងមេត្តាព្រហ្មវិហារឲ្យកើត និងឲ្យចម្រើន ។ បទថា

**សត្ត សំវដ្ដវិវដ្ដកប្បេ** បានដល់ មហាកប្ប ៧ ។ ពិតហើយ លោកកាន់យកសូម្បីសំវដ្ដដ្ឋាយី និងវិវដ្ដដ្ឋាយី ដោយ **សំវដ្ដ** និង **វិវដ្ដ** សព្ទនោះឯង ។ បទថា **ឥមំ លោកំ** បានដល់ កាមលោក ។ បទថា **សំវដ្ដមានេ សុទំ** បានដល់ កប្បវិនាស បទថា **សុទំ** ត្រឹមតែជានិបាត អធិប្បាយថា វិនាស ។ អាចារ្យពួកខ្លះពោលថា **សំវដ្ដមានេ សុទំ**[1] ដូច្នេះក៏មាន ។ បទថា **កប្បេ** បានដល់ លោក ។ លោកពោលថា **លោក** ដោយមាតិកានៃកប្ប ។ កាលលោកអស់ កប្បក៏វិនាសទៅដែរ ដូចដែលលោកពោលថា **កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា** កាលរមែងស៊ីនូវពួកសត្វទាំងអស់ ព្រមទាំងខ្លួនឯង ។ គប្បីជ្រាបថា ការទៅដរាបអស់កប្បក្នុងលោកនេះ ដោយគេជាសំវដ្ដកប្ប ព្រោះទ្រង់ត្រាស់ថា តថាគតជាអ្នកចូលដល់ព្រហ្មលោកជាន់អាភស្សរ ។ បទថា **អាភស្សរូបគោ** សេចក្ដីថា តថាគតចូលដល់ព្រហ្មលោកជាន់អាភស្សរ ដោយបដិសន្ធិក្នុងព្រហ្មលោកនោះ ព្រោះដូច្នោះ ទើបតថាគតជាអ្នកចូលដល់ព្រហ្មលោកជាន់អាភស្សរ ។ បទថា **វិវដ្ដមានេ** បានដល់ តាំងនៅ អធិប្បាយថា កើត ។ បទថា **សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជាមិ** សេចក្ដីថា តថាគតចូលដល់វិមាននៃព្រហ្ម ពោល គឺភូមិនៃបឋមជ្ឈាន ដែលកើតហើយអំពីខាងដើមដែលទទេ ព្រោះមិនមានសត្វណាមួយកើតក្នុងទីនោះ ដោយបដិសន្ធិ ។

បទថា **ព្រហ្មា** សេចក្ដីថា ឈ្មោះថា ព្រហ្ម ព្រោះអត្ថថា ជាបុគ្គល

---

១- បាលីទាំងពីរបទដូចគ្នាដដែល បណ្ឌិតគប្បីពិចារណា ។

ប្រសើរជាងសត្វជាន់កាមាវចរ និងព្រោះអត្ថថា កើតអំពីព្រហ្មវិហារធម៌ ព្រោះដុះដាលដោយគុណធម៌យ៉ាងនោះៗ ។ ឈ្មោះថា **មហាព្រហ្មា** ព្រោះជាព្រហ្មធំជាងព្រហ្មបារិសជ្ជា និងព្រហ្មបុរោហិត ឈ្មោះថា ជាបុគ្គលធំក្រៃលែង ព្រោះបង្ក្រាបព្រហ្មទាំងនោះបាន ។ ឈ្មោះថា **អភិភូ** ព្រោះមិនមានអ្នកណាគ្របសង្កត់ បានដោយគុណធម៌ ។ បទថា **អញ្ញទត្ថុ** ជានិបាតចុះក្នុងពាក្យពិតប្រាកដ ។ បទថា **ទសោ** គឺមានប្រក្រតីឃើញ ។ ទ្រង់អាចឃើញអតីត អនាគត និងបច្ចុប្បន្នបាន អធិប្បាយថា តថាគតរមែងឃើញវត្ថុដែលគួរឃើញដោយអភិញ្ញា តថាគតញ៉ាំងព្រហ្មដ៏សេស និងញ៉ាំងចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់តថាគត ដោយកម្លាំងឥទ្ធិបាទភាវនា ព្រោះហេតុនោះ គួរប្រកបថា **វសវត្តិ ហោមិ** តថាគតជាអ្នកញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ។

បានឮថា ក្នុងកាលនោះ ព្រះពោធិសត្វសូម្បីបានសមាបត្តិ ៨ ក៏ទ្រង់នៅតែពិចារណាមើលប្រយោជន៍របស់សត្វយ៉ាងនោះ និងការបំពេញបារមីរបស់ព្រះអង្គ ញ៉ាំងសេចក្តីប្រាថ្នាក្នុងឈានភូមិទាំង ២ នោះឲ្យកើត ទ្រង់អន្ទោលទៅមកៗ ដោយមេត្តាព្រហ្មវិហារធម៌ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សត្តវស្សានិ ។បេ។ វស្សវត្តី** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសវិបាកធំក្រៃលែង របស់បុណ្យដែលជារូបាវចរ ឥឡូវនេះ កាលទ្រង់សម្តែងដល់វិបាកដ៏ធំក្រៃលែងរបស់បុណ្យដែលជាកាមាវចរ ទើបត្រាស់ពាក្យជាដើមថា **ឆត្តឹសក្ខត្តុំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សក្កោ អហោសឹ** សេចក្ដីថា តថាគតមិនកើតក្នុងទីដទៃ បានជាសក្កទេវរាជ ជាទេវរាជជាន់តាវត្តិង្សអស់កាល ៣៦ ដង ។ បទថា **រាជា អហោសឹ** ជាដើម មានអត្ថដូចតទៅនេះ ឈ្មោះថា **រាជា** ព្រោះញ៉ាំងសត្វលោកឲ្យត្រេកអរដោយអរិយធម៌ ៤ និងដោយសង្គហវត្ថុ ៤ ។ ឈ្មោះថា **ចក្កវត្តិ** ព្រោះញ៉ាំងចក្ករតនៈឲ្យប្រព្រឹត្តទៅ ចក្ករតនរមែង វិលទៅដោយសម្បត្តិចក្រ ៤ ទាំងញ៉ាំងចក្ករតនៈដទៃឲ្យវិលទៅដោយសម្បត្តិចក្រ ៤ នោះ ទាំងមានចក្រ គឺឥរិយាបថ ៤ វិលទៅ ដើម្បីជាប្រយោជន៍ដល់បុគ្គលដទៃ ។ ម្យ៉ាងទៀត ពាក្យថា **រាជា** ក្នុងបទនេះ ជាពាក្យសមញ្ញ ។ បទថា **ចក្កវត្តិ** ជាវិសេសនៈ ឈ្មោះថា **ធម្មិកោ** ព្រោះប្រព្រឹត្តដោយធម៌ អធិប្បាយថា រមែងប្រព្រឹត្តដោយរបៀបបែបផែនជានិច្ច ។ ឈ្មោះថា **ធម្មរាជា** ព្រោះបានទទួលនូវសម្បត្តិដោយធម៌ ទើបជាព្រះរាជា ។ ឬឈ្មោះថា **ធម្មិកោ** ព្រោះប្រព្រឹត្តនូវធម៌ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ។ ឬឈ្មោះថា **ធម្មរាជា** ព្រោះប្រព្រឹត្តធម៌ដើម្បីជាប្រយោជន៍ដល់ខ្លួន ។ ឈ្មោះថា **ចាតុរន្តោ** ព្រោះជាឥស្សរៈក្នុងមហាសមុទ្រទាំង ៤ អធិប្បាយថា ជាឥស្សរៈក្នុងផែនដី ព្រោះមានសមុទ្រ ៤ ជាព្រំដែន និងព្រោះមានទ្វីប ៤ ជោមរោម ។ ឈ្មោះថា **វិជិតាវី** ប្រែថា ឈ្នះវិសេសហើយ ព្រោះឈ្នះសត្រូវខាងក្នុង និងឈ្នះព្រះរាជាគ្រប់អង្គខាងក្រៅ ដោយមិនចាំបាច់ដាក់អាជ្ញា មិនចាំបាច់ប្រើសស្ត្រា ឈ្មោះថា **ជនបត្ថាវរិយប្បត្តោ** ព្រោះជាអ្នកដល់ព្រមដោយការមាំទាំ គឺការស្ថិតស្ថេរក្នុងជនបទ ដែលបុគ្គលណាម្នាក់មិនអាចឲ្យកម្រើកទៅអំពីនោះបាន

ឬជនបទ ដល់នូវភាពជាជនបទមាំទាំក្នុងទីនោះ មិនចាំបាច់ខ្វល់ខ្វាយ ត្រេកអរក្នុងការងាររបស់ខ្លួន មិនញាប់ញ័រ មិនឃៀនឃ្លាត ។ ឈ្មោះថា **សត្ត-រតនសមន្នាគតោ** ព្រោះដល់ព្រមដោយរតនៈ ៧ ប្រការ គឺចក្ររ័ត្ន ១ ដំរីរ័ត្ន ១ សេះរ័ត្ន ១ មណីរ័ត្ន ១ នារីរ័ត្ន ១ គហបតីរ័ត្ន ១ បរិនាយករ័ត្ន ១ ។

ពិតហើយ ក្នុងរតនៈទាំងនោះ ព្រះរាជាចក្រពត្តិទ្រង់ឈ្នះដែន ដែលមិនមាននរណាឈ្នះបានដោយចក្ររ័ត្ន ទ្រង់ត្រាច់ទៅក្នុងដែនដោយដំរីរ័ត្ន សេះរ័ត្ន តាមគាប់ព្រះហឫទ័យ ទ្រង់គ្រប់គ្រងដែនដោយបរិនាយករ័ត្ន ទ្រង់សោយឧបភោគសុខដោយរតនៈដ៏សេស ។ ស្តេចចក្រពត្តិនោះ ទ្រង់ប្រកបដោយអំណាចនៃឧស្សាហ៍ ដោយរតនៈទី ១ ទ្រង់ប្រកបដោយអំណាចផ្លូវបញ្ញា ដោយរតនៈចុងក្រោយ ។ ទ្រង់ប្រកបសមត្ថភាព ដោយអំណាចពេញបរិបូណ៌ ដោយដំរីរ័ត្ន សេះរ័ត្ន គហបតីរ័ត្ន ។ ផលចាកការប្រកបនូវអំណាច ៣ យ៉ាង ដោយឥត្ថីរ័ត្ន និងមណីរ័ត្ន ។ ស្តេចចក្រពត្តិនោះសោយនូវភោគសុខ ដោយឥត្ថីរ័ត្ន និងមណីរ័ត្ន សោយឥស្សរិយសុខដោយរតនៈដ៏សេស ។ម្យ៉ាងទៀត ដោយការផ្សេងគ្នា រតនៈ ៣ ខាងដើមរបស់ស្តេចចក្រពត្តិ សម្រេចដោយអានុភាពរបស់កម្មដែលកើតអំពីកុសលមូល គឺអទោសៈ ។ រតនៈ ៣ កណ្តាល សម្រេចដោយអានុភាពរបស់កម្ម ដែលកើតអំពីកុសលមូល គឺអលោភៈ ។ រតនៈ ១ ចុងក្រោយ គប្បីជ្រាបថាសម្រេចដោយអានុភាពកម្ម ដែលកើតអំពីកុសលមូល គឺអមោហៈ ។

បទថា **បទេសរជ្ជស្ស** បានដល់ ដែនតូចៗ ។ បទថា **ឯតទហោសិ** សេចក្ដីថា ស្ដេចចក្រពត្តិ កាលទ្រង់ពិចារណាដល់សម្បត្តិរបស់ព្រះអង្គ មានព្រះតម្រិះជាដើមថា នេះជាផលនៃកម្មអ្វីរបស់អញហ្ន៎ ក្នុងកាលដែលជាស្ដេចចក្រពត្តិចុងក្រោយ ។ ការត្រិះរិះបានសម្រេចគ្រប់ប្រការក្នុងភពនោះៗ ។ នេះជាការប្រកបដោយអំណាចចក្រពត្តិកាល ក្នុងភពនោះ ។ បទថា **ឯវំ មហិទ្ធិកោ** សេចក្ដីថា ស្ដេចចក្រពត្តិមានឫទ្ធិច្រើនយ៉ាងនេះ ព្រោះដល់ព្រមដោយការទ្រទ្រង់នូវឃ្លាំង មានមណីរ័ត្ន និងហត្ថីរ័ត្នជាដើមជាប្រធាន និងព្រោះដល់នូវភាពជាអ្នកស្អកស្កម្មក្នុងជនបទ ។ បទថា **ឯវំ មហានុភាវោ** សេចក្ដីថា ស្ដេចចក្រពត្តិទ្រង់មិនបានធ្វើការបៀតបៀនបុគ្គលណាម្នាក់ ដោយបញ្ជូនចក្រកែវជាដើមទៅទម្លាយ ទ្រង់មានអានុភាពច្រើនយ៉ាងនេះជាដើមថា ទ្រង់ឡើងកាន់វេហាស៍ មានព្រះបញ្ជាឲ្យព្រះរាជាគ្រប់អង្គទទួលដោយសិរសា គឺត្បូង ។ បទថា **ទានស្ស** បានដល់ ទ្រង់បរិច្ចាគទេយ្យធម៌ មានបាយជាដើម ។ បទថា **ទមស្ស** បានដល់ ទ្រង់មានឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើម ព្រោះទ្រង់សង្កត់កិលេស មានរាគៈជាដើម ដោយការសមាទាន ។ បទថា **សញ្ញមស្ស** បានដល់ ជាអ្នកសង្រួមកាយ និងវាចា ។ ក្នុង ៣ ប្រការនោះ ការកម្ចាត់កិលេសដោយការសមាទានឯណា នុ៎ះជាបុណ្យសម្រេចដោយភាវនា ។ បុណ្យនោះឯង ជាមេត្តាព្រហ្មវិហារ លោកបំណងយកក្នុងទីនេះ ។ ក្នុងឧបចារៈ និងអប្បនាទាំង ២ យ៉ាងនោះ បុណ្យណាដល់នូវអប្បនា ការកើតឡើងក្នុងឈានភូមិ ២ តាមដែលពោលហើយ មានដោយបុណ្យនោះ ។ គប្បីជ្រាប

ថា ភាពជាចក្រពត្តិជាដើម គួរមានដោយវិបាក ៣ យ៉ាងនេះ ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាសាក្សី ហើយទ្រង់ប្រកាសភាពដែលបុណ្យមានផលច្រើន ឥឡូវនេះ កាលទ្រង់សម្តែងអត្ថនោះដោយគាថាព័ន្ធ ទើបត្រាស់ពាក្យជាដើមថា **បុញ្ញមេវ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុញ្ញមេវ សោ សិក្ខេយ្យ** សេចក្តីថា កុលបុត្រអ្នកប្រាថ្នាប្រយោជន៍គប្បីសិក្សា គប្បីតាំងមាំ គប្បីសេពនូវធម៌ជាកុសល ៣ យ៉ាង ដែលបានឈ្មោះថា **បុញ្ញ** ព្រោះឲ្យកើតផលគួរបូជា និងព្រោះជម្រះសន្តានរបស់ខ្លួន ។ បទថា **អាយតគ្គំ** សេចក្តីថា បុណ្យឈ្មោះថា **អាយតគ្គំ** ព្រោះមានផលបរិបូណ៌ មានផលធំក្រៃលែង ឬឧត្តមតទៅ ព្រោះមានផលគួរពេញចិត្ត ឬព្រោះប្រសើរដោយសេចក្តីចម្រើន គឺដោយភាពជាធំ និងឧត្តមដោយបច្ច័យ មានយោនិសោមនសិការជាដើម ។ **ត** អក្ខរៈ ជាបទសន្ធិ ។ម្យ៉ាងទៀត បុណ្យ ឈ្មោះថា **អាយតគ្គំ** ព្រោះប្រសើរ គឺជាប្រធាននៃសេចក្តីចម្រើន ដែលជាផលគួរពេញចិត្ត អធិប្បាយថា បន្ទាប់អំពីនោះក៏មានសុខជាកម្រៃ គឺមានសុខជាវិបាក ។

លោកសួរថា បុណ្យនោះដូចម្តេច កុលបុត្រគប្បីសិក្សាក្នុងបុណ្យបានដូចម្តេច ឆ្លើយថា គប្បីបំពេញទាន សមចរិយា និងមេត្តាចិត្ត ។

ក្នុងបទទាំងនោះ បទថា **សមចរិយំ** បានដល់ មានសីលបរិសុទ្ធ មានការប្រព្រឹត្តផ្លូវកាយជាដើម ព្រោះវៀរការប្រព្រឹត្តដែលមិនរៀបរយផ្លូវកាយជាដើម ។ បទថា **ភាវយេ** បានដល់ គប្បីឲ្យកើត គឺឲ្យចម្រើនក្នុងសន្តានរបស់

ខ្ជួន ។ បទថា **ឃតេ ធម្មេ** បានដល់ សុចរិតធម៌ មានទានជាដើមទាំងនេះ ។ បទថា **សុខសមុទ្ទយេ** បានដល់ មានសុខជាអានិសង្ស ។ អាចារ្យពួកខ្លះសម្តែងថា សូម្បីអានិសង្សផលក៏ជាសុខនៃធម៌ទាំងនោះ ។ បទថា **អព្យាបជ្ឈំ សុខំ លោកំ** បានដល់ លោកដែលមិនមានការបៀតបៀន គឺមិនមានទុក្ខ ព្រោះវៀរចាកព្យាបាទ មានកាមច្ឆន្ទៈជាដើម ។ តែមិនមានពាក្យពោលដល់ការមិនមានការបៀតបៀនចំពោះអ្នកដទៃ ។ ព្រហ្មលោករបស់ឈាន និងបុណ្យឈ្មោះថាជាសុខ និងឈ្មោះថាជាសុខដោយចំណែកមួយ ព្រោះច្រើនទៅដោយសេចក្តីសុខ ដោយអំណាចឈាន និងសមាបត្តិ ។ តែបណ្ឌិតអ្នកមានបញ្ញា រមែងចូលដល់លោកដែលជាសុខ ពោល គឺភាពជាអ្នកមានសម្បត្តិដទៃអំពីនោះនៃបុណ្យក្រៅអំពីនេះ ។

ក្នុងសូត្រនេះឯង ក្នុងគាថាទាំងឡាយ លោកពោលដល់វដ្តសម្បត្តិតែម្យ៉ាងដូច្នេះឯង ៕

**អដ្ឋកថា បុញ្ញសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឧភោអត្ថសូត្រ

[ ២៣ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ រមែងបានប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ ធម៌ ១ តើដូចម្តេច ។ គឺសេចក្តីមិនប្រមាទ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ រមែងបានប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

បណ្ឌិតទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ក្នុង
បុញ្ញកិរិយាវត្ថុទាំងឡាយ បណ្ឌិតមិនប្រមាទហើយ រមែង
បានប្រយោជន៍ទាំង ២ គឺ ប្រយោជន៍ក្នុងបច្ចុប្បន្ន ១
ប្រយោជន៍ក្នុងបរលោក ១ អ្នកមានប្រាជ្ញា ព្រោះបាន
ប្រយោជន៍ទាំង ២ ទើបហៅថា ជាបណ្ឌិត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## ឧភោអត្ថសូត្រ

ក្នុងឧភោអត្ថសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ២៣ ] បទថា **ភាវិតោ** បានដល់ ធ្វើឲ្យកើតឡើង និងឲ្យចម្រើនឡើង ។ បទថា **ពហុលីកតោ** បានដល់ ធ្វើឲ្យរឿយៗ ។ បទថា **អត្ថោ** បានដល់ ប្រយោជន៍ ។ ពិតហើយ ប្រយោជន៍នោះ លោកពោលថា **អត្ថោ** ព្រោះមិនមានសត្រូវ ព្រោះគួរចូលទៅដល់ ។ បទថា **សមធិគ្គយ្ហ តិដ្ឋតិ** បានដល់ ទាញដោយប្រពៃ គឺមិនលះ នៅប្រព្រឹត្តនៅឡើយ ។ បទថា **ទិដ្ឋ-ធម្មិកំ** បានដល់ អត្តភាពដែលឃើញប្រចក្ស លោកហៅថា **ទិដ្ឋធម៌** ។ សេចក្ដីចម្រើនក្នុងទិដ្ឋធម៌ ឈ្មោះថា **ទិដ្ឋធម្មិក** អធិប្បាយថា សេចក្ដីចម្រើនដែលទាក់ទងក្នុងលោកនេះ ។ បទថា **សម្បរាយិកំ** បានដល់ លោកដទៃឈ្មោះថា **សម្បរាយ** ព្រោះគួរទៅខាងមុខ ដោយអំណាចធម៌ ។ សេចក្ដីចម្រើនខាងមុខ ឈ្មោះថា **សម្បរាយិក** លោកអធិប្បាយថា សេចក្ដីចម្រើនដែលទាក់ទងក្នុងលោកខាងមុខ ។ សួរថា ប្រយោជន៍បច្ចុប្បន្ននោះ គឺអ្វី ប្រយោជន៍ខាងមុខ គឺអ្វី ឆ្លើយថា ពោលត្រឹមតែដោយសង្ខេប អ្វីណាជាសេចក្ដីសុខក្នុងលោកនេះ អ្វីណានាំសេចក្ដីសុខមកឲ្យក្នុងលោកនេះ នេះឯងគឺប្រយោជន៍បច្ចុប្បន្ន ។ ដូចជាសុខរបស់គ្រហស្ថ មានជាដើមយ៉ាងនេះ គឺរបស់ប្រើដែលល្អ ការងារមិនប្របូកប្របល់ ដឹងវិធីរក្សាសុខភាព ធ្វើរបស់ប្រើប្រាស់ស្អាត ចាត់ចែងការងារល្អ ជាងមានថ្វីដៃ និងស្វែងរកចំណេះដឹង

សង្គ្រោះបរិវារ ។ ឯសេចក្តីសុខរបស់បព្វជិត មានគ្រឿងប្រើប្រាស់ប្រចាំខ្លួន គ្រឿងប្រើប្រាស់ បានដល់ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈពួកណា ការបានគ្រឿងប្រើប្រាស់ទាំងនោះ ដោយមិនលំបាក ម្យ៉ាងទៀត ការសេពដោយការពិចារណា ការវៀរដោយការពិចារណា ក្នុងរបស់ប្រើប្រាស់ទាំងនោះ ការធ្វើវត្ថុឲ្យស្អាត ការប្រាថ្នាតិច ការសន្តោស ការស្ងាត់ ការមិនប្រឡូកប្រឡំ ។ គប្បីជ្រាបថា ការនៅក្នុងប្រទេសដ៏សមគួរ ការគប់រកសប្បុរស ការស្តាប់ធម៌ ការធ្វើទុកក្នុងចិត្ត ដោយឧបាយជាដើម ជាធម៌ទូទៅដល់គ្រហស្ថ និងបព្វជិតទាំង ២ នេះជាការសមគួរទាំង ២ ចំណែក ។

ការមិនប្រមាទក្នុងបទថា **អប្បមាទោ** នេះ គប្បីជ្រាបដោយផ្ទុយគ្នានឹងសេចក្តីប្រមាទ ។ សួរថា ឈ្មោះថា សេចក្តីប្រមាទនេះ គឺអ្វី ឆ្លើយថា គឺការប្រហែសធ្វេស សមដូចព្រះមានព្រះភាគត្រាស់ក្នុងគម្ពីរវិភង្គថា បណ្តាធម៌ទាំងនោះ សេចក្តីប្រមាទ តើដូចម្តេច ។ ការបណ្តោយចិត្ត ការឲ្យកម្លាំងដល់ការបណ្តោយចិត្ត ក្នុងកាយទុច្ចរិតក្តី ក្នុងវចីទុច្ចរិតក្តី ក្នុងមនោទុច្ចរិតក្តី ក្នុងកាមគុណ ៥ ក្តី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែស ក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។ ព្រោះដូច្នោះ គប្បីជ្រាបការមិនប្រមាទ ដោយ

ផុយគ្នានឹងការប្រមាទ ដូចដែលបានពោលហើយ ។ ពិតហើយ ការមិនប្រមាទនោះ ដោយអត្ថ បានដល់ ការមិនទៅប្រាសចាកសតិ ។ ពាក្យថា មិនប្រមាទនេះ ជាឈ្មោះនៃសតិដែលចូលទៅតម្កល់ជានិច្ចនោះឯង ។ តែអាចារ្យពួកខ្លះពោលថា អរូបក្ខន្ធ ៤ ដែលប្រព្រឹត្តទៅដោយប្រកបជាមួយសតិសម្បជញ្ញៈ ឈ្មោះថា ការមិនប្រមាទ ។

ព្រះមានព្រះភាគត្រាស់ថា **ភាវិតោ ពហុលីកតោ** ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ ដូច្នេះ ។ សួរថា ការមិនប្រមាទនេះគប្បីឲ្យចម្រើនដូចម្តេច ឆ្លើយថា ការចម្រើនតែម្យ៉ាង តែបែកគ្នា មិនឈ្មោះថា ចម្រើនការមិនប្រមាទឡើយ ការធ្វើបុណ្យ ធ្វើកុសលទាំងអស់ណាមួយ គប្បីជ្រាបថា ការចម្រើនការមិនប្រមាទទាំងអស់ ។ តែផ្សេងគ្នា បានដល់ ការចម្រើនសីល សមាធិ បញ្ញា សំដៅដល់ឧបនិស្ស័យនៃវិវដ្ត ការដល់សរណៈ និងការសង្រួមតាមផ្លូវកាយ និងចិត្ត ព្រោះហេតុនោះ ការចម្រើនកុសល ការចម្រើនធម៌ដែលមិនមានទោស គប្បីជ្រាបថា ជាការចម្រើនសេចក្តីមិនប្រមាទ ។

ពិតហើយ បទថា **អប្បមាទោ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ប្រយោជន៍ធំ គឺទ្រង់កាន់យកប្រយោជន៍ច្រើនតាំងនៅ ។ មិនគួរពោលថា ព្រះធម្មកបិកនាំយកពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងអស់ មកពោលធ្វើអត្ថនៃបទ គឺ **អប្បមាទ** ចេញអំពីក្រៅផ្លូវទៅ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការមិនប្រមាទជាធម៌ធំ ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធ កាលទៀបបរិនិព្វាន ទ្រង់ផ្ទំត្រង់ចន្លោះសាលព្រឹក្សទាំងគូ ទៀបក្រុងកុសិនារា ទ្រង់ប្រមូល

ធម៌ ដែលទ្រង់សម្តែងមកអស់កាល ៤៥ ព្រះវស្សា តាំងពីការត្រាស់ដឹងមក ទើបប្រទានព្រះឱវាទដល់ភិក្ខុទាំងឡាយថា **អប្បមាទេន សម្បាទេថ** អ្នកទាំងឡាយ ចូរញុំាងការមិនប្រមាទឲ្យដល់ព្រមចុះ ។ ទ្រង់ពោលពង្រីកសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ស្នាមជើងទាំងឡាយឯណានីមួយ របស់ពួកសត្វដែលនៅលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះ តែងប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីប្រាកដជាវិសេសជាងស្នាមជើងនៃសត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះជាស្នាមជើងធំ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្រ្គោះចូលអប្បមាទធម៌ ដូច្នោះឯង ។

អធិប្បាយសេចក្តីក្នុងគាថាទាំងឡាយ មានដូចតទៅនេះ បទថា **អប្បមាទំ បសំសន្តិ** សេចក្តីថា បណ្ឌិតទាំងឡាយជាអ្នកមានបញ្ញា មានព្រះពុទ្ធជាដើម រមែងសរសើរ គឺរមែងពណ៌នា រមែងលើកតម្កើងការមិនប្រមាទក្នុងការធ្វើបុណ្យ មានទានជាដើម ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបណ្ឌិតមិនប្រមាទហើយ រមែងកាន់យកប្រយោជន៍ទាំង ២ បាន ។ សួរថា ប្រយោជន៍ទាំង ២ នោះ គឺអ្វី ឆ្លើយថា គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងអនាគត ១ គប្បីជ្រាបការអធិប្បាយបទក្នុងគាថានេះយ៉ាងនេះ ។ ក្នុងបទថា **ទិដ្ឋេ ធម្មេ ច យោ អត្ថោ** ប្រយោជន៍ក្នុងបច្ចុប្បន្ន បានដល់ ប្រយោជន៍របស់គ្រហស្ថ គឺកម្មដែលមិនមានទោស ប្រយោជន៍ដែលគ្រហស្ថគួរបាន មានវិធីប្រកបកសិកម្ម និងគោរក្ខកម្មជាដើម ដូចដែលព្រះមានព្រះភាគត្រាស់

ដោយន័យជាដើមថា **អនាកុលា ច កម្មន្តា** ការងារមិនច្របូកច្របល់ ... ដូច្នេះ ។ ឯបព្វជិត គប្បីជ្រាបថា បានដល់ប្រយោជន៍ មានការមិនក្តៅក្រហាយជាដើម ។ ឯបទថា **យោ ចត្ថោ សម្បរាយិកោ** ប្រយោជន៍ក្នុងសម្បរាយភព គប្បីជ្រាបថា លោកពោលដល់ការប្រព្រឹត្តធម៌ទាំង ២ ចំណែក គឺទាំងគ្រហស្ថ និងបព្វជិត ។ បទថា **អត្ថាភិសមយា** បានដល់ ព្រោះបាននូវប្រយោជន៍ គឺប្រយោជន៍ទាំង ២ ។ ការបានឈ្មោះថា **សមយ** ព្រោះរួមគ្នា សម្ពន្ធគ្នា ប្រជុំគ្នាដោយវត្ថុដែលគួរបាន ។ **សមយ** សព្ទនោះឯង គឺ **អភិ-សមយ** ឬ **សមយ** ឈ្មោះថា **អភិសមយ** ព្រោះមានមុខទល់រកគ្នា ។ គប្បីជ្រាបអត្ថនៃបទក្នុងទីនេះ ដូច្នេះ ។ ឈ្មោះថា **ធីរោ** ព្រោះជាអ្នកដល់ព្រមដោយបញ្ញា ។ ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបការសង្គ្រោះក្នុងព្រះនិព្វានដែលជាប្រយោជន៍យ៉ាងក្រៃលែង ដោយ **អត្ថ** សព្ទ ។ បទដ៏សេសជាក់ច្បាស់ល្អហើយ ។

ក្នុងសូត្រនេះ លោកពោលដល់វដ្តសម្បត្តិតែម្យ៉ាង ដោយប្រការដូច្នេះ ឯក្នុងគាថា គប្បីឃើញការសង្គ្រោះនូវវិវដ្តៈផងដែរ សមដូចព្រះមានព្រះភាគត្រាស់ថា

**អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។**
**ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា**
**អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។**
**តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា**
**ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។**

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះដោយប្លែកគ្នា ( ទើបស្ថិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរ នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញាតែងប៉ះពាល់នូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

ព្រោះដូច្នោះ ក្នុងបទថា **អត្ថាភិសមយា** នេះ គប្បីជ្រាបសេចក្តីសូម្បីដោយប្រយោជន៍ដែលជាលោកុត្តរ ។ល។

**អដ្ឋកថាឧភោអត្ថសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## វេបុល្លបព្វតសូត្រ

[ ២៤ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលម្នាក់ ស្ទុះទៅ អន្ទោលទៅ អស់កប្ប បំណែកឆ្អឹង ពំនូកឆ្អឹង គំនរឆ្អឹងជាច្រើន បើបុគ្គលប្រមូលនាំមកតម្កល់ទុក ( ១ កន្លែង ) ហើយរក្សាទុក មិនឲ្យវិនាស ខ្ចាត់ខ្ចាយទៅ ឆ្អឹងនឹងដូចជាភ្នំវេបុល្លនេះដូច្នោះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ ទ្រង់ត្រាស់ដូច្នេះថា គំនរឆ្អឹង បុគ្គលម្នាក់ៗ ក្នុងមួយកប្ប ជាគំនរប៉ុនភ្នំ ឯភ្នំនោះឯង ដែលព្រះសម្មាសម្ពុទ្ធត្រាស់ថា ភ្នំវេបុល្ល ជាភ្នំធំ ជាភ្នំខ្ពស់ ជាងភ្នំគិជ្ឈកូដ ក្បែរក្រុងគិរិព្វជៈ គឺរាជគ្រឹះរបស់ពួកជនអ្នកស្រុកមគធៈ កាលណាបើបុគ្គលឃើញអរិយសច្ចទាំងឡាយ ដោយបញ្ញាដ៏ប្រពៃ គឺទុក្ខ ១ ហេតុដែលនាំឲ្យកើតទុក្ខ ១ ការកន្លងបង់ទុក្ខ ១ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលជាទីញ៉ាំងសត្វឲ្យទៅកាន់ទីរលត់ទុក្ខ ១ លុះបុគ្គលនោះ អន្ទោលទៅអស់ ៧ ជាតិ ជាយ៉ាងក្រៃលែង នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សំយោជនៈទាំងពួង ។

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។*

# អដ្ឋកថា

## វេបុល្លបព្វតសូត្រ

*ក្នុងវេបុល្លបព្វតសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ២៤ ] បទថា* **បុគ្គល** *ក្នុងបទថា* **ឯកបុគ្គលស្ស** *នេះ ជាវោហារកថា ។ ពិតហើយ ទេសនារបស់ព្រះសម្ពុទ្ធមាន ២ យ៉ាង គឺសម្មតិទេសនា និងបរមត្ថទេសនា ក្នុងទេសនា ២ យ៉ាងនោះ សម្មតិទេសនា គឺបុគ្គល សត្វ ស្រី ប្រុស ក្សត្រ ព្រាហ្មណ៍ ទេវតា មារ បរមត្ថទេសនា គឺអនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន ។*

*ក្នុងទេសនា ២ យ៉ាងនេះ ព្រះមានព្រះភាគទ្រង់សម្តែងសម្មតិទេសនា ដល់បុគ្គលអ្នកស្តាប់ទេសនា ដោយសម្មតិហើយ អាចសម្រេចគុណវិសេសបាន ។ ទ្រង់សម្តែងបរមត្ថទេសនា ដល់បុគ្គលដែលស្តាប់ទេសនា ដោយបរមត្ថហើយ អាចសម្រេចគុណវិសេសបាន ។ គប្បីជ្រាបឧបមាក្នុងសេចក្តីនោះដូចតទៅនេះ ឧបមាដូចអាចារ្យអ្នកឈ្លាសក្នុងភាសាពណ៌នាអត្ថនៃវេទ ៣ ដោយភាសាទមិឡ បុគ្គលអ្នកចេះភាសាទមិឡក៏ដឹងសេចក្តី ប្រាប់ដោយភាសាបុរាណដល់បុគ្គលដែលចេះភាសាគជាដើមណានីមួយ យ៉ាងណា មាណពទាំង*

ឡាយ ក៏អាស្រ័យអាចារ្យអ្នកឈ្លាស រមែងរៀនសិប្បៈបានលឿន ដូច្នោះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ព្រះសម្ពុទ្ធដូចអាចារ្យ ព្រះត្រៃបិដកដែលតាំងនៅក្នុងការៈដែលគួរប្រាប់ ដូចត្រៃវេទ ភាពជាអ្នកឈ្លាសក្នុងសម្មតិ និងបរមត្ថ ដូចភាពជាអ្នកឈ្លាសក្នុងភាសា វេនេយ្យសត្វដែលអាចចាក់ធ្លុះដោយសម្មតិ និងបរមត្ថ ដូចមាណពអ្នកចេះភាសាវៀងៗ ខ្លួន ការសម្តែងដោយសម្មតិ និងបរមត្ថរបស់ព្រះមានព្រះភាគ ដូចការប្រាប់ដោយភាសាទមិឡជាដើមរបស់អាចារ្យ ។ ក្នុងសេចក្តីនេះ អាចារ្យបានពោលថា

ព្រះសម្ពុទ្ធប្រសើរជាងអ្នកប្រាប់ទាំងឡាយ ទ្រង់បានប្រាប់សច្ចៈ ២ យ៉ាង គឺសម្មតិសច្ច និងបរមត្ថសច្ច មិនបានប្រាប់សច្ចៈជាគម្រប់ ៣ ឡើយ សម្មតិសច្ចជាហេតុសន្ទត្ថក្នុងលោក បរមត្ថសច្ចជារបស់ពិតនៃធម៌ទាំងឡាយ ព្រោះដូច្នោះ វោហាររបស់ព្រះសាស្តាជាទីពឹងរបស់សត្វលោក ទ្រង់ជាអ្នកឈ្លាសក្នុងវោហារ ទ្រង់ពោលសម្មតិសច្ចថា ជាអរិយវោហារ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ត្រាស់បុគ្គលកថាដោយហេតុ ៨ ប្រការ គឺដើម្បីសម្តែងជល់ហិរិ និងឱត្តប្បៈ ១ ដើម្បីសម្តែងភាពដែលសត្វមានកម្មជារបស់ខ្លួន ១ ដើម្បីសម្តែងសេចក្តីព្យាយាមជាគ្រឿងធ្វើនៃបុរសចំពោះខ្លួន ១ ដើម្បីសម្តែងអនន្តរិយកម្ម ១ ដើម្បីសម្តែងព្រហ្មវិហារ ១ ដើម្បីសម្តែងបុព្វេ-និវាសញ្ញាណ ១ ដើម្បីសម្តែងទក្ខិណាវិសុទ្ធិ ១ មិនលះលោកសម្មតិ ១ ។ កាលពោលថា ខន្ធ ធាតុ អាយតនៈ គួរខ្មៀស គួរខ្លាចដូច្នេះ មហាជនតែង

មិនដឹង រមែងដល់នូវការវង្វេង ឬក្លាយជាបរបក្ខថា នេះអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈ ឈ្មោះថា គួររង្កៀស គួរខ្ពើច ដូច្នេះ ។ តែបើពោលថា ស្រី ប្រុស សត្វ ព្រាហ្មណ៍ គួររង្កៀស គួរខ្ពើច ដូច្នេះ មហាជនរមែងដឹង រមែងមិនវង្វេង ឬមិនក្លាយជាបរបក្ខ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថាដើម្បីសម្តែងហិរិ និងឱត្តប្បៈ ។ កាលពោលថា ខន្ធ កម្មស្សកតា ធាតុ អាយតនៈ ក៏មានន័យដូចគ្នា ។ ព្រោះដូច្នោះ ព្រះមានព្រះភាគត្រាស់បុគ្គលកថា ក៏ដើម្បីសម្តែងភាពដែលសត្វមានកម្មជារបស់ខ្លួន សូម្បីកាលពោលថា មហាវិហារ មានវេឡុវ័នជាដើម សាងឡើងដោយខន្ធ ធាតុ អាយតនៈ ក៏មានន័យនេះដូចគ្នា កាលពោលថា ខន្ធទាំងឡាយសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត ធាតុ អាយតនៈ ធ្វើលោហិតុប្បាទ ធ្វើសង្ឃភេទ ក៏មានន័យនេះដូចគ្នា កាលពោលថា ខន្ធ ធាតុ អាយតនៈ រមែងមានមេត្តា ដូច្នេះ ក៏ន័យនេះដូចគ្នា ។ កាលពោលថា ខន្ធ ធាតុ អាយតនៈ រមែងរឭកដល់បុព្វេនិវាស ក៏ន័យនេះដូចគ្នា ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងសេចក្តីព្យាយាមចំពោះខ្លួន ដើម្បីសម្តែងអនន្តរិយកម្ម ដើម្បីសម្តែងព្រហ្មវិហារ និងដើម្បីសម្តែងបុព្វេនិវាស ។ កាលពោលថា ខន្ធ ធាតុ អាយតនៈ បរិភោគ មហាជនក៏មិនដឹង រមែងដល់នូវការវង្វេង ឬក្លាយជាបរបក្ខថា នេះអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈ ឈ្មោះថាបរិភោគ ។ តែបើពោលថា បុគ្គលទាំងឡាយរមែងបរិភោគ ដូច្នេះ មហាជនរមែងដឹង មិនវង្វេង ឬក្លាយជាបរបក្ខឡើយ ។ ព្រោះដូច្នោះ ទើបព្រះមាន

ព្រះភាគត្រាស់បុគ្គលកថា ដើម្បីសម្តែងទក្ខិណាវិសុទ្ធិ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទាំងឡាយត្រាស់ដឹងហើយ ទ្រង់មិនលះលោកសម្មតិ ទ្រង់តាំងនៅក្នុងលម្អរបស់លោក មួយអន្ទើដោយការសម្តែងធម៌តាមសមញ្ញារបស់លោក ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីមិនលះលោកសម្មតិ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគអង្គនោះ កាលទ្រង់សម្តែងអត្ថដែលគួរសម្តែង ដោយលោកវោហារ ទើបត្រាស់ពាក្យជាដើមថា **ឯកបុគ្គលស្ស** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯកបុគ្គលស្ស** បានដល់ សត្វ ១ ។ បទថា **កប្បំ** បានដល់ អស់មហាកប្ប ។ ពិតហើយ **កប្បំ** នេះ ជាទុតិយាវិភត្តិចុះក្នុងអច្ចន្តសំយោគ គឺអស់ ឬរហូត គប្បីកាន់យកកប្បដែលសត្វទាំងឡាយត្រាច់អន្ទោលទៅ ។ បទថា **អដ្ឋិកង្កលោ** បានដល់ ចំណែកនៃឆ្អឹង ។ អាចារ្យពួកខ្លះពោលថា **អដ្ឋិខលោ** ដូច្នេះក៏មាន សេចក្តីថា សន្សំឆ្អឹង ។ បទថា **អដ្ឋិបុញ្ជោ** បានដល់ ពូកឆ្អឹង ។ បទថា **អដ្ឋិរាសិ** ជាវេវចនៈនៃបទថា **អដ្ឋិបុញ្ជោ** នោះឯង ។ តែអាចារ្យពួកខ្លះពោលថា ចាប់ពីចង្កេះចុះទៅ ឈ្មោះ **កង្កលោ** ចាប់ពីលើចង្កេះឡើងទៅ ត្រឹមមួយជួរត្នោត ឈ្មោះ **បុញ្ជោ** លើសពីមួយជួរត្នោតឡើងទៅ ជា **រាសិ** គឺគំនរ នុ៎ះគ្រាន់តែមតិរបស់អាចារ្យទាំងនោះទេ ។ ទាំងអស់នោះជាពាក្យពោលត្រួតនៃ **សម្ពហ** សព្ទនោះឯង ។ ពាក្យថា **ភ្នំវេបុល្ល** នេះ ព្រោះនាំមកដោយប្រៀបធៀបគ្នា ។ បទថា **សចេ**

**សំហារកោ អស្ស** សេចក្តីថា អាចារ្យរមែងពោលដោយកំណត់ថា បើបុគ្គលណាម្នាក់គប្បីប្រមូលគរជាគំនរ មិនឲ្យរាត់រាយ ។ បទថា **សម្ភតញ្ច ន វិនស្សេយ្យ** អាចារ្យរមែងពោលដោយកំណត់ថា បើចំណែកនៃឆ្អឹងដែលបុគ្គលណានាំទៅហើយ មិនគប្បីវិនាស ព្រោះមិនពុកផុយ មិនជាលម្អិតតូចធំ ដោយមិនអន្តរធានទៅ ។

ក្នុងព្រះសូត្រនេះ មានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ កាលសត្វមួយត្រាច់អន្ទោលទៅ អស់មហាកប្ប ១ ដោយកើតហើយកើតទៀត ដោយកម្មកិលេស គំនរឆ្អឹងធំគប្បីមានយ៉ាងនេះ ប៉ុនភ្នំវេបុល្លបព៌ត ដោយកម្ពស់និងចំណែកទទឹង បើបុគ្គលណាគប្បីរបួរមមកជាគំនរ និងបើចំណែកនៃឆ្អឹងនោះ ដែលបុគ្គលណានាំទៅហើយ មិនគប្បីវិនាស តាំងនៅ ។ ន័យនេះលោកពោលវៀរអត្តភាពដែលជាឱបបាតិកៈ ប្រាសចាកការដាក់ចុះនូវសាកសពដូចប្រទីបរលត់ហើយ និងអត្តភាពតូចៗ ដែលមិនមានឆ្អឹង ។ តែអាចារ្យពួកខ្លះពោលថា ព្រោះនាំន័យនេះមក ដោយការកំណត់ បើគប្បីមានឆ្អឹងរបស់សត្វទាំងនោះស្មើប៉ុនភ្នំ លោកក៏ពោលដល់បរិមាណគំនរឆ្អឹង ។ អាចារ្យពួកខ្លះពោលថា នេះមិនមែនយ៉ាងនោះ ព្រោះបរិមាណនេះ លោកពោលកំណត់ដោយសព្វញ្ញុតញ្ញាណ ដោយអំណាចគំនរឆ្អឹងដែលបានទុកនោះឯង ដូច្នោះគប្បីកាន់យកដោយន័យដែលពោលហើយនោះ ដោយប្រការដូច្នេះ ។

គប្បីជ្រាបក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **មហេសិនា** សេចក្តីថា ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ជាអ្នកស្វែងរកគុណធំ ព្រោះស្វែងរកគុណ

មានសីលក្ខន្ធដ៏ធំជាដើម ។ បទថា **ឥតិ វុត្តំ មហេសិនា** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងព្រះអង្គ ធ្វើដូចបុគ្គលដទៃ ដូចក្នុងប្រយោគជាដើមថា **ទសពលសមន្នាគតោ ភិក្ខវេ តថាគតោ** ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបហើយ ដោយកម្លាំង ១០ ដូច្នេះ ។ បទថា **វេបុល្លោ** សេចក្តីថា ភ្នំឈ្មោះថា **វេបុល្ល** ព្រោះភ្នំ ៥ តាំងព័ទ្ធជុំវិញនគររាជគ្រឹះយ៉ាងបរិបូណ៌ ។ ភ្នំវេបុល្លបព៌តធំជាងនោះ គឺឧត្តមជាងចំណែកនៃទិសដែលតាំងនៅ ។ បទថា **គិជ្ឈកូដស្ស គិរិព្វជេ** បានដល់ ជិតក្រុងរាជគ្រឹះ ឈ្មោះគិរិព្វជបុរី ។

ដោយសេចក្តីមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ទោសក្នុងវដ្ដៈថា បុថុជ្ជន មានការមិនកំណត់ដឹង កាត់នូវឫសរបស់កពមិនដាច់ អស់កាលមានប្រមាណប៉ុណ្ណេះ ដូច្នេះឯង ជាព្រៃខ្មោច ឥឡូវនេះ កាលទ្រង់សម្តែងថា បុថុជ្ជនល្ងង់ខ្លៅ ព្រោះមិនដឹង មិនយល់នូវអរិយសច្ចពួកណាទើបជាបុគ្គលជាក់ចុះសាកសពក្នុងព្រៃខ្មោចយ៉ាងនេះ ព្រះអរិយបុគ្គលឃើញអរិយសច្ចទាំងនោះ ទើបមិនធ្លាក់ក្នុងព្រៃខ្មោច ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា **យតោ ច អរិយសច្ចានិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យតោ** ប្រែថា កាលណា ។ បទថា **អរិយ-សច្ចានិ** បានដល់ ឈ្មោះថា **អរិយ** ព្រោះការអស់ទុក្ខ និងឈ្មោះថា **សច្ច** ព្រោះភាពជារបស់ពិត ព្រោះដូច្នោះ ទើបឈ្មោះថា អរិយសច្ច ឬសច្ចៈ ធ្វើនូវភាពអរិយៈ ។ ទើបឈ្មោះថា អរិយសច្ច ឬសច្ចៈដែលព្រះអរិយៈទាំង-ឡាយ មានព្រះពុទ្ធជាដើមគប្បីចាក់ធ្លុះ ទើបឈ្មោះថា **អរិយសច្ច** ។ ម្យ៉ាង

ទៀត សច្ចៈរបស់ព្រះអរិយៈ ឈ្មោះថា អរិយសច្ច ។ ពិតហើយ ព្រះមានព្រះភាគ ឈ្មោះថា អរិយៈ ព្រោះជាទីពឹង មិនជាសត្រូវរបស់លោក ព្រមទាំងទេវលោក ។ ឈ្មោះថា សច្ចៈរបស់ព្រះអរិយៈនោះ ព្រោះឃើញដោយសយម្ភូញាណ ព្រោះដូច្នោះ ទើបឈ្មោះថា អរិយសច្ច ។ បទថា **សម្ម-ប្បញ្ញាយ បស្សតិ** បានដល់ រមែងឃើញ គឺដោយមគ្គប្បញ្ញា ដែលប្រព្រឹត្តទៅដោយវិបស្សនាបញ្ញា ដោយប្រពៃ ដោយហេតុ ដោយការដឹង ដោយការកំណត់ដឹង ការលះ និងការធ្វើឲ្យជាក់ច្បាស់ ការចម្រើន និងការត្រាស់ដឹង ។ បទថា **ទុក្ខំ** ជាដើម សម្ដែងន័យសរុបរបស់អរិយសច្ច ។ ក្នុងបទថា **ទុក្ខំ** នោះ ឈ្មោះថា **ទុក្ខ** ព្រោះភាពជារបស់គួររង្កៀស ដោយជាទីរួមអន្តរាយច្រើនយ៉ាង និងព្រោះភាពទទេចាកសេចក្ដីសុខសាន្ត ដែលពួកបុគ្គលពាលប្រាថ្នា ។ ការកើតនៃទុក្ខ ឈ្មោះថា **ទុក្ខសមុទយ** ព្រោះជាហេតុកើតនៃទុក្ខ ។ និព្វាន ឈ្មោះថា ជាធម៌ដែលឈានកន្លងនៃទុក្ខ ព្រោះជាហេតុកន្លងទៅនៃទុក្ខ ឬដែលឈានកន្លងទុក្ខ ដែលជាអារម្មណប្បច្ច័យ ។ ឈ្មោះថា អរិយៈ ព្រោះឆ្ងាយចាកកិលេសទាំងឡាយ និងព្រោះអស់សេចក្ដីទុក្ខ ។ អរិយមគ្គមានអង្គ ៨ ដោយអំណាចនៃអង្គ ៨ មានសម្មាទិដ្ឋិជាដើម ។ ឈ្មោះថា **មគ្គ** ព្រោះសម្លាប់កិលេសឲ្យអស់ទៅ ឬបុគ្គលត្រូវការនិព្វានគប្បីស្វែងរក ឬព្រោះស្វែងរកនិព្វានឯង ។ ឈ្មោះថា **ទុក្ខូបសមគាមី** ព្រោះដល់នូវការស្ងប់ គឺការរម្ងត់នៃទុក្ខចាកមគ្គនោះឯង ភ្ជាប់ជាមួយបទថា **យតោ សម្មប្បញ្ញាយ បស្សតិ** កាលណា បុគ្គលរមែងពិចារណាឃើញអរិយសច្ចដោយបញ្ញាដ៏ប្រពៃ ដូច្នេះ ។

បទថា **ស សត្តក្ខត្តុំបរមំ សន្ធាវិត្វាន បុគ្គលោ** សេចក្តីថា ព្រះអរិយបុគ្គល ដែលជាសោតាបន្ន មានឥន្ទ្រិយទន់ជាងគេបង្អស់ ឃើញអរិយសច្ច ៤ នោះ ត្រាច់ទៅអន្ទោលទៅ គឺស្ទុះទៅ ដោយកើតនូវការជាប់តគ្នាក្នុងកពជាដើម ៧ ដង យ៉ាងក្រៃលែង ។ ពិតហើយ ព្រះសោតាបន្នទាំងឡាយ ៣ ពួក គឺឯក-ពីជី ១ កោលំកោលៈ ១ សត្តក្ខត្តុបរម ១ ព្រោះមានឥន្ទ្រិយក្លៀវក្លា កណ្តាល និងទន់ខ្សោយ ។ បទថា **ស សត្តក្ខត្តុំបរមំ សន្ធាវិត្វាន** នេះ ព្រះមានព្រះ ភាគត្រាស់ដល់ព្រះសោតាបន្ន ដែលមានឥន្ទ្រិយទន់ជាងព្រះសោតាទាំងពួង។ បទថា **ទុក្ខស្សន្តករោ ហោតិ** សេចក្តីថា ជាអ្នកធ្វើទីបំផុត គឺធ្វើទីបំផុតនៃ វដ្តទុក្ខបាន ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ព្រោះសំយោជនៈទាំង ពួងអស់ទៅ អធិប្បាយថា ព្រោះសម្រេចមគ្គដ៏កំពូលដោយលំដាប់ ហើយ សំយោជនៈអស់ទៅ ដោយមិនមានសេសសល់ ។ ព្រះមានព្រះភាគ ទ្រង់ កាន់យកកំពូលទេសនា ដោយអរហត្តផលនោះឯង ៗ៕

**អដ្ឋកថាវេបុល្លបព្វតសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សម្បជានមុសាវាទសូត្រ

[ ២៥ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលកន្លងធម៌ ១ ហើយ តថាគតមិនដែលពោលថា បុរសបុគ្គលនោះ មិនគប្បីធ្វើបាបកម្មបន្តិចបន្តួច ដូច្នេះឡើយ ។ ធម៌ ១ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១ នេះ គឺសម្បជានមុសាវាទ ( ការពោលពាក្យកុហកទាំងដឹងខ្លួន ) ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វដែលកន្លងធម៌ ១ គឺអ្នកពោលពាក្យកុហក មាន
បរលោក កន្លងបង់ហើយ មិនគប្បីធ្វើអំពើបាប មិន
មានឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## សម្បជានមុសាវាទសូត្រ

*សម្បជានមុសាវាទសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ២៥ ] អ្វីជាហេតុឲ្យកើតបទថា* **ឯកធម្មំ អតីតស្ស ។** *រឿងមានដូច្នេះ លាភសក្ការៈជាច្រើន កើតដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ វិនាសចាកពួកតិត្ថិយ ។ ពួកតិត្ថិយកាលសាបសូន្យលាភសក្ការៈ ក៏អាប់ឱន អស់នូវតេជះ កើតនូវសេចក្តីប្រណែន ទើបនាំគ្នាទៅបបួលបរិព្វាជិកា ឈ្មោះចិញ្ចមាណវិកាថា នែប្អូនស្រី ចូរនាងបង្កាច់ព្រះគោតម ដោយពាក្យមិនពិតចុះ ។ នាងចិញ្ចមាណវិកា ក៏ចូលទៅរកព្រះមានព្រះភាគ ដែលកំពុងសម្តែងធម៌ក្នុងកណ្តាលបរិស័ទ បានពោលបង្កាច់ដោយពាក្យមិនពិត សក្កទេវរាជបានប្រកាសភាពមិនពិតរបស់នាង នៅក្នុងកណ្តាលបរិស័ទ មហាជននាំគ្នាផ្តាសាថា វ៉ុយ មេកាឡកិណី ហើយទាញចេញពីវិហារ ផែនដីក៏បើកឱកាសឲ្យនាងចិញ្ចមាណវិកា មានសរីរៈដូចអង្កត់ឧសឆេះដោយភ្លើង ទៅកើតក្នុងអវីចិមហានរក ពួកតិត្ថិយរឹងរឹតតែវិនាសចាកលាភសក្ការៈខ្លាំងឡើង ។*

*ភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ នាងចិញ្ចមាណវិកា ជេរប្រទេចព្រះសម្មាសម្ពុទ្ធ ដែលជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ទ្រទ្រង់នូវគុណក្រៃលែង ដោយពាក្យមិនពិត ដល់នូវសេចក្តីវិនាសធំ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យហេតុនោះ ទើបត្រាស់មហាបទុមជាតកថា ម្នាលភិក្ខុទាំងឡាយ ចិញ្ចមាណវិកាបានជេរតថាគតដោយពាក្យមិនពិត ហើយដល់នូវសេចក្តីវិនាសធំក្រៃលែង មិនមែនតែក្នុងឥឡូវនេះទេ សូម្បី*

កាលមុនក៏ដូចគ្នា កាលទ្រង់សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបត្រាស់ព្រះសូត្រនេះ ដោយបទថា **ឯកធម្មមតីតស្ស** ដើម្បីឲ្យកើតរឿងនេះឡើង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឯកធម្មំ** បានដល់ ធម៌ ១ គឺវចីសច្ចៈ ។ បទថា **អតីតស្ស** សេចក្តីថា កាលបុគ្គលកន្លងនូវមារយាទរបស់ព្រះអរិយៈទាំងឡាយ វៀរវោហារដែលមិនមែនជាអរិយៈ ៨ ប្រការហើយ ដើម្បីតាំងមាំក្នុងវោហារដែលជាអរិយៈ ៨ ប្រការ ទើបទាញយកដោយបទថា **សច្ចំ ភណេ ន អលិកំ** គួរពោលសេចក្តីពិត មិនគួរពោលឡេះឡោះ ដូច្នេះជាដើម ។ បុគ្គល គឺបុរស ឈ្មោះថា បុរសបុគ្គល បានដល់ បុរសបុគ្គលនោះ ។ បទថា **អករណីយំ** បានដល់ មិនអាចដើម្បីធ្វើ ។ ពិតហើយ បុគ្គលនិយាយកុហកទាំងដឹងខ្លួន និងធ្វើបាបកម្ម កាលគេពោលថា លោកធ្វើកម្មនេះ នៅអះអាងដោយពាក្យថា ខ្ញុំមិនបានធ្វើ ដូច្នេះ បដិបត្តិយ៉ាងនេះ នៅតែធ្វើបាប-កម្មរឿយៗ ទៅ រមែងមិនខ្មាសក្នុងបាបកម្មនោះ ព្រោះកន្លងបង់នូវលំដាប់ពាក្យសច្ចៈ ដែលជាមារយាទល្អ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **កតមំ ឯកធម្មំ យថិទំ ភិក្ខវេ សម្បជានមុសាវាទោ** ធម៌ ១ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ធម៌ ១ នេះ គឺសម្បជានមុសាវាទ ដូច្នេះ ។

គប្បីជ្រាបអធិប្បាយក្នុងគាថាដូចតទៅនេះ បទថា **មុសាវាទិស្ស** បានដល់ ច្រើនដោយពោលកុហកមិនពិត មិនមែនមិនឲ្យអ្នកដទៃដឹង ។ ពាក្យពោល ១០ ម៉ាត់ មិនមានពាក្យពិតសូម្បីតែមួយម៉ាត់ ។ បទថា **ជន្តុនោ** បានដល់ សត្វ ។ ពិតហើយ សត្វ លោកហៅថា **ជន្តុ** ព្រោះអត្ថថា ជាអ្នក

កើត ។ បទថា **វិតិណ្ណបរលោកស្ស** បានដល់ លះបង់លោកខាងមុខចោល ហើយ ព្រោះបុគ្គលបែបនេះ រមែងមិនឃើញសម្បត្តិទាំង ៣ គឺមនុស្ស-សម្បត្តិ ទេវលោកសម្បត្តិ និងនិព្វានសម្បត្តិ ។ បទថា **នត្ថិ បាបំ** បានដល់ បាបនេះ ដែលបុគ្គលបែបនោះ មិនគប្បីធ្វើមិនមាន ។ល។

**អដ្ឋកថា សម្បជានមុសាវាទសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទានសូត្រ

[ ២៦ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀត មន្ទិល គឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។ ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណា របស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឲ្យ និងការចែករំលែកយ៉ាងណា សត្វទាំងឡាយ មិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះ សត្វទាំងឡាយមិនបានឲ្យទានហើយ ទើបហ៊ានបរិភោគ មួយទៀត មន្ទិល គឺសេចក្តីកំណាញ់ ក៏តែងគ្របសង្កត់ចិត្តសត្វ

ទាំងឡាយនោះ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បើសត្វទាំងឡាយ គប្បីដឹងផលនៃការចែករំលែកថា
មានផលច្រើន ដូចព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំត្រាស់
ទុកហើយយ៉ាងនេះ សត្វទាំងឡាយមានចិត្តជ្រះថ្លា គប្បី
បន្ទោបង់មន្ទិល គឺសេចក្តីកំណាញ់ចេញ ទានដែលគេ
ឲ្យហើយ ដល់ព្រះអរិយៈទាំងឡាយណា រមែងមាន
ផលច្រើន បុគ្គលទាំងឡាយ គួរឲ្យទានដល់ព្រះអរិយៈ
ទាំងនោះ ក្នុងកាលដ៏គួរ មួយទៀត ជនច្រើននាក់ឲ្យ
បាយជាទក្ខិណាទាន ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយ
ទាយកទាំងឡាយ លុះច្យុតអំពីអត្តភាពជាមនុស្សនេះ
ហើយ រមែងទៅកាន់ស្ថានសួគ៌ ទាយកទាំងនោះ លុះ
ទៅកាន់ស្ថានសួគ៌ ជាអ្នកមានចំណង់ក្នុងកាម រមែង
រីករាយក្នុងស្ថានសួគ៌នោះ សត្វទាំងឡាយមិនកំណាញ់
រមែងសោយផលនៃការចែករំលែក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## ទានសូត្រ

ក្នុងទានសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ២៦ ] បទថា **ឯវំ** ក្នុងបទថា **ឯវញ្ចេ** នេះ ប្រព្រឹត្តទៅក្នុងសេចក្តីឧបមា ។ បទថា **ចេ** ជានិបាត ចុះក្នុងបរិកប្ប ។ បទថា **សត្តា** បានដល់ជាអ្នកជាប់ជំពាក់ គឺផ្សាយទៅក្នុងអារម្មណ៍ មានរូបជាដើម ។ បទថា **ជានេយ្យុំ** ប្រែថា គប្បីដឹង ។ បទថា **ទានសំវិភាគស្ស** បានដល់ ចេតនាដែលរួបរួមទេយ្យធម៌ មានបាយជាដើម ឲ្យដល់អ្នកដទៃ ដោយការអនុគ្រោះ និងការបូជាឯណាមួយ ឈ្មោះថា ទាន ឯចេតនាដែលចែករំលែកនូវវត្ថុដែលខ្លួនកាន់យកបរិភោគហើយ ឲ្យឈ្មោះថា **សំវិភាគ** គឺការចែករំលែក ។ បទថា **វិបាកំ** គឺផល ។ បទថា **យថាហំ ជានាមិ** បានដល់ ដូចតថាគតដឹង ។ សេចក្តីនេះព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើសត្វទាំងឡាយគប្បីដឹងផលនៃការឲ្យទាន ដូចតថាគតដោយកម្លាំងញាណ ដែលជាផលនៃកម្មដោយប្រចក្សក្នុងឥឡូវនេះ មានពាក្យជាដើមថា ផលទានរមែងមានដល់ ១០០ ដង ដោយឲ្យទានដល់សត្វតិរច្ឆាន ហើយសោយសុខប្រព្រឹត្តទៅក្នុង ១០០ អត្តភាព ដូច្នេះ ។ បទថា **ន អទត្វា ភុញ្ជេយ្យុំ** សេចក្តីថា សត្វទាំងឡាយ មិនទាន់ឲ្យរបស់ដែលគួរបរិភោគដែលមានដល់ខ្លួន ដល់អ្នកដទៃមុនហើយ ក៏នឹងមិនបរិភោគ កាលណាឲ្យហើយ ទើបបរិភោគ ។ បទថា **ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ** ម្យ៉ាងទៀត សេចក្តីកំណាញ់

*ជាមន្ទិល នឹងមិនគ្របសង្កត់សត្វទាំងឡាយនោះ សេចក្តីថា ការកំណាញ់ ដែលជាមន្ទិលណាមួយរបស់បណ្តាធម៌ចំណែកខ្មៅ ដែលឧបក្កិលេសទម្លាយនូវការផូរផង់របស់ចិត្ត មានលក្ខណៈ មិនព្រមឲ្យសម្បត្តិរបស់ខ្លួនទូទៅដល់អ្នកដទៃ ។ ម្យ៉ាងទៀត សេចក្តីកំណាញ់ និងមន្ទិល មានឥស្សា លោភៈ ទោសៈជាដើម ដែលធ្វើអន្តរាយដល់ទានដទៃ និងមិនគប្បីគ្របសង្កត់ចិត្តរបស់សត្វទាំងនោះ ដោយអាការដែលមិនមានចេតនានឹងឲ្យ ឬមានចេតនាមិនបរិសុទ្ធ ។ បុគ្គលណា កាលដឹងផលនៃទានដោយប្រពៃ នឹងគប្បីឲ្យឱកាសដល់សេចក្តីកំណាញ់ដែលជាមន្ទិលក្នុងចិត្តរបស់ខ្លួនបាន ។ បទថា* **យោបិ នេសំ អស្ស ចរិមោ អាលោបោ** *បានដល់ គប្បីមានពំនូតបាយចុងក្រោយបង្អស់របស់សត្វទាំងនោះ ។ បទថា* **ចរិមំ កពលំ** *ជាវេវចនៈនៃពាក្យថា* **អាលោបោ** *នោះឯង សេចក្តីនេះ លោកអធិប្បាយថា តាមប្រក្រតី សត្វទាំងនេះ មានជីវិតនៅបានឯង ដោយដុំបាយដរាបណា បន្ទល់ពំនូតបាយ ១ ដុំ ក្នុងពំនូតបាយទាំងនោះ ដើម្បីជាប្រយោជន៍ដល់ខ្លួន ហើយឲ្យដុំបាយទាំងអស់ក្រៅអំពីមួយដុំនោះ ដល់អ្នកដែលត្រូវការមករក ដុំបាយដែលបន្ទល់នោះ ឈ្មោះថាដុំបាយចុងក្រោយ ក្នុងទីនេះ បទថា* **តតោបិ ន អសំវិភជិត្វា ភុញ្ជេយ្យុំ សចេ នេសំ បដិគ្គាហកា អស្សុ** *សត្វទាំងនោះមិនគប្បីចែកពំនូតក្រោយអំពីពំនូតបាយនោះហើយ ក៏មិនគប្បីបរិភោគ បើបដិគ្គាហករបស់សត្វទាំងនោះគប្បីមាន សេចក្តីថា បើបដិគ្គាហករបស់សត្វទាំងនោះគប្បីមាន សេចក្តីថា បើបដិគ្គាហករបស់សត្វទាំងនោះគប្បីមាន សត្វទាំងឡាយគប្បីវែកអំពី*

ដុំបាយ មានប្រមាណតាមដែលពោលហើយ គប្បីឲ្យចំណែកមួយ ហើយសឹមបរិភោគ សត្វទាំងឡាយគប្បីដឹងដូចដែលតថាគតដឹងផលនៃការឲ្យទាន ដោយជាក់ច្បាស់ ដូច្នោះ ។ ដោយបទថា **យស្មា ច ខោ** ជាដើម ព្រះមានព្រះភាគទ្រង់ញ៉ាំងព្រះពុទ្ធបំណងឲ្យសម្រេច ព្រោះសត្វទាំងនោះ មិនដឹងផលក្នុងការចែកទានយ៉ាងនេះ ព្រោះផលរបស់កម្មមិនទាន់ប្របក្ស ដោយបទនេះ គប្បីឃើញថា សម្តែងដល់ការមិនបដិបត្តិក្នុងបុណ្យ និងបដិបត្តិក្នុងវត្ថុដែលមិនមែនបុណ្យ ។ ក្នុងគាថាទាំងនោះ មានអធិប្បាយដូចតទៅនេះ បទថា **យថាវុត្តំ មហេសិនា** សេចក្តីថា ដូចដែលព្រះមានព្រះភាគទ្រង់ស្វែងរកគុណធំក្រៃលែងត្រាស់ហើយដោយន័យជាដើមថា បុគ្គលឲ្យទានដល់សត្វតិរច្ឆាន គប្បីបាននូវផលទានរាប់រយដង ដូច្នេះ ឬដោយន័យក្នុងព្រះសូត្រថា **ឯវញ្ចេ សត្តា ជានេយ្យុំ** បើសត្វទាំងឡាយដឹងផលនៃការឲ្យទានយ៉ាងនោះ ដូច្នេះ អធិប្បាយថា ដូចព្រះមានព្រះភាគត្រាស់ហើយ ដោយព្រះញាណ គឺទ្រង់ជ្រាបដោយចិត្ត បទថា **វិបាកំ សំវិភាគស្ស** បានដល់ ផលនៃការចែករំលែក ។ នឹងពោលដល់ទានដូចម្តេច ។ បទថា **យថា ហោតិ មហប្ផលំ** គួរបង់ជាអត្ថថា បើសត្វទាំងឡាយនេះគប្បីដឹងដោយវិធីដែលផលនោះ ជាផលធំសោត ។ បទថា **វិនេយ្យ មច្ឆេរមលំ** សេចក្តីថា សត្វទាំងឡាយគប្បីកម្ចាត់សេចក្តីកំណាញ់ដែលជាមន្ទិល មានចិត្តផូរផង់ដោយចំពោះយ៉ាងក្រៃលែង ដោយការជឿផលនៃកម្ម និងដោយការជឿព្រះរតនត្រ័យ គប្បីឲ្យទានដែលឲ្យហើយតិចតួច ក៏មានផលច្រើនក្នុងអរិយបុគ្គល ដែលសម្បូរដោយគុណ មានសីលជាដើម

ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយតាមកាលដ៏គួរ ។ លោកអ្នកដែលគួរដល់ទក្ខិណាទាន ព្រោះធ្វើឲ្យមានផលច្រើន ឈ្មោះថា ទក្ខិណេយ្យបុគ្គល គឺជាអ្នកបដិបត្តិប្រពៃ ។ ឲ្យទក្ខិណា គឺទេយ្យធម៌ដែលអ្នកឲ្យ ជឿលោកខាងមុខ ក្នុងទក្ខិណេយ្យបុគ្គលទាំងនោះ ដោយទាននោះជាទានធំ ។ម្យ៉ាងទៀត សួរថា គួរឲ្យទានដូចម្តេច ឆ្លើយថា គួរឲ្យទក្ខិណាទានក្នុងទក្ខិណេយ្យបុគ្គល ម្យ៉ាងទៀត បុគ្គលអ្នកឲ្យចុតិអំពីមនុស្សនេះហើយ រមែងទៅកាន់ស្ថានសួគ៌ ដោយបដិសន្ធិ ។ បទថា **កាមកាមិនោ** សេចក្តីថា ទាយកអ្នកប្រាថ្នាកាម គឺមានការព្រមក្នុងកាមគ្រប់យ៉ាង ព្រោះជាអ្នកធ្វើសេចក្តីល្អ ដោយបានទទួលកម្មដែលជាសម្បត្តិនៃទេវសម្បត្តិដ៏ឧឡារ គឺគួរប្រាថ្នា រមែងត្រេកអរ គឺបានទទួលការបម្រើតាមគាប់ចិត្ត ។៚

**អដ្ឋកថា ទានសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## មេត្តាភាវនាសូត្រ

[ ២៧ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលឯណានីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលបុគ្គលចែកឲ្យជាចំណែក

១៦ៗ ជនឡើយ មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ។ ម្នាលភិក្ខុទាំងឡាយ ដូចពន្លឺពួកផ្កាយឯណានីមួយ ពន្លឺពួកផ្កាយទាំងអស់នោះ មិនដល់មួយចំណិតពន្លឺព្រះចន្ទ្រ ដែលបុគ្គលចែកជាចំណែក ១៦ៗ ជនឡើយ ពន្លឺព្រះចន្ទ្រ តែងគ្របសង្កត់ពន្លឺផ្កាយទាំងអម្បាលនោះ ភ្លឺស្វាងរុងរឿង ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលឯណានីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិត នៃមេត្តាចេតោវិមុត្តិ ដែលចែកឲ្យជាចំណែក ១៦ៗ ជន មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ក៏ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចមេឃដែលស្រឡះ ប្រាសចាកពពក ក្នុងសរទសម័យ ក្នុងខែជាខាងចុងនៃរដូវភ្លៀង ព្រះអាទិត្យ ក៏រះត្រដួចត្រដឹមក្នុងពពក កម្ចាត់បង់ងងឹតពួងដ៏អាកាសទាំងអស់ ភ្លឺស្វាងរុងរឿង ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលឯណានីមួយ បុញ្ញកិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិត នៃមេត្តាចេតោវិមុត្តិ ដែលបុគ្គលចែកឲ្យជាចំណែក ១៦ៗ ជនឡើយ មេត្តាចេតោវិមុត្តិ តែងគ្របសង្កត់បុញ្ញកិរិយាវត្ថុទាំងនោះ ភ្លឺស្វាងរុងរឿង ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចផ្កាយព្រឹក ភ្លឺស្វាងរុងរឿងក្នុងបច្ចូសសម័យនៃរាត្រី ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុទាំងឡាយ ដែលឲ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលឯណានីមួយ បុញ្ញ-កិរិយាវត្ថុទាំងអស់នោះ មិនដល់មួយចំណិតនៃមេត្តាចេតោវិមុត្តិ ដែលចែកឲ្យ

ជាចំណែក ១៦ៗ ជងឡើយ មេត្តាចេតោវិមុត្តិតែងគ្របសង្កត់បុញ្ញកិរិយាវត្ថុ ទាំងនោះ ភ្លឺស្វាងរុងរឿង ដូច្នោះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា មានស្មារតី ចម្រើនមេត្តា មិនមានប្រមាណ
បដិយសំយោជនៈទាំងឡាយ របស់បុគ្គលនោះ អ្នក
ឃើញកិរិយាអស់ទៅនៃកិលេស រមែងស្តួចស្តើង បើ
បុគ្គលមានចិត្តមិនប្រទូស្តសត្វ សូម្បីតែសត្វមួយ ចម្រើន
មេត្តា ជាបុគ្គលឈ្លាសវៃ ដោយមេត្តានោះ មួយទៀត
ព្រះអរិយៈ កាលអនុគ្រោះសត្វទាំងអស់ ដោយចិត្ត
ហើយ ឈ្មោះថា ធ្វើបុណ្យច្រើន ជនទាំងឡាយណា
ឈ្នះផែនដីដ៏ដេរដាសទៅដោយសត្វ ជនទាំងឡាយនោះ
ជាធម្មិករាជ ប្រហែលដោយឥសី ហើយញុំាងការបូជា
ឲ្យប្រព្រឹត្តទៅ ( គឺទ្រង់ឈ្លាសវៃ ក្នុងការទំនុកបម្រុង
ធញ្ញាហារ គឺស្រែស្រូវ ឲ្យសម្បូណ៌ក្នុងព្រះរាជអាណា-
ចក្រ ១ ទ្រង់ឈ្លាសវៃក្នុងការសង្គ្រោះរាជបុរស ១ ទ្រង់
ប្រកបឧបាយចងចិត្តមនុស្ស ឲ្យបូលចិត្ត ១ ទ្រង់មាន
ព្រះបន្ទូលផ្អែមល្ហែម ១ ជាហេតុឲ្យស្រុកទេសរាបទាប
សាន្តត្រាណគ្មានចោរ ទាល់តែមិនបាច់ដាក់គន្លឹះ ចាក់
សោទ្វារផ្ទះ ១ ) ការបូជាទាំងឡាយនោះ មិនដល់

មួយចំណិត នៃបុគ្គលអ្នកចម្រើនមេត្តាចិត្ត ដែលចែក
ឲ្យជាចំណែក ១៦ៗ ដងឡើយ ( ដូចពួកផ្កាយទាំង
អស់ មិនដល់មួយចំណិតនៃពន្លឺព្រះចន្ទ្រ ) បុគ្គលណា
មិនសម្លាប់សត្វដោយខ្លួនឯង មិនប្រើគេឲ្យសម្លាប់ មិន
ផ្ចាញ់ផ្ចាល ដោយខ្លួនឯង មិនប្រើគេឲ្យផ្ចាញ់ផ្ចាល ជា
អ្នកមានចំណែកនៃមេត្តា ក្នុងសត្វទាំងឡាយទាំងពួង
ពៀរមិនមាន ដល់បុគ្គលនោះ ដោយហេតុណានីមួយ
ឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

**តតិយវគ្គ ចប់**

## ឧទ្ទាននៃតតិយវគ្គនោះ គឺ

និយាយអំពីចិត្ត ១ ចម្រើនឈាន ១ ប្រយោជន៍ទាំងពីរ
១ គំនរឆ្អឹងដូចជាភ្នំវេបុល្ល ១ សម្បជានមុសាវាទ ១
ទាន ១ ការចម្រើនមេត្តា ១ ព្រះសូត្រទាំងឡាយក្នុង
ធម៌មួយៗ គឺព្រះសូត្រ ( ខាងចុង ) ៧ សូត្រ ព្រះសូត្រ
ខាងដើម ២០ សូត្រ សង្រ្គោះជាសូត្រ ២៧ សូត្រ ។

**ឯកនិបាត ចប់**

# អដ្ឋកថា

## មេត្តាភាវនាសូត្រ

ក្នុងមេត្តាភាវនាសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ២៧ ] បទថា **យានិ កានិចិ** បានដល់ បុញ្ញកិរិយាវត្ថុមិនមានសេសសល់ ។ បទថា **ឱបធិកានិ បុញ្ញកិរិយាវត្ថូនិ** ជាពាក្យកំណត់ដល់បុញ្ញកិរិយាវត្ថុទាំងនោះ ។ ខន្ធទាំងឡាយលោកហៅថា ឧបធិ ក្នុងបទនោះ ។ សីលជាហេតុនៃឧបធិ ឬការខ្វល់ខ្វាយដែលជាឧបធិរបស់ខន្ធទាំងនោះ ឈ្មោះថា **ឱបធិ** គឺមានឧបធិសម្បត្តិជាហេតុ ធ្វើឲ្យកើតក្នុងអត្តភាពក្នុងសម្បត្តិភព គឺឲ្យផលដែលប្រព្រឹត្តទៅក្នុងបដិសន្ធិ ។ បទថា **បុញ្ញកិរិយាវត្ថូនិ** គឺឈ្មោះថា បុញ្ញកិរិយាវត្ថុ ព្រោះជាបុញ្ញកិរិយា និងជាវត្ថុនៃផលានិសង្សនោះ ។ បុញ្ញកិរិយាវត្ថុទាំងនោះ ដោយសង្ខេបមាន ៣ យ៉ាង គឺ **ទានមយ** បុណ្យសម្រេចដោយការឲ្យ ១ **សីលមយ** បុណ្យសម្រេចដោយការរក្សាសីល ១ **ភាវនាមយ** បុណ្យសម្រេចដោយការភាវនា ១ ។ ក្នុងបុញ្ញកិរិយាវត្ថុ ៣ យ៉ាងនោះ បទដែលគួរពោល នឹងមានច្បាស់ក្នុងអដ្ឋកថាតិកនិបាតតទៅ ។

បទថា **មេត្តាយ ចេតោវិមុត្តិយា** បានដល់ ការចូលឈានពួក ៣ និងឈានពួក ៤ ដែលបានដោយមេត្តាភាវនា កាលពោលថា មេត្តា រមែងសំដៅទាំងឧបចារៈ ទាំងអប្បនា ។ តែបើពោលថា ចេតោវិមុត្តិ រមែងសំដៅដល់អប្បនាឈានតែម្យ៉ាងប៉ុណ្ណោះ អប្បនាឈាននោះ លោកហៅថា ចេតោវិមុត្តិ ព្រោះចិត្តផុតដោយល្អចាកធម៌ដែលជាសត្រូវ មាននីវរណៈជាដើម ។ បទថា

**កលំ នាគ្ឃន្តិ សោឡសឹ** បានដល់ បុញ្ញកិរិយាវត្ថុ មានឧបធិជាហេតុ រមែងមិនដល់ចម្រៀកទី ១៦ នៃមេត្តាវិហារធម៌ សេចក្តីនេះ លោកអធិប្បាយថា ការធ្វើផលនៃមេត្តាចេតោវិមុត្តិឲ្យជា ១៦ គឺឲ្យជា ១៦ ចំណែក ហើយធ្វើចំណែក ១ អំពីចំណែក ១៦ នោះ ឲ្យជា ១៦ ចំណែកទៀត បុញ្ញ-កិរិយាវត្ថុ មានឧបធិសម្បត្តិជាហេតុដទៃ គង់មិនដល់ ១ ចំណែក ក្នុងចំណែកទី ១៦ នោះ ។

បទថា **អធិគ្គហេត្វា** គឺគ្របសង្កត់ហើយ ។ បទថា **ភាសតេ** គឺតែងភ្លឺស្រឡះ ព្រោះបរិសុទ្ធចាកគ្រឿងសៅហ្មង ។ បទថា **តបតេ** បានដល់ ដុតធម៌ដែលជាបដិបក្ខ មិនឲ្យសេសសល់ទៀតឡើយ ។ បទថា **វិរោចតេ** បានដល់ រមែងរុងរឿងដោយសម្បត្តិទាំង ២ ។ ពិតហើយ មេត្តាចេតោវិមុត្តិ រមែងភ្លឺស្វាង ដូចការផូរផង់ដែលប្រាសចាកសេចក្តីសៅហ្មង បានដល់ ការភ្លឺរបស់ព្រះចន្ទ រមែងកម្ចាត់ គឺដុតធម៌ដែលជាសត្រូវ ដូចពន្លឺកម្ចាត់ងងឹត រមែងភ្លឺរុងរឿង ដូចផ្កាយព្រឹក ដូច្នេះ ។

បទថា **សេយ្យថាបិ** ជានិបាតចុះក្នុងអត្ថ សម្តែងសេចក្តីប្រៀបធៀប ។ បទថា **តារករូបានំ** បានដល់ សេចក្តីរុងរឿង ។ បទថា **ចន្ទិយា** បានដល់ ឈ្មោះថា **ចន្ទី** ព្រោះអត្ថថា មានរស្មី អធិប្បាយថា នៃរស្មី គឺនៃពន្លឺរបស់ព្រះចន្ទ្រនោះ បទថា **វស្សានំ** បានដល់ រដូវ ដែលបានឈ្មោះថា ជាពហុវចនៈថា **វស្សានិ** ដូច្នេះ ។ បទថា **បច្ឆិមេ មាសេ** បានដល់ ក្នុងខែកត្តិក ។ បទថា **សរទសមយេ** បានដល់ ក្នុងសរទកាល គឺរដូវស្លឹកឈើ

ជ្រុះ ។ ខែអស្សុជ និងខែកត្តិក លោកហៅថា សារទវដូវក្នុងលោក ។ បទថា **វិទ្ធេ** បានដល់ អណ្ដែតឡើង អធិប្បាយថា អណ្ដែតទៅដោយប្រាសចាក ពពក ដូចលោកពោលថា **វិគតវលាហកេ** គឺប្រាសចាកភ្លៀង ។ បទថា **ទេវេ** បានដល់ ក្នុងអាកាស ។ បទថា **នភំ អព្ភុស្សក្កមានោ** បានដល់ អណ្ដែតកាន់អាកាស អំពីទីដែលរះ ។ បទថា **តមគតំ** បានដល់ អាកាស ងងឹត ។ បទថា **អភិហច្ច** បានដល់ ទម្លាយ គឺកម្ចាត់ ។ បទថា **ឱសធិ-តារកា** បានដល់ ផ្កាយណា ឈ្មោះថា **ឱសធិ** ព្រោះជាហេតុឲ្យមានរស្មី ច្រើនឡើង ឬព្រោះផ្កាយព្រឹក បន្ថែមឲ្យមានកម្លាំងច្រើនឡើង ។

ក្នុងបទនេះ លោកពោលថា ព្រោះហេតុអ្វី កាលនៅមានអាសវៈ ទើប ព្រះមានព្រះភាគត្រាស់ថា មេត្តាវិសេសជាងបុណ្យ មានឧបធិសម្បត្តិក្រៅពី នេះទៅវិញ លោកឆ្លើយថា ព្រោះបដិបត្តិប្រពៃក្នុងសត្វទាំងឡាយ ដោយការ ប្រព្រឹត្តប្រសើរបំផុត និងការមិនមានទោស ។ វិហារធម៌ទាំងឡាយនេះ ជា ធម៌ប្រសើរបំផុត ជាសម្មាបដិបត្តិក្នុងសត្វទាំងពួង គឺមេត្តាឈាន ។ ពួក ព្រហ្មមានចិត្តមិនប្រទូស្ត យ៉ាងណា ព្រះយោគីទាំងឡាយដែលប្រកបដោយ វិហារធម៌ទាំងនោះ ក៏ប្រៀបស្មើដោយគុណ ដូច្នោះ ជាការពិត ដូចលោក ពោលថា **មេត្តាព្រហ្មវិហារា** មេត្តាជាព្រហ្មវិហារធម៌ ។ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគត្រាស់មេត្តាថា វិសេសជាងបុណ្យ មានឧបធិសម្បត្តិ ក្រៅអំពីនេះ ព្រោះជាបដិបត្តិប្រពៃក្នុងសត្វទាំងឡាយ ដោយការប្រសើរបំផុត និងដោយការមិនមានទោស ។ សួរថា បើដូច្នេះ ព្រោះហេតុអ្វី ទើបព្រះមាន

ព្រះភាគត្រាស់មេត្តាប៉ុណ្ណោះថា វិសេសដល់ម៉េ្វះ ឆ្លើយថា ព្រោះមេត្តាជាទីតាំងរបស់ព្រហ្មវិហារធម៌ក្រៅអំពីនេះ និងព្រោះកល្យាណធម៌ទាំងអស់ មានទានជាដើមគ្រប់បរិបូណ៌ ។ មេត្តានេះ មានការប្រព្រឹត្ត អាចារដែលជាប្រយោជន៍ក្នុងសត្វទាំងឡាយជាលក្ខណៈ មានការប្រមូលនូវប្រយោជន៍ជារស មានការដកនូវអាឃាតជាគ្រឿងប្រាកដ មានមេត្តាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ដោយមិនវៀរ កាលបើដូច្នោះ ភាវនា មានករុណាជាដើម រមែងសម្រេចបានដោយងាយ ព្រោះហេតុនោះ ទើបមេត្តាជាទីតាំងនៃព្រហ្មវិហារក្រៅអំពីនេះ ។ ពិតហើយ កាលមានអធ្យាស្រ័យឧបការៈក្នុងសត្វទាំងឡាយ ភាពជាបុគ្គលនាំសត្វឲ្យចេញទៅចាកទុក្ខ ភាពជាបុគ្គលប្រាថ្នានឹងឲ្យសម្បត្តិវិសេសតាំងនៅបានយូរ រមែងសម្រេចបានដោយងាយ ព្រោះមិនមានការសម្ងាប់ ម្យ៉ាងទៀត ព្រោះមានចិត្តប្រព្រឹត្តទៅស្មើក្នុងទីទាំងពួងដោយហេតុយ៉ាងនេះ ព្រះពោធិសត្វទាំងឡាយ ជាអ្នកបង្អោនទៅក្នុងការចែករំលែកសុខ ដែលជាប្រយោជន៍ដល់លោកទាំងមូល មិនធ្វើការចែករំលែកដោយការជ្រើសរើសថា គួរឲ្យដល់បុគ្គលនោះ មិនគួរឲ្យដល់បុគ្គលនោះ ដូច្នេះហើយ ឲ្យទានដែលជាហេតុដល់នូវសេចក្តីសុខដល់សព្វសត្វ ដែលមិនរើសមុខ សមាទានសីលដើម្បីជាប្រយោជន៍ដល់សព្វសត្វ បំពេញនេក្ខម្មៈដើម្បីឲ្យសីលបរិបូណ៌ បំពេញបញ្ញាឲ្យបរិសុទ្ធ ដើម្បីការមិនវង្វេងក្នុងប្រយោជន៍សុខរបស់សព្វសត្វ ប្រារព្ធសេចក្តីព្យាយាមមាំ ដើម្បីជាប្រយោជន៍និងសេចក្តីសុខក្រៃលែង សម្រេចនូវភាពជាបុគ្គលក្លៀវក្លា ដោយការព្យាយាម

ដ៏ឧត្តម អត់នូវទោសដែលជាអជ្ឈាស្រ័យ ដែលជាប្រយោជន៍ច្រើនប្រការ ដល់សព្វសត្វ មិនខុសពាក្យពោលដែលបានប្តេជ្ញា ដោយពាក្យជាដើមថា ខ្ញុំនឹងឲ្យ នឹងធ្វើវត្ថុនេះដល់អ្នក ជាអ្នកតាំងចិត្តពិត ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់សព្វសត្វ ដែលជាអ្នកផ្សាយមេត្តា មិនអណ្តែតក្នុងសព្វសត្វ ជាអ្នកឲ្យអភ័យក្នុងកំហុសខុសឆ្គងរបស់សព្វសត្វ ដោយអជ្ឈាស្រ័យអនុគ្រោះ ព្រោះបានធ្វើឧបការៈមុន ក៏មិនទទួលផលតបស្នង ។ ព្រះមហាសត្វទាំងឡាយ បំពេញបារមីហើយ ញុំាងកល្យាណធម៌ទាំងអស់ ដែលជាប្រភេទនៃពុទ្ធធម៌ ១៨ ពួក រហូតដល់ទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ និងអសាធារណញ្ញាណ ៦ ឲ្យបរិបូណ៌ ។ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគត្រាស់មេត្តានោះ ឲ្យវិសេសជាងបុណ្យ មានឧបធិសម្បត្តិក្រៅអំពីនេះ ដើម្បីទ្រង់សម្តែងដល់ការវិសេសនោះថា មេត្តាបរិបូណ៌ជាងកល្យាណ-ធម៌ទាំងអស់ មានទានជាដើម ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់សម្តែងភាពដែលមេត្តា មានអានុភាពច្រើនជាងបុណ្យ មានឧបធិសម្បត្តិក្រៅអំពីនេះដោយវេលាមសូត្រ ។ ក្នុងសូត្រនោះ លោកពោលថា ការថ្វាយទានដល់ព្រះសោតាបន្នមួយអង្គ មានផលច្រើនជាងមហាទានរបស់វេលាមព្រាហ្មណ៍ យ៉ាងណា ការថ្វាយទានដល់ព្រះអនាគាមីមួយអង្គ មានផលច្រើនជាងព្រះសោតាបន្ន ១០០ ។បេ។ ការថ្វាយទានដល់ព្រះមានព្រះភាគ មានផលច្រើនជាងព្រះបច្ចេកពុទ្ធរាប់រយអង្គ ការថ្វាយទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន មានផលច្រើនជាងព្រះ

មានព្រះភាគនោះ ការឲ្យវិហារដល់សង្ឃដែលមកអំពីទិសទាំង ៤ មានផលច្រើនជាងទានរបស់ព្រះសង្ឃដែលមានព្រះពុទ្ធជាប្រធាននោះទៀត ការទទួលសរណគមន៍ មានផលច្រើនជាងការឲ្យវិហារដល់ព្រះសង្ឃនោះទៀត ការសមាទានសីលមានផលច្រើនជាងការទទួលសរណគមន៍ទៀត ការចម្រើនមេត្តាសូម្បីត្រឹមមួយរយៈ ដែលរឹតទឹកដោះគោស្រស់ ព្រះមានព្រះភាគក៏ត្រាស់ថា មានផលច្រើនជាងការសមាទានសីលនោះ ដូច្នោះ ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលគហបតី វេលាមព្រាហ្មណ៍បានឲ្យទានណា ដែលឈ្មោះថាមហាទាន និងបុគ្គលណា ញ៉ាំងបុគ្គលដែលមានទិដ្ឋិល្អ មួយរូប ( សោតាបន្នបុគ្គល ) ឲ្យបរិភោគទាននេះ ជាទានមានផលច្រើនជាងមហាទាន បុគ្គលណា ញ៉ាំងបុគ្គលដែលមានទិដ្ឋិល្អ ១០០ រូបឲ្យបរិភោគ ។បេ។ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទដោយការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដោយហោចទៅនិងបុគ្គលណា ចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរឹតទឹកដោះគោប៉ុណ្ណោះ និងបុគ្គលណា ចម្រើននូវអនិច្ចសញ្ញាសូម្បីអស់កាលគ្រាន់តែផ្ទាត់ម្រាមដៃប៉ុណ្ណោះ ការចម្រើននេះ មានផលច្រើនជាងទាននោះទៅទៀត ដូច្នេះ ។

តែមិនគួរពោលដល់មេត្តានោះល្អជាងបុណ្យបន្តិចបន្តួច ព្រោះភាពជាបុណ្យប្រកបដោយមហគ្គតកម្ម សមដូចដែលលោកពោលក្នុងសំយុត្តនិកាយ

សទ្ធាយតនវគ្គថា

កាមាវចរកម្មឯណា ដែលបុគ្គលធ្វើត្រូវប្រមាណ កម្មនោះមិនក្រាញនៅតែត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះ មិនស្ថិតនៅតែ ត្រឹមរូបារូបាវចរកម្មប៉ុណ្ណោះទេ ក៏យ៉ាងនោះដែរ ដូច្នេះ ។

កាមាវចរកម្ម ឈ្មោះថា ធ្វើល្មមប្រមាណ ។ តែមហគ្គតកម្ម ឈ្មោះថា ធ្វើមិនល្មមប្រមាណ ព្រោះផុតប្រមាណហើយ ធ្វើ ចម្រើន ដោយការផ្សាយទៅ ដោយចំពោះ និងមិនចំពោះ ។ កាមាវចរកម្មមិនអាចទាញជាប់ក្នុងរវាងមហគ្គតកម្ម ឬគ្របសង្កត់កម្មនោះ ហើយកាន់យកឱកាសនៃផលរបស់ខ្លួន តាំងនៅបានឡើយ តែមហគ្គតកម្មនោះឯងតែងគ្របសង្កត់បរិត្តកម្មនោះ ដូចជំនន់ទឹកធំគ្របសង្កត់ជំនន់ទឹកតូច ហើយកាន់យកឱកាសរបស់ខ្លួន តាំងនៅ ហាមនូវផលនៃកម្មនោះហើយ នាំចូលទៅកាន់ភាពជាសម្លាញ់របស់ព្រហ្មដោយខ្លួនឯង ដោយហេតុនោះ ទើបសេចក្តីនេះ ជាអធិប្បាយរបស់មហគ្គតកម្មនោះ ។ ក្នុងគាថាទាំងឡាយ គប្បីជ្រាបសេចក្តីដូចតទៅនេះ បទថា **យោ** បានដល់ គ្រហស្ថ ឬបព្វជិតណាមួយ ។ បទថា **មេត្តំ** បានដល់ មេត្តាឈាន ។ បទថា **អប្បមាណំ** បានដល់ មិនមានប្រមាណដោយអំណាចភាវនា និងអារម្មណ៍ ពិតហើយ មេត្តាមានប្រមាណដោយមិនធ្វើការប្រកាន់ជាចំណែកមួយក្នុងអារម្មណ៍ ដូចអសុភភាវនាជាដើមឡើយ ដោយផ្សាយទៅមិនចំពោះ និងដោយការចម្រើនដោយស្ទាត់ជំនាញ ព្រោះមិនមានប្រមាណជាអារម្មណ៍ ។

បទថា **តន្ទ្វ សំយោជនា ហោន្តិ** សេចក្តីថា សំយោជនៈ មានបដិឃ-សំយោជនៈជាដើម ដែលអ្នកពិចារណាធ្វើនូវមេត្តាឈានឲ្យជាបាទ ហើយសម្រេចអរិយមគ្គថ្នាក់ទាប លះបានដោយងាយនោះឯង រមែងជាធម្មជាតស្រាលស្តើង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បស្សតោ ឧបធិក្ខយំ** របស់អ្នកពិចារណាឃើញធម៌ ដែលជាទីអស់ទៅនៃឧបធិ ។ ពិតហើយ និព្វាន លោកហៅថា ការអស់ទៅនៃឧបធិ ព្រះយោគាវចរ រមែងឃើញនិព្វាននោះ ដោយមគ្គញ្ញាណ ដោយសម្រេចការធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលជាទីអស់ទៅនៃឧបធិនោះ ។ ម្យ៉ាងទៀត បទថា **តន្ទ្វ សំយោជនា ហោន្តិ** សេចក្តីថា នឹងពោលទៅថ្វីដល់សំយោជនៈ ១០ ប្រការរបស់បុគ្គលពិចារណាឃើញធម៌ដែលជាទីអស់ទៅនៃឧបធិនោះ ព្រោះវិបស្សនាដែលមានមេត្តាឈានជាបទដ្ឋាន ដែលខ្ជួនសម្រេចអរហត្ត ពោល គឺការអស់ទៅនៃឧបធិដោយលំដាប់ រមែងជាធម្មជាតស្រាល អធិប្បាយថា រមែងលះបាន ។

ម្យ៉ាងទៀត បទថា **តន្ទ្វ សំយោជនា ហោន្តិ** សេចក្តីថា បដិឃៈ និងសំយោជនៈដែលសម្បយុត្តដោយបដិឃៈ រមែងជាធម្មជាតស្រាលស្តើង ។ បទថា **បស្សតោ ឧបធិក្ខយំ** គប្បីឃើញសេចក្តីក្នុងបទនេះយ៉ាងនេះថា នៃបុគ្គលដែលពិចារណាឃើញមេត្តា ដែលជាទីអស់ទៅនៃឧបក្កិលេសនៃសំយោជនៈទាំងនោះឯង ដោយការសម្រេច ដោយប្រការដូច្នេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអានិសង្សនៃការសម្រេចដ៏កំពូលនៃមេត្តាភាវនា ដែលលះកិលេសនិងការសម្រេចដល់ព្រះនិព្វានហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់

អានិសង្សដទៃ ទើបត្រាស់ពាក្យជាដើមថា **ឯកម្បិ ចេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អទុដ្ឋចិត្តោ** បានដល់ ចិត្តដែលមិនប្រទូស្ត ដោយសេចក្តីព្យាបាទ ព្រោះសង្កត់សេចក្តីព្យាបាទបានដោយល្អ ដោយកម្លាំងមេត្តា ។ បទថា **មេត្តាយតិ** បានដល់ ធ្វើមេត្តាដោយការផ្សាយប្រយោជន៍ឲ្យ ។ បទថា **កុសលោ** បានដល់ ជាបុគ្គលមានកុសល គឺមានបុណ្យច្រើន ព្រោះសេចក្តីល្អក្រៃលែង ឬជាបុគ្គលមានសេចក្តីក្សេម ព្រោះប្រាសចាកនូវសេចក្តីវិនាស មានបដិឃៈជាដើម ។ បទថា **តេន** បានដល់ ព្រោះការចម្រើនមេត្តានោះ ។ ច សព្វ ក្នុងបទថា **សព្វេ ច បាណេ** ជានិបាត ចុះក្នុងព្យតិរេក ( ការប្រជែងគ្នា ) ។ បទថា **មនសានុកម្បំ** បានដល់ មានចិត្តអនុគ្រោះ លោកអធិប្បាយសេចក្តីនោះថា មេត្តាជាវិស័យនៃសត្វមួយក៏ដោយ តែគំនរមហាកុសល ព្រះអរិយបុគ្គលមានចិត្តបរិសុទ្ធ មានចិត្តអនុគ្រោះសត្វទាំងពួង ដោយការផ្សាយប្រយោជន៍ ដូចកូនដែលជាទីស្រឡាញ់របស់ខ្លួន រមែងធ្វើ គឺផលិតនូវបុណ្យដ៏ធំក្រៃលែង អាចបង្វិបាករបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុង ៦៤ មហាកប្បបាន ។ បទថា **សត្តសណ្ឌំ** បានដល់ ពេញទៅដោយពួកសត្វ គឺមិនវៀរចាកសត្វទាំងឡាយ អធិប្បាយថា ដេរដាសដោយពួកមនុស្ស ។ បទថា **វិជិត្វា** បានដល់ ទ្រង់ឈ្នះដោយធម៌តែម្យ៉ាង មិនមែនដោយដំបង និងសស្ត្រា ។ បទថា **រាជីសយោ** បានដល់ ព្រះរាជាទ្រទ្រង់នូវធម៌ ដូចជាឥសីទាំងឡាយ ។ បទថា **យជមានា** បានដល់ ឲ្យទានជាដើម ។ បទថា **អនុបរិយគា** បានដល់ ទ្រង់យាងទៅ ។

ក្នុងបទថា **អស្សមេធំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បានឮថា សង្គហវត្ថុ ៤ គឺ **សស្សមេធ បុរិសមេធ សម្មាបាស វាចាបេយ្យ** មានមកក្នុងរជ្ជកាលមុនៗ ការយកចំណែកទី ១០ អំពីស្រូវដែលសម្រេចហើយក្នុងចំណែកដែលព្រះរាជាទ្រង់សង្គ្រោះសត្វលោក ឈ្មោះថា **សស្សមេធ** គឺទ្រង់ឈ្លាសក្នុងការទំនុកបម្រុងស្រូវ ៗ ការបន្ថែមអាហារ និងថ្លៃឈ្នួលដល់ទាហានរៀងរាល់ ៦ ខែ ឈ្មោះថា **បុរិសមេធ** គឺទ្រង់ឈ្លាសក្នុងការសង្គ្រោះមនុស្ស ៗ ការទទួលសញ្ញាបំណុលក្នុងដៃរបស់អ្នកក្រ រៀរតែបៀវត្សរ៍ ៣ ឆ្នាំ ហើយបន្ថែមទ្រព្យប្រមាណ ១០០០-២០០០ ដើម្បីជាកម្រៃ ឈ្មោះថា **សម្មាបាស** គឺទាក់មនុស្សដោយប្រពៃ ដូចប្រដាប់ចងទុកក្នុងហទយៈ ព្រោះដូច្នោះ ទើបលោកពោលថា **សម្មាបាស** សង្គ្រោះដោយវាចាទន់ភ្លន់ ដូចជាហៅថា ពុក អ៊ុំជាដើម ឈ្មោះថា **វាចាបេយ្យ** គឺពោលពាក្យផ្អែមគួរស្រឡាញ់ រៀរដែនដែលព្រះរាជាទ្រង់សង្គ្រោះដោយសង្គហវត្ថុ ៤ យ៉ាងនេះ រមែងជាដែនដែលសម្បូរស្តុកស្តម្ភ មានទឹកបរិបូណ៌ ក្សេមផុតភ័យ ៗ ពួកមនុស្សត្រេកអរ ប្រឡែងគ្នា ច្រៀងរាំជាមួយកូន ផ្ទះក៏មិនបិទទ្វារ នេះហៅថា **និរគ្គឡ** ព្រោះមិនមានគន្លឹះទ្វារផ្ទះ ៗ នេះជាបុរាណបវេណី ៗ តែក្នុងកាលជាក្រោយក្នុងរជ្ជកាលព្រះបាទឱក្កាករាជ ពួកព្រាហ្មណ៍បានប្តូរសង្គហវត្ថុ ៤ នេះ និងសម្បត្តិរបស់ដែននេះចោល ៗ ធ្វើឲ្យមានតម្លៃខ្ពស់ឡើង ហើយនឹងយញ្ញវិធី ៥ ប្រការ មាន **អស្សមេធំ បុរិសមេធំ** ជាដើម សមដូចព្រះមានព្រះភាគត្រាស់ក្នុងព្រាហ្មណធម្មិយសូត្រថា

**តេសំ អាសិ វិបល្លាសោ ទិស្វាន អណុតោ អណុំ**

**។បេ។**

**តេ តត្ថ មន្តេ គន្ថេត្វា ឱក្កាកំ តទុបាគមុំ ។**

*ព្រាហ្មណ៍ទាំងនោះ មានសេចក្តីវិបល្លាស ព្រោះឃើញ កាមសុខមានប្រមាណតិច ដែលកើតអំពីកាមគុណ មាន ប្រមាណតិចផង*

*។បេ។*

*ព្រាហ្មណ៍ទាំងនោះតែងមន្ត ព្រោះចង់បានទ្រព្យទាំងនោះ បានចូលទៅរកព្រះបាទឱក្កាកៈ ក្នុងវេលានោះ ។*

*ក្នុងយញ្ញទាំងនោះ យញ្ញឈ្មោះ* **អស្សមេធ** *ព្រោះជាទីសម្លាប់សេះ ។ អស្សមេធនេះជាឈ្មោះរបស់យញ្ញដែលជាផល ដែលឲ្យបានសម្បត្តិដ៏សេស ទាំងពួង វៀរផែនដី និងមនុស្ស ជាយញ្ញវិធីដែលគួរខ្លាច ព្រោះចាំបាច់ត្រូវ សម្លាប់សត្វចិញ្ចឹមមួយមុខ ៥០០ អស់វារៈ ៧-៩ ដង ក្នុងថ្ងៃមួយចុង ក្រោយ ត្រង់សសរបូជាយញ្ញ ២០ ត្រូវបូជាដោយការបូជាយញ្ញ ២ យ៉ាង ។ បទនេះជាឈ្មោះរបស់យញ្ញដែលជាផល ឲ្យបានទូវសម្បត្តិ ដូចបានពោល ហើយក្នុងអស្សមេធ ដែលនឹងត្រូវបូជាដោយការបូជាយញ្ញ ៤ យ៉ាងជាមួយ នឹងផែនដី ។ យញ្ញឈ្មោះថា* **សម្មាបាស** *ព្រោះជាគន្លង គឺបន្សាត់ទៅនូវ គន្ធឹះនឹមទន្តល បទនេះជាឈ្មោះនៃការបូជាយញ្ញ ដែលគេស៊កគន្លឹះនឹមទន្តល គឺកំណាត់ឈើចូលទៅក្នុងប្រហោងនឹម ហើយធ្វើរានទទួលក្នុងឱកាសដែល*

នឹមនោះធ្លាក់ទៅ ហើយវិលត្រឡប់ ចាប់ពីឱកាសត្រង់សសរបូជាយញ្ញ ដែលជាការឃ្លាតទី បានលិចចុះទៅក្នុងស្ទឹងសល្លវតី ធ្វើការបូជាយញ្ញ យញ្ញឈ្មោះថា **វាជបេយ្យ** ព្រោះជាទីផឹកទឹកសក្តិសិទ្ធិ យញ្ញនេះ ជាឈ្មោះរបស់យញ្ញដែលជាទក្ខិណាមួយមុខ ១៧ៗ សសរយញ្ញ ធ្វើដោយដើមព្នៅ ដែលគួរបូជាដោយសត្វ ១៧ ដោយយញ្ញឯណានីមួយ ។ យញ្ញឈ្មោះថា **និរគ្គឡ** ព្រោះមិនមានរនុកទ្វារ យញ្ញនេះជាឈ្មោះនៃការកំណត់ការសម្លាប់សេះ ដែលជាឈ្មោះ ដោយបរិយាយ ជាទក្ខិណា ឲ្យនូវសម្បត្តិដូចបានពោលហើយក្នុងអស្សមេធ ដែលគួរបូជាដោយយញ្ញ ៩ យ៉ាង និងដោយដី មួយអន្ទើដោយបុរស ។ បទថា **ចន្ទប្បភា** បានដល់ រស្មីព្រះចន្ទ ។ បទថា **តារគណាវ សព្វេ** សេចក្តីថា ពួកផ្កាយទាំងអស់ រមែងមិនដល់ចម្រៀកទី ១៦ នៃរស្មីព្រះចន្ទ យ៉ាងណា យញ្ញទាំងឡាយ មានអស្សមេធទាំងនោះជាដើម រមែងមិនដល់ចម្រៀកទី ១៦ នៃមេត្តាចិត្ត ដែលបានពោលហើយដោយលក្ខណៈដែលពោលហើយ ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **យោ ន ហន្តិ** ដូច្នេះ ដើម្បីសម្តែងដល់អានិសង្សនៃមេត្តាភាវនា ដែលជាបច្ចុប្បន្ន និងសម្បរាយ-កពដទៃទៀត ។ ក្នុងបទទាំងនោះ បទថា **យោ** បានដល់ បុគ្គលអ្នកខ្វល់ខ្វាយហើយ ក្នុងការចម្រើនមេត្តាព្រហ្មវិហារ ។ បទថា **ន ហន្តិ** បានដល់ មិនបៀតបៀនសត្វណាមួយ ឬមិនប្រទូស្តដោយដុំដី និងកំណាត់ឈើជាដើម ព្រោះសង្កត់ព្យាបាទដោយល្អ ដោយអានុភាពនៃមេត្តានោះឯង ។ បទថា **ន**

**ឃាតេតិ** *បានដល់ មិនបបួលអ្នកដទៃឲ្យសម្លាប់សត្វ ។ បទថា* **ន ជិនាតិ** *បានដល់ មិនឈ្នះបុគ្គលណាម្នាក់ ដោយការប្រណាំងប្រជែង និងពោលរករឿងឈ្លោះ ឬមិនឈ្នះបុគ្គលណាម្នាក់ ដោយបន្តក្តីជាដើម បំណងនឹងឲ្យកើតសេចក្តីជ្រះថ្លា ព្រោះមិនមានការប្រណាំងប្រជែងនោះឯង ។ បទថា* **ន ជាបយេ** *បានដល់ មិនគប្បីបបួលអ្នកដទៃធ្វើឲ្យអ្នកដទៃសាបសូន្យចាកទ្រព្យ ។ បទថា* **មេត្តំ សោ** *បានដល់ មានចំណែកនៃចិត្តសម្រេចដោយមេត្តា ។ម្យ៉ាងទៀត ឈ្មោះថា* **មេត្តំ សោ** *ព្រោះមានចំណែកនៃមេត្តា គឺមានចំណែកផ្សេងៗ ព្រោះមិនលះដោយពិត ។ បទថា* **សព្វភូតេសុ** *បានដល់ក្នុងសព្វសត្វ ។ បទថា* **វេរន្តស្ស ន កេនចិ** *បានដល់ អកុសល វៀររបស់នោះ រមែងមិនមាន ព្រោះហេតុអ្វី អធិប្បាយថា ការពិរោធដែលបានដល់ពៀរក្នុងបុគ្គល រមែងមិនមានដល់បុគ្គលអ្នកមានវិហារធម៌ គឺមេត្តានោះ និងដោយបុរសណាម្នាក់ឡើយ ។៚*

**អដ្ឋកថាមេត្តភាវនាសូត្រទី ៧ ចប់**

ក្នុងឯកនិបាតនេះ ព្រះមានព្រះភាគត្រាស់ដល់វិវដ្ដៈ ក្នុង ១៥ សូត្រ គឺក្នុង ១៣ សូត្រតាមលំដាប់ និងក្នុងសិក្ខាសូត្រ ២ ត្រាស់វដ្ដៈ និងវិវដ្ដៈ ក្នុង ៤ សូត្រ គឺនីវរណសូត្រ ១ សំយោជនសូត្រ ១ អប្បមាទសូត្រ ១ អដ្ឋិសញ្ចយសូត្រ ១ ( វេបុល្លបព្វតំ ) ។ តែសូត្រក្រៅអំពីនោះ ត្រាស់ដល់វដ្ដៈតែម្យ៉ាង ដោយប្រការដូច្នេះ ៗ។

**អដ្ឋកថា ឥតិវុត្តកឯកនិបាត ចប់**

# សុត្តន្តបិដក

## ឥតិវុត្តក ទុកនិបាត បឋមវគ្គ

### បឋមភិក្ខុសូត្រ

[ ២៨ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ។ ភិក្ខុប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺភាពជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ នេះឯង រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា ក្នុងសាសនានេះ មិនបានគ្រប់គ្រងទ្វារអម្បាល
នេះ គឺចក្ខុ ១ សោតៈ ១ ឃានៈ ១ ជិវ្ហា ១ កាយ ១
មនៈ ១ ជាអ្នកមិនដឹងប្រមាណក្នុងភោជន មិនសង្រួម
ក្នុងឥន្ទ្រិយទាំងឡាយ ភិក្ខុនោះតែងបាននូវសេចក្តីទុក្ខ
គឺទុក្ខក្នុងកាយផង ទុក្ខក្នុងចិត្តផង ភិក្ខុបែបនោះ មាន

កាយក្តៅក្រហាយ មានចិត្តក្តៅក្រហាយ តែងនៅជាទុក្ខទាំងថ្ងៃទាំងយប់ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## បឋមភិក្ខុសូត្រ

[ ២៨ ] ក្នុងបឋមភិក្ខុសូត្រទី ១ នៃទុកនិបាត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **ទ្វីហិ** បានដល់ កំណត់ចំនួន ។ បទថា **ធម្មេហិ** បានដល់ ចង្អុលបង្ហាញនូវចំនួនដែលបានកំណត់ ។ បទថា **ទ្វីហិ ធម្មេហិ** បានដល់ ដោយអកុសលធម៌ ២ ប្រការ ។ បទថា **សមន្នាគតោ** គឺប្រកបហើយ ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា **ទុក្ខំ វិហរតិ** បានដល់ នៅជាទុក្ខក្នុងឥរិយាបថ ៤ ដោយទុក្ខព្រោះកិលេស និងដោយទុក្ខផ្លូវកាយ ផ្លូវចិត្ត ។ បទថា **សវិឃាតំ** បានដល់ មានការក្តៅក្រហាយដោយកិលេស ដែលចូលទៅប្រទូស្តផ្លូវចិត្ត និងកាយ ។ បទថា **សឧបាយាសំ** បានដល់ មានការចង្អៀតចង្អល់ ដោយការចង្អៀតចង្អល់ព្រោះកិលេស ដោយការក្តៅក្រហាយផ្លូវកាយ និងដោយសេចក្តីលំបាកហួសកម្លាំង ។ បទថា **សបរិឡាហំ** បានដល់ មានការក្តៅក្រហាយ ដោយការដុតកម្តៅនៃកិលេស

និងដោយការក្តៅក្រហាយ ព្រោះកិលេស និងដោយការក្តៅក្រហាយផ្លូវតាមកាយ ។ បទថា **កាយស្ស ភេទា** បានដល់ លះនូវខន្ធដែលមានវិញ្ញាណ ។ បទថា **បរម្មរណា** បានដល់ ក្នុងការប្រកាន់ខន្ធដែលកើតហើយក្នុងរវាងនោះ ។ ម្យ៉ាងទៀត បទថា **កាយស្ស ភេទា** បានដល់ ព្រោះកាត់នូវជីវិតិន្ទ្រិយ ។ បទថា **បរម្មរណា** បានដល់ ក្រោយអំពីចុតិ ។ បទថា **ទុគ្គតិ ចាដិកង្ខា** បានដល់ គប្បីប្រាថ្នាគតិណាមួយនៃអបាយ ៤ ដែលបានដល់ទុគ្គតិ អធិប្បាយថា មានចំណែកពិតប្រាកដ ។

បទថា **អគុត្តទ្វារោ** បានដល់ មិនសង្រួមទ្វារ ។ តែក្នុងកន្ទែងខ្លះ អាចារ្យពោលថា បទថា **អគុត្តទ្វារោ** បានដល់ ក្នុងឥន្ទ្រិយទាំងឡាយ ។ អាចារ្យពោលដល់ការមិនសង្រួមឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ ដោយបទនោះ ។ ឈ្មោះថា មិនដឹងប្រមាណក្នុងភោជន ព្រោះមិនដឹងប្រមាណក្នុងភោជន ដោយការទទួល និងការបរិភោគ ។

កេចិអាចារ្យពោលថា ព្រោះភាពជាបុគ្គលមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ព្រោះភាពជាអ្នកមិនដឹងប្រមាណក្នុងភោជនក៏មាន ។

សួរថា ភាពជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយដូចម្តេច ឬក៏ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយដូចម្តេច ឆ្លើយថា ព្រោះមិនមានការសង្រួម ឬមិនសង្រួមក្នុងចក្ខុន្ទ្រិយដោយពិត ។ ដ្បិតថា សតិក្តី ការមិនមានសតិក្តី មិនកើតឡើង ព្រោះអាស្រ័យចក្ខុបសាទឡើយ ។ ពិតហើយ ខណៈណា រូបារម្មណ៍មកកាន់គន្លងចក្ខុ ខណៈនោះ កាលភវង្គកើតឡើង ២

ជន ហើយរលត់ទៅ កិរិយាមនោធាតុញ៉ាំងអាវជ្ជនកិច្ចឲ្យសម្រេច កើតឡើង ហើយ រមែងរលត់ទៅ បន្ទាប់អំពីនោះ ចក្ខុវិញ្ញាណធ្វើកិច្ចឃើញ បន្ទាប់អំពីនោះ វិបាកមនោធាតុ ធ្វើកិច្ចទទួល បន្ទាប់អំពីនោះ វិបាកាហេតុកមនោវិញ្ញាណ-ធាតុធ្វើកិច្ចពិចារណា បន្ទាប់អំពីនោះ កិរិយាហេតុកមនោវិញ្ញាណធាតុ ញ៉ាំងវោដ្ឋព្វនកិច្ចឲ្យសម្រេច កើតហើយរលត់ទៅក្នុងរវាងនោះ ជវនចិត្តរមែងស្ទុះទៅ ។ ក្នុងជវនចិត្តនោះ សេចក្តីសង្រួមក្តី ការមិនសង្រួមក្តី រមែងមានក្នុងសម័យនៃភវង្គក៏មិនមែន ក្នុងសម័យនៃអាវជ្ជនៈជាដើមណាមួយ ក៏មិនមែន ។ ក្នុងខណៈនៃជវនចិត្ត បើភាពជាអ្នកទ្រុស្តសីលក្តី ការមិនមានសតិក្តី ការមិនដឹងក្តី ការមិនអត់ធន់ក្តី ការខ្ជិលច្រអូសក្តី រមែងកើតឡើង រមែងមិនមាននូវការសង្រួម ភិក្ខុនោះសូម្បីនៅយ៉ាងនេះ ក៏លោកពោលថា ជាអ្នកមិនសង្រួមក្នុងចក្ខុទ្វារ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកាលមិនមានការសង្រួមនោះ សូម្បីទ្វារក៏មិនជាការគ្រប់គ្រង សូម្បីភវង្គក៏មិនជាការគ្រប់គ្រង សូម្បីវិថីចិត្ត មានអាវជ្ជនៈជាដើម ក៏មិនជាការគ្រប់គ្រង ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ដូចកាលទ្វារ ៤ ក្នុងនគរមិនបិទទ្វារផ្ទះ ខ្លោងទ្វារ និងបន្ទប់ជាដើម ខាងក្នុងបិទយ៉ាងល្អហើយក៏ពិតមែន តែទោះជាដូច្នោះ របស់ទាំងអស់ខាងក្នុងនគរ ក៏ឈ្មោះថា មិនរក្សា មិនគ្រប់គ្រងឡើយ ចោរទាំងឡាយចូលទៅតាមទ្វារនគរ ប្រាថ្នាវត្ថុណា ក៏គប្បីនាំវត្ថុនោះទៅ យ៉ាងណា កាលភាពជាអ្នកទ្រុស្តសីលជាដើម កើតឡើងក្នុងជវនចិត្ត កាលមិនមានការសង្រួម សូម្បីទ្វារក៏មិនជាការគ្រប់គ្រង សូម្បីភវង្គក៏មិនជាការគ្រប់គ្រង

សម្បីវិថីចិត្ត មានអាវជ្ជនៈជាដើម ក៏មិនជាការគ្រប់គ្រង កាលមិនមានអសំវរៈនោះ កាលសីលជាដើមកើតឡើងហើយក្នុងជវនចិត្ត សម្បីទ្វារ ក៏ឈ្មោះថាគ្រប់គ្រង សម្បីភវង្គ ក៏ឈ្មោះថា គ្រប់គ្រង សម្បីវិថីចិត្ត មានអាវជ្ជនចិត្តជាដើម ក៏ឈ្មោះថា គ្រប់គ្រង ។ សួរថា សេចក្តីនេះ ដូចអ្វី ឆ្លើយថា ដូចកាលទ្វារនគរបិទល្អហើយ ទ្វារផ្ទះខាងក្នុងជាដើមមិនបិទក៏ពិត តែរបស់ទាំងអស់ខាងក្នុងនគរក៏ឈ្មោះថា ជាការរក្សាល្អហើយ ជាការគ្រប់គ្រងល្អហើយនោះឯង កាលទ្វារនគរបិទហើយ ចោរទាំងឡាយ ក៏ចូលទៅមិនបាន យ៉ាងណា កាលសីលជាដើមកើតឡើងក្នុងជវនចិត្ត សម្បីទ្វារ ក៏ឈ្មោះថា គ្រប់គ្រង សម្បីភវង្គ ក៏ឈ្មោះថា គ្រប់គ្រង សម្បីវិថីចិត្ត មានអាវជ្ជនៈជាដើម ក៏ឈ្មោះថា គ្រប់គ្រង ដូច្នោះឯង ។ ដូច្នោះ ការមិនសង្រួម សម្បីកើតឡើងក្នុងខណៈនៃជវនចិត្ត ក៏លោកពោលថា សង្រួមក្នុងចក្ខុទ្វារ ។ សម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបភាពជាអ្នកមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ និងភាពជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំង-ឡាយ ដោយប្រការដូច្នេះ ។

សួរថា ភិក្ខុឈ្មោះថា ជាអ្នកមិនស្គាល់ប្រមាណក្នុងភោជនដូចម្តេច ឬឈ្មោះថា ជាអ្នកដឹងប្រមាណក្នុងភោជនដូចម្តេច ឆ្លើយថា បុគ្គលណា ជាអ្នកមានការចង់បានច្រើន មិនស្គាល់ប្រមាណក្នុងការទទួល បុគ្គលមានការចង់បានច្រើននោះ ក៏ដូចជាឈ្មួញលោហៈ ចង់បាននូវគ្រឿងប្រដាប់ និងរបស់ទៅហើយ ក៏ទុកដាក់របស់ដែលគួរទុកដាក់ក្នុងថ្នក់ ហើយបន្លកប្រាប់ដល់មហាជន

ដែលកំពុងឃើញថា ចូរពួកអ្នកយកវត្ថុនោះ ចូរយកវត្ថុនោះ ដូច្នេះ យ៉ាងណា បុគ្គលលើកតម្កើងសីលក្តី គម្ពីរក្តី គុណរបស់ធុតង្គក្តី របស់ខ្លួនមានប្រមាណតិច ដោយហោចសូម្បីត្រឹមតែការនៅព្រៃដល់មហាជនដែលដឹង កាលសរសើរហើយ កាន់យករទេះ ជញ្ជូនបច្ច័យ នាំចូលទៅ ក៏មិនពោលថា ល្មមហើយ នៅទទួលទៀតដូច្នោះដូចគ្នា ។ ព្រោះថា បុគ្គលមិនអាចឲ្យវត្ថុ ៣ យ៉ាងពេញបានទេ គឺភ្លើងពេញដោយឧស សមុទ្រពេញដោយទឹក បុគ្គលមានចំណង់ច្រើនពេញដោយបច្ច័យ ។

គំនរភ្លើង មហាសមុទ្រ និងបុគ្គលដែលមានការប្រាថ្នាច្រើន
ទាំង ៣ នេះ រមែងមិនពេញដោយបច្ច័យជាច្រើន ។

ដ្បិតថា បុគ្គលមានការប្រាថ្នាច្រើន មិនអាចទាញទឹកចិត្តរបស់មាតាបង្កើតបាន ព្រោះបុគ្គលបែបនេះ រមែងញុំាងលាភដែលមិនទាន់កើតមិនឲ្យកើតឡើង និងរមែងសាបសូន្យចាកលាភ ដែលកើតឡើងហើយ ដូច្នេះ ។ នឹងពោលដល់បុគ្គលដែលមិនស្គាល់ប្រមាណក្នុងការទទួល ។ បុគ្គលណាប្រាថ្នាចង់បាន ត្រូវការអាហារ សូម្បីបានហើយ ដោយធម៌ ដោយស្មើ មិនជាបុគ្គលឃើញទោស មិនមានបញ្ញាជាគ្រឿងចេញទៅ បរិភោគពេញពោះតាមតម្រូវការ ដោយមិនមែនវិធី ដោយមិនមែនឧបាយ ដូចអាហារហត្ថកព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ អត្ថវដ្តកព្រាហ្មណ៍ កាកមាសកព្រាហ្មណ៍ និងភុត្តវម្មិកព្រាហ្មណ៍ណាម្នាក់ ជាបុគ្គលប្រាថ្នាចំពោះតែសេចក្តីសុខក្នុងការដេក ជាសុខក្នុងការផ្អែក សុខក្នុងការដេកលក់ នេះ ឈ្មោះថាជា

*បុគ្គលមិនស្គាល់ប្រមាណក្នុងការបរិភោគ ។ បុគ្គលណា ជាអ្នកដឹងប្រមាណក្នុងភោជន ដោយអំណាចនៃការដឹងប្រមាណក្នុងការទទួល ដែលលោកពោលយ៉ាងនេះថា សូម្បីទេយ្យធម៌មានច្រើន អ្នកឲ្យបំណងនឹងឲ្យតិច អ្នកទទួលរមែងទទួលតិចតាមបំណងរបស់អ្នកឲ្យ ទេយ្យធម៌មានតិច អ្នកឲ្យបំណងនឹងឲ្យច្រើន អ្នកទទួលរមែងទទួលតែបន្តិច ដោយអំណាចនៃទេយ្យធម៌ ទេយ្យធម៌មានច្រើន អ្នកឲ្យក៏បំណងនឹងឲ្យច្រើន អ្នកទទួលដឹងកម្លាំងរបស់ខ្លួន តែងទទួលតែរបស់ល្មមប្រមាណប៉ុណ្ណោះ ការដឹងប្រមាណក្នុងការបរិភោគ ដែលបានដល់ការពិចារណា ដែលលោកពោលដោយន័យជាដើមថា ពិចារណាអាហារក្នុងអាហារដោយឧបាយ មិនបរិភោគដើម្បីលេង ដើម្បីស្រវឹង ដូច្នេះ និងដោយន័យជាដើមថា កាលបានហើយ មិនប្រាថ្នា មិនចង់បាន មិនត្រូវការបិណ្ឌបាត ជាអ្នកឃើញទោស មានបញ្ញាជាគ្រឿងចេញទៅ បរិភោគហើយ ដឹងដោយបញ្ញាជាគ្រឿងពិចារណាហើយ ទើបបរិភោគអាហារ ដូច្នេះ នេះឈ្មោះថា ជាអ្នកដឹងប្រមាណក្នុងភោជន ។ គប្បីជ្រាបថា ភិក្ខុជាអ្នកមិនដឹងនូវប្រមាណ និងជាអ្នកដឹងប្រមាណក្នុងភោជនយ៉ាងនេះ ។*

*គប្បីជ្រាបសេចក្តីក្នុងគាថាទាំងឡាយ មានបទថា* **ចក្ខុំ** *ជាដើម ឈ្មោះថា* **ចក្ខុ** *ព្រោះអត្ថថា ឃើញ អធិប្បាយថា ពេញចិត្តក្នុងរូប ឬដូចប្រាប់ដល់ការសម និងមិនសម ។ ឈ្មោះថា* **សោត** *ព្រោះអត្ថថា រមែងស្តាប់ ឈ្មោះថា* **ឃាន** *ព្រោះអត្ថថា ហិតស្រូបនូវក្លិន ភាពជាអ្នកនៅមានជីវិតជានិមិត្ត មានអាហារជារស ឈ្មោះថា* **ជិវ្ហា** *ព្រោះអត្ថថា ហៅរកនូវជីវិតនោះ*

ឈ្មោះថា **កាយ** ព្រោះអត្ថថា ចម្រើនដោយភាពគួរខ្ពើម ឈ្មោះថា **មន** ព្រោះអត្ថថា ដឹង គឺដឹងច្បាស់ ។ បុរាណាចារ្យពោលថា ឈ្មោះថា **មន** ព្រោះអត្ថថា រមែងដឹង អធិប្បាយថា រមែងដឹងអារម្មណ៍ ដូចវាល់ដោយនាឡិ និងដូចថ្លឹងដោយទម្ងន់ គប្បីជ្រាបអត្ថនៃបទក្នុងសូត្រនេះប៉ុណ្ណេះ ។

ដោយសេចក្ដីពិត ចក្ខុមាន ២ យ៉ាង គឺមំសចក្ខុ ១ បញ្ញាចក្ខុ ១ ។ ក្នុងចក្ខុ ២ យ៉ាងនោះ បញ្ញាចក្ខុមាន ៥ យ៉ាង គឺពុទ្ធចក្ខុ ១ សមន្តចក្ខុ ១ ញាណចក្ខុ ១ ទិព្វចក្ខុ ១ ធម្មចក្ខុ ១ ។

ក្នុងចក្ខុ ៥ យ៉ាងនោះ ឈ្មោះថា **ពុទ្ធចក្ខុ** ក្នុងពុទ្ធវចនៈថា **អទ្ទសំ ខោ អហំ ភិក្ខវេ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ** ម្នាលភិក្ខុទាំងឡាយ កាលតថាគតកំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុដូច្នេះជាដើម ។ ឈ្មោះថា **សមន្តចក្ខុ** ក្នុងបទថា **សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ** សព្វញ្ញុតញ្ញាណលោកហៅថា **សមន្តចក្ខុ** ។ ឈ្មោះថា **ញាណចក្ខុ** ដូចក្នុងបទថា **ចក្ខុំ ឧទបាទិ** ចក្ខុកើតឡើងហើយ ដូច្នេះជាដើម ។ ឈ្មោះថា **ទិព្វចក្ខុ** ក្នុងពុទ្ធវចនៈថា **អទ្ទសំ ខោ អហំ ភិក្ខវេ ទិព្វេន ចក្ខុនា វិសុទ្ធេន** ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញ ( ពួកបញ្ចវគ្គិយភិក្ខុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ) ដោយទិព្វចក្ខុដ៏បរិសុទ្ធ ដូច្នេះជាដើម ។ ឈ្មោះថា **ធម្មចក្ខុ** បានដល់ មគ្គ ៣ ខាងដើម ក្នុងបទថា **វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ** ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិលបានកើតឡើងហើយដូច្នេះជាដើម ។

មំសចក្ខុមាន ២ យ៉ាង គឺសសម្ភារចក្ខុ ១ បសាទចក្ខុ ១ ក្នុងមំស-ចក្ខុ ២ យ៉ាងនោះ ដុំសាច់តាំងនៅក្នុងប្រឡង់ភ្នែក កំណត់ដោយប្រឡង់ភ្នែកទាំងសងខាង គឺដោយឆ្អឹងប្រឡង់ភ្នែកខាងក្រោម ឆ្អឹងចិញ្ចើមខាងលើ ដោយខួរក្បាលខាងក្នុង ដោយរោមភ្នែកខាងក្រៅ រមែងមានសម្ភារៈ ១៤ យ៉ាង គឺធាតុ ៤ វណ្ណៈ គន្ធៈ រស ឱជា សម្ភវៈ សណ្ឋាន ជីវិត ភាវៈ កាយ-បសាទ ចក្ខុបសាទ ដោយពិស្តារមានសម្ភារៈ ៤៤ យ៉ាង ដោយអំណាចនៃរូប ៤៤ គឺរូប ៤០ ព្រោះសម្ភារៈ ១០ គឺធាតុ ៤ វណ្ណៈ គន្ធៈ រស ឱជា សណ្ឋាន សម្ភវៈដែលអាស្រ័យធាតុ ៤ សម្ភារៈនីមួយៗ មានធាតុ ៤ ជាសមុដ្ឋាន សម្ភារៈ ៤ គឺជីវិត ភាវៈ កាយបសាទ ចក្ខុបសាទ មានកម្មជាសមុដ្ឋាន ដោយចំណែកមួយប៉ុណ្ណោះ ។ កាលសត្វលោកដឹងថា ចក្ខុ-សមូល ក្រាស់ ស្អាត បរិបូណ៌ ទូលាយ ដូច្នេះ ឈ្មោះថា រមែងមិនដឹងចក្ខុ រមែងដឹងវត្ថុដោយភាពជាចក្ខុ គឺដុំសាច់ដែលតាំងនៅត្រង់ប្រឡង់ភ្នែក ទាក់ទងដល់ខួរ សីសៈ ដោយអំពោះ គឺសរសៃ ដែលមានពណ៌-សខ្លះ ខ្មៅខ្លះ ក្រហមខ្លះ ជាដី ទឹក ភ្លើង ខ្យល់ ដែលជាពណ៌-ស ព្រោះមានសេម្ហៈច្រើន ដែលមានពណ៌ខ្មៅ ព្រោះស្ទួស្ទឹកម្រើក ដែលមានពណ៌ក្រហម ព្រោះឈាមតាំងនៅ ដែលដូចជាផ្ទូវ ព្រោះច្រើនដោយធាតុដី ឈ្មោះថា រមែងហូរចេញ ព្រោះច្រើនដោយធាតុទឹក ឈ្មោះថា រមែងដុតរោល ព្រោះច្រើនដោយធាតុភ្លើង ឈ្មោះថា រមែងវិលទៅមក ព្រោះច្រើនដោយធាតុខ្យល់ នេះ ឈ្មោះថា **សសម្ភារចក្ខុ** ។ បសាទអាស្រ័យមហាភូតរូប ៤ ទាក់ទងក្នុងចក្ខុនោះ

ឈ្មោះថា **បសាទចក្ខុ** ។ ពិតហើយ បសាទចក្ខុនេះ រមែងប្រព្រឹត្តទៅដោយភាពជាវត្ថុ ទ្វារ តាមសមគួរដល់ចក្ខុវិញ្ញាណជាដើម ។

សូម្បីក្នុងសោតៈជាដើម គប្បីជ្រាបសេចក្ដីដូចតទៅនេះ សោតៈមាន ២ យ៉ាង គឺទិព្វសោត ១ មំសសោត ១ ។ សោតៈ ២ យ៉ាងនេះ សោតៈក្នុងប្រយោគជាដើមថា បានឮសំឡេងទាំង ២ ដោយសោតធាតុដែលជាទិព្វ បរិសុទ្ធកន្លងនូវសោតៈមនុស្ស នេះ ឈ្មោះថា **ទិព្វសោត** ។ មំសសោតៈមាន ២ យ៉ាង គឺសសម្ភារសោត ១ បសាទសោត ១ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងចក្ខុនោះឯង ។ ឃានៈ និងជិវ្ហាក៏ដូចគ្នា ។ តែកាយមានច្រើនយ៉ាង គឺចោបនកាយ ករជកាយ សមូហកាយ បសាទកាយ ។ ក្នុងកាយទាំងនោះ កាយក្នុងប្រយោគជាដើមថា **កាយេន សំវុតា ធីរា អថោ វាចាយ សំវុតា** អ្នកប្រាជ្ញទាំងឡាយ បានសង្រួមកាយ សង្រួមវាចា នេះ ឈ្មោះថា **ចោបនកាយ** ។

កាយក្នុងប្រយោគជាដើមថា **ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ** ភិក្ខុនោះក៏និម្មិតនូវកាយផ្សេងចេញអំពីកាយនេះ ឈ្មោះថា **ករជកាយ** ។ តែសមូហកាយមានច្រើនយ៉ាងមកហើយ ដោយអំណាចនៃពួកវិញ្ញាណជាដើម ។ ពិតហើយ លោកពោលពួកវិញ្ញាណក្នុងបទជាដើមថា នៃអាវុសោ ពួកវិញ្ញាណទាំងនេះមាន ៦ យ៉ាងដូច្នេះ ។ លោកពោលដល់ពួកផស្សៈជាដើម ក្នុងបទជាដើមថា ពួកផស្សៈ ៦ យ៉ាង ដូច្នេះ។ ម្យ៉ាងទៀត លោកពោលវេទនាក្ខន្ធជាដើម ក្នុងបទជាដើមថា **កាយបស្សទ្ធិ កាយលហុតា** លោកពោល

*បឋវីធាតុជាដើម ដោយន័យជាដើមថា បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងពិចារណាឃើញបឋវីកាយ អាបោកាយ តេជោកាយ វាយោកាយ កេសកាយ លោមកាយ ដោយភាពជារបស់មិនទៀង ដូច្នេះ ។ ការពាល់ត្រូវផោដ្ឋព្វៈដោយកាយ ឈ្មោះថា* **បសាទកាយ** *គប្បីជ្រាបបសាទកាយក្នុងបទនេះ ពិតហើយ បសាទកាយនោះ តែងប្រព្រឹត្តទៅដោយភាពជាវត្ថុទ្វារ តាមសមគួរដល់កាយវិញ្ញាណជាដើម ។ វិញ្ញាណទាំងអស់ លោកហៅថា មនោក៏ពិតតែគប្បីជ្រាបថា ភវង្គ មួយអន្ទើដោយអាវជ្ជនៈជាទ្វារ ព្រោះក្នុងទីនេះលោកបំណងយកភាពជាទ្វារ ។*

*បទថា* **ឯតានិ យស្ស ទ្វារានិ អគុត្តានិ ច ភិក្ខុនោ** *សេចក្តីថា ភិក្ខុណាមិនបិទទ្វារ ដែលមានចិត្តជាគម្រប់ ៦ នេះដោយទ្វារ គឺសតិ ព្រោះដល់នូវសេចក្តីប្រមាទ ដោយប្រាសចាកសតិ ។ បទថា* **ភោជនម្ហិ ។បេ។ អធិគច្ឆតិ** *សេចក្តីថា ភិក្ខុនោះមិនដឹងប្រមាណក្នុងភោជនតាមន័យដែលពោលរួចមកហើយ វៀរចាកការសង្រួមក្នុងឥន្ទ្រិយទាំងឡាយ រមែងដល់នូវសេចក្តីទុក្ខដោយប្រការទាំងពួង គឺទុក្ខកាយ ក្នុងបច្ចុប្បន្នដោយរោគជាដើម និងក្នុងភពខាងមុខ ត្រូវចូលដល់ទុគ្គតិ ទុក្ខចិត្ត ដោយត្រូវកិលេស មានរាគៈជាដើមដុតរោល និងដោយការប្រណែន និងការបង្អៀតបង្អល់ ។ ព្រោះហេតុនោះបុគ្គលនោះ មានកាយត្រូវភ្លើងទុក្ខដុតរោល មានចិត្តត្រូវភ្លើងទុក្ខដុតរោលទាំងក្នុងលោកនេះ និងលោកខាងមុខ រមែងនៅជាទុក្ខអស់កាលជានិច្ច ទាំង*

ពេលថ្ងៃ និងពេលយប់ មិនមានសេចក្ដីសុខ នឹងពោលទៅថ្វី ក្នុងការកន្ទួងបង់នូវទុក្ខក្នុងវដ្ដៈនោះ ។ល។

**អដ្ឋកថា បឋមភិក្ខុសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយភិក្ខុសូត្រ

[ ២៩ ] ខ្ញុំបានស្ដាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ រមែងនៅជាសុខ មិនថ្នាំងថ្នាក់ មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ ភិក្ខុប្រកបដោយធម៌ ២ តើដូចម្ដេច ។ គឺភាពជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ នេះឯង រមែងនៅជាសុខ មិនថ្នាំងថ្នាក់ មិនចង្អៀតចង្អល់ មិនក្រវល់ក្រវាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា ក្នុងសាសនានេះ បានគ្រប់គ្រងទ្វារទាំងឡាយ
នេះ គឺចក្ខុ ១ សោតៈ ១ ឃានៈ ១ ជិវ្ហា ១ កាយ ១

មនៈ ១ ល្អហើយ ជាអ្នកដឹងប្រមាណក្នុងភោជន សង្រួម

ក្នុងឥន្ទ្រិយទាំងឡាយ ភិក្ខុនោះ តែងបានសេចក្តីសុខ គឺ

សុខក្នុងកាយផង សុខក្នុងចិត្តផង ភិក្ខុបែបនោះ មាន

កាយមិនក្តៅក្រហាយ មានចិត្តមិនក្តៅក្រហាយ រមែង

នៅជាសុខ ទាំងថ្ងៃ ទាំងយប់ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ទុតិយភិក្ខុសូត្រ

ក្នុងភិក្ខុសូត្រទី ២ គប្បីជ្រាបដោយន័យដែលផ្ទុយគ្នា តាមដែលបានពោលមកហើយនោះឯង ។ល។

**អដ្ឋកថា ទុតិយភិក្ខុសូត្រទី ២ ចប់**

# សុត្តន្តបិដក

## តបនីយសូត្រ

[ ៣០ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំឲ្យក្តៅនេះ មាន ២ ។ ធម៌នាំឲ្យក្តៅ ២ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹងអាស្រ័យ ធ្វើតែអំពើបាប ធ្វើតែអំពើរឹងរូស ធ្វើតែអំពើអាក្រក់ បុគ្គលនោះតែងក្តៅក្រហាយ ដោយគិតថា អាត្មាអញមិនបានធ្វើអំពើល្អផង តែងក្តៅក្រហាយ ដោយគិតថា អាត្មាអញ ធ្វើតែអំពើអាក្រក់ផង ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំឲ្យក្តៅ មាន ២ នេះឯង ។ លុះព្រះមានព្រះភាគសម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា ធ្វើកាយទុច្ចរិត វចីទុច្ចរិត ឬធ្វើមនោទុច្ចរិត
ឬក៏អំពើណាមួយ ដទៃទៀត ដែលប្រកបដោយទោស
មិនបានធ្វើកុសលកម្ម ធ្វើតែអកុសលជាច្រើន បុគ្គល
អ្នកឥតបញ្ញានោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ
តែងចូលទៅកាន់នរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## តបនីយសូត្រ

[ ៣០ ] ក្នុងតបនីយសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **តបនីយា** សេចក្តីថា ធម៌ឈ្មោះថា ជាហេតុឲ្យក្តៅក្រហាយ ព្រោះក្តៅក្រហាយ បៀតបៀន រុកកួន ទាំងក្នុងលោកនេះ និងលោកខាងមុខ ។ ម្យ៉ាងទៀត ធម៌ ឈ្មោះថា ជាហេតុឲ្យក្តៅក្រហាយ ព្រោះការដល់នូវភាពក្តៅក្រហាយជាទុក្ខ ធម៌ទាំងឡាយវិលឲ្យទុក្ខនោះកើត និងឲ្យទុក្ខនោះកើត ទាំងក្នុងបច្ចុប្បន្ន និងសម្បរាយភព ។ ម្យ៉ាងទៀត ឈ្មោះថា **តបន** ព្រោះជាគ្រឿងក្តៅក្រហាយ អធិប្បាយថា ការក្តៅក្រហាយតាមដុតរោលខាងក្រោយ ។ ឈ្មោះថា **តបនីយា** ព្រោះវិលដោយភាពជាហេតុនៃការក្តៅក្រហាយនោះ ។ បទថា **អកតកល្យាណោ** ឈ្មោះថា **កតកល្យាណោ** ព្រោះមិនធ្វើល្អ មិនធ្វើសេចក្តីចម្រើន គឺមិនធ្វើបុណ្យ ។ ២ បទដ៏សេសជាវេវចនៈនៃបទថា **អកតកល្យាណោ** នោះឯង ។ ពិតហើយ បុណ្យទាន ហៅថា **កល្យាណ** ព្រោះអត្ថថា ព្រោះឧបការៈដល់ការរស់នៅ និងព្រោះជាសុខតទៅ ហៅថា **កុសល** ព្រោះអត្ថថា កម្ចាត់នូវភាពគួរខ្ពើម និងសេចក្តីអាក្រក់ជាដើម ហៅថា **ភីរុត្តាណំ** ( ទប់ទល់នឹងសេចក្តីខ្លាច ) ព្រោះអត្ថថា ការពារនូវសេចក្តីខ្លាចទុក្ខ និងខ្លាចសង្សារ ។ បទថា **កតបាបោ** ឈ្មោះថា ធ្វើបាប ព្រោះធ្វើគឺសន្សំតែអាក្រក់ ។ ២ បទដ៏សេស ជាវេវចនៈនៃបទថា **កតបាបោ** នោះឯង ។ អកុសលកម្ម លោកហៅថា **បាប** ព្រោះអត្ថថា លាមក ហៅថា

**លុទ្ធ** ( គ្រោតគ្រាត ) ព្រោះសភាវៈគ្រោតគ្រាតជាសភាវៈកាច ទាំងក្នុងខណៈដែលខ្វនរស់នៅ ទាំងក្នុងខណៈឲ្យផល និងហៅថា **កិព្ពិសម្ប** ( ទារុណ ) ព្រោះត្រូវកិលេសប្រទូស្ត ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដោយធម្មាធិដ្ឋានថា **ទ្វេ ធម្មា តបនីយា** ដូច្នេះហើយ ទើបទ្រង់សម្តែងកុសលធម៌ដែលមិនបានធ្វើ និងអកុសលធម៌ដែលធ្វើហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពដែលធម៌ទាំងនោះជាហេតុឲ្យក្តៅក្រហាយ ទើបត្រាស់ថា បុគ្គលនោះរមែង ក្តៅក្រហាយថាអញមិនបានធ្វើកម្មល្អ ដូច្នេះ រមែងជាស់តឿនថា អញធ្វើតែបាបដូច្នេះក៏មានដោយប្រការដូច្នេះ អធិប្បាយថា ជននោះ តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ រមែងសោកក្នុងកាលជាខាងក្រោយ ដូច្នេះ ។

ក្នុងគាថាទាំងឡាយ គប្បីជ្រាបសេចក្តីដូច្នេះ ឈ្មោះថា ទុច្ចរិត ព្រោះប្រព្រឹត្តគួរខ្ពើម ឬប្រព្រឹត្តអាក្រក់ ព្រោះស្អុយដោយកិលេស ។ ការប្រព្រឹត្តអាក្រក់ផ្លូវកាយ ឬប្រព្រឹត្តអាក្រក់ប្រព្រឹត្តទៅផ្លូវកាយ ឈ្មោះថា កាយទុច្ចរិត សូម្បីវចីទុច្ចរិត មនោទុច្ចរិត ក៏គប្បីឃើញយ៉ាងនេះ ។ ម្យ៉ាងទៀត កាយទុច្ចរិតជាដើមនេះ លោកបំណងយកកម្មបថ ។ បទថា **យញ្ចញ្ញំ ទោសសញ្ហិតំ** ព្រះមានព្រះភាគ ត្រាស់សំដៅដល់អកុសលកម្ម ដែលមិនដល់នូវភាពជាកម្មបថ ។ បទនោះ មានអធិប្បាយដូចតទៅនេះ និងអកុសលកម្មដទៃរមែងរាប់ថា ជាកាយកម្មជាដើម មិនបានដោយចំពោះ មិនដល់នូវភាពជាកម្មបថ ឈ្មោះថា ប្រកបដោយទោសៈ ព្រោះទាក់ទងជាមួយកិលេស មាន

រាគៈជាដើម ធ្វើកុសលកម្មនោះ ។

បទថា **និរយំ** បានដល់ ទុគ្គតិទាំងអស់ ដែលបានឈ្មោះថា នរក ព្រោះអត្ថថា មិនមានសេចក្តីត្រេកអរ ឬព្រោះអត្ថថា មិនមានសេចក្តីពេញចិត្ត ឬនិរិទ្ទុក្ខក្នុងសុគតិទាំងអស់ ព្រោះឃាត់នូវសេចក្តីសុខ គឺសេចក្តីចម្រើន ។ គប្បីឃើញអត្ថក្នុងបទទាំងនោះថា បុគ្គលនោះ គឺបុគ្គលបែបនោះ រមែងចូលដល់ ( សភាពបែបនោះ ) ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងសូត្រនេះ គួរពោលដល់រឿងរបស់បុគ្គលទាំងនេះ គឺ នន្ទគោឃាតកៈ ២ នាក់បងប្អូន ម្នាក់ឈ្មោះនន្ទយក្ខ ម្នាក់ឈ្មោះនន្ទមាណព ព្រោះជាហេតុឲ្យក្តៅក្រហាយ ព្រោះកាយទុច្ចរិត ។

មានរឿងថា ពីរនាក់បងប្អូននោះ សម្លាប់មេគោដោយបែងចែកសាច់ជា ២ ចំណែក បន្ទាប់អំពីនោះ បុរសជាប្អូននិយាយនឹងបងថា ខ្ញុំមានកូនច្រើន សូមបងឲ្យពោះវៀនធំទាំងនេះដល់ខ្ញុំចុះ ពេលនោះ បងប្រុសពោលនឹងប្អូនប្រុសនោះថា សាច់ទាំងអស់បែងចេញជា ២ ចំណែកហើយ ឯងនឹងយកអ្វីទៀត ទើបវាយប្អូននោះឲ្យស្លាប់ ។ បងប្រុសបែរត្រឡប់មើល ប្អូនប្រុសស្លាប់ហើយ កើតសេចក្តីក្តៅក្រហាយចិត្តថា អញធ្វើកម្មធ្ងន់ អញសម្លាប់ប្អូនប្រុសដោយមិនមែនហេតុឡើយ បងប្រុសកើតនូវការក្តៅក្រហាយយ៉ាងខ្លាំងក្លា ទើបគេនឹកដល់កម្មនោះ ទាំងក្នុងទីឈរ ទាំងក្នុងទីអង្គុយ រមែងមិនបាននូវការផូរផង់ចិត្តឡើយ សូម្បីការស៊ី ការផឹក ការទំពាររបស់គាត់ ក៏មិនបានផ្សាយនូវភាពធ្លាញ់ទៅក្នុងរាងកាយឡើយ បានប្រាកដត្រឹមតែស្បែកដណ្តប់

ធ្មឹងប៉ុណ្ណោះ លំដាប់នោះ ព្រះថេរៈមួយរូបបានសួរគាត់ថា នែឧបាសក អ្នកស្គមស្គាំងអ្វីម៉្លេះ ឃើញតែស្បែកដណ្តប់ធ្មឹងប៉ុណ្ណោះ អ្នកមានរោគអ្វី ឬមានកម្មអ្វីដែលនាំឲ្យអ្នកក្តៅក្រហាយ ។ គាត់បានសារភាពរឿងរ៉ាវនោះទាំងអស់ ។ លំដាប់នោះ ព្រះថេរៈពោលដល់បុរសនោះថា នែឧបាសក អ្នកធ្វើកម្មខុសក្នុងទីដែលមិនគួរខុសឲ្យធ្ងន់ប្រើន ដោយកម្មនោះឯង បុរសនោះ ក៏ទៅកើតក្នុងនរក ។

ការក្តៅក្រហាយព្រោះវចីទុច្ចរិត គួរពោលដល់រឿងសុប្បពុទ្ធសក្យៈ កោកាលិក និងនាងចិញ្ចមាណវិកាជាដើម ។ ក្តៅក្រហាយព្រោះមនោទុច្ចរិត គួរពោលដល់រឿងឧក្កលៈ និងជយកញ្ញៈ[១]ជាដើម ។

## អដ្ឋកថាតបនីយសូត្រទី ៣ ចប់

១- បាលីក្នុងទីខ្លះ ជាឲុក្កណៈ និងវស្សគញ្ញៈ

# សុត្តន្តបិដក

## អតបនីយសូត្រ

[ ៣១ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំមិនឲ្យក្តៅក្រហាយនេះមាន ២ ។ ធម៌នាំមិនឲ្យក្តៅក្រហាយ ២ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើសេចក្តីល្អទុកហើយ បានធ្វើកុសលទុកហើយ បានធ្វើសេចក្តីពឹងពាក់ទុកហើយ មិនបានធ្វើបាប មិនបានធ្វើសេចក្តីរឹងរូស មិនបានធ្វើសេចក្តីអាក្រក់ បុគ្គលនោះ តែងមិនក្តៅក្រហាយ ដោយគិតថា អាត្មាអញ បានធ្វើសេចក្តីល្អទុកហើយផង តែងមិនក្តៅក្រហាយ ដោយគិតថា អាត្មាអញ មិនបានធ្វើសេចក្តីអាក្រក់ទុកហើយផង ។ ម្នាលភិក្ខុទាំងឡាយ ធម៌នាំមិនឲ្យក្តៅក្រហាយមាន ២ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា លះបង់កាយទុច្ចរិត វចីទុច្ចរិត ឬលះបង់
មនោទុច្ចរិត ឬអំពើណាមួយដទៃទៀត ដែលប្រកប
ដោយទោស មិនធ្វើអកុសលកម្ម ធ្វើតែកុសលកម្មជា
ច្រើន បុគ្គលនោះ ជាអ្នកប្រកបដោយបញ្ញា លុះបែក
ធ្លាយរាងកាយស្លាប់ទៅ តែងចូលទៅកាន់ស្ថានសួគ៌ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## អតបនីយសូត្រ

[ ៣១ ] ក្នុងអដ្ឋកថា អតបនីយសូត្រទី ៤ គប្បីជ្រាបអត្ថដោយការផ្ទុយគ្នា តាមដែលពោលហើយ ក្នុងអដ្ឋកថាតបនីយសូត្រទី ៣ ។៚

**អដ្ឋកថា អតបនីយសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមសីលសូត្រ

[ ៣២ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺប្រកបដោយសីលលាមក ១ ប្រកបដោយទិដ្ឋិលាមក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ នេះឯង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនណា ប្រកបដោយធម៌ ២ យ៉ាងនេះ គឺដោយសីល
លាមក ១ ដោយទិដ្ឋិលាមក ១ ជនអ្នកឥតបញ្ញានោះ
លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងចូលទៅកាន់នរក ។

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៥ ។*

# អដ្ឋកថា

## បឋមសីលសូត្រ

*[ ៣២ ] ក្នុងបឋមសីលសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **ទាបកោន ច សីលេន** *សេចក្តីថា អាចារ្យទាំងឡាយពោលថា ការមិនសង្រួម ដែលធ្វើឲ្យសីលដាច់ ឈ្មោះថា សីលលាមក ។ ក្នុងបទនោះ បើការមិនសង្រួមជាសីលដូចគ្នាសោត ព្រោះភាពជាអ្នកទ្រុស្តសីល សីលនោះនឹងហៅថា សីលដូចម្តេច ។ ក្នុងបទនោះ មានអធិប្បាយដូច្នេះ លោកពោលវត្ថុដែលមិនឃើញក្នុងលោក ថាឃើញ ឬបុគ្គលមិនមានសីល ថាជាអ្នកមានសីលដូច្នេះ យ៉ាងណា សូម្បីក្នុងសេចក្តីនេះ លោកក៏ហៅការមិនមានសីលក្តី មិនសង្រួមក្តី ថាសីលនោះឯង ។*

*ម្យ៉ាងទៀត ឈ្មោះថា សីល សូម្បីមានក្នុងអកុសលធម៌ទាំងឡាយ ព្រោះបាលីថា ម្នាលនាយជាងឈើ ចុះសីលទាំងឡាយជាអកុសល តើដូចម្តេច ។ កាយកម្មជាអកុសល វចីកម្មជាអកុសល អាជីវៈជាបាប ... ដូច្នេះ ព្រោះហេតុនោះ ការប្រព្រឹត្តប្រពៃទាំងអស់ជាប្រក្រតី ដូចសម្រេចតាមសភាវៈដោយការស្និទ្ធស្នាល លោកហៅថា សីល ។ បទថា* **ទាបកោន ច សីលេន**

ព្រះមានព្រះភាគ ត្រាស់ដល់អកុសលដ៏លាមក ព្រោះអត្ថថា មិនជាការឈ្លាស ។ បទថា **ចាបិកាយ ច ទិដ្ឋិយា** បានដល់ មិច្ឆាទិដ្ឋិទាំងអស់ដ៏លាមក ។ តែដោយសេចក្តីវិសេស ទិដ្ឋិ ៣ យ៉ាង គឺអហេតុកទិដ្ឋិ ១ អកិរិយទិដ្ឋិ ១ នត្ថិកទិដ្ឋិ ១ លាមកជាង ។ ក្នុងបទនោះ បុគ្គលប្រកបដោយសីលដ៏លាមក ជាអ្នកវិបត្តិដោយប្រយោគ បុគ្គលដែលប្រកបដោយទិដ្ឋិដ៏លាមក ជាបុគ្គលវិបត្តិដោយអាសយ ( អធ្យាស្រ័យ ) បុគ្គលដែលវិបត្តិដោយប្រយោគ និងអាសយ ជាអ្នកធ្លាក់នរកដោយពិត សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ដូច្នោះ ។

ក្នុងបទថា **ទ្វីហិ ធម្មេហិ សមន្នាគតោ** នេះ គប្បីឃើញជាពាក្យសម្តែងដល់លក្ខណៈ មិនមែនសម្តែងដល់បែបផែន ។ បើក្នុងលោក ការឈឺថ្កាត់ទាំងឡាយគប្បីមានដល់យើងសោត គួរឲ្យថ្នាំប្រភេទនេះ ដល់បុគ្គលដែលឈឺថ្កាត់ទាំងនោះ ដូច្នេះ ។ ក្នុងឋានៈបែបនេះ ជនដទៃក៏មានន័យនេះដូចគ្នា ។ បទថា **ទុប្បញ្ញោ** គឺមិនមានបញ្ញា ។៚

**អដ្ឋកថា បឋមសីលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយសីលសូត្រ

[ ៣៣ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺប្រកបដោយសីលចម្រើន ១ ប្រកបដោយទិដ្ឋិចម្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ នេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ទុក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនណា ប្រកបដោយធម៌ ២ នេះ គឺដោយសីលល្អ
១ ដោយទិដ្ឋិល្អ ១ ជនអ្នកប្រកបដោយបញ្ញានោះ
លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងចូលទៅ
កាន់ស្ថានសួគ៌ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## ទុតិយសីលសូត្រ

[ ៣៣ ] ក្នុងទុតិយសីលសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ភត្តិកេន ច សីលេន** បានដល់ បារិសុទ្ធិសីល ៤ មានកាយសុចរិតជាដើម ។ ពិតហើយ បារិសុទ្ធិសីល ៤ នោះ ជាការស្អាតក្នុងខ្លួនឯង ព្រោះមិនពព្រុសជាដើម និងនាំមកនូវគុណដ៏ល្អ មានសមថៈ និងវិបស្សនាជាដើម ព្រោះហេតុនោះ ទើបលោកពោលថា **ភទ្ទកំ** ។ បទថា **ភទ្ទិកាយ ច ទិដ្ឋិយា** បានដល់ កម្មស្សកតាញាណ និងសម្មាទិដ្ឋិ ដែលជាកម្មបថ ។

ក្នុងបទនោះ បុគ្គលប្រកបដោយសីលដ៏ចម្រើន ជាអ្នកដល់ព្រមដោយប្រយោគ ប្រកបដោយទិដ្ឋិដ៏ចម្រើន ជាអ្នកដល់ព្រមដោយអាសយ បុគ្គលដល់ព្រមដោយប្រយោគ និងអាសយ ជាអ្នកចូលដល់ស្ថានសួគ៌ ដោយប្រការដូច្នេះ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ២ នេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅតម្កល់ដូច្នោះ ។ បទថា **សប្បញ្ញោ** គឺមានបញ្ញា ។ បទដ៏សេសមានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា ទុតិយសីលសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## អាតាបីសូត្រ

[ ៣៤ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មិនមានសេចក្តីខ្លាចបាប មិនគួរដើម្បីត្រាស់ដឹង មិនគួរដើម្បីរម្ងត់ មិនគួរដើម្បីបាននូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីខ្លាចបាប ទើបគួរដើម្បីត្រាស់ដឹង គួរដើម្បីរម្ងត់ គួរដើម្បីបាននូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា មិនមានព្យាយាមដុតកម្តៅកិលេស មិនមានសេចក្តីខ្លាចបាប ជាអ្នកខ្ជិលច្រអូស មានព្យាយាមថោកថយ ច្រើនដោយថីនមិទ្ធៈ មិនមានសេចក្តីអៀនខ្មាស មិនមានសេចក្តីអើពើ ភិក្ខុនោះ មិនគួរដើម្បីបាននូវសេចក្តីត្រាស់ដឹងដ៏ឧត្តមឡើយ ភិក្ខុណាជាអ្នកមានស្មារតី មានបញ្ញាជាគ្រឿងរក្សាខ្លួន មានឈាន មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីខ្លាចបាប មិនប្រមាទ ផ្តាច់បង់នូវគ្រឿងប្រកប នៃជាតិជរាបាន ភិក្ខុនោះ ទើបគួរដើម្បីបាននូវសេចក្តីត្រាស់ដឹងដ៏ឧត្តម ក្នុងលោកនេះ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី៧ ។

# អដ្ឋកថា

## អាតាបីសូត្រ

[ ៣៤ ] ក្នុងអាតាបីសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អនាតាបី** បានដល់ មិនមានព្យាយាម ឈ្មោះ **អាតាប** ព្រោះអត្ថថា ដុតនូវកិលេសទាំងឡាយ ។ ឈ្មោះថា **អាតាបី** ព្រោះមានសេចក្តីព្យាយាម ។ ឈ្មោះថា **អនាតាបី** ព្រោះមិនមានសេចក្តីព្យាយាម លោកអធិប្បាយថា ជាអ្នកខ្ជិលប្រអូស វៀរចាកសម្មប្បធាន ។ ការតក់ស្លុតចំពោះបាប លោកហៅថា **ឱត្តប្ប** ឈ្មោះថា **ឱត្តប្បី** ព្រោះមានការតក់ស្លុត ។ ឈ្មោះថា **អនោត្តប្បី** ព្រោះមិនមានការតក់ស្លុត បានដល់ វៀរចាកការតក់ស្លុត ។ម្យ៉ាងទៀត ការមិនមានសេចក្តីព្យាយាម ជាបដិបក្ខចំពោះសេចក្តីព្យាយាម បានដល់ ការខ្ជិលប្រអូស ។ ឈ្មោះថា **អនាតាបី** ព្រោះមិនមានសេចក្តីព្យាយាម ។ ការមិនតក់ស្លុតណា ដែលលោកពោលយ៉ាងនេះថា បុគ្គលមិនតក់ស្លុតចំពោះវត្ថុដែលគួរតក់ស្លុត ឬមិនតក់ស្លុត ព្រោះចូលដល់អកុសលធម៌ដ៏លាមក ការមិនតក់ស្លុតនោះ ឈ្មោះថា **អនោត្តាប** ។ ឈ្មោះថា **អនោត្តាបី** ព្រោះមិនមានការតក់ស្លុត គប្បីជ្រាបសេចក្តីក្នុងសូត្រនេះ ដោយ

ប្រការដូច្នេះ ។

បទថា **អភព្វោ** ប្រែថា មិនគួរ ។ បទថា **សម្ពោធាយ** គឺដើម្បីអរិយមគ្គ ។ បទថា **និព្វានាយ** បានដល់ ដើម្បីអមតមហានិព្វាន ដែលស្ងប់កិលេសបានដោយឥតសេសសល់ ។ បទថា **អនុត្តរស្ស យោគក្ខេមស្ស** បានដល់ អរហត្តផល ។ ពិតហើយ អរហត្តផលនោះ ឈ្មោះថា ជាអនុត្តរៈ ព្រោះមិនមានវត្ថុដែលក្រៃលែងជាង ឈ្មោះថា **ខេម** ព្រោះមិនត្រូវយោគៈ ៤ បៀតបៀន ទើបលោកពោលថា **និព្វាន** នឹងពោលថាជាដែនក្សេមចាកនូវយោគៈ ។ បទថា **អធិគមាយ** បានដល់ ដើម្បីត្រាស់ដឹង ។ បទថា **អាតាបី** ប្រែថា មានការព្យាយាម ។ ពិតហើយ អ្នកមានសេចក្ដីព្យាយាមនោះ ជាអ្នកប្រកបដោយវិរិយារម្ភៈ ដូចលោកពោលនៅទុកក្នុងទីឃនិកាយ បាដិកវគ្គ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានព្យាយាមប្រារព្ធហើយ ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីចម្រើនពួកកុសលធម៌ ជាអ្នកមានកម្លាំងចិត្ត មានសេចក្ដីសង្វាតមាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ ឈ្មោះថា **អាតាបី** ព្រោះមានប្រក្រតីដុតនូវកិលេស ដោយឥតសេសសល់ ។ បទថា **ឱត្តប្បី** បានដល់ មានប្រក្រតីដុតនូវកិលេស ព្រោះប្រកបដោយឱត្តប្បៈ ដូចលោកពោលឯក្នុងធម្មសង្គណីយ៉ាងនេះថា ត្រង់ដែលបុគ្គលតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ... ដូច្នេះ ។ ព្រោះដូច្នោះ ទើបឈ្មោះថា **ឱត្តប្បី** ។ ពិតហើយ បុគ្គលដែលប្រកបដោយហិរិ និងឱត្តប្បៈ ព្រោះវៀរ

ចាកអកុសលធម៌ដ៏លាមកនោះ លោកពោលថា ជាអ្នកមានឱត្តប្បៈ ដោយប្រការដូច្នេះ ។ បុគ្គលដល់ព្រមដោយហិរិ និងឱត្តប្បៈ ជាអ្នកមានប្រក្រតីឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិច ជាអ្នកធ្វើនូវសេចក្តីបរិបូណ៌ក្នុងសីលទាំងឡាយ ។ លោកសម្តែងដល់សីលសម្បទានៃបុគ្គលនោះ ដោយប្រការដូច្នេះ ។ បទថា **អាតាបី** លោកសម្តែងដល់ភាពដែលបុគ្គលនោះជាអ្នកខ្វល់ខ្វាយក្នុងសមថភាវនា និងវិបស្សនាភាវនា ដោយសម្តែងដល់ការដុតកិលេស ដោយន័យនេះ ។ម៉្យាងទៀត សេចក្តីព្យាយាមតាមដែលពោលហើយ វៀរចាកសទ្ធា សតិ សមាធិ បញ្ញា នឹងមិនមាន ព្រោះហេតុនោះ ឥន្ទ្រិយដែលមានសទ្ធាជាគម្រប់ ៥ ធ្វើវិមុត្តិឲ្យចាស់ក្លា លោកពោលដោយអត្ថប៉ុណ្ណោះ ។ ក្នុងការសម្រេចទាំងនោះ សញ្ញាដែលជានិព្វេធភាគី ៦ យ៉ាង គឺសញ្ញាក្នុងវត្ថុដែលមិនទៀង ថាទៀង ១ សញ្ញាក្នុងវត្ថុមិនទៀង ថាជាទុក្ខ ១ សញ្ញាក្នុងទុក្ខ ថាជាអនត្តា ១ សញ្ញាក្នុងការលះទុក្ខ ១ សញ្ញា ក្នុងការអស់តម្រេក ១ សញ្ញាក្នុងនិរោធ ១ ជាការសម្រេចនោះឯង ។

ព្រះសាស្តា កាលទ្រង់សម្តែងដល់ភាពជាអ្នកគួរដើម្បីសម្រេចមគ្គផលនិព្វាន ព្រោះសីល សមាធិ បញ្ញា ដែលជាលោកិយរបស់អ្នកប្រកបដោយធម៌ទាំង ២ នេះសម្រេច ទើបត្រាស់ថា **អាតាបី ច ខោ ។បេ។ អធិគមាយ** ភិក្ខុមានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីខ្លាចបាប ទើបគួរដើម្បីត្រាស់ដឹង គួរដើម្បីរម្ងត់ គួរដើម្បីបាននូវធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ដូច្នេះ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **កុសីតោ** សេចក្តីថា ឈ្មោះថា **កុសីត** ព្រោះលិចចុះ ជាប់ជំពាក់ដោយធម៌ដ៏លាមក ដែលគួរខ្ពើម បានដល់ កាមវិតក្ក ព្យាបាទវិតក្ក និងវិហិង្សាវិតក្ក ព្រោះច្រើនទៅដោយមិច្ឆាទិដ្ឋិ ឬជ្រួតជ្រាបទៅកាន់ភាពដែលគួរខ្ពើម ផុតចាកអំពីបដិបត្តិប្រពៃ ព្រោះដូច្នោះ ទើបឈ្មោះថា **កុសីត** ផ្លាស់ ឌ អក្ខរៈជា ត អក្ខរៈ ។ បទថា **ហីនវីរិយោ** បានដល់ មិនមានសេចក្តីព្យាយាម គឺវៀរចាកការធ្វើសេចក្តីព្យាយាមក្នុងឥរិយាបថ ៤ ជាអ្នកច្រើនទៅដោយថីនមិទ្ធៈ ព្រោះថីនមិទ្ធៈ ជាការខ្ជិលច្រអូសផ្លូវចិត្ត មានសភាពងោកងុយ ព្រោះមិនឧស្សាហ៍ មិទ្ធៈ ជាការខ្ជិលច្រអូសផ្លូវកាយ មិនអង់អាច មានការបង្អៀតបង្អល់ជាសភាវៈប្រព្រឹត្តទៅរឿយៗ ។ ឈ្មោះថា **អហិរិកោ** ព្រោះមិនមានហិរិដែលមានលក្ខណៈខ្ពើមនូវសេចក្តីអាក្រក់ និងព្រោះប្រកបដោយការមិនមានហិរិដែលជាបដិបក្ខចំពោះហិរិនោះ ឈ្មោះថា **អនាទរោ** ព្រោះមិនមានការអើពើក្នុងកិច្ចបដិបត្តិប្រពៃ ព្រោះមិនមានហិរិ ឱត្តប្បៈ និងវីរិយៈ ។ម្យ៉ាងទៀត ឈ្មោះថា **អនាទរោ** ព្រោះមិនធ្វើនូវកិរិយា ២ យ៉ាង ក្នុងធម៌ និងបុគ្គលដោយមិនមានហិរិ និងឱត្តប្បៈទាំង ២ យ៉ាង ។ បទថា **ផុដ្ឋុំ** គឺដើម្បីពាល់ត្រូវ ។ បទថា **សម្ពោធិមុត្តមំ** សេចក្តីថា មិនគួរសម្រេចអរហត្តដ៏ឧត្តមពោល គឺសម្ពោធិញាណ ។ បទថា **សតិមា** បានដល់ មានសតិប្រកបដោយសតិប្បដ្ឋាន ៤ មួយអន្លើដោយការចងចាំល្អ អាចរឭកដល់វត្ថុដែលធ្វើ និងពាក្យដែលនិយាយយូរហើយបាន ។ បទថា **និបកោ** បានដល់ មានបញ្ញា

រក្សាខ្លួន ព្រោះប្រកបដោយភាពឈ្លាសវៃ ពោល គឺដឹងខ្លួនក្នុងឋានៈ ៧ យ៉ាង និងពោល គឺយល់ក្នុងការរក្សាកម្មដ្ឋាន ។ បទថា **ឈាយី** បានដល់ មានឈានដោយឈាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន ១ លក្ខណូបនិជ្ឈាន ១ ។ បទថា **អប្បមត្តោ** បានដល់ មិនប្រមាទដោយកម្មដ្ឋានភាវនា ដោយន័យជាដើមថា ភិក្ខុរមែងជម្រះចិត្តចាកនីវរណធម៌ ដោយការចង្ក្រម ដោយការអង្គុយអស់ថ្ងៃ ។ បទថា **សំយោជនំ ជាតិជរាយ ឆេត្វា** បានដល់ កាត់នូវកិលេស ១០ យ៉ាង មានកាមរាគៈជាដើម ដែលបានឈ្មោះថា សំយោជនៈ ព្រោះប្រកបសត្វដោយជាតិ និងជរា ចាកឫសគល់ដោយការដកអនុស័យដាច់ហើយ ។ ម្យ៉ាងទៀត បទថា **សំយោជនំ ជាតិជរាយ ឆេត្វា** បានដល់ កាត់កិលេសជាគ្រឿងប្រកបសត្វ ដោយជាតិជរាដាច់ហើយ ។ សេចក្តីពិត បុគ្គលកាត់សំយោជនៈដាច់មិនបាន ក៏គង់កាត់ និងដកជរាមិនបាន តែបុគ្គលដែលកាត់សំយោជនៈបាន ក៏កាត់ជាតិជរាដាច់បាន ព្រោះដកនូវហេតុចេញបាន ព្រោះដូច្នោះ កាលកាត់សំយោជនៈដាច់ ឈ្មោះថា កាត់នូវជាតិជរាដាច់បាន សមដូចព្រះមានព្រះភាគត្រាស់ថា **សំយោជនំ ជាតិជរាយ ឆេត្វា** ដូច្នេះ ។ បទថា **ឥធេវ សម្ពោធិមនុត្តរំ ផុសេ** បានដល់ គប្បីពាល់ត្រូវ គឺគប្បីសម្រេចអរហត្តដ៏កំពូលក្នុងអត្តភាពនេះឯង ។៚

**អដ្ឋកថា អាតាបីសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## បឋមនកុហនាសូត្រ

[ ៣៥ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ មិនមែនដើម្បីកុហកនូវជន មិនមែនដើម្បីរួសរាយចំពោះជន មិនមែនដើម្បីអានិសង្ស គឺលាភសក្ការៈ និងសេចក្តីសរសើរទេ មិនប្រព្រឹត្តព្រហ្មចរិយៈដោយគិតថា មហាជន ចូរស្គាល់នូវអាត្មាអញដូច្នេះឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ តាមពិតនោះ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ ដើម្បីសង្រួមផង ដើម្បីលះបង់ផង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់បានសម្តែងនូវ
ព្រហ្មចរិយៈ ដែលមិនអាងតាមពាក្យគេថា ទីប្រព្រឹត្ត
ទៅ ដើម្បីចុះស៊ប់កាន់ព្រះនិព្វាន ដើម្បីសង្រួម ដើម្បី
លះបង់ នេះជាផ្លូវដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់
មានព្រះអធ្យាស្រ័យដ៏ធំ ស្វែងរកនូវគុណដ៏ធំ ទ្រង់
ប្រតិបត្តិមកហើយ ជនទាំងឡាយណា ដើរតាមផ្លូវ
ដែលព្រះពុទ្ធបានសម្តែងហើយនោះ ឈ្មោះថា ធ្វើតាម
ពាក្យប្រដៅនៃព្រះសាស្តា នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## បឋមនកុហនាសូត្រ

*ក្នុងបឋមមកុហនាសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ៣៥ ] បទថា* **ន** *ក្នុងបទថា* **នយិទំ** *នេះ ជានិបាត ចុះក្នុងអត្ថបដិសេធ ។ បទថា* **ន** *សព្ទ នោះ តជាយបទថា* **វុស្សតិ ។ យ** *អក្ខរៈធ្វើជាបទសន្ធិ ។*

**ឥទំ** *សព្ទ ត្រឹមតែជានិបាត ក្នុងបទជាដើមថា* **ឯកមិទាហំ ភិក្ខវេ សមយំ ឧក្កដ្ឋាយំ វិហរាមិ សុភគវនេ សាលរាជមូលេ** *ម្នាលភិក្ខុទាំង-ឡាយ សម័យមួយ តថាគតនៅក្នុងសុភគវ័ននេះ ទៀបគល់សាលរាជព្រឹក្សនាដែនឧក្កដ្ឋា ។ មកក្នុងការឃើញច្បាស់ក្នុងទីជិត តាមដែលព្រះមានព្រះភាគត្រាស់ជាដើមថា* **ឥទំ ខោ តំ ភិក្ខវេ អប្បមត្តកំ ឱរមត្តកំ សីលមត្តកំ** *ម្នាលភិក្ខុទាំងឡាយ ( បុថុជ្ជនកាលពោលសរសើរគុណរបស់តថាគត ) តែងពោលសរសើរដោយគុណជាតណា គុណជាតនុ៎ះ មានប្រមាណតិច មានប្រមាណស្តួចស្តើង បានត្រឹមតែសីលប៉ុណ្ណោះ ។*

*មកក្នុងការឃើញច្បាស់ក្នុងទីជិត ដូចលោកពោលក្នុងបទជាដើមថា*

**ឥទំ ហិ តំ ជេតវនំ ឥសិសង្ឃនិសេវិតំ**
**អាវុត្ថំ ធម្មរាជេន បីតិសញ្ជននំ មម ។**

*វត្តជេតពននេះ ជាវត្តមានប្រយោជន៍ដែលពួក*
*ឥសី គឺភិក្ខុសង្ឃគង់នៅមិនដាច់ ជាវត្តដែលព្រះ*
*សម្ពុទ្ធជាធម្មរាជ ទ្រង់គង់នៅ ជាទីញុំាងបីតិឲ្យ*

កើតដល់ខ្ញុំព្រះអង្គ ។

ក្នុងទីនេះ គប្បីឃើញក្នុងទីជិត ដូចលោកពោលក្នុងសូត្រនេះ **ព្រហ្មចរិយ** សព្ទ មកក្នុងការឲ្យ ( ទាន ) ដូចក្នុងបុណ្ណកជាតក ( វិធុរជាតក ) ថា អ្វីជាវត្តរបស់ព្រះអង្គ អ្វីជាព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រនាគ ឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើត ( ក្នុងកពនាគ ) ទាំងវិមានធំរបស់ព្រះអង្គនេះ នេះជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយ ដូចម្តេច ។ ខ្ញុំ និងភរិយាទាំង ២ នាក់ ( កាលនៅ ) ក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំដូចជាអណ្តូង ( នៃមហាជន ) ទាំងពួកសមណៈ និងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្ប៉ានគរនោះ បានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសម្នាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក នុ៎ះជាវត្ត នុ៎ះជាព្រហ្មចរិយៈរបស់ខ្ញុំ ដូច្នេះ ។

មកក្នុងអត្ថថា វេយ្យាវច្ចៈ ដូចក្នុងអង្កុរបេតវត្ថុថា អំពីជាតិមុន កាលអ□នៅក□□ារវនគរ មានសីលដូចមេ□ មានសមាចារដូចមេ□ ផលបុណ□ សម្រេចក□□□បសម□□ដោយការប្រព្រឹត□□ព្រហ្មចរិយៈដូចមេ□ ។

ខ្ញុំបានលើកដើមដៃខាងស្តាំ ( បង្ហាញលំនៅនៃអសយ្ហមហាសេដ្ឋីដល់ជនទាំងនោះ ) ថា សេចក្តីចម្រើន ចូរមានដល់អ្នកទាំងឡាយចុះ អ្នកទាំង-ឡាយ ចូរនាំគ្នាទៅក្នុងទីនោះចុះ អសយ្ហមហាសេដ្ឋី តែងឲ្យទានក្នុងទីនុ៎ះ

ដៃរបស់ខ្ញុំអាចឲ្យសម្រេចសេចក្ដីប្រាថ្នាបាន ដោយហេតុនោះ ទើបដៃរបស់ខ្ញុំបញ្ចេញនូវសេផ្អែមបាន ដោយហេតុនោះ បុណ្យក៏សម្រេចក្នុងដៃរបស់ខ្ញុំ ដោយព្រហ្មចរិយៈនោះ ដូច្នេះ ។

មកក្នុងសីល គឺសិក្ខាបទ ៥ ដូចក្នុងតិត្តិរជាតកនេះថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយៈ ( សីល ៥ ) នុ៎ះឯង ឈ្មោះតិត្តិរិយព្រហ្មចរិយៈ ដូច្នេះ ។

មកក្នុងព្រហ្មវិហារ ដូចក្នុងមហាគោវិន្ទសូត្រថា ម្នាលបញ្ចសិខៈ ឯព្រហ្មចរិយធម៌នោះឯង មិនមែនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ ( កិលេស ) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានបានទេ ( គ្រាន់តែឲ្យបានទៅ ) កើតក្នុងព្រហ្មលោកប៉ុណ្ណោះ ដូច្នេះ ។

មកហើយក្នុងមេថុនវិរតិ ដូចក្នុងសល្លេខសូត្រថា ពួកអ្នកត្រូវធ្វើសេចក្ដីជួរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងប្រព្រឹត្តនូវអព្រហ្មចរិយធម៌ក្នុងវត្ថុណា ពួកយើងនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងវត្ថុនោះ ដូច្នេះ ។

មកក្នុងសទារសន្តោស ដូចក្នុងមហាធម្មបាលជាតកថា ពួកយើងមិនប្រព្រឹត្តក្រៅចិត្តភរិយាទេ ទាំងពួកភរិយាក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធម៌ លើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើងមិនស្លាប់ ។

មកក្នុងសេចក្ដីព្យាយាម ដូចក្នុងលោមហំសសូត្រថា ម្នាលសារីបុត្ត

មួយទៀត តថាគតធ្លាប់ប្រព្រឹត្តព្រហ្មចរិយៈ ដែលប្រកបដោយអង្គ ៤ គឺ បើនិយាយពីតបៈ តថាគតជាអ្នកមានតបៈដ៏ក្រៃលែង ... ។

មកហើយក្នុងឧបោសថមានអង្គ ៨ ដែលធ្វើដោយការទូន្មានខ្លួន ដូចក្នុងនិមិជាតក ( នេមិជាតក ) ថា បុគ្គលកើតក្នុងត្រកូលក្សត្រ ដោយព្រហ្មចរិយៈថោកទាប ដល់នូវភាពជាទេវតា ដោយព្រហ្មចរិយៈជាកណ្តាល បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់ ។

មកហើយក្នុងអរិយមគ្គ ដូចក្នុងមហាគោវិន្ទសូត្រនោះឯងថា ម្នាលបញ្ចសិខៈ ព្រហ្មចរិយធម៌របស់តថាគតនេះឯង ទើបរមែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ ( កិលេស ) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានតែមួយយ៉ាង ។បេ។ គឺអរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។

មកហើយក្នុងពាក្យទូន្មាន ( សាសនា ) ទាំងអស់ ដែលស្រោះដោយសិក្ខា ៣ ដូចក្នុងបាសាទិកសូត្រថា ( ម្នាលចុន្ទ ឥឡូវនេះ ) ព្រហ្មចរិយធម៌ ( គឺសាសនា ) របស់តថាគតក៏មាំមួន ផ្សាយទូលាយទៅ មានគេចេះដឹងច្រើន ក្រាស់ក្រែល ទាំងពួកទេវតា និងមនុស្សក៏សម្តែងបានដោយប្រពៃហើយ ។

ក្នុងទីនេះ **ព្រហ្មចរិយ** សព្ទ រមែងប្រព្រឹត្តទៅក្នុងអរិយមគ្គ និងក្នុងពាក្យប្រៀនប្រដៅ ។

បទថា **វុស្សតិ** បានដល់ នៅ អធិប្បាយថា ប្រព្រឹត្ត ។ បទថា

**ជនក្កុហនត្ថំ** បានដល់ ដើម្បីបោកបញ្ឆោតជន គឺសត្វលោក ដោយន័យជាដើមថា ឱ ! លោកម្ចាស់មានសីល សម្បូរដោយវត្ត មានការប្រាថ្នាតិចសន្តោស មានការវិសេសច្រើន មានអំណាចច្រើន ដូច្នេះ ។ បទថា **ជន-លបនត្ថំ** បានដល់ ដើម្បីញុំាងមនុស្សដែលមានចិត្តជ្រះថ្លាថា ទានដែលថ្វាយដល់លោកម្ចាស់បែបនេះ នឹងមានផលច្រើន ឲ្យពោលថា ត្រូវការដោយអ្វី ចូរនាំអ្វីមក ដូច្នេះ ។ បទថា **លាភសក្ការសិលោកានិសំសត្ថំ** បានដល់ ដើម្បីអានិសង្សដែលជាបច្ចុប្បន្ន របស់អ្នកប្រព្រឹត្តព្រហ្មចរិយៈ គឺការបានទូវបច្ច័យ ៤ ដែលលោកពោលដោយភាពជាអានិសង្សរបស់សីលថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ គប្បីទទួលបានថា អញគប្បីបានបរិក្ខារ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជៈ និងសក្ការៈ ដែលបានដល់ការឲ្យបច្ច័យ ៤ ដោយគោរព ទាំងការអើពើ ការរាប់អានច្រើន ការធ្វើសេចក្តីគោរព និងការសរសើរ ដែលបានដល់ការប៉ោងឡើង ការលើកតម្កើង ការមានឈ្មោះបោះសំឡេង ដោយន័យជាដើមថា ភិក្ខុជាអ្នកសម្បូរដោយសីល ជាពហូសូត ជាអ្នកទ្រទ្រង់នូវធុតង្គជាអ្នកប្រារព្ធសេចក្តីព្យាយាម ។ បទថា **ឥតិ មំ ជនោ ជានាតុ** ចង់ជាអត្ថថា ព្រហ្មចរិយៈនេះ ភិក្ខុមិននៅដើម្បីឲ្យគេសរសើរ ដោយគុណដែលមាននៃខ្លួនថា ចូរជនស្គាល់ គឺចូរសរសើរអញជាដើមថា មានការនៅប្រព្រឹត្តព្រហ្ម-ចរិយៈយ៉ាងនេះ ភិក្ខុនេះជាអ្នកទ្រុស្តសីល មានកល្យាណធម៌ តែអាចារ្យពួកខ្លះ ពោលសេចក្តីក្នុងបទនេះយ៉ាងនេះថា បទថា **ជនក្កុហនត្ថំ** បានដល់

កាលភិក្ខុមានសេចក្តីប្រាថ្នាលាមក ប្រាថ្នាច្រើន ដើម្បីនឹងបោកបញ្ឆោតជន ដោយការកុហក ដោយកុហនវត្ថុ ៣ យ៉ាង ពោល គឺរាយមន្ត អាស្រ័យឥរិយាបថ សេពនូវបច្ច័យ ។ បទថា **ជនលបនត្ថំ** បានដល់ កាលភិក្ខុមានសេចក្តីប្រាថ្នាលាមក ដើម្បីជួបនូវជន ដោយពាក្យរៀបរាប់ ឬដោយពាក្យលើកសរសើរ ដោយពោលញញឹមឲ្យគេដឹងអត្ថជាដើម ដើម្បីបច្ច័យ ។ បទថា **លាភសក្ការសិលោកានិសំសត្ថំ** បានដល់ ដើម្បីភិក្ខុមានសេចក្តីប្រាថ្នាលាមក ដើម្បីឲ្យសម្រេចអានិសង្ស ពោល គឺលាភសក្ការៈ សេចក្តីសរសើរ ព្រោះជាអ្នកធ្ងន់ក្នុងលាភជាដើម ។ បទថា **ឥតិ មំ ជនោ ជានាតុ** បានដល់ ដើម្បីការប្រាថ្នាលាមក ភិក្ខុមិននៅប្រព្រឹត្តព្រហ្មចរិយៈ ដោយគិតថា ចូរជនស្គាល់អញយ៉ាងនេះ ដោយបំណងការសរសើរគុណដែលមិនមាន ។ តែសេចក្តីខាងដើម មានសារៈជាង ។

បទថា **អថ** ក្នុងបទថា **អថខោ** នេះ ជានិបាត ចុះក្នុងអត្ថដទៃ ។ បទថា **ខោ** ជានិបាត ចុះក្នុងអវធារណៈ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងថា **ឥទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ** ដូច្នេះ ដែលមានសេចក្តីដទៃចាកការបោកបញ្ឆោតនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់បយោគនោះ ទើបត្រាស់ថា **សំវរត្ថាយ បហានត្ថាយ** ដូច្នេះ ។

ក្នុងបទថា **សំវរត្ថាយ បហានត្ថាយ** នោះ សំវរៈមាន ៥ យ៉ាង គឺ បាដិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយ-

សំវរៈ ១ ។

ក្នុងសំវរៈ ៥ នោះ ដែលឈ្មោះថា បាតិមោក្ខសំវរៈ មកហើយ ដោយន័យជាដើមថា ភិក្ខុចូលដល់ដោយបាតិមោក្ខសំវរៈ ដូច្នេះ បាតិមោក្ខ-សំវរៈនេះ ហៅថា សីលសំវរៈក៏មាន ។

សតិសំវរៈមកហើយក្នុងបទថា ភិក្ខុរមែងរក្សាចក្ខុន្ទ្រិយ គឺដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ដូច្នេះ ។

ញាណសំវរៈនោះ មកហើយក្នុងគាថាថា ម្នាលអជិតៈ សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ដូច្នេះ ។

ខន្តិសំវរៈមកហើយដោយន័យជាដើមថា ភិក្ខុរមែងអត់ធន់ចំពោះត្រជាក់ និងក្តៅ ដូច្នេះ ។

វីរិយសំវរៈនេះមកហើយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលទុកនូវកាមវិតក្កដែលកើតហើយ ដូច្នេះ ។ តែដោយអត្ថ ចេតនា និងវិរតិ ប្រព្រឹត្តទៅហើយ ដោយការលះបាណាតិបាតជាដើម និងដោយការធ្វើវត្តបដិបត្តិដោយសង្ខេប គឺការសង្រួមកាយ និងវាចាទាំងពួង ដោយពិស្តារ គឺការមិនកន្លងកងអាបត្តិ ៧ ឈ្មោះថា សីល-សំវរៈ ។ សតិសំវរៈ គឺសតិនោះឯង ឬកុសលក្ខន្ធដែលមានសតិជាប្រធាន ។ ញាណសំវរៈ គឺញាណនោះឯង ។ កុសលក្ខន្ធដែលប្រព្រឹត្តទៅហើយ ដោយ

ការអត់ធន់ ព្រោះមានអទោសៈជាប្រធាន ឈ្មោះថា ខន្តិសំវរៈ ។ អាចារ្យពួកខ្លះពោលថា បញ្ញា ។ សេចក្តីព្យាយាមដែលប្រព្រឹត្តទៅហើយដោយការអត់ធន់ក្នុងកាមវិតក្កជាដើម ឈ្មោះថា វិរិយសំវរៈ ។ ក្នុងសំវរៈទាំងនោះ គប្បីជ្រាបថា ដំបូងឈ្មោះថា សំវរៈ ព្រោះការពារភាពជាអ្នកទ្រុស្តសីល មានកាយទុច្ចរិតជាដើម ទី ២ ឈ្មោះថា សំវរៈ ព្រោះការពារនូវការវង្វេង ទី ៣ ឈ្មោះថា សំវរៈ ព្រោះការពារនូវការមិនដឹង ទី ៤ ឈ្មោះថា សំវរៈ ព្រោះការពារនូវការមិនអត់ធន់ ទី ៥ ឈ្មោះថា សំវរៈ ព្រោះសង្រួម គឺរាំងនូវការខ្ជិលច្រអូស អធិប្បាយថា ដើម្បីការសង្រួម គឺដើម្បីឲ្យសម្រេចការសង្រួម ដើម្បីប្រយោជន៍ដល់ការសង្រួមនោះ ដោយប្រការដូច្នេះ ។

បហានមាន ៥ យ៉ាង គឺតទង្គប្បហាន ១ វិក្ខម្ភនបហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ក្នុងបហានទាំងនោះ អត្ថដែលគួរពោល បានពោលហើយ ក្នុងអដ្ឋកថាបឋមសូត្រ ឥតិវុត្តកៈ ឯកនិបាតរួចហើយ អធិប្បាយថា ដើម្បីការលះ គឺដើម្បីឲ្យសម្រេចការលះ ដើម្បីជាប្រយោជន៍ដល់ការលះ ព្រោះលះបង់ ឬព្រោះឈានកន្លងនូវកិលេស មានរាគៈជាដើមយ៉ាងនេះយ៉ាងនោះ ទាំង ៥ យ៉ាង ។

ក្នុងបទនោះ កេចិអាចារ្យពោលថា ការហាមកិលេសចូលទៅក្នុងចិត្តសន្តាន ដោយការសង្រួម ការហាមកិលេសចូលទៅក្នុងចិត្តសន្តាន និងការដកដោយបហាន សូម្បីទាំង ២ យ៉ាង គប្បីឃើញថា ទាំង ២ យ៉ាង សម្បូរ

តាមសមគួរ ។ ពិតហើយ ធម៌មានសីលជាដើម ឈ្មោះថា **សំវរ** ព្រោះការសង្រួម ឈ្មោះថា **បហាន** ព្រោះការលះ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **អនីតិហំ** បានដល់ អន្តរាយទាំងឡាយ ទាំងដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ទាំងដែលប្រព្រឹត្តទៅក្នុងសម្បរាយភព លោកហៅថា **ឦតិ** ( ចង្រៃ ) ។ ឈ្មោះថា **ឦតិហំ** ព្រោះព្រហ្មចរិយៈ កម្ចាត់នូវចង្រៃ គឺធ្វើឲ្យវិនាស បានដល់ លះ ។ បទថា **អនុ ឦតិហំ** ជា **អនីតិហំ** គឺកម្ចាត់ចង្រៃទាំងឡាយ បានដល់សាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ម្យ៉ាងទៀត ឧបក្កិលេស មានតណ្ហាជាដើម ឈ្មោះថា **ឦតិហា** ព្រោះនាំទៅ គឺប្រព្រឹត្តទៅដោយចង្រៃទាំងឡាយ ដែលមិនមានប្រយោជន៍ ។ ឈ្មោះថា **អនីតិហំ** ព្រោះមិនមានចង្រៃ ។ លទ្ធិរបស់តិរ្ថិយតាមដែលបានពោលមកហើយ ឈ្មោះថា **ឦតិហា** ព្រហ្មចរិយៈនេះ ឈ្មោះថា **អនីតិហា** ព្រោះផ្ទុយគ្នានឹងលទ្ធិតិរ្ថិយនោះ ។ បាឋៈថា **អនិតិហំ** ដូច្នេះក៏មាន ។ មានអធិប្បាយថា វិចិកិច្ឆា ឈ្មោះថា **ឥតិហា** ព្រោះមានចង្រៃក្នុងធម៌ទាំងឡាយមិនមែនតិច ព្រហ្មចរិយៈ ឈ្មោះថា **អនិតិហា** ព្រោះមិនមានការសង្ស័យ ព្រោះកាលអ្នកបដិបត្តិតាមពាក្យប្រៀនប្រដៅដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសហើយ ជាអ្នកអស់សេចក្តីសង្ស័យ អធិប្បាយថា ព្រហ្មចរិយៈជាអបរប្បច្ច័យ គឺមិនអាស្រ័យវត្ថុដទៃ សមដូចលោកពោលថា ព្រះធម៌ជាអតក្កាវចរ មិនមានវិតក្កជាគ្រឿងកង្វល់ ព្រោះអ្នកប្រាជ្ញគប្បីដឹងឯង ។ ដើម្បីឲ្យងាយក្នុងគាថា កេចិអាចារ្យក៏ពោលពាក្យជាទីយៈថា **អនីតិហំ**

ដូច្នេះ ។

ព្រហ្មចរិយៈ ឈ្មោះថា ជាហេតុឲ្យដល់នូវត្រើយ គឺព្រះនិព្វាន ព្រោះជាហេតុឲ្យដល់ទីបំផុត គឺទីពឹង គឺត្រើយដែលបានដល់និព្វាន អធិប្បាយថា មានវិមុត្តិជារស ព្រោះវិមុត្តិជារស ជាហេតុឲ្យដល់នូវព្រះនិព្វានដោយចំណែកមួយប៉ុណ្ណោះ ។ ព្រហ្មចរិយៈនោះ ជាហេតុឲ្យដល់នូវត្រើយ គឺព្រះនិព្វាន ។ បទថា **សោ** សេចក្តីថា ព្រះមានព្រះភាគអង្គណា ទ្រង់បំពេញបារមី ៣០ ទ្រង់ទម្លាយសព្វកិលេស ហើយទើបត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះមានព្រះភាគអង្គនោះ ទ្រង់បានសម្តែង គឺទ្រង់ចង្អុលបង្ហាញ ។ម្យ៉ាងទៀត លោកពោលអរិយមគ្គថា **និព្វានោគធោ** ឈមចុះកាន់និព្វាន ព្រោះវៀរអរិយមគ្គនោះចេញហើយ នឹងមិនមានការឈមចុះកាន់ព្រះនិព្វានបានឡើយ និងព្រោះអរិយមគ្គនោះ មិនទាក់ទងនឹងព្រះនិព្វានហើយ ប្រព្រឹត្តទៅមិនបាន ម្យ៉ាងទៀត ព្រហ្មចរិយៈនោះ ឈ្មោះថា **និព្វានោគធគាមិ** ព្រោះជាហេតុឲ្យសម្រេចព្រះនិព្វាននោះ ដោយចំណែកមួយ ។ ម្យ៉ាងទៀត បទថា **និព្វានោគធគាមិនំ** បានដល់ ជាហេតុឲ្យដល់ខាងក្នុងព្រះនិព្វាន អធិប្បាយថា មគ្គព្រហ្មចរិយៈ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ហើយទើបប្រព្រឹត្តទៅខាងក្នុងព្រះនិព្វាននោះឯង ។ បទថា **មហាត្តេហិ** បានដល់ ព្រះមានព្រះភាគ ទ្រង់មានខ្លួនធំ គឺមានអធ្យាស្រ័យក្រៃលែង ។ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា ជាអ្នកស្វែងរកគុណធំ ព្រោះស្វែងរកមហានិព្វាន ឬខន្ធមានសីលក្ខន្ធជាដើមដ៏ធំ ។ ព្រះពុទ្ធទាំងឡាយនោះ ទ្រង់យាងទៅហើយ គឺ

បដិបត្តិហើយ ។

បទថា **យថា ពុទ្ធេន ទេសិតំ** សេចក្តីថា ជនពួកណាបដិបត្តិមគ្គព្រហ្ម-ចរិយៈនោះ និងសាសនព្រហ្មចរិយៈ ដែលមានប្រយោជន៍នោះដោយអាការដែលតថាគតជាសម្មាសម្ពុទ្ធសម្តែង មានអភិញ្ញេយ្យធម៌ជាដើម ដោយភាពជាអភិញ្ញេយ្យធម៌ជាដើមនោះឯង ជនទាំងនោះជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ គឺធ្វើតាមឱវាទរបស់តថាគតជាសាស្តា ដែលប្រៀនប្រដៅដោយប្រយោជន៍បច្ចុប្បន្ន និងសម្បរាយភពតាមសមគួរ និងធ្វើទីបំផុត គឺការប្រព្រឹត្តទៅមិនបាននៃវដ្តទុក្ខទាំងមូល ឬនឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតនៃទុក្ខបាន ដោយប្រការដូច្នេះ ។

**អដ្ឋកថា បឋមនកុហនាសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ទុតិយនកុហនាសូត្រ

[ ៣៦ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ មិនមែនដើម្បីកុហកនូវជន មិនមែនដើម្បីរួសរាយចំពោះជន មិនមែនដើម្បីអានិសង្ស គឺលាភសក្ការៈ និងសេចក្តីសរសើរទេ មិនប្រព្រឹត្តព្រហ្ម-ចរិយៈ ដោយគិតថា មហាជន ចូរស្គាល់នូវអាត្មាអញ ដូច្នេះឡើយ ។ ម្នាល

*ភិក្ខុទាំងឡាយ តាមពិតនោះ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ ដើម្បីដឹងផង ដើម្បីកំណត់ដឹងផង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា*

*ព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់បានសម្តែងព្រហ្ម-*
*ចរិយៈ ដែលមិនអាងតាមពាក្យគេថា ទីប្រព្រឹត្តទៅ*
*ដើម្បីចុះស៊ប់កាន់ព្រះនិព្វាន ដើម្បីដឹង ដើម្បីកំណត់ដឹង*
*នេះជាផ្លូវ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់មាន*
*ព្រះអធ្យាស្រ័យធំ ស្វែងរកនូវគុណដ៏ធំទ្រង់ប្រតិបត្តិមក*
*ហើយ ជនទាំងឡាយណា ដើរតាមផ្លូវដែលព្រះពុទ្ធ*
*ទ្រង់សម្តែងហើយនោះ ឈ្មោះថា ធ្វើតាមពាក្យប្រដៅ*
*នៃព្រះសាស្តា នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។*

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៩ ។*

# អដ្ឋកថា

## ទុតិយនកុហនាសូត្រ

*[ ៣៦ ] ក្នុងទុតិយនកុហនាសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **អភិញ្ញត្ថំ** *បានដល់ ដើម្បីការដឹងនូវធម៌ទាំងពួង ដោយចំណែក មានកុសលជាដើម និងដោយចំណែក មានខន្ធជាដើម ដោយមិនវិបរិត ដោយ*

ការដឹងវិសេសក្រៃលែង ។ បទថា **បរិញ្ញត្ថំ** បានដល់ ដើម្បី កំណត់ដឹង ដើម្បីឈានកន្លងនូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយន័យជាដើមថា **ឥទំ ទុក្ខំ** ប្រែថា នេះជាទុក្ខដូច្នេះ ។

ក្នុងបទនោះ ការដឹងក្រៃលែងក្នុងវត្ថុដែលគួរដឹងក្រៃលែង ជាវិស័យនៃអរិយសច្ច ៤ ការដឹងប្រពៃ គឺការកំណត់ដឹង ។ បើការកំណត់ជាវិស័យនៃទុក្ខសច្ចសោត ព្រហ្មចរិយៈ វៀរចាកការត្រាស់ដឹងដោយបហាន សច្ឆិកិរិយា និងភាវនា រមែងប្រព្រឹត្តទៅមិនបាន ។ គប្បីជ្រាបថា ក្នុងទីនេះ លោកបំណងយកបហានជាដើម ។ បទដ៏សេស មានអត្ថតាមដែលបានពោលហើយ ក្នុងសូត្រតាមលំដាប់ ។

**អដ្ឋកថា ទុតិយនកុហនាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សោមនស្សសូត្រ

[ ៣៧ ] ខ្ញុំបានស្តាប់មកហើយថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ រមែងច្រើនដោយសេចក្តីសុខ និងសោមនស្ស ជាអ្នកប្រារព្ធដើម្បីអស់អាសវៈទាំងឡាយ ដោយឧបាយនៃបញ្ញា ក្នុងបច្ចុប្បន្ន ។ ប្រកបដោយធម៌ ២ តើដូចម្តេច ។ គឺប្រកបដោយសេចក្តីសង្វេគក្នុងទីទាំងឡាយ ដែលជាទីតាំងនៃ

សេចក្តីសង្វេគ ១ ប្រកបដោយសេចក្តីព្យាយាម ដោយឧបាយនៃសេចក្តីសង្វេគ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ នេះឯង រមែងច្រើនដោយសេចក្តីសុខ និងសោមនស្ស ជាអ្នកប្រារព្ធ ដើម្បីអស់អាសវៈទាំងឡាយ ដោយឧបាយនៃបញ្ញា ក្នុងបច្ចុប្បន្ន ។ លុះព្រះមានព្រះភាគសម្តែងសេចក្តីនេះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុជាបណ្ឌិត មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស
មានបញ្ញាជាគ្រឿងរក្សាខ្លួន គប្បីសង្វេគក្នុងទីជាទីតាំង
នៃសេចក្តីសង្វេគទាំងឡាយ គប្បីពិចារណាដោយ
បញ្ញា ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ មានព្យាយាម
ជាគ្រឿងដុតកម្តៅកិលេស ប្រព្រឹត្តស្ងប់ មិនរាយមាយ
ប្រកបរឿយៗ នូវចេតោសមថៈហើយ គប្បីដល់នូវ
កិរិយាអស់ទៅនៃទុក្ខបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

បឋមវគ្គ ចប់

## ឧទ្ទាននៃបឋមវគ្គនោះ គឺ

និយាយអំពីភិក្ខុ ប្រកបដោយធម៌ ២ មាន ២ លើក
ធម៌ដុតកម្តៅ ១ ធម៌មិនបានដុតកម្តៅ ១ ប្រយោជន៍
ក្នុងបរលោក មាន ២ លើក ភិក្ខុមានព្យាយាម ជា

គ្រឿងដុតកម្តៅកិលេស ១ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ មិនមែនដើម្បីកុហក មាន ២ លើក ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងមានសេចក្តីសុខ និងសោមនស្ស ១ ទាំងអម្បាលនោះ ត្រូវជា ១០ ។

# អដ្ឋកថា

## សោមនស្សសូត្រ

[ ៣៧ ] ក្នុងសោមនស្សសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សុខសោមនស្សពហុលោ** នេះ មានអធិប្បាយដូច្នេះ បទថា **សុខំ** បានដល់ សុខតាមផ្លូវកាយ ។ បទថា **សោមនស្សំ** បានដល់ សុខតាមផ្លូវចិត្ត ព្រោះដូច្នោះ ទើបលោកពោលថា បុគ្គលដែលមានសុខតាមផ្លូវកាយ និងសុខតាមផ្លូវចិត្ត ប្រព្រឹត្តទៅរឿយៗ ថា ជាអ្នកច្រើនទៅដោយសេចក្តីសុខ និងសោមនស្ស ។

បទថា **យោនិ** មកក្នុងអត្ថថា កំណើត ៤ ដូចក្នុងប្រយោគជាដើមថា **ចតស្សោ ខោ ឥមា សារិបុត្ត យោនិយោ** ម្នាលសារីបុត្ត កំណើត ( របស់សត្វ ) នេះមាន ៤ ដូច្នេះ ។ មកក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **យោនិ ហេសា**[១] **ភូមិជ ផលស្ស អធិគមាយ** ម្នាលភូមិជៈ ព្រោះមាន

១- បិដកខ្មែរជា ហេតុយោនិសោ ។

ទំនងដែលនាំឲ្យត្រាស់ដឹងនូវផលបាន ដូច្នេះ ។ មកក្នុងអត្ថថា ទ្វារប្រសូត ដូចក្នុងប្រយោគជាដើមថា **ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ** តថាគតនឹងហៅអ្នកកើតអំពីកំណើត អ្នកកើតក្នុងផ្ទៃនៃព្រាហ្មណីជាមាតា ថា ជាព្រាហ្មណ៍ក៏ទេ និងដូចប្រយោគមួយគាថាថា

**តមេនំ កម្មជវាតា និព្វត្តិត្វា ឧទ្ធំ បាទំ**
**អធោសិរំ សម្បរិវត្តេត្វា មាតុ យោនិមុខេ សម្បដិបាទេន្តិ ។**

កម្មជវាតកើតឡើង បក់ទារកនោះ ឲ្យមានជើងឡើងលើ
ឲ្យមានក្បាលចុះក្រោម ហើយឲ្យធ្លាក់ទៅក្នុងទ្វារប្រសូតិ
របស់មាតា ដូច្នោះ ។

តែក្នុងទីនេះ លោកបំណងយកហេតុ ។ បទថា **អស្ស** ប្រែថា ដោយ ។ បទថា **អារទ្ធា** បានដល់ តាំងទុក ផ្គងទុក ឬឲ្យសម្រេចចប់រិបូណ៌ ។

ក្នុងបទថា **អាសវានំ ខយាយ** នេះ ឈ្មោះថា អាសវៈ ព្រោះហូរចេញ លោកអធិប្បាយថា អាសវៈទាំងឡាយហូរ គឺផ្សាយចេញតាមភ្នែកខ្លះ ចិត្តខ្លះ ។ ម្យ៉ាងទៀត ឈ្មោះថា អាសវៈ ព្រោះហូរចាកធម៌ដល់គោត្រភូ ចាកឱកាស ដល់ភវគ្គព្រហ្ម អធិប្បាយថា អាសវៈទាំងឡាយធ្វើឱកាសនោះ ក្នុងធម៌ទាំងនោះទុកខាងក្នុងប្រព្រឹត្តទៅ ។ អាការនេះមានសេចក្តីថា ធ្វើទុកខាងក្នុង ។ ឈ្មោះថា អាសវៈ ព្រោះអត្ថថា ត្រាំទុកយូរ ដូចគ្រឿងត្រាំ មានទឹកផ្អែមជាដើម ។ ទឹកផ្អែមជាដើម ដែលសត្វលោកត្រាំទុកយូរ ហៅថា អាសវៈ ។ កិលេសទាំងនេះ គួរជាអាសវៈ ព្រោះអត្ថថា ត្រាំទុកយូរ សម

ដូចព្រះមានព្រះភាគត្រាស់ថា **បុរិមា ភិក្ខវេ កោដិ ន បញ្ញាយតិ អវិជ្ជាយ ឥតោ បុព្វេ អវិជ្ជា នាហោសិ** ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុនអំពីកាលនេះ ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា អាសវៈ ព្រោះហូរទៅ សុះទៅកាន់សង្សារទុក្ខដ៏ទូលាយ ក្នុងទីនេះ មិនមានពាក្យពោលមកអំពីមុន កិលេសទាំងឡាយរមែងប្រកបក្នុងទីដែលពោលដល់អាសវៈ ។ ពាក្យក្រោយរមែងប្រកបទុកសូម្បីក្នុងកម្ម ម្យ៉ាងទៀត អាសវៈទាំងឡាយ មិនមែនជាកម្មកិលេសទាំងអស់ឡើយ ។ អន្តរាយមានប្រការផ្សេងៗ ក៏ជាអាសវៈដោយពិត ដ្បិតថា អាសវៈដែលមកក្នុងអភិធម្ម មាន ៤ យ៉ាង គឺកាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ព្រោះដូច្នោះ កិលេសទាំងឡាយ មានកាមរាគៈជាដើម ក៏ជាអាសវៈ សូម្បីក្នុងព្រះសូត្រ លោកក៏ពោលដល់កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងអកុសលធម៌ដ៏សេស ក្នុងទីនេះថា

> ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីរាំងនូវអាសវៈ
> ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន តែមួយយ៉ាង
> ដល់ពួកអ្នកទេ ... ដូច្នេះ ។

ក្នុងបទនេះថា **ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ** ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយជាបច្ចុប្បន្ន ១ ដើម្បីឃាត់ហាមនូវអាសវៈទាំងឡាយដែលនឹងមានទៅខាងមុខ ១ ដូច្នេះ ។ លោកសម្តែងដល់ការចូលទៅបៀតបៀនអ្នកដទៃ ធ្វើឲ្យអ្នកដទៃក្តៅក្រហាយ

*ការសម្លាប់ ការចងជាដើម និងអន្តរាយមានប្រការផ្សេងៗ ដែលជាទុក្ខក្នុងអបាយ អាសវៈទាំងនោះ មកក្នុងវិន័យ ២ យ៉ាង គឺដើម្បីការពារនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់អាសវៈទាំងឡាយដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ១ ។ អាសវៈមកក្នុងសឡាយតនសំវរសូត្រ ៣ យ៉ាង ដូចក្នុងបាលីជាដើមថា* **តយោ មេ អាវុសោ អាសវា កាមាសវោ ភវាសវោ អវិជ្ជាសវោ** *ម្នាលអាវុសោទាំងឡាយ អាសវៈនេះមាន ៣ គឺ កាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ដូច្នេះ ។ ក្នុងសូត្រដទៃក៏យ៉ាងនោះ ។ ក្នុងអភិធម្មអាសវៈ ៣ រួមជា ៤ ដោយថែមទិដ្ឋាសវៈ ដោយការសម្តែងដើម្បីឲ្យដឹង អាសវៈមាន ៥ យ៉ាង គឺអាសវៈនាំសត្វទៅនរកក៏មាន ១ អាសវៈនាំសត្វទៅកាន់កំណើតតិរច្ឆានក៏មាន ១ អាសវៈនាំសត្វទៅកាន់បេតវិស័យក៏មាន ១ អាសវៈនាំសត្វទៅកាន់មនុស្សលោកក៏មាន ១ អាសវៈនាំសត្វទៅកាន់ទេវលោកក៏មាន ១ តែក្នុងទីនេះ លោកបំណងយកកម្មប៉ុណ្ណោះជាអាសវៈ ក្នុងឆក្កនិបាត អាសវៈមាន៦ យ៉ាង ដោយន័យជាដើមថា* **អត្ថិ អាសវា សំវរា បហាតព្វា** *អាសវៈទាំងឡាយគប្បីលះព្រោះការសង្រួមក៏មាន ដោយការសម្តែងដល់ការសង្រួមអាសវៈទាំងពួង អាសវៈទាំងនោះមាន ៧ យ៉ាង រួមគ្នានឹងធម៌ដែលទស្សនៈគប្បីលះ ។ តែក្នុងទីនេះ ដោយការសម្តែងក្នុងអភិធម្ម គប្បីជ្រាបថា លោកបំណងយកអាសវៈ ៤ ។*

*ក្នុងបទថា* **ខយាយ** *នេះ ការទម្លាយអាសវៈទាំងឡាយ មួយអន្ទើដោយរស ក្នុងបទថា អាសវៈអស់ទៅ វិនាសទៅ បែកទៅ ទម្លាយទៅ ការ*

មិនទៀង ការអន្តរធាន លោកពោលថា ការអស់ទៅនៃអាសវៈទាំងឡាយ ។

**ខយ** សព្ទ មកក្នុងអត្ថថា អាការអស់ទៅ ការមិនមាន ការអស់ ការមិនកើតនៃអាសវៈទាំងឡាយ ដូចក្នុងប្រយោគនេះថា **ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈធម៌ទាំងឡាយ របស់បុគ្គលអ្នកដឹង អ្នកឃើញ ... ដូច្នេះ ។ មកក្នុងអត្ថថា អរិយមគ្គដែលអស់នៃអាសវៈ ដូចក្នុងប្រយោគជាដើមថា

**សេក្ខស្ស សិក្ខមានស្ស ឧជុមគ្គានុសារិនោ**
**ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា ។**

ញាណជាបឋម ក្នុងកិរិយាអស់ទៅ កើតឡើងដល់សេក្ខ-
បុគ្គល អ្នកកំពុងសិក្សា អ្នករឭករឿយៗ នូវផ្លូវដ៏ត្រង់ ...
ដូច្នេះ ។

មកក្នុងអត្ថថា ផល ដូចក្នុងប្រយោគជាដើមថា **អាសវានំ ខយា សមណោ ហោតិ** ជាសមណៈព្រោះអស់នូវអាសវៈទាំងឡាយ ដូច្នេះ ។ មកក្នុងអត្ថថានិព្វាន ដូចក្នុងប្រយោគជាដើមថា

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**
**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

កាលបុគ្គលគយយ៉ាំមើលទោស របស់បុគ្គលដទៃជាប្រក្រតី
មានការសម្គាល់ហេតុក្នុងការពោលទោស ( អ្នកដទៃ ) ជា

និច្ចជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែង ចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីធម៌ ជាគ្រឿងអស់អាសវៈ ដូច្នេះ ។

ក្នុងសូត្រនេះ លោកពោលថា **អាសវាធំ ១យ៉ាង** សំដៅដល់ ផល អធិប្បាយថា ដើម្បីជាប្រយោជន៍ដល់អរហត្តផល ។

បទថា **សំវេជនីយេសុ ឋានេសុ** បានដល់ ក្នុងឋានៈដែលឲ្យកើត សេចក្តីសង្វេគ គឺក្នុងវត្ថុដែលគួរសង្វេគ មានជាតិជាដើម វត្ថុដែលគួរសង្វេគ ទាំងនេះ គឺជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខ អតីតវដ្តមូលទុក្ខ អនាគត វដ្តមូលទុក្ខ ទុក្ខព្រោះការស្វែងរកអាហារក្នុងបច្ចុប្បន្ន ឈ្មោះថា ឋានៈដែល ជាទីតាំងនៃសេចក្តីសង្វេគ ។ ម្យ៉ាងទៀត គប្បីជ្រាបបទទាំងឡាយ មានយ៉ាង នេះថា លោកសន្និវាសត្រូវភ្លើងឆេះសព្វហើយ ... មានសេចក្តីខ្វល់ខ្វាយ (ជានិច្ច) ... មានដំណើរទៅ ( ជានិច្ច ) ... ដើរទៅកាន់ផ្លូវខុស ... សត្វលោក មិនទៀង ត្រូវជរានាំចូលទៅ ( រកសេចក្តីស្លាប់ ) ... សត្វលោកឥតមាន ទីពឹង ឥតមានទីផ្អែក ... គ្មានអ្វីជារបស់ខ្លួន ត្រូវលះបោលរបស់ទាំងអស់ ហើយទៅ ... មានសេចក្តីខ្វះខាត មិនឆ្អែត ជាទាសៈនៃតណ្ហា[១] ... ដូច្នេះ ឈ្មោះថា ឋានៈដែលឲ្យកើតសេចក្តីសង្វេគក្នុងទីនេះ ។ បទថា **សំវេជនេន** បានដល់ ដោយការសង្វេគ ដែលបានដល់ការខ្វាចកើត អាស្រ័យវត្ថុដែល គួរសង្វេគ មានជាតិជាដើម ។ តែដោយអត្ថ ញាណ មួយអន្លើដោយ

---

១- សេចក្តីពិស្តារមានក្នុងបដិសម្ភិទាមគ្គ ប. ៦៩ ទំ. ២៨៤ ។

ឱត្តប្បៈ ឈ្មោះថា សេចក្តីសង្វេគ ។ បទថា **សំវេគស្ស** បានដល់ កើតនូវសេចក្តីសង្វេគ ព្រោះទុក្ខមានជាតិជាដើមច្រើនយ៉ាង រាប់តាំងអំពីឈមចុះកាន់គភ៌ជាដើម ។ អាចារ្យពួកខ្លះពោលថា **សំវេជិត** ក៏មាន ។ បទថា **យោនិសោ បធានេន** បានដល់ ដោយសេចក្តីព្យាយាមដោយឧបាយ គឺដោយការព្យាយាមប្រពៃ ។ ពិតហើយ សម្មាវាយាមៈនោះ លោកពោលថាជាប្រធាន ព្រោះជាទីតាំងនៃសេចក្តីព្យាយាម និងព្រោះឲ្យសម្រេចភាវនាថ្នាក់ខ្ពស់ ដូចបុគ្គលដែលលះអកុសលធម៌បាន បណ្តាកុសលធម៌ រមែងធ្វើការភាវនាឲ្យបរិបូណ៌ ដូច្នោះ ។

ក្នុងបទនោះ ភិក្ខុមិនឃើញទីជ្រកកោន ទីពួន ទីពឹងណាក្នុងភពជាដើមដោយសេចក្តីសង្វេគ មិនជាប់ក្នុងភពនោះ មានចិត្តមិនជាប់ជំពាក់ និងអស់នូវការអាល័យក្នុងការដែលនឹងបែរត្រឡប់ទៅ ព្រោះជាបដិបក្ខចំពោះវត្ថុនោះទើបជាបុគ្គលបង្អោនទៅដើម្បីព្រះនិព្វាន ឱនទៅដើម្បីនិព្វាន ទោរទន់ទៅដើម្បីព្រះនិព្វាន ឈមទៅដើម្បីព្រះនិព្វានដោយពិត ។ ភិក្ខុនោះ ជាអ្នកច្រើនទៅដោយយោនិសោមនសិការ ព្រោះអាស្រ័យកល្យាណមិត្ត ជាអ្នកប្រកបទៅដោយអជ្ឈាស្រ័យបរិសុទ្ធ ជាអ្នកប្រកប និងខ្វល់ខ្វាយនៅក្នុងសមថ-វិបស្សនា រមែងនឿយណាយក្នុងសង្ខារទាំងពួង ខ្វល់ខ្វាយឲ្យកើតវិបស្សនា ។ ការដែលភិក្ខុច្រើនដោយយោនិសោមនសិការ ជាអ្នកប្រកបទៅដោយអជ្ឈា-ស្រ័យបរិសុទ្ធ ជាអ្នកប្រកប និងខ្វល់ខ្វាយនៅក្នុងសមថៈ និងវិបស្សនានេះគប្បីជ្រាបភាពជាអ្នកច្រើនទៅដោយសុខ និងសោមនស្សក្នុងបច្ចុប្បន្ននោះឯង

*ដោយហេតុដែលភិក្ខុជាអ្នកតាំងនៅក្នុងសមថៈ ជាអ្នកប្រកបសេចក្ដីខ្វល់ខ្វាយក្នុងវិបស្សនា រមែងនឿយណាយក្នុងសង្ខារទាំងពួង ខ្វល់ខ្វាយឲ្យកើតវិបស្សនានោះ គប្បីជ្រាបថា ជាអ្នកប្រារព្ធហេតុ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។*

*ក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយដូចតទៅនេះ បទថា* **សមិជេ-យ្យ** *បានដល់ គប្បីសង្កេត គឺគប្បីធ្វើនូវការសង្កេតនោះឯង ។ អាចារ្យពួកខ្លះពោលថា* **សមិជិតាន** *ដូច្នេះក៏មាន អធិប្បាយថា ជាអ្នកមានការសង្កេតតាមន័យដែលពោលហើយ ។ បទថា* **បណ្ឌិតោ** *បានដល់ ជាអ្នកមានបញ្ញា អធិប្បាយថា បានដល់ តិហេតុកបដិសន្ធិ ។ បទថា* **បញ្ញាយ សមវេក្ខិយ** *បានដល់ ពិចារណាសង្កេតវត្ថុ ដោយការសង្កេតដោយប្រពៃដោយបញ្ញា ។ម្យ៉ាងទៀត ពិចារណាហើយដោយប្រពៃដោយបញ្ញា បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។*

**អដ្ឋកថា សោមនស្សសូត្រទី ១០ ចប់**

**បឋមវគ្គទី ១**

# សុត្តន្តបិដក

## ឥតិវុត្តក ទុកនិបាត ទុតិយវគ្គ

### វិតក្កសូត្រ

[ ៣៨ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ វិតក្កមាន ២ យ៉ាង គឺខេមវិតក្ក ( វិតក្កប្រកបដោយករុណាជាដើម ) ១ វិវេកវិតក្ក ( វិតក្កប្រកបដោយវិវេក ) ១ តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអ្នករីករាយ ក្នុងសេចក្តីមិនព្យាបាទ ត្រេកអរហើយ ក្នុងសេចក្តីមិនព្យាបាទ ម្នាលភិក្ខុទាំងឡាយ វិតក្កនេះឯង តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគតនោះ ដែលជាអ្នករីករាយ ក្នុងសេចក្តីមិនព្យាបាទ ត្រេកអរក្នុងសេចក្តីមិនព្យាបាទថា តថាគតមិនបានបៀតបៀនសត្វណាមួយ ដែលនៅតក់ស្លុត ឬដែលនឹងធឹង ដោយសេចក្តីប្រព្រឹត្ត ( កាយប្រយោគ ឬវចីប្រយោគ ) នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នករីករាយក្នុងវិវេក ត្រេកអរក្នុងវិវេក ម្នាលភិក្ខុទាំងឡាយ វិតក្កនេះឯង តែងផុសផុលឡើងជាច្រើន ចំពោះព្រះតថាគតនោះ ដែលជាអ្នករីករាយក្នុងវិវេក ត្រេកអរក្នុងវិវេកថា អកុសលនោះ តថាគតបានលះអស់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គួររីករាយក្នុងសេចក្តីមិនព្យាបាទ ត្រេកអរក្នុងសេចក្តីមិនព្យាបាទចុះ ម្នាលភិក្ខុទាំងឡាយ វិតក្កនេះឯង នឹងផុសផុលឡើងជាច្រើន ចំពោះ

អ្នកទាំងឡាយនោះ ដែលរីករាយ ក្នុងសេចក្តីមិនព្យាបាទ ត្រេកអរក្នុងសេចក្តីមិនព្យាបាទថា យើងទាំងឡាយ មិនបៀតបៀនសត្វណាមួយ ដែលតក់ស្លុត ឬដែលនឹងធឹង ដោយសេចក្តីប្រព្រឹត្តនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររីករាយក្នុងវិវេក ចូរត្រេកអរក្នុងវិវេកចុះ ម្នាលភិក្ខុទាំងឡាយ វិតក្កនេះឯង នឹងផុសផុលឡើងជាច្រើន ចំពោះអ្នកទាំងឡាយនោះ ដែលរីករាយក្នុងវិវេក ត្រេកអរក្នុងវិវេកថា អ្វីជាអកុសល អ្វីដែលយើងមិនទាន់លះបង់ យើងលះបង់អ្វី ។ លុះព្រះមានព្រះភាគទ្រង់សម្តែង សេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

វិតក្ក ២ យ៉ាង គឺខេមវិតក្កទី ១ ដែលព្រះអង្គទ្រង់សម្តែងហើយ តអំពីនោះ វិវេកវិតក្កទី ២ ដែលព្រះអង្គទ្រង់ប្រកាសហើយ តែងផុសផុលឡើង ចំពោះព្រះតថាគត ជាព្រះពុទ្ធ ដែលបុគ្គលដទៃ គ្របសង្កត់មិនបាន ។ តថាគតហៅបុគ្គលអ្នកបន្ទោបង់នូវងងឹត ដល់នូវត្រើយ ស្វែងរកនូវគុណដ៏ធំ ដល់នូវសេចក្តីត្រាស់ដឹង ស្ងាត់ ( ក្នុងឈាន ) មិនមានអាសវៈ ឆ្លងនូវពិសគឺកិលេស រួចស្រឡះហើយ ព្រោះការអស់តណ្ហានោះឯង ថាជាអ្នកប្រាជ្ញ ទ្រទ្រង់នូវកាយ ជាទីបំផុត កម្ចាត់បង់នូវមារ ដល់នូវត្រើយនៃជរា ។ បុគ្គលឈរលើកំពូលភ្នំ ជាវិការនៃថ្មសុទ្ធ គប្បីឃើញនូវប្រជុំជន

ដោយជុំវិញ មានឧបមាដូចម្តេចមិញ លោកអ្នកមាន
បញ្ញាល្អ មានចក្ខុជុំវិញ មានសេចក្តីសោកទៅប្រាស
ហើយ គប្បីឡើងកាន់ប្រាសាទជាវិការនៃធម៌ រមែង
ឃើញនូវប្រជុំជន ដែលមានសេចក្តីសោក មិនទាន់
ឆ្លងហើយ មានជាតិ និងជរាគ្របសង្កត់ហើយ ក៏មាន
ឧបមេយ្យដូច្នោះដែរ ។

ខ្ញុំបានស្តាប់មកថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុក ហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## វិតក្កសូត្រ

ក្នុងវិតក្កសូត្រទី ១ នៃវគ្គទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៣៨ ] **តថាគត** សព្វ ក្នុងបទថា **តថាគតំ ភិក្ខវេ** នេះ រមែងប្រាកដក្នុងវោហារថា សត្វ និងសម្មាសម្ពុទ្ធជាដើម ។ ប្រាកដក្នុងវោហារថា សត្វ ដូចក្នុងបទជាដើមថា **ហោតិ តថាគតោ បរម្មរណា** សត្វលុះរំលាយខន្ធទៅខាងមុខអំពីសេចក្តីស្លាប់ ... ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សម្មាសម្ពុទ្ធ** ដូចក្នុងប្រយោគជាដើមថា

**តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ។**

*យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មក ហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ដូច្នេះ ។*

*ប្រាកដក្នុងអត្ថថា* **ធម្មំ** *ដូចក្នុងប្រយោគជាដើមថា*

**តថាគតំ ទេវមនុស្សបូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ។**

*យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌ ដែលមានមកហើយដូចគ្នា ដែលមនុស្ស និងទេវតាតែងបូជា សូមមានសិរីសួស្តី ដូច្នេះ ។*

*ប្រាកដក្នុងអត្ថថា* **សង្ឃ** *ដូចក្នុងប្រយោគជាដើមថា*

**តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ។**

*យើងទាំងឡាយ សូមនមស្ការនូវព្រះសង្ឃ ដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ដូច្នេះ ។*

*តែក្នុងទីនេះ ប្រាកដក្នុងអត្ថថា* **សម្មាសម្ពុទ្ធ** *ព្រោះដូច្នោះ ក្នុងបទថា* **តថាគតំ** *នេះ លោកពោលដល់ព្រះមានព្រះភាគថា ជាតថាគតដោយហេតុ ៨ ប្រការ ។ ហេតុ ៨ ប្រការដូចម្តេច ។ ឈ្មោះថា* **តថាគត** *ព្រោះយាងមកយ៉ាងនោះ ។ ឈ្មោះថា* **តថាគត** *ព្រោះយាងទៅយ៉ាងនោះ ។ ឈ្មោះថា* **តថាគត** *ព្រោះដឹងលក្ខណៈដែលពិត ។ ឈ្មោះថា* **តថាគត** *ព្រោះត្រាស់ដឹងធម៌ដែលពិត ដោយសេចក្តីពិត ។ ឈ្មោះថា* **តថាគត** *ព្រោះទ្រង់ឃើញការពិត ។ ឈ្មោះថា* **តថាគត** *ព្រោះទ្រង់ទូន្មានវត្ថុ ដែលពិត ។ ឈ្មោះថា* **តថាគត** *ព្រោះទ្រង់ធ្វើតែការពិត ។ ឈ្មោះថា* **តថាគត** *ព្រោះអត្ថថា ទ្រង់គ្របសង្កត់ ។*

សួរថា ព្រះមានព្រះភាគឈ្មោះថា **តថាគត** ព្រោះយាងមកយ៉ាងនោះដូចម្ដេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់បំពេញទានបារមី ទ្រង់បំពេញនូវសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់បរិច្ចាគមហាបរិច្ចាគទាំង ៥ នេះ គឺបរិច្ចាគអវយវៈ ១ បរិច្ចាគខ្លួន ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគកិរិយា ១ បរិច្ចាគរាជសម្បត្តិ ១ ដោយទំនងដូចគ្នា ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយមានព្រះវិបស្សីជាដើមយាងមកយ៉ាងណា សូម្បីព្រះមានព្រះភាគនៃយើង ក៏យាងមកយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** សមដូចលោកពោលថា

**យថេវ លោកម្ហិ វិបស្សិ អាទយោ**
**សព្វញ្ញុភាវំ មុនយោ ឥធាគតា**
**តថា អយំ សក្យមុនីបិ អាគតោ**
**តថាគតោ វុច្ចតិ តេន ចក្ខុមា។**

ព្រះមុនីទាំងឡាយ មានព្រះវិបស្សីជាដើម យាងមកកាន់ភាពជាសព្វញ្ញូក្នុងលោកនេះយ៉ាងណា សូម្បីព្រះសក្យមុនី ក៏យាងមកយ៉ាងនោះដូចគ្នា ដោយហេតុនោះ ព្រះមានព្រះភាគមានចក្ខុ ទើបឈ្មោះថា **តថាគត** ដូច្នេះ ។

ព្រះមានព្រះភាគ យាងមកយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា

**តថាគត** ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅយ៉ាងនោះ ដូចម្ដេច ឆ្លើយថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម ដែលប្រសូតភ្លាម កាលប្រតិស្ឋានព្រះបាទទាំង ២ លើផែនដី ហើយទ្រង់បែរព្រះភក្ត្រទៅទិសឧត្តរ ឈាន ៧ ជំហាន យ៉ាងណា សូម្បីព្រះមានព្រះភាគនៃយើង ក៏យាងទៅយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** សមដូចលោកពោលថា

**មុហុត្តជាតោវ គវម្បតិ យថា**
**សមេហិ បាទេហិ ផុសី វសុន្ធរំ ។**
**សោ វិក្កមី សត្ត បទានិ គោតមោ**
**សេតញ្ច ឆត្តំ អនុធារយុំ មរូ ។**
**គន្ត្វាន សោ សត្ត បទានិ គោតមោ**
**ទិសា វិលោកេសិ សមា សមន្តតោ ។**
**អដ្ឋង្គុបេតំ គិរមព្ភុទីរយិ**
**សីហោ យថា បព្វតមុទ្ធនិដ្ឋិតោ ។**

ព្រះពុទ្ធព្រះនាមថា **គវម្បតិ** ប្រសូតក្នុងកាលឥឡូវនេះ ទ្រង់ជាន់ផែនដី ដោយព្រះបាទទាំងគូស្មើគ្នា យ៉ាងណា ព្រះគោតមនោះ ក៏ដូច្នោះ ទ្រង់ឈានព្រះបាទបាន ៧ ជំហាន ពួកទេវតានាំគ្នាបាំងស្វេតច្ឆត្រ កាលព្រះអង្គយាងទៅបាន ៧ ជំហានហើយ ទ្រង់ឈប់

សម្លឹងមើលទិសស្មើគ្នាដោយជុំវិញ ទ្រង់បន្លឺព្រះវាចាប្រកបដោយអង្គ ៨ ដូចរាជសីហ៍ឈរលើកំពូលភ្នំ ដូច្នោះ ។

ព្រះមានព្រះភាគយាងទៅយ៉ាងនោះ ទើបឈ្មោះថា **តថាគត** ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងនូវលក្ខណៈដែលពិតដូចម្តេច ឆ្លើយថា ទ្រង់ដឹងសាមញ្ញលក្ខណៈ មួយអន្លើដោយលក្ខណៈនៃរូបធម៌ និងអរូបធម៌ទាំងពួង ។ ពិតហើយ គឺទ្រង់សម្រេចដោយញាណគតិ ត្រាស់ដឹងមិនខុស ព្រោះដូច្នោះ ទើបឈ្មោះថា **តថាគត** ។ សមដូចលោកពោលថា

**សព្វេសំ បន ធម្មានំ សកសាមញ្ញលក្ខណំ**
**តថមេវាគតោ យស្មា តស្មា ជាថោ តថាគតោ ។**

ព្រះមានព្រះភាគ ជានាថ ទ្រង់ដឹងសាមញ្ញលក្ខណៈរបស់ខ្លួននៃធម៌ទាំងពួងដោយពិតនោះឯង ដូច្នោះ ទើបឈ្មោះថា **តថាគត** ។

ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងលក្ខណៈដែលពិតដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងធម៌ដែលពិត ដោយជារបស់ពិតដូចម្តេច ឆ្លើយថា អរិយសច្ច ៤ ឈ្មោះថា ធម៌ដែលពិត សមដូចព្រះតម្រាស់ថា **ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ កតមានិ ចត្តារិ ឥទំ ទុក្ខំ អរិយសច្ចន្តិ ភិក្ខវេ អថមេតំ អវិតថមេតំ**

**អធញ្ញការមត់** ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ អរិយសច្ច ៤ គឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ទុក្ខនេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ គប្បីជ្រាបពិស្តារតទៅថា ព្រះមានព្រះភាគត្រាស់ដឹងនូវអរិយសច្ចទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងនូវធម៌ពិត ។ ព្រោះ **គត** សព្ទ ក្នុងទីនេះ មានអត្ថថា ត្រាស់ដឹងក្រៃលែង ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងធម៌ពិត ដោយសេចក្ដីពិត ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញពិតដូចម្ដេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់ដឹង ទ្រង់ឃើញដោយអាការទាំងពួងនូវរូបារម្មណ៍ដែលមកតាមចក្ខុទ្វារនៃសត្វទាំងឡាយ ប្រមាណមិនបានក្នុងលោកធាតុ ដែលមិនមានប្រមាណ ក្នុងទេវលោក មួយអន្លើដោយមនុស្សលោក កាលទ្រង់ដឹង ទ្រង់ឃើញយ៉ាងនេះ ទ្រង់ចែករូបារម្មណ៍នោះ ដោយអារម្មណ៍គួរប្រាថ្នាជាដើម ឬដោយការបានបទ ព្រោះទិដ្ឋៈ សុតៈ មុតៈ វិញ្ញាតៈ ដោយន័យជាដើមថា រូបដែលសម្ដែងពណ៌ អាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តទៅដោយការប៉ះខ្ទប់ មានពណ៌ខៀវ ពណ៌លឿង ជារូបារម្មណ៍ដូចម្ដេច ដោយឈ្មោះសន្ទឹកសន្ទាប់ ឬដោយ ១៣ វារៈ ឬដោយ ៥២ ន័យ ជាសេចក្ដីពិតនោះឯង មិនពិតមិនមាន ។ ក្នុងសំឡេងជាដើម ដែលមកតាមសោតទ្វារក៏មានន័យដូច្នេះ សមដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះ មិនស្ថិតនៅក្នុងតថាគតទេ ។

ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ឃើញពិត ។ គប្បីជ្រាបអត្ថនៃបទថា **តថាគតោ** ក្នុងអត្ថថា ឃើញនូវសេចក្ដីពិតក្នុងទីនេះ ។ សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ទូន្មានវត្ថុដែលពិតដូចម្ដេច ឆ្លើយថា រហូតរាត្រីណា ព្រះមានព្រះភាគ ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដរាបអស់រាត្រីណា ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងរវាងនេះ ពាក្យទូន្មាន មានសុត្តៈ គេយ្យៈជាដើមណា ដែលព្រះមានព្រះភាគបានត្រាស់ហើយ អស់កាល ៤៥ វស្សា ទាំងអស់នោះបរិសុទ្ធបរិបូណ៌ ញាំញីនូវការស្រវឹងក្នុងរាគៈជាដើម ដែលជារបស់ពិតប្រាកដដូចគ្នា ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលចុន្ទ តថាគតត្រាស់ដឹង នូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេស-និព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្ដែងហៅ

ចន្លុលបង្ហាញនូវហេតុណា ក្នុងចន្លោះនុ៎ះ ហេតុទាំងអស់ នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បានជាគេហៅថា **ព្រះតថាគត ។**

**គត** សព្ទ ក្នុងទីនេះ មានអត្ថថា ពោល ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ទូន្មាននូវវត្ថុដែលពិត ។ម្យ៉ាងទៀត ការ ពោល ឈ្មោះថា **អាគទ** អធិប្បាយថា ពាក្យពោល ។ គប្បីជ្រាបបទ សម្រេច ក្នុងទីនេះ យ៉ាងនេះថា ឈ្មោះថា **តថាគតោ** ផ្លាស់ **ទ** ជា **ត** ក្នុង បទថា **តថោ អវិបរិតោ អាគតោ អស្ស** មានវាចាពិត មិនប្រែប្រួល ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ធ្វើតែការពិត ដូចម្តេច ឆ្លើយថា ពិតហើយ កាយរបស់ព្រះមានព្រះភាគ រមែងអនុលោម តាមវាចា សូម្បីវាចាក៏អនុលោមតាមកាយ ព្រោះដូច្នោះ ព្រះមានព្រះភាគ ជាអ្នកពោលយ៉ាងណា ធ្វើយ៉ាងនោះ និងធ្វើយ៉ាងណា ពោលយ៉ាងនោះ កាលព្រះអង្គពោលវាចាយ៉ាងណា សូម្បីកាយក៏ទៅ គឺប្រព្រឹត្តទៅយ៉ាងនោះ និងកាយយ៉ាងណា វាចាក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យថាវាទី ភិក្ខវេ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ តថាគតថាយ៉ាង ណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនេះ ថាយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ថាយ៉ាងនោះ ហេតុនោះ ទើបបានជាគេហៅថា **តថាគត ។**

ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ធ្វើតែការពិត ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះអត្ថថា ទ្រង់គ្របសង្កត់ដូចម្ដេច ឆ្លើយថា ព្រោះព្រះមានព្រះភាគ ទ្រង់ធ្វើភវគ្គព្រហ្មទុកខាងលើ ធ្វើអវីចីទុកខាងក្រោម ទ្រង់គ្របសង្កត់សព្វសត្វក្នុងលោកធាតុមិនមានប្រមាណក្នុងទទឹង គុណរបស់ទ្រង់ថ្លឹង ឬវាស់មិនបាន ដោយសីលក្ដី សមាធិក្ដី បញ្ញាក្ដី វិមុត្តិក្ដី វិមុត្តិញ្ញាណទស្សនៈក្ដី ដោយពិត ទ្រង់កាលបុគ្គលថ្លឹងមិនបាន វាស់មិនបាន ជាទេវតាក្រៃលែងជាងទេវតា មិនមានទេវតាក្រៃលែងជាង ជាសក្កៈក្រៃលែងជាងសក្កៈទាំងឡាយ ជាព្រហ្មក្រៃលែងជាងព្រហ្មទាំងឡាយ ឧត្តមជាងសត្វទាំងពួង ព្រោះដូច្នោះ ទើបឈ្មោះថា **តថាគត** ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

**សទេវកេ ភិក្ខវេ លោកេ។បេ។ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ តស្មា តថាគតោតិ វុច្ចតីតិ។**

ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ អង់អាច ជាអ្នកឃើញពិត មានអំណាចគ្របសង្កត់លោក ព្រមទាំងទេវលោក ។បេ។ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសបាន ហេតុនោះ បានជាគេហៅថា តថាគត ។ នេះជាបទសម្រេចក្នុងសេចក្ដីនោះ ពាក្យពោលក៏ដូចឱសថ ជាលីលានៃទេសនា និងជា

ការសន្សំបុណ្យ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគអង្គនោះ
មានអានុភាពច្រើន ញាំញីនូវពាក្យជំទាស់ទាំងអស់ និងលោក
ព្រមទាំងទេវលោក ដូចគ្រូឱសថបង្រ្កាបពស់ដោយថ្នាំទិព្វ ដូច្នោះ។

ព្រះមានព្រះភាគ មានពាក្យពោលវិសេសតាម ដែលពោលហើយ ជាពាក្យពិតមិនប្រែប្រួល ក្នុងការគ្របសង្កត់សត្វលោកទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបថា ឈ្មោះថា **តថាគតោ** ព្រោះផ្លាស់ **ឧ** ជា **ត** ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ឈ្មោះថា តថាគត ព្រោះ អត្ថថា ទ្រង់គ្របសង្កត់ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **តថាគត** ព្រោះដឹង គឺត្រាស់ដឹងដោយសេចក្តីពិត អធិប្បាយថា ឈ្មោះថា **តថាគត** ព្រោះដឹង គឺដឹងនូវលោកទាំងមូល ដោយតីរណបរិញ្ញាដែលពិត ។ ឈ្មោះថា **តថាគត** ព្រោះលះលោក-សមុទយៈ ដោយបហានបរិញ្ញាដែលពិត ។ ឈ្មោះថា **តថាគត** ព្រោះសម្រេចលោកនិរោធ គឺរម្ងត់តណ្ហាដែលជាហេតុឲ្យកើតលោក ដោយការធ្វើឲ្យជាក់ច្បាស់ដែលពិត ។ ឈ្មោះថា **តថាគត** ព្រោះទ្រង់ទៅ គឺបដិបត្តិលោកនិរោធគាមិនីបដិបទា ដោយភាវនាដែលពិត សមដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបានត្រាស់
ដឹងហើយ តថាគតផុតចាកលោក ( គឺទុក្ខសច្ច ) ហើយ
ម្នាលភិក្ខុទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹង

ហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ តថាគតបានត្រាស់ដឹងហើយ លោកនិរោធ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោកនិរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោក ព្រមទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ត្រាច់រង្គាត់ រកអារម្មណ៍នោះ តថាគតបានដឹងជាក់ស្តែងហើយដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា **តថាគត** ដូច្នេះ ។

ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ដោយហេតុ ៨ ប្រការទៀត គឺឈ្មោះថា **តថាគត** ព្រោះយាងមកដើម្បីសេចក្តីពិត ឈ្មោះថា **តថាគត** ព្រោះយាងទៅដើម្បីសេចក្តីពិត ឈ្មោះថា **តថាគត** ព្រោះទ្រង់ត្រាស់ដឹងនូវសេចក្តីពិត ឈ្មោះថា **តថាគត** ព្រោះយាងទៅយ៉ាងនោះ ឈ្មោះថា **តថាគត** ព្រោះដូចគ្នាយ៉ាងនោះ ឈ្មោះថា **តថាគត** ព្រោះប្រព្រឹត្តទៅយ៉ាងនោះ ឈ្មោះថា **តថាគត** ព្រោះមិនយាងទៅចាកសេចក្តីពិត ឈ្មោះថា **តថាគត** ព្រោះព្រះអង្គយាងទៅយ៉ាងនោះ ។ សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងមកដើម្បីសេចក្តីពិតដូចម្តេច ឆ្លើយថា មហាបដិញ្ញាឯណា ដែល

ព្រះមានព្រះភាគជាសុមេធតាបស បានបំពេញអភិនីហារ ដែលប្រកបដោយគុណ ៨ ប្រការ ដូចបានពោលហើយយ៉ាងនេះថា

*អភិនីហាររមែងសម្រេច ព្រោះដល់ព្រមដោយធម៌ ៨ ប្រការ គឺ កាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១ ការជួបព្រះសាស្តា ១ បព្វជ្ជា ១ ការដល់ព្រមដោយគុណ ១ អធិការ ១ ការមានឆន្ទៈ ១ ដូច្នេះ ។*

ឲ្យប្រព្រឹត្តទៅហើយ ក្នុងបាទមូលរបស់ព្រះពុទ្ធទីបង្ករទសពលថា បើអញឆ្លងលោក ព្រមទាំងទេវលោកហើយ នឹងញុំាងសត្វឲ្យឆ្លងផង អញផុតហើយ នឹងញុំាងសត្វឲ្យផុតផង អញទូន្មានហើយ នឹងញុំាងសត្វឲ្យទូន្មានផង អញរួចស្រឡះហើយ នឹងញុំាងសត្វឲ្យរួចស្រឡះផង អញបរិនិព្វានហើយ នឹងញុំាងសត្វឲ្យបរិនិព្វានផង ដូច្នេះ ។ សមដូចលោកពោលថា

*តែថា ប្រយោជន៍អ្វីអាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោក ព្រមទាំងទេវលោកឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញជាបុរសសម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើនដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ គឋាគតនឹងកាត់ខ្សែ*

សង្សារ កម្ចាត់បង់កពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។

ព្រះមានព្រះភាគ ជាលោកនាថ ទ្រង់មិនពោលឲ្យខុសមហាបដ្ឋានោះ ដែលជាហេតុនៃការពិចារណា និងសមាទានដែលជាប្រកពកើតនៃធម៌ ដែលធ្វើឲ្យបានជាព្រះពុទ្ធទាំងអស់ ព្រោះព្រះអង្គបំពេញបារមី ៣០ មានទានបារមីជាដើម ដោយគ្រប់បរិបូណ៌ជាលំដាប់ ដោយសេចក្ដីគោរព ដរាបអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ទ្រង់បំពេញមហាបរិច្ចាគ ៥ មានបរិច្ចាគអវយវៈជាដើម ទ្រង់ចម្រើនអធិដ្ឋាន ៤ មានសច្ចាធិដ្ឋានជាដើម ទ្រង់សន្សំបុញ្ញសម្ភារ និងញាណសម្ភារ ទ្រង់ញុំាងសេចក្ដីព្យាយាមខាងដើម ប្រព្រឹត្តធម៌ខាងដើម ទ្រង់ប្រាប់ធម៌ និងទ្រង់ប្រព្រឹត្តជាប្រយោជន៍ដល់ញាតិជាដើម ឲ្យល្អក្រៃលែង ទ្រង់សម្រេចពុទ្ធចរិយា ដែលជាទីបំផុតក្រៃលែងហើយ ទើបត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដូច្នោះ មហាបដ្ឋានោះ របស់ព្រះមានព្រះភាគ ទើបពិត មិនជាដទៃ ការមិនពិត សូម្បីត្រឹមចុងរោមទ្រាយមិនមានដល់ព្រះមានព្រះភាគអង្គនោះ ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធទាំង ២៤ អង្គ គឺព្រះទីបង្ករទសពល ព្រះកោណ្ឌញ្ញៈ ព្រះសុមង្គល ព្រះកស្សបៈ ទ្រង់កើតហើយតាមលំដាប់ បានព្យាករសុមេធតាបសនោះថា នឹងបានជាព្រះពុទ្ធ ដូច្នេះ ព្រះមានព្រះភាគបានទទួលព្យាករក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយ ២៤ អង្គយ៉ាងនេះ កាលទ្រង់បានទទួលអានិសង្សដែលព្រះពោធិសត្វទាំងឡាយដែលបំពេញបារមី គួរបានហើយ ទើបយាងមក ព្រោះហេតុនោះ

ទើបឈ្មោះថា **តថាគត** ព្រោះមក គឺសម្រេចភាពជាអ្នកត្រាស់ដឹងក្រៃលែង ដោយសេចក្តីពិត ដែលជាមហាអភិញ្ញា ដូចបានពោលហើយនោះ ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងមកដើម្បីសេចក្តីពិត ដោយប្រការដូច្នេះ ។ សួរថា ព្រះព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅដើម្បីសេចក្តីពិតដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគជាលោកនាថ ទ្រង់ឃើញនូវសត្វបានទទួលទុក្ខធំ និងការចង្អៀតចង្អល់ ទ្រង់តាំងព្រះហឫទ័យថា មិនមានអ្នកដទៃជាទីពឹងរបស់ពួកសត្វនោះបាន អញប៉ុណ្ណោះដែលឆ្លងផុតហើយចាកសង្សារទុក្ខនេះ អញនឹងឲ្យពួកសត្វទាំងនោះឆ្លងផុតដែរ ដូច្នេះ ទើបទ្រង់បំពេញបារមីធំក្រៃលែង ដោយមហាករុណា ។ កាលទ្រង់បំពេញហើយ ទ្រង់ខ្វល់ខ្វាយដើម្បីឲ្យកើតប្រយោជន៍ដល់សត្វលោកទាំងមូល តាមដែលទ្រង់តាំងបណិធាន មិនជាប់ជំពាក់ក្នុងរាងកាយ និងជីវិត ទ្រង់បំពេញទុក្ករកិរិយា ដែលធ្វើបានលំបាកក្រៃលែង ឲ្យចិត្តកើតនូវការតក់ស្លុត ដោយហេតុត្រឹមតែអ្នកដទៃបានឮ បានស្តាប់ ទ្រង់បដិបត្តិដោយប្រការដែលបដិបត្តិរបស់មហាពោធិសត្វទាំងឡាយ ដែលជាចំណែកនៃការលះ ឬជាចំណែកនៃការសៅហ្មង ឬជាចំណែកនៃការតាំងនៅក៏មិនមែន ដែលពិតនោះ នៅមានចំណែកដ៏វិសេសក្រៃលែងទៀត ទើបទ្រង់សមោធានពោធិសម្ភារ មិនឲ្យមានសេសសល់តាមលំដាប់ ហើយសម្រេចសម្ពោធិញ្ញាណដ៏ក្រៃលែង ។ បន្ទាប់អំពីនោះ ទ្រង់រង់ចាំជាស់តឿនអ្នកដទៃដោយព្រះមហាករុណានោះ ទ្រង់លះនូវការត្រេកអរក្នុងការស្ងាត់ និងសេចក្តីសុខ គឺការរួចផុតដ៏ស្ងប់ក្រៃលែង ទ្រង់

មិនពិចារណាដល់ការសរសើរ ការមើលងាយ និងការខុសប្រក្រតី ដែលជនទាំងនោះ ធ្វើឲ្យកើតឡើងក្នុងលោក ដែលច្រើនដោយជនពាល ទ្រង់សម្រេចពុទ្ធកិច្ច មិនមានសេសសល់ ដោយការដឹកនាំវេនេយ្យជន ។ អាការដែលព្រះមានព្រះភាគ ទ្រង់កាន់យកដល់ដោយព្រះករុណាក្នុងសត្វទាំងឡាយក្នុងពុទ្ធកិច្ចនោះ នឹងមានច្បាស់ខាងមុខ ។ ព្រះមហាករុណាក្នុងសត្វទាំងឡាយរបស់ព្រះលោកនាថដែលជាព្រះពុទ្ធ យ៉ាងណា សូម្បីរបស់បុគ្គលដែលជាពោធិសត្វ ក៏យ៉ាងនោះ ជារបស់ពិត មិនជាដទៃ ព្រោះដូចគ្នាក្នុងសូត្រទាំងពួង មានមហាកិនីហារកាលសូត្រជាដើម និងដោយប្រការទាំងពួង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅ គឺប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់លោកទាំងមូល ដោយមហាករុណាដែលពិត មានរសស្មើគ្នា ក្នុងសព្វសត្វ ដែលមិនមានកំណត់ សូម្បីត្រឹមតែ ៣ ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅដើម្បីការពិត ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងសេចក្តីពិតដូចម្តេច ឆ្លើយថា អរិយមគ្គញ្ញាណ ៤ ឈ្មោះថា **សេចក្តីពិត** ។ ពិតហើយ អរិយមគ្គញ្ញាណទាំងនោះ ឈ្មោះថា **ពិត** មិនដទៃឡើយ ព្រោះមិនខុសសភាវៈ និងលក្ខណៈ ព្រមដោយរសរបស់អរិយសច្ច ៤ ដែលជាហេតុនៃការប្រព្រឹត្តទៅ ការត្រឡប់ទៅ និងទាំង ២ យ៉ាងនោះ សមោធានធម៌ដែលគួរដឹងទាំងអស់យ៉ាងនេះថា នេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះការរម្ងត់

ទុក្ខ នេះបដិបទាឲ្យដល់ការរម្ងត់ទុក្ខ និងរបស់ធម៌ទាំងឡាយ ដើម្បីការប្រព្រឹត្តទៅ ដោយការមិនវិបរិត ដែលបានដល់ការមិនវង្វេង និងការត្រាស់ដឹងក្នុងអរិយមគ្គញាណនោះ ដែលបានដោយការកាត់ផ្ដាច់ចំណែកដែលសៅហ្មងត្រាស់ដឹង ទាក់ទងនឹងសភាវៈតាមសេចក្ដីពិត ដែលមានវិភាគនៃអរិយ-មគ្គញាណនោះជាដើមថា ទុក្ខ មានការបៀតបៀន តាក់តែង ដុត ប្រែប្រួលជាអត្ថ សមុទយៈ មានការខ្វល់ខ្វាយជាហេតុ ពាក់ព័ន្ធជាប់ជំពាក់ជាអត្ថនិរោធ ជាគ្រឿងរលាស់ចេញ ស្ងាត់ចាកកិលេស មិនតាក់តែងអមតៈជាអត្ថមគ្គ នាំចេញទៅជាហេតុ ជាទស្សនៈ ជាអធិបតីជាអត្ថ ដូច្នេះ ។ ព្រះមានព្រះភាគ មិនមានអ្នកដទៃណែនាំ ទ្រង់ដឹង គឺសម្រេចអរិយមគ្គញាណនោះដោយព្រះអង្គឯង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ឈ្មោះថា **តថាគត** និងត្រាស់ដឹងតាមសេចក្ដីពិត ។

មគ្គញាណគួរឲ្យជាក់ច្បាស់ ដោយប្រការណា អប្បដិហតញ្ញាណ គឺញាណដែលមិនមានអ្វីរាំងបាន ចតុបដិសម្ភិទាញាណ ចតុវេសារជ្ជញ្ញាណ បញ្ចគតិបរិច្ឆេទញ្ញាណ គឺញាណកំណត់គតិ ៥ ឆអសាធារណញ្ញាណ សត្តពោជ្ឈង្គវិភាវនញ្ញាណ គឺញាណដែលធ្វើឲ្យជាក់ច្បាស់នូវពោជ្ឈង្គ ៧ អដ្ឋមគ្គង្គវិភាវនញ្ញាណ គឺញាណដែលធ្វើឲ្យជាក់ច្បាស់នូវអង្គនៃមគ្គ ៨ នវានុបុព្វវិហារសមាបត្តិញ្ញាណ គឺញាណក្នុងការចូលអនុបុព្វវិហារ ៩ និងទសពលញ្ញាណនៃព្រះមានព្រះភាគ គួរឲ្យជាក់ច្បាស់ក្នុងកាល ៣ ។ ក្នុងមគ្គញាណនោះ គួរដឹងណាមួយ មានសភាវកិច្ចជាដើម មានទីនៅវិសេស

ជាដើម និងមាននាម និងគោត្រ ដែលទាក់ទងដោយខន្ធជាដើម ក្នុងខន្ធ ធាតុ អាយតនៈ ដែលជាអតីត ដែលផ្សេងគ្នា មានថោកទាបជាដើម របស់សត្វ ដែលផ្សេងគ្នា មានអំពើអាក្រក់ជាដើម ដែលមិនមានប្រមាណ ក្នុងលោក-ធាតុ ដែលមិនមានប្រមាណ ។ ម្យ៉ាងទៀត ព្រះញាណរបស់ព្រះមានព្រះភាគ មិនមានអ្វីរាំងឡើយ ក្នុងសេចក្ដីវិសេស មានវណ្ណៈ សណ្ឋាន ក្លិន រស និងផស្សៈជាដើមរបស់រូបធម៌ ដែលកើតឡើងព្រោះបច្ច័យនោះៗ ក្នុងរូបធម៌ទាំងឡាយដែលល្អិតក្រៃលែង តាំងនៅខាងក្នុង និងនៅឆ្ងាយ ដែលទាក់ទងដោយអនិន្ទ្រិយ រមែងប្រព្រឹត្តទៅ ដោយប្រចក្សក្នុងទីទាំងពួង ដូចកន្ទួតព្រៃ ដែលដាក់លើបាតដៃ ។ ញាណទាំងនេះ គឺញាណក្នុងអនាគត និងបច្ចុប្បន្ន ក៏យ៉ាងនោះ ឈ្មោះថា **អប្បដិហតញ្ញាណ** ក្នុងកាល ៣ ដូចលោកពោលថា ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរាំងក្នុងអតីតកាល ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរាំង ក្នុងអនាគតកាល ញាណរបស់ព្រះពុទ្ធ មិនមានអ្វីរាំងក្នុងបច្ចុប្បន្នកាល ។ ញាណទាំងនោះ ឈ្មោះថា **តថ** មិនជាដទៃឡើយ ព្រោះមិនខុសអំពីសភាវលក្ខណៈ មួយអន្លើដោយរសនៃធម៌ទាំងឡាយ ក្នុងញាណនោះៗ ព្រះមានព្រះភាគទ្រង់សម្រេចញាណទាំងនោះដោយសយម្ភូ ទើបឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បដិសម្ភិទាមាន ៤ គឺអត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ។

ក្នុងបដិសម្ភិទា ៤ នោះ ញាណដែលជាប្រភេទនៃអត្ថ ដើម្បីអាចធ្វើឲ្យ

ជាក់ច្បាស់ និងកំណត់ព្រមដោយលក្ខណៈរបស់ប្រភេទនៃអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ញាណដែលកើតក្នុងធម៌ អាចធ្វើឲ្យជាក់ច្បាស់ និងកំណត់ដោយលក្ខណៈនៃប្រភេទរបស់ធម៌ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ញាណដែលប្រព្រឹត្តទៅក្នុងការយល់ភាសា អាចធ្វើឲ្យជាក់ច្បាស់ និងកំណត់ព្រមដោយលក្ខណៈ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ញាណដែលប្រព្រឹត្តទៅក្នុងបដិភាណ ដើម្បីធ្វើឲ្យជាក់ច្បាស់ និងកំណត់ដោយលក្ខណៈនៃប្រភេទរបស់បដិភាណ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ សមដូចព្រះមានព្រះភាគត្រាស់ថា

*សេចក្តីដឹងក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថ និងធម៌នោះឈ្មោះថា និរុត្តិប្បដិសម្ភិទា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ដូច្នេះ ។*

ក្នុងអត្ថប្បដិសម្ភិទានេះ ដោយសង្ខេប ផលរបស់ហេតុ ឈ្មោះថា **អត្ថ** ព្រោះមិនមានទុក្ខ និងព្រោះគួរដល់ក្រៃលែង តែដោយប្រភេទ ធម៌ ៥ យ៉ាង គឺធម៌ណា ដែលអាស្រ័យបច្ច័យកើតឡើង ១ ធម៌រម្ងាត់កិលេស ១ ពាក្យពោលដែលមានប្រយោជន៍ ១ វិបាក ១ កិរិយា ១ ឈ្មោះថា **អត្ថ** ។ ញាណដែលជាប្រភេទនៃអត្ថនោះ របស់អ្នកពិចារណាអត្ថនោះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ដោយសង្ខេប បច្ច័យ ឈ្មោះថា **ធម៌** ព្រោះបច្ច័យនោះរមែងជាក់ច្បាស់ រមែងឲ្យប្រព្រឹត្ត និងរមែងឲ្យសម្រេចដល់ប្រយោជន៍នោះៗ ដូច្នោះ ទើបលោកហៅថា **ធម៌** តែដោយប្រភេទ ធម៌ ៥ យ៉ាង គឺការកើត

នៃផលណាមួយ ហេតុ ១ អរិយមគ្គ ១ ពាក្យដែលជាភាសិត ១ កុសល ១ ឈ្មោះថា **ធម៌** ញាណដែលជាប្រភេទក្នុងធម៌នោះ របស់អ្នកពិចារណាធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ សេចក្តីនេះ ក៏លោកពោលថា

សេចក្តីដឹងក្នុងទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថា អត្ថប្បដិសម្ភិទា សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ។

ការដឹងក្នុងហេតុ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងផលរបស់ហេតុ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ធម៌ពួកណាកើតហើយ ចម្រើនហើយ កើតព្រមហើយ កើតឡើងហើយ កើតឡើងក្រៃលែងហើយ ប្រាកដហើយ ការដឹងក្នុងធម៌ទាំងនេះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ធម៌ទាំងនោះកើតហើយ ចម្រើនហើយ កើតព្រមហើយ កើតឡើងហើយ កើតឡើងក្រៃលែងហើយ ចាកធម៌ណា ការដឹងក្នុងធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងជរា និងមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ការដឹងក្នុងហេតុកើតជរា និងមរណៈ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងការរលត់ជរា និងមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ការដឹងក្នុងបដិបទាឲ្យដល់នូវការរលត់ជរា និងមរណៈ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងជាតិ ក្នុងភព ក្នុងឧបាទាន ក្នុងតណ្ហា ក្នុងវេទនា ក្នុងផស្សៈ ក្នុងសឡាយតនៈ ក្នុងនាមរូប ក្នុងវិញ្ញាណ ក្នុងសង្ខារទាំងឡាយ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ការដឹងក្នុងហេតុកើតរបស់សង្ខារ

ឈ្មោះថា **ធម្មប្បដិសម្ភិទា** ការដឹងក្នុងការវម្មត់សង្ខារ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ការដឹងក្នុងបដិបទាឲ្យដល់នូវការវម្មត់សង្ខារ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ( ក្នុងវិភង្គក៏លោកពោលទៀតថា )

ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ នេះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ភិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះៗ ថា នេះ សេចក្តីនៃភាសិតនេះ នេះ សេចក្តីនៃភាសិតនេះនេះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ដូច្នេះ ។

ពួកធម៌ជាកុសល តើដូចម្តេច ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រកបដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ ហើយកើតឡើង ក្នុងសម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះពួកធម៌ជាកុសល សេចក្តីដឹងក្នុងធម៌ទាំងឡាយនេះ ឈ្មោះថា ធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងវិបាកនៃធម៌ទាំងឡាយនោះ ឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។

គប្បីជ្រាបសេចក្តីពិស្តារដូចតទៅនេះថា

ភាសាតាមសភាវៈ គឺពាក្យពោលដែលជាសេចក្តីពិតក្នុងអត្ថ និងក្នុងធម៌នោះ ការដឹងដែលជាប្រភេទរបស់ភាសាតាមតំបន់របស់សត្វទាំងពួង ក្នុងការពោលភាសាតាមសភាវៈ ដោយភាសាមគធៈថា នេះជាភាសាតាមសភាវៈ

នេះមិនមែនភាសាតាមសភាវៈ ដូច្នេះ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ការដឹងក្នុងញាណរបស់អ្នកពិចារណា ធ្វើនូវញាណទាំងអស់ ដែលប្រព្រឹត្តទៅហើយដោយពិស្តារ ដោយគោចរកិច្ច ក្នុងញាណទាំងនោះ តាមដែលពោលហើយក្នុងអារម្មណ៍ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ បដិសម្ភិទាញាណទាំង ៤ នេះ ដែលព្រះមានព្រះភាគទ្រង់សម្រេចដោយព្រះអង្គឯង ទើបជារបស់ពិតរបស់មែន មិនជារបស់ដទៃ ព្រោះមិនប្រព្រឹត្តទៅក្នុងការប្រែប្រួល ដោយមិនខុសក្នុងវិស័យរបស់ខ្លួននោះៗ មានអត្ថ និងធម៌ជាដើម ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះដឹងតាមសេចក្តីពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ដឹង ទ្រង់ឃើញ ទ្រង់សម្រេច ទ្រង់ត្រាស់ដឹងក្រៃលែងដល់បទដែលគួរដឹកនាំទាំងពួងនោះ ដោយអាការទាំងអស់ពិតហើយ ព្រះមានព្រះភាគ ត្រាស់ដឹងនូវអភិញ្ញេយ្យធម៌ ព្រោះជាធម៌ដែលគួរដឹងក្រៃលែង ត្រាស់ដឹងបរិញ្ញេយ្យធម៌ ព្រោះជាធម៌ដែលគួរកំណត់ដឹង ត្រាស់ដឹងនូវបហាតព្វធម៌ ព្រោះជាធម៌ដែលគួរលះ ត្រាស់ដឹងនូវសច្ឆិកាតព្វធម៌ ព្រោះជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងភាវេតព្វធម៌ ព្រោះជាធម៌ដែលគួរធ្វើឲ្យចម្រើន ដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចបង្អាច់ព្រះអង្គ ដោយភាពជាធម៌បានថា ធម៌ទាំងនេះ ព្រះមានព្រះភាគមិនទាន់បានត្រាស់ដឹង ដូច្នេះ ។

ឈ្មោះថា **បហាតព្វធម៌** បានដល់ អនុប្បត្តិធម៌ទាំងពួង ដែលព្រះសម្មាសម្ពុទ្ធទ្រង់លះបានហើយ ត្រង់មណ្ឌលពោធិព្រឹក្ស ដោយមិនមាន

សេសសល់ មិនមានកិច្ចដែលត្រូវធ្វើក្រៃលែងជាង ដើម្បីលះបហាតពួធម៌នោះទៀត ពិតហើយ កិលេស ១៥០០ មានលោភៈ ទោសៈ មោហៈ ការដាក់ចិត្ត វិបរិត ការមិនខ្មាស ការមិនខ្លាចបាប ការងើកឆ្មុយ ការក្រោធ ការចងសេចក្តីក្រោធ ការលុបគុណ ការវាយស្មើ ការប្រណែន ការកំណាញ់ មាយា អួតអាង មុខរឹង ប្រណាំងវាសនា ប្រកាន់ខ្លួន មើលងាយ ស្រវឹង ប្រមាទ អកុសលមូល ៣ ទុច្ចរិត វិបល្លាស មន្ទិល វិតក្ក ការបោកបញ្ឆោត ការស្វែងរក តណ្ហា ការស្វែងរកខុស ៤ យ៉ាង អាសវៈ គន្ថៈ ឱឃៈ យោគៈ អគតិ ការប្រកាន់ព្រោះតណ្ហា នីវរណៈ ៥ ការវិនាសផ្លូវចិត្ត ការពាក់ព័ន្ធផ្លូវចិត្ត វិវាទមូល ៦ អនុស័យ ៧ មិច្ឆត្តៈ ៨ អឃាតវត្ថុ ៩ ឫសគល់តណ្ហា អកុសលកម្មបថ ១០ ការស្វែងរកមិនសមគួរ ២១ ទិដ្ឋិ ៦២ តណ្ហាវិបរិត ១០៨ ព្រះមានព្រះភាគទ្រង់លះ ទ្រង់កាត់ផ្តាច់ ទ្រង់ដកបាន មួយអន្លើដោយវាសនា ដែលសមណៈ ។បេ។ ឬព្រាហ្មណ៍ណាមួយ មិនអាចបង្អាប់ព្រះអង្គ ដោយភាពជាធម៌បានថា កិលេសទាំងនេះ ព្រះមានព្រះភាគ ទ្រង់មិនទាន់លះបាន ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់ដល់អន្តរាយិកធម៌ មានកម្ម វិបាក កិលេស ការពោលទោស ការកន្លងល្មើសអាជ្ញា ថាគួរអន្តរាយដោយចំណែកមួយ ដែលសមណៈ ។បេ។ ឬព្រាហ្មណ៍ណាមួយ មិនអាចបង្អាប់ព្រះអង្គបានថា អន្តរាយិកធម៌នោះ មិនគួរអន្តរាយ ដោយការសេព ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ជាគ្រឿងនាំចេញចាកទុក្ខដ៏កំពូល មានអរិយមគ្គជា

អណ្តាប់ដំបូង មាន ៧ ចំណែក ជា ៣៧ ប្រភេទ សង្គ្រោះដោយសីល សមាធិ បញ្ញា ដើម្បីការរលាស់ចេញចាកវដ្តទុក្ខដោយមិនសេសសល់ ធម៌នោះ តែងនាំអ្នកបដិបត្តិចេញចាកវដ្តទុក្ខដោយចំណែកមួយ ដែលសមណៈ ឬព្រាហ្មណ៍ ។បេ។ ឬព្រហ្មណាមួយ មិនអាចបង្អាប់ព្រះអង្គ ដោយភាពជាធម៌បានថា ធម៌ជាគ្រឿងនាំចេញទុក្ខដែលទ្រង់សម្តែង មិននាំចេញពិត ដូច្នេះ ។ ដូចមានអ្នកពោលថា កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ដឹងធម៌ទាំងនោះ ព្រះអង្គមិនបានត្រាស់ដឹងធម៌ទាំងនេះពិត ដូច្នេះ ។ គប្បីជ្រាបសេចក្តីពិស្តារតទៅ

ចតុវេសារជ្ជញ្ញាណរបស់ព្រះមានព្រះភាគប្រព្រឹត្តទៅហើយ ដោយអាការមិនវិបរិត ព្រោះត្រាស់ដឹងនូវសេចក្តីពិតរបស់សេចក្តីវិសេស នៃញាណបហាន និងទេសនារបស់ព្រះអង្គ ឈ្មោះថា ពិតប្រាកដ មិនដទៃ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងការពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គតិមាន ៥ យ៉ាង គឺនិរយគតិ ១ តិរច្ឆានគតិ ១ បេតគតិ ១ មនុស្សគតិ ១ ទេវគតិ ១ ក្នុងគតិ ៥ នោះ គតិទាំងអស់ គឺមហានរក ៨ រណ្តៅ មានសញ្ជីវនរកជាដើម ឧស្សទនរក ១៦ រណ្តៅ មានកុក្កុលនរក ( នរកផេះក្តៅ ) ជាដើម និងលោកន្តរនរក ឈ្មោះថា **នរក** ព្រោះមិនមានការត្រេកអរ មានតែទុក្ខដោយចំណែកមួយ និងឈ្មោះថា គតិ ព្រោះត្រូវទៅដោយកម្មរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា **និរយគតិ** មានសីតនរកដែលងងឹត ក៏សង្គ្រោះចូលក្នុងនរកទាំងនោះ ។ សត្វទាំងឡាយ

មានដង្កូវ កណ្តូប ពស់ បក្សី ឆ្កែ ឆ្កែចចកជាដើម ឈ្មោះថា **តិរច្ឆាន** ព្រោះជាសត្វទៅទទឹង ។ តិរច្ឆានគតិ ព្រោះទៅកាន់ភាពជាតិរច្ឆាននោះឯង ។ ឈ្មោះថា **បេត** ព្រោះប្រេតទាំងឡាយ មានបរទត្តូបជីវិប្រេត និងនិជ្ឈាមតណ្ហិកប្រេតជាដើម មានតែការស្រេកឃ្លាន គឺប្រាសចាកសេចក្តីសុខ ច្រើនទៅដោយសេចក្តីទុក្ខ ឈ្មោះថា **បេតគតិ** ព្រោះទៅកាន់ភាពជាប្រេតនោះឯង ។ ពួកអសុរ មានកាលកញ្ចិកាសុរជាដើម ក៏នៅក្នុងប្រេតទាំងនោះ ។

នៅក្នុងមហាទ្វីប ៤ មានជម្ពូទ្វីបជាដើម និងបុគ្គលនៅក្នុងទ្វីបតូចៗ ឈ្មោះថា **មនុស្ស** ព្រោះជាអ្នកមានចិត្តខ្ពស់ ។ ឈ្មោះថា **មនុស្សគតិ** ព្រោះទៅកាន់ភាពជាមនុស្សនោះឯង ។

ពួកទេវតា ២៦ ជាន់ គឺតាំងអំពីចាតុម្មហារាជិកា រហូតដល់ទេវតាដែលបាននេវសញ្ញានាសញ្ញាយតនៈ រមែងត្រេកអរ គឺលេងកីឡា និងរុងរឿងដោយឫទ្ធានុភាពរបស់ខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវ** ឈ្មោះថា **ទេវគតិ** ព្រោះទៅកាន់ភាពជាទេវតានោះឯង ។

គតិទាំងនេះ ព្រោះផ្សេងគ្នានៃឧប្បត្តិភព ដែលកើតដោយកម្មវដ្តនោះៗ ដូច្នោះ ដោយអត្ថ បានដល់ វិបាកក្ខន្ធ និងកដត្តារូប ( រូបដែលកើតអំពីកម្ម ) ។ ក្នុងគតិនោះ ញាណរបស់ព្រះមានព្រះភាគ រមែងប្រព្រឹត្តទៅដោយឋានៈ ដោយហេតុ ដោយអំណាចហេតុផល ការចែក និងការកំណត់តាមអំណាចថា គតិឈ្មោះនេះ រមែងកើតដោយកម្មឈ្មោះនេះ ពួកសត្វទាំងនេះផ្សេងគ្នា ដោយការចែកយ៉ាងនេះ ជាចំណែកមួយ ព្រោះកម្មនោះផ្សេងគ្នា

ដោយការចែកយ៉ាងនេះ ដោយការផ្សេងគ្នានៃបច្ច័យ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា

ម្នាលសារីបុត្ត គតិនេះ មាន ៥ ប្រការ គតិ ៥ ប្រការ តើដូចម្តេច គឺនរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។ ម្នាលសារីបុត្ត តថាគតស្គាល់នរកផង ស្គាល់ផ្លូវជាទីទៅកាន់នរកផង ស្គាល់សេចក្តីប្រត្រិបត្តិ ជាទីទៅកាន់នករផង ឯបុគ្គលប្រតិបត្តិយ៉ាងណាហើយ លុះបែកធ្លាយរាងកាយខាងមុខ អំពីសេចក្តីស្លាប់ ទៅរមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក តថាគតស្គាល់ ច្បាស់នូវប្រតិបត្តិនោះផង ។

ញាណទាំងឡាយរបស់ព្រះមានព្រះភាគ ឈ្មោះថា ជាញាណពិតប្រាកដ មិនជាទេ ព្រោះមិនខុសក្លាំងក្លាត់ ដោយការប្រព្រឹត្តទៅនៃអាការវិបរិត ក្នុងវិស័យនោះៗ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងពិត ដោយប្រការដូច្នេះ ។

មយ៉ាងទៀត ការប្រកាសការផ្សេងគ្នា មានភាពជាបុគ្គលមានធូលី គឺកិលេសតិច និងធូលី គឺកិលេសច្រើនជាដើម ដោយការត្រាស់ដឹងដល់ការខ្ទះខាតនៃយោគៈ មានសទ្ធាជាដើមរបស់សត្វទាំងឡាយ ប្រព្រឹត្តទៅហើយដោយអាការ ៥០ ទុំះ ជាបដិភាណកំណត់ដឹងនូវការទន់ខ្សោយ និងចាស់ក្លានៃឥន្ទ្រិយរបស់ព្រះមានព្រះភាគ ។ សមដូចពោលថា បុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលឥតសទ្ធា ឈ្មោះថា

អ្នកមានធូលីច្រើនក្នុងភ្នែក ដូច្នេះ ។

គប្បីជ្រាបសេចក្តីពិស្តារដូចតទៅនេះថា អធ្យាស្រ័យជាដើមរបស់សត្វទាំងឡាយ ដោយន័យជាដើមថា បុគ្គលនេះមានធូលី គឺកិលេសតិច បុគ្គលនេះជាសស្សតទិដ្ឋិ បុគ្គលនេះជាឧច្ឆេទទិដ្ឋិ បុគ្គលនេះតាំងនៅក្នុងខន្តីដែលជាអនុលោម បុគ្គលនេះតាំងនៅក្នុងយថាភូតញ្ញាណ បុគ្គលនេះជាកាមាសយ គឺមានអធ្យាស្រ័យទៅក្នុងកាម បុគ្គលនេះមានអធ្យាស្រ័យទៅក្នុងនេក្ខម្មៈជាដើម បុគ្គលនេះជានេក្ខម្មាសយ បុគ្គលនេះមិនមានអធ្យាស្រ័យក្នុងកាមជាដើម និងដោយន័យជាដើមថា កាមរាគនៃបុគ្គលនេះនឹងច្រើន តែមិនមានបដិឃៈជាដើម បដិឃៈនៃបុគ្គលនេះខ្លាំងក្លា តែមិនមានកាមរាគជាដើម បុញ្ញាភិសង្ខាររបស់បុគ្គលនេះក្រៃលែង អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ មិនក្រៃលែង អបុញ្ញាភិសង្ខាររបស់បុគ្គលនេះក្រៃលែង បុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារមិនក្រៃលែង អនេញ្ជាភិសង្ខាររបស់បុគ្គលនេះក្រៃលែង បុញ្ញាភិសង្ខារ អបុញ្ញា-ភិសង្ខារមិនក្រៃលែង កាយសុចរិត វចីសុចរិត មនោសុចរិតរបស់បុគ្គលនេះក្រៃលែង បុគ្គលនេះបង្អោនទៅក្នុងសេចក្តីអាក្រក់ បុគ្គលនេះបង្អោនទៅក្នុងសេចក្តីប្រណីត បុគ្គលនេះប្រកបដោយកម្មាវរណៈ បុគ្គលនេះប្រកបដោយកិលេសាវរណៈ បុគ្គលនេះប្រកបដោយវិបាកាវរណៈ បុគ្គលនេះ មិនប្រកបដោយកម្មាវរណៈ បុគ្គលនេះ មិនប្រកបដោយកិលេសាវរណៈ បុគ្គលនេះមិនប្រកបដោយវិបាកាវរណៈ នុ៎ះជាអាសយានុសយញ្ញាណរបស់ព្រះមានព្រះភាគ ប្រព្រឹត្តទៅដោយអាការប្រកាសឲ្យដឹងតាមសេចក្តីពិត ។

ព្រះបាលីក្នុងបដិសម្ភិទាមគ្គមានជាដើមថា

ព្រះតថាគតជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិត ជ្រាបនូវអធ្យាស្រ័យរបស់សត្វទាំងឡាយ ជ្រាបនូវពួកសត្វដែលមានភ័ព្វ និងឥតភ័ព្វ ក្នុងលោកនេះ ( ញាណបែបនេះ ឈ្មោះថា សត្តាសយានុសយញ្ញាណរបស់ព្រះតថាគត ) ដូច្នេះ ។

យមកប្បាដិហារិយញ្ញាណ របស់ព្រះមានព្រះភាគ មានការធ្វើច្រើនយ៉ាង និងការនិម្មិតដោយឫទ្ធិ ដែលមិនទូទៅដល់អ្នកដទៃ ប្រាកដជាគំនរភ្លើងជាផ្ការទឹកអំពីព្រះវរកាយខាងលើ ខាងក្រោម ខាងមុខ ខាងក្រោយចាកព្រះនេត្រស្តាំ-ឆ្វេង ព្រះកាណ៌ ព្រះនាសិក ចន្ទយស្មា ឆ្អឹងជំនីរ ព្រះហស្ត និងព្រះបាទ និងចាករណ្តៅពេម ក្នុងរវាងម្រាមព្រះហស្ត និងព្រះបាទ ។ ព្រះបាលីក្នុងបដិសម្ភិទាមគ្គមានជាដើមថា

ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវក ក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ការទឹកចេញអំពីព្រះកាយខាងលើ ... ដូច្នេះ លោកពោលដល់យមកប្បាដិហារ្យ ។

ញាណ គឺព្រះមហាករុណាសមាបត្តិ ដែលជាបច្ច័យ ឈមចុះកាន់មហាករុណារបស់ព្រះមានព្រះភាគ ប្រព្រឹត្តទៅហើយដោយន័យផ្សេងៗ ដោយមានព្រះបំណងនឹងនាំពួកសត្វដែលត្រូវសេចក្តីទុក្ខ និងធម៌ជាច្រើន មានរាគ

និងជាតិជាដើម ដែលបៀតបៀន បេញទៅចាកទុក្ខ និងធម៌នោះ ដូចព្រះ តម្រាស់ក្នុងបដិសម្ភិទាមគ្គថា

មហាករុណាសមាបត្តិញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។

កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញដោយអាការច្រើន

មហាករុណា រមែងចុះស៊ប់ក្នុងពួកសត្វ ... ដូច្នេះ ។

ព្រះញាណរបស់ព្រះមានព្រះភាគ មិនទូទៅដល់អ្នកដទៃ ប្រព្រឹត្តទៅជាប់មិនដាច់ គ្រាន់តែទ្រង់បំណងជ្រាបដល់ធម្មធាតុត្រឹមណា សង្ខតធម៌ និងអសង្ខតធម៌ជាដើមត្រឹមណាទាំងអស់នោះ ដោយអាការទាំងពួង វៀរពាក្យចង្អុលបង្ហាញអ្នកដទៃ ឈ្មោះថា សព្វញ្ញុតញ្ញាណ ព្រោះដឹងនូវសង្ខតធម៌ អសង្ខតធម៌ និងសម្មុតិសច្ចសព្វកាល ។ លោកហៅថា អនាវរណញ្ញាណ សំដៅដល់ការប្រព្រឹត្តទៅដែលមិនទើសទាក់ ព្រោះអស់អាវរណៈក្នុងវត្ថុនោះ នេះជាសង្ខេបក្នុងរឿងនេះ ឯសេចក្តីពិស្តារ នឹងមានខាងមុខ ។ អសាធារណញ្ញាណ ៦ យ៉ាង របស់ព្រះមានព្រះភាគទាំងនេះ ឈ្មោះថា ពិតប្រាកដ មិនដទៃ ព្រោះមិនខុសក្លាំងក្លាត់នៃវិស័យតាមអំណាច ដោយមិនប្រព្រឹត្តទៅក្នុងអាការវិបរិត ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ដឹងនូវការពិត ដោយប្រការដូច្នេះ ។

មួយ៉ាងទៀត ញាណប្រកាសពោជ្ឈង្គរបស់ព្រះមានព្រះភាគ ប្រព្រឹត្តទៅហើយ ដោយសរុប ( ក្នុងបដិសម្ភិទាមគ្គ ) យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គនេះ មាន ៧ ពោជ្ឈង្គ ៧ តើដូចម្ដេច សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វិរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ម្នាលភិក្ខុទាំងឡាយ នេះឯង ពោជ្ឈង្គ ៧ ដូច្នេះ ។

ដោយសាមញ្ញលក្ខណៈយ៉ាងនេះថា ធម្មសាមគ្គី មានសតិជាដើម ដែលជាបដិបក្ខចំពោះអន្តរាយទាំងឡាយមិនតិច មានការរួញរា រាយមាយហួងហែង ប្រកបសេចក្ដីព្យាយាមប្រាថ្នាតែកាមសុខ និងធ្វើខ្លួនឲ្យលំបាកប្រកាន់មាំដោយ ទិដ្ឋិថា ដាច់សូន្យ ការឃើញថាទៀងជាដើម យ៉ាងណាអរិយសាវកដទៃ គឺក្រោកឡើងចាកការដេកលក់ គឺកិលេស ចាក់ធ្លុះនូវអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយធម្មសាមគ្គីណា ធម្មសាមគ្គីនោះ លោកហៅថា **ពោធិ** ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃធម្មសាមគ្គីដែលជាហេតុត្រាស់ដឹងនោះ អរិយសាវក រមែងត្រាស់ដឹងដោយធម្មសាមគ្គី តាមដែលពោលហើយ លោកហៅថា **ពោធិ** ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់នោះ ដូច្នេះ ។ ដោយលក្ខណៈដ៏វិសេសយ៉ាងនេះថា សតិសម្ពោជ្ឈង្គ មានការចូលទៅតាំងទុកជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គ មានការថ្លុះបញ្ចាំងនូវធម៌ជាលក្ខណៈ វិរិយសម្ពោជ្ឈង្គ មានការផ្គងទុកជាលក្ខណៈ បីតិសម្ពោជ្ឈង្គ មានការផ្សាយទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជា

លក្ខណៈ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាលក្ខណៈ ដូច្នេះ ដោយសម្តែងការប្រព្រឹត្តទៅក្នុងលក្ខណៈ ១ ដោយជាឧបការៈនៃគ្នានិងគ្នានៃពោជ្ឈង្គ ៧ ដោយន័យជាដើមថា ក្នុងពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមានសតិ ប្រកបដោយបញ្ញាដ៏ងដោយជុំវិញ គឺសតិយ៉ាងក្រៃលែង រឭកដល់ សូម្បីតែវត្ថុដែលធ្វើ សូម្បីពាក្យដែលពោលយូរហើយបាន ដូច្នេះ ដោយសម្តែងវិស័យ ការធ្វើឲ្យជាក់ច្បាស់និងការប្រព្រឹត្តទៅនៃពោជ្ឈង្គទាំងនោះ ដោយន័យក្នុងវិភត្តិជាដើមថា បណ្តាសម្ពោជ្ឈង្គទាំងនោះ សតិសម្ពោជ្ឈង្គ តើដូចម្តេច ។

> សតិក្នុងធម៌ទាំងឡាយ ខាងក្នុងក៏មាន សតិក្នុងធម៌ទាំងឡាយ ខាងក្រៅក៏មាន ដូច្នេះ ។ ដោយសម្តែងវិធីចម្រើន ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវនិរោធ ជាគ្រឿងឈមទៅកាន់ការលះ ដូច្នេះ ។

ដោយអាការផ្សេងៗ យ៉ាងនេះ ដោយចែកចេញរហូតដល់ ៩ ម៉ឺន ៦ ពាន់ន័យ មានន័យជាដើមថា បណ្តាធម៌ទាំងនោះ ពោជ្ឈង្គ ៧ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ។បេ។ ក្នុងសម័យនោះ ពោជ្ឈង្គ ៧ គឺសតិសម្ពោជ្ឈង្គ ១ ។បេ។ ឧបេក្ខា សម្ពោជ្ឈង្គ ១

ក៏កើតមាន ។ បណ្ដាសម្មាជ្ឈត្តនោះ សតិសម្មាជ្ឈត្ត តើដូចម្ដេច ។បេ។ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ... ដូច្នេះ ។ ឈ្មោះថា ជាញាណពិតប្រាកដ មិនវិបរិត ព្រោះពោលមិនខុសសេចក្ដីនោះៗ ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងសេចក្ដីពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹង គឺសម្រេចនូវញាណតាមសេចក្ដីពិត ដោយអំណាចនៃបញ្ញាវិសេស ដែលមិនទូទៅដល់អ្នកដទៃ មានប្រភេទមិនមានទីបំផុត និងមិនមានប្រមាណ មានសតិប្បដ្ឋាន សម្មប្បធាន និងញាណដែលធ្វើឲ្យជាក់ច្បាស់ជាដើម តាមដែលពោលហើយ ដោយសរុបយ៉ាងនេះថា បណ្ដាអរិយសច្ចទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្ដេច ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការនេះឯង ។ មគ្គដ៏ប្រសើរមានអង្គ ៨ ប្រការ តើដូចម្ដេច ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ដូច្នេះ ។ ដោយសាមញ្ញលក្ខណៈយ៉ាងនេះថា ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសទាំងពួង ព្រោះធ្វើភាពជាអរិយៈ និងព្រោះបានអរិយផល ឈ្មោះថា **អដ្ឋង្គិក** ព្រោះអរិយៈមានអង្គ ៨ យ៉ាង និងព្រោះជាហេតុដោយចំណែកមួយ ដើម្បីសម្រេចដល់និព្វាន ឈ្មោះថា **មគ្គ** ព្រោះទម្លាយកិលេសឲ្យអស់ទៅ បុគ្គលសង្ឃឹមប្រយោជន៍ស្វែងរក ឬស្វែងរកព្រះនិព្វានដោយខ្លួនឯង ដូច្នេះ ដោយលក្ខណៈវិសេសយ៉ាងនេះថា សម្មាទិដ្ឋិ មានការឃើញប្រពៃជាលក្ខណៈ សម្មាសង្កប្ប មានការលើកឡើងប្រពៃជាលក្ខណៈ សម្មាវាចា មានការកំណត់ប្រពៃជាលក្ខណៈ សម្មាកម្មន្តៈ

មានការធ្វើប្រពៃជាលក្ខណៈ សម្មាអាជីវៈ មានការផូរផង់ជាលក្ខណៈ សម្មាវាយាម មានការផ្គងទុកប្រពៃជាលក្ខណៈ សម្មាសតិ មានការតាំងទុកប្រពៃជាលក្ខណៈ សម្មាសមាធិ មានការមិនរាយមាយប្រពៃជាលក្ខណៈ ដូច្នេះ ដោយការចែកកិច្ចយ៉ាងនេះថា សម្មាទិដ្ឋិ មានការលះមិច្ឆាទិដ្ឋិ និងកិលេសដែលជាសត្រូវរបស់ខ្លួន ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ និងឃើញសម្បយុត្តធម៌ ដោយការមិនវង្វេង ដោយការកម្ចាត់មោហៈ ដែលបិទបាំងព្រះនិព្វាននោះ សូម្បីសម្មាសង្កប្បជាដើមក៏ដូចគ្នា លះមិច្ឆាសង្កប្បជាដើម ធ្វើនិរោធឲ្យជាអារម្មណ៍ និងធ្វើនូវការលើកឡើងប្រពៃ ការកំណត់ ការធ្វើ ការផូរផង់ ការផ្គង ការតាំងទុក ការតាំងមាំនៃសហជាតធម៌ទាំងឡាយ ដូច្នេះ ដោយចែកការប្រព្រឹត្តទៅក្នុងភាគដើម និងភាគក្រោយ យ៉ាងនេះថា សម្មាទិដ្ឋិក្នុងភាគដើម មានខណៈផ្សេងៗ គ្នា មានអារម្មណ៍ មានទុក្ខជាដើម ដោយឡែកក្នុងកាលនៃមគ្គ មានខណៈតែមួយ ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ដោយកិច្ច បានឈ្មោះ ៤ យ៉ាង មានយ៉ាងនេះថា ដឹងក្នុងទុក្ខ ដូច្នេះ សូម្បីសម្មាសង្កប្បជាដើម ភាគខាងដើមក៏មានខណៈផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា ក្នុងកាលនៃមគ្គមានខណៈតែមួយ មានអារម្មណ៍តែមួយ ក្នុងអរិយមគ្គទាំងនោះ សម្មាសង្កប្ប ដោយកិច្ចបាន ឈ្មោះ ៣ យ៉ាង មានការត្រិះរិះចេញចាកកាម ដូច្នេះជាដើម អរិយមគ្គ ៣ មានសម្មាវាចាជាដើម មានចែកដូច្នេះថា ចេតនាជាគ្រឿងវៀរចាកពោលពាក្យកុហកជាដើម ជាវិរតិខ្លះ ជាចេតនាខ្លះ ក្នុងខណៈនៃមគ្គជាវិរតិ សម្មាវាយាម និងសម្មាសតិ ដោយកិច្ច បានឈ្មោះ ៤ យ៉ាង

ដោយអំណាចសម្មប្បធាន និងសតិប្បដ្ឋាន តែសម្មាសមាធិ សូម្បីក្នុងខណៈនៃមគ្គក៏ផ្សេងៗ គ្នា ដោយបឋមជ្ឈានជាដើម ដោយការផ្សេងគ្នានៃការចម្រើន ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិ ដែលអាស្រ័យវិវេក ... ដូច្នេះ ។ ដោយអាការច្រើនយ៉ាង យ៉ាងនេះ ដោយការចែក ៨៤000 ន័យ ដោយន័យជាដើមថា

បណ្តាធម៌ទាំងនោះ មគ្គមានអង្គ ៨ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្ត ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិក៏កើតមាន ដូច្នេះ ។

ទាំងអស់នេះ ជាសេចក្តីពិត ព្រោះត្រាស់មិនខុស ព្រះមានព្រះភាគឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងសេចក្តីពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះញាណរបស់ព្រះមានព្រះភាគ ដែលប្រព្រឹត្តទៅតាមលំដាប់ក្នុងសមាបត្តិទាំងនេះ គឺបឋមជ្ឈានសមាបត្តិ និរោធសមាបត្តិ ដោយអាការមានការប្រុងប្រៀប ( ការចូល ) និងការពិចារណាជាដើម ក្នុងអនុបុព្វវិហារសមាបត្តិ ព្រោះអត្ថថា ពីងផ្អែក និងព្រោះអត្ថថា គប្បីចូលដល់ និងដោយការតាមប្រកបតាមសមគួរ ឈ្មោះថា ពិតប្រាកដ មិនទៅជាដទៃ

ព្រោះឲ្យសម្រេចប្រយោជន៍នៃព្រះញាណនោះ ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ត្រាស់ដឹងសេចក្តីពិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ទសពលញ្ញាណរបស់ព្រះមានព្រះភាគទាំងនេះ គឺព្រះញាណជាគ្រឿងឈមចុះកាន់ហេតុ និងមិនមែនហេតុនៃផលនោះៗ ដោយមិនខុសថា វត្ថុនេះ ប្រព្រឹត្តទៅបាន និងវត្ថុនេះ ប្រព្រឹត្តទៅមិនបាន ជាគ្រឿងឈមចុះកាន់ផលនៃកម្មសមាទាន មានកម្មក្នុងអតីតរបស់ពួកសត្វទាំងនោះ តាមសេចក្តីពិតដោយឥតសេសសល់ ជាគ្រឿងឈមចុះដល់ការចែកកម្មដែលមានអាសវៈ និងមិនមានអាសវៈតាមសេចក្តីពិតថា នេះជាបដិបទាដែលនាំសត្វទៅកាន់នរក ។បេ។ នេះជាបដិបទាដែលនាំសត្វទៅកាន់ព្រះនិព្វានរបស់សត្វនោះៗ ក្នុងខណៈធ្វើកម្មនោះឯង ជាគ្រឿងឈមចុះកាន់ខន្ធ និងអាយតនៈ ដែលមានសភាពច្រើនយ៉ាង ទាំងជាឧបាទិន្នកសង្ខារ និងអនុបាទិន្នកសង្ខារជាដើម និងមានសភាពដែលផ្សេងគ្នាតាមសេចក្តីពិត ដោយន័យជាដើមថា សេចក្តីអស្ចារ្យនេះ រមែងកើតឡើងបាន ព្រោះទាក់ទងដោយធម៌នេះ ព្រោះភាពដែលសត្វ-លោកនោះ សម្បូណ៌ដោយធាតុឈ្មោះនេះ ជាគ្រឿងឈមចុះនូវការក្រៃលែង និងការទន់ខ្សោយនៃឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើម ជាគ្រឿងឈមចុះដល់ធម៌ មានឈាន និងវិមោក្ខជាដើម ព្រមទាំងទោសទាំងឡាយ មានសេចក្តីសៅហ្មងជាដើម ជាគ្រឿងញ៉ាំងនូវការបន្តនៃខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនរបស់សត្វទាំងឡាយ មួយអន្លើដោយការទាក់ទងក្នុងខន្ធនោះក្នុងជាតិទាំងឡាយដែលមិនមានប្រមាណ ជាគ្រឿងឈមចុះដល់ចុតិ និង

បដិសន្ធិរបស់ពួកសត្វ មួយអន្លើដោយការចែកការៈ មានថោកទាបជាដើម ជាគ្រឿងឈមចុះកាន់អរិយសច្ច ៤ តាមន័យដែលពោលហើយខាងដើមថា នេះទុក្ខ ដូច្នេះជាដើម ឈ្មោះថា ជារបស់ពិត មិនប្រែប្រួលទៅជាដទៃតាមការប្រព្រឹត្តទៅដោយពិត ព្រោះឈមចុះកាន់វិស័យរបស់ខ្លួន និងព្រោះឲ្យសម្រេចប្រយោជន៍តាមដែលខ្លួនបំណងមិនខុសក្លាំងក្លាត់ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងអង្គុត្តរនិកាយ ទសកនិបាតថា

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ រមែងជ្រាបច្បាស់នូវហេតុតាមហេតុផង ជ្រាបច្បាស់នូវអំពើមិនមែនជាហេតុតាមអំពើមិនមែនជាហេតុផង ដោយសេចក្តីជាក់លាក់ ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះត្រាស់ដឹងសេចក្តីពិតដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅហើយយ៉ាងនោះដូចម្តេច ឆ្លើយថា ការកើត ការត្រាស់ដឹង ការប្រកាសធម្មវិន័យ អនុបាទិសេសនិព្វានធាតុរបស់ព្រះមានព្រះភាគ ដូចគ្នាយ៉ាងនោះ ។ សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា ការកើតជាដើមនោះ ដែលព្រះលោកនាថប្រាថ្នាហើយ និងប្រព្រឹត្តហើយនូវប្រយោជន៍ណា ជាការពិតប្រាកដ មិនដទៃដោយប្រព្រឹត្តប្រយោជន៍មិនវិបរិត ព្រោះពោលមិនខុស ដើម្បីឲ្យប្រយោជន៍នោះសម្រេចដោយចំណែកមួយ ពិតហើយ ព្រះមានព្រះភាគ កាលជាពោធិសត្វ ទ្រង់បានបំពេញហេតុនៃភាពជាព្រះពុទ្ធទាំងអស់ មានការបំពេញ

សមត្តឹសបារមីជាដើម ដូចពោលហើយ ប្រថាប់នៅក្នុងជាន់តុសិតបុរី ពួកទេវតាក្នុងម៉ឺនចក្រវាល បានស្តាប់ពុទ្ធកោលាហល ទើបប្រជុំរួមគ្នា ចូលគាល់ទូលអារាធនាថា

**កាលោយំ តេ មហាវីរ ឧប្បជ្ជ មាតុកុច្ឆិយំ**
**សទេវកំ តារយន្តោ ពុជ្ឈស្សុ អមតំ បទំ។**

បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ គួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើតក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោក ព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ដូច្នេះ ។

ពិតហើយ បុព្វនិមិត្តកើតហើយ ទ្រង់ពិចារណាមើលមហាវិលោកនៈ ៥ ទ្រង់ត្រិះរិះថា ឥឡូវនេះ អញនឹងកើតក្នុងកំណើតមនុស្ស ហើយនឹងត្រាស់ដឹង ដូច្នេះ ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវី ក្នុងសក្យរាជត្រកូល ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ។ ពួកទេវតា និងមនុស្ស នាំគ្នារក្សាអស់កាល ១០ ខែ លុះដល់គ្រាទៀបភ្លឺ ក្នុងថ្ងៃពេញបូណ៌មី ខែពិសាខ ទ្រង់ក៏ប្រសូត ។ ក្នុងខណៈប្រសូត បុព្វនិមិត្ត ៣២ ប្រការ បានប្រាកដដល់ព្រះពោធិសត្វ ដូចក្នុងកាលបដិសន្ធិ ។ លោកធាតុមួយម៉ឺនកក្រើករំពើកញាប់ញ័រហើយ ។ ពន្លឺមិនមានប្រមាណផ្សាយទៅក្នុងម៉ឺនចក្រវាល មនុស្សខ្វាក់ ក៏បានមើលឃើញ ហាក់ដូចជាមានបំណងនឹងមើលព្រះសិរីដែលប្រមាណមិនបាន ។ មនុស្សថ្លង់ ក៏បានឮសំឡេង មនុស្ស-គ ក៏និយាយ

បាន មនុស្សគមក៏មានខ្លួនត្រង់ មនុស្សខ្វិនក៏ដើរបាន សព្វសត្វដែលត្រូវចង ក៏រួចចាកចំណង មានឃ្នាងជាដើម ភ្លើងនរកទាំងអស់ក៏រលត់ សេចក្តីស្រេកឃ្លានក្នុងបេតវិស័យក៏ស្ងប់ ភ័យមិនមានដល់សត្វតិរច្ឆានទាំងឡាយ រោគរបស់សត្វស្ងប់ សព្វសត្វពោលវាចាគួរស្រឡាញ់ សេះស្រែកដោយសំឡេងពីរោះ ដំរីបញ្ចេញកោញ្ចនាទ តូរ្យតន្ត្រីគ្រប់យ៉ាងបន្លឺឯង គ្រឿងប្រដាប់ មានគ្រឿងប្រដាប់ដៃជាដើមរបស់មនុស្សទាំងឡាយមិនប៉ះគ្នា ក៏នៅតែមានសំឡេងចេញមកយ៉ាងពីរោះ ទិសទាំងអស់ភ្លឺស្វាង ខ្យល់ត្រជាក់បក់ល្ហៀកៗ ធ្វើសត្វទាំងឡាយឲ្យកើតសេចក្តីសុខ ។ ភ្លៀងធ្លាក់ពុំជូកាល ទឹកខ្ចរចេញពីផែនដីហូរទៅ បក្សីទាំងឡាយ មិនហើរទៅតាមអាកាស ។ ស្ទឹងមិនហូរ ទឹកក្នុងមហាសមុទ្រ មានរសផ្អែម ។ កាលព្រះអាទិត្យលិចហើយ ពន្លឺក៏នៅតែមាន ពន្លឺទាំងអស់រុងរឿងក្នុងអាកាស ។ ពួកទេវតាទាំងអស់ វៀរអរូបាវចរទេព និងនរកទាំងអស់ បានប្រាកដរូបឲ្យឃើញដើមឈើ សន្ទះទ្វារ និងថ្មជាដើម បិទបាំងមិនបាន ។ សត្វទាំងឡាយ មិនចុតិ មិនកើត ។ ក្លិនទិព្វផ្សាយឡើងក្រអូបឈ្ងុយ កម្ចាត់នូវក្លិនមិនគួរប្រាថ្នា ។ ដើមឈើមានផ្លែគ្រប់ប្រភេទ ក៏ចេញផ្លែបរិបូរណ៍ មហាសមុទ្រ ក៏ដេរដាសទៅដោយផ្កាឈូក ៥ ពណ៌ ដែលពេញទាំងអស់ បណ្តាផ្កាគ្រប់ប្រភេទ ទាំងលើគោក ទាំងក្នុងទឹកក៏រីកស្គុសស្គាយ ។ ខន្ធបទុម គឺឈូកគុម្ពក៏រីកត្រង់គុម្ព សាខាបទុម គឺឈូកមានទង ក៏រីកត្រង់ទង លតាបទុម គឺឈូកវល្លិ ក៏រីកត្រង់វល្លិ ទណ្ឌបទុម គឺឈូកដើម ក៏ទម្លុះផ្ទាំងថ្មចេញមក មានស្លឹករាប់រយ គ្របដណ្តប់ខាងលើ ។

ឧលម្ពកបទុម គឺឈូកសំយុងក៏កើតក្នុងអាកាស ។ ភ្លៀងផ្កាធ្លាក់ដោយជុំវិញលើអាកាស តន្ត្រីទិព្វក៏បន្លឺសំឡេងទ្រហឹង លោកធាតុមួយម៉ឺន មានកម្រងមាលាដូចគ្នាតែមួយ ដូចបាច់ផ្កាដែលក្រងដាក់សំយុង ដូចសំណុំមាលាដែលចង ដូចទែនមាលាដែលប្រដាប់តាក់តែង មានផ្ទិតវាលវែងនីផុសចេញមកអប់ដោយក្លិនផ្កា និងធូមគន្ធៈល្អពន់ពេក ។ម្យ៉ាងទៀត បុព្វនិមិត្តទាំងនោះបានជានិមិត្តនៃការសម្រេចគុណវិសេសមិនមែនតែមួយ ដែលព្រះពោធិសត្វសម្រេចហើយខាងលើ ។ ព្រោះប្រាកដនូវភាពអស្ចារ្យមិនមែនតិចយ៉ាងនេះការកើតដែលព្រះពោធិសត្វនោះប្រាថ្នាប្រយោជន៍ឯណា ក៏បានពិតប្រាកដមិនទៅជាដទៃ ការសម្រេចអភិសម្ពោធិញ្ញាណនោះ ដោយចំណែកមួយ ។

ម្យ៉ាងទៀត ពួកបុគ្គលដែលគួរទូន្មានដើម្បីការត្រាស់ដឹង ដែលឈ្មោះថា ពុទ្ធវេនេយ្យនោះ ព្រះមានព្រះភាគទ្រង់ទូន្មានដោយព្រះអង្គឯងទាំងអស់ដោយមិនមានសេសសល់ឡើយ មិនមែនសាវកទូន្មានឡើយ ។ សាវកវេនេយ្យ និងធម្មវេនេយ្យទាំងនោះ ដែលពួកសាវកជាដើមទូន្មានហើយរមែងចូលដល់ និងចូលដល់បទណែនាំ ដោយប្រការដូច្នេះ ។ ការត្រាស់ដឹងក្រៃលែង ដែលព្រះមានព្រះភាគប្រាថ្នានូវប្រយោជន៍ណា ការត្រាស់ដឹងក្រៃលែង ដើម្បីការបានសម្រេចប្រយោជន៍នោះ ដោយចំណែកមួយ ជាសេចក្តីពិត មិនជាដទៃឡើយ ។

ម្យ៉ាងទៀត ការត្រាស់ដឹងក្រៃលែងយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ដឹងក្រៃលែងនូវសភាវៈនៃញេយ្យធម៌ ដែលគួរត្រាស់ដឹងដោយមិនសេសសល់

មិនវិបរិត ដោយព្រះញាណរបស់ព្រះអង្គ ដែលទាក់ទងត្រឹមតែនឹក ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃ ដូច្នោះ នេះជាសេចក្ដីពិតមិនប្រែប្រួលដទៃ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់មើលវិធីដែលគួរសម្ដែងនៃធម៌ទាំងនោះ និងអធ្យាស្រ័យ អនុស័យ និងការពេញចិត្តក្នុងការប្រព្រឹត្តរបស់សត្វនោះៗ ទ្រង់មិនលះនូវភាពជាធម៌ ទ្រង់មិនប្រញាប់ប្រញាល់ ឲ្យប្រព្រឹត្តទៅត្រឹមតែជាវោហារ ទ្រង់ប្រកាសភាវៈជាធម៌ ទ្រង់ទូន្មាននូវកំហុសតាមអធ្យាស្រ័យ និងតាមភាពជាធម៌ ទ្រង់ទូន្មានហើយ នូវវេនេយ្យសត្វទាំងឡាយ ឲ្យវេនេយ្យសត្វសម្រេចដល់អរិយភូមិ ។ សូម្បីការប្រកាសធម្មវិន័យរបស់ព្រះអង្គ ដើម្បីការសម្រេចនូវប្រយោជន៍នោះ និងដើម្បីការប្រព្រឹត្តទៅតាមសេចក្ដីពិត ក៏ជាការពិតប្រាកដ មិនដទៃឡើយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់សម្រេចអមតមហានិព្វានធាតុដែលនៅមានបញ្ចក្ខន្ធ ផុតចាកសភាវៈ ដែលជារូប និងមិនមែនរូប មានផស្សៈវេទនាជាដើម កន្លងបង់នូវសភាវៈនៃលោក ព្រោះមិនមានការបែកធ្លាយ មិនមានពន្លឺ ដោយវត្ថុណាមួយ ព្រោះមិនមានការជាប់ទាក់ទង ដោយភាពងងឹតវៀរចាកភាវៈ មានគតិជាដើម ព្រោះមិនមានពន្លឺនោះឯង មិនមានទីអាស្រ័យ មិនមានអារម្មណ៍ លោកហៅថា អនុបាទិសេស ព្រោះមិនមានត្រឹមតែកិលេស មានការប្រកាន់ជាដើម ដែលបានដល់ខន្ធ ។

ព្រះមានព្រះភាគទ្រង់សំដៅដល់សេចក្ដីនេះ ទើបត្រាស់ក្នុងឧទានថា

ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន

ទឹកមិនមាន ភ្លើងមិនមាន ខ្យល់មិនមាន អាកាសានញ្ចាយតនៈមិនមាន វិញ្ញាណញ្ចាយតនៈមិនមាន អាកិញ្ចញ្ញាយតនៈមិនមាន នេវសញ្ញានាសញ្ញាយតនៈមិនមាន លោកនេះមិនមាន លោកមុខមិនមាន ព្រះចន្ទ និងព្រះអាទិត្យ ទាំង ២ ក៏មិនមាន ក្នុងព្រះនិព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុត មិនមានការកើត មិនមានទីជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះ ជាទីបំផុតនៃទុក្ខតែម្យ៉ាង ដូច្នេះ ។

អមតមហានិព្វានធាតុនោះ គឺការរម្ងាត់ឧបាទានក្ខន្ធទាំងឡាយ ការស្ងប់សង្ខារទាំងពួង ការលះកិលេសទាំងពួង ការស្ងប់ទុក្ខទាំងពួង ការដកអាល័យទាំងពួង ការកាត់នូវវដ្ដៈទាំងពួង អមតមហានិព្វានធាតុនោះ មានលក្ខណៈស្ងប់បំផុត ព្រោះហេតុនោះ ទើបឈ្មោះថា ពិតប្រាកដ មិនវិបរិត ទោះក្នុងកាលណាក៏ដោយ ព្រោះមិនខុសសភាវៈតាមដែលពោលហើយ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅ យាងចូលដល់ យាងដល់ទ្រង់បដិបត្តិ គឺសម្រេចអភិជាតិជាដើម យ៉ាងនោះ ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយាងទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយ៉ាងនោះ ដូចម្ដេច ឆ្លើយថា ព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលមុនយ៉ាងណា សូម្បីព្រះ

មានព្រះភាគអង្គនេះ ក៏យ៉ាងនោះ លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា ព្រះមានព្រះភាគទាំងឡាយនោះយ៉ាងណា ដោយសង្ខេប គឺដោយមគ្គ-សីល ផលសីល លោកិយសីល លោកុត្តរសីលទាំងអស់ ដោយមគ្គ-សមាធិ ផលសមាធិ លោកិយសមាធិ លោកុត្តរសមាធិទាំងអស់ ដោយមគ្គប្បញ្ញា ផលប្បញ្ញា លោកិយប្បញ្ញា លោកុត្តរប្បញ្ញាទាំងអស់ ដោយសមាបត្តិវិហារធម៌ ២ លាន ៤ សែនកោដិ ដែលទ្រង់បដិបត្តិតាមរាល់ៗថ្ងៃ ដោយតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្ស-រណវិមុត្តិ តែដោយពិស្ដារ ព្រះមានព្រះភាគទាំងនោះ យ៉ាងណា ដោយអានុភាពដែលជាអចិន្តេយ្យ មិនមានទីបំផុត ប្រមាណមិនបាន ដោយគុណគឺទ្រង់ដឹងវត្ថុសព្វយ៉ាង សូម្បីព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏យ៉ាងនោះ ។

សេចក្ដីពិត ព្រះសម្មាសម្ពុទ្ធទាំងឡាយ មានការផ្សេងគ្នា ដោយការផ្សេងគ្នា ៥ ប្រការ គឺផ្សេងគ្នាដោយអាយុ ១ ផ្សេងគ្នាដោយទំហំព្រះវរកាយ ១ ផ្សេងគ្នាដោយត្រកូល ១ ផ្សេងគ្នាដោយទុក្ករកិរិយា ១ ផ្សេងគ្នាដោយព្រះរស្មី ១ តែមិនមានការផ្សេងគ្នាក្នុងវិសុទ្ធិ មានសីលវិសុទ្ធិជាដើមឡើយ និងក្នុងគុណដែលទ្រង់ចាក់ធ្លុះ ក្នុងកិច្ចបដិបត្តិសមថៈ និងវិបស្សនា ។ ដែលពិត ព្រះមានព្រះភាគ ដែលជាពុទ្ធៈទាំងនោះ មិនផ្សេងគ្នានិងគ្នា ដូចមាសដែលបាក់ត្រង់ពាក់កណ្ដាល ។ ព្រោះដូច្នោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ក្នុងកាលមុនយ៉ាងណា សូម្បីព្រះមានព្រះភាគអង្គនេះ ក៏យ៉ាងនោះ ។ ព្រះមាន

ព្រះភាគ ឈ្មោះថា **តថាគត** ព្រោះយ៉ាងនោះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត **គត** សព្ទ ក្នុងបទថា **តថាគតោ** នេះ មានសេចក្តីថា **ឥឆ** តែសត្វលោកពោល **គត** សព្ទ ប្រកបដោយ **ឥឆ** សព្ទ ចុះក្នុងអត្ថថា ប្រការ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះទ្រង់ប្រព្រឹត្តទៅយ៉ាងនោះដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះមានការដល់ ការទៅ ការដើរទៅ គឺការប្រព្រឹត្តទៅផ្លូវកាយ វាចា និងចិត្តយ៉ាងនោះ តាមគាប់ចិត្ត ព្រោះប្រកបដោយឥទ្ធានុភាព ដែលមិនទូទៅដល់អ្នកដទៃ ព្រោះទ្រង់បានអនាវរណញ្ញាណ ដើម្បីកិច្ចបដិបត្តិបារមីដ៏ឧក្រិដ្ឋនៃអត្ថប្បដិសម្ភិទាជាដើម និងព្រោះព្រះមានព្រះភាគមិនមានការផ្តាំផ្គងក្នុងទីណា ក្នុងការប្រព្រឹត្តទៅតាមកាលជាដើម ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះប្រព្រឹត្តទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគមិនទៅចាកសេចក្តីពិតដូចម្តេច ឆ្លើយថា ព្រះមានព្រះភាគ ឈ្មោះថា **អគត** ព្រោះទ្រង់មិនមានការទៅ ពោល គឺការប្រព្រឹត្តទៅ ដែលជាបដិបក្ខចំពោះសេចក្តីពិតនោះ ក្នុងការសម្រេចពោធិសម្ភារ ការមិនទៅរបស់ទ្រង់នោះមិនវិបរិត ក្នុងការបំពេញទានដើម្បីកម្ចាត់សេចក្តីកំណាញ់ជាដើម ដោយព្រះញាណដែលប្រព្រឹត្តទៅដោយន័យ មានការពិចារណាទោស និងអានិសង្សជាដើម ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះមិនទៅចាកញាណដែលពិត ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ

ឈ្មោះថា **អគត** ព្រោះមិនមានការទៅក្នុងគតិ ៥ ពោល គឺការប្រព្រឹត្តទៅក្នុងការតាក់តែងនៃកិលេស ឬការប្រព្រឹត្តទៅនៃខន្ធ ។ ការមិនទៅរបស់ព្រះអង្គនោះ ព្រោះប្រព្រឹត្តទៅដោយសឧបាទិសេសនិព្វាន និងអនុបាទិសេ-សនិព្វាន ដោយអរិយមគ្គញាណដែលពិត ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះមិនទៅចាកសេចក្តីពិត ដោយប្រការដូច្នេះ ។

សួរថា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះភាពដែលព្រះអង្គយាងទៅយ៉ាងនោះដូចម្តេច ឆ្លើយថា បទថា **តថាគតភាវេន** បានដល់ ព្រោះសេចក្តីពិតរបស់ព្រះតថាគត អធិប្បាយថា ព្រោះការមានពិត ។ សួរថា ព្រះតថាគតនោះ គឺនរណា ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះមានអ្វី ឆ្លើយថា មានព្រះសទ្ធម្ម ។ ព្រោះសទ្ធម្ម គឺអរិយមគ្គទៅហើយ ដូចដែលគួរទៅ ដោយការលះជាសមុច្ឆេទ ដោយដកចំណែកនៃកិលេសមិនឲ្យសេសសល់ ដោយកម្លាំងសមថៈ និងវិបស្សនាដែលពិតប្រាកដ ។

ផលធម៌ទៅហើយ គឺប្រព្រឹត្តទៅ ដូចដែលគួរទៅ ដោយការលះយ៉ាងស្ងប់ តាមសមគួរដល់មគ្គរបស់ខ្លួន ។ ចំណែកនិព្វានធម៌ ព្រះពុទ្ធជាដើមទ្រង់ដឹង គឺធ្វើឲ្យជាក់ច្បាស់ ដូចដែលទ្រង់ដឹងដោយបញ្ញា សម្រេចដោយការស្ងប់ទុក្ខក្នុងវដ្តៈទាំងមូល ដោយហេតុនោះ ទើបធម៌ ឈ្មោះថា **តថាគត** ។ សូម្បីបរិយត្តិធម៌ដែលព្រះមានព្រះភាគនៃយើងទ្រង់ដឹង ទ្រង់ប្រកាស ទ្រង់ឲ្យប្រព្រឹត្តទៅ ដូចព្រះពុទ្ធក្នុងកាលមុន ឲ្យប្រព្រឹត្តទៅហើយតាមសមគួរដល់អធ្យាស្រ័យជាដើមរបស់វេនេយ្យសត្វទាំងឡាយ ដោយអំណាចសុត្តៈ គេយ្យៈ

*ជាដើម និងដោយអំណាចការប្រកាសការប្រព្រឹត្តទៅជាដើម ព្រោះហេតុនោះ ទើបព្រះធម៌ ឈ្មោះថា* **តថាគត** *។ ព្រះធម៌ដែលសាវកទាំងឡាយរបស់ព្រះមានព្រះភាគដឹងហើយ ដឹងដល់ទូទៅហើយ ដូចព្រះមានព្រះភាគទ្រង់សម្តែង ព្រោះហេតុនោះ ទើបធម៌ ឈ្មោះថា* **តថាគត** *ដោយប្រការដូច្នេះ សូម្បីព្រះធម៌ទាំងអស់ ក៏ឈ្មោះថា* **តថាគត** *សមដូចសក្កទេវរាជត្រាស់ថា*

**តថាគតំ ទេវមនុស្សបូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ**

*យើងទាំងឡាយសូមនមស្ការ នូវព្រះធម៌ដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ដូច្នេះ ។*

*ព្រះមានព្រះភាគ ឈ្មោះថា* **តថាគត** *ព្រោះមានព្រះសទ្ធម្មនោះ ។ មួយវិញទៀត ព្រះអរិយសង្ឃក៏ដូចគ្នានឹងព្រះធម៌ ព្រះសង្ឃ ឈ្មោះថា* **តថាគត** *ព្រោះសម្រេចធម៌ទាំងនោះ ដូចដែលអ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងដើម្បីជាប្រយោជន៍ដល់អ្នកដទៃ បដិបត្តិសមថៈ និងវិបស្សនាដែលជាចំណែកខាងដើមដ៏បរិសុទ្ធ ហើយគប្បីសម្រេចដោយមគ្គនោះៗ ដូច្នោះ មួយវិញទៀត ព្រះសង្ឃ ឈ្មោះថា* **តថាគត** *ព្រោះត្រាស់ដឹង និងព្រោះប្រាប់បាន ដូចព្រះមានព្រះភាគទ្រង់សម្តែងន័យ មានបដិច្ចសមុប្បាទជាដើម ។ សមដូចសក្កទេវរាជត្រាស់ថា*

**តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ**

*យើងទាំងឡាយសូមនមស្ការ នូវព្រះសង្ឃដែល មានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ដូច្នេះ ។*

ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះមានព្រះសង្ឃជាសាវក ។ ព្រះមានព្រះភាគ ឈ្មោះថា **តថាគត** ព្រោះភាពដែលព្រះអង្គយាងទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

សេចក្តីនេះ ត្រឹមតែជាការពោលក្នុងការសម្តែងដល់ភាពដែលព្រះតថាគតយាងទៅយ៉ាងនោះប៉ុណ្ណោះ តែដោយពិត ព្រះតថាគតប៉ុណ្ណោះ គប្បីពណ៌នាភាពដែលព្រះតថាគតយាងទៅយ៉ាងនោះ ដោយអាការទាំងពួង ។ ព្រោះសេចក្តីនេះ ជាបទបាទរបស់ព្រះតថាគត ជាមហាគតិ មហាវិស័យ ។ មិនគួរពោលថា ធម្មកថិកអាងព្រះពុទ្ធវចនៈ ដែលជាព្រះត្រៃបិដក ដូចពុទ្ធ-វចនៈនៃបទអប្បមាទ ដោយការមានទៅតាមសមគួរ ជាព្រះធម្មកថិកក្រៅតម្រា ដូច្នេះ ។ ក្នុងសេចក្តីនោះ លោកក៏ពោលថា

ព្រះមុនីទាំងឡាយ ជាអ្នកស្វែងរកគុណធំ អំពីកាលមុន មកជា
ព្រះសព្វញ្ញូ ក្នុងលោកនេះ យ៉ាងណា សូម្បីព្រះសក្យមុនី ក៏យាង
មកយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកហៅថា **តថាគត** ។
ព្រះជិនស្រីទាំងឡាយ លះមន្ទិល មានកាមជាដើម ដោយឥត
សេសសល់ ហើយទៅដោយសមាធិញ្ញាណ យ៉ាងណា ព្រះ
សក្យមុនី មានបញ្ញារុងរឿងអំពីកាលមុន យាងទៅហើយយ៉ាង
នោះ ដោយហេតុនោះ ទើបឈ្មោះថា **តថាគត** ។
ព្រះជិនស្រី ជាសក្យៈ ទ្រង់ជាអគ្គបុគ្គល ទ្រង់ត្រាស់ដឹងនូវ
លក្ខណៈ មានធាតុ និងអាយតនៈជាដើម ដោយពិត ដោយចែក

ជាសភាវៈ និងសាមញ្ញ ដោយព្រះសយម្ភូញាណយ៉ាងនោះ ទើបឈ្មោះថា **តថាគត** ។

ព្រះជិនស្រី ត្រាស់ដឹងសច្ចធម៌ទាំងឡាយ ពិតដោយសមន្តចក្ខុ ធ្វើឲ្យជាក់ច្បាស់នូវឥទប្បច្ចយតាដែលពិត ដោយប្រការទាំងពួង ដោយមិនមានអ្នកដទៃទូន្មានយ៉ាងនោះ ដោយហេតុនោះ ទើបឈ្មោះថា **តថាគត** ។

ការឃើញពិតរបស់ព្រះជិនស្រី ក្នុងលោកធាតុ មានប្រភេទមិនតិច ក្នុងគោចរធម៌ មានរូបាយតនៈជាដើម ដែលមានប្រភេទដ៏វិចិត្រ ដោយហេតុនោះ ទើបឈ្មោះថា **តថាគត** អ្នកឃើញដោយប្រពៃ ។

ព្រោះព្រះមានព្រះភាគ ត្រាស់ធម៌ដែលពិតប៉ុណ្ណោះ ទ្រង់ធ្វើសមគួរតាមព្រះតម្រាស់របស់ព្រះអង្គ ទ្រង់គ្រប់គ្រងនូវលោកឲ្យប្រព្រឹត្តដោយគុណទាំងឡាយ ដោយហេតុនោះ ទើបឈ្មោះថា **តថាគត** ដែលទូន្មាននូវលោក ។

ព្រះមានព្រះភាគ ទ្រង់បានដឹងដោយការកំណត់ដឹងយ៉ាងនោះដោយពិត ដោយប្រការទាំងពួង ទ្រង់ឈានកន្លងនូវលោកជាដែនកើត ទ្រង់ដល់នូវការរម្ងត់ ដោយការធ្វើដ៏ប្រចក្ស និងទ្រង់ដល់នូវអរិយមគ្គ ទើបឈ្មោះថា **តថាគត** ។

ព្រះនាថ ព្រោះយាងមកដើម្បីជាប្រយោជន៍ដល់សត្វលោក

ដោយប្ញាដែលពិតយ៉ាងនោះ ដោយប្រការទាំងពួង និងយាង ទៅដោយព្រះករុណាដែលពិតក្នុងកាលទាំងពួង ដោយហេតុនោះ ទើបព្រះជិនស្រី ឈ្មោះថា **តថាគត** ។

ព្រះមានព្រះភាគត្រាស់ដឹងនូវព្រះញាណដែលពិត ដោយត្រាស់ ដឹងវិស័យតាមសេចក្ដីពិត យាងមកយ៉ាងនោះ តាំងអំពី កើត ទើបឈ្មោះថា **តថាគត** ព្រោះញ៉ាំងប្រយោជន៍ឲ្យដល់ព្រម ។

លោកអ្នកស្វែងរកគុណធំ ក្នុងកាលមុននោះ យ៉ាងណា សូម្បី ព្រះមានព្រះភាគអង្គនេះ ក៏យ៉ាងនោះ វាចាដែលបន្លឺចេញមក តាមគាប់ចិត្តយ៉ាងនោះ ព្រោះជាខ្លួននៃខ្លួនឯង ទើបឈ្មោះថា **តថាគត** ជាបុគ្គលដ៏ប្រសើរ ។

ការទៅមុន ដោយជាសត្រូវនៃពោធិសម្ភារ រមែងមិនមាន ឬ សូម្បីកាលអន្ទោលទៅក្នុងសង្សាររបស់ព្រះនាថនោះ ក៏មិនមាន ទិដ្ឋិរបស់ព្រះនាថ ដែលជាអ្នកឃើញទីបំផុតកត មិនមាន ព្រោះ ដូច្នោះ ទ្រង់មិនទៅអំពីសេចក្ដីពិត ទើបឈ្មោះថា **តថាគត** ។

ព្រះតថាគត ជាអ្នកទ្រទ្រង់នូវធម៌ ទ្រង់លះនូវមន្ទិលដែលលោក អ្នកស្វែងរកគុណធំ គប្បីលះ យ៉ាងណា បុគ្គលដែលជាអរិយៈ ជាអ្នកទូន្មានដ៏វិសេស ក៏ទៅយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះ ថា **តថាគត** ព្រោះភាពជាអ្នកមានការព្រមព្រៀង ។

អធិប្បាយថា បទថា **អរហា** ក្នុងបទថា **អរហន្តំ សម្មាសម្ពុទ្ធំ** នេះ

លោកពោលខាងដើមហើយ ឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង លោកអធិប្បាយថា ព្រោះត្រាស់ដឹងនូវធម៌ដែលគួរដឹកនាំណាមួយ ដោយព្រះអង្គឯង ដោយមិនវិបរិតចាកអាការទាំងពួងនៃធម៌ទាំងអស់នោះ ដោយបទនេះ ដែលលោកសម្តែងដល់ការសម្រេចសព្វញ្ញុតញ្ញាណ ដែលបានដល់អនាវរណញ្ញាណ ដែលទាក់ទងដោយការអាចក្នុងការសម្រេចធម៌ទាំងពួង ដោយប្រការគ្រប់យ៉ាង វៀរការអាងអ្នកដទៃ ។

សួរថា អនាវរណញ្ញាណដទៃអំពីសព្វញ្ញុតញ្ញាណមិនមែនឬ ពាក្យដែលពោលថា អសាធារណញ្ញាណ ៦ ជាពុទ្ធញ្ញាណ ដោយប្រការដទៃ ក៏មិនខុសទៅហើយឬ ឆ្លើយថា មិនខុសទេ ព្រោះភាពដែលញាណ ១ ប៉ុណ្ណោះលោកពោល ២ យ៉ាង ដើម្បីសម្តែងការមិនទូទៅដោយញាណដទៃ ដោយប្រភេទ ដែលប្រព្រឹត្តទៅនៃវិស័យ ព្រោះញាណនោះតែម្យ៉ាងប៉ុណ្ណោះ លោកពោលថា ជាសព្វញ្ញុតញ្ញាណ ព្រោះជាវិស័យនៃធម៌ដែលសន្មតថាជាសង្ខតៈ និងអសង្ខតៈ ដោយមិនសេសសល់ ហើយលោកពោលថា ជាអនាវ-រណញ្ញាណ អាស្រ័យការប្រព្រឹត្ត ដែលអស់នូវការជាប់ជំពាក់ ព្រោះមិនមានគ្រឿងការពារក្នុងញាណនោះ ដូចលោកពោលក្នុងបដិសម្ភិទាមគ្គថា ព្រះតថាគតទ្រង់ជ្រាបសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ មិនមានសេសសល់ ហេតុនោះ ទើបឈ្មោះថា **សព្វញ្ញុតញ្ញាណ** គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ទើបឈ្មោះថា **អនាវរណញ្ញាណ** ... ដូច្នេះជាដើម ។ ព្រោះ

ដូច្នោះ ដោយអត្ថ ទើបញាណទាំង ២ នោះ មិនផ្សេងគ្នា គប្បីប្រាថ្នាញាណនេះ ដោយចំណែកមួយប៉ុណ្ណោះ ភាពដែលសព្វញ្ញុតញ្ញាណ និងអនាវរណញ្ញាណ ជាញាណទូទៅ មិនជាអារម្មណ៍នៃធម៌ទាំងពួង គប្បីជួបដោយប្រការដទៃ ។ ម្យ៉ាងទៀត ញាណរបស់ព្រះមានព្រះភាគ មិនមានគ្រឿងរារាំងសូម្បីត្រឹមអណូមួយ ។ ម្យ៉ាងទៀត ភាពដែលអនាវរណញ្ញាណ ជាប្រការដទៃ អំពីការមិនជាអារម្មណ៍នៃធម៌ទាំងពួង ប្រព្រឹត្តទៅមិនបាន ភាពជាអនាវរណញ្ញាណ ព្រោះកើតឯង ដោយជាគ្រឿងរារាំងក្នុងញាណក៏មិនមាន ។

ម្យ៉ាងទៀត អនាវរណញ្ញាណចាកសព្វញ្ញុតញ្ញាណ ចូរលើកទុក តែក្នុងទីនេះ លោកបំណងយកសព្វញ្ញុតញ្ញាណប៉ុណ្ណោះ ថាជាអនាវរណញ្ញាណ ព្រោះប្រព្រឹត្តទៅ ដោយមិនមានអ្វីរារាំងក្នុងទីទាំងពួង ។ ព្រះមានព្រះភាគជាព្រះសព្វញ្ញូ ទ្រង់ដឹងសព្វយ៉ាង ព្រោះសម្រេចសព្វញ្ញុតញ្ញាណនោះឯង ទើបលោកពោលថា ជាសម្មាសម្ពុទ្ធ ព្រោះដឹងនូវធម៌ទាំងពួង មិនមែនតែម្តងប៉ុណ្ណោះ ។ ម្យ៉ាងទៀត លោកពោលក្នុងមហានិទ្ទេសថា

> ព្រះនាមថា ព្រះពុទ្ធនោះ ជាព្រះនាមមានក្នុងទីបំផុតនៃវិមោក្ខរបស់ព្រះពុទ្ធទាំងឡាយទ្រង់មានជោគ ការបញ្ញត្តិថា ព្រះពុទ្ធនេះ ( កើត ) ដោយការធ្វើឲ្យជាក់ច្បាស់ ព្រមដោយការបាទចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( លោកពោលថា ) ចំពោះព្រះពុទ្ធនោះ ដូច្នេះ ។

ពិតហើយ ការដែលព្រះមានព្រះភាគទ្រង់អាចសម្រេចធម៌ មិនមាន

សេសសល់ក្នុងសន្តាន មានដោយការសម្រេចញាណ ដែលអាចឲ្យត្រាស់ដឹងធម៌ទាំងពួង ក្នុងទីនេះ លោកពោលថា ញាណនេះ កាលប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅក្នុងវិស័យទាំងអស់តែម្តងប៉ុណ្ណោះឬ ឬថា ប្រព្រឹត្តទៅតាមលំដាប់ ដូច្នេះ ។ ក្នុងសេចក្តីនេះ បើញាណប្រព្រឹត្តទៅក្នុងវិស័យទាំងអស់ត្រឹមតែម្តងប៉ុណ្ណោះ ការត្រាស់ដឹងដោយចំណែក ដូចរបស់អ្នកសម្លឹងចិត្តអំពីចម្ងាយ ក្នុងការចូលទៅតាំងរួមគ្នារបស់សង្ខតធម៌ទាំងឡាយដែលផ្សេងគ្នា មានអតីត អនាគត បច្ចុប្បន្ន ខាងក្នុង និងខាងក្រៅជាដើម និងសម្មតិធម៌ដែលជាអសង្ខតៈ ក៏មិនគប្បីមានឬ ។ កាលបើដូច្នោះ ញាណ រមែងត្រូវគ្នាក្នុងពាក្យថា ធម៌ទាំងពួងជាវិស័យនៃព្រះញាណរបស់ព្រះមានព្រះភាគ ដោយរូបដែលរលាយទៅ ដូចដោយអាការជាអនត្តារបស់បុគ្គលដែលឃើញថា **សព្វេ ធម្មា អនត្តា** ធម៌ទាំងពួងជាអនត្តា ដូច្នេះ ។ ជនពួកណាពោលថា ព្រះញាណនៃព្រះពុទ្ធទាំងឡាយ វៀរការកំណត់ដែលជាវិស័យនៃលក្ខណៈញេយ្យធម៌ទាំងពួងតាំងនៅ រមែងប្រព្រឹត្តទៅសព្វកាល ដោយហេតុនោះ ទើបព្រះពុទ្ធទាំងឡាយនោះ ឈ្មោះថា **សព្វវិទូ** កាលពោលយ៉ាងនេះហើយ សូម្បីពាក្យថា បុគ្គលដ៏ប្រសើរ កាលដើរទៅ ក៏តាំងមាំ កាលឈរ ក៏តាំងមាំ ដូច្នេះ ជាពាក្យដែលត្រូវហើយ សូម្បីទោសដែលពោលដូច្នោះ ក៏មិនមានដល់ជនទាំងនោះ ។ ព្រះញាណនៃព្រះមានព្រះភាគ គប្បីជាវិស័យចំពោះប៉ុណ្ណោះ ព្រោះលក្ខណៈនៃញេយ្យធម៌ ដែលតាំងនៅជាអារម្មណ៍ និងព្រោះមិនមានសម្មតិធម៌ជាអតីត និងអនាគត ព្រោះដូច្នោះ ដែលលោកពោល

ថា ព្រះញាណរមែងប្រព្រឹត្តទៅតែម្តងប៉ុណ្ណោះ ដូច្នេះ ទើបមិនត្រឹមត្រូវ ។ ទោះបីពោលថា ព្រះញាណរមែងប្រព្រឹត្តទៅក្នុងវិស័យទាំងពួងតាមលំដាប់យ៉ាងនេះ ក៏មិនត្រឹមត្រូវ ។ ព្រោះថា កាលកំណត់យកញេយ្យធម៌ ដែលផ្សេងគ្នាមិនតិច ដោយសភាពជាតិ និងភូមិជាដើម និងដោយទិស ទឹកដី និងកាលជាដើម តាមលំដាប់ការត្រាស់ដឹងញេយ្យធម៌នោះ ដោយមិនសេសសល់ រមែងកើតមិនបាន ព្រោះញេយ្យធម៌មិនមានទីបំផុត ។ ជនពួកណាពោលថា ព្រះមានព្រះភាគ ព្រះសព្វញ្ញូ ដោយកំណត់សញ្ញាថា ធ្វើញេយ្យ-ធម៌ឲ្យប្រចក្ស ជាឯកទេស ព្រោះមិនភ្លាត់ចាកប្រយោជន៍ សូម្បីដែលសេសសល់ ក៏យ៉ាងនោះ ដូច្នេះ ព្រះញាណនោះ មិនមានការត្រិះរិះ ព្រោះអស់សេចក្តីសង្ស័យ ពិតហើយ ញាណដែលនៅមានការត្រិះរិះក្នុងលោក នៅពាក់ព័ន្ធដោយសេចក្តីសង្ស័យ ដូច្នេះ វាចារបស់ជនទាំងនោះ មិនត្រូវ ព្រោះមិនមានការកំណត់សញ្ញាថា នឹងធ្វើឲ្យប្រចក្សជាឯកទេសនៃញេយ្យធម៌ ដោយមិនភ្លាំងភ្លាត់ប្រយោជន៍ ក្នុងកាលញេយ្យធម៌ទាំងពួងមិនប្រចក្ស សូម្បីដ៏សេសក៏យ៉ាងនោះ ដូច្នេះ ។ ព្រោះញាណដ៏សេស ក៏មិនប្រចក្ស កាលបើដូច្នោះញាណនោះប្រចក្ស ការដែលញាណនោះសល់ ក៏មិនគប្បីមាន ព្រោះហេតុនោះ ទើបញាណទាំងអស់មិនជាហេតុ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះផុតវិស័យដែលត្រូវត្រិះរិះ សមដូចព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរ-និកាយ ចតុក្កនិបាតថា **ពុទ្ធានំ ភិក្ខវេ ពុទ្ធវិសយោ អចិន្តេយ្យោ ន ចិន្តេ-តព្វោ យំ ចិន្តេន្តោ ឧម្មាទស្ស វិឃាតស្ស ភាគី អស្ស** ម្នាលភិក្ខុទាំងឡាយ

ពុទ្ធវិស័យរបស់ព្រះពុទ្ធទាំងឡាយ ជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្តីឆ្កួត និងសេចក្តីលំបាកទទេ ដូច្នេះ ។ សេចក្តីសន្និដ្ឋានក្នុងរឿងនេះ ដូច្នេះថា ញាណណាមួយដែលព្រះមានព្រះភាគទ្រង់ប្រាថ្នា ទ្រង់ដឹងទាំងអស់ ឬឯកទេសព្រះញាណប្រព្រឹត្តទៅដោយប្រចក្ស ព្រោះមិនមានអ្វីធ្វើឲ្យទើសទាក់ក្នុងព្រះញាណនោះ ។ ម្យ៉ាងទៀត ការតាំងមាំជានិច្ច ក៏គប្បីមានមិនបានព្រោះប្រព្រឹត្តទៅទាក់ទងដោយការប្រាថ្នារបស់លោក ដោយមិនមែនវិស័យរបស់ញាណទាំងអស់ ដែលបុគ្គលប្រាថ្នានឹងដឹង ព្រោះមិនមានការរាយមាយ គប្បីប្រាថ្នាការសង្ស័យនោះដោយចំណែកមួយប៉ុណ្ណោះ ។

ព្រះញាណរបស់ព្រះមានព្រះភាគ សូម្បីជាវិស័យក្នុងអតីត ឬអនាគត ក៏ជាព្រះញាណប្រចក្ស ព្រោះវៀរចាកការប្រកាន់ ដោយការគិតគ្នេរ និងកាន់យកដោយការត្រិះរិះ ដោយបាលីក្នុងមហានិទ្ទេសថា ធម៌ទាំងអស់ជាប់ដោយការនឹក ជាប់ដោយការប្រាថ្នា ជាប់ដោយការធ្វើទុកក្នុងចិត្ត ជាប់ដោយចិត្តុប្បាទនៃព្រះពុទ្ធមានព្រះភាគ ដូច្នេះ ។ សួរថា ទោសនៃបុគ្គលដែលពោលថា ក្នុងចំណែកមួយប្រាថ្នាដឹងនូវញាណទាំងមូលកាលណា កាលនោះ ញាណរបស់ព្រះមានព្រះភាគ ដែលជាសកលវិស័យតែមួយប៉ុណ្ណោះ គប្បីប្រព្រឹត្តទៅដោយរូបដែលបែកធ្លាយទៅ ដូច្នេះ ទើបមិនមានមិនមែនឬ ឆ្លើយថា ព្រះញាណនោះមិនទាន់បរិសុទ្ធ ។ ពិតហើយ ពុទ្ធវិស័យនោះ ជាអចិន្តេយ្យបរិសុទ្ធ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ភាពជាអចិន្តេយ្យនៃព្រះញាណ

របស់ព្រះមានព្រះភាគ ដែលជាពុទ្ធៈគប្បីមានមិនបាន ព្រោះប្រព្រឹត្តទៅស្មើ ជាមួយញាណរបស់ជនច្រើន ដោយប្រការដទៃ ព្រោះដូច្នោះ សូម្បីធម៌ទាំង អស់ជាអារម្មណ៍ ក៏ធ្វើធម៌ទាំងនោះឲ្យកំណត់ល្អហើយ ឲ្យប្រព្រឹត្តទៅដូចធម៌ នោះ មានធម៌តែមួយជាអារម្មណ៍ ព្រោះហេតុនោះ ទើបព្រះញាណនេះ ជាអចិន្តេយ្យក្នុងទីនេះ ។

ព្រះមានព្រះភាគ ឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួង ដោយប្រពៃ និងដោយព្រះអង្គឯង តាមសមគួរដល់សេចក្តីប្រាថ្នា ដោយ កម្មផ្សេងវារៈគ្នា ឬតាមលំដាប់ ក្នុងទីជាមួយគ្នាយ៉ាងនេះថា ញេយ្យធម៌ មានប្រមាណប៉ុនណា ញាណក៏មានប្រមាណប៉ុណ្ណោះ ញាណមានប្រមាណ ប៉ុនណា ញេយ្យធម៌ក៏មានប្រមាណប៉ុណ្ណោះ ញាណមានញេយ្យធម៌ជាទី បំផុត ញេយ្យធម៌ក៏មានញាណជាទីបំផុត នុ៎ះគឺ **សម្មាសម្ពុទ្ធ** ។

បទថា **ទ្វេ វិតក្កា** បានដល់ សម្មាវិតក្ក ២ យ៉ាង ។ ក្នុងវិតក្ក ២ យ៉ាងនោះ ដែលឈ្មោះថា **វិតក្ក** ព្រោះត្រិះរិះ ឬជាហេតុត្រិះរិះ ឬការត្រិះរិះ វិតក្កនោះ មានការបណ្តុះនូវអារម្មណ៍ជាលក្ខណៈ មានការប៉ះខ្ទប់ជាកិច្ច មាន ការនាំចិត្តមកក្នុងអារម្មណ៍ជាអាការប្រាកដ ។ ព្រះមានព្រះភាគត្រាស់ថា **ទ្វេ វិតក្កា** ព្រោះធ្វើចិត្តនោះឲ្យជា ២ ដោយប្រភេទនៃវិស័យ ។ បទថា **សមុទាចរន្តិ** បានដល់ រមែងប្រព្រឹត្តទៅរឿយៗ ស្មើ និងដោយប្រពៃ ។ អាការ នេះមានសេចក្តីថា ព្រំដែន ។ ពាក្យថា ចំពោះព្រះតថាគតអរហន្តសម្មា-សម្ពុទ្ធ នេះ ដោយប្រយោគនោះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ មាន

អធិប្បាយថា វិតក្ក ២ ប្រការរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ មិនឈានកន្លងព្រំដែនគ្នានិងគ្នា និងដោយប្រពៃក្នុងវិស័យរបស់ខ្លួន ប្រព្រឹត្តទៅរឿយៗ សួរថា អ្វីជាវិស័យរបស់វិតក្កទាំងនោះ ឬអ្វីជាព្រំដែន វិតក្កទាំងនោះមិនឈានកន្លងព្រំដែនរឿយៗ ហើយ ប្រព្រឹត្តទៅដូចម្តេច ឆ្លើយថា វិតក្កទាំង ២ យ៉ាងនេះ គឺ **ខេមវិតក្ក ១ វិវេកវិតក្ក ១** ឈ្មោះថា វិតក្ក ក្នុងវិតក្ក ២ យ៉ាងនោះ **ខេមវិតក្ក** ប្រកបដោយករុណាយ៉ាងវិសេសរបស់ព្រះមានព្រះភាគ ហើយបានប្រកបដោយមេត្តា និងមុទិតាទៀត ព្រោះដូច្នោះ ខេម-វិតក្កនោះ គប្បីជ្រាបថា ជាចំណែកខាងដើម និងប្រកបដោយមហាករុណាសមាបត្តិ និងមេត្តាសមាបត្តិជាដើម ។ ឯវិវេកវិតក្ក ជាចំណែកខាងដើម និងប្រកបដោយផលសមាបត្តិ នៅបានទទួលទិព្វវិហារធម៌ទៀតជាដើម ។ វិវេកជាវិស័យរបស់វិតក្ក ២ យ៉ាងនោះ ដោយប្រការដូច្នេះ ព្រោះដូច្នោះ វិតក្ក ២ ប្រការ សូម្បីប្រព្រឹត្តទៅច្រើនក្នុងសន្តានមួយ ក៏មិនមានដោយការប្រព្រឹត្តទៅរួមវិស័យអស់កាលនោះឯង ព្រំដែនក៏មិនមានការប្រព្រឹត្តទៅលាយឡំគ្នា ។

ក្នុងវិតក្ក ២ យ៉ាងនោះ ខេមវិតក្កគប្បីឲ្យជាក់ច្បាស់ ដោយការឈមចុះកាន់ព្រះករុណារបស់ព្រះមានព្រះភាគ វិវេកវិតក្ក គប្បីឲ្យជាក់ច្បាស់ដោយសមាបត្តិទាំងឡាយ ។ តអំពីនេះទៅ ជាការជាក់ច្បាស់ក្នុងខេមវិតក្កនោះ គួរពោលដល់ខេមវិតក្ក ដោយអំណាចបឋមជ្ឈាន ក្នុងសមាបត្តិជាចំណែកខាងដើមនៃមហាករុណាសមាបត្តិ ដោយការឃើញអាការ មានការដែលលោក-សន្និវាសជារបស់ក្តៅដោយភ្លើងជាដើម មានភ្លើង គឺរាគៈជាដើម ដោយន័យ

ជាដើមថា លោកនេះត្រូវភ្លើងឆេះ មានតែទុក្ខ ដូច្នេះ ។ សមដូចលោកពោលថា

កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញដោយអាការច្រើន មហាករុណា រមែងចុះស៊ប់ក្នុងពួកសត្វ គឺកាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា លោកសន្និវាស ត្រូវភ្លើងឆេះសព្វហើយ មហាករុណាចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា លោកសន្និវាស មានសេចក្តីខ្វល់ខ្វាយ ( ជានិច្ច ) លោកសន្និវាស មានដំណើរទៅ ( ជានិច្ច ) លោកសន្និវាស ដើរទៅកាន់ផ្លូវខុស សត្វលោកមិនទៀង ត្រូវជរានាំចូលទៅ ( រកសេចក្តីស្លាប់ ) សត្វលោកឥតមានទីពឹងឥតមានទីផ្អែក សត្វលោកគ្មានអ្វីជារបស់ខ្លួន ត្រូវលះបោលរបស់ទាំងអស់ ហើយទៅ សត្វលោក មានសេចក្តីខ្វះខាតមិនឆ្អែត ជាទាសៈនៃតណ្ហា លោកសន្និវាស ឥតទីពឹងលោកសន្និវាស ឥតទីពួន លោកសន្និវាស មិនមានវត្ថុជាទីរឭក សត្វលោកកំពុងរវើរវាយ មិនស្ងប់រម្ងាប់ លោកសន្និវាសប្រកបដោយសរមុតហើយ ដោយសរផ្សេងៗ បុគ្គលដទៃនីមួយ ក្រៅពីតថាគត នឹងដកសររបស់លោកសន្និវាសនោះមិនមានឡើយ លោកសន្និវាស មានងងឹត គឺអវិជ្ជា ជាគ្រឿងរាំង ធ្លាក់ចុះក្នុងទ្រុង គឺកិលេស បុគ្គលដទៃនីមួយ ជាអ្នក

បង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស លុះក្នុងអំណាចអវិជ្ជា ជាអ្នកងងឹតងងុល ត្រូវអវិជ្ជារួបរឹត សាំញ៉ាំ ដូចអំបោះនៃជាងតម្បាញស្មុគស្មាញ ដូចអំបោះដែលជាងតម្បាញប្រឡាក់ដោយទឹកបាយដូចស្មៅយាប្លង និងស្មៅជំណោកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ លោកសន្និវាសជាប់ដោយទោស គឺពិសនៃអវិជ្ជា ប្រកបដោយកំហុស គឺកិលេស លោកសន្និវាស ត្រូវរាគៈ ទោសៈ មោហៈចាក់ស្រេះហើយ បុគ្គលដទៃទីមួយ ជាអ្នកដោះនូវបណ្ដាញរបស់លោក-សន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាសសឹកចុះក្នុងឃ្នាប គឺតណ្ហា លោកសន្និវាស ត្រូវបណ្ដាញ គឺតណ្ហារួបរឹត លោកសន្និវាស ត្រូវខ្សែតណ្ហាបន្សាត់ទៅហើយលោកសន្និវាស ប្រកបហើយដោយចំណង គឺតណ្ហា លោក-សន្និវាស ត្រាំនៅក្នុងតម្រាំ គឺតណ្ហា លោកសន្និវាស ក្ដៅដោយកម្ដៅ គឺតណ្ហា លោកសន្និវាស ក្ដៅក្រហាយ ដោយសេចក្ដីក្ដៅក្រហាយ គឺតណ្ហា លោកសន្និវាស សឹកចុះក្នុងឃ្នាប គឺទិដ្ឋិ លោកសន្និវាស ត្រូវបណ្ដាញ គឺទិដ្ឋិរួបរឹតហើយលោកសន្និវាស ត្រូវខ្សែទិដ្ឋិបន្សាត់ទៅ លោកសន្និវាស ប្រកបដោយគ្រឿងប្រកប គឺទិដ្ឋិ លោកសន្និវាស ត្រាំនៅក្នុងតម្រាំគឺទិដ្ឋិ លោកសន្និវាស ក្ដៅដោយកម្ដៅ គឺទិដ្ឋិ លោកសន្និវាស

ក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយ គឺទិដ្ឋិ លោកសន្និវាស ប្រកបដោយជាតិជានិច្ច លោកសន្និវាស ត្រាំក្នុងជរា លោកសន្និវាស ត្រូវព្យាធិគ្របសង្កត់ហើយ លោកសន្និវាស ត្រូវមរណៈបៀតបៀន លោកសន្និវាស មានទុក្ខធ្លាក់ត្រូវហើយ លោកសន្និវាស ត្រូវតណ្ហាទាក់ជាប់ហើយ លោកសន្និវាស ស្រោបហើយ ដោយកំពែង គឺជរា លោកសន្និវាស ត្រូវអន្ទាក់ គឺមច្ចុរឹតរួត លោកសន្និវាស ជាប់ដោយចំណងច្រើន គឺចំណងរាគៈ ចំណងទោសៈ ចំណងមោហៈ ចំណងមានះ ចំណងទិដ្ឋិ ចំណងកិលេស ចំណងទុច្ចរិត បុគ្គលដទៃទីមួយ ជាអ្នកស្រាយនូវចំណងរបស់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ដើរទៅកាន់ទីចង្អៀតខ្លាំង បុគ្គលដទៃទីមួយ ជាអ្នកបង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស មានកង្វល់ ដោយកង្វល់ច្រើន បុគ្គលដទៃទីមួយ ជាអ្នកកាត់នូវកង្វល់របស់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ធ្លាក់ចុះក្នុងជ្រោះធំ បុគ្គលដទៃទីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចពីជ្រោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ដើរទៅកាន់ផ្លូវលំបាកខ្លាំង បុគ្គលដទៃទីមួយ ជាអ្នកចម្លងលោកសន្និវាសនោះ ឲ្យឆ្លងផ្លូវលំបាក ក្រៅពីតថាគត មិន

មានឡើយ លោកសន្និវាស ដើរទៅក្នុងមហាសង្គ្រាម បុគ្គលដទៃទីមួយ ជាអ្នកស្រោយលោកសន្និវាសនោះ ឲ្យរួចចាកសង្គ្រាម ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស វិលវល់នៅក្នុងផ្លូវកម្រខ្វាំង បុគ្គលដទៃទីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចចាកផ្លូវកម្រ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស លិចចុះក្នុងល្បាប់ជ្រៅ ត្រូវភ្លើង គឺរាគៈ ភ្លើង គឺទោសៈ ភ្លើង គឺមោហៈ និងជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ញាំញីហើយ បុគ្គលដទៃទីមួយ ជាអ្នកលត់ភ្លើង របស់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស អណ្តែតឡើង ឥតមានទីពឹងជានិច្ច មានអាជ្ញាត្រូវហើយ ធ្វើតាមតែអាជ្ញានោះរមែងលំបាក លោកសន្និវាស ជាប់ចំណងវដ្តៈ ប្រាកដក្នុងទីសម្រាប់សម្លាប់ បុគ្គលដទៃទីមួយ ជាអ្នកស្រាយចំណងឲ្យដល់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ឥតមានទីពំនាក់ ដល់នូវភាពគួរអាណិតក្រៃពេក បុគ្គលដទៃទីមួយ ជាអ្នកជួយស្រោចស្រង់លោកសន្និវាសនោះ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ត្រូវសេចក្តីទុក្ខចាក់ដោតហើយ ត្រូវសេចក្តីទុក្ខ បៀតបៀនហើយអស់កាលយូរ លោកសន្និវាស ជាប់ចំពាក់ជានិច្ច ស្រេក

ឃ្លានជានិច្ច លោកសន្និវាស ខ្វាក់ ឥតមានចក្ខុ លោកសន្និ-វាស មានភ្នែកវិនាសហើយ ឥតមានអ្នកដឹកដៃ លោកសន្និ-វាស ស្ទុះទៅកាន់ផ្លូវខុស ដើរខុសផ្លូវ បុគ្គលដទៃទីមួយ ជាអ្នកនាំលោកសន្និវាសនោះ ឲ្យដើរទៅកាន់ផ្លូវដ៏ប្រសើរ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ស្ទុះទៅក្នុងជំនន់ធំ បុគ្គលដទៃទីមួយ ជាអ្នកស្រង់នូវលោកសន្និវាសនោះ អំពីជំនន់ ក្រៅពីតថាគត មិនមានឡើយ លោកសន្និវាស ត្រូវទិដ្ឋិទាំងពីររួបរឹត លោកសន្និវាស ប្រតិបត្តិខុស ព្រោះទុច្ចរិតទាំង ៣ លោកសន្និវាស ពេញដោយយោគធម៌ ប្រកបដោយយោគធម៌ទាំង ៤ លោកសន្និវាស ចាក់ស្រែះហើយ ដោយគន្ថកិលេសទាំង ៤ លោកសន្និវាស ប្រកាន់មាំដោយឧបាទានទាំង ៤ លោកសន្និវាស ឡើងកាន់គតិទាំង ៥ លោកសន្និវាស រមែងត្រេកអរដោយកាមគុណទាំង ៥ លោកសន្និវាស ត្រូវនីវរណៈទាំង ៥ គ្របសង្កត់ហើយ លោកសន្និវាស រមែងវិវាទដោយវិវាទមូលទាំង ៦ លោកសន្និវាស រមែងត្រេកអរដោយតណ្ហាកាយទាំង ៦ លោកសន្និវាស ត្រូវទិដ្ឋិទាំង ៦ រួបរឹតហើយ លោកសន្និវាស ត្រាំនៅហើយ ដោយតម្រាំទាំង ៧ លោកសន្និវាស ប្រកបហើយ ដោយសំយោជនៈទាំង ៧ លោកសន្និវាស ប៉ោងឡើងហើយ ដោយមានះទាំង ៧ លោក-

សន្និវាស វិលវល់តាមលោកធម៌ទាំង ៨ លោកសន្និវាស ទៀងដោយមិច្ឆត្តធម៌ទាំង ៨ លោកសន្និវាស រមែងប្រទូស្តដោយទោស សម្រាប់បុរស ៨ លោកសន្និវាស ចងគំនុំដោយអាឃាតវត្ថុទាំង ៩ លោកសន្និវាស ប៉ោងឡើងហើយ ដោយមានះទាំង ៩ លោកសន្និវាស រមែងត្រេកអរដោយតណ្ហាមូលកធម៌ទាំង ៩ លោកសន្និវាស រមែងសៅហ្មងដោយកិលេសវត្ថុទាំង ១០ លោកសន្និវាស ចងគំនុំដោយអាឃាតវត្ថុទាំង ១០ លោកសន្និវាស ប្រកបព្រមហើយ ដោយអកុសលកម្មបថទាំង ១០ លោកសន្និវាស ប្រកបដោយសញ្ញោជនៈទាំង ១០ លោកសន្និវាស ទៀងដោយមិច្ឆត្តធម៌ទាំង ១០ លោកសន្និវាស ប្រកបហើយ ដោយមិច្ឆាទិដ្ឋិមានវត្ថុ ១០ លោកសន្និវាស ប្រកបហើយ ដោយសក្កាយទិដ្ឋិមានវត្ថុ ១០ លោកសន្និវាស ត្រូវបបញ្ចធម៌ គឺតណ្ហាទាំង ១០៨ ឲ្យយឺតយូរហើយ លោកសន្និវាស ត្រូវទិដ្ឋិទាំង ៦២ រួបរឹតហើយ តថាគតឆ្លងរួចហើយ ឯសត្វលោក មិនទាន់ឆ្លងនៅឡើយ តថាគត រួចហើយ ឯសត្វលោក មិនទាន់រួចនៅឡើយ តថាគត ហ្វឹកហ្វឺនហើយ ឯសត្វលោក មិនទាន់ហ្វឹកហ្វឺននៅឡើយ តថាគត ស្ងប់ហើយ ឯសត្វលោក មិនទាន់ស្ងប់នៅឡើយ តថាគត សប្បាយចិត្តហើយ ឯសត្វលោក មិនទាន់សប្បាយចិត្តនៅ

ឡើយ តថាគត រលត់កិលេសហើយ ឯសត្វលោក មិនទាន់ រលត់កិលេសនៅឡើយ តថាគត ធ្ងន់ហើយ ដើម្បីចម្លង ( សត្វលោក ) តថាគត រួចហើយ ដើម្បីញ៉ាំងសត្វលោក ឲ្យរួច តថាគត ហ្វឹកហ្វឺនហើយ ដើម្បីហ្វឹកហ្វឺនសត្វលោក តថាគត ស្ងប់រម្ងាប់ហើយ ដើម្បីញ៉ាំងសត្វលោកឲ្យស្ងប់រម្ងាប់ តថាគត សប្បាយចិត្តហើយ ដើម្បីញ៉ាំងសត្វលោកឲ្យសប្បាយ ចិត្ត តថាគត រលត់កិលេសហើយ ដើម្បីញ៉ាំងសត្វលោកឲ្យ រលត់កិលេស មហាករុណាក៏ចុះស៊ប់ ក្នុងពួកសត្វ នេះឈ្មោះ ថា មហាករុណាសមាបត្តិញ្ញាណរបស់ព្រះតថាគត ដូច្នេះ[១] ។

ការឈមចុះកាន់មេត្តាក្នុងសត្វទាំងឡាយ របស់ព្រះមានព្រះភាគ គប្បី ឲ្យជាក់ច្បាស់ដោយន័យនេះឯង ។ ពិតហើយ សូម្បីមេត្តាបង្អោនទាំសេចក្ដី សុខដែលជាបដិបក្ខចំពោះទុក្ខ ដែលជាវិស័យនៃករុណា ចូលទៅក្នុងសត្វទាំង ឡាយ ក៏គង់ប្រព្រឹត្តទៅបាន ព្រោះហេតុនោះ ទើបអព្យាបាទវិតក្ក និង អវិហិង្សាវិតក្ក ឈ្មោះថា **ខេមវិតក្ក** ក្នុងបទនេះ ។ ឯ **វិវេកវិតក្ក** បានដល់ នេក្ខម្មវិតក្កនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបការប្រព្រឹត្តទៅដោយអំណាច ការពិចារណាបឋមជ្ឈាន ដែលជាចំណែកខាងដើម ក្នុងទិព្វវិហារធម៌ និង អរិយវិហារធម៌ នៃវិវេកវិតក្កនោះ ។ ក្នុងវិវេកវិតក្កនោះ សមាបត្តិវិហារ ធម៌ពួកណា ដែលរាប់បាន ២ លាន ៤ សែនកោដិ ដែលព្រះមានព្រះភាគ

---

១- សេចក្ដីពិស្ដារ មានក្នុងបិ. ៦៩ ទំ. ២៨៣ ។

ទ្រង់ប្រើរាល់ៗ ថ្ងៃ ព្រះញាណដែលទាក់ទងដោយសមាធិចរិយា និងញាណ-ចរិយា ដែលប្រព្រឹត្តទៅហើយ ដោយការប្រព្រឹត្តមុន និងសមាបត្តិ ២ លាន ៤ សែនកោដិ និងបញ្ញារបស់សមាបត្តិវិហារធម៌ពួកណា លោកពោលថា ជាមហាវជិរញ្ញាណ គប្បីជ្រាបការប្រព្រឹត្តទៅរឿយៗ នៃវិវេកវិតក្ករបស់ព្រះមានព្រះភាគ ដោយអំណាចនៃសមាបត្តិវិហារធម៌ទាំងនោះ ។ ម្យ៉ាងទៀត គប្បីចង្អុលបង្ហាញអត្ថនេះ ដោយមហាសច្ចកសូត្រ ។ ក្នុងសូត្រនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង តែងនៅអស់កាលជានិច្ច ដោយផលសមាធិណា កាលបើចប់គាថានោះហើយ តថាគតក៏តម្រង់ ទប់ទល់ តម្កល់ចិត្តខាងក្នុង ធ្វើឲ្យជាចិត្តមានអារម្មណ៍តែមួយ ក្នុងសមាធិនិមិត្តដែលមានហើយអំពីមុននោះឯង ដោយផលសមាធិនោះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់នាំសូត្រនេះមក ដើម្បីសម្តែងថា កាលសច្ចក-និគណ្ឋបុត្រពោលថា សមណគោតមមានរូបស្អាត គួរជ្រះថ្លា ចន្លោះព្រះទន្តជិតស្និទ្ធជាជួរ ព្រះជិវ្ហាទន់ ព្រះសូរសៀងដ៏ពីរោះ គង់នឹងឲ្យបរិស័ទពេញចិត្ត ដោយហេតុនោះ ទើបត្រាច់ទៅ តែក្នុងចិត្តរបស់សមណគោតម ដែលត្រាច់ប្រកាសឲ្យដឹងយ៉ាងនេះ តែងមិនមានសមាធិ ម្នាលអគ្គិវេស្សនៈ តថាគតមិនបានត្រាច់ប្រកាសឲ្យបរិស័ទពេញចិត្ត ដូចចាប់ចោរ មួយអន្លើដោយកស្តុតាងពិតប្រាកដ តថាគតសម្តែងធម៌ដល់បរិស័ទ មានចក្រវាលជាទីបំផុត ឲ្យនូវការសមគួរ មិនលាក់បាំង មិនជាប់ ប្រកបផលនៃផលសមាបត្តិនោះឯង ព្រោះស្ងាត់ដោយមានប្រក្រតី នៅដោយអារម្មណ៍តែមួយ ដូច្នេះ ។

ពិតហើយ ព្រះមានព្រះភាគ ទ្រង់កំណត់កាលដោយចំណែកខាងដើម ក្នុងខណៈដែលបរិស័ទឲ្យនូវសាធុការ ឬពិចារណានូវធម៌ ហើយទ្រង់ចូលផលសមាបត្តិ ក្នុងខណៈខ្យល់ដង្ហើមចូលចេញ ម្យ៉ាងទៀត កាលអស់នូវសំឡេងសាធុការ ទ្រង់មិនបានកំណត់ ទ្រង់ចេញអំពីសមាបត្តិក្នុងទីបំផុតនៃការពិចារណាធម៌ហើយ ទើបទ្រង់សម្តែងធម៌ ផ្តើមអំពីពេលដែលទ្រង់ផ្អាក ។ ពិតហើយ ការចូលកាន់ភវង្គរបស់ព្រះពុទ្ធទាំងឡាយស្រាលស្តើង ព្រះពុទ្ធទាំងឡាយទ្រង់ចូលសមាបត្តិ ក្នុងខណៈនៃខ្យល់ដង្ហើមចូលចេញ ។ គប្បីជ្រាបការប្រព្រឹត្តទៅរឿយៗ នៃខេមវិតក្ក និងវិវេកវិតក្ករបស់ព្រះមានព្រះភាគដោយអំណាចសមាបត្តិតាមដែលពោលហើយ ដែលប្រព្រឹត្តទៅដោយចំណែកខាងដើម ដោយប្រការដូច្នេះ ។

ក្នុងការប្រព្រឹត្តទៅរឿយៗ នោះ ព្រះមានព្រះភាគ មានធម៌នោះជាសមង្គី និងទ្រង់សម្រេចធម៌ដ៏ក្សេម ព្រោះមិនមានភ័យអំពីណាឡើយ ដោយអានុភាពនៃអព្យាបាទវិតក្ក និងអវិហិង្សាវិតក្ក ដែលលះនូវការសៅហ្មង មានព្យាបាទវិតក្ក និងវិហិង្សាវិតក្កជាដើម ។ បន្ទាប់អំពីនោះ ចិត្តក៏មានការក្សេមផុតភ័យសព្វកាល ព្រោះដូច្នោះ ខេមវិតក្កទាំង ២ យ៉ាង ក៏រមែងធ្វើនូវការក្សេមដល់ធម៌ទាំង ២ ផងដែរ ។ វិវេក ៣ យ៉ាង គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ និងវិវេក ៥ យ៉ាង គឺតទង្គវិវេក ១ វិក្ខម្ភនវិវេក ១ សមុច្ឆេទវិវេក ១ បដិបស្សទ្ធិវិវេក ១ និស្សរណវិវេក ១ រមែងដល់នូវការបរិបូណ៌ ដោយអានុភាពនៃនេក្ខម្មវិតក្ក ដែលលះនូវការសៅហ្មង មានការ

វិតក្កជាដើម ។

វិតក្កនោះ ឈ្មោះថា **វិវេកវិតក្ក** ព្រោះសហគតៈដោយការស្ងាត់ចាក អារម្មណ៍ និងចាកសម្បយោគ តាមសមគួរ ។ វិតក្ក ២ យ៉ាងនោះ សូម្បី មានលក្ខណៈដែលបែកចេញហើយ ក៏នៅតែប្រព្រឹត្តទៅដើម្បីភាពជាឧបការៈ ដល់គ្នានិងគ្នានៃបុគ្គលដែលជាអាទិកម្មិក ។

ពិតហើយ **វិវេកវិតក្ក** រមែងមានដើម្បីខេមវិតក្កដែលមិនទាន់កើត ដែលកើតហើយ ក៏ដើម្បីការបរិបូណ៌ក្រៃលែងឡើង យ៉ាងណា ខេមវិតក្ក ក៏ដូច្នោះ រមែងមានដើម្បីវិវេកវិតក្ក ដែលមិនទាន់កើតឲ្យកើតឡើង ដែលកើត ហើយក៏ឲ្យបរិបូណ៌ក្រៃលែងឡើង ។ ពិតហើយ មេត្តាវិហារធម៌ជាដើម នឹង មិនមានក្នុងរវាងដែលកាយ និងចិត្តចៀសចេញ ព្រោះវៀរចាកការលះនូវ ព្យាបាទជាដើម ចិត្តវិវេកជាដើមក៏មិនមាន ព្រោះហេតុនោះ គប្បីឃើញធម៌ ទាំងនេះថា មានឧបការៈដល់គ្នានិងគ្នា ។ ខេមវិតក្ក និងវិវេកវិតក្ករបស់ព្រះ មានព្រះភាគដែលទ្រង់លះនូវការសៅហ្មងបាន ដោយប្រការទាំងពួង តែងនាំ ប្រយោជន៍សុខ សូម្បីត្រឹមខណៈខ្យល់ដង្ហើមចេញចូល ដើម្បីជាប្រយោជន៍ ដល់សត្វលោក ។ គប្បីជ្រាបបទថា **ខេមោ ច វិតក្កោ បវិវេកោ ច វិតក្កោ** ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ពោលពាក្យជាដើមថា **អព្យាបជ្ឈា រាមោ** ដូច្នេះ ដើម្បីទ្រង់ចង្អុលបង្ហាញដល់វិតក្ក ២ យ៉ាង ដែលទ្រង់លើកឡើង មកសម្តែងហើយ ដោយប្រការដូច្នេះ ។

ការមិនបៀតបៀន ការមិនធ្វើឲ្យបុគ្គលណាម្នាក់លំបាក ឈ្មោះថា **អព្យាបជ្ឈ** ក្នុងបទថា **អព្យាបជ្ឈា រាមោ** នោះ ការមិនព្យាបាទនោះ ឈ្មោះថា **អព្យាបជ្ឈា រាមោ** ព្រោះមានការមិនព្យាបាទជាទីមកត្រេកអរ ឈ្មោះថា **អព្យាបជ្ឈរតោ** បានដល់ ត្រេកអរហើយក្នុងការមិនព្យាបាទ គឺមិនត្រេកអរក្នុងសេវនៈ ។ បទថា **ឃសេវ** កាត់បទជា **ឃសោ ឃវ** ។ បទថា **តិរិយាយ** គឺដោយការធ្វើ អធិប្បាយថា ដោយការខ្វល់ខ្វាយផ្លូវកាយ និងវាចា ។ បទថា **ន កិញ្ចិ ព្យាពាធេមិ** បានដល់ តថាគតនឹងមិនបៀតបៀន មិនធ្វើឲ្យបណ្ដាសត្វណាមួយជាដើម ដែលតក់ស្លុត ព្រោះប្រកបដោយសេចក្ដីតក់ស្លុត គឺតណ្ហាជាដើម ជាអ្នកមាំទាំ ព្រោះលះកិលេសទាំងពួង ដែលធ្វើឲ្យក្ដៅក្រហាយបានហើយ ព្រោះមិនមានសេចក្ដីព្យាបាទនោះឲ្យលំបាក ។

ព្រះមានព្រះភាគ ដែលមានព្រះករុណាជាអធ្យាស្រ័យ ច្រើនដោយមហាករុណាសមាបត្តិ ត្រាស់យ៉ាងនេះ សមគួរដល់ព្រះករុណាជាអធ្យាស្រ័យ ដែលទ្រង់ទន់ភ្លន់យ៉ាងក្រៃលែង ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្ដែងដល់អវិហិង្សាវិតក្ក និងអព្យាបាទវិតក្ក ។ ព្រះមានព្រះភាគត្រាស់សេចក្ដីនេះថា តថាគតបដិបត្តិយ៉ាងនេះ នៅដោយសមាបត្តិវិហារធម៌យ៉ាងនេះ ទទួលសក្ការៈ សេចក្ដីគោរព ការរាប់អាន ការថ្វាយបង្គំ និង ការបូជា ដែលអ្នកប្រាថ្នាបុណ្យធ្វើយ៉ាងនេះ ដោយកិរិយានេះ គឺដោយបដិបត្តិនេះ ទើបមិនបៀតបៀនសត្វណាមួយឡើយ ។ មួយប្រការទៀត តថាគតចម្រើននូវប្រយោជន៍ ទោះជាទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍

និងបរមត្ថប្រយោជន៍ដល់សត្វទាំងនោះ ដូច្នេះ ។ បទថា **យំ អកុសលំ តំ បហីនំ** សេចក្តីថា តថាគតលះ គឺដកនូវអកុសលមានកិលេស ១៥០០ និងមានប្រភេទច្រើន ដែលសម្បយុត្តដោយអកុសលទាំងនោះ នាមណ្ឌលពោធិ-ព្រឹក្សនោះឯង ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសមុច្ឆេទប្បហាន-វិវេក និងបដិបស្សទ្ធិវិវេក មួយអន្លើដោយនិស្សរណវិវេក ជាវិវេកដែលទ្រង់លើកឡើង តែក្នុងសេចក្តីនេះ អាចារ្យពួកខ្លះ លើកឡើង សូម្បីក្នុងតទង្គវិវេក និងវិក្ខម្ភនវិវេក ។ ដែលពិត ក្នុងសេចក្តីនេះ ព្រះមានព្រះភាគត្រាស់ដល់ការអស់កិលេសរបស់ព្រះអង្គ មួយអន្លើដោយបដិបទាដែលទ្រង់សម្រេច ដោយប្រការដូច្នេះ ។

ដោយហេតុនេះ ព្រះមានព្រះភាគ ទ្រង់ញុំាងអជ្ឈាស្រ័យក្នុងវិវេកដែលទ្រង់សន្សំមកអស់កប្ប ដែលរាប់មិនអស់ក្នុងទីបំផុត មួយអន្លើដោយព្រះអជ្ឈាស្រ័យ ក្នុងការចេញទៅហើយ ទ្រង់ចូលផលសមាបត្តិ ដែលមានការចេញទៅជាអជ្ឈាស្រ័យ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយមាតិកា គឺការលះកិលេស និងការពិចារណារបស់ព្រះអង្គ ក្នុងសេចក្តីនេះ ព្រះសាស្តាទ្រង់លើកវិតក្ក ២ នេះ ដើម្បីអត្ថឯណា ឥឡូវនេះ កាលទ្រង់សម្តែងដល់អត្ថនោះ ក៏បានត្រាស់ពាក្យជាដើមថា **តស្មា តិហ ភិក្ខវេ** ដូច្នេះ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ផ្តើមព្រះធម្មទេសនានេះ ដែលពោលដោយវិតក្ក ២ យ៉ាងដើម្បីឲ្យភិក្ខុទាំងឡាយ តាំងនៅក្នុងវិតក្កនោះដោយមាតិកា គឺការសម្តែងដល់ការប្រព្រឹត្តទៅរឿយៗ របស់ព្រះអង្គ ។

ក្នុងបទទាំងនោះ បទថា **តស្មា** បានដល់ ព្រោះខេមវិតក្ក និងវិវេក-វិតក្កប៉ុណ្ណោះ រមែងប្រព្រឹត្តទៅរឿយៗ ដល់តថាគតដែលត្រេកអរហើយ ក្នុងអព្យាបជ្ឈវិវេក ។ បទថា **តិហ** ត្រឹមតែជានិបាត ។ បទថា **អព្យាបជ្ឈារាមា វិហរថ** សេចក្តីថា អ្នកទាំងឡាយ ចូរជាអ្នកត្រេកអរដោយមេត្តាវិហារធម៌ និងករុណាវិហារធម៌ក្នុងសត្វទាំងពួងចុះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ដល់ការធ្វើព្យាបាទ និងកិលេសដែលតាំងនៅក្នុងទីតែមួយជាមួយនឹងព្យាបាទនោះ ឲ្យឆ្ងាយសែនឆ្ងាយ ។ បទថា **វោ** ក្នុងបទថា **តេសំ វោ** នេះ ត្រឹមតែជានិបាត ។

បទថា **បវិវេការាម វិហរថ** សេចក្តីថា ចូរពួកអ្នកធ្វើវិវេកទាំងអស់មានកាយវិវេកជាដើម និងវិវេក មានតទង្គវិវេកជាដើម ឲ្យជាទីគួរត្រេកអរចុះ ។ បទថា **ឥមាយ មយំ** ជាដើម ជាបទសម្តែងដល់អាការប្រព្រឹត្តទៅនៃខេមវិតក្ករបស់ភិក្ខុនោះ យ៉ាងណា បទថា **កឹ អកុសលំ** ជាដើម ជាបទសម្តែងអាការប្រព្រឹត្តទៅនៃវិវេកវិតក្កយ៉ាងនោះ ។ ក្នុងបទនោះ មានសេចក្តីថា ដែលបុគ្គលប្រាថ្នានឹងបំពេញធម៌ដែលមិនមានទោស ជាអ្នកស្វែងរកអ្វីជាកុសល គួរធ្វើការស្វែងរកកុសលធម៌ យ៉ាងណា សូម្បីបុគ្គលប្រាថ្នានឹងលះធម៌ដែលមានទោស ក៏មិនគួរធ្វើការស្វែងរកអកុសល ដូច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **កឹ អកុសលំ** ជាដើម ។ ពិតហើយ បរិញ្ញាភាវនា បហានភាវនា និងសច្ឆិកិរិយាភាវនា ជាខាងដើមនៃអភិញ្ញា ។

ក្នុងបទទាំងនោះ បទថា **កឹ អកុសលំ** សេចក្តីថា ព្រះមានព្រះភាគ

ទ្រង់សម្តែងដល់វិធីពិចារណាអកុសលដោយកិច្ចថា អ្វីឈ្មោះថា អកុសលដោយសភាវៈ អ្វីឈ្មោះថា ជាលក្ខណៈ ឬអ្វីឈ្មោះថាជារស ជាអាការប្រាកដ និងជាបទដ្ឋាននៃអកុសលនោះ ។ ម្យ៉ាងទៀត វិតក្កនេះមកហើយដោយអាទិកម្មិក ។ បទទាំង ២ នេះថា **កឹ អប្បហីនំ កឹ បជហាម** មកហើយដោយព្រះសេក្ខៈ ។ ព្រោះដូច្នោះ បទថា **កឹ អប្បហីនំ** បានដល់ ក្នុងបណ្តាអកុសលទាំងឡាយ មានកាមរាគសំយោជនៈជាដើម អកុសលណាមួយ ដែលយើងទាំងឡាយកាត់មិនទាន់បានដោយមគ្គ ។ បទថា **កឹ បជហាម** បានដល់ អញនឹងដកអកុសលអ្វី ។ ម្យ៉ាងទៀត បទថា **កឹ បជហាម** សេចក្តីថា ឥឡូវនេះ អញនឹងលះអកុសលចំណែកណាមួយ ក្នុងវិតក្ក-បរិយុដ្ឋាន និងអនុស័យ ។ តែអាចារ្យពួកខ្លះពោលថា **កិមប្បហីនំ** អកុ-សលណាមួយ ដែលមិនទាន់លះបាន ក៏មាន ។ លោកអធិប្បាយថា បណ្តាអកុសលច្រើនយ៉ាង ដូចជាទិដ្ឋិ និងសំយោជនៈជាដើម អកុសលណាមួយ ដែលអាត្មាអញមិនទាន់លះ ដោយប្រការណា ឬដោយមគ្គណា ។ បទដ៏សេស មានន័យដូចបានពោលហើយនោះឯង ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **ពុទ្ធំ** សេចក្តីថា ឈ្មោះថា **ពុទ្ធ** ព្រោះត្រាស់ដឹង ព្រោះចាក់ធ្លុះនូវធម៌មិនខុសចាកអរិយ-សច្ច ៤ ដោយព្រះសយម្ភូញាណ គឺព្រោះមិនមានញេយ្យធម៌ក្រៅអំពីសច្ច-ធម៌ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

**អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ**

**បហាតព្វំ បហីនម្មេ តស្មា ពុទ្ធោស្មិ ព្រាហ្មណា។**

វិជ្ជា និងវិមុត្តិ ដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ មគ្គសច្ច ដែលគប្បីចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ច ដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគត ឈ្មោះថា **ពុទ្ធ** ។

ព្រះពុទ្ធ ឈ្មោះថា ជាអ្នកសង្កត់នូវមារ ដែលអ្នកដទៃសង្កត់មិនបាន ព្រោះអត់ធន់ ព្រោះនាំទៅនូវពោធិសម្ភារ និងមហាករុណាទិគុណទាំងមូល ដែលអ្នកដទៃសង្កត់មិនបាន ម្យ៉ាងទៀត ព្រោះអត់សង្កត់ ព្រោះគ្របសង្កត់មារទាំង ៥ ដែលអ្នកដទៃសង្កត់មិនបាន ព្រោះលំបាកនឹងអត់ធន់ ដើម្បីគ្របសង្កត់ ព្រោះអត់សង្កត់ ព្រោះនាំទៅនូវពុទ្ធកិច្ចដែលអ្នកដទៃសង្កត់មិនបាន ដែលបានដល់ការប្រៀនប្រដៅដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ដល់ពួកវេនេយ្យសត្វ តាមសមគួរ ដោយការត្រាស់ដឹង មានអាសយ គឺអធ្យាស្រ័យ អនុសយ គឺកិលេសដេកត្រាំ ចរិយាធិមុត្តិ គឺការពេញចិត្តក្នុងការប្រព្រឹត្តជាដើម ឬព្រោះប្រកាសសាធុការក្នុងពុទ្ធកិច្ចនោះ ព្រោះអ្នកដទៃ វៀរព្រះពោធិសត្វមិនអាចអត់ធន់នាំទៅបានឡើយ ។

បទថា **ធំ** ក្នុងបទថា **សមុធាចរន្តិ ធំ** ត្រឹមតែជានិបាត ឬមានសេចក្តីស្មើគ្នានឹង **ធំ តថាគតំ**។ ព្រះមុនីឈ្មោះ **តមោនុទ** ព្រោះបន្ទោបង់ គឺបន្សាត់ទៅនូវអន្ធការ គឺមោហៈ ពាល គឺងងឹតក្នុងសន្តានរបស់ខ្លួន និងអ្នកដទៃ ។

ព្រះមុនីឈ្មោះថា **ចារគត** ព្រោះដល់នូវត្រើយ គឺព្រះនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា **ចារគត** ព្រោះដល់ត្រើយ គឺទីបំផុតនៃសង្សារទុក្ខទាំងមូល ដែលជាអភិនីហារធំ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **មុត្តោ មោចេយ្យំ** តថាគតរួចផុតហើយ នឹងឲ្យសត្វរួចផុតដែរ ដូច្នេះ ឬនៃគុណ គឺព្រះសព្វញ្ញុ ទាំងឡាយ ព្រះមុនីនោះ បន្ទោបង់នូវងងឹត ជាអ្នកដល់នូវត្រើយ អធិប្បាយថា ព្រះពុទ្ធជាអ្នកដល់នូវគុណដែលគួរដល់ចាកការដល់ត្រើយនោះឯង គឺដល់នូវគុណទាំងពួង មានសីល និងទសពលញ្ញាណជាដើម ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយគប្បីដល់ ។ បទថា **វសិមំ** សេចក្តីថា ព្រះមុនីឈ្មោះថា **វសិមា** ព្រោះមានការនៅជំនាញ មានអាវជ្ជនៈជាដើមយ៉ាងក្រៃលែង ដែលទាក់ទងដោយការសង្រួមក្នុងឈានជាដើម និងជាអ្នកជំនាញផ្លូវចិត្ត ដែលមិនទូទៅដល់អ្នកដទៃ បានដល់ ឫទ្ធិដែលជាអរិយៈ ។ ព្រះមុនីនោះ មានសេចក្តីជំនាញ អធិប្បាយថា ជាអ្នកមានអំណាច ។ ព្រះមុនីឈ្មោះថា **អនាសវ** ព្រោះមិនមានអាសវៈ មានកាមាសវៈជាដើមទាំងអស់ ។ ព្រះមុនីឈ្មោះថា **វិសន្តរ** ព្រោះលះនូវការមិនជារបៀប មានការមិនរៀបរយផ្លូវកាយជាដើម ឬព្រោះឆ្លងមន្ទិល គឺកិលេសទាំងពួង ពោល គឺថ្នាំពិស ឬឆ្លងនូវភ័យដែលជាទុក្ខក្នុងវដ្តៈទាំងមូលដែលជាថ្នាំពិស ហើយឆ្លងទៅ ព្រះមុនីនោះជាអ្នកឆ្លងវដ្តទុក្ខដែលជាថ្នាំពិស ។ ព្រះមុនីជាអ្នកបង្អោនទៅហើយក្នុងអរហត្តផល និងនិព្វានដែលអស់តណ្ហា ។ ឈ្មោះថា **មុនី** ព្រោះប្រកបដោយសេចក្តីល្អដ៏កំពូលដោយញាណ គឺភាពជាអ្នកនៅស្ងៀម ឬដោយភាពជាអ្នកស្ងៀមផ្លូវកាយ

ជាដើម ព្រោះទៅក្នុងអរហត្តផល និងនិព្វាន ។

បទថា **មុនិ** សេចក្តីថា មុនីមានច្រើនយ៉ាង គឺអាគារិយមុនី ១ អនាគារិយមុនី ១ សេក្ខមុនី ១ អសេក្ខមុនី ១ បច្ចេកមុនី ១ មុនិមុនី ១ ក្នុងមុនីទាំងនោះ គ្រហស្ថដែលសម្រេចផល ដឹងច្បាស់នូវពាក្យប្រៀនប្រដៅ ឈ្មោះថា **អាគារិយមុនី** បព្វជិតដូចគ្នានោះ ឈ្មោះថា **អនាគារិយមុនី** ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា **សេក្ខមុនី** ព្រះខីណាស្រព ឈ្មោះថា **អសេក្ខមុនី** ព្រះបច្ចេកពុទ្ធ ឈ្មោះថា **បច្ចេកមុនី** ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា **មុនិមុនី** ក្នុងទីនេះ បំណងយកព្រះមុនិមុនីនេះ ។

ព្រះមុនី ឈ្មោះថា **អន្តិមទេហធារី** ព្រោះជាអ្នកទ្រទ្រង់នូវរាងកាយដែលមានក្នុងទីបំផុត គឺចុងក្រោយ ព្រោះមិនមានភពថ្មីជាបន្តទៀយ ។ ព្រះមុនីនោះ ដែលទ្រទ្រង់នូវរាងកាយ ដែលមានក្នុងទីបំផុត ។ ព្រះមុនី ឈ្មោះថា **មារជហ** ព្រោះលះនូវកិលេសមារជាដើមបានដោយប្រពៃ ។ ព្រះមុនី ឈ្មោះថា **ជារគូ** ព្រោះជាអ្នកដល់ត្រើយនៃជរាទាំងពួង មានបាកជៈជាដើម ព្រោះទ្រង់សម្រេចអនុបាទិសេសនិព្វាន ព្រោះលះនូវហេតុនៃជរាបានហើយ ។ ក្នុងទីនេះ គប្បីឃើញថា លោកពោលការដល់នូវត្រើយនៃជាតិ មរណៈ សោកជាដើម ដោយមាតិកានៃជរា ភ្ជាប់សេចក្តីថា តថាគតពោលថា វិតក្ក ២ ប្រការនៃព្រះតថាគតយ៉ាងនោះ រមែងប្រព្រឹត្តទៅរឿយៗ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគទ្រង់សម្តែងវិតក្ក ២ ប្រការដោយគាថាទី ១ បន្ទាប់អំពីនោះ ទ្រង់សម្តែងវិវេកវិតក្កដោយគាថាទី ២ ឥឡូវនេះ ដើម្បីទ្រង់សម្តែង

ខេមវិតក្ក ទើបត្រាស់គាថាទី ៣ ថា **សេលេ យថា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ** បានដល់ ប្រៀបដូចបុរសដែលឈរលើកំពូលភ្នំថ្មតាន់ ។ កាលឈរលើភ្នំនោះ មិនមានការអើត-ក និងការចំអើតជាដើម ។ បទថា **តថូបមំ** គឺប្រៀបដូចភ្នំថ្មដែលប្រៀបគ្នាជាមួយអ្នកមានចក្ខុនោះ គប្បីជ្រាបសេចក្តីសង្ខេបក្នុងសេចក្តីនេះតទៅនេះ បុរសអ្នកមានចក្ខុឈរលើកំពូលភ្នំថ្ម គប្បីឃើញពួកជនដោយជុំវិញបាន យ៉ាងណា ព្រះមានព្រះភាគ ជាអ្នកមានបញ្ញាល្អ គឺមានបញ្ញាស្អាត មានចក្ខុជុំវិញ ប្រកបដោយសព្វញ្ញុតញ្ញាណ ឡើងកាន់ប្រាសាទដែលសម្រេចដោយធម៌ គឺសម្រេចដោយបញ្ញា ប្រាសចាកសេចក្តីសោក រមែងពិចារណាអាវជ្ជនៈ ត្រិះរិះដល់ពួកសត្វ ដែលធ្លង់សេចក្តីសោកមិនទាន់បានត្រូវជាតិ ជរា គ្របសង្កត់ ដូច្នេះដូចគ្នា ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ដូចបុរសធ្វើស្រែធំ ជុំវិញជើងភ្នំ ហើយសង់ខ្ទមត្រង់វាល អ្នកស្រែនោះ គប្បីបង្កាត់ភ្លើងនៅវេលាយប់ ប្រាកដការងងឹត ប្រកបដោយអង្គ ៤ ពេលនោះ កាលបុរសមានចក្ខុឈរលើកំពូលភ្នំ សម្លឹងមើលភូមិបទេសស្រែក៏មិនប្រាកដ ភ្លឺស្រែក៏មិនប្រាកដ ខ្ទមក៏មិនប្រាកដ អ្នកដេកក្នុងទីនោះក៏មិនប្រាកដ គប្បីប្រាកដត្រឹមតែអណ្តាតភ្លើង ត្រង់ខ្ទមប៉ុណ្ណោះ យ៉ាងណា កាលព្រះតថាគតឡើងកាន់ប្រាសាទ សម្រេចដោយធម៌ ទ្រង់ប្រមើលពួកសត្វ ក៏ដូច្នោះ សត្វដែលមិនបានធ្វើសេចក្តីល្អ ទោះអង្គុយខាងស្តាំក្នុងវិហារតែមួយ ក៏មិនបានមកកាន់គន្លងនៃពុទ្ធញ្ញាណ ដូចព្រួញដែលបាញ់ទៅក្នុង

វេលាយប់ តែវេនេយ្យសត្វដែលធ្វើល្អ សូម្បីឈរក្នុងទីឆ្ងាយ ក៏មកកាន់គន្លងរបស់ព្រះតថាគតនោះ ដូចភ្លើង ដូចភ្នំហិមពាន្ត ដូច្នោះ សមដូចព្រះសាស្ដាត្រាស់ថា

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**

**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា។**

ពួកសប្បុរស តែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត

ដូច្នោះ ពួកអសប្បុរស ( ទុកជាស្ថិតនៅ ) ក្នុងទីជិត

ក៏មិនរមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុង

វេលាយប់ដូច្នេះ ក្នុងសូត្រនេះ និងក្នុងគាថាទាំងឡាយ

ព្រះមានព្រះភាគ ទ្រង់សម្តែងធ្វើព្រះអង្គដូចអ្នកដទៃ ។

**អដ្ឋកថា វិតក្កសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទេសនាសូត្រ

[ ៣៩ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះធម៌ទេសនារបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ មាន ២ យ៉ាង ដោយបរិយាយ ។ ធម៌ទេសនា ២ យ៉ាងតើដូចម្តេច ។ គឺអ្នកទាំងឡាយ ចូរឃើញនូវបាបថាជាបាប នេះជាធម៌ទេសនាទី ១ លុះអ្នកទាំងឡាយ ឃើញនូវបាបថាជាបាបហើយ ចូរនឿយណាយ ចូរជិនឆ្អន់ ចូរផុតស្រឡះចាកបាបនោះ នេះឯងជាធម៌ទេសនាទី ២ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទេសនារបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ មាន ២ យ៉ាងនេះឯង ដោយបរិយាយ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកចូរឃើញនូវព្រះវាចា ដោយបរិយាយនៃព្រះតថាគត
ជាព្រះពុទ្ធ ដែលទ្រង់មានសេចក្តីអនុគ្រោះ ដល់សព្វ
សត្វផង នូវធម៌ទេសនា ២ យ៉ាង ដែលព្រះតថាគត
ប្រកាសហើយផង អ្នកទាំងឡាយ ជាអ្នកឈ្លាស ចូរ
ឃើញនូវអំពើបាប អ្នកទាំងឡាយ ចូរលះបង់នូវបាប
ក្នុងបាបនោះ តអំពីនោះទៅ ចូរអ្នកទាំងឡាយ មាន
ចិត្តប្រាសចាកសេចក្តីត្រេកអរហើយ នឹងធ្វើនូវទីបំផុត
នៃទុក្ខបាន ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ទេសនាសូត្រ

[ ៣៩ ] ក្នុងទេសនាសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ **បរិយាយ** សព្ទ ក្នុងបទថា **បរិយាយេន** នេះ មកក្នុងសេចក្ដីថា ទេសនា ដូចក្នុងប្រយោគជាដើមថា **មធុបិណ្ឌិកបរិយាយោ ត្វេវ នំ ធារេហិ** ចូរអ□ាំនូវសេចក្ដីនោះថា ធម្មបរិយាយនេះ ឈ្មោះមធុបិណ្ឌិកទេសនា ដូច្នេះចុះ ដូច្នេះ ។ មកក្នុងសេចក្ដីថា ហេតុ ដូចក្នុងប្រយោគមានជាដើមថា **អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ** ម្នាលព្រាហ្មណ៍ ពិតហើយ មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ ដែលគេថានោះត្រូវហើយ ដូច្នេះ ។ មកក្នុងសេចក្ដីថា វារៈ ដូចក្នុងប្រយោគជាដើមថា **កស្ស នុ ខោ អានន្ទ អជ្ជ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ** ម្នាលអានន្ទ ថ្ងៃនេះ ជាវេន ( វារៈ ) ភិក្ខុណាហ្ន៎ ដែលត្រូវឲ្យឱវាទពួកភិក្ខុនី ដូច្នេះ ។

ក្នុងទីនេះ សមគួរទាំងវារៈ ទាំងក្នុងហេតុ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ

ហេតុនោះ ធម្មទេសនា ២ យ៉ាង របស់តថាគត រមែងមានដោយហេតុ និង ដោយវារៈតាមសមគួរ ដូច្នេះ នេះជាអធិប្បាយក្នុងបទនេះ ។

ពិតហើយ ព្រះមានព្រះភាគ ក្នុងកាលខ្លះ ទ្រង់ចែកកុសលធម៌ និង អកុសលធម៌តាមសមគួរដល់អធ្យាស្រ័យរបស់វេនេយ្យសត្វ ដោយន័យជា ដើមថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះមានទោស ធម៌ទាំងនេះមិនមានទោស ធម៌ទាំងនេះគួរសេព ធម៌ទាំងនេះមិនគួរសេព ដូច្នេះ ទ្រង់សម្តែងឲ្យដឹងដោយមិនលាយឡំក្នុងអកុសលធម៌ ចូលជាមួយកុសលធម៌ ទ្រង់សម្តែងធម៌ថា ចូរពួកអ្នកឃើញនូវបាបថាជាបាប ។ ជួនកាល ទ្រង់ ប្រកាសទោស ដោយន័យជាដើមថា

> ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពថ្មីក ហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្ត ទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបាណាតិបាត ដែល ស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមាន អាយុខ្លី ដល់កើតជាមនុស្ស ដូច្នេះ ។

ទ្រង់ឲ្យនឿយណាយចាកបាប ដោយនិព្វិទាជាដើម ទ្រង់សម្តែងធម៌ថា ចូរពួកអ្នកនឿយណាយ ប្រាសចាកតម្រេក ដូច្នេះ ។

បទថា **ភវន្តិ** បានដល់ រមែងមាន គឺរមែងប្រព្រឹត្តទៅ ។ បទថា **បាបំ បាបកតោ បស្សថ** សេចក្តីថា ចូរពួកអ្នកឃើញធម៌ដ៏លាមកទាំងពួង ថា

ជាធម៌ដ៏លាមក ព្រោះនាំវត្តមិនជាប្រយោជន៍ និងទុក្ខមកឲ្យក្នុងបច្ចុប្បន្ន និងក្នុងអនាគត ។ ក្នុងបទទាំងនោះ បទថា **និព្វិន្ទថ** សេចក្ដីថា ពួកអ្នកឃើញទោសមានប្រការផ្សេងៗ គ្នា ដោយន័យជាដើមថា បាបឈ្មោះថាបាប ព្រោះជារបស់លាមក ដោយភាពជារបស់អាក្រក់ដោយចំណែកមួយ ឈ្មោះថាជាអកុសល ព្រោះជាការមិនឈ្លាស ឈ្មោះថា ជាការសៅហ្មង ព្រោះធ្វើចិត្តដែលធ្លាប់ភ្លឺថ្លា និងផូរផង់ ឲ្យវិនាសចាកភាពភ្លឺថ្លាជាដើម ឈ្មោះថាធ្វើឲ្យមានភពថ្មី ព្រោះធ្វើឲ្យកើតទុក្ខក្នុងភពរឿយៗ ឈ្មោះថា មានសេចក្ដីក្រវល់ក្រវាយ ព្រោះប្រព្រឹត្តទៅ មួយអន្លើដោយសេចក្ដីក្រវល់ក្រវាយ គឺក្ដៅក្រហាយ ឈ្មោះថា មានទុក្ខជាវិបាក ព្រោះឲ្យផលជាទុក្ខតែម្យ៉ាង ឈ្មោះថា ជាហេតុឲ្យមានជាតិ ជរា និងមរណៈតទៅ ព្រោះធ្វើឲ្យមានជាតិ ជរា និងមរណៈក្នុងអនាគតកាលអស់កាលយូរ មិនមានកំណត់ អាចកម្ចាត់ប្រយោជន៍សុខទាំងអស់បាន និងឃើញអានិសង្សក្នុងការលះបាបនោះ ដោយបញ្ញាដ៏ប្រពៃ ចូរនឿយណាយ គឺដល់នូវការនឿយណាយក្នុងធម៌ដ៏លាមកនោះ ។ កាលបើនឿយណាយ គប្បីចម្រើនវិបស្សនា ហើយចូរប្រាសចាកតម្រេក និងចូរដោះចាកបាបនោះ ដោយសម្រេចអរិយមគ្គ ឬចូរប្រាសចាកតម្រេក ដោយការប្រាសចាកតម្រេកជាសមុច្ឆេទដោយមគ្គ តែចូរដោះដោយបដិបស្សទ្ធិវិមុត្តិដោយផល ។

ម្យ៉ាងទៀត បទថា **ធាបំ** បានដល់ ឈ្មោះថា **ធាប** ព្រោះជារបស់លាមក ។ សួរថា លោកអធិប្បាយដូចម្ដេច ។ ឆ្លើយថា ឈ្មោះថា **ធាប**

ព្រោះជាវត្ថុគួរវៀរចាក គឺព្រះអរិយៈខ្ពើម ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាដើម ញុំាងសត្វឲ្យដល់ទុក្ខក្នុងវដ្តៈ ។ សួរថា បាបនោះដូចម្តេច ឆ្លើយថា ជាធម្មជាតធ្វើឲ្យកើតក្នុងភូមិ ៣ ពួកអ្នកឃើញបាបថាជាបាប មានអត្ថតាមដែលពោលហើយ ចម្រើនវិបស្សនា ដោយន័យជាដើមថា ជារបស់មិនទៀង ដោយភាពជាទុក្ខ ដោយភាពជារោគ ដោយភាពជាបូស ដោយភាពជាព្រួញ ដោយភាពជារបស់លំបាក ដោយការបៀតបៀន ដូច្នេះ ចូរនឿយណាយក្នុងបាបនោះ ។ បទថា **អយម្បិ ទុតិយា** បានដល់ ធម្មទេសនាប្រការទី ២ នេះ ជាការជ្រើសរើសបដិបត្តិចាកធម៌នោះ អាស្រ័យធម្មទេសនាប្រការទី ១ ដែលសម្តែងដល់វត្ថុមិនជាប្រយោជន៍ និងសេចក្តីវិនាស ដោយភាពពិតប្រាកដ ។

គប្បីជ្រាបអធិប្បាយក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **ពុទ្ធស្ស** បានដល់ ព្រះសព្វញ្ញុពុទ្ធ ។ បទថា **សព្វភូតានុកម្បិនោ** បានដល់ ព្រះពុទ្ធជាអ្នកអនុគ្រោះសត្វទាំងអស់ដោយមហាករុណា ។ បទថា **បរិយាយវចនំ** បានដល់ ការពោល គឺការសម្តែងដោយបរិយាយ ។ បទថា **បស្ស** គឺទ្រង់ហៅបរិស័ទ ។ លោកពោលសំដៅដល់បរិស័ទដែលជាប្រធាន តែអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគបានត្រាស់ថា **បស្ស** សំដៅដល់ ព្រះអគ្គប៉ុណ្ណោះ ។ បទថា **តត្ថ** បានដល់ ក្នុងបាបនោះ ។ បទថា **វិរជ្ជថ** សេចក្តីថា ចូរពួកអ្នកលះនូវតម្រេក ។ បទដ៏សេស មានន័យបានពោលហើយនោះឯង ។ល។

**អដ្ឋកថាទេសនាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## វិជ្ជាសូត្រ

[ ៤០ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជា ជាប្រធានដើម្បីចូលប្រទះនូវអកុសលធម៌ទាំងឡាយ អហិរិកៈ និងអនោត្តប្បៈ កើតតាមក្រោយ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯវិជ្ជា ជាប្រធាន ដើម្បីចូលប្រទះនូវកុសលធម៌ទាំង-ឡាយ ហិរិ និងឱត្តប្បៈ កើតតាមក្រោយ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ទុគ្គតិទាំងឡាយណានីមួយ ទាំងក្នុងលោកនេះ ទាំងក្នុង
បរលោក ទុគ្គតិទាំងអស់នោះ មានអវិជ្ជា ជាឫស មាន
សេចក្តីប្រាថ្នា និងសេចក្តីលោភ ជាគ្រឿងផុះដាលឡើង
បុគ្គលមានសេចក្តីប្រាថ្នាលាមក មានសេចក្តីមិនខ្មាស
បាប ទាំងមានសេចក្តីមិនអើពើ ក្នុងកាលណាហើយ
តែងទទួលនូវផលបាប ទៅកាន់អបាយ ព្រោះបាបនោះ
ក្នុងកាលនោះ ។ ព្រោះហេតុនោះ ភិក្ខុគប្បីញុំាងឆន្ទៈ
លោភៈ និងអវិជ្ជា ឲ្យវិនាសទៅផង ញុំាងវិជ្ជាឲ្យកើត
ឡើងផង ទើបលះបង់នូវទុគ្គតិទាំងពួងបាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## វិជ្ជាសូត្រ

[ ៤០ ] ក្នុងវិជ្ជាសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **បុព្វង្គមា** បានដល់ ជាប្រធាន ដោយអាការ ២ យ៉ាង គឺដោយសហជាតប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ឬជាហេតុជាប្រធាននៃអកុសលធម៌ខាងមុខ ។ ពិតហើយ ការកើតឡើងនៃអកុសល វៀរចាកអវិជ្ជាហើយ មិនមាន ។ បទថា **សមាបត្តិយា** បានដល់ ការដល់ព្រម គឺការប្រព្រឹត្តទៅដើម្បីបានចំពោះនូវសភាវៈ ។ ភាពជាឧបនិស្សយប្បច្ច័យនៃអកុសលធម៌ទាំងឡាយ ដោយភាពជាបច្ច័យនៃអយោនិសោមនសិការ ដោយការបិទបាំងទោស នៃការប្រព្រឹត្តទៅរបស់អកុសល និងដោយការដែលលះមិនបាន រមែងប្រាកដក្នុងសេចក្តីនោះ ។

គតិទាំងអស់ ឈ្មោះថា **ទុគ្គតិ** ក្នុងគាថានេះ ព្រោះជាទីតាំងនៃទុក្ខ មានព្យាធិ និងមរណៈជាដើម ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត កាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ឈ្មោះថា **ទុគ្គតិ** ព្រោះគតិដែលត្រូវកិលេស មានរាគៈជាដើមប្រទូស្ត ប្រព្រឹត្តទៅតាមកាយ វាចា និងចិត្ត ។ បទថា **អស្មិំ លោកេ** បានដល់ ក្នុងលោក ឬក្នុងមនុស្សគតិ ។ បទថា **បរម្ហិ ច** បានដល់ ក្នុងគតិដទៃចាកមនុស្សគតិនោះ ។ បទថា **អវិជ្ជាមូលិកា សព្វា** បានដល់ ការវិបត្តិនៃទុច្ចរិតទាំងអស់នោះ មានអវិជ្ជាជាមូលតែម្យ៉ាង ព្រោះមានអវិជ្ជាជាប្រធាន ដោយន័យដូចពោលហើយ ។ បទថា **ឥច្ឆាលោភសមុស្សយា**

សេចក្ដីថា ឈ្មោះថា **ឥច្ឆាលោភសមុស្សយា** ព្រោះការប្រាថ្នា មានលក្ខណៈស្វែងរកវត្ថុដែលមិនដល់ព្រម និងដែលសេចក្ដីលោភ មានលក្ខណៈចង់បាននូវវត្ថុដែលដល់ព្រមហើយ បង្កឡើង គឺសន្សំ ។ បទថា **យតោ** បានដល់ ព្រោះមានអវិជ្ជាជាហេតុ ជាបុគ្គលត្រូវអវិជ្ជាបិទបាំង ។ បទថា **ឆាបិច្ឆោ** បានដល់ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក មិនឃើញទោស ធ្វើនូវការបោកបញ្ឆោតជាដើម ដោយការសរសើរគុណដែលមិនមាន ព្រោះមានសេចក្ដីប្រាថ្នាលាមក ត្រូវអវិជ្ជាបិទបាំង គប្បីឃើញថា សូម្បីការប្រាថ្នាក្នុងខ្លួន ក៏ជាការកាន់យកដោយសេចក្ដីលោភដូចគ្នា ។ បទថា **អនាទរោ** បានដល់ វៀរចាកការអើពើក្នុងសព្រហ្មចារី ព្រោះមិនមានឱត្តប្បៈដែលកាន់យកលោកជាធំ ។ បទថា **តតោ** បានដល់ ព្រោះជាហេតុនៃអវិជ្ជា សេចក្ដីប្រាថ្នាលាមក ការមិនមានហិរិ មិនមានឱត្តប្បៈ ។ បទថា **បសវតិ** បានដល់ សន្សំបាប មានកាយទុច្ចរិតជាដើម ។ បទថា **អបាយំ តេន គច្ឆតិ** បានដល់ រមែងទៅ គឺរមែងចូលទៅដល់អបាយ មាននរកជាដើម ព្រោះបាបតាមដែលខ្វល់ខ្វាយនោះ ។ បទថា **តស្មា** បានដល់ ព្រោះអវិជ្ជាជាដើមនេះជាឫសគល់នៃទុច្ចរិតទាំងពួង និងជាហេតុនៃសេចក្ដីសៅហ្មង ដែលជាដែនកើតក្នុងទុគ្គតិទាំងពួងយ៉ាងនេះ ដូច្នោះ ភិក្ខុខ្ជាក់ចោលនូវការប្រាថ្នា ការលោភ អវិជ្ជា អហិរិកៈ និងអនោត្តប្បៈបាន លះដោយសមុច្ឆេទ ។ សួរថា ខ្ជាក់ដូចម្ដេច ទើបឲ្យវិជ្ជាកើតឡើងបាន ឆ្លើយថា ខ្វល់ខ្វាយតាមលំដាប់វិបស្សនា និងតាមលំដាប់មគ្គហើយញុំាងវិជ្ជា គឺអរហត្តមគ្គឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួន ។ បទថា

**សព្វា ទុគ្គតិយោ** បានដល់ គប្បីលះ គឺគប្បីលះបង់ គប្បីឈានកន្លងទុគ្គតិពោល គឺទុច្ចរិតទាំងពួង ឬគតិ ៥ ដែលឈ្មោះថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខក្នុងវដ្តៈ ពិតហើយ កម្មវដ្ត និងវិបាកវដ្ត ជាការលះបាន ដោយការលះកិលេសវដ្តនោះឯង ដោយប្រការដូច្នេះ ។

**អដ្ឋកថា វិជ្ជាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បញ្ញាសូត្រ

[ ៤១ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា សាបសូន្យចាកបញ្ញាដ៏ប្រសើរហើយ សត្វទាំងឡាយនោះ ឈ្មោះថា សាបសូន្យ អស់រលីង សត្វទាំងឡាយនោះ រមែងនៅជាទុក្ខ ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ ប្រាកដជាទៅកាន់ទុគ្គតិ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា មិនសាបសូន្យចាកបញ្ញាដ៏ប្រសើរហើយ សត្វទាំងឡាយនោះ ឈ្មោះថា មិនសាបសូន្យ សត្វទាំងឡាយនោះ តែងនៅជាសុខ មិនប្រកបដោយសេចក្តីថ្នាំងថ្នាក់ មិនប្រកបដោយសេចក្តីចង្អៀតចង្អល់ មិនប្រកបដោយសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាង

កាយស្លាប់ទៅ ប្រាកដជាទៅកាន់សុគតិ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកចូរមើលនូវសត្វលោក ព្រមទាំងទេវលោក ដែល
ជាប់នៅក្នុងនាម និងរូប រមែងសម្គាល់ថា នេះជារបស់
ពិត ព្រោះសាបសូន្យចាកបញ្ញាដ៏ប្រសើរ ។ បញ្ញាជា
គ្រឿងប្រព្រឹត្តទៅ ដើម្បីចាក់ធ្លុះនេះឯង ប្រសើរបំផុត
ក្នុងលោក ព្រោះបញ្ញានោះដឹងច្បាស់នូវកិរិយាអស់ជាតិ
និងភព ដោយប្រពៃ ទេវតា និងមនុស្សទាំងឡាយ
តែងស្រឡាញ់នូវព្រះសម្ពុទ្ធទាំងឡាយនោះ ដែលមាន
ស្មារតី មានបញ្ញា ជាគ្រឿងរីករាយ ទ្រទ្រង់នូវរាង
កាយជាទីបំផុត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## បញ្ញាសូត្រ

[ ៤១ ] ក្នុងបញ្ញាសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សុបរិហីនា** បានដល់ សាបសូន្យ ។ បទថា **យេ អរិយាយ បញ្ញាយ បរិហីនា** សេចក្តីថា សត្វពួកណាសាបសូន្យចាកវិបស្សនាបញ្ញា និងមគ្គប្បញ្ញា ដែលជាអរិយៈ គឺបរិសុទ្ធ ព្រោះតាំងនៅឆ្ងាយចាកកិលេសទាំងឡាយ ដោយការដឹងនូវការកើត និងការវិនាសនៃខន្ធ ៥ និងដោយការចាក់ធ្លុះអរិយសច្ច ៤ សត្វទាំងនោះ គឺវិនាសច្រើនពន់ពេក ចាកសម្បត្តិដែលជាលោកិយ និងលោកុត្តរ សួរថា សត្វទាំងនោះ ជាប្រភេទពួកណា ឆ្លើយថា ជាការពិតសត្វពួកណា ប្រកបដោយកម្មាវរណៈ សត្វទាំងនោះ វិនាស គឺខូះខាតសាបសូន្យច្រើន ដោយចំណែកមួយ ដោយភាពជាអ្នកទៀងចំពោះការឃើញខុស ដូចលោកពោលថា **ទុគ្គតិ បដិកង្ខា** ទុគ្គតិរមែងសង្ឃឹមបានដូច្នេះ ។ សូម្បីព្រមព្រៀងដោយគ្រឿងការពារ គឺវិបាក ក៏សាបសូន្យ ។ ម្យ៉ាងទៀត គប្បីជ្រាបក្នុងធម៌ចំណែកស ដែលជាសម្មាទិដ្ឋិ វៀរចាកអាវរណៈ ៣ យ៉ាង និងជាអ្នកប្រកបដោយកម្មស្សកតាញាណ ឈ្មោះថា មិនវិនាស ។ បទដ៏សេស គប្បីជ្រាបដោយទំនងដែលមានន័យដូចពោលហើយនោះឯង ។

ក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយដូច្នេះ បទថា **បញ្ញាយ** ជាបញ្ចមីវិភត្តិ សេចក្តីថា ព្រោះការវិនាសទៅចាកវិបស្សនាញាណ និងមគ្គញាណ ។ បទថា **បញ្ញាយ** នេះ ជាឆដ្ឋីវិភត្តិ សេចក្តីថា ព្រោះវិនាសទៅនៃញាណដែលបានពោលហើយ ។ ម្យ៉ាងទៀត ការមិនឲ្យកើតឡើងនៃ

ញាណ ដែលគួរឲ្យកើតនោះឯង ជាការវិនាសក្នុងបទនេះ ។ បទថា **និវិដ្ឋំ នាមរូបស្មឹ** បានដល់ ជាអ្នកតាំងមាំហើយ គឺឈមចុះហើយក្នុងនាមរូប គឺឧបាទានក្ខន្ធ ៥ ដោយអំណាចតណ្ហា និងទិដ្ឋិ ដោយន័យជាដើមថា **ឯតំ មម** នុ៎ះរបស់អញ ដូច្នេះ ព្រោះសាបសូន្យចាកបញ្ញានោះ ។ បទថា **ឥទំ សច្ចន្តិ មញ្ញតិ** បានដល់ រមែងសម្គាល់ថា នាមរូបនេះប៉ុណ្ណោះជាសេចក្តីពិត ដទៃជាមោឃ ដូច្នេះ គប្បីផ្ទាស់វិភត្តិជា **សទេវកេ លោកេ** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ចំណែកសៅហ្មងក្នុងគាថាទី ១ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសអានុភាពនៃបញ្ញាថា កិលេសវដ្តតែងប្រព្រឹត្តទៅដោយការប្រកាន់ និងការប្រកាន់មាំក្នុងនាមរូប ព្រោះមិនឲ្យកើតបញ្ញាយ៉ាងណា ការចូលទៅកាត់វដ្ដៈ ក៏ព្រោះកើតបញ្ញានោះ ដូច្នេះ ទើបត្រាស់គាថាថា **បញ្ញាហិ សេដ្ឋា លោកស្មឹ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **លោកស្មឹ** បានដល់ សង្ខារលោក ។ ធម៌ដូចគ្នានឹងបញ្ញាក្នុងសង្ខារទាំងឡាយ ក្នុងសត្វទាំងឡាយ រមែងមិនមានដូចព្រះសម្មាសម្ពុទ្ធ ពិតហើយ កុសលធម៌ទាំងឡាយ មានបញ្ញាយ៉ាងក្រៃលែង និងធម៌ដែលមិនមានទោសទាំងពួង ជាការដែលសម្រេច ព្រោះការសម្រេចនៃបញ្ញា សមដូចព្រះមានព្រះភាគត្រាស់ថា **សម្មាទិដ្ឋិស្ស សម្មាសង្កប្បោ បហោតិ** ការត្រិះរិះត្រូវកើតឡើង បុគ្គលមានសេចក្តីឃើញត្រូវ ដូច្នេះជាដើម ។ បញ្ញាដែលបំណងយកក្នុងទីនេះ លោកសរសើរថា ប្រសើរបំផុត ។ កាលទ្រង់សម្តែងដល់ការប្រព្រឹត្តទៅនោះ ទើបត្រាស់ថា **យាយំ និព្វេធគាមិនី**

ដូច្នេះជាដើម ។

អធិប្បាយសេចក្តីក្នុងបទនោះថា បញ្ញាណាដែលឲ្យដល់នូវការទម្លាយកិលេសថា បញ្ញានេះដល់នូវការទម្លាយ គឺទម្លាយកិលេស មានកងលោភៈជាដើម ដែលមិនធ្លាប់ទម្លាយ មិនទាន់ធ្លាប់ទម្លាយ រមែងទៅ រមែងប្រព្រឹត្តទៅ យោគាវចររមែងដឹង រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន និងអរហត្តដែលជាទីអស់ទៅ ជាទីបំផុតនៃជាតិ ពោល គឺការកើតគ្រាដំបូងនៃខន្ធទាំងឡាយក្នុងពួកសត្វ ក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសនោះៗ និងកម្មភព ដែលមានជាតិនោះជានិមិត្តដោយប្រពៃ មិនវិបរិតដោយបញ្ញាណា បញ្ញានេះជាមគ្គប្បញ្ញា មួយអន្ទើដោយវិបស្សនា ប្រសើរបំផុតក្នុងលោក ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រះខីណាស្រព ដែលដល់ព្រមហើយដោយបញ្ញានុភាព តាមដែលពោលហើយ ទើបត្រាស់គាថាចុងក្រោយថា **តេសំ ទេវា មនុស្សា ច** ដូច្នេះ ។

អធិប្បាយសេចក្តីនៃបទនោះថា ទេវតា និងមនុស្សទាំងឡាយ រមែងស្រឡាញ់ចំពោះព្រះខីណាស្រពទាំងនោះ ដែលឈ្មោះថាជា **សម្ពុទ្ធានំ** ដោយការត្រាស់ដឹងអរិយសច្ច ៤ ព្រោះសម្រេចសោឡសកិច្ច មានបរិញ្ញាជាដើមក្នុងអរិយសច្ច ៤ ។ ឈ្មោះថា **សតីមតំ** ព្រោះមានសតិបរិបូណ៌ ។ ឈ្មោះថា **ហាសបញ្ញានំ** ព្រោះដល់នូវការបរិបូណ៌នៃបញ្ញា ព្រោះដកនូវការរង្វេងបានដោយន័យដូចពោលហើយ ឬឈ្មោះថា **ហាសបញ្ញានំ** ព្រោះភាពដែលព្រះខីណាស្រព ច្រើនទៅដោយការរីករាយ ការដឹង ការត្រេកអរ និងបាមោជ្ជ

តាំងអំពីជាបុគ្គលបរិបូណ៌ដោយសីលជាដើម ក្នុងចំណែកខាងដើម រហូតធ្វើនិព្វានឲ្យជាក់ច្បាស់ ឈ្មោះថា **អន្តមសរីរធារីធំ** ព្រោះជាអ្នកអស់នូវកាវ-សំយោជនៈ ដោយប្រការទាំងពួង រមែងប្រាថ្នាដើម្បីសម្រេចនូវភាពយ៉ាងនោះខ្វះថា បញ្ញានុភាពគួរអស្ចារ្យ បើដូច្នោះ សូម្បីអាត្មាអញក៏គួរឆ្លងផុតទុក្ខទាំងពួងដូច្នេះបានដែរ ដូច្នេះ ។

**អដ្ឋកថា បញ្ញាសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សុក្កធម្មសូត្រ

[ ៤២ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ស ២ នេះ តែងរក្សានូវលោក ។ ធម៌ស ២ តើដូចម្តេច ។ គឺហិរិ ១ ឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បើធម៌ស ២ នេះ មិនគប្បីរក្សានូវលោកទេ ពាក្យថា មាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ប្រពន្ធរបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី មិនប្រាកដ ក្នុងលោកនេះបានឡើយ លោកនឹងដល់នូវការប្រឡូកប្រឡល់គ្នា ដូចជាសត្វពពែ កែះ មាន់ ជ្រូក ឆ្កែ និងចចកដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ស ២ នេះ តែងរក្សានូវលោក បានជាពាក្យថា មាតាក្តី ម្តាយមីងក្តី ម្តាយធំក្តី ប្រពន្ធរបស់អាចារ្យក្តី ប្រពន្ធរបស់គ្រូក្តី ទើបប្រាកដបាន ។ លុះព្រះមាន

ព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បើហិរិ និងឱត្តប្បៈ មិនមានដល់សត្វទាំងឡាយណា
សព្វកាលទេ សត្វទាំងឡាយនោះ ជាអ្នកឃ្លាតចាក
ឫសគល់នៃធម៌ស មានដំណើរទៅកាន់ជាតិ និង
មរណៈ ។ ចំណែកសត្វទាំងឡាយណា តម្កល់ទុកនូវ
ហិរិ និងឱត្តប្បៈ ដោយប្រពៃ សព្វកាល សត្វទាំង
ឡាយនោះ ជាអ្នកមានព្រហ្មចរិយៈចម្រើនហើយ
ជាអ្នកស្ងប់ អស់កពតទៅទៀតហើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## សុក្កធម្មសូត្រ

[ ៤២ ] ក្នុងសុក្កធម្មសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សុក្កា** ឈ្មោះថា សុក្កធម៌ ព្រោះជាធម៌ស ឯសុក្កធម៌ រមែងប្រព្រឹត្តទៅដើម្បីការផូរផង់ក្រៃលែង ដោយភាពជាធម៌ស ព្រោះហេតុនោះ ធម៌ទាំងឡាយ ឈ្មោះថា **ស** ព្រោះជាធម៌សបរិសុទ្ធ ធម៌ទាំងឡាយដែលជាកុសល

ទាំងពួង សូម្បីព្រមដោយរស ឈ្មោះថា ធម៌ស ព្រោះផុយគ្មានីឯភាពដែល ជាធម៌ខ្មៅ ។ ដ្បិតថា ធម៌សកើតឡើង ទើបចិត្តក៏បរិសុទ្ធ ។ បទថា **ធម្មា** បានដល់ ធម៌ជាកុសល ។ បទថា **លោកំ** បានដល់ សត្វលោក ។ បទថា **ចាលេន្តិ** បានដល់ ដាក់នូវព្រំដែនរក្សា ដោយការទទួល ការទ្រទ្រង់ ។

ក្នុងបទថា **ហិរិ ច ឱត្តប្បញ្ច** នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ឈ្មោះថា **ហិរិ** ព្រោះដែលគេខ្មាស ឬឈ្មោះថា **ហិរិ** ព្រោះជាហេតុខ្មាស ។ សូម្បីសេចក្តីនេះ លោកក៏ពោលនៅក្នុងធម្មសង្គណិថា ត្រង់ដែលបុគ្គលខ្មាស ដោយអំពើដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា **ហិរិ** ។ ឈ្មោះថា **ឱត្តប្ប** ព្រោះខ្លាច ឈ្មោះថា **ឱត្តប្ប** ព្រោះជាហេតុខ្លាច ។ សូម្បីសេចក្តីនេះ លោកក៏ពោលថា ត្រង់ដែលបុគ្គលក្តៅក្រហាយ ដោយអំពើដែលគួរក្តៅក្រហាយ ក្តៅក្រហាយដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា **ឱត្តប្ប** ។

ក្នុងហិរិ និងឱត្តប្បៈនោះ ហិរិកើតឡើងខាងក្នុង ឱត្តប្បៈកើតខាងក្រៅ ហិរិកាន់យកខ្លួនជាធំ ឱត្តប្បៈកាន់លោកជាធំ ។ ហិរិតាំងនៅក្នុងការខ្មាសជាសភាវៈ ឱត្តប្បៈតាំងនៅក្នុងការខ្លាចជាសភាវៈ ហិរិមានលក្ខណៈកោតក្រែង ឱត្តប្បៈមានលក្ខណៈឃើញភ័យ ដែលជាទោសគួរខ្លាច ។ ក្នុងហិរិ និងឱត្តប្បៈនោះ ហិរិកើតឡើងខាងក្នុង រមែងកើតដោយហេតុ ៤ យ៉ាង គឺពិចារណាដល់ជាតិ ១ ពិចារណាដល់វ័យ ១ ពិចារណាដល់ភាពជាអ្នកក្លៀវក្លា ១ ពិចារណាដល់ភាពជាពហុស្សូត ១ ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា

បុគ្គលពិចារណាដល់ជាតិយ៉ាងនេះថា ឈ្មោះថា ការធ្វើអាក្រក់នេះ មិនមែនជាការធ្វើរបស់បុគ្គល ដែលសម្បូរដោយជាតិ ជាការធ្វើរបស់អ្នកប្រមង់ជាដើម ដែលមានជាតិថោកថយ បុគ្គលសម្បូរដោយជាតិដូចអាត្មាអញ មិនគួរធ្វើកម្មនេះ ដូច្នេះហើយ មិនធ្វើកម្មអាក្រក់ មានបាណាតិបាតជាដើម កើតហិរិឡើង ។ ម្យ៉ាងទៀត ពិចារណាដល់វ័យយ៉ាងនេះថា ឈ្មោះថា ការធ្វើកម្មអាក្រក់នេះ ជាកម្មដែលក្មេងៗ គួរធ្វើ បុគ្គលអ្នកតាំងនៅក្នុងវ័យដូចអាត្មាអញ មិនគួរធ្វើកម្មនេះ ហើយមិនធ្វើបាបកម្ម មានបាណាតិបាតជាដើម ហិរិក៏កើតឡើង ។ ម្យ៉ាងទៀត ពិចារណាដល់ភាពជាបុគ្គលក្លៀវក្លាយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើរបស់បុគ្គលដែលមានកម្លាំងទន់ខ្សោយ បុគ្គលដែលសម្បូរកម្លាំងដូចអាត្មាអញ មិនគួរធ្វើកម្មនេះ ដូច្នេះហើយ មិនធ្វើនូវបាបកម្ម មានបាណាតិបាតជាដើម ក៏កើតហិរិឡើង ។ ម្យ៉ាងទៀត ពិចារណាដល់ភាពជាពហុស្សូតយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះ ជាការធ្វើរបស់អន្ធពាល មិនមែនជាការធ្វើរបស់បណ្ឌិត បុគ្គលជាបណ្ឌិតចេះដឹងច្រើន ដូចអាត្មាអញ មិនគួរធ្វើកម្មនេះ ដូច្នេះហើយ មិនធ្វើនូវបាបកម្ម មានបាណាតិបាតជាដើម ហិរិក៏កើតឡើង ។ បុគ្គលញុំាងហិរិដែលកើតខាងក្នុងឲ្យកើតឡើងដោយហេតុ ៤ ប្រការយ៉ាងនេះ និងកាលឲ្យកើតហើយ ពិចា-រណាដល់ហិរិក្នុងចិត្តរបស់ខ្លួន ហើយមិនធ្វើនូវបាបកម្ម ហិរិ ឈ្មោះថា កើតឡើងខាងក្នុង ដោយប្រការដូច្នេះ ។

សួរថា ឱត្តប្បៈ ឈ្មោះថា កើតខាងក្រៅដូចម្តេច ឆ្លើយថា បុគ្គល

ពិចារណាថា បើអាត្មាអញធ្វើនូវកម្មអាក្រក់នោះ អាត្មានឹងបានទទួលនូវការតិះដៀលក្នុងបរិស័ទ ៤ ។

វិញ្ញូជនទាំងឡាយ នឹងតិះដៀលអាត្មាអញ ដូចអ្នកនគររង្កៀសរបស់ស្មោកគ្រោក អាត្មាអញត្រូវអ្នកមានសីលកម្ចាត់ហើយ នឹងជាភិក្ខុនៅបានដូចម្តេច ដូច្នេះ ។

រមែងមិនធ្វើបាបកម្មដោយឱត្តប្បៈ ដែលកើតហើយខាងក្រៅ ។ ឱត្តប្បៈឈ្មោះថា តាំងឡើងខាងក្រៅ ដោយប្រការដូច្នេះ ។ សួរថា ហិរិ ឈ្មោះថា កាន់យកខ្លួនជាធំដូចម្តេច ឆ្លើយថា កុលបុត្រខ្លះក្នុងលោកនេះ ធ្វើខ្លួនឲ្យជាធំជាប្រធាន ហើយមិនធ្វើបាបកម្ម ដោយឃើញថា អ្នកបួសដោយសទ្ធា ជាពហូសូត ជាអ្នកទូន្មាននូវធុតង្គដូចអាត្មាអញ មិនគួរធ្វើអាក្រក់ ដូច្នេះ ហិរិឈ្មោះថា មានខ្លួនជាធំ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា **សោ អត្តានំយេវ អធិបតេយ្យំ ករិត្វា អកុសលំ បជហាតិ កុសលំ ភាវេតិ សាវជ្ជំ បជហាតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ** ភិក្ខុនេះធ្វើខ្លួនឯងឲ្យជាអាធិបតេយ្យហើយ រមែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។

សួរថា ឱត្តប្បៈ ឈ្មោះថា កាន់យកលោកជាធំដូចម្តេច ឆ្លើយថា កុលបុត្រពួកខ្លះក្នុងលោកនេះ គិតដល់លោកជាធំ និងចម្រើន ហើយមិនធ្វើបាបកម្ម ដូចលោកពោលក្នុងអង្គុត្តរនិកាយ តិកនិបាតថា លោកសន្និវាសនេះ

សោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិត ក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកមើល កុលបុត្រនេះចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្រឡូកប្រឡល់ ដោយធម៌ជាអកុសលដ៏លាមក ។ ម្យ៉ាងទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ចូរអ្នកមើលកុលបុត្រនេះ ចេញចាកផ្ទះ មកបួសដោយសទ្ធាហើយ នៅតែប្រឡូកប្រឡល់ដោយធម៌ជាអកុសលដ៏លាមក លុះភិក្ខុនោះ ប្រារព្ធលោកឲ្យអាធិបតេយ្យហើយ តែងលះបង់អកុសល ... ដូច្នេះ ។ ឱត្តប្បៈកាន់យកលោកជាធំដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ហិរិ តាំងនៅក្នុងការខ្មាសជាសភាវៈនេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ អាការនៃការខ្មាស ឈ្មោះថា **លជ្ជា** ហិរិ តាំងនៅដោយសភាវៈនោះ ការខ្លាចក្នុងអបាយ ឈ្មោះថា **ភ័យ** ឱត្តប្បៈ តាំងនៅដោយសភាវៈនោះ ទាំង ២ យ៉ាងនោះ ជាការប្រាកដក្នុងការវៀរចាកអំពើអាក្រក់ ។

ក្នុង ហិរិ និងឱត្តប្បៈនោះ មានវិនិច្ឆ័យថា ដូចដុំដែក ២ ដុំ ១ ដុំ

ត្រជាក់ ប្រឡាក់លាមក ១ ដុំក្តៅ ក្នុងដុំដែក ២ នោះ វិញ្ញូជនខ្ពើមរអើម ដុំដែកត្រជាក់ដែលប្រឡាក់លាមក ទើបមិនចាប់ មួយដុំទៀត មិនចាប់ ព្រោះខ្លាចនូវកម្តៅ យ៉ាងណា បណ្ឌិតខ្ពើម មិនធ្វើនូវអំពើអាក្រក់ ព្រោះខ្មាស ខ្លាចនូវអបាយ មិនធ្វើនូវអំពើអាក្រក់ ព្រោះខ្លាចក៏ដូច្នោះ ។ ហិរិ តាំងនៅក្នុងសភាវៈនៃការខ្មាស ឱត្តប្បៈ តាំងនៅក្នុងសភាវៈនៃការខ្លាច ដោយប្រការដូច្នេះ ។

សួរថា ហិរិ មានលក្ខណៈកោតក្រែង ឱត្តប្បៈ មានលក្ខណៈឃើញភ័យ ជាទោសដ៏គួរខ្លាចនោះដូចម្តេច ឆ្លើយថា ពិតហើយ បុគ្គលខ្លះញុំាងហិរិដែលមានលក្ខណៈកោតក្រែង ឲ្យកើតឡើងដោយគោរពក្នុងបុគ្គលនោះ ដោយអាការ ៤ យ៉ាង គឺពិចារណាដល់ភាពជាធំដោយជាតិ ១ ពិចារណាដល់ភាពជាធំដោយជាអ្នកទូន្មាន ១ ពិចារណាដល់ភាពជាធំក្នុងមត៌ក ១ ពិចារណាដល់ភាពជាធំក្នុងការប្រព្រឹត្តព្រហ្មចរិយៈ ១ ហើយមិនធ្វើអំពើបាប ។ បុគ្គលខ្លះខ្លាចដោយការឃើញទោស ដោយហេតុ ៤ យ៉ាង គឺអត្តានុវាទភ័យ ១ បរានុវាទភ័យ ១ ទណ្ឌភ័យ ១ ទុគ្គតិភ័យ ១ ហើយកើតឱត្តប្បៈ មានលក្ខណៈឃើញភ័យដែលមានទោសគួរខ្លាចហើយ មិនធ្វើកម្មអាក្រក់ ។ម្យ៉ាងទៀត ក្នុងសេចក្តីនេះ កាលលោកពោលដល់ហិរិឱត្តប្បៈដែលកើតខាងក្នុងជាដើម ដោយភាពជារបស់ប្រាកដក្នុងទីនោះៗ ជួនកាលហិរិឱត្តប្បៈនោះ មិនប្រាសចាកគ្នានិងគ្នាឡើយ ព្រោះការខ្មាសមិនមាន ការខ្លាចក៏មិនមាន ឬខ្លាចចំពោះបាបមិនមាន ការខ្មាសរមែងមិនមាន ដោយ

ប្រការដូច្នេះ ។

បទថា **ឥមេ ច ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ បើធម៌មិនមានទោស ២ យ៉ាងនេះ មិនគប្បីរក្សាលោក គឺបើធម៌រក្សាលោកមិនគប្បីមាន ។ បទថា **នយិធ បញ្ញាយេថ មាតា** សេចក្ដីថា ក្នុងលោកនេះ មាតាបង្កើត ក៏មិនគប្បីប្រាកដដោយការគោរពថា នេះម្ដាយរបស់អញ ដូច្នេះ គឺមិនគប្បីបានឈ្មោះថា នេះជាមាតា ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **មាតុច្ឆា** បានដល់ ប្អូនរបស់ម្ដាយ ។ បទថា **មាតុលានី** បានដល់ ភរិយារបស់ឪពុកធំ ។ បទថា **គរូនំ** បានដល់ បុគ្គលដែលនៅក្នុងឋានៈគួរគោរព មានអ៊ំ មា និងរៀមច្បងជាដើម ។ បទថា **សម្ភេទំ** បានដល់ លាយឡំគ្នា ឬទម្លាយមារយាទដែលល្អ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងឧបមាដោយបទជាដើមថា **យថា អជេឡកា** ដូច្នេះ ។ ម្យ៉ាងទៀត សត្វទាំងឡាយនេះ រមែងមិនដឹងនូវសេចក្ដីគោរព កោតក្រែងថា នេះមាតារបស់យើង ឬមីងរបស់យើង ដូច្នេះ ។ សត្វទាំងឡាយ រមែងបដិបត្តិខុសក្នុងវត្ថុដែលខ្លួនអាស្រ័យកើត ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើការប្រៀបធៀប ទើបបាននាំពពែ និងចៀមជាដើមមក សេចក្ដីសង្ខេបក្នុងសេចក្ដីនេះ មានដូច្នេះ ។ សត្វតិរច្ឆានទាំងឡាយ មានពពែ និងចៀមជាដើម វៀរចាកហិរិ និងឱត្តប្បៈ មិនសម្គាល់មាតាជាដើម ទម្លាយបវេណី សហាយស្មន់នឹងគ្នាបានគ្រប់កាល យ៉ាងណា មនុស្សលោកនេះ ក៏ដូច្នោះ បើមិនមានលោកបាលធម៌ គប្បីសេពសន្ថវៈបានគ្រប់កាលគ្រប់កន្លែង

ព្រោះលោកបាលធម៌ទាំងនេះ នៅគ្រប់គ្រងលោកនៅឡើយ ព្រោះដូច្នោះ ទើបមិនមានការសេពសន្ថវៈ ពាសវាលពាសកាល ដូច្នេះ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា ច ក្នុងបទថា **យេសំ ច ហិរិឱត្តប្បំ** ត្រឹមតែជានិបាត សេចក្តីថា សត្វពួកណាមិនមាន គឺមិនចូលដល់ហិរិ និងឱត្តប្បៈ ក្នុងកាលសព្វកាល គឺអស់កាលជានិច្ច ។ បទថា **វោក្កន្តា សុក្កមូលា តេ** សេចក្តីថា សត្វទាំងនោះឈានកន្លង គឺផុតចាកកុសល ព្រោះធ្វើនូវកម្មដែលកាត់ផ្តាច់កុសលមូល ឬព្រោះមិនមានហិរិ និងឱត្តប្បៈ ជាទីតាំងនៃកុសលកម្ម មានសុក្កធម៌ទៅប្រាសហើយ ឈានកន្លងហើយ ជាអ្នកដល់នូវជាតិ និងមរណៈ ព្រោះមានសភាវៈកើតស្លាប់រឿយៗ រមែងមិនផុតចាកសង្សារទៅបានឡើយ ។

បទថា **យេសញ្ច ហិរិឱត្តប្បំ** សេចក្តីថា សត្វពួកណាចូលទៅតាំងធម៌ទាំងនេះ គឺហិរិ និងឱត្តប្បៈដោយប្រពៃ ក្នុងកាលជានវក មជ្ឈិម និងថេរៈ អស់ថ្ងៃ និងយប់សព្វកាល សត្វទាំងនោះតក់ស្លុត លះនូវបាបដោយតទង្គប្បហានជាដើម ។ បទថា **វិរូឡ្ហព្រហ្មចរិយា** សេចក្តីថា សត្វទាំងនោះ ដល់នូវការស្អាតដោយសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ដែលជាអ្នកស្ងប់ ព្រោះស្ងប់នូវកិលេស ឬមានគុណ គឺសេចក្តីស្ងប់ដោយប្រការទាំងពួង ដោយការសម្រេចមគ្គជាន់ខ្ពស់ ជាអ្នកមានភពថ្មីអស់ហើយ ព្រោះអស់នូវភពថ្មី ៕

**អដ្ឋកថា សុក្កធម្មសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អជាតសូត្រ

[ ៤៣ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលមិនកើត មិនមាន មិនបានធ្វើ ដែលបច្ច័យមិនតាក់តែងហើយ តែងមាន ម្នាលភិក្ខុទាំងឡាយ បើធម្មជាតដែលមិនកើត មិនមាន មិនធ្វើ ដែលបច្ច័យមិនតាក់តែង និងមិនបានមានហើយ ការរលាស់ចេញចាកធម្មជាត ដែលកើត ដែលមាន ដែលបានធ្វើ ដែលបច្ច័យតាក់តែង ក៏រមែងមិនប្រាកដក្នុងលោកនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម្មជាត ដែលមិនកើត មិនមាន មិនបានធ្វើ ដែលបច្ច័យមិនតាក់តែងហើយ តែងមាន បានជាការរលាស់ចេញចាកធម្មជាត ដែលកើត ដែលមាន ដែលបានធ្វើ ដែលបច្ច័យតាក់តែងហើយ ទើបប្រាកដឡើងបាន ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលមិនគួរត្រេកអរនឹងកាយនេះ ដែលកើត ដែលមាន
ដែលកើតព្រម ដែលបានធ្វើ ដែលបច្ច័យតាក់តែង
ហើយ ជារបស់មិនទៀង ជារបស់ដែលជរា និងមរណៈ
តាក់តែងហើយ ជាទីនៅនៃរោគ ជារបស់ពុករលួយ
មានអាហារ និងតណ្ហាជាប្រភព ( ជាដែនកើត ) ឯព្រះ
និព្វានជាគ្រឿងរលាស់ចេញនូវកាយនោះ ទើបជារបស់
ស្ងប់ មិនជារបស់ប្រព្រឹត្តទៅតាមសេចក្តីត្រិះរិះ ជារបស់

ទៀត ជារបស់មិនកើត មិនកើតព្រម មិនមានសោក
ប្រាសចាកសេចក្តីត្រេកអរ ការរលត់នូវហេតុនៃទុក្ខ
ទាំងឡាយ ការរម្ងាប់នូវសង្ខារ ជាគុណនាំមកនូវសេចក្តី
សុខ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## អជាតសូត្រ

[ ៤៣ ] ក្នុងអជាតសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អត្ថិ ភិក្ខវេ** សួរថា អត្ថុប្បត្តិហេតុដូចម្តេច ឆ្លើយថា បានឮថា ថ្ងៃមួយកាលព្រះមានព្រះភាគទ្រង់ប្រកាសទោសក្នុងសង្សារ ដោយអនេកបរិយាយហើយទ្រង់សម្តែងធម៌បដិសំយុត្តដោយព្រះនិព្វាន ដោយការចង្អុលបង្ហាញជាដើម ភិក្ខុទាំងឡាយ បានកើតបរិវិតក្កថា ព្រះមានព្រះភាគត្រាស់សង្សារនេះ មួយអន្លើដោយហេតុ ដោយករណៈទាំងឡាយ មានអវិជ្ជាជាដើម តែមិនបានត្រាស់ដល់ការណៈឯណានីមួយនៃនិព្វាន ដែលចូលទៅស្ងប់សង្សារនោះ សេចក្តីនេះ មិនមែនហេតុ រមែងបានដោយផ្លូវសច្ចិកត្ថបរមត្ថ ឬដូចម្តេច ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់កម្ចាត់សេចក្តីសង្ស័យរបស់

ភិក្ខុទាំងនោះ ដើម្បីទម្លាយវាទៈដែលខុសរបស់សមណព្រាហ្មណ៍ក្នុងលោកនេះ ដែលមានទិដ្ឋិច្រើនខាងក្រៅ ដែលបដិបត្តិខុស ដូចលោកាយតិកជាដើមថា ពិតហើយ ដោយបរមត្ថ ឈ្មោះថា និព្វាន រមែងមិនមាន ត្រឹមតែពោលថា និព្វាន និព្វានប៉ុណ្ណោះ ព្រោះមានសភាវៈដែលខ្លួនមិនទាន់បាន ដើម្បីសម្តែងការមាននៃអមតមហានិព្វានដោយបរមត្ថ និងដើម្បីសម្តែងដល់ការមានអានុភាព មានការចេញទៅនៃអមតមហានិព្វាននោះជាដើម ទើបទ្រង់ភាសិតសូត្រនេះ ដោយឧទានដែលជាកម្លាំងនៃបីតិ ជាសេចក្តីពិត ព្រះសូត្រនេះសង្គ្រោះចូលក្នុងឧទានផងដែរ ។

ក្នុងបទទាំងនោះ បទថា **អត្ថិ** បានដល់ មាន គឺដោយបរមត្ថ ។ ទោះបទទាំងអស់ថា **អជាតំ អភូតំ អកតំ អសង្ខតំ** ជាវេវចនៈនៃគ្នានិងគ្នា ។ ម្យ៉ាងទៀត ឈ្មោះថា **អជាតំ** ព្រោះមិនកើត គឺមិនកើតដោយការព្រមព្រៀងនៃហេតុ ពោល គឺការប្រជុំនៃហេតុប្បច្ច័យ ដូចវេទនាជាដើម ។ ឈ្មោះថា **អភូតំ** ព្រោះវៀរហេតុហើយ នឹងមិនកើត មិនប្រាកដ មិនកើតឯង ។ ឈ្មោះថា **អកតំ** ព្រោះដែលបច្ច័យមិនធ្វើហើយ ដោយហេតុណាមួយ ព្រោះមិនកើត និងព្រោះមិនកើតយ៉ាងនេះ ។ ម្យ៉ាងទៀត លោកពោលថា **អសង្ខតំ** ដើម្បីសម្តែងថា សភាវៈដែលកើតហើយ កើតហើយ រមែងមានដល់សង្ខតធម៌ មាននាមរូបជាដើម មិនមានដល់និព្វាន ដែលមានសភាពជាអសង្ខតៈឡើយ ។ ម្យ៉ាងទៀត ដោយបដិលោម ឈ្មោះថា **សង្ខតំ** ព្រោះត្រូវបច្ច័យតាក់តែងហើយ ។ ម្យ៉ាងទៀត ឈ្មោះថា **អសង្ខតំ** ព្រោះបច្ច័យមិនតាក់

តែងហើយ និងវៀរចាកលក្ខណៈ ដែលបច្ច័យតាក់តែងហើយ ។ លោកពោលថា **អកតំ** ដើម្បីសម្ដែងថា ដែលបច្ច័យណាមួយមិនធ្វើហើយ ដោយការសង្ស័យថា កាលអស់សភាវៈនៃការកើត ដោយហេតុ មិនមែនតិចយ៉ាងនេះ និងគប្បីមានការធ្វើដោយហេតុមួយប៉ុណ្ណោះឬហ្ន៎ លោកពោលថា **អភូតំ** ដើម្បីត្រឡប់នូវការសង្ស័យប៉ុណ្ណោះថា ធម្មជាតនេះ សូម្បីមិនមានបច្ច័យ ក៏កើតហើយ ប្រាកដហើយឯងឬហ្ន៎ ។ លោកពោលថា **អជាតំ** ដើម្បីសម្ដែងថា ភាពជាធម្មជាតនេះ ដែលបច្ច័យមិនតាក់តែង មិនធ្វើ មិនកើតនេះ ព្រោះជាធម្មជាតដែលមិនកើតគ្រប់យ៉ាង គប្បីជ្រាបពាក្យទាំង ៤ នេះ មានអត្ថយ៉ាងនេះ ។

ព្រះមានព្រះភាគ ត្រាស់ភាពដែលនិព្វានមានដោយបរមត្ថថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលមិនកើតហើយ មិនឧប្បត្តិហើយ ដែលបច្ច័យមិនធ្វើហើយ មិនតាក់តែងហើយមាន ដើម្បីទ្រង់សម្ដែងហេតុក្នុងធម្មជាតនោះ ទើបត្រាស់ពាក្យជាដើមថា **នោ ចេតំ ភិក្ខវេ** ដូច្នេះ ។

គប្បីជ្រាបសេចក្ដីសង្ខេបនៃបទនោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើអសង្ខតធាតុ មានសភាពមិនកើតជាដើម មិនមាន គឺមិនគប្បីមានសោតការរលាស់ចេញ គឺការចូលទៅស្ងប់វដ្ដៈ ដោយមិនសេសសល់នៃសង្ខារពោល គឺខន្ធបញ្ចកៈ មានរូបជាដើម ដែលមានការកើតជាដើមជាសភាវៈ និងមិនគប្បីប្រាកដ គឺមិនគប្បីបាន មិនគប្បីមានក្នុងលោកនេះ ព្រោះធម៌ គឺអរិយមគ្គ មានសម្មាទិដ្ឋិជាដើម ធ្វើនិព្វានឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ រមែង

កាត់នូវកិលេសទាំងឡាយ ដោយមិនសេសសល់ ដោយហេតុនោះ ការមិនប្រព្រឹត្តទៅ ការទៅប្រាស ការរលាស់ចេញនូវវដ្តទុក្ខទាំងអស់ រមែងប្រាកដក្នុងនិព្វាននេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់ភាពដែលព្រះនិព្វានមាន ដោយផ្ទុយគ្នាយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់និព្វាននោះ ដោយអនុលោមតាមគ្នា ទើបត្រាស់ពាក្យជាដើមថា **យស្មា ច ខោ** ដូច្នេះ ។ ពាក្យនោះ មានសេចក្តីដូចបានពោលហើយ ។ម្យ៉ាងទៀត ក្នុងសេចក្តីនេះ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់អនុគ្រោះលោកទាំងពួង ទ្រង់សម្តែងការកើតឯង ដោយបរមត្ថនៃនិព្វានធាតុ ដោយសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតដែលមិនកើត តែមាន ដោយបទសូត្រមិនតិច ដូចជាពួកធម៌មិនមានបច្ច័យ ពួកធម៌ឥតបច្ច័យតាក់តែង ដូច្នេះ ...។ ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះ រមែងមានពិត ដីមិនមាន ដូច្នេះ ...។ ធម៌ណារម្ងាប់នូវសង្ខារទាំងពួង ជាគ្រឿងលះបង់នូវឧបធិ គឺខន្ធ និងកិលេសទាំងពួង ... ធម៌នេះ ជាហេតុដែលសត្វឃើញបានដោយកម្រដែរ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអសង្ខតធម៌ ( ធម៌ដែលបច្ច័យតាក់តែងមិនបាន ) ផង អសង្ខតគាមិមគ្គ ( ផ្លូវជាដំណើរទៅកាន់អសង្ខតធម៌ ) ផង ដល់អ្នកទាំងឡាយ ដូច្នេះ។ ព្រោះហេតុនោះ ទើបមិនគួរជំទាស់ ។ ការសង្ស័យ ការងឿងឆ្ងល់ មិនមានដល់អ្នកប្រាជ្ញទាំងឡាយ ដែលមិនទាន់ប្រចក្សក្នុងសេចក្តីនោះ ការវែកញែកដោយមាតិកា យកមកអធិប្បាយក្នុងរឿងនេះ ដើម្បីបន្ទោបង់នូវសេចក្តីសង្ស័យនៃ

បុគ្គលដែលមិនមានបញ្ញា ។ ការរលាស់ចេញ ដែលមានសភាវៈឆ្ងាយអំពីនោះ ដែលជាបដិបក្ខនៃកាម និងរូបទាំងឡាយដែលក្រៃលែង ព្រោះភាពជាអ្នកកំណត់ដឹង រមែងប្រាកដយ៉ាងណា ការរលាស់ចេញ ដែលមានសភាវៈឆ្ងាយទៅអំពីនោះ ដែលជាបដិបក្ខនៃសង្ខតធម៌ទាំងពួង ដែលមានបច្ច័យនោះជាសភាវៈ គប្បីមានដូច្នោះ ។ ការរលាស់ចេញនោះ ជាអសង្ខតធាតុ ។

គប្បីជ្រាបអត្ថដទៃឲ្យក្រៃលែងទៀតថា វិបស្សនាញាណ ឬអនុលោមញាណ មានសង្ខតធម៌ជាអារម្មណ៍ មិនអាចលះកិលេសទាំងឡាយបានដោយការកាត់ផ្តាច់ ។ ម្យ៉ាងទៀត ញាណក្នុងបឋមជ្ឈានជាដើម ដែលមានសម្មតិសច្ចជាអារម្មណ៍ រមែងលះកិលេសទាំងឡាយបានដោយវិក្ខម្ភនៈប៉ុណ្ណោះ លះមិនបានជាសមុច្ឆេទឡើយ ។ អារម្មណ៍ដែលមានសភាពខុសអំពីញាណទាំង ២ គឺនៃញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និងមានសម្មតិជាអារម្មណ៍ ដោយមិនអាចលះកិលេសទាំងឡាយបានជាសមុច្ឆេទ តែអរិយមគ្គញាណ ដែលធ្វើការលះកិលេសទាំងនោះបានជាសមុច្ឆេទនោះ គប្បីមាននោះ គឺអសង្ខតធាតុ ។

បទថា **អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ** នេះ ជាពាក្យទូន្មានដល់ភាពដែលនិព្វានមានដោយបរមត្ថ ព្រោះព្រះមានព្រះភាគត្រាស់មិនខុស ។ ពិតហើយ ពាក្យដែលព្រះមានព្រះភាគត្រាស់មិនខុសដោយបរមត្ថដូចដែលត្រាស់ថា **សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តា** ដូច្នេះ ។ ម្យ៉ាងទៀត **និព្វាន** សព្ទ ជាបរមត្ថវិស័យ តាមសេចក្តី

ពិត ក្នុងវិស័យណាមួយ ព្រោះមានការប្រព្រឹត្តទៅ ដូច **សីហ** សត្វ ដូច្នោះ ។ គប្បីជ្រាបភាពដែលអសង្ខតធាតុមានដោយបរមត្ថ សូម្បីដោយយុត្តិ ដោយន័យជាដើមយ៉ាងនេះថា អសង្ខតធាតុ មានដោយបរមត្ថ ព្រោះមានសភាពផុតចាកភាពវិបរិត ក្រៅអំពីនោះ ដូចពាក្យថា បឋវីធាតុ វេទនាជាដើម ដូច្នេះ ។

ក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយដូចតទៅនេះ បទថា **ជាតំ** បានដល់ ឈ្មោះថា **ជាតំ** ព្រោះអត្ថថា កើត អធិប្បាយថា ដល់នូវលក្ខណៈនៃជាតិ ។ បទថា **ភូតំ** ឈ្មោះថា **ភូតំ** ព្រោះអត្ថថា កើត អធិប្បាយថា មិនកើត ហើយកើត ។ បទថា **សមុប្បន្នំ** បានដល់ កើតឡើងហើយ ដោយការមានប្រយោជន៍ និងកើតឡើងហើយដោយធម៌ដែលមានប្រយោជន៍ ។ បទថា **កតំ** បានដល់ កើតដោយបច្ច័យជាហេតុ ។ បទថា **សង្ខតំ** បានដល់ ឈ្មោះថា **សង្ខតំ** ព្រោះបច្ច័យនោះឯងតាក់តែងហើយ ។ ពាក្យទាំងអស់នោះ ជាឈ្មោះនៃការកើតរបស់បច្ច័យ ឈ្មោះថា **អទ្ធុវំ** ព្រោះវៀរចាកវត្ថុដែលមានសារៈជារបស់ទៀងជាដើម ។ ឈ្មោះថា **ជរាមរណសង្ខាតំ** ព្រោះប្រឡូកប្រឡំ គឺទាក់ទងនឹងជរា មរណៈ ដោយចំណែកមួយប៉ុណ្ណោះ ។ អាចារ្យមួយពួកពោលថា **ជរាមរណសង្ឃដ្ដំ** ដូច្នេះក៏មាន អធិប្បាយថា ត្រូវជរា និងមរណៈបៀតបៀន គឺគ្របសង្កត់ ។ ឈ្មោះថា **រោគនិឌ្ឌំ** ព្រោះជាសម្បុកនៃរោគច្រើនយ៉ាង មានរោគភ្នែកជាដើម ។ ឈ្មោះថា **បភង្គុណំ** ព្រោះមានប្រក្រតីបែកធ្លាយយ៉ាងក្រៃលែង ដោយការសម្តែង ដោយសេចក្តីព្យាយាម ។

ឈ្មោះថា **អាហារនេត្តិប្បភវំ** គឺមានអាហារ និងតណ្ហាជាដែនកើត ព្រោះមានអាការ ៤ យ៉ាង និងនេត្តិ គឺតណ្ហាជាដែនកើត គឺសមុដ្ឋាន ។ បច្ច័យទាំងអស់ជាអាហារ តែក្នុងទីនេះ គប្បីជ្រាបថា ទោសទាំងឡាយ ឈ្មោះថា **តណ្ហា** ព្រោះតណ្ហា លោកប្រើសព្ទថា **នេត្តិ** ។ ព្រោះដូច្នោះ ឈ្មោះថា **អាហារនេត្តិប្បភវំ** ព្រោះមានអាហារ និងតណ្ហាជាដែនកើត ឬឈ្មោះថា **អាហារ** ព្រោះអត្ថថា នាំទៅ ឈ្មោះថា **នេត្តិ** ព្រោះអត្ថថា ប្រព្រឹត្តទៅ សូម្បីយ៉ាងនេះ ក៏ឈ្មោះថា **អាហារនេត្តិប្បភវំ** ។

បទថា **នាលំ តទភិនន្ទិតុំ** បានដល់ មិនគួរត្រេកអរ ពេញចិត្តក្នុងឧបាទានក្ខន្ធ ៥ ដែលប្រព្រឹត្តទៅក្រៃលែងដោយបច្ច័យយ៉ាងនេះ បន្ទាប់អំពីនោះ ជារបស់មិនទៀង និងជាទុក្ខ ដោយតណ្ហា និងទិដ្ឋិ ។ បទថា **តស្ស និស្សរណំ** សេចក្តីថា ការរលាស់ចេញ គឺការចេញទៅនៃសក្កាយនោះ ដូចបានពោលហើយដោយន័យជាដើមថា **ជាតំ ភូតំ** កើត កើតហើយ ដូច្នេះ ឈ្មោះថា **សន្តំ** ព្រោះភាវៈដែលចូលដល់សេចក្តីស្ងប់ ធម្មជាតនោះឯង ជាវត្ថុដែលគួរសរសើរ ព្រោះមិនមានកិលេស មានរាគៈជាដើម ដែលមានការមិនស្ងប់ជាសភាវៈ និងការមិនមានសង្ខារទាំងពួង ។ ឈ្មោះថា **អតក្កាវចរំ** ព្រោះមិនមានអារម្មណ៍នៃញាណក្នុងការត្រិះរិះ ឈ្មោះថា **ធុវំ** ព្រោះអត្ថថា ទៀង បន្ទាប់អំពីនោះ ក៏ជា **អជាតំ អសមុប្បន្នំ** ឈ្មោះថា **អសោកំ** ព្រោះមិនមានហេតុធ្វើឲ្យសោក ឈ្មោះថា **វិរជំ** ព្រោះធូលី មានរាគៈជាដើមប្រាសចាកហើយ ឈ្មោះថា **បទំ** ព្រោះគួរចូលដល់ ដោយការកន្ទងសង្សារទុក្ខ ។ ឈ្មោះ

ថា **និរោធោ ទុក្ខូបសមោ** ព្រោះជាហេតុរលត់នៃទុក្ខធម៌ មានជាតិជាដើម ឈ្មោះថា **សង្ខារូបសមោ** ព្រោះជាហេតុស្ងប់នៃសង្ខារទាំងពួង ដែលជាទុក្ខធម៌ បន្ទាប់អំពីនោះ ក៏ឈ្មោះថា **សុខោ** ព្រោះជាសុខដោយចំណែកមួយ ។ ព្រះមានព្រះភាគ ទ្រង់លើកតម្កើងអមតមហានិព្វានប៉ុណ្ណោះ ដោយបទទាំងអស់ ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងនិព្វានឲ្យជាក់ច្បាស់ដោយជំទាស់គ្នា ក្នុងគាថាទី ១ ដោយការអនុលោមតាម ដោយគាថាទី ២ ដោយប្រការដូច្នេះ ៕

**អដ្ឋកថា អជាតសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ធាតុសូត្រ

[ ៤៤ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្ត សម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ និព្វានធាតុនេះ មាន ២ ។ និព្វានធាតុ ២ តើដូចម្តេច ។ គឺសឧបាទិសេសនិព្វានធាតុ ១ អនុបាទិសេសនិព្វានធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសឧបាទិសេសនិព្វានធាតុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ច បានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជនៈ ក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយ

ប្រពៃ ប៉ុន្តែឥន្ទ្រិយទាំង ៥ របស់អរហន្តខីណាស្រពនោះ តាំងនៅដដែល អរហន្តខីណាស្រពនោះ នៅសោយអារម្មណ៍ ដែលពេញចិត្ត និងមិនពេញចិត្ត សោយសុខ និងទុក្ខ ព្រោះឥន្ទ្រិយទាំង ៥ នោះ មិនមានសេចក្តីថ្នាំងថ្នាក់ទេ ។ ការអស់រាគៈ អស់ទោសៈ អស់មោហៈណា របស់ព្រះអរហន្តនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សឧបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ អនុបាទិសេសនិព្វានធាតុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ ដោយលំដាប់ មានសំយោជនៈ ក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ការសោយនូវអារម្មណ៍ទាំងពួង មានសុខវេទនាជាដើម ការមិនត្រេកអរ ដោយកិលេសមានតណ្ហាជាដើម របស់ព្រះអរហន្តនោះ នឹងស្ងប់រម្ងាប់ ឥតកម្រើក ក្នុងអត្តភាពនេះឯង ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុបាទិសេសនិព្វានធាតុ ។ ម្នាលភិក្ខុទាំងឡាយ និព្វានធាតុមាន ២ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

និព្វានធាតុ ២ នេះ ព្រះសម្មាសម្ពុទ្ធទ្រង់មានចក្ខុ ព្រះអង្គមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) មិនញាប់ញ័រ
( ដោយលោកធម៌ ) ទ្រង់ប្រកាសហើយថា ធាតុមួយ
ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ ជាទីអស់ទៅនៃតណ្ហា

ក្នុងភព ជាសឧបាទិសេសៈ ចំណែកធាតុ ដែលប្រព្រឹត្ត
ទៅក្នុងបរលោក រលត់ភពទាំងឡាយ ដោយសព្វគ្រប់
ជាអនុបាទិសេសៈ ។ អរហន្តទាំងឡាយណា មានចិត្ត
ផុតស្រឡះហើយ អស់តណ្ហាក្នុងភពហើយ ព្រោះដឹង
ព្រះនិព្វាននេះ ដែលបច្ច័យមិនតាក់តែងហើយ អរហន្ត
ទាំងនោះ ត្រេកអរក្នុងការអស់ទៅ ព្រោះបានធម៌មាន
ខ្លឹម អរហន្តទាំងនោះ មិនបានញាប់ញ័រ ដោយលោក-
ធម៌ បានលះបង់នូវភពទាំងអស់ហើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## ធាតុសូត្រ

[ ៤៤ ] ក្នុងធាតុសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ទ្វេមា** កាត់បទជា **ទ្វេ ឥមា ។ តណ្ហា** លោកហៅថា **វាន ។** ឈ្មោះថា **និព្វាន** ព្រោះចេញចាកតណ្ហា ឬជាទីមិនមានតណ្ហា ឬកាលសម្រេចនិព្វានហើយ តណ្ហាមិនមាន ។ ឈ្មោះថា **និព្វានធាតុ** ព្រោះនិព្វាននោះឈ្មោះថា **ធាតុ** ព្រោះអត្ថថា មិនមែនសត្វ មិនមែនជីវៈ ព្រោះអត្ថថា ទ្រទ្រង់នូវ

សភាវៈ ។

បានឮថា និព្វានធាតុនោះ មិនផ្សេងគ្នាដោយបរមត្ថ តែប្រាកដដោយបរិយាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ទ្វេមា ភិក្ខវេ និព្វានធាតុយោ** ដូច្នេះ ទ្រង់សំដៅដល់ការផ្សេងគ្នាដោយបរិយាយនោះដើម្បីទ្រង់សម្តែងដល់ប្រភេទតាមព្រះបំណង ទើបត្រាស់ពាក្យជាដើមថា **សឧបាទិសេសា** ដូច្នេះ ។

ក្នុងបទទាំងនោះ ខន្ធបញ្ចកៈ ឈ្មោះថា **ឧបាទិ** ព្រោះឲ្យកើតដោយភាពជាផល កើតអំពីកិលេសទាំងឡាយ មានតណ្ហាជាដើម ។ ឧបាទិដ៏សេសឈ្មោះថា **ឧបាទិសេស** ។ ឈ្មោះថា **ឧបាទិសេសា** ព្រោះព្រមដោយឧបាទិសេស ព្រោះការមិនមានសឧបាទិសេសនោះ ទើបឈ្មោះថា **អនុបាទិសេសា** ។

បទថា **អរហំ** បានដល់ ឆ្ងាយចាកកិលេស អធិប្បាយថា មានកិលេសនៅឆ្ងាយ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក មហាអស្សបុរសូត្រថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា អរហន្ត តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹតទៅ មួយអន្ទើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេស

ឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះ
ថា អរហន្ត ដោយប្រការដូច្នេះឯង ។

បទថា **ខីណាសវោ** សេចក្ដីថា ឈ្មោះថា ខីណាស្រព ព្រោះអាសវៈ ៤ មានកាមាសវៈជាដើម របស់ព្រះអរហន្តអស់ហើយ ដាច់ហើយ លះបានហើយ ស្ងប់ហើយ មិនគួរនឹងកើត ត្រូវភ្លើង គឺញាណដុតហើយ ។ បទថា **វុសិតវា** សេចក្ដីថា ឈ្មោះថា នៅចប់ហើយ ព្រោះនៅហើយ នៅចប់ហើយ នៅស្រេចហើយ មានការនៅក្នុងលំនៅចប់ហើយ មានចរណៈដែលប្រព្រឹត្តហើយ ក្នុងគរុសំវាសខ្លះ ក្នុងអរិយមគ្គខ្លះ ក្នុងអរិយវាស ១០ ខ្លះ ។ បទថា **កតករណីយោ** សេចក្ដីថា ឈ្មោះថា ធ្វើកិច្ចដែលគួរធ្វើស្រេចហើយ ព្រោះព្រះសេក្ខៈ ៧ តាំងអំពីកល្យាណជន ដែលជាបុថុជ្ជន ឈ្មោះថា ធ្វើកិច្ចដែលគួរ ធ្វើដោយមគ្គ ៤ កិច្ចដែលគួរធ្វើទាំងអស់ ព្រះខីណាស្រពធ្វើសម្រេច គឺស្រេចហើយ កិច្ចដែលគួរធ្វើ ដើម្បីសម្រេចការអស់ទុក្ខជាងនេះមិនមាន ។ សូម្បីក្នុងសេចក្ដីនេះ ព្រះមានព្រះភាគក៏ត្រាស់ក្នុងអង្គុត្តរនិកាយ ឆក្កនិបាតថា

**តស្ស សម្មា វិមុត្តស្ស សន្តចិត្តស្ស ភិក្ខុនោ**
**កតស្ស បតិចយោ នត្ថិ ករណីយំ ន វិជ្ជតិ ។**

កាលបើភិក្ខុនោះ មានចិត្តផុតស្រឡះ ដោយប្រពៃហើយ
មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំនូវកិច្ចដែលលោកត្រូវ
ធ្វើ ក៏មិនមាន កិច្ចដែលគួរធ្វើ ក៏មិនមាន ។

បទថា **ឱហិតភារោ** បានដល់ ភារៈ ៣ យ៉ាង គឺខន្ធភារៈ ១ កិលេសភារៈ ១ អភិសង្ខារភារៈ ១ ។ ភារៈ ៣ យ៉ាងនេះ ដែលភិក្ខុនោះដាក់ចុះហើយ គឺលើកចុះហើយ ដាក់ហើយ ធ្វើឲ្យធ្លាក់ទៅហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **ឱហិតភារោ** ។ បទថា **អនុប្បត្តសទត្ថោ** បានដល់ សម្រេចប្រយោជន៍របស់ខ្លួនហើយ ។ លោកពោលថា **សកត្ថំ** គឺប្រយោជន៍របស់ខ្លួនក៏មាន ។ ផ្លាស់ **ឧ** ជា **ក** ។ ឈ្មោះថា **អនុប្បត្តសទត្ថោ** ព្រោះប្រយោជន៍របស់ខ្លួន ដែលភិក្ខុសម្រេចហើយ ។ គប្បីជ្រាបអរហត្តថា **សទត្ថោ** ។ ពិតហើយ អរហត្តនោះ ឈ្មោះថា ជាប្រយោជន៍ខ្លួន ព្រោះជាប្រយោជន៍ខ្លួន ដោយអត្ថថាទាក់ទងដោយខ្លួន ដោយអត្ថថា មិនលះខ្លួន និងដោយជាប្រយោជន៍ក្រៃលែងរបស់ខ្លួន ។ បទថា **បរិក្ខីណភវសំយោជនោ** បានដល់ ឈ្មោះថា សំយោជនៈក្នុងភព ព្រោះសំយោជនៈទាំងនេះ គឺកាមរាគសំយោជនៈ បដិឃសំយោជនៈ មានះ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ និងអវិជ្ជាសំយោជនៈ រមែងប្រកប គឺចូលទៅចងសត្វទាំងឡាយក្នុងភព ឬភពដោយភព ។ ឈ្មោះថា មានសំយោជនៈក្នុងភពអស់ហើយ ព្រោះសំយោជនៈទាំងនោះនៃអរហន្តអស់ហើយ គឺលោកលះបានហើយ ត្រូវភ្លើង គឺញាណដុតហើយ បទថា **សម្មទញ្ញា** ក្នុងបទថា **សម្មទញ្ញា វិមុត្តោ** នេះ បានដល់ ព្រោះដឹងដោយប្រពៃ សេចក្តីនេះ លោកអធិប្បាយថា ព្រោះដឹង គឺពិចារណា ត្រិះរិះជាក់ច្បាស់ ធ្វើឲ្យច្បាស់តាមសេចក្តីពិតដោយប្រពៃ នូវការតាំងនៅនៃខន្ធទាំងឡាយ ថាជាខន្ធ នៃអាយតនៈទាំងឡាយ ថាជាអាយតនៈ នៃធាតុ

ទាំងឡាយថាជារបស់សូន្យ នៃទុក្ខដោយការបៀតបៀន នៃសមុទយៈថាជាហេតុកើតឡើងនៃទុក្ខ នៃនិរោធថាជាទីស្ងប់ នៃមគ្គថាជាទស្សនៈ ឬ នូវប្រភេទមាន **សព្វេ សង្ខារា អនិច្ចា** ជាដើមដូច្នេះ ។

បទថា **វិមុត្តោ** បានដល់ វិមុត្តិ ២ យ៉ាង គឺរួចផុតដោយចិត្ត ១ រួចផុតដោយនិព្វាន ពិតហើយ ព្រះអរហន្ត ឈ្មោះថា រួចផុតដោយចិត្តខ្លះ ឈ្មោះថា រួចផុតដោយនិព្វានខ្លះ ព្រោះផុតចាកកិលេសទាំងឡាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ថា **សម្មទញ្ញា វិមុត្តោ** ។

បទថា **តស្ស តិដ្ឋន្តេវ បញ្ចិន្ទ្រិយានិ** សេចក្ដីថា ឥន្ទ្រិយ ៥ មានចក្ខុន្ទ្រិយជាដើមនៃអរហន្តនោះ នៅតាំងនៅដរាបស្មើគ្នានឹងកម្មដែលជាហេតុឲ្យកើតក្នុងភពចុងក្រោយ មិនទាន់អស់ទៅ ។ បទថា **អវិឃាតត្តា** បានដល់ ព្រោះមិនរលត់ដោយការរលត់ គឺការមិនកើត ។ បទថា **មនាបាមនាបំ** បានដល់ អារម្មណ៍ មានរូបដែលគួរពេញចិត្ត និងមិនគួរពេញចិត្តជាដើម ។ បទថា **បច្ចនុភោតិ** បានដល់ រមែងសោយ គឺរមែងបាន ។ បទថា **សុខទុក្ខំ បដិសំវេទេតិ** បានដល់ រមែងសោយសុខ និងទុក្ខដែលជាវិបាក គឺតែងបានដោយទ្វារទាំងនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងឧបាទិសេសដោយហេតុ មានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងសឧបាទិសេសនិព្វានធាតុ ទើបត្រាស់ពាក្យជាដើមថា **តស្ស យោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តស្ស** បានដល់ ព្រះអរហន្តដែលនៅមាន

សឧបាទិសេសនោះ ។ បទថា **យោ រាគក្ខយោ** បានដល់ ការអស់ទៅ គឺអាការអស់ទៅ ការមិនមាន ការមិនកើត ក្នុងទីបំផុតនៃរាគៈ ។ ក្នុងបទដ៏សេស ក៏មានន័យនេះ ។ ជាការសម្ដែងដល់សឧបាទិសេសនិព្វានធាតុដែលអស់រាគៈជាដើម ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

បទថា **ឥធេវ** បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា **សព្វវេទយិ-តានិ** បានដល់ វេទនាទាំងអស់ មានសុខវេទនាជាដើម ។ អព្យាកតវេទនា កុសលាកុសលវេទនា លោកលះបានមុនហើយ ។ បទថា **អនភិនន្ទិតានិ** បានដល់ លោកមិនត្រេកអរដោយកិលេស មានតណ្ហាជាដើម ។ បទថា **សីតិភវិស្សន្តិ** បានដល់ នឹងត្រជាក់ដោយការស្ងប់ចំណែកមួយ ។ គឺដោយការស្ងប់រម្ងាប់សេចក្ដីក្រវល់ក្រវាយក្នុងសង្ខារ គឺនឹងរលត់ ដោយការរលត់ដែលមិនមានបដិសន្ធិ ។ មិនមែនត្រឹមតែវេទនាតែម្យ៉ាងប៉ុណ្ណោះទេ នឹងរលត់សូម្បីខន្ធ ៥ ទាំងអស់ ក្នុងសន្តានព្រះខីណាស្រព ក៏នឹងរលត់ លោកប្រើទេសនាដោយមាតិកាថា **វេទយិត**។

ក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយដូចតទៅនេះ បទថា **ចក្ខុមតា** បានដល់ អ្នកមានចក្ខុ ដោយចក្ខុទាំង ៥ គឺពុទ្ធចក្ខុ ធម្មចក្ខុ ទិព្វចក្ខុ បញ្ញា-ចក្ខុ សមន្តចក្ខុ ។ បទថា **អនិស្សិតេន** បានដល់ មិនអាស្រ័យធម៌ណាមួយ ដោយជាទីអាស្រ័យរបស់តណ្ហា និងទិដ្ឋិ ឬមិនពាក់ព័ន្ធដោយចំណង គឺរាគៈជាដើម ។ បទថា **តាទិនា** បានដល់ ជាអ្នកមាំទាំ មានលក្ខណៈ មិនញាប់ញ័រ ពោល គឺភាពជាបុគ្គលឯកក្នុងអារម្មណ៍ទាំងពួង មានឥដ្ឋារម្មណ៍

ជាដើម ដោយឧបេក្ខាមានអង្គ ៦ ។ បទថា **ទិដ្ឋធម្មិកា** បានដល់ និព្វានធាតុដែលមាន គឺប្រព្រឹត្តទៅក្នុងអត្តភាពនេះ ។ បទថា **ភវនេត្តិសង្ខយា** បានដល់ ព្រោះអស់តណ្ហាដែលនាំទៅកាន់ភព ។ បទថា **សម្បរាយិកា** បានដល់ ដែលមានខាងមុខ គឺក្នុងចំណែកដទៃចាកការទម្លាយខន្ធ ។ បទថា **យម្හិ** បានដល់ ក្នុងឧបាទិសេសនិព្វាន ។ បទថា **ភវានិ** លោកពោលជាលិង្គវិបល្លាស ។ ឧបត្តិកពមិនសេសសល់ ដោយប្រការទាំងពួង រមែងរលត់ គឺរមែងមិនប្រព្រឹត្តទៅ ។ បទថា **តេ** បានដល់ ជនទាំងនោះ មានចិត្តផុតហើយយ៉ាងនេះ ។ បទថា **ធម្មសារាធិគមា** បានដល់ ព្រោះជាអ្នកមានវិមុត្តិជាសារៈ គឺព្រោះសម្រេចអរហត្តដែលជាសារៈក្នុងធម៌ទាំងឡាយ នៃធម្មវិន័យនេះ ។ បទថា **ខយេ** បានដល់ ត្រេកអរ ត្រេកអរក្រៃលែងហើយក្នុងនិព្វានដែលជាទីអស់កិលេស មានរាគៈជាដើម ។ ម្យ៉ាងទៀត ដែលជាសារៈក្នុងធម៌ទាំងឡាយ ដោយភាពជារបស់ទៀង និងដោយភាពជារបស់ប្រសើរបំផុត ព្រោះដូច្នោះ ទើបឈ្មោះថា មានធម៌ជាសារៈ គឺនិព្វាន ។ សមដូចព្រះមានព្រះភាគត្រាស់ថា **វិរាគោ សេដ្ឋោ ធម្មានំ វិរាគោ តេសំ អគ្គមក្ខាយតិ** វិរាគធម៌ប្រសើរជាងធម៌ទាំងឡាយ វិរាគធម៌ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ។ ជនទាំងឡាយត្រេកអរហើយ ក្នុងអនុបាទិសេសនិព្វាន ជាទីអស់កិលេស គឺជាទីអស់សង្ខារទាំងពួង ព្រោះសម្រេចធម៌ដែលជាសារៈនោះ ។ បទថា **បហំសុ** គឺលះហើយ ។ បទថា **តេ** ត្រឹមតែជានិបាត បទដ៏សេស មានន័យដូចពោលហើយនោះឯង ។l៚

# សុត្តន្តបិដក

## បដិសល្លានសូត្រ

[ ៤៥ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររីករាយក្នុងទីស្ងាត់ ត្រេកអរក្នុងទីស្ងាត់ ប្រកបរឿយៗ នូវចេតោសមថៈ ក្នុងខាងក្នុង កុំសាបសូន្យចាកឈាន ប្រកបព្រមដោយវិបស្សនា ចម្រើនសុញ្ញាគារស្ថាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ រីករាយក្នុងទីស្ងាត់ ត្រេកអរក្នុងទីស្ងាត់ ប្រកបរឿយៗ នូវចេតោសមថៈក្នុងខាងក្នុង មិនសាបសូន្យចាកឈាន ប្រកបដោយវិបស្សនា ចម្រើនសុញ្ញាគារស្ថានហើយ បណ្តាផលទាំងឡាយពីរផលណាមួយ គង់នឹងបានប្រាកដ គឺបានសម្រេចអរហត្ត ក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនទាំងឡាយណា ជាអ្នកមានចិត្តស្ងប់ មានបញ្ញា មានស្មារតី មានឈាន ពិចារណាឃើញធម៌ដោយប្រពៃ
មិនមានសេចក្តីអាល័យ ក្នុងកាមទាំងឡាយ ត្រេកអរ
ក្នុងសេចក្តីមិនប្រមាទ ជាអ្នកស្ងប់រម្ងាប់ ឃើញភ័យ
ក្នុងសេចក្តីប្រមាទ ជនទាំងឡាយនោះ មិនគួរដើម្បីនឹង
សាបសូន្យ ( ស្ថិតនៅ ) ក្នុងទីជិតនៃព្រះនិព្វាន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់

ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## បដិសល្លានសូត្រ

[ ៤៥ ] ក្នុងបដិសល្លានសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **បដិសល្លានារាមា** បានដល់ ជាអ្នកចៀសចាកសត្វ និងសង្ខារនោះៗ ហើយនៅ សម្ងំម្នាក់ឯង ។ ឈ្មោះថា មានកាយវិវេក ព្រោះសេពនូវមគ្គដ៏ឯក ។ ឈ្មោះថា **បដិសល្លានារាមា** ព្រោះមានការពួនសម្ងំ ដែលជាទីត្រេកអរ គឺជាទីពេញចិត្ត ។ បាលីថា **បដិសល្លាណារាមា** ដូច្នេះក៏មាន ។ ឈ្មោះថា **បដិសល្លាណារាមា** ព្រោះជាអ្នកមានការពួនសម្ងំ ដូចពោលហើយជាទីមកត្រេកអរ ព្រោះគួរមកត្រេកអរ ។ បទថា **វិហរថ** សេចក្តីថា អ្នកទាំងឡាយ ចូរជាបុគ្គលយ៉ាងនេះចុះ ។ ឈ្មោះថា **បដិសល្លានរតា** ព្រោះជាអ្នកត្រេកអរហើយ គឺត្រេកអរជានិច្ច ត្រេកអរហើយក្នុងការពួនសម្ងំ ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ការប្រកបសេចក្តីព្យាយាម និងជាអ្នកមានការពួនសម្ងំ ដែលជានិមិត្តនៃការប្រកបសេចក្តីព្យាយាមនោះ លោកសម្តែងហើយ ។ ការប្រកបសេចក្តីព្យាយាម វៀរចាកធម៌ទាំងឡាយនេះ គឺសីលសំវរៈ ជាអ្នកមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន សតិ និងសម្បជញ្ញៈ រមែងប្រព្រឹត្តទៅមិនបាន

ព្រោះហេតុនោះ គប្បីជ្រាបថា ធម៌ទាំងនោះ លោកពោលក្នុងទីនេះដោយអត្ថប៉ុណ្ណោះ ។

បទថា **អជ្ឈត្តំ ចេតោសមថមនុយុត្តោ** បានដល់ ប្រកបចិត្តរបស់ខ្លួនក្នុងសមថៈ ។ បទថា **អជ្ឈត្តំ អត្តនោ** នេះ សេចក្តីតែមួយដូចគ្នា ផ្សេងតែព្យញ្ជនៈប៉ុណ្ណោះ ។ បទថា **សមថំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយប្រកបតាមសព្ទ ។ បទថា **អនិរាកតជ្ឈានោ** បានដល់ មានឈានមិននាំចេញទៅខាងក្រៅ ឬមានឈានមិនសាបសូន្យ ។ ការនាំចេញ ឬការវិនាស ឈ្មោះថា **និរាកតំ** ដូចក្នុងពាក្យដែលលោកពោលនៅក្នុងសុត្តនិបាតថា **ថម្ភំ និរង្កត្វា និវាតវុត្តិ** បុគ្គលគួរធ្វើការរឹងត្អឹងឲ្យជ្រះស្រឡះ ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **វិបស្សនាយ សមន្នាគតោ** បានដល់ ប្រកបដោយអនុបស្សនា ៧ យ៉ាង ។

អនុបស្សនា ៧ យ៉ាង គឺអនិច្ចានុបស្សនា ១ ទុក្ខានុបស្សនា ១ អនត្តានុបស្សនា ១ និព្វិទានុបស្សនា ១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ វិបស្សនាទាំងនោះពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។

បទថា **ព្រូហេតា សុញ្ញាគារានំ** បានដល់ ចម្រើនសុញ្ញាគារ ម្យ៉ាងទៀត ក្នុងបទថា **សុញ្ញាគារានំ** នេះ បានដល់ ការស្ងាត់ណាមួយ ជាឋានៈដែលសមគួរដល់ការបំពេញភាវនា ។ ភិក្ខុទាំងឡាយរៀនកម្មដ្ឋាន ទាំងសមថ-កម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានហើយ ចូលទៅកាន់សុញ្ញាគារ អង្គុយបំពេញភាវនា អស់យប់ និងថ្ងៃ គប្បីជ្រាបថា ជាអ្នកចម្រើននូវសុញ្ញាគារ ។ រីឯ

បុគ្គលដែលនៅក្នុងប្រាសាទមួយជាន់ជាដើម ហើយសម្ដីង ក៏គប្បីជ្រាបថា ជាអ្នកចម្រើនសុញ្ញាគារដូចគ្នា ។

ភាពជាអ្នកមានកាយពួនសម្ងំឯណា ដែលលោកពោលក្នុងបទនេះថា **បដិសល្លានារាមា ភិក្ខវេ វិហរថ បដិសល្លានរតា** ភាពជាអ្នកមានកាយពួនសម្ងំនោះ រមែងមានដល់អ្នកមានសីលបរិសុទ្ធ រមែងមិនមានដល់អ្នកមិនមានសីល ឬមានសីលមិនបរិសុទ្ធ ព្រោះអ្នកមានសីលបរិសុទ្ធនោះ មិនមានការវិលត្រឡប់ចិត្តចាករូបារម្មណ៍ជាដើម ។ អត្ថនៃសេចក្ដីព្យាយាម លោកពោលក្នុងបទថា មានសីលបរិសុទ្ធ លោកសម្ដែងហើយ ។ លោកពោលដល់សមាធិភាវនា ដោយ ២ បទថា **អជ្ឈត្តំ ចេតោសមថមនុយុត្តា ១ អនិរាកតជ្ឈានា ១** លោកចាត់បញ្ញាភាវនាដោយបទនេះថា **វិបស្សនាយ សមន្នាគតា** ដូច្នេះ ។ លោកសម្ដែងសិក្ខា ៣ ជាលោកិយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់ផលដែលមានពិតនៃបុគ្គលដែលតាំងនៅក្នុងសិក្ខា ៣ នោះ ទើបត្រាស់ពាក្យជាដើមថា **បដិសល្លានារាមា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ព្រូហេតានំ** គឺចម្រើន ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ផលទី ៣ និងទី ៤ ។ បទថា **ចាដិកង្ខំ** បានដល់ គប្បីប្រាថ្នា គឺមានពិត ។ បទថា **អញ្ញា** បានដល់ អរហត្ត ពិតហើយ ព្រះអរហត្តនោះ លោកហៅថា **អញ្ញា** ព្រោះដឹងមិនលើសព្រំដែន ដែលដឹងបាន ដោយមគ្គញាណខាងក្រោម និងព្រោះមិនមានកិច្ចដែលត្រូវដឹងខាងលើ ព្រោះព្រះ

អរហន្តជាអ្នកមានការដឹងបរិបូណ៌ហើយ ។ បទថា **សតិ វា ឧបាធិសេសេ** បានដល់ កាលនៅមានកិលេស មិនអាចនឹងលះបាន ឬកាលមានញាណមិនទាន់ចាស់ក្លា កិលេសដែលគួរលះបានដោយញាណចាស់ក្លានោះមិនទាន់បាន ។ ព្រះមានព្រះភាគទ្រង់សំដៅដល់កិលេសនោះ ទើបត្រាស់ថា **សតិ វា ឧបា-ធិសេសេ** ដូច្នេះ ។ កាលនៅមានកិលេស ការគាក់តែងនៃខន្ធទាំងឡាយ ក៏នៅមាននោះឯង ។

ក្នុងសូត្រនេះ លោកសម្ដែងធម៌ ២ យ៉ាង គឺអនាគាមិផល ១ អរហត្តផល ១ ដោយប្រការដូច្នេះ ។ ក្នុង ២ សូត្រក្រៅអំពីនេះ ក៏ដូចគ្នានឹងសូត្រនេះ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូច្នេះ បទថា **យេ សន្តចិត្តា** បានដល់ ព្រះយោគាវចរពួកណា ឈ្មោះថា មានចិត្តស្ងប់ហើយ ព្រោះកិលេសស្ងប់ហើយដោយតទង្គប្បហាន ។ បញ្ញាលោកហៅថា **នេបក្កំ** គឺគ្រឿងរក្សាខ្លួន ។ ឈ្មោះថា **និបកា** ព្រោះប្រកបដោយបញ្ញានោះ ។ ព្រះមានព្រះភាគទ្រង់សម្ដែងញាណជាគ្រឿងបរិហារកម្មដ្ឋានដល់ជនទាំងនោះ ដោយបទថា **នេបក្កំ** នេះ ។ បទថា **សតិមន្តោ ច ឈាយិនោ** បានដល់ ឈ្មោះថា មានសតិ ព្រោះសតិដែលជាហេតុមិនលះកម្មដ្ឋាន ក្នុងការឈរ និងការអង្គុយជាដើម ឈ្មោះថា **ឈាយិនោ** ព្រោះមានឈាន មានលក្ខណៈចូលទៅនៃអារម្មណ៍ ។ បទថា **សម្មា ធម្មំ វិបស្សន្តិ កាមេសុ អនបេក្ខិនោ** សេចក្តីថា មិនមានការសម្លឹង គឺមិនត្រូវការក្នុងវត្ថុកាម និងកិលេសកាម ដោយន័យ

ជាដើមថា កាមទាំងឡាយប្រៀបដូចរាងឆ្អឹងក្នុងគំនរនោះឯង ដោយពិចារណាដល់ទោស កាលលះកាមទាំងឡាយនោះហើយ ធ្វើនូវឧបចារសមាធិ ឬក៏អប្បនាសមាធិដែលខ្លួនសម្រេចហើយឲ្យជាបាទ ហើយកំណត់នាមរូប និងបច្ច័យនៃនាមរូបនោះ រមែងឃើញធម៌ គឺខន្ធ ៥ មិនវិបរិតដោយប្រពៃតាមលំដាប់ មានការពិចារណាកលាបៈជាដើម ដោយភាពជារបស់មិនទៀងជាដើម ។ បទថា **អប្បមាទរតា** បានដល់ ត្រេកអរ គឺត្រេកអរក្រៃលែងក្នុងសេចក្តីមិនប្រមាទ ដោយការចម្រើនសមថៈ និងវិបស្សនា មានប្រការដូចពោលហើយ គឺមិនឲ្យយប់ និងថ្ងៃកន្លងទៅ ដោយសេចក្តីប្រមាទក្នុងធម៌នោះ ។ បទថា **សន្តា** ប្រែថា មាន ។ បាលីថា **សត្តា** ដូច្នេះក៏មានអធិប្បាយថា បានដល់ បុគ្គល ។ បទថា **បមាទេ ភយទស្សិនោ** បានដល់ឃើញភ័យក្នុងសេចក្តីប្រមាទ មានការចូលដល់នរកជាដើម ។ បទថា **អភព្វា បរិហានាយ** បានដល់ ជនទាំងនោះ ជាអ្នកមិនគួរដើម្បីវិនាសដោយជុំវិញចាកធម៌ គឺសមថៈ និងវិបស្សនា ឬចាកមគ្គផល ។ ព្រោះថា ជនទាំងឡាយ មិនសាបសូន្យចាកសមាបត្តិ គឺសមថៈ និងវិបស្សនា និងរមែងសម្រេចមគ្គផលដ៏សេស ដែលខ្លួនមិនទាន់សម្រេច ។ បទថា **និព្វានស្សេវ សន្តិកេ** បានដល់ ក្នុងទីជិតនៃនិព្វាន និងនៃអនុបាទិសេសនិព្វាននោះឯង ។ មិនយូរប៉ុន្មាន ជនទាំងនោះ នឹងសម្រេចនិព្វាននោះ ដោយប្រការដូច្នេះ ។

**អដ្ឋកថា បដិសល្លានសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សិក្ខានិសំសសូត្រ

[ ៤៦ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលមានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតី ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ មានសិក្ខាជាអានិសង្ស មានបញ្ញាជាកំពូល មានវិមុត្តិជាខ្លឹម មានសតិជាអធិបតីហើយ បណ្តាផលទាំង-ឡាយពីរ ផលណាមួយ គង់នឹងបានប្រាកដ គឺបានសម្រេចអរហត្តក្នុងបច្ចុប្បន្នពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

តថាគតហៅនូវបុគ្គល ដែលមានការសិក្សាបរិបូណ៌ មាន
ធម៌មិនបានលះបង់ មានបញ្ញាដ៏ឧត្តម បានឃើញព្រះ
និព្វាន ជាទីអស់ទៅនៃជាតិនោះឯង ថាជាមុនី ទ្រទ្រង់
នូវរាងកាយ ជាទីបំផុត កម្ចាត់បង់មារ ( មានកិលេស
មារជាដើម ) បានដល់ត្រើយនៃជរា ។ ម្នាលភិក្ខុទាំង-
ឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរត្រេកអរ
ក្នុងឈាន មានចិត្តតម្កល់មាំ មានព្យាយាមជាគ្រឿង
ដុតកម្តៅកិលេស ឃើញព្រះនិព្វានជាទីអស់ទៅនៃជាតិ
គ្របសង្កត់នូវមារ ព្រមទាំងសេនា សព្វកាល ដល់

ត្រើយនៃជាតិ និងមរណៈ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## សិក្ខានិសំសសូត្រ

[ ៤៦ ] ក្នុងសិក្ខានិសំសសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **សិក្ខា** ក្នុងបទថា **សិក្ខានិសំសា** នេះ ព្រោះត្រូវសិក្សា សិក្ខានោះមាន ៣ យ៉ាង គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិបញ្ញាសិក្ខា ១ ឈ្មោះថា **សិក្ខានិសំសា** ព្រោះមានសិក្ខា ៣ យ៉ាងនោះជាអានិសង្ស មិនមែនលាភសក្ការៈ និងការសរសើរឡើយ ។ បទថា **វិហរថ** បានដល់ អ្នកទាំងឡាយ ចូរជាអ្នកមានសិក្ខាជាអានិសង្សចុះ អធិប្បាយថា អ្នកទាំងឡាយចូរជាអ្នកឃើញអានិសង្សក្នុងសិក្ខា ៣ យ៉ាងនោះ គឺឃើញអានិសង្សដែលគួរនឹងបានដោយសិក្ខា ៣ យ៉ាងនោះចុះ ។ បទថា **បញ្ញុត្តរា** សេចក្តីថា ឈ្មោះថា មានបញ្ញាក្រៃលែង ព្រោះក្នុងសិក្ខា ៣ យ៉ាងនោះ មានបញ្ញា ពោលគឺអធិប្បបញ្ញាសិក្ខា មានបញ្ញានោះក្រៃលែង គឺជាប្រធានប្រសើរបំផុត អធិប្បាយថា បុគ្គលដែលមានសិក្ខាជាអានិសង្ស ជាអ្នកមានបញ្ញាក្រៃលែងដូច្នេះ ។ បទថា **វិមុត្តិសារា** បានដល់ ឈ្មោះថា មានវិមុត្តិជាសារៈ ព្រោះ

មានវិមុត្តិ ដែលបានដល់អរហត្តផលជាសារៈ អធិប្បាយថា កាន់យកវិមុត្តិតាមដែលពោលហើយនោះឯង ដោយភាពជាសារៈ ហើយតាំងនៅ ។ ពិតហើយ បុគ្គលដែលមានសិក្ខាជាអានិសង្ស និងមានបញ្ញាក្រៃលែង រមែងមិនប្រាថ្នាកពវិសេសឡើយ ។ ម្យ៉ាងទៀត ជនទាំងឡាយសង្ឃឹមសេចក្ដីចម្រើនរមែងប្រាថ្នានូវវិមុត្តិប៉ុណ្ណោះ ដោយភាពជាសារៈ ។ បទថា **សតាធិបតេយ្យា** បានដល់ ឈ្មោះថា មានសតិជាធំ ព្រោះមានសតិជាធំ ដោយអត្ថថា ធ្វើឲ្យចម្រើន អធិបតិនោះឯង ធ្វើឲ្យជា **អធិបតេយ្យំ** អធិប្បាយថា មានចិត្តតាំងមាំនៅក្នុងសតិប្បដ្ឋាន ៤ ខ្វល់ខ្វាយដោយសមថៈ និងវិបស្សនា ដោយគោលវិបស្សនា មានកាយានុបស្សនាជាដើម ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទនេះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានសិក្ខាជាអានិសង្ស ធ្វើការសិក្សាសិក្ខា ៣ យ៉ាង ក្នុងការបានខណៈដែលបានដោយកម្របែបនេះ ឲ្យជាអានិសង្សចុះ កាលនៅយ៉ាងនេះ ចូរជាអ្នកមានបញ្ញាក្រៃលែង គឺក្រៃលែងដោយបញ្ញា ចូរជាអ្នកប្រកបដោយលោកុត្តរប្បញ្ញាចុះ កាលបើដូច្នេះ ចូរជាអ្នកមានវិមុត្តិជាសារៈ មាននិព្វានជាសារៈ មិនមានដទៃជាសារៈចុះ អ្នកទាំងឡាយ ចូរជាអ្នកមានសតិជាធំ ចូរជាអ្នកខ្វល់ខ្វាយក្នុងការចម្រើនសតិប្បដ្ឋាន ឬចូរជាអ្នកមានចិត្ត មានសតិរក្សាក្នុងទីទាំងពួងចុះ នេះជាឧបាយយ៉ាងនោះ ។

ព្រះមានព្រះភាគ ទ្រង់ទូន្មានភិក្ខុទាំងឡាយក្នុងសិក្ខា ៣ ដោយប្រការដូច្នេះ ទ្រង់សម្ដែងដល់ឧបាយដែលនឹងឲ្យសិក្ខា ៣ ដែលគួរសិក្សាដល់ភាព

បរិបូណ៌ដោយសង្ខេប ។ ឥឡូវនេះ កាលទ្រង់ប្រកាសដល់កិច្ចបដិបត្តិនោះមិនជាមោឃ ដោយឃើញផលវិសេសរបស់អ្នកបដិបត្តិតាមដែលបានទូន្មាន ទើបត្រាស់ពាក្យជាដើមថា **សិក្ខានិសំសានំ** ដូច្នេះ ។ សេចក្តីនោះ មានអត្ថដូចបានពោលហើយ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូច្នេះ បទថា **បរិបុណ្ណសិក្ខំ** បានដល់ ព្រះអសេក្ខៈដែលមានសិក្ខាបរិសុទ្ធ ដោយការសម្រេចអគ្គផល ។ វិមុត្តិទាំងឡាយដែលកម្រើក លោកហៅថា **បហានធម្មិ** គឺធម៌ដែលវិនាសជាធម្មតា ក្នុងពាក្យថា **អបហានធម្មំ** នេះ ។ បហានធម៌ បានដល់ មានការវិនាសជាធម្មតា មានការកម្រើកជាធម្មតា ។ ឈ្មោះថា **នបហានធម្មោ** ព្រោះមិនមានការវិនាសជាធម្មតា គឺមានការមិនកម្រើកជាធម្មតា ។ បាលីថា **អបហា-នធម្មោ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ ឈ្មោះថា **ខយន្តោ** ព្រោះមានការអស់ទៅជាទីបំផុត ។ ព្រោះការអស់ទៅនៃជាតិ ឈ្មោះថា **ជាតិខយន្តោ** បានដល់ និព្វាននោះឯង ឈ្មោះថា **ជាតិខយន្តទស្សី** ព្រោះឃើញនិព្វាននោះ ។ បទថា **តស្មា** បានដល់ ព្រោះដល់ទីបំផុតនៃការដល់ត្រើយនៃជរា នេះជាអានិសង្សនៃការធ្វើសិក្ខាឲ្យបរិបូណ៌ ។ បទថា **សទា** គឺអស់កាលទាំងពួង ។ បទថា **ឈានរតា** បានដល់ ត្រេកអរហើយ ក្នុងឈាន ២ យ៉ាង គឺលក្ខណូបនិជ្ឈាន ១ អារម្មណូបនិជ្ឈាន ១ គឺមានចិត្តតាំងមាំចាកឈាននោះ ។ បទថា **មារំ សសេនំ អភិភុយ្យ** បានដល់ គ្របសង្កត់មារ ៤ យ៉ាង មួយអន្លើដោយសេនា បានដល់ សេនា គឺកិលេស និងសេនា គឺសេចក្តី

វិនាស មិនឲ្យសេសសល់ ។ ពិតហើយ កិលេសទាំងឡាយ លោកហៅថា **សេនា** ព្រោះចូលដល់ភាពជាសម្លាញ់របស់ទេវបុត្តមារ ក្នុងការសម្លាប់គុណ គឺសេចក្តីល្អ ។ ម្យ៉ាងទៀត រោគព្យសនៈជាដើម ក៏ជាសេនារបស់មច្ចុមារ ដូចព្រះមានព្រះភាគត្រាស់ក្នុងសុត្តនិបាតថា

កាមទាំងឡាយ ជាសេនាទី ១ របស់អ្នក សេចក្តីអផ្សុក ជាសេនាទី ២ សេចក្តីឃ្លាន និងស្រេក ជាសេនាទី ៣ របស់អ្នក តណ្ហាជាសេនាទី ៤ ថីនមិទ្ធៈ ជាសេនាទី ៥ សេចក្តីតក់ស្លុត ជាសេនាទី ៦ សេចក្តីសង្ស័យ ជាសេនាទី ៧ របស់អ្នក ការរមិលគុណ និងសេចក្តីរឹងត្អឹង ជាសេនាទី ៨ របស់អ្នក លាភ សេចក្តីសរសើរ សក្ការៈ និងយស ដែលបានដោយអំពើខុស បុគ្គលណាលើកតម្កើងខ្លួនឯងផង បន្អាប់បន្អោនពួកជនដទៃផង ម្នាលមារ នេះជាសេនារបស់អ្នក ជាសេនាសម្រាប់ប្រហាររបស់មារ បុគ្គលមិនក្លៀវក្លា មិនឈ្នះនូវសេនានោះទេ លុះតែឈ្នះសេនានោះ ទើបបាននូវសេចក្តីសុខ ។

និងដូចព្រះមានព្រះភាគត្រាស់ក្នុងភទ្ទេករត្តសូត្រថា

**អជ្ជេវ កិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ**
**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា។**

ឯការព្យាយាម ជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃ

នេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក បាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមាន សេនាដ៏ច្រើននោះ មិនមានសោះឡើយ ។

បទថា **ភវេថ ជាតិមរណស្ស ចារគា** បានដល់ អ្នកទាំងឡាយ ចូរ ជាអ្នកដល់ត្រើយនៃជាតិ និងមរណៈ គឺដល់នូវនិព្វានចុះ ។l៚

**អដ្ឋកថា សិក្ខានិសំសសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ជាគរិយសូត្រទី ១០

[ ៤៧ ] ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះ អរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីជាអ្នកភ្ញាក់រឭក មាន សតិ មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មានចិត្តទន់ មានសេចក្តីជ្រះថ្លា មាន ការឃើញ ក្នុងកាលគួរ ក្នុងកុសលធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ កាល បើភិក្ខុ ជាអ្នកភ្ញាក់រឭក មានសតិ មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មាន ចិត្តទន់ មានសេចក្តីជ្រះថ្លា មានការឃើញ ក្នុងកាលគួរ ក្នុងកុសលធម៌ទាំង នោះហើយ បណ្តាផលទាំងឡាយពីរ ផលណាមួយ គង់បានប្រាកដ គឺបាន សម្រេចអរហត្ត ក្នុងបច្ចុប្បន្ន ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់ នៅ ក៏គង់បានសម្រេចភាពជាអនាគាមី ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែង

សេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកទាំងឡាយ ចូរភ្ញាក់រឭកឡើង ចាំស្តាប់ពាក្យនុ៎ះ ជន
ទាំងឡាយណា ជាអ្នកដេកលក់ហើយ ជនទាំងឡាយ
នោះ ចូរភ្ញាក់ឡើង កិរិយាភ្ញាក់ចាកការលក់ ជាការ
ប្រសើរ ព្រោះភ័យមិនមានដល់បុគ្គលអ្នកភ្ញាក់ឡើយ ។
បុគ្គលណា ជាអ្នកភ្ញាក់រឭក មានសតិ មានសម្បជញ្ញៈ
មានចិត្តតម្កល់មាំ មានចិត្តទន់ មានចិត្តជ្រះថ្លា បុគ្គល
នោះ កាលពិចារណាឃើញធម៌ដ៏ប្រពៃ តាមកាលគួរ
ហើយ បុគ្គលនោះ ជាបុគ្គលប្រសើរឯក កម្ចាត់បង់នូវ
ងងឹត គឺអវិជ្ជាបាន ។ ព្រោះហេតុនោះ អ្នកទាំងឡាយ
គួរសេពគប់នូវជាគរិយធម៌ ភិក្ខុអ្នកមានព្យាយាម ជា
គ្រឿងដុតកម្តៅកិលេស មានបញ្ញា បានឈាន ផ្តាច់
បង់ នូវសំយោជនៈ នៃជាតិ និងជរាហើយ រមែងបាន
សម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកនេះឯង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១០ ។

# អដ្ឋកថា

## ជាគរិយសូត្រ

[ ៤៧ ] ក្នុងជាគរិយសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ជាគរោ** បានដល់ ជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭក គឺប្រាសចាកការដេកលក់ ប្រកបសេចក្តីព្យាយាមខ្វល់ខ្វាយហើយ ក្នុងមនសិការកម្មដ្ឋាន អស់យប់ និងថ្ងៃ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

ភិក្ខុក្នុងសាសនានេះ ញ៉ាំងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរារាំង ដោយការដើរទៅមក ដោយការអង្គុយ អស់មួយថ្ងៃ ញ៉ាំងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរារាំង ដោយការដើរទៅមក ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យា ដោយចំហៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងដោយជើង ជាអ្នកមានស្មារតី ដឹងខ្លួន ធ្វើទុកក្នុងចិត្ត ចំពោះឧដ្ឋានសញ្ញា ហើយក្រោកក្នុងបច្ឆិមយាមនៃរាត្រី ញ៉ាំងចិត្តឲ្យស្អាត ចាកធម៌ទាំងឡាយដែលរារាំង ដោយការដើរ ដោយការអង្គុយ ភិក្ខុជាអ្នកប្រកបរឿយៗ ក្នុងការព្យាយាម ជាគ្រឿងភ្ញាក់រឭក ក្នុងពេលមុនរាត្រី និងក្រោយរាត្រី យ៉ាងនេះឯង ។

ច សព្ទ ជាសម្បិណ្ឌនត្ថៈ គឺមានអត្ថបង្រួបបង្រួម ។ កាលពោលរាប់រយ ក៏រមែងប្រមូលមក ដោយ ច សព្ទ ។ បទថា **អស្ស** គឺ **សិយា** ប្រែថា គប្បីកើត ។ អាចារ្យពួកខ្លះពោលថា **ជាគរោ ច ភិក្ខុ វិហរេយ្យ** ភិក្ខុគប្បីមានសេចក្តីព្យាយាម ដូច្នេះក៏មាន ។ បទថា **សតោ** បានដល់ មាន

សតិ ដោយមិននៅប្រាសចាកសតិ ដោយមិនលះកម្មដ្ឋាន ក្នុងទីទាំងពួង និង ដោយកាលទាំងពួង ។ បទថា **សម្បជានោ** បានដល់ មានសម្បជញ្ញៈ ដោយ អំណាចនៃសម្បជញ្ញៈ ៤ យ៉ាង ដែលគួរជាទីតាំងរបស់សតិ ។ បទថា **សមាហិតោ** បានដល់ មានចិត្តតាំងមាំ គឺមានចិត្ត មានអារម្មណ៍តែមួយ ដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **បមុទិតោ** បានដល់ ត្រេកអរ គឺច្រើនទៅដោយបាមោជ្ជ ព្រោះឃើញអានិសង្សរបស់កិច្ចបដិបត្តិ និងព្រោះឃើញការប្រារព្ធព្យាយាមមិនជាមោឃ ដោយការសម្រេចភាព វិសេសក្រៃលែងឡើង ។ បទថា **វិប្បសន្នោ** បានដល់ ផូរផង់ដោយល្អ ព្រោះជាអ្នកច្រើនដោយសទ្ធាក្នុងសិក្ខា ដែលជាបដិបទាចាកការត្រេកអរនោះ និងក្នុងសាសនាដែលទ្រង់សម្តែងបដិបទា ។ គប្បីភ្ជាប់សេចក្តីថា **សព្វត្ថ អស្ស** គប្បីមានក្នុងទីទាំងពួង ឬភ្ជាប់ **សព្វត្ថ វិហារេយ្យ** គប្បីនៅក្នុងទីទាំងពួង ។

បទថា **តត្ថ កាលវិបស្សី ច កុសលេសុ ធម្មេសុ** បានដល់ ឃើញ ច្បាស់ក្នុងកាលនោះ ឬឃើញច្បាស់សមគួរដល់កាល ក្នុងការប្រកបកម្មដ្ឋាន នោះ គឺឃើញច្បាស់សមគួរដល់កាល ។ សួរថា លោកអធិប្បាយដូចម្តេច ឆ្លើយថា ភិក្ខុផ្តើមវិបស្សនាហើយ ពិចារណាដោយការពិចារណាជាក្រុម ជាដុំជាដើម វៀរអសប្បាយធម៌ ៧ មានអាវាសជាដើម ហើយសេព សប្បាយធម៌ មិនមានទីបញ្ចប់ក្នុងចន្លោះ មានចិត្តតាំងមាំ កំណត់អាការ ដែលចិត្តតាំងមាំ ប្រព្រឹត្តអនិច្ចានុបស្សនាជាដើម ក្នុងលំដាប់ដោយគោរព គប្បីជាអ្នកឃើញច្បាស់ សមគួរដល់កាលក្នុងកាលនោះៗ ឬក្នុងការប្រកប

កម្មដ្ឋាននោះយ៉ាងនេះ គឺក្នុងកាលណាវិបស្សនាចិត្តរួញរា ក្នុងកាលនោះ គប្បីឃើញច្បាស់ក្នុងពោជ្ឈង្គ ដែលមិនមានទោសជាកុសល បានដល់ ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ក្នុងកាលណាចិត្តរាយមាយ ក្នុងកាលនោះ គប្បីឃើញច្បាស់ក្នុងធម៌ គឺពោជ្ឈង្គដែលមិនមានទោស ជាកុសល បានដល់ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ដូច្នេះ ។ តែសតិសម្ពោជ្ឈង្គ គប្បីប្រាថ្នាសព្វកាល សមដូចព្រះមានព្រះភាគត្រាស់ថា

**សតិញ្ច ខ្វាហំ ភិក្ខវេ សព្វត្ថកំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិ ចាំបាច់ក្នុងទីទាំងពួង ដូច្នេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់សេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭក ដោយទេសនាដែលជាបុគ្គលាធិដ្ឋានហើយ ទើបប្រកាសធម៌ដែលមានការប្រកបសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭកបរិបូណ៌ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភារៈនៃការពិចារណា មួយអន្លើដោយឧបការកធម៌របស់ភិក្ខុអ្នកប្រារព្ធវិបស្សនា ដោយសង្ខេបហើយ ឥឡូវនេះ កាលទ្រង់សម្តែងដល់ការមិនខ្វះខាតចំពោះកិច្ចបដិបត្តិ របស់អ្នកបដិបត្តិយ៉ាងនោះ ទើបត្រាស់ពាក្យជាដើមថា **ជាគរស្ស ភិក្ខវេ ភិក្ខុនោ** ដូច្នេះ ។

ការកាន់យកសតិសម្បជញ្ញៈ ក្នុងការប្រកបសេចក្តីព្យាយាមនោះ នាំមកនូវការត្រេកអរ និងសេចក្តីជ្រះថ្លាដែលចាំបាច់ក្នុងទីទាំងពួង ការកាន់យកបន្ទប់នៃវិបស្សនាដែលដល់នូវការចាស់ក្លាហើយ ឈ្មោះថា វិបស្សនាសមគួរ

ដល់កាល ក្នុងការប្រកបកម្មដ្ឋាននោះ ។ កាលវិបស្សនាញាណទាំងក្លា ប្រព្រឹត្តទៅតាមវិថី ផុតចាកឧបក្កិលេស ហើយនាំទៅ បាមោជ្ជដ៏ក្រៃលែង និងការជ្រះថ្លានៃព្រះយោគី តែងមានក្នុងទីជិតនៃការសម្រេចធម្មវិសេស ដោយបាមោជ្ជ និងការជ្រះថ្លានោះ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងធម្មបទថា

**យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ**
**លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។**

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

**បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្ដីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **ជាគរន្តា សុណាថេតំ** សេចក្ដីថា អ្នកទាំងឡាយ ចូរជាអ្នកភ្ញាក់អំពីការដេកលក់ គឺសេចក្ដីប្រមាទ អំពីការដេកលក់ គឺអវិជ្ជា ដោយចំណែកមួយប៉ុណ្ណោះ គឺការប្រកបព្យាយាមដោយសេចក្ដីខ្វល់ខ្វាយក្នុងធម៌ មានសតិសម្បជញ្ញៈជាដើម

ចូរស្តាប់ពាក្យតថាគត ។ បទថា **យេ សុត្តា តេ បពុជ្ឈថ** សេចក្តីថា ជនពួកណាជាអ្នកដេកលក់ ចូលដល់នូវការដេកលក់ ដោយការដេកលក់តាមដែលពោលហើយ អ្នកទាំងនោះ ទាញយកឥន្ទ្រិយ ពល និងពោជ្ឈង្គ ដោយការប្រកបព្យាយាម ខ្វល់ខ្វាយក្នុងវិបស្សនា ចូរភ្ញាក់ចាកការដេកលក់នោះ ដោយបដិបត្តិសេចក្តីមិនប្រមាទចុះ ។ ម្យ៉ាងទៀត បទថា **ជាគរណ្ហ** គឺជានិមិត្តនៃសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭក ។ បទថា **ឯតំ** ក្នុងបទថា **សុណាថេតំ** នេះ លោកពោលហើយ ។ សួរថា ពាក្យនោះ គឺអ្វី ឆ្លើយថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា **យេ សុត្តា តេ បពុជ្ឈថ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យេ សុត្តា** បានដល់ ជនពួកណាដេកលក់ហើយ ដោយការដេកលក់ គឺកិលេស ជនទាំងនោះចូរភ្ញាក់ ដោយការត្រាស់ដឹងអរិយមគ្គ ។ បទថា **សុត្តា ជាគរិតំ សេយ្យោ** នេះ ជាពាក្យពោលដល់ហេតុនៃការត្រាស់ដឹង ។ ព្រោះភាពជាអ្នកភ្ញាក់ គឺការភ្ញាក់មានប្រការដូចបានពោលហើយចាកការដេកលក់ដូចពោលហើយ ជាគុណដ៏ប្រសើរ គឺគួរសរសើរនាំមកនូវប្រយោជន៍សុខដល់កុលបុត្រដែលប្រាថ្នាប្រយោជន៍ ដូច្នោះ អ្នកទាំងឡាយចូរភ្ញាក់ ។ បទថា **នត្ថិ ជាគរតោ ភយំ** នេះ សម្តែងដល់អានិសង្សក្នុងភាពជាអ្នកភ្ញាក់រឭកនោះ ។ ព្រោះថា បុគ្គលណាជាអ្នកភ្ញាក់រឭក ព្រោះប្រកបដោយធម៌ជាគ្រឿងភ្ញាក់រឭក មានសទ្ធាជាដើម រមែងភ្ញាក់ គឺមិនចូលដល់ការដេកលក់ គឺសេចក្តីប្រមាទ វដ្តភ័យទាំងអស់ គឺអត្តានុវាទភ័យ បរានុវាទភ័យ ទណ្ឌភ័យ ទុគ្គតិភ័យ ដែលមានជាតិជាដើមជានិមិត្ត រមែងមិនមាន

ដល់បុគ្គលនោះ ។

បទថា **កាលេន** បានដល់ ដោយកាលនៃអាវាសសប្បាយជាដើម ដែលខ្លួនបានហើយ ។ បទថា **សោ** ត្រឹមតែជានិបាត ។ បទថា **សម្មា ធម្មំ បរិវីមំសមានោ** សេចក្តីថា ពិចារណាដោយជុំវិញ គឺឃើញច្បាស់ដោយអាការទាំងពួង ដោយប្រការដែលនិព្វិទា និងវិរាគៈជាដើមកើតឡើង ដោយការដឹងធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាអារម្មណ៍នៃវិបស្សនាដោយប្រពៃ ។ បទថា **ឯកោទិភូតោ** បានដល់ ឈ្មោះថា **ឯកោទិ សមាធិ** ព្រោះមានសមាធិជាធម៌ឯក គឺប្រសើរបំផុតផុសឡើង ។ បុគ្គលនោះ ឈ្មោះថា **ឯកោទិភូតោ** ព្រោះមានសមាធិជាធម៌ឯកផុសឡើង កើតហើយ កើតឡើងហើយ ឧប្បត្តិកហើយដល់បុគ្គលនោះ ។ គប្បីឃើញពាក្យដែលជាបទនៃ **ភូត** សព្ទ ក្នុងបទនេះ ដូចបទនៃសព្ទថា **អគ្គិអាហិតាធិ** ភ្លើងត្រូវដុតហើយ ។ម្យ៉ាងទៀត ឈ្មោះថា **ឯកោទិភូតោ** ព្រោះជាធម៌ឯកផុសឡើង កើតហើយ គឺដល់ហើយ ។ ក្នុងបទថា **ឯកោទិ** នេះ លោកបំណងយកមគ្គសមាធិ ។ ក្នុងបទថា **សមាហិតោ** នេះ បានដល់ វិបស្សនាសមាធិ មួយអន្លើដោយសមាធិដែលមានឈានជាបាទ ។ ម្យ៉ាងទៀត បទថា **កាលេន** គឺដោយការបាក់ដួះនូវមគ្គ ។ បទថា **សម្មា ធម្មំ បរិវីមំសមានោ** បានដល់ ពិចារណាចតុសច្ចធម៌ ដោយបរិញ្ញាកិសម័យ ( ការត្រាស់ដឹងដោយការកំណត់ដឹង ) ជាដើមដោយប្រពៃ គឺត្រាស់ដឹងដោយឯកាកិសម័យ ( ត្រាស់ដឹងនូវធម៌ឯក ) ។ បទថា **ឯកោទិភូតោ** បានដល់ ឈ្មោះថា **ឯកោទិ** ព្រោះជាធម៌ឯក គឺប្រសើរ

មិនមានធម៌ រួមផុសឡើង ធ្វើកិច្ច ៤ ឲ្យសម្រេច គឺតម្កល់ដោយប្រពៃ ។ សមាធិនោះ ជាធម៌ឯក ផុសឡើងហើយ ។ បទទាំងពួងដូចគ្នានឹងបទមុននោះឯង ។ បទថា **វិហានេ តមំ សោ** បានដល់ អរិយសាវកយ៉ាងនេះ គប្បីកម្ចាត់ គឺគប្បីកម្ចាត់ងងឹត គឺអវិជ្ជា ដោយអរហត្តមគ្គ ដោយឥតសេសសល់ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកិច្ចបដិបត្តិមិនជាមោឃ ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលទ្រង់ទូន្មានឲ្យតាំងមាំក្នុងសេចក្តីនោះ ទើបត្រាស់គាថាចុងក្រោយថា **តស្មា ហវេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **តស្មា** សេចក្តីថា ព្រោះការចម្រើនសមថៈនិងវិបស្សនារបស់អ្នកភ្ញាក់រឭក ដោយការមិននៅប្រាសចាកសតិជាដើម តែងដល់នូវការបរិបូណ៌ អរិយមគ្គរមែងប្រាកដដោយលំដាប់ បន្ទាប់អំពីនោះ វដ្តភ័យទាំងអស់ រមែងមិនមានដល់ភិក្ខុនោះ ។ បទថា **ហវេ** គឺមាំទាំ ដោយចំណែកមួយ ។ បទថា **ភជេថ** បានដល់ គប្បីសេព អធិប្បាយថា ភិក្ខុសេពធម៌ជាគ្រឿងភ្ញាក់រឭកនេះ និងប្រកបដោយគុណ មានភាពជាអ្នកមាននូវព្យាយាមជាដើម ទម្លាយនូវសំយោជនៈជាដើម គប្បីពាល់ត្រូវ គឺគប្បីសម្រេចសម្ពោធិញ្ញាណ ដែលមិនមានធម៌ដទៃក្រៃលែងជាង គឺវៀរចាកធម៌ដែលក្រៃលែងជាង ពោល គឺញាណដែលជាផលដ៏ប្រសើរ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ៕៚

**អដ្ឋកថា ជាគរិយសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## អបាយសូត្រ

[ ៤៨ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ បើមិនទាន់លះបង់នូវបាបសមាចារៈនេះទេ មុខជានឹងទៅកើតក្នុងអបាយ កើតក្នុងនរកមិនខាន ។ បុគ្គល ២ ពួក តើដូចម្តេច ។ គឺបុគ្គលដែលមិនមែនជាព្រហ្មចារី ហើយប្តេជ្ញាខ្លួនជាព្រហ្មចារី ១ បុគ្គលដែលកម្ចាត់បង់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ដ៏បរិសុទ្ធបរិបូណ៌ ដោយអព្រហ្មចរិយធម៌ មិនមានមូល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះឯង បើមិនលះបង់នូវបាបសមាចារៈនេះទេ មុខជានឹងទៅកើតក្នុងអបាយ កើតក្នុងនរកមិនខាន ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលអ្នកនិយាយកុហក និងបុគ្គលដែលធ្វើបាប ហើយ
ពោលថា ខ្ញុំមិនធ្វើទេ រមែងទៅកើតក្នុងនរក បុគ្គល
ទាំង ២ ពួកនោះ ជាសត្វមានកម្មលាមក លះលោក
នេះហើយ រមែងមានទោសស្មើគ្នា ក្នុងបរលោក ។
បុគ្គលទាំងឡាយច្រើននាក់ មានកព័ន្ធព័ទ្ធដោយសំពត់
កាសាវៈ ប៉ុន្តែ ជាបុគ្គលមានធម៌លាមក មិនសង្រួម
បុគ្គលបាបទាំងនោះ នឹងទៅកើតក្នុងនរក ដោយកម្ម
ទាំងឡាយលាមក បុគ្គលបរិភោគដុំដែកក្តៅ មានរងើក
ភ្លើងជាឧបមា ប្រសើរជាង បុគ្គលទ្រុស្តសីល មិន

*សម្រែម បរិភោគដុំបាយ របស់អ្នកដែន មិនប្រសើរ*
*ឡើយ ។*

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១១ ។*

# អដ្ឋកថា

## អបាយិកសូត្រ

*ក្នុងអបាយិកសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ៤៨ ] បទថា* **អបាយិកា** *ឈ្មោះថា* **អបាយ** *ព្រោះនឹងកើតក្នុងអបាយ ។ ឈ្មោះថា* **នេរយិកា** *ព្រោះកើតក្នុងនរក ។ បទថា* **ឥធមប្បហាយ** *បានដល់ ព្រោះមិនលះនូវការប្រព្រឹត្តអាក្រក់ ២ យ៉ាង ដែលពោលដល់ក្នុងកាលឥឡូវនេះ អធិប្បាយថា ព្រោះមិនលះវាចា ចិត្ត និងទិដ្ឋិ ដែលប្រព្រឹត្តទៅហើយ ដោយបដិបត្តិមកយ៉ាងនោះ លើកតម្កើងមកយ៉ាងនោះ ។ បទថា* **អព្រហ្មចារី** *សេចក្តីថា ឈ្មោះថា* **ព្រហ្មចារី** *ព្រោះប្រព្រឹត្តព្រហ្មចរិយៈ គឺធម៌ដ៏ប្រសើរ ។ម្យ៉ាងទៀត ឈ្មោះថា* **ព្រហ្មចរិយំ** *ព្រោះមានការប្រព្រឹត្តព្រហ្មចរិយៈដ៏ប្រសើរ ។ ឈ្មោះថា* **អព្រហ្មចរិយេន** *ព្រោះមិនមែនព្រហ្មចារី អធិប្បាយថា បុគ្គលទ្រុស្តសីល ជាព្រហ្មចារីក្លែងក្លាយ ។ បទថា* **ព្រហ្មចារិប្បដិញ្ញោ** *បានដល់ ប្តេជ្ញាយ៉ាងនេះថា ខ្ញុំជាព្រហ្មចារី ។ បទថា* **បរិ-**

**បុញ្ញំ** បានដល់ មិនខូះខាត ព្រោះមិនមានការពព្រុស ពពាលជាដើម ។ បទថា **បរិសុទ្ធំ** បានដល់ បរិសុទ្ធ ព្រោះមិនមានឧបក្កិលេស ។ បទថា **អមូលកេន** បានដល់ ដោយអព្រហ្មចរិយៈ គឺដោយការប្រព្រឹត្តមិនប្រសើរ វៀរចាកមូល មានហេតុជាដើម គឺវៀរចាកមូលក្នុងការចោទទាំងឡាយនេះ គឺបានឃើញហើយ បានស្តាប់ហើយ បានរង្កៀសហើយ ។ បទថា **អព្រហ្ម-ចរិយេន** បានដល់ ដោយប្រព្រឹត្តមិនប្រសើរ ។ បទថា **អនុទ្ធំសេតិ** បានដល់ ទាំងដឹងថា បុគ្គលនោះ បរិសុទ្ធនៅតែកម្ចាត់ បៀតបៀន ចោទ ឬជេរ ដោយរឿងបារាជិក ។

ក្នុងគាថាទាំងឡាយ មានពាក្យអធិប្បាយដូចតទៅនេះ

បទថា **អភូតវាទី** បានដល់ មិនឃើញទោសនៃអ្នកដទៃឡើយ ពោលមុសាវាទ ដោយមិនពិត ឥតប្រយោជន៍ ហើយបន្ទាច់អ្នកដទៃ ។ បទថា **កត្វា** បានដល់ ឬបុគ្គលណាធ្វើនូវកម្មលាមក ហើយនៅពោលថា អញមិនបានធ្វើកម្មនេះ ។ បទថា **ឧភោបិ តេ បេច្ច សមា ភវន្តិ** បានដល់ ជនទាំង ២ ពួកនោះ កាលទៅកាន់លោកដទៃអំពីលោកនេះហើយ ជាអ្នកស្មើគ្នាដោយគតិ ព្រោះចូលដល់នរក ។ ក្នុងនរកនោះ កំណត់គតិរបស់ជន ២ ពួក តែមិនបានកំណត់អាយុរបស់ពួកគេទេ ព្រោះបុគ្គលធ្វើបាបច្រើន រមែងឆេះក្នុងនរកយូរ បុគ្គលធ្វើបាបតិច រមែងឆេះក្នុងនរកអស់កាលតិចតួច ព្រោះកម្មនៃជន ២ ពួកនោះលាមកដូចគ្នា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **និហីនកម្មា មនុជា បរត្ថ** ដូច្នេះ ។ គួរភ្ជាប់បទថា **បរត្ថ** ដោយបទថា **បេច្ច**

ដូច្នេះ ។ អធិប្បាយថា ជាអ្នកមានកម្មថោកទាបលះទៅហើយ គឺទៅអំពីលោកនេះហើយ រមែងជាអ្នកស្មើគ្នាក្នុងលោកខាងមុខ ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់វិបាកនៃមុសាវាទ ដែលប្រព្រឹត្តទៅហើយ ដោយការពោលពាក្យមិនពិត និងបិទបាំងទោសដែលពិត ឥឡូវនេះ ដើម្បីឲ្យកើតសង្វេគ ដោយការឃើញវិបាកនៃបាបកម្មរបស់ភិក្ខុអាក្រក់ដែលអន្ទុយក្នុងទីនោះ ទើបត្រាស់ ២ គាថា ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កាសាវកណ្ឋា** បានដល់ មានករុំដោយសំពត់កាសាវៈ ព្រោះមានទឹកម្ចត់ និងពណ៌លឿង ។ បទថា **ធាបធម្មា** បានដល់ ធម៌លាមក ។ បទថា **អសញ្ញតា** បានដល់ វៀរចាកការសង្រួមផ្លូវកាយជាដើម ។ បទថា **ធាធា** បានដល់ បុគ្គលអាក្រក់បែបនោះ កើតដោយកម្មលាមក ហើយសោយទុក្ខធំ តាមន័យដែលពោលហើយ ក្នុងលក្ខណសំយុត្ត មានពាក្យថា សង្ឃាដីរបស់ភិក្ខុនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ ... រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនោះក៏ចេះតែស្រែកថ្ងូរ ដូច្នេះ ។

ក្នុងគាថាទី ៣ គប្បីជ្រាបសេចក្តីដូចតទៅនេះ បទថា **យញ្ចេ ភុញ្ជេយ្យ ទុស្សីលោ** បានដល់ បុគ្គលទ្រុស្តសីល គឺមិនមានសីល មិនសង្រួមដោយកាយជាដើម ប្តេជ្ញាថា អញជាសមណៈ ទទួលដុំបាយដែលអ្នកដែនឲ្យដោយសទ្ធា ហើយបរិភោគ ។ ដុំដែកក្តៅ ដែលបុគ្គលទ្រុស្តសីលបរិភោគ គង់ប្រសើរជាង គឺល្អជាងការបរិភោគនោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា

ព្រោះការបរិភោគដុំដែកជាហេតុ បុគ្គលនោះ ក្តៅតែក្នុងអត្តភាពមួយប៉ុណ្ណោះ ឯបុគ្គលទ្រុស្តសីលបរិភោគរបស់ដែលគេឲ្យដោយសទ្ធា បុគ្គលនោះ គប្បីកើតក្នុងនរកអស់ជាតិមិនតែមួយ ។ ល។

**អដ្ឋកថា អចាយិកសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ទិដ្ឋិសូត្រ

[ ៤៩ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ត្រូវទិដ្ឋិទាំង ២ រួបរឹតហើយ ពួក ១ រមែងជាប់នៅ ពួក ១ រមែងស្ទុះទៅ ចំណែកឯពួកបុគ្គលមានចក្ខុ រមែងឃើញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ រមែងជាប់នៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ជាអ្នករីករាយក្នុងភព ត្រេកអរក្នុងភព ស្រើបស្រាលក្នុងភព កាលតថាគតសម្តែងធម៌ ដើម្បីរម្ងត់ភព ចិត្តរបស់ទេវតា និងមនុស្សទាំងឡាយនោះ ក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនចុះស៊ប់ ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយពួក ១ រមែងជាប់នៅយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ពួក ១ រមែងស្ទុះទៅ តើដូចម្តេច ។ ទេវតា និងមនុស្សទាំងឡាយពួក ១ កាលជិនធុទន់ នឿយណាយ ស្អប់ខ្ពើមភព រមែង

ត្រេកអរចំពោះការប្រាសចាកភពថា ម្នាលអ្នកដ៏ចម្រើន បានឮថា អត្តភាពនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងដាច់សូន្យ វិនាសទៅ មិនកើតទៅក្នុងខាងមុខទៀត ព្រោះហេតុណា នេះជាធម្មជាតស្ងប់រម្ងាប់ នេះជាធម្មជាតដ៏ឧត្តម នេះជាធម្មជាតដ៏ពិត ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ពួក ១ រមែងស្ទុះទៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះចំណែកបុគ្គលអ្នកមានចក្ខុ រមែងឃើញ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិត លុះឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈពិតហើយ ជាអ្នកប្រតិបត្តិ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងត់នូវខន្ធបញ្ចកៈ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលមានចក្ខុ រមែងឃើញយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អរិយសាវកណា ឃើញនូវខន្ធបញ្ចកៈ ដោយសភាវៈ
ពិតផង នូវការប្រព្រឹត្តកន្លងខន្ធបញ្ចកៈផង រមែងចុះ
ចិត្តស៊ប់ ក្នុងព្រះនិព្វាន ដោយសភាវៈពិត ព្រោះអស់
តណ្ហាក្នុងភព ប្រសិនបើអរិយសាវកនោះ កំណត់
ដឹងនូវខន្ធបញ្ចកៈ ប្រាសចាកតណ្ហាក្នុងភពតូច ភពធំ
ហើយ ភិក្ខុទាំងឡាយ សូន្យចាកខន្ធបញ្ចកៈហើយ
រមែងមិនបានមកកាន់ភពថ្មីទៀត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ១២ ។

## ទុតិយវគ្គ ចប់

## ឧទ្ទាននៃទុតិយវគ្គនោះ គឺ

និយាយអំពីឥន្ទ្រិយមានពីរលើក តបនិយធម៌មានពីរ
លើក សីល និងរឿងដទៃទៀតមានពីរលើក អំពីមិន
មានឱត្តប្បៈ ១ រឿងកុហកមានពីរលើក សំវេជនីយ
១ ត្រូវជា ១០ អំពីវិតក្ក ១ ទេសនា ១ វិជ្ជា ១
បញ្ញា ១ និងធម៌ ១ ត្រូវជា ៥ អំពីអជាតធម៌ ១ ធាតុ
១ ទីសម្ងំ ១ សិក្ខា ១ ជាគរិយធម៌ ១ អបាយ ១
ទិដ្ឋិ ១ ត្រូវជា ២២ ដែលលោកបានប្រកាសទុកហើយ ។

## ទុកនិបាត ចប់

# អដ្ឋកថា

## ទិដ្ឋិសូត្រ

ក្នុងទិដ្ឋិសូត្រទី ១២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៤៩ ] បទថា **ទ្វីហិ ទិដ្ឋិគតេហិ** នេះ ទិដ្ឋិគតៈ ក៏គឺទិដ្ឋិនោះឯង ដូចក្នុងបទជាដើមថា **គូថគតំ មុត្តគតំ** គឺលាមក និងមូត្រ ដូច្នេះ ។ ទិដ្ឋិទាំងឡាយ ដែលមានឋានៈជាទិដ្ឋិ ព្រោះត្រឹមតែដល់ទិដ្ឋិ ដោយប្រការដែលទទេចាកការកាន់យក ដោយទិដ្ឋិទាំងនោះ ។ បទថា **បរិយុដ្ឋិតា** បានដល់គ្របសង្កត់ ឬពាក់ព័ន្ធ ។ សព្ទថា **បរិយុដ្ឋាន** មានអត្ថថា ពាក់ព័ន្ធ ដូចក្នុងបទជាដើមថា **ចោរា មគ្គេ បរិយុដ្ឋឹសុ** ពួកចោរពួនស្កាត់ត្រង់ផ្លូវ ដូច្នេះ ។ បទថា **ទេវ** បានដល់ ឧបបត្តិទេវៈ ។ ឯឧបបត្តិទេពទាំងនោះ លោកហៅថា **ទេវ** ព្រោះលេង គឺលេងដោយកាមគុណដ៏ក្រៃលែង និងឧត្តម និងដោយឈានជាដើម ឬដល់ គឺសម្រេចប្រយោជន៍ដែលខ្លួនប្រាថ្នា ដោយអានុភាពនៃឫទ្ធិ ឈ្មោះថា **មនុស្សា** ព្រោះជាអ្នកមានចិត្តខ្ពស់ ។ ម្យ៉ាងទៀត បទនេះលោកពោលដោយការចង្អុលបង្ហាញដោយកំពូលដ៏ក្រៃលែងថា សព្ទថា **ទេវ-មនុស្សានំ** ជាសាស្តារបស់ទេវតា និងមនុស្សទាំងឡាយ ។ បទថា **ឱលិយន្តិ ឯកេ** សេចក្តីថា ទេវតា និងមនុស្សពួកខ្លះ រមែងពាក់ព័ន្ធ រមែងជាប់ រមែងដល់នូវការស្ញុបស្ញៅ តែងមិនចេញទៅអំពីនោះ ដោយការឃើញថាទៀងដែលជាការជាប់ និងការប្រកាន់មាំក្នុងភពទាំងឡាយថា **សស្សតោ អត្តា ច លោកោ ច** ខ្លួន និងលោកទៀង ដូច្នេះ ។ បទថា **អតិធាវន្តិ** សេចក្តីថា

មិនដល់នូវការសម្ពន្ធ ដោយភាពជាហេតុផលរបស់សភាវធម៌ សូម្បីមានសភាវៈទម្លាយទៅ ដោយបរមត្ថ ព្រោះស្ទុះទៅក្នុងភពនោះៗ ដោយការកាន់យកន័យដែលជាសេចក្ដីផ្សេងគ្នា ព្រោះដូច្នោះ រមែងស្ទុះទៅ គឺឈានកន្លងនូវភាពជាធម៌ ក្នុងការទាក់ទងបដិបត្តិដើម្បីរម្ងាត់ភព ក្នុងភាពសូន្យថា **ឧច្ឆិជ្ជតិ អត្តា ច លោកោ ច ន ហោតិ បរម្មរណា** ខ្លួន និងលោករមែងដាច់សូន្យខាងមុខអំពីស្លាប់ រមែងមិនមាន ។ ច សព្ទ ក្នុងបទថា **ចក្ខុមន្តោ ច បស្សន្តិ** ចុះក្នុងអត្ថជំទាស់គ្នា ឯទេវតា និងមនុស្ស ជាអ្នកមានបញ្ញាចក្ខុ ដោយការចាស់ក្លារបស់ញាណនៃការដល់ព្រម ដោយការប្រកបខាងដើម មិនអាស្រ័យអន្តធម៌ទាំង ២ គឺសស្សតៈ និងឧច្ឆេទៈ ដោយបញ្ញាចក្ខុនោះឯង ធ្វើឲ្យប្រចក្សដោយការឃើញបដិបត្តិជាកណ្ដាល ។ ពិតហើយ ទេវតា និងមនុស្សទាំងនោះ រមែងឃើញដោយមិនខុសថា ធម្មជាតនេះ អាស្រ័យត្រឹមនាមរូបកើតឡើង ព្រោះដូច្នោះ ទៀងក៏មិនមែន ដាច់សូន្យក៏មិនមែន ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **កថញ្ច ភិក្ខវេ** ដូច្នេះ ។ ដើម្បីទ្រង់សម្ដែងដល់ការជាប់ជាដើម ដោយបុគ្គលាធិដ្ឋាន ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភវា** បានដល់ កាមភព រូបភព អរូបភព ។ នៅមានភព ៣ ដទៃទៀត គឺសញ្ញីភព អសញ្ញីភព នេវសញ្ញីនាសញ្ញីភព ។ នៅមានភព ៣ ដទៃទៀត គឺឯកវោការភព ចតុវោការភព បញ្ចវោការភព ។ ឈ្មោះថា **ភវារាមា** ព្រោះត្រេកអរពេញចិត្តដោយភពទាំងនោះ ។ ឈ្មោះថា **ភវរតា** ព្រោះត្រេកអរ គឺត្រេកអរក្រៃលែងក្នុងភពទាំងឡាយ ។ ឈ្មោះ

ថា **ភវសម្មុទិតា** ព្រោះត្រេកអរក្នុងភពទាំងឡាយ ។ បទថា **ភវនិរោធាយ** បានដល់ ដើម្បីរម្ងត់ភពទាំងនោះក្នុងទីបំផុត គឺដើម្បីមិនឲ្យកើតតទៅ ។ បទថា **ធម្មេ ទេសិយមានេ** បានដល់ កាលនិយ្យានិកធម៌ ដែលព្រះតថាគតទ្រង់ប្រកាសហើយ គឺទ្រង់ប្រាប់ ។ បទថា **ន បក្ខន្ទតិ** បានដល់ ចិត្តមិនចូលទៅ គឺមិនឈមចុះ ព្រោះមានការរួញរាជាធម្មតា ព្រោះប្រកាន់មាំក្នុងភាពជារបស់ទៀង ។ បទថា **ន បសីទតិ** បានដល់ មិនដល់នូវការជ្រះថ្លា គឺមិនជឿធម៌នោះ ។ បទថា **ន សន្តិដ្ឋតិ** បានដល់ ចិត្តមិនតាំងនៅ គឺមិនតាំងនៅ បានដល់ មិនបង្អោនទៅក្នុងទេសនានោះ ។ ទេវតានិងមនុស្សទាំង-ឡាយ រមែងជាប់នៅក្នុងភព ដោយការប្រកាន់មាំ ក្នុងភាពជារបស់ទៀងដោយអាការយ៉ាងនេះ ។ បទថា **អដ្ដិយមានា** សេចក្ដីថា ព្រោះទេវតា និងមនុស្សទាំងឡាយឃើញជរា រោគ និងមរណៈជាដើម និងការសម្លាប់ ការចង ការកាត់ជាដើម ហើយត្រូវសេចក្ដីទុក្ខទាំងនោះបៀតបៀន ដោយភពគឺមានព្រម ជាបុគ្គលដែលត្រូវទុក្ខទាំងនោះឲ្យលំបាក ។ បទថា **ហរាយមានា** គឺ **លជ្ជមានា** បានដល់ ខ្មាស ។ បទថា **ជិគុច្ឆមានា** បានដល់ តាំងនៅដោយភាពជារបស់បដិកូល ។ បទថា **វិភវំ** គឺ **ឧច្ឆេទំ** បានដល់ ដាច់សូន្យ ។ បទថា **អភិនន្ទន្តិ** បានដល់ រមែងត្រេកអរ ដោយការត្រេកអរក្នុងតណ្ហានិងទិដ្ឋិ ។ បទថា **យតោ កិរ ភោ** ជាដើម សម្ដែងដល់ការត្រេកអររបស់ទេវតា និងមនុស្សទាំងនោះ ។

ក្នុងបទទាំងនោះ បទថា **យតោ** គឺ **យទា** ប្រែថា កាលណា ។ បទថា

**ភោ** ជាអាលបនៈ គឺពាក្យសម្រាប់ហៅ ។ បទថា **អយំ អន្តោ** ព្រះមានព្រះភាគត្រាស់ដល់វត្ថុ ដែលព្រះអដ្ឋកំណត់ដោយភាពជាគោលជាដើម ។ បទថា **ឧច្ចិជ្ជតិ** គឺ **ឧបច្ឆិជ្ជតិ** ប្រែថា ដាច់សូន្យ ។ បទថា **វិនស្សតិ** បានដល់មិនប្រាកដ ដល់នូវការវិនាស គឺការមិនមាន ។ បទថា **ន ហោតិ បរម្មរណា** បានដល់ ស្លាប់ហើយ រមែងមិនកើតទៀត ។ បទថា **ឯតំ សន្តំ** បានដល់ ការដាច់សូន្យជាដើមរបស់បុគ្គលនេះ ឈ្មោះថា **សន្តំ** ព្រោះស្ងប់ចាកអារម្មណ៍ទាំងពួង និងព្រោះស្ងប់ចាកការក្តៅក្រហាយទាំងពួង ឈ្មោះថា **បណីតំ** ព្រោះភាពជារបស់ល្អិត ឈ្មោះថា **យាថាវំ** ព្រោះមិនខុសការពិត ។ ក្នុងបទទាំងនោះ ទេវតា និងមនុស្សពោលបទទាំង ២ នេះថា **សន្តំ បណីតំ** ដោយការត្រេកអរក្រៃលែងក្នុងតណ្ហា ។ ពោលបទថា **យាថាវំ** ដោយការត្រេកអរក្រៃលែងក្នុងទិដ្ឋិ ។ បទថា **ឯវំ** បានដល់ ប្រកាន់មាំក្នុងការដាច់សូន្យតាមដែលពោលហើយយ៉ាងនេះ ។ បទថា **ភូតំ** បានដល់ ខន្ធបញ្ចកៈ ។ ខន្ធបញ្ចកៈនោះ លោកពោលថា **ភូតំ** ព្រោះកើតដោយបច្ច័យ និងមានដោយបរមត្ថ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ភូតមិទំ ភិក្ខវេ សមនុបស្សថ** ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ពិចារណាខន្ធបញ្ចកៈនេះ ។ ភិក្ខុរមែងឃើញដោយសេចក្តីពិត ដោយមិនវិបរិត ដោយមានលក្ខណៈ និងដោយសាមញ្ញលក្ខណៈ ព្រោះខន្ធបញ្ចកៈនេះត្រឹមតែជានាមរូប អធិប្បាយថា ភិក្ខុរមែងឃើញខន្ធបញ្ចកៈនេះត្រឹមតែជានាមរូប ដោយការឃើញនាមរូបព្រមដោយបច្ច័យយ៉ាងនេះ ក្នុងនាមរូបនោះថា ធម៌ទាំងឡាយ មានបឋវីធាតុ

*ជាដើមនេះជារូប ធម៌ទាំងឡាយ មានផស្សៈជាដើមនេះ ជានាម ខន្ធបញ្ចកៈទាំងនេះ ជាលក្ខណៈជាដើមរបស់នាមរូបទាំងនោះ អវិជ្ជាជាដើមនេះ ជាបច្ច័យនៃនាមរូបទាំងនោះ និងដោយអនិច្ចានុបស្សនាជាដើមយ៉ាងនេះថា ធម៌ទាំងនេះ មិនមានហើយ ក៏កើតមាន មានហើយ ក៏វិនាស ព្រោះដូច្នោះ ទើបធម៌ទាំងឡាយមិនទៀង ព្រោះមិនទៀង ទើបជាទុក្ខ ព្រោះជាទុក្ខ ទើបជាអនត្តាដូច្នេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់សម្តែងវិបស្សនា-ភូមិ ដែលមានតរុណវិបស្សនាជាទីបំផុត ។*

*បទថា* **និព្វិទាយ** *បានដល់ ដើម្បីការនឿយណាយ ធម្មជាតដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលបានដល់ខន្ធបញ្ចកៈ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងពលវិបស្សនា គឺវិបស្សនាដ៏មានកម្លាំងដោយបទនេះ ។ បទថា* **វិរាគាយ** *បានដល់ ដើម្បីវិរាគៈ គឺដើម្បីប្រាសចាកតម្រេក ។ ដោយបទនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់មគ្គ ។ បទថា* **និរោធាយ** *បានដល់ដើម្បីរលត់ ។ ដោយបទនេះ ទ្រង់សម្តែងដល់មគ្គដូចគ្នា ។ម្យ៉ាងទៀត បទថា* **និរោធាយ** *ទ្រង់សម្តែងដល់ឧបាទិសេសនិព្វាន ព្រមដោយបដិ-បស្សទ្ធិនិរោធ ។ បទថា* **ឯវំ ចក្ខុមន្តោ បស្សន្តិ** *បានដល់ បុគ្គលមានបញ្ញាចក្ខុ រមែងឃើញចតុសច្ចធម៌ដោយចក្ខុ គឺមគ្គប្បញ្ញា ដោយចំណែកដែលមានខាងដើមយ៉ាងនេះ ។*

*ក្នុងគាថាទាំងឡាយ គប្បីជ្រាបអធិប្បាយដូចតទៅនេះ បទថា* **យោ ភូតំ ភូតតោ ទិស្វា** *សេចក្តីថា ព្រះអរិយសាវកណា ឃើញខន្ធបញ្ចកៈដែល*

កើតហើយដោយសេចក្តីពិត គឺដោយភាពដែលមិនវិបរិត ដោយមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា ដោយបទនេះ ទ្រង់សម្តែងដល់បរិញ្ញាកិ-សម័យ ។ បទថា **ភូតស្ស ច អតិក្កមំ** បានដល់ ភាវនាកិសម័យ គឺការត្រាស់ដឹងដោយភាវនា ។

ពិតហើយ អរិយមគ្គ លោកពោលថា ឈានកន្លងនូវខន្ធបញ្ចកៈ ព្រោះជាហេតុឈានកន្លងនូវខន្ធ ៥ ។ បទថា **យថាភូតេ** បានដល់ បង្អោនទៅ ទោរទន់ទៅក្នុងនិព្វាន ដែលមានសភាវៈជាសច្ចធម៌ មិនវិបរិត ។ ដោយបទនេះ ទ្រង់សម្តែងដល់សច្ឆិកិរិយាកិសម័យ ។ បទថា **ភវតណ្ហា បរិក្ខយា** បានដល់ ព្រោះអស់ទៅ គឺព្រោះកាត់ផ្តាច់នូវភវតណ្ហាដោយប្រការទាំងពួង ។ ដោយបទនេះ ទ្រង់សម្តែងដល់សមុទយប្បហាន ។ បទថា **សចេ** ក្នុងបទថា **សចេ ភូតំ បរិញ្ញោ សោ** នេះ ត្រឹមតែជានិបាត អធិប្បាយថា បើអរិយ-សាវកនោះកំណត់ដឹងខន្ធបញ្ចកៈដែលកើតហើយ គឺកំណត់ដឹងខន្ធ ព្រោះអស់ភវតណ្ហា ដោយមគ្គដែលជាឧបាយ ឈានកន្លងខន្ធបញ្ចកៈ បន្ទាប់អំពីនោះក៏បង្អោនទៅក្នុងនិព្វានតាមសេចក្តីពិត ។ បទថា **ភវាភវេ** សេចក្តីថា ភិក្ខុប្រាសចាកតណ្ហា គឺទម្លាយនូវកិលេសបានហើយ ក្នុងភពតូច និងភពធំ ឬព្រោះការឃើញនូវការដាច់សូន្យជាដើម រមែងមិនមកកាន់ភពថ្មី គឺដល់នូវភាពជាបុគ្គលមិនមានបញ្ញត្តិនោះឯង ព្រោះការមិនកើតតទៅ គឺមិនកើតតទៅនៃអត្តភាព ដែលបានដល់ឧបាទានក្ខន្ធដែលកើតហើយ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយអនុបាទិសេសនិព្វានធាតុ ។

ទ្រង់ត្រាស់ដល់វដ្តៈក្នុងសូត្រទី ១១ ក្នុងវគ្គនេះ ត្រាស់ដល់វដ្តៈ និងវិវដ្តៈ ក្នុងសូត្រទី ៣ ទី ៤ ទី ៥ និងក្នុងសូត្រចុងក្រោយ ដោយប្រការដូច្នេះ ។ សូម្បីក្នុងសូត្រដ៏សេស គប្បីជ្រាបថា ជាវិវដ្តៈតែម្យ៉ាង ៕

## អដ្ឋកថា និដ្ឋិសូត្រទី ១២ ចប់

## អដ្ឋកថា ឥតិវុត្តក ខុកនិបាត ចប់

# សុត្តន្តបិដក

## ឥតិវុត្តក តិកនិបាត បឋមវគ្គ

### អកុសលមូលសូត្រ

[ ៥០ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលនេះ មាន ៣ ។ អកុសលមូល ៣ តើដូចម្តេច ។ គឺលោភៈ ជាអកុសលមូល ១ ទោសៈ ជាអកុសលមូល ១ មោហៈ ជាអកុសលមូល ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

លោភៈ ទោសៈ មោហៈ ដែលកើតអំពីខ្លួន តែង
បៀតបៀននូវបុរសមានចិត្តលាមក ដូចជាផ្លែឫស្សី
តែងបៀតបៀននូវដើមរបស់វា ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

# ឥតិវុត្តក តិកនិបាត វគ្គទី ១

## អកុសលមូលសូត្រ

[ ៥០ ] ក្នុងអកុសលមូលសូត្រទី ១ នៃតិកនិបាត គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **តីណិ** ជាការកំណត់រាប់ចំនួន ។ បទថា **ឥមានិ** ជាពាក្យចង្អុលបង្ហាញដល់ទីនៅចំពោះមុខ ។ បទថា **អកុសលមូលានិ** ជាតួយ៉ាងនៃធម៌ដែលទ្រង់កំណត់ ។ បទថា **អកុសលមូលានិ** នោះ មានអធិប្បាយដូចតទៅនេះថា កិលេសជាត ឈ្មោះថា ជាអកុសលមូល ព្រោះជាអកុសលផង ជាមូលនៃអកុសលផង ។ម្យ៉ាងទៀត ឈ្មោះថា ជាអកុសលមូល ព្រោះជាឫសគល់នៃអកុសលទាំងឡាយ ដោយអត្ថថា ជាហេតុ ជាបច្ច័យ ជាបភវៈ គឺជាដែនកើតមុន ជាជនកៈ គឺអ្នកឲ្យកំណើត ជាសមុដ្ឋាបកៈ គឺជាអ្នកស្ថាបនា ជានិព្វត្តកៈ គឺជាអ្នកឲ្យកើតនៃអកុសលធម៌ទាំងឡាយ អធិប្បាយថា ជាករណៈ ( ហេតុ ) នៃអកុសលធម៌ទាំងឡាយ ។ ព្រោះថា ការណៈ លោកហៅថា ហេតុ ព្រោះជាដែន ប្រព្រឹត្តទៅនៃផល ហៅថា បច្ច័យ ព្រោះជាហេតុឲ្យកើតផលអាស្រ័យ ប្រព្រឹត្តទៅ ហៅថា បភវៈ ព្រោះជាដែនកើតមុននៃផល ហៅថា ជនកៈ ព្រោះញ៉ាំងផលរបស់ខ្លួនឲ្យកើត ហៅថា សមុដ្ឋាបកៈ ព្រោះឲ្យនូវផ្លែផ្កា និងហៅថា និព្វត្តៈ ព្រោះញ៉ាំងផលឲ្យកើតឡើង យ៉ាងណា កិលេសជាត មានលោភៈជាដើម ឈ្មោះថា ជាឫសគល់ ព្រោះអត្ថថា ជាទីតាំងនៃអកុសលទាំងឡាយក៏ដូច្នោះ

ព្រោះដូច្នោះ ទើបមានអធិប្បាយថា បទថា **អកុសលមូលានិ** សេចក្តីថា ជាហេតុឲ្យអកុសលធម៌ទាំងឡាយសម្រេចភាពជាធម៌ ដែលសម្បូរហើយ ។

ឯអាចារ្យពួកខ្លះពោលថា សេចក្តីលោភ ដែលឲ្យអកុសលទាំងឡាយសម្រេចភាពជាអកុសល ជាមូលនៃអកុសលទាំងឡាយ មានលោភៈជាដើម ដូចពូជនៃស្រូវសាលីជាដើម ជាមូលនៃស្រូវសាលីជាដើម និងដូចទឹកថ្នាំនៃកែវមណីជាដើម ជាមូលនៃពន្លឺរបស់អញ្ញមណីជាដើមដូច្នោះ កាលបើដូច្នោះ ក្នុងរូបដែលមានអកុសលចិត្តជាសមុដ្ឋាន មិនគប្បីមានភាពដែលអកុសលធម៌ទាំងនោះជាហេតុ ជាបច្ច័យ ព្រោះថា រូបដែលមានអកុសលចិត្តជាសមុដ្ឋាននោះ ឲ្យសម្រេចភាពជាអកុសលធម៌ដល់វាមិនបាន តែមិនមែនជាបច្ច័យមិនបាន ដូចព្រះតម្រាស់ដែលត្រាស់ក្នុងបដ្ឋានថា ( ពាក្យថា ហេតុប្បច្ច័យ ) បានដល់ហេតុជាបច្ច័យនៃពួកធម៌ ដែលប្រកបដោយហេតុផង នៃពួករូបដែលតាំងឡើងអំពីធម៌នោះផង ដោយហេតុប្បច្ច័យ ។

ការដែលមានលោភៈជាអកុសល មិនគប្បីមានដល់អហេតុកសត្វ ព្រោះមិនមានឫសគល់ដទៃ ដែលឲ្យសម្រេចភាពជាអកុសល ។ ម្យ៉ាងទៀត ភាពដែលធម៌ទាំងឡាយ មានលោភៈជាដើម ជាអកុសលជាដើមសម្រេចហើយដោយសភាវៈគប្បីមាន តែភាពដែលធម៌ទាំងឡាយ ដែលសម្បយុត្តដោយលោភៈជាដើមនោះជាអកុសលជាដើម ជាធម៌ទាក់ទងដោយលោភៈជាដើមគប្បីមានដូច្នេះ កាលបើដូច្នោះ ការដែលអកុសលធម៌ទាំងឡាយ មានអលោភៈជាដើមជាកុសលសម្រេចបានដោយសភាវៈ ដូចភាពដែលលោភៈជាដើមជា

អកុសល សម្រេចបានដោយសភាវៈនោះ ដូច្នោះ អលោភៈជាដើម គប្បីជាកុសលតែម្យ៉ាង មិនជាអព្យាកតៈផង មិនមានផង ព្រោះដូច្នោះ អ្នកសិក្សាគួរស្វែងរកសភាវៈរបស់កុសលធម៌ជាដើម សូម្បីក្នុងមូលទាំងឡាយ ដូចក្នុងសម្បយុត្តធម៌ទាំងឡាយ ។ បណ្ឌិតគប្បីកាន់យកមូលថាជាហេតុ ដូចយោនិសោមនិសការជាដើម ជាហេតុនៃភាពជាកុសល និងដូចអយោនិសោមនសិការជាដើម ជាហេតុនៃភាពជាអកុសល កាលមិនកាន់យកមូលនៃភាពជាលោភៈជាដើម ដោយអំណាចនៃការញុំាងភាពជាអកុសលឲ្យសម្រេច ហើយកាន់យកដោយអំណាចនៃការញុំាងភាពជាធម៌ ដែលប្រតិស្ឋានយ៉ាងល្អហើយ ឲ្យសម្រេចយ៉ាងនេះ ក៏មិនមានទោសអ្វីឡើយ ព្រោះថា ធម៌ទាំងឡាយដែលបានហេតុ និងបច្ច័យហើយ នឹងប្រតិស្ឋានមាំទាំ ដូចដើមឈើដែលមានឫសគល់ធំវិសាល ឯធម៌ដែលវៀរចាកហេតុ នឹងមិនប្រតិស្ឋានមាំទាំ ដូចដើមល្ង និងសារាយជាដើម ព្រោះដូច្នោះ កិលេសទាំង ៣ យ៉ាងទើបឈ្មោះថា ជាអកុសលមូល ព្រោះជាមូលដែលជាឧបការៈដល់អកុសលធម៌ទាំងឡាយ ដោយសំដៅដល់ហេតុជាដើម ។ តែព្រោះហេតុដែលចិត្តុប្បាទជាអកុសល ដែលផុតចាកកិលេសដែលជាឫសគល់ រមែងមិនមាន ដូច្នោះ គប្បីជ្រាបថា ដោយកិលេសដែលជាមូលទាំង ៣ ទ្រង់សំដែងគ្រប ដណ្ដប់គំនរអកុសលទាំងអស់ ។

ដើម្បីទ្រង់សំដែងអកុសលមូលទាំងនោះដោយសរុប ទើបត្រាស់ពាក្យជាដើមថា **លោភោ អកុសលមូលំ** ដូច្នេះ ។ បណ្ដាពាក្យទាំងនោះ ពាក្យ

ដែលត្រូវពោលក្នុងលោកៈជាដើម ខ្ញុំបានពោលហើយខាងដើមនោះឯង ក្នុងវគ្គនោះ សេចក្តីលោកជាដើម ដែលមគ្គទី ៣ គប្បីលះ មានមកហើយ តែក្នុងព្រះសូត្រនេះ សេចក្តីលោកជាដើម មិនមានសេសសល់ឡើយ នេះឯង ជាការប្លែកផ្សេងគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថាដូចតទៅនេះ បទថា **បាបចេតសំ** បានដល់ ចិត្តលាមក ព្រោះប្រកបដោយអកុសលធម៌ ។ បទថា **ហឹសន្តិ** សេចក្តីថា រមែងបៀតបៀនក្នុងខណៈនៃការប្រព្រឹត្តទៅរបស់ខ្លួន និងក្នុងខណៈនៃវិបាកក្នុងអនាគត ។ បទថា **អត្តសម្ភូតា** សេចក្តីថា កើតហើយក្នុងខ្លួន ។ បទថា **តចសារំ** បានដល់ មិនមានបទ្ទា អធិប្បាយថា ដើមឫស្សី ។ បទថា **សម្ផលំ** បានដល់ ផ្លែរបស់ខ្លួន មានអធិប្បាយថា មិនកើតមានខ្លឹមខាងក្នុង ដូចជាដើមគគីរ និងដើមធ្នង់ជាដើម សូម្បីដើមឫស្សីជាដើម ដែលបានឈ្មោះថា **តចសារៈ** ព្រោះមានខ្លឹមខាងក្រៅ គឺសេចក្តីលោភជាដើមដែលកើតក្នុងខ្លួនឯង និងញ៉ាំងបុគ្គលដែលមានចិត្តលាមក ប្រាសចាកខ្លឹម គឺសីលខាងក្នុងឲ្យវិនាសទៅ ដូចផ្លែឫស្សីដែលកើតត្រង់ដើមនោះឯង រមែងបៀតបៀន គឺឲ្យដើមឫស្សីវិនាសទៅ ដូច្នោះ ។៚

**អដ្ឋកថាអកុសលមូលសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ធាតុសូត្រ

[ ៥១ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធាតុនេះ មាន ៣ ។ ធាតុ ៣ តើដូចម្តេច ។ គឺរូបធាតុ ១ អរូបធាតុ ១ និរោធធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធាតុមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនទាំងឡាយណា កំណត់ដឹងក្នុងរូបធាតុ មិនតាំងនៅ
ក្នុងអរូបធាតុ ចុះចិត្តស៊ប់ក្នុងនិរោធ ជនទាំងនោះ ឈ្មោះ
ថា ញុំាងមច្ចុឲ្យសាបសូន្យ ។ ព្រះសម្មាសម្ពុទ្ធដែល
មិនមានអាសវៈ បានពាល់ត្រូវនូវអមតធាតុ ដែលមិន
មានឧបធិ ដោយនាមកាយ ធ្វើឲ្យជាក់ច្បាស់ នូវព្រះ
និព្វាន ដែលជាទីលះបង់ឧបធិ ទ្រង់សម្តែងព្រះនិព្វាន
ដែលមិនមានសោក មិនមានតម្រេក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ធាតុសូត្រ

[ ៥១ ] ក្នុងធាតុសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ធាតុយោ** សេចក្ដីថា ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់នូវផល និងសភាវៈរបស់ខ្លួន ព្រោះថា បណ្ដាផល និងសភាវៈទាំង ២ យ៉ាងនេះ វត្ថុដែលឲ្យកើតឲ្យផល ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់នូវផលរបស់ខ្លួន និងសភាវៈរបស់ខ្លួន ក្រៅអំពីនេះ ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់ចំពោះសភាវៈតែម្យ៉ាង ។ **រូបភព** ឈ្មោះថា **រូបធាតុ** ។ ទីមករបស់ធាតុ គប្បីកំណត់ដោយភព ទីមករបស់ភព គប្បីកំណត់ដោយធាតុ ដូច្នោះ ទើបក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ការកំណត់ដោយភព ព្រោះដូច្នោះ រូបធាតុ គឺរូបាវចរធម៌ដែលព្រះមានព្រះភាគត្រាស់ក្នុងធម្មសង្គណិយ៉ាងនេះថា

ពួកធម៌ជារូបាវចរ តើដូចម្ដេច ។ ខាងក្រោម កំណត់យកព្រហ្មលោកជាទីបំផុត ខាងលើ កំណត់យកអកនិដ្ឋទេវលោកជាទីបំផុត ទីណាដែលមានក្នុងចន្លោះនេះ ធម៌ គឺចិត្ត និងចេតសិក ដែលត្រាច់ទៅក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនុ៎ះ នៃបុគ្គលអ្នកចូល ( កាន់សមាបត្តិ ) ឬបុគ្គលដែលកើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន នេះពួកធម៌ជារូបាវចរ ។ **អរូបភព** ឈ្មោះថា **អរូបធាតុ** ទោះបីក្នុងព្រះសូត្រនេះ ក៏ត្រាស់ដល់ការកំណត់ដោយភព ដូច្នោះ អរូបធាតុ គឺអរូបាវចរធម៌ ដែលព្រះមានព្រះភាគត្រាស់ក្នុងធម្មសង្គណិយ៉ាងនេះថា ពួកធម៌ជាអរូបាវចរ តើដូចម្ដេច ។ ខាងក្រោម កំណត់

*យកពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនភពជាទីបំផុត ខាងលើ កំណត់យកទេវតាដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនភពជាទីបំផុត ទីណា ដែលមានក្នុងចន្លោះនេះ ធម៌ គឺចិត្ត និងចេតសិក ត្រាច់ចុះក្នុងទីនុ៎ះ រាប់ បញ្ចូលក្នុងទីនុ៎ះ នៃបុគ្គលអ្នកចូល ( កាន់សមាបត្តិ ) ឬបុគ្គលដែលទៅ កើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន នេះពួកធម៌ជាអរូបាវចរ ។ ព្រះនិព្វាន គប្បីជ្រាបថា ឈ្មោះថាជា* **និរោធធាតុ** *។*

*ម្យ៉ាងទៀត ការប្រព្រឹត្តទៅនៃធម៌ដែលប្រកបដោយរូប គឺទាក់ទងដោយ រូប ឈ្មោះថា* **រូបធាតុ** *បានដល់ បញ្ចវោការភព និងឯកវោការភព ។ កាម- ភព និងរូបភពទាំងមូល សង្គ្រោះចូលជាមួយបញ្ចវោការភព និងឯកវោការ- ភពនោះ ការប្រព្រឹត្តទៅនៃធម៌ដែលវៀរចាករូប ឈ្មោះថា* **អរូបធាតុ** *បាន ដល់ ចតុវោការភព ។ អរូបភព សង្គ្រោះចូលជាមួយអរូបធាតុនោះ ដូច្នោះ ទើបដោយបទទាំង ២ ទ្រង់សម្តែងដល់ភព ៣ ដែលប្រព្រឹត្តទៅក្នុងសង្សារទាំង អស់ តែដោយបទទី ៣ ទ្រង់សង្គ្រោះអសង្ខតធម៌ប៉ុណ្ណោះ ដូច្នោះ ក្នុងសូត្រ នេះ មគ្គ និងផលទាំងឡាយ ឈ្មោះថា ជាធម៌ដែលផុតចាកភព ៣ តែ អាចារ្យពួកខ្លះពោលថា ដោយបទទាំង ២ ធម៌ដែលជាសភាវៈនៃរូប ឈ្មោះ ថា* **រូបធាតុ** *ធម៌ដែលជាសភាវៈនៃអរូប ឈ្មោះថា* **អរូបធាតុ** *ដូច្នេះ ព្រះ មានព្រះភាគ ទ្រង់សម្តែងដល់បញ្ចក្ខន្ធដោយមិនមានចំណែកសល់ និងថា ធម៌ដែលជាអារម្មណ៍របស់រូបតណ្ហា ឈ្មោះថា* **រូបធាតុ** *ដែលជាអារម្មណ៍ របស់អរូបតណ្ហា ឈ្មោះថា* **អរូបធាតុ** *។ ពាក្យទាំងអស់នោះ ទ្រង់មិនបាន*

បំណាងយកក្នុងសូត្រនេះឡើយ ព្រោះដូច្នោះ គប្បីជ្រាបអត្ថតាមន័យដែលពោលមកហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **រូបធាតុំ បរិញ្ញាយ** សេចក្តីថា កំណត់ដឹងនូវការប្រព្រឹត្តទៅនៃធម៌ ដែលទាក់ទងដោយរូប ដោយបរិញ្ញា ៣ មានញាតបរិញ្ញាជាដើម ។ បទថា **អរូបេសុ អសណ្ឋិតា** សេចក្តីថា មិនប្រតិស្ឋានហើយ គឺមិនពាក់ព័ន្ធក្នុងធម៌ទាំងឡាយ ដែលជាអរូបាវចរ ដោយអំណាចតវរាគៈ និងដោយអំណាចតវទិដ្ឋិ ។ ភិក្ខុទាំងឡាយសូធ្យថា **អរូបេសុ អសណ្ឋិតា** ដូច្នេះក៏មាន ឯសេចក្តីក៏យ៉ាងនោះដូចគ្នា ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគត្រាស់ការកំណត់ដឹងនូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **និរោធេ យេ វិមុច្ចន្តិ** សេចក្តីថា អ្នកជាព្រះខីណាស្រពពួកណា ធ្លងផុតចាកកិលេស ដោយមិនមានសេសសល់ក្នុងព្រះនិព្វាន ដែលជាអារម្មណ៍ដោយសមុច្ឆេទ ( វិមុត្តិ ) និងបដិបស្សទ្ធិ ( វិមុត្តិ ) ដោយអំណាចនៃមគ្គផលថ្នាក់ខ្ពស់ ។ បទថា **តេ ជនា មច្ចុហាយិនោ** សេចក្តីថា បុគ្គលជាព្រះខីណាស្រពទាំងនោះ កន្លងផុតសេចក្តីស្លាប់បានហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចអមតធម៌ ដោយការឈានកន្លងធាតុទាំង ៣ យ៉ាងនេះហើយ កាលនឹងញ៉ាំងឧស្សាហ៍ ក្នុងការបានសម្រេចអមតធម៌នោះ ឲ្យកើតដល់ជនទាំងនោះថា បដិបទានេះផង ផ្លូវដែលតថាគតដើរទៅហើយផង តថាគតសម្តែងហើយ ដល់អ្នកទាំងឡាយ

ដូច្នេះ ទើបត្រាស់គាថាទី ២ បន្ត ។

បណ្ដាបទទាំងនោះ បទថា **កាយេន** សេចក្ដីថា ដោយនាមកាយ ឬ ដោយមគ្គ និងផលទាំងឡាយ ។ បទថា **ផុស្សយិត្វា** ប្រែថា សម្រេចហើយ ។ បទថា **និរុបធឹ** សេចក្ដីថា វៀរចាកឧបធិគ្រប់យ៉ាង មានខន្ធូបធិជាដើម ។ បទថា **ឧបធិប្បដិនិស្សគ្គំ** បានដល់ ហេតុជាគ្រឿងលះបង់ គឺឧបធិទាំងនោះឯង ព្រោះថា ឧបធិទាំងអស់ ព្រះខីណាស្រពលះបង់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយមគ្គញ្ញាណ ព្រោះដូច្នោះ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយមគ្គញ្ញាណនោះ ទើបជាហេតុនៃការលះបង់នូវឧបធិទាំងនោះ ។ បទថា **សច្ឆិកត្វា** សេចក្ដីថា ព្រះសម្មាសម្ពុទ្ធមិនមានអាសវៈ ទ្រង់ធ្វើអមតធាតុឲ្យជាក់ច្បាស់ដល់ព្រះអង្គ ដោយការចូលផលសមាបត្តិ តាមកាលដ៏សមគួរ ទ្រង់សម្ដែងបទ គឺព្រះនិព្វាននោះឯង ដែលមិនសោយសោក ប្រាសចាកធូលី ព្រោះដូច្នោះ បណ្ឌិតគួរធ្វើសេចក្ដីប្រឹងប្រែងដើម្បីសម្រេចបទ គឺព្រះនិព្វាននោះ ។៚

**អដ្ឋកថា ធាតុសូត្រទី ២ ចប់**

# សុត្តន្តបិដក

## បឋមវេទនាសូត្រ

[ ៥២ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះមាន ៣ ។ វេទនា ៣ តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ វេទនាមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សាវ័កនៃព្រះពុទ្ធ មានចិត្តតម្កល់មាំ មានសម្បជញ្ញៈ
មានសតិ ដឹងច្បាស់នូវវេទនាទាំងឡាយផង នូវទីកើត
នៃវេទនាទាំងឡាយផង វេទនាទាំងនោះ រលត់ទៅក្នុង
ទីណា ក៏ដឹងច្បាស់នូវទីនោះផង នូវមគ្គជាដំណើរទៅ
កាន់ទីអស់ទៅនៃវេទនាផង ភិក្ខុអស់តណ្ហា តែងបរិ-
និព្វាន ព្រោះអស់វេទនាទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## បឋមវេទនាសូត្រ

[ ៥២ ] ក្នុងបឋមវេទនាសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វេទនា** សេចក្ដីថា ចេតសិកធម៌ ឈ្មោះថា **វេទនា** ព្រោះដឹង គឺសោយរសនៃអារម្មណ៍ ដើម្បីសម្ដែងវេទនាទាំងនោះ ដោយចែកចេញទៅ ទើបត្រាស់ពាក្យជាដើមថា **សុខា វេទនា** ដូច្នេះ ។ បណ្ដាសព្ទទាំងនោះ **សុខ** សព្ទ ខ្ញុំបានពោលហើយខាងដើម ដោយអំណាចនៃអត្ថុទ្ធារកណ្ឌ ។

តែ **ទុក្ខ** សព្ទ មកក្នុងអត្ថថា រឿងរបស់ទុក្ខ ដូចក្នុងប្រយោគជាដើមថា **ជាតិបិទុក្ខា** ការកើតជាទុក្ខ ដូច្នេះ ។

មកក្នុងអត្ថថា អារម្មណ៍ដែលជាទុក្ខ ដូចក្នុងប្រយោគជាដើមថា **រូបញ្ច ហិទំ មហាលិ ឯកន្តទុក្ខំ អភវិស្ស ទុក្ខានុបតិតំ ទុក្ខាវក្កន្តំ** ម្នាលមហាលិ រូបនេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ ដូច្នេះ ។

មកក្នុងអត្ថថា ការសន្សំទុក្ខ ដូចក្នុងប្រយោគជាដើមថា **ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំនូវបាប រមែងនាំមកនូវសេចក្ដីទុក្ខ ដូច្នេះ ។

មកក្នុងអត្ថថា ឋានៈដែលជាហេតុនៃទុក្ខ ដូចក្នុងប្រយោគជាដើមថា **យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ ទុក្ខា និរយាតិ** ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះ មិនងាយនឹងធ្វើឧបមាឲ្យដល់កម្រិតនរក ដែលមានទុក្ខបានឡើយ ដូច្នេះ ។

មកក្នុងអត្ថថា ទុក្ខវេទនា ដូចក្នុងប្រយោគជាដើម **សុខស្ស ច បហានា**

**ទុក្ខស្ស ច បហានា** កាលណាបើខ្លួននេះ បានលះបង់សុខផង លះបង់ទុក្ខផង ... ដូច្នេះ ។

សូម្បីក្នុងព្រះសូត្រនេះ ក៏មកហើយក្នុងទុក្ខវេទនាប៉ុណ្ណោះ តែដោយអត្ថវចនៈ ឈ្មោះថា **សុខ** ព្រោះជាអ្នកសោយឲ្យសប្បាយ ឈ្មោះថា **ទុក្ខ** ព្រោះអ្នកសោយឲ្យលំបាក ។ វេទនា ឈ្មោះថា **អទុក្ខមសុខ** ព្រោះមិនទុក្ខមិនសុខ ។ **ម** អក្ខរៈ ក្នុងពាក្យថា **អទុក្ខមសុខា** ត្រាស់ដោយអំណាចនៃបទសន្ធិ ។

បណ្តាវេទនាទាំង ៣ នោះ វេទនាដែលមានការសោយឥដ្ឋារម្មណ៍ជាលក្ខណៈ ឈ្មោះថា **សុខវេទនា** ដែលមានការសោយអនិដ្ឋារម្មណ៍ជាលក្ខណៈ ឈ្មោះថា **ទុក្ខវេទនា** ។ ដែលមានការសោយអារម្មណ៍ខុសចាក ២ យ៉ាងនោះ ឈ្មោះថា **អទុក្ខមសុខវេទនា** ព្រោះដូច្នោះ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា ទើបប្រាកដច្បាស់ តែអទុក្ខមសុខវេទនាមិនប្រាកដ ព្រោះថា ក្នុងកាលណា សេចក្តីសុខកើតឡើង ក្នុងកាលនោះ សេចក្តីសុខនឹងធ្វើសរីរៈទាំងមូលឲ្យញាប់ញ័រ ឲ្យជ្រួតជ្រាប ឲ្យផ្សាយទៅពេញរាងកាយទាំងមូល ដូចឲ្យបរិភោគសប្បិ ដែលចម្អិនហើយរាប់រយដង ដូចលាបដោយប្រេងល្អដែលចម្រាញ់រាប់រយដង និងដូចឲ្យកម្តៅរលត់ទៅដោយទឹក ១០០០ ក្អមកើតឡើង ដូចបន្លឺវាចាចេញមកថា ឱ ! សុខហ្ន៎ ឱ ! សុខហ្ន៎ ។ កាលណាទុក្ខកើតឡើង កាលនោះ ទុក្ខនឹងធ្វើឲ្យសរីរៈទាំងមូលញាប់ញ័រ ជ្រួតជ្រាបផ្សាយទៅពេញរាងកាយ ដូចដាក់អំបែងក្តៅចូលទៅ និងដូចយកទឹកទន់ដែង

ស្រោច ដូចឲ្យរើរវាយថា ឱ ! ទុក្ខហ្ន៎ ឱ ! ទុក្ខហ្ន៎ ដូច្នេះ ទើបការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា ប្រាកដច្បាស់ ។

ចំណែកអទុក្ខមសុខវេទនាដឹងបានលំបាក ឲ្យឃើញបានលំបាក ផងនឹតអទុក្ខមសុខវេទនានោះ ជាវេទនាមានអាការជាកណ្ដាល ដោយជំទាស់នឹងអារម្មណ៍ដែលគួរត្រេកអរ និងមិនត្រេកអរ ក្នុងកាលដែលសុខ និងទុក្ខប្រាសទៅ រមែងប្រាកដច្បាស់ដល់អ្នកកាន់យកដោយន័យនេះប៉ុណ្ណោះ ។

សេចក្ដីនេះប្រៀបដូចអ្វី ប្រៀបដូចផ្លូវដែលម្រឹគឆ្លងទៅហើយលើផ្ទាំងថ្មដោយភាពជាផ្លូវដែលចូលទៅក្នុងភូមិបទេស ដែលមានធូលីក្នុងដើមនៃផ្លូវនិងខាងចុងនៃផ្លូវ យ៉ាងណា ភាវៈនៃការសោយអារម្មណ៍ ដែលជាកណ្ដាលក៏ដូច្នោះដូចគ្នា និងដឹងបានដោយការសោយសុខ និងទុក្ខក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ ការកាន់យកមជ្ឈត្តារម្មណ៍ ដូចជាការដើរលើផ្ទាំងថ្មរបស់ម្រឹគ ព្រោះមិនមានការទាញយកឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។ ការសោយមជ្ឈត្តារម្មណ៍នោះ គឺអទុក្ខមសុខវេទនានោះឯង ដោយប្រការដូចពោលមកនេះ ក្នុងព្រះសូត្រនេះ សូម្បីព្រះមានព្រះភាគក៏ត្រាស់វេទនា ៣ យ៉ាង ជាសុខ ជាទុក្ខ និងជាអទុក្ខមសុខវេទនា តែក្នុងទីខ្លះ ត្រាស់វេទនា ២ យ៉ាងដោយជាសុខវេទនា និងទុក្ខវេទនា ដូចព្រះតម្រាស់ក្នុងពហុវេទនីយសូត្រថាម្នាលអានន្ទ វេទនា ២ ក៏តថាគតបានសម្ដែងដោយបរិយាយ ... ដូច្នេះ ។ ក្នុងទីខ្លះ ( ចូឡវេទល្លសូត្រ ) ត្រាស់ ៣ យ៉ាង ដោយចែកជាសុខចំណែកមួយ ទុក្ខចំណែកមួយ អទុក្ខមសុខចំណែកមួយថា សុខវេទនាមានកិរិយាស្ថិត

នៅដដែល ជាសុខ មានការប្រែប្រួលទៅវិញ ជាទុក្ខ ទុក្ខវេទនាមានកិរិយាស្ថិតនៅ ជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញ ជាសុខ ឯអទុក្ខមសុខវេទនាមានការដឹងច្បាស់ ជាសុខ មានការមិនដឹង ជាទុក្ខ ដូច្នេះ ។ ក្នុងទីខ្លះ ទ្រង់ត្រាស់វេទនាទាំងអស់ថាជាទុក្ខ ។ ដូចព្រះតម្រាស់ដែលត្រាស់នៅក្នុងសំយុត្តនិកាយ សឡាយតនវគ្គថា អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ដូច្នេះ ។

ក្នុងសេចក្តីនោះ មានពាក្យចោទសួរថា បើក្នុងសូត្រដទៃៗ យ៉ាងនេះនិងក្នុងព្រះអភិធម្ម ព្រះមានព្រះភាគមិនបានត្រាស់វេទនាទាំង ៣ ហើយសោតកាលបើដូច្នោះ ហេតុអ្វី ទើបត្រាស់យ៉ាងនេះថា អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ និងថា ម្នាលអានន្ទ វេទនា ២ ក៏តថាគតបានសម្តែងដោយបរិយាយ ដូច្នេះ ។ ឆ្លើយថា ព្រះមានព្រះភាគត្រាស់ដោយទ្រង់សំដៅយកពាក្យទាំង ២ នេះ ព្រោះដូច្នោះ ទើបទេសនាចាត់ជាទេសនាដោយបរិយាយ ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ការប្រែប្រួលនៃសង្ខារ តថាគតពោលសំដៅដល់ការមិនទៀងនៃសង្ខារ អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ និងថា ម្នាលអានន្ទ វេទនា ២ ក៏តថាគតបានសម្តែងដោយបរិយាយ ដូច្នេះ ។ ព្រោះថា ក្នុងបណ្តាវេទនាទាំង ៣ នេះ ការដែលវេទនាទាំង ២ យ៉ាង គឺ សុខវេទនា ១ អទុក្ខមសុខវេទនា ១ ជាទុក្ខដោយត្រង់មិនមាន តែព្រះមានព្រះភាគត្រាស់ថា ជាទុក្ខដោយបរិយាយ ដើម្បីសម្តែងដល់បុគ្គលមិនមាន

ធន្ទៈក្នុងវេទនាទាំង ២ នោះ តាមអធ្យាស្រ័យរបស់វេនេយ្យសត្វ ព្រោះដូច្នោះ ទេសនាបែបនេះ ទើបចាត់ជាទេសនាដោយបរិយាយ ឯទេសនាពោលដោយវេទនា ៣ នេះ ជាទេសនាដោយត្រង់ អធិប្បាយថា ពោលតាមសភាវ-ធម៌ ព្រោះដូច្នោះ ទើបក្នុងសេចក្ដីនេះ កថានេះនៃអាចារ្យទាំងឡាយ មានការស្របគ្នា ។

ចំណែកបុគ្គលដែលចូលចិត្តពោលផ្ដេសផ្ដាសថា ទេសនាពោលដោយវេទនា ៣ ជាទេសនាដោយបរិយាយដូចគ្នា ព្រោះពោលដល់ភាពជាទុក្ខ ២ យ៉ាង ។ បុគ្គលនោះ គប្បីត្រូវជាស់តឿនយ៉ាងនេះថា អ្នកកុំពោលយ៉ាងនោះ ព្រោះព្រះមានព្រះភាគត្រាស់វេទនាសព្វយ៉ាងថាជាទុក្ខ ដោយមានបំណងថា ម្នាលអានន្ទ ការប្រែប្រួលនៃសង្ខារ តថាគតពោលដល់ការមិនទៀងនៃសង្ខារ អារម្មណ៍ឯណានីមួយ ដែលបុគ្គលបានសោយហើយ អារម្មណ៍នោះក៏ជាទុក្ខ ។ បើក្នុងរឿងនេះ ទេសនាដែលពោលដោយពួក ៣ នៃវេទនា គប្បីជាទេសនាដោយបរិយាយសោត ពាក្យដែលខ្ញុំពោលសំដៅយកនេះ ក៏គួរពោលបានថា វេទនាជា ៣ តែពាក្យនេះ ក៏មិនបានពោលឡើយ ។

ម្យ៉ាងទៀត សេចក្ដីនេះឯង គួរពោលបានថា នៃអាវុសោ ទ្រង់សម្ដែងវេទនា ៣ ដោយបំណងអ្វី បើមានពាក្យពោលថា វេទនា ៣ ទ្រង់ត្រាស់តាមអធ្យាស្រ័យនៃវេនេយ្យសត្វថា ទុក្ខវេទនាយ៉ាងទន់ ជាសុខ វេទនាយ៉ាងខ្លាំងក្លា ជាទុក្ខ វេទនាយ៉ាងកណ្ដាល ជាអទុក្ខមសុខវេទនា ដូច្នេះសោត ពិតហើយ ក្នុងវេទនាទាំងនោះ សេចក្ដីចម្រើននៃសុខវេទនាជាដើម មិនមានដល់

សត្វទាំងឡាយឡើយ ដូច្នេះ ។ គេនឹងត្រូវសួរថា អាវុសោ អ្វីជាសភាវៈនៃទុក្ខវេទនា ដែលជាហេតុឲ្យវេទនាទាំងអស់ ត្រូវហៅថាជាទុក្ខ បើវេទនាណាកើតឡើង សត្វទាំងឡាយបំណងនឹងចេញទៅតែម្យ៉ាងនោះឯង ជាសភាវៈនៃទុក្ខវេទនា ឯទុក្ខវេទនាណាកើតឡើងហើយ សត្វទាំងឡាយ មិនបំណងនឹងឲ្យប្រាសចេញទៅឡើយ វេទនាណាកើតឡើង មិនបំណងទាំង ២ យ៉ាង វេទនានោះ គប្បីជាទុក្ខវេទនាបានដូចម្ដេច ពិតហើយ វេទនាណា កាត់នូវសុខនិស្ស័យរបស់ខ្លួន វេទនានោះក៏ជាទុក្ខ វេទនាណាធ្វើការអនុគ្រោះ វេទនានោះគប្បីជាទុក្ខបានដូចម្ដេច ម្យ៉ាងទៀត ព្រះអរិយៈទាំងឡាយ ឃើញសភាពណាជាទុក្ខ សភាពនោះជាសភាវៈនៃទុក្ខវេទនា ព្រះអរិយៈទាំងឡាយ ឃើញវេទនាដោយភាពជាទុក្ខ ព្រោះហេតុដែលសង្ខារទាំងឡាយជាទុក្ខ ហើយវេទនានោះក៏ជាសភាវៈដែលមានជាប្រចាំ ព្រោះដូច្នោះ វេទនាទាំងនោះ គប្បីមានសភាវៈជាទុក្ខយ៉ាងទន់ យ៉ាងកណ្ដាល និងយ៉ាងខ្លាំងក្លាបានដូចម្ដេច ។ បើវេទនាទាំងឡាយគប្បីមានភាពជាទុក្ខ ព្រោះភាពដែលសង្ខារទាំងឡាយជាទុក្ខប៉ុណ្ណោះសោត ទេសនាដែលទ្រង់ចែកភាពជាទុក្ខចេញទៅ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភាពជាទុក្ខមាន ៣ យ៉ាង គឺទុក្ខទុក្ខតា ភាពជាទុក្ខ គឺទុក្ខ-វេទនា ១ វិបរិណាមទុក្ខតា ភាពជាទុក្ខ គឺការប្រែប្រួលនៃសុខ ១ សង្ខារទុក្ខតា ភាពជាទុក្ខ គឺសង្ខារ ១ ក៏គប្បីឥតប្រយោជន៍ទៅហើយ កាលបើដូច្នោះ ព្រះសូត្រនោះឯង គប្បីត្រូវជំទាស់ ។ បើពាក្យដែលពោលថា ទុក្ខ-វេទនាយ៉ាងទន់ ជាសុខវេទនា ក្នុងរូបាវចរជ្ឈាន ៣ ខាងដើម ក៏ត្រូវ ព្រោះ

*សំដៅដល់សុខវេទនា ។ ទុក្ខវេទនាយ៉ាងកណ្តាលក្នុងចតុត្ថជ្ឈាន និងអរូបជ្ឈាន ព្រោះសំដៅដល់អទុក្ខមសុខវេទនា កាលបើដូច្នោះ ពាក្យថា រូបាវចរសមាបត្តិ ៣ ខាងដើម ស្ងប់ជាងចតុត្ថជ្ឈានសមាបត្តិ និងអរូបសមាបត្តិ ក៏ត្រូវផងដែរ ។*

*ម្យ៉ាងទៀត ភាពដែលទុក្ខវេទនាជារបស់ក្រៃលែងជាងគ្នាក្នុងសមាបត្តិដែលស្ងប់ និងប្រណីតជាងគ្នា នឹងត្រូវបានដូចម្តេច ព្រោះដូច្នោះ ភាពដែលទេសនាពោលដោយវេទនា ៣ ជាទេសនាដោយបរិយាយ ទើបមិនត្រូវ ។*

*សួរថា ក្នុងសមាបត្តិទាំង ៣ ខាងដើម ពាក្យណាដែលទ្រង់ត្រាស់ថា សញ្ញាវិបល្លាសក្នុងទុក្ខថាជាសុខ ពាក្យនោះដូចម្តេច ឆ្លើយថា សេចក្តីនោះ ព្រះមានព្រះភាគ ត្រាស់សំដៅយកសញ្ញាក្នុងភាពជាសុខដោយចំណែកមួយ និងសញ្ញាក្នុងទុក្ខនិមិត្ត ថាជាសុខនិមិត្ត ព្រោះទ្រង់ដឹងតាមសេចក្តីពិត ព្រោះភាពជាវិបរិណាមទុក្ខ និងសង្ខារទុក្ខ ។*

*សួរថា កាលបើដូច្នោះ ចំណែកពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ វេទនាដែលជាសុខ គប្បីឃើញដោយភាពជាទុក្ខដូច្នេះ ដូចម្តេច ឆ្លើយថា ពាក្យនេះ ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់ប្រកបសេចក្តីឲ្យជិតស្និទ្ធ ក្នុងការទ្រង់សម្តែងនូវការប្រែប្រួល ព្រោះភាពដែលទុក្ខនោះជាឧបាយ ឲ្យចូលដល់នូវការប្រាសចាកតម្រេកក្នុងសុខវេទនានោះ និងព្រោះភាពដែលសុខវេទនាអណ្តែតទៅរកទុក្ខច្រើន ។ ពិតហើយ បណ្ឌិតទាំងឡាយ ឃើញសុខ ថាជាទុក្ខនោះឯង ប្រព្រឹត្តទៅហើយ ព្រោះសុខជាហេតុនៃទុក្ខ និងព្រោះសុខត្រូវទុក្ខធម៌ជាអនេកជាប់តាម ។*

កាលបើដូច្នេះ សុខវេទនាក៏មិនមានឡើយ ព្រោះហេតុនៃសេចក្ដីសុខមិនមានកំណត់ពិតប្រាកដ ព្រោះថា គ្រឿងបរិភោគ និងគ្រឿងស្លៀកដណ្ដប់ជាដើមដែលសន្មតថា ជាហេតុនៃសុខវេទនានោះឯង កាលបរិភោគ និងប្រើប្រាស់លើសប្រមាណ និងមិនត្រូវកាល រមែងដល់នូវភាពជាហេតុនៃទុក្ខវេទនា តែមិនគួរពោលថា សុខកើតឡើងដោយហេតុឯណា សេចក្ដីទុក្ខក៏កើតឡើងដោយហេតុនោះដូចគ្នា ព្រោះដូច្នោះ ទើបគ្រឿងបរិភោគ និងគ្រឿងស្លៀកដណ្ដប់ទាំងនោះ មិនមែនជាហេតុនៃសេចក្ដីសុខ ។ តែជាសញ្ញានៃសេចក្ដីសុខនៃបុគ្គលដែលមិនដឹងទាំងឡាយ ក្នុងកាលទុក្ខប្រាសទៅក្នុងចន្លោះ ។ ឧបមាដូចបុគ្គលតាំងនៅក្នុងឥរិយាបថ មានការឈរអស់កាលយូរជាដើម និងសម្គាល់ថាជាសុខ ក្នុងកាលប្ដូរឥរិយាបថ និងដូចសម្គាល់ថាសុខរបស់អ្នកដែលរែកធ្ងន់ក្នុងកាលដាក់អម្រែកចុះ ព្រោះដូច្នោះ នឹងមិនមានសុខទេឬសេចក្ដីនោះ ជាការកំណត់ភាពដែលទុក្ខមិនមានកំណត់ពិតប្រាកដ ដោយមិនកំណត់ដឹងហេតុនៃសុខ ដោយពាល់ត្រូវនោះឯង ។

ពិតហើយ សុខត្រឹមតែអារម្មណ៍ប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ព្រោះទ្រង់មនសិការដល់ហេតុនៃសេចក្ដីសុខតែម្យ៉ាង សេចក្ដីសុខនោះ ផ្សេងគ្នាដោយការកំណត់សរីរៈ ដែលប្រព្រឹត្តទៅខាងក្នុង ចំណែកទាំង ២ យ៉ាងនោះ ដែលកើតឡើងព្រមគ្នា កើតឡើងក្នុងទីជាមួយគ្នា គប្បីជ្រាបថា ជាហេតុនៃសេចក្ដីសុខជាដើម ។

ទាំង ២ យ៉ាងនោះ ប្រភេទណាជាហេតុនៃសុខវេទនា ប្រភេទនោះ ជូន

កាល ក៏មិនជាហេតុនៃទុក្ខវេទនា ព្រោះដូច្នោះ វេទនាដែលលោកកំណត់នោះឯង ជាហេតុនៃសេចក្តីសុខជាដើម ឧបមាដូចតេជោធាតុអំពីឧណ្ហភូមិប៉ះខ្ទប់នូវពូជណាមួយ មានស្រូវសាលី ស្រូវដំណើប បន្លែ និងសម្ទូងជាដើម រវាងទីតាំងនៃដើមបានហើយ ក៏ជាហេតុនៃការត្រេកអរ និងមានរសជាតិឆ្ងាញ់ ជួនកាល ប៉ះខ្ទប់ពូជប្រភេទនោះដូចគ្នា តែក៏មិនជាហេតុនៃការត្រេកអរ និងមានរសឆ្ងាញ់ យ៉ាងណា ការឧបមេយ្យ ក៏គប្បីជ្រាបដូច្នោះដូចគ្នា ។ ជួនកាល វេទនាដែលប្រាសទៅចាកទុក្ខ បានទទួលសុខវេទនាដទៃ ក្នុងកាលនោះ នឹងមានសេចក្តីសម្គាល់ក្នុងសេចក្តីសុខនោះឯងថាជាសុខ មិនមែនត្រឹមតែពេលដែលសេចក្តីទុក្ខប្រាសទៅ ដូចការសម្គាល់ក្នុងសេចក្តីសុខថាជាសុខនៃបុគ្គលដែលនឿយហត់ក្នុងការដើរផ្លូវ និងក្តៅក្រហាយព្រោះការក្រវល់ក្រវាយ ដោយការគក់ប្រចាប់ និងការផ្លាស់ប្តូរឥរិយាបថ ដូច្នោះ ។ ដោយប្រការដទៃ ទោះក្នុងរវាងកាល សុខសញ្ញាគប្បីមានក្នុងកាលដែលអន្តរាយកន្លងទៅ តែក្នុងខណៈដែលត្រឹមតែជាទុក្ខកន្លងទៅ ការកំណត់ថាជាសុខគប្បីមាន ព្រោះមិនចូលទៅបាននូវវេទនាពិសេស ។ ការឧបមេយ្យនេះ គប្បីសម្រេចយ៉ាងនោះដោយចំណែកមួយនោះឯង កាលណា សត្វទាំងឡាយប្រាថ្នាក្រៃលែង នូវអារម្មណ៍ទាំងឡាយដែលប្រណីតៗ ក្រៃលែង ក្នុងរូបតែម្យ៉ាង ដោយសេចក្តីលំបាកច្រើន កាលនោះ បុគ្គលណាម្នាក់ក៏មិនអាចធ្វើនូវការតបស្នងសត្វទាំងនោះបាន ដោយបច្ច័យត្រឹមតែស្មើគ្នាដែលនឹងបានមក មានតែឲ្យកើតតណ្ហាដូច្នេះ ។ ព្រោះវេទនាជាបច្ច័យ ទើបតណ្ហាកើតឡើង កាលបើដូច្នោះ ការ

សម្គាល់ថាជាសុខវិសេស កាលកើតឡើងដោយភាពដែលវត្ថុទាំងឡាយ មានគ្រឿងក្រអូប មានរសឆ្ងាញ់ និងសុខសម្ផស្សជាដើមដទៃ គប្បីកើតក្នុងឃានទ្វារ ជិវ្ហាទ្វារ និងកាយទ្វារទាំងឡាយ និងក្នុងសោតទ្វារដែលជាទីទទួលសំឡេងនៃតូរ្យតន្ត្រីមានអង្គ ៥ ដូចគ្នានឹងទិព្វតន្ត្រី ព្រោះទុក្ខវិសេសណាមួយកន្លងទៅ ។ ព្រោះហេតុនោះ ទើបក្នុងទុក្ខវេទនាណាមួយ សុខសញ្ញាមិនមានព្រោះទុក្ខក្នុងរវាងកន្លងទៅ ដល់សុខសញ្ញាក៏មិនមាន ក្នុងខណៈត្រឹមតែទុក្ខកន្លងទៅតែម្យ៉ាង ។ វេទនាទាំង ៣ ទ្រង់កំណត់ដោយអាគម ដោយយុត្តិ ព្រោះដូច្នោះ ទេសនាពោលដោយវេទនា ៣ ពួក របស់ព្រះមានព្រះភាគ ទើបជានីតត្ថទេសនា គឺទេសនាដែលមានអត្ថនាំចេញទៅហើយ គឺទ្រង់សម្តែងចំពោះបុគ្គលតែម្យ៉ាង មិនមែននេយ្យត្ថទេសនា គឺទេសនាដែលមានអត្ថ ត្រូវនាំចេញដល់មនុស្សទូទៅ គួរយល់អត្ថដូចពោលមកនេះ បើបុគ្គលណា ចូលដល់ទេសនានោះ តាមដែលបានពណ៌នាសោត សេចក្តីនោះជាការល្អ បើបុគ្គលនោះចូលមិនដល់ទេសនានោះ នឹងត្រូវបញ្ជូនទៅថា ចូរទៅតាមសប្បាយរបស់ខ្លួនចុះ ដូច្នេះ ។

វេទនាទាំង ៣ នោះ ដែលមានលក្ខណៈត្រូវកំណត់សភាវៈដែលប្រែជែងគ្នា ដូចពណ៌នានេះឯង ព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ វេទនាទាំង ៣ នោះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ព្រះយោគាវចរទាំងឡាយដែលប្រកបការបំពេញវិបស្សនាដើម្បីសម្តែងអរូបកម្មដ្ឋានដោយមុខ គឺវេទនា ព្រោះថា កម្មដ្ឋាន ២ យ៉ាង គឺរូបកម្មដ្ឋាន និងអរូបកម្មដ្ឋាន ។ ក្នុងកម្មដ្ឋាន

ទាំង ២ នោះ ព្រះមានព្រះភាគ កាលនឹងត្រាស់រូបកម្មដ្ឋាន បានត្រាស់ដោយអំណាចនៃមនសិការដោយសង្ខេបខ្លះ ដោយអំណាចនៃមនសិការពិស្តារខ្លះ ដោយអំណាចនៃការកំណត់ធាតុជាដើមយ៉ាងនោះខ្លះ តែកាលនឹងត្រាស់អរូបកម្មដ្ឋាន ក៏ត្រាស់ដោយអំណាចនៃផស្សៈខ្លះ ដោយអំណាចនៃវេទនាខ្លះ ដោយអំណាចនៃចិត្តខ្លះ ព្រោះថា ព្រះយោគាវចររូបខ្លះ កាលរឭកដល់អារម្មណ៍ដែលចូលកាន់គន្លងផស្សៈ មានចិត្ត និងចេតសិកធ្លាក់ទៅគ្រាដំបូង ក្នុងអារម្មណ៍នោះ ពាល់ត្រូវអារម្មណ៍នោះ ក៏ប្រាកដច្បាស់ ។ សម្រាប់ព្រះយោគាវចររូបខ្លះ វេទនាដែលសោយអារម្មណ៍នោះកើតឡើង និងប្រាកដច្បាស់ ។ តែសម្រាប់រូបខ្លះ វិញ្ញាណដែលដឹងអារម្មណ៍នោះ កើតឡើងមិនប្រាកដច្បាស់ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់អរូបកម្មដ្ឋាន ៣ យ៉ាង តាមដែលប្រាកដដោយអធ្យាស្រ័យនៃបុគ្គលនោះៗ ដោយមានផស្សៈជាដើមជាប្រធាន ។

ក្នុងបុគ្គល ៣ ប្រភេទនោះ ផស្សៈប្រាកដច្បាស់ដល់បុគ្គលណា សូម្បីអ្នកនោះនឹងកំណត់អារម្មណ៍ មានផស្សៈជាគម្រប់ ៥ នោះឯងថា មិនមែនផស្សៈតែម្យ៉ាងប៉ុណ្ណោះកើតឡើង សូម្បីវេទនាដែលសោយអារម្មណ៍នោះឯងក៏នឹងកើតឡើង ព្រមគ្នានឹងផស្សៈនោះ សូម្បីសញ្ញាដែលចាំអារម្មណ៍នោះ សូម្បីចេតនាដែលគិតដល់អារម្មណ៍នោះ សូម្បីវិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ក៏កើតព្រមជាមួយនឹងផស្សៈនោះ ។ វេទនាប្រាកដដល់បុគ្គលណា បុគ្គលនោះនឹងកំណត់អារម្មណ៍ មានផស្សៈជាគម្រប់ ៥ ដូចគ្នាថា មិន

មែនវេទនាតែម្យ៉ាងប៉ុណ្ណោះកើតឡើង សូម្បីផស្សៈដែលពាល់ត្រូវក៏នឹងកើតព្រមជាមួយនឹងវេទនានោះ សូម្បីសញ្ញាដែលចាំបាន សូម្បីចេតនាដែលនឹកគិត សូម្បីសញ្ញាដែលដឹងច្បាស់ ក៏នឹងកើតឡើងជាមួយវេទនានោះ ។ វិញ្ញាណប្រាកដច្បាស់ដល់បុគ្គលណា បុគ្គលនោះ ក៏កំណត់អារម្មណ៍ មានផស្សៈជាគម្រប់ ៥ ដូចគ្នាថា មិនមែនតែវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះដែលកើតឡើង ទោះផស្សៈដែលពាល់ត្រូវនូវអារម្មណ៍នោះ ក៏កើតឡើងព្រមជាមួយនឹងវិញ្ញាណនោះ សូម្បីវេទនាដែលសោយអារម្មណ៍ សូម្បីសញ្ញាដែលចាំអារម្មណ៍ និងចេតនាដែលនឹកគិត ក៏កើតឡើងព្រមជាមួយនឹងវិញ្ញាណនោះ ព្រះយោគាវចរនោះពិចារណាថា ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ នេះ អាស្រ័យអ្វីដូច្នេះ និងដឹងច្បាស់ថា អាស្រ័យវត្ថុ ។ករជកាយ ឈ្មោះថា **វត្ថុ** ។

ពាក្យដែលព្រះមានព្រះភាគត្រាស់ថា វិញ្ញាណនៃតថាគតនេះអាស្រ័យនៅក្នុងករជកាយនេះ ទាក់ទងហើយក្នុងករជកាយនេះ ទ្រង់សំដៅយកករជ-កាយណា ករជកាយនោះ ដោយអត្ថ បានដល់ ភូត និងឧបាទាយរូបទាំងឡាយ ។ ភិក្ខុនោះ ឃើញត្រឹមតែនាម និងរូបប៉ុណ្ណោះថា បណ្តាធម៌ ២ យ៉ាងនេះ វត្ថុជារូប ធម៌មានផស្សៈជាគម្រប់ ៥ ជានាម ដោយប្រការដូចពោលមកនេះ ។ ក្នុង ២ យ៉ាងនោះ **រូប** បានដល់ រូបក្ខន្ធ **នាម** បានដល់ ខន្ធ ៤ ដែលមិនមែនជារូប ដូច្នោះ ទើបរួមជាខន្ធ ៥ ។ ពិតហើយ បញ្ចក្ខន្ធដែលនឹងផុតចាកនាមរូប ឬនាមរូបដែលផុតពីបញ្ចក្ខន្ធមិនមាន ។ ភិក្ខុនោះ កាលពិចារណាថា បញ្ចក្ខន្ធទាំងនេះមានអ្វីជាហេតុ ក៏ឃើញថា មានអវិជ្ជាជាហេតុ

*បន្ទាប់អំពីនោះ លើកបញ្ចក្ខន្ធឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃនាមរូបមួយអន្លើដោយបច្ច័យថា នាមរូបនេះជាបច្ច័យផង ជាបច្ច័យកើតឡើងផង មិនមានសត្វ ឬបុគ្គលដទៃ មានត្រឹមតែគំនរសង្ខារសុទ្ធៗ ប៉ុណ្ណោះ ហើយពិចារណាតាមលំដាប់វិបស្សនាថា* **អនិច្ចំ ទុក្ខំ អនត្តា** *ដូច្នេះ ។ លោកបំណងបដិវេធថា គឺការត្រាស់ដឹង អញនឹងត្រាស់ដឹងក្នុងថ្ងៃនេះៗ ក្នុងសម័យនោះបាននូវឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ ភោជនជាទីសប្បាយ ឬការស្តាប់ធម៌ជាទីសប្បាយ ហើយអង្គុយក្នុងមួយប៉ុណ្ណោះ ក៏ញុំាងវិបស្សនាឲ្យដល់ទីបំផុត រមែងតាំងនៅក្នុងអរហត្តផល ។ គប្បីជ្រាបកម្មដ្ឋានរហូតដល់អរហត្តរបស់ជន ៣ ពួក ដូចពណ៌នាមកនេះ ។ តែក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ កាលត្រាស់អរូបកម្មដ្ឋាន តាមអធ្យាស្រ័យនៃអ្នកដែលត្រាស់ដឹងដោយអំណាចនៃវេទនា ទើបត្រាស់ដោយអំណាចនៃវេទនា ។*

*ក្នុងព្រះសូត្រនេះ គប្បីជ្រាបបកិណ្ណកដូច្នេះ គឺលក្ខណៈ ១ អធិដ្ឋាន ១ ឧប្បត្តិ ១ អនុស័យ ១ ឋានៈ ១ បវត្តិកាល ១ ឥន្ទ្រិយ ១ ទុវិធាទិតា ១ ។*

*បណ្តាបកិណ្ណក ៨ យ៉ាងនោះ លក្ខណៈ ខ្ញុំបានពោលខាងដើមស្រេចហើយ ផស្សៈ ឈ្មោះថា* **អធិដ្ឋាន** *។ ព្រោះព្រះបាលីថា* **ផស្សប្បច្ចយា វេទនា** *ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ដូច្នេះ ។ ទើបផស្សៈជាទីតាំងនៃវេទនា ។ ពិតហើយ ផស្សៈនោះ ព្រះមានព្រះភាគទ្រង់ប្រៀបធៀបដោយឧបមានឹងមេគោដែលគេបកស្បែកហើយ ព្រោះផស្សៈជាទីតាំងនៃវេទនា ។ បណ្តាវេទនាទាំងនោះ ផស្សៈដែលឲ្យសោយសុខ ជាទីតាំងនៃសុខ-*

វេទនា ផស្សៈដែលឲ្យសោយទុក្ខ ជាទីតាំងនៃទុក្ខវេទនា ផស្សៈដែលឲ្យសោយអទុក្ខមសុខវេទនា ជាទីតាំងនៃអទុក្ខមសុខវេទនា អធិប្បាយថា បានដល់ អាសន្នការណ៍ គឺហេតុជិត ។ សួរថា វេទនាជាបទដ្ឋានរបស់អ្វី ឆ្លើយថា វេទនាជាបទដ្ឋានរបស់តណ្ហា ដោយមានសេចក្ដីប្រាថ្នាក្រៃលែង ដោយព្រះបាលីថា **វេទនាបច្ចយា តណ្ហា** ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ។

សួរថា សុខវេទនាជាបទដ្ឋាននៃតណ្ហា ចូរស្ទុះទុកសិនចុះ តែវេទនាក្រៅអំពីនេះ ជាបទដ្ឋាននៃតណ្ហាបានដូចម្ដេច ខ្ញុំនឹងឆ្លើយដូចតទៅ ជាបឋមសូម្បីបុគ្គលដល់ព្រមដោយសេចក្ដីសុខនៅប្រាថ្នាសេចក្ដីសុខ ដូច្នោះ ឬសេចក្ដីសុខដែលក្រៃលែងជាងនោះ នឹងពោលទៅថ្វីដល់បុគ្គលដែលត្រូវសេចក្ដីទុក្ខគ្របសង្កត់នោះ ។ ហើយអទុក្ខមសុខ លោកហៅថា សុខដូចគ្នា ព្រោះជាការស្ងប់ ទើបវេទនាទាំង ៣ ជាបទដ្ឋាននៃតណ្ហា ។

ហេតុដែលកើត ឈ្មោះថា **ឧប្បត្តិ** ពិតហើយ សត្វ និងសង្ខារទាំងឡាយ ដែលជាឥដ្ឋារម្មណ៍ ជាហេតុដែលកើតឡើងនៃសុខវេទនា ។ សត្វនិងសង្ខារទាំងនោះ ដែលជាអនិដ្ឋារម្មណ៍ជាហេតុ ជាទីកើតឡើងនៃទុក្ខវេទនា ដែលជាមជ្ឈត្តារម្មណ៍ជាហេតុ ជាទីកើតឡើងនៃអទុក្ខមសុខវេទនា ក្នុងឧប្បត្តិហេតុនេះ គប្បីជ្រាបភាពជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដោយការកាន់យកអាការរបស់វេទនានោះអំពីវិបាក ។

ពាក្យថា **អនុសយ** សេចក្ដីថា ក្នុងបណ្ដាវេទនាទាំង ៣ នេះ ព្រោះសុខវេទនា ទើបរាគានុស័យដេកត្រាំ ព្រោះទុក្ខវេទនា ទើបបដិឃានុស័យ

ដេកត្រាំ ព្រោះអទុក្ខមសុខវេទនា ទើបអវិជ្ជាដេកត្រាំ សមដូចលោកពោល ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកថា ម្នាលអាវុសោវិសាខៈ រាគានុស័យ ដេកសម្ងំនៅក្នុងសុខវេទនា ដូច្នេះជាដើម ។ អ្នកសិក្សាគប្បីចាប់ទិដ្ឋានុស័យ និងមានានុស័យ ដែលជាចំណែកនៃរាគៈ ចូលក្នុងរាគានុស័យនេះផងដែរ ។ ព្រោះបុគ្គលដែលមានទិដ្ឋិទាំងឡាយ រមែងជឿមាំក្នុងសក្កាយ ដោយន័យជាដើមថា ជារបស់ស្ថិតស្ថេរ ព្រោះការត្រេកអរនឹងសេចក្ដីសុខ ។ បុគ្គលមានមានះមកអំពីកំណើត អាងនូវមានះ ដោយន័យជាដើមថា អញជាបុគ្គលប្រសើរបំផុត ។ ឯវិចិកិច្ឆានុស័យដែលប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា ក៏ត្រូវរាប់ចូលផង ។ សមដូចព្រះតម្រាស់ទ្រង់ត្រាស់នៅក្នុងបដិច្ចសមុប្បាទវិភង្គថា **វេទនាបច្ចយា វិចិកិច្ឆា** ព្រោះវេទនាជាបច្ច័យ ទើបមានវិចិកិច្ឆា ដូច្នេះ ។ អនុស័យទាំងឡាយ នៅមានការប្រព្រឹត្តទៅដោយកម្លាំង ព្រោះភាវៈដែលមិនទាន់លះបានក្នុងសន្តាននោះៗ ។ ព្រោះដូច្នោះ ពាក្យថា រាគានុស័យដេកសម្ងំនៅក្នុងសុខវេទនា ទើបបានសេចក្ដីថា រាគៈដែលគួរដល់ការកើតឡើង ក្នុងកាលបានហេតុដ៏សមគួរ ទើបដូចជាដេកត្រាំក្នុងសន្តាននោះ ព្រោះមិនទាន់លះបានដោយមគ្គ សូម្បីបទដ៏សេស ក៏មានន័យនេះ ។

ពាក្យថា **ឋាន** សេចក្ដីថា កាយ និងចិត្តជាឋានៈនៃវេទនា សមដូចព្រះតម្រាស់ត្រាស់ក្នុងធម្មសង្គណិថា

សេចក្ដីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងកាយ សេចក្ដីសុខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ ដ៏ឆ្ងាញ់ពិសា ជាសុខ ដែលកើត

អំពីសម្ផស្សនៃកាយ វេទនាដ៏ឆ្ងាញ់ពិសា ជាសុខ ដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះសុខ កើតមានក្នុងសម័យនោះ ដូច្នេះ ។

ពាក្យថា **បវត្តិកាល** បានដល់ បវត្តិក្ខណៈ និងការរាប់ការប្រព្រឹត្តទៅ ។ អធិប្បាយថា ភាពដែលសុខវេទនាជាសុខ និងភាពដែលទុក្ខវេទនាជាទុក្ខ លោកកំណត់ហើយ ដោយបវត្តិក្ខណៈ សមដូចលោកពោលថា

> ម្នាលអាវុសោវិសាខៈ សុខវេទនាមានកិរិយាឋិតនៅដដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខវេទនាមានកិរិយាឋិតនៅ ជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ គឺ ការរាប់ការមិនរាប់ បានដល់ ការដឹង ការមិនដឹងនូវការប្រព្រឹត្តទៅនៃអទុក្ខមសុខវេទនា ជាគ្រឿងកំណត់ភាពជាសុខ និងជាទុក្ខ ។

អធិប្បាយថា ការមាននៃសុខវេទនា ជាសេចក្ដីសុខ ការមិនមាននៃសុខវេទនា ជាទុក្ខ ការមាននៃទុក្ខវេទនា ជាទុក្ខ ការមិនមាននៃទុក្ខវេទនាជាសុខ ។ ការរាប់ការប្រព្រឹត្តទៅនៃអទុក្ខមសុខវេទនា គឺ ការរាប់ ការមិនរាប់ បានដល់ ការដឹង ការមិនដឹង នូវការប្រព្រឹត្តទៅនៃអទុក្ខមសុខវេទនាជាគ្រឿងកំណត់ភាពជាសុខ និងជាទុក្ខ ។ សូម្បីពាក្យនេះ លោកក៏ពោលថា

ម្នាលអាវុសោវិសាខៈ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ ជាសុខ មានការមិនដឹង ជាទុក្ខ ។

បទថា **ឥន្ទ្រិយ** សេចក្តីថា ពិតហើយ វេទនា ៣ មានសុខវេទនាជាដើម ព្រះមានព្រះភាគទ្រង់ចែកដោយឥន្ទ្រិយ ៥ ប្រការ គឺសុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោសមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ព្រោះអត្ថថា ជាអធិបតី អធិប្បាយថា ការត្រេកអរតាមកាយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅថា **សុខិន្ទ្រិយ** ។ ការមិនត្រេកអរ ត្រាស់ហៅថា **ទុក្ខិន្ទ្រិយ** ។ ឯការត្រេកអរតាមចិត្ត ត្រាស់ហៅថា **សោមនស្សិន្ទ្រិយ** ។ ការមិនត្រេកអរត្រាស់ហៅថា **ទោមនស្សិន្ទ្រិយ** ។ ទាំង ២ យ៉ាងមិនត្រាស់ហៅថា ការត្រេកអរ ការមិនត្រេកអរជា **ឧបេក្ខិន្ទ្រិយ** ។ សួរថា ក្នុងសេចក្តីនេះ មានអ្វីជាហេតុ ឆ្លើយថា ព្រោះមិនមានការផ្សេងគ្នាថា អទុក្ខមសុខវេទនា ព្រះមានព្រះភាគ មិនបានត្រាស់ចែកដូចសុខវេទនា និងទុក្ខវេទនាតាមកាយ និងចិត្ត ដែលត្រាស់ចែកថា សុខិន្ទ្រិយ សោមនស្សិនទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ ដូច្នេះ ។ ព្រោះថា សុខវេទនាមានការអនុគ្រោះជាសភាវៈ ឯទុក្ខវេទនា មានការជុតជាសភាវៈ ម្យ៉ាងទៀត ធ្វើនូវការអនុគ្រោះកាយ ម្យ៉ាងទៀត ធ្វើនូវការជុតចិត្ត យ៉ាងណា អទុក្ខមសុខវេទនា មិនយ៉ាងនោះឡើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគមិនបានត្រាស់ចែក ព្រោះមិនមានការផ្សេងគ្នា ។

ពាក្យថា **ឱវិធាធិតា** សេចក្តីថា ពិតហើយ វេទនាទាំងអស់ ដោយអត្ថថា សោយអារម្មណ៍ ក៏មានតែម្យ៉ាងប៉ុណ្ណោះ តែដោយញែកទីអាស្រ័យ

ក៏មាន ២ យ៉ាង គឺវេទនាតាមផ្លូវកាយ និវេទនាតាមផ្លូវចិត្ត ។ មាន ៣ យ៉ាង គឺសុខវេទនា ទុក្ខវេទនា និងអទុក្ខមសុខវេទនា ដោយអំណាចកំណើត៤ មាន ៤ យ៉ាង ដោយអំណាចឥន្ទ្រិយ និងដោយអំណាចគតិមាន ៥ យ៉ាង ដោយអំណាចទ្វារ និងដោយអំណាចអារម្មណ៍មាន ៦ យ៉ាង ដោយការប្រកបជាមួយនឹងវិញ្ញាណធាតុ ៧ មាន ៧ យ៉ាង ដោយមានលោកធម៌ ៨ ជាបច្ច័យមាន ៨ យ៉ាង ដោយការចែកសុខជាដើម នីមួយៗចេញ ចេញជាអតីតជាដើមមាន ៩ យ៉ាង ។ វេទនាទាំងនោះឯង ដោយចែកជាខាងក្នុង និងខាងក្រៅ មាន ១៨ យ៉ាង ដោយចែកអារម្មណ៍ ៦ មានរូបជាដើម ចែកនីមួយៗ ជា ៣ តាមអំណាចនៃសុខជាដើម ក៏មាន ១៨ ដូចគ្នា អធិប្បាយថា ក្នុងរូបារម្មណ៍ សុខខ្ទះ ទុក្ខខ្ទះ អទុក្ខមសុខខ្ទះកើតឡើងក្នុងអារម្មណ៍ មានសទ្ទារម្មណ៍ជាដើម ក្រៅអំពីនេះក៏ដូចគ្នា ។ម្យ៉ាងទៀត ដោយអំណាចមនោបវិចារៈ ១៨ វេទនាក៏មាន ១៨ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា

ព្រោះឃើញនូវរូបដោយចក្ខុ ហើយពិចារណានូវរូប ដែលជាទីតាំងនៃសោមនស្ស ពិចារណានូវរូបដែលជាទីតាំងនៃទោមនស្ស ពិចារណានូវរូបដែលជាទីតាំងនៃឧបេក្ខា ឮសំឡេងដោយត្រចៀក ... ហិតក្លិនដោយច្រមុះ ... ជញ្ជក់នូវរសដោយអណ្តាត ...ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ពិចារណានូវធម្មារម្មណ៍

ដែលជាទីតាំងនៃសោមនស្ស ពិចារណានូវធម្មារម្មណ៍ ដែលជាទីតាំងនៃទោមនស្ស ពិចារណានូវធម្មារម្មណ៍ដែលជាទីតាំងនៃឧបេក្ខា ។

ដោយប្រការដូចពណ៌នាមកនេះ ទើបវេទនា មាន ១៨ ។ មួយ៉ាងទៀត វេទនាជា ៣៦ គឺគេហសិតសោមនស្ស ៦ គេហសិតទោមនស្ស ៦ គេហសិតឧបេក្ខា ៦ សោមនស្សជាដើមដែលអាស្រ័យនេក្ខម្មៈក៏ដូចគ្នា ។ វេទនា មាន ១០៨ គឺវេទនាក្នុងអតីត ៣៦ ក្នុងអនាគត ៣៦ ក្នុងបច្ចុប្បន្ន ៣៦ ក្នុងអធិការនៃវេទនានេះ គប្បីជ្រាបកាពដែលវេទនាមាន ២ យ៉ាងជាដើម ដូចពណ៌នាមកនេះ ។

បកិណ្ណកកថា ចប់

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **សមាហិតោ** សេចក្ដីថា ជាអ្នកមានចិត្តតាំងមាំដោយសមាធិ បែកប្រភេទជាឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **សមាហិតោ** នោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ការប្រកបរឿយៗ នូវសមថភាវនា ។ បទថា **សម្បជានោ** សេចក្ដីថា ដឹងច្បាស់ដោយប្រពៃ ដោយសម្បជញ្ញៈ ៤ ប្រការ មានសាត្ថកសម្បជញ្ញៈជាដើម ។ បទថា **សម្បជានោ** នោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ការប្រកបរឿយៗ នូវវិបស្សនា ។ បទថា **សតោ** សេចក្ដីថា ជាអ្នកតម្កល់សតិ ដោយបទថា **សតោ** នោះ ធម៌ទាំងឡាយ រមែងដល់នូវសេចក្ដីបរិបូណ៌ដោយភាវនា ដោយន័យនៃសមថៈ និងវិបស្សនា ។ ព្រះមាន

ព្រះភាគ ទ្រង់សម្តែងភាពជាអ្នកប្រកបព្រមដោយវិបស្សនានុយោគនោះ ។ បទថា **វេទនា ច បជានាតិ** សេចក្តីថា ពុទ្ធសាវកកាលកំណត់ដឹងដោយ បរិញ្ញា ៣ ក្នុងចំណែកខាងដើម ដោយចែកតាមសេចក្តីពិតថា វេទនាទាំងនេះ វេទនាមានប៉ុណ្ណេះ ដូច្នេះ និងដោយលក្ខណៈមានអនិច្ចលក្ខណៈជាដើមថា វេទនា មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតា ដូច្នេះហើយ ចម្រើន វិបស្សនា រមែងដឹងច្បាស់ ដោយការចាក់ធ្លុះ ដោយការកំណត់ដឹង ដោយ អរិយមគ្គ ។ បទថា **វេទនានញ្ច សម្ភវំ** បានដល់ សមុទយសច្ច ។ បទថា **យត្ថ ចេតា និរុជ្ឈន្តិ** សេចក្តីថា ដោយហេតុមានប្រមាណប៉ុណ្ណេះ វេទនា រមែងរលត់ទៅក្នុងទីណា ទីនោះ ជានិរោធសច្ច ។ បទថា **ខយគាមិនំ** ក្តាប់សេចក្តីថា ដឹងអរិយមគ្គដែលជាហេតុឲ្យដល់នូវការអស់ទៅនៃវេទនា ។ បទថា **វេទនានំ ខយា** សេចក្តីថា ព្រោះរម្ងត់ដោយមិនឲ្យកើតឡើង នៃវេទនាទាំងឡាយ ដោយអរិយមគ្គ ដែលចាក់ធ្លុះសច្ចៈទាំង ៤ ដូច្នេះ ។ បទថា **និច្ឆាតោ បរិនិព្វុតោ** សេចក្តីថា អស់នូវតណ្ហា គឺលះតណ្ហាបាន ជាបុគ្គលបរិនិព្វានហើយ ដោយកិលេសបរិនិព្វាន និងខន្ធបរិនិព្វាន ។

**អដ្ឋកថា បឋមវេទនាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទុតិយវេទនាសូត្រ

[ ៥៣ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះ មាន ៣ ។ វេទនា ៣ តើដូចម្តេច ។ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីឃើញនូវសុខវេទនា ថាជាទុក្ខ គប្បីឃើញនូវទុក្ខវេទនា ថាជាព្រួញ គប្បីឃើញនូវអទុក្ខមសុខវេទនា ថាជារបស់មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ ឃើញសុខវេទនា ថាជាទុក្ខ ឃើញទុក្ខវេទនា ថាជាព្រួញ ឃើញអទុក្ខមសុខវេទនា ថាជារបស់មិនទៀងហើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុប្រសើរ ឃើញត្រូវ ផ្តាច់បង់តណ្ហា ដោះស្រាយសំយោជនៈ ធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះយល់ច្បាស់នូវមានះដោយប្រពៃ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុណា បានឃើញសុខវេទនាថាជាទុក្ខ បានឃើញ
ទុក្ខវេទនាថាជាព្រួញ បានឃើញអទុក្ខមសុខវេទនា ជា
ទីស្ងប់នោះ ថាជារបស់មិនទៀង ភិក្ខុនោះឯង ឃើញ
( វេទនាទាំង ៣ ) ដោយប្រពៃ រមែងរួចស្រឡះក្នុង
វេទនា ដោយការសង្រួមកាយ វាចា ចិត្ត ភិក្ខុនោះឯង
មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ ព្រោះត្រាស់ដឹង ជា
អ្នកស្ងប់រម្ងាប់ ជាមុនីកន្លងផុតនូវយោគៈ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## ទុតិយវេទនាសូត្រ

[ ៥៣ ] ក្នុងទុតិយវេទនាសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ទុក្ខតោ ទដ្ឋព្វា** សេចក្តីថា សុខវេទនាគប្បីឃើញដោយញាណ-ចក្ខុថា ជាទុក្ខ ដោយអំណាចនៃវិបរិណាមទុក្ខ ។ បទថា **សល្លតោ ទដ្ឋព្វា** សេចក្តីថា ទុក្ខវេទនាគប្បីឃើញថា ដូចជាព្រួញ ព្រោះភាពជាទុក្ខ ដោយអត្ថថា នាំចេញទៅបានលំបាក ព្រោះអត្ថថា ចាក់ដុះ និងព្រោះអត្ថថា បៀតបៀនខាងក្នុង ។ បទថា **អនិច្ចតោ** សេចក្តីថា អទុក្ខមសុខវេទនា គប្បីឃើញថា មិនទៀង ព្រោះមានហើយ ត្រឡប់ជាមិនមាន ព្រោះមានការកើតឡើងហើយ វិនាសទៅក្នុងទីបំផុត ព្រោះជារបស់មួងម្កាល និងព្រោះជារបស់ប្រឆាំងនឹងការទៀង ។

ក្នុងរឿងវេទនានេះ វេទនាទាំងអស់ ត្រូវឃើញជារបស់មិនទៀងក៏ពិតតែព្រះសាស្តា កាលទ្រង់សម្តែងអត្ថនេះថា ការឃើញទុក្ខ ជាគ្រឿងសម្គាល់នៃវិភគៈ ជាការត្រេកអរក្រៃលែងជាងការឃើញនូវការមិនទៀង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលគប្បីឃើញនូវសុខវេទនាថាជាទុក្ខ គប្បីឃើញ

នូវទុក្ខវេទនាថាជាព្រួញ ។ មួយវិញទៀត ព្រះមានព្រះភាគត្រាស់ពាក្យនេះយ៉ាងនោះ ក៏ដើម្បីឲ្យកើតនូវការនឿយណាយក្នុងសង្ខារទាំងឡាយ ដែលបុថុជ្ជនប្រកាន់មាំថាជាសុខ ។ ដោយពាក្យថា **ទុក្ខតោ** នោះ ព្រះមានព្រះភាគទ្រង់សំដែងដល់ភាពដែលសុខវេទនានោះថាជាទុក្ខ ព្រោះជាទុក្ខប្រចាំសង្ខារ ។ ព្រោះហេតុដែលសេចក្ដីសុខជាវិបរិណាមទុក្ខ ដោយព្រះបាលីថា ធម៌ណាមិនទៀង ធម៌នោះជាទុក្ខ ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ សុខវេទនាត្រូវឃើញដោយភាពជាទុក្ខ ដូច្នេះហើយ ព្រោះហេតុដែលទុក្ខវេទនាជាទុក្ខទុក្ខ សម្រាប់ជនទាំងឡាយ ដែលគិតថា សូម្បីសេចក្ដីសុខដែលមានសភាពដូច្នោះ សេចក្ដីទុក្ខនឹងខ្លាំងក្លាប៉ុនណា ដូច្នេះហើយ ទើបត្រាស់ថា ទុក្ខវេទនាត្រូវឃើញដូចជាព្រួញ។ តែកាលទ្រង់សំដែងថា វេទនាក្រៅពីនេះជាទុក្ខ ព្រោះជាសង្ខារទុក្ខនោះឯង ទើបត្រាស់ថា អទុក្ខមសុខវេទនាត្រូវឃើញដោយភាពជារបស់មិនទៀង ដូច្នេះ ។

មួយវិញទៀត បណ្ដាពាក្យទាំងនោះ ដោយពាក្យនេះថា សុខវេទនាត្រូវឃើញដោយភាពជាទុក្ខនេះ ព្រះមានព្រះភាគទ្រង់សំដែងដល់ឧបាយ សម្រាប់ដកនូវរាគៈ ព្រោះថា រាគានុស័យដេកត្រាំ ព្រោះសុខវេទនា ។ ដោយពាក្យនេះថា ទុក្ខវេទនាត្រូវឃើញដូចព្រួញនេះ ព្រះមានព្រះភាគទ្រង់សំដែងឧបាយសម្រាប់ដកនូវទោសៈ ព្រោះបដិឃានុស័យដេកត្រាំ ព្រោះទុក្ខវេទនា ។ ដោយពាក្យនេះថា អទុក្ខមសុខវេទនា ត្រូវឃើញដោយការមិនទៀងនេះ ព្រះមានព្រះភាគទ្រង់សំដែងឧបាយសម្រាប់ដកនូវមោហៈ ព្រោះថា អវិជ្ជានុស័យ

ដេកត្រាំ ព្រោះអទុក្ខមសុខវេទនា ។

ទំនងដូចគ្នានោះដែរ ព្រះមានព្រះភាគ ទ្រង់សម្ដែងការលះសង្កិលេស គឺតណ្ហា ដោយពុទ្ធវចនៈដំបូង ព្រោះសង្កិលេស គឺតណ្ហានោះ ជាហេតុឲ្យពេញចិត្តក្នុងសុខ ទ្រង់សម្ដែងការលះសង្កិលេស គឺទុច្ចរិត ដោយពុទ្ធវចនៈបទទី ២ ព្រោះថា សត្វទាំងឡាយ មិនដឹងនូវទុក្ខតាមសេចក្ដីពិត ទើបប្រព្រឹត្តទុច្ចរិត ដើម្បីដោះស្រាយនូវទុក្ខនោះ ។ ទ្រង់សម្ដែងការលះសង្កិលេស គឺទិដ្ឋិ ដោយព្រះពុទ្ធវចនៈបទទី ៣ ព្រោះបុគ្គលដែលឃើញអទុក្ខមសុខ ដោយការមិនទៀង មិនមានសង្កិលេស គឺទិដ្ឋិ ។ ម្យ៉ាងទៀត ទ្រង់សម្ដែងអទុក្ខមសុខវេទនាថាជាគ្រឿងសម្គាល់នៃអវិជ្ជា ព្រោះភាពដែលសង្កិលេស គឺទិដ្ឋិជាគ្រឿងសម្គាល់នៃអវិជ្ជា ។ ម្យ៉ាងទៀត ដោយព្រះពុទ្ធវចនៈដំបូង ទ្រង់សម្ដែងដល់ការកំណត់ដឹងវិបរិណាមទុក្ខ ។ ដោយបទទី ២ ទ្រង់សម្ដែងដល់សេចក្ដីកំណត់ដឹងនូវទុក្ខទុក្ខ ។ បទទី ៣ ទ្រង់សម្ដែងដល់ការកំណត់ដឹងសង្ខារទុក្ខ ។ ម្យ៉ាងទៀត ដោយព្រះពុទ្ធវចនៈដំបូង ទ្រង់សម្ដែងដល់ការកំណត់ដឹងឥដ្ឋារម្មណ៍ ។ ពុទ្ធវចនៈបទទី ២ ទ្រង់សម្ដែងដល់ការកំណត់ដឹងអនិដ្ឋារម្មណ៍ ។ ដោយពុទ្ធវចនៈបទទី ៣ ទ្រង់សម្ដែងដល់ការកំណត់ដឹងដោយមជ្ឈត្តារម្មណ៍ ព្រោះថា កាលប្រាសចាកតម្រេកក្នុងធម្មារម្មណ៍ទាំងនោះហើយ សូម្បីអារម្មណ៍ទាំងឡាយ ក៏ជាការប្រាសចាកតម្រេកផងដែរ ។ គប្បីជ្រាបដូច ពណ៌នាមកនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ការរួចផុតដោយមិនមានទីតាំង ដោយទុក្ខានុបស្សនាដែលទ្រង់សម្ដែងហើយ ដោយការកំណត់ការលះភគៈជាបទដំបូង ។

ការរួចផុតដោយមិនមាននិមិត្ត ដោយអនិច្ចានុបស្សនា ដែលទ្រង់សម្តែងហើយដោយការកំណត់ការលះទោសៈជាប្រការទី ២ ។ ការរួចផុតដោយជារបស់ទទេ ដោយអនត្តានុបស្សនា ឈ្មោះថា ទ្រង់សម្តែងហើយដោយកំណត់ការលះមោហៈជាប្រកាទី ៣ ។

បទថា **យតោ** ស្មើគ្នានឹង **យទា** ឬ **យស្មា ។** បទថា **អរិយោ** សេចក្តីថា ជាអ្នកនៅឆ្ងាយចាកកិលេសទាំងឡាយ គឺជាអ្នកបរិសុទ្ធ ។ បទថា **សម្មទ្ទសោ** សេចក្តីថា មានប្រក្រតីឃើញវេទនាទាំងឡាយ ឬអរិយសច្ចទាំង ៤ មិនខុសក្លាំងក្លាត់ ។ បទថា **អច្ឆេច្ឆិ តណ្ហំ** សេចក្តីថា កាត់តណ្ហាដែលមានវេទនាជាឫសគល់ ដោយមគ្គខាងចុង បានដល់ កាត់ផ្តាច់ដោយមិនមានសល់ ។ បទថា **វិវត្តយិ សំយោជនំ** សេចក្តីថា បង្វិលសំយោជនៈ ១០ ទៅដោយជុំវិញ គឺធ្វើឲ្យមិនមានមូល ។ បទថា **សម្មា** បានដល់ ដោយហេតុ គឺដោយការណ៍ ។ បទថា **មានាភិសមយា** សេចក្តីថា ព្រោះត្រាស់ដឹងដោយការឃើញ ឬព្រោះត្រាស់ដឹងដោយការលះនូវមានះ ដោយបហាន ។ អធិប្បាយថា អរហត្តមគ្គ ឃើញនូវមានះដោយអំណាចនៃកិច្ច នេះជាការលះមានះ ដោយការឃើញនូវមានះនោះ ។ ចំណែកមានះដែលជាសត្រូវ ក៏ត្រូវអរិយមគ្គលះបានផងដែរ ដូចជីវិតរបស់សត្វដែលត្រូវឃើញហើយ តែងលះបានដោយពិសដែលឃើញហើយ នេះជាការលះមានះដោយបហាននោះ ។ បទថា **អន្តមកាសិ ទុក្ខស្ស** សេចក្តីថា ព្រះអរិយសាវកបានធ្វើទីបំផុត ពោលគឺចំណុច បានដល់ ទីបំផុតនៃចុងផ្លូវរបស់វដ្តទុក្ខទាំងអស់ ព្រោះភាពនៃមានះ

ដែលព្រះអរិយៈឃើញហើយ និងលះបានហើយដោយអរហត្តមគ្គ ដោយប្រការដូច្នេះ ។ មានអធិប្បាយថា បានធ្វើទុក្ខឲ្យសល់ត្រឹមតែរាងកាយក្នុងជាតិចុងក្រោយ ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **យោ** បានដល់ អរិយសាវកណា ។ បទថា **អទ្ទ** ប្រែថា បានឃើញហើយ អធិប្បាយថា ឃើញសុខវេទនាថាជាទុក្ខ ។ ពិតហើយ សុខវេទនា ដូចភោជនដែលលាយដោយថ្នាំពិស ក្នុងកាលបរិភោគ នឹងឲ្យនូវការឆ្ងាញ់ ក្នុងកាលប្រែប្រួលទៅ រមែងជាទុក្ខតែម្យ៉ាង ។ បទថា **ទុក្ខមទ្ទក្ខិ សល្លតោ** សេចក្តីថា ទុក្ខវេទនាកាលកើតឡើងក្តី ដល់នូវឋិតិក្ខណៈក្តី បែកធ្លាយក្តី រមែងបៀតបៀនទាំងអស់ ដូចព្រួញកំពុងដោតចូលសរីរៈក្តី ឈប់ក្តី កំពុងដកចេញក្តី តែងឲ្យកើតនូវការឈឺចាប់ទាំងអស់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ឃើញទុក្ខនោះថាដូចជាព្រួញ ។ បទថា **អទក្ខិ ឆំ អនិច្ចតោ** សេចក្តីថា ឃើញអទុក្ខមសុខវេទនាដែលកើតឡើងល្អិតជាង ព្រោះជាសភាវៈដែលល្អិតជាងសុខ និងទុក្ខ ដោយភាពមិនទៀង ព្រោះមានការមិនទៀងជាទីបំផុត ។ បទថា **សវេ សម្មទ្ទសោ** សេចក្តីថា ព្រះអរិយសាវកនោះឯង មានប្រក្រតីឃើញវេទនាទាំង ៣ ថាជាទុក្ខជាដើម ដោយពាល់ត្រូវពិត ។ បទថា **យតោ** ស្មើគ្នានឹង **យស្មា** ប្រែថា ព្រោះហេតុណា ។ បទថា **តត្ថ** ប្រែថា ក្នុងវេទនា ។ បទថា **វិមុច្ចតិ** សេចក្តីថា រមែងរួចផុតដោយអំណាចនៃសមុច្ឆេទ-វិមុត្តិ ។ មានពាក្យអធិប្បាយដូច្នេះថា ព្រោះលោកឃើញសុខជាដើម ដោយ

ភាពជាទុក្ខជាដើម ដូច្នោះ ទើបលោករួចផុតក្នុងវេទនានោះ ដោយអំណាចនៃការកាត់ផ្តាច់ ព្រោះលះឆន្ទរាគៈ ទាក់ទងដោយវេទនានោះ ព្រោះថា កាលពោលដល់ **យំ** សត្វ ក៏គួរនាំយក **តំ** សត្វ មកពោលផង ។

ម្យ៉ាងទៀត បទថា **យតោ** សេចក្តីថា សង្រួមហើយ គឺមានខ្លួនរវាំងប្រយ័ត្នហើយ ដោយកាយ វាចា និងចិត្ត ម្យ៉ាងទៀត ព្រះអរិយសាវកឈ្មោះថា **យតោ** ព្រោះព្យាយាម គឺផ្តើមតាំងសេចក្តីព្យាយាម អធិប្បាយថាជាប់បន្តគ្នា ។ បទថា **អភិញ្ញាវោសិតោ** សេចក្តីថា ស្រេចអស់ហើយ គឺធ្វើកិច្ចស្រេចហើយដោយអភិញ្ញា ៦ ព្រោះចម្រើនកម្មដ្ឋាន មានសច្ចៈ ៤ ជាអារម្មណ៍ ដោយមានវេទនាជាគោល ។ បទថា **សន្តោ** បានដល់ ស្ងប់ហើយ ដោយការស្ងប់កិលេស មានរាគៈជាដើម ។ បទថា **យោគាតិគោ** សេចក្តីថា ព្រះយោគាវចរឈានកន្លងនូវយោគៈទាំង ៤ យ៉ាង មានកាមយោគៈជាដើម ឈ្មោះថា **មុនី** ព្រោះដឹងប្រយោជន៍ទាំង ២ យ៉ាង ។□

**អដ្ឋកថា ទុតិយវេទនាសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមឯសនាសូត្រ

[ ៥៤ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះ មាន ៣ ។ ការស្វែងរក ៣ តើដូចម្តេច ។ គឺការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរក មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សាវ័កនៃព្រះពុទ្ធ មានចិត្តតម្កល់មាំ មានសម្បជញ្ញៈ
មានសតិ ដឹងច្បាស់នូវការស្វែងរកទាំងឡាយផង នូវ
ទីកើតនៃការស្វែងរកទាំងឡាយផង ការស្វែងរកទាំងនុ៎ះ
រលត់ទៅ ក្នុងទីណា ក៏ដឹងច្បាស់នូវទីនោះផង នូវមគ្គ
ជាដំណើរទៅកាន់ទីអស់ទៅ នៃការស្វែងរកផង ភិក្ខុ
អស់ទៅនៃតណ្ហា តែងបរិនិព្វាន ព្រោះអស់ទៅនៃការ
ស្វែងរកទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## បឋមឯសនាសូត្រ

ក្នុងបឋមឯសនាសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៥៤ ] ការស្វែងរក គឺការស្វះស្វែង បានដល់ ការត្រិះរិះរក ឈ្មោះថា **ឯសនា** ។ ដើម្បីទ្រង់សម្ដែងការស្វែងរកទាំងនោះ ដោយចែកចេញទៅ ទើបត្រាស់ពាក្យជាដើមថា **កាមេសនា**។

បណ្ដាបទទាំងនោះ បទថា **កាមេសនា** គឺការស្វែងរកកាម ឬការស្វែងរក ពោល គឺកាម ឈ្មោះថា **កាមេសនា** ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ថា

> បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្ដេច សេចក្ដីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ តម្រេកក្នុងកាមទាំងឡាយ សេចក្ដីស្រើបស្រាលក្នុងកាមទាំងឡាយ សេចក្ដីស្នេហាក្នុងកាមទាំងឡាយ សេចក្ដីអន្ទះអន្ទែងក្នុងកាមទាំងឡាយ សេចក្ដីជ្រប់ក្នុងកាមទាំងឡាយ សេចក្ដីចុះចិត្តស៊ប់ក្នុងកាមណា នេះហៅថា ការស្វែងរកកាម ។

ព្រោះដូច្នោះ កាមរាគៈគប្បីជ្រាបថា ជាកាមឯសនា សូម្បីក្នុងភវេសនា គឺការស្វែងរកភព ក៏មានន័យដូចគ្នា ។ សមដូចព្រះតម្រាស់ដែលត្រាស់ថា

> បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្ដេច ។ សេចក្ដីពេញចិត្តនឹងភព ក្នុងភពទាំងឡាយ ។បេ។ សេចក្ដីជ្រប់

ក្នុងភពណា នេះហៅថា ការស្វែងរកភព ។

ព្រោះដូច្នោះ តម្រេកក្នុងការស្វែងរក គឺការប្រាថ្នារូបភព និងអរូបភព គប្បីជ្រាបថា **ភវេសនា** ។ ការស្វែងរកព្រហ្មចរិយៈ ឈ្មោះថា **ព្រហ្មចរិ-យេសនា** ដូចព្រះតម្រាស់ត្រាស់ថា

បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុស មានសភាពយ៉ាងនេះណា ដូច្នេះថា លោកទៀងខ្លះ ថា លោកមិនទៀងខ្លះ ។បេ។ ថា សត្វ ខាងមុខអំពីសេចក្ដីស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។

ព្រោះដូច្នោះ ការស្វែងរកព្រហ្មចរិយៈដែលសន្មតថាជាទិដ្ឋិ គប្បីជ្រាបថា បានដល់ ការស្វែងរកទិដ្ឋិព្រហ្មចរិយៈ ដោយហេតុត្រឹមប៉ុណ្ណោះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់សម្ដែងរាគៈ និងទិដ្ឋិ ថាជាឯសនា ។

មិនមែនត្រឹមតែរាគៈ និងទិដ្ឋិតែម្យ៉ាងនោះទេ ដែលទ្រង់សម្ដែងថាជាឯសនា សូម្បីកម្មដែលតាំងនៅក្នុងទីតែមួយជាមួយរាគៈ និងទិដ្ឋិនោះ ក៏ទ្រង់សម្ដែងថា ជាឯសនា សូម្បីព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះថា

បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកកាម តើដូចម្ដេច ។ សេចក្ដីត្រេកអរក្នុងកាម កាយកម្ម វចីកម្ម មនោកម្ម ជាអកុសលដែលតាំងនៅក្នុងទីជាមួយគ្នានឹងសេចក្ដីត្រេកអរក្នុងកាមនោះ នេះ

ហៅថា ការស្វែងរកកាម ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកភព តើដូចម្ដេច ។ សេចក្ដីត្រេកអរក្នុងភព កាយកម្ម វចីកម្ម មនោកម្ម ជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នា នឹងសេចក្ដីត្រេកអរក្នុងភពនោះ នេះហៅថា ការស្វែងរកភព ។ បណ្ដាការស្វែងរកទាំង ៣ នោះ ការស្វែងរកព្រហ្មចរិយៈ តើដូចម្ដេច ។ អន្តគ្គាហិកទិដ្ឋិ ( ទិដ្ឋិដែលកាន់យកនូវទីបំផុត ) កាយកម្ម វចីកម្ម មនោកម្ម ជាអកុសល ដែលតាំងនៅក្នុងទីជាមួយគ្នា នឹងអន្តគ្គាហិកទិដ្ឋិនោះ នេះហៅថា ការស្វែងរកព្រហ្មចរិយៈ ។ គប្បីជ្រាបឯសនា ៣ យ៉ាងនេះ ដូចពណ៌នាមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ ធម៌ទាំងឡាយ មានអវិជ្ជាជាដើម និងតណ្ហា ដែលជាហេតុនៃការកើតឡើងនៃឯសនា ឈ្មោះថា **សមុទយា** ក្នុងពាក្យថា **សមុទយា** នេះ អធិប្បាយថា បានដល់ សមុទយៈ ។ បទថា **យត្ថ ចេតា និរុជ្ឈន្តិ** សេចក្ដីថា ព្រហ្មចរិយេសនា រមែងរលត់ទៅដោយបឋមមគ្គ កាមេសនា រមែងរលត់ទៅដោយអនាគាមិមគ្គ ភវេសនា រមែងរលត់ទៅដោយអរហត្តមគ្គ គប្បីជ្រាបតាមដែលពណ៌នាមកនេះ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថាបឋមឯសនាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយឯសនាសូត្រ

[ ៥៥ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះ មាន ៣ ។ ការស្វែងរក ៣ តើដូចម្តេច ។ គឺការស្វែងរកកាម ១ ការស្វែងរកភព ១ ការស្វែងរកព្រហ្មចរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ការស្វែងរកកាម ការស្វែងរកភព និងការស្វែងរក
ព្រហ្មចរិយៈ ដែលជាទីស្ទាបអង្អែល ថាជារបស់ពិត
ជាទីតាំងនៃទិដ្ឋិ ជាទីដុះដាលនៃកិលេស ការស្វែងរក
របស់ភិក្ខុ អ្នកប្រាសចាកសេចក្តីត្រេកអរទាំងពួង ផុត
ស្រឡះ ព្រោះអស់តណ្ហា បានលះបង់ហើយ ទាំង
ហេតុជាទីតាំងនៃទិដ្ឋិ ក៏បានដកចោលហើយ ភិក្ខុមិនមាន
សេចក្តីប្រាថ្នា មិនមានសេចក្តីងឿងឆ្ងល់ ព្រោះអស់
ទៅនៃការស្វែងរកទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## ទុតិយឯសនាសូត្រ

ក្នុងទុតិយឯសនាសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៥៥ ] បទថា **ព្រហ្មរិយេសនា សហ** សេចក្តីថា មួយអន្លើដោយការស្វែងរកព្រហ្មចរិយៈ ។ សព្ទថា **ព្រហ្មចរិយេសនា** នេះ ជាសព្ទនិទ្ទេសដោយការលុបវិភត្តិចេញ ម្យ៉ាងទៀត បទថា **ព្រហ្មចរិយេសនា** នេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ មានពាក្យអធិប្បាយដូចតទៅនេះថា កាមេសនា ភវេសនា រួមគ្នាជាព្រហ្មចរិយេសនា ទើបជាឯសនា ៣ យ៉ាង ។ ក្នុងបណ្តាឯសនាទាំងនោះ ដើម្បីសម្តែងព្រហ្មចរិយេសនាដោយសរុប ទើបព្រះមានព្រះភាគត្រាស់ ពាក្យនេះទុកថា **ឥតិ សច្ចបរាមាសោ ទិដ្ឋិដ្ឋានា សមុស្សយា** ដែលជាទីស្ទាបអង្អែលថាជារបស់ពិត ជាទីតាំងនៃទិដ្ឋិ ជាទីផុះដាលនៃកិលេស ដូច្នេះ ។

ពាក្យនោះ មានអធិប្បាយដូច្នេះ ការប្រកាន់មាំថា វត្ថុនេះ ពិតយ៉ាងនោះ ដោយប្រការយ៉ាងនេះ ឈ្មោះថា **ឥតិ សច្ចបរាមាសោ** ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់សម្តែងអាការ គឺការប្រព្រឹត្តទៅនៃទិដ្ឋិថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃមិនពិត ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិដ្ឋានា** ព្រោះជាហេតុនៃការមិនមានប្រយោជន៍គ្រប់យ៉ាង សមដូចព្រះមានព្រះភាគ ត្រាស់ក្នុងអង្គុត្តរនិកាយ ឯកនិបាតថា ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ដូច្នេះ ។ និងមានពាក្យអធិប្បាយថា មិច្ឆាទិដ្ឋិទាំងនោះឯង

ទាំងដែលចម្រើនក្រៃលែងឡើងៗ ទាំងជាទីកើតឡើង ដោយជាទីកើតនៃកិលេស មានលោភៈជាដើម ទិដ្ឋិទាំងឡាយ ដែលប្រកាន់ខុសថា វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃ ដូច្នេះ ទាំងជាហេតុនៃការមិនជាប្រយោជន៍គ្រប់យ៉ាង ទាំងជាហេតុនៃការបង្កនូវទុក្ខ គឺកិលេស ទើបឈ្មោះថា **ព្រហ្ម-ចរិយេសនា** ។ ដោយបទនៃព្រះគាថាថា ដែលជាទីស្ទាបអង្អែលថាជារបស់ពិត ជាទីតាំងនៃទិដ្ឋិ ជាទីដុះដាលនៃកិលេស នេះគប្បីជ្រាបថា ឈ្មោះថាទ្រង់សម្តែងព្រហ្មចរិយេសនាហើយ ដោយអាការនៃការប្រព្រឹត្តទៅ និងដោយការសម្រេច ។ បទថា **សព្វរាគវិរត្តស្ស** សេចក្តីថា បុគ្គលដែលប្រាសចាកតម្រេក អំពីចាកកាមរាគៈ និងភវរាគៈទាំងពួង ។ បន្ទាប់អំពីនោះទៅ ទើបព្រះអរហន្ត ឈ្មោះថា ជាអ្នករួចផុត ព្រោះធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះបង្អោនទៅក្នុងព្រះនិព្វាន ពោល គឺធម៌ជាទីអស់ទៅនៃតណ្ហា ។ បទថា **ឯសនា បដិនិស្សដ្ឋា** សេចក្តីថា កាមេសនា និងភវេសនា ឈ្មោះថា លោករលាស់ចេញហើយ គឺលះហើយ ដោយប្រការទាំងពួង ។ បទថា **ទិដ្ឋិដ្ឋានា សមូហតា** សេចក្តីថា ជាទីតាំងនៃទិដ្ឋិ ពោល គឺព្រហ្ម-ចរិយេសនា នឹងត្រូវដកឡើងដោយបឋមមគ្គនោះឯង ។ បទថា **ឯសនានំ ខយា** សេចក្តីថា ព្រោះអស់ទៅ គឺព្រោះរលត់ទៅដោយមិនកើតឡើងនៃការស្វែងរកទាំង ៣ យ៉ាងនេះ ត្រាស់ហៅថា ភិក្ខុ ព្រោះទម្លាយកិលេសបានហើយ ត្រាស់ហៅថា **និរាសោ** ព្រោះមិនមានការសង្ឃឹម ដោយប្រការទាំងពួង និងត្រាស់ហៅថា **អកថំកថី** ព្រោះលះនូវការពោលពាក្យថា ដូចម្តេច ។

ដោយការសង្ស័យ ដែលជាទិដ្ឋិបានហើយ ។□

**អដ្ឋកថា ទុតិយឯសនាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអាសវសូត្រ

[ ៥៦ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះ មាន ៣ ។ អាសវៈ ៣ តើដូចម្តេច ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សាវកនៃព្រះពុទ្ធ មានចិត្តតម្កល់មាំ មានសម្បជញ្ញៈ
មានសតិ ដឹងច្បាស់នូវអាសវៈទាំងឡាយផង នូវទី
កើតនៃអាសវៈទាំងឡាយផង អាសវៈទាំងនោះ រលត់
ទៅក្នុងទីណា ក៏ដឹងច្បាស់នូវទីនោះផង នូវមគ្គជាដំណើរ
ទៅកាន់ទីអស់ទៅ នៃអាសវៈផង ភិក្ខុមិនមានសេចក្តី
ប្រាថ្នា តែងបរិនិព្វាន ព្រោះអស់អាសវៈទាំងឡាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## បឋមអាសវសូត្រ

ក្នុងបឋមអាសវសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៥៦ ] អាសវៈ ក្នុងកាមទាំងឡាយ ឈ្មោះថា **កាមាសវោ** ម្យ៉ាងទៀត អាសវៈ ពោល គឺកាម ឈ្មោះថា **កាមាសវោ** តែដោយអត្ថ កាមរាគៈ និងការត្រេកអរក្រៃលែង ក្នុងរូបជាដើម ឈ្មោះថា **កាមសវោ** ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព សេចក្តីប្រាថ្នាក្នុងឈាន រាគៈដែលសហគតៈដោយទិដ្ឋិ និងសេចក្តីប្រាថ្នាក្នុងភព ឈ្មោះថា **ភវាសវោ** ។ អវិជ្ជានោះឯង ឈ្មោះថា **អវិជ្ជាសវោ** ។

ក្នុងបទថា **អាសវានញ្ច សមុទ្ទយំ** នេះ អយោនិសោមនសិការ និងកិលេសទាំងឡាយ មានអវិជ្ជាជាដើម ឈ្មោះថា ជាហេតុកើតនៃអាសវៈទាំងឡាយ ។ សមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ក្នុងសព្វាសវសំវរសូត្រថា

ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយខុសទំនង អាសវៈទាំងឡាយ ដែលមិនទាន់កើតឡើង រមែងកើតឡើងបានផង អាសវៈទាំងឡាយដែលកើតឡើងហើយ រឹងរឹតតែចម្រើនឡើងផង ដូច្នេះ ។

និងក្នុងសូត្រដែលត្រាស់ក្នុង ( ឥតិវុត្តកៈ ) ថា

ម្នាលភិក្ខុទាំងឡាយ អវិជ្ជាជាប្រធានដើម្បីចូលប្រទះ នូវអកុសល-

ធម៌ទាំងឡាយ អហិរិកៈ និងអនោត្តប្បៈកើតតាមក្រោយ ដូច្នេះ ។

បទថា **មគ្គញ្ច ១យតាមិនំ** សេចក្តីថា ឈ្មោះថា អរិយមគ្គដែលជាហេតុឲ្យដល់នូវធម៌ ជាទីអស់ទៅនៃអាសវៈផង ។ បណ្តាអាសវៈទាំងនោះ កាមាសវៈ លះបានដោយអនាគាមិមគ្គ ភវាសវៈ និងអវិជ្ជាសវៈ លះបានដោយអរហត្តមគ្គ ។ តែអាចារ្យពួកខ្លះពោលថា សូម្បីកាមាសវៈ ក៏ត្រូវមគ្គខាងចុងសម្លាប់ ដូចកាមុបាទាន ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា បឋមអាសវសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយអាសវសូត្រ

[ ៥៧ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះ មាន ៣ ។ អាសវៈ ៣ តើដូចម្តេច ។ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា មានកាមាសវៈអស់ហើយ មានអវិជ្ជាសវៈ
អស់ហើយ មានភវាសវៈអស់ហើយ មានចិត្តផុតស្រឡះ

ហើយ មិនមានឧបធិ បុគ្គលនោះ ឈ្មោះមារ ព្រម
ទាំងវាហនៈ ទ្រទ្រង់នូវកាយជាទីបំផុត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## ទុតិយអាសវសូត្រ

[ ៥៧ ] ក្នុងទុតិយអាសវសូត្រទី ៨ មិនមានពាក្យដែលមិនធ្លាប់ពោលមកអំពីមុន ។៚

**អដ្ឋកថា ទុតិយអាសវសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## តណ្ហាសូត្រ

[ ៥៨ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហានេះ មាន ៣ ។ តណ្ហា ៣ តើដូចម្តេច ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់

សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ជនទាំងឡាយប្រកបហើយ ព្រោះប្រកបដោយតណ្ហា
មានចិត្តត្រេកអរ ក្នុងភពតូច និងភពធំ ជនទាំងនោះ
ឈ្មោះថា ប្រកបដោយយោគៈ ពោល គឺអន្ទាក់នៃមារ
មិនក្សេមចាកយោគៈ សត្វទាំងឡាយ នៅមានដំណើរ
ទៅកាន់ជាតិ និងមរណៈ តែងទៅកាន់សង្សារ ចំណែក
ពួកសត្វណា លះបង់តណ្ហាបានហើយ សត្វទាំងនោះ
ឈ្មោះថា ប្រាសចាកតណ្ហាក្នុងភពតូច និងភពធំ ពួក
សត្វណា បានដល់នូវការអស់អាសវៈក្នុងលោកសត្វ
ទាំងនោះឯង ឈ្មោះថា បានដល់នូវត្រើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## តណ្ហាសូត្រ

ក្នុងតណ្ហាសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៥៨ ] កិលេសជាត ឈ្មោះថា តណ្ហា ព្រោះអត្ថថា ចង់បាន ។ ម្យ៉ាងទៀត ឈ្មោះថា តណ្ហា ព្រោះប្រាថ្នាចំពោះអារម្មណ៍ មានរូបជាដើម

ឥឡូវនេះ ដើម្បីសម្ដែងចែកតណ្ហានោះ ទើបត្រាស់ពាក្យជាដើមថា **កាម-តណ្ហា** ដូច្នេះ ។

បណ្ដាតណ្ហាទាំង ៣ នោះ រាគៈដែលប្រកបទៅដោយបញ្ចកាមគុណ ឈ្មោះថា **កាមតណ្ហា** ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព ការប្រាថ្នាក្នុងឈាន រាគៈដែលសហគតៈដោយសស្សតទិដ្ឋិ និងការប្រាថ្នាដោយអំណាចភវរាគៈ ឈ្មោះថា **ភវតណ្ហា** ។ រាគៈដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។ម្យ៉ាងទៀត តណ្ហាដ៏សេស វៀរតណ្ហា ២ យ៉ាងខាងក្រោយ ឈ្មោះថា **កាមតណ្ហា** ទាំងអស់ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ក្នុងវិភង្គថា

> តណ្ហាទាំង ៣ នោះ ភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើដោយភវទិដ្ឋិ នេះហៅថា ភវតណ្ហា ។ បណ្ដាតណ្ហា ទាំង ៣ នោះ វិភវតណ្ហា តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត ប្រព្រឹត្តទៅមួយអន្លើដោយឧច្ឆេទទិដ្ឋិ នេះហៅថា វិភវតណ្ហា ។ តណ្ហាដ៏សេស ឈ្មោះថា កាមតណ្ហា ។

តណ្ហាទាំង ៣ នេះ តណ្ហានីមួយៗ ចែកជា ៦ ដោយប្រភេទអារម្មណ៍ គឺរូបតណ្ហា ។បេ។ ទើបធម្មតណ្ហា ជាតណ្ហា ១៨ យ៉ាង តណ្ហាទាំងនោះរួមជា ៣៦ គឺតណ្ហាក្នុងរូបខាងក្នុងជាដើម ១៨ តណ្ហាក្នុងរូបខាងក្រៅជាដើម ១៨ ដូច្នោះ ទើបរួមជាតណ្ហា ១០៨ ដោយចែកជាអតីត ៣៦ អនាគត ៣៦

បច្ចុប្បន្ន ៣៦ តែតណ្ហានោះ កាលធ្វើនូវការសង្គ្រោះ ដោយមិនទាក់ទងនឹងការចែកប្រភេទតាមកាលទាំង ៣ ក៏មាន ៣៦ ប៉ុណ្ណោះឯង កាលមិនធ្វើការចែករូប ( តណ្ហា ) ជាដើម ចែកចេញជាខាងក្នុង ខាងក្រៅ ក៏មាន ១៨ ប៉ុណ្ណោះ កាលធ្វើត្រឹមតែការចែកតាមអារម្មណ៍ មានរូបជាដើម ក៏សល់ ៦ ប៉ុណ្ណោះ តណ្ហាទាំងនោះ កាលចាត់ដោយមិនធ្វើការចែកទៅតាមអារម្មណ៍ ក៏មានត្រឹម ៣ ប៉ុណ្ណោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **តណ្ហាយោគេន** សេចក្តីថា ដោយគ្រឿងចង គឺតណ្ហា ដោយគ្រឿងចង គឺកាម និងដោយគ្រឿងចង គឺភព ។ ភ្ជាប់សេចក្តីដោយបទថា **សំយុត្តា** ។ ម្យ៉ាងទៀត បានដល់ ត្រូវប្រកបក្នុងភពជាដើម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **រត្តចិត្តា ភវាភវេ** ដូច្នេះ អធិប្បាយថា មានចិត្តជាប់ជំពាក់ហើយក្នុងភពតូច និងភពធំ ។ ម្យ៉ាងទៀត បទថា **ភវោ** បានដល់ សស្សតទិដ្ឋិ ។ បទថា **អភវោ** បានដល់ ឧច្ឆេទទិដ្ឋិ ព្រោះដូច្នោះ ជនទាំងនោះជាអ្នកមានចិត្តជាប់ជំពាក់ក្នុងភវាភវៈ គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្តែងភវតណ្ហា និងវិភវតណ្ហា ។ ក្នុងធម៌ចំណែកនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្តែងកាមតណ្ហាតែម្យ៉ាង ដោយបទនេះថា **តណ្ហាយោគេន** ដូច្នេះ ។ បទថា **តេ យោគយុត្តា មារស្ស** សេចក្តីថា បុគ្គលទាំងនោះ គឺបុគ្គលដូចដែលពោលមកនេះ ត្រូវប្រកបហើយ គឺត្រូវចងហើយដោយចំណង ពោល គឺអន្ទាក់នៃមារ ព្រោះថា រាគៈ ព្រះមានព្រះភាគ

ត្រាស់ថា ជាគ្រឿងចងរបស់មារ ជាអន្ទាក់របស់មារ ។ សមដូចមារក្រាបទូល ក្នុងសំយុត្តនិកាយ សគាថវគ្គថា

អន្ទាក់ គឺរាគៈណា ដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ខ្ញុំនឹងបៀតបៀនព្រះអង្គ ដោយអន្ទាក់នោះ បពិត្រព្រះសមណៈ ព្រះអង្គមិនរួច ( ចាកវិស័យ ) របស់ខ្ញុំឡើយដូច្នេះ ។

ពួកសត្វ ឈ្មោះថា ជាបុគ្គលមិនក្សេមចាកយោគៈ ព្រោះមិនទាន់បានសម្រេចនិព្វាន និងអរហត្ត ដែលឈ្មោះថា ជាដែនក្សេមចាកយោគៈ ព្រោះត្រូវយោគៈទាំង ៤ រាំង ឈ្មោះថា **ជនា** ព្រោះជាអ្នកកើតកិលេស និងអភិសង្ខារទាំងឡាយដែលជាប់តគ្នា ។ ឈ្មោះថា **សត្តា** ព្រោះជាប់ គឺជំពាក់ក្នុងរូបជាដើម និងទៅកាន់សង្សារ ពោល គឺការកើតឡើងបន្តៗ នៃខន្ធជាដើមដែលត្រាស់យ៉ាងនេះថា

លំដាប់នៃខន្ធ ធាតុ និងអាយតនៈទាំងឡាយ ដែលប្រព្រឹត្តទៅមិនដាច់ ហៅថា សង្សារ ។

គឺនឹងមិនផុតអំពីសង្សារនោះ ។ ព្រោះហេតុអ្វី ព្រោះប្រកបដោយចំណង គឺតណ្ហា ។ សត្វទាំងឡាយដែលដល់នូវជាតិ និងមរណៈ គឺជាអ្នកមានប្រក្រតីចូលដល់ការកើត និងការស្លាប់រឿយៗ នោះឯង ព្រះមានព្រះភាគកាលទ្រង់សម្តែងវដ្តៈ ដោយពាក្យមានប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិវដ្តៈ ទើបត្រាស់គាថាថា **យេ ច តណ្ហំ បហាត្វាន** ដូច្នេះ ។ ព្រះ

គាថានោះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម ។

**អដ្ឋកថា តណ្ហាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## មារធេយ្យសូត្រ

[ ៥៩ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ រមែងកន្លងនូវវិស័យនៃមារ រុងរឿងដូចព្រះអាទិត្យ ។ ប្រកបដោយធម៌ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ នេះឯង រមែងកន្លងនូវវិស័យនៃមារ រុងរឿងដូចព្រះអាទិត្យ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សីល សមាធិ និងបញ្ញា ទាំងអម្បាលនុ៎ះ ដែលបុគ្គល
ណា បានអប់រំល្អហើយ បុគ្គលនោះ រមែងកន្លងនូវ
វិស័យនៃមារ រុងរឿងដូចព្រះអាទិត្យ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់

ទុកហើយ ។ សូត្រទី ១០ ។

បឋមវគ្គ ចប់

ឧទ្ទាននៃបឋមវគ្គនោះ គឺ

និយាយអំពីមូល ១ ធាតុ ១ វេទនាពីរលើក ការ
ស្វែងរកពីរលើក អាសវៈ ពីរលើក តណ្ហា ១ វិស័យ
នៃមារ ១ លោកពោលថា បឋមវគ្គ ជាវគ្គដ៏ឧត្តម ។

# អដ្ឋកថា

## មារធេយ្យសូត្រ

[ ៥៩ ] ក្នុងមារធេយ្យសូត្រទី ១០ មានការកើតឡើងដូចម្តេច បានឮថា ថ្ងៃមួយ ព្រះបរមសាស្តា មានបរិស័ទដែលជាព្រះសេក្ខៈ ជាចំណែកច្រើនចោមរោមហើយ ប្រថាប់គន់គ្រួតមើលអធ្យាស្រ័យនៃបរិស័ទទាំងនោះកាលទ្រង់សរសើរអសេក្ខភូមិ ទើបត្រាស់ព្រះសូត្រនេះ ដើម្បីឲ្យកើតឧស្សាហ៍ក្នុងការសម្រេចគុណវិសេសដែលខ្ពស់ឡើង ។

បណ្តាបទទាំងនោះ ក្នុងបទថា **អតិក្កម្ម** ជាដើម មានសេចក្តីសង្ខេបដូចតទៅនេះ ( ភិក្ខុប្រកបដោយធម៌ ៣ ) នឹងរុងរឿងឈានកន្លង គឺឈានរំលង បានដល់ គ្របសង្កត់អន្ទាក់នៃមារ គឺអារម្មណ៍ បានដល់ វិស័យ គឺ

ឋានៈ ជាទីតាំងនៃឥស្សរិយៈរបស់មារ ដូចព្រះអាទិត្យ ព្រះអាទិត្យដែលផុតចាកការងងឹត គឺពពកជាដើម ប្រកបដោយគុណសម្បត្តិ ៣ ប្រការ គឺឫទ្ធិ ១ អានុភាព ១ និងតេជៈរបស់ខ្លួន ១ ផ្សាយឡើងកាន់នភាកាស រុងរឿងភ្លឺស្វាង បញ្ចេញពន្លឺ គ្របសង្កត់ កម្ចាត់ងងឹតដែលនៅក្នុងអាកាសទាំងអស់យ៉ាងណា ភិក្ខុដែលជាព្រះខីណាស្រព ក៏ដូច្នោះដូចគ្នា ប្រកបដោយគុណ ៣ ប្រការ ផុតចាកឧបក្កិលេសគ្រប់យ៉ាង រមែងរុងរឿងគ្របសង្កត់ប្រព្រឹត្តទៅនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ពោល គឺទីតាំងនៃមារ ដូច្នេះឯង ។

ធម៌ ឈ្មោះថា **សេក្ខ** ក្នុងបទថា **អសេក្ខេន** នេះ ព្រោះកើតហើយក្នុងសិក្ខាទាំងឡាយ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយ ឈ្មោះថា **សេក្ខ** ព្រោះធម៌ទាំងនេះជារបស់ព្រះសេក្ខៈ ៧ ពួក ។ ម្យ៉ាងទៀត ឈ្មោះថា **សេក្ខ** ព្រោះកំពុងសិក្សាដោយខ្លួនឯងនោះឯង ដោយនៅសិក្សាមិនទាន់សម្រេច បានដល់ មគ្គធម៌ និងផលធម៌ខាងក្រោម ៣ យ៉ាង តែអគ្គផលធម៌ គឺអរហត្តផល មិនជាសេក្ខធម៌ទេ ព្រោះមិនមានសីលដែលត្រូវសិក្សាខាងលើ ព្រោះដូច្នោះ ទើបឈ្មោះថា **អសេក្ខ** ។ ព្រោះថា នេះជាការជំទាស់ក្នុងធម៌ដែលនៅមានការសង្ស័យក្នុងភាពជាព្រះសេក្ខៈ ព្រោះដូច្នោះ ទាំងក្នុងលោកិយធម៌ និងនិព្វានធម៌ គប្បីជ្រាបថា មិនគួរដល់ភាពជាអសេក្ខធម៌ ។ ព្រោះថា សិក្ខាពោល គឺសីល សមាធិ បញ្ញាដែលផុតហើយចាកកិលេស ដែលជាបដិបក្ខចំពោះខ្លួន គឺបរិសុទ្ធហើយ ដែលគួរពោលបានថា ជាសិក្ខាដែលល្អក្រៃលែង ព្រោះមិនចូលដល់ភាពជាអារម្មណ៍នៃឧបក្កិលេសទាំងឡាយ មានក្នុងមគ្គផល

ទាំង ៨ ព្រោះហេតុនោះ ធម៌ គឺអរហត្តផល ក៏ជាធម៌កើតឡើង ព្រោះសិក្ខាទាំងនោះ ដូចគ្នានឹងធម៌ គឺមគ្គ ៤ និងផល ៣ ខាងក្រោម ដូច្នោះ កាលព្រះអរហន្តដែលប្រកបដោយសិក្ខានោះនៅជាសេក្ខៈ ដូចបុគ្គលក្រៅអំពីនេះក៏គប្បីមានសេចក្ដីសង្ស័យថា ដែលឈ្មោះថា **សេក្ខ** ព្រោះអត្ថថា ធម៌ទាំងនេះជារបស់សេក្ខបុគ្គល ព្រោះអត្ថថា សីលជាសិក្ខារបស់លោកទាំងនេះមាន ព្រោះហេតុនោះ ដើម្បីហាមសេចក្ដីសង្ស័យនោះ ទើបលោកពោលពាក្យថា **អសេក្ខ** ជាកិច្ចបដិសេធការៈនៃសេក្ខបុគ្គលតាមដែលពោលហើយ ។ ព្រោះថា សិក្ខាទាំងឡាយដែលប្រព្រឹត្តទៅក្នុងអរហត្តផល មិនធ្វើកិច្ចនៃការសិក្សា ព្រោះសម្រេចកិច្ចនូវការសិក្សាហើយ និងប្រព្រឹត្តទៅដោយភាពជាផលនៃការសិក្សាតែម្យ៉ាង ព្រោះដូច្នោះ ទើបសិក្ខាទាំងនោះ មិនគួរហៅថា **សិក្ខា** ។ សូម្បីបុគ្គលដែលដល់ព្រមដោយសិក្ខានោះ ក៏មិនគួរហៅថា **សេក្ខបុគ្គល** ។ ម្យ៉ាងទៀត ធម៌ដែលសម្បយុត្តដោយសិក្ខានោះ ក៏មិនមានការសិក្សាជាប្រក្រតី ។ ផលធម៌ដ៏កំពូល គឺអរហត្តផល ក៏មិនជាសេក្ខធម៌ តាមអត្ថ មានអាទិយ៉ាងនេះថា កើតហើយក្នុងសិក្ខាទាំងឡាយ ។ ចំណែកសិក្ខាក្នុងផលជាន់ទាបទាំងឡាយ ញុំាងកិច្ចនៃការសិក្សាក្នុងសកទាគាមិមគ្គ ព្រោះភាពជាឧបនិស្ស័យនៃវិបស្សនាជាដើម ព្រោះដូច្នោះ ទើបសិក្ខាទាំងឡាយ គួរហៅថា **សិក្ខា** និងដែលដល់ព្រមដោយសិក្ខានោះ ក៏គួរហៅថា **សេក្ខបុគ្គល** ទាំងធម៌ដែលសម្បយុត្តដោយសិក្ខានោះ ក៏ជាធម៌មានការសិក្សាជាប្រក្រតី ។ សេក្ខធម៌ទាំងឡាយ ត្រូវជាសេក្ខធម៌នោះឯង តាមអត្ថដែលពោលហើយ ។

ម្យ៉ាងទៀត បើមានពាក្យសួរថា ពាក្យថា **សេក្ខ** ជាពាក្យហៅព្រះអរិយៈទាំងឡាយ ដែលមិនទាន់សម្រេចការសិក្សា ដូច្នេះ ។ ចំណែកពាក្យថា **អសេក្ខ** ជាពាក្យសម្ដែងដល់ព្រះអរិយសាវកទាំងឡាយ ដែលសម្រេចការសិក្សា ព្រោះដូច្នោះ លោកិយធម៌ និងនិព្វានធម៌ មិនគួរជាអសេក្ខធម៌ឡើយ ធម៌ទាំងឡាយ ដែលដល់នូវសេចក្ដីចម្រើន ទាំងជាសេក្ខធម៌ ទាំងជាអសេក្ខធម៌ ភាពដែលធម៌ប្រភេទខ្លះ ក្នុងបណ្ដាសេក្ខធម៌ទាំងឡាយ ដែលដល់នូវសេចក្ដីចម្រើន ជាអសេក្ខធម៌ក៏ត្រឹមត្រូវ ព្រោះដូច្នោះ ធម៌ គឺអរហត្តមគ្គទាំងឡាយ ជាអសេក្ខធម៌ ក៏ត្រឹមត្រូវ ព្រោះអធិប្បាយយ៉ាងនេះថា ដល់នូវសេចក្ដីចម្រើនហើយ និងជាសេក្ខធម៌ តាមអត្ថដែលពោលហើយដូច្នេះឬ ឆ្លើយថា សេចក្ដីនោះ មិនមែនដូច្នោះឡើយ ព្រោះការហៅយ៉ាងនេះ មានក្នុងធម៌ដែលដូចគ្នា ព្រោះថា អរហត្តផល មានការធ្វើដែលមិនផ្សេងអំពីអរហត្តមគ្គ វៀរតែការធ្វើកិច្ច មានបរិញ្ញាជាដើម និងភាពជាវិបាកនៃអរហត្តផល ព្រោះដូច្នោះ សេក្ខធម៌ទាំងនោះឯង អាចពោលបានថា ដល់នូវភាពជាអរហត្តផល ។ វិបាកសុខ គឺសុខដែលកើតអំពីផល ជាសុខប្រណីតជាងកុសលសុខ ព្រោះស្ងប់ជាងគ្នា ។ ព្រោះដូច្នោះ ធម៌ដែលដល់នូវសេចក្ដីចម្រើននោះឯងនៅមាន ដូច្នោះ ទើបហៅថា **អសេក្ខធម៌** ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសអានុភាពនៃព្រះខីណាស្រពដោយការដល់ព្រមដោយធម៌ទាំងនោះ ដោយទ្រង់ចែកអសេក្ខធម៌ទាំងនោះចេញជា ៣ យ៉ាង តាមអំណាចនៃខន្ធក្នុងទីនេះ ទើបត្រាស់ពាក្យជាដើមថា **អសេក្ខេន**

**សីលក្ខន្ធេន** ដូច្នេះ ។

អត្ថនៃ **សីល** សព្ទ ក្នុងពាក្យថា **សីលក្ខន្ធេន** នោះ ខ្ញុំបានពោលហើយខាងដើម ។ ឯ **ខន្ធ** សព្ទ មានប្រយោគដែលឃើញបានក្នុងអត្ថទាំងឡាយជាច្រើន គឺក្នុងគំនរ ក្នុងបញ្ញត្តិ ក្នុងការស្អាត ក្នុងគុណធម៌ ។ ពិតហើយ **ខន្ធ** សព្ទ មកក្នុងគំនរ ដូចក្នុងប្រយោគជាដើមថា **អសង្ខេយ្យោ អប្បមេយ្យោ មហាឧទកក្ខន្ធោត្វេវ សង្ខំ គច្ឆតិ** គំនរទឹកធំ ដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់ យ៉ាងណាមិញ ។ ដែលមកក្នុងបញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា តីរេ សោតេន វុយ្ហមានំ** ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹក ក្នុងឆ្នេរទន្លេគង្គា ។ មកក្នុងការស្អាត ដូចក្នុងប្រយោគជាដើមថា **ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនា-យតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ** ចិត្ត សេចក្តីដឹង អារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ។ មកក្នុងគុណធម៌ ដូចក្នុងប្រយោគជាដើមថា **ន ខោ អាវុសោ វិសាខ អរិយេន អដ្ឋង្គិកេន មគ្គេន តយោ ខន្ធា សង្គហិតា តីហិ ច ខោ អាវុសោ វិសាខ ខន្ធេហិ អរិយោ អដ្ឋង្គិកោ មគ្គោ សង្គហិតោ** ម្នាលអាវុសោវិសាខៈ ខន្ធទាំង ៣ ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខៈ តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ។

ក្នុងព្រះសូត្រនេះ **១ឆ្** សព្វ គប្បីឃើញថា មកហើយ ក្នុងគុណធម៌តែម្យ៉ាង ព្រោះដូច្នោះ ទើបមានអធិប្បាយថា ដោយគុណធម៌ ពោល គឺសីលជាអសេក្ខៈ ។

បទថា **សមន្នាគតោ** សេចក្តីថា ប្រកបព្រមហើយ គឺជាបុគ្គលដល់ព្រមហើយ ឈ្មោះថា **សមាធិ** ព្រោះជាហេតុតាំងមាំ ឬព្រោះតាំងមាំឯង ឬការតាំងមាំនៃចិត្តនោះឯង ។ ឈ្មោះថា **បញ្ញា** ព្រោះដឹង គឺចាក់ធ្លុះតាមសេចក្តីពិត ដោយប្រការទាំងពួង ។ ខន្ធ គឺសីលនោះឯង ឈ្មោះថា **សីលក្ខន្ធ** ក្នុងសមាធិ និងបញ្ញាដ៏សេស ក៏មានន័យនេះដូចគ្នា ។ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈដែលជាអគ្គផល ឈ្មោះថា សីលក្ខន្ធដែលជាអសេក្ខៈ ដោយសភាវៈនោះឯង ក្នុងបណ្តាខន្ធទាំងនោះ ។ សម្មាសមាធិ ក៏ដូចគ្នា គឺជាអគ្គផល ឈ្មោះថា សមាធិក្ខន្ធដែលជាអសេក្ខៈ ។ ឯសម្មាវាយាមៈ និងសម្មាសតិ ដល់នូវការសង្គ្រោះចូលក្នុងសមាធិក្ខន្ធ ព្រោះជាឧបការៈដល់សមាធិក្ខន្ធនោះ ។ សម្មាទិដ្ឋិក៏ដូច្នោះ គឺជាអគ្គផល ឈ្មោះថា បញ្ញាខន្ធដែលជាអសេក្ខៈ ។ សម្មាសង្កប្ប ដល់នូវការសង្គ្រោះចូលក្នុងបញ្ញាខន្ធ ព្រោះជាឧបការៈដល់បញ្ញាខន្ធ ដោយប្រការដូចពណ៌នាមកនេះ ក្នុងសេចក្តីនេះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ គឺអរហត្តផលទាំង ៨ សង្គ្រោះចូលក្នុងខន្ធទាំង ៣ ។

បទថា **យស្ស ឋិតោ សុភាវិតា** មានការក្លាប់សេចក្តីថា ព្រះអរហន្តរូបណាអប់រំតាមខន្ធដែលជាអសេក្ខៈ ដែលមានសីលជាដើមល្អហើយ គឺចម្រើនល្អហើយ ព្រះអរហន្តរូបនោះ រមែងរុងរឿងដូចព្រះអាទិត្យ ។ ព្រះថេរៈខ្លះសូធ្យថា **យស្ស ចេតោ** ដូច្នេះក៏មាន ។ ច សព្ទ នៃបទថា **ចេតោ** នោះត្រឹមតែជានិបាត ។ ក្នុងវគ្គនេះ ព្រះមានព្រះភាគត្រាស់វដ្ដៈ ក្នុងសូត្រដំបូងត្រាស់វិវដ្ដ ក្នុងសូត្រចុងក្រោយ ឯក្នុងសូត្រក្រៅអំពីនេះ ត្រាស់វដ្ដៈផងវិវដ្ដៈផង ដូចពណ៌នាមក ដូច្នេះឯង ។៚

**អដ្ឋកថា មារធេយ្យសូត្រទី ១០ ចប់**
**វគ្គទី ១ ចប់**

# សុត្តន្តបិដក

## ឥតិវុត្តក តិកនិបាត ទុតិយវគ្គ

### បុញ្ញកិរិយាវត្ថុសូត្រ

[ ៦០ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ ។ បុញ្ញកិរិយាវត្ថុ ៣ តើដូចម្តេច ។ គឺទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយ-បុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញ-កិរិយាវត្ថុ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះ ហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សានូវបុណ្យ ដែល
មានផលបរិបូណ៌ មានវិបាកជាសុខ គឺគួរចម្រើនទាន
ផង ការប្រព្រឹត្តស្មើ គឺសីលផង មេត្តាចិត្តផង លុះ
ចម្រើនធម៌ទាំង ៣ នេះ ដែលមានអានិសង្ស ជាសុខ
ហើយ រមែងចូលទៅកាន់លោក ដែលជាសុខ ឥត
មានការបៀតបៀន ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## បុញ្ញកិរិយាវត្ថុសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញកិរិយាវត្ថុសូត្រទី ១ វគ្គទី ២ ដូច្នេះ បទថា **បុញ្ញកិរិយាវត្ថូនិ** សេចក្តីថា កុសលទាំងឡាយ ដែលឲ្យកើតផល ក្នុងភពដែលគួរបូជា ឬជម្រះសន្តានរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា **បុញ្ញ** បុណ្យទាំងនោះផង ឈ្មោះថា **កិរិយា** ព្រោះត្រូវធ្វើដោយហេតុ ដោយបច្ច័យទាំងឡាយផង ព្រោះដូច្នោះ ទើបឈ្មោះថា **បុញ្ញកិរិយា** ។ បុញ្ញកិរិយានោះឯង ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ព្រោះជាទីតាំងនៃអានិសង្ស នោះៗ ។

បទថា **ទានមយំ** បានដល់ ចេតនាជាគ្រឿងបរិច្ចាគទេយ្យធម៌នៃខ្លួន ដល់អ្នកដទៃ ដោយអំណាចនៃការអនុគ្រោះ ឬដោយអំណាចនៃការបូជារបស់ បុគ្គលដែលកាត់នូវឫស គឺភពមិនទាន់ដាច់ ឈ្មោះថា **ទាន** ព្រោះជាហេតុឲ្យ គេឲ្យ ។ ទាននោះឯង ឈ្មោះថា **ទានមយ** ។ ចេតនាដែលប្រព្រឹត្តទៅហើយ ដោយន័យដែលលោកពោលហើយក្នុងកាលទាំង ៣ គឺក្នុងកាលដែលជា ឯ ខាងដើម តាំងអំពីការញ៉ាំងបច្ច័យ ៤ ទាំងនោះឲ្យកើតឡើង ១ ក្នុងវេលាប រិច្ចាគ ១ ក្នុងការរឭកដោយចិត្តត្រេកអរក្នុងកាលជាខាងក្រោយ ១ របស់ បុគ្គលអ្នកឲ្យវត្ថុនោះៗ ក្នុងបណ្តាបច្ច័យ ៤ មានចីវរជាដើម ឬក្នុងបណ្តា ទានវត្ថុ ១០ យ៉ាង មានបាយជាដើម ឬបណ្តាអារម្មណ៍ ៦ មានរូបជាដើម ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ដែលសម្រេចដោយការឲ្យទាន ។

បទថា **សីលមយំ** បានដល់ ចេតនាដែលប្រព្រឹត្តទៅហើយដល់បុគ្គលដែលសមាទានសីល ៥ សីល ៨ ឬសីល ១០ ដោយអំណាចនៃការកំណត់ឲ្យជានិច្ចសីល និងឧបោសថសីលជាដើម ឬដែលគិតថា អញនឹងបួសដើម្បីបំពេញសីលឲ្យបរិបូណ៌ ដូច្នេះហើយ ទៅកាន់វិហារបួស បុគ្គលនឹងញុំាងមនោរថឲ្យដល់ទីបំផុត រឭកថា អញបួសហើយជាការល្អហើយហ្ន៎ ដូច្នេះ បំពេញបាតិមោក្ខឲ្យបរិបូណ៌ដោយសទ្ធា ពិចារណាបច្ច័យ ៤ មានចីវរជាដើមដោយបញ្ញា សង្រួមចក្ខុទ្វារក្នុងរូបដែលមកកាន់គន្លងជាដើម ដោយសតិ និងជម្រះអាជីវបារិសុទ្ធិសីល ដោយសេចក្តីព្យាយាម រមែងតាំងមាំ ព្រោះដូច្នោះ ចេតនានោះ ឈ្មោះថា **បុញ្ញកិរិយាវត្ថុ** សម្រេចដោយសីល ។

ម្យ៉ាងទៀត ចេតនារបស់ភិក្ខុដែលពិចារណាឃើញច្បាស់នូវចក្ខុ សោត ឃាន ជិវ្ហា កាយ មនៈ ដោយមិនទៀង ជាទុក្ខ ជាអនត្តា ដោយវិបស្សនាមគ្គ ដែលពោលហើយក្នុងបដិសម្ភិទា ១ ចេតនារបស់បុគ្គលពិចារណាឃើញច្បាស់នូវរូបទាំងឡាយ ។បេ។ ធម៌ទាំងឡាយ ។បេ។ ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ ។បេ។ ចក្ខុសម្ផស្ស ។បេ។ មនោសម្ផស្ស ។បេ។ ចក្ខុសម្ផស្សជាវេទនា ។បេ។ មនោសម្ផស្សជាវេទនា ។បេ។ រូបសញ្ញា ។បេ។ ធម្មសញ្ញា ។បេ។ ជរាមរណៈ ដោយភាពជារបស់មិនទៀង ជាទុក្ខ និងជាអនត្តា ១ ឈានចេតនាដែលប្រព្រឹត្តទៅហើយ ក្នុងអារម្មណ៍ ៣៨ ប្រការ មានបឋវីកសិណជាដើម ១ ចេតនាដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការសន្សំ និងមនសិការជាដើម ក្នុងប្រភពនៃការងារ ប្រភពនៃសិប្បៈ និង

ឋាន: ជាទីតាំងនៃវិជ្ជា ដែលមិនមានទោស ១ ឯណា បុគ្គលញុំាងចេតនាទាំងអស់នោះឲ្យចម្រើន ដោយបុញ្ញកិរិយានេះ ព្រោះដូច្នោះ ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ដែលសម្រេចដោយការនា តាមន័យដែលពោលហើយនេះឯង ។

ក្នុងបណ្តាកម្មទាំង ៣ យ៉ាងនេះ បើធ្វើកម្មឯណាមួយដោយកាយ តាំងអំពីចំណែកដើម តាមសមគួរ កម្មនោះជាកាយកម្ម ។ បើបន្ទឹវាចាដែលជាប្រយោជន៍ដល់កម្មនោះ កម្មនោះជាវចីកម្ម កាលមិនញុំាងអង្គ គឺកាយ និងអង្គ គឺវាចាឲ្យកម្រើក គិតដោយចិត្ត កម្មនោះជាមនោកម្ម ។ ម្យ៉ាងទៀត ក្នុងកាលដែលបុគ្គលឲ្យបាយជាដើម ដោយគិតថា អញនឹងឲ្យបាយ និងទឹកជាដើមក្តី ដោយរឭកដល់ទានបារមីក្តី បុញ្ញកិរិយាវត្ថុ ជាទានមយ: ។ កាលឲ្យទានដោយតាំងនៅក្នុងបដិបទា បុញ្ញកិរិយាវត្ថុ ជាសីលមយ: កាលឲ្យទាន ដោយផ្តើមតាំងការពិចារណានាមរូប ដោយការអស់ទៅ ដោយការសូន្យទៅ ដោយកម្ម បុញ្ញកិរិយាវត្ថុជាភាវនាមយ: ។ បុញ្ញកិរិយាវត្ថុ ៧ ដទៃទៀត គឺបុញ្ញកិរិយាវត្ថុដែលសហគត:ដោយការឱនលំទោន ១ សហគត: ដោយការខ្នះខ្នែង ១ ការឲ្យចំណែកបុណ្យ ១ ការអនុមោទនា ១ ការសម្តែងធម៌ ១ ការស្តាប់ធម៌ ១ ការធ្វើទិដ្ឋិឲ្យត្រង់ ១ ។ សូម្បីការដល់ព្រះរតនត្រ័យជាសរណ: តែងសង្គ្រោះចូលក្នុងការធ្វើទិដ្ឋិឲ្យត្រង់នោះឯង ពាក្យដែលគួរពោលក្នុងរឿងនេះ នឹងមានច្បាស់ខាងមុខ ។

បណ្តាបុញ្ញកិរិយាវត្ថុ ៧ យ៉ាងនោះ បុញ្ញកិរិយាវត្ថុដែលសហគត:

ដោយការឱនលំទោន គប្បីជ្រាបដោយអំណាចនៃការឃើញភិក្ខុដែលជាថេរៈហើយ ទទួលបាត្រ ចីវរ និងថ្វាយបង្គំ ឬឲ្យនូវផ្លូវជាដើម ។

បុញ្ញកិរិយាវត្ថុ ដែលសហគតៈដោយការខ្វល់ខ្វាយ គប្បីជ្រាបដោយអំណាចនៃការធ្វើវត្តបដិបត្តិដល់ភិក្ខុដែលជាថេរៈ ដោយអំណាចនៃការដែលឃើញភិក្ខុចូលស្រុកដើម្បីបិណ្ឌបាត ទទួលបាត្ររបស់លោកហើយ ដាក់នូវភិក្ខាក្នុងផ្ទះឲ្យរៀបរយ នាំចូលទៅប្រគេន និងដោយអំណាចនៃការស្តាប់ថា ចូរនាំយកបាត្ររបស់ភិក្ខុទាំងឡាយមក ដូច្នេះហើយ ប្រញាប់ទៅនាំបាត្រមកជាដើម ។

បុញ្ញកិរិយាវត្ថុ គឺការឲ្យចំណែកបុណ្យ គប្បីជ្រាបដោយអំណាចនៃការបង្អោនចិត្តថា សូមចំណែកបុណ្យសម្រេចដល់សត្វទាំងពួង ព្រោះការប្រគេនបច្ច័យ ៤ ឬព្រោះការធ្វើការបូជាព្រះរតនត្រ័យ ដោយគ្រឿងក្រអូបជាដើម ឬព្រោះការធ្វើបែបនោះ ដទៃៗ ទៀត ។

បុញ្ញកិរិយាវត្ថុ គឺការអនុមោទនាចំណែកបុណ្យក៏យ៉ាងនោះ គប្បីជ្រាបដោយអំណាចនៃការអនុមោទនានៃបុណ្យដែលអ្នកដទៃឲ្យហើយ ។ ការដែលភិក្ខុមិនប្រាថ្នា ការជំនាញក្នុងធម៌ដើម្បីខ្លួន សំដែងធម៌ដល់អ្នកដទៃ ដោយអធ្យាស្រ័យដែលពេញទៅដោយការអនុគ្រោះ នេះឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយការសំដែងធម៌ ។ តែការដែលភិក្ខុមួយរូប តាំងសេចក្តីប្រាថ្នាថា ជនទាំងឡាយនឹងដឹងថា អញជាធម្មកថិក ដោយវិធីយ៉ាងនេះហើយ អាស្រ័យលាភសក្ការៈ និងការលើកតម្កើង ហើយសំដែងធម៌ មិនមានផល

ច្រើនឡើយ ។ ការដែលមនុស្សស្តាប់ធម៌ដោយចិត្តទន់ភ្លន់ ប្រាថ្នានូវប្រ-យោជន៍ មានយោនិសោមនសិការថា នេះជាឧបាយ ឲ្យបានបំពេញប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃពិតប្រាកដ នេះជាបុញ្ញកិរិយាវត្ថុដែលសម្រេចដោយការស្តាប់ធម៌ ។ តែការដែលបុគ្គលម្នាក់ៗ ស្តាប់ធម៌ដោយគិតថា ចូរជនទាំងឡាយស្គាល់អញថា ជាអ្នកមានសទ្ធាដោយវិធីនេះ មិនមានផលច្រើនឡើយ ។ ការដែលទិដ្ឋិប្រព្រឹត្តទៅត្រង់ ឈ្មោះថា ការធ្វើទិដ្ឋិឲ្យត្រង់ ។ ពាក្យថា ការធ្វើទិដ្ឋិឲ្យត្រង់នេះ ជាឈ្មោះរបស់សម្មាទស្សនៈដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា ទានដែលឲ្យហើយមានផល ព្រោះថា ការធ្វើទិដ្ឋិឲ្យត្រង់ ទោះជាញាណវិប្បយុត្តខាងដើម ឬខាងក្រោយ តែក្នុងកាលធ្វើទិដ្ឋិឲ្យត្រង់ហើយ ក៏ជាញាណសម្បយុត្តនោះឯង ។

តែអាចារ្យពួកខ្លះពោលថា ទស្សនៈ គឺការឃើញដោយអំណាចនៃការដឹង និងការដឹងច្បាស់ ១ វិញ្ញាណដែលជាកុសល ១ កម្មស្សកតាញាណជាដើម ១ ជាសម្មាទស្សនៈ ។ បណ្តាធម៌ ៣ មានទស្សនៈជាដើមនោះ សូម្បីក្នុងកាលញាណមិនទាន់កើតឡើង ក៏មានការសង្គ្រោះហេតុដែលសមគួរដល់ហេតុ ជាគ្រឿងរឭកដល់បុណ្យដែលខ្លួនធ្វើហើយ ជាមួយនឹងវិញ្ញាណដែលជាកុសលបាន ។ មានការសង្គ្រោះចូលជាមួយកម្មស្សកតាញាណ គឺការឃើញប្រពៃតាមគន្លងនៃកម្មបាន តែការឃើញប្រពៃនោះ មានការកំណត់ធម៌ទាំងពួងជាលក្ខណៈ ព្រោះថា កាលធ្វើបុណ្យឯណានីមួយ បុណ្យនោះ ក៏នឹងមានផលច្រើន ព្រោះទិដ្ឋិទាំងឡាយត្រង់នោះឯង តែមានការសង្គ្រោះបុញ្ញ-

កិរិយាវត្ថុ ៧ នេះ ចូលជាមួយបុញ្ញកិរិយាវត្ថុ ៣ យ៉ាង មានទានមយៈជាដើម អធិប្បាយថា បណ្តាបុញ្ញកិរិយាវត្ថុទាំង ៧ យ៉ាងនោះ ការឱនលំទោន ការខ្នះខ្នែង សង្គ្រោះចូលក្នុងសីលមយៈ ការឲ្យនូវចំណែកបុណ្យ និងការអនុមោទនានូវចំណែកបុណ្យ សង្គ្រោះចូលក្នុងទានមយៈ ការសម្តែងធម៌ និងការស្តាប់ធម៌ សង្គ្រោះចូលក្នុងភាវនាមយៈ ការធ្វើទិដ្ឋិឲ្យត្រង់ សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ ។ បុញ្ញកិរិយាវត្ថុ ៣ តើដូចម្តេច ។ គឺទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ដូច្នេះ ។ ក្នុងអធិការនេះ បុញ្ញកិរិយាវត្ថុទាំង ៣ យ៉ាង មានការប្រព្រឹត្តទៅដោយអំណាចនៃកុសលចេតនាដែលជាកាមាវចរ ៨ ឧបមាដូចបុគ្គលសម្តែងជដែលស្ទាត់ជំនាញ ក៏មិនពិចារណាដល់អនុសន្ធិឡើយ ធម៌ពួកខ្លះក៏ប្រព្រឹត្តទៅបាន យ៉ាងណា កាលព្រះយោគាវចរប្រកបរឿយៗ នូវសមថភាវនា និងវិបស្សនា ភាវនាដែលស្ទាត់ជំនាញ មនសិការដោយចិត្តដែលជាញាណវិប្បយុត្ត ប្រព្រឹត្តទៅបានក្នុងចន្លោះៗ ទាំងអស់នោះ ជាបុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយភាវនាតែម្យ៉ាង ដោយអំណាចនៃកុសលចេតនាដែលជាមហគ្គតៈ មិនមែនជាបុញ្ញកិរិយាវត្ថុក្រៅអំពីនេះឡើយ អត្ថនៃព្រះគាថា ខ្ញុំពោលហើយខាងដើមនោះឯង ។

**អដ្ឋកថា បុញ្ញកិរិយាវត្ថុសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ចក្ខុសូត្រ

[ ៦១ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុនេះ មាន ៣ ។ ចក្ខុ ៣ តើដូចម្តេច ។ គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុរសឧត្តម បានពោលនូវចក្ខុ ៣ នេះ គឺមំសចក្ខុ ១
ទិព្វចក្ខុ ១ បញ្ញាចក្ខុដ៏ប្រសើរបំផុត ១ ការកើតឡើង
នៃមំសចក្ខុ ជាឧបាយនៃទិព្វចក្ខុ កាលដែលញាណ គឺ
បញ្ញាចក្ខុដ៏ឧត្តម កើតឡើងហើយ បុគ្គលរមែងរួចស្រឡះ
ចាកទុក្ខទាំងពួង ព្រោះបាននូវចក្ខុនោះ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ចក្ខុសូត្រ

ក្នុងចក្ខុសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦១ ] បទថា **ចក្ខូនិ** សេចក្តីថា ឈ្មោះថា **ចក្ខុ** ព្រោះរមែងឃើញ អធិប្បាយថា ចក្ខុរមែងប្រព្រឹត្តទៅ ដូចនឹងប្រាប់ផ្លូវដែលរាបស្មើ និងមិនរាបស្មើ ម្យ៉ាងទៀត ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា គាប់ចិត្ត ។ សួរថា ដែលឈ្មោះថា ប្រពៃនេះ គឺដូចម្តេច ឆ្លើយថា គាប់ចិត្ត ។ ដូចបុគ្គលទាំងឡាយពោលថា ឃ្មុំចូលចិត្តទឹកផ្អែម មនុស្សចូលចិត្តបាយ ។ ម្យ៉ាងទៀត អាយតនៈទាំងនេះ កាលសោយរសនៃអារម្មណ៍ តែងដូចជាគាប់ចិត្ត ព្រោះដូច្នោះទើបឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា គាប់ចិត្ត តែចក្ខុទាំងនោះ ដោយសង្ខេបមាន ២ យ៉ាង គឺញាណចក្ខុ និងមំសចក្ខុ ។

បណ្តាចក្ខុទាំង ២ យ៉ាងនោះ មំសចក្ខុបានពោលខាងដើមហើយ ក្នុងព្រះសូត្រនេះ ញាណចក្ខុត្រាស់ចែកជា ២ យ៉ាង គឺទិព្វចក្ខុ និងបញ្ញាចក្ខុ ។

បណ្តាបទទាំងនោះ បទថា **ទិព្វចក្ខុ** សេចក្តីថា ចក្ខុ ឈ្មោះថា **ទិព្វ** ព្រោះជាទិព្វ អធិប្បាយថា ចក្ខុនៃទេវតាទាំងឡាយដែលកើតអំពីសុចរិតកម្ម មិនមានទឹកប្រមាត់ ស្លេស្ម និងឈាមជាដើមបិទបាំង ជាចក្ខុដែលមានបសាទជាទិព្វ អាចទទួលអារម្មណ៍សូម្បីទីឆ្ងាយបាន ព្រោះផុតចាកឧបក្កិលេស ។ ញាណចក្ខុនេះ ដែលកើតដោយកម្លាំងនៃការចម្រើនវីរិយៈ ក៏ដូច្នោះដូចគ្នា ព្រោះដូច្នោះ ទើបឈ្មោះថា ជាទិព្វ ព្រោះដូចទិព្វ ។ ញាណចក្ខុ ឈ្មោះថា ជាទិព្វ ព្រោះបានមកដោយអំណាចនៃទិព្វវិហារធម៌ ព្រោះអាស្រ័យទិព្វវិហារ

ធម៌របស់ខ្លួន ព្រោះរុងរឿងច្រើន ដោយការកំណត់អាលោកកសិណ ព្រោះមានការធ្វើទៅបានទូលាយ ដោយការឃើញរូបដែលនៅខាងក្រៅកំពែងជាដើម ។ ទិព្វចក្ខុទាំងអស់នោះ គប្បីជ្រាបតាមគន្លងនៃសទ្ទសាស្ត្រ ។ អាយតនៈឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ដូចជាចក្ខុ ដោយអត្ថថា ឃើញ គឺដោយការធ្វើទស្សនកិច្ច ដូច្នេះក៏មាន ។ ចក្ខុផង ជាទិព្វផង ព្រោះហេតុនោះ ទើបឈ្មោះថា **ទិព្វចក្ខុ** ។

ធម្មជាត ឈ្មោះថា បញ្ញា ព្រោះដឹងច្បាស់ ។ តើដឹងច្បាស់នូវអ្វី គឺដឹងច្បាស់នូវអរិយសច្ច ៤ ដោយន័យជាដើមថា នេះទុក្ខ សមដូចព្រះធម្មសេនាបតីសារីបុត្រពោលក្នុងមហាវេទល្លសូត្រថា ម្នាលអាវុសោ បុគ្គលដែលចេះដឹងច្បាស់ហ្នឹងឯង ហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះ ដឹងច្បាស់នូវអ្វី ដឹងច្បាស់ថា នេះទុក្ខ ... ដូច្នេះ ។ ឯក្នុងអដ្ឋកថា លោកពោលថា ឈ្មោះថា **បញ្ញា** ដោយអំណាចនៃការបញ្ញត្ត ។ តើបញ្ញត្តដូចម្ដេច បញ្ញត្តថា **អនិច្ចំ ទុក្ខំ អនត្តា** បញ្ញានោះ ដោយលក្ខណៈជាដើម មានការចាក់ធ្លុះសេចក្ដីពិតជាលក្ខណៈ ឬមានការចាក់ធ្លុះមិនខុសជាលក្ខណៈ ដូចការចាក់ធ្លុះនៃព្រួញ ដែលនាយខ្មាន់ធ្នូអ្នកឈ្លាសបាញ់ទៅ មានការបញ្ជូនឲ្យឃើញអារម្មណ៍ជាកិច្ច ដូចប្រទីប មានការមិនវង្វេងជាគ្រឿងប្រាកដ ដូចមគ្គុទ្ទេសក៍ដ៏ល្អប្រាប់ផ្លូវដល់អ្នកទៅព្រៃ តែដោយវិសេសហើយ ក្នុងទីនេះ ទ្រង់បំណងយកបញ្ញា ពោល គឺអាសវក្ខយញ្ញាណថា ឈ្មោះថា **បញ្ញាចក្ខុ** ព្រោះអត្ថថា ឃើញសច្ចៈទាំង ៤ ដែលទ្រង់ត្រាស់សំដៅយកថា ចក្ខុកើតឡើងហើយ

ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដូច្នេះ ។

ម្យ៉ាងទៀត បណ្តាចក្ខុទាំងនោះ មំសចក្ខុ ជារបស់តូច ទិព្វចក្ខុជារបស់ធំ ក្រៅអំពីនេះ ( បញ្ញាចក្ខុ ) ជាអប្បមាណ មំសចក្ខុ ជារូប ចក្ខុ ២ យ៉ាងក្រៅអំពីនេះជាអរូប ។ មំសចក្ខុក្តី ទិព្វចក្ខុក្តី ជាលោកិយ នៅមានអាសវៈ និងមានរូបជាអារម្មណ៍ ក្រៅអំពីនេះ ( បញ្ញាចក្ខុ ) ជាលោកុត្តរ មិនមានអាសវៈ មានសច្ចៈទាំង ៤ ជាអារម្មណ៍ មំសចក្ខុជាអព្យាកតៈ ទិព្វចក្ខុជាកុសលក៏មាន ជាអព្យាកតៈក៏មាន បញ្ញាចក្ខុក៏ដូចគ្នា ។ មំសចក្ខុជាកាមាវចរ ទិព្វចក្ខុជារូបាវចរ ក្រៅអំពីនេះ ជាលោកុត្តរ គប្បីជ្រាបការបែកដោយន័យជាដើម ដូចពណ៌នាមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **អនុត្តរំ** ត្រាស់សំដៅដល់បញ្ញាចក្ខុ ដ្បិតថា បញ្ញាចក្ខុនោះ ឈ្មោះថា **អនុត្តរំ** ព្រោះជាអាសវក្ខយញ្ញាណ ។ បទថា **អក្ខាសិ បុរិសុត្តមោ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធជាបុគ្គលឧត្តម គឺប្រសើរជាងមនុស្សទាំងឡាយ ទ្រង់សម្តែង ។ ការប្រព្រឹត្តទៅនៃមំសចក្ខុ ឈ្មោះថា **ឧប្បាទ** ។ ឧបាយ គឺហេតុនៃទិព្វចក្ខុ ឈ្មោះថា **មគ្គ** អធិប្បាយថា ទិព្វចក្ខុដែលកើតឡើងដល់បុគ្គលមានភ្នែកល្អតាមប្រក្រតីប៉ុណ្ណោះ ព្រោះមានការចម្រើនអាលោកកសិណហើយ កើតទិព្វចក្ខុញាណឡើង ហើយអាលោកកសិណនោះ មិនមានក្នុងមណ្ឌលនៃកសិណ ដោយវៀរចាកឧគ្គហនិមិត្ត ដូច្នេះ ។ បទថា **យតោ** ប្រែថា ក្នុង

កាលណា ។ បទថា **ញាណំ** បានដល់ អាសវក្ខយញ្ញាណ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បញ្ញាចក្ខុ អនុត្តរំ** ប្រែថា បញ្ញាចក្ខុ ជាភ្នែកដ៏ប្រសើរ ។ បទថា **តស្ស ចក្ខុស្ស បដិលាភា** សេចក្ដីថា បុគ្គលរមែងរួចផុត គឺរួចផុតចាកវដ្ដៈទាំងពួង បានដោយការនា ព្រោះបញ្ញាចក្ខុដែលប្រសើរកើតឡើង ។ល។

**អដ្ឋកថា ចក្ខុសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឥន្ទ្រិយសូត្រ

[ ៦២ ] ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះ មាន ៣ ។ ឥន្ទ្រិយ ៣ តើដូចម្ដេច ។ គឺអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ញាណជាបឋម ក្នុងកិរិយាអស់ទៅ កើតឡើងដល់សេក្ខ-
បុគ្គល អ្នកកំពុងសិក្សា អ្នករៀនរៀបៗ នូវផ្លូវដ៏ត្រង់
លំដាប់អំពីនោះមក អរហត្ត ក៏កើតឡើង លំដាប់អំពី

អរហត្តផលនោះមក បច្ចវេក្ខណញ្ញាណ ក៏កើតឡើង
ដល់ព្រះខីណាស្រព ដែលដល់នូវតាទិលក្ខណៈ រួច
ស្រឡះហើយ ព្រោះអស់ទៅនៃភវសំយោជនៈថា វិមុត្តិ
របស់អាត្មាអញ មិនកម្រើក បើបុគ្គលប្រកបដោយ
ឥន្ទ្រិយ ជាអ្នកស្ងប់រម្ងាប់ ត្រេកអរក្នុងព្រះនិព្វាន ជាទី
ស្ងប់ ឈ្នះនូវមារ ព្រមទាំងវាហនៈហើយ រមែងទ្រទ្រង់
នូវរាងកាយជាទីបំផុត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## ឥន្ទ្រិយសូត្រ

ក្នុងឥន្ទ្រិយសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦២ ] បទថា **ឥន្ទ្រិយានិ** សេចក្តីថា ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ធំក្រៃលែង អធិប្បាយថា ធម្មជាតពួកណា ហាក់ដូចជាធំក្នុងសហជាតធម៌ទាំងឡាយ ដែលសហជាតធម៌នោះ ត្រូវអនុលោមតាមធម្មជាតនោះ ឈ្មោះថា **ឥន្ទ្រិយ** ។ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះជាធម៌ដែលព្រះមានព្រះភាគទ្រង់ជាធំ ជាធម្មិស្សរៈ និងប្រកបដោយភាពជាធំនៃចិត្តដ៏កំពូល

ទ្រង់ឃើញហើយ គឺទ្រង់សម្រេចហើយមុនជាងជនទាំងពួង ព្រោះទ្រង់ឃើញហើយ គឺទ្រង់សម្តែងហើយដល់ជនដទៃមុនជនទាំងពួង និងព្រោះទ្រង់ឃើញហើយដោយអារម្មណការនា និងសេវនា ។ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះជាគ្រឿងសម្គាល់នៃបុញ្ញកម្មដែលជាធំ គឺជាឧបនិស្ស័យនៃការសម្រេចមគ្គ ដូច្នេះក៏មាន ។

បទថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** បានដល់ ឥន្ទ្រិយដែលកើតឡើងខាងដើមនេះនៃអ្នកបដិបត្តិ ដោយគិតថា អញនឹងសម្រេចអមតបទ ឬសច្ច-ធម៌ទាំង ៤ ដែលមិនធ្លាប់ដឹង គឺមិនធ្លាប់សម្រេចក្នុងសង្សារដែលមានទីបំផុតដែលបុគ្គលតាមទៅមិនដឹងហើយ នេះជាឈ្មោះនៃបញ្ញាក្នុងសោតាបត្តិមគ្គ ។ បទថា **អញ្ញិន្ទ្រិយំ** បានដល់ ជាធំ ដោយការដឹងទូទៅ ។ ក្នុងបទថា **អញ្ញិន្ទ្រិយំ** នេះ មានអត្ថវចនៈដូចតទៅនេះ ឥន្ទ្រិយ ឈ្មោះថា **អញ្ញា** ព្រោះដឹងទូទៅ គឺដឹងមិនលើសព្រំដែននៃធម៌ដែលបានឃើញហើយ ដោយបឋមមគ្គញាណនោះឯង ឧបមាដូចបញ្ញាក្នុងបឋមមគ្គ រមែងប្រព្រឹត្តទៅដោយអំណាចនៃការសម្រេច ដោយបរិញ្ញាកិច្ចជាដើម ក្នុងទុក្ខជាដើម យ៉ាងណា បញ្ញានេះ ក៏យ៉ាងនោះដូចគ្នា ព្រោះដូច្នោះ អញ្ញានោះផង ឈ្មោះថា **ឥន្ទ្រិយ** តាមអត្ថដូចពោលមកហើយផង ព្រោះដូច្នោះ ទើបឈ្មោះថា **អញ្ញិន្ទ្រិយ** ។ ម្យ៉ាងទៀត ឈ្មោះថា **អញ្ញិន្ទ្រិយ** ព្រោះជាឥន្ទ្រិយរបស់ព្រះអរិយបុគ្គល ដែលឈ្មោះថា **អញ្ញ** ព្រោះអត្ថថា ដឹងទូទៅ ។ ពាក្យថា **អញ្ញិន្ទ្រិយំ** នេះ ជាឈ្មោះនៃញាណក្នុងទី ៦ ស្ថាន ចាប់អំពីសោតាបត្តិផលទៅ ។ បទថា **អញ្ញាតា-**

**វិន្ទ្រិយំ** បានដល់ ឥន្ទ្រិយរបស់ព្រះអរិយបុគ្គលដែលដឹងទូទៅដល់ហើយ ព្រោះកើតឡើងអំពីបុគ្គលដែលដឹងទូទៅដល់ហើយ គឺព្រះខីណាស្រព ដែលមានកិច្ចដោយញាណសម្រេចហើយ ក្នុងសច្ចៈទាំង ៤ និងជាដែនកើតនៃឥន្ទ្រិយ ៨ គឺមគ្គ ៤ ផល ៤ ។ ក្នុងបណ្ដាឥន្ទ្រិយ ៨ នេះ ឥន្ទ្រិយទី ១ និងទីបំផុត គប្បីជ្រាបថា តាំងនៅក្នុងឋានៈតែមួយ ដោយមគ្គទី ១ ឯផល ៤ ក្រៅអំពីនេះ គប្បីជ្រាបថា តាំងនៅក្នុងឋានៈ ៦ យ៉ាង ( សោតាបត្តិផល ដល់អរហត្តមគ្គ ) ដោយអំណាចមគ្គ និងផលក្រៅអំពីនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **សិក្ខមានស្ស** សេចក្ដីថា សិក្ខា គឺបំពេញនូវអធិសីលសិក្ខាជាដើម ។ បទថា **ឧជុមគ្គានុសារិនោ** សេចក្ដីថា អរិយមគ្គ ហៅថា ផ្លូវត្រង់ ។ បុគ្គលឈ្មោះថាតាមរឭកដល់ផ្លូវត្រង់ ព្រោះរឭកដល់ផ្លូវត្រង់នោះរឿយៗ ព្រោះរៀនអន្តធម៌ ២ យ៉ាង អធិប្បាយថា ញុំាំងមគ្គឲ្យកើតឡើងតាមលំដាប់ ។ បទថា **ខយស្មឹ** សេចក្ដីថា ញាណក្នុងអគ្គមគ្គ គឺអរហត្តមគ្គ ពោល គឺធម៌ជាទីអស់ទៅ ព្រោះកិលេសអស់ទៅដោយមិនមានសេសសល់ កើតឡើងមុន គឺដំបូងនោះឯង ។ បទថា **តតោ អញ្ញា អនន្តរា** សេចក្ដីថា បន្ទាប់អំពីមគ្គញាណនោះទៅ អរហត្តក៏កើតឡើង ។ម្យ៉ាងទៀត បទថា **ឧជុមគ្គានុសារិនោ** សេចក្ដីថា សម្រាប់ព្រះយោគាវចរដែលរឭករឿយៗ គឺជាប់តាម បានដល់ បដិបត្តិមគ្គខាងដើម ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការរៀរនូវថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ និងការរារែក ការត្រេកត្រអាលជាដើម ហើយចម្រើនសមថៈ និង

វិបស្សនា ធ្វើឲ្យជាយុគនទ្ធធម៌ ( ធម៌ជាគូ ) ក្នុងលំដាប់នៃគោត្រភូញាណ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ គឺញាណទី ១ នឹងកើតឡើងក្នុងសោតាបត្តិមគ្គ ។ ដែលឈ្មោះថា ជាទីអស់ទៅព្រោះកិលេសទាំងឡាយ ដែលតាំងនៅក្នុងទីជាមួយគ្នា ដែលលោកឃើញហើយអស់ទៅ ។ បទថា **តតោ អញ្ញា អនន្តរា** សេចក្ដីថា បន្ទាប់អំពីបឋមញ្ញាណនោះ គឺតាំងអំពីរយៈពេលជាប់គ្នាទៅរហូតដល់អញ្ញា គឺមគ្គខាងលើ ( អរហត្តមគ្គ ) អញ្ញិន្ទ្រិយរមែងកើតឡើង ។ បទថា **តតោ អញ្ញា វិមុត្តស្ស** សេចក្ដីថា ក្រោយអំពីអញ្ញា គឺអញ្ញិន្ទ្រិយនោះ គឺបន្ទាប់អំពីអរហត្តមគ្គញ្ញាណ បច្ចវេក្ខណញ្ញាណរមែងកើតឡើងដល់ព្រះយោគាវចរដែលរួចផុតហើយ ដោយអរហត្តផល គឺអញ្ញាតាវិន្ទ្រិយដោយបញ្ញាវិមុត្តិ ។ បទថា **ញាណំ វេ ហោតិ តាទិនោ** សេចក្ដីថា ក្នុងកាលបន្ទាប់អំពីការសម្រេចអរហត្តផល បច្ចវេក្ខណញ្ញាណ នឹងកើតឡើងដល់ព្រះខីណាស្រព ជាអ្នកដល់នូវលក្ខណៈនៃអ្នកមិនញាប់ញ័រ ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ។ ព្រះមានព្រះភាគត្រាស់ថា **អកុប្បា មេ វិមុត្តិ** ប្រែថា វិមុត្តិរបស់តថាគតមិនកម្រើក ដូច្នេះ ។ សួរថា កើតឡើងបានដូចម្ដេច ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់សម្ដែងហេតុនៃការដែលបុគ្គលរួចផុត ហើយមិនកម្រើកថា **ភវសំយោជនក្ខយា** ព្រោះអស់ទៅនៃភព និងសំយោជនៈ ។

ឥឡូវនេះ កាលទ្រង់សរសើរព្រះខីណាស្រព ដូច្នោះហើយ ទើបត្រាស់ព្រះគាថាទី ៣ ថា **សវេ ឥន្ទ្រិយសម្បន្នោ** ព្រះខីណាស្រពនោះឯង ជាអ្នកដល់ព្រមដោយឥន្ទ្រិយ ។

*បណ្ដាបទទាំងនោះ បទថា* **ឥន្ទ្រិយសម្បន្នោ** *សេចក្ដីថា ជាអ្នកប្រកប ដោយលោកុត្តរឥន្ទ្រិយ ៣ យ៉ាងតាមដែលពោលមកហើយ ។ ម្យ៉ាងទៀត ជាអ្នកប្រកបព្រមហើយ គឺបរិបូណ៌ហើយ ដោយឥន្ទ្រិយទាំងឡាយ មាន សទ្ធាជាដើម ដែលបរិសុទ្ធខ្លះ ដែលបានមកអំពីការស្ងប់រម្ងាប់ខ្លះ បន្ទាប់អំពី នោះទៅ ប្រកបព្រមហើយដោយឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមដែលស្ងប់ រម្ងាប់ល្អហើយ ដែលប្រាសចាកការសេពខុសហើយ ដោយហេតុនោះ ទើប ព្រះមានព្រះភាគត្រាស់ថា* **សន្តោ** *ប្រែថា ស្ងប់ហើយ អធិប្បាយថា ស្ងប់ រម្ងាប់ហើយ ដោយការស្ងប់សេចក្ដីក្រវល់ក្រវាយដែលកើតអំពីកិលេសសព្វ យ៉ាង ។ បទថា* **សន្តិបទេ រតោ** *សេចក្ដីថា ត្រេកអរក្រៃលែងហើយ គឺ បង្អោនចិត្តទៅហើយក្នុងព្រះនិព្វាន ។ ម្យ៉ាងទៀត ក្នុងព្រះគាថានេះ បទថា* **ឥន្ទ្រិយសម្បន្នោ** *នេះ ទ្រង់សម្ដែងភាពដែលព្រះខីណាស្រពនោះជាបុគ្គលមាន មគ្គចម្រើនហើយ និងភាពជាបុគ្គលមានខន្ធកំណត់ដឹងហើយ ដោយបទថា* **សន្តោ** *នេះ ទ្រង់សម្ដែងដល់ភាពដែលព្រះខីណាស្រពនោះជាអ្នកលះកិលេស បានហើយ ។ តែបទថា* **សន្តិបទេ រតោ** *នេះ ទ្រង់សម្ដែងដល់ភាពដែលព្រះ ខីណាស្រពនោះ ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ល។*

**អដ្ឋកថា ឥន្ទ្រិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អទ្ធាសូត្រ

[ ៦៣ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលនេះ មាន ៣ ។ កាល ៣ តើដូចម្តេច ។ គឺអតីតកាល ១ អនាគតកាល ១ បច្ចុប្បន្នកាល ១ ។ ម្នាលភិក្ខុទាំងឡាយ កាលមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

សត្វទាំងឡាយ មានសេចក្តីសម្គាល់ ក្នុងកិរិយាពោល
ជាសត្វ ជាបុគ្គលជាដើម តាំងនៅក្នុងកិរិយាពោល
ដោយអំណាចនៃតណ្ហា និងទិដ្ឋិ លុះមិនកំណត់ដឹងនូវ
កិរិយាពោល ដោយបរិញ្ញាទាំង ៣ យ៉ាង ក្នុងធម៌
ដែលប្រកបដោយភូមិ ៣ ហើយ រមែងមកកាន់ទី
ប្រកបនៃមរណៈ ព្រះខីណាស្រព រមែងមិនសម្គាល់
គឺមិនជឿនូវបុគ្គលអ្នកប្រាប់ ព្រោះកំណត់ដឹងនូវពាក្យ
ពោល វិមោក្ខ គឺព្រះនិព្វានជាទីរម្ងាប់ដ៏ប្រសើរ ឈ្មោះ
ថា លោកបានសម្រេចហើយដោយចិត្ត ព្រះខីណាស្រព
នោះឯង ដល់ព្រមដោយការពោល ជាអ្នកស្ងប់រម្ងាប់
ត្រេកអរក្នុងព្រះនិព្វាន ជាទីស្ងប់ ពិចារណាហើយទើប
សេព តាំងនៅក្នុងនិព្វានធម៌ ដល់នូវវេទ រមែងមិនដល់
នូវការរាប់ថា ( ជាមនុស្ស ឬទេវតា ) ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## អទ្ធាសូត្រ

ក្នុងអទ្ធាសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៣ ] កាល ឈ្មោះថា **អទ្ធា** ។ ក្នុងពាក្យថា **អតីតោ អទ្ធា** ជាដើម មានបរិយាយ ២ យ៉ាង គឺបរិយាយតាមព្រះសូត្រ ១ បរិយាយតាមព្រះអភិធម្ម ១ ។ ក្នុងបរិយាយ ២ យ៉ាងនោះ ដោយការបរិយាយតាមព្រះសូត្រមុនបដិសន្ធិកាល ឈ្មោះថា **អតីតអទ្ធា** ។ ក្រោយអំពីចុតិ ឈ្មោះថា **អនាគតអទ្ធា** ។ ចន្លោះបដិសន្ធិ និងចុតិ រួមទាំងចុតិ និងបដិសន្ធិ ឈ្មោះថា **បច្ចុប្បន្នអទ្ធា** ។ ដោយការបរិយាយតាមព្រះអភិធម្ម ពេលដែលរលត់ទៅហើយតាមធម្មតា ព្រោះឆ្លងនូវខណៈទាំង ៣ នេះ គឺឧប្បាទក្ខណៈ ឋិតិក្ខណៈ ភង្គក្ខណៈទៅ ឈ្មោះថា **អតីតអទ្ធា** ។ ពេលដែលមិនទាន់ដល់ខណៈទាំង ៣ ឈ្មោះថា **អនាគតអទ្ធា** ។ ពេលដែលដល់ព្រមទៅដោយខណៈទាំង ៣ ឈ្មោះថា **បច្ចុប្បន្នអទ្ធា** ។

ម្យ៉ាងទៀត ឯការចែកកាល មានអតីតជាដើមនេះ គប្បីជ្រាបថា មាន ៤ យ៉ាង ដោយអំណាចនៃអទ្ធា ១ សន្តតិ ១ សម័យ ១ ខណៈ ១ ។

បណ្ណា ៤ យ៉ាងនោះ ការចែកដោយអទ្ធា បានពោលមកហើយ ។ ដោយអំណាចនៃសន្តតិ រូបទាំងនេះដូចគ្នា មានឧតុតែមួយជាសមុដ្ឋាន មានអាហារតែមួយជាសមុដ្ឋាន សូម្បីកំពុងប្រព្រឹត្តទៅដោយអំណាចខាងដើម និងខាងចុង ជាបច្ចុប្បន្ន ។ រូបទាំងឡាយដែលមានឧតុ និងអាហារ មិនដូចគ្នាជាសមុដ្ឋាន មុនអំពីនោះ ជាអតីត ក្រោយអំពីនោះ ជាអនាគត ។ រូបទាំង-ឡាយដែលកើតអំពីចិត្ត ដែលមានវិថីតែមួយ មានជវនៃតែមួយ និងមានសមាបត្តិតែមួយជាសមុដ្ឋាន ជាបច្ចុប្បន្ន មុនអំពីនោះ ជាអតីត ក្រោយអំពីនោះ ជាអនាគត ។ សម្រាប់រូបទាំងឡាយ ដែលមានកម្មជាសមុដ្ឋានតែម្យ៉ាងដោយអំណាចនៃសន្តតិ កាលផ្សេងគ្នានៃកាល មានអតីតជាដើម រមែងមិនមាន ។ តែគប្បីជ្រាបថា រូបចំពោះយ៉ាងនោះជាអតីតជាដើម ដោយអំណាចនៃរូបទាំងនោះដែលមានឧតុ អាហារ និងចិត្តជាសមុដ្ឋាន ជាអ្នកឧបត្ថម្ភ ។ តែដោយអំណាចនៃសម័យ រូបទាំងឡាយដែលកំពុងប្រព្រឹត្តទៅ ដោយអំណាចនៃការបន្តក្នុងសម័យផ្សេងៗគ្នា ដូចជាមួយយាម មួយព្រឹក មួយល្ងាច មួយយប់ មួយថ្ងៃជាដើម ឈ្មោះថា ជាបច្ចុប្បន្នក្នុងសម័យនោះៗ ។ មុនអំពីនោះ ជាអតីត ក្រោយអំពីនោះ ជាអនាគត នេះជាន័យក្នុងរូបធម៌មុន ។

ឯក្នុងអរូបធម៌ទាំងឡាយ ដោយអំណាចនៃខណៈ ធម៌ទាំងឡាយដែលទាក់ទងក្នុងខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើមជាបច្ចុប្បន្ន មុនអំពីនោះ ជាអតីត ក្រោយអំពីនោះ ជាអនាគត ។ ម្យ៉ាងទៀត ធម៌ទាំងឡាយដែលធ្វើកិច្ចជាហេតុ ជាបច្ច័យ កន្លងទៅហើយជាអតីត ធម៌ទាំងឡាយដែលធ្វើកិច្ចជា

ហេតុសម្រេចហើយ តែធ្វើកិច្ចជាបច្ច័យមិនទាន់សម្រេចជាបច្ចុប្បន្ន ធម៌ទាំងឡាយដែលមិនដល់ព្រមដោយកិច្ចទាំង ២ យ៉ាងជាអនាគត ម្យ៉ាងទៀត ក្នុងខណៈនៃកិច្ចរបស់ខ្លួន ធម៌ទាំងឡាយជាបច្ចុប្បន្ន មុនអំពីនោះជាអតីត ក្រោយអំពីនោះជាអនាគត ។ បណ្តាសការៈទាំង ៤ មានអទ្ធាជាដើម ការពោលដល់ខណៈប៉ុណ្ណោះ ជាការបរិយាយដោយត្រង់ ដែលសល់អំពីនោះ ជាការបរិយាយដោយអម ព្រោះថា ឈ្មោះថា ការផ្សេងគ្នានៃកាល មានអតីតជាដើមនេះ មានសម្រាប់ធម៌ទាំងឡាយ មិនមានសម្រាប់កាល តែ **កាល** ដោយបរមត្ថមិនមាន ព្រោះសំដៅយកធម៌ដែលមានអតីតជាដើម ជាប្រភេទ តែក្នុងទីនេះ ក៏គប្បីជ្រាបថា ទ្រង់ត្រាស់ដោយពាក្យជាដើមថា **អតីត** ដោយវោហារនោះឯង ។

ក្នុងគាថាទាំងឡាយមានអធិប្បាយដូចតទៅនេះ បទថា **អក្ខេយ្យសញ្ញិនោ** គប្បីជ្រាបវិនិច្ឆ័យដូច្នេះ វត្ថុដែលពោល ឈ្មោះថា **អក្ខេយ្យ** ព្រោះដែលគេពោល គឺពោល បានដល់ ឲ្យបុគ្គលដទៃដឹងនូវបញ្ញត្តិ គឺកថាវត្ថុដោយអត្ថ បានដល់ បញ្ចក្ខន្ធ មានរូបជាដើម សមដូចលោកពោលក្នុងសង្គីតិសូត្រថា

> បុគ្គលប្រារព្ធអតីតកាល និយាយពាក្យថា រឿងយ៉ាងនេះកើតមានក្នុងអតីតកាលហើយ ១ បុគ្គលប្រារព្ធអនាគតកាល និយាយពាក្យថា រឿងយ៉ាងនេះនឹងមានក្នុងអនាគតកាល ១ បុគ្គលប្រារព្ធបច្ចុប្បន្នកាលក្នុងកាលឥឡូវនេះ និយាយពាក្យថា រឿងយ៉ាងនេះ

កើតឡើងក្នុងកាលឥឡូវនេះ ១ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីសម្តែងអត្ថដោយសូត្រដែលពោលដល់គន្លងនៃនិរុត្តិ ដែលព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ រូបណាដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ ការពិចារណានូវរូបនោះ ថាកើតមានរួចហើយ ឈ្មោះរបស់រូបនោះ ថាកើតមានរួចហើយ បញ្ញត្តិរបស់រូបនោះ ថាកើតមានរួចហើយ តែការពិចារណានូវរូបនោះ ថាគ្មានក្នុងបច្ចុប្បន្ននេះទេ ការពិចារណានូវរូបនោះ ថាគ្មានទៅក្នុងអនាគតទេ ដូច្នេះ ។

បុគ្គលមានការសម្គាល់ក្នុងរឿងដែលនឹងត្រូវពោលដល់ ដោយអំណាចនៃការសម្គាល់ក្នុងខន្ធបញ្ចកៈ ពោលដល់រឿងដែលត្រូវពោលដល់ ដោយភាពជាកថាវត្ថុដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា អញ របស់អញ ទេវតា មនុស្សស្រី និងប្រុស ដោយប្រការដូចពោលហើយ អធិប្បាយថា ជាបុគ្គលមានសេចក្តីសម្គាល់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា ជាសត្វ ជាបុគ្គលជាដើម ។ សត្វទាំងឡាយតាំងនៅហើយក្នុងវត្ថុ ដែលនឹងត្រូវពោលដល់ ដោយអំណាចនៃការប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ ម្យ៉ាងទៀត តាំងនៅហើយដោយអាការ ៨ ដោយអំណាចនៃរាគៈជាដើម អធិប្បាយថា ជាអ្នកតម្រេកហើយ ជាអ្នកតាំងនៅហើយ ដោយអំណាចនៃរាគៈ បុគ្គលដែលទោសៈប្រទូស្តហើយ ជាអ្នកតាំងនៅហើយដោយអំណាចនៃទោសៈ បុគ្គល

វាង្វេងហើយ ជាអ្នកតាំងនៅហើយដោយអំណាចនៃមោហៈ ដែលត្រូវទិដ្ឋិពាល់ត្រូវហើយ ជាអ្នកតាំងនៅហើយដោយអំណាចនៃទិដ្ឋិ ជាអ្នកមានកិលេសខ្ជាំងក្លា ជាអ្នកតាំងនៅហើយ ដោយអំណាចនៃអនុស័យ បុគ្គលដែលត្រូវកិលេសរួបរឹត ជាអ្នកតាំងនៅហើយដោយអំណាចនៃមានះ បុគ្គលដែលញុំាងចិត្តឲ្យធ្លាក់ចុះមិនបាន ជាអ្នកតាំងនៅហើយដោយអំណាចនៃវិចិកិច្ឆា ជាបុគ្គលដែលមានការរាយមាយ ជាអ្នកតាំងនៅហើយដោយអំណាចឧទ្ធច្ចៈ ដូច្នេះ ។ បទថា **អក្ខេយ្យំ អបរិញ្ញាយ** សេចក្តីថា ព្រោះមិនដឹងវត្ថុដែលត្រូវពោលដល់នោះ ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយបរិញ្ញាទាំង ៣ ព្រោះហេតុដែលមិនដឹងវត្ថុនោះ ។ បទថា **យោគមាយន្តិ មច្ចុនោ** សេចក្តីថា រមែងចូលដល់គ្រឿងប្រកប ( សំណាញ់ ) នៃមរណៈ និងគ្រឿងចងសត្វជាមួយមរណៈនោះ អធិប្បាយថា មិនបែកពីគ្នា ។ ម្យ៉ាងទៀត បទថា **យោគំ** បានដល់ ឧបាយ លោកអធិប្បាយថា សត្វទាំងឡាយរមែងចូលដល់សំណាញ់ គឺសេចក្តីវិនាស និងសំណាញ់ គឺកិលេស ដែលជាទីតាំងនៃមារ និងសេនា ដែលដាក់បង្កាត់សន្ទឹងទុកដោយឧបាយនោះ សមដូចព្រះតម្រាស់ត្រាស់ក្នុងភទ្ទេករត្តិសូត្រថា

ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុ ដែលមានសេនា
ដ៏ច្រើននោះ មិនមានសោះឡើយ ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងវដ្ត ដោយព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិវដ្ត ទើបត្រាស់ពាក្យជាដើមថា

**អក្ខេយ្យញ្ញូ បរិញ្ញាយ។**

ឥ សព្ទ ក្នុងបទគាថាថា **អក្ខេយ្យញ្ញូ បរិញ្ញាយ** នោះ ចុះក្នុងអត្ថជាព្យតិរេក ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងគុណវិសេសដែលគប្បីបាន ដោយការកំណត់ដឹងវត្ថុដែលពោល គឺកំពុងត្រាស់ដល់នោះឯងឲ្យជាក់ច្បាស់ដោយ ឥ សព្ទនោះ ។ បទថា **បរិញ្ញាយ** សេចក្តីថា ព្រោះកំណត់ដឹងថា ជាទុក្ខ ដោយមគ្គប្បញ្ញាដែលប្រកបដោយវិបស្សនា គឺព្រោះឈានកន្លងនូវទុក្ខនោះ ដោយការលះកិលេសដែលទាក់ទងដោយទុក្ខនោះ ឬព្រោះញ៉ាំងកិច្ចនៃបរិញ្ញាទាំង ៣ ឲ្យដល់ទីបំផុត ។ បទថា **អក្ខាតារំ ន មញ្ញតិ** សេចក្តីថា ព្រះខីណាស្រព ឈ្មោះថា មិនសម្គាល់ថា មានអ្នកបង្គាប់បញ្ជា ព្រោះលះនូវការសម្គាល់បាន ដោយប្រការទាំងពួង អធិប្បាយថា មិនជឿអ្វីដែលជាសភាវៈ មានអ្នកសាងជាដើម ថាជាអត្តា ។ បទថា **ផុដ្ឋោ វិមោក្ខោ មនសា សន្តិបទមនុត្តរំ** សេចក្តីថា ព្រោះព្រះខីណាស្រពពាល់ត្រូវហើយ គឺពាល់ត្រូវហើយ បានដល់ ធម៌ គឺព្រះនិព្វាន ដែលឈ្មោះថា **វិមោក្ខ** ព្រោះផុតចាកសង្ខតធម៌គ្រប់យ៉ាង និងបានឈ្មោះថា **សន្តិបទ** ព្រោះជាទីតាំងនៃការស្ងប់រម្ងាប់នូវការក្តៅក្រហាយ ដែលកើតអំពីកិលេសទាំងពួង ព្រោះដូច្នោះទើបលោកមិនសម្គាល់ថា មានអ្នកបង្គាប់បញ្ជា ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលត្រាស់ការសម្រេចនូវទុក្ខសច្ចដោយបរិញ្ញាកិច្ច និងសម្រេចសមុទយសច្ចដោយបហានកិច្ចហើយ ដោយពាក្យថា បរិញ្ញាយ ដូច្នេះ ឥឡូវនេះ ទើបត្រាស់ការសម្រេចមគ្គ ដោយភាវនាកិច្ច និង

*និរោធ ដោយសច្ចិកិរិយាកិច្ច ដោយពាក្យនេះថា* **ផុដ្ឋា វិមោក្ខា មនសា សន្តិបទមនុត្តរំ** *ពាក្យនោះ មានអធិប្បាយថា អរិយមគ្គ ឈ្មោះថា* **វិមោក្ខ** *ព្រោះផុតចាកកិលេសទាំងឡាយ ដោយអំណាចសមុច្ឆេទប្បហាន ។ វិមោក្ខ នោះ លោកពាល់ត្រូវហើយ គឺបានសម្ផស្សហើយ បានដល់ ចម្រើនហើយ ដោយមគ្គចិត្ត ដោយហេតុនោះឯង ព្រះនិព្វានជាសន្តិបទដ៏កំពូល ឈ្មោះថា លោកពាល់ត្រូវហើយ គឺបានសម្ផស្សហើយ បានដល់ ធ្វើឲ្យជាក់ច្បាស់ ហើយ ។ បទថា* **អាកាស្ពេយ្យសម្បន្នា** *សេចក្តីថា បុគ្គលរួចផុតល្អហើយ ចាកអក្ខេយ្យនិមិត្តនោះ ព្រោះលះវិបល្លាសក្នុងលោក ដែលត្រូវវិបត្តិប្រភេទ ផ្សេងៗ កម្ចាត់ហើយចេញបាន ឈ្មោះថា ជាអ្នកដល់ព្រមហើយនូវអក្ខេយ្យ-និមិត្ត គឺប្រកបដោយសម្បត្តិទាំងឡាយ ដែលកើតហើយចាកការកំណត់ដឹង នូវវត្ថុដែលត្រូវពោលដល់ ។ បទថា* **សង្ខាយ សេវី** *សេចក្តីថា ជាអ្នកមាន ប្រក្រតីពិចារណា គឺពិចារណាហើយ ទើបសេពនូវបច្ច័យ មានចីវរជាដើម ព្រោះដល់នូវការបរិបូណ៌នៃបញ្ញា ។ ម្យ៉ាងទៀត ជាអ្នកមានប្រក្រតីពិចារណា អារម្មណ៍សព្វយ៉ាង ដែលមកកាន់គន្លង ហើយសេពដោយអំណាចនៃឆឡង្គុ-បេក្ខា ព្រោះជាអ្នកមានធម៌ដែលរាប់បានហើយ ។ បទថា* **ធម្មដ្ឋោ** *សេចក្តី ថា ជាអ្នកតាំងនៅហើយក្នុងអសេក្ខធម៌ គឺនិព្វានធម៌នោះឯង ។ បទថា* **វេទគូ** *សេចក្តីថា ជាអ្នកដល់នូវវេទ ព្រោះដល់នូវត្រើយនៃអរិយសច្ច ៤ ដែលគប្បី ដឹង ។ បុគ្គលមានគុណយ៉ាងនេះ ជាព្រះអរហន្ត រមែងមិនឈ្មោះថា ចូលដល់ នូវការរាប់ថា ជាមនុស្ស ឬទេវតា ព្រោះមិនមានភពថ្មី ក្នុងបណ្តាភពទាំង-*

ឡាយ ភពណាមួយតទៅទៀតឡើយ គឺដល់នូវភាពជាបុគ្គលមិនមានបញ្ញត្តិ ។ ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនា ដោយអនុបាទាទិសេសនិព្វាន ដោយប្រការដូចពោលមកនេះ ។៚

## អដ្ឋកថា អទ្ធាសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ទុច្ចរិតសូត្រ

[ ៦៤ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ទុច្ចរិតនេះមាន ៣ ។ ទុច្ចរិត ៣ តើដូចម្តេច ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ ទុច្ចរិតមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលធ្វើកាយទុច្ចរិតផង វចីទុច្ចរិតផង ធ្វើមនោទុច្ចរិតផង
នូវអំពើណាមួយ ដែលប្រកបដោយទោសផង មិនធ្វើនូវ
អំពើជាកុសល ធ្វើតែអំពើជាអកុសលដ៏ច្រើន បុគ្គលឥត
ប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## ទុច្ចរិតសូត្រ

ក្នុងទុច្ចរិតសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៤ ] ការប្រព្រឹត្តអាក្រក់ ឬការប្រព្រឹត្តថោកទាប ឈ្មោះថា **ទុច្ចរិត**។ ការប្រព្រឹត្តអាក្រក់ដោយកាយ ឬការប្រព្រឹត្តអាក្រក់ ដែលប្រព្រឹត្តទៅហើយតតាមកាយ ឈ្មោះថា **កាយទុច្ចរិតំ**។ ក្នុងបទទាំងឡាយដ៏សេសក៏មានន័យនេះដូចគ្នា ។

ទុច្ចរិតទាំងនេះ គួរពោលតាមបញ្ញត្តិខ្លះ តាមកម្មបថខ្លះ បណ្តាបទទាំង ២ យ៉ាងនោះ នឹងពោលតាមបញ្ញត្តិមុន ការល្មើសសិក្ខាបទដែលទ្រង់បញ្ញត្តិតាមកាយទ្វារ ជាកាយទុច្ចរិត ការល្មើសសិក្ខាបទដែលទ្រង់បញ្ញត្តិហើយតាមវចីទ្វារ ជាវចីទុច្ចរិត ។ ការប្រព្រឹត្តកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តិទាំង ២ នោះ ជាមនោទុច្ចរិតនោះឯង គឺការពោលតាមបញ្ញត្តិ ។ ឯចេតនា ៣ មានបាណាតិបាតជាដើម ដែលកើតឡើងទាំងកាយទ្វារ ទាំងវចីទ្វារ ឈ្មោះថា **កាយទុច្ចរិត**។ ចេតនាទាំង ៤ មានមុសាវាទជាដើមក៏ដូច្នោះ ឈ្មោះថា ជា **វចីទុច្ចរិត** ។ ធម៌ដែលប្រកបដោយចេតនា ៣ យ៉ាង គឺអភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ ឈ្មោះថាជា **មនោទុច្ចរិត** នោះឯង គឺការពោលតាមកម្មបថ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បាបធម៌ដែលដល់នូវកម្មបថនោះឯង ព្រះមានព្រះភាគត្រាស់ដោយភាពជាកាយទុច្ចរិតជាដើម ព្រោះដូច្នោះ ដើម្បីទ្រង់សង្គ្រោះយកបាបធម៌ដទៃនោះចូលផង ទើបទ្រង់ត្រាស់ថា

**យញ្ញាញ្ញំ នោសសញ្ញិតំ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **យញ្ញាញ្ញំ នោសសញ្ញិតំ** បានដល់ ប្រកបដោយកិលេស មានរាគៈជាដើម ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា ទុច្ចរិតសូត្រទី ៥ ចប់**

# សុចរិតសូត្រ

[ ៦៥ ] ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សុចរិតនេះ មាន ៣ ។ សុចរិត ៣ តើអ្វីខ្លះ ។ គឺកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ សុចរិតមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា លះនូវកាយទុច្ចរិតផង នូវវចីទុច្ចរិតផង លះ
នូវមនោទុច្ចរិតផង នូវអំពើណាមួយ ដែលប្រកបដោយ
ទោសផង មិនធ្វើអកុសលកម្ម ធ្វើតែកុសលកម្មដ៏ច្រើន
បុគ្គលប្រកបដោយប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ
រមែងទៅកើតក្នុងស្ថានសួគ៌ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## សុចរិតសូត្រ

ក្នុងសុចរិតសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៥ ] ការប្រព្រឹត្តិល្អ ឬការប្រព្រឹត្តិស្អាត ឈ្មោះថា **សុចរិត** ។ ការប្រព្រឹត្តិល្អដោយកាយ ឬការប្រព្រឹត្តិល្អដែលប្រព្រឹត្តទៅហើយ ដោយកាយ ឈ្មោះថា **កាយសុចរិតំ**។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។

ក្នុងព្រះសូត្រនេះ មានពោលដល់ ២ យ៉ាងដូចគ្នា គឺដោយអំណាចនៃបញ្ញត្តិ និងដោយអំណាចនៃកម្មបថ ។ បណ្តា ២ យ៉ាងនោះ ការមិនល្មើសសិក្ខាបទ ដែលទ្រង់បញ្ញត្តិហើយតាមកាយទ្វារ ឈ្មោះថា **កាយសុចរិត** ។ ការមិនល្មើសសិក្ខាបទដែលទ្រង់បញ្ញត្តហើយតាមវចីទ្វារ ឈ្មោះថា **វចី-សុចរិត**។ ការមិនល្មើសសិក្ខាបទដែលទ្រង់បញ្ញត្តិហើយទាំង ២ ទ្វារ ឈ្មោះថា ជា **មនោសុចរិត** ព្រោះដូច្នោះ នេះជាការពោលតាមបញ្ញត្តិ ចំណែកចេតនាក្តី វិរតិ ៣ ក្តី ដែលកើតឡើងហើយ ដល់បុគ្គលអ្នកវៀរចាកបាណា-តិបាតជាដើម ជា **កាយសុចរិត** ចេតនាក្តី វិរតិ ៤ ក្តី ដែលកើតឡើងដល់បុគ្គលអ្នកវៀរចាកមុសាវាទជាដើម ជា **វចីសុចរិត** ។ ធម៌ដែលសម្ប-យុត្តដោយចេតនា ៣ យ៉ាង គឺអនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ជា **មនោ-សុចរិត** ព្រោះដូច្នោះ នេះជាការពោលតាមកម្មបថ ។ ពាក្យដ៏សេសមានន័យដូចពោលហើយ ។៚

**អដ្ឋកថា សុចរិតសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សោចេយ្យសូត្រ

[ ៦៦ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សោចេយ្យៈ ( សេចក្តីស្អាត ) នេះ មាន ៣ ។ សោចេយ្យៈ ៣ តើអ្វីខ្លះ ។ គឺកាយសោចេយ្យៈ ១ វចីសោចេយ្យៈ ១ មនោសោចេយ្យៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សោចេយ្យៈ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

( ពួកព្រះអរិយៈ មានព្រះពុទ្ធជាដើម ) តែងហៅនូវ
បុគ្គលអ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត មិនមាន
អាសវៈ លះបង់នូវទុច្ចរិតទាំងពួង ថាជាអ្នកស្អាត
បរិបូណ៌ដោយសេចក្តីស្អាត ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## សោចេយ្យសូត្រ

ក្នុងសោចេយ្យសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៦ ] បទថា **សោចេយ្យានិ** បានដល់ ការស្អាត ។ បទថា **កាយសោចេយ្យំ** បានដល់ កាយសុចរិត ។ សូម្បី **វចីសោចេយ្យ** និង **មនោសោចេយ្យ** ក៏បានដល់ វចីសុចរិត និងមនោសុចរិតនោះឯង ។ សម ដូចពាក្យដែលត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា

ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានេះ ឈ្មោះថា ការស្អាតតាមកាយ ព្រោះលះនូវកាយទុច្ចរិតគ្រប់យ៉ាងបានហើយ ដោយអំណាចនៃការកាត់ផ្តាច់ ព្រោះដូច្នោះ ទើបឈ្មោះថា ការស្អាតតាមកាយ ។ បទថា **សោចេយ្យសម្បន្នំ** សេចក្តីថា ចូលដល់ហើយដោយសោចេយ្យសម្បត្តិ ដែលបរិសុទ្ធល្អហើយ ព្រោះរម្ងាប់នូវកិលេសបានហើយ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ល។

**អដ្ឋកថា សោចេយ្យសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## មោនេយ្យសូត្រ

[ ៦៧ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ មោនេយ្យៈ ( ការស្ងប់ស្ងៀម ) នេះ មាន ៣ ។ មោនេយ្យៈ ៣ តើអ្វីខ្លះ ។ គឺកាយមោនេយ្យៈ ១ វចីមោនេយ្យៈ ១ មនោមោនេយ្យៈ ១ ។ ម្នាលភិក្ខុទាំងឡាយ មោនេយ្យៈ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

( ពួកព្រះអរិយៈ មានព្រះពុទ្ធជាដើម ) តែងហៅនូវបុគ្គល
អ្នកស្ងប់ស្ងៀមកាយ ស្ងប់ស្ងៀមវាចា ស្ងប់ស្ងៀមចិត្ត
មិនមានអាសវៈ អ្នកលាងមន្ទិលដ៏លាមកចោលហើយ
ថាជាអ្នកស្ងប់ស្ងៀម បរិបូណ៌ដោយការស្ងប់ស្ងៀម ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## មោនេយ្យសូត្រ

*ក្នុងមោនេយ្យសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*[ ៦៧ ] បទថា* **មោនេយ្យានិ** *នេះ បុគ្គលឈ្មោះថា* **មុនិ** *ព្រោះដឹងលោកនេះផង ព្រោះដឹងលោកខាងមុខផង ប្រយោជន៍របស់ខ្លួនផង ប្រយោជន៍អ្នកដទៃផង បានដល់ ព្រះសេក្ខបុគ្គល ៧ ពួក មួយអន្លើដោយកល្យាណ-បុថុជ្ជន និងព្រះអរហន្ត ។ តែក្នុងទីនេះ ទ្រង់បំណងយកព្រះអរហន្តប៉ុណ្ណោះ ។ ភាពនៃមុនី ព្រោះដូច្នោះ ទើបឈ្មោះថា* **មោនេយ្យ** *បានដល់ កាយសមាចារ វចីសមាចារ និងមនោសមាចាររបស់ព្រះអរហន្ត ។ម្យ៉ាងទៀត ធម៌ គឺមោនេយ្យប្បដិបទា ដែលធ្វើឲ្យជាមុនី ឈ្មោះថា* **មោនេយ្យ។**

*មោនេយ្យៈទាំងនោះ មានសេចក្ដីពិស្ដារក្នុងមហានិទ្ទេសដូចតទៅនេះ*

*កាយមោនេយ្យៈ តើដូចម្ដេច ។ ការលះបង់កាយទុច្ចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្យៈ ។ កាយសុចរិត ៣ យ៉ាង ឈ្មោះថា កាយមោនេយ្យៈ ។ ញាណ មានកាយជាអារម្មណ៍ ឈ្មោះថា កាយមោនេយ្យៈ ។ ការកំណត់ដឹងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅ មួយអន្លើដោយការកំណត់ដឹង ឈ្មោះថា កាយមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងកាយ ឈ្មោះថា កាយមោនេយ្យៈ ។ ចតុត្ថជ្ឈានសមាបត្តិ ដែលរលត់កាយសង្ខារ ឈ្មោះថា កាយមោនេយ្យៈ ។ នេះ ឈ្មោះថា កាយមោនេយ្យ ។*

វចីមោនេយ្យៈ តើដូចម្តេច ។ ការលះបង់វចីទុច្ចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យៈ ១ ។ វចីសុចរិត ៤ យ៉ាង ឈ្មោះថា វចីមោនេយ្យៈ ។ ញាណ មានវាចាជាអារម្មណ៍ ឈ្មោះថា វចីមោនេយ្យៈ ។ ការកំណត់ដឹងវាចា ឈ្មោះថា វចីមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅ មួយអន្លើដោយការកំណត់ដឹង ឈ្មោះថា វចី-មោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងវាចា ឈ្មោះថា វចីមោ-នេយ្យៈ ។ ទុតិយជ្ឈានសមាបត្តិ ដែលរម្ងាប់វចីសង្ខារ ឈ្មោះថា វចីមោនេយ្យៈ ។ នេះ ឈ្មោះថា វចីមោនេយ្យៈ ។

មនោមោនេយ្យៈ តើដូចម្តេច ។ ការលះបង់មនោទុច្ចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យៈ ។ មនោសុចរិត ៣ យ៉ាង ឈ្មោះថា មនោមោនេយ្យៈ ។ ញាណ មានចិត្តជាអារម្មណ៍ ឈ្មោះថា មនោមោនេយ្យៈ ។ ការកំណត់ដឹងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ មគ្គប្រព្រឹត្តទៅ មួយអន្លើដោយការកំណត់ដឹង ឈ្មោះថា មនោមោនេយ្យៈ ។ ការលះបង់ឆន្ទរាគក្នុងចិត្ត ឈ្មោះថា មនោមោនេយ្យៈ ។ សញ្ញាវេទយិតនិរោធសមាបត្តិ ដែលរម្ងាប់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យៈ ។ នេះ ឈ្មោះថា មនោមោនេយ្យៈ ដូច្នេះ ។

បទថា **និន្ហាតបាបកំ** សេចក្តីថា ជាអ្នកមានមន្ទិល គឺបាបដែលលាងល្អហើយ ដោយទឹកដ៏ប្រសើរ គឺអដ្ឋង្គិកមគ្គ ៕៚

# សុត្តន្តបិដក

## បឋមរាគសូត្រ

[ ៦៨ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មិនបាន លះរាគៈ មិនបានលះទោសៈ មិនបានលះមោហៈទេ ម្នាលភិក្ខុទាំងឡាយ បុគ្គល នេះ ហៅថា ជាអ្នកត្រូវមារចងបានផង ត្រូវអន្ទាក់មារបញ្ចូលហើយផង ជាអ្នក ត្រូវមារមានចិត្តបាបធ្វើបានតាមប្រាថ្នាផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណា មួយ បានលះរាគៈ លះទោសៈ លះមោហៈហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គល នេះ ហៅថា ជាអ្នកមិនត្រូវមារចងបានផង អន្ទាក់របស់មារក៏ថ្ងោះចេញផង មារ មានចិត្តបាបធ្វើមិនបានតាមប្រាថ្នាផង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តី នុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា ឃ្លាតចេញចាករាគៈផង ទោសៈផង អវិជ្ជា
ផង ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម តែង
ហៅនូវបុគ្គល អ្នកមានខ្លួនចម្រើនហើយ លះបង់នូវ
កិលេសទាំងពួងនោះថា ជាអរហន្ត ជាព្រហ្ម ជាព្រះ
តថាគត ជាព្រះពុទ្ធ អ្នកកន្លងបង់នូវពៀរ និងភ័យ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## បឋមរាគសូត្រ

ក្នុងបឋមរាគសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៨ ] បទថា **យស្ស កស្សចិ** ជាពាក្យពោលដល់បុគ្គលដែលមិនបានកំណត់ពិតប្រាកដ ព្រោះដូច្នោះ កាលបុគ្គលណាម្នាក់ ជាគ្រហស្ថក្តី ជាបព្វជិតក្តី ។ បទថា **រាគោ អប្បហីនោ** សេចក្តីថា កិលេស ឈ្មោះថា **រាគ** ព្រោះអត្ថថា តម្រេកដែលបុគ្គលណាម្នាក់ មិនទាន់លះបានហើយដោយអំណាចនៃសមុច្ឆេទប្បហាន គឺមិនឲ្យដល់នូវការកើតឡើងជាធម្មតាដោយមគ្គ ។ ក្នុងទោសៈ និងមោហៈទាំងឡាយ ក៏មានន័យដូចគ្នា ។ បណ្តាកិលេសទាំងនោះ រាគៈ ទោសៈ មោហៈ ដែលនឹងឲ្យទៅអបាយ នឹងលះបានដោយបឋមមគ្គ កាមរាគយ៉ាងគ្រោតគ្រាត និងទោសៈដែលគ្រោតគ្រាត លះបានដោយទុតិយមគ្គ កាមរាគ និងទោសៈទាំងនោះឯង លះមិនមានសេសសល់ដោយតតិយមគ្គ ។ ភវរាគៈ និងមោហៈដ៏សេស លះបានដោយមគ្គទី ៤ ។ កាលលះកិលេសទាំងនេះបានយ៉ាងនេះ កិលេសទាំងអស់ រមែងលះបានដូចគ្នា ព្រោះតាំងនៅក្នុងទីតែមួយនឹងកិលេសទាំងនោះ ។ រាគៈជាដើម តាមដែលពណ៌នាមកនេះ បុគ្គលណាម្នាក់ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី មិនទាន់លះបានដោយមគ្គ ។

បទថា **ពទ្ធោ មារស្ស** សេចក្តីថា បុគ្គលនោះ តថាគតហៅថា ត្រូវមារ គឺកិលេសចងហើយ និងត្រូវកិលេសមារចងហើយដោយអន្ទាក់ដ៏ក្រៃលែង ដែលត្រូវអភិសង្ខារមារជាដើមចងហើយ ដោយអន្ទាក់ដ៏ក្រៃលែង

នោះដូចគ្នា ។ បទថា **បដិមុក្កស្ស មារបាសោ** សេចក្តីថា កិលេស ពោល គឺអន្ទាក់នៃមារ ឈ្មោះថា បុគ្គលនេះមិនទាន់លះកិលេស បានទាក់ចងហើយ ព្រោះមិនទាន់លះកិលេសបាននោះឯង អធិប្បាយថា រឹតហើយ គឺស៊កចូល ទៅហើយក្នុងចិត្តសន្តានរបស់ខ្លួន បានដល់ ត្រូវមារនោះបង្គាប់ឲ្យចងឯង ។ ម្យ៉ាងទៀត អន្ទាក់មារគប្បីជារបស់ដែលគេចងហើយ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងធម៌ចំណែក-សុតទៅនេះ បទថា **ឱមុក្កស្ស** សេចក្តីថា អន្ទាក់មារនោះ គប្បីជារបស់ដែលគេដោះ គឺស្រាយហើយ បានដល់ តាំងនៅមិនបាន ។ ពាក្យដ៏សេស គប្បីជ្រាបតាមបរិយាយដែលផ្ទុយគ្នា តាមដែលពោលមក ហើយ ។

ក្នុងព្រះសូត្រនេះ គាថាមានមកហើយ ដោយអំណាចនៃធម៌ដែលជា ចំណែក-សប៉ុណ្ណោះ ក្នុងគាថានោះមានសេចក្តីសង្ខេបដូចតទៅនេះ ព្រះអរិយៈ ទាំងឡាយ មានព្រះពុទ្ធជាដើម ពោលដល់ព្រះអរិយបុគ្គលដែលខ្ជាក់ចោល នូវរាគៈ ទោសៈ និងអវិជ្ជាចេញហើយ គឺឲ្យរលត់ទៅហើយដោយអគ្គមគ្គ ដែលមានកាយអប់រំហើយថា ជាបុគ្គលប្រសើរ គឺជាព្រះព្រហ្ម ឬជាបុគ្គល ប្រសើរបំផុត គឺសម្រេចអរហត្តផលហើយ អង្គណាមួយអង្គ ក្នុងបណ្តាព្រះ អរហន្តទាំងឡាយ ដែលឈ្មោះថា អប់រំខ្លួនហើយ ព្រោះមានសីល សមាធិ និងបញ្ញា ព្រះនីណាស្រេពដទៃៗ ជាអ្នកប្រកបដោយគុណសម្បត្តិ គឺឧប- និស្ស័យក្នុងកាលមុនមកហើយ លោកអ្នកទាំងនោះដល់ហើយ គឺសម្រេចហើយ នូវព្រះនិព្វាន ដោយមជ្ឈិមប្បដិបទាដែលសង្គ្រោះដោយសីលក្ខន្ធ សមាធិក្ខន្ធ

និងបញ្ញាខន្ធ វៀរចាកអន្តធម៌ទាំង ២ ។ ម្យ៉ាងទៀត លោកអ្នកទាំងនោះ ចាក់ធ្លុះនូវលក្ខណៈដែលពិតនៃខន្ធជាដើមតាមសេចក្តីពិត លោកអ្នកទាំងនោះ ដឹងក្រៃលែងហើយនូវទុក្ខជាដើម ដែលជាធម៌ពិត ដោយមិនខុសក្លាំងក្លាត់ ហើយលោកទាំងនោះ ឃើញអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយ អំណាចត្រឹមតែឃើញប៉ុណ្ណោះ ។ ម្យ៉ាងទៀត ព្រះអរិយបុគ្គល ៨ ពួកនេះ មានវាចាប្រព្រឹត្តទៅហើយ ដោយអំណាចនៃអរិយវោហារតែម្យ៉ាង ដោយ វៀរវោហារដែលមិនមែនរបស់ព្រះអរិយៈ មានកាយប្រព្រឹត្តទៅហើយ ដោយ សមគួរដល់វាចា និងមានវាចាប្រព្រឹត្តទៅហើយ សមគួរដល់កាយ យ៉ាងណា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ពោល គឺហៅ បានដល់ សរសើរ បុគ្គលនោះ ដែលទៅហើយយ៉ាងនោះថា លោកអ្នកទាំងនេះជាព្រះអរិយបុគ្គល ដែលឈ្មោះថា **ពុទ្ធំ** ព្រោះដឹងអរិយសច្ច ៤ ដែលឈានកន្លងចាកបុគ្គល វេរ ចាកកិលេសវេរ និងភ័យ មានការតិះដៀលខ្លួនឯងជាដើម ឈ្មោះថា **វេរភយាតីតំ** ដែលឈ្មោះថា **សព្វបហាយិនំ** ព្រោះលះកិលេស និង អភិសង្ខារជាដើមទាំងមូលបាន ដូច្នោះ ។

**អដ្ឋកថាបឋមភាគសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយរាគសូត្រ

[ ៦៩ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី មិនបានលះរាគៈ មិនបានលះទោសៈ មិនបានលះមោហៈទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា មិនបានឆ្លងនូវសមុទ្រ ( គឺសំសារ ) ដែលប្រកបដោយរលកធំ ប្រកបដោយរលកតូច ( គឺសេចក្តីក្រោធ និងឧបាយាសៈ ) ប្រកបដោយអាវដ្តៈ ( គឺកាមគុណ ៥ ) ប្រកបដោយការចាប់ទាំងប្រកបដោយអារក្សទឹក ( គឺវិសភាគបុគ្គលដែលប្រាកដស្មើ ដោយមករកាច និងត្រីកាច ) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី បានលះរាគៈ លះទោសៈ លះមោហៈហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ហៅថា បានឆ្លងសមុទ្រ ដែលប្រកបដោយរលកធំ ប្រកបដោយរលកតូច ប្រកបដោយអាវដ្តៈ ប្រកបដោយការចាប់ ទាំងប្រកបដោយអារក្សទឹក បានឈ្មោះថា ខីណាសវព្រាហ្មណ៍ បានឆ្លងទៅកាន់ត្រើយខាងនាយ ហើយស្ថិតនៅលើគោក ( គឺព្រះនិព្វាន ) ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណា ឃ្លាតចាករាគៈផង ទោសៈផង អវិជ្ជាផង
បុគ្គលនោះ ឈ្មោះថា បានឆ្លងនូវសមុទ្រនេះ ដែល
ប្រកបដោយការចាប់ ប្រកបដោយអារក្សទឹក ទាំង
ប្រកបដោយរលកធំ គួរខ្លាច ដែលឆ្លងបានដោយ កម្រ

ជាអ្នកកន្ទន់នូវកិលេស ជាគ្រឿងជាប់ចំពាក់ លះបង់មច្ចុ
មិនមានឧបធិ បានលះបង់ទុក្ខ ដើម្បីមិនទៅកើតក្នុង
ភពថ្មីទៀត បុគ្គលនោះ ឈ្មោះថា សម្រេចប្រយោជន៍
គឺព្រះនិព្វាន រមែងមិនដល់នូវការរាប់ដោយ ( នាម
និងគោត្ត ) ឡើយ តថាគតពោលថា បុគ្គលនោះ
បានញ៉ាំងមច្ចុរាជឲ្យវង្វេង ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

### វគ្គទី ២ ចប់

## ឧទ្ទាននៃទុតិយវគ្គនោះ គឺ

និយាយអំពីបុញ្ញកិរិយាវត្ថុ ១ ចក្ខុ ១ ឥន្ទ្រិយ ១
កាល ១ ចរិត ២ លើក សេចក្តីស្អាត ១ ការស្ងប់
ស្ងៀម ១ រាគៈ ២ លើក លោកពោលនូវវគ្គទីពីរថា
ជាវគ្គដ៏ឧត្តម ។

# អដ្ឋកថា

## ទុតិយភាគសូត្រ

ក្នុងទុតិយភាគសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៦៩ ] បទថា **ន អតរិ** ប្រែថា ឆ្លងមិនបាន ។ បទថា **សមុទ្ទំ** បាន ដល់ សមុទ្រ គឺសង្សារ ឬសមុទ្រ គឺអាយតនៈ មានចក្ខាយតនៈជាដើម សង្សារ និងអាយតនៈទាំង ២ យ៉ាងនោះ ឈ្មោះថា **សមុទ្ទ** ព្រោះដូចជាសមុទ្រ ដោយអត្ថថា បំពេញបានដោយលំបាក ។ម្យ៉ាងទៀត ឈ្មោះថា **សមុទ្ទ** ព្រោះអត្ថថា ដូចសមុទ្រ អធិប្បាយថា ឈ្មោះថា ដូចជាសមុទ្រ ព្រោះជាទីនៅអាស្រ័យនៃកិលេស គឺព្រោះសន្តានរបស់សត្វដែលជាផ្ទះរបស់កិលេស ។ បទថា **សវីចឹ** សេចក្តីថា មានរលក ដោយរលក គឺសេចក្តីក្រោធ និងការចង្អៀតចង្អល់ សមដូចព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីរលកនេះឯង ជាឈ្មោះនៃសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ចិត្ត ។ បទថា **សាវដ្តំ** សេចក្តីថា ដល់ព្រមដោយអន្ទង់ ដោយអន្ទង់ គឺកាមគុណ ៥ សមដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីទឹកកួចវិលនេះឯង ជាឈ្មោះនៃកាមគុណ ៥ ។ បទថា **សគហំ សរក្ខសំ** សេចក្តីថា ឈ្មោះថា ប្រកបដោយបុគ្គលដែលជាវិសភាគគ្នា ដូចគ្នានឹងមករកាច ត្រីកាច និងអារក្ខទឹកសមុទ្រ ព្រោះឲ្យកើតអនត្ថៈដល់បុគ្គលដែលទៅកាន់ទីរកស៊ីរបស់ខ្លួន ។ សមដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីត្រីកាចនេះ ជាឈ្មោះនៃមាតុគ្រាម ។ បទថា **អតរិ** សេចក្តីថា ឆ្លងផុតសមុទ្រតាមដែលពោលហើយ

ដោយសំពៅ គឺមគ្គប្បញ្ញា ។ បទថា **តិណ្ណោ** ប្រែថា ឆ្លងផុតទៅហើយ ។ បទថា **ចារគតោ** បានដល់ ជាអ្នកចូលដល់ត្រើយ គឺត្រើយខាងនាយនៃសមុទ្រនោះ បានដល់ និរោធ ។ បទថា **ថលេ តិដ្ឋតិ** សេចក្ដីថា បន្ទាប់អំពីនោះទៅ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ដែលបន្សាត់បាបហើយ ឈរលើគោក គឺត្រើយនាយ បានដល់ ព្រះនិព្វាន ព្រោះឆ្លងអន្លង់ទឹកធំ គឺសង្សារ និងអន្លង់ទឹកធំ មានកាមជាដើម ។

ក្នុងព្រះសូត្រនេះ គាថាក៏មានមកហើយ ដោយអំណាចនៃធម៌ដែលជាចំណែកសដូចគ្នា ។ បណ្ដាបទទាំងនោះ បទថា **ឧម្មិភយំ** បានដល់ ភ័យអំពីរលក តាមដែលពោលហើយ រលកនោះ ឈ្មោះថា ជាភ័យ ព្រោះជាដែនគប្បីខ្លាច ។ បទថា **ឧត្តរំ** បានដល់ ឆ្លងបានលំបាកពន់ពេក ។ បទថា **អច្ចតរិ** ប្រែថា បានឆ្លងផុតហើយ ។ បទថា **សង្គាតិគោ** សេចក្ដីថា ឈ្មោះថា ឆ្លងគ្រឿងជាប់ជំពាក់ទៅហើយ ព្រោះជាអ្នកឈានកន្លង គឺលះនូវគ្រឿងជាប់ជំពាក់ ៥ យ៉ាង មានរាគៈជាដើម បានហើយ ។ បទថា **អដ្ឋង្គតោ សោ ន បមាណមេតិ** សេចក្ដីថា បុគ្គលនោះយ៉ាងនោះ គឺជាព្រះអរហន្ត ឈ្មោះថា ជាអ្នកដល់នូវការដាច់សូន្យហើយ ព្រោះកិលេស មានរាគៈជាដើម ដែលជាធម៌ធ្វើប្រមាណ ដល់ការរលត់ សូន្យទៅ ដោយចំណែកមួយពិត ។ បន្ទាប់អំពីនោះទៅ ជាអ្នកដែលបុគ្គលណាម្នាក់ មិនអាចរាប់បានថា បុគ្គលនោះ បែបនេះ ដោយសីល ដោយសមាធិ ដោយបញ្ញា ព្រោះបរិបូណ៌នៃធម្មក្ខន្ធ មានសីលជាដើម ឈ្មោះថា មិនដល់នូវការរាប់ ។ ម្យ៉ាងទៀត បុគ្គល

នោះ ដល់នូវការតាំងនៅមិនបាន ពោល គឺអនុបាទិសេសនិព្វាន ឈ្មោះថា រមែងមិនដល់ គឺមិនចូលដល់ការរាប់ ព្រោះជាបុគ្គលដែលបុគ្គលណាម្នាក់ មិនអាចនឹងរាប់បានថា ព្រះអរហន្តនោះ ជាអ្នកតាំងនៅហើយ ដោយគតិនេះ នឹងជាបុគ្គលបែបនេះ ដោយឈ្មោះ និងគោត្រ ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះធម្មទេសនា ដោយអនុបាទិសេសនិព្វានធាតុនោះឯងថា តថាគតពោលថា ភិក្ខុនោះញុំាងមច្ចុរាជឲ្យវង្វេងបានហើយ គឺជាបុគ្គលដែលមច្ចុរាជមិនអាចជាប់តាមបាន ។

ក្នុងវគ្គនេះ គប្បីជ្រាបថា ព្រះមានព្រះភាគបានត្រាស់វដ្តៈ ក្នុងសូត្រទី ១ ទី ៥ និងទី ៦ ត្រាស់វិវដ្តៈ ក្នុងសូត្រទី ២ ទី ៧ និងទី ៨ ត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ក្នុងព្រះសូត្រដ៏សេស ដោយប្រការដូចពណ៌នាមកនេះ ។

**អដ្ឋកថា ទុតិយភាគសូត្រទី ១០ ចប់**

**វគ្គទី ២ ចប់**

# សុត្តន្តបិដក

# ឥតិវុត្តក តិកនិបាត តតិយវគ្គ

## មិច្ឆាទិដ្ឋិកសូត្រ

[ ៧០ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឮសេចក្តីនោះ ( អំពីសម្នាក់ ) នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយពោលទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ លុះតែហេតុណាដែលតថាគតដឹងដោយខ្លួនឯង ឃើញដោយខ្លួនឯង ជ្រាបច្បាស់ដោយខ្លួនឯង ទើបតថាគតពោលនូវហេតុនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វដែលប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោ-ទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងអបាយ ទុគ្គតិ

វិនិបាត នរក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលក្នុងលោកនេះ ជាអ្នកស្តាប់តិច មិនបានធ្វើបុណ្យ
តម្កល់ចិត្តខុស ពោលវាចាខុស ធ្វើការងារខុសដោយ
កាយ បុគ្គលនោះជាអ្នកឥតប្រាជ្ញា លុះបែកធ្លាយរាង
កាយស្លាប់ទៅ ព្រោះជីវិត ក្នុងមនុស្សលោកនេះតិច
ណាស់ រមែងកើតក្នុងនរក ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## មិច្ឆាទិដ្ឋិកសូត្រ

[ ៧០ ] ក្នុងមិច្ឆាទិដ្ឋិកសូត្រទី ១ នៃវគ្គទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ទិដ្ឋា មយា** សេចក្តីថា សត្វទាំងឡាយដែលតថាគតឃើញហើយ គឺដែលតថាគតឃើញហើយ ដោយចក្ខុទាំងពីរ គឺសមន្តចក្ខុនិងទិព្វចក្ខុ បានដល់ ដោយប្រចក្ស ។ ដោយពាក្យថា **ទិដ្ឋា មយា** នោះព្រះមានព្រះភាគ ទ្រង់ជំទាស់នូវការបានស្តាប់តាមគ្នាមកជាដើម សេចក្តីនេះនឹងមានមកក្នុងព្រះបាលី ក្នុងឥឡូវនេះឯង ។ បទថា **កាយទុច្ចរិតេន សមន្នាគតា** សេចក្តីថា ជាអ្នកដល់ព្រមដោយកាយទុច្ចរិត ។ បទថា **អរិយានំ ឧបវាទកា** សេចក្តីថា ជាអ្នកប្រទូស្ត គឺជេរ បានដល់ តិះដៀលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ដោយហោចសូម្បីព្រះសោតាបន្នដែលជាគ្រហស្ថ ដោយការពោលបន្ទាប់ដែលមិនពិត ជាហេតុកម្ចាត់នូវគុណ ។ បទថា **មិច្ឆាទិដ្ឋិកា** បានដល់ ជាអ្នកមានការឃើញខុស ។ បទថា **មិច្ឆាទិដ្ឋិកម្មសមាទានា** សេចក្តីថា បុគ្គលណា សមាទាននូវកម្មច្រើនប្រភេទព្រោះមានការឃើញខុសជាហេតុនោះឯង និងសមាទានកម្មដទៃទៀត មានកាយកម្មជាដើម ដែលមានមិច្ឆាទិដ្ឋិជាមូល ។ កាលអរិយូបវាទកម្ម និងមិច្ឆា-ទិដ្ឋិ ទ្រង់កាន់យកហើយ ដោយវចីទុច្ចរិត និងមនោទុច្ចរិតនោះឯង ក្នុងទីនេះកាលត្រាស់ដដែលទៀត ក៏ដើម្បីទ្រង់សម្តែងថា អរិយូបវាទកម្ម និងមិច្ឆាទិដ្ឋិមានទោសច្រើន ព្រោះថា បណ្តា ២ យ៉ាងនោះ អរិយូបវាទមានទោសច្រើន

ស្មើគ្នានឹងអនន្តរិយកម្ម ។ សមដូចព្រះតម្រាស់ក្នុងមហាសីហនាទសូត្រថា

ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផល ក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះ ជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យក៏យ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរង់ទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់យ៉ាងនោះដែរ ដូច្នេះ ។ កម្មដទៃដែលឈ្មោះថា មានទោសច្រើនជាងមិច្ឆាទិដ្ឋិមិនមាន សមដូចព្រះតម្រាស់ ដែលត្រាស់អង្គុត្តរ-និកាយ ឯកនិបាតថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌ ១ ដែលមានទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយមានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ប្រារព្ធពាក្យជាដើមថា **តំ ទោ បង** ដើម្បីសម្តែងនូវការបញ្ជាក់អត្ថតាមដែលត្រាស់ថា ជាធម៌ដែលប្រែចក្សដល់ព្រះអង្គឯង ពាក្យនោះ យល់បានងាយហើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **មិច្ឆាមនំ បណិធាយ** សេចក្ដីថា តាំងចិត្តដោយមិនមែនជាឧបាយ ដោយអំណាចនៃធម៌ទាំងឡាយ មានអភិជ្ឈាជាដើម ។ បទថា **មិច្ឆាវាចំ អភាសិយ** សេចក្ដីថា ពោលវាចាខុស ដោយអំណាចនៃមុសាវាទជាដើម ។ បទថា **មិច្ឆា-កម្មានិ កត្វាន** សេចក្ដីថា ធ្វើកាយកម្មដោយអំណាចនៃបាណាតិបាតជាដើម ម្យ៉ាងទៀត បទថា **មិច្ឆា មនំ បណិធាយ** សេចក្ដីថា តាំងចិត្តខុស ដោយអំណាចនៃមិច្ឆាទិដ្ឋិ សូម្បីក្នុងបទទាំង ២ ដ៏សេស ក៏មានន័យនេះដូចគ្នា ។ ឥឡូវនេះ ព្រះមានព្រះភាគទ្រង់សម្ដែងដល់ហេតុ ក្នុងការប្រព្រឹត្តទុច្ចរិតយ៉ាងនោះនៃបុគ្គលនោះ ។

បទថា **អប្បស្សុតោ** មានអធិប្បាយថា វៀរចាកសុតៈដែលនាំនូវប្រយោជន៍មកឲ្យខ្លួន និងអ្នកដទៃ ។ បទថា **អបុញ្ញករោ** សេចក្ដីថា បន្ទាប់អំពីនោះទៅ នឹងធ្វើការខុស គឺនឹងមានសេចក្ដីអាក្រក់ជាធម្មតា ព្រោះភាពជាអ្នកមិនឈ្លាសក្នុងអរិយធម៌ ។ បទថា **អប្បស្មឹ ឥធ ជីវិតេ** សេចក្ដីថា ក្នុងជីវិតបន្តិចបន្តួចក្នុងលោកនេះ គឺមនុស្សលោក សមដូចព្រះតម្រាស់ត្រាស់ក្នុងមហាបទានសូត្រថា បុគ្គល ( ក្នុងសម័យនេះ ) ដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងតិចជាង ១០០ ឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ក៏មាន ( ដោយតិច ) ដូច្នេះ ។ និងត្រាស់ថា មនុស្សទាំងឡាយមានអាយុតិច ព្រោះដូច្នោះ បុគ្គលដែលជាពហូសូត មានបញ្ញា ប្រញាប់ធ្វើនូវបុណ្យ ហើយនឹងបានទៅកាន់ស្ថានសួគ៌ ឬតាំងនៅក្នុងព្រះនិព្វាន ឯបុគ្គលណាសិក្សា

តិច មិនបំពេញបុណ្យ បុគ្គលនោះ នឹងជាបុគ្គលមានបញ្ញាថោកថយ កាល កាយបែកធ្លាយទៅ រមែងចូលដល់នរក ។ល។

**អដ្ឋកថាមិច្ឆាទិដ្ឋិកសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សម្មាទិដ្ឋិកសូត្រ

[ ៧១ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោ-សុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឮសេចក្តីនោះ ( អំពីសម្នាក់ ) នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយពោលទេ ម្នាលភិក្ខុទាំង-ឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលភិក្ខុទាំងឡាយ លុះតែហេតុណាដែលតថាគត បានដឹងដោយខ្លួនឯង បានឃើញដោយខ្លួនឯង

ជ្រាបច្បាស់ដោយខ្លួនឯងពិតមែន ទើបតថាគតពោលនូវហេតុនោះថា ម្នាល ភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិ សួគ៌ ទេវលោក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គល ក្នុងលោកនេះ ជាពហុស្សូត បានធ្វើបុណ្យ
តម្កល់ចិត្តត្រូវ ពោលវាចាត្រូវ ធ្វើការងារត្រូវដោយ
កាយ បុគ្គលនោះ ប្រកបដោយបញ្ញា លុះបែកធ្លាយ
រាងកាយ ស្លាប់ទៅ ព្រោះជីវិតក្នុងមនុស្សលោកនេះ
តិចណាស់ រមែងទៅកើតក្នុងស្ថានសួគ៌ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## សម្មាទិដ្ឋិកសូត្រ

[ ៧១ ] ក្នុងសម្មាទិដ្ឋិកសូត្រទី ២ គប្បីជ្រាបតាមបរិយាយដែលផ្ទុយគ្នា តាមដែលពោលទុកហើយ ក្នុងសូត្រទី ១ ។ល។

**អដ្ឋកថា សម្មាទិដ្ឋិកសូត្រទី ២ ចប់**

# សុត្តន្តបិដក

## និស្សារណិយសូត្រ

[ ៧២ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធាតុជាគ្រឿងរលាស់ចេញនេះ មាន ៣ ។ ធាតុជាគ្រឿងរលាស់ចេញ ៣ តើអ្វីខ្លះ ។ ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់នេក្ខម្មៈ គឺបឋមជ្ឈាន ១ ការរលាស់ចេញចាករូបធម៌ទាំងឡាយនេះ បានដល់អរូបជ្ឈាន ១ ធម្មជាតណាមួយ ដែលកើតហើយ ដែលបច្ច័យតាក់តែងហើយ ដែលកើតឡើងព្រោះអាស្រ័យហេតុ ការរលត់ គឺព្រះនិព្វានជាគ្រឿងរលាស់ចេញចាកធម្មជាតនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ធាតុជាគ្រឿងរលាស់ចេញ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

( ភិក្ខុណា ) ដឹងនូវការរលាស់ចេញចាកកាមផង ដឹង

នូវឧបាយ ជាគ្រឿងកន្លងរូបធម៌ទាំងឡាយផង កាល

ពាល់ត្រូវព្រះនិព្វាន ជាទីរម្ងាប់នូវសង្ខារទាំងពួង ជា

អ្នកមានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស សព្វៗ

កាល ភិក្ខុនោះ ឈ្មោះថា ជាអ្នកឃើញដោយប្រពៃ

ជាអ្នកសង្រួម រមែងចុះចិត្តស៊ប់ ក្នុងព្រះនិព្វាន ជាទី

រម្ងាប់នូវសង្ខារទាំងពួងនោះ ភិក្ខុនោះ ជាអ្នកមានព្រហ្ម-

ចរិយធម៌ នៅរួចហើយ ជាអ្នកស្ងប់រម្ងាប់ ព្រោះដឹង

ច្បាស់ ឈ្មោះថា អ្នកប្រាជ្ញ អ្នកប្រព្រឹត្តកន្លងនូវយោគៈ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## និស្សរណិយសូត្រ

ក្នុងនិស្សរណិយសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧២ ] បទថា **និស្សរណិយា** សេចក្តីថា បដិសំយុត្តដោយធាតុដែលរលាស់ចេញទៅ ។ បទថា **ធាតុយោ** បានដល់ សភាវៈដែលទទេចាកសត្វ ។ បទថា **កាមានំ** បានដល់ កិលេសកាម និងវត្ថុ ។ ម្យ៉ាងទៀត បទថា **កាមានំ** បានដល់ កិលេសកាម ព្រោះថា ធាតុទាំងឡាយដែលចេញទៅអំពីកិលេសកាម និងចេញទៅអំពីវត្ថុកាមក៏ដូចគ្នា មិនមែនចេញទៅដោយប្រការដទៃ សមដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ ឆក្កនិបាតថា

សេចក្តីត្រេកអរកើតឡើង ដោយអំណាចការត្រិះរិះ ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រក្នុងលោក មិនមែនកាមទេ សេចក្តីត្រេកអរកើតឡើង ដោយអំណាចការត្រិះរិះ ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រទាំងឡាយ តែងស្ថិតនៅក្នុងលោក ដោយប្រការដូច្នោះ តែអ្នកប្រាជ្ញទាំងឡាយ រមែងកម្ចាត់បង់នូវសេចក្តីគាប់ចិត្តក្នុងអារម្មណ៍ទាំងឡាយនោះចេញ ។

ការប្រាសទៅ ឈ្មោះថា **និស្សរណា** ។ បទថា **នេក្ខម្មំ** បានដល់ បឋមជ្ឈាន ។ ដោយពិសេសហើយ នេក្ខម្មៈនោះ គប្បីឃើញថា មានអសុភជាអារម្មណ៍ តែបុគ្គលណាធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយសម្រេចមគ្គទី ៣ ហើយធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយអនាគាមិផលចិត្តនៃបុគ្គលនោះ នឹងរលាស់ចេញចាកកាមទាំងឡាយ ដោយចំណែកមួយ

នោះឯង ដូច្នោះ នេក្ខម្មៈនេះ គប្បីជ្រាបថា ជាការរលាស់ចេញចាកកាមទាំងឡាយយ៉ាងឧក្រិដ្ឋ ។ បទថា **រូបានំ** បានដល់ រូបធម៌ទាំងឡាយ ដោយពិសេសហើយ គឺរូបាវចរធម៌ទាំងអស់ បែកប្រភេទជាកុសលវិបាក និងកិរិយាមួយអន្លើដោយអារម្មណ៍ទាំងឡាយ ។ បទថា **អារុប្បំ** បានដល់ អរូបាវចរជ្ឈាន តែអាចារ្យពួកខ្លះពោលអត្ថនៃបទថា **កាមានំ** ថា បានដល់ កាមាវចរធម៌ទាំងអស់ និងពោលអត្ថនៃបទថា **នេក្ខម្ម** ថា បានដល់ រូបាវចរជ្ឈានទាំង ៥ ពាក្យនោះ មិនមានក្នុងអដ្ឋកថាទាំងឡាយ និងមិនពាល់ត្រូវផង ។ បទថា **ភូតំ** ប្រែថា កើតហើយ ។ បទថា **សង្ខតំ** សេចក្តីថា ដែលបច្ច័យទាំង-ឡាយចាត់ចែង គឺតាក់តែងធ្វើហើយ ។ បទថា **បដិច្ចសមុប្បន្នំ** សេចក្តីថា កើតឡើងចាកហេតុ ។ ដោយបទទាំង ៣ រមែងគ្រប់ដណ្តប់ដល់ធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយឥតសេសសល់ ព្រះនិព្វាន ឈ្មោះថា **និរោធ** ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ការកំណត់ដឹងកាមដោយធាតុដំបូង ការកំណត់ដឹងរូបដោយធាតុទី ២ ការកំណត់ដឹងធម៌ដែលបច្ច័យតាក់តែងទាំងអស់ ដោយធាតុទី ៣ ទើបជាការត្រាស់នូវឈានកន្លងភពគ្រប់គ្រាន់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយ ដូចតទៅនេះ បទថា **កាម-និស្សរណំ ញត្វា** សេចក្តីថា ដឹងថា នេះជាការរលាស់ចេញចាកកាម និងការរលាស់ចេញចាកកាម មានដោយអាការយ៉ាងនេះ ។ ឈ្មោះថា **អតិក្កមំ** ព្រោះហេតុឈានកន្លងដោយឧបាយនោះ គឺឧបាយជាគ្រឿងឈានកន្លង ។ ដឹងឧបាយជាគ្រឿងឈានកន្លងរូបនោះ គឺអរូប ។ ធម៌ ឈ្មោះថា **សព្វសង្ខារ-**

**សមថោ** ព្រោះជាទីស្ងប់រម្ងាប់នៃសង្ខារទាំងឡាយ បានដល់ ព្រះនិព្វាន ។ ឃើញនូវព្រះនិព្វាននោះ ។ ពាក្យដ៏សេស មានន័យដូចបានពោលមកហើយខាងដើមនោះឯង ៕ល៚

**អដ្ឋកថានិស្សរណិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សន្តតរសូត្រ

[ ៧៣ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អរូបជ្ឈាន ជាធម្មជាតល្អិតជាងរូបជ្ឈានទាំងឡាយ និរោធជាសភាពល្អិតលើសជាងអរូបជ្ឈានទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងសូត្រនោះថា

ពួកសត្វណា ដែលទៅកាន់រូបភពក្តី ពួកសត្វណា ដែល
តាំងនៅក្នុងអរូបភពក្តី ( សត្វទាំងនោះ ) មិនដឹងច្បាស់
នូវនិរោធ ជាអ្នកមកកាន់ភពថ្មីទៀត ។ ពួកជនណា
កំណត់ដឹងនូវរូបភពទាំងឡាយក្តី មិនតាំងនៅក្នុងអរូប-
ភពទាំងឡាយក្តី ហើយចុះចិត្តស៊ប់ ក្នុងនិរោធ ពួក
ជននោះ ឈ្មោះថា អ្នកមានមច្ចុសាបសូន្យហើយ ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គបាននូវអមតធាតុ ដោយនាម-
កាយ ព្រះអង្គមិនមានឧបធិ បានធ្វើឲ្យជាក់ច្បាស់នូវ
ធម៌ ជាគ្រឿងរលាស់ចេញចាកឧបធិ ព្រះអង្គមិនមាន
អាសវៈ ទ្រង់សម្តែងនូវបទដែលមិនមានសោក មិន
មានធូលី ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់បាន ត្រាស់ទុកហើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## សន្តតរសូត្រទី ៤

ក្នុងសន្តតរសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧៣ ] បទថា **រូបេហិ** សេចក្តីថា រូបាវចរធម៌ទាំងឡាយ ។ បទថា **សន្តតរា** សេចក្តីថា ស្ងប់ល្អជាង ព្រោះថា រូបាវចរធម៌ទាំងឡាយ ឈ្មោះថា ស្ងប់ហើយ ព្រោះសង្កត់នូវកិលេសបាន ព្រោះលះអង្គដែលគ្រោតគ្រាតដែលមានវិតក្កជាដើម និងព្រោះមានភូមិមាំទាំហើយ ឯអរូបធម៌ទាំងឡាយមានព្រឹត្តិកម្មស្ងប់ល្អជាងរូបធម៌ទាំងនោះ ព្រោះមានអង្គស្ងប់ និងព្រោះមានអារម្មណ៍ស្ងប់ ព្រោះដូច្នោះ ទើបអរូបធម៌ទាំងនោះ ព្រះមានព្រះភាគត្រាស់ថា **សន្តតរា** ប្រែថា ស្ងប់ជាង ។ ព្រះនិព្វាន ឈ្មោះថា **និរោធោ** ព្រោះថា

ផលសមាបត្តិស្ងប់ជាងអរូបជ្ឈានទី ៤ សូម្បីមិនទាន់មានសេចក្តីសុខមកើតឡើង ព្រោះនៅមានសង្ខារសេសសល់ ព្រោះស្ងប់នូវសេចក្តីក្រវល់ក្រវាយដែលកើតអំពីកិលេស និងព្រោះមានព្រះនិព្វានជាអារម្មណ៍ នឹងពោលទៅថ្វីដល់ធម៌ដែលស្ងប់នៃសង្ខារទាំងពួង គឺព្រះនិព្វាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អរូបេហិ និរោធោ សន្តតរោ** ប្រែថា និរោធស្ងប់ជាងអរូបទាំងឡាយ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **រូបូបគា** ប្រែថា ចូលដល់រូបភព ។ ពិតហើយ រូបភពក្នុងគាថានេះ ទ្រង់ត្រាស់ថា រូប ដូចក្នុងប្រយោគជាដើមថា ញុំាងមគ្គឲ្យចម្រើនដើម្បីចូលដល់រូប ។ បទថា **អរូបដ្ឋាយិនោ** បានដល់ អរូបាវចរទាំងឡាយ ។ បទថា **និរោធំ អប្បជានន្តា អាគន្តារោ បុនព្ភវំ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា និរោធជាធម៌ស្ងប់ជាងរូបធម៌ និងអរូបធម៌ទាំងឡាយនោះឯង ។ បទថា **អរូបេសុ អសណ្ឋិតា** អធិប្បាយថា ជនពួកណាមិនតាំងនៅក្នុងអរូបភពទាំងឡាយដោយការជាប់ក្នុងអរូប គឺកំណត់ដឹងនូវអរូបភពទាំងនោះ ។ បទថា **យេ** ក្នុងពាក្យថា **និរោធេ យេ វិមុច្ចន្តិ** ត្រឹមតែជានិបាត ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។៘

## អដ្ឋកថា សន្តតរសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បុត្តសូត្រ

[ ៧៤ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុត្ត ៣ នេះ រមែងមាន ប្រាកដក្នុងលោក ។ បុត្ត ៣ តើអ្វីខ្លះ ។ គឺអតិជាតបុត្ត ១ អនុជាតបុត្ត ១ អវជាតបុត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អតិជាតបុត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ ជាអ្នកមិនដល់ព្រះពុទ្ធជាទីរឭក មិនដល់ព្រះធម៌ជាទីរឭក មិនដល់ព្រះសង្ឃជាទីរឭក មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ទើបឯកូនរបស់មាតាបិតាទាំងនោះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អតិជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ អនុជាតបុត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ ដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបឯកូនរបស់មាតាបិតាទាំងនោះ ដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក

ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ដែរ ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អនុជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ អវជាតបុត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្ត ក្នុងលោកនេះ ដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយ-មជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបកូនរបស់មាតាបិតាទាំងនោះ មិនដល់ព្រះពុទ្ធជាទីរឭក មិនដល់ព្រះធម៌ជាទីរឭក មិនដល់ព្រះសង្ឃជាទីរឭក មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អវជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ កូន ៣ នេះ រមែងមានប្រាកដក្នុងលោក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បណ្ឌិតទាំងឡាយ តែងប្រាថ្នាអតិជាតបុត្ត និងអនុជាត-
បុត្ត មិនប្រាថ្នាអវជាតបុត្ត ដែលជាកូនផ្តាច់បង់ត្រកូល
ឡើយ ។ កូនទាំងនេះឯង តែងមានក្នុងលោក ម្យ៉ាង
ទៀត កូនទាំងឡាយណា ជាឧបាសក ( កូនទាំងនោះ )

ឈ្មោះថា ជាអ្នកបរិបូណ៌ដោយសទ្ធា និងសីល ជាអ្នក
ដឹងពាក្យពេចន៍ ជាអ្នកប្រាសចាកសេចក្ដីកំណាញ់ រមែង
រុងរឿងក្នុងពួកបរិស័ទ ដូចជាព្រះចន្ទ្រដែលផុតស្រឡះ
ហើយ ចាកដុំនៃពពក ដូច្នោះ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## បុត្តសូត្រ

ក្នុងបុត្តសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧៤ ] កូនដែលកើតអំពីទ្រូង គឺកើតអំពីខ្លួន ឬសូម្បីកូនចិញ្ចឹម ឈ្មោះថា បុត្រ ។ បទថា **សន្តោ** ប្រែថា មាន ។ បទថា **សំវិជ្ជមានា លោកស្មឹ** សេចក្ដីថា រកបានក្នុងលោកនេះ ។ ឈ្មោះថា **សន្តោ** ព្រោះមាន ។ ឈ្មោះថា **សំវិជ្ជមានា** ព្រោះប្រាកដហើយ ។ បទថា **អតិជាតោ** សេចក្ដីថា កើតមកលើមាតាបិតាដោយគុណរបស់ខ្លួន ។ អធិប្បាយថា មានគុណខ្ពស់ជាងមាតាបិតាទាំងនោះ ។ បទថា **អនុជាតោ** សេចក្ដីថា មើតមកប្រហាក់ប្រហែលនឹងមាតាបិតាដោយគុណទាំងឡាយ អធិប្បាយថា មានគុណស្មើនឹងមាតាបិតាទាំងនោះ ។ បទថា **អវជាតោ** សេចក្ដីថា កើតមកមិនស្មើ

មាតាបិតាដោយគុណទាំងឡាយ អធិប្បាយថា មានគុណទាបជាងមាតាបិតាទាំងនោះ ។

កូនដែលប្រកបដោយគុណទាំងឡាយណា ដែលព្រះមានព្រះភាគទ្រង់បំណងយកហើយថា ជាអ្នកក្រៃលែងជាងមាតាបិតា ស្មើមាតាបិតា និងទាបជាងមាតាបិតា ដើម្បីទ្រង់សម្តែងចែកនូវគុណទាំងនោះ ទើបទ្រង់តាំងជាកថេតុកម្យតាបុច្ឆាថា **កតមេ ភិក្ខវេ បុត្តា អតិជាតោ ហោតិ** ដូច្នេះហើយ ទើបទ្រង់ប្រារព្ធនិទ្ទេសដោយន័យជាដើមថា **ឥធ ភិក្ខវេ បុត្តស្ស** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **ន ពុទ្ធំ សរណំ គតា** នោះ ដូចតទៅនេះ ព្រះពុទ្ធមានព្រះគុណជាងពួកសត្វដែលអ្នកទាំងឡាយស្គាល់ហើយថា **ពុទ្ធោ** ព្រោះសំដៅយកខន្ធសន្តាន ដែលទ្រង់អប់រំហើយ ដោយការសម្រេចវិមោក្ខដ៏កំពូល មានព្រះញាណមិនមានអ្វីរារាំងក្នុងធម៌ទាំងអស់ជានិមិត្ត ឬការសម្រេចសច្ចញ្ញាណ មានសព្វញ្ញុតញ្ញាណជាបទដ្ឋាន សមដូចលោកពោលក្នុងចូឡនិទ្ទេសថា

ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងឯង ឥតមានអាចារ្យ បានត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ ដែលព្រះអង្គ មិនធ្លាប់បានស្តាប់មកក្នុងកាលមុន ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយនោះផង សម្រេចនូវភាពស្ទាត់ ក្នុងពលធម៌ទាំងឡាយផង ។

ទើបទ្រង់ព្រះនាមថា **ពុទ្ធ** ការពង្រីកសព្ទថា **ពុទ្ធ** ដោយអត្ថ មាន

ប្រមាណប៉ុណ្ណេះសិន តែពាក្យថា **ពុទ្ធ** ដោយព្យញ្ជនៈ គប្បីជ្រាបសេចក្តីតាមន័យយ៉ាងនេះថា បុគ្គលដែលមានការដឹង មានការភ្ញាក់ហើយ ដោយប្រាសចាកការដេកលក់ គឺកិលេស មួយអន្លើដោយវាសនា ដោយចំណែកមួយ ព្រោះដូច្នោះ ទើបឈ្មោះថា **ពុទ្ធ** ។ ម្យ៉ាងទៀត បុគ្គលដែលមានការរីក ជាអ្នកប្រាជ្ញ ជាអ្នករីកដោយបញ្ញា ព្រោះដូច្នោះ ទើបឈ្មោះថា **ពុទ្ធ** ។ បុគ្គលអ្នកត្រាស់ដឹង ( សច្ចៈ ៤ ) ព្រោះដូច្នោះ ទើបឈ្មោះថា **ពុទ្ធ** ។ អ្នកឲ្យបុគ្គលដទៃដឹង អ្នកញ៉ាំងពួកសត្វឲ្យដឹងតាម ព្រោះដូច្នោះ ទើបឈ្មោះថា **ពុទ្ធ** ។ សមដូចលោកពោលក្នុងចូឡនិទ្ទេសថា

*ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងឯង មិនមានបុគ្គលជាអាចារ្យ បានត្រាស់ដឹងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយដែលព្រះអង្គ មិនធ្លាប់ឮហើយក្នុងកាលមុន ទាំងបានដល់សព្វញ្ញុតញ្ញាណ ក្នុងសច្ចៈទាំងនោះ និងភាវៈស្ទាត់ក្នុងពលទាំងឡាយ ។ សំណួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះឈ្មោះថា ព្រះពុទ្ធ ដោយអត្ថដូចម្តេច ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ញ៉ាំងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថា ព្រះពុទ្ធ*

ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៃលែងជាង ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់កម្ចាត់បង់សេចក្ដីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាមព្រះពុទ្ធនុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្ត និងអមាត្យថ្វាយ មិនមែនពួកញាតិនិងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធនុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ បញ្ញត្តិថា ព្រះពុទ្ធនេះ កើតព្រោះការត្រាស់ដឹងព្រម ដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ

( លោកពោលថា ) ព្រះពុទ្ធ ដូច្នេះ ។

វត្ថុដែលឈ្មោះថាជាសរណៈ ព្រោះកម្ចាត់នូវទុក្ខភ័យជាដើម អធិប្បាយថា បៀតបៀន គឺឲ្យវិនាស បានដល់ កម្ចាត់អនត្ថៈ អបាយទុក្ខសព្វយ៉ាង និងសង្សារទុក្ខទាំងពួងបាន ។ បទថា **សរណំ គតា** សេចក្តីថា ជាអ្នកដល់ គឺចូលដល់ព្រះពុទ្ធយ៉ាងនេះថា យើងខ្ញុំសូមដល់ គឺគប់រក បានដល់ សេព ដោយអត្ថថា ចូលទៅអង្គុយជិតព្រះមានព្រះភាគ ដោយបំណងនេះថា ព្រះមានព្រះភាគ ទ្រង់ជាពុទ្ធ ទ្រង់ជាសរណៈ ទ្រង់ជាគតិ ទ្រង់ជាទីទៅខាងមុខ ទ្រង់ជាទីគោង ទ្រង់ជាអ្នកទម្លាយទុក្ខ ទ្រង់ឃើញច្បាស់នូវប្រយោជន៍នៃយើងទាំងឡាយ ឬយើងទាំងឡាយដឹង គឺត្រាស់ដឹងតាមយ៉ាងនេះ ដូច្នេះ ឈ្មោះថា ជាអ្នកដល់នូវព្រះពុទ្ធថា ជាសរណៈ ឯបុគ្គលដល់ដោយន័យផ្សេងគ្នា ដូចពោលមកហើយនោះ មិនឈ្មោះថា ដល់នូវព្រះពុទ្ធជាសរណៈឡើយ ។

បទថា **ធម្មំ សរណំ គតា** សេចក្តីថា សភាវៈដែលឈ្មោះថា ព្រះធម៌ ព្រោះទ្រទ្រង់នូវអ្នកបានសម្រេចអរិយមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ បដិបត្តិតាមពាក្យដែលទ្រង់ទូន្មាន មិនឲ្យធ្លាក់ទៅក្នុងអបាយ ៤ ព្រះធម៌នេះ ដោយអត្ថ បានដល់ អរិយមគ្គ និងព្រះនិព្វាននោះឯង ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា

ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ ដូច្នេះ ។

សេចក្តីពិស្តារគួរជ្រាបដូចតទៅនេះ ព្រះធម៌មិនមែនអរិយមគ្គ និងព្រះនិព្វានតែប៉ុណ្ណោះទេ ដែលពិត បានដល់ព្រះបរិយត្តិធម៌ មួយអន្លើដោយអរិយមគ្គ និងអរិយផលផងដែរ សមដូចទ្រង់ត្រាស់ក្នុងឆត្តមាណវកវិមានវត្ថុថា

ចូរអ្នកដល់នូវធម៌ ដែលប្រាសចាករាគៈ ( អរិយមគ្គ ) មិនរំភើប
មិនមានសោក ( អរិយផល ) ជាសង្ខារធម៌ដែលបច្ច័យ ប្រជុំ
តាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែល
លោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ ដូច្នេះ ។

បណ្តាគុណទាំងនោះ មគ្គដែលព្រះមានព្រះភាគត្រាស់ថា ធម៌ដែលប្រាសចាករាគៈ អរហត្តផល ត្រាស់ហៅថា ជាធម៌មិនរំភើប មិនមានសោក ។ ព្រះនិព្វានត្រាស់ហៅថា ជាសង្ខារធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ធម្មក្ខន្ធទាំងអស់ ដែលទ្រង់ចែកដោយបិដកទាំង ៣ ត្រាស់ហៅថា ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត ដែលលោកចែកត្រឹមត្រូវហើយ ។ ជាអ្នកដល់នូវព្រះធម៌នោះថាជាសរណៈ តាមន័យដែលពោលហើយ ឈ្មោះថា ដល់នូវព្រះធម៌ជាសរណៈ ឯបុគ្គលដល់ដោយន័យផ្ទុយគ្នា តាមដែលពោលមកហើយ ឈ្មោះថា មិនដល់នូវព្រះធម៌ជាសរណៈឡើយ ។

ឈ្មោះថា ព្រះសង្ឃ ព្រោះប្រកបដោយភាពស្មើគ្នាដោយសីល និងទិដ្ឋិ ។ ព្រះសង្ឃនោះ ដោយអត្ថ បានដល់ ប្រជុំនៃអរិយបុគ្គល ៨ ពួក សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ក្នុងវិមានវត្ថុនោះឯងថា

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវទានដែលបុគ្គលឲ្យហើយ

ចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូ
នៃបុរសនោះ ចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌
ចូរអ្នកដល់នូវព្រះសង្ឃនេះ ជាសរណៈចុះ ។

បុគ្គលដល់នូវព្រះសង្ឃថាជាសរណៈ តាមន័យដែលពោលមកហើយ ឈ្មោះថា ដល់ព្រះសង្ឃថាជាសរណៈ ឯបុគ្គលដែលដល់ដោយន័យផ្ទុយគ្នា តាមដែលពោលមកហើយ មិនឈ្មោះថា ដល់នូវព្រះសង្ឃថាជាសរណៈ ដោយប្រការដូច្នេះ ។

ក្នុងរឿងការដល់សរណគមន៍នេះ ដើម្បីភាពជាអ្នកឈ្លាសក្នុងសរណគមន៍ គប្បីជ្រាបវិធីដូច្នេះ គឺសរណៈ ១ សរណគមន៍ ១ អ្នកដល់នូវសរណគមន៍ ១ ប្រភេទនៃសរណគមន៍ ១ ផលនៃសរណគមន៍ ១ ការសៅហ្មង ១ ការដាច់ ១ ការផូរផង់ ១ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិធីទាំងនេះ ដោយអត្ថនៃបទមុន ឈ្មោះថា ជាសរណៈ ព្រោះកម្ចាត់នូវទុក្ខជាដើម អធិប្បាយថា ពុទ្ធរតនៈជាដើម រមែងកម្ចាត់ភ័យ កម្ចាត់នូវការខ្លាច ទុក្ខ ទុគ្គតិ កិលេសទូទៅបាន គឺញុំាងភ័យជាដើមឲ្យវិនាសទៅ ព្រោះការដល់នូវសរណៈនោះឯងរបស់អ្នកដល់នូវសរណៈទាំងឡាយ ។ ពាក្យថា **សរណ** នេះ ជាឈ្មោះនៃព្រះរតនត្រ័យ ម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា ជាសរណៈ ព្រោះកម្ចាត់នូវភ័យរបស់សត្វទាំងឡាយ ដោយការឲ្យបែរចូលមករកប្រយោជន៍ និងឲ្យបែរចេញអំពីធម៌ដែលមិនជាប្រយោជន៍ ព្រះធម៌ ឈ្មោះថា ជាសរណៈ ព្រោះកម្ចាត់នូវភ័យរបស់សត្វ

*ទាំងឡាយបាន ដោយការឲ្យច្រូងផុតកន្តារ គឺភព និងឲ្យនូវការសប្បាយចិត្ត ព្រះសង្ឃ ឈ្មោះថា ជាសរណៈ ដោយការធ្វើឲ្យអ្នកបំពេញបុណ្យ ទោះបី តិចតួច ឲ្យបានទទួលផលបរិបូណ៌ ព្រោះដូច្នោះ ទើបព្រះរតនត្រ័យ ឈ្មោះ ថា ជាសរណៈដោយបរិយាយនេះ ។ ចិត្តុប្បាទដែលកម្ចាត់កិលេសបានដោយ ការជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ និងភាពជាអ្នកធ្ងន់ក្នុងព្រះរតនត្រ័យនោះ ប្រព្រឹត្តទៅហើយ ដោយអាការ គឺភាពជាអ្នកមានព្រះរតនត្រ័យនោះ ជាទី ប្រព្រឹត្តទៅខាងមុខ ឈ្មោះថា* **សរណគមន៍។** *សត្វដែលដល់ព្រមដោយព្រះ រតនត្រ័យនោះ ឈ្មោះថា ជាអ្នកដល់នូវសរណៈ អធិប្បាយថា ចូលដល់ ដោយចិត្តុប្បាទ មានប្រការដូចពោលហើយយ៉ាងនេះថា ព្រះរតនៈទាំង ៣ នេះជាសរណៈរបស់អញ រតនៈទាំង ៣ នេះ ជាទីប្រព្រឹត្តទៅខាងមុខរបស់ អញ ដូច្នេះ គប្បីជ្រាបវិធី ៣ យ៉ាង គឺសរណៈ ១ សរណគមន៍ ១ អ្នក ដល់សរណគមន៍ ១ ប៉ុណ្ណោះសិន ។*

*ពោលដោយប្រភេទសរណគមន៍មាន ២ យ៉ាង គឺលោកិយសរណ- គមន៍ និងលោកុត្តរសរណគមន៍ ក្នុងសរណគមន៍ ២ យ៉ាងនោះ លោកុត្តរ- សរណគមន៍ ពោលដោយអារម្មណ៍ មានព្រះនិព្វានជាអារម្មណ៍ ពោលដោយ កិច្ច រមែងសម្រេចព្រោះព្រះរតនត្រ័យទាំងអស់ ដល់អ្នកឃើញសច្ចៈហើយ ដោយការដល់សរណៈ និងការកាត់ផ្តាច់ឧបក្កិលេស ក្នុងខណៈនៃមគ្គ លោកិយសរណគមន៍ ដោយអារម្មណ៍ មានពុទ្ធាទិគុណជាអារម្មណ៍ រមែង សម្រេចដល់បុថុជ្ជនទាំងឡាយ ដោយការដល់សរណៈ និងដោយការសង្កត់*

ឧបក្កិលេស ។ លោកិយសរណគមន៍នោះ ដោយអត្ថ ត្រាស់ហៅថា ជាការបានចំពោះនូវសទ្ធាក្នុងវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើម ១ ជាសម្មាទិដ្ឋិ មានសទ្ធាក្នុងវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើមជាមូល ១ ជាទិដ្ឋុជុកម្ម ក្នុងបុញ្ញកិរិយាវត្ថុ ១០ ។

លោកិយសរណគមន៍នោះ ប្រព្រឹត្តទៅហើយដោយអាការ ៤ គឺអត្តសន្និយ្យាតនៈ គឺការប្រគល់កាយថ្វាយខ្លួន ១ តប្បរាយនតា គឺការមានព្រះរតនត្រ័យនេះជាទីទៅខាងមុខ ១ សិស្សភាវូបគមនៈ គឺចូលដល់ភាពជាសិស្ស ១ បណិបាត គឺការឱនលំទោន ១ ។ ក្នុងអាការ ៤ យ៉ាងនោះ ការពលីជីវិតដើម្បីព្រះពុទ្ធជាដើមយ៉ាងនេះថា **អជ្ជ អាទឹ កត្វា អហំ អត្តានំ ពុទ្ធស្ស និយ្យាតេមិ ធម្មស្ស សង្ឃស្ស** ខ្ញុំសូមប្រគល់កាយថ្វាយខ្លួនដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ តាំងអំពីថ្ងៃនេះជាដើមទៅ ដូច្នេះ ឈ្មោះថា **អត្តសន្និយ្យាតន។**

ភាពជាអ្នកមានព្រះរតនត្រ័យនោះជាទីពឹងអាស្រ័យ គឺភាពជាអ្នកមានព្រះរតនត្រ័យនោះដែលប្រព្រឹត្តទៅខាងមុខយ៉ាងនេះថា **អជ្ជ អាទឹ កត្វា អហំ ពុទ្ធបរាយណោ ធម្មបរាយណោ សង្ឃបរាយណោ ឥតិ មំ ធារេហិ** ខ្ញុំមានព្រះពុទ្ធជាទីទៅខាងមុខ មានព្រះធម៌ជាទីទៅខាងមុខ មានព្រះសង្ឃជាទីទៅខាងមុខ តាំងអំពីថ្ងៃនេះជាដើមទៅ ដូច្នេះ ឈ្មោះថា **តប្បរាយន។**

ការចូលដល់ភាពជាសិស្សយ៉ាងនេះថា **អជ្ជ អាទឹ កត្វា អហំ ពុទ្ធស្ស អន្តេវាសិកោ ធម្មស្ស សង្ឃស្ស ឥតិ មំ ធារេតុ** សូមលោកទាំងឡាយចាំ

*នូវខ្ញុំយ៉ាងនេះថា ខ្ញុំជាអន្តេវាសិករបស់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ចាប់ពីថ្ងៃនេះជាដើមទៅ ដូច្នេះ ឈ្មោះថា* **សិស្សភាវូបគមន។**

*ការបង្អោនយ៉ាងក្រៃលែង ក្នុងព្រះពុទ្ធជាដើមយ៉ាងនេះថា* **អជ្ជ អាទឹ កត្វា អហំ អភិវាទនបច្ចុដ្ឋានអញ្ជលិកម្មសាមីចិកម្មំ ពុទ្ធាទីនំ ឯវ តិណ្ណំ វត្ថូនំ ករោមិ ឥតិ មំ ធារេតុ** *ខ្ញុំសូមធ្វើការអភិវាទ ការទទួលនូវអញ្ជលិកម្ម និងសាមីចិកម្មដល់វត្ថុទាំង ៣ មានព្រះពុទ្ធជាដើមនោះឯង តាំងអំពីថ្ងៃនេះជាដើមទៅ ដូច្នេះ ឈ្មោះថា* **បណិបាត។**

*ពិតហើយ បុគ្គលធ្វើអាការ ៤ យ៉ាងនេះ ណាមួយ ឈ្មោះថា កាន់យកសរណគមន៍ហើយនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាប* **អត្តសន្និយ្យាតន** *យ៉ាងនេះថា ខ្ញុំសូមលះបង់ខ្លួន លះបង់ជីវិត ដើម្បីព្រះមានព្រះភាគ ដើម្បីព្រះធម៌ ដើម្បីព្រះសង្ឃ ទាំងខ្លួន ទាំងជីវិត ឈ្មោះថា ខ្ញុំលះបង់ហើយនោះឯង ខ្ញុំសូមដល់ព្រះពុទ្ធថាជាសរណៈ តាំងអំពីថ្ងៃនេះជាដើមទៅ រហូតដល់អស់ជីវិត សូមព្រះពុទ្ធជាទីពឹង ទីរឭក ជាទីជ្រកកោន ជាទីពួនសម្ងំនៃខ្ញុំ ។ គប្បីឃើញ* **សិស្សភាវូបគមន** *ដូចការចូលដល់សរណៈរបស់ព្រះមហាកស្សបត្ថេរយ៉ាងនេះថា*

> *អើហ្ន៎ ប្រសិនបើអាត្មាអញ ជួបនឹងបុគ្គលដែលជាគ្រូ ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញ បានជួបនឹងបុគ្គលដែលមានគតិល្អ ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញ បានជួបនឹងបុគ្គលដែលត្រាស់ដឹងធម៌*

ក៏សូមឲ្យជួបតែនឹងព្រះមានព្រះភាគ ដូច្នេះ ។

គប្បីជ្រាប **តប្បរាយន** ដូចការដល់សរណៈរបស់អាឡវកយក្ខជាដើម យ៉ាងនេះថា

ខ្ញុំនឹងចេញពីស្រុកមួយ ទៅស្រុកមួយ ចេញអំពីបុរីមួយ ទៅបុរីមួយ នមស្ការនូវព្រះពុទ្ធផង ព្រះធម៌ដ៏ប្រសើរផង ដូច្នេះ ។

**បណិបាត** គប្បីជ្រាបយ៉ាងនេះថា

កាលនោះឯង ព្រហ្មាយុ ក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គធៀងស្មាម្ខាង ក្រាបទៀបព្រះបាទានៃព្រះមានព្រះភាគ ដោយក្បាល ជប់ព្រះបាទានៃព្រះមានព្រះភាគ ដោយមាត់ផង ប្របាច់ដោយដៃផង បន្លឺឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា ព្រហ្មាយុព្រាហ្មណ៍ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ ឈ្មោះព្រហ្មាយុព្រាហ្មណ៍ ដូច្នេះ ។

ការថ្វាយបង្គំនេះ មាន ៤ យ៉ាង ដោយអំណាចនៃភាពជាញាតិ ១ ខ្លាច ១ ជាអាចារ្យ ១ ជាទក្ខិណេយ្យបុគ្គល ១ ក្នុង ៤ យ៉ាងនោះ ការដល់សរណៈមានដោយការបន្ទោនខ្លួន ចំពោះទក្ខិណេយ្យបុគ្គល មិនមែនដោយហេតុដទៃ ។ ព្រោះថា បុគ្គលនឹងដល់សរណៈ ដោយអំណាចនៃគុណដ៏ប្រសើរ នៃព្រះរតនត្រ័យនោះឯង ហើយនឹងដាច់ដោយអំណាចនៃការកាន់យកវត្ថុដទៃ ថាប្រសើរជាង ព្រោះដូច្នោះ បុគ្គលណាថ្វាយបង្គំដោយគិតថា បុគ្គលនេះឧត្តមជាងសព្វសត្វ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក សរណៈ

ឈ្មោះថា បុគ្គលនោះកាន់យកហើយ ។ ឯបុគ្គលណា ថ្វាយបង្គំ ដោយសម្គាល់ថាជាញាតិ ដោយខ្លាច ដោយសម្គាល់ថាជាអាចារ្យ មិនឈ្មោះថា កាន់យកសរណៈឡើយ ។ កាលឧបាសក ឬឧបាសិកាចូលដល់សរណៈយ៉ាងនេះ កាលថ្វាយបង្គំញាតិ ដែលបួសក្នុងសម្នាក់តិរ្ថិយទាំងឡាយ ដោយគិតថា អ្នកនេះជាញាតិរបស់អញ សរណៈរមែងមិនដាច់ នឹងពោលទៅថ្វីដល់សរណៈរបស់បុគ្គលដែលថ្វាយបង្គំអ្នកមិនបានបួសក្នុងសម្នាក់តិរ្ថិយជាដើមនោះ កាលថ្វាយបង្គំព្រះរាជាព្រោះសេចក្ដីខ្លាចក៏យ៉ាងនោះ គឺសរណៈមិនដាច់ ព្រោះថាព្រះរាជានោះ កាលមិនថ្វាយបង្គំ នឹងធ្វើនូវវត្ថុមិនជាប្រយោជន៍ឲ្យ ព្រោះជាបុគ្គលដែលរាស្ត្រគួរបូជា ដូច្នេះឯង ។ម្យ៉ាងទៀត តិរ្ថិយជាអ្នកឲ្យនូវវិជ្ជាណាមួយ ទោះថ្វាយបង្គំ សរណៈក៏មិនដាច់ ប្រភេទនៃសរណគមន៍គប្បីជ្រាបដោយប្រការដូចពណ៌នាមក ដូច្នេះ ។

ក្នុងសរណគមន៍ ២ យ៉ាងនេះ លោកុត្តរសរណគមន៍ មានសាមញ្ញផល ៤ ជាវិបាកផល មានការអស់ទៅនៃទុក្ខទាំងមូល ជាអានិសង្សផល សមដូចព្រះមានព្រះភាគត្រាស់ក្នុងធម្មបទថា

លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ
ជាទីពឹង ។បេ។ បុគ្គលអាស្រ័យទីពឹងនេះ រមែងរួច
ស្រឡះចាកទុក្ខទាំងពួងបាន ដូច្នេះ ។

ម្យ៉ាងទៀត អានិសង្សផលនៃលោកុត្តរសរណគមន៍នោះ គប្បីជ្រាបដោយអំណាចនៃការមិនចូលដល់សង្ខារ ដោយជារបស់ទៀងជាដើម សមដូច

ព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គឺសោតាបន្ន គប្បីប្រកាន់នូវសង្ខារណាមួយ ថាជាវត្ថុទៀង ថាជាសុខ ថាជាខ្លួន គប្បីផ្តាច់បង់ជីវិតមាតា គប្បីផ្តាច់បង់ជីវិតបិតា គប្បីផ្តាច់បង់ជីវិតព្រះអរហន្ត មានចិត្តប្រទូស្តចំពោះព្រះតថាគត បំបែកសង្ឃ ឧទ្ទិសខ្លួនចំពោះគ្រូដទៃ ដោយហេតុឯណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺថា ហេតុនុ៎ះ មិនដែលមានឡើយ[១] ដូច្នេះ ។

ឯលោកិយសរណគមន៍ មានភវសម្បត្តិខ្លះ ភោគសម្បត្តិខ្លះ ជាផលដូចគ្នា សមដូចព្រះមានព្រះភាគ ត្រាស់ក្នុងសំយុត្តនិកាយ សគាថវគ្គថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធ ជាទីរឭក
ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ លុះ
លះបង់រាងកាយជារបស់មនុស្សហើយ នឹងទៅបំពេញ
ក្នុងពួកនៃទេវតាមិនខាន ដូច្នេះ ។

ព្រះធម្មសង្គាហកាចារ្យ បានពោលពាក្យដទៃ ក្នុងសំយុត្តនិកាយ សឡាយតនវគ្គថា

គ្រានោះឯង សក្កទេវានមិន្ទ ព្រមទាំងទេវតា ៨០០០០ អង្គ ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ ក៏ថ្វាយ

---

១- សេចក្តីពិស្តារ មើលក្នុងបិ. ៤០ ទំ.៥៩ ។

បង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវានមិន្ទ ឋិតក្នុងទីដ៏សមគួរហើយ ទើបព្រះមហា-មោគ្គល្លានដ៏មានអាយុ បាននិយាយដូច្នេះថា បពិត្រទេវានមិន្ទ ការដល់នូវព្រះពុទ្ធជាទីពឹងប្រពៃណាស់ ។ បពិត្រទេវានមិន្ទ សត្វពួកខ្លះក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធ ជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក យ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១ ពណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ បពិត្រទេវានមិន្ទ ការដល់នូវព្រះធម៌ជាទីពឹងប្រពៃណាស់ ។បេ។ បពិត្រទេវានមិន្ទ ការដល់នូវព្រះសង្ឃ ជាទីពឹងប្រពៃណាស់ ។បេ។ ផោដ្ឋព្វៈជាទិព្វ ១ ដូច្នេះ ។

គប្បីជ្រាបសេចក្ដីពិសេសនៃផលរបស់សរណគមន៍ ដោយអំណាចនៃវេលាមសូត្រជាដើម ។ ផលនៃសរណគមន៍ គប្បីជ្រាបដូចពណ៌នាមកនេះ ។

ក្នុង ២ យ៉ាងនេះ លោកិយសរណគមន៍ នឹងសៅហ្មងដោយការមិនដឹង ការសង្ស័យ និងការឃើញខុសក្នុងវត្ថុ ៣ ប្រការជាដើម មិនរុងរឿង មិនទូលំទូលាយ ។ ឯលោកុត្តរសរណគមន៍ មិនមានការសៅហ្មង ។ម្យ៉ាងទៀត ការដាច់នៃលោកិយសរណគមន៍មាន ២ យ៉ាង គឺដាច់មានទោស និងដាច់មិនមានទោស បណ្ដា ២ យ៉ាងនោះ ដាច់មានទោស ព្រោះការប្រគល់

កាយថ្វាយខ្លួនដល់សាស្តាដទៃជាដើម ការដាច់មានទោសនោះ មានផលមិនគួរប្រាថ្នា ។ ឯការដាច់មិនទោស ព្រោះធ្វើកាលកិរិយា ការដាច់នេះ មិនមានផល ព្រោះមិនមានវិបាក ។ ឯលោកុត្តរសរណគមន៍ មិនមានការដាច់ឡើយ ព្រោះថា ព្រះអរិយសាវកសូម្បីក្នុងភពដទៃ ក៏មិនអាងសាសនាដទៃ ថាជាសរណៈឡើយ ព្រោះដូច្នោះ គប្បីជ្រាបការសៅហ្មង និងការដាច់នៃសរណគមន៍ ដូចពណ៌នាមក ដូច្នេះ ។

ឯការផូរផង់មានចំពោះលោកិយសរណគមន៍ប៉ុណ្ណោះ ព្រោះការសៅហ្មងកើតឡើងដល់លោកិយសរណគមន៍ណា ការផូរផង់គប្បីមានចំពោះលោកិយ-សរណគមន៍នោះឯង ឯលោកុត្តរសរណគមន៍ ផូរផង់ជានិច្ចហើយនោះឯង ។

ការញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះជាសភាវៈ ដោយកិច្ចរបស់ខ្លួននោះឯងឲ្យធ្លាក់ទៅ ឈ្មោះថា **អតិបាត** ក្នុងបទថា **បាណាតិបាតា** នេះ អធិប្បាយថា មិនមែនឲ្យធ្លាក់ទៅសន្សឹមៗ តែឲ្យដាច់ទៅយ៉ាងរហ័ស ។ មួយវិញទៀត ការប្រើសស្ត្រាជាដើមគ្របសង្កត់ឲ្យកន្លងទៅ ឈ្មោះថា **អតិបាត** អធិប្បាយថា ការសម្លាប់សត្វមានជីវិត ។ មួយវិញទៀត ខន្ធសន្តានដែលហៅថា សត្វ ឈ្មោះថា **បាណ** ក្នុងពាក្យថា **បាណាតិបាតា** នេះ ខន្ធសន្តាននោះដោយបរមត្ថ បានដល់ រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយ ។ ពិតហើយ កាលរូប-ជីវិតិន្ទ្រិយដែលបុគ្គលឲ្យវិនាសហើយ អរូបជីវិតិន្ទ្រិយក្រៅនេះ ក៏វិនាសទៅ ព្រោះអរូបជីវិតិន្ទ្រិយទាក់ទងនឹងរូបជីវិតិន្ទ្រិយនោះ ។ ចេតនាគិតនឹងសម្លាប់នៃបុគ្គលដែលមានសេចក្តីសម្គាល់ក្នុងសត្វមានជីវិតនោះ ថាជាសត្វមានជីវិត

ដែលញ៉ាំងសេចក្តីព្យាយាមចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយឲ្យតាំងឡើង ប្រព្រឹត្តទៅហើយតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **បាណាតិបាត** ពិតហើយ មហាភូតរូបទាំងឡាយដែលកើតឡើងព្រោះមហាភូតរូបដែលជាហេតុឲ្យធ្វើសេចក្តីព្យាយាមជាបច្ច័យ ដូចគ្នានឹងមហាភូតរូបមុនៗដែលមិនទាន់កើតឡើងក្នុងភូតរូប ជាទីអាស្រ័យនៃជីវិតិន្ទ្រិយ ដែលកំពុងប្រព្រឹត្តទៅជាបច្ចុប្បន្ន និងកើតឡើងចំពោះទីមិនដូចគ្នាប៉ុណ្ណោះ ដោយចេតនាឯណា ចេតនាដែលញ៉ាំងបយោគនោះឲ្យកើតឡើង ឈ្មោះថា **បាណាតិបាត** ព្រោះថាភូតទាំងឡាយដែលមានសេចក្តីព្យាយាមបានហើយ និងមិនដូរផង់ដូចភូតមុនៗ ព្រោះដូច្នោះ ទើបភូតទាំងនោះមិនជាហេតុនៃភូតទាំងឡាយ ដែលមានជាតិស្មើគ្នា ។ ពាក្យថា ប្រព្រឹត្តទៅហើយតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ សម្តែងដល់ការមិនមាននៃការញ៉ាំងសត្វមានជីវិតឲ្យធ្លាក់កន្លងទៅ ដោយវធកចេតនា ដែលប្រព្រឹត្តទៅហើយក្នុងមនោទ្វារ ។ ពិតហើយ ក្នុងកុលុម្ពសូត្រ ព្រះមានព្រះភាគ ទ្រង់បំណងយកវិជ្ជាមយិទ្ធិថា សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ ដែលមានឫទ្ធិ ដល់នូវការជំនាញផ្លូវចិត្ត រមែងមិនសម្លឹងសត្វដែលកើតក្នុងគភ៌ ដែលនៅក្នុងផ្ទៃរបស់ស្រីដទៃ ដោយចិត្តដែលថោកទាប វិជ្ជាមយិទ្ធិនោះ វៀរវចីទ្វារហើយ មិនអាចឲ្យកើតឡើងបាន ព្រោះដូច្នោះ ទើបវិជ្ជាមយិទ្ធិនោះ សម្រេចដោយអំណាចនៃវចីទ្វារប៉ុណ្ណោះ ។ តែវាទៈរបស់អាចារ្យ ដែលពោលថា ឫទ្ធិ ដែលសម្រេចដោយការភាវនា លោកបំណងយកក្នុងកុលុម្ពសូត្រនោះ ខុសពីភូមិដទៃដែលពោលក្នុងកុសលត្តិកៈ វេទនាត្តិកៈ

និងវិតក្កតិកៈ ។

បាណាតិបាតនោះ ឈ្មោះថា មានទោសតិច ព្រោះសត្តតិរច្ឆានជាដើម ដែលប្រាសចាកគុណ និងសត្វដែលមានជីវិតតូចៗ ។ ឈ្មោះថា មានទោសច្រើន ព្រោះសត្វមានជីវិតមានខ្លួនធំ ព្រោះអ្វី ព្រោះមានប្រយោគធំ ត្រូវព្យាយាមច្រើន បើមានប្រយោគស្មើគ្នា បាណាតិបាត ឈ្មោះថា មានទោសច្រើន ព្រោះមានវត្ថុធំជាដើម ។ ក្នុងបណ្តាមនុស្សជាដើមដែលមានគុណ ព្រោះបុគ្គលមានគុណតិច បាណាតិបាតក៏មានទោសតិច បើបុគ្គលមានគុណច្រើន បាណាតិបាតក៏មានទោសច្រើន តែបើរាងកាយ និងគុណស្មើគ្នា បាណាតិបាត ឈ្មោះថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមខ្សោយកម្លាំង។ ឈ្មោះថា មានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ម្យ៉ាងទៀត ក្នុងរឿងបាណាតិបាតនេះ ការដែលបាណាតិបាតមានទោសច្រើន ព្រោះមានប្រយោគ និងវត្ថុធំជាដើម គប្បីជ្រាបដោយការមានចេតនាកើតឡើង ព្រោះបច្ច័យទាំងនេះមានកម្លាំង ។ ភាវៈដែលប្រយោគជាប្រយោគធំ ព្រោះចេតនាជាគ្រឿងឲ្យសម្រេច ញ៉ាំងកិច្ចរបស់ខ្លួនឲ្យសម្រេចដោយអំណាច ញ៉ាំងប្រយោគតាមដែលខ្លួនបំណងឲ្យសម្រេចដោយរហ័ស និងដែលបានសេវនៈដោយជវនទាំងឡាយ ដែលប្រព្រឹត្តទៅច្រើនដង ។ ជួនកាលប្រយោគស្មើគ្នា ក្នុងសត្វដែលមានខ្លួនតូច និងខ្លួនធំ ចេតនារបស់អ្នកសម្លាប់សត្វធំ មានកម្លាំងខ្លាំងជាងនឹងកើតឡើង ព្រោះដូច្នោះ ទើបការដែលវត្ថុជារបស់ធំ ជាហេតុនៃភាពជាចេតនាមានកម្លាំងខ្លាំងជាង ដូច្នោះ ទាំង ២ យ៉ាងនេះ ទើបជាហេតុនៃ

បាណាតិបាត មានទោសច្រើន ដោយភាវៈដែលចេតនាមានកម្លាំងនោះឯង ។ ម្យ៉ាងទៀត កាលភាពដែលសត្វនឹងត្រូវសម្លាប់មានគុណច្រើន ភាវៈដែលបាណាតិបាតនោះមានទោសច្រើន គប្បីឃើញថា សូម្បីចេតនាដែលមិនជាឧបការៈដល់ការញុំាងខេត្តពិសេសឲ្យសម្រេច ជាចេតនាដែលមាននូវកម្លាំងខ្លាំងក្លាជាងនឹងកើតឡើង ដូចចេតនាដែលជាឧបការៈប្រព្រឹត្តទៅហើយ ក្នុងសត្វដែលនឹងត្រូវសម្លាប់ ព្រោះដូច្នោះ ភាវៈជាបច្ច័យទាំងឡាយ មានប្រយោគ និងវត្ថុជាដើមមិនធំ ក៏គប្បីជ្រាបការដែលបាតិបាតមានទោសច្រើន ដោយអំណាចភាវៈដែលចេតនាជាចេតនាមានកម្លាំង ព្រោះបច្ច័យទាំងឡាយមានភាពជាបុគ្គលមានគុណច្រើនជាដើមនោះឯង ។

បាណាតិបាតនោះ មានអង្គប្រកប ៥ យ៉ាង គឺបាណោ ១ បាណសញ្ញិតា ១ វធកចិត្តំ ១ ឧបក្កមោ ១ តេនមរណំ ១ ។ បាណាតិបាតដែលប្រកបដោយអង្គ ៥ មិនវៀរអង្គណាមួយ គប្បីជ្រាបថា ជាបាណាតិបាត ។ ក្នុងអង្គប្រកប ៥ យ៉ាងនោះ ការដឹងថា សត្វមានជីវិត និងចិត្តគិតសម្លាប់ ចាត់ជាបុព្វភាគ ។ ឯសេចក្ដីព្យាយាមសម្លាប់ ជាអង្គប្រកបឲ្យវធកចេតនាប្រាកដច្បាស់ ។ បាណាតិបាតនោះ មានប្រយោគ ៦ គឺសាហត្ថិកប្បយោគ សម្លាប់ដោយដៃខ្លួនឯង ១ អាណត្តិកប្បយោគ ឲ្យអ្នកដទៃសម្លាប់ ១ និស្សគ្គិយប្បយោគ សម្លាប់ដោយលែងអាវុធទៅ ១ ថាវរប្បយោគ សម្លាប់ដោយថាវរវត្ថុ ១ វិជ្ជាមយប្បយោគ សម្លាប់ដោយវេទមន្ត ១ ឥទ្ធិមយប្បយោគ សម្លាប់ដោយឫទ្ធិ ១ ។

បណ្ដាបយោគទាំង ៦ នោះ បយោគ គឺការសម្លាប់ដែលកើតឡើង ដោយដៃរបស់ខ្លួន ឈ្មោះថា **សាហត្ថិកប្បយោគ** បយោគដែលប្រព្រឹត្តទៅ ដោយការប្រើអ្នកដទៃ ឈ្មោះថា **អាណត្តិកប្បយោគ** បយោគដែលប្រព្រឹត្ត ទៅ ដោយការបាញ់ដោយព្រួញ និងដោយការពួយលំពែងជាដើម ឈ្មោះថា **និស្សគ្គិយប្បយោគ** បយោគដែលប្រព្រឹត្តទៅ ដោយការជីករណ្ដៅជាដើម ឈ្មោះថា **ថាវរប្បយោគ** បយោគដែលសម្រេចដោយការរាយមន្ត ដូចការ រាយមន្តរបស់គ្រូអថ៌នជាដើម ឈ្មោះថា **វិជ្ជាមយប្បយោគ** បយោគដែល សម្រេចដោយឫទ្ធិ កើតអំពីវិបាកនៃកម្ម គប្បីឃើញបយោគរបស់អ្នកមាន ឫទ្ធិ ឲ្យសត្វមានពិសខាំសម្លាប់ជាដើម ។

ក្នុងសេចក្ដីនេះ មានអ្នកចោទសួរថា ក្នុងកាលសង្ខារទាំងឡាយ មាន ការរលត់គ្រប់ៗ ខណៈជាសភាវៈ អ្នកណាជាអ្នកសម្លាប់ ឬអ្នកណាត្រូវ សម្លាប់ បើការបន្តនៃចិត្ត និងចេតសិកមាន ការបន្តនៃចិត្ត និងចេតសិកនោះ ជាធម៌ដែលមិនអាចញាប់ញ័របាន បុគ្គលណាម្នាក់ ក៏ឲ្យញាប់ញ័រមិនបាន ដោយអំណាចនៃការកាប់ និងការវាយជាដើម ព្រោះមិនមានរូបរាងសោត កាលបើដូច្នោះ ការបន្តនៃរូបឯណាមាន ការបន្តនៃរូបនោះ ឧបមាដូចអង្កត់ ឧស និងកំណាត់ឈើ ព្រោះមិនមានចេតនា ព្រោះដូច្នោះ ជាបាណាតិបាត មិនបានឡើយ ក្នុងការបន្តនៃរូបនោះ ដោយការកាប់ជាដើម សូម្បីបយោគ ក្នុងរាងកាយដែលស្លាប់ហើយ បាណាតិបាត នឹងគប្បីមានបយោគ មានការ ប្រហារ និងមិនប្រហារជាដើម តាមដែលពោលហើយ ក្នុងសត្វ និងសង្ខារ

ដែលជាអតីត ជាអនាគត ឬជាបច្ចុប្បន្ន ។ ជាបឋមក្នុងកាលទាំង ៣ នោះ បយោគតាមដែលពោលហើយ នឹងមិនកើតមានក្នុងអតីត និងអនាគត ព្រោះអតីត និងអនាគតទាំងនោះ ជាសភាវៈមិនមាន បយោគក្នុងបច្ចុប្បន្ន ដែលកំពុងបែរមុខទៅកាន់ការអស់ទៅសូន្យទៅ ក៏មិនមានប្រយោជន៍ ព្រោះសង្ខារទាំងឡាយ ប្រព្រឹត្តទៅមួយជួរខណៈ ព្រោះសង្ខារទាំងឡាយ មានការរលត់ទៅ តាមកិច្ចរបស់ខ្លួននោះឯងជាសភាវៈ ការស្លាប់ជាតួហេតុនៃបយោគ មានការប្រហារ និងមិនប្រហារជាដើមមិនមាន ព្រោះវៀរចាកហេតុនៃការអស់ទៅ សូន្យទៅក្នុងរូប តើអ្នកណាជាម្ចាស់របស់បយោគ ព្រោះសង្ខារទាំងឡាយ មិនមានចិត្ត បាណាតិបាត នឹងជាកម្មពន្ធរបស់អ្នកណា ព្រោះសង្ខារដែលបែកធ្លាយសព្វកាល ដែលសមគួរនឹងការបំណងសម្លាប់នោះឯងមិនឈប់រហូតឲ្យដល់ទីបំផុតនៃការធ្វើ ទាក់ទងនឹងការប្រព្រឹត្តទៅមួយជួរខណៈ ។

ខ្ញុំនឹងឆ្លើយតទៅថា គំនរសង្ខារ ពោល គឺសត្វដែលដល់ព្រមទៅដោយវធកចេតនា តាមដែលពោលហើយជាអ្នកសម្លាប់ គំនរនៃរូបធម៌ និងអរូបធម៌ ដែលមានបយោគនៃការសម្លាប់ ដែលគំនរសង្ខារឲ្យប្រព្រឹត្តទៅហើយជាគ្រឿងសម្គាល់ ជាទីតាំងនៃការពោលថា ជីវិតិន្ទ្រិយ គឺវិញ្ញាណដែលប្រាសចាកភ្លើងធាតុ ស្លាប់ហើយ ដែលគួរដល់ការប្រព្រឹត្តទៅខាងលើ គឺបន្តទៅក្នុងអនាគត ដូចធ្លាប់ប្រព្រឹត្តទៅក្នុងកាលមុននោះឯងត្រូវសម្លាប់ ព្រោះធ្វើបយោគនៃការសម្លាប់តាមដែលពោលហើយ ។ ម្យ៉ាងទៀត ការបន្តនៃចិត្ត និងចេត-

សិកត្រូវសម្លាប់ កាលភាវៈនៃការបន្តរបស់ចិត្ត និងចេតសិកមិនជាអារម្មណ៍ របស់បយោគនៃការសម្លាប់មាន ការបន្តនៃចិត្ត និងចេតសិកនោះ តែងដាច់សូន្យទៅ ដោយការដាច់សូន្យនៃជីវិតិន្ទ្រិយ ដោយអំណាចនៃបយោគដែលធ្វើហើយក្នុងក្ខូតរូបទាំងឡាយ ព្រោះការបន្តនៃចិត្ត និងចេតសិកនោះមាន ព្រឹត្តិ-កម្មមិនរួញរាជាងការបន្តនៃរូបក្នុងបញ្ចវោការភព ព្រោះដូច្នោះ បាណាតិបាតនឹងមិនកើតមិនមែនឡើយ ទាំងមិនមែនជាហេតុ និងជាបយោគដែលឥតប្រយោជន៍ក៏មិនមែន មរណៈមិនមែនមិនមានហេតុ ព្រោះហេតុ ៣ ប្រការ គឺព្រោះសង្ខារ និងកលាបៈដែលគួរកើតឡើង បន្ទាប់អំពីនោះ មិនកើតឡើងយ៉ាងនោះ ដោយអំណាចបយោគដែលធ្វើហើយក្នុងសង្ខារទាំងឡាយ ដែលជាបច្ចុប្បន្ន ១ ព្រោះខណិកមរណៈនៃសង្ខារទាំងឡាយ ដែលមានមួយជួរខណៈ ទ្រង់មិនបំណងយកថាជាមរណៈក្នុងទីនេះឯង ១ ព្រោះការរលត់នៃសន្តតិជាវត្ថុដែលមានហេតុតាមន័យដែលបានពោលមកហើយ ១ ។ សង្ខារលោកពោលថា ធ្វើហេតុដែលមានការញ៉ាំងផលឲ្យកើតឡើង ដោយសមគួរដល់ខ្លួនពិត ប្រាកដដោយហេតុត្រឹមតែមាននោះឯង ព្រោះកើតឡើងតាមបច្ច័យក្នុងសង្ខារទាំងឡាយ ដែលប្រាសចាកចេតនា ។ ប្រទីបរមែងចាំងនូវពន្លឺ យ៉ាងណា ព្រោះដូច្នោះ ការហៅថា ការសម្លាប់ រមែងប្រាកដច្បាស់ ដូច្នោះ នឹងមិនប្រាថ្នាយកបាណាតិបាតនៃចិត្តចេតសិក ( នាម ) និងកលាបៈ ( រូប ) ដែលកើតព្រមគ្នានឹងបំណងគិតនឹងសម្លាប់តែម្យ៉ាង តែបំណងយកបាណា-តិបាតនៃចិត្តចេតសិក និងកលាបៈដែលកំពុងប្រព្រឹត្តទៅ ដោយអំណាចនៃ

ការបន្តប៉ុណ្ណោះ ព្រោះដូច្នោះ ទើបកម្មពន្ធព្រោះបាណាតិបាតមាននោះឯង ការធ្វើប្រយោជន៍ រមែងប្រាកដដល់ប្រទីបជាដើម ដែលកំពុងឆេះបំភ្លឺដោយអំណាចនៃការជាប់តគ្នា ដូច្នេះឯង ក្នុងអទិន្នាទានជាដើម ការពិចារណានេះគួរអធិប្បាយឲ្យជាក់ច្បាស់តាមសភាវៈដែលពិត ។ ជាអ្នកវៀរចាកបាណាតិបាតនោះ ។ ឈ្មោះថា **អប្បដិវិរតា** ព្រោះវៀរមិនដាច់ ។

ការកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** ។ លោកអធិប្បាយថា ការនាំរបស់អ្នកដទៃទៅ គឺការលួច បានដល់ ការកាន់យក ។ បណ្តាបទទាំងនោះ បទថា **អទិន្នំ** បានដល់ របស់ដែលអ្នកដទៃរក្សា កាលដល់នូវភាពជាអ្នកធ្វើតាមគាប់ចិត្ត ក្នុងរបស់ដែលអ្នកដទៃហួងហែងឯណា មិនគួរបានទទួលទោសទណ្ឌ មិនគួរពោលតិះដៀល ថេយ្យចេតនារបស់បុគ្គលដែលមានការសម្គាល់ក្នុងទ្រព្យ ដែលអ្នកដទៃហួងហែងនោះជារបស់ដែលអ្នកដទៃហួងហែង ញុំាងនូវសេចក្តីព្យាយាម កាន់យកវត្ថុនោះ ឲ្យតាំងឡើង ឈ្មោះថា **អទិន្នាទាន** ។

អទិន្នាទាននោះ ឈ្មោះថា មានទោសតិច ព្រោះទ្រព្យនោះអន់ មានទោសច្រើន ព្រោះទ្រព្យនោះប្រណីត ព្រោះហេតុអ្វី ព្រោះវត្ថុប្រណីត ឈ្មោះថា មានទោសតិច ព្រោះរបស់អ្នកដទៃតិច ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យអ្នកដទៃច្រើន ដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះវត្ថុធំ និងព្រោះបយោគធំ តែកាលមានវត្ថុស្មើគ្នា អទិន្នាទាន ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យរបស់បុគ្គលមានគុណធម៌ខ្ពស់ ឈ្មោះថា មានទោសតិច

ព្រោះទ្រព្យរបស់អ្នកមានគុណធម៌ទាបជាង បុគ្គលមានគុណធម៌ខ្ពស់ៗ នោះ សំដៅដល់យកគុណដែលខ្ពស់នោះជាគោល តែកាលវត្ថុ និងគុណស្មើគ្នា អទិន្នាទាន ឈ្មោះថា មានទោសតិច ព្រោះកិលេស និងបយោគជារបស់ទន់ខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេស និងបយោគខ្លាំងក្លា ។

អទិន្នាទាននោះ មានអង្គប្រកប ៥ យ៉ាង គឺបរបរិគ្គហិតំ ១ បរបរិគ្គហិតសញ្ញិតា ១ ថេយ្យចិត្តំ ១ ឧបក្កមោ ១ តេនហរណំ ១ ។ បយោគមាន ៦ យ៉ាង មានសាហត្ថិកប្បយោគជាដើមដូចគ្នា បយោគទាំងនោះប្រព្រឹត្តទៅហើយ ដោយអំណាចនៃអវហារទាំងនេះ គឺថេយ្យាវហារ ១ បសយ្ហាវហារ ១ បរិកប្បាវហារ ១ បដិច្ឆន្នាវហារ ១ កុសាវហារ ១ ។ បណ្តាបយោគទាំងនោះ ការលួចទ្រព្យអ្នកដទៃដោយការរាយមន្ត ឈ្មោះថា វិជ្ជាមយប្បយោគ ការបណ្តាលមកនូវទ្រព្យអ្នកដទៃដោយកាយប្បយោគ និងវិធីបយោគដែលសម្រេចដោយអានុភាពនៃឫទ្ធិបែបនោះ វៀរចាកមន្ត គប្បីជ្រាបថា ឈ្មោះថា ឥទ្ធិមយប្បយោគ ។

បទថា **កាមេសុ** បានដល់ មេថុនសមាចារ ។ បទថា **មិច្ឆាចារា** បានដល់ អាចារដ៏លាមក ដែលលោកតិះដៀលហើយដោយចំណែកមួយ ។ តែដោយលក្ខណៈ ចេតនាដែលគិតនឹងកន្លងល្មើសអគមនីយដ្ឋាន ដែលបានប្រព្រឹត្តទៅហើយតាមកាយទ្វារ ដោយបំណងនឹងសេពអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** បណ្តាអគមនីយដ្ឋានទាំងនោះ ស្រី ២០ ពួក គឺស្រី ១០ ពួក មានស្រីដែលមាតារក្សាហើយជាដើម និង ១០ ពួកទៀត មានស្រីដែល

ទិញមកដោយទ្រព្យជាដើម ឈ្មោះថា អគមនីយដ្ឋាននៃបុរសទាំងឡាយ តែបុរសដទៃជាអគមនីយដ្ឋាន សម្រាប់ស្រី ១២ ពួក គឺស្រីដែលមានការរក្សា និងមានអាជ្ញាដោយជុំវិញ ២ ពួក និងស្រីដែលទិញមកបានដោយទ្រព្យជាដើម ១០ ពួក ក្នុងពួកស្រីទាំងឡាយ ។

មិច្ឆាចារនេះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋានដែលវៀរចាកគុណ មានសីលជាដើម ដែលឈ្មោះថា មានទោសច្រើន ព្រោះដល់ព្រមដោយគុណ មានសីលជាដើម ម្យ៉ាងទៀត ក្នុងអគមនីយដ្ឋានដែលប្រាសចាកគុណ មិច្ឆាចាររបស់បុគ្គលប្រព្រឹត្តខុសព្រោះការបង្ខិតបង្ខំមានទោសច្រើន តែឈ្មោះថា មានទោសតិច ព្រោះជនទាំង ២ មានឆន្ទៈរួមគ្នា ទោះបីជនទាំង ២ មានឆន្ទៈរួមគ្នា កាមេសុមិច្ឆាចារ ឈ្មោះថា មានទោសតិច ព្រោះកិលេសនិងសេចក្តីព្យាយាមទន់ខ្សោយ ឈ្មោះថា មានទោសច្រើន ព្រោះកិលេសនិងសេចក្តីព្យាយាមខ្លាំងក្លា ។

កាមេសុមិច្ឆាចារនោះ មានអង្គ ៤ គឺអគមនីយវត្ថុ ១ តត្ថសេវនចិត្តំ ១ សេវនបយោគោ ១ មគ្គេនមគ្គប្បដិបត្តិអធិវាសនំ ១ ក្នុងបណ្តាអង្គ ៤ នោះ កាមេសុមិច្ឆាចាររបស់បុគ្គលដែលឲ្យប្រព្រឹត្តទៅតាមការពេញចិត្តរបស់ខ្លួន មានអង្គ ៣ ចំណែករបស់បុគ្គលដែលឲ្យប្រព្រឹត្តទៅហើយដោយបង្ខំ មានអង្គ ៣ ព្រោះដូច្នោះ គប្បីឃើញថាមានអង្គ ៤ ដោយកាន់យកមិនមានចំណែកសេសសល់ តែការសម្រេចប្រយោជន៍នឹងមាន ក៏ដោយអង្គ ៣ ប៉ុណ្ណោះ កាមេសុមិច្ឆាចារ មានបយោគ ១ គឺសាហត្ថិកប្បយោគប៉ុណ្ណោះ ។

បទថា **មុសា** បានដល់ កាយប្បយោគ និងវចីបយោគ ដែលកាច់បំបាក់នូវប្រយោជន៍របស់បុគ្គលដែលប្រាថ្នានឹងពោលឲ្យខុស ចេតនាដែលញ៉ាំងកាយប្បយោគ និងវចីបយោគ ក្នុងការពោលឲ្យខុសចំពោះអ្នកដទៃរបស់បុគ្គលនោះឲ្យតាំងឡើង ដោយការបំណងពោលឲ្យខុស ឈ្មោះថា **មុសាវាទ** ម្យ៉ាងទៀត រឿងដែលមិនពិត ឈ្មោះថា **មុសា** ។ ការញ៉ាំងអ្នកដទៃឲ្យយល់ក្នុងរឿងដែលមិនពិតនោះ ថាពិត ថាមែន ឈ្មោះថា **វាទ** ព្រោះដូច្នោះ ចេតនារបស់បុគ្គលដែលបំណងនឹងឲ្យអ្នកដទៃយល់រឿងដែលមិនពិតថាពិត ដែលញ៉ាំងប្រយោគក្នុងការឲ្យអ្នកដទៃយល់នោះ ឲ្យតាំងឡើង ឈ្មោះថា **មុសាវាទ** ។

មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលខ្លួនកាច់បំបាក់នោះមានតិច ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលខ្លួនកាច់បំបាក់មានច្រើន ។ ម្យ៉ាងទៀត សម្រាប់គ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា មិនមាន ព្រោះមិនបំណងនឹងឲ្យរបស់ខ្លួនដល់អ្នកដទៃ ឈ្មោះថា មានទោសតិច តែបើពោលធ្វើជាសាក្សី កាច់បំបាក់ផលប្រយោជន៍ ឈ្មោះថា មានទោសច្រើន ។ សម្រាប់បព្វជិត មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យនៃបូរណកថា ថាថ្ងៃនេះ ក្នុងស្រុក មានប្រេង ប្រហែលជាហូរទៅដូចស្ទឹង ដោយបំណងនឹងសើច ព្រោះបានប្រេងឬសប្បិបន្តិចបន្តួច ឈ្មោះថា មានទោសតិច តែបើពោលដល់វត្ថុ ដែលមិនបានឃើញសោះ ដោយន័យជាដើមថា បានឃើញ មុសាវាទ ឈ្មោះថា

មានទោសច្រើន ម្យ៉ាងទៀត មុសាវាទ ឈ្មោះថា មានទោសតិច ព្រោះខ្លួនកាច់បំបាក់នូវប្រយោជន៍មានគុណតិច មានទោសច្រើន ព្រោះកាច់បំបាក់នូវប្រយោជន៍មានគុណច្រើន មុសាវាទមានទោសតិច ឬមានទោសច្រើននឹងមាន ក៏ដោយអំណាចកិលេសទន់ខ្សោយ និងខ្លាំងក្លានោះឯង ។

អង្គរបស់មុសាវាទនោះមាន ៤ គឺអតថំវត្ថុ ១ វិសំវាទនចិត្តំ ១ តជ្ជោវាយាមោ ១ បរស្សតទត្ថវិជាននំ ១ ។ ពិតហើយ សូម្បីការឲ្យអ្នកដទៃយល់នូវសេចក្តីនោះ គប្បីជ្រាបថាជាអង្គ ១ ព្រោះការធ្វើបយោគពោលដោយបំណងនឹងពោលឲ្យខុស កាលអ្នកដទៃមិនយល់សេចក្តីនោះ ការពោលឲ្យខុសមិនសម្រេច ឯអាចារ្យពួកខ្លះពោលថា មុសាវាទមានអង្គប្រកប ៣ គឺអភូតវចនំ គឺនិយាយមិនពិត ១ វិសំវាទនចិត្តំ ចិត្តគិតនឹងពោលឲ្យខុស ១ បរស្សតទត្ថវិជាននំ ឲ្យអ្នកដទៃយល់នូវអត្ថនោះ ១ ។ បើបុគ្គលដទៃពិចារណាហើយ ទើបដឹងសេចក្តីនោះ ព្រោះដឹងបានយឺតយូរ ចេតនាដែលជាហេតុឲ្យកិរិយាតាំងឡើង រមែងទាក់ទងនឹងមុសាវាទកម្មក្នុងខណៈនោះឯង ព្រោះចេតនាដែលជាហេតុឲ្យសម្រេច ប្រព្រឹត្តទៅហើយ ។

បទថា **សុរា** បានដល់ សុរា ៥ យ៉ាង គឺបិដ្ឋសុរា សុរាធ្វើដោយម្សៅ ១ បូវសុរា សុរាធ្វើដោយនំ ១ ឱទនសុរា សុរាធ្វើដោយបាយ ១ កិណ្ណបក្ខិត្តា សុរាដែលផ្សំដោយមេ ១ សម្ភារសំយុត្តា សុរាដែលផ្សំដោយគ្រឿងផ្សំផ្សេងៗ ១ ។ បទថា **មេរយំ** បានដល់ គ្រឿងត្រាំ ៥ យ៉ាង គឺបុប្ផាសវៈ គ្រឿងត្រាំ គឺផ្កា ១ ផលាសវៈ គ្រឿងត្រាំ គឺផ្លែ ១ មធ្វាសវៈ

គ្រឿងត្រាំដោយទឹកឃ្មុំ ១ គុឡាសវៈ គ្រឿងត្រាំដោយទឹកអំពៅ ១ សម្ភារ-សំយុត្ត គ្រឿងត្រាំដែលប្រកបដោយគ្រឿងផ្សំ ១ ទាំង ២ យ៉ាងនោះ ឈ្មោះថា **មជ្ជ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ចេតនាជាហេតុផឹកនូវទឹកស្រវឹងនោះ ឈ្មោះថា **បមាទដ្ឋាន** ព្រោះជាហេតុនៃសេចក្តីប្រមាទ ។ ដោយលក្ខណៈ ចេតនាដែលប្រមាទប្រព្រឹត្តទៅហើយតាមកាយទ្វារ ដោយអំណាចនៃការស្រវឹង ផ្តើមពីទឹកស្រវឹង ពោល គឺសុរាមេរ័យតាមដែលពោលហើយ ឈ្មោះថា **សុរាមេរយមជ្ជប្បមាទដ្ឋានា**។

សុរាមេរយមជ្ជប្បមា មានអង្គប្រកប ៤ យ៉ាង គឺមជ្ជភាវោ ១ បាតុ-កម្យតាចិត្តំ ១ តជ្ជោវាយាមោ ១ អជ្ឈោហរណំ ១ ។

ការៈដែលសុរាមេរយមជ្ជប្បមាទដ្ឋាននោះ មានទោសដោយចំណែកមួយ ព្រោះបុគ្គលនោះ ផឹកដោយអកុសលចិត្តតែម្យ៉ាង ។ តែសុរានោះ មិនហូរចូលមាត់របស់អរិយសាវកទាំងឡាយ ទាំងដែលមិនដឹងវត្ថុថាជាទឹកស្រវឹងនឹងពោលទៅថ្វីដល់ដឹងនោះ ។ ការផឹកទឹកស្រវឹង ត្រឹមបន្តិចបន្តួចក៏មានទោសតិច ការផឹកទឹកស្រវឹងត្រឹមកន្ទះអាឡ្ហកៈ ច្រើនជាងទឹកស្រវឹងបន្តិចបន្តួចនោះមានទោសច្រើន ។ កាលផឹកទឹកស្រវឹងច្រើនហើយ តែអាចឲ្យកាយកម្រើកទៅធ្វើកម្ម មានការប្លន់អ្នកស្រុកជាដើម មានទោសច្រើននោះឯង ។

ពិតហើយ ការធ្វើអាក្រក់ក្នុងព្រះខីណាស្រព ដល់លំដាប់បាណាតិបាតមានទោសច្រើន ការធ្វើអាក្រក់ក្នុងសម្នាក់នៃព្រះខីណាស្រពដល់លំដាប់អទិន្នា-ទាន មានទោសច្រើន បាបកម្ម ព្រោះការកន្លងល្មើសកិក្ខុនីជាព្រះខីណាស្រព

ដល់លំដាប់មិច្ឆាចារ មានទោសច្រើន ការធ្វើអាក្រក់ ព្រោះការបំបែកសង្ឃឲ្យបែកគ្នាដោយមុសាវាទ ដល់លំដាប់មុសាវាទ មានទោសច្រើន ។ ការធ្វើអាក្រក់ ព្រោះកម្ម មានការផឹកទឹកស្រវឹងច្រើន រហូតដល់អាចឲ្យកាយកម្រើកបាន ហើយប្លន់ សម្លាប់អ្នកស្រុកជាដើម ព្រោះសុរាបានៈ មានទោសច្រើន ។ ការធ្វើសង្ឃឲ្យប្រេះឆា ដោយមុសាវាទតែម្យ៉ាង មានទោសច្រើនជាងបាបកម្មទាំងអស់នេះ ។ ព្រោះអ្នកធ្វើសង្ឃភេទនោះ រមែងឆេះក្នុងនរកអស់កប្ប ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបាបកម្មនោះ ដោយអាការ ៦ យ៉ាង គឺដោយសភាវៈ ១ ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូល ១ ដោយកម្ម ១ ដោយផល ១ ។

បណ្តាអាការទាំង ៦ យ៉ាងនោះ ពោលដោយសភាវៈបាណាតិបាតជាដើម ជាសភាវៈនៃចេតនាតែម្យ៉ាង ។ ពោលដោយអារម្មណ៍ បាណាតិបាតមានសង្ខារជាអារម្មណ៍ ដោយមានជីវិតិន្ទ្រិយជាអារម្មណ៍ ។ អទិន្នាទានមានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ។ មិច្ឆាចារ មានសង្ខារជាអារម្មណ៍ ដោយអំណាចផោដ្ឋព្វៈ អាចារ្យមួយពួកទៀតពោលថា មានសត្វជាអារម្មណ៍ មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ការផឹកសុរាមានសង្ខារជាអារម្មណ៍ ។ ពោលដោយវេទនា បាណាតិបាតមានវេទនាជាទុក្ខ អទិន្នាទាន មានវេទនា ៣ មិច្ឆាចារ មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងមជ្ឈត្តា គឺអទុក្ខមសុខវេទនា សុរាបានៈ ក៏ដូចគ្នា ( គឺមានវេទនា ២ ) តែទាំង ២ យ៉ាង ( មិច្ឆាចារ និងសុរាបានៈ ) មិនមែន

មានវេទនាជាកណ្តាលៗ ដោយចិត្តដែលជាហេតុឲ្យសម្រេចចិត្ត មុសាវាទមានវេទនា ៣ ។ ពោលដោយមូល បាណាតិបាតមានមូល ២ ដោយអំណាចនៃទោសៈ និងមោហៈ អទិន្នាទាន និងមុសាវាទមានមូល ២ ដោយអំណាចនៃទោសៈ និងមោហៈ ឬដោយអំណាចនៃលោភៈ និងមោហៈ ។ មិច្ឆាចារ និងសុរាបានៈមានមូល ២ ដោយអំណាចនៃលោភៈ និងមោហៈ ពោលដោយកម្ម បណ្តាកម្មទាំង ៥ នោះ មុសាវាទតែម្យ៉ាង ជាវចីកម្ម ។ សិក្ខាបទដ៏សេស ៤ ជាកាយកម្មទាំងអស់ ពោលដោយផល ឲ្យកើតក្នុងអបាយទាំងអស់ ទោះដល់សុគតិក៏ឲ្យផលមិនគួរប្រាថ្នាច្រើនប្រភេទ មានជាអ្នកមានអាយុតិចជាដើម ព្រោះដូច្នោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបាបកម្មទាំងនេះ ដោយសភាពជាដើម ដូចពណ៌នាមក ដូច្នេះ ។

បទថា **អប្បដិវិរតា** បានដល់ មិនជាអ្នកវៀរ ព្រោះមិនមានសមាទាន-វិរតិ និងសម្បត្តិវិរតិ ។ បទថា **ទុស្សីលា** សេចក្តីថា បន្ទាប់អំពីនោះទៅ ក៏ជាបុគ្គលមិនមានសីល ព្រោះមិនមានត្រឹមតែបញ្ចសីល ។ បទថា **បាបធម្មា** បានដល់ ធម៌ដ៏លាមក គឺអាចារដែលអាក្រក់ ។ បទថា **បាណាតិបាតា បដិវិរតោ** សេចក្តីថា ជាអ្នកវៀរ គឺតាំងនៅឆ្ងាយចាកបាណាតិបាត ព្រោះការសមាទានសិក្ខាបទ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏មានន័យនេះ ។

ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យដោយសភាវៈ ១ ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូល ១ ដោយធម៌ ១ ដោយការសមាទាន ១ ដោយការដាច់ ១ ដោយផល ១ នៃវេរមណីទាំងឡាយ មានបាណាតិបាតវេរមណី

ជាដើម ដូចតទៅនេះ ។

ពិតហើយ បណ្តាអាការទាំង ៨ យ៉ាងនេះ ដោយសភាវៈហើយ វេរមណីទាំង ៥ ជាចេតនាខ្លះ ជាវិរតិខ្លះ តែទេសនាមានមកហើយ ដោយអំណាចនៃវិរតិ ។ វិរតិរបស់បុគ្គលដែលវៀរចាកបាណាតិបាត ដែលប្រកបដោយកុសលចិត្ត ដែលលោកពោលយ៉ាងនេះថា ( ក្នុងសម័យនោះ វិរតិនោះ ) បានដល់ ការវៀរ ការវៀរចាកអំពីបាណាតិបាត ដូច្នេះ ដោយប្រភេទមាន ៣ យ៉ាង គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ បណ្តាវិរតិ ៣ យ៉ាងនោះ វិរតិដែលកើតឡើងដល់បុគ្គលមិនបានសមាទានសិក្ខាបទ តែពិចារណាឃើញជាតិ វ័យ និងភាពជាពហូសូតជាដើមរបស់ខ្លួនហើយ ក៏មិនកន្លងល្មើសវត្ថុដែលជួនប្រទះ ដោយគិតថា រឿងនេះមិនសមគួរដល់អញដែលនឹងធ្វើដូច្នេះ ឈ្មោះថា **សម្បត្តវិរតិ** ។ ឯវិរតិដែលកើតឡើងដល់អ្នកសមាទានសិក្ខាបទហើយ សូម្បីលះបង់ជីវិតរបស់ខ្លួនដែលមានគុណក្រៃលែងជាងសិក្ខាបទនោះ ក៏មិនកន្លងល្មើសវត្ថុ ព្រោះបានសមាទានសិក្ខាបទ ឈ្មោះថា សមាទានវិរតិ តែវិរតិដែលសម្បយុត្តដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទ-វិរតិ** ដែលផ្តើមអំពីការកើតឡើងហើយ សូម្បីការគិតថា អញនឹងសម្លាប់សត្វ ក៏មិនកើតដល់ព្រះអរិយបុគ្គលទាំងឡាយ ។ ក្នុងបណ្តាវិរតិទាំង ៣ នោះ ក្នុងទីនេះ លោកបំណងយកសមាទានវិរតិ ។

ពោលដោយអារម្មណ៍ៗ នៃបាណាតិបាតជាដើមនោះឯង ជាអារម្មណ៍នៃបាណាតិបាតវេរណីជាដើមនោះ ។ ព្រោះថា ឈ្មោះថា ការវៀរនឹងមាន

ក៏ព្រោះមានវត្ថុដែលកន្លងល្មើសនោះឯង ម្យ៉ាងទៀត កុសលធម៌ទាំងនោះដែលមានជីវិតិន្ទ្រិយជាអារម្មណ៍នោះឯង រមែងលះនូវការទ្រុស្តសីលទាំងឡាយមានបាណាតិបាតជាដើមបាន ដូចអរិយមគ្គដែលមានព្រះនិព្វានជាអារម្មណ៍ រមែងលះកិលេសទាំងឡាយបាន ដូច្នោះ ។

ពោលដោយវេទនា វិរតិទាំងអស់ ជាសុខវេទនាទាំងអស់ ។

ពោលដោយមូល កុសលធម៌ទាំងនេះ ជារបស់ដែលវៀរដោយចិត្តដែលសម្បយុត្តដោយញាណ មានមូល ៣ ដោយអំណាចនៃអលោភៈ អទោសៈ និងអមោហៈនៃបុគ្គលដែលវៀរដោយចិត្ត ដែលជាញាណវិប្បយុត្ត មានមូល ២ ដោយអំណាចនៃះអលោភៈ និងអទោសៈ ។

ពោលដោយកម្ម ការវៀរចាកមុសាវាទជាវចីកម្ម ចំណែកដ៏សេសជាកាយកម្ម ។

ពោលដោយសមាទាន បុគ្គលមិនបានទទួលការសមាទាននោះ ក្នុងសម្នាក់នៃបុគ្គលដទៃដែលជាគរុដ្ឋានិយបុគ្គល សមាទាននូវសីល ៥ ដោយខ្លួនឯង ជាឯកជ្ឈសមាទាន ឬជាបច្ចេកសមាទាន រមែងជាការសមាទានហើយ ។

ពោលដោយការដាច់សម្រាប់គ្រហស្ថទាំងឡាយ សិក្ខាបទណាដែលកន្លងល្មើសហើយ នឹងដាច់ចំពោះសិក្ខាបទនោះប៉ុណ្ណោះ ក្រៅពីនេះ មិនដាច់ឡើយ ។

ព្រោះហេតុអ្វី ព្រោះគ្រហស្ថទាំងឡាយ មានសីលមិនទាក់ទងគ្នា ជាបច្ចេកសមាទាន រក្សាចំពោះសិក្ខាបទដែលអាចរក្សាបានប៉ុណ្ណោះ ។ ចំណែក

បព្វជិត កាលកន្លងល្មើសសិក្ខាបទ ១ ក៏ដាច់ទាំងអស់ ។

# អានិសង្សការមិនសម្លាប់សត្វជាដើម

គប្បីជ្រាបវិនិច្ឆ័យដោយផល ដូចតទៅនេះថា បណ្តាវេរមណីទាំងនេះ បាណាតិបាតាវេរមណី មានផលយ៉ាងនេះ គឺ **អង្គបច្ចង្គសម្បន្នតា** ភាពជាអ្នកបរិបូណ៌ដោយអវយវៈតូចធំ ១ **អារោហបរិណាហសម្បត្តិ** ដល់ព្រមដោយកម្ពស់ និងទំហំ ១ **ជវនសម្បត្តិ** ដល់ព្រមដោយបដិភាណក្លៀវក្លា ១ **សុបតិដ្ឋិតបាទតា** ភាពជាអ្នកមានជើងតាំងនៅសមសួន ១ **ចារុតា** ភាពជាអ្នកស្រស់ប្រស់ ១ **មុទុតា** ភាពជាអ្នកទន់ភ្លន់ ១ **សុចិតា** ភាពជាអ្នកស្អាត ១ **សូរតា** ភាពជាអ្នកក្លៀវក្លា ១ **មហាព្វលតា** ភាពជាអ្នកមានកម្លាំងច្រើន ១ **វិសដ្ឋវចនតា** ភាពជាអ្នកមានសម្តីពីរោះពិសា ១ **សត្តានំបិយមនាបតា** ភាពជាអ្នកគួរស្រឡាញ់ គួរពេញចិត្តរបស់សត្វទាំងឡាយ ១ **អភិជ្ជបរិសតា** ភាពជាអ្នកមានបរិស័ទមិនបែកខ្វែកគ្នា ១ **អឆម្ភិតា** ភាពជាអ្នកមិនតក់ស្លុត ១ **ទុប្បធំសិយតា** ភាពជាបុគ្គលដែលគេផ្ចាញ់បានដោយកម្រ ១ **បរូបក្កមេន អមរណតា** ភាពជាអ្នកមិនស្លាប់ដោយអ្នកដទៃសម្លាប់ ១ **មហាបរិវារតា** ភាពជាអ្នកមានបរិវារច្រើន ១ **សុវណ្ណតា** ភាពជាអ្នកមានពណ៌សម្បុរល្អ ១ **សុសណ្ឋានតា** ភាពជាអ្នកមានទ្រង់ទ្រាយល្អ ១ **អប្បាពាធតា** ភាពជាអ្នកមានរោគតិច ១ **អសោកតា** ភាពជាអ្នកមិនសោយសោក ១ **បិយមនាបេហិ អវិប្បយោគោ** ជាអ្នកមិនព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ១ **ទីឃាយុកតា** ភាពជាអ្នកមានអាយុវែង ១ ។

អទិន្នាទានាវេរមណី មានផលយ៉ាងនេះ គឺ **មហាធនធញ្ញតា** ភាពជាអ្នកមានទ្រព្យ និងស្រូវច្រើន ១ **អនន្តភោគតា** ភាពជាអ្នកមានភោគៈ ជាអនេក ១ **ថិរភោគតា** ភាពជាអ្នកមានភោគៈស្ថិតស្ថេរ ១ **ឥច្ឆិតានំ ភោគានំ ខិប្បំ បដិលាភោ** បានភោគទ្រព្យតាមដែលត្រូវការយ៉ាងឆាប់រួសរាន់ ១ **រាជាទីហិ អសាធារណភោគតា** ភាពជាអ្នកមានភោគៈមិនទូទៅដល់ព្រះរាជាជាដើម ១ **ឧឡារភោគតា** ភាពជាអ្នកមានភោគៈដ៏ឱឡារ ១ **តត្ថ តត្ថ ជេដ្ឋកភាវោ** ភាពជាប្រធានក្នុងទីនោះៗ ១ **នត្ថិភាវស្ស អជាននតា** ភាពជាអ្នកមិនស្គាល់ពាក្យថាមិនមាន ១ **សុខវិហារិតា** ភាពជាអ្នកនៅសុខ ១ ។

អព្រហ្មចរិយាវេរមណី មានផលយ៉ាងនេះ គឺ **វិគតបច្ចត្ថិកតា** ភាពជាអ្នកប្រាសចាកសត្រូវ ១ **សព្វសត្តានំ បិយមនាបតា** ភាវៈជាទីស្រឡាញ់ជាទីពេញចិត្តនៃសព្វសត្វ ១ **អន្នបានវត្ថច្ឆាទនាទីនំ លាភិតា** ភាពជាអ្នកមានប្រក្រតី បាននូវរបស់ផ្សេងៗ ដូចជាបាយ ទឹក សំពត់ និងវត្ថុជាគ្រឿងបិទបាំង ១ **សុខសុបនតា** ភាពជាអ្នកដេកលក់ជាសុខ ១ **សុខបដិពុជ្ឈនតា** ភាពជាអ្នកភ្ញាក់ឡើងជាសុខ ១ **អបាយភយវិមោក្ខោ** ផុតចាកភ័យក្នុងអបាយ ១ **ឥត្ថីភាវនបុំសកភាវានំ អភព្វតា** មិនគួរដល់ការកើតជាស្រី ឬជាខ្ទើយ ១ **អក្កោធនតា** ជាអ្នកមិនក្រោធ ១ **សច្ចការិតា** ជាអ្នកមានប្រក្រតីធ្វើពិត ១ **អមង្កុតា** ជាអ្នកមិនខ្មាសអៀន ១ **អារាធនសុខតា** ភាពជាអ្នកមានសេចក្ដីសុខដោយការទទួលអញ្ជើញ ១ **បរិបុណ្ណិន្ទ្រិយតា** ជាអ្នកមានឥន្ទ្រិយបរិបូណ៌ ១ **បរិបូណ្ណលក្ខណតា** ជាអ្នកមានលក្ខណៈបរិបូណ៌ ១ **និរាសង្កតា**

ជាអ្នកប្រាសចាកសេចក្ដីវង្វេងស ១ **អប្បោស្សុក្កតា** ភាពជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច ១ **សុខវិហារិតា** ភាពជាអ្នកនៅជាសុខ ១ **អកុតោភយតា** ភាពជាអ្នកមិនមានភ័យអំពីទីណា ១ **បិយវិប្បយោគាភាវោ** មិនមានការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ១ ។ ឯផលនៃការវៀរចាកមិច្ឆាចារ ក៏សង្រ្គោះចូលក្នុងផលរបស់ **អព្រហ្មចរិយាវេរមណី** នោះឯង ។ ព្រោះដូច្នោះទើបព្រះមានព្រះភាគត្រាស់ថា **អព្រហ្មចរិយាវេរមណី** ដូច្នេះ ។

មុសាវាទាវេរមណី មានផលយ៉ាងនេះ គឺ **វិប្បសន្និន្ទ្រិយតា** ជាអ្នកមានឥន្រ្ទិយផូរផង់ ១ **វិសដ្ឋមធុរភាណិតា** ជាអ្នកមានប្រក្រតី ពោលពាក្យពីរោះផ្អែមល្ហែម ១ **សមសិតសុទ្ធទន្តតា** ជាអ្នកមានធ្មេញរាបស្មើ សផង ស្អាតផង ១ **នាតិថូលតា** ជាអ្នកមិនធាត់ពេក ១ **នាតិកិសតា** ជាអ្នកមិនស្គមពេក ១ **នាតិរស្សតា** ជាអ្នកមិនទាបពេក ១ **នាតិទីឃតា** ជាអ្នកមិនខ្ពស់ពេក ១ **សុខសម្ផស្សតា** ជាអ្នកមានសម្ផស្សជាសុខ ១ **ឧប្បលគន្ធ-មុខតា** ជាអ្នកមានក្លិនមាត់ក្រអូបដូចផ្កាឧប្បល ១ **សុស្សូសកបរិសតា** ជាអ្នកមានបរិស័ទស្ដាប់បង្គាប់តាំងនៅក្នុងឱវាទ ១ **អាទេយ្យវចនតា** ជាអ្នកមានវាចាគួរកាន់យក ១ **កមលទលសទិសមុទុលោហិតតនុជិវ្ហតា** ជាអ្នកមានអណ្ដាតទន់ក្រហម ជួនកាល ដូចត្របកផ្កាកោមុទ ១ **អលីនតា** ជាអ្នកមិនរួញរា ១ **អនុទ្ធតតា** ជាអ្នកមិនរាយមាយ ១ ។

សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី មានផលដូច្នេះ គឺ **អតីតានាគតបច្ចុប្បន្នេសុ កិច្ចករណីយេសុ អប្បមាទតា** ជាអ្នកមិនប្រមាទក្នុងកិច្ច

និងករណីយកិច្ច ទាំងជាអតីត អនាគត និងបច្ចុប្បន្ន ១ **ញាណវន្តតា** ជាអ្នកមានញាណ ១ **សទា ឧបដ្ឋិតស្សតិតា** ជាអ្នកមានសតិសព្វកាល ១ **ឧប្បន្នេសុ កិច្ចករណីយេសុ ឋានុប្បត្តិកបដិភាណវន្តតា** ជាអ្នកមានបដិភាណកើតឡើងគ្រប់អន្លើក្នុងកាលមានកិច្ច និងករណីយកិច្ចកើតឡើង ១ **អនលសតា** ជាអ្នកមិនខ្ជិលច្រអូស ១ **អជឡតា** ជាអ្នកមិនល្ងង់ខ្លៅ ១ **អនម្ពត្តតា** ជាអ្នកមិនច្ឆួត ១ **អច្ចម្ភិតា** ជាអ្នកមិនតក់ស្លុត ១ **អសារម្ភិតា** ជាអ្នកមិនមានការប្រណាំងប្រជែង ១ **អនិស្សុកិតា** ជាអ្នកមិនមានសេចក្តីប្រណែន ១ **អមច្ឆរិតា** ជាអ្នកមិនមានសេចក្តីកំណាញ់ ១ **សច្ចវាទិតា** ជាអ្នកមានប្រក្រតីពោលពាក្យសច្ចៈ ១ **អបិសុណ អផរុស អសម្ផប្បលាប-វាទិតា** ជាអ្នកមានប្រក្រតីមិនពោលញុះញង់ គ្រោតគ្រាត និងឥតប្រយោជន៍ ១ **កតញ្ញុតា** ជាបុគ្គលកតញ្ញូ ១ **កតវេទិតា** ជាអ្នកមានកតវេទី ១ **ភោគ-វន្តតា** ជាអ្នកមានភោគៈ ១ **សីលវន្តតា** ភាពជាអ្នកមានសីល ១ **ឧជុគតា** ជាអ្នកស្មោះត្រង់ ១ **អក្កោធនតា** ជាអ្នកមិនក្រោធ ១ **ហិរោត្តប្បសម្បន្នតា** ជាអ្នកដល់ព្រមដោយហិរិ និងឱត្តប្បៈ ១ **ឧជុទិដ្ឋិតា** ជាអ្នកមានទិដ្ឋិត្រង់ ១ **មហាត្តតា** ជាអ្នកមានចិត្តធំ ១ **បណ្ឌិតតា** ភាពជាអ្នកឈ្លាស ១ **អត្ថា-នត្ថកុសលតា** ជាអ្នកឈ្លាសក្នុងវត្ថុជាប្រយោជន៍ និងមិនជាប្រយោជន៍ ១ ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដោយសភាវៈជាដើម នៃបាណាតិបាតា-វេរមណីជាដើម ដូចពណ៌នាមកនេះ ។

បទថា **សីលវា** បានដល់ ជាអ្នកមានសីល ដោយអំណាចបញ្ចសីល

តាមដែលពោលហើយ ។ បទថា **កល្យាណធម្មោ** បានដល់ ជាអ្នកមានធម៌ ស្អាត អធិប្បាយថា មានបញ្ញាប្រកបដោយទិដ្ឋិសម្បត្តិ ដែលចុះបញ្ចាំងដល់ សរណគមន៍ ។ បុត្រឯណា កាលមាតាបិតាមិនមានសទ្ធា ជាអ្នកទ្រុស្តសីល ខ្លួនឯងក៏ដូច្នោះ បុត្រនោះ គប្បីជ្រាបថា ជាអវជាតបុត្រនោះឯង ព្រោះថា ភាពជាអ្នកមិនមានសទ្ធាជាដើម លោកពោលថា ជាលក្ខណៈនៃភាពជា អវជាតបុត្រក្នុងទីនេះ និងភាពជាអ្នកមិនមានសទ្ធាជាដើមនោះ មានក្នុង អវជាតបុត្រនោះ តែព្រះមានព្រះភាគត្រាស់ហៅអតិជាតបុត្រជាដើម ព្រោះ ប្រៀបធៀបនឹងមាតាបិតា ។

បទថា **យោ ហោតិ កុលគន្ធនោ** បានដល់ កូនដែលទម្លាយត្រកូល គឺធ្វើត្រកូលឲ្យវិនាស ។ ពិតហើយ **គន្ធ** សព្ទ ក្នុងទីនេះ មានអត្ថថា ទម្លាយ ដូចក្នុងប្រយោគជាដើមថា **ឧប្បលគន្ធបច្ចត្ថិកា**[១] ពួកសត្រូវ អ្នកពុះទ្រូងអារ យកបេះដូង ដូច្នេះ តែអាចារ្យពួកខ្លះ ពោលថា **កុលធំសនោ** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **ឯតេ ខោ បុត្តា លោកស្មឹ** សេចក្តីថា កូន ៣ ពួក មានអតិជាតបុត្រទាំងនេះជាដើម ឈ្មោះថា ជាកូនមាននៅក្នុងលោកនេះ ផុតចាកលោកនេះទៅ មិនមានទេ បណ្តាកូន ៣ ពួកនេះ កូនពួកណាជា ឧបាសក គឺកូនពួកណាជាឧបាសក ព្រោះដល់ព្រមដោយសរណគមន៍ គឺដឹង នូវកម្ម ដោយកម្មស្សកតាញាណ កូនទាំងនោះ ជាបណ្ឌិតមានបញ្ញាដល់ ព្រម គឺបរិបូណ៌ សីល ៥ និងសីល ១០ ឈ្មោះថា **វទញ្ញូ** ព្រោះដឹងនូវវាចា

១- បិ. ១ ទំ. ១១០ ។

របស់យាចកទាំងឡាយ ដោយការញុំាងបំណងរបស់យាចកនោះឲ្យពេញ ដោយត្រឹមតែឃើញមុខប៉ុណ្ណោះ ម្យ៉ាងទៀត ឈ្មោះថា **វទញ្ញូ** ព្រោះវិគ្គហៈថា បានឮនូវពាក្យយាចកទាំងនោះថា សូមឲ្យទានចុះ ដូច្នេះ ក៏ដឹងអត្ថនោះ ដោយបរិច្ចាគទ្រព្យដល់យាចកទាំងនោះ ដោយគិតថា មនុស្សទាំងនេះ មិនធ្លាប់ឲ្យទានក្នុងកាលមុន ទើបដូច្នេះ ឯអញមិនគួរមានសភាពយ៉ាងនេះ ។ ម្យ៉ាងទៀត ឈ្មោះថា **វទញ្ញូ** ព្រោះវិគ្គហៈថា យល់នូវពាក្យរបស់បណ្ឌិតទាំងឡាយ ដែលសម្ដែងដល់ភាពដែលសត្វមានកម្មជារបស់ខ្លួនជាដើម ឯអាចារ្យពួកខ្លះពោលថា **បទញ្ញូ** អធិប្បាយថា ជាអ្នកមានប្រក្រតីបរិច្ចាគដោយការបន្ថែមឲ្យ ។ ឈ្មោះថា **វីតមច្ឆរា** ព្រោះប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ក្នុងវេលាពេចនោះឯង ។ បទថា **អត្ថាយនា** សេចក្ដីថា កូនទាំងនោះរមែងរុងរឿង គឺស្អាតក្នុងបរិស័ទទាំងឡាយ មានឧបាសកជាដើម និងក្នុងបរិស័ទទាំងឡាយ មានក្សត្រជាដើម ដូចព្រះចន្ទដែលផុតចាកមេឃ ពោលគឺពពក ឬផុតចាកពពកដែលក្រាស់ ដូច្នោះ អធិប្បាយថា រមែងស្អាត ។៙

## អដ្ឋកថា បុត្តសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អវុដ្ឋិកសូត្រ

[ ៧៥ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេចខ្លះ ។ គឺបុគ្គលស្មើដោយមេឃមិនបង្អុរភ្លៀងចុះ ១ បុគ្គលស្មើដោយមេឃដែលបង្អុរភ្លៀងចុះត្រង់ប្រទេសមួយៗ ១ បុគ្គលស្មើដោយមេឃដែលបង្អុរភ្លៀងចុះសព្វប្រទេស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃ មិនបង្អុរភ្លៀងចុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនដែលឲ្យបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងសម្រាប់ប្រទីប ដល់ពួកសមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ និងអ្នកពណ៌នាហើយសូម និងយាចកទាំងពួង ដល់ម្តងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃមិនបង្អុរភ្លៀងចុះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃបង្អុរភ្លៀងចុះ ត្រង់ប្រទេសមួយៗ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកឲ្យបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងសម្រាប់ប្រទីប ដល់ពួកសមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ អ្នកពណ៌នាហើយសូម និងយាចកពួកខ្លះ មិនឲ្យទានដល់សមណៈ ព្រាហ្មណ៍ពួកខ្លះ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃបង្អុរភ្លៀងចុះត្រង់ប្រទេសមួយៗ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃបង្អុរភ្លៀង

ចុះសព្វប្រទេស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ តែងឲ្យបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងសម្រាប់ប្រទីប ដល់ពួកសមណៈ ព្រាហ្មណ៍ អ្នកកំព្រា អ្នកដំណើរ អ្នកពណិ៌នាហើយសូម និងយាចកទាំងពួង ម្នាលភិក្ខុទាំងឡាយ បុគ្គលស្មើដោយមេឃ បង្អុរភ្លៀងចុះសព្វប្រទេស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង តែងមានប្រាកដ ក្នុងលោក ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

> បុគ្គលណា បាននូវសមណៈ បាននូវព្រាហ្មណ៍ បាន
> នូវអ្នកកំព្រា អ្នកដំណើរ ទាំងបាននូវជនអ្នកពណិ៌នា
> ហើយសូមទាំងឡាយ ហើយមិនចាត់ចែងនូវបាយ ទឹក
> ភោជន បណ្ឌិតទាំងឡាយ តែងហៅនូវបុគ្គលដ៏លាមក
> នោះឯងថា ដូចជាមេឃដែលមិនបង្អុរភ្លៀងចុះ ដូច្នោះ ។
> បុគ្គលណា មិនឲ្យទាន ដល់សមណៈពួកខ្លះ ឲ្យទាន
> ដល់សមណៈពួកខ្លះ ពួកជនអ្នកមានប្រាជ្ញា តែងហៅ
> បុគ្គលនោះឯងថា ដូចជាមេឃដែលបង្អុរភ្លៀងចុះ ក្នុង
> ប្រទេសមួយៗ ដូច្នោះ ។ បុរស មានវាចានាំឲ្យបាន
> បាយដោយងាយ មានសេចក្តីអនុគ្រោះសព្វសត្វ មាន
> ចិត្តរីករាយ តែងចាត់ចែង ( ទេយ្យធម៌ ) ពោលថា

អ្នកទាំងឡាយចូរឲ្យ អ្នកទាំងឡាយចូរឲ្យ ប្រៀបដូច
មហាមេឃគ្រហឹម គំរាមហើយបង្អុរភ្លៀងចុះ ធ្វើទីទួល
និងទីទាប បង្ហូរឲ្យពេញដោយទឹក យ៉ាងណាមិញ បុគ្គល
ខ្លះ ក្នុងលោកនេះ ជាអ្នកមានសភាពដូច្នោះ បាន
ប្រមូលមក នូវទ្រព្យដែលកើតដោយសេចក្ដីព្យាយាម
តាមផ្លូវធម៌ ក៏ជប់លៀង ពួកជនអ្នកពណិព្វកាហើយសូម
ដែលមកដល់ដោយល្អ ដោយបាយទឹក ក៏យ៉ាងនោះដែរ ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## អវុដ្ឋិកសូត្រ

ក្នុងអវុដ្ឋិកសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧៥ ] បទថា **អវុដ្ឋិកសមោ** សេចក្ដីថា ដូចគ្នានឹងមេឃដែលមិនធ្វើភ្លៀងឲ្យធ្លាក់ ។ ព្រោះពពកដុំខ្លះ កម្រាស់ ១០០ ជាន់ ១០០០ ជាន់ តាំងឡើង គ្រហឹម ជាលប្រវាត់ មិនឲ្យភ្លៀងសូម្បីមួយតំណក់ធ្លាក់ចុះមកហើយក៏ស្ងាត់ទៅ ។ ព្រះមានព្រះភាគទ្រង់សម្ដែងថា បុគ្គលពួកខ្លះក៏មានឧបមាដូច្នោះ ទើបត្រាស់ថា **អវុដ្ឋិកសមោ** ប្រែថា បុគ្គលស្មើដោយភ្លៀង

*មិនធ្លាក់ ដូច្នេះ ។ បទថា* **បទេសវស្សី** *សេចក្តីថា ដូចគ្នានឹងមេឃធ្វើឲ្យធ្លាក់ក្នុងទីខ្លះ អធិប្បាយថា បុគ្គលឈ្មោះថាបទេសវស្សី ព្រោះដូចគ្នានឹងមេឃដែលធ្វើឲ្យធ្លាក់ត្រង់ទីខ្លះ ។ មេឃខ្លះ កាលមនុស្សទាំងឡាយឈរ ក្នុងទីមួយកន្លែងនោះឯង ក៏ធ្លាក់របេ៉សរប៉ស់ ដោយបុគ្គលខ្លះសើម បុគ្គលខ្លះក៏មិនសើម ព្រះមានព្រះភាគទ្រង់សម្តែងបុគ្គលពួកខ្លះ ដែលមានឧបមាយ៉ាងនោះថា ដូចជាភ្លៀងធ្លាក់ចំពោះកន្លែងខ្លះ ។ បទថា* **សព្វត្ថាភិវស្សី** *សេចក្តីថា ស្មើគ្នានឹងមេឃដែលឲ្យភ្លៀងធ្លាក់ទូទៅសព្វទីកន្លែងក្នុងបទេស គឺផែនដីមានផ្ទៃប្រឹថពី ភ្នំ និងសមុទ្រជាដើម អធិប្បាយថា មេឃខ្លះផ្សាយទូទៅពេញសកលចក្រវាល ឲ្យភ្លៀងធ្លាក់សព្វទីកន្លែង ទើបព្រះមានព្រះភាគត្រាស់ថា* **សព្វត្ថាភិវស្សី** *ដូច្នេះ ដោយទ្រង់ប្រៀបធៀបមហាមេឃដែលតាំងឡើងក្នុងទិសទាំង ៤ នោះទៅនឹងបុគ្គលពួកខ្លះ ។ បទថា* **សព្វេសានំ** *ស្មើគ្នានឹង* **សព្វេសំ** *បានដល់ គ្រប់ពួកគ្រប់ក្រុម ។ម្យ៉ាងទៀត បាឋៈក្នុងព្រះបាលីក៏យ៉ាងនេះឯង ។ បទថា* **ន ទាតា ហោតិ** *សេចក្តីថា បុគ្គលមានប្រក្រតីមិនឲ្យទាន អធិប្បាយថា មិនឲ្យអ្វីដល់បុគ្គលណា ព្រោះជាបុគ្គលកំណាញ់ស្វិតស្វាញ ។*

*ឥឡូវនេះ កាលទ្រង់សម្តែងខេត្ត និងទេយ្យធម៌ ដោយការចែក ទើបត្រាស់ពាក្យជាដើមថា* **សមណព្រាហ្មណា** *ដូច្នេះ ។ ក្នុងពាក្យថា* **សមណ-ព្រាហ្មណា** *នោះ ព្រះមានព្រះភាគទ្រង់បំណងយកទាំងសមណៈដែលបន្សាត់បាបហើយ ទាំងសមណៈត្រឹមតែបព្វជ្ជា ទាំងព្រាហ្មណ៍ដែលបន្សាត់បាបហើយ*

និងព្រាហ្មណ៍ត្រឹមតែកំណើតក្នុងទីនេះ ។ បុគ្គលក្រីក្រ ឈ្មោះថា **កបណា** អ្នកដើរផ្លូវដែលអស់ស្បៀង ឈ្មោះថា **អទ្ធិកា** បុគ្គលណាម្នាក់បបួលមនុស្ស ក្នុងការធ្វើទាន ត្រាច់សរសើរទានដោយន័យជាដើម អ្នកទាំងឡាយ ចូរមាន ចិត្តខ្ពស់ មានចិត្តជ្រះថ្លា បរិច្ចាគរបស់ដែលគួរប្រាថ្នា គួរចង់បាន គួរពេញ ចិត្ត មិនមានទោស តាមកាល អ្នកទាំងឡាយ នឹងទៅកាន់សុគតិ នឹងទៅ កាន់ព្រហ្មលោក ជនទាំងនោះ ឈ្មោះថា **វណិព្វកា**។ ជនពួកណា ដើរសូម របស់បន្តិចបន្តួចតែម្យ៉ាងថា សូមអ្នកទាំងឡាយឲ្យត្រឹមតែមួយក្តាប់ មួយកំបង់ មួយផ្តិលចុះ ដូច្នេះ ជនទាំងនោះ ឈ្មោះថា **យាចកា**។ បណ្តាសព្ទទាំងនោះ សព្ទថា **សមណា** និង **ព្រាហ្មណា** ព្រះមានព្រះភាគទ្រង់សម្តែងដល់ព្រំដែននៃ គុណ និងព្រំដែននៃឧបការៈ ដោយសព្ទថា **សមណព្រាហ្មណា** ទ្រង់សម្តែង ដល់ខេត្តនៃករុណា ដោយពាក្យថា **កបណា** ជាដើម ។

បទថា **អន្នំ** បានដល់ របស់គួរទំពា និងរបស់គួរបរិភោគណាមួយ ។ បទថា **បានំ** បានដល់ គ្រឿងផឹក មានទឹកដែលធ្វើអំពីផ្លែស្វាយជាដើម ។ បទ ថា **វត្ថំ** បានដល់ គ្រឿងបិទបាំង មានសំពត់ស្លៀក និងសំពត់ដណ្តប់ជាដើម បទថា **យានំ** បានដល់ វត្ថុដែលញ៉ាំងការធ្វើដំណើរឲ្យសម្រេច មានរថ និងរ (គ្រែស្នែង) ដោយហោចសូម្បីត្រឹមតែស្បែកជើង ។ បទថា **មាលា** បាន ដល់ ផ្កាគ្រប់ប្រភេទ មានផ្កាដែលក្រង និងផ្កាដែលមិនបានក្រងជាដើម ។ បទថា **គន្ធំ** បានដល់ គន្ធជាតិឯណានីមួយ និងឧបករណ៍នៃគ្រឿងក្រអូប ដែលបុកហើយ និងមិនបានបុក ។ បទថា **វិលេបនំ** បានដល់ គ្រឿងលាប ។

បទថា **សេយ្យា** បានដល់ គ្រឿងដេក មានគ្រែ និងតាំងជាដើម និងសំពត់បាវ៉ា សំពត់កោជវៈជាដើម ។ សូម្បីអាសនៈ ព្រះមានព្រះភាគទ្រង់កាន់យក ហើយ ដោយសព្ទថា **សេយ្យ** ក្នុងពាក្យថា **សេយ្យាវសថំ** នេះ ។ បទថា **អាវសថំ** បានដល់ ទីអាស្រ័យដែលជាគ្រឿងបន្ទោបង់នូវអន្តរាយ មានខ្យល់ និងកម្ដៅថ្ងៃជាដើម បទថា **បទីបេយ្យំ** បានដល់ គ្រឿងឧបករណ៍នៃពន្លឺ មានប្រទីប និងចង្កៀងជាដើម ។

បទថា **ឯវំ ខោ ភិក្ខវេ** សេចក្ដីថា កាលទេយ្យធម៌មាន បុគ្គលមិនឲ្យរបស់ដែលត្រូវឲ្យយ៉ាងនេះដល់បដិគ្គាហកៈទាំងឡាយ ដោយប្រការទាំងពួងរមែងដូចជាមេឃដែលមិនឲ្យភ្លៀងធ្លាក់ ។ ទ្រង់អធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ពពកកម្រាស់ ១០០ ជាន់ ១០០០ ស្រទាប់ តាំងឡើងហើយមិនបង្អុរចុះមកឡើយ រសាតបាត់អស់ទៅ យ៉ាងណា បុគ្គលណា ប្រមូលសម្បត្តិដ៏ឱឡារ និងបរិបូណ៌ នៅគ្រប់គ្រងផ្ទះក៏ដូច្នោះដូចគ្នា មិនឲ្យភិក្ខាសូម្បីមួយវែក ឬបបរត្រឹមមួយត្រឡោកដល់បុគ្គលណាម្នាក់ ចៀសចេញទៅហើយ ។ អស់អំណាច រមែងទៅកាន់មាត់នៃមច្ចុ បុគ្គលនោះ រមែងឈ្មោះថាដូចមេឃដែលមិនឲ្យភ្លៀងធ្លាក់ ដូច្នេះ ។ ក្នុងបទដ៏សេស គប្បីជ្រាបព្រះតម្រាស់ត្រាស់ដដែលៗ ដោយន័យនេះ ។

ក្នុងបុគ្គល ៣ ពួកនោះ បុគ្គលពួកដំបូង គប្បីត្រូវតិះដៀលដោយចំណែកមួយប៉ុណ្ណោះ ។ បុគ្គលពួកទី ២ គួរសរសើរ បុគ្គលពួកទី ៣ គួរសរសើរក្រៃលែង ។ ម្យ៉ាងទៀត បុគ្គលទី ១ គប្បីជ្រាបថា អាក្រក់ជាង

បុគ្គលគ្រប់ប្រភេទពួកទី ២ គប្បីជ្រាបថា ថ្នាក់កណ្តាល ពួកទី ៣ គប្បីជ្រាបថា ឧត្តមបំផុត ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **សមណេ** ជាពហុវចនៈ ជាទុតិយាវិភត្តិ ។ ក្នុងបទដ៏សេសក៏ដូចគ្នា ។ បទថា **លទ្ធាន** ប្រែថា បាន គឺប្រាប្តាសមណៈ ដែលជាទក្ខិណេយ្យបុគ្គល ហើយត្រូវសួរក៏មិនចែករំលែកឲ្យ ។ បទថា **អន្នបានញ្ច ភោជនំ** សេចក្តីថា មិនចាត់ចែងបាយ ឬទឹក ឬភោជនដែលគួរបរិភោគដទៃដែលមាន ។ ក្នុងព្រះគាថានេះមានសេចក្តីសង្ខេបដូច្នេះថា បុគ្គលណាបានសមណៈដែលជាបដិគ្គាហក ចូលទៅរកហើយ ទាំងខ្លួនឯងក៏មានទេយ្យធម៌ នៅតែមិនធ្វើ សូម្បីត្រឹមតែរំលែកបាយជាដើម បុគ្គលនោះ នឹងឲ្យទានដទៃបានដូចម្តេច បណ្ឌិតពោល គឺហៅបុគ្គលដែលកំណាញ់ស្វិតស្វាញបែបនោះ ថាជាបុរសអធម៌ ជាបុគ្គលអាក្រក់ដូចគ្នានឹងមេឃដែលមិនឲ្យភ្លៀងធ្លាក់ ដូច្នេះ ។

បទថា **ឯកច្ចានំ ន ទទាតិ** សេចក្តីថា កាលរបស់ដែលត្រូវឲ្យមានសន្និកសន្និបាប់ក៏មិនព្រមឲ្យដល់បុគ្គលពួកខ្លះ ដោយអំណាចនៃសេចក្តីក្រោធក្នុងបុគ្គលទាំងនោះ ឬដោយអំណាចនៃលោភៈក្នុងទេយ្យធម៌ ។ បទថា **ឯកច្ចានំ បវេច្ឆតិ** សេចក្តីថា តែឲ្យដល់បុគ្គលពួកខ្លះប៉ុណ្ណោះ ។ បទថា **មេធាវិនោ** បានដល់ អ្នកមានបញ្ញា គឺជាបណ្ឌិត ។

បទថា **សុភិក្ខវាចោ** សេចក្តីថា បុគ្គលណាប្រើឲ្យគេឲ្យនូវរបស់នោះដល់យាចកទាំងឡាយ ដែលចូលទៅរកហើយ ដោយន័យជាដើមថា អ្នកទាំង

ឡាយ ចូរឲ្យបាយ អ្នកទាំងឡាយចូរឲ្យទឹក បុគ្គលនោះ ឈ្មោះថា **សុភិក្ខ-វាចោ** ព្រោះវិគ្គហៈថា ជាអ្នកមានការហោមាត់សូមងាយ ព្រោះមានការសូមបានដោយងាយ ។ អាចារ្យពួកខ្លះពោលថា **សុភិក្ខវស្សី** ដូច្នេះក៏មាន ។ សត្វលោកមានភិក្ខាហាររកបានងាយ យ៉ាងណា មហាមេឃដែលញុំាងភ្លៀងឲ្យធ្លាក់សព្វអន្លើ រមែងឈ្មោះថា ធ្លាក់ចុះមកបានងាយ ដូច្នោះ ។ បុគ្គលនោះក៏ដូច្នោះ ជាអ្នកញុំាងភ្លៀងឲ្យធ្លាក់ក្នុងទីគ្រប់អន្លើ ដោយមហាទាន រកភិក្ខាបានដោយងាយ ។ បទថា **អាមោទមានោ បកិរេតិ** សេចក្តីថា អ្នកដែលមានចិត្តត្រេកអរ និងរីករាយហើយ ឲ្យទានដោយដៃរបស់ខ្លួន ដូចព្រោះទេយ្យធម៌ក្នុងស្រែ គឺបដិគ្គាហក សូម្បីវាចា ក៏ពោលថា អ្នកទាំងឡាយ ចូរឲ្យទានចុះ អ្នកទាំងឡាយ ចូរឲ្យទានចុះ ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាវៈដែលមេឃឲ្យភ្លៀងធ្លាក់ ធ្វើឲ្យភិក្ខារកបានងាយ ទើបត្រាស់ពាក្យជាដើមថា **យថាបិ មេឃោ** ដូច្នេះ ។

ក្នុងព្រះគាថានោះ មានសេចក្តីសង្ខេបដូចតទៅនេះថា មេឃគ្រហឹមដោយសំឡេងតិចៗ ហើយ ទើបគ្រហឹមសព្វទិសទី មានជ្រោះ និងអូរជាដើម ហើយធ្លាក់ចុះមក ហូរទៅកាន់ទីទាប និងទីទួលសព្វអន្លើ ពេញទៅដោយឧទកវារី ធ្វើឲ្យជាជំនន់ទឹកតែមួយ យ៉ាងណា បុគ្គលដែលចិត្តទូលាយពួកខ្លះក្នុងទីនេះ គឺក្នុងលោក ក៏ដូច្នោះ ព្រោះជាអ្នកមានចិត្តស្មើក្នុងមនុស្សទូទៅ ដូចមហាមេឃ ដូច្នោះ ព្រោះត្រូវឲ្យភ្លៀងធ្លាក់ចុះមក ជាអ្នកមិនខ្ជិលច្រអូស ដោយទ្រព្យដែលជារបស់រកបានមកដោយសេចក្តីព្យាយាម គឺកើតឡើងដោយ

សេចក្តីព្យាយាមរបស់ខ្លួន ប្រមូលនូវទ្រព្យនោះដោយធម៌ គឺដោយប្រពៃ ញ៉ាំងវណិព្វកទាំងឡាយដែលដល់ហើយ គឺមកដល់ហើយ ឲ្យឆ្អែត គឺឲ្យឆ្អែត ស្កប់ស្កល់ដោយប្រពៃ គឺសមគួរដល់កាលៈទេសៈ ព្រោះសមគួរដល់សេចក្តីត្រូវការដោយប្រពៃនោះឯង ដោយបាយ ទឹក និងដោយទេយ្យធម៌ដទៃៗ ដែលកើតអំពីទ្រព្យដែលប្រមូល ដូច្នេះ ។ល។

**អដ្ឋកថា អវុដ្ឋិកសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សុខសូត្រ

[ ៧៦ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្តីសុខ ៣ យ៉ាងនេះ គួរតែរក្សាសីល ។ សេចក្តីសុខ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺបណ្ឌិតគប្បីរក្សាសីល ដោយបំណងថា សូមឲ្យសេចក្តីសរសើរមកដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីល ដោយបំណងថា សូមឲ្យភោគៈទាំងឡាយ កើតឡើងដល់អាត្មាអញ ១ បណ្ឌិតគប្បីរក្សាសីល ដោយបំណងថា អាត្មាអញលុះដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតឯសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតកាលប្រាថ្នាសេចក្តីសុខ ៣ យ៉ាងនេះឯង គួរតែរក្សាសីល ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះ

ហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បណ្ឌិតកាលប្រាថ្នា នូវសេចក្ដីសុខ ៣ យ៉ាង គឺសេចក្ដីសរសើរ ១ ការបានទ្រព្យ ១ ការលះលោកនេះហើយរីករាយក្នុងស្ថានសួគ៌ ១ គួរតែរក្សាសីល ។ កាលបើបុគ្គលមិនធ្វើបាបទេ តែទៅសេពគប់នឹងបុគ្គលធ្វើបាបបុគ្គលនោះ ត្រូវអ្នកផងរង្កៀស ព្រោះអំពើអាក្រក់ផងតំណិះដំណៀលរមែងចម្រើនឡើងដល់បុគ្គលនោះផង ។ បុគ្គលយកបុគ្គលបែបណា ជាមិត្រផង សេពគប់នូវមិត្តបែបណាផង បុគ្គលនោះឯង នឹងប្រាកដស្មើដោយមិត្រនោះៗ ព្រោះការនៅរួម នឹងក្លាយទៅជាបែបគ្នានោះពិត ។ បុគ្គលបាប កាលបើបុគ្គលស្អាតដទៃ មកសេពគប់ហើយ បុគ្គលបាបត្រូវបុគ្គលស្អាត ( នោះ ) មកកប់ប្រសព្វហើយ រមែងប្រឡាក់នូវបុគ្គលអ្នកមកកប់ប្រសព្វ ( នោះ ) ដែលគេមិនបានប្រឡាក់ ( ដោយបាបធម៌ ) ផង ដូចព្រួញដែលគេលាបថ្នាំពិស កាលប្រឡាក់នូវបំពង់ព្រួញ ដូច្នោះឯង ។ អ្នកប្រាជ្ញ ព្រោះខ្លាចការប្រឡាក់ ( ដោយបាប ) ទើបមិនយកបុគ្គលបាបជាសម្លាញ់ឡើយ ។ នរជនណាខ្ចប់ត្រីស្អុយដោយចុងស្បូវ ស្បូវក៏មានក្លិនស្អុយ ផ្សាយចេញទៅ យ៉ាង

*ណាមិញ ការសេពគប់នឹងបុគ្គលពាល ក៏យ៉ាងនោះ*
*ដែរ ។ នរជនណា ខ្ចប់ខ្ចីមក្រស្នាដោយស្លឹកឈើ ស្លឹក*
*ឈើ ក៏មានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការ*
*សេពនឹងអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ហេតុនោះ បណ្ឌិត*
*ដឹងនូវការសម្រេចនៃផលរបស់ខ្លួន ដូចជាកញ្ចប់នៃស្លឹក*
*ឈើហើយ មិនគប្បីសេពគប់នឹងពួកអសប្បុរសឡើយ*
*គួរសេពគប់ តែនឹងពួកសប្បុរស ។ ( ព្រោះ ) ពួក*
*អសប្បុរស តែងនាំទៅកាន់នរក ពួកសប្បុរស តែង*
*ញុំាងសត្វឲ្យទៅកាន់ស្ថានសួគ៌ ។*

*ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៧ ។*

# អដ្ឋកថា

## សុខបត្ថនាសូត្រទី ៧

*[ ៧៦ ] ក្នុងសុខបត្ថនាសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **សុខានិ** *បានដល់ ហេតុនៃសេចក្តីសុខ ។ បទថា* **បត្ថយមានោ** *សេចក្តីថា ប្រាថ្នា គឺមានចំណង់ ។ បទថា* **សីលំ** *បានដល់ ទាំងសីលរបស់គ្រហស្ថ និងសីលរបស់បព្វជិត អធិប្បាយថា បើគ្រហស្ថ ត្រូវរក្សាសីល*

របស់គ្រហស្ថ បើជាបព្វជិត ក៏ត្រូវរក្សាចតុប្បរិសុទ្ធិសីល ។ បទថា **រក្ខេយ្យ** សេចក្ដីថា សមាទានហើយ មិនកន្លងល្មើស រក្សាដោយល្អនោះឯង ។

បទថា **បសំសា មេ អាគច្ឆន្តុ** សេចក្ដីថា អ្នកឈ្លាស គឺអ្នកមានបញ្ញា ប្រាថ្នាថា សូមកិត្តិសព្ទដែលល្អរបស់អញចូរមកដល់ ដូច្នេះហើយ រក្សាសីល អធិប្បាយថា កិត្តិសព្ទដែលល្អរបស់គ្រហស្ថអ្នកមានសីល តែងផ្សាយទៅកណ្ដាលបរិស័ទ ដោយន័យជាដើមថា កូនរបស់ត្រកូលនោះ ឈ្មោះនោះ ជាអ្នកមានសីល មានកល្យាណធម៌ មានសទ្ធាជ្រះថ្លាហើយ ជាអ្នកឲ្យទាន ជាអ្នកបំពេញបុណ្យ ដូច្នេះ ។ កិត្តិសព្ទដ៏ល្អរបស់បព្វជិត រមែងផ្សាយទៅក្នុងកណ្ដាលបរិស័ទ ដោយន័យជាដើមថា ភិក្ខុឈ្មោះនោះ ជាអ្នកមានសីល សម្បូរដោយវត្ត ស្ងប់ស្ងៀម នៅរួមដោយសប្បាយ មានសេចក្ដីគោរព មានការកោតក្រែង ដូច្នេះ សមដូចទ្រង់ត្រាស់ថា ម្នាលគហបតី មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ដូច្នេះ ។

ម្យ៉ាងទៀត សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងអាកង្ខេយ្យសូត្រថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ផង ជាទីពេញចិត្តផង ជាទីគោរពផង ជាទីសរសើរផង របស់ពួកសព្រហ្មចារី ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ភោគា មេ ឧប្បជ្ជន្តុ** ដូចតទៅនេះថា ជាបឋម កាលគ្រហស្ថអ្នកមានសីល មានកល្យាណធម៌ ចិញ្ចឹមជីវិតដោយ

សិប្បៈ និងសេចក្ដីព្យាយាមណាមួយ ដូចជាកសិណកម្ម ពាណិជកម្ម និងទទួលរាជការ កាលបើដូច្នោះ ភោគៈទាំងឡាយដែលមិនទាន់កើត រមែងកើតដល់បុគ្គលនោះ ភោគៈដែលកើតឡើងហើយ នឹងដល់នូវសេចក្ដីចម្រើន ព្រោះភាពជាអ្នកមិនប្រមាទក្នុងសិប្បៈ និងភាពជាអ្នកឲ្យឧស្សាហ៍ប្រឹងប្រែង តាមកាល និងតាមឧបាយ ។ ឯបព្វជិត កាលដល់ព្រមដោយសីលាចារវត្ត មានប្រក្រតីមិនប្រមាទ មនុស្សទាំងឡាយជ្រះថ្លាហើយ ក្នុងការដល់ព្រមដោយសីល និងគុណ មានការប្រាថ្នាតិចជាដើមរបស់បព្វជិត ដែលបរិបូណ៌ដោយសីល និងនាំបច្ច័យមកឲ្យយ៉ាងមហោឡារ កាលបើដូច្នោះ ភោគៈដែលមិនទាន់កើតឡើង រមែងកើតឡើងដល់បព្វជិតនោះ និងដែលកើតឡើងហើយ ក៏មាំទាំ សមដូចព្រះតម្រាស់ដែលត្រាស់ថា ម្នាលគហបតី មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលក្នុងលោកនេះ តែងបាននូវគំនរសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្ដីមិនប្រមាទ ដូច្នេះ ។ ម្យ៉ាងទៀត សមដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដូច្នេះ គួរធ្វើសីលឲ្យបរិបូណ៌ ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **បត្ថយានោ** បានដល់ **បត្ថយន្តោ** ប្រែថា ប្រាថ្នា ។ បទថា **តយោ សុខេ** ស្មើគ្នានឹង **តីណិ សុខានិ** ប្រែថា សេចក្ដីសុខ ៣ ប្រការ ។ បទថា **វិត្តលាភំ** សេចក្ដីថា បានទ្រព្យ អធិប្បាយថា ការកើតឡើងនៃភោគទ្រព្យ ។ ដោយបទដែល

បែកផ្សេងគ្នា បណ្ដាសុខទាំង ៣ យ៉ាងនេះ គប្បីជ្រាបថា ទ្រង់កាន់យក ចេតសិកសុខ ដោយការសរសើរកាយិកសុខ ដោយកោគៈ ឧបបត្តិសុខ ដោយទ្រព្យក្រៅអំពីនេះ ម្យ៉ាងទៀត គប្បីជ្រាបថា ទ្រង់កាន់យកសុខក្នុង បច្ចុប្បន្ន ដោយសព្ទទី ១ សុខក្នុងសម្បរាយិកភពដោយសព្ទទី ៣ សុខ ទាំង ២ យ៉ាង ដោយសព្ទទាំង ២ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការវៀរចាកបាបមិត្ត និង ការសេពគប់កល្យាណមិត្ត ដែលជាហេតុពិសេសនៃការសរសើរជាដើម ដូច សីល ដែលជាហេតុធម្មតានៃការសរសើរជាដើម មួយអន្លើដោយទោស និង អានិសង្ស ទើបត្រាស់ពាក្យជាដើមថា **អករោន្តោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សង្កិយោ** សេចក្ដីថា បុគ្គលនោះគប្បីត្រូវ រង្កៀស ព្រោះសេចក្ដីអាក្រក់ថា បុគ្គលនេះ ធ្វើអាក្រក់មកហើយ ឬនឹងធ្វើ តទៅដោយពិត ។ ម្យ៉ាងទៀត ព្រោះចូលទៅសេពគប់នឹងជនអាក្រក់ទាំង ឡាយ ។

បទថា **អស្ស** សេចក្ដីថា ទោសរបស់បុគ្គលដែលសេពគប់មិត្តអាក្រក់ នេះសូម្បីមិនមាន ក៏ដុះដាលឡើងព្រោះសេពគប់មិត្តអាក្រក់ ។ បទថា **រូហតិ** បានដល់ ដល់នូវការដុះដាល ពេញបរិបូណ៌ គឺផ្សាយទៅ ។ ម្យ៉ាងទៀត បទ ថា **អស្ស** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ សេចក្ដីថា ក្នុងបុគ្គលនោះ ។ បទថា **សវេ តាទិសកោ ហោតិ** សេចក្ដីថា បុគ្គលណាគប់ និងចូលទៅ គប់រកបាបមិត្ត ឬកល្យាណមិត្តបែបណា បុគ្គលនោះ ក៏នឹងទៅជាយ៉ាងនោះ

*គឺមានបាបធម៌ ឬមានកល្យាណធម៌ ដូចទឹកដែលស្អាត និងស្មោកគ្រោក ដោយអំណាចនៃទឹកនោះ ។ ព្រោះហេតុអ្វី ព្រោះការនៅរួមគ្នាជាហេតុឲ្យបុគ្គលទៅជាយ៉ាងនោះ អធិប្បាយថា ការនៅរួមគ្នាជាមួយបុគ្គលគ្រោតគ្រាត មិនគួរធ្វើ ព្រោះការនៅរួមគ្នា គឺការនៅប្រឡូកប្រឡំគ្នា បានដល់ ការស្និទ្ធស្នាលគ្នា ជាហេតុឲ្យទទួលយកកិរិយាអាការរបស់បុគ្គលដែលគប់រក ដែលជាឧបនិស្ស័យរបស់ខ្លួន ដូចកែវផលិក និងកែវមណីដែលនៅរួមគ្នាដូច្នោះ ។*

*បទថា* **សេវមានោ សេវមានំ** *សេចក្តីថា បុគ្គលអាក្រក់ កាលសេពគប់បុគ្គលដទៃ ដែលបរិសុទ្ធតាមប្រក្រតីដែលគប់រកខ្លួនសព្វកាល ឬដែលគេគប់រក រមែងធ្វើឲ្យបុគ្គលនោះប្រឡាក់ ។ បទថា* **សម្ផុដ្ឋោ សម្ផុសំ** *សេចក្តីថា បុគ្គលអាក្រក់ ដែលបុគ្គលបរិសុទ្ធតាមប្រក្រតីនោះសេពគប់ដោយការនៅរួមគ្នា គឺប្រឡូកប្រឡំគ្នា សូម្បីខ្លួនឯង កាលសេពគប់យ៉ាងនោះ ។ បទថា* **សរោ ទុដ្ឋោ កលាបំវ** *សេចក្តីថា ឧបមាដូចព្រួញដែលលាបដោយថ្នាំពិស ដាក់ក្នុងបំពង់ព្រួញ រមែងប្រឡាក់នូវបំពង់ព្រួញដែលព្រួញទាំងអស់ ប៉ះពាល់ហើយ យ៉ាងណា បុគ្គលអាក្រក់ក៏ដូច្នោះ រមែងប្រឡាក់អ្នកដទៃដែលបរិសុទ្ធដោយប្រក្រតី ដោយសេចក្តីអាក្រក់ ។ បទថា* **ឧបលេបភយា ធីរោ** *សេចក្តីថា បុគ្គល ឈ្មោះថា ធីរៈ ព្រោះជាអ្នកសម្បូរដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ គឺបុគ្គលដែលជាបណ្ឌិត មិនគួរមានមនុស្សអាក្រក់ជាសម្លាញ់ ។ បទថា* **បូតិមច្ឆំ កុសគ្គេន** *សេចក្តីថា បុគ្គលណា យកស្លឹកស្បូវក្លាំងចងត្រីស្អុយ ដែលជាវត្ថុគួរខ្ពើម គឺចងវុំឲ្យជាកញ្ចប់ ស្លឹកស្បូវក្លាំងទាំងនោះនៃបុគ្គល*

នោះ ទោះមិនស្អុយ ក៏ឈ្មោះថា ស្អុយ ព្រោះខ្ចប់ត្រីស្អុយ និងបញ្ចេញក្លិនស្អុយត្រឡប់ទៅ យ៉ាងណា ។ បទថា **ឯវំ ពាលូបសេវនា** សេចក្តីថា ការគប់រក ការសមាគមនឹងបុគ្គលពាល គប្បីឃើញឧបមាដូច្នោះ ។ បទថា **ឯវំ ធីរូបសេវនា** សេចក្តីថា ការគប់រក ការសមាគម ជាមួយបណ្ឌិតនៃបុគ្គលអ្នកមិនមានសីលតាមប្រក្រតី រមែងជាហេតុឲ្យក្លិនសីលផ្សាយទៅ ដោយអំណាចនៃការសមាទានសីលជាដើម ។ ដូចស្លឹកឈើ ទោះមិនមានក្លិនក្រអូបតែឈ្មោះថា មានក្លិនក្រអូបផ្សាយទៅ ព្រោះខ្ចប់នូវក្រស្នា ដូច្នោះ ។

បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលការសេពគប់មិត្រមិនល្អមានទោសបែបនេះ និងការគប់មិត្រដែលល្អ មានអានិសង្សបែបនេះ គឺដូច្នេះដូច្នោះ បណ្ឌិតដឹងផលរបស់ខ្លួនដោយការលាយឡំគ្នានៃវត្ថុដែលមានក្លិនស្អុយនិងក្លិនក្រអូប និងការសមាគមជាមួយមនុស្សល្អ និងមនុស្សមិនល្អ ដូចខ្ចប់ប្រហុក និងក្រស្នាដោយស្លឹកឈើ គឺដូចត្រីស្អុយ និងក្រស្នាដោយស្លឹកឈើ ។ បទថា **ញត្វា សម្បាកមត្តនោ** សេចក្តីថា បណ្ឌិតដឹង គឺដឹងនូវការសម្រេចផលរបស់ខ្លួន ដែលមានទុក្ខជាផល និងមានសុខជាផល និងមានសុខជាកម្រៃហើយ មិនគួរគប់រកអសប្បុរស គឺមិត្រអាក្រក់ គួរសេពគប់តែពួកសប្បុរសគឺបណ្ឌិតដែលស្ងប់រម្ងាប់ហើយ ជាអ្នកមានទោសទៅប្រាសហើយ ឬដែលអ្នកប្រាជ្ញសរសើរហើយ សមដូចព្រះមានព្រះភាគត្រាស់ថា អសប្បុរសនាំទៅកាន់នរក ឯសប្បុរសឲ្យដល់នូវសុគតិ ។

ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងហេតុនៃសេចក្តីសុខ ៣

យ៉ាង តាមដែលពោលមកហើយ ដោយព្រះគាថាដំបូង ហើយទ្រង់សម្តែងហេតុដែលជាទីមកនៃសេចក្តីសុខ សេចក្តីសរសើរ មួយអន្លើដោយការវៀរធម៌ដែលជាបដិបក្ខដោយ ៥ ព្រះគាថា បន្ទាប់អំពីនោះ ទើបសម្តែងនូវសេចក្តីសុខចុងក្រោយ មួយអន្លើដោយហេតុដែលប្រកបសេចក្តីសុខទាំង ៣ យ៉ាង ដោយគាថាចុងក្រោយ ។ល។

## អដ្ឋកថា សុខបត្ថនាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ភិន្ទុរសូត្រ

[ ៧៧ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ រូបកាយនេះ មានសេចក្តីបែកធ្លាយជាធម្មតា វិញ្ញាណមានការទៅប្រាសជាធម្មតា ឧបធិទាំងពួងជារបស់មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកប្រាជ្ញមានខ្លួនអប់រំហើយ ដឹងច្បាស់ នូវកាយដែល
បែកធ្លាយផង ដឹងច្បាស់ នូវវិញ្ញាណដែលពុកផុយផង
ឃើញភ័យក្នុងឧបធិទាំងឡាយផង ហើយកន្លងជាតិ
និងមរណៈ បានដល់និព្វាន ជាទីរម្ងាប់សង្ខារទាំងពួងដ៏

ឧត្តម រមែងទទួនរង់ចាំតែកាល ( បរិនិព្វាននៃខន្ធ ) ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ៨ ។

# អដ្ឋកថា

## ភិទុរសូត្រ

[ ៧៧ ] ក្នុងភិទុរសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ភិទុរាយំ** កាត់បទជា **ភិទុរោ អយំ**។ បទថា **កាយោ** បានដល់ រូបកាយ ។ ឯរូបកាយនោះ ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំនៃអវយវៈតូចធំទាំងឡាយ មានសក់ជាដើម និងឈ្មោះថា **កាយ** ព្រោះមានវិគ្គហៈថាជា **អាយ** គឺជាប្រភពកើតនៃវត្ថុគួរខ្ពើម គួររអើមទាំងឡាយ យ៉ាងនេះក៏មាន ។ ក្នុងពាក្យថា **កាយ** នោះ មានអត្ថវចនៈដូចតទៅនេះថា អការ ឈ្មោះថា **អាយ** ព្រោះជាទីមក ។ សួរថា អ្វីមក ឆ្លើយថា វត្ថុដែលគួរខ្ពើម មានសក់ជាដើមមក ។ ដូច្នោះ អាការ ឈ្មោះថា **កាយ** ព្រោះជាទីមកនៃវត្ថុគួរខ្ពើមទាំងឡាយ ដូច្នេះក៏បាន ។ តែដោយអត្ថហើយ បានដល់ គំនរនៃធម៌ទាំង-ឡាយ គឺភូតរូប និងឧបាទាយរូបដែលប្រព្រឹត្តទៅ ដោយអំណាចនៃសន្តិ ៤ យ៉ាង ។ មានពុទ្ធាធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រូបកាយដែលសម្រេចដោយមហាភូតទាំង ៤ នេះ មានការបែកធ្លាយ មានការវិនាសទៅ

ជាសភាវៈ មានការខ្ចាត់ខ្ចាយទៅគ្រប់ខណៈជាសភាវៈ ។ បាឋៈថា **ភិទុរាយំ** ដូច្នេះក៏មាន ។ អត្ថក៏យ៉ាងនោះឯង ។ បទថា **វិញ្ញាណំ** បានដល់ កុសលចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ឯអត្ថវចនៈ មានដូចតទៅនេះ ចិត្ត ឈ្មោះថា វិញ្ញាណ ព្រោះដឹងច្បាស់នូវអារម្មណ៍នោះៗ ព្រោះថា ការបែកសតិចេញអំពីសញ្ញាបាន គឺការដឹងច្បាស់អារម្មណ៍ បានដល់ ញាណ ឈ្មោះថា វិញ្ញាណ ។ បទថា **វិភាគធម្មំ** គឺមានការវិនាសជាធម្មតា អធិប្បាយថា មានការបែកធ្លាយទៅជាធម្មតា ។ បទថា **សព្វេ ឧបធី** សេចក្តីថា ឧបធិទាំងនេះ គឺខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ បញ្ចកាមគុណូបធិ ដែលសន្មតថា ឧបធិ ព្រោះអត្ថថា ជាទីចូលទៅទ្រទ្រង់នូវសេចក្តីទុក្ខទាំងអស់នេះ បានដល់ ឧបាទានក្ខន្ធ កិលេស និងអភិសង្ខារ ជាបញ្ចកាមគុណ ឈ្មោះថា **អនិច្ចា** ព្រោះអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ ឈ្មោះថា **ទុក្ខា** ព្រោះអត្ថថា កើតឡើងនិងវិនាសទៅ និងព្រោះបៀតបៀន ។ ឈ្មោះថា **វិបរិណាមធម្មា** ព្រោះអត្ថថា លះប្រក្រតី ព្រោះជាសភាវៈដែលត្រូវប្រែប្រួលទៅ ដោយហេតុ ២ ប្រការ គឺជរា និងមរណៈ ។

ដោយប្រការដូចពណ៌នាមកនេះ ព្រះមានព្រះភាគត្រាស់ដល់វារៈនៃការពិចារណាតាមអធ្យាស្រ័យនៃបុគ្គលដែលដឹងយ៉ាងនោះ ដោយមុខ គឺអនិច្ចានុបស្សនា និងទុក្ខានុបស្សនា ទ្រង់បែករូបធម៌ និងវិញ្ញាណចេញអំពីគ្នា រួបទ្រង់សមោធានធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ចូលគ្នាតែមួយ ដោយទ្រង់បែកចេញជាឧបធិទៀត ព្រោះបណ្តាលក្ខណៈទាំង ៣ នេះ អនិច្ចលក្ខណៈ

ឃើញងាយ ក្នុងបណ្ដាលក្ខណៈទាំង ៣ នេះ លក្ខណៈ ២ យ៉ាងប៉ុណ្ណោះ មានមកក្នុងព្រះបាលីក៏ពិត តែទោះជាដូច្នោះ ដោយព្រះបាលីថា វត្ថុណា ជាទុក្ខ វត្ថុនោះជាអនត្តា គប្បីយល់ថា អនត្តលក្ខណៈ ទ្រង់ក៏សម្ដែងហើយ ដូចគ្នា ដោយទុក្ខលក្ខណៈនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថាដូចតទៅនេះ បទថា **ឧបធីសុ ភយំ ទិស្វា** សេចក្ដីថា ឃើញភ័យក្នុងឧបធិទាំង ៣ ដោយអំណាចនៃភយតូបដ្ឋានញាណ គឺឃើញនូវឧបធិទាំងនោះជារបស់គួរខ្លាច ។ ព្រះមានព្រះភាគ ទ្រង់សម្ដែង នូវវិបស្សនាដែលមានកម្លាំង ដោយបទថា **ឧបធីសុ ភយំ ទិស្វា** នេះ ព្រោះ ព្រះមានព្រះភាគ ទ្រង់ចែកភយតូបដ្ឋានញាណនោះឯងចេញទៅ ហើយត្រាស់ នូវវិបស្សនាដែលមានកម្លាំង ជាអាទីនវានុបស្សនា ១ និព្វិទានុបស្សនា ១ ដោយជាញាណដែលប្លែកគ្នា ។ បទថា **ជាតិមរណមច្ចគា** សេចក្ដីថា ភិក្ខុ ពិចារណាយ៉ាងនេះបន្តវិបស្សនាញាណដោយមគ្គហើយ សម្រេចអរហត្តផល បន្តអំពីមគ្គនោះទៅ រមែងឈ្មោះថា ជាអ្នកកន្លងផុតជាតិ និងមរណៈបាន តើ កន្លងផុតបានដូចម្ដេច ។ បទថា **សម្បត្វា បរមំ សន្តឹ** សេចក្ដីថា ព្រោះការ សម្រេចសន្តិធម៌ដ៏កំពូល គឺឧត្តម បានដល់ មិនមានធម៌ដទៃក្រៃលែងជាង គឺ ព្រះនិព្វានដែលជាទីរម្ងាប់សង្ខារទាំងឡាយ ភិក្ខុនោះក៏យ៉ាងនោះ ។ បទថា **កាលំ កង្ខតិ ភាវិតត្តោ** សេចក្ដីថា ភិក្ខុឈ្មោះថា មានខ្លួនអប់រំហើយ ព្រោះ ភាពជាអ្នកមានកាយ ដែលអប់រំហើយដោយសីល សមាធិ និងបញ្ញា ហេតុ ដែលសម្រេច គឺការសម្រេចភាវនា ដោយអំណាចនៃអរិយមគ្គ ៤ ដែលមិន

អាល័យ គឺជល់នូវសេចក្តីស្លាប់ និងការរស់នៅ រមែងសង្ឃឹម គឺសម្លឹងឃើញកាលកិរិយា ដោយខន្ធបរិនិព្វានរបស់ខ្លួនតែម្យ៉ាង ។ បុគ្គលនោះមិនមានសេចក្តីប្រាថ្នាក្នុងអ្វីមួយឡើយ ដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងថេរគាថាថា

អាត្មាមិនត្រេកអរនឹងសេចក្តីស្លាប់ មិនត្រេកអរ នឹងការរស់នៅ អាត្មារង់ចាំតែកាលនឹងបរិនិព្វាន ដូចជាអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ដូច្នេះ ។៚

**អដ្ឋកថា ភិក្ខុសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ធាតុសោសំសន្ទនសូត្រ

[ ៧៨ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយរមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា គឺសត្វដែលមានអធ្យាស្រ័យថោកទាប រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាប សត្វដែលមានអធ្យាស្រ័យល្អ រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រហែលគ្នា ស្មើគ្នាជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងអតីតកាល គឺពួកសត្វដែលមានអធ្យាស្រ័យថោកទាប ប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួក

សត្វដែលមានអធ្យាស្រ័យថោកទាប សត្វទាំងឡាយដែលមានអធ្យាស្រ័យល្អ ប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ គង់នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងអនាគតកាល គឺពួកសត្វដែលមានអធ្យាស្រ័យថោកទាប នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាប ពួកសត្វដែលមានអធ្យាស្រ័យល្អ នឹងប្រហែលគ្នា នឹងស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ សត្វទាំងឡាយ រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វ ដោយធាតុដូចគ្នា ក្នុងបច្ចុប្បន្នកាល គឺពួកសត្វដែលមានអធ្យាស្រ័យថោកទាប រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យថោកទាប ពួកសត្វដែលមានអធ្យាស្រ័យល្អ រមែងប្រហែលគ្នា ស្មើគ្នា ជាមួយនឹងពួកសត្វដែលមានអធ្យាស្រ័យល្អ ។ លុះព្រះមានព្រះភាគទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រៃគឺកិលេសកើតឡើងហើយ ព្រោះតែការជាប់ចំពាក់
ដែលបុគ្គលនឹងកាត់ផ្ដាច់បាន ដោយការមិនជាប់ចំពាក់
បុគ្គលអ្នកមានប្រាជ្ញានឹងឆ្លងមហាសមុទ្រ ហើយលិច
ទៅក្នុងមហាសមុទ្រវិញ ព្រោះតែឡើងកាន់ក្បូនឈើដ៏
តូច យ៉ាងណាមិញ ឯបុគ្គលអ្នកចិញ្ចឹមជីវិតដោយប្រពៃ
រមែងលិចចុះក្នុងមហាសមុទ្រ គឺសង្សារ ព្រោះតែ

អាស្រ័យនឹងបុគ្គលខ្ជិលច្រអូស យ៉ាងនោះដែរ ។ ព្រោះ
ហេតុនោះ បុគ្គលគួរវៀរនូវបុគ្គលខ្ជិលនោះ ដែលមាន
ព្យាយាមថោកទាប ហើយគួរនៅរួមដោយបណ្ឌិតទាំង
ឡាយ ដែលជាអ្នកស្ងាត់ ជាអ្នកឆ្ងាយចាកកិលេស មាន
ចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ជាអ្នកមានឈាន អ្នក
ប្រារព្ធព្យាយាមជានិច្ច ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ សូត្រទី ៩ ។

# អដ្ឋកថា

## ធាតុសោសំសន្ទនសូត្រ

ក្នុងធាតុសោសំសន្ទនសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៧៨ ] បទថា **ធាតុសោ** បានដល់ ដោយធាតុ ។ ធាតុ គឺអធ្យាស្រ័យ គឺសភាវៈនៃអធ្យាស្រ័យ ដែលត្រាស់ហៅថា អធិមុត្តិក៏មាន ព្រះអង្គទ្រង់បំណាងយកថា ធាតុ ក្នុងព្រះសូត្រនេះ ។ បទថា **សំសន្ទន្តិ** សេចក្តីថា ចូលគ្នាបាន គឺរួមគ្នាបានតាមធាតុ គឺតាមអធ្យាស្រ័យ ព្រោះមានធាតុមានចំណែកស្មើគ្នានោះ ។ បទថា **សមេន្តិ** សេចក្តីថា ជាអ្នកមានការគិតរួមគ្នាសមាគមគ្នាបាន គឺគប់រកគ្នាបាន បានដល់ ចូលទៅរកគ្នាបាន ព្រោះជាអ្នក

មានអធ្យាស្រ័យស្មើគ្នានោះឯង ម្យ៉ាងទៀត ការគាប់ចិត្ត ការអត់ធន់ និងការឃើញស្មើគ្នាក្នុងរឿងនោះៗ ។ បទថា **ហីនាធិមុត្តិកា** សេចក្តីថា ឈ្មោះថាមានអធិមុត្តិថោកទាប ព្រោះមានការទោរទន់ទៅក្នុងធម៌ដែលថោកទាប មានកាមគុណជាដើម គឺមានអធ្យាស្រ័យថោកទាប ។ បទថា **កល្យាណាធិមុត្តិកា** សេចក្តីថា ឈ្មោះថា មានអធិមុត្តិល្អ ព្រោះមានការទោរទន់ទៅក្នុងធម៌ដែលល្អ មាននេក្ខម្មៈជាដើម គឺមានអធ្យាស្រ័យប្រណីត អធិប្បាយថា បើអាចារ្យ និងឧបជ្ឈាយ៍ ជាអ្នកមិនមានសីល តែអន្តេវាសិក និងសទ្ធិវិហារិក ជាអ្នកមានសីល អន្តេវាសិក និងសទ្ធិវិហារិកទាំងនោះ តែងមិនចូលទៅរកអាចារ្យ និងឧបជ្ឈាយ៍ នឹងចូលទៅរកចំពោះតែភិក្ខុដែលមានសមណសារុប្បដូចខ្លួន ។ បើអាចារ្យ និងឧជ្ឈាយ៍ជាអ្នកមានសីល អន្តេវាសិក និងសទ្ធិវិហារិកក្រៅអំពីនេះ ជាអ្នកមិនមានសីល អន្តេវាសិក និងសទ្ធិវិហារិកទាំងនោះ មិនចូលទៅរកអាចារ្យ និងឧបជ្ឈាយ៍ ទៅរកតែបុគ្គលដែលមានអធ្យាស្រ័យថោកទាបដូចខ្លួនប៉ុណ្ណោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ការចូលទៅរកយ៉ាងនេះ នឹងមានចំពោះក្នុងបច្ចុប្បន្នតែម្យ៉ាងក៏មិនមែន ដោយពិតហើយ សូម្បីអតីត និងអនាគត ក៏មានដូច្នេះ ទើបត្រាស់ថា **អតីតម្បិ ភិក្ខវេ** ដូច្នេះជាដើម ដោយសង្ខេបហើយ បុគ្គលតាំងមាំក្នុងសង្កិលេសធម៌ ឈ្មោះថា ជាអ្នកមានអធ្យាស្រ័យអាក្រក់ បុគ្គលតាំងមាំក្នុងវោទានធម៌ ឈ្មោះថា មានអធ្យាស្រ័យស្អាត សួរថា ការដែលបុគ្គលទ្រុស្តសីល គប់រកបុគ្គលទ្រុស្តសីលប៉ុណ្ណោះ

ការដែលបុគ្គលមានសីលគប់រកអ្នកមានសីលប៉ុណ្ណោះ ការដែលបុគ្គលមានបញ្ញាថោកថយ គប់រកបុគ្គលដែលមានបញ្ញាថោកថយប៉ុណ្ណោះ ការដែលបុគ្គលមានបញ្ញាគប់រកបុគ្គលមានបញ្ញាប៉ុណ្ណោះ នេះអ្នកណាកំណត់ ឆ្លើយថា ធាតុ គឺអធ្យាស្រ័យកំណត់ ។

បានឮថា ភិក្ខុច្រើនរូបត្រាច់ភិក្ខាចារក្នុងស្រុកមួយ មនុស្សទាំងនោះនាំភត្តជាច្រើនមកដាក់រហូតពេញបាត្រ ពោលថា សូមលោកម្ចាស់ទាំងឡាយឆាន់តាមចំណែកដែលត្រូវការ ហើយបញ្ជូនទៅ ។ ភិក្ខុទាំងឡាយពោលថា អាវុសោទាំងឡាយ មនុស្សទាំងឡាយប្រកបការងារដែលសមគួរដល់ធាតុ គឺអធ្យាស្រ័យ ដូច្នេះ ។ ធាតុ គឺអធ្យាស្រ័យរមែងកំណត់យ៉ាងនេះ បណ្ឌិតគប្បីសម្តែងធាតុសំយុត្តដូចតទៅនេះថា ព្រះមានព្រះភាគផ្ទំលើព្រះទែន ប្រឈូនលើភ្នំគិជ្ឈកូដ ទតមើលព្រះសារីបុត្រ និងព្រះមោគ្គល្លាន ដែលថ្វាយការរក្សាមួយរូបៗ ចង្ក្រមជាមួយបរិស័ទរបស់ខ្លួន ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញដែរឬទេ សារីបុត្រចង្ក្រមជាមួយភិក្ខុទាំងឡាយជាច្រើន ពួកភិក្ខុទូលថា ខ្ញុំព្រះអង្គឃើញ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ សុទ្ធតែជាអ្នកមានបញ្ញាច្រើន ដូច្នេះ គួរនាំរឿងទាំងអស់មកសម្តែងដោយពិស្តារ[១] ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **សំសគ្គា** សេចក្តីថា ព្រោះប្រកបរួមគ្នា ដោយអំណាចការនៅរួមគ្នាជាដើម ដោយ

១- សេចក្តីពិស្តារមានក្នុង បិ. ៣២ ទំ. ៣២ ។

សន្និលេស ។ម្យ៉ាងទៀត ព្រោះប្រឡូកប្រឡំគ្នា ក្នុងការប្រឡូកប្រឡំ ៥ យ៉ាងណាមួយយ៉ាងនេះ គឺទស្សនសំសគ្គៈ ប្រឡូកប្រឡំដោយការឃើញ ១ សវនសំសគ្គៈ ប្រឡូកប្រឡំដោយការស្តាប់ ១ សមុល្លាបសំសគ្គៈ ប្រឡូកប្រឡំដោយការចរចា ១ សម្ភោគសំសគ្គៈ ប្រឡូកប្រឡំដោយការប្រើប្រាស់រួម ១ កាយសំសគ្គៈ ប្រឡូកប្រឡំដោយកាយ ១ ។ បទថា **វិធោ ជាតោ** សេចក្តីថា កិលេសកើតឡើង ព្រោះមិនទាន់បានដកឡើងដោយមគ្គ ។ បទថា **អសំសគ្គេន ឆិជ្ជតិ** សេចក្តីថា កិលេសដាច់ទៅខាងដើម ដោយការវៀរចាកការប្រឡូកប្រឡំ មានកាយវិវេកជាដើម ហើយដាច់ទៅ គឺលះបានទៀត ដោយការមិនជាប់ជំពាក់ដោយចំណែកមួយ គឺដោយសមុច្ឆេទវិវេក ។ ដោយសង្ខេប ការកើតឡើង និងការរលត់ទៅនៃអជ្ឈាស្រ័យដែលថោកទាប ឈ្មោះថា ទ្រង់សម្តែងហើយដោយសង្ខេប ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។ ព្រោះហេតុដែលភិក្ខុទាំងនោះ ជាអ្នកប្រឡូកប្រឡំគ្នា ហើយកិលេសទាំងនោះក៏កើតឡើង និងចម្រើនឡើងដោយអំណាចនៃការខ្ជិលច្រអូស មិនមែនដោយអំណាចនៃការប្រារព្ធសេចក្តីព្យាយាម ដូច្នោះ ភិក្ខុវៀរបុគ្គលដែលមានអជ្ឈាស្រ័យថោកទាប ជាអ្នកខ្ជិលច្រអូស ហើយគប់រកបុគ្គលដែលមានអជ្ឈាស្រ័យល្អ ជាអ្នកប្រកបសេចក្តីព្យាយាម គប្បីកាត់កិលេសដែលកើតអំពីការប្រឡូកប្រឡំគ្នាបាន ដោយការមិនប្រឡូកប្រឡំគ្នា ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងអត្ថតាមដែលពោលហើយដោយពិស្តារ ទើបបានត្រាស់ពាក្យជាដើមថា **បរិត្តំ ធារុំ** ដូច្នេះ ដើម្បីប្រកាស

ទោសនៃការគប់រកបុគ្គលដែលខ្ជិលច្រអូស ។

បណ្ដាបទទាំងនោះ បទថា **បរិត្តំ ទារុំ** បានដល់ កំណាត់ឈើតូចៗ ។ បទថា **យថា សីទេ មហណ្ណវេ** សេចក្ដីថា ដូចបុគ្គលបំណងឆ្លងមហាសមុទ្រ ដោយនាំយកក្បូនសម្រេចដោយឈើតូចៗ ជិះឆ្លង និងមិនដល់ត្រើយ គង់លិចចុះក្នុងមហាសមុទ្រនោះឯង គប្បីធ្លាក់ទៅជាចំណីរបស់ត្រី និងអណ្ដើក យ៉ាងណា ។ បទថា **ឯវំ កុសីតំ អាគម្ម សាធុជីវីបិ សីទតិ** សេចក្ដីថា បុគ្គលដែលអាស្រ័យអ្នកខ្ជិលច្រអូស ប្រាសចាកការប្រារព្ធព្យាយាម ធ្លាក់នៅក្នុងអំណាចកិលេស ត្រូវគេធ្វើការប្រឡូកប្រឡំ ទោះបីមានជីវិតរាបស្មើ មានអាជីវៈបរិសុទ្ធ និងមានសីលបរិសុទ្ធ តែត្រូវកាមវិតក្កជាដើម ដែលកើតឡើងអំពីការប្រឡូកប្រឡំជាមួយនឹងបុគ្គលថោកទាបបៀតបៀន ក៏មិនអាចទៅដល់ត្រើយបាន នឹងលិចក្នុងអន្លង់មហាសមុទ្រនោះឯងដូចគ្នា ។ បទថា **តស្មា** សេចក្ដីថា ព្រោះការប្រឡូកប្រឡំជាមួយបុគ្គលខ្ជិលច្រអូស ជាហេតុនាំអនត្ថៈយ៉ាងនេះមកឲ្យ ដូច្នោះ ភិក្ខុគួរវៀរមិត្តដែលខ្ជិលច្រអូស ព្រោះតែងលិចចុះក្នុងការខ្ជិលច្រអូស ដោយការប្រកបនូវសេចក្ដីខ្ជិលច្រអូសរឿយៗ ព្រោះអាស្រ័យបុគ្គលនោះ គឺបុគ្គលដែលមានសេចក្ដីព្យាយាមទាបជាង បុគ្គលនោះឯង បានដល់ មិនមានសេចក្ដីព្យាយាម តែគប្បីនៅរួម គឺសេពគប់រកបណ្ឌិតទាំងឡាយ គឺគប់រកអ្នកមានបញ្ញានោះឯង ដែលជាអ្នកស្ងប់ស្ងាត់ដោយអំណាចនៃកាយវិវេក និងតទង្គវិវេកជាដើមដោយចំណែកមួយនោះឯង ។ ដែលឈ្មោះថា **អរិយេហិ** គឺបុគ្គលបរិសុទ្ធ ព្រោះបន្ទាប់អំពីនោះទៅ

នឹងជាអ្នកឆ្ងាយចាកកិលេស ។ ឈ្មោះថា **បហិតត្តោហិ** ព្រោះមានខ្លួនបញ្ជូនទៅហើយកាន់ព្រះនិព្វាន ។ បុគ្គលឈ្មោះថា **ឈាយីហិ** ព្រោះសម្លឹងដោយអំណាចនៃអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ បុគ្គលឈ្មោះថា **អារទ្ធវីរិយេហិ បណ្ឌិតេហិ** ព្រោះជាបុគ្គលប្រារព្ធសេចក្តីព្យាយាម ដោយភាពជាបុគ្គលផ្គងសេចក្តីព្យាយាមអស់កាលសព្វកាលនោះឯង ។

**អដ្ឋកថា ធាតុសោសំសន្ទនសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## បរិហានសូត្រ

[ ៧៩ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់សេក្ខភិក្ខុ ។ ធម៌ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេក្ខភិក្ខុក្នុងសាសនានេះ ជាអ្នកមានការងារជាទីត្រេកអរ ត្រេកអរក្នុងការងារ ប្រកបរឿយៗ នូវការងារជាទីត្រេកអរ ១ ជាអ្នកមានតិរច្ឆានកថាជាទីត្រេកអរ ត្រេកអរក្នុងតិរច្ឆានកថា ប្រកបរឿយៗ នូវតិរច្ឆានកថាជាទីត្រេកអរ ១ ជាអ្នកមានការដេកលក់ជាទីត្រេកអរ ត្រេកអរក្នុងការដេកលក់ ប្រកបរឿយៗ នូវការដេកលក់ជាទីត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុ ។ ធម៌ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេក្ខភិក្ខុ ក្នុងសាសនានេះ ជាអ្នកមិនមានការងារជាទីត្រេកអរ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយៗ នូវការងារជាទីត្រេកអរ ១ ជាអ្នកមិនមានតិរច្ឆានកថាជាទីត្រេកអរ មិនត្រេកអរក្នុងតិរច្ឆានកថា មិនប្រកបរឿយៗ នូវតិរច្ឆានកថា ជាទីត្រេកអរ ១ ជាអ្នកមិនមានការដេកលក់ជាទីត្រេកអរ មិនត្រេកអរក្នុងការដេកលក់ មិនប្រកបរឿយៗ នូវការដេកលក់ជាទីត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ នេះឯង រមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់សេក្ខភិក្ខុ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ភិក្ខុអ្នកមានការងារជាទីត្រេកអរផង ត្រេកអរក្នុងតិរច្ឆាន-
កថាផង មានការដេកលក់ជាទីត្រេកអរផង មានចិត្ត
រវើរវាយប្រាកដដូច្នោះ មិនគួរដើម្បីបានសម្ពោធិដ៏ប្រសើរ
ឡើយ ។ ព្រោះហេតុនោះ ភិក្ខុនោះ គួរជាអ្នកមាន
កិច្ចការតិច មានការដេកលក់តិច មានចិត្តមិនរវើរវាយ
ប្រាកដដូច្នោះ ទើបគួរនឹងបានសម្ពោធិដ៏ប្រសើរ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

**តតិយវគ្គ ចប់**

### ឧទ្ទាននៃតតិយវគ្គនោះ គឺ

*និយាយអំពីទិដ្ឋិ ២ លើក និស្សរណីយធាតុ ១ រូបជ្ឈាន និងអរូបជ្ឈាន ១ បុត្ត ១ បុគ្គលប្រៀបដោយមេឃ មិនបង្អុរភ្លៀង ១ សេចក្តីសុខ ១ ការបែកធ្លាយ ១ ធាតុ ១ សេចក្តីសាបសូន្យ ១ រួមទាំងអស់ ត្រូវជា ១០ ។*

## អដ្ឋកថា

## បរិហានសូត្រ

*ក្នុងបរិហានសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

[ *៧៩* ] *បទថា* **បរិហានាយ សំវត្តន្តិ** *សេចក្តីថា រមែងមានដើម្បីការមិនចម្រើន គឺមានដើម្បីជាអន្តរាយចំពោះការសម្រេចមគ្គ ។ ឈ្មោះថា មគ្គដែលបានសម្រេចហើយ វិនាសទៅវិញ មិនមាន ។ ព្រះមានព្រះភាគកាលទ្រង់ចែកធម៌ដែលទ្រង់លើកឡើងសម្តែង ដោយអំណាចនៃធម្មាធិដ្ឋានថា ធម៌ ៣ យ៉ាងដូច្នេះ ដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ សេក្ខភិក្ខុក្នុងសាសនានេះ ដូច្នេះ ។*

*ក្នុង ៣ យ៉ាងនោះ ភិក្ខុ ឈ្មោះថា* **កម្មារាមោ** *ព្រោះមានការងារជាទីមកត្រេកអរ ព្រោះត្រូវត្រេកអរនឹងការងារ ។ ឈ្មោះថា* **កម្មរតោ** *ព្រោះត្រេកអរហើយក្នុងការងារ ។ ឈ្មោះថា* **កម្មារាមតមនុយុត្តោ** *ព្រោះប្រកបរឿយៗ គឺខ្វល់ខ្វាយត្រេកអរក្រៃលែងក្នុងការងារ គឺត្រេកត្រអាលក្នុង*

ការងារ ការងារដែលត្រូវធ្វើយ៉ាងនេះ ឈ្មោះថា ការងារ ក្នុងបទថា **កម្មា-រាមោ** នោះ ដូចជាការធ្វើឧបករណ៍ មានការពិនិត្យចីវរ ការធ្វើចីវរ ការជួសជុលស្លាកបាត្រ ខ្សែឃោគ វត្តពន្ធចង្កេះ ធម្មក្រក ជើងបាត្រ អំបែងរងជើង ការបោសសម្អាត និងការជួសជុលទីដែលទ្រុឌទ្រោម និងទីដែលបែកបាក់ក្នុងវិហារជាដើម ពិតហើយ ភិក្ខុរបខ្ញុះ ធ្វើវត្តទាំងនេះ រមែងធ្វើវត្តទាំងនោះឯង ពេញៗ មួយថ្ងៃ ។ បទថា **កម្មារាមោ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកការងារនោះ ឯភិក្ខុណា ក្នុងកាលធ្វើការងារនេះប៉ុណ្ណោះ ទើបធ្វើការងារទាំងនេះ ក្នុងពេលរៀនឧទ្ទេស ក៏រៀនឧទ្ទេស ក្នុងវេលាស្វាធ្យាយ ក៏ស្វាធ្យាយ ក្នុងគ្រាធ្វើវត្ត មានការបោសសម្អាតលានព្រះចេតិយជាដើម ក៏ធ្វើវត្ត ក្នុងកាលធ្វើមនសិការ ក៏ធ្វើមនសិការ ក្នុងសព្វត្ថកម្មដ្ឋាន ឬក្នុងបារិហារិយកម្មដ្ឋាន ភិក្ខុនោះ ឈ្មោះថា ជាអ្នកមានការងារមកមិនជាទីត្រេកអរ គឺមិនអំពល់ក្នុងការងារ ការងាររបស់ភិក្ខុនោះ ធ្វើតែការងារដែលព្រះសាស្តាទ្រង់អនុញ្ញាតតែប៉ុណ្ណោះ ដោយន័យក្នុងអង្គុត្តរនិកាយ ទសនិបាតថា

> ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើណាដ៏ខ្ពស់ និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវស្ងួរគ្នីគ្នាហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូសក្នុងអំពើនោះ ប្រកបដោយប្រាជ្ញា ជាគ្រឿងពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើ គួរចាត់ចែងបាន ដូច្នេះ ។

បទថា **ភស្សារាមោ** សេចក្តីថា ភិក្ខុណាញុំាងថ្ងៃ និងយប់ឲ្យកន្លងទៅដោយអំណាចនៃការពោលដល់រាជកថាជាដើម ដែលព្រះមានព្រះភាគត្រាស់ហាមហើយ ភិក្ខុនេះ ជាអ្នកនិយាយមិនចេះចប់ ព្រោះដូច្នោះ ទើបភិក្ខុនេះ ឈ្មោះថា **ភស្សារាមោ** គឺត្រេកអរក្នុងការនិយាយ ។ ឯភិក្ខុណាពោលធម៌ វិសជ្ជនាបញ្ហា ពេលយប់ខ្លះ ថ្ងៃខ្លះ ភិក្ខុនេះ ឈ្មោះថា ជាអ្នកនិយាយតិច ជាអ្នកពោលមានទីបំផុត ព្រោះហេតុអ្វី ព្រោះថា លោកប្រព្រឹត្តតាមវិធីដែលព្រះមានព្រះភាគត្រាស់ហើយក្នុងបាសរាសិសូត្រថា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀម នៅដ៏ប្រសើរ ១ ដូច្នេះ ។

បទថា **និទ្ទារាមោ** សេចក្តីថា ភិក្ខុណាធាន់ទាល់តែពេញពោះតាមត្រូវការ ប្រកបរឿយៗ នូវសេចក្តីសុខក្នុងការដេក សុខក្នុងការមើតពត់ សុខក្នុងការលក់ ។ ភិក្ខុណាដើរក្តី អង្គុយក្តី ត្រូវថីនមិទ្ធៈគ្របសង្កត់ ហើយដេកលក់ ភិក្ខុនេះ ឈ្មោះថា **និទ្ទារាមោ** គឺត្រេកអរក្នុងការដេកលក់ ។ ឯភិក្ខុណា មានចិត្តឈមចុះកាន់ភវង្គ ព្រោះអាពាធរបស់ករជកាយ ភិក្ខុនេះ មិនឈ្មោះថា **និទ្ទារាមោ** ឡើយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងមហាសច្ចកសូត្រថា

ម្នាលអគ្គិវេស្សនៈ តថាគតត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដិ មានជាន់ ៤ ហើយផ្ទាប់សិង

*ដោយចំហៀងខាងស្តាំ មានសតិ និងសម្បជញ្ញៈ ចុះសិបកាន់កិរិយាលក់ ក្នុងវេលាទីបំផុត នៃគិម្ហៈរដូវ ដូច្នេះ ។*

*ក្នុងព្រះសូត្រនេះ សូម្បីកល្យាណបុថុជ្ជន ក៏គប្បីជ្រាបថា ជាព្រះសេក្ខៈដូចគ្នា ព្រោះដូច្នោះ គប្បីជ្រាបថា ធម៌ ៣ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីសាបសូន្យនូវការសម្រេចគុណវិសេស នៃកល្យាណបុថុជ្ជនទាំងអស់នោះ និងការសម្រេចគុណវិសេសខ្ពស់ឡើងនៃព្រះសេក្ខៈក្រៅអំពីនេះ ។ គប្បីជ្រាបការពង្រីកសេចក្តីនៃធម៌ចំណែក-សតាមបរិយាយដែលផ្ទុយគ្នា តាមដែលពោលហើយ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា* **ឧទ្ធតោ** *សេចក្តីថា គឺមិនស្ងប់ ព្រោះឧទ្ធច្ចៈដែលធ្វើឲ្យចិត្តរាយមាយ ។ បទថា* **អប្ប-កិច្ចស្ស** *សេចក្តីថា គប្បីជាអ្នកមានកិច្ចតិច ព្រោះធ្វើក្នុងពេលដែលខ្វល់ខ្វាយប្រកបកិច្ច មានប្រការដូចពោលហើយ តាមដែលទ្រង់អនុញ្ញាត ។ បទថា* **អប្បមិទ្ធោ** *សេចក្តីថា គប្បីជាអ្នកវៀរចាកការដេកលក់ ដោយអំណាចជាគរិយានុយោគ ដែលត្រាស់ដោយន័យជាដើមថា ដោយការចង្ក្រម ដោយការអង្គុយអស់ថ្ងៃ ។ បទថា* **អនុទ្ធតោ** *សេចក្តីថា ជាបុគ្គលមិនមានការពោលដែលជាទីមកត្រេកអរ ឈ្មោះថា ជាអ្នកមិនរាយមាយ គឺមានចិត្តស្ងប់ អធិប្បាយថា មានចិត្តជាសមាធិ ព្រោះវៀរនូវការរាយមាយនៃចិត្តដែលកើតឡើង ព្រោះជាអ្នកមានការជជែក ជាទីមកត្រេកអរ ។ ពាក្យដ៏សេស មាន*

អត្ថនាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចច្បាប់ពោលហើយ ក្នុងកាលមុន ។

ដោយប្រការដូចពណ៌នាមកនេះ ព្រះមានព្រះភាគត្រាស់វដ្តៈក្នុងព្រះសូត្រទី ១ ទី ២ ទី ៤ ទី ៥ ទី ៦ ទី ៧ ទី ៨ និងទី ៩ ក្នុងវគ្គនេះហើយ ។ ក្នុងវគ្គក្រៅអំពីនេះ ត្រាស់វដ្តៈផង វិវដ្តៈផង ៕

**អដ្ឋកថា បរិហានសូត្រទី ១០ ចប់**

**វគ្គទី ៣ ចប់**

# សុត្តន្តបិដក

## ឥតិវុត្តក តិកនិបាត ចតុត្ថវគ្គ

### វិតក្កសូត្រ

[ ៨០ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កនេះមាន ៣ ។ អកុសលវិតក្ក ៣ តើដូចម្តេចខ្លះ ។ គឺវិតក្កដែលប្រកបដោយសេចក្តីប្រាថ្នា មិនឲ្យអ្នកដទៃមើលងាយខ្លួន ១ វិតក្កដែលប្រកបដោយលាភសក្ការៈ និង សេចក្តីសរសើរ ១ វិតក្កដែលប្រកបដោយសេចក្តីអាណិតបុគ្គលដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្ក មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

បុគ្គលណាមួយ ប្រកបដោយសេចក្តីប្រាថ្នា មិនឲ្យអ្នក
ដទៃមើលងាយខ្លួន ជាអ្នកធ្ងន់ក្នុងលាភ និងសក្ការៈ
មានសេចក្តីរីករាយ ជាមួយនឹងពួកអមាត្យ បុគ្គលនោះ
ឈ្មោះថា ឆ្ងាយអំពីការអស់ទៅនៃសំយោជនៈ ។ បុគ្គល
ណាមួយ ក្នុងលោកនេះ លះបង់បុត្ត និងករិយាផង
លះបង់សត្វចិញ្ចឹមផង លះបង់សេចក្តីសង្គ្រោះក្នុងវិវាហៈ
ផង ភិក្ខុប្រាកដដូច្នោះនោះ គួរដើម្បីបាននូវសម្ពោធិដ៏
ឧត្តម ។ សូត្រទី ១ ។

# អដ្ឋកថា

# វគ្គទី ៤

# វិតក្កសូត្រ

ក្នុងវិតក្កសូត្រទី ១ នៃវគ្គទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨០ ] បទថា **អកុសលា វិតក្កា** សេចក្តីថា វិតក្កទាំងឡាយដែលកើតចាកភាពជាអ្នកមិនឈ្លាស អធិប្បាយថា បានដល់ មិច្ឆាវិតក្ក ។ បទថា **អនវញ្ញត្តិ** ក្នុងបទថា **អនវញ្ញត្តិប្បដិសំយុត្តោ** នេះ បានដល់ ការមិនត្រូវមើលងាយ ព្រោះភាពដែលខ្លួនមិនត្រូវអ្នកដទៃមើលងាយ គឺតិះដៀលមិនបាន មានឥច្ឆាចារដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា ធ្វើម្តេចហ្ន៎ អ្នកដទៃមិនគប្បីមើលងាយអញ ដូច្នេះ ដែលប្រកប គឺទាក់ទងដោយការមិនត្រូវមើលងាយនោះ ឬវិតក្កដែលបដិសំយុត្តដោយការមិនត្រូវមើលងាយ ដែលប្រារព្ធឥច្ឆាចារនោះ ប្រព្រឹត្តទៅហើយ ព្រោះដូច្នោះ ពាក្យថា **អនវញ្ញត្តិ** នេះ ជាឈ្មោះនៃវិតក្កដែលតាំងនៅក្នុងឥច្ឆាចារ ឲ្យប្រព្រឹត្តទៅហើយ ព្រោះត្រូវការលើកតម្កើងថា ធ្វើម្តេចហ្ន៎ អ្នកដទៃ ទាំងគ្រហស្ថ និងបព្វជិត មិនគប្បីតិះដៀលអញឲ្យថោកទាប ។ បទថា **លាភសក្ការសិលោកប្បដិសំយុត្តោ** សេចក្តីថា វិតក្កដែលប្រកបដោយលាភ មានចីវរជាដើម សក្ការៈ និងកិត្តិសព្ទ ដោយធ្វើឲ្យជាអារម្មណ៍ ។ បទថា **បរានុទ្ទយតាបដិសំយុត្តោ** សេចក្តីថា ប្រកបដោយសេចក្តីស្រឡាញ់ដែលជាម្ចាស់ផ្ទះ ដែលជាការអាណិតអាសូរប្រៀបផ្ទឹមក្នុងអ្នកដទៃ ដែលព្រះមានព្រះភាគត្រាស់សំដៅយកថា

ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ នៅច្រឡូកច្រឡំដោយពួកស្តេច ដោយពួកមហាមាត្យរបស់ស្តេច ដោយពួកព្រាហ្មណ៍ ដោយពួកគហបតី ដោយពួកតិរ្ថិយ ដោយពួកសាវ័ករបស់តិរ្ថិយ ដោយពួកគ្រហស្ថ មានសេចក្តីរីករាយជាមួយគ្នា មានសេចក្តីសោយសោកជាមួយគ្នា កាលបើពួកគ្រហស្ថបានសុខ ក៏បានសេចក្តីសុខ កាលបើពួកគ្រហស្ថបានទុក្ខ ក៏បានសេចក្តីទុក្ខ កាលបើកិច្ចដែលត្រូវធ្វើកើតឡើង ក៏ខំប្រឹងប្រែងធ្វើដោយខ្លួនឯង ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បុគ្គលដែលប្រកបដោយការប្រាថ្នាមិនឲ្យអ្នកដទៃមើលងាយ ឈ្មោះថា **អនវញ្ញត្តិសំយុត្តោ** ។ បុគ្គលឈ្មោះថា **លាភសក្ការគារវោ** ព្រោះមានសេចក្តីធ្ងន់ក្នុងលាភសក្ការៈ មិនមែនក្នុងធម៌ ។ បុគ្គលឈ្មោះថា **អមាត្យ** ព្រោះជាអ្នកជិតស្និទ្ធ គឺរួមសុខរួមទុក្ខគ្នា បានដល់ ដែលឧបត្ថម្ភដូចគ្នានឹងសម្លាញ់ បុគ្គលដែលមានប្រក្រតីត្រេកអរជាមួយអមាត្យទាំងនោះ ដោយអំណាចសេចក្តីស្រឡាញ់ដែលជាម្ចាស់ផ្ទះ ឈ្មោះថា ជាអ្នកមានសេចក្តីរីករាយជាមួយនឹងពួកអមាត្យ ។ បទថា **សហានន្ទី អមច្ចេហិ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់វិតក្កដែលប្រកបដោយការអាណិតអាសូរអ្នកដទៃ ។ បទថា **អារា សំយោជនក្ខយា** សេចក្តីថា បុគ្គលត្រូវវិតក្កទាំង ៣ នេះគ្របសង្កត់ រមែងជាអ្នកឆ្ងាយចាកការអស់ទៅនៃសំយោជនៈ គឺអរហត្ត អធិប្បាយថា អរហត្តនោះ ជារបស់រកបានលំបាកសម្រាប់បុគ្គលនោះ ។ បទថា **បុត្តបសុំ** បានដល់ បុត្រផង សត្វចិញ្ចឹម

ផង ។ ដោយ **បុត្ត** សព្ទ ក្នុងបទថា **បុត្តបសុំ** នេះ ទ្រង់សង្គ្រោះយកកិរិយាជាដើមផង ។ ដោយ **បសុ** សព្ទ ទ្រង់សង្គ្រោះយកសេះ ក្របី ស្រែ និងចម្ការជាដើមចូលផង ។ បទថា **វិវាហោ** សេចក្តីថា ក្នុងការឲ្យធ្វើវិវាហ-មង្គល ។ បទថា **វិវាហោ** នេះ ទ្រង់សង្គ្រោះយកអាវាហមង្គលចូលផង ។ បទថា **សន្ថវានិ** បានដល់ ការគ្រប់គ្រង អធិប្បាយថា គួរដល់ការរវាំងប្រយ័ត្ន ។ តែអាចារ្យទាំងឡាយពោលថា បានដល់ ការស្និទ្ធស្នាល អធិប្បាយថា ស្និទ្ធស្នាលជាមិត្រ ភ្ជាប់សេចក្តីថា លះបោលទាំងអស់ ។ បទថា **ភព្ពោ សោ តាទិសោ ភិក្ខុ** សេចក្តីថា បុគ្គលនោះ ឈ្មោះថា ជាបុគ្គលបែបនោះ ព្រោះលះនូវធម៌ជាគ្រឿងយឹតយូរគ្រប់យ៉ាង តាមដែលត្រាស់ហើយ គប្បីឃើញសម្មាបដិបត្តិដែលព្រះសាស្តាត្រាស់ដោយប្រការនោះ ឈ្មោះថា ជាភិក្ខុ ព្រោះឃើញភ័យក្នុងសង្សារ រមែងគួរសម្រេចសម្ពោធិញាណដ៏ឧត្តម គឺអរហត្ត ។៤៤៕

**អដ្ឋកថា វិតក្កសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សក្ការសូត្រ

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលត្រូវសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលអសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វដែលសក្ការៈ និងអសក្ការៈ ទាំងពីរយ៉ាងនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឮសេចក្ដីនោះ ( អំពីសម្នាក់ ) នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយពោលទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វដែលអសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលសក្ការៈ និងអសក្ការៈទាំងពីរយ៉ាងនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតហើយ ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុ

ទាំងឡាយ លុះតែហេតុណា ដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង ជ្រាបច្បាស់ខ្លួនឯង ពិតមែន ទើបតថាគតពោលនូវហេតុនោះថា ម្នាលភិក្ខុទាំង-ឡាយ តថាគតបានឃើញពួកសត្វដែលសក្ការៈ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលអសក្ការៈ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកសត្វ ដែលសក្ការៈ និងអសក្ការៈ ទាំងពីរនោះ គ្របសង្កត់ហើយ រួបរឹតចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

បុគ្គលណា ដែលគេធ្វើសក្ការៈ និងអសក្ការៈទាំងពីរ
យ៉ាង ជាអ្នកនៅដោយសេចក្តីមិនប្រមាទ មានសមាធិ
មិនញាប់ញ័រ អ្នកប្រាជ្ញតែងហៅបុគ្គលអ្នកមានឈាន
មានព្យាយាមជាប់មិនដាច់ បានឃើញច្បាស់ ដោយ
ទិដ្ឋិដ៏ល្អិត មានសេចក្តីត្រេកអរ ក្នុងការអស់ទៅ នៃ
ឧបាទាននោះ ថាជាសប្បុរស ។ សូត្រទី ២ ។

# អដ្ឋកថា

## សក្ការសូត្រ

ក្នុងសក្ការសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨១ ] បទថា **សក្ការេន** សេចក្ដីថា ត្រូវសក្ការៈដែលជាហេតុ ។ ម្យ៉ាងទៀត បទថា **សក្ការេន** នេះ សេចក្ដីថា ត្រូវហេតុ ឬសក្ការៈ ឬត្រូវអកុសលធម៌ មានសក្ការៈជាហេតុ ( គ្របសង្កត់ ) អធិប្បាយថា ព្រោះអាស្រ័យសក្ការៈ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្ដីប្រាថ្នាលាមក ត្រូវចំណង់គ្របសង្កត់ តាំងនៅក្នុងឥច្ឆាចារ គិតថា អញនឹងឲ្យសក្ការៈកើតឡើង ហើយប្រព្រឹត្តស្វែងរកដែលមិនសមគួរច្រើនយ៉ាង ចុតិអំពីលោកនេះហើយ ទើបកើតក្នុងអបាយ ។ ឯបុគ្គលដទៃបានសក្ការៈណាហើយ ដល់នូវសេចក្ដីប្រមាទ ដែលមានសក្ការៈយ៉ាងនោះជានិមិត្ត ដោយអំណាចនៃមានះ មទៈ និងមច្ឆរិយៈជាដើម ចុតិអំពីលោកនេះហើយ កើតក្នុងអបាយទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់សំដៅយកថា ដែលត្រូវសក្ការៈគ្របសង្កត់ហើយ រួបរឹតចិត្តហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិភូតា** សេចក្ដីថា ត្រូវសក្ការៈ គ្របសង្កត់ហើយ ។ បទថា **បរិយាទិន្នចិត្តា** សេចក្ដីថា មានចិត្តដែលសក្ការៈញាំញីទៅហើយ គឺជាបុគ្គលមានកុសលចិត្ត ត្រូវឥច្ឆាចារ និងអកុសល មានមានះ និងមទៈជាដើមឲ្យដល់នូវការអស់ទៅ ។ ម្យ៉ាងទៀត បទថា **បរិយា-ទិន្នចិត្តា** នេះ សេចក្ដីថា មានចិត្តដែលសក្ការៈទាញដោយជុំទិស អធិប្បាយ

ថា ជាអ្នកមានចិត្តសន្តានត្រូវចំណែកនៃអកុសលធម៌ មានប្រការដូចពោល ហើយ ទាញហើយដោយជុំវិញ ដោយមិនមានវារៈនៃកុសលចិត្តកើតឡើង ។ បទថា **អសក្ការេន** សេចក្ដីថា ដែលហេតុ គឺអសក្ការៈដែលអ្នកដទៃឲ្យប្រព្រឹត្ត ទៅហើយក្នុងខ្លួន ដោយបំណងឲ្យខ្មាស ដោយការចំអក ឬត្រូវអកុសលធម៌ មានមានះជាដើម ដែលមានសក្ការៈជាហេតុគ្របសង្កត់ហើយ ។ បទថា **សក្ការេន ច អសក្ការេន ច** សេចក្ដីថា ត្រូវសក្ការៈដែលបុគ្គលណាម្នាក់ ឲ្យប្រព្រឹត្តទៅហើយផង អសក្ការៈ ដែលបុគ្គលណាម្នាក់ឲ្យប្រព្រឹត្តទៅហើយ ផង អធិប្បាយថា ព្រះមានព្រះភាគទ្រង់សំដៅយកបុគ្គលបែបនោះ ខាងដើម ជនពួកណាធ្វើសក្ការៈហើយ ក្រោយមក ជនទាំងនោះ មិនធ្វើសក្ការៈ ព្រោះ ដឹងថា មិនមានសារធម៌ ទើបត្រាស់ថា **សក្ការេន ច អសក្ការេន ច** ដូច្នេះ ។

ក្នុងរឿងដែលគួរនាំមក គួរនាំរឿងទេវទត្តជាដើម ដែលត្រូវសក្ការៈគ្រប សង្កត់មកសម្ដែងជាគំរូ ។

សមដូចព្រះមានព្រះភាគត្រាស់ក្នុងសង្ឃភេទខន្ធកៈថា

ផ្លែចេកតែងសម្លាប់ដើមចេក ផ្លែឫស្សីតែងសម្លាប់ដើមឫស្សី ផ្លែ បបុសតែងសម្លាប់ដើមបបុស សក្ការៈតែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌ តែងសម្លាប់មេសេះអស្សតរ ដូច្នេះ ។

គួរនាំរឿងព្រះបាទទណ្ឌកីព្រះរាជាដែនកាលិង្គ និងព្រះបាទមេជ្ឈៈជាដើម ត្រូវអសក្ការៈដែលទ្រង់ធ្វើចំពោះមនុស្សល្អគ្របសង្កត់ហើយ មកសម្ដែងជា គំរូ ។ សមដូចសង្កិច្ចឥសីពោលថា

ព្រះរាជាទណ្ឌកីបានបាចរោយធូលី ( ស្មោះ ) លើតាបសឈ្មោះ
កីសវច្ឆៈ មិនមានធូលី ( កិលេស ) ព្រះរាជានោះក៏ដល់នូវ
សេចក្ដីវិនាស ដូចជាដើមត្នោត ដែលគេកាត់ត្រង់គល់ ។

ព្រះបាទនាលិកីរៈណា បានបៀតបៀន បព្វជិតទាំងឡាយ ជាអ្នក
សង្រួម ជាអ្នករម្ងាប់បាប មិនប្រទូស្ត កំពុងសម្ដែងធម៌ ឆ្កែ
ទាំងឡាយចោមខាំស៊ីនូវព្រះបាទនាលិកីរៈនោះ ឲ្យអន្ទះអន្ទែងក្នុង
បរលោក ។

ព្រះរាជាព្រះនាមមេជ្ឈៈ ព្រមទាំងបរិស័ទ ញុំាងចិត្តឲ្យប្រទូស្ត
ក្នុងតាបសឈ្មោះមាតង្គបណ្ឌិត មានយសហើយ ក៏ដល់នូវ
សេចក្ដីវិនាស ក្នុងកាលនោះដែនឈ្មោះមេជ្ឈៈ ក៏ទៅជាព្រៃ
ដូច្នេះ ។

តិរិយទាំងឡាយ មាននិគ្គណ្ឋនាដបុត្រជាដើម ដែលត្រូវសក្ការៈផង
អសក្ការៈផងគ្របសង្កត់ ក៏គួរនាំមកសម្ដែងផងដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **ឧភយំ** បាន
ដល់ សក្ការៈផង និងអសក្ការៈផង ទាំង ២ យ៉ាង ។ បទថា **សមាធិ ន
វិកម្បតិ** សេចក្ដីថា សមាធិរមែងមិនញាប់ញ័រ គឺមានសភាពជាឯកនោះឯង
តាំងនៅ ។ ព្រះមានព្រះភាគត្រាស់ថា ជាអ្នកមានប្រក្រតីនៅដោយសេចក្ដី
មិនប្រមាទថា សមាធិរបស់បុគ្គលណាមិនកម្រើក អធិប្បាយថា របស់បុគ្គល
ឈ្មោះថា ជាអ្នកមានប្រក្រតីជាអ្នកនៅដោយការមិនប្រមាទ គឺជាព្រះអរហន្ត

ព្រោះលះនូវធម៌ ដែលជាហេតុនៃសេចក្ដីប្រមាទ មានរាគៈជាដើមបានដោយល្អ ព្រោះថា លោកមិនញាប់ញ័រ ព្រោះលោកធម៌ទាំងឡាយ ។ បទថា **សុខុមទិដ្ឋិវិបស្សកំ** សេចក្ដីថា បុគ្គលឈ្មោះថា ឃើញច្បាស់នូវទិដ្ឋិដ៏សុខុម ព្រោះមានការឃើញច្បាស់ ប្រព្រឹត្តទៅហើយរឿយៗ ដោយទិដ្ឋិ គឺបញ្ញាដ៏សុខុម ព្រោះបានសម្រេចផលសមាបត្តិ ។ បទថា **ឧបាទានក្ខយារាមំ** សេចក្ដីថា បុគ្គលឈ្មោះថា ជាអ្នកអស់ឧបាទានជាទីមកត្រេកអរ ព្រោះមានអរហត្តផលដែលជាទីអស់ទៅ គឺជាទីបំផុតនៃឧបាទានទាំង ៤ ដែលខ្លួនគប្បីត្រេកអរ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា សក្ការសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ទេវសទ្ទសូត្រ

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ សំឡេងទេវតា ៣ យ៉ាងនេះ តែងលាន់ឮ ក្នុងទេវលោក ព្រោះអាស្រ័យសម័យនោះៗ ។ សំឡេង ៣ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកគិតដើម្បីកោរសក់ ពុកចង្កា ស្លៀកសំពត់កាសាយៈទាំងឡាយ ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតា ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវកនុ៎ះ គិតដើម្បីច្បាំងនឹងកិលេស-

មារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសំឡេងទេវតាទី ១ ក្នុងទេវលោកទាំង-ឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យណា អរិយសាវកប្រកបរឿយៗ នូវព្យាយាម ដើម្បីចម្រើន នូវពោធិបក្ខិយធម៌ ៧ ពួក ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតា ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវកនុ៎ះ កំពុងច្បាំង នឹងកិលេសមារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសំឡេងទេវតាទី ២ ក្នុងទេវលោក ទាំងឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។ ម្នាលភិក្ខុទាំង-ឡាយ មួយវិញទៀត សម័យណា អរិយសាវកធ្វើឲ្យជាក់ច្បាស់ សម្រេច នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេច សម្រាន្តនៅ ម្នាលភិក្ខុទាំងឡាយ សម័យនោះ សំឡេងទេវតាក្នុងទេវលោក ទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវកនុ៎ះ ឈ្នះសង្គ្រាមហើយ ឈ្នះ រាប គ្របសង្កត់នូវកំពូលនៃសង្គ្រាមនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជា សំឡេងទេវតាទី ៣ ក្នុងទេវលោកទាំងឡាយតែងលាន់ឮឡើង ព្រោះអាស្រ័យ សម័យនោះៗ ។ ម្នាលភិក្ខុទាំងឡាយ សំឡេងនៃទេវតា ក្នុងទេវលោកទាំង-ឡាយ មាន ៣ យ៉ាងនេះឯង តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។

ពួកទេវតា បានឃើញសាវកនៃព្រះសម្មាសម្ពុទ្ធ ដែល
ឈ្នះសង្គ្រាមហើយ លោកមានគុណដ៏ធំ ប្រាសចាក
សេចក្តីកោតញញើត ទើបនមស្ការថា បពិត្របុរស

អាជានេយ្យ អ្នកណា បានបង្ក្រាបសង្គ្រាម ដែលគេ ឈ្នះបានដោយកម្រ បានឈ្នះសេនានៃមច្ចុ ដែលបុគ្គល ដទៃ មិនអាចឃាត់ខាំងបានដោយវិមោក្ខ ខ្ញុំសូមនមស្ការ អ្នកនោះ ព្រោះហេតុនោះ ពួកទេវតា តែងនមស្ការនូវ សាវក នៃព្រះសម្មាសម្ពុទ្ធនុ៎ះ ដែលមានសេចក្តីប្រាថ្នា សម្រេចហើយ សាវកនៃព្រះសម្មាសម្ពុទ្ធ គប្បីដល់នូវ អំណាចនៃមច្ចុទៀត ដោយហេតុណា ពួកទេវតាមិន ឃើញហេតុនោះ របស់សាវកនៃព្រះសម្មាសម្ពុទ្ធនោះ ឡើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## ទេវសទ្ទសូត្រ

ក្នុងទេវសទ្ទសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨២ ] បទថា **ទេវេសុ** សេចក្តីថា វៀរទេវតាដែលជាអរូបាវចរ និងទេវតាដែលជាអសញ្ញីទាំងឡាយ ក្នុងឧបបត្តិទេពដទៃអំពីនោះ ។ បទថា **ទេវសទ្ទា** បានដល់ សំឡេងដែលកើតឡើងអំពីបីតិរបស់ទេវតាទាំងឡាយ ។ បទថា **និច្ឆរន្តិ** បានដល់ បន្លឺចេញដោយអំណាចនៃការសន្ទនាប្រាស្រ័យគ្នា ។ បទថា **សមយា សមយំ ឧបាទាយ** សេចក្តីថា អាស្រ័យសម័យដ៏សមគួរ

មានអធិប្បាយថា ទេវតាទាំងឡាយតាំងនៅក្នុងកាលណា អាស្រ័យកាលនោះ ឃើញអរិយសាវកនោះ ។ បន្ទាប់អំពីនោះ អាស្រ័យសម័យ គឺពេលដែលជួបនោះ ។ ចំណែកអាចារ្យពួកខ្លះពោលថា សំដៅយកគ្រប់សម័យ អធិប្បាយថា អាស្រ័យសម័យនោះៗ នៃលោកទាំងនោះ ។

បទថា **យស្មិំ សមយេ** សេចក្តីថា ក្នុងសម័យដែលព្រះអរិយសាវក ឃើញទោសក្នុងកាមទាំងឡាយ ដោយន័យជាដើមថា **អដ្ឋិកង្កលូបមា កាមា** កាមទាំងឡាយឧបមាដោយរាងឆ្អឹង និងដោយការគ្រប់គ្រងផ្ទះ ដោយន័យជាដើមថា **សម្ពាធោ ឃរាវាសោ** ការនៅគ្រប់គ្រងផ្ទះចង្អៀតចង្អល់យ៉ាងក្រៃលែង និងឃើញអានិសង្សក្នុងការចេញបួស ដោយន័យដែលផ្ទុយគ្នា ក្នុងការនៅគ្រប់គ្រងផ្ទះនោះយ៉ាងល្អ ។ ព្រោះថា កាលនោះឯង ចិត្តរបស់អរិយ-សាវកនោះ នឹងបង្អោនទៅក្នុងបព្វជ្ជាតែម្យ៉ាង ។ បទថា **អរិយសាវកោ** បានដល់ សាវករបស់លោកអ្នកដ៏ប្រសើរ គឺព្រះមានព្រះភាគសម្មាសម្ពុទ្ធ គឺអរិយសាវកដែលបំណងនឹងចូលដល់ភាពជាសាវក ឬជាអរិយសាវកដោយពិត ពាក្យប្រារព្ធនេះ ទេវតាពោលសំដៅយកសាវក និងព្រះពោធិសត្វដែលមានភពចុងក្រោយ ។ បទថា **កេសមស្សុំ ឱហារេត្វា** សេចក្តីថា កោរសក់និងពុកមាត់ គឺនាំចេញទៅ ។ បទថា **កាសាយានិ វត្ថានិ អច្ឆាទេត្វា** សេចក្តីថា ស្លៀកដណ្តប់សំពត់ដ៏សមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ឈ្មោះថា **កាសាយ** ព្រោះជ្រលក់ដោយទឹកម្ចត់ ។ បទថា **អគារស្មា អនគារិយំ បព្វជ្ជាយ ចេតេតិ** សេចក្តីថា តាំងចិត្តបួសថា អញចេញចាកអាគារ គឺផ្ទះ

បួសជាបព្វជិត ជាអ្នកមិនមានផ្ទះ អធិប្បាយថា នឹងបួស ព្រោះហេតុដែល កសិកម្ម និងពាណិជកម្មជាដើម ដែលជាប្រយោជន៍ ដល់ការគ្រប់គ្រងផ្ទះ លោកហៅថា **អគារិយ** ។ កសិកម្ម និងពាណិជកម្មនោះ មិនមានក្នុងបព្វជ្ជា ដូច្នោះ បព្វជ្ជា គប្បីជ្រាបថា ជា **អនាគារិយ** ក្នុងពាក្យថា **អគារស្មា អនគារិយំ បព្វជ្ជាយ ចេតេតិ** នេះ ។ បទថា **មារេន** បានដល់ កិលេស-មារ ។ បទថា **សង្គាមាយ ចេតេតិ** សេចក្តីថា ញុំាងគំនិតឲ្យកើតឡើង ដើម្បីច្បាំង គឺត្រៀមនូវការយកជ័យជម្នះមារ ព្រោះទេវបុត្តមារ តែងព្យាយាម ធ្វើអន្តរាយដល់បុគ្គលដែលបដិបត្តិបែបនោះ ដូច្នោះ គប្បីជ្រាបអធិប្បាយក្នុង បទថា **មារ** បានដល់ ទេវបុត្តមារក៏មាន សូម្បីទេវបុត្តមារនេះ ក៏ធ្វើការជំទាស់ នូវសេចក្តីប្រាថ្នារបស់អ្នកបដិបត្តិនោះដូចគ្នា ។ ផ្តើមតាំងអំពីថ្ងៃបព្វជ្ជា គោរ សក់ហើយ លោកសមាទានសីល រក្សាសីលឲ្យបរិសុទ្ធ បំពេញកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន ឈ្មោះថា រាំងនូវកិលេសមារ ដោយអំណាចនៃតទង្គ-ប្បហាន និងវិក្ខម្ភនប្បហានតាមសមគួរ មិនឈ្មោះថា ច្បាំង ព្រោះមិនមាន ការប្ញូន់ស្រុក ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា គិតដើម្បីច្បាំងនឹង កិលេសមារ ដូច្នេះ ។

បទថា **សត្តន្នំ** សេចក្តីថា ដោយពួក ៧ តែដោយបទ ( ប្រភេទ ) ពោធិបក្ខិយធម៌នោះមាន ៣៧ ប្រការ ។ ពោធិបក្ខិយធម៌នោះ ៣៧ ប្រការ ដូចម្តេច គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ដូច្នេះ ។ ពោលដោយប្រភេទមាន ៣៧

*ដោយកោដ្ឋាស គឺពួក មាន ៧ មានសតិប្បដ្ឋានជាដើម ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា* **សត្តន្នំ** *ដូច្នេះ ។ បទថា* **ពោធិបក្ខិយានំ** *សេចក្តីថា នៃពោធិបក្ខិយធម៌ដែលជាចំណែករបស់អរិយបុគ្គល ឬមគ្គញ្ញាណនោះឯង ដែលបានឈ្មោះថា* **ពោធិ** *ព្រោះអត្ថថា ជាហេតុត្រាស់ដឹង អធិប្បាយថា បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកនៃពោធិញ្ញាណ ។ បាឋៈថា* **ពោធិបក្ខិកានំ** *ដូច្នេះក៏មាន អធិប្បាយថា មានធម៌ដែលជាចំណែកនៃពោធិ ឬប្រកបក្នុងធម៌ដែលជាចំណែកនៃពោធិ ។ បទថា* **ភាវនានុយោគមនុយុត្តោ** *សេចក្តីថា ប្រកបសេចក្តីព្យាយាមរឿយៗ ក្នុងការចម្រើនអរិយមគ្គឲ្យវិបស្សនាផុសឡើង ព្រោះថា ក្នុងខណៈនៃវិបស្សនាញាណ សតិប្បដ្ឋានជាដើម ឈ្មោះថា ជាចំណែកនៃពោធិដោយអម តែក្នុងខណៈនៃមគ្គប៉ុណ្ណោះ សតិប្បដ្ឋានជាដើមនោះ ទើបឈ្មោះថា ជាពោធិបក្ខិយធម៌ដោយត្រង់ ។*

*បទថា* **អាសវានំ ខយា** *សេចក្តីថា ព្រោះអស់អាសវៈទាំងឡាយ មានកាមាសវៈជាដើម អធិប្បាយថា អាសវៈទាំងឡាយ កាលអស់ទៅហើយ កិលេសទាំងអស់ ក៏ឈ្មោះថា អស់ទៅដូចគ្នា ។ ដោយពាក្យថា* **អាសវានំ ខយា** *នោះ ជាការត្រាស់ដល់អរហត្តមគ្គផងដែរ ។ បទថា* **អនាសវំ** *សេចក្តីថា វៀរចាកអាសវៈ ។ ក្នុងបទថា* **ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ** *នេះ ព្រះមានព្រះភាគត្រាស់ដល់សមាធិ ដែលសម្បយុត្តដោយអរហត្តផល ដោយពាក្យថា* **ចេតោ** *ត្រាស់បញ្ញាដែលសម្បយុត្តដោយអរហត្តផលនោះ ដោយពាក្យថា* **បញ្ញា** *។ បណ្តាចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ២ យ៉ាងនោះ* **សមាធិ** *គប្បី*

ជ្រាបថា ឈ្មោះថា **ចេតោវិមុត្តិ** ព្រោះផុតចាករាគៈ **បញ្ញា** គប្បីជ្រាបថា ឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះផុតចាកអវិជ្ជា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះថា សមាធិឯណា របស់អរិយសាវកនោះ សមាធិនោះ ឈ្មោះថា សមាធិន្ទ្រិយរបស់លោក ម្នាលភិក្ខុទាំងឡាយ ព្រោះថា បញ្ញាឯណា របស់អរិយសាវកនោះ បញ្ញានោះ ឈ្មោះថា បញ្ញិន្ទ្រិយរបស់លោក ។ ដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិមាន ព្រោះការប្រាសទៅនៃរាគៈ បញ្ញាវិមុត្តិមាន ព្រោះការប្រាសទៅនៃអវិជ្ជា ។

ម្យ៉ាងទៀត ក្នុងពាក្យថា **ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ** នេះ ផលនៃសមថៈ គប្បីជ្រាបថា ជាចេតោវិមុត្តិ ផលនៃវិបស្សនា គប្បីជ្រាបថា ជាបញ្ញាវិមុត្តិ ។ បទថា **ទិដ្ឋេវ ធម្មេ** សេចក្តីថា ក្នុងអត្តភាពនេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** សេចក្តីថា ធ្វើឲ្យប្រចក្សដោយបញ្ញាដែលពិសេសក្រៃលែង ដោយខ្លួនឯងនោះឯង គឺដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។ បទថា **ឧបសម្បជ្ជ វិហរតិ** សេចក្តីថា ដល់ គឺឲ្យដល់ព្រមហើយ ។ បទថា **តមេវ សង្គាម-សីសំ អភិវិជិយ អជ្ឈាវសតិ** សេចក្តីថា ឈ្នះមារហើយ គ្របសង្កត់នូវតំណែងនៃភាពជាធំ គឺអរហត្តផលសមាបត្តិ ដែលជាប្រធាននៃអរិយមគ្គពោល គឺសង្គ្រាមដែលអរិយសាវកនោះធ្វើសម្រេចហើយ ព្រោះមានជ័យជម្នះដែលខ្លួនឈ្នះហើយ អធិប្បាយថា ចូលសមាបត្តិនោះឯង ។ សំឡេងនៃទេវតាទាំងនោះខ្ទរខ្ទាយទៅក្នុងពួកទេវតាដែលឃើញ សេចក្តីពិតហើយ ។ ដោយពិសេសហើយ គប្បីជ្រាបថា បានដល់ ទេវតាជាន់សុទ្ធាវាស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **មហន្តំ** សេចក្ដីថា ឈ្មោះថា ជាអ្នកធំ ព្រោះធំដោយគុណ មានសីលជាដើម ។ បទថា **វីតសារទំ** សេចក្ដីថា ប្រាសចាកសេចក្ដីកោតញញើត គឺប្រាសចាកការខ្មាសអៀន ព្រោះមិនមានកិលេសដែលធ្វើឲ្យតក់ស្លុត ។ បទថា **បុរិសាជញ្ញ** សេចក្ដីថា បុរសដ៏ឧត្ដម បុគ្គលជាតិអាជានេយ្យ ក្នុងបុរសទាំងឡាយ ដូចសេះដែលជាជាតិអាជានេយ្យជាដើមក្នុងសត្វទាំងឡាយ មានសេះជាដើម ។ បទថា **ទុជ្ជយមជ្ឈភូ** សេចក្ដីថា គ្របសង្កត់ គឺគ្រប់គ្រងកងទ័ព គឺកិលេសដែលមនុស្សជាច្រើន មិនអាចឈ្នះបាន អាចារ្យពួកខ្លះពោលថា **អជ្ឈយិ** ដូច្នេះក៏មាន ដោយអត្ថថា យកឈ្នះបាន ។ បទថា **ជេត្វាន មច្ចុនោ សេនំ វិមោក្ខេន អនាវរំ** សេចក្ដីថា ឈ្នះសេនានៃមច្ចុ គឺមារ ឈ្មោះថា មិនមានអ្នកណាពាំងបាន ព្រោះជនដទៃមិនអាចជំទាស់ពាំងបាន ព្រោះជាសេនាមានចំនួនច្រើន ដោយគ្របសង្កត់លោកទាំង ៣ បាន និងដោយចែកចេញដល់ ១៥០០ ជាដើម ដោយវិមោក្ខ គឺអរិយមគ្គ ។ ភ្ជាប់សេចក្ដីថា បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការដល់លោកដែលឈ្នះមារ ដែលគេឈ្នះបានដោយក្រ ដូច្នេះ ។ បទថា **ឥតិ** សេចក្ដីថា ដោយប្រការដូចពោលហើយ ។ បទថា **ហិ** ត្រឹមតែជានិបាត ។ ព្រះមានព្រះភាគទ្រង់សម្ដែងអត្ថ ដែលបានត្រាស់ហើយនោះឯង ដោយអំណាចនៃនិគមវចនៈ គឺពាក្យចុងក្រោយថា ពួកទេវតាតែងនមស្ការនូវសាវ័ក នៃព្រះសម្មាសម្ពុទ្ធនុ៎ះ ដែលមានសេចក្ដីប្រាជ្ញា

សម្រេចហើយ ។ម្យ៉ាងទៀត បទថា **ឥតិ** បានដល់ ដោយហេតុនេះ សួរថា ហេតុនោះ គឺអ្វី ឆ្លើយថា គឺព្រះអរិយបុគ្គល មានមានសៈ គឺអរហត្តសម្រេច ហើយ ដោយការឈ្នះសេនានៃមច្ចុមារ ដោយហេតុនេះ អធិប្បាយថា ទេវតា ទាំងឡាយតែងនមស្ការ ព្រះវីណាស្រេពនោះ ។

ឥឡូវនេះ កាលទ្រង់សម្តែងហេតុនេះដោយផល ទើបព្រះមានព្រះភាគ ត្រាស់ថា សាវកនៃព្រះសម្មាសម្ពុទ្ធ គប្បីដល់នូវអំណាចនៃមច្ចុទៀត ដោយ ហេតុណា ពួកទេវតាមិនឃើញហេតុនោះ របស់សាវកនៃព្រះសម្មាសម្ពុទ្ធ នោះឡើយ ដូច្នេះ ។ បាទព្រះគាថានេះ មានអធិប្បាយថា ព្រោះទេវតាទាំង-ឡាយ សូម្បីស្វែងរក ក៏មិនឃើញហេតុរបស់ព្រះវីណាស្រេពនោះ ដែលជា បុរសអាជានេយ្យដ៏ប្រណីត សូម្បីប្រមាណប៉ុនអណូដែលជាហេតុឲ្យបុគ្គល ទៅ គឺចូលទៅកាន់អំណាចនៃមច្ចុ គឺសេចក្តីស្លាប់ ដូច្នោះ ទើបវិសុទ្ធិទេព ទាំងឡាយ នមស្ការព្រះវីណាស្រេពនោះ ។៚

**អដ្ឋកថា សភិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បញ្ចបុព្វនិមិត្តសូត្រ

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ ទេវតាមានការច្យុតជាធម្មតា ចាកពួកទេវតា ក្នុងកាលណា បុព្វនិមិត្ត ៥ យ៉ាង តែងកើតឡើងប្រាកដ ដល់ទេវតានោះ ( ក្នុងកាលនោះ ) គឺកម្រងផ្កាទាំងឡាយ ស្វិតស្រពោន ១ សំពត់ទាំងឡាយសៅហ្មង ១ ញើសទាំងឡាយ តែងហូរចេញអំពីក្លៀក ១ សម្បុរមិនល្អតាំងឡើងក្នុងកាយ ១ ទេវតាមិនត្រេកអរក្នុងទេវាសនៈរបស់ខ្លួន ១ ។ ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយ តែងដឹងនូវបុព្វនិមិត្តនោះថា ទេវបុត្តនេះ មានការច្យុតជាធម្មតា ហើយក៏អនុមោទនាដោយវាចា ៣ បទថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកច្យុតអំពីទេវលោកនេះ ទៅកាន់សុគតិចុះ លុះអ្នកទៅកាន់សុគតិហើយ សូមឲ្យមានលាភ ដែលបានដោយងាយចុះ លុះមានលាភដែលបានដោយងាយហើយ សូមតាំងនៅដោយប្រពៃចុះ ។

[ ៨៤ ] កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្វីហៅថាដំណើរទៅកាន់សុគតិរបស់ទេវតាទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហៅថាលាភដែលបានដោយងាយរបស់ទេវតាទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហៅថា ការតាំងនៅដោយប្រពៃនៃទេវតាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃមនុស្ស ( នេះ ) ឯង ដែលហៅថា ដំណើរទៅកាន់សុគតិរបស់ទេវតាទាំងឡាយ លុះបានកើតជាមនុស្សហើយ បានចំពោះនូវសទ្ធា ក្នុងធម្មវិន័យណា ដែលព្រះតថាគតសម្ដែងហើយ ម្នាលភិក្ខុទាំងឡាយ ការបាននូវសទ្ធា

នេះឯង ហៅថា លាភដែលបានដោយងាយរបស់ទេវតាទាំងឡាយ ឯសទ្ធា របស់គេនោះ ជាសទ្ធាខ្ជាប់ខ្ជួន កើតជាឫសគល់តាំងនៅមាំមួន ដែលបុគ្គល ណាមួយ ទោះជាសមណៈ ឬព្រាហ្មណ៍ ឬទេវតា ឬមារ ឬព្រហ្ម ក្នុងលោក មិនអាចនឹងនាំយកទៅបាន ម្នាលភិក្ខុទាំងឡាយ ការតាំងនៅមាំនៃសទ្ធានេះ ឯង ហៅថា ការតាំងនៅដោយប្រពៃ របស់ទេវតាទាំងឡាយ ។

ទេវតាច្យុតចាកពួកទេវតា ព្រោះអស់ទៅនៃអាយុ ក្នុង
កាលណា សំឡេង ៣ យ៉ាង របស់ពួកទេវតាកាល
អនុមោទនា តែងលាន់ឮឡើង ( ក្នុងកាលនោះ ) ថា
ម្នាលអ្នកដ៏ចម្រើន សូមអ្នកច្យុតអំពីទេវលោកនេះ ទៅ
កាន់សុគតិ ជាមួយនឹងពួកមនុស្សចុះ លុះអ្នកបានកើត
ជាមនុស្សហើយ សូមឲ្យបាននូវសទ្ធាដ៏ប្រសើរ ក្នុង
ព្រះសទ្ធម្មចុះ ក៏សទ្ធារបស់អ្នកនោះ ជាសទ្ធាខ្ជាប់ខ្ជួន
ដែលបានជាឫសគល់ តាំងនៅមាំមួន ក្នុងព្រះសទ្ធម្ម
ដែលព្រះតថាគត សម្ដែងហើយ ដោយប្រពៃ ដែល
បុគ្គលណាមួយ មិនអាចនាំយកទៅបាន ដរាបអស់ជីវិត ។
អ្នកត្រូវលះកាយទុច្ចរិតផង លះវចីទុច្ចរិតផង លះ
មនោទុច្ចរិតផង លះអំពើដទៃ ដែលប្រកបដោយ
ទោសផង ធ្វើកុសលដោយកាយ ធ្វើកុសលដោយ
វាចា ធ្វើកុសលដោយចិត្តឲ្យច្រើន ប្រមាណមិនបាន

បរិសុទ្ធ មិនមានគ្រឿងសៅហ្មង ។ លំដាប់នោះ អ្នកប្រាជ្ញត្រូវធ្វើបុណ្យ ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្ននោះឲ្យច្រើនដោយទាន ហើយញុំាងពួកសត្វដទៃ ឲ្យតាំងនៅក្នុងព្រះសទ្ធម្ម ដែលជាព្រហ្មចរិយៈ ទេវតាទាំងឡាយ ដឹងច្បាស់នូវទេវតា កាលច្យុតក្នុងកាលណា ក៏អនុមោទនា ( ក្នុងកាលនោះ ) ដោយសេចក្តីអនុគ្រោះនេះថា ម្នាលទេវតា ចូរអ្នកមកឲ្យរឿយៗ ។ សូត្រទី ៤ ។

# អដ្ឋកថា

## បញ្ចបុព្វនិមិត្តសូត្រ

ក្នុងបញ្ចបុព្វនិមិត្តសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨៣-៨៤ ] បទថា **យទា** ប្រែថា ក្នុងកាលណា ។ បទថា **ឧបេត** បានដល់ ទេវតាពួកឧបបត្តិទេព ។

ទេវៈមាន ៣ ពួក គឺសម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ក្នុងទេវៈ ៣ ពួកនេះ ក្សត្រជាព្រះរាជាទាំងឡាយ ឈ្មោះថា សម្មតិទេព ទេវតាដែលខ្ពស់ជាងនោះចាប់ពីចាតុម្មហារាជិកាជាដើម ឈ្មោះថា ឧបបត្តិទេព ព្រះខីណាស្រព ឈ្មោះថា វិសុទ្ធិទេព ។ តែក្នុងព្រះសូត្រទ្រង់បំណងយក

ទេវតាជាន់កាមាវចរ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា បទថា **ឧបេតា** បានដល់ ឧបបត្តិទេព ។

បទថា **ទេវកាយា** សេចក្តីថា ចាកជំនុំនៃទេវៈ ឬចាកតំណែងនៃទេវៈ អធិប្បាយថា ចាកទេវលោក ព្រោះថា **កាយ** សព្ទនេះ សំដៅដល់ការនៅជាពួក ។ បទថា **ចវនធម្មោ** សេចក្តីថា មានការស្លាប់ជាធម្មតា អធិប្បាយថា មានមរណៈប្រាកដហើយ ព្រោះអស់អាយុ ឬអស់បុណ្យ ។

បទថា **បញ្ចស្ស បុព្វនិមិត្តានិ បាតុភវន្តិ** សេចក្តីថា បុព្វនិមិត្តនៃការស្លាប់ ៥ ប្រការ រមែងកើតឡើង ឬប្រាកដដល់ទេវតានោះជាអ្នកមានមរណៈប្រាកដហើយ ។ បទថា **មាលា មិលាយន្តិ** សេចក្តីថា ផ្កាដែលទេវបុត្រនោះប្រដាប់នោះក្រៀមស្វិត គឺអស់នូវសម្រស់ ដូចបោះទៅក្នុងទីក្តៅ ក្នុងគ្រាថ្ងៃត្រង់ ។ បទថា **វត្ថានិ កិលិស្សន្តិ** សេចក្តីថា អាភរណៈ គឺសំពត់ដែលទេវបុត្រនោះស្លៀកដណ្តប់ហើយ មានពណ៌ដូចព្រះអាទិត្យដែលទើបតែនឹងរះក្នុងអាកាសដែលប្រាសចាកពពក ក្នុងសរទសម័យ មានពណ៌ផ្សេងៗ ក៏ថមថយ មិនចាំងចែង ដល់នូវការសៅហ្មង ដូចបោះទៅក្នុងភក់ ហើយជាន់ឈ្លីក្នុងខណៈនោះឯង ។ បទថា **កច្ឆេហិ សេទា មុច្ចន្តិ** សេចក្តីថា ក្នុងខណៈនោះ តំណក់ញើសហូរចេញអំពីក្លៀកទាំង ២ របស់ទេវបុត្រ ដែលមាននូវសរីរៈមិនធ្លាប់មានញើសមកអំពីមុន ដូចកែវមណីដោយកំណើតដែលបរិសុទ្ធល្អ ដូចបដិមាមាសដែលសិប្បករជាអ្នកជំនាញតាក់តែងហើយ ញើសនេះមិនមែនហូរចេញអំពីក្លៀកតែម្យ៉ាងនោះទេ សូម្បីញើសខ្មៅ ក៏ហូរចេញអំពី

*រាងកាយទាំងមូលរបស់ទេវបុត្រនោះ ដោយកាយរបស់ទេវបុត្រ ហាក់ដូចជាធ្ងន់ដោយសំណាញ់ ដែលប្រដាប់ដោយសំណាញ់នៃកែវមុក្តា ដែលខ្លួនប្រដាប់ហើយ ។ បទថា* **កាយេ ទុព្វណ្ណិយំ ឱក្កមតិ** *សេចក្តីថា តាំងអំពីបដិសន្ធិ រាងកាយផ្សាយនូវរស្មីទៅក្នុងទី ១ យោជន៍ខ្លះ ២ យោជន៍ខ្លះ ១២ យោជន៍ខ្លះ តាមអានុភាពរបស់ខ្លួន ប្រាសចាកជរាភាព មានធ្មេញបាក់ សក់ស្កូវជាដើម ការរងា ការក្តៅ នឹងមិនចូលទៅប៉ះពាល់ ដូចគ្នានឹងទេពធីតាក្មេងៗ អាយុ ១៦ ឆ្នាំ និងដូចទេវបុត្រក្មេងអាយុ ២០ ឆ្នាំ តែក្នុងខណៈនោះរូបក៏ខុសប្រក្រតី គឺរូបអាក្រក់ចូលមកជំនួស គឺស្ថិតនៅក្នុងកាយដែលអស់រស្មី អស់តេជះ ។ បទថា* **សកេ អាសនេ នាភិរមតិ** *សេចក្តីថា នឹងមិនត្រេកអរ គឺមិនបាននូវការត្រេកអរក្នុងទិព្វាសនៈសម្រាប់លេង និងបម្រើដោយពួកស្រីស្នំរបស់ខ្លួន ។*

*បានឮថា ការស្លាប់នឹងមានដល់ទេវបុត្រនោះដោយ ៧ ថ្ងៃ ដោយការរាប់ថ្ងៃរបស់មនុស្ស ព្រោះដូច្នោះ ទើបបុព្វនិមិត្តទាំងនេះប្រាកដដោយការកើតឡើងនៃបុព្វនិមិត្តនោះ ទេវបុត្រនោះ រមែងត្រូវសេចក្តីសោកមានកម្លាំងគ្របសង្កត់ ដោយគិតថា អញត្រូវព្រាត់ប្រាសចាកសម្បត្តិបែបនេះ ដោយហេតុនេះ ការក្រវល់ក្រវាយយ៉ាងធំ រមែងកើតឡើងក្នុងកាយរបស់ទេវបុត្រនោះ ដោយហេតុនោះ ទើបញើសហូរចេញអំពីខ្លួន ដោយប្រការទាំងពួង ។ ទេវ-បុត្រអង្គខ្លះ មានទុក្ខប្រមាណមិនបានអស់កាលយូរមក មិនអាចកាត់បន្ថយទុក្ខនោះបាន ខ្សឹកខ្សួលថា យើងក្តៅ យើងលំបាក មិនបានការស្រស់ស្រាយ*

ក្នុងទីណាមួយ រវើរវាយ ត្រាច់ទៅក្នុងទីនោះៗ ទេវតាខ្លះតម្កល់សតិបាន មិនបានបង្ហាញការខុសប្រក្រតីតាមកាយ និងវាចា កាលអត់សង្កត់នូវទុក្ខ គឺការព្រាត់ប្រាសរបស់ជាទីស្រឡាញ់មិនបាន ក៏ក្តៅក្រហាយត្រាច់ទៅ ។

បុព្វនិមិត្តទាំងនេះ រមែងប្រាកដចំពោះទេវតាដែលមានសក្តិទាំងឡាយប៉ុណ្ណោះ ដូចនិមិត្តទាំងឡាយ មានឧក្កាបាត ផែនដីកម្រើក និងចន្ទ្រគ្រាសជាដើម នឹងប្រាកដដល់អ្នកមានបុណ្យធំក្នុងលោក ដូចជាព្រះរាជា និងរាជ-អមាត្យជាដើម មិនប្រាកដដល់មនុស្សទូទៅឡើយ ទេវតាពួកខ្លះ ដឹងនិមិត្តទាំងនោះ កើតហើយថា និមិត្តទាំងនេះ ឈ្មោះថា ជាបុព្វនិមិត្តនៃមរណៈ មិនមែនដឹងគ្រប់អង្គទាំងអស់ទេ ទេវបុត្រទាំងនោះ ទេវបុត្រដែលកើតដោយកុសលធម៌ទន់ខ្សោយ ក៏នឹងតក់ស្លុតថា ឥឡូវនេះ អ្នកណានឹងថា អញកើតក្នុងទីណា ឯពួកដែលមានបុណ្យច្រើន មិនខ្លាច មិនតក់ស្លុត ដោយគិតថា អញបានឲ្យទាន បានរក្សាសីល បានសន្សំបុណ្យច្រើនហើយ អញចុតិអំពីលោកនេះហើយ សង្ឃឹមបានសុគតិនោះឯង ។ ទេវតាទាំងឡាយ កាលកាន់យកបុព្វនិមិត្តដែលប្រាកដឡើងយ៉ាងនោះហើយ រមែងចូលទៅកាន់ឧទ្យាន-នន្ទវ័ន ឧទ្យាននន្ទវ័ននោះ មានជាប្រចាំក្នុងទេវលោកគ្រប់ជាន់នោះឯង ។

បទថា **តីហិ វាចាហិ អនុមោទន្តិ** សេចក្តីថា ទេវតាទាំងឡាយតែងអនុមោទនាដោយពាក្យទាំង ៣ ដែលខ្ញុំនឹងពោលក្នុងកាលឥឡូវនេះ គឺរមែងញុំាងនូវការត្រេកអររីករាយឲ្យកើតឡើង រមែងឲ្យសប្បាយចិត្ត ឬធ្វើសេចក្តីត្រេកអរដែលសមគួរដល់សភាពការក្នុងខណៈនោះ ដោយអំណាចការ

សប្បាយចិត្តនោះ ឯអាចារ្យពួកខ្លះពោលអត្ថនៃបទថា **អនុមោទន្តិ** ជា **ឱវទន្តិ** ។ បទថា **ឥតោ** សេចក្ដីថា ចាកទេវលោក ។ បទថា **ភោ** ជាអាលបនៈ គឺពាក្យហៅ ។ បទថា **សុគតឹ** បានដល់ គតិដែលល្អ អាចារ្យទាំងឡាយពោលសំដៅដល់មនុស្សលោក ។ បទថា **គច្ឆ** សេចក្ដីថា ចូលដល់ដោយអំណាចនៃបដិសន្ធិ ។

បទថា **ឯវំ វុត្តេ** សេចក្ដីថា កាលព្រះមានព្រះភាគត្រាស់ដល់ពាក្យដែលទេវតាទាំងនោះ គប្បីពោលដល់ទេវបុត្រនោះ ដោយន័យជាដើមថា អ្នកឃ្លាតចាកទេវលោកនេះហើយ ចូរទៅកាន់សុគតិចុះ ក្នុងកាលនោះយ៉ាងនេះ ។ ភិក្ខុរូបណាមួយ គឺរូបមួយដែលមិនប្រាកដ ដោយនាម និងគោត្រ អង្គុយក្នុងបរិស័ទនោះ ជាអ្នកឈ្លាសក្នុងអនុសន្ធិ បានក្រាបទូលពាក្យជាដើមថា **កិន្នុ ខោ ភន្តេ** នេះ បំណងថា ព្រះមានព្រះភាគត្រាស់សុគតិទាំងនេះដោយមិនប្លែកគ្នា មិនជាក់ច្បាស់ឡើយ បើដូច្នោះ អញនឹងឲ្យព្រះអង្គត្រាស់សុគតិជាដើមនោះឲ្យជាក់ច្បាស់ជាងនេះទៀត ភាពជាមនុស្ស ដែលទេវតាទាំងឡាយបំណងក្រៃលែង ដោយជាហេតុនៃការបានចំពោះនូវគុណវិសេស មានសទ្ធាជាដើម និងដោយហេតុនៃការចូលដល់ភាពជាទេវតា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភាពនៃមនុស្ស ( នេះ ) ឯងដែលហៅថា ដំណើរទៅកាន់សុគតិរបស់ទេវតាទាំងឡាយ ដូច្នេះ ។

បទថា **សុគតិគមនសង្ខាតំ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ហើយដោយប្រពៃថា ទៅកាន់សុគតិ អធិប្បាយថា ទ្រង់សរសើរគឺទ្រង់លើកតម្កើង

ហើយ បទថា **យំ** ក្នុងបទថា **យំ មនុស្សភូតោ** នេះ ជាកិរិយាបរាមាស ដោយបទថា **យំ** នោះ លោកសំដៅដល់កិរិយា គឺការបានចំពោះ ក្នុងបទថា **បដិលភតិ** នេះ អធិប្បាយថា បានចំពោះនូវសទ្ធា ។ បទថា **មនុស្សភូតោ** សេចក្តីថា កើតហើយក្នុងមនុស្សទាំងឡាយ ម្យ៉ាងទៀត បានដល់ ភាពជាមនុស្ស ព្រោះបុគ្គលដែលកើតក្នុងទេវលោក ដោយច្រើនលំបាកនឹងបានស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគត មិនដូចមនុស្សទាំងឡាយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **មនុស្សភូតោ** ដូច្នេះ ។ បទថា **តថាគតប្បវេទិតេ ធម្មវិនយេ** សេចក្តីថា ក្នុងពាក្យប្រៀនប្រដៅដែលសង្គ្រោះដោយសិក្ខា ៣ ដែលព្រះតថាគត គឺព្រះមានព្រះភាគទ្រង់សម្តែងហើយ ។

ព្រោះថា ពាក្យប្រៀនប្រដៅនោះ លោកហៅថា **ធម្មវិន័យ** ឈ្មោះថា **ធម៌** ព្រោះមិនប្រាសទៅអំពីធម៌ និងឈ្មោះថា **វិន័យ** ព្រោះទូន្មានវេនេយ្យសត្វ តាមសមគួរដល់កិលេស ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះដឹកនាំបុគ្គលមានកំណើត គឺអ្នកមានធូលីក្នុងភ្នែកតិច ដែលឈ្មោះថាជាធម៌ ព្រោះមិនប្រាសចាកធម៌ ព្រោះសម្បូរដោយឧបនិស្ស័យ ។ ម្យ៉ាងទៀត លោកហៅថា **ធម៌វិន័យ** ព្រោះទូន្មានដោយធម៌តែម្យ៉ាង មិនមែនទូន្មានដោយដំបង និងសស្ត្រា ។ ម្យ៉ាងទៀត លោកហៅថា **ធម៌វិន័យ** ព្រោះការទូន្មាននោះប្រកបដោយធម៌ ។ ម្យ៉ាងទៀត លោកហៅថា **ធម៌វិន័យ** ព្រោះនាំចូលទៅរកធម៌ ដើម្បីមគ្គផល និងនិព្វានតាមលំដាប់ ម្យ៉ាងទៀត លោកហៅថា **ធម៌វិន័យ** ព្រោះជាគ្រឿងដឹកនាំ ដែលប្រព្រឹត្តទៅហើយដោយធម៌

មានមហាករុណា និងសព្វញ្ញុតញ្ញាណជាដើម ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះធម៌ជាគ្រឿងនាំចូលទៅរកធម៌របស់ព្រះមានព្រះភាគ ដែលជាអគ្គធម៌ ជាធម្មកាយ ជាធម្មសាមី មិនមែននាំចូលទៅរកធម៌របស់អ្នកតក្កវិជ្ជាទាំងឡាយ ។ ម្យ៉ាងទៀត លោកហៅថា **ធម្មវិន័យ** ព្រោះជាគ្រឿងទូន្មានដែលប្រព្រឹត្តទៅហើយ ក្នុងធម៌ គឺមគ្គផល ឬក្នុងធម៌ដែលជាវិស័យគប្បីឲ្យសម្រេចក្នុងព្រះធម្មវិន័យនោះ ។

បទថា **សទ្ធំ បដិលភតិ** សេចក្តីថា ញុំាងសទ្ធាឲ្យកើតឡើងដោយន័យជាដើមថា **ស្វាក្ខាតោ ភគវតា ធម្មោ** អធិប្បាយថា អ្នកមានសទ្ធា កាលបដិបត្តិក្នុងធម៌វិន័យនេះតាមដែលទ្រង់ទូន្មាន រមែងញុំាងចិត្តឲ្យត្រេកអរក្នុងទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ ក្នុងបទថា **សុលទ្ធលាភសង្ខាតំ** នេះ មានអធិប្បាយថា ការបានប្រាក់ មាស ស្រែ ចម្ការជាដើម រមែងនាំសេចក្តីសុខ ក្នុងការប្រើប្រាស់មកឲ្យសព្វសត្វហាមនូវសេចក្តីទុក្ខ មានការឃ្លាន និងការស្រេកជាដើម បន្ទោបង់នូវចំណង់ក្នុងប្រាក់ និងមាសបាន នាំសេចក្តីស្ងប់ក្នុងលោកមកឲ្យ ព្រោះបានទទួលរតនៈមានមុក្តាជាដើម យ៉ាងណា សូម្បីសទ្ធាដែលជាលោកិយ និងលោកុត្តរក៏ដូច្នោះ នឹងនាំវិបាកសុខដែលជាលោកិយ និងលោកុត្តរមកឲ្យ តាមដែលកើតឡើង និងហាមឃាត់នូវទុក្ខ មានជាតិ ជរាជាដើមបាន និងរម្ងាប់នូវការមិនមានគុណធម៌ចេញបាន ជាហេតុឲ្យបានទទួលនូវរតនៈ មានសតិសម្ពោជ្ឈង្គជាដើម នឹងនាំមកនូវសន្តិក្នុងលោក ដល់ពួកជនអ្នកបដិបត្តិដោយសទ្ធាធុរៈ

សមដូចព្រះមានព្រះភាគត្រាស់ថា

**សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ដូច្នេះ ។

គប្បីជ្រាបអត្ថបានចំពោះនូវសទ្ធា ជាលាភដែលបុគ្គលបានល្អហើយ ដូចពណ៌នាមកនេះ ។

ព្រោះការបានចំពោះនូវសទ្ធានេះ ជាលាភដែលជាប់តាមខ្លួនទៅបាន មិនទូទៅដល់អ្នកដទៃ ជាហេតុឲ្យបាននូវសម្បត្តិគ្រប់យ៉ាង និងជាហេតុនៃការបាននូវលោកិយទ្រព្យ មានប្រាក់មាសជាដើម អធិប្បាយថា អ្នកមានសទ្ធាប៉ុណ្ណោះនឹងធ្វើបុណ្យ មានទានជាដើមបាន ហើយនឹងជួបនូវទ្រព្យដែលជាគ្រឿងត្រេកអរនៃចិត្តដ៏ឧឡារ និងញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃនោះឯងឲ្យដល់ព្រមដោយបុណ្យនោះ តែបុណ្យទាំងនោះ នឹងមិនឲ្យនូវប្រយោជន៍ទាំងក្នុងលោកនេះ និងលោកខាងមុខដល់អ្នកមិនមានសទ្ធាឡើយ គប្បីជ្រាបថា សទ្ធាជាលាភដែលបានដោយល្អ ដោយប្រការដូចពណ៌នាមកនេះ ។ ពិតហើយ លោកពណ៌នាសទ្ធាជាអនេក ដោយឋានៈផ្សេងៗ គឺថា សទ្ធាជាស្បៀងខ្លះ សទ្ធាជាសម្ភារៈគម្រប់ ២ របស់បុរសខ្លះ សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោកនេះខ្លះ ព្រះសមុទ្ទជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ

ខ្វះ សទ្ធាជាពូជ តបៈជាភ្លៀងខ្វះ ម្នាលភិក្ខុទាំងឡាយ អរិយសាវកតាំងនៅក្នុងសទ្ធាខ្វះ សត្វរមែងធ្វងឱឃៈបានដោយសទ្ធាខ្វះ ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **សា ខោ បនស្ស** ដូច្នេះ ដើម្បីទ្រង់សម្តែងដល់សទ្ធាប្រភេទដែលឈមចុះជ្រៅ ជាហេតុឲ្យឈ្មោះថា ជាអ្នកតាំងមាំក្នុងកុសលធម៌ ក្នុងព្រះសាសនា ។

បណ្តាបទទាំងនោះ បទថា **អស្ស** នេះ មានអត្ថស្មើគ្នានឹង **ភវេយ្យ** ប្រែថា គប្បីជា ។ បទថា **និវិដ្ឋា** សេចក្តីថា តាំងមាំ គឺជ្រាបចូលទៅក្នុងចិត្តសន្តាន ។ បទថា **មូលជាតា** បានដល់ មានឫសកើតហើយ ។ សួរថា អ្វីជាឫសគល់របស់សទ្ធា ឆ្លើយថា យោនិសោមនសិការជាហេតុនៃការជឿក្នុងវត្ថុដែលគួរជឿ ជាឫសគល់នៃសទ្ធា ។ ម្យ៉ាងទៀត គប្បីជ្រាបអង្គនៃសោតាបត្តិមគ្គ ៤ យ៉ាង គឺសេពគប់សប្បុរស ១ ស្តាប់ធម៌របស់សប្បុរស ១ ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ១ បដិបត្តិធម៌សមគួរដល់ធម៌ ១ ថាជាឫសគល់នៃសទ្ធា ។ បទថា **បតិដ្ឋិតា** បានដល់ ឈមចុះហើយដោយជាភាវៈដែលបុគ្គលណាម្នាក់ឲ្យញាប់ញ័រមិនបាន ព្រោះសម្រេចអរិយមគ្គ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ទឡ្ហា អសំហារិយា** ដូច្នេះ ។ បទថា **ទឡ្ហា** នេះ ប្រែថា មាំទាំ ។ បទថា **អសំហារិយា** នេះ សេចក្តីថា ជារបស់ដែលបុគ្គលណាម្នាក់មិនអាចនាំទៅបាន ឬឲ្យបាត់ទៅ ឬនាំចេញទៅបាន ។

ទេវតាទាំងនោះ ប្រាថ្នានឹងឲ្យទេវបុត្រនោះបានសម្រេចសោតាបត្តិផល

ទើបពោលយ៉ាងនោះ ដោយប្រការដូច្នេះ ។ ព្រោះទេវតាទាំងនោះ ប្រាថ្នាព្រះអរិយបុគ្គលដែលសមគួរដល់ការចូលទៅសោយកាមសុខក្នុងទេវលោករបស់ខ្លួនប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបលោកពោលថា ម្នាលទេវតា ចូរអ្នកមកឲ្យរឿយៗ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ សូម្បីការស្លាប់ និងអស់បុណ្យ មានដោយការចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ច្យុតចាកពួកទេវតាព្រោះអស់ទៅនៃអាយុ ដូច្នេះ ។ បទថា **អនុមោទតំ** សេចក្តីថា ដែលអនុមោទនា ។ បទថា **មនុស្សានំ សហាព្យតំ** បានដល់ ដល់នូវភាពជាអ្នកនៅរួមគ្នានឹងមនុស្សទាំងឡាយ ។ ឈ្មោះថា **សហាព្យ** ព្រោះអត្ថថា នៅរួម បានដល់ ប្រព្រឹត្តទៅជាមួយគ្នា ភាវៈនៃសហាព្យៈនោះ ឈ្មោះថា **សហាព្យតា** ។ បទថា **និវិដ្ឋស្ស** សេចក្តីថា គប្បីជាគុណជាតមាំទាំ ។ បទថា **យាវជីវំ** សេចក្តីថា ត្រឹមតែការប្រព្រឹត្តទៅនៃជីវិត អធិប្បាយថា ទម្រាំបរិនិព្វាន ។ បទថា **អប្បមាណំ** សេចក្តីថា វៀរចាកប្រមាណ ដោយអំណាចនៃការធ្វើឲ្យច្រើន ឲ្យឱឡារ និងធ្វើឲ្យច្រើនដង ដោយសេចក្តីគោរព ។ បទថា **និរូបធិ** សេចក្តីថា វៀរចាកឧបធិ គឺសង្កិលេសដែលជាហេតុកើតសេចក្តីសៅហ្មង អធិប្បាយថា បរិសុទ្ធក្រៃលែង គឺប្រាសចាកមន្ទិលទោស ។

ព្រោះហេតុដែលទេវតាទាំងនោះ មិនប្រាថ្នាមហគ្គតកុសល ព្រោះមិនចង់ផុតអំពីកាមលោក រមែងប្រាថ្នាចំពោះបុណ្យ ដែលជាកាមាវចរតែម្យ៉ាង

ដូច្នោះ ក្នុងព្រះសូត្រនេះ គប្បីជ្រាបយ៉ាងនេះថា លោកចុតិចាកទេវលោកនេះហើយ កើតក្នុងមនុស្ស ដឹងក្តីហើយ លះនូវទុច្ចរិតគ្រប់យ៉ាង មានកាយ-ទុច្ចរិតជាដើម សន្សំសុចរិតទាំងឡាយ មានកាយសុចរិតជាដើមឲ្យឱឡារ ឲ្យបរិបូណ៌ ហើយចូរជាអ្នកមានសទ្ធាដែលមកហើយ ដោយអរិយមគ្គ ព្រោះទេវតាទាំងនោះគង់ប្រាថ្នាបឋមមគ្គខ្លះ ទុតិយមគ្គខ្លះ លោកុត្តរមគ្គខ្លះ ព្រោះខ្ជួនកន្លងនូវការកើតក្នុងទេវលោកមិនបាន ដូច្នោះ គប្បីជ្រាបអត្ថនៃបទទាំង-ឡាយថា **អប្បមាណំ និរូបធឹ** ដោយអំណាចនៃកុសលទាំងនោះថា កុសលឈ្មោះថា មិនមានប្រមាណ ព្រោះចូលទៅកាត់នូវកិលេសទាំងឡាយ មានកាមរាគយ៉ាងគ្រោតគ្រាត ដែលតាំងនៅក្នុងទីតែមួយ ក្នុងឋានៈជាសត្រូវជាដើម ដែលធ្វើនូវប្រមាណ ម្យ៉ាងទៀត ឈ្មោះថា មិនមានឧបធិ ព្រោះលះខន្ធូបធិ ដែលគួរដល់ការកើតឡើងចាកភពទី ៧ និងអភិសង្ខារូបធិ ដែលកើតអំពីខន្ធូបធិនោះ ទាំងកិលេសូបធិដែលមគ្គនោះៗ គប្បីសម្លាប់ និងព្រោះអាស្រ័យព្រះនិព្វាន ពោល គឺធម្មជាតដែលមិនមានឧបធិ ព្រោះឧបធិកើតឡើងមិនបាន ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងកម្មដែលបិទទ្វារអបាយដោយចំណែកមួយយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងកម្ម ដែលឲ្យកើតសគ្គសម្បត្តិ ទើបត្រាស់ពាក្យជាដើមថា **តតោ ឱបធិកំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱបធិកំ** បានដល់ ឲ្យផលជាឧបធិ អធិប្បាយថា ឲ្យកើតនូវសម្បត្តិ គឺអត្តភាព និងភោគសម្បត្តិ ។ អត្តភាពលោកហៅថា **ឧបធិ។** ដែលត្រាស់ក្នុងវិភង្គថា កម្មសមាទានដ៏លាមកពួកខ្លះ

មានឧបធិសម្បត្តិរាំង មិនឲ្យផលក៏មាន ដូច្នេះ ។ សូម្បីកាមគុណក៏ត្រាស់ហៅថា **ឧបធិ** ដូចព្រះតម្រាស់ក្នុងសំយុត្តនិកាយ សគាថវគ្គថា ដ្បិតឧបធិទាំងឡាយ ជាគ្រឿងសោកសៅរបស់ជន ដូច្នេះ ។

ក្នុងពាក្យថា ដ្បិតឧបធិទាំងឡាយ ជាគ្រឿងសោកសៅរបស់ជននេះ មានអត្ថវចនៈដូច្នេះ អត្តភាព និងកាមគុណ ឈ្មោះថា **ឧបធិ** ព្រោះជាទីដែលសត្វទ្រទ្រង់នូវសុខ និងទុក្ខ ។ បុណ្យ ឈ្មោះថា ឲ្យកើតឧបធិ ព្រោះមានឧបធិជាហេតុ ជាប្រក្រតី ឬគួរដល់ឧបធិ ។

សួរថា បុណ្យនោះ ធ្វើដូចម្តេច ឆ្លើយថា ធ្វើដោយទាន ព្រោះថា ទានមនុស្សក្រៅអំពីនេះធ្វើបានងាយ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។ ម្យ៉ាងទៀត ដោយបទថា **ធាខេន** ព្រះមានព្រះភាគត្រាស់យកអភយទានផងដែរ មិនមែនត្រាស់តែអាមិសទានប៉ុណ្ណោះទេ ព្រោះដូច្នោះ គប្បីជ្រាបថាទ្រង់សង្គ្រោះយកសីលផងដែរ ។

ព្រោះទេវតាទាំងនោះ ប្រាថ្នានូវសេចក្តីវិនាសនៃកាយអសុរ និងការបរិបូណ៌នៃកាយទេវតា ដោយចំណែកមួយប៉ុណ្ណោះ ព្រោះដូច្នោះ កាលទ្រង់សម្តែងឧបាយដល់ទេវបុត្រនោះ ទើបប្រកបទេវបុត្រក្នុងធម្មទាន ដោយបាទនៃគាថាថា **អញ្ញេបិ មច្ចេ សទ្ធម្មេ ព្រហ្មចរិយេ និវេសយ** ដូច្នេះ ។

បទថា **យទា វិទូ** សេចក្តីថា ពេលណាទេវតាទាំងឡាយគប្បីដឹង គឺគប្បីជ្រាបទេវតាដែលនឹងចុតិ ពេលនោះ ទេវតាទាំងឡាយ នឹងអនុមោទនាដោយសេចក្តីអនុគ្រោះ គឺដោយភាពជាអ្នកប្រាថ្នាដើម្បីបំបាត់ទុក្ខ តាមដែល

*ពោលហើយនេះថា នែទេវៈ ចូរអ្នកមក គឺចូរត្រឡប់មកកាន់ទេវកាយនេះ ដោយអំណាចការកើតឡើងរឿយៗ ដូច្នេះ ។*

**អដ្ឋកថា បញ្ចបុព្វនិមិត្តសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ពហុជនហិតសូត្រ

*[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ បុគ្គល ៣ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ជានាយសារថីទូន្មាននូវបុរស ជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ទ្រង់ខ្ជាក់ចោលនូវត្រៃភព ព្រះអង្គបានត្រាស់ឡើងក្នុងលោកនេះ ទ្រង់សម្ដែងធម៌ មានលម្អបទដើម លម្អបទកណ្ដាល លម្អបទចុង ប្រកបដោយអត្ថ និងព្យញ្ជនៈ ទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះជាបុគ្គលទី ១ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍*

ដល់ជនច្រើន ដើម្បីសេចក្ដីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតា និងមនុស្ស ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សាវករបស់ព្រះសាស្ដានោះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ មានសោឡសកិច្ច ធ្វើស្រេចហើយ មានភារៈ គឺខន្ធ ៥ ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួន សម្រេចហើយ មានកិលេសជាគ្រឿងប្រកបសត្វទុកក្នុងភព អស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ សាវកនោះ តែងសម្ដែងធម៌ មានលម្អបទដើម មានលម្អបទកណ្ដាល មានលម្អបទចុង ប្រកបដោយអត្ថ និងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ បរិសុទ្ធបរិបូណ៌ទាំងអស់ ម្នាលភិក្ខុ ទាំងឡាយ នេះបុគ្គលទី ២ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បី ប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់ សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សាវក របស់ព្រះសាស្ដានោះ ជាសេក្ខបុគ្គលកំពុងប្រតិបត្តិ ជាពហុស្សុត បរិបូណ៌ ដោយសីល និងវត្ត សាវកនោះតែងសម្ដែងធម៌ មានលម្អបទដើម មានលម្អ បទកណ្ដាល មានលម្អបទចុង ប្រកបដោយអត្ថ និងព្យញ្ជនៈ ប្រកាស ព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះបុគ្គលទី ៣ កាលកើតឡើងក្នុងលោក ក៏កើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដី

ចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង កាលកើតឡើង ក្នុងលោក តែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

ព្រះសាស្តា ព្រះអង្គស្វែងរកគុណដ៏ធំ ជាបុគ្គលទី ១ ក្នុងលោក សាវកអ្នកប្រព្រឹត្តតាមព្រះសាស្តានោះ មានខ្លួនអប់រំហើយ ( ជាបុគ្គលទី ២ ) មួយទៀត សាវកដទៃជាសេក្ខបុគ្គលកំពុងប្រតិបត្តិ ជាពហុស្សូត បរិបូណ៌ដោយសីល និងវត្ត ( ជាបុគ្គលទី ៣ ) ។ បុគ្គល ៣ ពួកនេះ ប្រសើរជាងទេវតា និងមនុស្ស លោកជាអ្នកធ្វើពន្លឺ គឺធម៌ សម្តែងឡើងនូវធម៌ គឺចតុរារិយសច្ច បានបើកទ្វារនៃព្រះអមតនិព្វាន លោកទាំងនោះ តែងញុំាងជនច្រើននាក់ឲ្យរួចចាកយោគៈបាន ។ ពួកជនណាឈានឡើងកាន់អរិយមគ្គ ដែលព្រះមានព្រះភាគ ដូចជានាយឈ្មួញដ៏ប្រសើរដោយសីលាទិគុណ ទ្រង់សម្តែងហើយដោយប្រពៃ ពួកជនណា មិនប្រមាទក្នុងសាសនារបស់ព្រះសុគត ពួកជននោះៗ តែងធ្វើនូវទីបំផុតទុក្ខក្នុងអត្តភាពនេះបាន ។ សូត្រទី ៥ ។

# អដ្ឋកថា

## ពហុជនហិតសូត្រ

ក្នុងពហុជនហិតសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨៥ ] បទថា **លោកេ** នេះ លោកមាន ៣ គឺសត្វលោក ១ សង្ខារលោក ១ ឱកាសលោក ១ ។ ក្នុងលោកទាំង ៣ នោះ ពួកសត្វទាំងឡាយ ដែលទាក់ទងដោយឥន្ទ្រិយ ដែលប្រព្រឹត្តទៅដោយអំណាចនៃការបន្តរបស់រូបធម៌ និងអរូបធម៌ និងរូបធម៌ផង អរូបធម៌ផង ឈ្មោះថា សត្វលោក ។ លោកដែលចែកប្រភេទជាដី និងភ្នំជាដើម ឈ្មោះថា ឱកាសលោក ខន្ធទាំងឡាយក្នុងលោកទាំង ២ ឈ្មោះថា សង្ខារលោក ។ លោកទាំង ៣ នោះ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ទ្រង់បំណងយកសត្វលោក ព្រោះដូច្នោះ ទើបបទថា **លោកេ** បានដល់ សត្វលោក ។ សូម្បីក្នុងលោកទាំងនោះ បុគ្គល ៣ ប្រភេទ មិនកើតក្នុងទេវលោក មិនកើតក្នុងព្រហ្មលោក តែកើតក្នុងមនុស្សលោក ទោះបីក្នុងមនុស្សលោក ក៏មិនកើតក្នុងចក្រវាលដទៃ កើតឡើងក្នុងចក្រវាលនេះប៉ុណ្ណោះ ទោះបីក្នុងចក្រវាលនេះ ក៏មិនកើតក្នុងទីសព្វអន្លើ ព្រះតថាគត ទ្រង់កើតឡើងក្នុងមជ្ឈិមបទេស ដែលមានបណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ ជុំវិញ ៩០០ យោជន៍ ដែលកំណត់យ៉ាងនេះ គឺក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិ-

មជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគម ឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍ ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជៈ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជន-បទ ។ មិនមែនតែព្រះតថាគត កើតឡើងតែម្យ៉ាងប៉ុណ្ណោះទេ ព្រះបច្ចេកពុទ្ធ អគ្គសាវកពុទ្ធ អសីតិមហាថេរៈ ពុទ្ធមាតា ពុទ្ធបិតា ស្តេចចក្រពត្តិ និង ព្រាហ្មណគហបតី ដែលមានគោលពួកដទៃ តែងកើតក្នុងមជ្ឈិមបទេសនេះដូចគ្នា ក្នុងព្រះសូត្រនេះ បានន័យនេះក្នុងតថាគតវារៈតែម្យ៉ាង ដោយអំណាច នៃសព្វត្ថកន័យ ក្នុងព្រះសូត្រក្រៅអំពីនេះ បានន័យដោយអំណាចនៃឯក-ទេសន័យ ។

ពាក្យទាំង ២ ថា **ឧប្បជ្ជមានា ឧប្បជ្ជន្តិ** នេះ ជាពាក្យដែលពោល ប្លែកទៅប៉ុណ្ណោះ គប្បីជ្រាបអធិប្បាយក្នុងពាក្យនេះយ៉ាងនេះថា បុគ្គល ៣ ប្រភេទ កាលកើត រមែងកើតឡើងដើម្បីជាប្រយោជន៍ដល់មហាជន មិនមែន កើតឡើងដោយហេតុដទៃ ព្រោះក្នុងពាក្យថា **ឧប្បជ្ជមានា ឧប្បជ្ជន្តិ** នេះ បុគ្គលណាម្នាក់មិនអាចនឹងផ្លាស់លក្ខណៈនៃសព្វបែបនេះ ដោយលក្ខណៈនៃ សព្វដទៃបានឡើយ ម្យ៉ាងទៀត បុគ្គលប្រភេទនោះ ឈ្មោះថា នឹងកើតឡើង ឈ្មោះថា កំពុងកើតឡើង ឈ្មោះថា កើតឡើងហើយ ព្រោះដូច្នោះ គប្បី

ជ្រាបការប្លែកគ្នានៃកាល ដូច្នេះ ។

ពិតហើយ ព្រះតថាគត កាលទ្រង់បំពេញមហាភិនីហារ ទ្រង់ស្វែងរកពុទ្ធការកធម៌ ទ្រង់បំពេញបារមី ទ្រង់បរិច្ចាគមហាបរិច្ចាគទាំង ៥ ទ្រង់បំពេញញាតត្ថចរិយា ញុំាងលោកត្ថចរិយា ពុទ្ធត្ថចរិយាឲ្យដល់ទីបំផុត ហើយបំពេញបារមីទាំងឡាយ ស្ថិតនៅក្នុងតុសិតភព ច្យុតអំពីតុសិតភពនោះហើយ បដិសន្ធិក្នុងបច្ឆិមភព ប្រថាប់នៅក្នុងផ្ទះ យាងចេញមហាភិនេស្រ្កមណ៍ ទ្រង់បំពេញមហាបធាន មានបញ្ញាចាស់ក្លា ទ្រង់យាងឡើងកាន់ពោធិមណ្ឌល ទ្រង់កម្ចាត់មារ និងពល ក្នុងបឋមយាម ទ្រង់បានទទួលបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ឆិមយាមទ្រង់ញុំាងព្រះញាណឲ្យឈមចុះក្នុងបដិច្ចសមុប្បាទ ពិចារណាសង្ខារទាំងពួង ដោយអនេកប្បការ ទ្រង់ចាក់ធ្លុះសោតាបត្តិមគ្គ រហូតធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថា នឹងកើត ។ ក្នុងខណៈនៃអរហត្តមគ្គ ឈ្មោះថា កំពុងកើត ក្នុងខណៈនៃអរហត្តផល ឈ្មោះថា កើតហើយ ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ មិនមានកិច្ច គឺការញុំាងឥទ្ធិវិធញ្ញាណជាដើមឲ្យកើតឡើងតាមលំដាប់ ដូចសាវកទាំងឡាយ ។ តែគំនរពុទ្ធគុណទាំងអស់ ឈ្មោះថា ហូរមកហើយ មួយអន្លើដោយអរហត្តមគ្គនោះឯង ព្រោះដូច្នោះ ទើបបុគ្គលទាំង ៣ ប្រភេទនោះ ឈ្មោះថា កើតឡើងហើយ ក្នុងខណៈនៃអរហត្តផលចិត្ត ព្រោះកិច្ចគ្រប់យ៉ាងកើតឡើងហើយ ។ ក្នុងព្រះសូត្រនេះត្រាស់ថា **ឧប្បជ្ជតិ** ទ្រង់សំដៅដល់ខណៈនៃអរហត្តផលចិត្ត នេះជាអធិប្បាយក្នុងពាក្យថា កើតឡើង នេះ ។

សូម្បីសាវកដែលជាខីណាស្រព សន្សំបុញ្ញសម្ភារៈ ដែលជាហេតុនៃសាវកពោធិញ្ញាណដោយជុំវិញ បំពេញគតបច្ចាគតវត្ត ដែលជាបុព្វប្បយោគ បុព្វចរិយា កើតក្នុងភពចុងក្រោយ ដឹងក្តីតាមលំដាប់ហើយ ឃើញទោសក្នុងសង្សារ តាំងចិត្តបព្វជ្ជា ញុំាងបព្វជ្ជាឲ្យដល់កំពូល បំពេញសីលាទិគុណជាដើម ប្រព្រឹត្តសមាទានធុតង្គធម៌ ប្រឹងប្រែងប្រកបព្យាយាមជាគ្រឿងភ្ញាក់រឭក ញុំាងឈានទាំងឡាយឲ្យកើតហើយ ផ្តើមតាំងវិបស្សនា សូម្បីកាលសម្រេចនូវមគ្គខាងក្រោម ឈ្មោះថា នឹងកើត ។ ក្នុងខណៈនៃអរហត្តមគ្គចិត្ត ឈ្មោះថា កំពុងកើត ។ តែក្នុងខណៈនៃអរហត្តផលចិត្ត ឈ្មោះថា កើតហើយ ឯព្រះសេក្ខៈ តាំងពីបុព្វូបនិស្ស័យ រហូតដល់គោត្រភូញាណ ឈ្មោះថា នឹងកើត ក្នុងខណៈនៃបឋមមគ្គចិត្ត ឈ្មោះថា កំពុងកើត ចាប់តាំងអំពីខណៈនៃបឋមផល ឈ្មោះថា កើតហើយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ខ្ញុំពោលអត្ថនៃបទទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើង ដូច្នេះ បរិបូណ៌ហើយ ។

ឥឡូវនេះ ខ្ញុំវិនិច្ឆ័យក្នុងបទថា **ពហុជនហិតាយ** ជាដើមតទៅ បទថា **ពហុជនហិតាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់មហាជន ។ បទថា **ពហុជនសុខាយ** សេចក្តីថា ដើម្បីសេចក្តីសុខដល់មហាជន ។ បទថា **លោកានុកម្បាយ** សេចក្តីថា អាស្រ័យសេចក្តីអនុគ្រោះសត្វលោក ។ សួរថា សត្វលោកប្រភេទណា ឆ្លើយថា សត្វលោកប្រភេទដែលស្តាប់ព្រះ

ធម្មទេសនានៃព្រះតថាគតហើយ ចាក់ធ្លុះនូវធម៌ ផឹកនូវអម្រឹត ។

ព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ចាក់ធ្លុះនូវធម៌ ដោយការសម្ដែងធម្មចក្កប្បវត្តនសូត្រ របស់ព្រះមានព្រះភាគ រហូតដល់ទ្រង់ប្រៀនប្រដៅសុភទ្ទបរិព្វាជកឲ្យសម្រេចធម៌ ដោយអាការយ៉ាងនេះ រាប់មិនអស់ សត្វដែលបានសម្រេចធម្មាភិសម័យក្នុងឋានៈទាំង ៤ នេះ គឺក្នុងពេលសម្ដែងមហាសមយសូត្រ ក្នុងពេលសម្ដែងមង្គលសូត្រ ចូឡរាហុលោវាទ-សូត្រ និងសមចិត្តសូត្រ មិនមានកំណត់ចំនួនឡើយ ។ ទាំងនេះ ក៏ដោយសេចក្ដីអនុគ្រោះសត្វលោកប្រមាណមិនបាននោះ ។ ការកើតឡើងនៃព្រះអរហន្តសាវក និងព្រះសេក្ខបុគ្គល ដើម្បីអនុគ្រោះសត្វលោក គប្បីជ្រាបអធិប្បាយដូច្នេះ ដោយអំណាចនៃសត្វដែលសម្រេចបដិវេធ ដោយទេសនាដែលព្រះធម្មសេនាបតីជាដើម និងព្រះថេរៈទាំងឡាយ ដែលជាឃ្លាំងនៃព្រះធម៌សម្ដែងហើយខ្លះ ដោយអំណាចនៃសត្វទាំងឡាយ ដែលចាក់ធ្លុះដោយទេសនា ដែលព្រះមហិន្ទត្ថេរជាដើមសម្ដែងហើយ ក្នុងកាលតមកខ្លះ ដោយអំណាចនៃសត្វទាំងឡាយដែលអាស្រ័យពាក្យប្រៀនប្រដៅ តាំងនៅក្នុងផ្លូវនៃស្ថានសួគ៌ និងព្រះនិព្វានក្នុងអនាគតកាល រហូតដល់ថ្ងៃនេះ គឺបន្ទាប់អំពីនេះទៅ ។ម្យ៉ាងទៀត បទថា **ពហុជនហិតាយ** សេចក្ដីថា ដើម្បីជាប្រយោជន៍ដល់មនុស្សច្រើន អធិប្បាយថា ទ្រង់ចម្រុលនូវហិតសុខ ទាំងជាបច្ចុប្បន្ន និងសម្បរាយិកភពដល់ជនទាំងនោះ ដោយព្រះបញ្ញាសម្បត្តិ ។ បទថា **ពហុជនសុខាយ** សេចក្ដីថា ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់

*ជនច្រើន អធិប្បាយថា ទ្រង់ប្រគល់ឲ្យនូវឧបករណ៍នៃសេចក្តីសុខដោយបាគសម្បត្តិ ។ បទថា* **លោកានុកម្បាយ** *សេចក្តីថា ដើម្បីទ្រង់អនុគ្រោះដល់សត្វលោក អធិប្បាយថា រក្សាគ្រប់គ្រងដល់សត្វលោក ដូចមាតាបិតាដោយមេត្តាសម្បត្តិ និងករុណាសម្បត្តិ ។ បទថា* **អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ** *សេចក្តីថា ក្នុងព្រះសូត្រនេះ វារៈដំបូង ទ្រង់សម្តែងការកើតឡើងនៃព្រះតថាគតដើម្បីការសម្រេចនូវនិញ្វនមគ្គ និងផលរបស់សត្វលោកទាំងនោះ ដោយកាន់យកវេនេយ្យសត្វ ដែលជាភព្វបុគ្គលនោះឯង ដោយ* **ទេវ** *សព្ទ និង* **មនុស្ស** *សព្ទ តែក្នុងវារៈ ទី ២ ទី ៣ ពាក្យថា* **អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ** *គប្បីប្រកបដោយអំណាចនៃព្រះអរហន្តនិងសេក្ខបុគ្គល ។ បណ្តាបទទាំងនោះ បទថា* **អត្ថាយ** *នេះ មានពុទ្ធាធិប្បាយថា ដើម្បីជាប្រយោជន៍យ៉ាងក្រៃលែង គឺដើម្បីព្រះនិញ្វន ។ ដោយបទថា* **ហិតាយ** *មានអធិប្បាយថា ដើម្បីជាប្រយោជន៍ដល់មគ្គដែលឲ្យសម្រេចព្រះនិញ្វននោះ ។ ពិតហើយ ឈ្មោះថា ប្រយោជន៍ដែលក្រៃលែងជាងមគ្គ ដែលជាហេតុឲ្យសម្រេចព្រះនិញ្វននោះមិនមាន ។ បទថា* **សុខាយ** *មានពុទ្ធាធិប្បាយថា ដើម្បីសេចក្តីសុខដែលអំពីផលសមាបត្តិ ព្រោះមិនមានសេចក្តីសុខដទៃ ដែលក្រៃលែងជាងផលសមាបត្តិនោះ សមដូចព្រះតម្រាស់ត្រាស់ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាតថា សមាធិនេះ ជាសុខក្នុងបច្ចុប្បន្នផង មានផលជាសុខតទៅផង ។ អត្ថនៃបទទាំងឡាយ មានពាក្យថា* **តថាគតោ** *ខ្ញុំបានពោលហើយខាងដើម ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វិជ្ជាចរណសម្បន្នោ** ដូចតទៅនេះថា ព្រះមានព្រះភាគទ្រង់សម្បូរ គឺប្រកបដោយវិជ្ជា ៣ តាមន័យដែលមកហើយក្នុងភយភេរវសូត្រ វិជ្ជា ៦ មកហើយដោយអំណាចនៃអភិញ្ញា ៦ វិជ្ជា ៨ មកហើយក្នុងអម្ពដ្ឋសូត្រ ចរណៈ ១៥ ប្រការ មានសីលសំវរៈជាដើម មិនជាសាធារណៈដល់សាវកដទៃឡើយ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **វិជ្ជា-ចរណសម្បន្នោ**។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សុគតោ** ព្រោះយាងទៅល្អផង ព្រោះយាងទៅកាន់ទីល្អផង ព្រោះយាងទៅដោយប្រពៃផង ព្រោះត្រាស់ដោយប្រពៃផង ។ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះទ្រង់ជ្រាបច្បាស់នូវលោកដោយប្រការទាំងពួង ។ ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះមិនមានអ្នកដទៃប្រសើរជាង ។ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះញ៉ាំងបុរសដែលគួរទូន្មាន គឺបុរសដែលជាវេនេយ្យសត្វឲ្យរឭកបាន បានដល់ ទ្រង់ដឹកនាំ ។ ទ្រង់ព្រះនាមថា **សត្ថា** ព្រោះទ្រង់ទូន្មានតាមសមគួរដោយទិដ្ឋធម្មិកត្ថប្រ-យោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ។ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះត្រាស់ដឹងដោយព្រះញាណ ដែលកើតឡើងឯង ដោយអាការទាំងពួង ដើម្បីវេនេយ្យសត្វទាំងមូល ។ នេះជាសេចក្ដីសង្ខេបក្នុងបទថា **វិជ្ជា-ចរណសម្បន្នោ** នេះ ឯសេចក្ដីពិស្ដារ គួរកាន់យកអំពីវិសុទ្ធិមគ្គឯណោះចុះ។

បទថា **សោ ធម្មំ ទេសេតិ អាទិ ។បេ។ បរិយោសានកល្យាណំ** សេចក្ដីថា ព្រះមានព្រះភាគអង្គនោះ ទ្រង់អាស្រ័យសេចក្ដីករុណាក្នុងសត្វទាំងឡាយ ទើបទ្រង់លះបង់វិវេកសុខដ៏កំពូល ទ្រង់សម្ដែងធម៌ កាលទ្រង់

សម្តែងធម៌នោះ តិចក្តី ច្រើនក្តី ឈ្មោះថា ទ្រង់សម្តែងធម៌ មានលម្អក្នុងបទដើមជាដើមដោយប្រការមួយ ។ សេចក្តីនេះដូចម្តេច ឆ្លើយថា ព្រះគាថានីមួយៗ ឈ្មោះថា មានលម្អក្នុងបទដើមដោយបាទទី ១ ឈ្មោះថា មានលម្អត្រង់កណ្តាលដោយបាទទី ២ និងបាទទី ៣ ឈ្មោះថា មានលម្អក្នុងទីបំផុតដោយបាទចុងក្រោយ ព្រោះជាធម៌ស្ងប់ និងគួរកាន់យក ។ ព្រះសូត្រមួយឈ្មោះថា ល្អខាងដើមដោយនិទាន ឈ្មោះថា ល្អខាងចុង ដោយពាក្យនិគមឈ្មោះថា ល្អត្រង់កណ្តាលដោយពាក្យដ៏សេស ។ ព្រះសូត្រមានអនុសន្ធិផ្សេងៗ គ្នា ឈ្មោះថា ល្អខាងដើម ដោយអនុសន្ធិដើម ឈ្មោះថា ល្អក្នុងបរិយោសាន ដោយអនុសន្ធិចុង ឈ្មោះថា ល្អត្រង់កណ្តាល ដោយអនុ-សន្ធិដ៏សេស ។

ម្យ៉ាងទៀត សាសនធម៌ទាំងមូល ឈ្មោះថា ល្អខាងដើមដោយសីលដែលជាប្រយោជន៍របស់ខ្លួន ឈ្មោះថា ល្អត្រង់កណ្តាល ដោយសមថៈវិបស្សនា មគ្គ និងផល ឈ្មោះថា ល្អខាងចុង ដោយព្រះនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា ល្អខាងដើម ដោយសីល និងសមាធិ ល្អត្រង់កណ្តាលដោយវិបស្សនា និងមគ្គ ល្អក្នុងបរិយោសាន ដោយផល និងព្រះនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា ល្អខាងដើម ព្រោះទ្រង់ជាអ្នកត្រាស់ដឹងប្រពៃហើយឈ្មោះថា ល្អត្រង់កណ្តាល ព្រោះធម៌ជាធម៌ដែលព្រះមានព្រះភាគ ត្រាស់ល្អហើយ ឈ្មោះថា ល្អក្នុងបរិយោសាន ព្រោះសង្ឃបដិបត្តិល្អហើយ ។ ម្យ៉ាងទៀត ឈ្មោះថា ល្អខាងដើម ដោយអភិសម្ពោធិញ្ញាណ ឈ្មោះថា ល្អ

ក្នុងកណ្ដាល ដោយបច្ចេកពោធិញ្ញាណ ឈ្មោះថា ល្អក្នុងទីបំផុត ដោយសាវកពោធិញ្ញាណដែលអ្នកបដិបត្តិគប្បីត្រាស់ដឹង ព្រោះស្ដាប់ហើយក៏យ៉ាងនោះ ។ ព្រះធម៌នេះ ដែលបុគ្គលស្ដាប់ រមែងនាំសេចក្ដីល្អនោះមកឲ្យ សូម្បីដោយការស្ដាប់ ព្រោះសង្កត់នីវរណៈបាន ។ ព្រោះដូច្នោះ ទើបឈ្មោះថា ល្អបទដើម កាលបដិបត្តិ តែងនាំសេចក្ដីសុខនោះឯងមកឲ្យដោយកិច្ចបដិបត្តិ ព្រោះនាំសេចក្ដីសុខដែលកើតអំពីសមថៈ និងវិបស្សនាមកឲ្យ ព្រោះដូច្នោះ ទើបឈ្មោះថា ល្អត្រង់បទកណ្ដាល ហើយអ្នកបដិបត្តិយ៉ាងនោះ កាលផលនៃកិច្ចបដិបត្តិសម្រេចហើយ រមែងនាំភាពល្អនោះឯងមកឲ្យ ដោយផលនៃកិច្ចបដិបត្តិ ព្រោះនាំនូវភាពជាបុគ្គលមិនញាប់ញ័រមកឲ្យ ព្រោះដូច្នោះ ទើបឈ្មោះថា ល្អក្នុងបរិយោសាន ។ ម្យ៉ាងទៀត សារធម៌នោះ ឈ្មោះថា មានលម្អខាងដើម ដោយសេចក្ដីបរិសុទ្ធនៃដែនកើត ព្រោះជាដែនកើតនៃទីពឹង ឈ្មោះថា មានលម្អត្រង់កណ្ដាល ដោយសេចក្ដីបរិសុទ្ធនៃខ្លួន ។ ឈ្មោះថា មានលម្អក្នុងបរិយោសាន ដោយសេចក្ដីបរិសុទ្ធនៃកិច្ច ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សោ ធម្មំ ទេសេតិ អាទិ ។បេ។ បរិយោសានកល្យាណំ** ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ណា ទ្រង់រមែងប្រកាសសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ សម្ដែងដោយន័យផ្សេងៗ គ្នា ព្រហ្មចរិយៈនោះ ឈ្មោះថា **សាត្ថំ** ព្រោះសម្បូរដោយអត្ថ ឈ្មោះថា **សព្យញ្ជនំ** ព្រោះសម្បូរដោយព្យញ្ជនៈតាមឋានានុរូប ។ ឈ្មោះថា **សាត្ថំ** ព្រោះប្រកបដោយ

**សង្កាស** គឺធ្វើឲ្យដឹងច្បាស់ **ប្រកាស** ការបើកផ្សារ ការចែក ការធ្វើឲ្យងាយ **បញ្ញត្ត អត្ថ** និង **បទ** ។ ឈ្មោះថា **សព្យញ្ជនំ** ព្រោះសម្បូរដោយអក្ខរៈ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេស ។ ម្យ៉ាងទៀត ឈ្មោះថា **សាត្ថំ** ព្រោះជារបស់ជ្រៅដោយអត្ថ និងជ្រៅដោយការចាក់ធ្លុះ ឈ្មោះថា **សព្យញ្ជនំ** ព្រោះជារបស់ជ្រៅដោយធម៌ និងជ្រៅដោយទេសនា ។ ម្យ៉ាងទៀត ឈ្មោះថា **សាត្ថំ** ព្រោះជាវិស័យនៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ឈ្មោះថា **សព្យញ្ជនំ** ព្រោះជាវិស័យនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ។ ព្រហ្មចរិយៈ ឈ្មោះថា ជាទីតាំងនៃសេចក្ដីជ្រះថ្លា របស់បរិក្ខកជន គឺជនអ្នកមានបញ្ញា ព្រោះជាធម៌ដែលបណ្ឌិតគប្បីសេព ព្រោះដូច្នោះ ទើបឈ្មោះថា **សាត្ថំ** ព្រហ្មចរិយៈជាទីតាំងនៃសេចក្ដីជ្រះថ្លា របស់លោកិយជន ព្រោះជាវត្ថុដែលគួរកាន់យក ព្រោះដូច្នោះ ទើបឈ្មោះថា **សព្យញ្ជនំ** ។ ឈ្មោះថា **សាត្ថំ** ព្រោះមានពាក្យអធិប្បាយថា ជ្រាលជ្រៅ ឈ្មោះថា **សព្យញ្ជនំ** ព្រោះមានបទងាយយល់ ។

ព្រហ្មចរិយៈ ឈ្មោះថា **កេវលបរិបុណ្ណំ** ព្រោះបរិបូណ៌ទាំងអស់ ព្រោះមិនមានបទដែលត្រូវនាំចូលទៅបំពេញ ។ ឈ្មោះថា **បរិសុទ្ធំ** ព្រោះមិនមានទោស មិនមានវត្ថុដែលត្រូវនាំចេញ ។ ម្យ៉ាងទៀត ព្រហ្មចរិយៈ ឈ្មោះថា **សាត្ថំ** ព្រោះងាយចំពោះសម្រេចដោយកិច្ចបដិបត្តិ ឈ្មោះថា **សព្យញ្ជនំ** ព្រោះងាយចំពោះការរៀនដោយបរិយត្តិ ។ ឈ្មោះថា **បរិបុណ្ណំ** ព្រោះបរិបូណ៌ទៅដោយធម្មក្ខន្ធទាំង ៥ មានសីលជាដើម ឈ្មោះថា **បរិសុទ្ធំ**

ព្រោះប្រាសចាកឧបក្កិលេស ព្រោះប្រព្រឹត្តដើម្បីដកនូវកិលេស និងព្រោះមិនប្រាថ្នាលោកាមិស ។ ឈ្មោះថា **ព្រហ្មចរិយំ** ព្រោះជាវត្ថុដែលបុគ្គលបដិបត្តិកំណត់ដោយសិក្ខា ៣ ព្រោះជាព្រហ្ម គឺបុគ្គលប្រសើរបំផុតនឹងត្រូវប្រព្រឹត្តនិងជាចរិយារបស់បុគ្គលដែលជាព្រហ្មទាំងនោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **សាត្ថំ សព្យញ្ជនំ ។បេ។ បកាសេតិ** ដូច្នេះ ។

បទថា **បឋមោ** បានដល់ បុគ្គលឈ្មោះថាទី ១ ព្រោះប្រព្រឹត្តទៅតាមលំដាប់នៃការរាប់ និងព្រោះជាអ្នកខ្ពស់ជាងសត្វលោកទាំងពួង ។ បទថា **តស្សេវ សត្ថុនោ សាវកោ** បានដល់ ព្រះសង្ឃ ដូចនឹងព្រះធម្មសេនាបតីជាដែនកើតហើយក្នុងទីបំផុតនៃការស្តាប់ធម្មទេសនារបស់ព្រះសាស្តា គឺព្រះមុនីសម្មាសម្ពុទ្ធដែលមានព្រះគុណ តាមដែលពោលហើយនោះឯង មិនមែនជាសាវករបស់ព្រះសាស្តា ដោយហេតុនៃការប្តេជ្ញា ដូចបូរណកស្សបៈជាដើម។ បទថា **ធាដិបនោ** សេចក្តីថា ឈ្មោះថា **ធាដិបទ** ព្រោះកើត គឺកើតដោយអរិយជាតិ ដោយអរិយមគ្គពោល គឺបដិបទា អធិប្បាយថា មានកិច្ចបដិបត្តិមិនទាន់សម្រេច គឺកំពុងបដិបត្តិ ។ ព្រះអរិយបុគ្គល ឈ្មោះថា **ពហុស្សុតោ** ព្រោះមានបរិយត្តិធម៌ មានសុត្តៈ និងគេយ្យៈជាដើមដែលស្តាប់ច្រើនហើយ ។ ឈ្មោះថា **សីលវត្តូបបន្នោ** ព្រោះចូលដល់ គឺសម្បូរ បានដល់ ប្រកបទៅដោយសីល មានបាតិមោក្ខសំវរសីលជាដើម និងដោយធុតង្គវត្ត មានការនៅព្រៃជាវត្តជាដើម ។

ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះធម្មទេសនា ឈ្មោះថា ជាទេសនា

*អនុគ្រោះដល់សត្វលោក ព្រោះអធ្យាស្រ័យប្រកបដោយឧបការ ព្រះធម្ម-ទេសនានោះ ទាក់ទងក្នុងបុគ្គល ៣ ពួកនោះ ដោយប្រការដូច្នេះ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា* **តស្សន្វយោ** *សេចក្តីថា សាវក ឈ្មោះថា ជាអ្នកអនុលោមតាម គឺកើតខាងក្រោយព្រះអង្គ ដោយការអនុលោមតាមបដិបទា និងព្រះធម្មទេសនារបស់ព្រះសាស្តាអង្គនោះ ។ ឈ្មោះថា* **ភាវិតត្តោ** *ព្រោះកម្ចាត់ងងឹត គឺអវិជ្ជា ដោយពន្លឺពោល គឺពន្លឺនៃព្រះធម៌ក្នុងសន្តានរបស់ខ្លួន និងសន្តានរបស់អ្នកដទៃ ។ បទថា* **ធម្មមុធីរយន្តា** *បានដល់ ពោលចតុរារិយសច្ចធម៌ ។ បទថា* **អបាបុរន្តិ** *បានដល់ រមែងបើកចេញ ។ បទថា* **អមតស្ស** *បានដល់ ព្រះនិព្វាន ។ បទថា* **ទ្វារំ** *បានដល់ អរិយមគ្គ ។ បទថា* **យោគា** *សេចក្តីថា ចាកកាមយោគៈជាដើម ។ បទថា* **សត្ថវាហេន** *សេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា* **សត្ថវាហា** *ព្រោះនាំ គឺនាំវេនេយ្យសត្វ គឺជញ្ជូនសត្វចាកកន្តារ គឺភព ព្រះមានព្រះភាគជាសត្ថវាហៈអង្គនោះ ។ បទថា* **សុទេសិតំ មគ្គមនុក្កមន្តិ** *សេចក្តីថា វេនេយ្យសត្វរមែងអនុលោមតាម គឺបដិបត្តិអរិយមគ្គ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងហើយដោយប្រពៃ តាមគន្លងនៃទេសនារបស់ព្រះអង្គ ។ បទថា* **ឥធេវ** *បានដល់ ក្នុងអត្តភាពនេះឯង ពាក្យដ៏សេស ងាយយល់ទាំងអស់ហើយ ។៚*

**អដ្ឋកថា ពហុជនហិតសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អសុភានុបស្សីសូត្រ

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរពិចារណាឃើញរឿយៗ នូវអាការមិនស្អាតក្នុងកាយ ឯអានាបានស្សតិកម្មដ្ឋាន ក៏អ្នកទាំងឡាយ ចូរតាំងឡើងប្រាកដ ឲ្យមានមុខឆ្ពោះទៅកាន់អារម្មណ៍ខាងក្នុង អ្នកទាំងឡាយចូរពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថាមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ពិចារណាឃើញរឿយៗ នូវអាការមិនស្អាតក្នុងកាយហើយ រាគានុស្ស័យណា គួរដល់កិរិយាកើតឡើងក្នុងសុភធាតុ ( កាន់យកនូវអារម្មណ៍ថាស្អាត ) រាគានុស្ស័យនោះ អ្នកទាំងឡាយរមែងលះបង់បាន ។ កាលអានាបានស្សតិកម្មដ្ឋាន តាំងឡើងប្រាកដ មានមុខឆ្ពោះទៅកាន់អារម្មណ៍ខាងក្នុងហើយ អាសយវិតក្កទាំងឡាយណាជាខាងក្រៅ ដែលជាចំណែកនៃសេចក្តីចង្អៀតចង្អល់ អាសយវិតក្កទាំងនោះ មិនមានតទៅទៀតឡើយ ។ កាលបើអ្នកទាំងឡាយ ពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថា មិនទៀងហើយ អវិជ្ជា អ្នកទាំងឡាយ ក៏រមែងលះបង់បាន វិជ្ជាសោត ក៏រមែងកើតឡើង ។ ភិក្ខុជាអ្នកពិចារណាឃើញរឿយៗ ក្នុងកាយថា មិនស្អាត មានសតិតម្កល់ខ្ជាប់ក្នុងអានាបានស្សតិកម្មដ្ឋាន ពិចារណាឃើញព្រះនិព្វានជាទីរម្ងាប់សង្ខារទាំងពួងហើយ ជាអ្នកមានព្យាយាម ជាគ្រឿងដុតកម្តៅកិលេសសព្វៗកាល ។ ភិក្ខុនោះឯង ឈ្មោះថា ឃើញដោយប្រពៃ ជាអ្នកសង្រួម រមែងចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ជាទីរម្ងាប់សង្ខារទាំងពួងនោះ ភិក្ខុនោះឯង ជាអ្នកមាន

ព្រហ្មចរិយធម៌ ប្រព្រឹត្តរួចហើយ ជាអ្នកស្ងប់ ព្រោះដឹងច្បាស់ ឈ្មោះថា អ្នកប្រាជ្ញប្រព្រឹត្តកន្លងយោគៈ ។ សូត្រទី ៦ ។

# អដ្ឋកថា

## អសុភានុបស្សីសូត្រ

ក្នុងអសុភានុបស្សីសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨៦ ] បទថា **អសុភានុបស្សី** សេចក្តីថា អ្នកទាំងឡាយកាលពិចារណាឃើញថា មិនស្អាត ឈ្មោះថា ជាអ្នកពិចារណាឃើញការមិនស្អាត គឺអាការមិនស្អាតក្នុងកាយ ដោយអំណាចនៃអាការ ៣២ និងដោយអំណាចនៃការបង្អោនទាំចូលទៅរកនិមិត្តដែលខ្ជួនកាន់យកហើយ ក្នុងសាកសពដែលហើមប៉ោងហើយជាដើម ។ បទថា **អានាបានស្សតិ** បានដល់ សតិក្នុងខ្យល់ដង្ហើម គឺសតិដែលប្រារព្ធខ្យល់ដង្ហើមនោះ ប្រព្រឹត្តទៅ អធិប្បាយថា សតិដែលកំណត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដូចព្រះតម្រាស់ថា ពាក្យថា អានៈ បានដល់ ខ្យល់ដកដង្ហើមចូល មិនមែនខ្យល់ដកដង្ហើមចេញទេ[១] ។ បទថា **វោ** បានដល់ អ្នកទាំងឡាយ ។ ក្នុងបទថា **អជ្ឈត្តំ** នេះ លោកបំណងយកអារម្មណ៍ខាងក្នុង ។ បទថា **បរិមុខំ** បានដល់ ចំពោះមុខ ។ បទ

---

១- បិ. ៧០ ទំ. ១០៧ អានៈ លោកប្រែថា ខ្យល់ដង្ហើមចេញ អបានៈ លោកប្រែថា ខ្យល់ដង្ហើមចូល តែក្នុងទីនេះ យើងកាន់យកតាមអដ្ឋកថា ។

ថា **សុប្បតិដ្ឋិតា** សេចក្តីថា តាំងមាំដោយល្អ លោកអធិប្បាយថា អានាបានស្សតិ អ្នកទាំងឡាយ ចូរតាំងទុកដោយល្អចំពោះមុខកម្មដ្ឋាន ដូច្នេះ ។ ម្យ៉ាងទៀត បទថា **បរិមុខំ** សេចក្តីថា មានការនាំចេញទៅតាមដែលបានកំណត់ហើយ ដូចព្រះសារីបុត្រពោលក្នុងបដិសម្ភិទាមគ្គថា បទថា **បរិ** សេចក្តីថា កំណត់ ។ បទថា **មុខំ** ដោយអត្ថថា នាំចេញ ។ បទថា **សតិ** ដោយអត្ថថា ចូលទៅតាំងទុក ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ចូរតាំងសតិចំពោះមុខ ដូច្នេះ ។ ពាក្យថា ចូរតាំងសតិចំពោះមុខ នេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ការចម្រើនកម្មដ្ឋាន គឺអានាបានស្សតិ ១៦ បែប ក្នុងសតិប្បដ្ឋាន ៤ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដែលជាសប្បាយដល់បុគ្គលមានរាគចរិត និងវិតក្កចរិត ដោយអំណាចនៃការពិចារណាកាយរឿយៗ ដោយការធ្វើទុកក្នុងចិត្តថា បដិកូល ដោយសង្ខេបប៉ុណ្ណោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងចំពោះវិបស្សនាកម្មដ្ឋានសុទ្ធៗ ទើបត្រាស់ពាក្យជាដើមថា **សព្វសង្ខារេសុ អនិច្ចានុបស្សី វិហារថ** ដូច្នេះ ។

ក្នុងវិបស្សនាកម្មដ្ឋាន គប្បីជ្រាបចតុក្កៈ ៤ នេះ គឺអនិច្ចំ ១ អនិច្ចលក្ខណៈ ១ អនិច្ចានុបស្សនា ១ អនិច្ចានុបស្សី ១ ។ ខន្ធបញ្ចកៈ ឈ្មោះថា **អនិច្ចំ** ព្រោះមានហើយ ត្រឡប់ជាមិនមាន ព្រោះប្រកបដោយការកើតឡើង និងការវិនាសទៅ ព្រោះប្រព្រឹត្តទៅមួយជួរខណៈ និងព្រោះជំទាស់នឹងនិច្ចៈ ។

អាការដែលមានហើយ ត្រឡប់ជាមិនមានឯណារបស់ខន្ធបញ្ចកៈនោះ ទុំះ ឈ្មោះថា **អនិច្ចលក្ខណៈ** ។ វិបស្សនាដែលប្រារព្ធអនិច្ចលក្ខណៈនោះប្រព្រឹត្តទៅ ឈ្មោះថា **អនិច្ចានុបស្សនា** ព្រះយោគាវចរឃើញច្បាស់នូវអនិច្ចលក្ខណៈនោះថា មិនទៀង ឈ្មោះថា **អនិច្ចានុបស្សី** ក្នុងសតិប្បដ្ឋាននេះ គួរនឹងពោលអសុភកថា ១១ យ៉ាង ឲ្យដល់នូវបឋមជ្ឈាន អានាបានកថា មានវត្ថុ ១៦ ឲ្យដល់នូវចតុត្ថជ្ឈាន និងវិបស្សនាកថា ដោយពិស្តារតែអសុភកថាជាដើមនោះ ខ្ញុំបានពោលហើយក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដោយពិស្តារគ្រប់ប្រការ ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះចុះ ។

ឥឡូវនេះ ដើម្បីសម្តែងផលវិសេសដែលគប្បីឲ្យសម្រេចដោយអសុភានុបស្សនាជាដើម ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **អសុភានុបស្សីនំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុភាយ ធាតុយា** សេចក្តីថា ក្នុងភាពជារបស់ស្អាត អធិប្បាយថា ក្នុងសុភនិមិត្ត ។ បទថា **រាគានុសយោ** បានដល់ កាមរាគានុស័យនោះ ដែលគួរដល់ការកើតឡើងព្រោះសុភារម្មណ៍ ។ កាមរាគានុស័យនោះ ព្រះយោគាវចរលះបានដោយអនាគាមិមគ្គ ដែលខ្លួនកាន់យកអសុភនិមិត្តរបស់អ្នកពិចារណាឃើញអសុភ ក្នុងអាការ ៣២ មានសក់ជាដើម ឬក្នុងសាកសពដែលហើមប៉ោងជាដើម ហើយញុំាងបឋមជ្ឈានឲ្យកើតឡើងក្នុងអសុភនិមិត្តនោះ ធ្វើបឋមជ្ឈាននោះឲ្យជាបាទ ផ្តើមចម្រើន

វិបស្សនា ហើយសម្រេច អធិប្បាយថា កាត់ផ្ដាច់ដោយអាការទាំងពួង ។ ដូចដែលព្រះមានព្រះភាគត្រាស់នៅក្នុងអង្គុត្តរនិកាយ នវកនិបាតថា គឺចម្រើនអសុភ ដើម្បីលះរាគៈ ដូច្នេះ ។

បទថា **ពាហិរា** សេចក្ដីថា អកុសលធម៌ ឈ្មោះថា ខាងក្រៅ គឺឈ្មោះថា ជាខាងក្រៅ ព្រោះជាទីតាំងនៃអារម្មណ៍ខាងក្រៅ និងមិននាំនូវប្រយោជន៍មកឲ្យ ។ បទថា **វិតក្កាសយា** បានដល់ មិច្ឆាវិតក្ក មានការត្រិះរិះក្នុងកាមជាដើម ។ មិច្ឆាវិតក្កទាំងនោះដែលមិនទាន់លះបាន និងអនុលោមតាមអាសយ គឺកិលេសដែលដេកត្រាំ ព្រះមានព្រះភាគត្រាស់ថា **វិតក្កាសយា** ព្រោះកាលមានសេចក្ដីព្រមព្រៀងនៃបច្ច័យ ក៏នឹងកើតឡើងបាន ។ ក្នុងវិតក្កទាំង ៣ នេះ កាមវិតក្ក ព្រះមានព្រះភាគទ្រង់កាន់យកហើយដោយសព្ទថា **កាមរាគ** នោះឯង ។ ព្រោះដូច្នោះ វិតក្កដ៏សេសចាកកាមវិតក្កនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកហើយ ។ បទថា **វិឃាតបក្ខិកា** សេចក្ដីថា ជាចំណែកនៃសេចក្ដីទុក្ខ គឺធ្វើការកើតឡើងនៃសេចក្ដីទុក្ខដោយអំណាចនៃការបង់បាន ។ បទថា **តេ ឆ ហោន្តិ** សេចក្ដីថា លះនូវកាមវិតក្កទាំងនោះបាន ។ មហាវិតក្ក ៩ យ៉ាង មួយអន្លើដោយកាមវិតក្ក ៨ គឺព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ ញាតិវិតក្ក ១ ជនបទវិតក្ក ១ អមរាវិតក្ក គឺត្រិះរិះដល់ទេវតា ១ អនវញ្ញត្តិបដិសំយុត្តវិតក្ក គឺវិតក្កដែលប្រកបដោយការមិនមើលងាយ ១ លាភសក្ការសិលោកបដិសំយុត្តវិតក្ក គឺវិតក្កដែលប្រកបលាភសក្ការៈ និងសេចក្ដីសរសើរ ១ បរានុទ្ទយតាបដិសំយុត្ត

វិតក្ក គឺវិតក្កដែលប្រកបដោយការអាណិតអាសូរក្នុងអ្នកដទៃ ១ ដែលសង្កត់សង្កិនបានខាងដើម ដោយសមាធិដែលកើតដោយអនាបានស្សតិ និងលះបានដោយមិនមានសេសសល់ តាមសមគួរដោយអរិយមគ្គដែលធ្វើវិបស្សនានោះឲ្យជាបាទ ហើយសម្រេច ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ នវកនិបាតថា ចម្រើនអនាបានស្សតិ ដើម្បីផ្តាច់ផ្តិលនូវវិតក្ក ដូច្នេះ ។

បទថា **យា អវិជ្ជា សា បហីយតិ** សេចក្តីថា អវិជ្ជាណាដែលបិទបាំងសភាវៈនៃសេចក្តីពិត ធ្វើនូវសេចក្តីវិនាសឲ្យសព្វយ៉ាងជាមូលនៃវដ្តទុក្ខទាំងមូល អវិជ្ជានោះ បុគ្គលពិចារណាឃើញការមិនទៀងដែលនឹងផ្តាច់ផ្តិលបាន ។ បានឮថា បទថា **យា អវិជ្ជា សា បហីយតិ** នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃព្រះទីណាស្រេចដែលជាសុខវិបស្សកៈដែលនៅចប់ព្រហ្មចរិយៈដោយអាការនៃអនិច្ចលក្ខណៈ សេចក្តីនោះ មានសេចក្តីសង្ខេបដូចតទៅនេះថា កាលព្រះយោគាវចរទាំងឡាយ ផ្តើមតាំងសមសនញ្ញាណ ឃើញនូវសង្ខារទាំងពួង ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយការមិនទៀងជាដើម វិបស្សនាដែលជាវុដ្ឋានគាមិនី ដែលប្រព្រឹត្តទៅថា មិនទៀង ដូច្នេះ បន្តបានដោយមគ្គក្នុងពេលណា ក្នុងពេលនោះ អរហត្តមគ្គក៏កើតឡើងតាមលំដាប់ កាលលោកទាំងនោះពិចារណាអនិច្ចលក្ខណៈរឿយៗក៏លះអវិជ្ជាបានដោយឥតសេសសល់ អរហត្តមគ្គវិជ្ជានឹងកើតឡើង ។ ពាក្យថា **អនិច្ចានុបស្សីនំ វិហារតំ** នេះ ព្រះមានព្រះភាគត្រាស់ដោយអនិច្ចលក្ខណៈ

ជាធម៌ប្រាកដដល់ព្រះយោគាវចរទាំងនោះ ឬដោយជាឧបាយក្នុងការកាន់យកលក្ខណៈទាំង ២ ក្រៅពីនេះ តែមិនបានត្រាស់តាមដែលព្រះយោគាវចរគប្បីពិចារណាលក្ខណៈតែម្យ៉ាងប៉ុណ្ណោះរឿយៗ សមដូចព្រះមានព្រះភាគត្រាស់ថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាជាទុក្ខ វត្ថុនោះជាអនត្តា ដូច្នេះ ។ និងដូចព្រះតម្រាស់ដែលត្រាស់ក្នុងឧទានថា ម្នាលមេឃិយៈ ព្រោះថា កាលភិក្ខុមានសេចក្តីសម្គាល់ថា មិនទៀងហើយ សេចក្តីសម្គាល់ថា មិនមែនខ្លួនរមែងតាំងនៅ ( ក្នុងចិត្ត ) ភិក្ខុដែលមានសេចក្តីសម្គាល់ថា មិនមែនខ្លួនរមែងដល់នូវការដកអស្មិមានៈ ឈ្មោះថា ដល់និព្វានក្នុងបច្ចុប្បន្ន ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **អានាបានេ បដិស្សតោ** សេចក្តីថា មានសតិចំពោះក្នុងអានាបាននិមិត្ត អធិប្បាយថា ចូលទៅតាំងសតិមាំ ។ បទថា **បស្សំ** សេចក្តីថា ឃើញនូវព្រះនិព្វានដែលជាទីរម្ងាប់នូវសង្ខារដោយញាណចក្ខុ ដែលជាទីអស់ទៅនៃអាសវៈ ។ បទថា **អាតាបី សព្វទា** សេចក្តីថា មានសេចក្តីព្យាយាមរឿយៗ ក្នុងធម៌ មានអសុភានុបស្សនាជាដើម ដោយមិនផ្អាកក្នុងរវាង គឺប្រកបហើយប្រកបទៀតជានិច្ច ។ បទថា **យតោ** បានដល់ ព្យាយាម ម្យ៉ាងទៀត បានដល់ ជាអ្នកទៀងទាត់ក្នុងធម៌នោះ គឺក្នុងព្រះនិព្វានដែលជាទីរម្ងាប់នៃសង្ខារទាំងពួងដោយសម្មត្តនិយាម រួចផុតដោយអំណាចអរហត្តផល ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕៚

**អដ្ឋកថា អសុភានុបស្សីសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ធម្មានុធម្មប្បដិបន្នសូត្រ

[ ៨៧ ] កាលបុគ្គលនិយាយថា ភិក្ខុអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ដោយសភាពដ៏សមគួរណា សភាពដ៏សមគួរនេះ ជារបស់ភិក្ខុអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ដោយសេចក្តីអធិប្បាយដូច្នេះ ឈ្មោះថា និយាយធម៌មែនពិត មិនឈ្មោះថា និយាយអធម៌ ឬឈ្មោះថា ត្រិះរិះធម៌មែនពិត មិនឈ្មោះថា ត្រិះរិះអធម៌ឡើយ លុះវៀរទាំងពីរនោះចេញ ទើបជាអ្នកព្រងើយ មានសតិសម្បជញ្ញៈ ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ ត្រិះរិះរឿយៗ
នូវធម៌ រឭករឿយៗ នូវធម៌ រមែងមិនសាបសូន្យចាក
ព្រះសទ្ធម្មឡើយ ។ ( ភិក្ខុនោះ ) ទោះបីដើរ ឬឈរ
ឬអង្គុយ ឬដេក ក៏រម្ងាប់ចិត្ត ( របស់ខ្លួន ) ក្នុងកម្មដ្ឋាន
ខាងក្នុង រមែងបានដល់ព្រះនិព្វាន ជាទីស្ងប់រម្ងាប់ ពុំ
ខានឡើយ ។ សូត្រទី ៧ ។

# អដ្ឋកថា

## ធម្មានុធម្មប្បដិបន្នសូត្រ

ក្នុងធម្មានុធម្មប្បដិបន្នសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៨៧ ] លោកុត្តរ ៩ យ៉ាង ឈ្មោះថា ធម៌ ក្នុងបទថា **ធម្មានុធម្មប្បដិបន្នស្ស** នេះ ធម៌ដែលសមគួរដល់ធម៌នោះ គឺធម៌ដែលជាបដិបទាខាងដើម មានសីលវិសុទ្ធិជាដើម ដល់អ្នកបដិបត្តិធម៌សមគួរដល់ធម៌នោះ គឺកំពុងបដិបត្តិដើម្បីសម្រេចលោកុត្តរធម៌នោះ បទថា **អយមនុធម្មោ ហោតិ** សេចក្ដីថា ធម៌នេះ ជាធម៌មានសភាពសមគួរ គឺមានសភាវៈសមគួរ ។ បទថា **វេយ្យាករណាយ** បានដល់ ដោយវាចាជាគ្រឿងពោល ។ បទថា **យំ** ក្នុងបទថា **ធម្មានុធម្មប្បដិបន្នោ យំ** នេះ **យំ** ជាបឋមាវិភត្តិ ប្រើក្នុងអត្ថតតិយាវិភត្តិ មានពាក្យអធិប្បាយថា ភិក្ខុ កាលព្យាករថា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌នោះ គួរឈ្មោះថា ព្យាករដោយប្រពៃនោះឯង ដោយធម៌ដ៏សមគួរណា ភិក្ខុនោះ មិនគួរវិញ្ញូជនតិះដៀល ព្រោះសេចក្ដីនោះជាហេតុ ។ ម្យ៉ាងទៀត បទថា **យំ** ជាកិរិយាបរាមាស ។ ដោយបទថា **យំ** នោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ការពោលធម៌នោះឯង និងការត្រិះរិះដល់ធម្មវិតក្កដូចគ្នា ដែលជាហេតុសមគួរ គឺជាហេតុសមគួរដល់វាចាជាគ្រឿងពោលថា ធម៌នេះ សមគួរដល់អ្នកបដិបត្តិធម៌ សមគួរដល់ធម៌ ធម៌នេះសមគួរយ៉ាងនោះ ដូច្នេះ ដោយឧបេក្ខាដែលសម្បយុត្តដោយញាណ ក្នុងកាលមិនមានកិច្ចទាំង ២ យ៉ាងនោះ ។ បទថា **ភាសមានោ ធម្មំយេវ ភាសេយ្យ** សេចក្ដី

ថា បើភិក្ខុពោល គប្បីពោលធម៌ គឺកថាវត្ថុ ១០ យ៉ាងនោះឯង មិនមែនពោលធម៌ដែលមានអត្ថច្រើនជាដើម ដែលផ្សេងគ្នានឹងកថាវត្ថុ ១០ យ៉ាងនោះឡើយ ព្រះមានព្រះភាគត្រាស់នៅក្នុងឧទានថា

មួយទៀត ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ គឺអប្បិច្ឆកថា ១ សន្តុដ្ឋិកថា ១ បវិវេកកថា ១ អសំសគ្គកថា ១ វិរិយារម្ភកថា ១ សីលកថា ១ សមាធិកថា ១ បញ្ញាកថា ១ វិមុត្តិកថា ១ វិមុត្តិញ្ញាណទស្សនកថា ១ ដែលជាកថាផូរផង់ជាទីសប្បាយ ទូលាយចិត្ត ប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយតែម្យ៉ាង ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងចំពោះ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វានដូច្នេះ ។

ព្រោះថា បុគ្គលមានប្រក្រតីបាននូវកថា ដែលមានការផូរផង់ប៉ុណ្ណោះទើបគួរពោលធម៌នោះ ។ បទថា **ភាសមានោ ធម្មំយេវ ភាសេយ្យ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ការដល់ព្រមដោយកល្យាណមិត្ត ។

បទថា **ធម្មវិតក្កំ** សេចក្តីថា កាលភិក្ខុត្រិះរិះដល់នេក្ខម្មវិតក្កជាដើមដែលមិនប្រាសចាកធម៌ ឧស្សាហ៍នឹងចម្រើនក្រៃលែងឡើង ដោយគិតថា អញនឹងបំពេញបដិបទា មានសីលជាដើមឲ្យបរិបូណ៌ ។ តែវិតក្កនោះ គប្បីជ្រាបថា មានច្រើនប្រភេទ ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការវៀរចាកធម៌ដែល

ជាឧបការៈ ហើយចម្រើននូវធម៌ ដែលជាឧបការៈដល់សីលជាដើម ដោយអំណាចនៃការនាំធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាសចេញ តែមិនតាំងនៅក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកនៃការមាំទាំ ញុំាងភាពជាធម៌ ដែលប្រព្រឹត្តទៅក្នុងចំណែកនៃគុណវិសេស និងភាពជាធម៌ដែលប្រព្រឹត្តទៅដោយចំណែកនៃការចាក់ធ្លុះឲ្យដល់ព្រម ។ បទថា **នោ អធម្មវិតក្កំ** សេចក្ដីថា មិនគប្បីត្រិះរិះដល់កាមវិតក្ក ។

បទថា **តទុភយំ វា បន** សេចក្ដីថា ភិក្ខុវៀរនូវការពោលធម៌ដើម្បីអនុគ្រោះពួកជនដទៃ និងការត្រិះរិះនូវធម៌ដើម្បីអនុគ្រោះពេលនេះ ដែលព្រះមានព្រះភាគត្រាស់ហើយ ។ម្យ៉ាងទៀត វៀរផ្ដាច់ គឺមិនបដិបត្តិ បានដល់ មិនធ្វើទាំង ២ យ៉ាងនោះ ។ បទថា **ឧបេក្ខកោ** សេចក្ដីថា ជាកណ្ដាលក្នុងបដិបទាយ៉ាងនោះ ចម្រើនចំពោះសមថភាវនា និងវិបស្សនាភាវនាប៉ុណ្ណោះ ។ម្យ៉ាងទៀត ជាអ្នកព្រងើយកន្តើយក្នុងកិច្ចបដិបត្តិសមថៈ ធ្វើវិបស្សនាកម្មដ្ឋានតែម្យ៉ាង គឺញុំាងវិបស្សនាឲ្យខ្ពស់ឡើង ព្រងើយកន្តើយក្នុងវិបស្សនានោះដោយអំណាចនៃសង្ខារុបេក្ខាញាណ គប្បីជាអ្នកមានសតិសម្បជញ្ញៈដោយវិបស្សនានោះ និងជាញាណចាស់ក្លា រឹងប៉ឹង ផូរផង់ ហូរទៅរហូតដល់វិបស្សនាញាណ ត្រូវបន្តដោយមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ ភិក្ខុ ឈ្មោះថា **ធម្មា-រាមោ** ព្រោះមានធម៌ គឺសមថៈ និងវិបស្សនាជាទីមកត្រេកអរ ដោយអត្ថថាគួរត្រេកអរ ។ ឈ្មោះថា **ធម្មរតោ** ព្រោះត្រេកអរហើយក្នុងធម៌នោះឯង ។

ឈ្មោះថា **ធម្មំ អនុវិចិន្តយំ** ព្រោះពិចារណាក្នុងធម៌នោះរឿយៗ គឺរឭកដល់ធម៌នោះ អធិប្បាយថា ធ្វើទុកក្នុងចិត្ត ។ បទថា **អនុស្សរំ** សេចក្តីថា រឭកដល់ធម៌នោះឯងរឿយៗ ដោយអំណាចនៃភាវនាដែលខ្ពស់ឡើង ។ ម្យ៉ាងទៀត ឈ្មោះថា **ធម្មារាមោ** ព្រោះមានធម៌ មានសីលជាដើមជាទីមកត្រេកអរ ដោយអត្ថថា ត្រូវត្រេកអរដោយអំណាចនៃការតាំងនៅក្នុងសីល ដែលជាប្រភពកើតនៃវិមុត្តិ ហើយសម្តែងដល់អ្នកដទៃ ឈ្មោះថា **ធម្មរតោ** ព្រោះត្រេកអរហើយ គឺត្រេកអរក្រៃលែងហើយក្នុងធម៌នោះយ៉ាងនោះឯង ។ ភិក្ខុកាលស្វែងរកការប្រព្រឹត្តទៅនៃធម៌ទាំងឡាយ មានសីលជាដើមទាំងនោះឯង ឈ្មោះថា **ធម្មំ អនុវិចិន្តយំ** ព្រោះគ្នេរគ្នន់ក្នុងធម៌ មាននេក្ខម្មសង្កប្បជាដើម ដោយមិនឲ្យនូវឱកាសដល់កាមវិតក្កឡើយ ។ ម្យ៉ាងទៀត ភិក្ខុកាលដុតវិតក្កទាំង ២ យ៉ាងនោះ ( កាមវិតក្ក ព្យាបាទវិតក្ក ) ដែលជាវិតក្កគ្រោតគ្រាតព្រងើយហើយ រឭកដល់រឿយៗ នូវធម៌ គឺសមថៈ និងវិបស្សនានោះឯង ដោយអំណាចនៃភាវនាដែលខ្ពស់ជាលំដាប់ គឺឲ្យប្រព្រឹត្តទៅដោយអំណាចនៃការចម្រើន ។ បទថា **សទ្ធម្មា** សេចក្តីថា មិនសាបសូន្យចាកពោធិ-បក្ខិយធម៌ដែលចែកប្រភេទចេញជា ៣៧ ប្រការ និងចាកលោកុត្តរធម៌ ៩ ប្រការ អធិប្បាយថា មិនយូរ ក៏នឹងបានសម្រេចលោកុត្តរធម៌នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងវិធីនៃការរឭកដល់ធម៌នោះ ទើបត្រាស់ពាក្យជាដើមថា **ចរំ វា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចរំ វា** សេចក្តីថា ដើរទៅដោយអំណាច

នៃការត្រាច់ភិក្ខាចារ ឬដោយអំណាចនៃការចង្ក្រម ។ បទថា **យទិ វា តិដ្ឋំ** បានដល់ ឈរក្តី អង្គុយក្តី ។ បទថា **ឧទ វា សយំ** បានដល់ ដេកក្តី ។ តាំងនៅក្នុងឥរិយាបថទាំង ៤ យ៉ាងនេះ ។ បទថា **អជ្ឈត្តំ សមយំ ចិត្តំ** សេចក្តីថា ញុំាងចិត្តរបស់ខ្លួនឲ្យដល់ព្រមនូវការសម្រេចខាងក្នុងអារម្មណ៍ ពោល គឺកម្មដ្ឋាន តាមដែលពោលមកហើយ ដោយអំណាចនៃការរម្ងាប់ គឺដោយអំណាចនៃការលះកិលេសទាំងឡាយ មានរាគៈជាដើម ។ បទថា **សន្តិមេវាធិគច្ឆតិ** សេចក្តីថា ដល់នូវសេចក្តីស្ងប់ដោយចំណែកមួយ គឺព្រះនិព្វាននោះឯង ។

**អដ្ឋកថា ធម្មានុធម្មប្បដិបន្នសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អន្ធករណសូត្រ

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្ក ៣ យ៉ាងនេះ ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ ។ អកុសលវិតក្ក ៣ តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺកាមវិតក្ក ( សេចក្តីត្រិះរិះប្រកបដោយកាម ) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន

១ ។ ម្នាលភិក្ខុទាំងឡាយ ព្យាបាទវិតក្ក ( សេចក្តីត្រិះរិះប្រកបដោយព្យាបាទ ) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ វិហឹសាវិតក្ក ( សេចក្តីត្រិះរិះប្រកបដោយការបៀតបៀន ) ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្ក ៣ យ៉ាងនេះឯង ធ្វើឲ្យងងឹត ធ្វើមិនឲ្យមានបញ្ញាចក្ខុ ធ្វើមិនឲ្យមានញាណ ធ្វើបញ្ញាឲ្យរលត់ ជាចំណែកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ កុសលវិតក្ក ៣ យ៉ាងនេះ មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចម្រើន មិនមែនជាចំណែកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ។ កុសលវិតក្ក ៣ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺនេក្ខម្មវិតក្ក ( សេចក្តីត្រិះរិះប្រកបដោយការចេញចាកកាម ) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចម្រើន មិនមែនជាចំណែកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អព្យាបាទវិតក្ក ( សេចក្តីត្រិះរិះមិនប្រកបដោយព្យាបាទ ) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចម្រើន មិនមែនជាចំណែកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ អវិហឹសាវិតក្ក ( សេចក្តីត្រិះរិះមិន

ប្រកបដោយការបៀតបៀន ) មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចម្រើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ កុសលវិតក្ក ៣ យ៉ាងនេះឯង មិនធ្វើឲ្យងងឹត ធ្វើឲ្យមានបញ្ញាចក្ខុ ធ្វើឲ្យមានញាណ ធ្វើបញ្ញាឲ្យចម្រើន មិនមែនជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ។

បុគ្គល គប្បីត្រិះរិះនូវកុសលវិតក្កទាំង ៣ យ៉ាងទៀត គប្បីលះបង់នូវអកុសលវិតក្កទាំង ៣ ចេញ បុគ្គលនោះឈ្មោះថា រម្ងាប់នូវវិតក្ក និងវិចារៈបាន ដូចទឹកភ្លៀង កាលរម្ងាប់ធូលី ដែលតាំងឡើងដូច្នោះដែរ បុគ្គលនោះមានចិត្តជាគ្រឿងរម្ងាប់វិតក្ក ឈ្មោះថា បានដល់ដោយប្រពៃនូវសន្តិបទ គឺព្រះនិព្វានក្នុងបច្ចុប្បន្ននេះឯង ។

សូត្រទី ៨ ។

# អដ្ឋកថា

## អន្ធករណសូត្រ

ក្នុងអន្ធករណសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ

[ ៨៨-៨៩ ] បទថា **អកុសលវិតក្កា** បានដល់ វិតក្កទាំងឡាយដែលកើតអំពីការមិនឈ្លាស ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **អន្ធករណា** ដូចតទៅនេះ វិតក្ក ឈ្មោះថា ធ្វើនូវការងងឹត ព្រោះកើតឡើងឯងដល់បុគ្គលណា នឹងធ្វើបុគ្គលនោះឲ្យខ្វាក់ ព្រោះហាមការឃើញនូវសេចក្ដីពិត ។ ឈ្មោះថា **អចក្ខុករណា** ព្រោះមិនធ្វើឲ្យកើតបញ្ញាចក្ខុ ឈ្មោះថា **អញ្ញាណករណា** ព្រោះធ្វើនូវការមិនដឹង ។ បទថា **បញ្ញានិរោធិកា** សេចក្ដីថា ឈ្មោះថា ញុំាងបញ្ញាឲ្យរលត់ ព្រោះរលត់បញ្ញា ៣ យ៉ាង គឺកម្មស្សកតាបញ្ញា ១ ឈានបញ្ញា ១ វិបស្សនាបញ្ញា ១ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **វិឃាតបក្ខិកា** ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃវិឃាតពោល គឺទុក្ខ ព្រោះឲ្យផលមិនគួរប្រាថ្នា ។ ឈ្មោះថា **អនិព្វានសំវត្តនិកា** ព្រោះមិនញុំាងការរលត់កិលេសឲ្យប្រព្រឹត្តទៅ ។ បទថា **កាមវិតក្កោ** បានដល់ វិតក្កដែលបដិសំយុត្តដោយកាម អធិប្បាយថា កាមវិតក្កនោះ ជាវិតក្កដែលប្រកបដោយកិលេសកាម ប្រព្រឹត្តទៅក្នុងវត្ថុកាម ។ វិតក្កដែលបដិសំយុត្តដោយព្យាបាទ ឈ្មោះថា **ព្យាបាទវិតក្កោ** ។ វិតក្កដែលបដិសំយុត្តដោយវិហិង្សា ឈ្មោះថា **វិហឹសាវិតក្កោ**។ វិតក្កទាំង ២ យ៉ាងនេះ គឺកាមវិតក្ក និងព្យាបាទវិតក្ក កើតឡើងក្នុងសត្វខ្លះ ក្នុងសង្ខារខ្លះ អធិប្បាយថា

កាមវិតក្កកើតឡើង ដល់បុគ្គលអ្នកត្រិះរិះ ដល់សត្វ ឬសង្ខារដែលជាទីស្រឡាញ់ ជាទីពេញចិត្ត ។ ព្យាបាទវិតក្ក កើតឡើងក្នុងសត្វ ឬសង្ខារដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត តាំងអំពីពេលដែលក្រោធហើយសម្លឹងមើលរហូតដល់ឲ្យវិនាសទៅ ។ វិហិង្សាវិតក្ក មិនកើតឡើងក្នុងសង្ខារទាំងឡាយ ព្រោះថា ធម្មតាសង្ខារដែលនឹងឲ្យកើតទុក្ខមិនមាន តែកើតឡើងក្នុងសត្វទាំងឡាយ ក្នុងពេលដែលគិតថា សូមសត្វទាំងឡាយលំបាកខ្លះ ត្រូវសម្លាប់ខ្លះ ដាច់សូន្យខ្លះ វិនាសខ្លះ ចូរអន្តរធានខ្លះ ។

សេចក្តីត្រិះរិះក្នុងកាមជាដើម គឺកាមវិតក្កជាដើមនោះ អធិប្បាយថា ដោយអត្ថ កាមវិតក្កជាដើម និងកាមសង្កប្បជាដើម មិនប្លែកគ្នាឡើយ ។ ចំណែកសញ្ញាដែលសម្បយុត្តដោយកាមជាដើមនោះ ឈ្មោះថា កាមសញ្ញាជាដើម ព្រោះការបែកគ្នានៃកាមធាតុជាដើម និងគប្បីរកបាន ព្រោះមកហើយក្នុងព្រះបាលី ( វិភង្គ ) ថា

សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្តដែលប្រកបដោយកាម ។បេ។ មិច្ឆាសង្កប្បនេះ ហៅថា កាមធាតុ ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយព្យាបាទ គឺ មិច្ឆាសង្កប្ប នេះហៅថា ព្យាបាទធាតុ ។បេ។ ភាពនៃចិត្តមិនត្រេកអរ ក្នុងអាឃាតវត្ថុ ១០ នេះ ហៅថា ព្យាបាទធាតុ ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយវិហឹសា គឺមិច្ឆាសង្កប្ប នេះហៅថា វិហឹសាធាតុ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ បៀតបៀនពួកសត្វ

ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយខ្សែក្តី ។បេ។ នេះហៅថា វិហឹសាធាតុ ។

១- សេចក្តីពិស្តារ មើលក្នុង បិ.៨០ ទំ. ១៦១ ។

ដូច្នោះកថា ២ យ៉ាង ក្នុងកាមធាតុទាំងនោះ លោកចងក្រង មិនលាយឡំគ្នា បណ្តាធាតុទាំង ៣ នោះ កាលកាន់យកកាមធាតុ ធាតុទាំង ២ ក្រៅពីនេះ ឈ្មោះថា រមែងកាន់យកហើយផងដែរ តែកាលទ្រង់ចេញអំពីកាមធាតុនោះឯង ទ្រង់ក៏បង្អុលបានថា នេះជាព្យាបាទធាតុ នេះជាវិហិង្សាធាតុ ដូច្នោះ ទើបកថានេះ ឈ្មោះថា **សព្វសង្គាហិកា** ។ តែព្រះមានព្រះភាគ ត្រាត្រាស់ដល់កាមធាតុ ទ្រង់ក៏ដាក់ព្យាបាទធាតុក្នុងតំណែងនៃព្យាបាទធាតុ ដាក់វិហិង្សាធាតុក្នុងតំណែងវិហិង្សាធាតុ ដោយត្រាស់ប្រាប់ធាតុដ៏សេសថា ឈ្មោះថាជាកាមធាតុ ដូច្នោះ ទើបកថានេះ ឈ្មោះថា **អសម្ភិន្នកថា** ។

គប្បីជ្រាបអត្ថក្នុងធម៌ចំណែក-សដោយបរិយាយ ដែលញែកចេញតាមដែលពោលហើយដូចតទៅនេះ វិតក្កដែលបដិសំយុត្តដោយនេក្ខម្មៈ ឈ្មោះថា **នេក្ខម្មវិតក្កោ** ។ នេក្ខម្មវិតក្កនោះ ជាកាមាវចរក្នុងចំណែកខាងដើមដែលចម្រើនអសុភ ជារូបាវចរក្នុងឈានដែលមានអសុភជាអារម្មណ៍ ជាលោកុត្តរក្នុងពេលមគ្គផលកើតឡើង ព្រោះធ្វើឈាននោះឲ្យជាបាទ វិតក្កដែលបដិសំយុត្ត ដោយការមិនព្យាបាទ ឈ្មោះថា **អព្យាបាទវិតក្កោ** ។ អព្យាបាទវិតក្កនោះ ជាកាមាវចរក្នុងចំណែកខាងដើម ដែលចម្រើនមេត្តា ជារូបាវចរក្នុងឈាន មានមេត្តាជាអារម្មណ៍ ជាលោកុត្តរ ក្នុងកាលដែលមគ្គផលកើតឡើង

ព្រោះធ្វើឈាននោះឲ្យជាបាទ ។ វិតក្កដែលបដិសំយុត្តដោយអវិហិង្សា ឈ្មោះថា **អវិហិង្សាវិតក្កោ។** អវិហិង្សាវិតក្កនោះ ជាកាមាវចរក្នុងចំណែកខាងដើមដែលចម្រើនករុណា ជារូបាវចរក្នុងឈាន ដែលមានករុណាជាអារម្មណ៍ ជាលោកុត្តរក្នុងពេលដែលមគ្គផលកើតឡើង ព្រោះធ្វើឈាននោះឲ្យជាបាទ តែកាលណាអលោភៈជាប្រធាន កាលនោះ មេត្តា និងករុណាទាំង ២ ក្រៅអំពីនេះ ក៏ត្រូវអនុលោមតាមអលោភៈនោះ កាលណាមេត្តាជាប្រធាន កាលនោះ អលោភៈ និងករុណាទាំង ២ ក្រៅអំពីនេះ ក៏ត្រូវអនុលោមតាមមេត្តានោះ កាលណាករុណាជាប្រធាន កាលនោះ អលោភៈ និងមេត្តាទាំង ២ ក្រៅអំពីនេះ ក៏ត្រូវអនុលោមតាមករុណានោះ ។ នេក្ខម្មសង្កប្បជាដើម គឺនេក្ខម្មវិតក្កជាដើមនោះឯង អធិប្បាយថា ដោយអត្ថហើយ នេកម្មវិតក្កជាដើម និងនេក្ខម្មសង្កប្បជាដើម មិនមានការផ្សេងគ្នាឡើយ តែសញ្ញាដែលសម្បយុត្តដោយនេក្ខម្មវិតក្កជាដើម ឈ្មោះថា នេក្ខម្មសញ្ញាជាដើម ។

ព្រោះនេក្ខម្មធាតុជាដើម មានការផ្សេងគ្នា ព្រោះមានមកក្នុងព្រះបាលី ( វិភង្គ ) ថា

សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ តម្រិះត្រូវដែលប្រកបដោយនេក្ខម្មៈ គឺសម្មាសង្កប្ប នេះហៅថា នេក្ខម្មធាតុ ។ មួយទៀត កុសលធម៌ទាំងអស់ ក៏ឈ្មោះថា នេក្ខម្មធាតុដែរ ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយអព្យាបាទ គឺសម្មាសង្កប្ប នេះហៅថា អព្យាបាទធាតុ ។ ការស្រឡាញ់ អាការ

ប្រព្រឹត្តស្រឡាញ់ ភាពនៃអាការប្រព្រឹត្តស្រឡាញ់ គឺមេត្តាចេតោ-វិមុត្តិណា ក្នុងពួកសត្វ នេះហៅថា អព្យាបាទធាតុដែរ ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ គឺសម្មាសង្កប្ប នេះហៅថា អវិហឹសាធាតុ ។ ការអាណិត អាការប្រព្រឹត្តអាណិត ភាពនៃអាការប្រព្រឹត្តអាណិត គឺករុណា ចេតោវិមុត្តិណា ក្នុងសត្វទាំងឡាយ នេះហៅថា អវិហឹសាធាតុដែរ ដូច្នេះ ។

ក្នុងសុក្កបក្ខនេះ កថាទាំង ២ យ៉ាង គឺសព្វសង្គាហិកកថា អសម្ភិន្នកថា គប្បីជ្រាបតាមន័យដែលពោលមកហើយនោះឯង ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **វិតក្កយេ** បានដល់ ក្នុងពួក ៣ នៃវិតក្ក ។ បទថា **និរាករេ** សេចក្តីថា ចេញចាកសន្តានរបស់ខ្លួន គឺគប្បីបន្ទោបង់ អធិប្បាយថា គប្បីលះ ។ បទថា **សវេ វិតក្កានិ វិចារិតានិ សមេតិ វុដ្ឋីវ រជំ សមូហតំ** សេចក្តីថា ឧបមាដូចខែក្នុងចុងរដូវក្តៅ កាលភ្លៀងពុំធ្លាក់ចុះមក ភ្លៀងនឹងឲ្យធូលីដែលគរលើផែនដី ដែលខ្យល់បក់ឡើងទៅឲ្យស្ងប់បានមួយរំពេច យ៉ាងណា ព្រះ-យោគាវចរនោះ ក៏ដូច្នោះដូចគ្នា នឹងឲ្យវិតក្កអន្ទោលទៅក្នុងមិច្ឆាវិតក្ក និងវិចារៈដែលសម្បយុត្តដោយវិតក្កនោះស្ងប់ គឺរម្ងាប់បាន បានដល់ ដាច់ទៅហើយ ព្រះយោគាវចរនោះ មានចិត្តស្ងប់ចាកវិតក្ក គឺមានអរិយមគ្គចិត្ត ដែលឈ្មោះថា ស្ងប់ហើយចាកវិតក្ក ព្រោះរម្ងាប់មិច្ឆាវិតក្កគ្រប់យ៉ាងបាន ទើបបានដល់

គឺបានសម្រេចសន្តិបទ គឺព្រះនិព្វានក្នុងលោកនេះឯង គឺក្នុងបច្ចុប្បន្ននេះឯង ។

**អដ្ឋកថា អនុត្តរិយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អន្តរាមលសូត្រ

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុងនេះ មាន ៣ យ៉ាង ។ ធម៌ ៣ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ លោភៈជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសៈ ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាខ្មាំងខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាមន្ទិលខាងក្នុង មិនមែនជាមិត្តខាងក្នុង ជាអ្នកសម្លាប់ខាងក្នុង ជាសឹកសត្រូវខាងក្នុង មាន ៣ យ៉ាងនេះឯង ។ លោភៈ ជាធម៌ញុំាងសេចក្តីវិនាសឲ្យកើត លោភៈ ជាធម៌ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះឡើយ ។ បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌ សេចក្តី

លោភ គ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកម្លាំង ក៏កើតឡើងក្នុងកាលនោះ ។ លុះតែបុគ្គលណា បានលះបង់សេចក្ដីលោភហើយ ទើបមិនជាប់ចិត្តក្នុងអារម្មណ៍ ដែលគួរជាប់ចិត្ត សេចក្ដីលោភ ដែលអរិយមគ្គកម្ចាត់បង់ចាកបុគ្គលនោះ ដូចតំណក់ទឹកដែលរមៀលចេញអំពីស្លឹកឈូក ដូច្នោះឯង ។ ទោសៈ ជាធម៌ញុំាងសេចក្ដីវិនាសឲ្យកើត ទោសៈ ជាធម៌ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះ ។ ជនអ្នកប្រទូស្ត រមែងមិនស្គាល់ប្រយោជន៍ ជនអ្នកប្រទូស្ត រមែងមិនឃើញធម៌ ទោសៈ គ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកម្លាំង ក៏កើតឡើង ក្នុងកាលនោះ ។ លុះតែបុគ្គលណា បានលះបង់ទោសៈហើយ ទើបមិនប្រទូស្តក្នុងអារម្មណ៍ដែលគួរប្រទូស្ត ទោសៈ ដែលអរិយមគ្គកម្ចាត់បង់ហើយចាកបុគ្គលនោះ ដូចជាផ្លែត្នោតទុំ ដែលជ្រុះចាកទង ដូច្នោះឯង ។

មោហៈជាធម៌ញុំាងសេចក្ដីវិនាសឲ្យកើត មោហៈជាធម៌ញុំាងចិត្តឲ្យកម្រើក ភ័យកើតហើយខាងក្នុងចិត្ត ជនមិនដឹងនូវភ័យនោះ ។ ជនអ្នកវង្វេង រមែងមិនស្គាល់ប្រយោជន៍ ជនអ្នកវង្វេង រមែងមិនឃើញធម៌ មោហៈគ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកម្លាំង ក៏កើតឡើងក្នុងកាលនោះ ។ លុះតែបុគ្គលណា បានលះបង់មោហៈហើយ ទើបមិនវង្វេងក្នុងអារម្មណ៍ ដែលគួរវង្វេង បុគ្គលនោះ រមែងកម្ចាត់បង់នូវមោហៈ

*ទាំងពួង ( ដោយមគ្គទី ៤ ) ដូចជាព្រះអាទិត្យ កាល*

*រះឡើង កម្ចាត់បង់ងងឹត ដូច្នោះឯង ។ សូត្រទី ៨ ។*

# អដ្ឋកថា

## អន្តរាមលសូត្រ

*ក្នុងអន្តរាមលសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

[ *៩០* ] **អន្តរា** *សទ្ទ ក្នុងបទថា* **អន្តរាមលា** *នេះ មកក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា ជនទាំងឡាយរមែងប្រជុំសន្ទនា* **នទីតីរេសុ សណ្ឋាណេ សភាសុ រថិយាសុ ច ជនា សង្គម្ម មន្តេន្តិ មញ្ច តញ្ច កិមន្តរំ** *ជនទាំងឡាយមកប្រជុំនិយាយគ្នា ទៀបច្រាំងស្ទឹងទាំងឡាយផង ក្នុងរោងសម្រាប់សម្រាកផង ក្នុងរោងសម្រាប់ប្រជុំគ្នានិយាយផង នាផ្លូវច្រកផង ហើយនិយាយចំពោះខ្ញុំផង ចំពោះលោកផង តើព្រោះហេតុអ្វី ដូច្នេះ ។*

*មានមកក្នុងអត្ថថា ខណៈ ដូចក្នុងប្រយោគជាដើមថា* **អទ្ទសា ខោ មំ ភន្តេ អញ្ញតរា ឥត្ថី វិជ្ជន្តរិកាយ ភាជនំ ធោវន្តិ** *បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជន៍បានឃើញខ្ញុំព្រះអង្គ ក្នុងពេល ( ខណៈ ) មានផ្លេកបន្ទោរ ដូច្នេះ ។*

*មកក្នុងអត្ថថា ចន្លោះ ដូចក្នុងប្រយោគជាដើមថា* **អបិចាយំ ភិក្ខវេ តបោទាទ្វិន្នំ មហានិរយានំ អន្តរិកាយអាគច្ឆតិ** *ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ*

ស៊ីងតាបោទានេះ ហូរមកតាមចន្លោះនៃមហានរកទាំងពីរ ។

មកក្នុងអត្ថថា សំពត់ដណ្តប់ ដូចក្នុងប្រយោគជាដើមថា **បីតវត្ថេ បីតធជេ បីតាលង្ការភូសិតេ បីតន្តរាហិ វគ្គូហិ អបិលន្ធាវ សោភសិ ។** ម្នាលនាងមានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងអលង្ការលឿង នាង បើទុកជាមិនប្រដាប់ដោយសំពត់ស្បៀក មានពណ៌លឿងទាំងឡាយ មានសាច់ដ៏ល្អិតក៏ដោយ ក៏នៅតែល្អ ... ដូច្នេះ ។

មកក្នុងអត្ថថា ចិត្ត ដូចក្នុងប្រយោគជាដើមថា **យស្សន្តរតោ ន សន្តិ កោបា** ការកម្រើក មិនមានកង្វិតរបស់បុគ្គលណា ដូច្នេះ ។

ក្នុងទីនេះ គប្បីជ្រាបថា **អន្តរា** សព្ទ មកក្នុងអត្ថថា ចិត្តនោះឯង ព្រោះដូច្នោះ អកុសលធម៌ទាំងនោះ ឈ្មោះថា **អន្តរា** ព្រោះមានខាងក្នុង គឺចិត្ត ។ ឈ្មោះថា ជាមន្ទិល ព្រោះធ្វើនូវការសៅហ្មងឲ្យដល់សន្តានដែលមន្ទិលនោះកើតឡើង ។

ឈ្មោះថា **មលា** ក្នុងបទថា **អន្តរា មលា** នោះ មន្ទិល មាន ២ យ៉ាង គឺមន្ទិលនៃរាងកាយ ១ មន្ទិលនៃចិត្ត ១ ក្នុងមន្ទិល ២ យ៉ាងនោះ មន្ទិលនៃរាងកាយ បានដល់ ញើសក្អែលជាដើម កើតហើយក្នុងរាងកាយ និងលម្អងធូលីដែលអណ្តែតមកជាប់ត្រង់រាងកាយនោះ មន្ទិលនោះ នឹងនាំចេញទៅបានដោយទឹក តែសង្កិលេស មិនដូច្នោះឡើយ ព្រោះសង្កិលេសជាដើម ជាមន្ទិលនៃចិត្ត ជម្រះចោលបានដោយអរិយមគ្គប៉ុណ្ណោះ សមដូចបុរាណាចារ្យពោលពាក្យនេះថា

ព្រះមានព្រះភាគ ជាមហាឥសី មិនបានត្រាស់ថា កាលរូបសៅហ្មងហើយ សត្វទាំងឡាយក៏សៅហ្មង កាលរូបបរិសុទ្ធហើយសត្វទាំងឡាយក៏បរិសុទ្ធ តែព្រះមហេសីត្រាស់ថា កាលចិត្តសៅហ្មងហើយ សត្វទាំងឡាយក៏សៅហ្មង កាលចិត្តបរិសុទ្ធហើយ សត្វទាំងឡាយ ក៏សបរិសុទ្ធ ដូច្នេះ ។

ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ ខន្ធ-វារវគ្គថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្តរមែងជ្រោកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធដូច្នេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា គប្បីបដិបត្តិដើម្បីជម្រះមន្ទិលនៃចិត្ត ទើបត្រាស់ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយមន្ទិលនៃចិត្ត មាន ៣ យ៉ាង ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ថា អកុសលមូល មានលោភៈជាដើមនេះ កើតឡើងហើយក្នុងចិត្តរបស់សត្វទាំងឡាយ នឹងធ្វើសេចក្តីសៅហ្មងឲ្យគឺនឹងបន្ថែមនូវការសៅហ្មងច្រើនប្រការ ព្រោះដូច្នោះ ទើបឈ្មោះថា ជាមន្ទិលនៃចិត្ត យ៉ាងណា លោភៈជាដើមក៏យ៉ាងនោះ កាលកើតឡើងក្នុងសត្វនោះឯង នឹងនាំអនត្ថៈច្រើនប្រភេទមកឲ្យ នឹងឲ្យកើតទុក្ខច្រើនប្រការដល់សត្វទាំងឡាយ ដូចអមិត្រ និងសត្រូវ ដែលបរិភោគរួមគ្នា ដេករួមគ្នា ក៏អន្តរាយសម្លឹងឱកាស ដូច្នោះ ទើបត្រាស់ពាក្យជាដើមថា **អន្តរា អមិត្តោ** ដូច្នេះ ។

ក្នុងបណ្តាអមិត្រជាដើមនោះ ឈ្មោះថា **អមិត្តា** ព្រោះផ្ទុយគ្នានឹងមិត្រ

ឈ្មោះថា **សបត្តា** ព្រោះធ្វើកិច្ចរបស់សត្រូវ ឈ្មោះថា **វធកា** ព្រោះបៀត បៀន ឈ្មោះថា **បច្ចត្ថិកា** ព្រោះជាសត្រូវដោយត្រង់ ។ ក្នុងពាក្យថា **អន្តរា អមិត្តា** នេះ គប្បីជ្រាបកិលេស មានលោភៈជាដើម ជាអមិត្រជាដើម ដោយអាការ ២ យ៉ាង អធិប្បាយថា បុគ្គលមានពៀរ កាលបានទូវឱកាស ក៏កាត់ក្បាលរបស់អ្នកមានពៀរដោយសស្ត្រាខ្លះ ញុំាងអនត្ថៈយ៉ាងធំ ឲ្យកើតឡើងដោយឧបាយខ្លះ លោភៈជាដើមនេះ នឹងញុំាងអនត្ថៈបែបនោះ ឬមានកម្លាំងច្រើនជាងនោះឲ្យកើតឡើង ដោយការកាត់ក្បាល គឺបញ្ញា ១ ដោយប្រគល់កំណើតឲ្យ ១ សេចក្តីនេះដូចម្តេច អធិប្បាយថា កាលឥដ្ឋារម្មណ៍ជាដើម មកកាន់គន្លងចក្ខុទ្វារ សេចក្តីលោភជាដើម នឹងប្រារព្ធឥដ្ឋារម្មណ៍ជាដើម ទាំងនោះកើតតាមខ្វូរ ដោយហេតុត្រឹមប៉ុណ្ណេះ ក្បាល គឺបញ្ញារបស់បុគ្គលនោះ ក៏ឈ្មោះថា ត្រូវដកហើយ សូម្បីក្នុងសោតទ្វារជាដើម ក៏មានន័យដូចគ្នា ។ គប្បីជ្រាបការប្រឡូកប្រឡំគ្នានៃអមិត្រជាដើម ដោយការដកនូវក្បាល គឺបញ្ញា ដូចពណ៌នាមកនេះ តែលោភៈជាដើម ដែលជាអកុសល មានកម្មជាហេតុ និងនាំទៅកាន់កំណើតទាំង ៤ មានអណ្ឌជកំណើតជាដើមជាប្រភេទ ភ័យធំ ២៥ ប្រការ មានការចូលទៅកាន់កំណើតជាមូល និងកម្មករណៈ ៣២ ប្រការ នឹងមកដល់បុគ្គលនោះឯង ។ ការប្រឡូកប្រឡំគ្នានៃអមិត្រជាដើមរបស់កិលេស មានលោភៈទាំងនោះជាដើម គប្បីជ្រាបដោយការប្រគល់កំណើត ៤ ឲ្យដោយប្រការដូច្នេះ ។ ដូច្នោះ ទើបលោភៈជាដើមទ្រង់បានត្រាស់ហើយ ដោយពាក្យជាដើមថា **អន្តរា អមិត្តា** ព្រោះប្រឡូកប្រឡំគ្នានៃអមិត្រជាដើម និង

ព្រោះជាធម៌ដែលកើតឡើងក្នុងចិត្ត ម្យ៉ាងទៀត លោភៈជាដើម រមែងធ្វើបាន នូវវត្ថុ ដែលអមិត្រមិនអាចធ្វើបាន និងភាពជាអមិត្រជាដើម ក៏កើតអំពី សេចក្តីលោភជាដើម ព្រោះដូច្នោះ គប្បីជ្រាបភាពដែលអកុសលធម៌ទាំងនោះ មិនមែនជាមិត្រជាដើម សមដូចព្រះតម្រាស់ត្រាស់ក្នុងធម្មបទថា

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេក ឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយ ដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាង សេចក្តីវិនាសនោះទៅទៀត ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថាទាំងឡាយដូចតទៅនេះថា សេចក្តីលោភ ឈ្មោះថា **អនត្ថជននោ** ព្រោះញ៉ាំងអនត្ថៈឲ្យកើតឡើងដល់ខ្លួន និងអ្នកដទៃ មានព្រះតម្រាស់ដែលត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាតថា

បុគ្គលអ្នកលោភ តែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះ ក៏ជាអកុសលដែរ បុគ្គលអ្នកលោភ ត្រូវ លោភៈគ្របសង្កត់ មានចិត្តត្រូវលោភៈរួបរឹត តែងរករឿង បង្ក ទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការ តិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញ ជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុ នោះ ហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយ

ដ៏លាមកជាច្រើន កើតអំពីលោភៈ មានលោភៈជាដើមហេតុ មានលោភៈជាប្រភព មានលោភៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រមដោយប្រការដូច្នេះ ។

សូម្បីពាក្យដទៃដែលទ្រង់ត្រាស់ក្នុងអង្គុត្តរនិកាយ តិកនិបាត ក៏មានដូច្នេះថា

ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ រមែងទទួលទុក្ខទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តខ្លះ ... ដូច្នេះ ។

បទថា **ចិត្តប្បកោបនោ** សេចក្តីថា ញុំាងចិត្តឲ្យញាប់ញ័រ អធិប្បាយថា លោភៈ កាលកើតឡើងក្នុងវត្ថុដែលជាទីតាំងនៃសេចក្តីលោភ នឹងញុំាងចិត្តឲ្យញាប់ញ័រ ឲ្យកម្រើក ឲ្យប្រែប្រួលទៅ ឲ្យដល់នូវពិការកើតឡើង មិនឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃសេចក្តីជ្រះថ្លាជាដើម ។ បទថា **ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ** សេចក្តីថា ពាលមហាជននេះ មិនដឹង គឺមិនស្គាល់វត្ថុនោះ ពោល គឺលោភៈដែលកើតឡើងក្នុងរវាង គឺខាងក្នុង បានដល់ ក្នុងចិត្តរបស់ខ្លួននោះឯង ថាជាភ័យ គឺជាហេតុនៃភ័យ មានការកើតអនត្ថៈ ការកម្រើកនៃចិត្តជាដើម ។ បទថា **លុទ្ធោ អត្ថំ ន ជានាតិ** សេចក្តីថា បុគ្គលដែលលោភហើយ រមែងមិនដឹងអត្ថ គឺប្រយោជន៍ មានប្រយោជន៍

ខ្លួន និងប្រយោជន៍អ្នកដទៃជាដើម តាមសេចក្ដីពិត ។ បទថា **ធម្មំ ន បស្សតិ** សេចក្ដីថា បុគ្គលដែលលោភហើយ គឺត្រូវសេចក្ដីលោភគ្របសង្កត់ហើយ មានចិត្តត្រូវលោភចោមរោមហើយ រមែងមិនឃើញ គឺមិនដឹងដោយប្រចក្ស នូវធម៌ដែលជាផ្លូវនៃកុសលកម្មបថ ១០ នឹងពោលទៅថ្វីដល់ការបានឃើញ ឧត្តរិមនុស្សធម្មនោះ ។ ព្រះមានព្រះភាគបានត្រាស់ក្នុងអង្គុត្តរនិកាយ តិក-និបាតថា

> ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាង ... ដូច្នេះជាដើម ។

បទថា **អន្ធតមំ** បានដល់ ការងងឹតដែលធ្វើនូវការខ្វាក់ ។ បទថា **យំ** ស្មើគ្នានឹង **យត្ថ** ប្រែថា ក្នុងកាលណា ។ ពិតហើយ បទថា **យំ** នេះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ អធិប្បាយថា ក្នុងកាលណា សេចក្ដីលោភគ្របសង្កត់ គឺរឹតរួតនរជន ក្នុងកាលនោះ នឹងមានការងងឹត ម្យ៉ាងទៀត បទថា **យំ** ជាតតិយាវិភត្តិ មានការប្រកបសេចក្ដីថា ព្រោះសេចក្ដីលោភដែលកើតឡើង ធ្វើនូវការគ្របសង្កត់ គឺរឹតរួតនរជន ដូច្នោះ កាលនោះ នឹងមានការងងឹត ដូច្នេះ ។ ព្រោះ **យត** សព្ទ មានការសម្ពន្ធគ្នាដោយចំណែកមួយ ។ ម្យ៉ាងទៀត បទថា **យំ** ជាកិរិយាបរាមាស ។ ក្នុងបទថា **លោភោ**

**សហាតេ** នេះ សេចក្ដីថា ការគ្របសង្កត់ គឺការប្រឈមមុខនៃលោកៈនេះ ដែលព្រះមានព្រះភាគត្រាស់ហើយ ការគ្របសង្កត់ គឺការសង្កត់សង្កិននេះ និងការប្រព្រឹត្តទៅ បានដល់ ការកើតឡើងនៃជរា ដែលធ្វើនូវការខ្វាក់ ។ ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ គប្បីឃើញយ៉ាងនេះថា លោកៈ រមែងគ្របសង្កត់ គឺសង្កត់សង្កិននរជនណា ក្នុងកាលនោះ ជរា រមែងមានដល់នរជននោះ បន្ទាប់អំពីនោះ បុគ្គលលោភហើយ រមែងមិនឃើញអត្ថ រមែងមិនឃើញធម៌ ។

បទថា **យោ ច លោភំ បហន្ត្វាន** សេចក្ដីថា ក្នុងខាងដើម បុគ្គលណាលះលោភៈបានដោយសមថវិបស្សនាតាមសមគួរ ដោយអំណាចនៃតទង្គប្បហាន និងវិក្ខម្ភនប្បហាន និងមិនលោភក្នុងរូបជាដើមដែលជាទិព្វ ជាទីតាំងនៃលោភៈដែលប្រាកដហើយ ដោយអានុភាពនៃវិបស្សនាមានកម្លាំង ព្រោះលះបានយ៉ាងនោះ ។ បទថា **លោភោ បហីយតេ តម្ហា** សេចក្ដីថា សេចក្ដីលោភដែលអរិយមគ្គលះបាន គឺរលាស់ចេញបាន បានដល់ លះទៅដោយចំណែកមួយចាកព្រះអរិយបុគ្គលនោះ ។ សេចក្ដីនេះដូចម្ដេច ឆ្លើយថា បទថា **ឧទពិន្ទុវ បោក្ខរា** សេចក្ដីថា ដូចតំណក់ទឹកដែលរមៀលធ្លាក់អំពីស្លឹកឈូក ។ សូម្បីបណ្ដាគាថាដ៏សេស ក៏គប្បីជ្រាបតាមន័យនេះ ។

ម្យ៉ាងទៀត គប្បីជ្រាបទោសៈដែលឲ្យកើតអនត្ថៈ និងទោសៈ ដែលជាហេតុនៃការសាបសូន្យប្រយោជន៍តាមគន្លងនៃព្រះសូត្រ ដែលមកហើយដោយ ន័យជាដើមថា

បុគ្គលអ្នកប្រទូស្ត តែងសន្សំនូវកម្មណា ដោយកាយ

វាថា ចិត្ត កម្មនោះ ក៏ជាអកុសល ដែលបុគ្គលអ្នកប្រទូស្ត ដែលត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត តែងរកឿងបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយដ៏លាមក ជាច្រើនកើតអំពីទោសៈ មានទោសៈជាដើមហេតុ មានទោសៈជាប្រភព មានទោសៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រម ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត ម្នាលអាវុសោ បុគ្គលអ្នកប្រទូស្ត ត្រូវទោសៈគ្រប់សង្កត់ មានចិត្តត្រូវទោសៈរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ រមែងទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តខ្លះ ... ដូច្នេះ ។

ម្យ៉ាងទៀត ម្នាលអាវុសោ បុគ្គលប្រទូស្ត ត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់

នូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្វះ មិនដឹងច្បាស់
នូវប្រយោជន៍ទាំងពីរខាង ... ដូច្នេះជាដើម ។
ម្យ៉ាងទៀត គប្បីជ្រាបកាលដែលមោហៈឲ្យកើតអនត្ថៈ
និងកាលដែលមោហៈជាហេតុ នៃការសាបសូន្យចាក
ប្រយោជន៍ តាមគន្លងនៃព្រះសូត្រ ដែលមកហើយដោយ
ន័យជាដើមថា បុគ្គលអ្នកវង្វេង តែងសន្សំនូវកម្មណា
ដោយកាយ វាចា ចិត្ត ... ដូច្នេះ ។
និងដោយន័យជាដើមថា ម្នាលអាវុសោ បុគ្គលអ្នកវង្វេង
ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែង
គិតដើម្បីបៀតបៀនខ្លួនឯង ... ដូច្នេះ ។
បុគ្គលវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈ
រួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាម
ពិតខ្វះ ... ដូច្នេះ ។

បទថា **តាលបក្កំវ ពន្ធនា** សេចក្តីថា ទោសៈដែលព្រះយោគាវចរនោះលះបាន គឺរលាស់ចេញបានចាកចិត្ត ព្រោះការកើតឡើងនៃមគ្គញាណទី ៣ ដូចផ្លែត្នោតទុំជ្រុះចាកទង ព្រោះកម្តៅកើតឡើង ដូច្នោះ ។ បទថា **មោហំ វិហាន្តិ សោ សព្វំ** សេចក្តីថា ព្រះអរិយបុគ្គលនោះ សម្លាប់ គឺកម្ចាត់ បាន ដល់ ផ្តាច់ផ្តិលនូវមោហៈទាំងអស់ គឺមិនឲ្យសល់ដោយមគ្គទី ៤ ។ បទថា **អាទិច្ចោ វុទយំ តមំ** សេចក្តីថា ដូចព្រះអាទិត្យឧទ័យ គឺរះឡើង កម្ចាត់ងងឹត

គឺអន្ធការ ដូច្នោះ ។ល។

**អដ្ឋកថា អន្តរាមនសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទេវទត្តសូត្រ

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្ម ៣ យ៉ាង គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ស្ថិតនៅអស់ ១ កប្ប លែងកែបាន ។ អសទ្ធម្ម ៣ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវសេចក្តីប្រាថ្នាដ៏លាមក គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ស្ថិតនៅអស់ ១ កប្ប លែងកែបាន ១ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវភាពនៃបាបមិត្តគ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ស្ថិតនៅអស់ ១ កប្ប លែងកែបាន ១ ។ មួយវិញទៀត កិច្ចដែលគួរធ្វើតទៅទៀត នៅមាន ( ប៉ុន្តែ ) ទេវទត្តដល់នូវសេចក្តីវិនាសក្នុងពាក់កណ្តាល ចាកឈាន និងអភិញ្ញាជាន់ទាបផង ចាកការត្រាស់ដឹងនូវគុណវិសេសជាន់ខ្ពស់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តដែលត្រូវអសទ្ធម្ម ៣ នេះឯង គ្របសង្កត់ រួបរឹតចិត្តហើយ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ស្ថិតនៅអស់ ១ កប្ប លែងកែបាន ។

បុគ្គលទីមួយ ក្នុងលោក កុំមានសេចក្តីប្រាថ្នាដ៏លាមក

ដោយដាច់ខាត គតិរបស់បុគ្គលទាំងឡាយ ដែលមាន សេចក្តីប្រាថ្នាដ៏លាមក យ៉ាងណាមិញ អ្នកទាំងឡាយ ត្រូវដឹងនូវទេវទត្តនោះ ដោយហេតុនេះ យ៉ាងនោះចុះ ។ តថាគតឮថាទេវទត្តនេះ គេដឹងថាជាបណ្ឌិត គេសរសើរ ថាជាអ្នកមានខ្លួនអប់រំហើយ ហាក់ដូចជារុងរឿង ដោយ យសបរិវារ ហើយស្ថិតនៅ ទេវទត្តនោះ ជាអ្នកសន្សំ រឿយៗ នូវសេចក្តីប្រមាទ បៀតបៀនតថាគតនោះហើយ ដល់នូវអវិចីនរក មានទ្វារ ៤ ជាទីគួរខ្លាច ។ បុគ្គល ណា ប្រទូស្តចំពោះបុគ្គល ដែលមិនប្រទូស្ត អ្នកមិន ធ្វើបាបកម្ម ផលបាប រមែងប៉ះពាល់ត្រូវបុគ្គល អ្នក មានចិត្តប្រទូស្ត មិនអើពើនោះឯង ។ បុគ្គលណាសម្គាល់ ដើម្បីនឹងប្រទូស្តនូវសមុទ្រ ដោយថ្នាំងដ៏ពេញដោយថ្នាំ ពិស បុគ្គលនោះ មិនគប្បីប្រទូស្ត ដោយថ្នាំងដ៏ពេញ ដោយថ្នាំពិសនោះបាន ព្រោះថា សមុទ្រ ជាសភាពធំ មហិមា យ៉ាងណាមិញ ។ បុគ្គលណាបៀតបៀនតថាគត នុ៎ះ ដែលកំពុងប្រតិបត្តិដោយប្រពៃ មានព្រះហឫទ័យ ស្ងប់រម្ងាប់ ដោយវាទៈជាទោស វាទៈ ( របស់បុគ្គល នោះ ) ក៏មិនដុះឡើងក្នុងព្រះតថាគតនោះ ក៏យ៉ាងនោះ ដែរ ។ ភិក្ខុ ជាអ្នកប្រព្រឹត្តទៅតាមផ្លូវ នៃបុគ្គលណា

ហើយបានដល់នូវការអស់ទៅនៃសេចក្ដីទុក្ខ បណ្ឌិត
គប្បីធ្វើបុគ្គលមានសភាពដូច្នោះ ឲ្យជាមិត្តផង គប្បី
សេពគប់ចំពោះបុគ្គលនោះផង ។

ខ្ញុំបានស្ដាប់មកហើយថា សេចក្ដីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

ចតុត្ថវគ្គ ចប់

## ឧទ្ទាននៃចតុត្ថវគ្គនោះ គឺ

និយាយអំពីវិតក្ក ១ សក្ការៈ ១ សំឡេង ១ ទេព-
ច្យុត ១ បុគ្គលក្នុងលោក ១ អសុភ ១ ធម៌ ១ ងងឹត
១ មន្ទិល ១ ទេវទត្ត ១ ត្រូវជា ១០ ។

# អដ្ឋកថា

## ទេវទត្តសូត្រ

[ ៩១ ] ក្នុងទេវទត្តសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ក្នុងព្រះសូត្រ មានពាក្យថា **តីហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ** មានរឿងកើតឡើងដូចម្ដេច មានរឿងពិស្ដារថា កាលទេវទត្តធ្លាក់អវិចីមហានរកហើយ ភិក្ខុដែលជាគ្នីគ្នារបស់ទេវទត្ត និងពួកតិរ្ថិយទាំងឡាយ បាននាំគ្នាពោលទោស

ថា ទេវទត្ត ត្រូវព្រះសមណគោតមផ្ដាសា ទើបត្រូវផែនដីស្រូប ។ មនុស្ស ទាំងឡាយ បានស្ដាប់ដូច្នោះហើយ ជនណាមិនជ្រះថ្លាក្នុងព្រះសាសនា ក៏កើត នូវសេចក្ដីសង្ស័យឡើងថា សេចក្ដីនេះ ដូចមនុស្សទាំងឡាយនិយាយពិតឬ ហ្ន៎ ។ ភិក្ខុទាំងឡាយបានក្រាបទូលព្រឹត្តិការណ៍នោះ ដល់ព្រះមានព្រះភាគ ។ កាលនោះ ព្រះមានព្រះភាគ ត្រាស់បដិសេធការយល់ខុសរបស់មនុស្សទាំង នោះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនដាក់ផ្ដាសា ដល់បុគ្គលណាម្នាក់ ឡើយ ព្រោះដូច្នោះ ទេវទត្ត មិនមែនតថាគតដាក់ផ្ដាសាឡើយ ទេវទត្តធ្លាក់ នរកដោយកម្មរបស់ខ្លួននោះឯង ដូច្នេះ ទើបត្រាស់ព្រះសូត្រនេះ ដោយ អត្ថុប្បត្តិហេតុនេះ ។

បណ្ដាបទទាំងនោះ បទថា **អសទ្ធម្មេហិ** បានដល់ ធម៌របស់អសប្បុរស បទថា **អតេកិច្ឆោ** សេចក្ដីថា ព្យាបាលមិនបាន អធិប្បាយថា កែខៃមិនបាន ព្រោះកើតក្នុងអវីចី មិនមានការកែខៃ ព្រោះទេវទត្តជាបុគ្គលមិនគួរព្រះពុទ្ធ ទាំងឡាយឲ្យត្រឡប់ចិត្ត ទេវទត្តឈ្មោះថា **ចាបិច្ឆោ** ព្រោះមានសេចក្ដីប្រាថ្នា លាមកប្រព្រឹត្តទៅ ដោយបំណងប្រកាសគុណដែលខ្លួនមាន ។ ភាវៈនៃបុគ្គល ប្រាថ្នាលាមកនោះ ឈ្មោះថា **ចាបិច្ឆតា**។ ត្រូវសេចក្ដីប្រាថ្នាលាមកនោះគ្រប សង្កត់ហើយ ទេវទត្តនោះកើតសេចក្ដីប្រាថ្នាឡើងថា អញនឹងធ្វើព្រះពុទ្ធ អញ នឹងគ្រប់គ្រងសង្ឃ ។ ទេវទត្តឈ្មោះថា **ចាបមិត្តោ** ព្រោះមានមិត្តដ៏ថោកទាប គឺលាមក មានកោកាលិកជាដើម ។ ភាវៈនៃបុគ្គលមានមិត្តអាក្រក់នោះ ឈ្មោះថា **ចាបមិត្តតា** ត្រូវភាពជាអ្នកមានមិត្រអាក្រក់នោះ គ្របសង្កត់

ហើយ ។ បទថា **ឧត្តរិករណីយេ** សេចក្តីថា កាលមគ្គផលដែលជាករណីយកិច្ចយ៉ាងខ្ពស់ ដែលបុគ្គលគប្បីសម្រេចដោយឈាន និងអភិញ្ញាដែលខ្លួនមិនទាន់បានសម្រេចមាន អធិប្បាយថា មិនទាន់បានសម្រេចមគ្គផលនោះ ដោយអាការយ៉ាងនោះ ។

បទថា **ឱរមត្តកេន** សេចក្តីថា ត្រឹមបន្តិចបន្តួច គឺត្រឹមឈាន និងអភិញ្ញាប៉ុណ្ណោះ ។ បទថា **វិសេសាធិគមេន** សេចក្តីថា ព្រោះសម្រេចឧត្តរិមនុស្សធម៌ ។ បទថា **អន្តរា** ប្រែថា ត្រង់កណ្តាល ។ បទថា **វោសានំ អាបាទិ** សេចក្តីថា មិនទាន់សម្រេចកិច្ចឡើយ តែសម្គាល់ថា អញសម្រេចកិច្ចហើយ ដល់នូវសេចក្តីវិនាសចាកសមណធម៌ ។

ដោយប្រការដូចពណ៌នាមកនេះ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ប្រកាសទោសក្នុងភាពជាបុថុជ្ជនដោយវិសេស ដោយព្រះសូត្រនេះថា ភាពជាបុថុជ្ជនរបស់បុគ្គលនោះធ្ងន់ព្រោះហេតុដែលញ៉ាំងសម្បត្តិ មានឈាន និងអភិញ្ញាជាទីបំផុត ឲ្យកើតឡើងបាន តែមិនទាន់លះហេតុនៃទុក្ខ មានបែបផ្សេងៗ ដែលនាំអនត្ថៈមកឲ្យជាអនេក ការវួតនូវគុណដែលមិនមាន ការសេពគប់អសប្បុរសនិងការប្រកបនូវសេចក្តីខ្ជិលច្រអូសរឿយៗ មិនបាន នឹងបានជួបនូវទោសដែលកែខៃមិនបាន តាំងនៅអស់កប្បក្នុងអវិចីមហានរក ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ សព្ទថា **មា** ជានិបាត ប្រើក្នុងអត្ថថា បដិសេធ ។ បទថា **ជាតុ** ដោយចំណែកមួយ ។ បទថា **កោចិ** ជាពាក្យហៅរួមទាំងអស់ ។ បទថា **លោកស្មឹ** បានដល់ ក្នុង

*សត្វលោក អធិប្បាយថា បុគ្គលណាម្នាក់ ក្នុងលោកនេះ កុំបីមានការប្រាថ្នាលាមកដោយចំណែកមួយ ។ បទថា* **តទិមិនាបិ ជានាថ ចាបិច្ឆានំ យថាគតិ** *សេចក្តីថា គតិដូចម្តេច គឺការសម្រេចដូចម្តេច បានផលខាងមុខដូចម្តេចរបស់បុគ្គលដែលមានសេចក្តីប្រាថ្នាលាមក អ្នកទាំងឡាយ ចូរដឹងនូវគតិនោះដោយហេតុនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់អាងទេវទត្តជាគំរូ ទើបត្រាស់យ៉ាងនេះ ។*

*បទថា* **បណ្ឌិតោតិ សមញ្ញាតោ** *សេចក្តីថា ដែលដឹងថាជាបណ្ឌិតព្រោះជាពហុសច្ចក្នុងបរិយត្តិ ។ បទថា* **ភាវិតត្តោតិ សម្មតោ** *សេចក្តីថា លើកតម្កើងគ្នាថា មានខ្លួនអប់រំហើយ ដោយឈាន និងអភិញ្ញាទាំងឡាយ ។ ពិតហើយ ទេវទត្តនោះ ក្នុងកាលមុន ជាបុគ្គលសូម្បីព្រះធម្មសេនាបតីក៏សរសើរថា ជាគោធិបុត្រ ជាអ្នកមានឫទ្ធិច្រើន ជាគោធិបុត្រ មានអានុភាពច្រើន ។ បទថា* **ជលំវ យសសា អដ្ឋា ទេវទត្តោតិ វិស្សុតោ** *សេចក្តីថា មានឈ្មោះល្បី គឺប្រាកដយ៉ាងនេះថា ទេវទត្តរុងរឿងប្រាកដច្បាស់ តាំងនៅហើយ ដោយកិត្តិយស និងបរិវាររបស់ខ្លួន ។ បាឋៈថា* **មេ សុតំ** *ដូច្នេះក៏មានអធិប្បាយថា ខ្ញុំបានស្តាប់ហើយ គឺបានស្តាប់មក បានដល់ ទេវទត្តជាបណ្ឌិតជាដើមនោះ ត្រឹមតែខ្ញុំស្តាប់មកប៉ុណ្ណោះ ព្រោះទេវទត្តមានសភាពយ៉ាងនោះ គឺស្ងប់ពីរបីថ្ងៃប៉ុណ្ណោះ ។*

*បទថា* **សោ បមាទមនុចិណ្ណោ អាសជ្ជ នំ តថាគតំ** *សេចក្តីថា ទេវទត្តនោះ មានសភាពយ៉ាងនេះ មិនស្គាល់ប្រមាណខ្លួនឯង គឺដល់នូវការ*

ប្រមាទ ដោយតែងតាំងព្រះសម្មាសម្ពុទ្ធស្មើនឹងខ្លួនថា ព្រះពុទ្ធក៏ជាសក្យបុត្រ យើងក៏ជាសក្យបុត្រ ព្រះពុទ្ធជាសមណៈ យើងក៏ជាសមណៈ ព្រះពុទ្ធក៏ជាអ្នកមានឫទ្ធិ យើងក៏ជាអ្នកមានឫទ្ធិ ព្រះពុទ្ធជាអ្នកមានទិព្វចក្ខុ យើងក៏មានទិព្វចក្ខុ ព្រះពុទ្ធជាអ្នកមានទិព្វសោត យើងក៏មានទិព្វសោត ព្រះពុទ្ធបានចេតោបរិយញ្ញាណ យើងក៏បានចេតោបរិយញ្ញាណ ព្រះពុទ្ធដឹងធម៌ដែលជាអតីត អនាគត និងបច្ចុប្បន្ន យើងក៏ដឹងធម៌ទាំងនោះដែរ ដូច្នេះ ទេវទត្តបោះបោកបៀតបៀនព្រះតថាគត ព្រោះត្រូវមារបណ្តាលចិត្តថា ឥឡូវនេះ យើងនឹងធ្វើជាព្រះពុទ្ធ យើងនឹងថែរក្សាភិក្ខុសង្ឃ ។ អាចារ្យពួកខ្លះពោលថា **បមាទមនុជីនោ** ដូច្នេះក៏មាន ។ ពាក្យនោះមានអត្ថថា ដល់នូវសេចក្តីប្រមាទតាមន័យដែលពោលហើយ អាស្រ័យសេចក្តីប្រមាទ សាបសូន្យចាកឈាន និងអភិញ្ញាដំណាលគ្នានឹងចិត្តប្បាទដែលលើកខ្លួនស្មើនឹងព្រះពុទ្ធនោះឯង ។បទថា **អវីចិនិរយំ បត្តោ ចតុទ្វារំ ភយានកំ** សេចក្តីថា ដល់នូវមហានរកដែលមានឈ្មោះថា អវីចី ព្រោះអណ្តាតភ្លើង ឬសត្វដែលកើតក្នុងនរកនោះមានជានិរន្តរ ឈ្មោះថា មានទ្វារ ៤ ប្រកបដោយទ្វារធំ ៤ ក្នុងទិសទាំង ៤ ដែលគួរខ្លាចពន្លឹក ដោយអំណាចបដិសន្ធិ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកថា

ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត មានជ្រុងបួន
មានទ្វារបួន បែងចែកដោយចំណែកៗ មានរបងដែកព័ទ្ធ
ជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃក្រោយនៃមហានរក

នោះ សុទ្ធតែដែក មានភ្លើងឆេះភ្លឺប្រាលរន្ទាលផ្សាយទៅ
បានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗ កាល ដូច្នេះ ។

បទថា **អទុដ្ឋស្ស** បានដល់ មានចិត្តមិនត្រូវទោសៈប្រទូស្តហើយ ។ បទថា **ទុព្ភេ** បានដល់ **ទុស្សេយ្យ** ប្រែថា គប្បីប្រទូស្ត ។ បទថា **តមេវ បាបំ ផុសតិ** សេចក្តីថា ផលអាក្រក់ គឺផលនៃបាបដែលថោកទាបពាល់ត្រូវ គឺចូលដល់ បានដល់ គ្របសង្កត់បុគ្គលថោកទាប ប្រទូស្តចំពោះបុគ្គលមិនប្រទូស្តនោះឯង ។ បទថា **ភេស្មា** សេចក្តីថា សមុទ្រនាំឲ្យបុគ្គលខ្លាចព្រោះទទឹង និងជម្រៅ អធិប្បាយថា ធំផង ជ្រៅផង ។ បទថា **វាទេន** បានដល់ ដោយទោស ។ បទថា **វិហឹសតិ** សេចក្តីថា បៀតបៀន គឺកាច់បំបាក់ ។ បទថា **វាទោ តម្ហិ ន រូហតិ** សេចក្តីថា ទោសដែលអ្នកដទៃដាក់ក្នុងតថាគតនោះ មិនដុះឡើង គឺមិនតាំងនៅ អធិប្បាយថា នឹងឲ្យកើតសេចក្តីពិការដល់ព្រះអង្គ ដូចថ្នាំពិសតែមួយផ្តាំង នឹងមិនធ្វើមហាសមុទ្រឲ្យពុលបាន ដូច្នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា ទេវទត្តជាអ្នកមិនផុតអំពីទុក្ខដោយទ្រង់សម្តែងថា ទេវទត្តប្រកបដោយសេចក្តីប្រាថ្នាលាមកជាដើម បានចូលដល់នរកហើយ ដោយគាថា ៦ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងថា ហេតុនៃការអស់ទុក្ខរបស់បុគ្គលប្រកបដោយធម៌ ដែលផ្ទុយនឹងការប្រាថ្នាដ៏លាមកនោះ ទើបត្រាស់គាថាចុងក្រោយថា **តាទិសំ មិត្តំ** ជាដើម ។

គាថាចុងក្រោយមានអត្ថថា ភិក្ខុដើរផ្លូវ គឺធ្វើដំណើរតាមផ្លូវរបស់បុគ្គល

អ្នកប្រតិបត្តិប្រពៃហើយ បានដល់ បដិបត្តិប្រពៃហើយ គប្បីដល់នូវការអស់ទៅ គឺអស់នូវវដ្តទុក្ខទាំងមូល ដោយការប្រកបដោយគុណ មានសេចក្តីប្រាថ្នាតិចជាដើម ភិក្ខុដែលជាបណ្ឌិត គឺអ្នកមានបញ្ញា គួរធ្វើបុគ្គលបែបនេះ គឺព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធឲ្យជាមិត្តរបស់ខ្លួន គឺធ្វើនូវសេចក្តីស្និទ្ធស្នាលជាមួយលោក និងការសេពគប់ គឺគួរចូលទៅអង្គុយជិតលោកនោះឯង ។

ក្នុងវគ្គនោះ ព្រះមានព្រះភាគបានត្រាស់វិវដ្តៈ ក្នុងសូត្រទី ៦ ទី ៧ ត្រាស់វដ្តៈផង វិវដ្តៈផង ក្នុងសូត្រដ៏សេស ៕

**អដ្ឋកថា ទេវតាសូត្រទី ១០ ចប់**

**វគ្គទី ៤ ចប់**

# សុត្តន្តបិដក

## ឥតិវុត្តក តិកនិបាត បញ្ចមវគ្គ

### អគ្គប្បសាទសូត្រ

[ ៩២ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លា ចំពោះវត្ថុដ៏ប្រសើរនេះ មាន ៣ ។ សេចក្តីជ្រះថ្លាចំពោះវត្ថុដ៏ប្រសើរ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិនមានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន គឺមានសញ្ញាយ៉ាងល្អិតក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ ( ធម៌ដែលមានបច្ច័យប្រជុំតាក់តែង ) ក្តី ជាអសង្ខតធម៌ ( ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង ) ក្តី វិរាគៈ ( ការប្រាសចាកតម្រេក ) ដែលជាគ្រឿងញាំញីនូវសេចក្តីស្រវឹង នាំចេញនូវសេចក្តីស្រេកឃ្លាន ដកឡើងនូវសេចក្តីអាល័យ កាត់ផ្តាច់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់មិនសេសសល់ មិនមានតណ្ហានេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងវិរាគធម៌ហើយ ពួកសត្វ

នោះ ឈ្មោះថាជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺការឃើញត្រូវ ១ ការត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ រឭកត្រូវ ១ តាំងចិត្តមាំត្រូវ ១ នេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងធម៌ គឺមគ្គដ៏ប្រសើរហើយ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃជាសាវករបស់ព្រះតថាគត ដែលចាត់ជាគូនៃបុរសមាន ៤ គូ ចាត់ជាបុរសបុគ្គល ( រៀងគ្នា ) មាន ៨ នេះប្រាកដជាប្រសើរជាងសង្ឃ និងគណៈទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណា ជ្រះថ្លាក្នុងសង្ឃហើយ ពួកសត្វនោះ ឈ្មោះថា ជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ កាលបើពួកសត្វជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរហើយ មានផលក៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ មាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

កាលបើពួកសត្វជ្រះថ្លាក្នុង ( ព្រះរតនត្រ័យ ) ថាជារបស់
ប្រសើរ ដឹងច្បាស់ថាជាសភាវៈប្រសើរ គឺថាជ្រះថ្លាក្នុង
ព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គលដ៏ឧត្តម ជ្រះថ្លា
ក្នុងព្រះធម៌ដ៏ប្រសើរ ជាគ្រឿងប្រាសចាកតម្រេកស្ងប់

រម្ងាប់ ( កិលេស ) នាំមកនូវសេចក្តីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្តយ៉ាងខ្ពង់ខ្ពស់ ឲ្យនូវទានក្នុងវត្ថុដ៏ប្រសើរ បុណ្យដ៏ប្រសើរ ក៏រមែងចម្រើនទាំងអាយុ ពណ៌ យស កេរ្តិ៍ឈ្មោះ សេចក្តីសុខ និងកម្លាំងដ៏ប្រសើរ ក៏រមែងចម្រើន អ្នកប្រាជ្ញ ជាអ្នកឲ្យ ( នូវទេយ្យធម៌ ) ចំពោះវត្ថុដ៏ប្រសើរ ហើយជាអ្នកមានចិត្តតាំងមាំ ក្នុងធម៌ដ៏ប្រសើរ លុះកើតជាទេវតា ឬកើតជាមនុស្ស សម្រេចនូវសម្បត្តិដ៏ប្រសើរ រមែងរីករាយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

# វគ្គទី ៥

## អគ្គប្បសាទសូត្រ

ក្នុងបសាទសូត្រទី ១ នៃវគ្គទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៩២ ] **អគ្គ** សព្ទនេះ ក្នុងពាក្យថា **អគ្គប្បសាទា** នេះ ប្រាកដក្នុងអត្ថថា ខាងដើម ទីបំផុត ចំណែក និងប្រសើរបំផុត ។ ពិតហើយ **អគ្គ** សព្ទនេះ ប្រាកដក្នុងអត្ថខាងដើម ដូចក្នុងប្រយោគជាដើមថា **អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ** ម្នាលអ្នករក្សាទ្វារជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគណ្ឋប្រុស និងពួកនិគណ្ឋស្រី ។

**អជ្ជតគ្គេ ធានុបេតំ សរណំ គតំ** ( សូមព្រះគោតមដ៏ចម្រើន ចាំនូវខ្ញុំព្រះអង្គថាជាឧបាសក ) អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមរៀងទៅ ។

មកក្នុងអត្ថថា ទីបំផុត ដូចក្នុងប្រយោគជាដើមថា **តេនេវ អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសេយ្យ ឧច្ឆុគ្គំ វេឡគ្គំ** បុគ្គលស្ទាបអង្គែលចុងអំពៅចុងឫស្សី ដោយម្រាមដៃនោះឯង ។ និងដូចពាក្យថា **ឧច្ឆុគ្គំ** ចុងអំពៅ **វេឡគ្គំ** ចុងឫស្សីជាដើម ។

ប្រាកដក្នុងអត្ថថា ចំណែក ដូចក្នុងប្រយោគជាដើមថា **អម្ពិលគ្គំ វា... មធុរគ្គំ វា... តិត្តកគ្គំ វា ...** ឱជារសជូរក្តី ... មានឱជារសផ្អែមក្តី ... មាន

ឱជាសេល្វឹង្កី ... ។ **អនុជានាមិ ភិក្ខវេ វិហារគ្គេន គាហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យប្រគល់តាមកំណត់នៃវិហារ ។ **អនុជានាមិ ភិក្ខវេ បរិវេណគ្គេន គាហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមកំណត់នៃបរិវេណ ។

និងប្រាកដក្នុងអត្ថថា ប្រសើរបំផុត ដូចក្នុងប្រយោគជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អគ្គោ ច សេដ្ឋោ ច ធាមោក្ខោ ច ឧត្តមោ ច បវរោ ច** បណ្តាបុគ្គលទាំង ៤ នេះ បុគ្គលនេះ ចាត់ថា ជាអ្នកលើសលុប ជាចម្បង ជាប្រធាន ឧត្តម ប្រសើរយ៉ាងនោះដែរ ។ **អគ្គោហមស្មិ លោកស្ស** យើងជាកំពូលនៃលោក ។

ក្នុងសូត្រនេះ **អគ្គ** សព្ទ គប្បីជ្រាបថា ប្រាកដក្នុងអត្ថប្រសើរបំផុតប៉ុណ្ណោះ ព្រោះដូច្នោះ ទើបមានអធិប្បាយថា សេចក្តីជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរទាំងឡាយ គឺវត្ថុដ៏ប្រសើរបំផុត ទើបឈ្មោះថា ប្រសើរបំផុត ឬជ្រះថ្លាក្នុងវត្ថុប្រសើរបំផុត ទើបឈ្មោះថា ជ្រះថ្លាក្នុងទីដ៏ប្រសើរ ។ ម្យ៉ាងទៀត អត្ថមុនព្រះមានព្រះភាគ ត្រាស់ព្រះរតនត្រ័យ មានពុទ្ធជាដើមដោយ **អគ្គ** សព្ទ ។

ក្នុងសត្វលោកទាំងនោះ ព្រះមានព្រះភាគ ឈ្មោះថា ប្រសើរបំផុត ដោយអត្ថថា មិនមានបុគ្គលប្រៀប ដោយអត្ថថា ជាបុគ្គលវិសេសដោយគុណ និងដោយអត្ថថា មិនមានបុគ្គលស្មើដូច ។ ពិតហើយ ទ្រង់ឈ្មោះថា ជាបុគ្គលកំពូល ដោយអត្ថថា មិនមានបុគ្គលប្រៀប ព្រោះធ្វើអភិនីហារមក

ច្រើន និងសន្សំបារមី ១០ មកជាដើម ទើបមិនដូចគ្នានឹងមនុស្សទាំងឡាយ ព្រោះព្រះគុណ គឺពោធិសម្ភារទាំងនោះ និងព្រោះព្រះពុទ្ធគុណទាំងឡាយ ។ ឈ្មោះថា ជាបុគ្គលប្រសើរ ព្រោះជាបុគ្គលឧត្តមជាងសត្វទាំងឡាយ ដោយអត្ថថា ជាបុគ្គលវិសេសដោយគុណ ព្រោះព្រះអង្គមានមហាករុណាគុណជាដើម ដែលវិសេសជាងគុណទាំងឡាយរបស់សព្វសត្វដ៏សេស ឈ្មោះថា ជាបុគ្គលប្រសើរ ដោយអត្ថថា ជាបុគ្គលមិនមានអ្នកស្មើ ព្រោះព្រះសម្មាសម្ពុទ្ធអង្គនេះ ជាបុគ្គលស្មើដោយព្រះគុណដោយរូបកាយ និងព្រះគុណដោយធម្មកាយ និងព្រះសម្មាសម្ពុទ្ធទាំងឡាយក្នុងកាលមុន ជាអ្នកមិនស្មើនឹងសព្វសត្វ ។ម្យ៉ាងទៀត ព្រះមានព្រះភាគ លោកហៅថា ជាបុគ្គលប្រសើរក្នុងលោក ព្រោះមានហេតុប្រាកដដែលរកបានលំបាក ព្រោះភាពជាអច្ឆរិយៈ ព្រោះនាំមកនូវហិតសុខដល់ជនច្រើន និងព្រោះភាពជាបុគ្គលមិនមាន ២ និងមិនមានសម្មាញ់ជាដើម ដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ ឯកនិបាតថា

> ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ។បេ។ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ ... ។
>
> ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក បានដោយកម្រក្នុងលោក ការកើតប្រាកដនៃបុគ្គលឯក តើគឺនរណា គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ... ។
>
> ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏

រមែងកើតឡើង ជាមនុស្សអស្ចារ្យ ... ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងឥតមានពីរ មិនមានសម្លាញ់ មិនមានបុគ្គលមានអត្តភាពដូច មិនមានបុគ្គលមានអត្តភាពស្មើ ជាអ្នកបែងភាគធម៌ ឥតមានបុគ្គលចាប់កុំហសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើង ២ បុគ្គលឯក តើគឺនរណា គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ... ។

ព្រះធម៌ និងព្រះសង្ឃ ក៏ឈ្មោះថា ប្រសើរជាងព្រះធម៌ និងសង្ឃដទៃ ( លទ្ធិដទៃ ) ដោយអត្ថថា មិនមានវត្ថុដូច និងដោយជារបស់មានហេតុប្រាកដ ដែលរកបានកម្រជាដើម ព្រោះជាអ្នកមានគុណវិសេស ។ ពិតហើយ ព្រះធម៌ និងព្រះសង្ឃពួកដទៃ គណនាដោយគុណ មិនមានគុណវិសេសឲ្យស្មើ ឬប្រហាក់ប្រហែល ដោយភាពជាព្រះធម៌ ជាស្វាក្ខាតធម៌ និងភាពដែលព្រះសង្ឃនោះ ជាអ្នកបដិបត្តិល្អជាដើមមិនមាន តើនឹងមានបុគ្គលប្រសើរបំផុតមកអំពីណា ។ ឯព្រះធម៌ និងព្រះសង្ឃក្នុងសាសនានេះ ឈ្មោះថា ប្រសើរបំផុតជាងព្រះធម៌ និងព្រះសង្ឃដទៃទាំងនោះ ព្រោះជាធម៌ និងជាសង្ឃដែលមានគុណវិសេសក្នុងខ្លួនឯងនោះឯង ម្យ៉ាងទៀត ព្រះធម៌ និងព្រះសង្ឃទាំងនោះ ជាហេតុនាំមកនូវប្រយោជន៍ និងសេចក្តីសុខមកឲ្យជនច្រើន ព្រោះជាការកើតឡើងដែលរកបានដោយកម្រ និងជាវត្ថុដែលគួរអស្ចារ្យ និង

មិនមានបុគ្គលគម្រប់ ២ មិនមានបុគ្គលជាសម្លាញ់ជាដើម ពិតហើយ ព្រះមានព្រះភាគ ជាបុគ្គលមានការប្រាកដ ដែលរកបានលំបាក ព្រោះធម៌ដ៏ប្រសើរឯណា សូម្បីព្រះធម៌ និងព្រះសង្ឃ ក៏ជាបុគ្គលមានការប្រាកដ ដែលរកបានដោយលំបាក ព្រោះធម៌ដ៏ប្រសើរនោះ ។ សូម្បីក្នុងភាពជាអច្ឆរិយៈជាដើម ក៏មានន័យនេះដូចគ្នា ។ សេចក្តីជ្រះថ្លា ក្នុងវត្ថុដ៏លើស គឺវត្ថុដ៏ប្រសើរឧត្តម បវរ បានដល់ វត្ថុវិសេសដោយគុណយ៉ាងនេះ ព្រោះដូច្នោះ ទើបឈ្មោះថា **អគ្គប្បសាទា** តែការជ្រះថ្លាដែលជារបស់ដ៏ប្រសើរ ព្រោះកើតឡើងក្នុងព្រះពុទ្ធជាដើម ដ៏ប្រសើរតាមដែលពោលមកហើយ ក្នុងអត្ថទី ២ ឈ្មោះថា ជាការជ្រះថ្លាដ៏ប្រសើរ ។ ឯជនណាប្រព្រឹត្តមកហើយ តាមគន្លងនៃព្រះអរិយៈ មានការជ្រះថ្លាឈមចុះហើយ ការជ្រះថ្លាទាំងនោះ ជាការជ្រះថ្លាដ៏ប្រសើរ ដោយចំណែកមួយនោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា **អគ្គប្បសាទា** ដូចដែលព្រះតម្រាស់ត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ដូច្នេះ ។ ម្យ៉ាងទៀត ការជ្រះថ្លាទាំងនេះ ឈ្មោះថា ជាការជ្រះថ្លាដ៏ប្រសើរ ព្រោះមានផលដ៏ប្រសើរក៏មាន ។ សមដូចព្រះមានព្រះភាគត្រាស់ថា កាលបើពួកសត្វជ្រះថ្លា ក្នុងវត្ថុដ៏ប្រសើរ មានផលក៏ប្រសើរ ។

បទថា **យាវតា** សេចក្តីថា មានប្រមាណប៉ុន្មានណា ។ បទថា **សត្តា** បានដល់ សត្វមានជីវិតទាំងឡាយ ។ បទថា **អបទា** បានដល់ មិនមានជើង ។ បទថា **ទ្វិបទា** បានដល់ មានជើង ២ ក្នុង ២ បទដ៏សេស ក៏មាន

*ន័យដូចគ្នា ។* **វា** *សព្ទ ជាសមុច្ចយត្ថៈ មិនមែនជាវិកប្បត្ថៈ ( មានអត្ថរួម ) ដូចក្នុងពាក្យថា* **អនុប្បន្នា វា កាមាសវា ឧប្បជ្ជន្តិ ឧប្បន្នា វា កាមាសវា បវឌ្ឍន្តិ** *កាមាសវៈដែលមិនទាន់កើតឡើង នឹងកើតឡើងក៏មាន អាសវៈដែលកើតហើយ នឹងចម្រើនឡើងក៏មាន ដោយអត្ថថា មិនទាន់កើត នឹងកើតឡើងហើយ និងក្នុងពាក្យថា* **ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ** *ដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដែលជាភូតខ្លះ ដើម្បីអនុគ្រោះ សត្វទាំងឡាយដែលជាសម្ភវេសីខ្លះ មានអត្ថថា ទាំងភូត និង សម្ភវេសី និងក្នុងពាក្យថា* **អគ្គិតោ វា ឧទកតោ វា មិថុភេទតោ វា** *ចាកភ្លើងខ្លះ ចាកទឹកខ្លះ ចាកការបែកបាក់មិត្តសន្ថវៈខ្លះ ដោយអត្ថថា ចាកភ្លើងផង ចាកទឹកផង ចាកការបែកបាក់មិត្រផង យ៉ាងណា ក្នុងពាក្យថា* **អបទា វា ។បេ។ អគ្គមក្ខាយតិ** *នេះ ក៏ដូច្នោះ គប្បីជ្រាបអត្ថ ដោយអំណាចការរួមគ្នាថា មិនមានជើងក្តី មានជើង ២ ក្តី ដោយហេតុនោះ ទើបខ្ញុំពោលថា* **វា** *សព្ទ ជាសមុច្ចយត្ថៈ មិនមែនជាវិកប្បត្ថៈ ។ បទថា* **រូបិនោ** *បានដល់ មានរូប ។ បទថា* **អរូបិនោ** *បានដល់ មិនមានរូប ។ បទថា* **សញ្ញិនោ** *បានដល់ មានសញ្ញា ឈ្មោះថា* **អសញ្ញិនោ** *ព្រោះមិនមានសញ្ញា ។ សត្វទាំងឡាយដែលទាក់ទងក្នុងភវគ្គព្រហ្ម ឈ្មោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះសម្មាសម្ពុទ្ធទ្រង់ជាព្រះធម្មរាជា ទ្រង់សម្តែងអត្ថដល់ភពទាំង ៩ ដោយមិនមានសេសសល់ គឺ កាមភព ១ រូបភព ១ អរូបភព ១ ឯកវោការភព ១ ចតុវោការភព ១*

បញ្ចវោការភព ១ សញ្ញីភព ១ អសញ្ញីភព ១ នេវសញ្ញីនាសញ្ញីភព ១ ។ អធិប្បាយថា បណ្ដាភពទាំង ៩ នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងកាមភព រូបភព បញ្ចវោការភព ឯកវោការភព ដោយ **រូប** សព្ទ ។ ទ្រង់សម្ដែង អរូបភព ចតុវោការភព ដោយ **អរូប** សព្ទ ។ ចំណែកអសញ្ញីភពជាដើម ទ្រង់សម្ដែងដោយសរុបនោះឯង ។ ដោយ **អបទា** សព្ទជាដើម ទ្រង់សម្ដែង ជាឯកទេសរបស់កាមភព បញ្ចវោការភព និងសញ្ញីភព ។

សួរថា ហេតុអ្វី ទើបក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សំដៅយកសត្វ មិនមានជើងជាដើម ព្រោះទ្រង់មិនបំណងយកសត្វជើង ២ ប៉ុណ្ណោះ ថាជា អ្នកប្រសើរជាងសត្វជើង ២ ទាំងឡាយ ដូចក្នុងអទុតិយសូត្រ ( សូត្រដែល ពោលដោយបុគ្គលឯកមិនមានបុគ្គលជាគម្រប់ ២ ) តែទ្រង់សំដៅយកសត្វ ដែលមិនមានជើងជាដើម ខ្ញុំនឹងពោលឆ្លើយក្នុងអទុតិយសូត្រ ទ្រង់សំដៅយក សត្វជើង ២ ប៉ុណ្ណោះ ដោយអំណាចជាបុគ្គលប្រសើរជាង ។ បុគ្គលឈ្មោះ ថា ដែលប្រសើរបំផុត កាលកើតឡើងក្នុងលោក មិនកើតឡើងក្នុងពួកសត្វ ដែលមិនមានជើង ឬមានជើង ៤ ឬមានជើងច្រើនឡើយ តែកើតក្នុងពពួក សត្វដែលមានជើង ២ ប៉ុណ្ណោះ ។ សួរថា ក្នុងសត្វមានជើង ២ ពួកណា ឆ្លើយថា ក្នុងពពួកមនុស្ស និងពពួកទេវតាទាំងឡាយ ។

កាលកើតឡើងក្នុងពួកមនុស្ស នឹងកើតជាព្រះពុទ្ធដែលជាអ្នកអាចឲ្យ សត្វលោកទាំងអស់ ប្រព្រឹត្តទៅក្នុងអំណាចរបស់ព្រះអង្គ តែក្នុងអដ្ឋកថា អង្គុត្តរនិកាយ លោកពោលថា ទ្រង់អាចឲ្យសត្វលោក ៣០០០ លោកធាតុ

ប្រព្រឹត្តទៅក្នុងអំណាច កាលកើតឡើងក្នុងពួកទេវៈ នឹងកើតជាមហាព្រហ្ម ដែលឲ្យសត្វមួយម៉ឺនលោកធាតុប្រព្រឹត្តទៅក្នុងអំណាច ជនដែលជាកប្បិយការក ឬអារាមិកជន រមែងដល់ព្រមដល់ព្រះពុទ្ធនោះ ដោយប្រការដូច្នេះ ទើបលោកពោលក្នុងអទុតិយសូត្រនោះថា ជាបុគ្គលប្រសើរជាងសត្វជើង ២ ទាំងឡាយ ដោយប្រសើរជាងមនុស្ស និងទេវតានោះឯង តែក្នុងព្រះសូត្រនេះ ត្រាស់យ៉ាងនេះ ដោយគ្របដណ្តប់ដល់សត្វមិនមានសេសសល់ថា សត្វដែលទាក់ទងដោយអត្តភាព មានប្រមាណប៉ុនណា ឥតជើងក្តី ។បេ។ មានសញ្ញាក៏មិនមែនក្តី មិនមានសញ្ញាក៏មិនមែនក្តី បណ្តាសត្វទាំងនោះ ព្រះតថាគតបណ្ឌិតពោលថា ជាបុគ្គលដ៏ប្រសើរ ។ បទថា **តេសំ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនិទ្ធារណៈ ។ **ម** អក្ខរៈ គ្រាន់តែធ្វើការភ្ជាប់បទ បែកបទចេញជា **អគ្គោ អក្ខាយតិ** ដូច្នេះ ។

បទថា **អគ្គោ វិបាកោ ហោតិ** សេចក្តីថា ការជ្រះថ្លាណារបស់អ្នកជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ការជ្រះថ្លានោះ ជាវត្ថុដ៏ប្រសើរ ជាវត្ថុដ៏ឧត្តម ឬជាវត្ថុដ៏កំពូល ព្រោះដូច្នោះ ផលនៃការជ្រះថ្លានោះក៏ជារបស់ដ៏លើស ជារបស់ប្រសើរ ជារបស់ដ៏ឧត្តម ជារបស់ដ៏កំពូល ជារបស់ដ៏ឱឡារបំផុត ជារបស់ប្រណីតបំផុត តែការជ្រះថ្លានោះមាន ២ យ៉ាង ដោយចែកជាលោកិយ និងលោកុត្តរ ក្នុង ២ យ៉ាងនោះ ខ្ញុំនឹងពោលដល់ផលនៃការជ្រះថ្លាដែលជាលោកិយមុន គួរជ្រាបការប្រកបផលវិសេសនៃការជ្រះថ្លា ដោយអំណាចនៃសុត្តបទ ( សំយុត្តនិកាយ សគាថវគ្គ ) មានយ៉ាងនេះថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះពុទ្ធ ជាទីរឭក ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សហើយ នឹងទៅបំពេញក្នុងពួកនៃទេវតាមិនខាន ។

បីតិដែលមានក្នុងកាយរបស់បុគ្គល ដែលកំណត់ថាពុទ្ធោ ជាវត្ថុប្រសើរជាងបីតិរបស់ជាអ្នកជម្ពូទីប សូម្បីដោយកសិណា ។

និងដូចព្រះតម្រាស់ដែលត្រាស់ក្នុងវិនយបិដក ចុល្លវគ្គថា

ដំរី ១ សែន សេះ ១ សែន រថទឹមដោយមេសេះអស្សតរ ១ សែន ស្រីជំទង់ដែលពាក់ដោយកុណ្ឌលជាវិការនៃកែវមណី ១ សែន មិនដល់មួយចំណិតនៃការឈានទៅ ១ ជំហាន ដែលបណ្ឌិតចែកឲ្យជាចំណែក ១៦ អស់វារៈ ១៦ ដងទេ ។

និងដូចព្រះតម្រាស់ដែលត្រាស់ក្នុងសំយុត្តនិកាយ សំឡាយតនវគ្គថា

បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះហេតុតែដល់នូវព្រះពុទ្ធជាទីពឹងហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក យ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១

ពណ៌សម្បុរជាទិព្វ ១ សេចក្ដីសុខជាទិព្វ ១ យស
ជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេង
ជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈ
ជាទិព្វ ១ ។

ព្រោះដូច្នោះ ការជ្រះថ្លានោះ គប្បីជ្រាបថា ឲ្យនូវវិបាកជាសុខ ក្នុងសម្បត្តិភព មួយអន្លើដោយការឲ្យអបាយទុក្ខវិលត្រឡប់ គឺឃាត់នូវអបាយទុក្ខបាន ។ ឯការជ្រះថ្លាដែលជាលោកុត្តរ ឲ្យវិបាកជាសាមញ្ញផលផង ញ៉ាំងវដ្ដទុក្ខឲ្យវិលត្រឡប់ផង ។ ការជ្រះថ្លាទាំងអស់នេះ នឹងឲ្យវដ្ដទុក្ខវិលត្រឡប់បាន ក្នុងសម្បរាយភពនេះឯង សមដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវ័ក រឭករឿយៗ នូវសទ្ធារបស់ខ្លួន ក្នុងសម័យនោះ អរិយសាវ័កនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរិតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវ័កនោះ រមែងជាចិត្តត្រូវត្រង់ ... បាននូវសេចក្ដីរីករាយ ដែលប្រកបដោយធម៌ កាលបើមានសេចក្ដីរីករាយហើយ បីតិក៏កើតឡើង ... ភិក្ខុនោះ ដឹងច្បាស់ថា ។បេ។ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ សភាវធម៌ ឈ្មោះថា **ធម្មា** ។ បទថា **សង្ខតា** សេចក្ដីថា ធម៌ទាំងឡាយដែលបច្ច័យទាំងឡាយ តាក់តែងស្រេចរៀបរយហើយ ព្រោះដូច្នោះ ទើបឈ្មោះថា **សង្ខារ** គឺ ធម៌ដែលមានបច្ច័យ ។ ធម៌ទាំងឡាយដែលហេតុផងបច្ច័យណាមួយផង មិនធ្វើ គឺមិនតាក់តែងហើយ ព្រោះដូច្នោះ ទើបឈ្មោះ

ថា **អសង្ខតា** គឺព្រះនិព្វានដែលមិនមានបច្ច័យ ធម៌ទាំងឡាយ ឈ្មោះថា **អសង្ខត** ព្រោះជំទាស់ចំពោះសង្ខតធម៌ទាំងឡាយ ព្រោះដូច្នោះ ពាក្យនេះ ទើបជាពហុវចនៈ ។ បទថា **វិរាគោ តេសំ អគ្គមក្ខាយតិ** សេចក្ដីថា បណ្ដាសង្ខតធម៌ និងអសង្ខតធម៌ទាំងឡាយនោះ អសង្ខតធម៌ ពោល គឺវិរាគៈ បណ្ឌិតហៅថា ប្រសើរ គឺប្រសើរ បានដល់ ឧត្ដម ដោយអត្ថថា ខ្ពង់ខ្ពស់ ព្រោះជាធម៌ល្អិត និងសុខុម តាមសភាវៈនោះឯង ព្រោះជាសភាវៈស្ងប់ និងប្រណីតជាង ព្រោះជាវត្ថុជ្រាលជ្រៅ ព្រោះជាការស្វាងស្រវឹងជាដើម ។ បទថា **យទិទំ** ជានិបាត ដោយអត្ថ គឺ **យោ អយំ** ។ បទថា **មទនិម្មទនោ** ជាដើម ទាំងអស់ជាវេវចនៈនៃព្រះនិព្វានដូចគ្នា ។ ពិតហើយ ការស្រវឹងគ្រប់យ៉ាង មានស្រវឹងព្រោះមានះ ស្រវឹងក្នុងភាពជាបុរសជាដើម នឹងស្វាងទៅ គឺត្រូវទម្លាយព្រោះមកដល់និព្វាននោះ ការស្រេកទាំងអស់ មានការស្រេកកាមជាដើម ក៏នឹងត្រូវនាំចេញទៅ សូម្បីអាល័យទាំងអស់ មានអាល័យក្នុងកាមជាដើម ក៏នឹងត្រូវដកឡើង កម្មវដ្ដៈ កិលេសវដ្ដៈ និងវិបាកវដ្ដៈទាំងពួងក៏ត្រូវកាត់ផ្ដាច់ តណ្ហាទាំងពួង ដែលចែកប្រភេទជា ១០៨ យ៉ាង នឹងអស់ទៅ កិលេសក៏ប្រាសចេញអស់ ទុក្ខតែងរលត់ព្រោះមកដល់និព្វាននោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **មទនិម្មទនោ ។បេ។ និរោធោ ។** ម្យ៉ាងទៀត តណ្ហានេះ លោកពោលថា **វាន** ព្រោះមានវិគ្គហៈថា នាំទៅ គឺដោតក្រងភពចូលជាមួយភព ដោតក្រងកម្មចូលនឹងផល តណ្ហា គឺវានៈ មិនមានក្នុងធម្មជាតនេះ ឬកាលសម្រេចដល់ធម្មជាតនោះហើយ វានៈនោះ មិនមាន

ដល់ព្រះអរិយបុគ្គល ព្រោះដូច្នោះ ទើបធម្មជាតនោះ ឈ្មោះថា **និព្វាន** ។

ក្នុងបទថា **អគ្គោ វិបាកោ ហោតិ** នេះ គួរជ្រាបផលវិសេសនៃការជ្រះថ្លាក្នុងធម៌ ដោយអំណាចនៃសុត្តបទយ៉ាងនេះថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះធម៌ ជាទីពឹង
ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះ
បង់រាងកាយជារបស់មនុស្សហើយ នឹងទៅបំពេញក្នុង
ពួកនៃទេវតាមិនខាន ។
បីតិដែលមានក្នុងកាយរបស់បុគ្គល ដែលកំណត់ថា
ធម្មោ ជាវត្ថុប្រសើរជាងបីតិរបស់អ្នកជម្ពូទ្វីប សូម្បី
ដោយកសិណ ។
បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះ
ហេតុតែដល់នូវព្រះធម៌ជាទីពឹងហើយ លុះបែកធ្លាយ
រាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក
យ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វ
ដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១
ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជា
ទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ
១ ក្លិន ជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។

កាលបើដូច្នោះ ក្នុងសេចក្តីនេះ ការប្រសើរក៏ឈ្មោះថា មកហើយដោយ

អំណាចនៃអសង្ខតធម៌ប៉ុណ្ណោះ សូម្បីអំណាចនៃអរិយមគ្គ ក៏បានអត្ថនេះដូចគ្នា ដើម្បីសម្ដែងដល់ការចេញទៅនៃសង្ខតធម៌ទាំងអស់ ដែលមានព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ ដូច្នេះ ។ និងព្រះតម្រាស់ក្នុងធម្មបទថា ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ ។

បទថា **សង្ឃា វា គណា វា** បានដល់ ពួក ឬគណៈក្នុងលោក ពោលគឺប្រជុំជនមានប្រមាណប៉ុនណា ។ បទថា **តថាគតសាវកសង្ឃោ** បានដល់សង្ឃសាវករបស់ព្រះតថាគតដែលរួមគ្នា ដោយការស្មើគ្នានៃទិដ្ឋិ និងសីលគឺជំនុំនៃព្រះអរិយបុគ្គល ៨ ពួក ។ បទថា **តេសំ អគ្គមក្ខាយតិ** សេចក្ដីថាសង្ឃសាវករបស់ព្រះតថាគត បណ្ឌិតពោលថា ប្រសើរ គឺប្រសើរបំផុត បានដល់ ឧត្ដម សេចក្ដីថា លើសលន់ដោយគុណវិសេស មានសីល សមាធិបញ្ញា និងវិមុត្តិជាដើមរបស់ខ្លួន ។ បទថា **យទិទំ** សេចក្ដីថា ទាំងនេះ ។ បទថា **ចត្តារិ បុរិសយុគានិ** បានដល់ គូនៃបុរស ៤ គូ ដោយជាគូៗ យ៉ាងនេះ គឺលោកតាំងនៅក្នុងមគ្គទី ១ ផលទី ១ ជាគូ ១ រហូតដល់តាំងនៅក្នុងមគ្គទី ៤ ផលទី ៤ ជាគូ ១ ។ បទថា **អដ្ឋ បុរិសបុគ្គលា** បានដល់ បុរសបុគ្គល ៨ ពួក ដោយអំណាចបុរសបុគ្គល តាមន័យនេះ គឺបុរសបុគ្គលដែលតាំងនៅក្នុងបឋមមគ្គ ១ បឋមផល ១ ។ ក្នុងទីនេះ បទនេះ គឺ **បុរិសោ** ក្ដី **បុគ្គលោ** ក្ដី មានអត្ថតែមួយ ។ តែពាក្យនេះ ទ្រង់ត្រាស់តាំងដោយអំណាច

នៃវេនេយ្យសត្វ ។ បទថា **ឯស ភគវតោ សាវកសង្ឃោ** សេចក្តីថា ដោយជាគូនៃបុរស ៤ គូនេះ ដោយរាប់រៀងជាបុរសបុគ្គល ៨ នេះឯង ឈ្មោះថា សង្ឃសាវកនៃព្រះមានព្រះភាគ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អាហុនេយ្យោ** ជាដើមតទៅ របស់ដែលឈ្មោះថា **អាហុន** ព្រោះគេគប្បីនាំមកបូជា អធិប្បាយថា គប្បីនាំមកអំពីចម្ងាយ ហើយប្រគេនដល់លោកអ្នកមានសីលទាំងឡាយ ។ ពាក្យនេះ ជាឈ្មោះនៃបច្ច័យ ៤ ។ ព្រះសង្ឃ ឈ្មោះថា ជាបុគ្គលគួរទទួលរបស់ដែលគេនាំមកបូជានោះ ព្រោះធ្វើឲ្យជាទានមានផលច្រើន ព្រោះដូច្នោះ ទើបឈ្មោះថា **អាហុនេយ្យ** ។ម្យ៉ាងទៀត សម្បត្តិទាំងអស់ដែលគេនាំមកអំពីចម្ងាយហើយ បូជាក្នុងភ្លើង គឺ **អាហុន** នេះ ឬភ្លើង គឺ **អាហវន** គួរដល់សក្ការៈជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា **អាហវនីយ** ។ ភ្លើងរបស់ព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា **អាហវនីយ** ដែលជាហេតុឲ្យព្រាហ្មណ៍ទាំងនោះមានលទ្ធិថា យញ្ញ ដែលបូជាហើយ មានផលច្រើន បើភ្លើងនោះ ឈ្មោះថា **អាហវនីយ** ព្រោះការៈដែលបូជាហើយ មានផលច្រើន ព្រះសង្ឃនោះឯងក៏ឈ្មោះថា **អាហវនីយ** ព្រោះយញ្ញដែលបូជាហើយក្នុងសង្ឃ ក៏មានផលច្រើន ដូចព្រះតម្រាស់ក្នុងធម្មបទថា

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ ចំណែកអ្នកណា
បូជាលោក ដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយ
រំពេច ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការ

បូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ពាក្យថា **អាហាវនីយ** នេះ ក្នុងនិកាយដទៃ ដោយអត្ថ ដូចគ្នានឹងបទថា **អាហុនេយ្យោ** ក្នុងព្រះសូត្រនេះ តែដោយព្យញ្ជនៈផ្សេងគ្នាត្រឹមបន្តិចបន្តួចប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបលោកពណ៌នាសេចក្តីយ៉ាងនេះ ។

តែរបស់ដែលឲ្យភ្ញៀវ ដែលរៀបចំដោយសក្ការៈ ដើម្បីជាប្រយោជន៍ដល់ញាតិ និងមិត្រទាំងឡាយដែលជាទីស្រឡាញ់ ជាទីពេញចិត្ត ដែលមកហើយអំពីទិសធំ និងទិសតូច ទ្រង់ត្រាស់ហៅថា **អាហុន** ក្នុងពាក្យថា **អាហុនេយ្យោ** នេះ របស់ដែល ឲ្យភ្ញៀវនោះ វៀរមនុស្សទាំងនោះ គឺភ្ញៀវប្រភេទនោះហើយ គួរប្រគេនដល់សង្ឃប៉ុណ្ណោះ ម្យ៉ាងទៀត ព្រោះថា ព្រះសង្ឃនោះ នឹងប្រាកដក្នុងរវាងពុទ្ធន្តរមួយ មិនមានសព្វកាលឡើយ ។ តែក្នុងទីនេះ អត្ថរបស់បទមានដូច្នេះ ព្រះសង្ឃប្រកបហើយដោយធម៌ទាំងឡាយ ដែលធ្វើនូវភាពជាបុគ្គលគួរស្រឡាញ់ គួរពេញចិត្តដូច្នោះ តាមដែលពណ៌នាមកនេះ ទើបព្រះសង្ឃឈ្មោះថា **អាហុនេយ្យោ** ព្រោះរបស់សម្រាប់ទទួលភ្ញៀវ គួរប្រគេនដល់សង្ឃ ព្រោះលោកគួរទទួលនូវរបស់សម្រិតសម្រាំង ឯអត្ថាធិប្បាយរបស់អាចារ្យទាំងឡាយ ដែលមានបាលីថា **អាហាវនីយោ** ព្រោះព្រះសង្ឃគួរដល់ការធ្វើមុន ដូច្នោះ ទើបព្រះសង្ឃ ឈ្មោះថា **អាហាវនីយ** ព្រោះមនុស្សទាំងឡាយគួរនាំរបស់មកបូជាមុនអ្នកដទៃ ។ ម្យ៉ាងទៀត ព្រះសង្ឃ ឈ្មោះថា **អាហាវនីយ** ព្រោះគួរដល់ការបូជាដោយប្រការទាំងពួង ក្នុងព្រះសូត្រនេះ ព្រះសង្ឃនោះ ទ្រង់ត្រាស់ហៅថា **អាហុនេយ្យោ** ដូចអធិប្បាយ

នេះឯង ។

បទថា **ទក្ខិណា** សេចក្តីថា ព្រះសង្ឃឈ្មោះថា **ទក្ខិណេយ្យ** ព្រោះគួរដល់ទានដែលមនុស្សទាំងឡាយជឿបរលោក ហើយថ្វាយនូវទក្ខិណានោះ ឬជាបុគ្គលដែលឧបការៈដល់ទក្ខិណា ព្រោះឲ្យទក្ខិណាបរិសុទ្ធ ដោយធ្វើឲ្យមានផលច្រើន ។ ព្រះសង្ឃឈ្មោះថា **អញ្ជលិករណីយោ** ព្រោះគួរដល់អញ្ជលិកម្ម គឺការសំពះ ដែលសត្វលោកទាំងអស់ធ្វើដោយដាក់ដៃទាំង ២ លើក្បាល ។ បទថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** បានដល់ ជាទីដុះឡើងនៃបុណ្យរបស់សត្វលោកទាំងមូល មិនមានទីដទៃដូច ។ ឧបមាដូចទីដែលមានស្រូវសាលីក្រហម ឬស្រូវដំណើបដុះ សត្វលោក ហៅថា ស្រែស្រូវសាលី ស្រែស្រូវដំណើប យ៉ាងណា ព្រះសង្ឃក៏ដូច្នោះ ជាទីដុះនៃបុណ្យរបស់សត្វលោក មួយអន្លើដោយទេវលោក ព្រោះថា បុណ្យទាំងឡាយដែលឲ្យកើតប្រយោជន៍ និងសេចក្តីសុខច្រើនប្រការដល់សត្វលោក អាស្រ័យសង្ឃហើយ ទើបដុះឡើង ព្រោះដូច្នោះ ទើបសង្ឃឈ្មោះថា ជាស្រែបុណ្យនៃ សត្វលោក មិនមានស្រែបុណ្យដទៃ ក្រៅលែងជាង ។

ក្នុងទីនេះ ក៏គួរជ្រាបនូវការប្រកបផលវិសេសនៃការជ្រះថ្លាក្នុងព្រះសង្ឃ ដោយអំណាចនៃសុត្តបទ យ៉ាងនេះថា

ជនទាំងឡាយណាមួយ បានដល់នូវព្រះសង្ឃ ជាទី
ពឹង ជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ
លុះលះបង់រាងកាយជារបស់មនុស្សហើយ នឹងទៅ

បំពេញក្នុងពួកនៃទេវតាមិនខាន ។
បីតិដែលមានក្នុងកាយរបស់បុគ្គល ដែលកំណត់ថា
សង្ឃ្យា ជាវត្ថុប្រសើរជាងបីតិរបស់អ្នកជម្ពូទ្វីប សូម្បី
ដោយកសិណា ។
បពិត្រទេវានមិន្ទ សត្វពួកខ្លះ ក្នុងលោកនេះ ព្រោះ
ហេតុតែដល់នូវព្រះសង្ឃជាទីពឹងហើយ លុះបែកធ្លាយ
រាងកាយស្លាប់ទៅ តែងកើតក្នុងសុគតិសួគ៌ទេវលោក
យ៉ាងនេះឯង សត្វទាំងនោះ រមែងបាននូវរបស់ជាទិព្វ
ដទៃ ដោយឋានៈទាំង ១០ យ៉ាង គឺអាយុជាទិព្វ ១
ពណ៌សម្បុរជាទិព្វ ១ សេចក្តីសុខជាទិព្វ ១ យសជា
ទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១
ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។

ដោយព្រះពុទ្ធវចនៈនោះ គប្បីជ្រាបភាពដែលការជ្រះថ្លានោះជារបស់ដ៏ប្រសើរ និងភាពដែលគួរជ្រះថ្លានោះ មានផលក្រៃលែង ។ម្យ៉ាងទៀត គប្បីជ្រាបភាពដែលជ្រះថ្លាមានផលដ៏ប្រសើរ ដោយអំណាចនៃការឲ្យសម្រេចផលដ៏ឧឡារ មានការកាត់ផ្តាច់វដ្តទុក្ខ ផ្តើមអំពីការកើតក្នុងភពទី ៧ ជាដើម ព្រោះបានចំពោះនូវការឃើញដ៏កំពូល ជាហេតុនៃការសម្រេចនូវភាពជាសុខដ៏កំពូល ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា **អគ្គតោ** សេចក្តី

ថា បុគ្គលជ្រះថ្លាហើយ ក្នុងព្រះរតនត្រ័យដ៏ប្រសើរ ដោយភាពជារបស់ដ៏ប្រសើរនោះឯង ។ បទថា **អគ្គំ ធម្មំ** សេចក្តីថា ដឹង គឺជ្រាបនូវសភាវៈដ៏ប្រសើរ គឺភាពដែលព្រះពុទ្ធជាបុគ្គលត្រាស់ដឹងល្អហើយ ភាពដែលព្រះធម៌ជាធម៌ល្អ និងភាពដែលព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ បានដល់ សភាវៈដ៏ឧត្តមរបស់ព្រះរតនត្រ័យ ដែលមិនទូទៅដល់វត្ថុដទៃ ឬសភាវៈនៃគុណមានទសពលញ្ញាណជាដើម ជាធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ និងភាពជាបុគ្គលបដិបត្តិល្អហើយជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះរតនត្រ័យ ដែលជាទីតាំងនៃការជ្រះថ្លាដ៏ប្រសើរដោយទូទៅយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងព្រះរតនត្រ័យនោះ ដោយមិនទូទៅដោយការចែកចេញទៅ ទើបត្រាស់ពាក្យជាដើមថា **អគ្គេ ពុទ្ធេ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសន្នានំ** សេចក្តីថា ជ្រះថ្លាហើយ គឺបង្អោនចិត្តជឿហើយ ដោយការជ្រះថ្លាដែលតាំងមាំហើយ និងដោយការជ្រះថ្លាក្រៅអំពីនេះ ។ បទថា **វិរាគូបសមេ** សេចក្តីថា ដែលប្រាសចាកតម្រេក និងដែលស្ងប់ អធិប្បាយថា ដែលជាហេតុប្រាសចាកតម្រេកដោយចំណែកមួយនៃរាគៈទាំងអស់ និងដែលជាហេតុស្ងប់ដោយចំណែកមួយនៃកិលេសទាំងអស់ ។ បទថា **សុខេ** សេចក្តីថា ដែលឈ្មោះថា ជាសុខ ព្រោះព្រះធម៌ជាហេតុអស់វដ្តទុក្ខ និងព្រោះព្រះធម៌ជាហេតុនៃសេចក្តីសុខ ព្រោះរម្ងាប់នូវសង្ខារទាំងឡាយ ។ បទថា **អគ្គស្មឹ ទានំ ទទតំ** សេចក្តីថា ឲ្យទាន គឺបរិច្ចាគ

ទេយ្យធម៌ក្នុងព្រះរតនត្រ័យដ៏ប្រសើរ ។

បណ្ដារតនៈទាំង ៣ ពួក ជនកាលបម្រើ គឺបូជាព្រះមានព្រះភាគដែលទ្រង់តាំងព្រះជន្មនៅដោយបច្ច័យ ៤ និងបម្រើ គឺបូជា បានដល់ បូជាព្រះធាតុ-ចេតិយជាដើម ឧទ្ទិសចំពោះព្រះមានព្រះភាគដែលបរិនិព្វានហើយ ឈ្មោះថាថ្វាយទានក្នុងព្រះពុទ្ធ ។ ពួកជនណា គិតថា យើងទាំងឡាយនឹងបូជាធម៌ ជនទាំងនោះ គប្បីឧបដ្ឋាក គឺបូជា បានដល់ សក្ការៈនូវបុគ្គលទាំងឡាយ ដែលទ្រទ្រង់នូវធម៌ ដោយបច្ច័យ ៤ កាលសាងព្រះធម៌ឲ្យតាំងនៅអស់កាលយូរ ឈ្មោះថា ឲ្យទានក្នុងព្រះធម៌ ។ កាលឧបដ្ឋាក គឺបូជា បានដល់ ធ្វើសក្ការៈព្រះអរិយសង្ឃយ៉ាងនេះ ដោយបច្ច័យ ៤ និងបដិបត្តិយ៉ាងនេះក្នុងភិក្ខុក្រៅអំពីនេះ ឧទ្ទិសដល់ព្រះអរិយសង្ឃនោះ ឈ្មោះថា ថ្វាយទានក្នុងសង្ឃ ។

បទថា **អគ្គំ បុញ្ញំ បវឌ្ឍតិ** សេចក្ដីថា កាលជនទាំងឡាយ មានចិត្តជ្រះថ្លាក្នុងរតនត្រ័យយ៉ាងនេះ ញុំាងបរិច្ចាគយ៉ាងឧឡារ និងការបូជាសក្ការៈយ៉ាងឧឡារឲ្យប្រព្រឹត្តទៅ ឈ្មោះថា កសាងកុសលដ៏ប្រសើរ គឺឧឡាររាល់ៗថ្ងៃ ។

ឥឡូវនេះ ដើម្បីសម្ដែងភាពដែលបុណ្យនោះ ជារបស់ដ៏ប្រសើរ ព្រោះមានផលដ៏ប្រសើរ ទើបត្រាស់ពាក្យជាដើមថា **អគ្គំ អាយុ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អគ្គំ អាយុ** បានដល់ អាយុទិព្វ ឬអាយុមនុស្សដ៏ប្រសើរ គឺវែងបំផុត ។ បទថា **បវឌ្ឍតិ** សេចក្ដីថា កពូនខ្ពស់ឡើងៗ។ បទថា **វណ្ណោ** បានដល់ រូបសម្បត្តិ ។ បទថា **យសោ** បានដល់ បរិវារ-

សម្បត្តិ ។ បទថា **កិត្តិ** បានដល់ សំឡេងសាទរកងរំពង ។ បទថា **សុខំ** បានដល់ សេចក្តីសុខតាមកាយ និងចិត្ត ។ បទថា **ពលំ** បានដល់ កម្លាំងកាយ និងកម្លាំងវិជ្ជា ។ បទថា **អគ្គស្ស ទាតា** សេចក្តីថា ថ្វាយដល់ព្រះរតនត្រ័យដ៏ប្រសើរ ម្យ៉ាងទៀត បំពេញបុណ្យក្នុងព្រះរតនត្រ័យនោះ ដោយការថ្វាយទេយ្យធម៌ដ៏ប្រសើរ ឲ្យឱឡារ ។ បទថា **អគ្គធម្មសមាហិតោ** សេចក្តីថា តាំងនៅហើយ គឺប្រកបហើយដោយធម៌ គឺសេចក្តីជ្រះថ្លា និងធម៌មានទានជាដើមដ៏ប្រសើរ បានដល់ ប្រកបដោយការជ្រះថ្លាមិនញាប់ញ័រ ឬប្រកបដោយធម៌ទាំងឡាយ មានការស្រឡាញ់ និងការពេញចិត្តនៃបុគ្គលជាច្រើនជាដើម ដែលជាផលនៃសេចក្តីជ្រះថ្លានោះ ។ បទថា **អគ្គប្បត្តោ បមោទតិ** សេចក្តីថា ជួបនូវភាពដ៏ប្រសើរ គឺប្រសើរបំផុតក្នុងពួកសត្វ ត្រង់ទីដែលខ្លួនកើតហើយ ឬជាអ្នកសម្រេចមគ្គផលដែលជាលោកុត្តរ រមែងត្រេកអរ គឺរីករាយ បានដល់ ពេញចិត្តច្រើនដូច្នេះឯង ៗល។

**អដ្ឋកថា អគ្គប្បសាទសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ជីវិតសូត្រ

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ការចិញ្ចឹមជីវិតដោយកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាតនេះ លាមកជាងការចិញ្ចឹមជីវិតទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ក្នុងលោក រមែងមានពាក្យផ្តាសា ដូច្នេះថា អ្នកជាបុគ្គលប្រព្រឹត្តត្រាច់ទៅដើម្បីបិណ្ឌបាត មានតែបាត្រក្នុងដៃ ។ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែពួកកុលបុត្រដែលចូលចិត្តចិញ្ចឹមជីវិតដោយកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាតនោះ សុទ្ធតែជាអ្នកប្រព្រឹត្តទៅ ក្នុងអំណាចនៃប្រយោជន៍ ព្រោះអាស្រ័យប្រយោជន៍ មិនមែនព្រោះព្រះរាជាបៀតបៀន មិនមែនព្រោះចោរបៀតបៀន មិនមែនព្រោះជំពាក់បំណុល មិនមែនព្រោះភ័យគ្របសង្កត់ មិនមែនព្រោះដុនដាប ដោយការចិញ្ចឹមជីវិតទេ ពិតជាព្រោះការត្រិះរិះថា ពួកយើងត្រូវជាតិ ជរា មរណៈ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងចង្អៀតចង្អល់ចិត្តគ្របសង្កត់ហើយ ជាអ្នកត្រូវទុក្ខរឹបជាន់ ត្រូវទុក្ខគ្របសង្កត់ហើយ ធ្វើដូចម្តេចហ្ន៎ ការធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ ម្នាលភិក្ខុទាំង-ឡាយ កុលបុត្រនេះបានបួសយ៉ាងនេះហើយ ក៏ជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លាក្នុងកាម មានចិត្តព្យាបាទ មានការត្រិះរិះក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយជាប្រក្រតីគឺមិនសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអង្កត់ឧសសម្រាប់ដុតខ្មោចមានភ្លើងឆេះទាំងសងខាង ប្រឡាក់លាមកត្រង់កណ្តាល រមែងមិនផ្សព្វផ្សាយទៅដើម្បីជាឧសក្នុងស្រុក ក្នុងព្រៃបានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំង-

ឡាយ តថាគតពោលនូវបុគ្គលនេះថា សាបសូន្យចាកភោគៈ របស់គ្រហស្ថផង មិនបានញុំាងប្រយោជន៍ ជារបស់សមណៈឲ្យបរិបូណ៌ផង ក៏យ៉ាងនោះដែរ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

( បុគ្គលទ្រុស្តសីល ) រមែងសាបសូន្យ ចាកភោគៈ
របស់គ្រហស្ថផង ចាកប្រយោជន៍ជារបស់សមណៈផង
ជាបុគ្គលមានចំណែកអាក្រក់ តែងខ្ចាត់ខ្ចាយ រោយរាយ
វិនាសទៅ ដូចជាឧសដុតខ្មោច ។ បុគ្គលបរិភោគដុំដែក
ក្តៅ ដូចជាអណ្តាតភ្លើង ប្រសើរជាងបុគ្គលទ្រុស្ត
សីល មិនសង្រួម ហើយបរិភោគនូវបិណ្ឌបាតរបស់
អ្នកដែន មិនប្រសើរសោះឡើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## ជីវិតសូត្រ

ក្នុងជីវិតសូត្រទី ២ ទ្រង់សម្តែងដោយអំណាចហេតុដែលកើតឡើង ។

[ ៩៣ ] បានឮមកថា សម័យមួយ ព្រះមានព្រះភាគ គង់នៅត្រង់និគ្រោធារាម ជិតក្រុងកបិលវត្ថុ ភិក្ខុទាំងឡាយនាំគ្នាក្រាលទីអង្គុយ និងទីដេកសម្រាប់អាគន្តុកភិក្ខុទាំងឡាយ កាលអាគន្តុកភិក្ខុទាំងឡាយកំពុងទុកដាក់បាត្រ

និងចីវរ សាមណេរទាំងឡាយ នាំគ្នាទទួលយកលាភរបស់ភិក្ខុទាំងឡាយ ដែលមកដល់ហើយ ក្នុងទីចែកលាភ បានបញ្ចូនសំឡេងអឺងកង ព្រះមានព្រះភាគ ទ្រង់បានឮសំឡេងនោះហើយ ទ្រង់បានបណាម គឺបណ្តេញភិក្ខុទាំងនោះ ។ បានឮថា ភិក្ខុទាំងនោះ ជាភិក្ខុថ្មីទាំងអស់ មកកាន់ធម្មវិន័យនេះមិនទាន់យូរឡើយ មហាព្រហ្ម ជ្រាបដល់ព្រឹត្តិការណ៍នោះហើយ បានយាងមកហើយ ទូលសូមពុទ្ធានុគ្រោះ ដល់ភិក្ខុដែលត្រូវបណ្តេញទាំងនោះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ពេញព្រះហឫទ័យក្នុងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគទ្រង់បានបើកឱកាសឲ្យដល់មហាព្រហ្មនោះ ។ ពេលនោះ មហាព្រហ្មបានក្រាបទូលព្រះមានព្រះភាគៗ បានបើកឱកាសឲ្យព្រហ្មហើយ ព្រហ្មថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួច ក៏ចៀសចេញទៅ ។ កាលនោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ចូរសង្ឃមកចុះ ហើយទ្រង់សម្តែងអាការដល់ព្រះអានន្ទត្ថេរ ។ កាលនោះ ទើបភិក្ខុទាំងនោះត្រូវព្រះអានន្ទត្ថេរហៅមក បាននាំគ្នាគាល់ព្រះមានព្រះភាគ ត្រេកអរហើយ បានអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះមានព្រះភាគទ្រង់ពិចារណារកព្រះធម្មទេសនា ដែលជាទីសប្បាយនៃភិក្ខុទាំងនោះ ទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះត្រូវតថាគតបណ្តេញ ព្រោះហេតុនៃអាមិស ធម្មទេសនាគួរពោលអំពីពំនូតបាយ នឹងបានជាទីសប្បាយរបស់ភិក្ខុទាំងនេះ ដូច្នេះហើយ ទើបទ្រង់សម្តែងព្រះធម្មទេសនានេះថា **អន្តមិទំ ភិក្ខវេ** ដូច្នេះជាដើម ។

ក្នុងព្រះធម្មទេសនានោះ **អន្ត** សព្ទនេះ មកហើយក្នុងអត្ថថា ចំណែក

ដូចក្នុងប្រយោគជាដើមថា **សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា បុព្វន្ត-កប្បិកា បុព្វន្តានុទិដ្ឋិនោ** ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ទាំង-ឡាយពួកមួយ ជាអ្នកកំណត់នូវចំណែកនៃខន្ធខាងដើម មានសេចក្តីឃើញរឿយៗ នូវចំណែកនៃខន្ធខាងដើម ។

មកហើយក្នុងអត្ថថា កាត់ផ្តាច់ ដូចក្នុងប្រយោគជាដើមថា **អន្តមកាសិ ទុក្ខស្ស** បានកាត់ផ្តាច់នូវទុក្ខហើយ ។ **អន្តវា អយំ លោកោ បរិវដុមោ** លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដូច្នេះ ។

មកហើយក្នុងអត្ថថា គ្របសង្កត់ ដូចក្នុងប្រយោគជាដើមថា **សា ហរិតន្តំ វា បថន្តំ វា សេលន្តំ វា** តេជោធាតុនោះ ឆេះស្មៅស្រស់ខ្លះ ឆេះផ្លូវធំខ្លះ ថ្មភ្នំខ្លះ ។

មកហើយក្នុងអត្ថថា អវយវៈក្នុងរាងកាយ ដូចក្នុងប្រយោគជាដើមថា **អន្តំ អន្តគុណំ** ពោះវៀនធំ ពោះវៀនតូច ។

មកហើយក្នុងអត្ថថា ចិត្ត ដូចក្នុងប្រយោគជាដើមថា **ចរន្តិ លោកេ បរិវារឆន្នា អន្តោ អសុទ្ធា ពហិ សោភមានា** ជនទាំងឡាយ មានបរិវារហែហម មិនស្អាតខាងក្នុង ស្អាតតែខាងក្រៅ តែងត្រាច់ទៅក្នុងលោកបាន ( យ៉ាងនោះដែរ ) ដូច្នេះ ។

មកហើយក្នុងអត្ថថា ខាងក្នុង ដូចក្នុងប្រយោគជាដើមថា **អប្បេ-កច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគតានិ អន្តោ និមុគ្គបោសីនិ** ក្នុងគុម្ពនៃព្រលិតក្តី ក្នុង

គុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹកនៅឡើយ ដូច្នេះ ។

មកហើយក្នុងអត្ថថា លាមក ដូចក្នុងប្រយោគជាដើមថា **មិគានំ កោដ្ឋកោ អន្តោ បក្ខីនំ បឆ វាយសោ ឯរណ្ឌោ អន្តោ រុក្ខានំ តយោ អន្តា សមាគតា** ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ ឯក្អែកជាសត្វថោកទាបជាងបក្សីទាំងឡាយដែរ ដើមល្ហុងជាឈើថោកទាបជាងឈើទាំង-ឡាយ ពួកថោកទាបទាំង ៣ មកជួបប្រទះគ្នា ដូច្នេះ ។

ក្នុងព្រះសូត្រនេះ **អន្ត** សព្ទ គប្បីជ្រាបអត្ថក្នុងវត្ថុដែលថោកទាបប៉ុណ្ណោះ ព្រោះដូច្នោះ បទថា **អន្តមិទំ ភិក្ខវេ ជីវិកានំ** ទើបមានអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ជីវិត គឺការរស់នៅនេះ ជាជីវិតថោកថយ បានដល់លាមក ដោយអត្ថថា អាក្រក់ជាងការរស់នៅគ្រប់ប្រភេទរបស់អ្នកចិញ្ចឹមជីវិតទាំងឡាយ ។

បទថា **យទិទំ បិណ្ឌោល្យំ** សេចក្តីថា ជីវិតរបស់អ្នកចិញ្ចឹមជីវិតដោយការស្វែងរកដុំបាយ គឺដោយការត្រាច់សូម ។ ក្នុងបទថា **បិណ្ឌោល្យំ** នេះ មានអត្ថនៃបទដូចតទៅនេះ បុគ្គលឈ្មោះថា **បិណ្ឌោល** ព្រោះត្រាច់ទៅដើម្បីដុំបាយ ។ កិច្ចរបស់អ្នកត្រាច់ទៅដើម្បីដុំបាយនោះ ឈ្មោះថា **បិណ្ឌោល្យ** អធិប្បាយថា ជាអ្នកចិញ្ចឹមជីវិតដោយការស្វែងរកដុំបាយ ។

ការជេរឈ្មោះថា **អភិសាប** អធិប្បាយថា មនុស្សទាំងឡាយក្រោធហើយ នឹងជេរដល់សត្រូវរបស់ខ្លួនថា ឯងគួរស្លៀកសំពត់ចាស់ៗ មានដៃកាន់

អំបែង ដើររកដុំបាយ ។ ម្យ៉ាងទៀត នឹងជេរយ៉ាងនេះថា ឯងមិនមានអ្វីធ្វើទេឬ ទើបលះបង់ហិរោត្តប្បៈ ទាំងដែលនៅមានកម្លាំង និងសេចក្តីព្យាយាម ហើយជាមនុស្សកំព្រា មានដៃកាន់អំបែងសុំទានគេបរិភោគ ។

បទថា **តញ្ច ខោ ឯតំ** សេចក្តីថា រមែងចូលដល់ភាពជាអ្នករស់នៅដោយការស្វែងរកដុំបាយ ដែលមានការថ្កោសាបែបនោះ ។ បទថា **កុលបុត្តា ឧបេន្តិ អត្ថវសិកា** សេចក្តីថា កុលបុត្រដោយកំណើត និងកុលបុត្រដែលមានអាចារក្នុងសាសនារបស់តថាគត ជាអ្នកនៅក្នុងអំណាចអត្ថ គឺជាអ្នកនៅក្នុងអំណាចនៃហេតុ អាស្រ័យក្នុងអំណាចនៃហេតុ ហើយចូលដល់ គឺជួប ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **រាជាភិនីតា** ជាដើម ដូចតទៅនេះ មនុស្សពួកណាត្រូវព្រះរាជាចងដាក់ក្នុងគុក ព្រោះបរិភោគរបស់ព្រះរាជា គេចទៅបួសមនុស្សទាំងនោះ ឈ្មោះថា **រាជាភិនីតា** ព្រោះត្រូវនាំទៅកាន់ពន្ធនាគារ ។ ចំណែកពួកមនុស្សណា ត្រូវចោរចាប់ក្នុងព្រៃ គ្រាខ្លះ ត្រូវចោរសម្លាប់ គ្រាខ្លះ សំណូមពរថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ដោះលែងហើយ ខ្ញុំលែងគ្រប់គ្រងផ្ទះហើយបួស បើខ្ញុំធ្វើបុណ្យណាមួយ មានពុទ្ធបូជាជាដើមក្នុងទីនោះៗ ខ្ញុំនឹងឲ្យចំណែកបុណ្យដល់លោកទាំងឡាយ ដូច្នេះហើយ ជាបុគ្គលដែលចោរទាំងនោះដោះលែង ហើយទៅបួស ជនទាំងនោះ ឈ្មោះថា **ចោរាភិនីតា** ព្រោះជាអ្នកត្រូវចោរនាំទៅកាន់ទីដែលត្រូវសម្លាប់ ។ មនុស្សទាំងឡាយណា ជំពាក់បំណុលគេ ហើយមិនមានអ្វីសង រត់ទៅបួស ជនទាំងនោះ ឈ្មោះថា **ឥណដ្ដា** ក្នុងបទថា កុលបុត្រទាំងឡាយក្នុងសាសនា

របស់តថាគត មិនមែនព្រោះព្រះរាជាបៀតបៀន ។បេ។ មិនមែនព្រោះដុនដាប ព្រោះការចិញ្ចឹមជីវិតទេ ម្យ៉ាងទៀត ចូលដល់ដោយគិតថា ពួកយើងត្រូវជាតិ ។បេ។ គ្របសង្កត់ហើយ ធ្វើដូចម្តេចហ្ន៎ ការធ្វើនូវទីបំផុតនៃគំនរទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។

បណ្តាបទទាំងនោះ បទថា **ឳតិណ្ណម្ហា** កាត់បទជា **ឳតិណ្ណា អម្ហា** ប្រែថា យើងទាំងឡាយជាអ្នកត្រូវជាតិ ។បេ។ គ្របសង្កត់ហើយ ។

ក្នុងបទថា **ជាតិយា** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការកកើតជាដំបូងនៃខន្ធទាំងឡាយក្នុងពួកសត្វនោះៗ ឈ្មោះថា **ជាតិ** ការចាស់ ឈ្មោះថា **ជរា** ការបែកធ្លាយ ឈ្មោះថា **មរណៈ** ។ ការក្តៅក្រហាយ គឺការដុតរោលខាងក្នុងនៃបុគ្គលដែលត្រូវវិនាសព្រោះញាតិ វិនាសព្រោះរោគ វិនាសព្រោះភោគៈ វិនាសសីល និងវិនាសទិដ្ឋិពាល់ត្រូវ ឈ្មោះថា **សោក** ។ ការយំរៀបរាប់ដោយវាចានៃបុគ្គល ដែលត្រូវសេចក្តីវិនាសពាល់ត្រូវហើយ ឈ្មោះថា **បរិទេវ** ។ ការបៀតបៀនផ្លូវកាយ នៃអ្នកមានផោដ្ឋព្វៈដែលមិនគួរប្រាថ្នាពាល់ត្រូវ ឈ្មោះថា **ទុក្ខ** ។ ការបៀតបៀនផ្លូវចិត្តរបស់បុគ្គលមានចិត្តពាល់ត្រូវក្នុងអាឃាតវត្ថុទាំងឡាយ ឈ្មោះថា **ទោមនស្ស** ។ សេចក្តីលំបាកដ៏ខ្លាំងក្លា កើតអំពីការតានតឹងរបស់បុគ្គល ដែលវិនាសញាតិជាដើមពាល់ត្រូវ ជាអ្នកមិនអាចទុកចិត្តបាន ឈ្មោះថា **ឧបាយាស** ។ បុគ្គលត្រូវទុក្ខទាំងឡាយ មានជាតិជាដើមគ្របសង្កត់ហើយ ឈ្មោះថា **ទុក្ខបរេតា** គឺបុគ្គលត្រូវទុក្ខទាំងឡាយ មានជាតិទុក្ខជាដើម ចូលជ្រែកចូលទៅខាងក្នុង ។

បទថា **ទុក្ខុបរេតា** នេះ សេចក្តីថា ជាបុគ្គលត្រូវទុក្ខ ជាហេតុនៃទីតាំងរបស់សេចក្តីទុក្ខគ្របសង្កត់ហើយ អធិប្បាយថា ជាតិជាដើម ឈ្មោះថា **ទុក្ខ** ព្រោះជាទីតាំងនៃសេចក្តីទុក្ខនោះ សោកបរិទេវទុក្ខទោមនស្ស និងឧបាយាស ឈ្មោះថា **ទុក្ខ** ព្រោះជាតួទុក្ខ ។ បទថា **អប្បេវនាម ។បេ។ បញ្ញាយេថ** សេចក្តីថា ធ្វើម្តេចហ្ន៎ ការកាត់ផ្តាច់ គឺកិរិយាមានទីបំផុតនៃកងទុក្ខក្នុងវដ្តៈទាំងនេះគប្បីប្រាកដ ។

បទថា **សោ ច ហោតិ អភិជ្ឈាលុ** នេះ ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងដល់កុលបុត្រដែលឲ្យនូវការគិតកើតឡើងខាងដើមថា អញនឹងធ្វើទីបំផុតនៃទុក្ខ ដូច្នេះហើយ បួស តែខាងក្រោយមិនអាចធ្វើការបួសនោះឲ្យដល់ទីបំផុតទុក្ខបាន ។ បណ្តាបទទាំងនោះ បទថា **អភិជ្ឈាលុ** បានដល់ជាអ្នកសម្លឹងទ្រព្យរបស់អ្នកដទៃ ។ បទថា **តិព្វសារាគោ** សេចក្តីថា ជាអ្នកមានរាគៈច្រើន ។ បទថា **ព្យាបន្នចិត្តោ** សេចក្តីថា ជាអ្នកមានចិត្តវិបត្តិព្រោះជាចិត្តខូចដោយព្យាបាទ ។ បទថា **បទុដ្ឋមនសង្កប្បោ** សេចក្តីថា ជាអ្នកត្រូវទោសៈប្រទូស្តហើយ ដោយអំណាចនៃការសម្លាប់ជនដទៃ ដូចគោកាចមានស្នែងមុតស្រួច ។ បទថា **មុដ្ឋស្សតិ** សេចក្តីថា ជាអ្នកមិនមានស្មារតី គឺធ្វើអ្វីមួយក្នុងទីនេះហើយ ក៏រឭកក្នុងទីនេះមិនបាន ដូចក្អែកលាក់ដុំបាយ និងដូចក្អែលាក់ដុំសាច់ហើយ រឭកមិនបាន ដូច្នោះ ។ បទថា **អសម្បជានោ** សេចក្តីថា មិនមាននូវបញ្ញា គឺវៀរចាកការកំណត់ខន្ធជាដើម ។ បទថា **អសមាហិតោ** សេចក្តីថា នៅស្ងៀមមិនបាន ដូចទូកដែលចងត្រង់ទី

ដែលមានទឹកហូរខ្លាំង ។ បទថា **វិព្ភន្តចិត្តោ** សេចក្ដីថា ភិតភ័យ ដូចម្រឹគចូលមកកាន់ផ្លូវ ។ បទថា **ចាគតិន្ទ្រិយោ** សេចក្ដីថា ជាអ្នកមិនសង្រួមឥន្ទ្រិយ ដូចគ្រហស្ថទាំងឡាយ ដែលមិនសង្រួមឥន្ទ្រិយ សម្លឹងមើលមនុស្សដែលខ្វួនហួងហែង ព្រោះមិនមានការសង្រួម ។

បទថា **ឆវាលាតំ** បានដល់ ដុំអង្កត់ឧស ក្នុងទីដែលបូជាសព ។ បទថា **ឧភតោ បទិត្តំ មជ្ឈេ គូថគតំ** សេចក្ដីថា អង្កត់ឧសវែងប្រមាណ ៨ ធ្នាប់ ភ្លើងឆេះទាំងសងខាង ត្រង់កណ្ដាលប្រឡាក់លាមក ។ បទថា **នេវ គាមេ** សេចក្ដីថា ពិតហើយ បើអង្កត់ឧសនោះ ជារបស់ដែលបុគ្គលណាម្នាក់គិតថា អាចនាំចូលទៅប្រើការដើម្បីជាប្រយោជន៍ធ្វើជានឹមនង្គ័ល ធ្វើជាផ្ទោង និងជញ្ជាំងបានសោត ឬពុះធ្វើជាឧសប្រើប្រាស់ក្នុងផ្ទះ បើជារបស់ដែលបុគ្គលណាម្នាក់ គិតថា អាចនាំចូលទៅដើម្បីជាប្រយោជន៍ដល់រនូតគ្រែជាដើម ត្រង់ខ្នមស្រែបានសោត ក៏គប្បីសម្រេចជាឈើក្នុងព្រៃ ។ តែព្រោះហេតុប្រយោជន៍ទាំង ២ យ៉ាងនោះ បុគ្គលមិនអាចនាំមកប្រើបាន ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។

បទថា **តថូបមាហំ** សេចក្ដីថា តថាគតហៅបុគ្គលតាមដែលពោលមកហើយនោះថា ឧបមាដូចយ៉ាងនោះ គឺដូចឧសដែលដុតខ្មោច ។ បទថា **គិហិភោគា ច បរិហីនោ** សេចក្ដីថា ជាបុគ្គលវិនាសចាកភោគៈដែលនឹងត្រូវបាន កាលគ្រហស្ថទាំងឡាយដែលគ្រប់គ្រងផ្ទះចែកមត៌ក និងដោយប្រការដទៃផងដែរ ។ បទថា **សាមញ្ញត្ថញ្ច** សេចក្ដីថា នឹងមិនញុំាង

*សាមញ្ញផលដែលសទ្ធិវិហារិក និងអន្តេវាសិក តាំងនៅក្នុងឱវាទរបស់ឧបជ្ឈាយ៍ និងអាចារ្យទាំងឡាយហើយ គប្បីដល់ដោយអំណាចនៃបរិយត្តិ និងបដិវេធឲ្យបរិបូណ៌ ។*

*ម្យ៉ាងទៀត គប្បីជ្រាបថា ព្រះសាស្តាទ្រង់មិននាំឧបមានេះមកដោយអំណាចនៃបុគ្គលទ្រុស្តសីល តែទ្រង់នាំមកដោយអំណាចនៃបុគ្គលមានសីលបរិសុទ្ធ មិនខ្ជិលច្រអូស ជាអ្នកមានចិត្តត្រូវទោសទាំងឡាយ មានអភិជ្ឈាជាដើមប្រទូស្តហើយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា* **គិហិភោគា** *សេចក្តីថា ចាកគ្រឿងឧបភោគដែលឲ្យកើតកាមសុខ ។ បទថា* **បរិហីនោ** *បានដល់ វិនាសទ្រុឌទ្រោមហើយ ។ បទថា* **សាមញ្ញត្ថំ** *បានដល់ ជាពហុស្សូតក្នុងបដិវេធផង ពហុស្សូតក្នុងផ្លូវបរិយត្តិផង ព្រោះថាបុគ្គលបែបនោះ មិនអាចបានស្តាប់រឿងដែលមិនទាន់បានស្តាប់ និងញុំាងរឿងដែលបានស្តាប់ហើយ ឲ្យជាក់ច្បាស់ ព្រោះជាបុគ្គលខ្ជិលច្រអូស ។ បុគ្គលអាក្រក់ អស់នូវសិរី ព្រោះហេតុនោះ ទើបឈ្មោះថា មានចំណែកអាក្រក់ គឺបុគ្គលមិនមានបុណ្យ បានដល់ បុរសកាឡកិណី ។ បទថា* **បរិធំសមានោ** *សេចក្តីថា វិនាស ។ បទថា* **បកិរេតិ** *សេចក្តីថា ខ្ចាត់ខ្ចាយ គឺរាត់រាយទៅ ។ ពាក្យទាំងអស់នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកការមិនកើតឡើងនៃសេចក្តីចម្រើន គឺសាមញ្ញផលនោះឯង ។ បទថា* **ឆវាលាតំវ វិនស្សតិ** *សេចក្តីថា បុគ្គលនោះ គឺបុគ្គលប្រភេទនោះ មិនប្រកបប្រយោជន៍ដល់បុគ្គលណាម្នាក់ឡើយ វិនាសទៅដូចអង្កត់ឧសដុតខ្មោចដែលពោលមកហើយ ព្រោះ*

ជាអ្នកភ្លាំងភ្លាត់ចាកប្រយោជន៍ទាំង ២ ។ ទោះបីមិនបានធ្វើនូវការកន្លងល្មើស តាមកាយ និងវាចា តែកាលមិនជម្រះចិត្តឲ្យស្អាតក៏វិនាសបាន នឹងពោលទៅថ្វីដល់ការបានប្រព្រឹត្តកន្លងតាមកាយ និងតាមវាចានោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទោសក្នុងភាពជាអ្នកទ្រុស្តសីល ដោយទ្រង់សម្តែងដល់ចំណែកនៃសេចក្តីទុក្ខ ក្នុងអបាយរបស់បុគ្គលនោះហើយ ដោយពាក្យថា **ឥស្សុក្កី** កាលទ្រង់បំណាងឲ្យសត្វទាំងឡាយស្ងាត់ចាកទោស នៃភាពទ្រុស្តសីលនោះ ទើបត្រាស់គាថា ២ ពួក ដោយន័យជាដើមថា មានកព្ចែពព្ចែដោយសំពត់កាសាវៈ ដូច្នេះ ។ អត្ថនៃព្រះគាថាទាំង ២ នោះ បានពោលហើយខាងដើមនោះឯង ។[១]

**អដ្ឋកថា ជីវិតសូត្រទី ២ ចប់**

---

១- លោកមានពោលក្នុងអបាយសូត្រ ។

# សុត្តន្តបិដក

## សង្ឃាដិកណ្ណសូត្រ

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុចាប់ជាយសង្ឃាដិ ( នៃតថាគត ) ហើយដើរតាមអំពីខាងក្រោយៗ ដាក់ជើង ( ខ្លួន ) ត្រង់កន្លែងជើង ( នៃតថាគត ) តែថា ភិក្ខុនោះ ជាអ្នកច្រើនដោយអភិជ្ឈា មានតម្រេកដ៏ក្លៀវក្លាក្នុងកាម មានចិត្តព្យាបាទ មានសេចក្តីត្រិះរិះ ក្នុងចិត្តដ៏អាក្រក់ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនមាំមួន មានចិត្តភ្ញាក់ផ្អើល មានឥន្ទ្រិយជាប្រក្រតី ភិក្ខុនោះ ឈ្មោះថា នៅឆ្ងាយអំពីតថាគតដោយពិត ឯតថាគត ក៏ឈ្មោះថា នៅឆ្ងាយអំពីភិក្ខុនោះដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ មិនឃើញធម៌ កាលបើមិនឃើញធម៌ហើយ ឈ្មោះថា មិនឃើញតថាគត ។ ម្នាលភិក្ខុទាំងឡាយ បើទុកជាភិក្ខុនោះ នៅក្នុងទីមួយចំនួនរយយោជន៍ តែភិក្ខុនោះ មិនជាអ្នកច្រើនដោយអភិជ្ឈា មិនមានតម្រេកដ៏ក្លៀវក្លាក្នុងកាម មិនមានចិត្តព្យាបាទ មិនមានសេចក្តីត្រិះរិះ ក្នុងចិត្តដ៏អាក្រក់ ប្រុងស្មារតី ដឹងខ្លួន មានចិត្តមាំមួន មានចិត្តមូលនឹងធឹង ក្នុងអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយ ភិក្ខុនោះ ឈ្មោះថា នៅជិតតថាគតដោយពិត ទាំងតថាគត ក៏ឈ្មោះថា នៅជិតភិក្ខុនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះឃើញធម៌ កាលបើឃើញធម៌ហើយ ឈ្មោះថា ឃើញតថាគត ។

អ្នកចូរមើលចុះ ភិក្ខុណាដែលជាអ្នកប្រាថ្នាធំ បៀតបៀនគេ លុះអំណាចតណ្ហាជាគ្រឿងញាប់ញ័រ មានចិត្តមិន

ត្រជាក់ ចំពាក់នៅ ( ក្នុងកាម ) បើទុកជាភិក្ខុនោះជាប់ កៀកនឹងព្រះពុទ្ធ ដែលមិនមានតណ្ហាជាគ្រឿងញាប់ញ័រ មានចិត្តត្រជាក់ ឥតជាប់ចំពាក់ ក៏ឈ្មោះថា នៅឆ្ងាយជាដរាប ។ លុះតែភិក្ខុណា ជាបណ្ឌិតបានដឹងច្បាស់នូវធម៌ ( ដោយញាតបរិញ្ញា និងតីរណបរិញ្ញា ) ដឹងច្បាស់នូវចតុសច្ចធម៌ ( ដោយមគ្គញាណ ) មិនមានតណ្ហាជាគ្រឿងញាប់ញ័រ ស្ងប់រម្ងាប់ ដូចជាអន្លង់ទឹកប្រាសចាកខ្យល់ មិនកម្រើក មានចិត្តត្រជាក់ មិនជាប់ចំពាក់ អ្នកចូរមើលចុះ ភិក្ខុនោះ ឈ្មោះថា នៅជិតព្រះពុទ្ធ ដែលមិនមានតណ្ហាជាគ្រឿងញាប់ញ័រ មានចិត្តត្រជាក់ មិនជាប់ចំពាក់ក្នុងកាមជាដរាប ។ សូត្រទី ៣ ។

# អដ្ឋកថា

## សង្ឃាដិកណ្ណសូត្រ

ក្នុងសង្ឃាដិកណ្ណសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៩៤ ] បទថា **សង្ឃាដិកណ្ណេ** បានដល់ ត្រង់ជាយចីវរ ។ បទថា **គហេត្វា** សេចក្តីថា តោង ។ បទថា **អនុពន្ធោ អស្ស** សេចក្តីថា គប្បីជាប់តាមទៅ ។ មានពុទ្ធាធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរបខ្ទះ ក្នុង

ធម្មវិន័យនេះ ទោះបីប្រើដៃរបស់ខ្លួន តោងជាយចីវរតថាគតដែលតថាគត ដណ្តប់ហើយ ជាប់តាមតថាគតទៅ គឺជាអ្នកនៅជិតតថាគតយ៉ាងនេះ ។

បទថា **បាទេ បាទំ និក្ខិបន្តោ** សេចក្តីថា ដាក់ជើងរបស់ខ្លួនត្រង់ស្នាមជើងរបស់តថាគតដែលកំពុងដើរទៅ គឺក្នុងទីដែលតថាគតដាក់ជើង បន្ទាប់ពីការលើកជើងឡើងហើយ ។ ដោយពាក្យទាំង ២ នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា បើភិក្ខុនោះមិនទៅឆ្ងាយអំពីទីឈរ ទីដើររបស់តថាគត នៅក្បែរតថាគតសព្វកាលសោត ។ បទថា **សោ អារកាវ មយ្ហំ អហញ្ច** សេចក្តីថា ភិក្ខុនោះ កាលមិនបំពេញបដិបទា ដែលតថាគតពោលហើយឲ្យបរិបូណ៌ ក៏ឈ្មោះថា ជាអ្នកនៅឆ្ងាយតថាគតនោះឯង តថាគតក៏ឈ្មោះថា នៅឆ្ងាយពីបុគ្គលនោះដូចគ្នា ។ ដោយពាក្យនេះ ព្រះអង្គទ្រង់សម្តែងថា ការឃើញតថាគតដោយមំសចក្ខុនោះក្តី ការនៅរួមគ្នាដោយកាយក្តី មិនមែនហេតុតែការឃើញដោយញាណចក្ខុប៉ុណ្ណោះ និងការរួមគ្នាដោយធម្មកាយឯណោះទេ ដែលជាប្រមាណក្នុងរឿងនេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ មិនឃើញធម៌ កាលបើមិនឃើញធម៌ហើយ ឈ្មោះថា មិនឃើញតថាគត ដូច្នេះ ។ ក្នុងបទថា **ធម្មំ ន បស្សតិ** នោះ មានអធិប្បាយថា លោកុត្តរធម៌ ៩ យ៉ាង ឈ្មោះថា ធម៌ ភិក្ខុនោះ មិនអាចឃើញលោកុត្តរធម៌នោះបាន ដោយចិត្តដែលត្រូវអភិជ្ឈាជាដើមប្រទូស្ត ព្រោះមិនឃើញធម៌នោះ ទើបភិក្ខុនោះ ឈ្មោះថា មិនឃើញធម្មកាយ ដែលព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គថា

កុំឡើយវក្កលិ ប្រយោជន៍អ្វីដោយកាយសម្អុយ ដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថា ឃើញធម៌ ដូច្នេះ ។

និងពុទ្ធដីកាក្នុងទីឃនិកាយ បាដិកវគ្គថា ព្រោះពាក្យថា ធម្មកាយដូច្នេះក្តី ព្រហ្មកាយដូច្នេះក្តី ធម្មភូតដូច្នេះក្តី ព្រហ្មភូតដូច្នេះក្តី ជាឈ្មោះរបស់តថាគត ដូច្នេះជាដើម ។ បទថា **យោជនសតេ** សេចក្តីថា ក្នុងទីចម្ងាយប្រមាណ ១០០ យោជន៍ អធិប្បាយថា ក្នុងទី ១០០ យោជន៍ជាទីបំផុត ។ ពាក្យដ៏សេស គប្បីជ្រាបដោយបរិយាយ ដែលថ្លៃអំពីពេលមកហើយ ។ គប្បីជ្រាបភាពដែលលោក ជាបុគ្គលមិនមានការសម្ងំជាប្រក្រតី ដោយអំណាចនៃការសម្រេចអរិយមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូច្នេះ បទថា **មហិច្ឆោ** សេចក្តីថា ឈ្មោះថា ប្រាថ្នាច្រើន ព្រោះមានចំណង់ខ្លាំងក្លាក្នុងកាមទាំងឡាយ ។ បទថា **វិឃាតវា** សេចក្តីថា ឈ្មោះថា ជាអ្នកមានការបង្អៀតបង្អល់ ព្រោះមានការត្រិះរិះដោយចិត្ត ដែលត្រូវការចង់បានប្រទូស្តហើយ ព្រោះជាអ្នកមានការប្រាថ្នាច្រើន ដោយអំណាចនៃអាឃាតក្នុងសត្វទាំងឡាយ និងព្រោះមិនបានតាមត្រូវការ ។ បទថា **ឃដានុគោ** សេចក្តីថា កាលជាប់តាម តណ្ហានោះដូចជាទាសៈនៃតណ្ហា ពោល គឺការញាប់ញ័រមិនទាន់រលត់ ព្រោះត្រូវក្រវល់ក្រវាយដែលកើតអំពីកិលេស មានរាគៈជាដើមគ្របសង្កត់ហើយ គឺជាប់ហើយ

ដោយចំណាំងអារម្មណ៍ មានរូបជាដើម ។ បទថា **បស្ស យាវញ្ច អារកា** អធិប្បាយថា បុគ្គលទោះបីនៅជិតព្រះសម្មាសម្ពុទ្ធ ដែលជាអ្នកមិនញាប់ញ័រ មានទុក្ខរម្ងាប់ហើយ ជាអ្នកប្រាសចាកតម្រេកហើយ តាមអំណាចនៃឱកាស តែជាអ្នកប្រាថ្នាច្រើន មានការចង្អៀតចង្អល់ ប្រព្រឹត្តទៅតាមតណ្ហា នៅមិនទាន់រម្ងាប់ទុក្ខបាន នៅមានតម្រេក គឺនៅជាពាលបុថុជ្ជន ឈ្មោះថា នៅឆ្ងាយអំពីព្រះមានព្រះភាគជាដរាប តាមសភាវធម៌ សូម្បីនឹងក្រាបទូលក៏មិនមែនធ្វើបានងាយ សមដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា

មេឃ និងផែនដី រមែងឆ្ងាយអំពីគ្នា ត្រើយសមុទ្រនោះ លោកពោលថា ឆ្ងាយអំពីគ្នា ព្រះអាទិត្យជាអ្នកធ្វើនូវពន្លឺ រះឡើងអំពីទិសណា អស្តង្គតទៅវិញក្នុងទិសណា រមែងឆ្ងាយអំពីគ្នា បណ្ឌិតទាំងឡាយពោលថា ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរស ឆ្ងាយក្រៃលែងឆ្ងាយជាងនោះទៅទៀត ។

បទថា **ធម្មមភិញ្ញាយ** សេចក្តីថា ដឹងហើយដោយបញ្ញាជាគ្រឿងដឹងក្រៃលែងនូវសច្ចធម៌ទាំង ៤ ដោយញាតប្បរិញ្ញា និងតីរណប្បរិញ្ញា ក្នុងចំណែកខាងដើម តាមសមគួរ ។ បទថា **ធម្មមញ្ញាយ** សេចក្តីថា ដឹងធម៌នោះឯងក្នុងកាលក្រោយមក ដោយមគ្គញ្ញាណតាមដែនកំណត់ ដោយអំណាចបរិញ្ញាជាដើម ។ បទថា **បណ្ឌិតោ** បានដល់ បុគ្គលដែលជាបណ្ឌិត ព្រោះជាពហូសូតខាងបដិវេធ ។ បទថា **រហទោវ និវាតេ ច** សេចក្តីថា ជាអ្នកមិនញាប់ញ័រ គឺវៀរចាកការរំជើបរំជួល ព្រោះកិលេសស្ងប់រម្ងាប់ ដូចអន្លង់ទឹក

ក្នុងទីដែលស្ងប់ខ្យល់ ដូច្នោះ អធិប្បាយថា អន្ទង់ទឹកនោះ ក្នុងទីដែលមិនមានខ្យល់ មិនត្រូវខ្យល់បក់ នឹងរាបស្មើ មិនមានរលក យ៉ាងណា សូម្បីភិក្ខុនេះ មានកិលេសស្ងប់ហើយ វៀរចាកការញាប់ញ័រ ព្រោះកិលេសស្ងប់ដោយសមាធិ ដែលសម្បយុត្តដោយអរហត្តផល ក្នុងទីសព្វអន្ទើ គឺជាអ្នកមានសភាពស្ងប់សព្វកាល ។ បទថា **អនេជោ** សេចក្តីថា ភិក្ខុនោះជាព្រះអរហន្ត មានសភាពមិនញាប់ញ័រជាដើម ដោយឱកាស ទោះនៅឆ្ងាយព្រះសម្មាសម្ពុទ្ធ ដែលមានសភាពមិនញាប់ញ័រ ក៏ដូចជានៅជិត គឺក្នុងសម្នាក់នោះឯង តាមសភាវធម៌ ដូច្នេះ ៕ល៕

**អដ្ឋកថា សង្ឃាដិកណ្ណសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អគ្គិសូត្រ

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះមាន ៣ យ៉ាង ។ ភ្លើង ៣ យ៉ាង តើដូចម្តេច ។ ភ្លើង គឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើង គឺមោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភ្លើងមាន ៣ យ៉ាងនេះឯង ។

ភ្លើង គឺរាគៈ រមែងដុតពួកសត្វ ដែលត្រេកត្រអាលជ្រប់
នៅក្នុងកាម ចំណែកភ្លើង គឺទោសៈ រមែងដុតពួកជន
ដែលមានចិត្តព្យាបាទ ជាអ្នកសម្លាប់សត្វ ឯភ្លើង គឺ

មោហៈ រមែងជុតពួកសត្វដែលវង្វេង មិនឈ្លាសវៃក្នុងអរិយធម៌ ។ ពួកសត្វដែលមិនស្គាល់ភ្លើងទាំងនេះ ជាអ្នកត្រេកត្រអាលក្នុងសក្កាយ ( ឧបាទានក្ខន្ធ ៥ ) រមែងញុំាងភ្លើងទាំងនោះឲ្យចម្រើន ទាំងញុំាងនរក តិរច្ឆានកំណើតអសុរកាយ និងបិត្តិវិស័យឲ្យចម្រើន មិនផុតចាកចំណងមារបានឡើយ ។ លុះតែបុគ្គលទាំងឡាយណា ប្រកប ( ដោយភាវនា ) ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ ទាំងយប់ទាំងថ្ងៃ បុគ្គលទាំងនោះ មានសេចក្តីសម្គាល់ថា មិនស្អាតជានិច្ច ទើបញុំាងភ្លើង គឺរាគៈឲ្យរលត់បាន ជាសត្វខ្ពង់ខ្ពស់ជាងជន ទើបញុំាងភ្លើង គឺទោសៈ ឲ្យរលត់ ដោយមេត្តាភាវនាបាន ទាំងញុំាងភ្លើងគឺមោហៈឲ្យរលត់ ដោយប្រាជ្ញាជាគ្រឿងទម្លុះទម្លាយកិលេស ។ លុះភិក្ខុទាំងនោះ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ រម្ងត់ភ្លើងកិលេសបានហើយ រមែងរលត់ទាំងខន្ធ មិនមានសេសសល់ កន្លងផុតនូវទុក្ខ មិនមានសេសសល់ ។ អ្នកប្រាជ្ញទាំងឡាយ ជាអ្នកឃើញនូវអរិយធម៌ ( និព្វាន និងសច្ចៈ ៤ ) ដល់នូវវេទ ព្រោះដឹងដោយប្រពៃ ដឹងច្បាស់នូវធម៌

ជាគ្រឿងអស់ជាតិ រមែងមិនវិលមកកាន់ភពទៀត
ឡើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## អគ្គិសូត្រ

ក្នុងអគ្គិសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ

[ ៩៥ ] ឈ្មោះថា **អគ្គី** ព្រោះអត្ថថា ដុត ។ ភ្លើង គឺរាគៈ ឈ្មោះថា **រាគគ្គិ** ។ ព្រោះថា រាគៈកើតឡើង នឹងដុត គឺឆេះនូវសត្វទាំងឡាយ ព្រោះដូច្នោះ ទើបត្រាស់ថា **អគ្គិ** ។ ក្នុងទោសៈ និងមោហៈ ២ យ៉ាងក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **រាគគ្គិ** ជាដើមតទៅ ភ្លើងឆេះឡើង ព្រោះអាស្រ័យកំញមឯណា ក៏ឆេះនូវកំញមនោះ ក្តៅរោលរាលនោះឯង យ៉ាងណា រាគៈជាដើម ក៏ដូច្នោះដូចគ្នា កើតឯងក្នុងសន្តានណា ក៏ដុតរោលនូវសន្តាននោះ ឲ្យរលាកខ្លាំងឡើង ជារបស់ដែលលត់បានលំបាក ។ បណ្តាសត្វដែលត្រូវរាគៈជាដើមដុតនោះ ពួកសត្វដែលរោលរាល កើតហើយអំពីរាគៈដុតនូវហទយៈ ជួបនូវការស្លាប់ ព្រោះសេចក្តីទុក្ខ គឺមិនបាននូវវត្ថុដែលត្រូវការ មិនមានប្រមាណ ។ នេះជាការដុតរោលរបស់រាគៈ ។ តែដោយពិសេស បានដល់ ទេវតាពួកមនោបទោសិកា គឺទេវតាដែលច្យុតព្រោះខឹង

ព្រោះការដុតពេលនៃទោសៈ ។ ទេវតាពួកខិឌ្ឌាបទោសិកា ( ច្យុតព្រោះសប្បាយក្នុងការលេងភ្លេចបរិភោគ ) ជាគំរូ ព្រោះការដុតពេលនៃមោហៈ ។ ព្រោះថា ការបាត់បង់ស្មារតីនៃទេវតាទាំងនោះ មានដោយអំណាចមោហៈ ព្រោះដូច្នោះ ទេវតាទាំងនោះ កាលបណ្តោយឲ្យវេលាបរិភោគអាហារកន្លងហួសទៅ ដោយអំណាចនៃការលេង រហូតដល់ធ្វើកាលកិរិយានេះ គឺការដុតពេលនៃរាគៈជាដើមដែលមានផលទាន់ភ្នែក ។ តែមានផលក្នុងសម្បរាយិកកពដ៏ខ្លាំងក្លាជាង ព្រោះបញ្ជប់បានលំបាក មានដោយអំណាចនៃការកើតឡើងក្នុងនរកជាដើម អធិប្បាយនេះ គួរពង្រីកឲ្យជាក់ច្បាស់តាមអាទិត្តបរិយាយសូត្រ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូច្នេះ បទថា **កាមេសុ មុច្ឆិតេ** សេចក្តីថា ដល់នូវការងប់ជ្រប់ គឺភាពល្ងង់ បានដល់ សេចក្តីប្រមាទ ដោយអត្ថថា **មិច្ឆាចារ** ដោយអំណាចការៈដែលត្រូវជ្រមុជក្នុងវត្ថុកាមទាំងឡាយ ។ បទថា **ព្យាបន្នេ** សេចក្តីថា មានចិត្តដល់នូវសេចក្តីវិនាស ។ ភ្ជាប់សេចក្តីថា រមែងដុត ។ បទថា **ឆរេ** ក្នុងបទថា **ឆរេ ចាណាតិបាតិនោ** នេះ ជាកិរិយារបស់ភ្លើង គឺទោសៈ ។ បទថា **អរិយធម្មេ អកោវិទេ** សេចក្តីថា ជនពួកណា វៀរការធ្វើទុកក្នុងចិត្តនូវការរៀន និងការសាកសួរក្នុងធម៌ទាំងឡាយមានខន្ធ និងអាយតនៈជាដើម ទូទៅគ្រប់យ៉ាង ឈ្មោះថា ជាអ្នកមិនឈ្លាសក្នុងធម៌ ជនទាំងនោះ ត្រូវសេចក្តីវង្វេងគ្របសង្កត់ហើយ ព្រះមានព្រះភាគត្រាស់ហៅថា ឈ្មោះថា ជាអ្នកវង្វេងដោយវិសេស ។ បទថា **ឯតេ អគ្គី**

**អជានន្តា** សេចក្ដីថា មិនដឹងថា ភ្លើង គឺរាគៈជាដើមនេះ ដុតពេលទាំងក្នុងភពនេះ និងក្នុងសម្បរាយិកភព គឺមិនចាក់ធ្លុះដោយអំណាចនៃការសម្រេចដោយបរិញ្ញាកិច្ច និងដោយអំណាចនៃការសម្រេចដោយបហានកិច្ច ។ បទថា **សក្កា យាភិរតា** សេចក្ដីថា ត្រេកអរក្រៃលែងក្នុងកាយរបស់ខ្លួន គឺក្នុងឧបាទានក្ខន្ធ ៥ ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា **វឌ្ឍយន្តិ** សេចក្ដីថា ចម្រើន គឺសន្សំ ដោយការកើតឡើងរឿយៗ ។ បទថា **និរយំ** បានដល់នរកគ្រប់រណ្ដៅ គឺនរកធំ ៨ រណ្ដៅ និងឧស្សទនរក ១៦ រណ្ដៅ ។ បទថា **តិរច្ឆានញ្ច យោនិយោ** បានដល់ កំណើតតិរច្ឆានផងដែរ ។ បទថា **អសុរំ** បានដល់ អសុរកាយ ភ្ជាប់សេចក្ដីថា បន្ថែមនូវបិត្តិវិស័យចូលផងដែរ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងវដ្ដៈដោយមុខ គឺការសម្ដែងភាវៈដែលភ្លើង គឺរាគៈជាដើមដុតពេលទាំងក្នុងភពនេះ និងភពខាងមុខ ដោយព្រះតម្រាស់ត្រឹមប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីសម្ដែងវិវដ្ដៈ ដោយការរម្ងាត់នូវភ្លើងរាគៈជាដើម ទើបត្រាស់ពាក្យជាដើមថា **យេ ច រត្តិន្ទិវា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យុត្តា** សេចក្ដីថា ប្រកបហើយ ដោយអំណាចនៃការប្រកបរឿយៗ នូវភាវនា ។ បណ្ដាភាវនាទាំង ២ នោះ សាសនានៃព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងភាពដែលភ្លើង គឺរាគៈជាដើមរលត់បាន មិនមែនក្នុងសាសនាដទៃ ។ ម្យ៉ាងទៀត កាលទ្រង់សម្ដែងវិធីរលត់ភ្លើង គឺរាគៈទាំងនោះជាដើមនោះ និងអសុភកម្មដ្ឋានដែលមិនទូទៅដល់សាសនាដទៃ ដោយសង្ខេបប៉ុណ្ណោះ ទើបត្រាស់ថា

*លុះតែបុគ្គលទាំងឡាយណា ប្រកប ( ដោយភាវនា ) ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ ទាំងយប់ទាំងថ្ងៃ បុគ្គលទាំងនោះ មានសេចក្ដីសម្គាល់ថាមិនស្អាតជានិច្ច ទើបញ៉ាំងភ្លើង គឺរាគៈឲ្យរលត់បាន ជាសត្វខ្ពង់ខ្ពស់ជាងជនទើបញ៉ាំងភ្លើង គឺទោសៈឲ្យរលត់ ដោយមេត្តាភាវនាបាន ទាំងញ៉ាំងភ្លើង គឺមោហៈឲ្យរលត់ ដោយប្រាជ្ញាជាគ្រឿងទម្លុះទម្លាយកិលេស ។*

*បណ្ដាបទទាំងនោះ បទថា* **អសុភសញ្ញិនោ** *សេចក្ដីថា បុគ្គលឈ្មោះថា មានអសុភសញ្ញាជាប្រក្រតី ព្រោះប្រកបសេចក្ដីព្យាយាមរឿយៗ ក្នុងអសុភភាវនា ដោយអំណាចអាការ ៣២ និងដោយអំណាចអារម្មណ៍ មានសាកសពដែលហើមប៉ោងជាដើម ។ បទថា* **មេត្តាយ** *សេចក្ដីថា ដោយមេត្តាភាវនាដែលត្រាស់ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកថា ភិក្ខុនោះ រមែងមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ក្នុងគាថានេះ អ្នកសិក្សាគប្បីជ្រាបការរលត់ភ្លើង គឺរាគៈ ភ្លើង គឺទោសៈ ដោយអនាគាមិមគ្គ ដែលកើតឡើងដោយឈាន មានអសុភជាអារម្មណ៍ និងមានមេត្តាឈានជាអារម្មណ៍ឲ្យជាបាទ ។ បទថា* **បញ្ញាយ** *សេចក្ដីថា ដោយមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **យាយំ និព្វេធគាមិនី** *ព្រោះថា បញ្ញានោះ នឹងទម្លុះទម្លាយនូវកិលេស និងខន្ធ គឺប្រព្រឹត្តទៅ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា* **និព្វេធ-គាមិនី។**

*បទថា* **អសេសំ បរិនិព្វន្តិ** *សេចក្ដីថា លោកទាំងនោះឲ្យភ្លើង គឺរាគៈ*

ជាដើមរលត់ទៅមិនមានសេសសល់ដោយអរហត្តមគ្គ ហើយតាំងនៅ ដោយសឧបាទិសេសនិព្វានធាតុ ឈ្មោះថា ជាអ្នកមានបញ្ញាគ្រឿងរក្សាខ្លួន ព្រោះដល់នូវការបរិបូណ៌នៃបញ្ញា ឈ្មោះថា ជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ព្រោះជាអ្នកលះនូវការខ្ជិលបានជាសមុច្ឆេទហើយដោយសម្មប្បធាន និងព្រោះជាអ្នកខ្មីឃ្មាត ដោយការចូលផលសមាបត្តិ ឈ្មោះថា ជាអ្នករម្ងត់ មិនមានសេសសល់ ដោយអនុបាទិសេសនិព្វានធាតុ ព្រោះចិត្តចុងក្រោយរលត់ហើយ បន្ទាប់អំពីនោះទៅ ក៏នឹងឆ្លងទៅ គឺឈានកន្លងវដ្តទុក្ខបាន មិនមានសេសសល់ គឺមិនបន្សល់ឡើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងនូវការរលត់ដោយអនុបាទិសេស-និព្វានធាតុដល់ពួកភិក្ខុដែលរម្ងត់ភ្លើង គឺរាគៈជាដើមបានយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សរសើរដោយគុណធម៌ទាំងឡាយ ដែលលោកបានចាក់ធ្លុះហើយ ទើបត្រាស់គាថាចុងក្រោយ ។

បណ្ដាបទទាំងនោះ បទថា **អរិយទស្សា** សេចក្ដីថា បុគ្គលណាបានឃើញនូវធម៌ដែលអរិយៈទាំងឡាយ គឺបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមគប្បីឃើញ ឬឃើញព្រះនិព្វានដែលឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ ម្យ៉ាងទៀត ឃើញនូវសច្ចៈទាំង ៤ ដ៏ប្រសើរ ព្រោះដូច្នោះ ទើបលោកទាំងនោះ ឈ្មោះថា **អរិយទស្ស** គឺជាអ្នកឃើញនូវសច្ចៈដ៏ប្រសើរ ។ បុគ្គលណាដល់នូវទីបំផុតនៃវេទ គឺមគ្គញាណ ឬដល់ទីបំផុតនៃសង្សារដោយវេទ គឺមគ្គប្បញ្ញាណនោះ ព្រោះដូច្នោះ ទើបលោកទាំងនោះឈ្មោះថា **វេទគុនោ**

គឺជាអ្នកទូវទីបំផុតនៃវេទ ។ បទថា **សម្មទញ្ញាយ** សេចក្តីថា ព្រោះដឹងកុសលធម៌ និងខន្ធជាដើម ដែលត្រូវដឹងគ្រប់យ៉ាង ដោយប្រពៃនោះឯង ។ បទដ៏សេស មានន័យដូចពោលមកហើយ ។ល។

**អដ្ឋកថា អគ្គិសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ឧបបរិក្ខសូត្រ

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុពិចារណាយ៉ាងណាៗ ហើយ វិញ្ញាណ មិនរាយមាយ មិនរវើរវាយទៅខាងក្រៅ ទាំងមិនស្ថិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ភិក្ខុគួរពិចារណាយ៉ាងនោះៗ ទើបហេតុជាគ្រឿងបន្តឲ្យកើតនៃជាតិទុក្ខ ជរាទុក្ខ និងមរណទុក្ខ មិនមានតទៅ ។

ភិក្ខុដែលបានលះបង់ នូវគ្រឿងជាប់ចំពាក់ ៧ យ៉ាង
កាត់ផ្តាច់នូវតណ្ហា សម្រាប់នាំទៅកាន់ភព រមែងអស់
ការត្រាច់រង្គាត់ទៅកាន់ជាតិ ភពថ្មីរបស់ភិក្ខុនោះ មិន
មានទៀតឡើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## ឧបបរិក្ខសូត្រ

[ ៩៦ ] ក្នុងឧបបរិក្ខសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **តថា តថា** បានដល់ ដោយអាការនោះៗ ។ បទថា **ឧបបរិក្ខេយ្យ** សេចក្តីថា គប្បីពិចារណាមើល ឬ ពិនិត្យមើល ។ បទថា **យថា យថាស្ស ឧបបរិក្ខតោ** សេចក្តីថា កាលភិក្ខុនោះពិចារណាដោយប្រការណាមួយ ។ បទថា **ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ** សេចក្តីថា វិញ្ញាណ គឺចិត្តនៃភិក្ខុនោះ ឈ្មោះថា ជាចិត្តមិនរាយមាយ ព្រោះមិនមានការរាយមាយ ដែលកើតឡើងក្នុងអារម្មណ៍ មានរូបជាដើមខាងក្រៅ គឺជាចិត្តតាំងមាំ គប្បីជាចិត្តមិនរាយមាយអំពីអារម្មណ៍កម្មដ្ឋាននោះឯង មានពុទ្ធាធិប្បាយថា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុរូបនេះ ជាអ្នកប្រារព្ធវិបស្សនា ពិចារណា គឺពិចារណាសង្ខារទាំង-ឡាយ បានដល់ កាន់យកនិមិត្តក្នុងសមថៈ ដោយអំណាចនៃការកំណត់អាការដែលចិត្តតាំងមាំមកអំពីមុន ហើយឲ្យសម្មសនញ្ញាណ ប្រព្រឹត្តទៅសព្វកាល មិនមានរវាងចន្លោះ ដោយគោរព វិបស្សនាចិត្តរបស់ខ្លួន នឹងមិនកើតឡើងក្នុងអារម្មណ៍ មានរូបជាដើម ដែលក្រៅអំពីកម្មដ្ឋាន គឺមិនគប្បីជាចំណែកនៃការរាយមាយ ព្រោះប្រារព្ធសេចក្តីព្យាយាមច្រើនពេក ដោយប្រការណាមួយ ភិក្ខុគប្បីពិចារណា គឺត្រិះរិះដោយប្រការនោះៗ ដូច្នេះ ។ បទថា **អជ្ឈត្តំ អសណ្ឋិតំ** សេចក្តីថា ព្រោះចិត្តរបស់ភិក្ខុនោះ ឈ្មោះថា កំពុងឈប់ហើយ ព្រោះកំពុងឈប់ដោយអំណាចនៃការញាប់ញ័រ ឈ្មោះថា

**អជ្ឈត្តំ** គឺក្នុងអារម្មណ៍កម្មដ្ឋាន ពោល គឺអារម្មណ៍ដែលមានខាងក្នុងដោយការគ្របសង្កត់នូវការខ្ជិលប្រអូសបាន ព្រោះហេតុនៀយណាយនូវសេចក្តីព្យាយាម ប្រព្រឹត្តទៅថយចុះហើយ សមាធិក៏ទីងមានកម្លាំង តែកាលព្រះយោគាវចរប្រកបសេចក្តីព្យាយាមជានិច្ចហើយ ចិត្តក៏ឈ្មោះថា ជាចិត្តមិនឈប់ គឺចិត្តប្រព្រឹត្តទៅកាន់វិថីហើយ ដូច្នោះ គប្បីពិចារណាដោយប្រការដែលលោកពិចារណាហើយវិញ្ញាណ គឺចិត្តមិនឈប់ខាងក្នុង គឺគប្បីប្រព្រឹត្តទៅកាន់វិថី ។ បទថា **អនុបាទាយ ន បរិតស្សេយ្យ** មានការភ្ជាប់សេចក្តីថា ភិក្ខុនោះគួរពិចារណា ដោយប្រការដែលភិក្ខុនោះពិចារណា មិនកាន់យកសង្ខារណាមួយក្នុងរូបជាដើម ដោយអំណាចការប្រកាន់ដោយតណ្ហា និងទិដ្ឋិថា នុ៎ះជារបស់អញ នុ៎ះជាអត្តារបស់អញ ហើយបន្តអំពីនោះទៅ ក៏មិនគប្បីតក់ស្លុត ដោយអំណាចការប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ សួរថា កាលពិចារណាដូចម្តេច ទើបទាំង ៣ យ៉ាងនេះ ( ចិត្តមិនរាយមាយ មិនរវើរវាយទៅខាងក្រៅ មិនឈប់នៅខាងក្នុង ) ទើបមាន ឆ្លើយថា កាលភិក្ខុនោះពិចារណាដល់ធម៌ដែលជាចំណែកនៃការរាយមាយ ជាចំណែកនៃការខ្ជិលប្រអូស ប្រកបសេចក្តីព្យាយាមឲ្យស្មើ ជម្រះចិត្តឲ្យស្អាតចាកវិបស្សនូបក្កិលេសខាងដើមហើយ ក៏ពិចារណាដោយវិបស្សនាញាណ ប្រព្រឹត្តទៅកាន់វិបស្សនាវិថី ដោយប្រពៃនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបាយសម្រាប់ជម្រះចិត្តឲ្យស្អាតចាកសេចក្តីព្យាយាមច្រើនពេក ការព្យាយាមធូរថយពេក និងវិបស្សនូបក្កិ-

លេស ដោយបដិបទាញាណទស្សនវិសុទ្ធិដែលប្រារព្ធហើយដល់ភិក្ខុ ដែលបំពេញកម្មដ្ឋាន មានសច្ចៈទាំង ៤ ជាអារម្មណ៍តាមលំដាប់ហើយ ឥឡូវនេះ កាលទ្រង់សម្ដែងថា កាលព្រះយោគាវចរ ជម្រះវិបស្សនាញាណឲ្យស្អាតយ៉ាងនោះ មិនយូរមិនឆាប់ ក៏នឹងប្រព្រឹត្តទៅដើម្បីបន្តដោយវិបស្សនាមគ្គ ហើយឈានកន្លងវដ្ដទុក្ខទាំងអស់បាន ទើបត្រាស់ពាក្យជាដើមថា **ពហិទ្ធា ភិក្ខវេ វិញ្ញាណេ** ដូច្នេះ ។ ពាក្យនោះ មានន័យដូចពោលមកហើយនោះឯង ។

ឯព្រះពុទ្ធវចនៈដែលព្រះមានព្រះភាគត្រាស់ថា ទើបហេតុជាគ្រឿងបន្តឲ្យកើតនៃទុក្ខ គឺជាតិ ជរា និងមរណៈ នឹងមិនមានតទៅ មានអត្ថដូច្នេះ គឺកាលកិលេសអស់ទៅហើយ ដោយមគ្គខាងចុងតាមលំដាប់មគ្គ ដោយមិនមានសេសសល់ឡើយ ព្រោះបន្តដោយវិបស្សនាមគ្គយ៉ាងនេះ ហេតុជាគ្រឿងបន្តឲ្យកើត គឺហេតុកើតឡើងនៃវដ្ដទុក្ខទាំងពួង គឺជាតិ ជរា និងមរណៈ មិនមាន ឯការកើតឡើងនៃវដ្ដទុក្ខទាំងមូល ក៏នឹងមិនមាន ក្នុងកាលតទៅ គឺក្នុងអនាគត ម្យ៉ាងទៀត ហេតុកើតនៃទុក្ខ ពោល គឺជាតិ ក៏នឹងមិនមាន ឯការកើតនៃទុក្ខ គឺជរា និងមរណៈ ក៏នឹងមិនមាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាតទៅ បទថា **សត្តសង្គប្បហីនស្ស** សេចក្ដីថា បុគ្គលឈ្មោះថា លះនូវគ្រឿងជាប់ជំពាក់ ៧ យ៉ាងបាន ព្រោះលះនូវគ្រឿងជាប់ជំពាក់ទាំងនោះបាន គឺតណ្ហាសង្គៈ ១ ទិដ្ឋិសង្គៈ ១ មានសង្គៈ កោធសង្គៈ ១ អវិជ្ជាសង្គៈ ១ កិលេសសង្គៈ ១ ទុច្ចរិតសង្គៈ ១ ។ តែអាចារ្យពួកខ្លះពោលថា គឺជាប់ជំពាក់ ៧ យ៉ាង គឺអនុស័យ ៧ នោះឯង ។

*បទថា* **នេត្តិច្ឆិន្នស្ស** *សេចក្តីថា បុគ្គលកាត់នូវកិលេសដែលនាំទៅកាន់ភពដាច់ហើយ ។ បទថា* **វិក្ខីណោ ជាតិសំសារោ** *សេចក្តីថា សង្សារឈ្មោះថា ជាតួជាតិ ព្រោះជាហេតុនៃជាតិដោយការប្រព្រឹត្តទៅ ដោយអំណាចការកើតឡើងហើយ កើតឡើងទៀត ព្រោះដូច្នោះ ទើបឈ្មោះថា* **ជាតិសំសារោ** *សង្សារ គឺជាតិនោះអស់ហើយ គឺដល់នូវទីបំផុតហើយ ព្រោះតណ្ហាដែលនាំទៅកាន់ភព ត្រូវកាត់ផ្តាច់ហើយ បន្ទាប់អំពីនោះ ភពថ្មីរបស់លោកមិនមានទៀតឡើយ ដូច្នេះ ៕*

**អដ្ឋកថា ឧបបរិក្ខសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## កាមូបបត្តិសូត្រ

*[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃកាមនេះមាន ៣ ។ ការកើតឡើងនៃកាម ៣ តើដូចម្តេច ។ គឺពួកសត្វដែលមានកាមតាំងឡើងចំពោះ ១ ពួកសត្វដែលកើតក្នុងឋាននិម្មានរតី ( ត្រេកអរចំពោះកាម ដែលនិម្មិតដោយខ្លួនឯង ) ១ ពួកសត្វដែលកើតក្នុងឋានបរនិម្មិតវសវត្តី ( ប្រព្រឹត្តទៅក្នុងអំណាចនៃកាម ដែលអ្នកដទៃនិម្មិតឲ្យ ) ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃកាម មាន ៣ នេះឯង ។*

*ពួកសត្វដែលមានកាមតាំងឡើងចំពោះក្តី ពួកទេវតាណា*

ដែលកើតក្នុងឋានបរនិម្មិតវសវត្តីក្តី ពួកទេវតាណាដែលកើតក្នុងឋាននិម្មានរតីក្តី និងពួកសត្វណាដទៃ ក្រៅអំពីនេះ ដែលជាអ្នកបរិភោគនូវកាមក្តី ( ពួកសត្វទាំងអស់នោះ ) មិនធ្លងនូវកាមបានបែបនេះហើយ ប្រែទៅជាដទៃ ព្រោះការបរិភោគកាមបានឡើយ ( ព្រោះហេតុនោះ ) កាមទាំងឡាយណា ជារបស់ទិព្វក្តី កាមទាំងឡាយណា ជារបស់មនុស្សក្តី អ្នកប្រាជ្ញលះបង់នូវកាមទាំងអស់នោះ កាត់ផ្តាច់នូវខ្សែ គឺតណ្ហាជាគ្រឿងជាប់ចំពាក់ ដោយសេចក្តីរីករាយក្នុងរូបជាទីស្រឡាញ់ដែលពួកសត្វធ្លងបានដោយក្រ ហើយរលត់ មិនមានសេសសល់ កន្លងនូវទុក្ខ មិនមានសេសសល់ ពួកអ្នកប្រាជ្ញ ជាអ្នកឃើញនូវអរិយធម៌ ដល់នូវវេទ ព្រោះដឹងដោយប្រពៃ ដឹងច្បាស់នូវធម៌ ជាគ្រឿងអស់ជាតិរមែងមិនវិលមកកាន់ភពថ្មីទៀតឡើយ ។ សូត្រទី ៦ ។

# អដ្ឋកថា

## កាមូបបត្តិសូត្រ

ក្នុងកាមូបបត្តិសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៩៧ ] បទថា **កាមូបបត្តិយោ** បានដល់ ការបាននូវកាម ឬការសេពនូវកាម ។ បទថា **បច្ចុបដ្ឋិតកាមា** បានដល់ ជាអ្នកប្រាថ្នាជានិច្ច គឺមានអារម្មណ៍ជានិច្ច ដូចមនុស្សទាំងឡាយ ។ អធិប្បាយថា មនុស្សទាំងឡាយប្រើអំណាចក្នុងវត្ថុជានិច្ច មានចិត្តប្រតិព័ទ្ធ ទោះនាំយកមាតុគ្រាមនោះឯងមកឲ្យរាប់រយ រាប់ពាន់ក៏នៅតែទទួលរហូត ។ ទេវតាពួកខ្លះក៏ដូចគ្នា អធិប្បាយថា ទេវតាដែលនៅក្នុងទេវលោក ៤ ជាន់ រាប់អំពីទេវតាជាន់ចាតុម្មហារាជិកាទៅ ក៏សោយអំណាចក្នុងវត្ថុជានិច្ច ។ ក្នុងសេចក្តីនេះ មានរឿងរបស់បញ្ចសិខទេវបុត្រជាគំរូ ។ ទោះបីសត្វដែលកើតក្នុងអបាយដ៏សេស វៀរសត្វនរកក៏ដូចគ្នា គឺប្រើអំណាចក្នុងវត្ថុជានិច្ចនោះឯង ។ ពិតហើយ ត្រីក៏ប្រើអំណាចក្នុងត្រីញីរបស់ខ្លួន អណ្តើកក៏ប្រើអំណាចក្នុងអណ្តើកញីរបស់ខ្លួន សត្វតិរច្ឆានទាំងអស់ និងប្រេតប្រភេទវិនិបាតកៈ រមែងប្រើអំណាចក្នុងវត្ថុជានិច្ច ដូចពណ៌នាមកនេះ ព្រោះដូច្នោះ សត្វទាំងនេះ តាំងអំពីសត្វដែលកើតក្នុងអបាយដ៏សេស រហូតដល់ទេវតាជាន់តុសិត វៀរសត្វនរក ឈ្មោះថា មានកាមប្រាកដហើយ ។

បទថា **និម្មានរតិនោ** សេចក្តីថា ទេវតាទាំងឡាយ ឈ្មោះថា និម្មានរតី ព្រោះមានការត្រេកអរក្នុងនិម្មិតសម្បត្តិ និម្មិតដែលនិម្មិតឡើងឯង អធិប្បាយថា ទេវតាទាំងនោះ រមែងប្រាថ្នារូបប្រភេទណា ដោយអំណាចនៃរូបពណ៌

ទៀត រូបពណ៌លឿងជាដើម ក៏និម្មិតរូបប្រភេទនោះ ហើយត្រេកអរ ដូចទេវតាពួកមនាបកាយិកាដែលនៅចំពោះមុខព្រះអនុរុទ្ធ ដូច្នោះ ។

បទថា **បរនិម្មិតវសវត្តិនោ** សេចក្តីថា ទេវតា ឈ្មោះថា បរនិម្មិតវសវត្តី ព្រោះញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងកាម ដែលទេវតាដទៃនិម្មិត អធិប្បាយថា ទេវតាដទៃដឹងចិត្តរបស់ទេវតាជាន់បរនិម្មិតវសវត្តី ហើយនិម្មិតកាមភោគៈឲ្យតាមចិត្ត ទេវតាទាំងនោះក៏សោយអំណាចក្នុងកាមភោគៈ ដែលទេវតាដទៃនិម្មិតឲ្យនោះ ។ សួរថា ទេវតាទាំងនោះដឹងចិត្តរបស់អ្នកដទៃបានដូចម្តេច ឆ្លើយថា ដឹងបានដោយអំណាចនៃការគប់រកគ្នាមកជាប្រចាំ អធិប្បាយថា ដូចភ្នាក់ងារអ្នកនាំយកព្រះក្រយាហារ ជាអ្នកឈ្លាសក្នុងព្រះក្រយាហារដែលព្រះរាជាចូលចិត្តសោយ យ៉ាងណា ទេវតាដទៃក៏ដឹងអារម្មណ៍ដែលទេវតាជាន់បរនិម្មិតវសវត្តី គាប់ចិត្តដោយប្រក្រតី រមែងនិម្មិតអារម្មណ៍បែបនោះដូច្នោះ ទេវតាទាំងនោះ ញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍នោះ រមែងបរិភោគកាមទាំងឡាយ ដោយអំណាចការសេពមេថុនជាដើម តែអាចារ្យពួកខ្លះពោលថា កាមកិច្ចរបស់ទេវតាទាំងនោះ រមែងសម្រេចដោយហេតុត្រឹមតែញញឹមដោយហេតុត្រឹមតែការសម្លឹងមើល ដោយហេតុត្រឹមតែឱបក្រសោបដោយហេតុត្រឹមតែចាប់ដៃ ដូច្នេះ ។ ក្នុងអដ្ឋកថា លោកជំទាស់ពាក្យនោះថា ហេតុត្រឹមតែការញញឹមជាដើមមិនមាន អធិប្បាយថា បុគ្គលដែលមិនពាល់ត្រូវគ្នា ដោយកាយកាមកិច្ច គឺផោដ្ឋព្វៈរមែងមិនសម្រេចបានឡើយ ។ សម្រាប់ទេវតាជាន់កាមាទាំង ៦ មានកាមជាប្រក្រតីដូចគ្នា ដូចដែលព្រះមានព្រះភាគ

ត្រាស់ក្នុងវិភង្គថា

ពួកទេវតាដែលស្ថិតនៅក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់នោះជា
អ្នកសម្រេចនូវកាមទាំងពួង ៗ អាយុរបស់ពួកទេវតាទាំងអស់
ដែលបណ្ឌិតរាប់ដោយរួបរួម តើប៉ុន្មានឆ្នាំ ដូច្នេះ ៗ

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថាទាំងឡាយតទៅនេះ បទថា **យេ ចញ្ញេ** បានដល់ ទេវតាដទៃអំពីទេវតាដែលពោលមកហើយ និងមនុស្សដែលបរិភោគកាម និងសត្វដែលចូលដល់អបាយពួកខ្លះទាំងអស់ ៗ បទថា **ឥត្ថភាវញ្ញថាភាវំ** សេចក្តីថា ទេវតា និងមនុស្សទាំងនោះ រមែងមិនប្រព្រឹត្តទៅកន្លង គឺមិនកន្លងផុតសង្សារ ២ ប្រភេទ គឺអត្តភាពតាមដែលពោលមកនេះ ១ ភាពដទៃអំពីនេះ ពោល គឺឧបបត្តិភពដទៃ ១ ៗ បទថា **សព្វេ បរិច្ចជេ កាមេ** សេចក្តីថា បណ្ឌិតគប្បីលះនូវកាមទាំងអស់ ចែកប្រភេទជាកាមចិត្តជាដើម ទាំងជាវត្ថុកាម និងកិលេសកាម អធិប្បាយថា កាលលះនូវកិលេសកាមដោយអនាគាមិមគ្គនោះឯង ឈ្មោះថា លះវត្ថុកាម ៗ បទថា **បិយរូបសាតរូបគធិតំ** សេចក្តីថា ត្រេកអរហើយ ក្នុងបិយរូបទាំងឡាយ ដោយការពេញចិត្តសុខវេទនា ក្នុងរូបជាដើម ៗ បទថា **ឆេត្វា សោតំ ទុរច្ចយំ** សេចក្តីថា កាត់ផ្តាច់នូវក្រសែតណ្ហា ដែលអ្នកដទៃឈានកន្លងបានដោយលំបាក គឺឈានកន្លងបានដោយកម្រ ដោយអរហត្តមគ្គ ៗ បទដ៏សេសមានន័យដូចពោលហើយ ខាងដើមនោះឯង ។ល។

**អដ្ឋកថាកាមូបបត្តិសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## កាមយោគសូត្រ

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយកាមយោគៈ ( កិលេសជាគ្រឿងប្រកប គឺតម្រេកក្នុងបញ្ចកាមគុណ ) ប្រកបដោយភវ-យោគៈ ( កិលេសជាគ្រឿងប្រកប គឺតម្រេកក្នុងរូបភព និងអរូបភព ) ឈ្មោះថា សកទាគាមិបុគ្គល ព្រោះនៅមកកាន់អត្តភាពជាមនុស្សនេះវិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកកាមយោគៈ តែប្រកបដោយភវយោគៈ ឈ្មោះថា អនាគាមិបុគ្គល ព្រោះមិនមកកាន់អត្តភាពជាមនុស្សទៀត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកកាមយោគៈ ប្រាសចាកភវយោគៈ ឈ្មោះថា អរហន្ត អស់អាសវៈហើយ ។

ពួកសត្វ ដែលប្រកបដោយកាមយោគៈ និងភវយោគៈ
ទាំងពីរ ជាសត្វប្រព្រឹត្តទៅដើម្បីជាតិ និងមរណៈ រមែង
អន្ទោលទៅកាន់សង្សារ ។ ចំណែកពួកសត្វណា បាន
លះបង់នូវកាមទាំងឡាយ តែមិនទាន់ដល់នូវការអស់
ទៅនៃអាសវៈ នៅប្រកបដោយភវយោគៈនៅឡើយ
ពួកសត្វនោះ ហៅថា អនាគាមិបុគ្គល ។ លុះតែពួក
សត្វណា បានកាត់នូវសេចក្តីសង្ស័យ អស់សេចក្តី
ប្រកាន់ក្នុងភពថ្មីហើយ ឬពួកសត្វណា ដែលបានដល់
នូវការអស់ទៅនៃអាសវៈក្នុងលោក ពួកសត្វនោះឯង
ឈ្មោះថា បានដល់នូវត្រើយ គឺព្រះនិព្វាន ។ សូត្រទី ៧ ។

# អដ្ឋកថា

## កាមយោគសូត្រ

ក្នុងកាមយោគសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៩៨ ] បទថា **កាមយោគយុត្តោ** សេចក្តីថា រាគៈដែលប្រកបដោយបញ្ចកាមគុណ ឈ្មោះថា **កាមយោគ** បុគ្គលអ្នកប្រកបដោយកាមយោគៈនោះ ឈ្មោះថា **កាមយោគយុត្តោ** ។ បទថា **កាមយោគយុត្តោ** នេះ ជាឈ្មោះរបស់កាមរាគៈ ដែលមិនទាន់កាត់ផ្តាច់ ។ តម្រេកដោយអំណាចការពេញចិត្តក្នុងរូបកព និងអរូបកព ឈ្មោះថា **ភវយោគ** ។ សេចក្តីប្រាថ្នាក្នុងឈាន និងរាគៈដែលប្រកបដោយសស្សតទិដ្ឋិក៏យ៉ាងនោះ គឺឈ្មោះថាភវយោគៈដូចគ្នា បុគ្គលប្រកបដោយភវយោគៈនោះ ឈ្មោះថា **ភវយោគយុត្តោ** អធិប្បាយថា លះភវរាគៈមិនទាន់បាន ។ បទថា **អាគាមី** សេចក្តីថា បុគ្គលសូម្បីតាំងនៅក្នុងព្រហ្មលោក ក៏នៅតែមកកាន់មនុស្សលោកនេះជាប្រក្រតី ដោយអំណាចនៃបដិសន្ធិ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មកកាន់អត្តភាពជាមនុស្សនេះវិញ ដូច្នេះ អធិប្បាយថា មានការមកកាន់ភាពជាយ៉ាងនេះ ពោល គឺអត្តភាពនៃមនុស្សជាធម្មតា បានដល់មានការកើតក្នុងមនុស្សទាំងឡាយជាប្រក្រតី កាលទ្រង់សម្តែងថា កាមយោគៈជាហេតុនៃការមកកាន់ភាពជាយ៉ាងនេះ ក្នុងមនុស្សលោកនេះដោយពិត តែទោះជាយ៉ាងនោះ បុគ្គលណាប្រកបដោយកាមយោគៈ បុគ្គលនោះ រមែងឈ្មោះថា ជាអ្នកប្រកបដោយភវយោគៈ ដោយចំណែកមួយ ដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ពាក្យទាំង ២ រួមគ្នាថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែល

ប្រកបដោយកាមយោគៈ ប្រកបដោយភវយោគៈ ... ដូច្នេះ ។

អសុភជ្ឈានក៏ឈ្មោះថា ប្រាសចាកកាមយោគៈ ក្នុងបទថា **កាម-យោគវិសំយុត្តោ** នេះ ។ អនាគាមិមគ្គដែលព្រះអរិយបុគ្គលសម្រេចហើយ ដោយការធ្វើអសុភជ្ឈាននោះឲ្យជាបាទ ឈ្មោះថា ប្រាសចាកកាមយោគៈ ដោយចំណែកមួយប៉ុណ្ណោះ ។ ព្រោះហេតុនោះ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលនៃមគ្គទី ៣ លោកហៅថា **កាមរាគវិសំយុត្តោ** ដូច្នេះ ។ ព្រោះឆន្ទរាគៈក្នុងរូបភព និងអរូបភពដែលព្រះយោគីលះមិនទាន់បាន ដោយអនាគាមិមគ្គ ដូច្នោះ ទើបព្រះយោគាវចរនោះ លោកហៅថា **ភវយោគយុត្តោ** ព្រោះមិនទាន់លះភវយោគៈបាន ។ បទថា **អនាគាមី** បានដល់ ព្រះអរិយ-បុគ្គលដែលមិនមកកាន់កាមលោក ដោយអំណាចបដិសន្ធិ អធិប្បាយថា ព្រះអនាគាមិបុគ្គល ឈ្មោះថា មិនមកកាន់សភាពយ៉ាងនេះ ព្រោះសម្រេចភាពជាបុគ្គលមិនមានសំយោជនៈខាងក្នុង ដោយការដកចេញបាននូវឱរម្ភាគិយ-សំយោជនៈ ដោយមិនមានសេសសល់ មួយអន្លើដោយអំណាចនៃការព្រាត់ប្រាសចាកកាមយោគៈនោះឯង ជាបុគ្គលបរិនិព្វានក្នុងជាន់នោះ ដែលមិនត្រឡប់មកជាធម្មតា ។

ភវយោគៈ ដែលព្រះអរិយបុគ្គលណាលះបានហើយ ដោយមិនមានចំណែកសល់ សូម្បីកិលេសដ៏សេស មានអវិជ្ជាយោគៈជាដើម រមែងឈ្មោះថា ដែលព្រះអរិយបុគ្គលនោះលះបានហើយនោះឯង ព្រោះកិលេសទាំងនោះតាំងនៅក្នុងទីជាមួយគ្នា ព្រោះហេតុនោះ ព្រះអរិយបុគ្គលដែលមានសំយោជនៈ

គឺកពអស់ហើយនោះ ទើបលោកហៅថា ព្រះអរហន្តខីណាស្រព ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកកាមយោគៈ ប្រាសចាកភវយោគៈ ឈ្មោះថា អរហន្ត អស់អាសវៈហើយ ដូច្នេះ ។ ក្នុងអធិការនេះ គប្បីឃើញថា ព្រះអនាគាមី ប្រាសហើយចាកកាមយោគៈ ព្រះមានព្រះភាគត្រាស់ដើម្បីសរសើរនូវតតិយមគ្គ ដូចការលះសុខ ទុក្ខ សោមនស្ស ទោមនស្សរបស់ចតុត្ថជ្ឈាន ( និងសរសើរ ) ចតុត្ថមគ្គ ដូចការអស់ទៅនៃសំយោជនៈ គឺទិដ្ឋិវិចិកិច្ឆា សីលព្វតបរាមាស ដូច្នោះ ។ បុថុជ្ជនទាំងអស់ មួយអន្លើដោយព្រះសោតាបន្ន និងព្រះសកទាគាមី ព្រះមានព្រះភាគទ្រង់កាន់យកហើយដោយបទដំបូង ។ ព្រះអនាគាមីទាំងអស់ ទ្រង់កាន់យកហើយដោយបទទី ២ ។ ឯព្រះអរហន្ត ទ្រង់កាន់យកដោយបទទី ៣ ។

ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ញុំាងព្រះធម្មទេសនាឲ្យចប់ដោយកំពូល គឺអរហត្ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះគាថាទាំងឡាយតទៅ បទថា **ឧភយំ** សេចក្តីថា ដោយចំណែក ២ អធិប្បាយថា ប្រកបដោយកាមយោគៈ និងភវយោគៈទាំង ២ ។ បទថា **សត្តា គច្ឆន្តិ សំសារំ** សេចក្តីថា សត្វ ៣ ប្រភេទ គឺ បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី នឹងត្រូវទៅ គឺអន្ទោលទៅ ព្រោះមិនទាន់លះកាមយោគៈ និងភវយោគៈបាន បន្ទាប់អំពីនោះ ក៏នឹងជាបុគ្គលទៅកាន់ជាតិ និងមរណៈ ។

ក្នុងបណ្តាព្រះសោតាបន្ន ៣ ពួក គឺឯកពីជី កោលំកោលៈ សត្តក្ខត្តុ-បរម ព្រះសោតាបន្ន មានឥន្ទ្រិយទន់ជាងគេបង្អស់ ឈ្មោះថា សត្តក្ខត្តុបរម លោករមែងមិនកើតក្នុងភពទី ៨ តែត្រូវអន្ទោលទៅ ដោយអំណាចនៃការកើតរបស់ខ្លួន ដែលធម្មតាបានកំណត់ ។ ព្រះសោតាបន្នក្រៅអំពីនេះក៏ដូចគ្នា បណ្តាព្រះសកទាគាមីទាំងឡាយ ព្រះសកទាគាមីណាសម្រេចសកទាគាមិមគ្គក្នុងលោកនេះហើយ កើតក្នុងទេវលោក មកកើតក្នុងលោកនេះទៀត ព្រោះសកទាគាមីនោះ ឈ្មោះថា អន្ទោលទៅដោយអំណាចនៃជាតិរបស់ខ្លួន ដែលសភាវៈកំណត់ហើយ ។ តែព្រះសកទាគាមិបុគ្គលណា កើតក្នុងទេវលោកជាន់នោះៗ ឯង ឬក្នុងមនុស្សលោកនោះឯង ដោយវៀរវាងមិស្សកន័យ ព្រះសកទាមីទាំងនោះ ត្រូវអន្ទោលទៅនោះឯង ព្រោះត្រូវកើតឡើងរឿយៗ ទម្រាំឥន្ទ្រិយចាស់ក្លា ដោយបានសម្រេចមគ្គជាន់ខ្ពស់បន្ត ។ តែក្នុងបុថុជ្ជន រឿងដែលត្រូវពោលដល់មិនមានឡើយ ព្រោះសំយោជនៈក្នុងភពទាំងពួង មិនទាន់អស់ទៅ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ពួកសត្វដែលប្រកបដោយកាមយោគៈ និងភវយោគៈទាំងពីរ ជាសត្វប្រព្រឹត្តទៅដើម្បីជាតិ និងមរណៈ រមែងអន្ទោលទៅកាន់សង្សារ ដូច្នេះ ។

បទថា **កាមេ បហាន្វាន** សេចក្តីថា លះកិលេសកាមទាំងឡាយ ពោលគឺកាមរាគៈដោយអនាគាមិមគ្គ ។ បទថា **ឆិន្នសំសយា** សេចក្តីថា មានការសង្ស័យផ្តាច់ផ្តិលហើយដោយល្អ ការកាត់សេចក្តីសង្ស័យនោះឯង នឹងមានដោយសោតាបត្តិមគ្គប៉ុណ្ណោះ ដើម្បីទ្រង់សរសើរមគ្គទី ៤ ទើបត្រាស់យ៉ាង

នេះ អធិប្បាយថា ព្រះអរហន្តទាំងឡាយ ទ្រង់បំណងយកថា បុគ្គលកាត់នូវសេចក្តីសង្ស័យបានហើយ ក្នុងព្រះគាថានេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ខីណមានបុនព្ភវា** ដូច្នេះ ។ ព្រះអរិយបុគ្គល ឈ្មោះថា មានមានះ និងភពថ្មីអស់ហើយ ព្រោះលោកមានមានះទាំង ៩ និងភពថ្មីជាបន្ទអស់ហើយ ដោយប្រការទាំងពួង ។ ក្នុងបទថា **ខីណមានបុនព្ភវា** នេះ កិលេសដែលមគ្គទី ៤ គប្បីសម្លាប់ ព្រះមានព្រះភាគទ្រង់កាន់យកហើយដោយ **មាន** សព្ទ ឬដោយអំណាចនៃលក្ខណៈ ព្រោះកិលេស មានអត្ថតែម្យ៉ាង ជាមួយនឹងមានះនោះ ។ សឧបាទិសេសនិព្វានធាតុ ឈ្មោះថា ព្រះមានព្រះភាគត្រាស់ហើយដល់ព្រះខីណាស្រព មានអាសវៈអស់ហើយ អនុបាទិសេសនិព្វានធាតុ ដែលព្រះមានព្រះភាគត្រាស់ហើយដល់ព្រះខីណាស្រព មានភពថ្មីអស់ហើយ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា កាមយោគសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## កល្យាណសីលសូត្រ

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ មានធម៌ល្អ មានប្រាជ្ញាល្អ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ចប់សព្វគ្រប់ហើយ ហៅថាជាបុរសដ៏ខ្ពង់ខ្ពស់ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល បានសង្រួម ដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អ យ៉ាងនេះឯង ។ ដូច្នេះ ហៅថា ភិក្ខុមានសីលល្អ ។ ភិក្ខុមានធម៌ល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបរឿយៗ នូវការចម្រើននូវពោធិបក្ខិយធម៌ ៣៧ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានធម៌ល្អ យ៉ាងនេះឯង ។ ដូច្នេះ ហៅថា ភិក្ខុមានសីលល្អ មានធម៌ល្អ ។ ភិក្ខុមានប្រាជ្ញាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រាជ្ញាល្អ យ៉ាងនេះឯង ។ ភិក្ខុដែលមានសីលល្អ មានធម៌ល្អ មានប្រាជ្ញាល្អ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ចប់សព្វគ្រប់ហើយ ហៅថា ជាឧត្តមបុរស ក្នុងធម្មវិន័យនេះ ដូច្នេះឯង ។

ភិក្ខុណា មិនមានអំពើអាក្រក់ ដោយកាយ ដោយវាចា
ដោយចិត្ត អ្នកប្រាជ្ញ ហៅភិក្ខុនោះ ដែលមានសេចក្តី

ខ្លាសបាប ថាជាអ្នកមានសីលល្អ ដោយពិត ។ ធម៌ទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីសម្រេចសម្ពោធិញ្ញាណ ដែលភិក្ខុណា បានចម្រើន ដោយល្អហើយ អ្នកប្រាជ្ញហៅភិក្ខុនោះ ដែលមិនមានកិលេសក្រាស់ ថាជាអ្នកមានធម៌ល្អ ដោយពិត ។ ភិក្ខុណា ដឹងច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខរបស់ខ្លួន ក្នុងលោកនេះ អ្នកប្រាជ្ញហៅភិក្ខុនោះ ដែលមិនមានអាសវៈ ថាជាអ្នកមានប្រាជ្ញាល្អ ដោយពិត អ្នកប្រាជ្ញ ពោលនូវភិក្ខុដែលបរិបូណ៌ដោយធម៌ទាំងឡាយនោះ ជាអ្នកមិនមានទុក្ខ អស់សេចក្តីសង្ស័យ លះបង់នូវកិលេសទាំងពួង ថាជាអ្នកមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិ ក្នុងលោកទាំងពួង ។

សូត្រទី ៨ ។

# អដ្ឋកថា

## កល្យាណសីលសូត្រ

ក្នុងកល្យាណសីលសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ៩៩ ] បទថា **កល្យាណសីលោ** សេចក្តីថា ជាអ្នកមានសីលដ៏ស្អាត គឺមានសីលដល់ព្រមហើយ បានដល់ មានសីលបរិបូណ៌ហើយ ។ ក្នុងអង្គ-គុណទាំង ៣ នោះ ភិក្ខុ ឈ្មោះថា មានសីលបរិបូណ៌ ដោយហេតុ ២ ប្រការ គឺដោយការឃើញទោសនៃសីលវិបត្តិដោយប្រពៃនោះឯង ១ ដោយការឃើញនូវអានិសង្សនៃសីលសម្បត្តិ ១ តែក្នុងពាក្យថា មានកល្យាណសីលនេះ គប្បីជ្រាបភាពដែលសីលនោះ ល្អដោយអំណាចនៃមគ្គសីល និងផលសីល ដែលផុតចាកគ្រឿងចងទាំងអស់ បរិបូណ៌ដោយអាការទាំងពួង ។

ពោធិបក្ខិយធម៌ទាំងអស់ ទ្រង់បំណងយកថាជាកល្យាណធម៌ ព្រោះដូច្នោះ ភិក្ខុ ឈ្មោះថា **កល្យាណធម្មោ** ព្រោះមានពោធិបក្ខិយធម៌ មានសតិប្បដ្ឋានជាដើម ដែលជាធម៌ស្អាត ។

ភិក្ខុអ្នកមានបញ្ញាល្អ ដោយអំណាចបញ្ញាក្នុងមគ្គនោះឯង ឈ្មោះថា **កល្យាណប្បញ្ញោ** អធិប្បាយថា ធម៌ទាំងឡាយ មានសីលជាដើម ដែលជាលោកុត្តរធម៌ប៉ុណ្ណោះ ឈ្មោះថា ជាកល្យាណធម៌ដោយចំណែកមួយ ព្រោះជាធម៌ដែលមិនកម្រើកជាសភាវៈ ។

ឯអាចារ្យពួកខ្លះពោលថា ភិក្ខុឈ្មោះថា មានសីលស្អាតដោយអំណាចនៃចាតុប្បារិសុទ្ធិសីល ឈ្មោះថា ដោយអំណាចនៃធម៌ គឺវិបស្សនាមគ្គ ឈ្មោះថា មានបញ្ញាល្អ ដោយអំណាចនៃបញ្ញាក្នុងមគ្គផល ។ អាចារ្យមួយពួកពោល

ថា សីល ធម៌ និងបញ្ញាទាំងនោះ គឺអសេក្ខៈ ។ ឯអាចារ្យដទៃពោលថា មគ្គសីល និងផលសីលរបស់ព្រះសោតាបន្ន និងព្រះសកទាមីទាំងឡាយ ឈ្មោះថា កល្យាណសីល ព្រោះដូច្នោះ ព្រះសោតាបន្នក្តី ព្រះសកទាគាមីក្តី ព្រះមានព្រះភាគទ្រង់កាន់យកហើយ ដោយបទថា **កល្យាណសីលោ** នេះ អធិប្បាយថា ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ ឈ្មោះថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ធម៌ គឺអនាគាមិមគ្គ និងអនាគាមិផល និងធម៌ គឺមគ្គដ៏ប្រសើរ ឈ្មោះថាជា **កល្យាណធម្មោ** ព្រោះថា បណ្តាធម៌ទាំងនោះ ពោធិបក្ខិយធម៌ រមែងដល់នូវភាពបរិបូណ៌ដោយភាវនា ព្រោះដូច្នោះ ព្រះអរិយបុគ្គល ៣ ពួក រាប់តាំងអំពីព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គទី ៣ ទៅ រមែងឈ្មោះថា ព្រះមានព្រះភាគទ្រង់កាន់យកហើយ ដោយបទថា **កល្យាណធម្មោ** នេះ បញ្ញាក្នុងអគ្គផល ឈ្មោះថា **កល្យាណប្បញ្ញោ** ព្រោះដល់នូវទីបំផុតនៃកិច្ចដោយបញ្ញា ព្រោះដូច្នោះ ព្រះអរហន្តជាអ្នកដល់នូវសេចក្តីបរិបូណ៌ដោយបញ្ញា ទើបព្រះមានព្រះភាគត្រាស់ថា មានកល្យាណធម៌ ... ។ បុគ្គលដូចពោលមកនេះឯង ទ្រង់បំណាងយកហើយ ។ ព្រោះដូច្នោះ នឹងមានប្រយោជន៍អ្វីដោយការប្រកែកដែលធ្វើឲ្យយឺតយូរនោះ ក្នុងសេចក្តីនេះ ធម៌ គឺអគ្គមគ្គ និងអគ្គផល ព្រះមានព្រះភាគត្រាស់ថា ជាកល្យាណសីលជាដើម ដូច្នោះ ក្នុងសេចក្តីនេះ ទើបជាការពេញចិត្តរបស់ពួកយើងទាំងឡាយ ព្រោះថា ដោយវិភាគនៃធម៌ហើយ នេះជាបុគ្គលវិភាគ មិនមែនធម្មវិភាគឡើយ ។

ព្រះនិព្វានដែលស្ងាត់ចាកសង្ខតធម៌គ្រប់យ៉ាង ព្រះមានព្រះភាគត្រាស់

ហៅថា សុទ្ធៗ ក្នុងបទថា **កេវលី** នេះ ព្រោះមិនមានអ្វីលាយឡំ ។ អរហត្ត ឈ្មោះថា **កេវលី** ព្រោះលោកសម្រេចព្រះនិព្វានហើយ ។ម្យ៉ាងទៀត ឈ្មោះថា ជាអរហត្តសុទ្ធៗ ព្រោះបរិបូណ៌ដោយបហានភាវនា និងបរិបូណ៌ដោយធម៌មិនមានទោសជាបរិយោសាន និងព្រោះមានសេចក្តីសុខ ដែលជាទីត្រេកអរនៃចិត្ត ព្រោះអត្ថថា មានការស្អាត ឈ្មោះថា ព្រះខីណាស្រពសុទ្ធៗ ព្រោះបានសម្រេចអរហត្តនោះ ។ ឈ្មោះថា **វុសិតវា** ព្រោះចប់មគ្គព្រហ្មចរិយៈ គឺញ៉ាំងមគ្គព្រហ្មចរិយៈឲ្យសម្រេចតាំងនៅហើយ ។ ភិក្ខុដែលព្រះមានព្រះភាគត្រាស់ហៅថា **ឧត្តមបុរសោ** ព្រោះប្រកបទៅដោយអសេក្ខធម៌ដ៏ខ្ពង់ខ្ពស់ ឬដ៏កំពូល ។

## អធិប្បាយ ពាក្យថា ចាតុមោក្ខ

សួរថា ក្នុងបទថា **សីលវា** នេះ ឈ្មោះថា **សីល** ដោយអត្ថដូចម្តេច ឆ្លើយថា ឈ្មោះថា **សីល** ដោយអត្ថថា ប្រក្រតី ។ សួរថា ឈ្មោះថា **ប្រកតី** ដូចម្តេច ឆ្លើយថា បានដល់ សមាទាន គឺការតាំងមាំ អធិប្បាយថា បានដល់ ភាពជាបុគ្គលមានកាយកម្មជាដើមរៀបរយ ដោយអំណាចភាពជាបុគ្គលមានសីលបរិសុទ្ធ ។ ម្យ៉ាងទៀត បានដល់ ការចូលទៅទ្រទ្រង់ អធិប្បាយថា ភាវៈដែលចូលទៅទ្រទ្រង់ ដោយអំណាចនៃការតាំងនូវកុសលធម៌មានឈានជាដើម ព្រោះដូច្នោះ ឈ្មោះថា **សីល** ព្រោះតាំងមាំ ឬព្រោះទ្រទ្រង់ ។ នេះជាការពោលដោយអត្ថនៃសីល ដោយលក្ខណន័យនៃសព្ទ ។ ឯអាចារ្យមួយពួកទៀត ពណ៌នាដោយនិរុត្តិន័យថា **សីលដ្ឋ** មានសិរជាអត្ថ

**សីលដ្ឋ** មានសីតលៈជាអត្ថ **សីលដ្ឋ** មានសិរៈជាអត្ថ ។ បុគ្គល ឈ្មោះថា **សីលវា** ព្រោះអត្ថថា មានសីលនោះដោយបរិបូណ៌ ឬព្រោះមានសីលដោយកល្យាណសីលក្រៃលែង អធិប្បាយថា សម្បូរដោយសីល ដោយអំណាចនៃចតុប្បារិសុទ្ធិសីល ។ អាចារ្យពួកខ្លះធ្វើ អធិប្បាយថា ដើម្បីទ្រង់សម្តែងសីលដែលជាគោល ក្នុងបណ្តាចតុប្បារិសុទ្ធិសីលទាំងនោះឲ្យពិស្តារ ទើបព្រះមានព្រះភាគត្រាស់ថា **ចាតិមោក្ខសំវរសំវុតោ** ដូច្នេះ ។

ឯអាចារ្យពួកខ្លះពោលថា ដោយបទទាំង ២ ព្រះមានព្រះភាគត្រាស់បាតិមោក្ខសំវរសីលហើយ តែព្រោះសីល គឺបាតិមោក្ខសំវរៈនោះឯង ក្នុងបទក្រៅអំពីនេះ ទើបឥន្ទ្រិយសំវរសីលត្រឹមតែជាការរក្សាទ្វារ ៦ ប៉ុណ្ណោះ ។ អាជីវបារិសុទ្ធិសីល ត្រឹមតែជាការញ៉ាំងបច្ច័យឲ្យកើតឡើងដោយធម៌តែម្យ៉ាង បច្ចយសន្និស្សិតសីល ត្រឹមតែជាការពិចារណាបច្ច័យដែលបានមកហើយថា នេះជាប្រយោជន៍ហើយ ទើបបរិភោគប៉ុណ្ណោះ ពោលដោយត្រង់ហើយ សីល គឺបាតិមោក្ខសំវរសីលនោះឯង ។ ភិក្ខុណាមានសីលដាច់ហើយ ភិក្ខុនោះប្រៀបដូចជាបុរសដែលមានក្បាលដាច់ហើយ មិនចាំបាច់ពោលដល់ក្នុងរឿងដៃ និងជើង ថាត្រូវរក្សាអវយវៈដ៏សេស ឯភិក្ខុណាសីលមិនដាច់ ភិក្ខុនោះប្រៀបដូចបុរសដែលមានក្បាលមិនដាច់ អាចរក្សាសីលទាំងនោះឲ្យនៅជាប្រក្រតីបាន ព្រោះដូច្នោះ ពាក្យថា **សីលវា** នេះ ព្រះមានព្រះភាគ ទ្រង់លើកបាតិ-មោក្ខសំវរសីលនោះឯងឡើងសម្តែង ហើយទើបត្រាស់ពាក្យជាដើមថា **ចាតិ-មោក្ខសំវរសំវុតោ** ដូច្នេះ ដើម្បីញ៉ាំងសីល គឺបាតិមោក្ខនោះឲ្យពិស្តារ ។

បណ្ដាបទទាំងនោះ បទថា **បាតិមោក្ខំ** បានដល់ សីល គឺសិក្ខាបទ អធិប្បាយថា សីល គឺសិក្ខាបទនោះ ឈ្មោះថា **បាតិមោក្ខ** ព្រោះញុំាងសត្វ ដែលរក្សាសីល គឺសិក្ខាបទនោះឲ្យផុត គឺរួចផុតចាកទុក្ខទាំងឡាយ មានទុក្ខ ដែលធ្វើឲ្យត្រូវកើតក្នុងអបាយជាដើម ។ ការសង្រួម ឈ្មោះថា **សំវរ** បាន ដល់ ការមិនប្រព្រឹត្តកន្លងតាមកាយ វាចា ។ ការសង្រួមក្នុងបាតិមោក្ខនោះឯង ឈ្មោះថា **បាតិមោក្ខសំវរ** ។ ភិក្ខុ ឈ្មោះថា **បាតិមោក្ខសំវរសំវុត** ព្រោះ សង្រួមហើយ គឺមានកាយ វាចាបិទបាំងហើយ ដោយបាតិមោក្ខសំវរៈនោះ ។

បទថា **បាតិមោក្ខសំវរសំវុតោ** នេះ ជាគ្រឿងចង្អុលបង្ហាញដល់ភាព ដែលភិក្ខុនោះតាំងមាំហើយក្នុងសីលនោះ ។ បទថា **វិហរតិ** សម្ដែងដល់ការ ដល់ព្រម ត្រឹមតែការនៅសមគួរដល់បាតិមោក្ខសំវរៈទាំងនោះ ។ បទថា **អាចារគោចរសម្បន្នោ** សម្ដែងដល់ធម៌ដែលជាឧបការៈដល់ការសង្រួមក្នុង បាតិមោក្ខខាងក្រោម និងដល់ការតាមប្រកបនូវគុណវិសេសខាងលើ ។ បទ ថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** សម្ដែងដល់សភាវៈធម្មតានៃការមិន កម្រើកចាកបាតិមោក្ខសីល ។ បទថា **សមាទាយ** សម្ដែងដល់ការកាន់យក សិក្ខាបទទាំងឡាយដោយមិនមានសេសសល់ ។ បទថា **សិក្ខតិ** សម្ដែងដល់ ភាវៈ គឺការដល់ព្រមក្នុងសិក្ខា ។ បទថា **សិក្ខាបទេសុ** សម្ដែងដល់ធម៌ដែល ត្រូវសិក្សា ។

ម្យ៉ាងទៀត ឈ្មោះថា **បាតិ** ព្រោះអត្ថថា មានប្រក្រតីធ្លាក់ទៅក្នុង អបាយទាំងឡាយច្រើនដង ព្រោះភាវៈមានការធ្វើអាក្រក់បានងាយផង និង

ព្រោះការធ្វើបុណ្យបានដោយលំបាក បានដល់ បុថុជ្ជន ។ មា៉ងទៀត ឈ្មោះថា **ចាតិ** ព្រោះអត្ថថា ត្រូវកម្លាំងកម្មបទ្យាត់ទៅក្នុងភពជាដើម ដោយភាពជារបស់មិនទៀង ឈ្មោះថា មានការដើរទៅជាប្រក្រតី ព្រោះវិលទៅជុំវិញដោយមិនមានទីបំផុត ដូចក្តារយន្តរបស់ស្មូនឆ្នាំង ដូច្នោះ ។ មា៉ងទៀត ឈ្មោះថា **ចាតិ** ព្រោះញុាំងអត្តភាពឲ្យធ្លាក់ទៅក្នុងសត្តនិកាយនោះៗ ដោយអំណាចនៃមរណៈ បានដល់ សត្តសន្តាន គឺចិត្តនោះឯង ។ សីល ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ញុាំងសត្វឲ្យធ្លាក់ទៅនោះ ឲ្យផុតចាកសង្សារទុក្ខ អធិប្បាយថា សត្វផុតហើយចាកទុក្ខ ដោយការរួចផុតនៃចិត្ត ។ ដូចព្រះតម្រាស់ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានធម៌ជាគ្រឿងសៅហ្មងនៃចិត្ត រមែងជ្រាកជ្រាក ពួកសត្វដែលមានធម៌ជាគ្រឿងផូរផង់នៃចិត្ត រមែងបរិសុទ្ធ ដូច្នេះ ។ និងព្រះតម្រាស់ក្នុងទីឃនខសូត្រថា ស្រាប់តែចិត្តលោកក៏ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដោយប្រការ ដូច្នេះ ។ មា៉ងទៀត បុគ្គលឈ្មោះថា **ចាតិ** ព្រោះអត្ថថា ធ្លាក់ទៅ គឺប្រព្រឹត្តទៅ បានដល់ ប្រព្រឹត្តទៅក្នុងសង្សារ ដោយហេតុ មានអវិជ្ជាជាមូល ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ និទានវគ្គថា សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ដូច្នេះ ។

**សំវរ** ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ជាហេតុរួចផុតចាកកិលេសទាំង ៣ មានតណ្ហាជាដើមនៃសត្វដែលធ្លាក់ទៅនោះ ។ បទនោះគប្បីជ្រាបថា

សម្រេចរូបជាសមាស ដូចពាក្យជាដើមថា **តណ្ហាក្ការោ** ដូច្នេះ ។

ម្យ៉ាងទៀត សភាវៈឈ្មោះថា **ចាតិ** ព្រោះអត្ថថា ញុំាងសត្វឲ្យធ្លាក់ទៅ ឲ្យដល់នូវការវិនាស គឺឲ្យដល់ទុក្ខ បានដល់ ចិត្ត សមដូចព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ សគាថវគ្គថា ចិត្តតែងនាំសត្វលោកទៅ ចិត្តតែងកើចកន្ត្រាក់សត្វលោកទៅ ដូច្នេះ ។ **សំវរ** ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ជាគ្រឿងរួចផុតរបស់សត្វដែលធ្លាក់ទៅនោះ ។ ម្យ៉ាងទៀត ឈ្មោះថា **ចាតិ** ព្រោះអត្ថថា ជាហេតុធ្លាក់ទៅក្នុងអបាយទុក្ខ ឬក្នុងសង្សារទុក្ខ បានដល់សង្កិលេស មានតណ្ហាជាដើម សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា តណ្ហាតែងញុំាងបុរសឲ្យកើត បុរសមានតណ្ហា ជាគម្រប់ពីរ ដូច្នេះ ។ **សំវរ** ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ផុតចាកកិលេសជាហេតុឲ្យសត្វធ្លាក់ទៅនោះ ។ ម្យ៉ាងទៀត ធម្មជាតឈ្មោះថា **ចាតិ** ព្រោះធ្លាក់ទៅ បានដល់អាយតនៈខាងក្នុង និងខាងក្រៅ ៦ សមដូចព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ សគាថវគ្គថា លុះតែអាយតនៈខាងក្នុងទាំង ៦ កើតឡើង ទើបសត្វលោកកើតឡើងបាន សត្វលោករមែងធ្វើនូវសេចក្ដីស្និទ្ធស្នាល ក្នុងអាយតនៈខាងក្រៅទាំង ៦ ដូច្នេះ ។ **សំវរ** ឈ្មោះថា **ចាតិមោក្ខ** ព្រោះអត្ថថា ផុតចាកកិលេសជាហេតុឲ្យធ្លាក់ទៅ ពោល គឺអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ៦ នោះ ។ ម្យ៉ាងទៀត សភាវៈឈ្មោះថា **ចាតិ** ព្រោះអត្ថថា មានការធ្លាក់ទៅ គឺឲ្យដល់នូវការវិនាស បានដល់ សង្សារ ។ សំវរៈឈ្មោះថា **ចាតិមោក្ខ** ព្រោះផុតចាកសង្សារដែលធ្លាក់ទៅនោះ ។

*ម្យ៉ាងទៀត ព្រះមានព្រះភាគ ជាធម្មិស្សរៈ សត្វលោកថ្វាយព្រះនាមថា* **បតី** *ព្រោះជាធំជាងលោកទាំងពួង ។ ភិក្ខុរមែងរួចផុតដោយឧបាយនោះព្រោះហេតុនោះ ទើបឧបាយនោះ ឈ្មោះថា* **មោក្ខ** *ឧបាយជាគ្រឿងរួចផុតរបស់បុគ្គលដែលជាបតី ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តិហើយព្រោះហេតុនោះ ទើបឈ្មោះថា* **បតិមោក្ខ ។** *បតិមោក្ខនោះឯង គឺបាតិមោក្ខ ។ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា* **បតី** *ព្រោះអត្ថថា ឧត្តម ដោយភាពជាឫសគល់នៃគុណទាំងពួងផង ឈ្មោះថា* **មោក្ខ** *ព្រោះអត្ថថា ប្រព្រឹត្តទៅតាមដែលពោលហើយផង ព្រោះហេតុនោះ ទើបឈ្មោះថា* **បតិមោក្ខ** *បតិមោក្ខនោះឯង គឺបាតិមោក្ខ ។ សមដូចពាក្យដែលលោកពោលថា ពាក្យថា* **ធាតិមោក្ខ** *នេះ ជាប្រមុខ ពាក្យថា* **ធាតិមោក្ខ** *នេះ ជាប្រធាន គប្បីជ្រាបសេចក្ដីពិស្ដារដូចតទៅនេះ*

*ម្យ៉ាងទៀត* **ប** *សព្ទ ចុះក្នុងអត្ថថា* **បការៈ ។ អតិ** *សព្ទ ជានិបាតប្រើក្នុងអត្ថថា កន្លងចំណែក ព្រោះដូច្នោះ សំវរៈ ឈ្មោះថា* **ធាតិមោក្ខ** *ព្រោះអត្ថថា ញុំាងសត្វឲ្យផុតអច្ចន្ត ដោយប្រការទាំងពួង ។ សីលនេះ ត្រូវទៅព្រមជាមួយសមាធិ ទៅព្រមជាមួយបញ្ញា ដោយអំណាចនៃតទង្គៈ ។ ឈ្មោះថា* **ធាតិមោក្ខ** *ព្រោះញុំាងសត្វឲ្យផុត គឺរួចផុតអច្ចន្តដោយអំណាចវិក្ខម្ភនប្បហាន និងសមុច្ឆេទប្បហាន ។ សីលនេះឯង គឺបាតិមោក្ខ ។*

*ម្យ៉ាងទៀត សំវរៈ ឈ្មោះថា* **ធាតិមោក្ខ** *ព្រោះអត្ថថា រួចផុតចំពោះៗ អធិប្បាយថា ផុតចំពោះ គឺជាចំណែកៗ ចាកទោសដែលគប្បីកន្លងល្មើស*

នោះៗ ។ បតិមោក្ខនោះឯង គឺបាតិមោក្ខ ។ ម្យ៉ាងទៀត ព្រះនិព្វានឈ្មោះថា **មោក្ខ** សំវរៈ ឈ្មោះថា **បតិមោក្ខ** ព្រោះអត្ថថា ជាគ្រឿងផុតចំពោះ គឺប្រហែលនឹងមោក្ខៈនោះ អធិប្បាយថា បាតិមោក្ខសីលសំវរៈ រមែងដូចព្រះអាទិត្យដែលកំពុងរះ ធម៌ដែលមានចំណែកប្រៀបដូចមោក្ខធម៌នោះ ដូចជាការរះឡើងនៃព្រះនិព្វាន ព្រោះញុំាងកិលេសឲ្យរលត់តាមសមគួរ ព្រោះដូច្នោះ ទើបឈ្មោះថា **បតិមោក្ខ។** បតិមោក្ខនោះឯង គឺបាតិមោក្ខ ។

ម្យ៉ាងទៀត ឈ្មោះថា **បតិមោក្ខ** ព្រោះអត្ថថា ប្រព្រឹត្តទៅកាន់ការរួចផុត គឺបែរមុខទៅកាន់ព្រះនិព្វាន ។ បតិមោក្ខនោះឯង គឺបាតិមោក្ខ ។ ក្នុងអធិការនេះ គប្បីជ្រាបអត្ថនៃសព្ទថា **បាតិមោក្ខ** ដូចពណ៌នាមកនេះប៉ុណ្ណោះ ។

កុសលធម៌ ឈ្មោះថា សំវរៈ ព្រោះអត្ថថា ជាគ្រឿងរាំង គឺរាំង ។ សំវរៈ គឺបាតិមោក្ខ ព្រោះដូច្នោះ ទើបឈ្មោះថា **បាតិមោក្ខសំវរ។** តែដោយអត្ថ បានដល់ ចេតនាជាគ្រឿងវៀរចាកទោសដែលគប្បីឈានកន្លងបាបធម៌នោះៗ ។ ភិក្ខុចូលដល់ គឺប្រកបដោយបាតិមោក្ខសំវរៈនោះ ព្រះមានព្រះភាគត្រាស់ហៅថា បានសង្រួមដោយការសង្រួមក្នុងបាតិមោក្ខ ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងវិភង្គថា ពាក្យថា ជាអ្នកសង្រួម គឺជាអ្នកព្រមព្រៀង មូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយការសង្រួមក្នុងបាតិមោក្ខនេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ដូច្នេះ ។

បទថា **វិហរតិ** សេចក្តីថា រមែងនៅ គឺផ្លាស់ប្តូរ បានដល់ ប្រព្រឹត្តទៅ

ដោយការនៅ ដោយការផ្លាស់ប្តូរឥរិយាបថ ។

បទថា **អាចារគោចរសម្បន្នោ** សេចក្តីថា ភិក្ខុ ឈ្មោះថា សម្បូរដោយអាចារ និងគោចរ វៀរអគោចរ មានស្រីពេស្យាជាដើម ព្រោះសម្បូរដោយអាចារសម្បត្តិ ដែលសមគួរដល់ភិក្ខុ ដូចព្រះតម្រាស់យ៉ាងនេះថា ការមិនកន្លងល្មើស ប្រព្រឹត្តទៅតាមកាយ ការមិនកន្លងល្មើស ប្រព្រឹត្តទៅតាមវាចា ដូច្នេះ ព្រោះវៀរចាកអនាចារដោយប្រការទាំងពួង ដោយមិនធ្វើមិច្ឆាអាជីវៈ មានការឲ្យឫស្សីជាដើម និងការផ្តាំផ្ញើទាំងឡាយ មានផ្ញើកាយជាដើម និងដោយគោចរ ពោល គឺស្ថានទីដែលសមគួរ ដើម្បីនឹងចូលទៅជាប្រយោជន៍ដល់បិណ្ឌបាតជាដើម ។

ម្យ៉ាងទៀត ភិក្ខុណាមានសេចក្តីគោរព មានការកោតក្រែងនៅក្នុងព្រះសាស្តា មានសេចក្តីគោរព មានសេចក្តីកោតក្រែងក្នុងសព្រហ្មចារីទាំងឡាយដល់ព្រមដោយហិរិ និងឱត្តប្បៈ ស្លៀកដណ្តប់ជាបរិមណ្ឌល មានភ្នែកដាក់ចុះសម្បូរដោយឥរិយាបថ មានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ ដោយការឈានទៅ ដោយការឈានត្រឡប់ ដោយការក្រឡេកមើលនូវឆ្វេង-ស្តាំ ដោយការបត់ចូល ដោយការលាចេញ គួរជាទីជ្រះថ្លា ដឹងប្រមាណក្នុងការបរិភោគ តាមប្រកបសេចក្តីព្យាយាម ប្រកបដោយសតិ និងសម្បជញ្ញៈ មានការប្រាថ្នាតិច សន្តោស ស្ងាត់ហើយ មិនច្រឡូកច្រឡំដោយពួកគណៈ ធ្វើដោយគោរពក្នុងអភិសមាចារិកវត្ត ច្រើនទៅដោយសេចក្តីគោរពកោតក្រែង ភិក្ខុនេះ លោកពោលថា សម្បូរដោយអាចារ ។

គោចរមាន ៣ យ៉ាង គឺឧបនិស្សយគោចរ ១ អារក្ខគោចរ ១ ឧប-និពន្ធគោចរ ១ ។ ក្នុងគោចរ ៣ យ៉ាងនោះ កល្យាណមិត្តដែលប្រកប ដោយគុណសម្បត្តិ គឺកថាវត្ថុ ១០ មានលក្ខណៈដូចពោលហើយ អាស្រ័យ ភិក្ខុណា រមែងបានស្តាប់វត្ថុដែលមិនធ្លាប់បានស្តាប់ ធ្វើវត្ថុដែលស្តាប់ហើយ ឲ្យជាក់ច្បាស់ បន្ទោបង់សេចក្តីសង្ស័យចេញបាន ធ្វើនូវការយល់ឃើញឲ្យត្រង់ ញ៉ាំងចិត្តឲ្យជ្រះថ្លា កាលជាប់តាមសិក្សាភិក្ខុណា រមែងចម្រើនដោយសទ្ធា ចម្រើនដោយសីល សុតៈ ចាគៈ បញ្ញា ភិក្ខុនោះ ឈ្មោះថា **ឧបនិស្សយ-គោចរ** ។

ភិក្ខុណាចូលទៅកាន់ចន្លោះស្រុក ដើរទៅកាន់ថ្នល់ ដាក់ភ្នែកចុះ សម្លឹង មើលមួយជួរទឹម សង្រួមហើយដើរទៅ មិនសម្លឹងមើលដំរី មិនសម្លឹងមើល សេះ មិនសម្លឹងមើលរថ មិនសម្លឹងមើលអ្នកថ្មើរជើង មិនសម្លឹងមើលស្ត្រី មិនសម្លឹងមើលបុរស មិនសម្លឹងមើលទិសតូច និងទិសធំ ភិក្ខុនោះ ឈ្មោះថា **អារក្ខគោចរ** ។ ឯ **ឧបនិពន្ធគោចរ** បានដល់ សតិប្បដ្ឋាន ៤ ដែលជាទី ភិក្ខុចូលទៅចងចិត្តរបស់ខ្លួន ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងសំយុត្ត-និកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ ចុះទីជាទីគោចររបស់ភិក្ខុ ជាដែន នៃបិតារបស់ខ្លួន តើដូចម្តេច គឺសតិប្បដ្ឋានទាំង ៤ នេះឯង ដូច្នេះ ។ ដូច្នោះ ភិក្ខុឈ្មោះថា ដល់ព្រមដោយអាចារ និងគោចរ ព្រោះប្រកបដោយអាចារ-សម្បត្តិ តាមដែលពោលមកហើយ និងគោចរសម្បត្តិនេះ ។

បទថា **អណុមត្តេសុ វជ្ជេសុ ភយទស្សាវី** សេចក្តីថា មានប្រក្រតី

*ឃើញភ័យក្នុងទោសទាំងឡាយ មានអកុសលចិត្តប្បាទក្នុងសេក្ខិយវត្តដែលត្រូវហើយដោយមិនបានតាំងចិត្តជាដើម មានប្រមាណតិច គឺមានប្រមាណប៉ុនអណូ អធិប្បាយថា ភិក្ខុណាឃើញទោស មានប្រមាណប៉ុនបរិមាណូធ្វើឲ្យធំដូចភ្នំសិនេរុ ដែលមានកម្ពស់ ១៦៨០០០ យោជន៍ក្តី ភិក្ខុណាឃើញអាបត្តិត្រឹមតែទុក្កដសិត ដែលស្រាលជាងអាបត្តិទាំងពួង ធ្វើឲ្យធ្ងន់ដូចអាបត្តិបារាជិកក្តី ភិក្ខុនេះឈ្មោះថា មានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិច ។ បទថា* **សមាទាយ សិក្ខតិ សិក្ខាបទេសុ** *សេចក្តីថា ក្នុងបណ្តាសិក្ខាបទទាំងឡាយ សិក្ខាបទណាមួយដែលត្រូវសិក្សា សមាទានសិក្ខាបទនោះសព្វយ៉ាង គឺគ្រប់ទាំងអស់ ដោយប្រការទាំងពួង បានដល់មិនឲ្យសេសសល់ ហើយសិក្សា គឺប្រព្រឹត្តទៅ បំពេញឲ្យបរិបូណ៌ ។*

*បទថា* **ឥតិ កល្យាណសីលោ** *សេចក្តីថា ជាអ្នកមានសីលល្អដោយប្រការនេះ អធិប្បាយថា សីលដែលព្រះមានព្រះភាគទ្រង់សម្តែងដោយអំណាចនៃបុគ្គលាធិដ្ឋាន ហើយទ្រង់បញ្ចប់ដោយអំណាចនៃបុគ្គលាធិដ្ឋានថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសីលល្អយ៉ាងនេះឯង ដូច្នេះ ហៅថា ភិក្ខុមានសីលល្អ ដូច្នេះទៀត ដើម្បីទ្រង់សម្តែងថា សីលនេះជាទីតាំងនៃធម៌ទាំងនោះ ដោយមានព្រះបំណងនឹងសម្តែងធម៌ដែលត្រាស់ហើយ ក្នុងបទថា* **កល្យាណធម្មោ** *នេះ បទទាំងពួងមានជាដើមថា* **សត្តន្នំ ពោធិបក្ខិយានំ** *មានអត្ថដូចពោលខាងដើមនោះឯង ។ បទថា* **កល្យាណសីលោ** *ជាដើម ជាពាក្យត្រាស់ដដែលទៀត ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **ទុក្ខដំ** បានដល់ ធ្វើអាក្រក់ អធិប្បាយថា បានដល់ ទុច្ចរិត ។ បទថា **ហិរិមនំ** សេចក្តីថា មានការខ្មាស គឺដល់ព្រមដោយហិរិ អធិប្បាយថា បានដល់ សភាវៈដែលវៀសនូវការប្រព្រឹត្តអាក្រក់ដោយប្រការទាំងពួង ។ ម្យ៉ាងទៀត បទថា **ហិរិមនំ** បានដល់ មានចិត្តប្រកបដោយហិរិ ។ ក្នុងអធិការនេះ គប្បីជ្រាបថា ទ្រង់កាន់យកឱត្តប្បៈដោយសព្ទថា **ហិរិ** ហើយនោះឯង ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងហេតុនៃភាពជាបុគ្គលទុច្ចរិត ដោយប្រការទាំងពួង ដោយសព្ទថា **ហិរិឱត្តប្ប** ឈ្មោះថា រមែងញុំាងនូវភាពជាអ្នកមានសីលល្អឲ្យជាក់ច្បាស់ ដោយហេតុ ។

ភិក្ខុឈ្មោះថា **សម្ពោធិគាមិនោ** ព្រោះដល់ គឺជួបនូវសម្ពោធិញ្ញាណ គឺអរិយមគ្គញ្ញាណ អធិប្បាយថា ប្រព្រឹត្តទៅក្នុងចំណែកនៃពោធិ ។ បទថា **អនុស្សទំ** សេចក្តីថា វៀរចាកកិលេសដែលផ្សាយឡើង មានរាគៈជាដើម ។ អាចារ្យខ្លះពោលថា **តថាវិធំ** ដូច្នេះក៏មាន អធិប្បាយថា ពាក្យថា ជាអ្នកប្រកបរឿយៗ នូវការចម្រើននូវពោធិបក្ខិយធម៌នេះ ព្រះមានព្រះភាគត្រាស់ហើយ ក្នុងកាលមុនណាមួយ ក៏យ៉ាងនោះ គឺដូច្នោះ ។

បទថា **ទុក្ខស្ស** បានដល់ វដ្តទុក្ខ ឬហេតុនៃវដ្តទុក្ខ ។ បទថា **ឥធេវ ខយមត្តនោ** សេចក្តីថា រមែងដឹងច្បាស់នូវការអស់ទៅ គឺការមិនកើតឡើងនៃព្រៃស្ទុក គឺកិលេសដែលជាហេតុនៃវដ្តទុក្ខរបស់ខ្លួន គឺប្រព្រឹត្តទៅក្នុងផ្នែកនៃសមុទយៈ ដោយការសម្រេចការអស់ទៅនូវអាសវៈក្នុងអត្តភាពនេះឯង គឺ

ក្នុងអត្តភាពនេះ ។ម្យ៉ាងទៀត រមែងដឹងនូវការអស់ទៅ គឺអស់ទៅនូវវដ្តទុក្ខនោះឯង ដោយការរលត់នៃចរិមកចិត្ត ក្នុងអត្តភាពនេះឯង ។

បទថា **តេហិ ធម្មេហិ សម្បន្នំ** សេចក្តីថា ប្រកបហើយដោយធម៌មានសីលតាមដែលពោលហើយជាដើម ។ បទថា **អសិតំ** សេចក្តីថា មិនអាស្រ័យ គឺមិនទាក់ទងក្នុងអ្វីមួយ ព្រោះលះធម៌ដែលជាគ្រឿងអាស្រ័យ គឺតណ្ហា និងទិដ្ឋិបានហើយ ។ បទថា **សព្វលោកស្ស** បានដល់ ក្នុងសត្វលោកទាំងពួង ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនោះឯង ៕

**អដ្ឋកថា កល្យាណសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ទានសូត្រ

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ ទាននេះ មាន ២ យ៉ាង គឺអាមិសទាន ១ ធម្មទាន ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ យ៉ាងនេះ ធម្មទានប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការចែកនេះ មាន ២ យ៉ាង គឺការចែកអាមិសៈ ១ ការចែកធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការចែកទាំង ២ នេះ ការចែកធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីអនុគ្រោះនេះ មាន ២ យ៉ាង គឺសេចក្តីអនុគ្រោះ ដោយអាមិសៈ ១ សេចក្តីអនុគ្រោះ ដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីអនុគ្រោះទាំង ២ យ៉ាងនេះ សេចក្តី

អនុគ្រោះដោយធម៌ ប្រសើរជាង ។

ព្រះមានព្រះភាគ ពោលសរសើរ នូវទានណា ថាជាទានឧត្តម ប្រសើរលើស ត្រាស់សរសើរ នូវការចែកណា ( ថាជារបស់ឧត្តម ប្រសើរលើស ) អ្នកប្រាជ្ញមានចិត្តជ្រះថ្លា ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ កាលបើដឹងច្បាស់ហើយ នរណានឹងមិនបូជា ក្នុងកាលដែលគួរ ។ ពួកសត្វណា សម្តែងផង ស្តាប់ផង ទាំងពីរពួក មានចិត្តជ្រះថ្លា ក្នុងសាសនាព្រះសុគត ( មួយទៀត ) ពួកសត្វណា មិនធ្វេសប្រហែស ក្នុងសាសនាព្រះសុគត ប្រយោជន៍ដ៏សំខាន់នោះ របស់ពួកទាំងនោះ រមែងបរិសុទ្ធ ។ សូត្រទី ៩ ។

# អដ្ឋកថា

## ទានសូត្រ

[ ១០០ ] ក្នុងទានសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ទានំ** បានដល់ ក្នុងវត្ថុដែលគប្បីឲ្យ ។ម្យ៉ាងទៀត ចេតនា មួយអន្ទើដោយវត្ថុឈ្មោះថា ទាន ។ បទថា **ទាន** នេះ ជាឈ្មោះនៃការបរិច្ចាគសម្បត្តិ ។ បទថា **អាមិស ទានំ** សេចក្តីថា បច្ច័យ ៤ ឈ្មោះថា អាមិសទាន ដោយ

អំណាចនៃភាពជារបស់ដែលគប្បីឲ្យ អធិប្បាយថា បច្ច័យ ៤ លោកហៅថា អាមិស ព្រោះជាគ្រឿងពាល់ត្រូវដោយកិលេស មានតណ្ហាជាដើម ។ ម្យ៉ាងទៀត ចេតនាដែលជាគ្រឿងបរិច្ចាគបច្ច័យ ៤ ទាំងនោះ ឈ្មោះថា អាមិសទាន ។

បទថា **ធម្មទានំ** សេចក្តីថា បុគ្គលខ្លះក្នុងសាសនានេះ កាលចែកកុសលកម្មបថ និងអកុសលកម្មបថថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះជាអកុសល ធម៌នេះមានទោស ធម៌នេះមិនមានទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះអ្នកប្រាជ្ញសរសើរ ធម៌ទាំងនេះ សមាទានឲ្យបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីវត្តឥតប្រយោជន៍ ដើម្បីទុក្ខ ធម៌ទាំងនេះតែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដូច្នេះ ធ្វើនូវកម្ម និងផលនៃកម្មឲ្យប្រាកដ ដូចចន្លុលឲ្យឃើញលោកនេះ និងលោកខាងមុខ ដោយប្រចក្ស សម្តែងនូវធម៌ ឲ្យលះបង់នូវអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌ទាំងឡាយ នេះឈ្មោះថា **ធម្មទាន** ។ ឯបុគ្គលពួកខ្លះ ចង្អុលបង្ហាញនូវសច្ចៈទាំងឡាយឲ្យជាក់ច្បាស់ថា ធម៌ទាំងនេះ ជាអភិញ្ញេយ្យធម៌ ធម៌ទាំងនេះ ជាបរិញ្ញេយ្យធម៌ ធម៌ទាំងនេះ ជាបហាតព្វធម៌ ធម៌ទាំងនេះ ជាសច្ឆិកាតព្វធម៌ ធម៌ទាំងនេះ ជាភាវេតព្វធម៌ ដូច្នេះ សម្តែងធម៌ដែលជាបដិបទាដើម្បីសម្រេចនូវអមតធម៌ នេះឈ្មោះថា ធម្មទានដ៏កំពូល ។

បទថា **ឯតទគ្គំ** កាត់បទជា **ឯតំ អគ្គំ** ប្រែថា ធម្មទាននេះជាកំពូល ។ បទថា **យទិទំ** កាត់បទជា **យំ ឥទំ** សេចក្តីថា បណ្តាទានទាំង ២ យ៉ាងនេះ

ធម្មទានដែលពោលហើយនេះ ជាកំពូល គឺប្រសើរបំផុត បានដល់ ឧត្តម អធិប្បាយថា បុគ្គលនឹងរួចចាកអនត្ថៈទាំងពួង គឺឈានកន្លងនូវទុក្ខ ក្នុងវដ្ដៈទាំងមូលបាន ព្រោះអាស្រ័យធម្មទានដែលជាឧបាយ ញុំាងសត្វឲ្យដល់ព្រះនិព្វាន ។ ធម្មទានដែលជាលោកិយ ជាហេតុនៃទានសព្វយ៉ាង ជាឫសគល់នៃសម្បត្តិទាំងពួង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងធម្មបទថា

ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង
សេចក្ដីត្រេកអរក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង ការ
អស់តណ្ហា ឈ្នះទុក្ខទាំងពួង ដូច្នេះ ។

ក្នុងអធិការនេះ **អភយទាន** គប្បីជ្រាបថា ទ្រង់សង្គ្រោះចូលដោយធម្មទាននោះឯង ។ ការមិនបរិភោគបច្ច័យទាំងឡាយខ្លួនឯង អំពីបច្ច័យ ៤ ដែលខ្លួនគប្បីបរិភោគ ហើយចែកចាយដល់អ្នកដទៃ ដោយមានបំណងដើម្បីផ្សាយដល់មនុស្សទូទៅ ឈ្មោះថា **អាមិសសំវិភាគោ** គឺចែករំលែកនូវអាមិស ។ ភាពជាបុគ្គលមិនមានការខ្វល់ខ្វាយតិច សម្ដែងធម៌ដែលខ្លួនដឹងហើយ គឺសម្រេចហើយដល់អ្នកដទៃ ដោយមានបំណងនឹងផ្សាយធម៌ដល់មនុស្សទូទៅ ឈ្មោះថា **ធម្មសំវិភាគោ** គឺចែករំលែកនូវធម៌ ។ ការអនុគ្រោះ ការសង្គ្រោះជនដទៃដោយបច្ច័យ ៤ និងដោយសង្គហវត្ថុ ៤ ឈ្មោះថា **អាមិសានុគ្គហោ** គឺអនុគ្រោះដោយអាមិស ។ ការអនុគ្រោះ ដោយការសង្គ្រោះដល់អ្នកដទៃដោយធម៌ ដោយន័យដូចពោលហើយនោះឯង ឈ្មោះថា **ធម្មានុគ្គហោ**។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា **យមាហុ ទានំ បរមំ** សេចក្តីថា ព្រះមានព្រះភាគទាំងឡាយត្រាស់ទានណាថាប្រសើរ គឺឧត្តម ដោយភាពដែលចិត្ត គឺចេតនា ខេត្ត គឺ បដិគ្គាហក និងទេយ្យធម៌ ជារបស់ឱឡារ ឬ ដោយញ៉ាំងភោគសម្បត្តិជាដើមឲ្យបរិបូណ៌ គឺ ញ៉ាំងភោគសម្បត្តិជាដើម ឲ្យចេញផ្លែផ្កា ម្យ៉ាងទៀត ត្រាស់ថា កំពូល ព្រោះញ៉ាំញី គឺការកម្ចាត់ធម៌ដែលជាបដិបក្ខដទៃៗ មានលោភៈ និងមច្ឆរិយៈចេញបាន ។ បទថា **អនុត្តរំ** សេចក្តីថា ព្រះមានព្រះភាគទាំងឡាយត្រាស់ទានណាថា ឈ្មោះថា វៀរចាកទានដទៃដ៏កំពូលជាង នឹងឲ្យសម្រេចភាពជាធំ ព្រោះញ៉ាំងចេតនាសម្បត្តិជាដើមឲ្យប្រព្រឹត្តទៅល្អក្រៃលែង និងព្រោះភាពជាទាន មានផលប្រសើរដោយភាពជាកំពូលនៃទាន ។ ក្នុងបទថា **យំ សំវិភាគំ** នេះ គប្បីនាំយកបទទាំង ២ ថា **បរមំ អនុត្តរំ** មកភ្ជាប់ប្រកបចូលផង ។ បទថា **អវណ្ណយិ** សេចក្តីថា ប្រកាសហើយ គឺសរសើរហើយដោយន័យ ( ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ) ជាដើមថា ទាយកកាលឲ្យភោជនាហារ ឈ្មោះថា ឲ្យស្ថាន ៥ យ៉ាង ដល់បដិគ្គាហកទាំងឡាយ ដូច្នេះ ដោយន័យ ( ក្នុងឥតិវុត្តកៈ ) ជាដើមថា ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹង ដូច្នោះ ... ដូច្នេះ ។

ដើម្បីទ្រង់សម្តែងទាន និងការចែកទានថា មានផលច្រើន គឺមានផលក្រៃលែងនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **អគ្គម្ហិ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អគ្គម្ហិ** សេចក្តីថា ក្នុងព្រះសម្មាសម្ពុទ្ធ និងក្នុង

ព្រះអរិយសង្ឃដ៏ប្រសើរបំផុត គឺជាស្រែបុណ្យដ៏កំពូល ព្រោះប្រកបដោយគុណវិសេស មានសីលជាដើម ។ បទថា **បសន្នចិត្តោ** សេចក្ដីថា ញុំាងចិត្តឲ្យជ្រះថ្លា គឺកំណត់ដោយការជឿកម្ម និងផលនៃកម្ម និងជឿក្នុងព្រះរតនត្រ័យ អធិប្បាយថា ទាន គឺឲ្យទេយ្យធម៌សូម្បីតិច រមែងមានអានុភាពច្រើន គឺរុងរឿង វិសាលទៅបានច្រើន ព្រោះការដល់ព្រមដោយចិត្ត គឺចេតនាសម្បទា និងព្រោះដល់ព្រមដោយខេត្ត គឺបដិគ្គាហក ដូចបដិគ្គាហកាចារ្យពោលក្នុងវិមានវត្ថុថា

កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬ
សាវករបស់ព្រះតថាគតហើយ ទក្ខិណាទាន ឈ្មោះថា
មានផលតិច មិនមែនឡើយ ។

បទថា **វិញ្ញូ** បានដល់ អ្នកមានប្រាជ្ញា ។ បទថា **បជានំ** សេចក្ដីថា ដឹងច្បាស់នូវផលនៃទាន និងអានិសង្សរបស់ទាន ដោយប្រពៃនោះឯង ។ បទថា **កោ ន យជេថ កាលេ** សេចក្ដីថា បុគ្គលណាមិនឲ្យទានក្នុងកាលដែលសមគួរ អធិប្បាយថា ទានរមែងសម្រេចក្នុងកាលដែលប្រជុំដោយវត្ថុ ៣ យ៉ាង គឺសទ្ធា ១ ទេយ្យធម៌ ១ បដិគ្គាហក ១ មិនមែនកើតដោយប្រការដទៃ ។ម្យ៉ាងទៀត នឹងឲ្យទានដល់បដិគ្គាហកទាំងឡាយបានក្នុងកាលដ៏គួរប៉ុណ្ណោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការចែក និងអនុគ្រោះ ដោយអាមិសទាន ដោយគាថាទី ១ យ៉ាងនេះហើយ ដើម្បីទ្រង់សម្ដែងការចែក និង

ការអនុគ្រោះ ដោយធម្មទាន ទើបត្រាស់គាថាទី ២ ថា **យេ ចេវ ភាសន្តិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧភយំ** សេចក្ដីថា ជនទាំង ២ ចំណែក គឺអ្នកសម្ដែង និងអ្នកស្ដាប់ ដែលលោកពោលហើយថា **ភាសន្តិ សុណន្តិ** ដូច្នេះ ។ ក្នុងបទថា **ឧភយំ** នោះ មានសេចក្ដីសង្ខេបដូចតទៅនេះ បុគ្គលពួកណា មានចិត្តជ្រះថ្លាហើយក្នុងសាសនា គឺព្រះសទ្ធម្មរបស់ព្រះសុគត គឺព្រះមានព្រះភាគ តាំងនៅក្នុងធម៌ដែលជាប្រធាន គឺវិមុត្តាយតនៈ រមែងសម្ដែងផង រមែងស្ដាប់ផង ប្រយោជន៍ ពោល គឺធម្មទាន ការចែកចាយធម៌ និងការអនុគ្រោះ ដោយធម៌របស់អ្នកសម្ដែង និងបដិគ្គាហកទាំងនោះ ឈ្មោះថា ជាកំពូល ព្រោះញ៉ាំងបរមត្ថប្រយោជន៍ឲ្យសម្រេច ឈ្មោះថា រមែងបរិសុទ្ធ ព្រោះបរិសុទ្ធចាកមន្ទិល ដែលធ្វើសេចក្ដីសៅហ្មងសព្វយ៉ាង មានសេចក្ដីសៅហ្មងព្រោះតណ្ហាជាដើម សួរថា របស់បុគ្គលដូចម្ដេច ឆ្លើយថា របស់បុគ្គលដែលមិនប្រមាទក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសុគត បុគ្គលណាមិនប្រមាទក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គឺក្នុងឱវាទ ដែលទ្រង់ទូន្មាន ដែលទ្រង់ប្រកាសហើយ ដោយសង្ខេបយ៉ាងនេះថា

ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឲ្យកើតឡើង
ការធ្វើចិត្តរបស់ខ្លួនឲ្យ ផូរផង់ នេះជាពាក្យប្រដៅ
របស់ព្រះពុទ្ធទាំងឡាយ ។

ដូច្នេះហើយ ញ៉ាំងសិក្ខា ៣ មានអធិសីលសិក្ខាជាដើមឲ្យដល់ព្រម

ដោយគោរព ប្រយោជន៍ រមែងបរិសុទ្ធដល់មនុស្សទាំងនោះ រមែងញុំាងអ្នកទាំងនោះឲ្យផ្លូវផង់ពន់ពេក ដោយអរហត្តផលវិសុទ្ធិ ដូច្នេះ ។៙

**អដ្ឋកថា ធានសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## តេវិជ្ជសូត្រ

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវបុគ្គលដទៃ ថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោល និងបង្ហាញនូវមន្តប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវបុគ្គលដទៃ ថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោល និងបង្ហាញនូវមន្តប៉ុណ្ណោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រឭកជាតិដែលបានអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១ សែនជាតិខ្លះ រឭកបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ

មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុនោះ រឭកតាមនូវជាតិ ដែលអាស្រ័យនៅក្នុងកាលមុន បានជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ នេះជាវិជ្ជាទី ១ ដែលភិក្ខុនោះបានហើយ អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យាយាមដុតកម្តៅកិលេស មានចិត្តបូជាស្មុង ( ឥតមាននឹកនាដល់កាយ និងជីវិតឡើយ ) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានចក្ខុទិព្វ បរិសុទ្ធកន្លងបង់ចក្ខុជារបស់មនុស្ស ពិចារណាឃើញនូវសត្វទាំងឡាយ ដែលកំពុងច្យុត កំពុងកើត ទាបថោក និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់

មាំនូវកម្មជាសម្មាទិដ្ឋិ លុះសត្វទាំងនោះបែកធ្លាយរាងកាយ ស្លាប់ទៅ បាន ទៅកើតឯសុគតិសួគ៌ទេវលោក ភិក្ខុនោះ មានចក្ខុទិព្វ បរិសុទ្ធ កន្លងបង់ចក្ខុ ជារបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅ តាមកម្ម ដោយប្រការដូច្នេះ ។ នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានហើយ អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់ ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យាយាមដុតកម្តៅកិលេស មានចិត្តមូល ស៊ុង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនូវអាសវៈទាំងឡាយ ។ នេះជា វិជ្ជាទី ៣ ដែលភិក្ខុនោះបានហើយ អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹត ខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់ភិក្ខុនោះ ដែលមិនប្រហែសធ្វេស ខំព្យា-យាមដុតកម្តៅកិលេស មានចិត្តមូលស៊ុង ។ ម្នាលភិក្ខុទាំងឡាយ តថាគត បញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថាជាព្រាហ្មណ៍ មិនបញ្ញត្តនូវ បុគ្គលដទៃ ថាជាព្រាហ្មណ៍ ដោយគ្រាន់តែពាក្យពោលនិងបង្ហាញនូវមន្ត ប៉ុណ្ណោះទេ យ៉ាងនេះឯង ។

បុគ្គលណា បានដឹងនូវខន្ធសន្តាន ដែលអាស្រ័យនៅ
ក្នុងកាលមុន ទាំងឃើញនូវស្ថានសួគ៌ និងអបាយ ទាំង
បានដល់នូវការអស់ទៅនៃជាតិ ជាខាងក្រោយ បុគ្គល
នោះ ឈ្មោះថាអ្នកប្រាជ្ញបានញុំាងកិច្ចឲ្យសម្រេច ព្រោះ

ដឹងច្បាស់នូវចតុសច្ចធម៌ ។ ព្រាហ្មណ៍ ( ណា ) ជា
អ្នកបានត្រៃវិជ្ជា ដោយវិជ្ជា ៣ នុ៎ះ តថាគតហៅនូវ
ព្រាហ្មណ៍ អ្នកបានត្រៃវិជ្ជានោះ ថាជាព្រាហ្មណ៍ មិន
ហៅនូវបុគ្គលដទៃ ដែលជាអ្នកពោល និងបង្ហាញនូវ
មន្ត ថាជាព្រាហ្មណ៍ឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១០ ។

បញ្ចមវគ្គ ចប់

## ឧទ្ទាននៃបញ្ចមវគ្គនោះ គឺ

និយាយអំពីសេចក្តីជ្រះថ្លា ១ ការចិញ្ចឹមជីវិត ១ សង្ឃាដី
១ ភ្លើង ១ ការពិចារណា ១ ការកើតឡើងនៃកាម ១
កាមយោគៈ ១ សីលល្អ ១ ទាន ១ ព្រាហ្មណ៍ដោយ
ធម៌ ១ ត្រៃវិជ្ជា ១០ ។

តិកនិបាត ចប់

# អដ្ឋកថា

## តេវិជ្ជសូត្រ

ក្នុងតេវិជ្ជសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០១ ] បទថា **ធម្មេន** បានដល់ ញាយធម៌ គឺដោយហេតុ ដោយការណ៍ ពោល គឺសម្មាបដិបត្តិ អធិប្បាយថា ភិក្ខុរមែងមានវិជ្ជា ៣ ដោយបដិបទាណា បដិបទានោះ គប្បីជ្រាបថា ធម៌ ក្នុងអធិការនេះ ។ បដិបទានោះ គឺអ្វី គឺចរណសម្បទា ១ វិជ្ជាសម្បទា ១ ។ បទថា **តេវិជ្ជំ** សេចក្តីថា ប្រកបហើយដោយវិជ្ជា ៣ មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ។ បទថា **ព្រាហ្មណំ** បានដល់ ព្រាហ្មណ៍ដែលមានបាបបន្សាត់ហើយ ។ បទថា **បញ្ញាបេមិ** សេចក្តីថា ឲ្យដឹងទូទៅ គឺតែងតាំងឲ្យជាព្រាហ្មណ៍ ។ បទថា **នាញ្ញំ លបិតលាបនមត្តេន** សេចក្តីថា តថាគតមិនបញ្ញត្តបុគ្គលដទៃ គឺជាព្រាហ្មណ៍គ្រាន់តែដោយកំណើត ថាជាព្រាហ្មណ៍ ដោយហេតុត្រឹមតែការពោលតាម ដែលអដ្ឋកឥសីជាដើមបញ្ញត្តហើយ ។

ម្យ៉ាងទៀត បទថា **លបិតលាបនមត្តេន** សេចក្តីថា ដោយហេតុត្រឹមតែរៀន ឬឲ្យរៀនមន្តទាំងឡាយ ។ ព្រាហ្មណ៍ទាំងឡាយ ហៅបុគ្គលដែលឈ្មោះថា មានវិជ្ជា ៣ ព្រោះការរៀនពួក ៣ នៃវេទ មានសាមវេទជាដើម ថាជាព្រាហ្មណ៍ ព្រះមានព្រះភាគត្រាស់ជំទាស់ពាក្យរបស់ព្រាហ្មណ៍នោះ ពិតហើយ ដោយបរមត្ថ ព្រះមានព្រះភាគប្រារព្ធទេសនានេះ តាមអជ្ឈាស្រ័យនៃបុគ្គលដែលត្រាស់ដឹងយ៉ាងនោះ ដើម្បីទ្រង់សម្តែងថា ព្រាហ្មណកោរវាទីទាំង

នេះ ដែលអវិជ្ជារឹតរួតហើយ ហៅព្រាហ្មណ៍ ដែលមានវិជ្ជា ៣ ថាជាព្រាហ្មណ៍ អ្នកមានវិជ្ជា ៣ តែបុគ្គលអ្នកមានវិជ្ជាតាមដែលពោលមកនេះ ទើបឈ្មោះថា ជាព្រាហ្មណ៍ ។

ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បុគ្គលដល់ព្រមដោយវិជ្ជាតែង ជាបុគ្គលដល់ព្រមដោយចរណៈផងដែរ ព្រោះវៀរចរណសម្បត្តិចេញហើយ នឹងមានវិជ្ជាសម្បត្តិមិនបាន ដូច្នោះ ទើបព្រះមានព្រះភាគមានបំណងនឹងបញ្ញត្តព្រាហ្មណ៍ដោយមាតិកា គឺវិជ្ជាប៉ុណ្ណោះ ធ្វើនូវចរណសម្បត្តិឲ្យឈមចុះខាងក្នុង ទ្រង់តាំងទេសនាថា **ធម្មេនាហំ ភិក្ខវេ តេវិជ្ជំ ព្រាហ្មណំ បញ្ញាបេមិ** ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តនូវបុគ្គលអ្នកបានត្រៃវិជ្ជា ដោយធម៌ ថា ជាព្រាហ្មណ៍ ដូច្នេះហើយ ធ្វើជាកថេតុកម្យតាបុច្ឆាថា **កថញ្ចាហំ ភិក្ខវេ ធម្មេន តេវិជ្ជំ ព្រាហ្មណំ បញ្ញាបេមិ** ដូច្នេះហើយ កាលទ្រង់ចែកពួក ៣ នៃវិជ្ជាដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ទើបត្រាស់ពាក្យជាដើមថា **ឥធ ភិក្ខវេ ភិក្ខុ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេកវិហិតំ** សេចក្តីថា មានបែបមិនតិច ឬប្រព្រឹត្តទៅហើយ គឺពណ៌នាហើយ ដោយប្រការជាច្រើន ។ បទថា **បុព្វេ-និវាសំ** បានដល់ ខន្ធសន្តានដែលខ្លួនធ្លាប់អាស្រ័យហើយក្នុងភពនោះៗ ផ្តើមតាំងអំពីភពដែលជាអតីត ដែលមិនមានរវាងចន្លោះ ។ បទថា **និវុដ្ឋំ**[១] សេចក្តីថា ដែលខ្លួនធ្លាប់នៅអាស្រ័យហើយ គឺកើតមកហើយតាមលំដាប់ បានដល់

១- បាលីនេះ បិដកខ្មែរ មិនមាន ។

ខន្ធដែលកើតហើយរលត់ទៅ ក្នុងសន្តានរបស់ខ្លួន ៗ ម្យ៉ាងទៀត បានដល់ ខន្ធដែលខ្លួននៅអាស្រ័យហើយជាធម្មតា គឺខន្ធដែលខ្លួនធ្លាប់អាស្រ័យហើយ ដោយគោចរជាទីនៅអាស្រ័យ បានដល់ ខន្ធដែលដឹងហើយដោយវិញ្ញាណ របស់ខ្លួន ឬដែលដឹងហើយដោយវិញ្ញាណរបស់អ្នកដទៃ ព្រោះការរឭកដល់ ការវិលវល់ ដែលដាច់ទៅហើយជាដើម ៗ បទថា **អនុស្សរតិ** សេចក្តីថា តាមរឭកដោយលំដាប់ជាតិយ៉ាងនេះថា ១ ជាតិខ្លះ ២ ជាតិខ្លះ ឬបានដល់ រឭកដល់រឿយៗ គឺកាលចិត្តបង្អោនទៅហើយ រមែងរឭកក្នុងលំដាប់នៃ បរិកម្ម ៗ

សព្ទថា **សេយ្យថីទំ** ជានិបាត ប្រើក្នុងអត្ថដែលសម្តែងដល់អាការដែល ប្រារព្ធហើយ ៗ បទថា **សេយ្យថីទំ** នោះឯង ព្រះមានព្រះភាគដើម្បីសម្តែង អាការនៃបុព្វេនិវាសញ្ញាណនេះ ដែលឈ្មោះថា ព្រះយោគាវចរប្រារព្ធហើយ ទើបត្រាស់ពាក្យជាដើមថា **ឯកម្បិ ជាតឹ** ដូច្នេះ ៗ បណ្តាបទទាំងនោះ បទ ថា **ឯកម្បិ ជាតឹ** បានដល់ ខន្ធសន្តាន ១ ដែលមានបដិសន្ធិជាមូល មាន ចុតិជាបរិយោសាន ទាក់ទងហើយក្នុងភព ១ ៗ ក្នុងបទថា **ទ្វេបិ ជាតិយោ** ជាដើម ក៏មានន័យដូចគ្នា ៗ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនេកេបិ សំវដ្ដកប្បេ** ដូចតទៅនេះ កប្បដែលវិនាស ឈ្មោះថា សំវដ្តកប្ប កប្បដែលចម្រើន ឈ្មោះថា វិវដ្ត-កប្ប ៗ ក្នុង ២ កប្បយ៉ាងនោះ សំវដ្តដ្ឋាយីកប្ប ទ្រង់កាន់យកហើយដោយ សំវដ្តកប្ប ឯវិវដ្តដ្ឋាយីកប្ប ទ្រង់កាន់យកហើយដោយវិវដ្តកប្ប ព្រោះមាន

សំវដ្តកប្បនោះជាមូល ។ កាលបើដូច្នេះ អសង្ខេយ្យកប្ប ៤ ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះ មាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បសូន្យទៅ តាំងមានឡើង ១ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះវិនាសទៅ តាំងមានឡើង ១ ម្នាលភិក្ខុទាំងឡាយ កាលកប្បត្រឡប់ចម្រើន តាំងមានឡើងវិញ ១ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះចម្រើន តាំងមានឡើង ១[១] ។ អសង្ខេយ្យកប្បទាំងនោះ ព្រះមានព្រះភាគទ្រង់កំណត់កាន់យកហើយ ។ ក្នុងអសង្ខេយ្យកប្ប ៤ យ៉ាងនោះ សំវដ្តកប្ប មាន ៣ គឺតេជោសំវដ្តកប្ប វិនាសដោយភ្លើង ១ អាបោសំវដ្តកប្ប វិនាសដោយទឹក ១ វាយោសំវដ្តកប្ប វិនាសដោយខ្យល់ ១ ។ ខេត្តនៃសំវដ្តកប្ប មាន ៣ គឺអាភស្សរព្រហ្ម ១ សុភកិណ្ហព្រហ្ម ១ វេហប្ផលព្រហ្ម ១ ។ កាលកប្បវិនាសដោយភ្លើង ភ្លើងឆេះទាបជាងអាភស្សរព្រហ្ម ពេលដែលវិនាសដោយទឹក រមែងវិនាសទាបជាងសុភកិណ្ហព្រហ្ម ពេលដែលកប្បវិនាសដោយខ្យល់ ខ្យល់បក់កម្ទេចទាបជាងជាន់ព្រហ្មវេហប្ផលា តែបើពោលដោយពិស្តារ ចក្រវាលមួយសែន រមែងវិនាសរួមគ្នាទាំងអស់ ។

ភិក្ខុបែបនេះ កាលរឭកដល់ខន្ធដែលខ្លួនធ្លាប់អាស្រ័យមកអំពីមុន ដូចពណ៌នាមកនេះ រមែងរឭកបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះ ។ សួរថា រឭកបានដូចម្តេច ឆ្លើយថា រឭកបានដោយន័យ

១- សេចក្តីពិស្តារ មើលក្នុងបិ. ៤៣ ទំ. ២ ។

ជាដើមថា ក្នុងភពនោះ អាត្មាអញ ... ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អមុត្រាសឹ** សេចក្ដីថា អញបានកើតហើយ ក្នុងសំវដ្ដកប្បនោះ ឬក្នុងភពនោះ ឬក្នុងកំណើតនោះ ឬក្នុងគតិនោះ ឬក្នុងវិញ្ញាណដ្ឋិតិនោះ ឬក្នុងសត្តាវាសនោះ ឬក្នុងសត្តនិកាយនោះ ។ បទថា **ឯវន្នាមោ** សេចក្ដីថា អញមានឈ្មោះថា តិស្សៈ ឬឈ្មោះថា បុស្សៈ ។ បទថា **ឯវំគោត្តោ** សេចក្ដីថា អញជាគោតមគោត្រ ឬជាកស្សបគោត្រ ។ បទថា **ឯវំវណ្ណោ** សេចក្ដីថា អញមានពណ៌ស ឬមានពណ៌ខៀវ ។ បទថា **ឯវមាហារោ** សេចក្ដីថា អញមានបាយ និងស្រូវសាលី និងមានសាច់ជាអាហារ ឬបរិភោគផ្លែឈើប្រព្រឹត្តទៅហើយ ។ បទថា **ឯវំសុខទុក្ខប្បដិសំវេទី** សេចក្ដីថា អញសោយសុខ និងទុក្ខ មានសាមិសសុខ និងនិរាមិសសុខជាដើម ដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត មានប្រការមិនតែមួយ ។ បទថា **ឯវមាយុបរិយន្តោ** សេចក្ដីថា អាត្មាអញមានអាយុប្រមាណ ១០០ ឆ្នាំជាកំណត់ ឬអាយុប្រមាណ ៨ ម៉ឺន ៤ ពាន់កប្បជាកំណត់ ។ បទថា **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** សេចក្ដីថា អាត្មាអញកាលចុតិចាកភព ចាកកំណើត ចាកគតិ ចាកវិញ្ញាណដ្ឋិតិ ចាកសត្តាវាស ឬចាកសត្តនិកាយទាំងនោះហើយ មកកើតក្នុងភព ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ឬក្នុងសត្តនិកាយឈ្មោះនោះ ។ បទថា **តត្រាបាសឹ** សេចក្ដីថា កាលនោះ អញកើតក្នុងភព ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ឬក្នុងសត្តនិកាយនោះទៀត ។ បទថា **ឯវន្នាមោ** ជាដើម មាន

ន័យដូចពោលហើយនោះឯង ។

ម្យ៉ាងទៀត ព្រោះពាក្យថា អញមានហើយក្នុងភពនោះ នេះជាការរឭកដល់តាមសមគួរ ដល់អភិនីហារតាមកម្លាំងរបស់ខ្លួននៃព្រះយោគាវចរដែលជាអ្នកពិចារណា ចម្រើនឡើងដោយលំដាប់ ។ ពាក្យថា អាត្មាអញច្យុតិអំពីភពនោះហើយ ជាការពិចារណារបស់ព្រះយោគាវចរ ដែលពិចារណាថយក្រោយ ព្រោះដូច្នោះ ទើបលោកពោលថា អញបានកើតក្នុងភពនោះ ក្នុងលំដាប់នៃការកើតក្នុងភពនេះថា អញបានមកកើតក្នុងភពនេះ ។

បទថា **អមុត្រាសឹ** សេចក្តីថា អញបានកើតហើយក្នុងភព ។បេ។ ឬក្នុងសត្តនិកាយនោះ ។ បទថា **ឯវំនាមោ** សេចក្តីថា អញឈ្មោះទត្តៈ ឬមិត្តៈ ។ បទថា **ឯវំគោត្តោ** សេចក្តីថា អញជាវាសេដ្ឋគោត្រ ឬកស្សបគោត្រ ។ បទថា **ឯវំវណ្ណោ** សេចក្តីថា អញមានពណ៌ខ្មៅ ឬពណ៌ស ។ បទថា **ឯវមាហារោ** សេចក្តីថា អញមានអាហារបរិសុទ្ធ ឬមានបាយនៃស្រូវសាលីជាអាហារជាដើម ។ បទថា **ឯវំសុខទុក្ខប្បដិសំវេទី** សេចក្តីថា អញសោយសុខជាទិព្វ ឬសោយសុខ និងទុក្ខជារបស់មនុស្ស ។ បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា អញមានអាយុប៉ុណ្ណោះៗ យ៉ាងក្រៃលែងជាកំណត់យ៉ាងនេះ ។ បទថា **សោ តតោ ចុតោ** សេចក្តីថា អញច្យុតិអំពីភពនោះជាដើមៗ ។ បទថា **ឥធូបបន្នោ** សេចក្តីថា អញកើតជាមនុស្សក្នុងភពចុងក្រោយនេះ ។ បទថា **ឥតិ** ប្រែថា ដោយប្រការដូច្នេះ ។

បទថា **សាការំ សឧទ្ទេសំ** សេចក្តីថា មួយអន្លើដោយឧទ្ទេស ដោយ

អំណាចនៃនាម និងគោត្រជាដើម មួយអន្ទើដោយអាការ ដោយអំណាចនៃពណ៌សម្បុរជាដើម អធិប្បាយថា សត្វទាំងឡាយ រមែងហៅគ្នាថា តិស្សៈ ថា គោតម ដោយឈ្មោះ និងគោត្រ រមែងប្រាកដដោយការផ្សេងគ្នាថា ជាមនុស្ស សម្បុរស្រគាំ សម្បុរ-ស ដោយវណ្ណៈជាដើម ព្រោះដូច្នោះ នាម និងគោត្រ ទើបជាឧទ្ទេស ក្រៅអំពីនេះជាអាការ ។

បទថា **អយមស្ស បឋមា វិជ្ជា អធិគតា** សេចក្តីថា វិជ្ជានេះឈ្មោះថាទី ១ ព្រោះជាវិជ្ជាដែលភិក្ខុនេះបានសម្រេចជាលើកដំបូង គឺវិជ្ជា រមែងឈ្មោះថា ភិក្ខុសម្រេចហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ដោយអត្ថថា ធ្វើឲ្យប្រាកដ ។ សួរថា ភិក្ខុនេះធ្វើអ្វីឲ្យជាក់ច្បាស់ ឆ្លើយថា ធ្វើបុព្វេនិវាសញ្ញាណឲ្យជាក់ច្បាស់ថា មោហៈដែលបិទបាំងនូវវិជ្ជានោះ លោកហៅថា អវិជ្ជា ព្រោះអត្ថថា ធ្វើបុព្វេនិវាសញ្ញាណនោះឯងមិនឲ្យប្រាកដ ។ បទថា **តមោ** សេចក្តីថា មោហៈនោះឯង លោកហៅថា **តមោ** គឺងងឹត ព្រោះអត្ថថា បិទបាំង ។ បទថា **អាលោកោ** សេចក្តីថា វិជ្ជានោះឯង ឈ្មោះថា **អាលោក** ព្រោះអត្ថថា ធ្វើនូវពន្លឺ ។ ក្នុងបទថា **អាលោកោ** នេះ បានសេចក្តីដូច្នេះថា វិជ្ជាដែលភិក្ខុនោះសម្រេចហើយ ។ បទដ៏សេសជាការពោលសរសើរ ។ ក្នុងអធិការនេះ បណ្ឌិតគប្បីប្រកបសេចក្តីថា វិជ្ជានេះឯងដែលភិក្ខុនោះសម្រេចហើយ គឺការមិនដឹងនូវវិជ្ជាដែលភិក្ខុនោះសម្រេចហើយ ដែលលោកកម្ចាត់ហើយ គឺធ្វើឲ្យវិនាសហើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះវិជ្ជាកើតហើយ ។ ក្នុងបទទាំង ២ ដ៏សេស ក៏ន័យនេះឯង ។

*បទថា* **យថា** *ក្នុងបទថា* **យថាតំ** *នេះ ប្រើក្នុងអត្ថថា ឧបមា ។ បទថា* **តំ** *ត្រឹមតែជានិបាត អធិប្បាយថា ឈ្មោះថា* **អប្បមត្តស្ស** *ព្រោះមិននៅប្រាសចាកសតិ ឈ្មោះថា* **អាតាបិនោ** *ព្រោះមានសេចក្តីព្យាយាមជាគ្រឿងញាំងកិលេសឲ្យក្តៅ ឈ្មោះថា* **បហិតត្តស្ស** *គឺមានចិត្តដែលបញ្ជូនទៅហើយ ព្រោះមិនអាល័យក្នុងរាងកាយ និងជីវិតលោក អធិប្បាយដូច្នេះថា កាលភិក្ខុជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាម មានខ្លួនបញ្ជូនទៅហើយ អវិជ្ជាត្រូវកម្ចាត់ វិជ្ជាគប្បីកើតឡើង ងងឹតគប្បីកម្ចាត់ ពន្លឺគប្បីកើតឡើង យ៉ាងណា អវិជ្ជាដែលភិក្ខុនោះកម្ចាត់ហើយ វិជ្ជាកើតឡើងហើយ ងងឹតដែលភិក្ខុនោះកម្ចាត់ហើយ ពន្លឺកើតឡើងហើយ យ៉ាងនោះដូចគ្នា លោកបានផលដែលសមគួរដល់ការតាមប្រកបសេចក្តីព្យាយាមនោះហើយ នៅដូច្នេះ ។*

*ក្នុងបទថា* **ទិព្វេន ចក្ខុនា** *នេះ ពាក្យណាដែលគួរពោល ពាក្យនោះខ្ញុំពោលអស់ហើយខាងដើម ។ បទថា* **វិសុទ្ធេន** *សេចក្តីថា ទិព្វចក្ខុ ឈ្មោះថា រមែងបរិសុទ្ធ ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយមើលឃើញសត្វដែលចុតិនិងបដិសន្ធិ អធិប្បាយថា ភិក្ខុណាឃើញត្រឹមតែសត្វដែលចុតិប៉ុណ្ណោះ មិនឃើញសត្វដែលបដិសន្ធិ ភិក្ខុនោះ រមែងកាន់យកនូវឧច្ឆេទទិដ្ឋិ ។ ភិក្ខុណាឃើញត្រឹមតែសត្វដែលបដិសន្ធិប៉ុណ្ណោះ មិនឃើញសត្វដែលចុតិ ភិក្ខុនោះរមែងកាន់យក* **នវសត្តបាតុភាវទិដ្ឋិ** *គឺទិដ្ឋិប្រាកដក្នុងសត្តាវាស ៩ ។ ព្រោះភិក្ខុឃើញទាំង ២ យ៉ាង រមែងឈានកន្លងនូវគតិទាំង ២ យ៉ាង ដូច្នោះទស្សនៈនោះ នៃភិក្ខុនោះ ក៏ជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ភិក្ខុដែលជាពុទ្ធបុត្តនោះ*

រមែងឃើញទាំង ២ យ៉ាង គឺចុតិផង បដិសន្ធិផង ។ ដោយហេតុនោះ ទើបលោកពោលថា ទិព្វចក្ខុ ឈ្មោះថា វិសុទ្ធិ ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយសម្លឹងឃើញសត្វដែលចុតិ និងបដិសន្ធិ ។ ម្យ៉ាងទៀត ទិព្វចក្ខុ ឈ្មោះថា វិសុទ្ធិ ព្រោះវៀរឧបក្កិលេស ១១ យ៉ាង ។ ដូចលោកពោលថា ទិព្វចក្ខុ ឈ្មោះថា បរិសុទ្ធ ព្រោះមិនចូលទៅសៅហ្មងដោយឧបក្កិលេស ១១ យ៉ាង ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ តថាគតដឹងច្បាស់ថា វិចិកិច្ឆាជាឧបក្កិលេស ( គ្រឿងសៅហ្មង ) របស់ចិត្ត ហើយក៏បានលះបង់នូវវិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវអមនសិការជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ... ដឹងច្បាស់ថា សេចក្ដីរន្ធត់កាយ ... ដឹងច្បាស់ថា សេចក្ដីឆ្មើងឆ្មៃ ... ដឹងច្បាស់ថា សេចក្ដីក្រវល់ក្រវាយកាយ ... ដឹងច្បាស់ថា សេចក្ដីព្យាយាមតឹងពេក ... ដឹងច្បាស់ថា សេចក្ដីព្យាយាមធូរពេក ... ដឹងច្បាស់ថា សេចក្ដីប្រាថ្នាហួសពេក ... ដឹងច្បាស់ថា នានត្តសញ្ញា ... ដឹងច្បាស់ថា ការសម្លឹងមើលនូវរូបក្រៃពេកជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវការសម្លឹងមើលនូវរូបក្រៃពេកជាឧបក្កិលេសរបស់ចិត្តចេញ[១] ដូច្នេះ ។

ឈ្មោះថា **អតិក្កន្តមានុសកំ** ព្រោះឃើញរូបបានឆ្ងាយជាងទស្សនវិស័យដែលជាឧបចារៈរបស់មនុស្ស ។ ម្យ៉ាងទៀត ឈ្មោះថា **អតិក្កន្តមា-**

---

១- សេចក្ដីពិស្ដារ មានក្នុងបិ. ២៧ ទំ. ១៥៣ ។

**ឆុសកំ** នេះ ព្រោះឈានកន្លងមំសចក្ខុរបស់មនុស្ស ។ ដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងបង់នូវចក្ខុរបស់មនុស្សនោះ ។ បទថា **សត្តេ បស្សតិ** សេចក្តីថា រមែងឃើញ គឺសម្លឹងមើល បានដល់ សម្លឹងឃើញពួកសត្វទាំងឡាយដូចមនុស្សសម្លឹងមើលដោយមំសចក្ខុ ។

ក្នុងបទថា **ចវមានេ ឧបបជ្ជមានេ** នេះ លោកសំម្តែងថា ក្នុងខណៈដែលចុតិ ឬក្នុងខណៈដែលឧប្បត្តិ ព្រះអរិយបុគ្គលមិនអាចនឹងឃើញបានដោយចក្ខុដែលជាទិព្វ តែសត្វពួកណាជិតចុតិ និងចុតិក្នុងឥឡូវនេះ សត្វទាំងនោះ លោកបំណងយកថា កំពុងចុតិ សត្វពួកណាបដិសន្ធិហើយ ឬកើតហើយភ្លាមៗ សត្វទាំងនោះ លោកបំណងយកថា កំពុងបដិសន្ធិ ព្រះអរិយ-បុគ្គលរមែងឃើញសត្វទាំងនោះ ដែលកំពុងចុតិ កំពុងបដិសន្ធិបែបនេះ ។ បទថា **ហីនេ** សេចក្តីថា គួរមើលងាយ គួរប្រមាទ ដោយអំណាចនៃជាតិត្រកូល និងភោគៈជាដើម ដែលអាក្រក់ ព្រោះប្រកបទៅដោយផលរបស់មោហៈ ។ បទថា **បណីតេ** សេចក្តីថា ផ្ទុយគ្នានឹងការអាក្រក់នោះ ព្រោះប្រកបដោយផលនៃអមោហៈ ។ បទថា **សុវណ្ណេ** សេចក្តីថា ប្រកបហើយដោយពណ៌សម្បុរដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ព្រោះប្រកបដោយផលនៃអទោសៈ ។ បទថា **ទុព្វណ្ណេ** សេចក្តីថា ប្រកបទៅដោយវណ្ណៈដែលមិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ព្រោះប្រកបទៅដោយផលនៃទោសៈ អធិប្បាយថា មានរូបស្អាត មានរូបអាក្រក់ ។ បទថា **សុគតេ** សេចក្តីថា ទៅកាន់សុគតិ ឬស្តុកស្តម្ភ មានទ្រព្យច្រើន ព្រោះប្រកប

ទៅដោយវិបាក គឺអលោភៈ ។ បទថា **ទុគ្គតេ** សេចក្ដីថា ទៅកាន់ទុគ្គតិ ឬក្រីក្រ មានទឹក និងបាយមិនបរិបូណ៌ ព្រោះប្រកបទៅដោយផល គឺលោភៈ ។ បទថា **យថាកម្មូបគេ** សេចក្ដីថា ក្នុងពួកសត្វដែលទៅតាមកម្ម តាមដែលខ្លួនបានសន្សំ ។ បណ្ដាបទទាំងនោះ កិច្ចរបស់ទិព្វចក្ខុ ព្រះមានព្រះភាគត្រាស់ហើយដោយពាក្យមុនថា **ចវមានេ** ដូច្នេះជាដើម ។ ដោយបទនេះទ្រង់ត្រាស់ដល់កិច្ចរបស់យថាកម្មូបគញ្ញាណ ។

លំដាប់នៃការកើតឡើងរបស់យថាកម្មូបគញ្ញាណនេះ មានដូច្នេះថា ភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនអាលោកកសិណ បែរមុខទៅកាន់នរកខាងក្រោម រមែងឃើញពួកសត្វនរក កំពុងសោយទុក្ខ យ៉ាងទារុណ ការឃើញនេះ ជាកិច្ចរបស់ទិព្វចក្ខុញ្ញាណតែម្យ៉ាង ។ ភិក្ខុនោះមនសិការយ៉ាងនេះថា សត្វទាំងនេះធ្វើកម្មអ្វីហ្ន៎ ទើបសោយទុក្ខបែបនេះ ។ លំដាប់នោះ ញាណ មានកម្មនោះជាអារម្មណ៍ថា ធ្វើកម្មឈ្មោះនេះ ក៏កើតដល់ភិក្ខុនោះ ។ ខាងលើក៏ដូចគ្នា ភិក្ខុចម្រើនអាលោកកសិណ បែរមុខឆ្ពោះទៅកាន់ទេវលោក រមែងឃើញសត្វទាំងឡាយក្នុងនន្ទនវនឧទ្យាន មិស្សកវនឧទ្យាន និងបារុសកវនឧទ្យាន ជាដើម កំពុងសោយសម្បត្តិ ការឃើញនេះ ក៏ចាត់ជាកិច្ចរបស់ទិព្វ-ចក្ខុញ្ញាណដូចគ្នា ។ ភិក្ខុនោះមនសិការយ៉ាងនេះថា សត្វទាំងនេះធ្វើកម្មអ្វីហ្ន៎ ទើបសោយសម្បត្តិនេះ ។ លំដាប់នោះ លោកនឹងកើតញាណដែលមានកម្មនោះជាអារម្មណ៍ថា ធ្វើកម្មឈ្មោះនេះ ។ នេះឈ្មោះថា **យថាកម្មូបគញ្ញាណ** សូម្បីយថាកម្មូបគញ្ញាណនេះ ក៏មិនមានការញែកបរិកម្ម សូម្បីអនាគតំ-

*សញ្ញាណ ក៏មិនមានការញែកបរិកម្មដូចយថាកម្មុបគញ្ញាណ ដូច្នោះដែរ អធិប្បាយថា ញាណទាំងនេះ មានទិព្វចក្ខុជាបាទទាំងអស់ រមែងសម្រេចព្រមគ្នានឹងទិព្វចក្ខុ ។ ពាក្យណាដែលត្រូវពោល ក្នុងបទថា* **កាយទុច្ចរិតេន** *ជាដើម ពាក្យនោះ ខ្ញុំពោលអស់ហើយខាងដើមនោះឯង ។*

*ក្នុងវារៈនេះ វិជ្ជាដែលសម្បយុត្តដោយទិព្វចក្ខុញាណ ឈ្មោះថា វិជ្ជា អវិជ្ជាដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា អវិជ្ជា ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ក្នុងតតិយវារៈ វិជ្ជាដែលសម្បយុត្តដោយអរហត្តមគ្គញ្ញាណ ឈ្មោះថា វិជ្ជា ។ អវិជ្ជាដែលបិទបាំងសច្ចធម៌ទាំង ៤ ឈ្មោះថា អវិជ្ជា ។ ពាក្យដ៏សេសយល់បានងាយហើយព្រោះមានន័យដូចពោលខាងដើម ។ បទថា* **ឯវំ ខោ** *ជាដើម ជានិគមនវចនៈ ( ពាក្យសរុបចុងក្រោយ ) ។*

*ក្នុងគាថាទាំងឡាយ មានសេចក្តីសង្ខេបដូចតទៅនេះ ភិក្ខុណាបានដឹងហើយ គឺសម្រេចនូវបុព្វេនិវាសញ្ញាណតាមដែលពោលហើយ បានដល់ ដឹងដោយធ្វើឲ្យប្រាកដតាមន័យដែលពោលហើយ ។ បាឋៈជា* **យោ វេទិ** *ក៏មានអធិប្បាយថា ភិក្ខុណាបានដឹងហើយ គឺធ្វើបុព្វេនិវាសញ្ញាណឲ្យប្រាកដ តាំងនៅហើយ ភិក្ខុរមែងឃើញស្ថានសួគ៌ ពោល គឺទេវលោក ២៦ ជាន់ និងអបាយ ៤ ដោយទិព្វចក្ខុ ដោយន័យដូចពោលហើយនោះឯង ។*

*បទថា* **អថ** *សេចក្តីថា បន្ទាប់អំពីនោះ ភិក្ខុនោះដល់ គឺសម្រេចអរហត្តពោល គឺអស់ទៅនៃជាតិ ឬព្រះនិព្វាននោះឯង លំដាប់នោះ ភិក្ខុនោះ ឈ្មោះ*

ថា មានព្រហ្មចរិយៈនៅចប់ហើយ ដល់នូវការសម្រេចហើយ មានកិច្ចធ្វើស្រេចហើយ ព្រោះដឹងក្រៃលែង គឺដឹងសច្ចធម៌ទាំង ៤ ដែលព្រះអរិយបុគ្គលគប្បីដឹងដោយមគ្គប្បញ្ញាដ៏វិសេសក្រៃលែង ឈ្មោះថា ជាមុនី គឺជាព្រះខីណាស្រព ព្រោះប្រកបដោយមោនេយ្យធម៌ រមែងឈ្មោះថាជាព្រាហ្មណ៍ដែលមានវិជ្ជា ៣ ព្រោះប្រកបដោយវិជ្ជា ៣ តាមដែលពោលហើយនេះ និងព្រោះបន្សាត់បាបបានហើយ ដោយប្រការទាំងពួង ដោយវិជ្ជាទី ៣ បន្ទាប់អំពីនោះ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតហៅភិក្ខុនោះឯងដែលមានវិជ្ជា ៣ ថាជាព្រាហ្មណ៍ តែតថាគតមិនហៅអ្នកដទៃ គឺបុគ្គលដែលមានការពោលតាមគេសន្មត គឺអ្នកមានវិជ្ជា ៣ ដទៃ មានការទន្ទេញបទមន្តឈ្មោះយជុវេទជាដើម ថាជាព្រាហ្មណ៍ដោយធម៌ឡើយ ។

ដោយប្រការដូចពណ៌នាមកនេះ គប្បីជ្រាបថា ក្នុងវគ្គនេះ ព្រះមានព្រះភាគត្រាស់វដ្តៈក្នុងសូត្រទី ២ ត្រាស់វិវដ្តៈក្នុងសូត្រទី ៥ ទី ៨ និងទី ១០ ត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ក្នុងសូត្រក្រៅអំពីនេះ ៕□

**ធម្មសូត្រទី ១០ ចប់**

**វគ្គទី ៥ ចប់**

**ឥតិវុត្តក តិកនិបាត ចប់**

# សុត្តន្តបិដក

## ឥតិវុត្តក ចតុក្កនិបាត

### ព្រាហ្មណធម្មយាគសូត្រ

[ ១០២ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រាហ្មណ៍ គួរគេសូមបាន មានដៃលាងស្អាតគ្រប់កាល ទ្រទ្រង់នូវអត្តភាពជាទីបំផុត ជាពេទ្យវះកាត់យ៉ាងប្រសើរ អ្នកទាំងឡាយ ជាបុត្ត ជាឱរស កើតអំពីមាត់តថាគត កើតអំពីធម៌ មានធម៌តាក់តែងហើយ មានធម៌ជាមត៌ក មិនមានអាមិសៈជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទាននេះ មាន ២ គឺអាមិសទាន ១ ធម្មទាន ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ នេះ ធម្មទានប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការចែកនេះមាន ២ គឺការចែកអាមិសៈ ១ ការចែកធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការចែកទាំង ២ នេះ ការចែកធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការអនុគ្រោះនេះ មាន ២ គឺការអនុគ្រោះដោយអាមិសៈ ១ ការអនុគ្រោះដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការអនុគ្រោះទាំង ២ នេះ ការអនុគ្រោះដោយធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការបូជានេះ មាន ២ គឺការបូជាដោយអាមិសៈ ១ ការបូជាដោយធម៌ ១ ម្នាលភិក្ខុទាំង-ឡាយ បណ្តាការបូជាទាំង ២ នេះ ការបូជាដោយធម៌ប្រសើរជាង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

ព្រះតថាគតអង្គណា មិនមានព្រះហឫទ័យកំណាញ់
មានការអនុគ្រោះដល់សព្វសត្វ បានប្រោសប្រទានធម៌
សត្វទាំងឡាយ តែងនមស្ការព្រះតថាគតនោះ ប្រាកដ
ដូច្នោះ ព្រះអង្គប្រសើរជាងទេវតា និងមនុស្ស ទ្រង់
ដល់នូវត្រើយនៃភព ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។ សូត្រទី ១ ។

# អដ្ឋកថា

## ឥតិវុត្តក ចតុក្កនិបាត

## ព្រាហ្មណធម្មយាគសូត្រ

ក្នុងព្រាហ្មណធម្មយាគសូត្រទី ១ នៃចតុក្កនិបាត មានវិនិច្ឆ័យដូចតទៅ

[ ១០២ ] បទថា **អហំ** ជាបទសម្តែងដល់អត្តា គឺខ្លួន អធិប្បាយថា អត្តា ពោល គឺសន្តានដែលជារបស់ខ្លួន មិនមែនបុគ្គលដទៃ ហៅថា **អហំ** ព្រះសាស្តាទ្រង់ប្តេជ្ញាថា តថាគតជា ... ។ គឺកាលទ្រង់ប្តេជ្ញាភាពជាព្រាហ្មណ៍ដោយបរមត្ថ ដែលកំពុងត្រាស់ដល់ថា **អហំ** ថាមាននៅក្នុងព្រះអង្គ ទើបត្រាស់ថា តថាគតមាន ឯបទថា តថាគតជា ... ព្រះមានព្រះភាគក៏មិនបានត្រាស់ដូចបុថុជ្ជនទាំងឡាយ ដែលមិនទាន់លះអនុស័យ គឺទិដ្ឋិ និងមានះបាន ហើយនិយាយដោយអំណាចការប្រកាន់មាំដោយទិដ្ឋិ មានះ និងការមើលងាយថា អញមាន អញជាព្រហ្ម ជាមហាព្រហ្ម និងថា អញប្រសើរជាង ។ តែព្រះមានព្រះភាគទ្រង់លះទិដ្ឋានុស័យ និងមានានុស័យបានហើយ ដោយប្រការទាំងពួង ទ្រង់មិនស្ទុះរំលងសមញ្ញា ទ្រង់ញុំាងធម៌ឲ្យប្រតិស្ឋាននៅក្នុងសន្តាននៃវេនេយ្យសត្វ ដោយមិនជំទាស់នឹងលោកសម្មតិ ទ្រង់ប្តេជ្ញាថា គុណបែបនោះមានក្នុង ព្រះអង្គយ៉ាងគ្រប់គ្រាន់ ទើបត្រាស់ថា តថាគតជា... ។ បទថា **ព្រាហ្មណោ** សេចក្តីថា ឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បាបហើយ និងព្រោះស្វាធ្យាយដល់ព្រះព្រហ្ម ។ ក្នុងព្រះតម្រាស់នេះ មានអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រាហ្មណ៍ដោយបរមត្ថ ។

ព្រោះព្រះមានព្រះភាគទ្រង់ដល់ត្រើយនៃការសមាទានវត្ត មានទាន និងសញ្ញមៈ ( ការទូន្មានខ្លួន ) ជាដើម ដែលបរិបូណ៌ដោយអាការទាំងពួង ដោយការប្រព្រឹត្តតបៈ មិនមានសេសសល់ ទ្រង់នៅចប់ព្រហ្មចរិយៈហើយដោយល្អនោះឯង ទ្រង់ដល់នូវទីបំផុតនៃវេទ ទ្រង់មានវិជ្ជា និងចរណៈបរិសុទ្ធល្អហើយ ទ្រង់លាងមន្ទិល គឺបាបបានដោយប្រការទាំងពួង ត្រាស់ដល់ គឺត្រាស់ប្រាប់ព្រាហ្មណ៍ ពោល គឺអរិយមគ្គដ៏កំពូល និងទ្រង់ប្រកាសព្រហ្មចរិយៈដ៏បរិសុទ្ធល្អហើយ ព្រោះដូច្នោះ ទើបលោកពោលថា ទ្រង់ឈ្មោះថាជាព្រាហ្មណ៍ ដោយបរមត្ថ ព្រោះទ្រង់បន្សាត់បាបបានហើយ ដោយប្រការទាំងពួង និងព្រោះត្រាស់ដល់ គឺត្រាស់ប្រាប់ព្រះព្រហ្ម ( ព្រះសទ្ធម្មដ៏កំពូល ) ដល់អ្នកដទៃ ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសភាពជាព្រាហ្មណ៍ដ៏កំពូលនៃព្រះអង្គក្នុងលោក និងទេវលោកយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងថា កម្ម ៦ មានទានជាដើម ដែលព្រាហ្មណ៍បញ្ញត្តសម្រាប់ព្រាហ្មណ៍ ដែលបរិសុទ្ធល្អ មាននៅក្នុងព្រះអង្គយ៉ាងឧក្រិដ្ឋ ទើបត្រាស់ពាក្យថា **យាចយោគោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យាចយោគោ** បានដល់ ទ្រង់ប្រកបដោយភាវៈដែលគួរដល់អ្នកសូម ។ ជនពួកណាសូម ហេតុនោះ ជនទាំងនោះ ឈ្មោះថា **យាច។** ក្នុងទីនេះ អ្នកសូមទាំងនោះ គប្បីជ្រាបថា បានដល់ វេនេយ្យសត្វ អធិប្បាយថា អ្នកសូមទាំងនោះចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសូមឲ្យទ្រង់សម្តែងធម៌ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ

សម្តែងធម៌ចុះ សូមព្រះសុគតទ្រង់សម្តែងធម៌ចុះ ។ ព្រះមានព្រះភាគ ទ្រង់មិនបដិសេធនូវបំណងអ្នកសូមទាំងនោះ សម្តែងធម៌តាមគាប់ចិត្តរបស់អ្នកសូម ទ្រង់ប្រទានព្រះធម្មទាន ព្រោះហេតុនោះ ទើបឈ្មោះថា ទ្រង់សមគួរដល់អ្នកសូម ។ ព្រះអង្គទ្រង់មិនឆ្ងាយចាកអ្នកសូមទាំងនោះសព្វកាល គឺសព្វវេលា ម្យ៉ាងទៀត បទថា **យាចយោគោ** សេចក្តីថា ជាបុគ្គលគួរដល់នូវការសូម អធិប្បាយថា ទ្រង់ឈ្មោះថាជាអ្នកគួរដល់ការសូម ព្រោះទ្រង់ឲ្យនូវសេចក្តីត្រូវការរបស់អ្នកសូមបាន ។ បាឋៈថា **យាជយោគោ** ដូច្នេះក៏មាន ។ ក្នុងបទថា **យាជយោគោ** នោះ មានអធិប្បាយថា មហាទាន ហៅថា **យាជ** អធិប្បាយថា ការបូជា ។ តែក្នុងទីនេះ គប្បីជ្រាបថា បានដល់ ធម្មទាន ។ ព្រះមានព្រះភាគទ្រង់ប្រកបក្នុងទាន ព្រោះហេតុនោះ ទើបឈ្មោះថា **យាជ-យោគ** គឺជាអ្នកប្រកបក្នុងទាន ។ បទថា **សទា** ប្រែថា ទាំងពួង ។ អធិប្បាយថា ទ្រង់មានវត្តដែលគប្បីរឭកដល់ និងទ្រង់មានព្រះសទ្ធម្មជាមហាទាន ។ មួយប្រការទៀត ព្រះមានព្រះភាគទ្រង់ប្រកបសត្វដោយ **យាជ** គឺទាន ព្រោះហេតុនោះ ទើបឈ្មោះថា **យាជយោគ** អធិប្បាយថា ទ្រង់ប្រកបសត្វទាំងឡាយដោយ **យាជ** ពោល គឺទាន ៣ យ៉ាងតាមសមគួរ គឺទ្រង់ប្រកបសត្វក្នុងទាននោះ ។ អាចារ្យទាំងឡាយពោលថា **យាជយោគោ សតតំ** ដូច្នេះក៏មាន ។

បទថា **បយតបាណិ** បានដល់ ទ្រង់មានព្រះហស្តបរិសុទ្ធ អធិប្បាយថា បុគ្គលណាបង្អោនទៅក្នុងទាន កាលនឹងឲ្យអាមិសទាន រមែងជាអ្នកលាង

ដៃសព្វកាលនោះឯង ដើម្បីឲ្យទេយ្យធម៌ដោយគោរព ដោយដៃរបស់ខ្លួនឯង បុគ្គលនោះ លោកហៅថា **បយតបាណី** ជាអ្នកមានដៃលាងហើយ ។ ព្រះមានព្រះភាគ ក៏ទ្រង់បង្អោនទៅក្នុងធម្មទាន ទ្រង់ប្រកបខ្វល់ខ្វាយក្នុងធម្មទានសព្វកាលដោយគោរព ព្រោះហេតុដូចពោលមកនេះ ទើបលោកពោលថា ព្រះមានព្រះភាគ មានដៃលាងស្អាតហើយ ។ បទថា **សទា** គប្បីប្រកបចូលនឹងបទថា **បយតបាណី** នេះផងដែរ ។ បទថា **សទា បយតបាណី** សេចក្តីថា ព្រះសាស្តាទ្រង់ញុំាងការឲ្យនូវព្រះសទ្ធម្ម ឲ្យប្រព្រឹត្តទៅដល់សត្វលោកដែលជាវេនេយ្យសត្វសព្វកាល គឺសព្វវេលា ដោយមិនបែងចែក ឈ្មោះថា ទ្រង់ប្រកបសេចក្តីខ្វល់ខ្វាយក្នុងធម្មទាននោះ ។

ម្យ៉ាងទៀត ភាវនាហៅថា **យោគ** ដូចព្រះមានព្រះភាគត្រាស់ក្នុងធម្មបទថា ប្រាជ្ញារមែងកើតពីការប្រកប ដូច្នេះ ។ ព្រោះហេតុនោះ ក្នុងបទថា **យាជយោគោ** ទើបមានអធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ប្រកបរឿយៗនូវ **យាជភាវនា** គឺបរិច្ចាគភាវនា ។ ពិតហើយ ក្នុងមុនកាលត្រាស់ដឹង ព្រះសាស្តានៅជាព្រះពោធិសត្វ ត្រូវព្រះមហាករុណាជាស់តឿនហើយ ទ្រង់បានបំពេញនូវទាន ដោយមិនមានចំណែកសេសសល់ ទ្រង់បំពេញបារមីដ៏ឧក្រិដ្ឋក្នុងទាននោះ ហើយសម្រេចអភិសម្ពោធិញ្ញាណជាព្រះពុទ្ធ ហើយទ្រង់ក៏នៅតែបំពេញទាន ៣ យ៉ាង ទ្រង់ប្រទានធម្មទេសនាដោយពិសេស ព្រមទាំងទូន្មានអ្នកដទៃឲ្យតាំងនៅក្នុងធម្មទាននោះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ប្រទានទ្រព្យតាមបំណងដល់អ្នកសូម ដែលជាវេនេយ្យសត្វឲ្យជាធម្មទាន

ដោយចែកលោកិយទ្រព្យ និងលោកុត្តរទ្រព្យយ៉ាងនេះ គឺបុគ្គលខ្លះ ទ្រង់បាន ប្រទានសរណៈ បុគ្គលខ្លះ ទ្រង់បានប្រទានសីល ៥ បុគ្គលខ្លះ ទ្រង់បាន ប្រទានសីល ១០ បុគ្គលខ្លះ ទ្រង់បានប្រទានបារិសុទ្ធិសីល ៤ បុគ្គលខ្លះ ទ្រង់ បានប្រទានធុតធម៌ បុគ្គលខ្លះ ទ្រង់បានប្រទានឈាន ៤ បុគ្គលខ្លះ ទ្រង់បាន ប្រទានសមាបត្តិ ៨ បុគ្គលខ្លះ ទ្រង់បានប្រទានអភិញ្ញា ៥ មគ្គ ៤ សាមញ្ញផល ៤ វិជ្ជា ៣ បដិសម្ភិទា ៤ ហើយទ្រង់ទូន្មានបុគ្គលដទៃថា អ្នកទាំងឡាយ ចូរឲ្យ ឈ្មោះថា ទ្រង់ចម្រើននូវបរិច្ចាគការនា ដោយហេតុនោះ ទើបលោក ពោលថា ព្រះមានព្រះភាគទ្រង់ប្រកបរឿយៗ នូវបរិច្ចាគការនា ។ ម្យ៉ាងទៀត បទថា **បយតបាណិ** បានដល់ មានព្រះហស្តលាចេញហើយ អធិប្បាយថា ទ្រង់ប្រកបខ្វល់ខ្វាយក្នុងការឲ្យព្រះសទ្ធម្ម មិនក្តាប់ ដូចបុគ្គលលាដៃដើម្បីឲ្យ របស់ណាមួយដែលនៅក្នុងដៃ ព្រមទាំងពោលថា សូមមកទទួលយកចុះ ដូច្នោះ ។ ម្យ៉ាងទៀត បទថា **បយតបាណិ** បានដល់ មានព្រះហស្តអង់អាច អធិប្បាយថា ទ្រង់ធ្វើនូវការអាចហ៊ានក្នុងការប្រទានព្រះធម៌ ដូចបុគ្គលមាន ដៃអង់អាច ដើម្បីឲ្យអាមិសទាន ដូច្នោះ ។

បទថា **អន្តិមទេហធរោ** សេចក្តីថា ទ្រទ្រង់នូវអត្តភាពចុងក្រោយ ព្រោះធម៌ទាំងឡាយដែលធ្វើឲ្យជាព្រាហ្មណ៍ បរិបូណ៌ដោយការនៅប្រព្រឹត្ត ព្រហ្មចរិយធម៌ អធិប្បាយថា សម្រាប់បុគ្គលដែលមិនទាន់នៅចប់ព្រហ្មចរិយៈ មិនគប្បីមានគតិដែលសន្មតថា ថោកថយជាដើម ព្រោះលះធម៌ ព្រោះលះ ធម៌ទាំងឡាយ ដែលធ្វើឲ្យជាបុគ្គលថោកទាបមិនទាន់បាន គឺនៅមានការដេក

ក្នុងគភ៌ជាបន្ត ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងភាពដែលទ្រង់ជាព្រាហ្មណ៍ ជាអ្នកមានព្រហ្មចរិយធម៌នៅចប់ហើយ ។

បទថា **អនុត្តរោ ភិសក្កោ សល្លកត្តោ** សេចក្តីថា ព្រះមានព្រះភាគឈ្មោះថា ជាគ្រូពេទ្យដ៏កំពូល ព្រោះទ្រង់ព្យាបាលរោគ គឺវដ្តទុក្ខ ដែលព្យាបាលបានដោយក្រ ឈ្មោះថា សល្យទេព្យដ៏កំពូល ព្រោះកាត់ គឺដកឡើងបានជាសមុច្ឆេទនូវព្រួញទាំងឡាយ មានរាគៈជាដើម ដែលអ្នកដទៃមិនទាន់ដកឡើង ។ ព្រះមានព្រះភាគ ត្រាស់ការធ្វើបុគ្គលដទៃឲ្យបានជាព្រាហ្មណ៍ ដោយទ្រង់ប្រតិស្ឋានធម៌ទាំងឡាយ ដែលធ្វើឲ្យជាព្រាហ្មណ៍បានដោយត្រង់អធិដ្ឋានហើយក្នុងព្រះអង្គ ក្នុងសន្តតិរបស់បុគ្គលដទៃ ដោយពាក្យថា ជាពេទ្យវះកាត់យ៉ាងប្រសើរ ដូច្នេះ ។

បទថា **តស្ស មេ តុម្ហេ បុត្តា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាបុត្រ គឺចូរជាបុគ្គលដែលកើតអំពីឱរបស់តថាគត គឺជាបុគ្គលបែបនេះ ។ បទថា **ឱរសា** បានដល់ ជាអ្នកជាប់ជំពាក់ក្នុងទ្រូង ដូចជាឱរស គឺកូនដែលកើតអំពីទ្រូងនៃសត្វទាំងឡាយ រមែងជាអ្នកមានចំណែកនៃទ្រព្យសម្បត្តិ ដែលជារបស់បិតាជាពិសេស យ៉ាងណា សូម្បីព្រះអរិយបុគ្គលទាំងនេះ ក៏ដូច្នោះ កើតហើយក្នុងអរិយជាតិ ក្នុងទីបំផុតនៃការស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធ ទើបឈ្មោះថាជាឱរស ព្រោះជាអ្នកមានចំណែកនៃវិមុត្តិសុខ និងជារតនៈ គឺព្រះអរិយធម៌ ដែលជារបស់ព្រះសម្មាសម្ពុទ្ធនោះយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀត ព្រះអរិយសាវកទាំងឡាយដែលកំពុងឈាន

ចុះ និងឈានចុះកាន់អរិយភូមិ ដោយអានុភាពនៃព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ឈ្មោះថា រមែងគួរជាបុគ្គលដែលបុគ្គលណាម្នាក់គប្បីពោលថា ជាបុត្រដែលកើតអំពីទ្រូងដោយត្រង់ ព្រោះលោកមានអភិជាតិ ដែលសេចក្តីព្យាយាមឲ្យកើតហើយត្រង់ទ្រូងរបស់ព្រះសាស្តា ពិតហើយ ព្រះអរិយបុគ្គលទាំងនោះ ព្រះមានព្រះភាគទ្រង់ធ្វើក្នុងព្រះហឫទ័យ ដោយការមើលអាសយអនុស័យ ចរិយា និងអធិមុត្តិជាដើម និងដោយទ្រង់ពិចារណាដល់វត្ថុដែលជាទោសរឿយៗ ទ្រង់រាំងបំបែកចេញពីវត្ថុដែលជាទោសហើយ ឲ្យប្រតិស្ឋានទៅក្នុងធម៌ ដែលមិនមានទោស ទ្រង់ចិញ្ចឹមឲ្យធំ ថែទាំរាងកាយដោយធម៌ មានសីលជាដើម ។ បទថា **មុខតោ ជាតា** សេចក្តីថា ព្រះអរិយបុគ្គលទាំងឡាយ ឈ្មោះថា កើតអំពីព្រះឱស្ឋ ព្រោះកើតក្នុងអរិយជាតិ ដោយព្រះធម្មទេសនា ដែលកើតអំពីព្រះឱស្ឋ ។ម្យ៉ាងទៀត ព្រះអរិយបុគ្គលទាំងឡាយកើតហើយ ដោយអរិយមគ្គជាតិ ចាកមាត់កុសលធម៌ទាំងឡាយ គឺបាតិមោក្ខ មិនទូទៅដល់ធម៌ដទៃ ឬចាកវិមោក្ខមុខ ពោល គឺវិបស្សនា ដែលជាហេតុឲ្យដល់នូវការ ចេញទៅ ( វុដ្ឋានគាមិនីវិបស្សនា ) ព្រោះហេតុនោះ ទើបឈ្មោះថា កើតអំពីព្រះឱស្ឋ ។ ព្រះអរិយបុគ្គលទាំងឡាយ ឈ្មោះថា **ធម្មជា** ព្រោះថា កើតក្នុងសាសនធម៌ ឬក្នុងធម៌ គឺអរិយមគ្គ ដែលប្រជុំនូវត្រៃសិក្ខា ។ ព្រះអរិយបុគ្គលទាំងឡាយ ឈ្មោះថា **ធម្មនិម្មិតា** ព្រោះអត្ថថា ដែលធម៌នោះឯង និម្មិត គឺសាងហើយ ។ ព្រះអរិយបុគ្គលទាំងឡាយ ជាធម្មទាយាទ មានសតិ និងធម្មវិចយៈជាដើម មិនមែនជា

ទាយាទដោយអាមិស មានលាភ និងសក្ការៈជាដើមឡើយ អធិប្បាយថា ជាធម្មទាយាទ មិនមែនជាអាមិសទាយាទទេ ។

ធម៌ ក្នុងបទថា **ធម្មទាយាទា នោ អាមិសទាយាទា** នោះ មាន ២ យ៉ាង គឺនិប្បរិយាយធម៌ ១ បរិយាយធម៌ ១ ។ សូម្បីអាមិសក៏មាន ២ យ៉ាង គឺនិប្បរិយាយអាមិស ១ បរិយាយអាមិស ១ ។ សេចក្ដីនេះ មានអធិប្បាយដូចម្ដេច មានអធិប្បាយថា លោកុត្តរធម៌ ៩ ចែកប្រភេទជាមគ្គ ៤ ផល ៤ និព្វាន ១ ចាត់ជានិប្បរិយាយធម៌ មិនមែនចាត់ជាធម៌ដោយបរិយាយ គឺធម៌ដែលព្រះអរិយៈធ្វើឲ្យកើតឡើងហើយដោយពិត មិនមែនចាត់ជាធម៌ដោយបរិយាយ គឺដោយហេតុ ឬលេសណាមួយឡើយ ។ ឯកុសលដែលចូលទៅអាស្រ័យវិវដ្ដៈនេះ គឺបុគ្គលពួកខ្លះក្នុងលោកនេះ កាលប្រាថ្នាវិវដ្ដៈ ទើបឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើការបូជាព្រះសាស្ដាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ស្ដាប់ធម៌ សម្ដែងធម៌ ធ្វើឈានសមាបត្តិឲ្យកើត កាលធ្វើយ៉ាងនេះ រមែងបានទូវនិប្បរិយាយធម៌ គឺអមតនិព្វានដោយលំដាប់ កុសលនេះ ឈ្មោះថា បរិយាយធម៌ ។ ម្យ៉ាងទៀត បច្ច័យ ៤ មានចីវរជាដើម ឈ្មោះថា និប្បរិយាយអាមិសដូចគ្នា មិនជាអាមិសដោយបរិយាយ គឺដោយហេតុ ឬដោយលេសដទៃឡើយ ចំណែកកុសលដែលជាហេតុឲ្យដល់វដ្ដៈ គឺបុគ្គលពួកខ្លះក្នុងលោកនេះ កាលប្រាថ្នាវដ្ដៈ ត្រូវការភពដែលព្រមដោយសម្បត្តិ ទើបឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើត បុគ្គលនោះ កាលធ្វើយ៉ាងនេះ រមែងបានទូវសម្បត្តិរបស់ទេវតា និងមនុស្សតាមលំដាប់ កុសលនេះ

ឈ្មោះថា អាមិសបរិយាយ ។

បណ្ដាធម៌ ២ យ៉ាងនោះ និប្បរិយាយធម៌ ក៏ជារបស់ព្រះមានព្រះភាគ នោះឯង អធិប្បាយថា ព្រោះព្រះមានព្រះភាគត្រាស់ប្រាប់ភិក្ខុទាំងឡាយ ទើបសម្រេចមគ្គ ផល និព្វាន ដែលលោកពោលក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក យ៉ាងនេះថា ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលគេមិនទាន់រៀបចំ ។បេ។ ពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមជាខាងក្រោយ ដូច្នេះ ។ និងព្រះតម្រាស់ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេសថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ មានចក្ខុ មានញាណ មានធម៌ មានធម៌ដ៏ប្រសើរ ទ្រង់ជាអ្នកស្ដីប្រដៅ ទ្រង់ពោលរម្លឹកបង្អោនទៅរកប្រយោជន៍ ឲ្យនូវព្រះនិព្វានជាធម្មសា្វមិ ជាតថាគត ដូច្នេះ ។

សម្មឹបរិយាយធម៌ ក៏ជារបស់ព្រះមានព្រះភាគដូចគ្នា អធិប្បាយថា ព្រោះព្រះមានព្រះភាគត្រាស់ប្រាប់នោះឯង ទើបសាវកទាំងឡាយដឹងថា បុគ្គលប្រាជ្ញាវិវដ្ដៈ ឲ្យទាន ។បេ។ ធ្វើសមាបត្តិឲ្យកើតឡើង រមែងបាននូវអមតនិព្វានដោយលំដាប់ ។ សម្មឹអាមិសនិប្បរិយាយក៏ជារបស់ព្រះមានព្រះភាគដូចគ្នា អធិប្បាយថា ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាត ទើបភិក្ខុទាំងឡាយបានចីវរប្រណីត ផ្ដើមតាំងពីរឿងរបស់គ្រូពេទ្យឈ្មោះជីវកជាដើម សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ក្នុងវិនយបិដក ចីវរខន្ធកៈថា

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវគហបតីចីវរ ភិក្ខុណា ប្រាថ្នា ( បង្សុកូល ) ភិក្ខុនោះ ចូរទ្រទ្រង់សំពត់បង្សុកូលចុះ ភិក្ខុណាប្រាថ្នា ( គហបតីចីវរ ) ភិក្ខុនោះ ចូរត្រេកអរនឹងគហបតីចីវរចុះ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត តថាគតពោលសរសើរសេចក្ដីសន្ដោសដោយបច្ច័យណាមួយ ( តាមមានតាមបាន ) ។

ព្រោះព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយយ៉ាងនេះ ទើបភិក្ខុទាំង-ឡាយ បានបរិភោគបច្ច័យក្រៅអំពីនេះ ដូចពណ៌នាមកនេះ ។ អាមិសបរិយាយ ក៏ជារបស់ព្រះមានព្រះភាគដូចគ្នា អធិប្បាយថា ព្រោះព្រះមានព្រះភាគត្រាស់ប្រាប់នោះឯង ទើបសាវកទាំងឡាយដឹងថា បុគ្គលអ្នកប្រាថ្នាភពដែលសម្បូរដោយសម្បត្តិ ឲ្យទាន សមាទានសីល ។បេ។ ធ្វើសមាបត្តិឲ្យកើតហើយ បាននូវអាមិសបរិយាយ គឺទិព្វសម្បត្តិ មនុស្សសម្បត្តិដោយលំដាប់ ។ ព្រោះនិប្បរិយាយធម្មិក្ដី បរិយាយធម្មិក្ដី និប្បរិយាយអាមិសក្ដី បរិយាយអាមិសក្ដី ជារបស់ព្រះមានព្រះភាគទាំងអស់ ដូច្នោះ កាលទ្រង់សម្ដែងថា ទ្រង់ជាម្ចាស់ក្នុងធម៌ និងអាមិសនោះ កាលទ្រង់ប្រកបសាវកទាំងនោះចំពោះក្នុងធម៌ និងអាមិស ដែលប្រសើរជាង ដែលនាំមកនូវប្រយោជន៍ និងសេចក្ដីសុខដោយចំណែកមួយ ទើបត្រាស់យ៉ាងនេះថា អ្នកទាំងឡាយជាបុត្រ ជាឱរសេ កើតអំពីមាត់តថាគត ។បេ។ មិនមានអាមិសៈជាមត៌កឡើយ ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសភាពជាព្រាហ្មណ៍ដោយបរមត្ថរបស់ព្រះអង្គ និងភាពដែលអរិយសាវកទាំងឡាយ ជាបុត្រកើតអំពីទ្រូងជាដើមរបស់

ព្រះអង្គ ដែលមានការសមាទានវត្តដ៏បរិបូណ៌ ដែលទ្រង់បំពេញតបៈ ទ្រង់នៅចប់ព្រហ្មចរិយៈហើយ ដោយប្រពៃនោះឯង ទ្រង់សម្បូរដោយវិជ្ជា និងចរណៈដ៏បរិសុទ្ធល្អហើយ ទ្រង់ដល់ត្រើយ គឺទីបំផុតនៃវេទ មិនមានចំណែកសេសសល់ ទ្រង់បន្សាត់បាបទាំងពួងបានហើយ ទ្រង់ជាបុគ្គលគួរដល់ការសូមអស់កាលជាកិច្ច ទ្រង់ដល់នូវភាពជាទក្ខិណេយ្យបុគ្គលដ៏កំពូលក្នុងលោកមួយអន្លើនឹងទេវលោក ដោយប្រការដូចពោលមកនេះ ។

ព្រះមានព្រះភាគ ត្រាស់ដល់ព្រះអង្គថា ដូចជារាជសីហ៍ ដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាតថា ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា សត្វសីហៈនេះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ទ្រង់ដូចជាបុរសអ្នកចង្អុលផ្លូវ ដូចព្រះតម្រាស់ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គថា ម្នាលតិស្សៈ ពាក្យថា បុរសស្ទាត់ក្នុងផ្លូវនោះ ជាឈ្មោះរបស់ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ទ្រង់ដូចព្រះរាជា ដូចព្រះតម្រាស់ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា ម្នាលសេលព្រាហ្មណ៍ តថាគតជាស្ដេចព្រោះធម៌ ដូច្នេះ ។

ទ្រង់ដូចគ្រូពេទ្យ ដូចព្រះតម្រាស់ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកថា ម្នាលសុនក្ខត្ត ពាក្យថា ពេទ្យវះដ៏ជំនាញទុំៈ ជាឈ្មោះនៃព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

ព្រះសាស្ដាជាព្រាហ្មណ៍ ដូចព្រះតម្រាស់ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាតថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ ( អ្នកបន្សាត់បង់នូវបាប )

នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។ ក្នុងទីនេះ ព្រះមានព្រះភាគ ក៏ត្រាស់ព្រះអង្គថា ដូចព្រាហ្មណ៍ ។

ព្រាហ្មណ៍ទាំងឡាយ រមែងសម្គាល់ព្រាហ្មណកិច្ចរបស់ព្រាហ្មណ៍ខាងក្រៅសាសនានេះ ដែលប្រកបដោយគុណ មានទានជាដើមឯណាថា បរិបូណ៌ ដើម្បីទ្រង់ប្រកាសថា គុណ មានទានជាដើមរបស់ព្រះអង្គក្រៃលែង និងប្រសើរជាងគុណទាំងនោះ ឥឡូវនេះ ទើបព្រះមានព្រះភាគផ្តើមពាក្យថា **ធម្មានិ ភិក្ខវេ ធានានិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យាគា** បានដល់ មហាយញ្ញ អធិប្បាយថា មហាទាន លោកហៅថា **យិដ្ឋំ** ដូច្នេះក៏មាន ។ បណ្តាយញ្ញ ២ យ៉ាងនោះ យញ្ញ គឺ អាមិស គប្បីជ្រាបថា ជាទានរបស់វេលាមព្រាហ្មណ៍ ទានរបស់ព្រះវេស្សន្តរ និងយញ្ញរបស់ព្រះបាទមហាវិជិតរាជ ។ យញ្ញ គឺ ធម៌ គប្បីជ្រាបថា បានដល់ ការដែលទ្រង់សម្តែងមហាសមយសូត្រ មង្គលសូត្រ ចូឡរាហុលោវាទសូត្រ សមចិត្តសូត្រជាដើម ។ បទដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដូចតទៅនេះ បទថា **អយជិ** បានដល់ ព្រះមានព្រះភាគបានឲ្យហើយ ។ បទថា **អមច្ឆរី** សេចក្តីថា ព្រះមានព្រះភាគឈ្មោះថា ប្រាសចាកសេចក្តីកំណាញ់ ព្រោះទ្រង់លះសេចក្តីកំណាញ់ទាំងអស់បានហើយជាសមុច្ឆេទ ទៀបគល់ពោធិព្រឹក្សនោះឯង ។ បទថា **សព្វសត្តា-នុកម្បី** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់មានប្រក្រតីអនុគ្រោះសព្វសត្វ

ដោយព្រះមហាករុណា ដូចឪពុកអនុគ្រោះកូនជាទីស្រឡាញ់ ដូច្នោះ សមដូចព្រះតម្រាស់ដូច្នេះថា

ព្រះមុនីមានហឫទ័យស្មើ ចំពោះសត្វទាំងពួង គឺទេវទត្ត
ខ្មាន់ធ្នូ ចោរអង្គុលិមាល៍ រាហុល និងដំរីធនបាល ។

បទដ៏សេស មានអត្ថងាយយល់ហើយ ។l៚

**អដ្ឋកថា ព្រាហ្មណធម្មយាគសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សុលភសូត្រ

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ វត្ថុដែលតិចតួចផង ងាយបានផង វត្ថុទាំងនោះ មិនមានទោសផង នេះមាន ៤ ។ វត្ថុទាំង ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាចីវរទាំងឡាយ បំសុកូលចីវរ ជារបស់តិចតួចផង ងាយបានផង ចីវរនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភោជនទាំងឡាយ បិណ្ឌិយាលោបភោជន ជារបស់តិចតួចផង ងាយបានផង ភោជននោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេនាសនៈទាំងឡាយ រុក្ខមូលសេនាសនៈ ជារបស់តិចតួចផង ងាយបានផង សេនាសនៈនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភេសជ្ជៈទាំងឡាយ ទឹកមូត្រស្អុយ ជារបស់តិចតួចផង ងាយបានផង

ទឹកមូត្រនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៤ នេះឯង ជារបស់តិចតួចផង ងាយបានផង វត្ថុទាំងនោះ ជារបស់មិនមានទោសផង ។ ម្នាលភិក្ខុទាំងឡាយ វេលាណា ភិក្ខុត្រេកអរដោយរបស់តិចតួចផង ងាយបានផង មិនមានទោសផង តថាគតពោលនូវគុណណាមួយ របស់ភិក្ខុនេះ ថាជាអង្គនៃសមណភាព ។

កាលបើភិក្ខុត្រេកអរ ដោយវត្ថុមិនមានទោស ជារបស់
តិចតួច ជារបស់ងាយបានហើយ រមែងមានចិត្តមិន
ចង្អៀតចង្អល់ ព្រោះប្រារព្ធនូវសេនាសនៈ ចីវរ ទឹក
និងភោជនឡើយ ភិក្ខុនោះ មិនទើសទាល់ ក្នុងទិស
ទាំងឡាយឡើយ ។ ធម៌ទាំងឡាយណា ដែលតថាគត
ពោលទុកហើយ ថាជាធម៌សមគួរដល់សមណភាព ធម៌
ទាំងនោះ ភិក្ខុអ្នកសន្តោស មិនប្រហែសធ្វេស បាន
ហើយ ។ សូត្រទី ២ ។

# អដ្ឋកថា

## សុលភសូត្រ

[ ១០៣ ] ក្នុងសុលភសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អប្បានិ** បានដល់ បច្ច័យ ៤ បន្តិចបន្តួច ។ បទថា **សុលភានិ** គឺដែលបុគ្គល គប្បីបានដោយងាយ គឺអាចរកបានក្នុងទីណាមួយ ។ បទថា **អនវជ្ជានិ** គឺ ឈ្មោះថា វៀរចាកទោស គឺឈ្មោះថា មិនមានទោស ព្រោះបរិសុទ្ធដោយទី មក និងព្រោះមិនមានភាវៈជាទីតាំងនៃកិលេស មានការប្រដាប់កាយជាដើម ។ ក្នុងបទថា **អប្បានិ សុលភានិ** និងបទថា **អនវជ្ជានិ** នោះ មានអធិប្បាយ ថា ព្រះមានព្រះភាគទ្រង់សម្តែងការមិនមានទុក្ខ ដែលកើតអំពីការស្វែងរក ព្រោះភាពជាបច្ច័យ ៤ រកបានងាយ ។ ទ្រង់សម្តែងការមិនមានទុក្ខ ដែល កើតអំពីការរក្សា ព្រោះភាពដែលបច្ច័យ ៤ មានតិច ទ្រង់សម្តែងភាពដែល បច្ច័យ ៤ ជារបស់គួរដល់ភិក្ខុ ព្រោះបុគ្គលណាម្នាក់តិះដៀលមិនបាន ជា របស់មិនមានទោស ។ ទ្រង់សម្តែងភាពដែលបច្ច័យ ៤ មិនជាទីតាំងនៃការ តក់ស្លុត ព្រោះជារបស់តិចតួច ។ ទ្រង់សម្តែងថា បច្ច័យ ៤ មិនជាទីតាំងនៃ លាភ ព្រោះរកបានងាយ ទ្រង់សម្តែងថា បច្ច័យ ៤ ជាទីតាំងនៃនិស្សរ-ណប្បញ្ញាដោយអំណាចនៃទោស ព្រោះមិនមានទោស ។ បច្ច័យ ៤ មិនញុំាង សោមនស្សចិត្តឲ្យកើត ព្រោះលាភតាមដែលបាន ព្រោះមានតិច មិនញុំាង ទោមនស្សឲ្យកើត ព្រោះបានងាយ មិនញុំាងអញ្ញាណុបេក្ខា ដែលមានការ ក្តៅក្រហាយ ជានិមិត្តឲ្យកើត ព្រោះជាទីតាំងនៃការមិនក្តៅក្រហាយ ព្រោះ មិនមានទោស ។

បទថា **បំសុកូលំ** សេចក្តីថា ចីវរដ៏សេស ជ្រើសរើសយកសេស សំពត់ដែលជ្រុះតាមផ្លូវជាដើមមកធ្វើ ។ ដែលបានឈ្មោះយ៉ាងនេះថា បង្សុ-កូល ព្រោះដូចជាគំនរធូលី ដោយអត្ថថា ហុយឡើង ព្រោះនៅលើធូលីទាំងឡាយ ក្នុងទីណាមួយ មានផ្លូវដើរ ព្រៃខ្មោច និងគំនរសំរាមជាដើម និងព្រោះអត្ថថា ទៅ គឺដល់នូវភាពជារបស់គួរខ្ពើមដូចធូលី ។ បទថា **បិណ្ឌិ-យាលោបោ** សេចក្តីថា ភោជនដែលខ្លួនត្រាច់ទៅដោយកម្លាំងនៃស្មង ហើយបានមក ប្រមាណមួយផ្ទះមួយពំនូត ។ បទថា **រុក្ខមូលំ** សេចក្តីថា ជិតដើមឈើមួយកន្លែង ដែលសមគួរដល់វិវេក ។ បទថា **បូតិមុត្តំ** បានដល់ទឹកនោមគោប្រភេទណាមួយ អធិប្បាយថា រាងកាយ សូម្បីមានពណ៌សម្បុរដូចមាស ក៏ជាកាយស្អុយនោះឯង យ៉ាងណា ទឹកមូត្រ សូម្បីថ្មី ក៏ជាទឹកមូត្រស្អុយដូច្នេះដូចគ្នា ។ ក្នុងរឿងនេះ អាចារ្យពួកខ្លះ ហៅចំណិតសម៉ដែលត្រាំដោយទឹកនោមគោថា ទឹកមូត្រស្អុយ ។ អាចារ្យមួយពួកទៀត ពោលថា ភេសជ្ជៈ ប្រភេទណាមួយដែលគេលះបង់ គឺបោះបង់ចោល បានដល់ នាំចេញអំពីរានផ្សារជាដើម ព្រោះជារបស់ខូច ហៅថា ជាទឹកមូត្រស្អុយ ។

បទថា **យតោ ខោ** ជាបញ្ចមីវិភត្តិ ចុះក្នុងបឋមត្ត ។ មានពាក្យអធិប្បាយថា **យំ ខោ** ។ ដោយហេតុនោះ បទថា **យតោ ខោ** គឺគ្របដណ្តប់ដល់កិរិយាដែលលោកពោលថា **តុដ្ឋោ ហោតិ** ។ បទថា **តុដ្ឋោ** បានដល់ ដែលត្រេកអរ ។ បទថា **ឥទមស្សាហំ** សេចក្តីថា ការសន្តោសដោយបច្ច័យ ៤ តាមដែលពោលហើយ បន្តិចបន្តួច រកបានងាយ តថាគតពោលនូវការ

សន្តោសនេះ ថាជាអង្គនៃភាពជាសមណៈ គឺអង្គដែលធ្វើឲ្យបានជាសមណៈ អង្គណាមួយ គឺមួយអង្គ គឺមួយអង្គក្នុងអង្គទាំងឡាយ មានសីលសំវរៈជាដើមរបស់ភិក្ខុនេះ ។ ព្រោះថា ចតុប្បារិសុទ្ធិសីលរបស់ភិក្ខុដែលសន្តោស រមែងបរិបូណ៌ល្អ សមថភាវនា និងវិបស្សនាភាវនា រមែងដល់នូវការបរិបូណ៌ ។ មួយប្រការទៀត អរិយមគ្គ ឈ្មោះថា សាមញ្ញ គឺភាពជាសមណៈ ។ ពោលដោយសង្ខេប សាមញ្ញនោះមានអង្គ ២ គឺអង្គខាងក្រៅ ១ អង្គខាងក្នុង ១ ។ បណ្ដាអង្គទាំង ២ នោះ អង្គខាងក្រៅ បានដល់ សប្បុរិសូបស្សយៈ ១ សទ្ធម្មស្សវនៈ ១ ។ ឯអង្គខាងក្នុង បានដល់ យោនិសោមនសិការ ១ ធម្មានុធម្មប្បដិបត្តិ ១ ។ បណ្ដាធម៌ទាំងនោះ ព្រោះហេតុដែលធម៌ទាំងនេះ ជាតួធម្មានុធម្មប្បដិបត្តិផង ជាមូលនៃធម្មានុធម្មប្បដិបត្តិនោះផងតាមសមគួរ បានដល់ ធម៌ទាំងឡាយ មានយ៉ាងនេះ គឺអប្បិច្ឆតា សន្តុដ្ឋិតា បវិវិត្តតា គឺភាពជាអ្នកស្ងាត់ អសំសដ្ឋតា គឺការមិនច្រឡូកច្រឡំដោយពួកគណៈ អារទ្ធវីរិយតា គឺភាពជាអ្នកប្រារព្ធសេចក្ដីព្យាយាម ។ ដូច្នោះទើបព្រះមានព្រះភាគបានត្រាស់ថា តថាគតពោលនូវគុណណាមួយរបស់ភិក្ខុនេះ ថាជាអង្គនៃសមណភាព ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាដូចតទៅនេះ បទថា **សេនាសនមារព្ភ** បានដល់ អាស្រ័យសេនាសនៈ មានវិហារជាដើម និងសេនាសនៈ មានគ្រែនិងតាំងជាដើម ។ ក្នុងបទថា **ចីវរំ បានភោជនំ** មានការ ភ្ជាប់សេចក្ដីថា ប្រារព្ធស្បង់ចីវរជាដើម ទឹកផឹក មានទឹកផ្លែស្វាយជាដើម និងវត្ថុដែលគប្បី

បរិភោគ មានខាទនីយៈ និងភោជនីយៈជាដើម ។ មានវាចាប្រកបសេចក្តីថា ការបង្អៀតបង្អល់ គឺការៈដែលត្រូវបៀតបៀន បានដល់ សេចក្តីទុក្ខផ្លូវចិត្ត មិនមាន ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបដូច្នេះថា ការបង្អៀតបង្អល់នៃចិត្តឯណា ព្រោះមិនបានបច្ច័យដែលត្រូវការ រមែងមានដល់ភិក្ខុដែលមិនសន្តោស ជាអ្នកស្វែងរកបច្ច័យ មានសេនាសនៈជាដើម ដោយការចូលទៅកាន់ទីដែលគប្បីបាន ដោយបំណងថា ក្នុងអាវាសឈ្មោះនោះ បច្ច័យទាំង-ឡាយរកបានងាយក្តី ដោយការប្រកែកគ្នាថា បច្ច័យនេះដល់លំដាប់ខ្ញុំ មិនដល់លំដាប់លោកក្តី ដោយនវកម្មជាដើមក្តី ការបង្អៀតបង្អល់នោះ រមែងមិនមានដល់ភិក្ខុដែលសន្តោសក្នុងបច្ច័យទាំងនោះ ។ បទថា **ទិសា នប្បដិ-ហញ្ញន្តិ** សេចក្តីថា ព្រោះសន្តោស ទើបទិសទាំងឡាយ មិនបៀតបៀនដល់ភិក្ខុអ្នកសន្តោសដែលទៅកាន់ទិសទាំង ៤ សមដូចព្រះមានព្រះភាគត្រាស់ថា

បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរដោយបរិក្ខារតាមមាន តាមបាន ... ដូច្នេះ ។

អធិប្បាយថា ភិក្ខុណាកើតគំនិតឡើងថា អញទៅទីនោះហើយនឹងបាននូវបច្ច័យ មានចីវរជាដើម ទិសរបស់ភិក្ខុនោះ ឈ្មោះថា បៀតបៀន ។ ឯភិក្ខុណាមិនកើតគំនិតយ៉ាងនេះ ទិសរបស់ភិក្ខុនោះ ឈ្មោះថា មិនបៀតបៀន ។

បទថា **ធម្មា** បានដល់ ធម៌ដែលជាបដិបទាទាំងឡាយ ។ បទថា **សាមញ្ញស្សានុលោមិកា** បានដល់ ធម៌ទាំងឡាយ មានការប្រាថ្នាតិចជាដើម

ដែលសមគួរដល់សមណធម៌ ដល់សមថភាវនា និងវិបស្សនាភាវនា ឬដល់អរិយមគ្គនោះឯង ។ បទថា **អជ្ឈត្តរតា** សេចក្ដីថា ធម៌ទាំងអស់នោះឈ្មោះថា ភិក្ខុដែលមានចិត្តត្រេកអរហើយ គឺភិក្ខុមានចិត្តសន្ដោសហើយ សម្រេចហើយ គឺគ្រប់សង្កត់ធម៌ដែលជាបដិបក្ខបានហើយ បានដល់ ជាធម៌មាននៅខាងក្នុង មិនមែនមានខាងក្រៅឡើយ ៗល។

**អដ្ឋកថា សុលភសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អាសវក្ខយសូត្រ

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈទាំងឡាយថា មានដល់ភិក្ខុអ្នកដឹង អ្នកឃើញ មិនពោលថា មានដល់ភិក្ខុអ្នកមិនដឹង មិនឃើញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង តើដូចម្ដេច អ្នកឃើញ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង អ្នកឃើញថា នេះជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាហេតុនាំឲ្យកើតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង អ្នកឃើញថា នេះជាការរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការ

អស់ទៅអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹង អ្នកឃើញថា នេះជាបដិបទា ប្រព្រឹត្តទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដល់ភិក្ខុ អ្នកដឹងយ៉ាងនេះ អ្នកឃើញ យ៉ាងនេះឯង ។

កាលបើសេក្ខបុគ្គល កំពុងសិក្សា ត្រាច់ទៅតាមផ្លូវដ៏
ត្រង់ ញាណទី ១ ក្នុងការអស់ទៅនៃអាសវៈ ( ក៏កើត
មាន ) តអំពីនោះទៅ អរហត្តមគ្គញ្ញាណដ៏ប្រសើរ ( ក៏
កើតឡើង ) ។ កាលភិក្ខុមានចិត្តផុតស្រឡះចាកអាសវៈ
ដោយសារអរហត្តមគ្គញ្ញាណនោះហើយ វិមុត្តិញ្ញាណ
ដ៏ឧត្តម ក៏កើតឡើង សេចក្តីដឹង ក្នុងការអស់ទៅថា
សំយោជនៈទាំងឡាយ អស់ហើយ ដូច្នេះ ឯព្រះនិព្វាន
ជាគ្រឿងដោះចាកគ្រឿងចំពាក់ទាំងពួងនេះ បុគ្គលខ្ជិល
ល្ងង់ មិនដឹងច្បាស់ មិនគប្បីបានឡើយ ។ សូត្រទី ៣ ។

# អដ្ឋកថា

## អាសវក្ខយសូត្រ

[ ១០៤ ] ក្នុងអាសាវក្ខយសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ថា បទថា **ជានតោ** ប្រែថា ដឹង ។ បទថា **បស្សតោ** ប្រែថា ឃើញ បើបទទាំង ២ នោះមានអត្ថតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះសោត កាលបើដូច្នេះ ព្រះមានព្រះភាគ ទ្រង់អាស្រ័យលក្ខណៈនៃញាណ សម្ដែងអាងបុគ្គល ដោយបទថា **ជានតោ**។ ព្រោះថា ញាណ មានការដឹងជាលក្ខណៈ ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យអំណាចនៃញាណ សម្ដែងអាងបុគ្គល ដោយបទថា **បស្សតោ** ព្រោះថា បុគ្គលដែលដល់ព្រមដោយញាណ អាស្រ័យអំណាចនៃការឃើញ ទើបឃើញវិវដ្ដធម៌ទាំងឡាយដោយញាណ ប្រៀបដូចបុគ្គលដែលមានភ្នែកល្អ ឃើញនូវរូបទាំងឡាយដោយភ្នែក ដូច្នោះ ។ ម្យ៉ាងទៀត បទថា **ជានតោ** ប្រែថា ដឹងដោយ អនុពោធញ្ញាណ គឺញាណជាគ្រឿងដឹងតាម ។ បទថា **បស្សតោ** បានដល់ ឃើញដោយបដិវេធញ្ញាណ ។ ម្យ៉ាងទៀត កាលពោលដោយបដិលោម បានដល់ ឃើញដោយទស្សនមគ្គ ដឹងដោយភាវនាមគ្គ ។ ឯអាចារ្យពួកខ្លះពោលថា ដឹងដោយញាតបរិញ្ញា តីរណបរិញ្ញា និងបហានបរិញ្ញា ឃើញដោយវិបស្សនាដ៏កំពូល ។ មួយប្រការទៀត ដឹងនូវទុក្ខ ដោយការដឹង ដោយការកំណត់ដឹង ឃើញនិរោធដោយការដឹង ដោយការធ្វើឲ្យជាក់ច្បាស់ កាលញាណទាំង ២ នោះមានការដឹងដោយការលះ និងការចម្រើន ក៏ឈ្មោះថា សម្រេចផងដែរ ដូច្នោះទើបជាការត្រាស់ដល់ការសម្រេចសច្ចៈទាំង ៤ ។ តែក្នុងរឿងនេះ កាលណា

លោកបំណងយកវិបស្សនាញាណ កាលនោះគប្បីឃើញថា បទទាំង ២ គឺ **ជានតោ បស្សតោ** ជាការសម្តែងដល់ហេតុនៃមគ្គ កាលណា បំណងយកមគ្គញាណ កាលនោះគប្បីឃើញថា បទទាំង ២ សម្តែងកិច្ចរបស់មគ្គ ។

បទថា **អាសវានំ ខយំ** មានអធិប្បាយដូចតទៅនេះ ការលះ ការអស់ទៅជាសមុច្ឆេទ ការមិនកើតឡើង អាការអស់ទៅ ការមិនមាននៃអាសវៈទាំងឡាយ ហៅថា ការអស់អាសវៈ ដូចក្នុងសព្វាសវសំវរបរិយាយសូត្រដែលមកហើយយ៉ាងនេះថា

**ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនៃអាសវៈធម៌ទាំងឡាយ របស់បុគ្គលអ្នកដឹង អ្នកឃើញ ... ដូច្នេះ ។ និងដូចបទសូត្រមួយទៀតថា **អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ** បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈធម៌ទាំងឡាយ ។

ផល ហៅថា ការអស់អាសវៈ ដូចក្នុងប្រយោគជាដើមថា **អាសវានំ ខយា សមណោ ហោតិ** ជាសមណៈព្រោះអស់នូវអាសវៈទាំងឡាយ ដូច្នេះ ។ និព្វាន ហៅថា ការអស់អាសវៈ ដូចប្រយោគជាដើមថា

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**
**អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។**

កាលបុគ្គលគយយំមើលទោស របស់បុគ្គលដទៃជាប្រក្រតី
មានការសម្គាល់ហេតុក្នុងការពោលទោស ( អ្នកដទៃ ) ជា

និច្ច ជាប្រក្រតី អាសវៈទាំងឡាយរបស់បុគ្គលនោះ តែង
ចម្រើន បុគ្គលនោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីធម៌ជា
គ្រឿងអស់អាសវៈ ដូច្នេះ ។

មគ្គ ហៅថា ការអស់អាសវៈ ដូចក្នុងឥន្ទ្រិយសូត្រ និងក្នុងសូត្រនេះ
ដែលមកយ៉ាងនេះថា

**សេក្ខស្ស សិក្ខមានស្ស ឧជុមគ្គានុសារិនោ**
**ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា។**

ញាណជាបឋម ក្នុងកិរិយាអស់ទៅ កើតឡើងដល់សេក្ខ-
បុគ្គលអ្នកកំពុងសិក្សា អ្នករៀនរៀបៗ នូវផ្លូវដ៏ត្រង់ ...
ដូច្នេះ ។

ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា តថាគតពោលដល់ការ
សម្រេចអរិយមគ្គ សម្រាប់បុគ្គលដែលជាអ្នកប្រាជ្ញ ជាអ្នកឃើញតាមន័យ
ដែលបានពោលហើយ ។

បទថា **នោ អជានតោ នោ អបស្សតោ** សេចក្តីថា បុគ្គលណា
មិនដឹង មិនឃើញ តថាគតមិនពោលការសម្រេចអរិយមគ្គសម្រាប់បុគ្គល
បែបនោះឡើយ ។ បុគ្គលពួកណា ពោលការបរិសុទ្ធចាកសង្សារវដ្តសម្រាប់
បុគ្គលដែលមិនដឹង មិនឃើញ ព្រះមានព្រះភាគ ទ្រង់បដិសេធបុគ្គលទាំង
នោះ ដោយបទនេះថា **នោ អជានតោ នោ អបស្សតោ ។**ម្យ៉ាងទៀត
ព្រះមានព្រះភាគត្រាស់ឧបាយដោយ ២ បទដំបូង ត្រាស់បដិសេធវត្ថុដែល

មិនមែនឧបាយ ដោយបទថា **ជោ អជានតោ ជោ អបស្សតោ** នេះ ។ ម្យ៉ាងទៀត កាលពោលដោយសង្ខេប ព្រះមានព្រះភាគទ្រង់សម្តែងក្នុងសូត្រនេះថា ញាណជាគ្រឿងធ្វើអាសវៈឲ្យអស់ទៅដ៏សេស ជាបរិក្ខាររបស់ញាណនោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងញាណដែលបុគ្គលដឹង ឃើញ ជាហេតុឲ្យអស់អាសវៈ ទើបព្រះមានព្រះភាគទ្រង់បុច្ឆាថា **កិញ្ច ភិក្ខវេ ជានតោ** ដូច្នេះ ។

ពាក្យថា **កិញ្ច ភិក្ខវេ ជានតោ** នោះ មានអធិប្បាយដូចតទៅនេះ ការដឹងមានច្រើនយ៉ាង អធិប្បាយថា ភិក្ខុរូបខ្លះជាអ្នកមានបញ្ញា ចេះធ្វើឆត្ររូបខ្លះ ចេះធ្វើចីវរជាដើមណាមួយ កាលភិក្ខុនោះ តាំងនៅក្នុងបដិបទា គឺធ្វើការងារបែបនេះ ការចេះនោះ មិនគួរពោលថា មិនជាបទដ្ឋានរបស់មគ្គ និងផល ។ ឯភិក្ខុណាបួសក្នុងសាសនាហើយ ចេះធ្វើវេជ្ជកម្មជាដើម អាសវៈទាំងឡាយ រមែងចម្រើនដល់ភិក្ខុនោះឯង ដែលដឹងយ៉ាងនេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងចំពោះរឿងដែលដឹង រឿងដែលឃើញជាហេតុឲ្យអាសវៈទាំងឡាយអស់ទៅ ទើបត្រាស់ពាក្យថា **ឥទំ ទុក្ខំ** ជាដើម ។

ក្នុងពាក្យនោះ មានអធិប្បាយដូចតទៅនេះ សច្ចកម្មដ្ឋាន ៤ ឯណាដែលគួរពោល សច្ចកម្មដ្ឋាននោះបានពោលហើយដោយសង្ខេប នៅក្នុងយោនិសោមនសិការសូត្រខាងដើម ។ ម្យ៉ាងទៀត ក្នុងពាក្យនោះ លោកបាន

ធ្វើការពន្រ្ធឹកសេចក្តី ដោយន័យជាដើមថា ភិក្ខុធ្វើទុកក្នុងចិត្តដោយឧបាយថា នេះទុក្ខ ព្រោះមានគោលមកហើយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលធ្វើទុកក្នុងចិត្តដោយឧបាយហើយ ទើបលះបង់អកុសល ចម្រើនកុសលបាន ដូច្នេះ ។ ក្នុងទីនេះ គប្បីប្រកបចូលតាមន័យជាដើមថា សម្រាប់ភិក្ខុដែលដឹង ឃើញដោយមគ្គញាណ ដោយអំណាចនៃការចាក់ធ្លុះដោយបរិញ្ញា គឺដោយអំណាចការត្រាស់ដឹងដោយបរិញ្ញាថា នេះទុក្ខ ព្រោះមានគោលមកហើយថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការអស់ទៅនូវអាសវធម៌ទាំងឡាយ របស់បុគ្គលអ្នកដឹង អ្នកឃើញថា នេះទុក្ខ ដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ក្នុងអាសវៈទាំងឡាយ ទិដ្ឋាសវៈ អស់ទៅព្រោះបឋមមគ្គ គឺសោតាបត្តិមគ្គ កាមាសវៈអស់ទៅ ព្រោះតតិយមគ្គ ភវាសវៈ និងអវិជ្ជាសវៈ អស់ទៅព្រោះចតុត្ថមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា **វិមុត្តិញ្ញាណំ** បានដល់ បច្ចវេក្ខណញ្ញាណក្នុងវិមុត្តិ និព្វាន និងផល ។ បទថា **ឧត្តមំ** បានដល់ ឈ្មោះថា ឧត្តម ព្រោះមានធម៌ជាន់ខ្ពស់ជាអារម្មណ៍ ។ បទថា **ខយេ ញាណំ** បានដល់ ញាណក្នុងការអស់ទៅនៃអាសវៈ និងសំយោជនៈ គឺក្នុងអរិយមគ្គដែលធ្វើអាសវៈ និងសំយោជនៈឲ្យអស់ទៅ ។ គួរនាំមកភ្ជាប់ក្នុងទីនេះថា ញាណ ថាសំយោជនៈទាំងឡាយអស់ហើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងការពិចារណាកិលេស ដែលលះបានហើយ ដោយបទថា **ខីណា សំយោជនា ឥតិ ញាណំ** ដូច្នេះ ។

បច្ចវេក្ខណញ្ញាណទាំង ៤ ឈ្មោះថា ពោលហើយក្នុងទីនេះ ដូចពណ៌នាមក ដូច្នេះ ។ ពិតហើយ ក្នុងសូត្រនេះ មិនមានការពិចារណាដល់កិលេសដែលនៅសល់ ព្រោះព្រះមានព្រះភាគទ្រង់សំដៅដល់ការសម្រេចអរហត្តផលម្យ៉ាងទៀត ក្នុងបទថា **ជានតោ បស្សតោ** នេះ ព្រះមានព្រះភាគត្រាស់កិច្ចរបស់សម្មាទិដ្ឋិថា សំខាន់ក្រៃលែងក្នុងការសម្រេចនិព្វាន យ៉ាងណា កាលទ្រង់សម្ដែងថា កិច្ចរបស់សម្មប្បធានក៏ចាំបាច់ធ្វើឲ្យក្រៃលែងដូច្នោះដូចគ្នា ទើបត្រាស់គាថាចុងក្រោយថា **ន ត្វេវិទំ កុសីតេន** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ត្វេវិទំ** កាត់បទជា **ន តុ ឯវ ឥទំ។ តុ** សព្ទ ត្រឹមតែជានិបាត ។ **ម** អក្ខរៈ ក្នុងបទថា **ពាលេនមវិជានតា** ធ្វើការភ្ជាប់បទ ។ ក្នុងបទនេះ មានសេចក្ដីសង្ខេបដូច្នេះ និព្វាន ជាគ្រឿងដោះនូវគន្ថៈទាំងអស់ មានអវិជ្ជាកាយគន្ថៈជាដើម គឺជាការរួចផុត ដែលគប្បីសម្រេចបានដោយសេក្ខមគ្គ និងអសេក្ខមគ្គ ដែលបុគ្គលមិនដឹងច្បាស់នូវសច្ចៈ ៤ តាមសេចក្ដីពិត ដោយន័យជាដើមថា នេះទុក្ខ បុគ្គលឈ្មោះថាជាមនុស្សល្ងង់ គឺជាអ្នកមិនយល់ ព្រោះមិនដឹងច្បាស់នោះឯង មិនអាចត្រាស់ដឹងបាន យ៉ាងណា បុគ្គលដែលខ្ជិលច្រអូស មិនមានសេចក្ដីព្យាយាមក៏មិនអាចសម្រេចបានដូច្នោះ ព្រោះហេតុនោះ ទើបចាំបាច់ត្រូវព្យាយាមដើម្បីសម្រេចនិព្វាននោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ សគាថវគ្គថា

**អារព្ភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ**
**ធុនាថ មច្ចុនោ សេនំ នឡាគារំវ កុញ្ជរោ ។**

*អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកប*
*ព្យាយាម ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់សេនា*
*នៃមច្ចុ ដូចជាកុញ្ជរៈ ញាំញីផ្ទះបបុស ៗ។*

**អដ្ឋកថា អាសវក្ខយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សមណព្រាហ្មណសូត្រ

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាបដិបទា ប្រព្រឹត្តទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ តថាគតមិនសន្មតថា ជាសមណៈ ក្នុងពួកសមណៈ មិនសន្មតថា ជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ឡើយ មួយទៀត លោកដ៏មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវសាមញ្ញប្រយោជន៍ គឺអរិយមគ្គ ៤ និងព្រហ្មញ្ញប្រយោជន៍ គឺអរិយផល ៤ បានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា

នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទា ប្រព្រឹត្តទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ ទើបតថាគតសន្មតថា ជាសមណៈ ក្នុងពួកសមណៈ សន្មតថា ជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍បាន មួយវិញទៀត លោកដ៏មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញា ដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវសាមញ្ញប្រយោជន៍ និងព្រហ្មញ្ញប្រយោជន៍បាន ។

ពួកបុគ្គលណា មិនដឹងច្បាស់នូវទុក្ខផង នូវហេតុនាំឲ្យ
កើតទុក្ខផង នូវទីរលត់ទុក្ខ សព្វគ្រប់ ឥតមានសេស
សល់ផង មិនដឹងច្បាស់ នូវផ្លូវប្រព្រឹត្ត ទៅកាន់ទីស្ងប់
រម្ងាប់ទុក្ខនោះផង ពួកបុគ្គលនោះ រមែងសាបសូន្យចាក
ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកបុគ្គលនោះ មិនគួរធ្វើ
នូវទីបំផុត នៃទុក្ខបានឡើយ ពួកបុគ្គលនោះ ចូលទៅ
កាន់ជាតិ និងជរាដោយពិត ។ លុះតែពួកបុគ្គលណាដឹង
ច្បាស់នូវទុក្ខផង នូវហេតុនាំឲ្យកើតទុក្ខផង នូវទីរលត់
ទុក្ខ សព្វគ្រប់ ឥតមានសេសសល់ផង ដឹងច្បាស់នូវ
ផ្លូវប្រព្រឹត្ត ទៅកាន់ទីស្ងប់រម្ងាប់ទុក្ខនោះផង ទើបបរិបូណ៌
ដោយចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ពួកបុគ្គលនោះ គួរ
ធ្វើនូវទីបំផុត នៃទុក្ខបាន ពួកបុគ្គលនោះ មិនចូលទៅ
កាន់ជាតិ និងជរាឡើយ ។ សូត្រទី ៤ ។

# អដ្ឋកថា

## សមណព្រាហ្មណសូត្រ

ក្នុងសមណព្រាហ្មណសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៥ ] បទថា **យេហិ កេចិ** បានដល់ បុគ្គលពួកណាមួយ ។ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ** សេចក្តីថា មិនដឹង គឺមិនចាក់ធ្លុះទុក្ខសច្ច ដែលមិនវិបរិតដោយមគ្គប្បញ្ញា ដែលប្រកបដោយវិបស្សនាបញ្ញា ដោយសភាវៈ និងលក្ខណៈនៃកិច្ច ដែលពិតថា នេះទុក្ខ ទុក្ខមានប៉ុណ្ណោះ មិនមានទុក្ខក្រៅលែងជាងនេះ ។ បទដ៏សេសក៏មានន័យនេះឯង ។ ក្នុងបទថា **ន មេ តេ ភិក្ខវេ** ជាដើម មានសេចក្តីសង្ខេបដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយ ដែលមិនបានប្រកបកម្មដ្ឋាន មានសច្ចៈ ៤ ជាអារម្មណ៍ មិនមែនជាសមណៈដោយគ្រាន់តែបព្វជ្ជា និងជាព្រាហ្មណ៍ដោយគ្រាន់តែជាតិកំណើត បុគ្គលទាំងនោះ តថាគតមិនបានទទួល គឺមិនបានអះអាងថា ជាសមណៈ ក្នុងពួកសមណៈដែលមានបាបស្ងប់ហើយ និងថា ជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ដែលបន្សាត់បាបហើយ ព្រោះហេតុអ្វី ព្រោះបុគ្គលទាំងនោះ មិនមានធម៌ដែលធ្វើឲ្យជាសមណៈ និងធ្វើឲ្យជាព្រាហ្មណ៍ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **ន ច បនេតេ អាយស្មន្តោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សាមញ្ញត្ថំ** បានដល់ ផល ពោល គឺគុណរបស់សមណៈ អធិប្បាយថា បានដល់ សាមញ្ញផល ៤ ។ បទថា **ព្រហ្មញ្ញត្ថំ**

ជាវេវចនៈនៃបទថា **សាមញ្ញត្ថំ** នោះឯង ។ ចំណែកអាចារ្យពួកខ្លះទៀតពោលថា បទថា **សាមញ្ញត្ថំ** បានដល់ អរិយមគ្គ ៤ ។ បទថា **ព្រហ្មញ្ញត្ថំ** បានដល់ អរិយផល ៤ ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។ ក្នុងសុក្កបក្ខ គប្បីជ្រាបតាមអត្ថដោយបរិយាយផ្ទុយគ្នា តាមន័យដែលបានពោលមកហើយនោះឯង ។

ក្នុងគាថាទាំងឡាយ ពាក្យដែលមិនធ្លាប់អធិប្បាយមិនមាន ៕

**អដ្ឋកថា សមណព្រាហ្មណសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## សីលសម្បន្នសូត្រ

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា បរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា បរិបូណ៌ដោយវិមុត្តិ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ជាអ្នកទូន្មាន ពន្យល់ឲ្យដឹង សម្ដែងបញ្ជាក់ឲ្យឃើញផង ណែនាំ ធ្វើឲ្យអង់អាច ធ្វើឲ្យរីករាយ ( ក្នុងកុសលធម៌ ) អាចសម្ដែងនូវព្រះសទ្ធម្មបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះ នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការស្ដាប់ នូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការចូលទៅរកភិក្ខុទាំងនោះ ថាមានឧបការៈច្រើនផង

ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការចូលទៅអង្គុយជិតភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការរឭកនូវភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការបួសតាមភិក្ខុទាំងនោះថា មានឧបការៈច្រើនផង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសេពគប់ ចូលទៅអង្គុយជិតពួកភិក្ខុបែបនោះហើយ សីលក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង សមាធិក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ដោយភាវនាផង បញ្ញាខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង វិមុត្តិក្ខន្ធដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង វិមុត្តិញាណទស្សនក្ខន្ធ ដែលមិនទាន់បរិបូណ៌ រមែងដល់នូវការបរិបូណ៌ ដោយភាវនាផង ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបែបនោះ ហៅថា សាស្តាក៏បាន ហៅថា អ្នកនាំទៅនូវពួកក៏បាន ហៅថា អ្នកលះបង់សត្រូវក៏បាន ហៅថា អ្នកបន្ទោបង់ងងឹតក៏បាន ហៅថា អ្នកធ្វើពន្លឺក៏បាន ហៅថា អ្នកធ្វើឲ្យភ្លឺស្វាងក៏បាន ហៅថា អ្នកធ្វើប្រទីបក៏បាន ហៅថា អ្នកធ្វើរស្មីក៏បាន ហៅថា អ្នកទ្រោលបំភ្លឺដោយគប់ភ្លើងក៏បាន ហៅថា អរិយៈក៏បាន ហៅថា អ្នកមានចក្ខុក៏បាន ។

ការដែលបានជួបប្រទះជាដើម នូវពួកអរិយៈ ជាអ្នកដឹង
ច្បាស់ បានចម្រើនចិត្ត ចិញ្ចឹមជីវិតតាមធម៌ទុំះឯង ជា
ហេតុធ្វើឲ្យមានបាមោជ្ជ ។ ពួកអរិយៈនោះ តែងបំភ្លឺ

សម្តែងនូវព្រះសទ្ធម្ម អ្នកធ្វើរស្មី ធ្វើពន្លឺ អ្នកមានប្រាជ្ញា មានចក្ខុ លះបង់នូវសឹកសត្រូវ គឺកិលេស ។ ពួកអ្នកប្រាជ្ញ បានស្តាប់នូវពាក្យប្រដៅ របស់ពួកអរិយៈទាំងនោះហើយ រមែងដឹងច្បាស់ដោយប្រពៃ ស្គាល់ច្បាស់នូវធម៌ជាគ្រឿងអស់ទៅ នៃជាតិ ហើយមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។ សូត្រទី ៥ ។

# អដ្ឋកថា

## សីលសម្បន្នសូត្រ

ក្នុងសីលសម្បន្នសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៦ ] ក្នុងបទថា **សីលសម្បន្នា** មានអធិប្បាយថា លោកិយសីល និងលោកុត្តរសីលរបស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា សីល ។ ភិក្ខុទាំងឡាយ ឈ្មោះថា សម្បូរដោយសីល ព្រោះអត្ថថា សម្បូរ គឺប្រកបដោយសីលនោះៗ ។ សូម្បីក្នុងសមាធិ និងបញ្ញា ក៏មានន័យនេះឯង ។ ឯវិមុត្តិ បានដល់ ផលវិមុត្តិនោះឯង ។ វិមុត្តិញ្ញាណទស្សនៈ បានដល់ បច្ចវេក្ខណញ្ញាណ ។ ក្នុងអធិការនេះ ធម៌ ៣ មានសីលជាដើម ជាលោកិយផង លោកុត្តរផង វិមុត្តិជាលោកុត្តរតែម្យ៉ាង វិមុត្តិញ្ញាណទស្សនៈ ជាលោកិយតែម្យ៉ាង ។

ភិក្ខុទាំងឡាយ ឈ្មោះថា **ឱវាទកា** ព្រោះអត្ថថា ពោលប្រៀនប្រដៅ គឺទូន្មានបុគ្គលដទៃ ដោយទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និង បរមត្ថប្រយោជន៍ តាមសមគួរ ។ បទថា **វិញ្ញាបកា** បានដល់ ជួយបុគ្គល ដទៃឲ្យយល់នូវកម្ម និងផលនៃកម្ម ។ ម្យ៉ាងទៀត ក្នុងបទថា **វិញ្ញាបកា** មានអធិប្បាយថា ជួយបុគ្គលដទៃឲ្យយល់ គឺឲ្យដឹងនូវធម៌ទាំងឡាយ ដោយ ន័យ ៣ យ៉ាង តាមលក្ខណៈរបស់ខ្លួន គឺតាមសាមញ្ញលក្ខណៈ ដោយការ ចែកជាកុសល ដោយការចែកជាខន្ធជាដើម ដោយន័យជាដើមថា ធម៌ទាំង នេះជាកុសល ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះមានទោស ធម៌ទាំងនេះ មិនមានទោស ។ បទថា **សន្ទស្សកា** បានដល់ សម្តែងធម៌ទាំងនោះឯង ឲ្យ អ្នកដទៃឃើញច្បាស់ ដូចចាប់ធម៌ទាំងនោះដោយដៃ ។ បទថា **សមាទបកា** បានដល់ ធ្វើឲ្យអ្នកដទៃសមាទានសីលជាដើម ដែលមិនទាន់បានសមាទាន គឺ ធ្វើបុគ្គលដទៃឲ្យតាំងនៅក្នុងសីលជាដើមនោះ ។ បទថា **សមុត្តេជកា** សេចក្តី ថា ធ្វើចិត្តនៃបុគ្គលទាំងឡាយដែលតាំងនៅក្នុងកុសលធម៌យ៉ាងនេះ ឲ្យអាច ហ៊ានដោយល្អ ដោយការណែនាំក្នុងការបំពេញអធិចិត្តឲ្យខ្ពស់ឡើង គឺធ្វើចិត្ត របស់បុគ្គលនោះឲ្យផូរផង់ ដោយការពិចារណា ដោយប្រការដែលបុគ្គលនោះ គប្បីសម្រេចគុណវិសេសបាន ។ បទថា **សម្បហំសកា** សេចក្តីថា ធ្វើចិត្ត របស់បុគ្គលដទៃឲ្យត្រេកអរដោយល្អ ដោយគុណវិសេសតាមដែលបានហើយ នឹងគប្បីបានក្នុងលំដាប់ខ្ពស់ជាបន្ត គឺធ្វើចិត្តនៃបុគ្គលនោះឲ្យត្រេកអរដោយល្អ ដោយអំណាចនៃការពេញចិត្តដែលបានហើយ ។ បទថា **អលំ សមក្ខាតារោ**

បានដល់ ជាអ្នកអាចប្រាប់បរិយត្តិ គឺព្រះសទ្ធម្មតាមដែលបានពោល មិនឲ្យវិនាស ដោយបំណាននឹងអនុគ្រោះដោយប្រពៃនោះឯង ។

ម្យ៉ាងទៀត បទថា **សណ្ហស្សកោ** សេចក្តីថា កិច្ចកាលសម្តែងធម៌ ក៏សម្តែងដោយល្អនោះឯង ទាំងបវត្តិ គឺការប្រព្រឹត្តទៅ និងនិវត្តិ ការវិលត្រឡប់តាមសភាវលក្ខណៈ កិច្ចដែលពិត ។ បទថា **សមាទបកោ** សេចក្តីថា ញុំាងអ្នកស្តាប់ឲ្យកាន់យកសេចក្តីនោះឯង ដោយឲ្យអត្ថនោះតាំងមាំនៅក្នុងចិត្ត ។ បទថា **សមុត្តេជកោ** សេចក្តីថា ញុំាងអ្នកស្តាប់ឲ្យផូរផង់ ឬឲ្យរុងរឿងដោយល្អនោះឯង ដោយការឲ្យកើតឧស្សាហ៍ក្នុងការទទួលយកអត្ថនោះ ។ បទថា **សម្បហំសកោ** សេចក្តីថា ញុំាងអ្នកស្តាប់ឲ្យត្រេកអរ គឺឲ្យត្រេកអរដោយល្អនោះឯងនូវអត្ថនោះ ដោយការសម្តែងអានិសង្សក្នុងកិច្ចបដិបត្តិ ។ បទថា **អលំ សមក្ខាតារោ** សេចក្តីថា ជាអ្នកអាចប្រាប់បានតាមន័យដែលពោលហើយ ។ បទថា **សទ្ធម្មស្ស** បានដល់ ជាអ្នកសម្តែងនូវបដិវេធសទ្ធម្ម ឬព្រះសទ្ធម្មទាំង ៣ យ៉ាង ។

បទថា **ទស្សនម្បហំ** កាត់បទជា **ទស្សនំ បិ អហំ។** ឯការឃើញនេះមាន ២ យ៉ាង គឺឃើញដោយចក្ខុ ១ ឃើញដោយញាណ ១ បណ្តាការឃើញទាំង ២ យ៉ាងនោះ ការសម្លឹងមើលព្រះអរិយៈទាំងឡាយដោយភ្នែកសម្តែងនូវសេចក្តីជ្រះថ្លា ឈ្មោះថា ឃើញដោយចក្ខុ ។ ឯការសម្រេចធម៌ទាំងឡាយដែលធ្វើឲ្យជាព្រះអរិយៈ និងភាពជាព្រះអរិយៈដោយវិបស្សនា មគ្គ និងផល ឈ្មោះថា ឃើញដោយញាណ ។ តែក្នុងអត្ថនេះ លោកបំណាន

យកការឃើញដោយចក្ខុ ព្រោះថា ការសម្លឹងមើលព្រះអរិយៈទាំងឡាយ ដោយភ្នែក សម្តែងនូវការជ្រះថ្លា ក៏មានឧបការៈច្រើនដល់សត្វទាំងឡាយ ។ បទថា **សវនំ** បានដល់ ការបានឮដោយត្រចៀក កាលមនុស្សទាំងឡាយ និយាយគ្នាថា ព្រះខីណាស្រពឈ្មោះនោះ នៅក្នុងដែន ឬជនបទ ក្នុងគាម ឬ និគម ក្នុងវិហារ ឬគុហាឈ្មោះនោះ នេះក៏មានឧបការៈច្រើនដូចគ្នា ។ បទថា **ឧបសង្កមនំ** សេចក្តីថា ការចូលទៅរកព្រះអរិយៈទាំងឡាយ ដោយការគិតឃើញបែបនេះថា អញនឹងឲ្យទាន នឹងសួរបញ្ហា នឹងស្តាប់ធម៌ ឬនឹងធ្វើនូវសក្ការៈ ។ បទថា **បយិរុបាសនំ** បានដល់ ការចូលទៅអង្គុយជិតដើម្បីសួរបញ្ហា អធិប្បាយថា ការបានស្តាប់គុណរបស់ព្រះអរិយៈទាំងឡាយ ចូលទៅរកព្រះអរិយៈទាំងនោះ និមន្តហើយថ្វាយទាន ឬធ្វើវត្ត ហើយសួរបញ្ហាដោយន័យជាដើមថា បពិត្រលោកម្ចាស់ អ្វីឈ្មោះថាកុសល ការធ្វើការបម្រើជាដើម ចាត់ជាការចូលទៅអង្គុយជិតដូចគ្នា ។ បទថា **អនុស្សតិ** បានដល់ ការដែលបុគ្គលអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ រឭកដល់រឿយៗ នូវគុណវិសេស មានទិព្វវិហារធម៌ជាដើមរបស់ព្រះអរិយៈទាំងនោះ ជាអារម្មណ៍ថា ឥឡូវនេះ ព្រះអរិយៈទាំងឡាយ កំពុងឈប់សម្រាកក្នុងទីទាំងឡាយ មានគុម្ពឈើ គុហា និងមណ្ឌបជាដើម ដោយសេចក្តីសុខដែល កើតអំពីឈាន វិបស្សនា មគ្គ និងផល ។

ម្យ៉ាងទៀត បានដល់ បង្អោនទឹកដល់ឱវាទដែលបានអំពីសម្នាក់របស់ព្រះអរិយបុគ្គលទាំងនោះ ហើយរឭកដល់រឿយៗ យ៉ាងនេះថា ព្រះមានបុណ្យ

ត្រាស់សីលក្នុងទីនេះ ត្រាស់សមាធិក្នុងទីនេះ ត្រាស់វិបស្សនាក្នុងទីនេះ ត្រាស់មគ្គក្នុងទីនេះ ត្រាស់ផលក្នុងទីនេះ ។ បទថា **អនុបព្វជ្ជំ** បានដល់ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយ ហើយចេញចាកផ្ទះ បួសក្នុងសម្នាក់ព្រះអរិយៈទាំងនោះ អធិប្បាយថា ការធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយ ហើយបួសក្នុងសម្នាក់ព្រះអរិយៈទាំងនោះឯង ត្រាច់ទៅបំណាងតាំងនៅក្នុងឱវាទានុសាសនីរបស់ព្រះអរិយៈទាំងនោះ ឈ្មោះថា ការបួសតាម ។ ការបួសរបស់បុគ្គលដែលត្រាច់ទៅប្រាថ្នាក្នុងឱវាទានុសាសនី ក្នុងសម្នាក់បុគ្គលពួកដទៃ ក៏ឈ្មោះថា បួសតាម ។ ការបួសរបស់បុគ្គល ដែលបួសក្នុងសម្នាក់ដទៃ ព្រោះការជ្រះថ្លាក្នុងព្រះអរិយៈទាំងឡាយ ហើយត្រាច់ទៅប្រាថ្នាក្នុងឱវាទានុសាសនីក្នុងសម្នាក់ព្រះអរិយៈទាំងឡាយ ក៏ឈ្មោះថា បួសតាមដូចគ្នា ។ ឯការបួសរបស់បុគ្គលដែលបួសក្នុងសម្នាក់អ្នកដទៃ ព្រោះជ្រះថ្លាក្នុងបុគ្គលដទៃ ហើយត្រាច់ទៅ ប្រាថ្នាក្នុងឱវាទានុសាសនីរបស់បុគ្គលដទៃដូចគ្នា មិនឈ្មោះថា ជាការបួសតាម ។ បណ្ដាបុគ្គលដែលបួសតាមន័យដូចពោលហើយ ជាបឋម បុគ្គលដែលបួសតាមព្រះមហាកស្សបត្ថេរ មានចំនួនមួយសែននាក់ ។ អ្នកបួសតាមព្រះចន្ទគុត្តត្ថេរ ដែលជាសទ្ធិវិហារិករបស់ព្រះថេរៈនោះឯង ក៏មានចំនួនប៉ុណ្ណោះគ្នា ។ ព្រះសុរិយគុត្តត្ថេ ជាសទ្ធិវិហារិករបស់ព្រះចន្ទគុត្តត្ថេរ ព្រះអស្សគុត្តត្ថេរ ដែលជាសទ្ធិវិហារិករបស់ព្រះសុរិយគុត្តត្ថេរនោះ ព្រះយោនកធម្មរក្ខិតត្ថេរ ដែលជាសទ្ធិវិហារិករបស់ព្រះអស្សគុត្តត្ថេរនោះ មានអ្នកបួសតាមចំនួនប៉ុណ្ណោះដូចគ្នា ឯប្អូនប្រុសរបស់ព្រះបាទអសោក ជាសទ្ធិវិហារិក

ព្រះយោនកធម្មរក្ខិតត្ថេរនោះ បានឈ្មោះថា តិស្សត្ថេរ បុគ្គលដែលបួសតាមព្រះតិស្សត្ថេរនោះ មានចំនួន ២ កោដិកន្លះ ។ ចំណែកបុគ្គលដែលបួសតាមព្រះមហិន្ទត្ថេរ ដែលញ៉ាំងអ្នកកោះឲ្យជ្រះថ្លារាប់ចំនួនមិនបាន ។ ក្នុងកោះលង្កា បុគ្គលបួសដោយការជ្រះថ្លាក្នុងព្រះសាសនា ដរាបដល់សព្វថ្ងៃនេះ ឈ្មោះថាបួសតាមព្រះមហិន្ទត្ថេរទាំងអស់ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់ហេតុដែលទ្រង់ត្រាស់ថា ការឃើញព្រះអរិយៈទាំងនោះជាដើម មានឧបការៈច្រើន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **តថារូបេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **តថារូបេ** បានដល់ ព្រះអរិយៈបែបនោះ គឺជាអ្នកសម្បូរដោយគុណ មានសីលជាដើម ។

ព្រោះការឃើញ ការស្តាប់ និងការរឭកដល់ជាហេតុនៃការចូលទៅរក និងការចូលទៅអង្គុយជិត ដូច្នោះ ដើម្បីសម្តែងចំពោះការចូលទៅរក និងការចូលទៅអង្គុយជិត មិនអាស្រ័យដល់ការឃើញ ការឮ និងការរឭកដល់ ទើបព្រះមានព្រះភាគត្រាស់ថា **សេវតោ ភជតោ បយិរុបាសតោ** ដូច្នេះ ។ ព្រោះបានឃើញ បានស្តាប់ និងរឭកដល់រឿយៗ ទើបកុលបុត្រកើតសទ្ធាក្នុងព្រះអរិយៈទាំងឡាយ ហើយចូលទៅរក ចូលទៅអង្គុយជិតព្រះអរិយៈទាំងនោះ សួរបញ្ហា បាននូវសវនានុត្តរិយៈ ហើយក៏បំពេញគុណ មានសីលជាដើម ដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ ដូច្នេះ ។ សមដូចពាក្យដែលលោកពោលក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា កុលបុត្រក្នុងសាសនា

នេះ មានសទ្ធា ទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេវតោ** បានដល់ ចូលទៅរកតាមពេលដ៏សមគួរ ដោយការធ្វើវត្ត និងវត្តត្រឡប់ ។ បទថា **ភជតោ** បានដល់ គប់រកដោយអំណាចការស្រឡាញ់ និងការស្មោះត្រង់ ។ បទថា **បយិរុ-ចាសតោ** បានដល់ ចូលទៅអង្គុយជិតដោយការសួរបញ្ហា និងធ្វើតាមបដិបទា ។ អ្នកសិក្សាគប្បីជ្រាបការចែកអត្ថនៃបទទាំង ៣ ដូចពោលមកនេះ ។ ការបរិបូណ៌នៃវិមុត្តិញាណទស្សនៈ គប្បីជ្រាបបានដោយការកើតឡើងនៃបច្ចវេក្ខណញ្ញាណទី ១៩ ។

ក្នុងបទថា **ឯវរូបា ច តេ ភិក្ខវេ ភិក្ខូ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ភិក្ខុណាមានសភាពបែបនេះ គឺដូច្នេះ បានដល់ ទម្លាយកិលេសបានអស់ហើយ ព្រោះប្រកបដោយគុណតាមដែលពោលហើយ ភិក្ខុទាំងនោះហៅថា **សត្ថារោ** ព្រោះទូន្មានដោយការប្រកបសត្វទាំងឡាយក្នុងប្រយោជន៍មានទិដ្ឋធម្មិកត្ថប្រយោជន៍ជាដើមខ្លះ ហៅថា **សត្ថវាហា** ព្រោះជួយសត្វទាំងឡាយ ឲ្យឆ្លងផុតជាតិសង្សារជាដើមខ្លះ ហៅថា **រណញ្ជហា** ព្រោះលះសត្រូវ គឺកិលេសជាគ្រឿងសាំញ៉ាំ មានរាគៈជាដើម បានដោយខ្លួនឯង និងទូន្មានអ្នកដទៃឲ្យលះតាមខ្លះ ហៅថា **តមោនុទា** ព្រោះបន្ទោបង់នូវងងឹត គឺអវិជ្ជាដោយខ្លួនឯង និងទូន្មានអ្នកដទៃឲ្យបន្ទោបង់តាមខ្លះ ហៅថា **អាលោ-កាធិករា** ព្រោះធ្វើឲ្យកើតពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា និងជោតិ គឺបញ្ញាក្នុងសន្តានរបស់ខ្លួន និងបុគ្គលដទៃខ្លះ ។ ម្យ៉ាងទៀត ហៅថា **បភង្ករា** គឺអ្នកធ្វើ

*នូវរស្មីខ្លះ* **ឧក្កាធារា** *អ្នកទ្រទ្រង់នូវគប់ភ្លើងខ្លះ ព្រោះធ្វើធម៌ឲ្យជេរជាស ឲ្យផ្សាយទៅដោយរស្មី គឺញាណ ហៅថា* **អរិយា** *ព្រោះជាអ្នកឆ្ងាយចាក កិលេសទាំងឡាយ ១ ព្រោះមិនដើរទៅតាមផ្លូវដែលមិនគួរដើរ ១ ព្រោះដើរ ទៅក្នុងផ្លូវដែលគួរដើរ ១ ព្រោះហេតុឲ្យទៅជាយ៉ាងនោះរបស់ជនពួកដទៃ ១ ព្រោះសត្វលោក និងទេវលោក គប្បីដើរតាម ១ ហៅថា* **ចក្ខុមន្តោ** *ព្រោះ បាននូវបញ្ញាចក្ខុ និងធម្មចក្ខុ យ៉ាងល្អក្រៃលែង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថា ទាំងឡាយដូច្នេះ បទថា* **ឆាមោជ្ជករណដ្ឋានំ** *បានដល់ ទីតាំង គឺហេតុឲ្យ កើតនូវការត្រេកអរ ដែលប្រាសចាកអាមិស ។ លោកពោលដល់និទស្សនៈ ដែលគប្បីពោលក្នុងឥឡូវនេះថា* **ឯតំ** *។ បទថា* **វិជានតំ** *បានដល់ ស្គាល់ សេចក្ដីសៅហ្មង និងសេចក្ដីផូរផង់តាមសេចក្ដីពិត ។ បទថា* **ភាវិតត្តានំ** *បានដល់ ជាអ្នកមានសភាវៈ គឺចិត្តដែលអប់រំហើយ អធិប្បាយថា ជាអ្នក មានសន្តានអប់រំហើយ ដោយការអប់រំកាយជាដើម ។ បទថា* **ធម្មជីវិនំ** *សេចក្ដីថា ឈ្មោះថា ជាអ្នកមានប្រក្រតីនៅដោយធម៌ ព្រោះលះអាជីវៈ ហើយ ចិញ្ចឹមជីវិតដោយធម៌ គឺដោយញាណធម៌ ព្រោះនាំអត្តភាពទៅដោយធម៌ គឺ ដោយញាយធម៌ខ្លះ ព្រោះរស់នៅដោយផលធម៌ដ៏ប្រសើរ ទាក់ទងដោយ សមាបត្តិខ្លះ ។ ក្នុងទីនោះ មានសេចក្ដីសង្ខេបដូច្នេះថា ការឃើញព្រះអរិយៈ ទាំងឡាយដែលអប់រំខ្លួនហើយ ជាអ្នកសម្រេចសមាធិភាវនា និងបញ្ញាភាវនា ហើយ ជាបុគ្គលឈ្មោះថា ជាអ្នករស់នៅដោយធម៌ ព្រោះការអប់រំខ្លួន និង សម្រេចភាវនានោះឯង ឈ្មោះថា ជាហេតុនៃបីតិ និងបាមោជ្ជដោយចំណែក*

មួយប៉ុណ្ណោះ សម្រាប់បុគ្គលដែលមានបញ្ញាដឹងច្បាស់ ព្រោះជាហេតុនៃការសម្បូរនៃគុណទាំងឡាយ មានសីលជាដើម ដែលមិនក្តៅក្រហាយជានិមិត្ត ។

ឥឡូវនេះ ដើម្បីសម្តែងភាពដែលការឃើញព្រះអរិយៈទាំងឡាយនោះជាហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ២ គាថាខាងចុងថា **តេ ជោតយន្តិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ** បានដល់ ព្រះអរិយៈទាំងនោះ ដែលអប់រំខ្លួនហើយ មានប្រក្រតីនៅដោយធម៌ ។ បទថា **ជោតយន្តិ** បានដល់ សម្តែង ។ បទថា **ភាសយន្តិ** បានដល់ ធ្វើលោកឲ្យភ្លឺស្វាងដោយពន្លឺនៃព្រះសទ្ធម្ម អធិប្បាយថា សម្តែងធម៌ ។ បទថា **យេសំ** បានដល់ ព្រះអរិយៈឯណា ។ បទថា **សាសនំ** បានដល់ ឱវាទ ។ បទថា **សម្មទញ្ញាយ** បានដល់ ដឹងដោយប្រពៃនោះឯង ដោយញាណដែលជាចំណែកខាងដើម ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា សីលសម្បន្នសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## តណ្ហុប្បាទសូត្រ

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះវត្ថុជាទីកើតនៃតណ្ហានេះ មាន ៤ ។ វត្ថុជាទីកើតនៃតណ្ហា ៤ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុចីវរ ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះហេតុបិណ្ឌបាត ១ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើងព្រោះសេនាសនៈ ១ ម្នាលភិក្ខុទាំង-ឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ រមែងកើតឡើង ព្រោះសេចក្តីចម្រើននិងវិនាស ១ ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាកាលកើតឡើង ដល់ភិក្ខុ រមែងកើតឡើង ព្រោះវត្ថុជាទីកើតនៃតណ្ហា ៤ នេះឯង ។

បុរសដែលមានតណ្ហាជាគ្នា តែងវង្វាត់ទៅ អស់កាល
ជាយូរអង្វែង មិនប្រព្រឹត្តកន្លងនូវសង្សារ ដែលមាន
ការប្រែប្រួល ឥតឈប់បាន ។ ភិក្ខុបានដឹងច្បាស់ នូវ
តណ្ហាថាជាហេតុនាំឲ្យកើតទុក្ខ ថាមានទោសយ៉ាងនេះ
ហើយ គួរជាអ្នកមិនមានតណ្ហា មិនមានការប្រកាន់ស្អិត
មានស្មារតី ហើយគេចចេញ ( បាកខន្ធ ) ។ សូត្រ
ទី ៦ ។

# អដ្ឋកថា

## តណ្ហុប្បាទសូត្រ

ក្នុងតណ្ហុប្បាទសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៧ ] បទថា **តណ្ហុប្បាទា** នេះ មានអធិប្បាយថា ឈ្មោះថា **ឧប្បាទ** ព្រោះអត្ថថា ជាទីកើតឡើង ។ សួរថា អ្វីកើតឡើង ឆ្លើយថា តណ្ហា ការកើតឡើងនៃតណ្ហា ឈ្មោះថា **តណ្ហុប្បាទ** អធិប្បាយថា ជាទីតាំងនៃតណ្ហា គឺជាហេតុនៃតណ្ហា ។ បទថា **យត្ថ** បានដល់ ក្នុងអារម្មណ៍ទាំងឡាយណាដែលជានិមិត្ត ។ បទថា **ឧប្បជ្ជមានា** បានដល់ មានប្រក្រតីកើតឡើង ។ ក្នុងបទថា **ចីវរហេតុ** នេះ មានអធិប្បាយថា តណ្ហារមែងកើតឡើង ព្រោះហេតុនៃចីវរថា អាត្មាអញនឹងបានចីវរដែលគួរពេញចិត្ត ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ម្យ៉ាងទៀត សព្ទថា **ឥតិ** ក្នុងបទថា **ឥតិភវាភវហេតុ** នេះ ជានិបាត ប្រើក្នុងអត្ថថា និទស្សនៈ ដូចមានអត្ថថា ព្រោះហេតុនៃចីវរជាដើម ។ ម្យ៉ាងទៀត ក្នុងបទថា **ភវាភវ** នេះ លោកបំណងយកសប្បិ និងនវនីតប្រណីតជាដើម ព្រោះអត្ថថា ជាហេតុឲ្យនូវការមិនមានរោគ ។ បណ្តាសម្បត្តិ និងភពទាំងឡាយ សម្បត្តិ និងភពដែលប្រណីត និងប្រណីតជាង លោកហៅថា **ភវាភវ** ដូច្នេះក៏មាន ។ ម្យ៉ាងទៀត បទថា **ភវោ** បានដល់ សម្បត្តិ ។ បទថា **អភវោ** បានដល់ វិបត្តិ ។ បទថា **ភវោ** បានដល់ **វុឌ្ឍិ** គឺសេចក្តីចម្រើន ។ បទថា **អភវោ** បានដល់ **ហានិ** គឺសេចក្តីវិនាស ។ តណ្ហាក៏មានភវាភវៈនោះជានិមិត្ត ទើបកើតឡើង ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **ភវាភវហេតុ វា** ដូច្នេះ ។

*គាថាទាំងឡាយ មានអត្ថដូចពោលហើយខាងដើមនោះឯង ។ មួយវិញទៀត បទថា* **តណ្ហាទុតិយោ** *បានដល់ មានតណ្ហាជាសម្លាញ់ អធិប្បាយថា សត្វនេះ កាលអន្ទោលទៅក្នុងសង្សារវដ្ដ ដែលមានទីបំផុតខាងដើម ដែលបុគ្គលណាម្នាក់តាមដឹងមិនបាន ក៏មិនបានអន្ទោលទៅតែម្នាក់ឯង តែបានទូវតណ្ហាជាគម្រប់ ២ គឺជាសម្លាញ់ត្រាច់ទៅ ។ ពិតហើយ តណ្ហានោះ មិនឲ្យសត្វបានគិតដល់ការធ្លាក់ទៅក្នុងជ្រោះនោះ ឲ្យឃើញតែអានិសង្សក្នុងកពទាំងឡាយ សូម្បីរឹកវរដោយទោសជាអនេក ដូចព្រានវាយឃ្មុំដូច្នោះ ទើបឲ្យសត្វវិលវល់ក្នុងសំណាញ់ដែលឥតប្រយោជន៍ ។ បទថា* **ឯតមាទីនវំ ញត្វា** *សេចក្ដីថា ដឹងដល់ទោសនោះ គឺដឹងយ៉ាងនេះ និងដឹងដទៃក្នុងខន្ធទាំងឡាយទាំងជាអតីត អនាគត និងបច្ចុប្បន្ន ។ បទថា* **តណ្ហា ទុក្ខស្ស សម្ភវំ** *សេចក្ដីថា តណ្ហាជាប្រកពកើត គឺជាដែនកើត បានដល់ ជាហេតុនៃភ័យនិងវដ្ដទុក្ខ ។*

*ព្រះមានព្រះភាគ ទ្រង់សម្ដែងការដែលភិក្ខុមួយរូប ចម្រើនវិបស្សនាហើយសម្រេចអរហត្តផល ដោយពាក្យត្រឹមប៉ុណ្ណេះ ឥឡូវនេះ កាលទ្រង់សរសើរភិក្ខុដែលជាខីណាស្រពនោះ ទើបត្រាស់ពាក្យថា* **វីតតណ្ហោ** *ជាដើម ។*

*ឯពាក្យណា ដែលមិនបានពោលក្នុងទីនេះ ពាក្យនោះ មានន័យដូចពោលហើយខាងដើមនោះឯង ។ល។*

**អដ្ឋកថា តណ្ហុប្បាទសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សព្រហ្មកសូត្រ

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វទេវតា ( ទេវតាដើម ) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វាចារ្យ ( អាចារ្យដើម ) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងអាហុនេយ្យបុគ្គល ( បុគ្គលគួរបូជា ) ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវតានុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យៈនុ៎ះ ជាឈ្មោះរបស់មាតាបិតា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ( ព្រោះ ) មាតាបិតា មានឧបការៈច្រើន ជាអ្នកបីបាច់ ( ឲ្យគង់ជីវិត ) ជាអ្នកចិញ្ចឹម ( ឲ្យធំធាត់ ) ទាំងជាអ្នកបង្ហាញនូវលោកនេះ ដល់កូនទាំងឡាយ ។

មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យ
ក្តី អាហុនេយ្យៈក្តី ( សុទ្ធតែ ) ជាអ្នកអនុគ្រោះដល់

ពួកសត្វ គឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរ
នមស្ការ គួរធ្វើសក្ការៈដល់មាតាបិតាទាំងនោះ ដោយ
បាយ ទឹក សំពត់ គ្រឿងដេក គ្រឿងអប់ គ្រឿង
ផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះការដែល
បានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញ
ទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង
បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយ
ក្នុងស្ថានសួគ៌ ។ សូត្រទី ៧ ។

# អដ្ឋកថា

## សព្រហ្មកសូត្រទី ៧

ក្នុងសព្រហ្មកសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៨ ] បទថា **សព្រហ្មកានិ** សេចក្តីថា ឈ្មោះថា ជាត្រកូលមានបុគ្គលប្រសើរបំផុត ។ បទថា **យេសំ** សេចក្តីថា ត្រកូលទាំងឡាយណា ។ បទថា **បុត្តានំ** សេចក្តីថា ដែលបុត្រទាំងឡាយ ។ ពាក្យថា **បុត្តានំ** នេះជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ព្រោះប្រកបចូលជាមួយសព្ទ **បូជិតា** សព្ទ ។ បទថា **អជ្ឈាគារេ** សេចក្តីថា ក្នុងផ្ទះរបស់ខ្លួន ។ បទថា **បូជិតា ហោន្តិ** សេចក្តីថា ជាបុគ្គលដែលកូនទាំងឡាយបដិបត្តិហើយ ដោយវត្ថុដែល

មាននៅក្នុងផ្ទះ គឺប្រណិប័តន៍ហើយដោយវត្ថុដែលគប្បីពេញចិត្ត និងដោយវត្ថុដែលជាប្រយោជន៍ដល់រាងកាយ និងជាប្រយោជន៍ដល់វាចា ។

ព្រះមានព្រះភាគ កាលទ្រង់សរសើរត្រកូលដែលបុត្របូជាមាតាបិតាថា ឈ្មោះថាជាត្រកូលដែលមានព្រះព្រហ្មយ៉ាងនេះហើយ កាលទ្រង់សម្តែងភាវៈដែលត្រកូលទាំងនោះជាត្រកូលគួរសរសើរក្រៃលែង ទើបត្រាស់ពាក្យជាឈ្មោះថា **បុត្តានំ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ព្រហ្មា** ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់ឲ្យមាតាបិតាទាំងនោះសម្រេចជាព្រហ្មជាដើម ក្នុងសេចក្តីនោះ មានការអធិប្បាយធ្វើឲ្យជាក់ច្បាស់ដូចតទៅនេះ

ពាក្យថា **ព្រហ្ម** ជាឈ្មោះរបស់បុគ្គលប្រសើរបំផុត អធិប្បាយថា មាតានិងបិតាទាំងឡាយ នឹងមិនលះបង់នូវភាវនា ៤ យ៉ាង គឺមេត្តា ករុណា មុទិតា ឧបេក្ខាក្នុងបុត្រទាំងឡាយ ដូចមហាព្រហ្មមិនលះបង់ភាវនា ៤ យ៉ាងដូច្នោះ ។ ភាវនា ៤ យ៉ាងនោះ គប្បីជ្រាបបានក្នុងកាលនោះៗ គឺកាលកូននៅក្នុងឧទរ មាតាបិតាកើតមេត្តាចិត្តឡើងថា ធ្វើម្តេចហ្ន៎ អញនឹងបានឃើញបុត្រតូចមិនមានរោគ មានអវយវៈតូចធំគ្រប់បរិបូណ៌ ។ កាលណាកូនតូចនោះនៅទន់ខ្ចី ដេកលើកែប ត្រូវសត្វណាមួយ ឬសង្កិចខាំ ឬដេកមិនសប្បាយ ស្រែកយំឡើង មាតា បិតាបានឮសំឡេងកូនហើយ នឹងកើតសេចក្តីករុណា តែពេលដែលកូនរត់លេងទៅមក ឬក្នុងវ័យដែលស្រស់ស្អាត កំលោះក្រមុំ មាតា បិតាសម្លឹងមើលកូនហើយ មានចិត្តត្រេកអរ ដូចសំឡីដែលគេ

ថ្លួចហើយអស់ ១០០ ដង ដែលជ្រលក់ហើយក្នុងសប្បិ ក្នុងកាលនោះ មាតាបិតាក៏មានមុទិតាចិត្ត កាលណាកូនទាំងនោះ មាននាទីជាអ្នកចិញ្ចឹមករិយា បែកផ្ទះនៅដោយឡែក កាលនោះ មាតាបិតាក៏មានចិត្តជាកណ្តាលកើតឡើងថា កូនរបស់អញ អាចចិញ្ចឹមជីវិតតាមធម្មតារបស់ខ្លួនហើយ កាលបើដូច្នេះ ក្នុងពេលនោះ មាតាបិតាក៏មានឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា **ព្រហ្មា**នំ ជាឈ្មោះរបស់មាតាបិតា នេះ ព្រះមានព្រះភាគត្រាស់ ព្រោះមាតាបិតាទាំងឡាយ ដូចជាព្រហ្ម ព្រោះបានព្រហ្មវិហារទាំង ៤ យ៉ាង ក្នុងបុត្រទាំងឡាយ តាមកាល ដូចពណ៌នាមកនេះឯង ។

ទេវតា ៣ ពួក គឺសម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ឈ្មោះថា **ទេវ** ក្នុងពាក្យថា **បុព្វទេវា** នេះ ។ បណ្តាទេវតា ៣ ពួកនោះ ក្សត្រដែលជាព្រះរាជា ឈ្មោះថា **សម្មតិទេព** ព្រោះក្សត្រដែលជាព្រះរាជាទាំងនោះ ដែលសត្វលោកសន្មតថា **ទេវ** និង **ទេវី** ជាអ្នកសង្កត់សង្កិន និងជាអ្នកអនុគ្រោះសត្វលោកបានដូចជាទេវតា ។ ពួកសត្វដែលកើតឡើងក្នុងទេវលោក តាំងអំពីទេវតាជាន់ចាតុម្មហារាជិកា រហូតដល់ភវគ្គព្រហ្ម ឈ្មោះថា **ឧបបត្តិទេព** ។ ព្រះខីណាស្រព ឈ្មោះថា **វិសុទ្ធិទេព** ព្រោះបរិសុទ្ធចាកកិលេសទាំងឡាយ ។ ក្នុងសេចក្តីនោះ មានអត្ថវចនៈដូចតទៅនេះ ពួកសត្វឈ្មោះថា **ទេវ** ព្រោះលេង ព្រោះសប្បាយរុងរឿង និងឈ្នះបរបក្ខ ។

បណ្តាទេវតា ៣ ពួកនោះ វិសុទ្ធិទេពប្រសើរជាងទេវតាទាំងអស់ ។ វិសុទ្ធិទេពទាំងនោះ ប្រាថ្នាតែការសាបសូន្យទៅនៃវត្ថុដែលមិនជាប្រយោជន៍

និងការកើតឡើងនៃប្រយោជន៍ដល់បុគ្គលទាំងនោះ ដោយចំណែកមួយ មិនពិចារណាដល់កំហុសដែលពាលជនធ្វើឡើយ បដិបត្តិដើម្បីប្រយោជន៍ ដើម្បីចម្រើន ដើម្បីសេចក្ដីសុខ ដោយការប្រកបព្រហ្មវិហារ តាមដែលពោលហើយ និងនាំភាពដែលសក្ការៈមានផលច្រើន និងអានិសង្សច្រើន មកឲ្យជនទាំងនោះ ព្រោះជាទក្ខិណេយ្យបុគ្គល យ៉ាងណា សូម្បីមាតាបិតាទាំងឡាយក៏ដូច្នោះដូចគ្នា ប្រាថ្នាតែសេចក្ដីវិនាសទៅនៃវត្ថុដែលមិនជាប្រយោជន៍ និងការកើតឡើងនៃប្រយោជន៍ដល់បុគ្គលទាំងនោះ ដោយចំណែកមួយ មិនគិតដល់កំហុសរបស់កូនទាំងឡាយ ជាទក្ខិណេយ្យបុគ្គលដ៏កំពូល បដិបត្តិដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ព្រោះបានព្រហ្មវិហារទាំង ៤ ដោយន័យដែលពោលមកហើយ នាំមកនូវឧបការៈដែលកូនធ្វើហើយក្នុងខ្លួនឲ្យជាឧបការៈ មានផល និងអានិសង្សច្រើន ។ មាតា និងបិតាទាំងនោះ ជាទេវតាមកតាំងអំពីដើម ព្រោះមានឧបការៈដល់បុត្រទាំងនោះមុនទេវតាទាំងឡាយ ព្រោះហេតុនោះ បុត្រទាំងនោះ ស្គាល់ទេវតាដទៃថាជាទេវតា ឲ្យទេវតាទាំងនោះពេញចិត្ត ចូលទៅអង្គុយជិតទេវតាទាំងនោះ កាលដឹងវិធីឲ្យទេវតាពេញចិត្តហើយ បដិបត្តិយ៉ាងនោះ ក៏បានជួបនូវផលនៃបដិបត្តិនោះដោយអំណាចនៃមាតា បិតាទាំងនោះមុន ដូច្នោះ ទើបទេវតាដទៃនោះឈ្មោះថា ជាបច្ឆាទេវតា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវតានុ៎ះ ជាឈ្មោះរបស់មាតាបិតា ។

បទថា **បុព្វាចរិយា** បានដល់ ជាអាចារ្យដំបូង អធិប្បាយថា មាតា

បិតា កាលឲ្យកូនសិក្សា ក៏ឲ្យសិក្សាតាំងពីនៅក្មេងៗ ថា ចូរអង្គុយយ៉ាងនេះ ចូរដើរយ៉ាងនេះ ចូរឈរយ៉ាងនេះ ចូរដេកយ៉ាងនេះ ចូរទំពាយ៉ាងនេះ ចូរបរិភោគយ៉ាងនេះ បុរសនេះ គួរហៅថា ពុក បុរសនេះ គួរហៅថា បងប្រុស ប្អូនប្រុស នារីនេះ គួរហៅថា បងស្រី ប្អូនស្រី របស់នេះ គួរធ្វើ របស់នេះមិនគួរធ្វើ ទីនោះ គួរទៅ ទីនោះ មិនគួរចូលទៅ ដូច្នេះ ។ តមកអាចារ្យដទៃៗ ទើបឲ្យសិក្សាសិប្បៈយ៉ាងនេះ គឺការរាប់ម្រាមដៃ អាចារ្យដទៃឲ្យសរណៈ ឲ្យតាំងនៅក្នុងសីល ឲ្យបព្វជ្ជា ឲ្យរៀនធម៌ ឲ្យឧបសម្បទា និងឲ្យសម្រេចសោតាបត្តិមគ្គជាដើម ដូច្នោះ ទើបអាចារ្យទាំងនោះ ឈ្មោះថា បច្ឆាចារ្យ ឯមាតាបិតា ឈ្មោះថា ជាបុព្វាចារ្យមុនបុគ្គលទាំងឡាយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យនុ៎ះ ជាឈ្មោះរបស់មាតាបិតា ដូច្នេះ ។

បទថា **អាហុនេយ្យា** សេចក្ដីថា ទ្រព្យ ឈ្មោះថា **អាហុន** ព្រោះគេត្រូវនាំមកបូជា គឺបុគ្គលបំណងផលវិសេសត្រូវនាំមកអំពីចម្ងាយ ហើយទើបឲ្យដល់បុគ្គលមានគុណទាំងឡាយ ។ ពាក្យថា **អាហុន** នេះ ជាឈ្មោះនៃបាយ ទឹក និងសំពត់សម្រាប់បិទបាំងកាយជាដើម ។ មាតាបិតារមែងគួរដល់របស់បូជាទាំងនោះ ព្រោះជាស្រែសម្រាប់ដាំបណ្ដុះឧបការធម៌ ព្រោះដូច្នោះ ទើបឈ្មោះថា **អាហុនេយ្យ** ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា **អាហុនេយ្យ** នុ៎ះ ជាឈ្មោះរបស់មាតាបិតា ដូច្នេះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងហេតុក្នុងភាវៈ ដែលមាតាបិតាទាំងនោះជាព្រហ្មជាដើម ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **តំ កិស្ស ហេតុ ពហុការា** ប្រែថា សេចក្តីនោះ ព្រោះហេតុអ្វី ព្រោះមានឧបការៈច្រើន ។

បទថា **តំ កិស្ស ហេតុ** មានអធិប្បាយថា បើមានពាក្យសួរថា ព្រោះហេតុអ្វី ពាក្យថា **ព្រហ្មា** ជាដើមនោះ ទើបជាឈ្មោះរបស់មាតាបិតា ។ បទថា **ពហុការា** បានដល់ មានឧបការៈច្រើន ។ បទថា **អាបាទកា** បានដល់ អ្នកថ្នមបបោសអង្អែល គឺចិញ្ចឹមជីវិត អធិប្បាយថា ជីវិតរបស់កូនទាំងឡាយ មាតាបិតាថ្នមថៃ គឺចិញ្ចឹម បានដល់ បន្តឲ្យប្រព្រឹត្តទៅ គឺឲ្យដល់ព្រមដោយការសម្ពន្ធគ្នារៀយៗ ។ បទថា **ពោសកា** សេចក្តីថា មើលថៃ ដោយឲ្យផឹកឈាមក្នុងទ្រូង គឺទឹកដោះ ឲ្យដៃ និងជើងធំឡើង ។ បទថា **ឥមស្ស លោកស្ស ទស្សេតារោ** សេចក្តីថា ឈ្មោះថា ឃើញនូវឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងលោកនេះ កើតមានដល់កូនទាំងឡាយបាន ព្រោះអាស្រ័យមាតាបិតា ព្រោះដូច្នោះ ទើបមាតាបិតាទាំងនោះ ឈ្មោះថា ជាអ្នកបង្ហាញលោកនេះ ដល់បុត្រទាំងនោះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងភាពដែលមាតាបិតាទាំងនោះ ជាអ្នកមានឧបការៈច្រើន និងហេតុនៃភាពជាព្រហ្មជាដើម ដោយប្រការដូច្នេះ ។ ជាហេតុឲ្យបុត្រមិនអាចធ្វើការតបគុណមាតាបិតាឲ្យដល់ទីបំផុតបាន ដោយលោកិយ-ឧបការៈ ដោយបរិយាយណាមួយឡើយ ។ ព្រោះថា បើបុត្រតាំងចិត្តថា អញនឹងធ្វើតបគុណមាតាបិតា ហើយព្យាយាមក្រោកឡើង ឲ្យមាតាអង្គុយ

លើស្មាខាងស្តាំ ឲ្យបិតាអង្គុយលើស្មាខាងឆ្វេង ផ្គត់ផ្គង់លោកទាំង ២ អស់រយៈនៃឆ្នាំ ធ្វើទំនុកបម្រុងដោយបច្ច័យ ៤ និងដោយគ្រឿងក្រអូប គក់ប្រេបាច់ ងូតទឹក និងពត់កាយជាដើមតាមដែលលោកគាប់ចិត្ត មិនរង្កៀស សូម្បីតែមូត្រ និងករីសរបស់លោកទាំង ២ សោត ។

ដោយប្រណិប័តន៍មានប្រមាណប៉ុណ្ណេះ ក៏មិនឈ្មោះថា ជាអ្នកធ្វើនូវការតបស្នងមាតាបិតាឡើយ វៀរលែងតែការឲ្យលោកតាំងនៅក្នុងគុណវិសេសមានសទ្ធាជាដើម ដែលព្រះមានព្រះភាគត្រាស់ក្នុងអង្គុត្តរនិកាយ ទុកនិបាតថា

ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា កុលបុត្ត មិនងាយនឹងធ្វើការតបគុណដល់បុគ្គល ២ ពួកបានទេ ។ បុគ្គល ២ ពួក តើនរណាខ្លះ ។ គឺមាតា ១ បិតា ១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តមានអាយុ ១០០ ឆ្នាំ រស់នៅអស់រវាង ១០០ ឆ្នាំ គប្បីបញ្ជិះមាតាដោយស្មាម្ខាង បញ្ជិះបិតាដោយស្មាម្ខាង កុលបុត្តនោះបម្រើមាតាបិតាទាំង ២ នោះ ដោយការដុសជម្រះ បំបាត់ក្លិនអាក្រក់ រិតនួតដៃផ្ងូតទឹកគក់ប្រេបាច់ដៃជើង ឯមាតា បិតាទាំង ២ នោះ ក៏បន្ទោបង់មូត្រករីស លើស្មាកុលបុត្តនោះឯង ម្នាលភិក្ខុទាំងឡាយ ( ហេតុមានប្រមាណប៉ុណ្ណេះ ) គង់មិនទាន់ហៅថា ធ្វើ ឬថា ធ្វើតបដល់មាតា និងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តតម្កើងមាតា និងបិតា ឲ្យតាំងនៅក្នុងរាជសម្បត្តិមានឥស្សរភាពជាអធិបតី លើផែនដីធំ ដែលមានកែវទាំង ៧

ប្រការច្រើននេះ ម្នាលភិក្ខុទាំងឡាយ ( ហេតុមានប្រមាណប៉ុណ្ណេះ ) គង់មិនទាន់ហៅថា ធ្វើ ឬថា ធ្វើតបដល់មាតា និងបិតាឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា មាតា និងបិតា មានឧបការៈច្រើនដល់បុត្តទាំងឡាយ ព្រោះជាអ្នកថែរក្សា ចិញ្ចឹម បង្ហាញនូវលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ ( បើ ) កុលបុត្តណាមួយ ដឹកនាំមាតានិងបិតា ដែលមិនមានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា បើទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីលសម្បទា បើកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា បើឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថា ធ្វើ ឬថាធ្វើតបដល់មាតា និងបិតាមែន ។

ម្យ៉ាងទៀត គប្បីជ្រាបព្រះសូត្រ ដែលឲ្យសម្រេចភាពដែលមាតាបិតាជាអ្នកមានឧបការៈច្រើនដល់បុត្រយ៉ាងនេះថា ការបម្រើមាតាបិតា ១ សេចក្តីសង្គ្រោះដល់បុត្ត និងភរិយា ១ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការបម្រើមាតាបិតា បណ្ឌិតបញ្ញត្ត ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **វុច្ចរេ** បានដល់ តថាគតហៅ គឺពោល ។ បទថា **បជាយ អនុកម្បកា** សេចក្តីថា

*មាតាបិតា បំបាត់ជីវិតអ្នកដទៃខ្លះ លះបង់ទ្រព្យរបស់ខ្លួនខ្លះ ផ្គត់ផ្គង់បជា គឺបុត្ររបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា ជាអ្នកអាណិតអាសូរ គឺអនុគ្រោះបជា គឺបុត្រ ។ បទថា* **នមស្សេយ្យ** *សេចក្តីថា ទៅកាន់ទីបម្រើព្រឹកល្ងាច ធ្វើនូវការឱនលំទោនដោយគិតថា នេះជាស្រែ បុណ្យដ៏ឧត្តមរបស់អញ ។ បទថា* **សក្ករេយ្យ** *សេចក្តីថា គប្បីបូជាដោយសក្ការៈ ។*

*ឥឡូវនេះ កាលទ្រង់សម្តែងសក្ការៈនោះ ទើបត្រាស់ពាក្យជាដើមថា* **អន្នេន** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* **អន្នេន** *សេចក្តីថា ដោយបាយនិងបបរ និងរបស់ទំពា ។ បទថា* **ចានេន** *សេចក្តីថា ដោយទឹកបាន ៨ យ៉ាង ។ បទថា* **វត្ថេន** *សេចក្តីថា ដោយសំពត់ស្លៀកដណ្តប់ ។ បទថា* **សយនេន** *សេចក្តីថា ដោយទីដេក មានគ្រែ តាំង ពូក ខ្នើយជាដើម ។ បទថា* **ឧច្ឆាទនេន** *សេចក្តីថា ដោយគ្រឿងអប់ដែលកម្ចាត់ក្លិនស្អុយ និងធ្វើឲ្យមានក្លិនក្រអូប ។ បទថា* **ន្ហាបនេន** *សេចក្តីថា ដោយការឲ្យងូតទឹក ដោយប្រើទឹកក្តៅងូតឲ្យក្នុងពេលរងា និងប្រើទឹកត្រជាក់ងូតឲ្យក្នុងពេលក្តៅ ។ បទថា* **ចាទានំ ធោវនេន ច** *សេចក្តីថា ដោយការលាងជើងដោយទឹកក្តៅ និងទឹកត្រជាក់ និងដោយការលាបដោយប្រេង ។*

*បទថា* **ធំ** *ក្នុងពាក្យថា* **តាយ ធំ ចារិចរិយាយ** *នេះ ត្រឹមតែជានិបាត បទថា* **ចារិចរិយាយ** *បានដល់ ដោយការបម្រើដូចពោលមកហើយ ។ម្យ៉ាងទៀត បទថា* **ចារិចរិយាយ** *សេចក្តីថា ដោយការទំនុកបម្រុងដោយវិធី ៥ យ៉ាង មានការចិញ្ចឹម ការធ្វើកិច្ចឲ្យ និងការតាំងវង្សត្រកូលជាដើម ។ សម*

ដូចព្រះមានព្រះភាគត្រាស់ក្នុងសិង្គាលកសូត្រថា

ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯង ហើយ រមែងអនុគ្រោះកូន ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ ដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្ដឹងកិរិយាស្វាមីសមគួរឲ្យ ១ បែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។

ម្យ៉ាងទៀត កូនណាទំនុកបម្រុងមាតាបិតា ដោយធ្វើឲ្យជ្រះថ្លាក្រៃលែងក្នុងវត្ថុទាំង ៣ ឲ្យតាំងនៅក្នុងសីល ឬប្រកបក្នុងបព្វជ្ជា បុត្រនេះ គប្បីជ្រាបថា ជាបុត្រដ៏ប្រសើរក្នុងបណ្ដាអ្នកទំនុកបម្រុងមាតាបិតាទាំងឡាយ ។

ព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្ដែងថា ការបម្រើនេះជាហេតុនាំមកនូវប្រយោជន៍ សេចក្ដីចម្រើន និងសេចក្ដីសុខមកឲ្យក្នុងលោកទាំង ២ ដល់កូន

ទើបត្រាស់ថា

អ្នកប្រាជ្ញទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធ** សេចក្តីថា ក្នុងលោកនេះ អធិប្បាយថា មនុស្សជាបណ្ឌិតទាំងឡាយសរសើរ គឺលើកតម្កើង បានដល់ សរសើរបុគ្គលដែលបម្រើមាតាបិតា ដោយការទំនុកបម្រុង និងយកបុគ្គលនោះជាទិដ្ឋានុគតិ សូម្បីខ្លួនឯង ក៏បដិបត្តិក្នុងមាតាបិតារបស់ខ្លួនយ៉ាងនោះហើយ តែងជួបនូវបុណ្យច្រើន ។ បទថា **បេច្ច** សេចក្តីថា ជាអ្នកបម្រើមាតាបិតាទៅកាន់បរលោកហើយ ស្ថិតនៅក្នុងស្ថានសួគ៌ រមែងត្រេកអររីករាយដោយទិព្វសម្បត្តិទាំងឡាយ ។៙

**អដ្ឋកថា សព្រហ្មកសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ពហុការសូត្រ

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ និងគហបតីណា បាន ទំនុកបម្រុងអ្នកទាំងឡាយ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលាន-ប្បច្ចយភេសជ្ជបរិក្ខារ ព្រាហ្មណ៍ និងគហបតីទាំងនោះ ឈ្មោះថា មានឧបការៈច្រើន ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯអ្នកទាំងឡាយ ក៏ឈ្មោះថា មានឧបការៈច្រើន ដល់ពួកព្រាហ្មណ៍ និងគហបតីដែរ ព្រោះអ្នកទាំង-ឡាយ សម្តែងធម៌ មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះ ដែលបុគ្គលប្រព្រឹត្ត ដើម្បីប្រយោជន៍ រើចេញចាកឱឃៈ នឹងធ្វើឲ្យផុតទុក្ខដោយប្រពៃបាន ក៏ព្រោះតែអាស្រ័យគ្នាទៅវិញទៅមក យ៉ាងនេះឯង ។

ពួកគ្រហស្ថ និងបព្វជិត ទាំងពីរពួក អាស្រ័យគ្នាទៅ
វិញទៅមក ទើបញ៉ាំងព្រះសទ្ធម្ម ដែលជាទីក្សេមចាក
យោគៈដ៏ប្រសើរ ឲ្យសម្រេចបាន ឯពួកបព្វជិត តែង
ទទួលចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ
និងភេសជ្ជប្បច្ច័យ ជាគ្រឿងបន្ទោបង់សេចក្តីអន្តរាយ
អំពីពួកគ្រហស្ថ ។ ឯពួកគ្រហស្ថអ្នកស្វែងរកប្រយោជន៍
ក្នុងផ្ទះ បានអាស្រ័យសង្ឃជាសាវកនៃព្រះសុគតហើយ
ជឿ ( សេចក្តីប្រតិបត្តិ និងពាក្យ ) របស់ព្រះអរហន្ត

ទាំងឡាយ ដោយប្រាជ្ញាដ៏ប្រសើរ ជាអ្នកពិនិត្យ បាន
ប្រព្រឹត្តធម៌ ក្នុងសាសនានេះ ដែលជាផ្លូវប្រព្រឹត្តទៅ
កាន់សុគតិ រមែងជាអ្នកមានអំណរ រីករាយក្នុងទេវលោក
បានសម្រេចតាមសេចក្តីប្រាថ្នា ។ សូត្រទី ៨ ។

# អដ្ឋកថា

## ពហុការសូត្រ

ក្នុងពហុការសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១០៩ ] បទថា **ព្រាហ្មណគហបតិកា** បានដល់ ទាំងព្រាហ្មណ៍ ទាំងគហបតី ។ មនុស្សគ្រប់ពួកកាលគ្រប់គ្រងផ្ទះ វៀរពួកព្រាហ្មណ៍ គប្បីជ្រាបថា ឈ្មោះថា ជាគហបតីក្នុងទីនេះ ។ បទថា **យេ** សំដៅដល់ បុគ្គលដែលអះអាងមកមិនពិតប្រាកដ ។ បទថា **វោ** ជាទុតិយាវិភត្តិ ពហុវចនៈ ។ ក្នុងសេចក្តីនេះ មានអត្ថដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ-គហបតីទាំងឡាយ ដែលមានឧបការៈច្រើនដល់ពួកអ្នក ដែលបានដល់ ទាំងព្រាហ្មណ៍ ទាំងគហបតីដ៏សេស ពួកអ្នកប៉ុណ្ណោះ ដែលជនទាំងនោះនាំគ្នាទំនុកបម្រុង ដោយបច្ច័យទាំងឡាយ មានចីវរជាដើម ដោយគិតថា ជាបុញ្ញក្ខេត្តរបស់យើងទាំងឡាយ ដែលពួកយើងនាំគ្នាប្រតិស្ឋាន ជាទក្ខិណាឲ្យតម្លៃខ្ពង់ខ្ពស់ មានផលដ៏ប្រសើរ មានវិបាកជាសុខ ប្រព្រឹត្តទៅដើម្បីកើត

ក្នុងស្ថានសួគ៌ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា គ្រហស្ថទាំងឡាយ ជាអ្នកមានឧបការៈដល់ភិក្ខុទាំងឡាយ ដោយការថ្វាយអាមិស គឺដោយការចែករំលែកអាមិស បានដល់ ដោយការអនុគ្រោះដោយអាមិសយ៉ាងនេះហើយ ឥឡូវនេះដើម្បីទ្រង់សម្តែងថា សូម្បីភិក្ខុទាំងឡាយក៏មានឧបការៈដល់គ្រហស្ថទាំងនោះដូចគ្នា គឺការចែករំលែកនូវធម៌ បានដល់ ដោយការអនុគ្រោះដោយធម៌ ទើបត្រាស់ពាក្យជាដើមថា **តុម្ហេបិ ភិក្ខវេ** ពាក្យនោះ ក៏មានន័យដូចដែលបានពោលមកហើយនោះឯង ។

ដោយពាក្យនេះ ទ្រង់ត្រាស់ដល់អ្វី ឆ្លើយថា ត្រាស់ដល់ការឱនលំទោនចំពោះបិណ្ឌបាត គឺគោរពបិណ្ឌបាត ។ ក្នុងសេចក្តីនេះ មានអធិប្បាយតទៅនេះថា ម្នាលភិក្ខុទាំងឡាយ ព្រោះព្រាហ្មណគហបតីទាំងនេះមិនមែនញាតិមិនមែនមិត្រ មិនមែនអ្នកជំពាក់បំណុលរបស់អ្នកទាំងឡាយ ដោយពិត បុគ្គលនោះត្រូវការផលពិសេស ដោយគិតថា សមណៈទាំងនេះ ជាអ្នកប្រព្រឹត្តប្រពៃបដិបត្តិប្រពៃ បុណ្យដែលយើងទាំងឡាយធ្វើក្នុងសមណៈទាំងនេះ នឹងមានផលានិសង្សច្រើន ដូច្នេះ ទើបទំនុកបម្រុងអ្នកទាំងឡាយដោយបច្ច័យ ៤ មានចីវរជាដើម ដូច្នោះ អ្នកទាំងឡាយគួរឲ្យ សេចក្តីប្រាថ្នារបស់ជនទាំងនោះពេញបរិបូណ៌ ដល់ព្រមដោយការមិនប្រមាទចុះ ធម្មទេសនាក៏ល្អ និងគួរកាន់យកសម្រាប់បុគ្គលទាំងនោះ ដែលធ្វើតាមនោះឯង មិនមែនសម្រាប់អ្នកដទៃក្រៅអំពីនេះ អ្នកទាំងឡាយ គប្បីធ្វើនូវការមិនប្រមាទក្នុងសម្មាបដិបត្តិ

ដូចពណ៌នាមកនេះឯង ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា **ឯវមិទំ ភិក្ខវេ** ជាដើម មានសេចក្តីសង្ខេបដូចតទៅថា ម្នាលភិក្ខុទាំងឡាយ គ្រហស្ថ និងបព្វជិត អាស្រ័យគ្នាដោយអំណាចអាមិសទាន និងធម្មទាន មានប្រការដូចពោលមកយ៉ាងនេះហើយ នៅប្រព្រឹត្តសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈនេះ ដោយអំណាចការនិយមឧបោសថសីលជាដើម និងដោយអំណាចបារិសុទ្ធិសីល ៤ ជាដើម ដើម្បីដកនូវឱឃៈទាំង ៤ មានកាមោឃៈជាដើម និងដើម្បីធ្វើទីបំផុតនៃវដ្តទុក្ខទាំងអស់ ដោយប្រពៃនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **សាគារា** បានដល់ គ្រហស្ថទាំងឡាយ ។ បទថា **អនាគារា** បានដល់ លះនូវផ្ទះចេញបួស ។ បទថា **ឧភោ អញ្ញោញ្ញនិស្សិតា** សេចក្តីថា ទាំង ២ ចំណែកនោះអាស្រ័យគ្នានិងគ្នា អធិប្បាយថា គ្រហស្ថអ្នកមានផ្ទះ អាស្រ័យធម្មទានរបស់បព្វជិតដែលមិនមានផ្ទះ បព្វជិតដែលមិនមានផ្ទះ ក៏អាស្រ័យការថ្វាយបច្ច័យរបស់គ្រហស្ថអ្នកមានផ្ទះ ។ បទថា **អារាធយន្តិ** សេចក្តីថា ឲ្យសម្រេច គឺឲ្យដល់ព្រម ។ បទថា **សទ្ធម្មំ** បានដល់ បដិបត្តិសទ្ធម្ម និងបដិវេធសទ្ធម្ម ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ដ៏ឧត្តម ក្នុងបណ្តាធម៌ទាំងនោះ ទើបត្រាស់ថា **យោគក្ខេមំ អនុត្តរំ** គឺព្រះអរហត្ត និងព្រះនិព្វាន ។ បទថា **សាគារេសុ** សេចក្តីថា ចាកគ្រហស្ថដែលមានផ្ទះទាំងឡាយ ។ បទនេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថបញ្ចមីវិភត្តិ ។ម្យ៉ាងទៀត ដោយអត្ថថា ក្នុងសម្នាក់

របស់គ្រហស្ថទាំងឡាយដែលមានផ្ទះ ។ បទថា **បច្ចយំ** បានដល់ បច្ច័យ ២ យ៉ាងដ៏សេសតាមដែលបានពោលមកហើយ គឺបិណ្ឌបាត និងភេសជ្ជៈ ។ បទថា **បរិស្សយវិនោទនំ** បានដល់ ទីនៅអាស្រ័យ មានវិហារជាដើម ដែលបំបាត់អន្តរាយ មានអន្តរាយដែលកើតអំពីរដូវជាដើម ។

បទថា **សុគតំ** បានដល់ ព្រះអរិយបុគ្គល ៨ ពួក មួយអន្លើដោយកល្យាណបុថុជ្ជនទាំងឡាយ ដែលបដិបត្តិប្រពៃហើយ ។ ពិតហើយ សាវកទ្រង់សំដៅយកពាក្យថា **សុគត** ក្នុងគាថានេះ ។ បទថា **ឃរមេសិនោ** បានដល់ ជាអ្នកស្វែងរកផ្ទះ អធិប្បាយថា មានប្រក្រតីនៅគ្រប់គ្រងផ្ទះ ស្វែងរកឧបករណ៍នៃភោគទ្រព្យ និងគុណធម៌ មានសីលរបស់គ្រហស្ថជាដើម ។ បទថា **សទ្ទហានោ អរហតំ** សេចក្តីថា បុគ្គលជឿនូវពាក្យរបស់ព្រះអរិយបុគ្គលទាំងឡាយដែលជាព្រះអរហន្ត ឬជឿនូវបដិបត្តិបទាប្រពៃរបស់លោកទាំងនោះ អធិប្បាយថា ជឿមាំថា លោកទាំងនេះ ជាអ្នកបដិបត្តិប្រពៃ ពិតប្រាកដ សម្រាប់បុគ្គលដែលបដិបត្តិតាមលោកទាំងនេះ ដែលបានប្រាប់កិច្ចបដិបត្តិនោះ ក៏ប្រព្រឹត្តទៅដើម្បីសគ្គសម្បត្តិ និងនិព្វានសម្បត្តិ ។ បាឋៈថា **សទ្ធាតា** ដូច្នេះក៏មាន ។ បទថា **អរិយបញ្ញាយ** សេចក្តីថា ដោយបញ្ញាដែលបរិសុទ្ធល្អហើយ ។ បទថា **ឈាយិនោ** សេចក្តីថា ជាអ្នកសម្លឹងដោយឈានទាំង ២ គឺអារម្មណូបនិជ្ឈាននិងលក្ខណូបនិជ្ឈាន ។ បទថា **ឥធ ធម្មំ ចរិត្វាន** សេចក្តីថា កាលបដិបត្តិធម៌ មានសីលជាដើម ដែលជាផ្លូវនៃលោកិយសុខ និងលោកុត្តរសុខ ក្នុងអត្តភាពនេះ ឬក្នុងសាសនានេះ នឹងទៅ

*កាន់សុគតិ ដរាបណាមិនទាន់សម្រេចព្រះនិព្វាន ។ បទថា* **ឆន្ទិនោ** *សេចក្តីថា ឈ្មោះថា ជាអ្នកមានប្រក្រតីត្រេកអរ ព្រោះប្រកបដោយបីតិ និងសោមនស្ស តែអាចារ្យពួកខ្លះពោលថា បទថា* **ធម្មំ ចរិត្វាន មគ្គំ** *សេចក្តីថា សម្រេចនូវសោតាបត្តិមគ្គ បទថា* **តេវលោកស្មឹ** *សេចក្តីថា ក្នុងទេវលោកជាន់កាមាវចរ ៦ ជាន់ ។ បទថា* **មោទន្តិ កាមកាមិនោ** *សេចក្តីថា ឈ្មោះថា ជាអ្នកប្រាថ្នាកាម គឺជាអ្នកមានបំណងត្រេកអរ ព្រោះសម្រេចតាមវត្ថុបំណងហើយ ៕៚*

**អដ្ឋកថា ពហុការសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## កុហនសូត្រ

*[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមួយ ជាអ្នកញ៉ាំងគេឲ្យស្ងើច រឹងរូស រក់ទាក់ មានវាចាដូចស្នែង លើកកម្ពស់ មានចិត្តមិននឹងនួន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា មិនរាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រាសចាកធម៌វិន័យនេះផង ភិក្ខុទាំងនោះ មិនដល់នូវសេចក្តីចម្រើន លូតលាស់ ទូលំទូលាយ ក្នុងធម៌វិន័យនេះផង ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកភិក្ខុណា មិនជាអ្នកញ៉ាំងគេឲ្យស្ងើច មិនរក់ទាក់ មានប្រាជ្ញា មិនរឹងរូស មានចិត្តនឹងនួនល្អ ម្នាលភិក្ខុទាំងឡាយ*

ភិក្ខុទាំងនោះឯង ទើបឈ្មោះថា ជាអ្នករាប់អានតថាគតផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា មិនប្រាសចាកធម៌វិន័យនេះផង ភិក្ខុទាំងនោះ រមែងដល់នូវសេចក្តីចម្រើន លូតលាស់ ទូលំទូលាយ ក្នុងធម៌វិន័យនេះផង ។

ពួកភិក្ខុណា ដែលជាអ្នកញុំាងគេឲ្យស្ញើច រឹងរូស រាក់ទាក់ មានវាចាដូចស្នែង លើកកម្ពស់ មានចិត្តមិននឹងនួន ភិក្ខុទាំងនោះ មិនលូតលាស់ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងឡើយ ។ លុះតែពួកភិក្ខុណា មិនជាអ្នកញុំាងគេឲ្យស្ញើច មិនរាក់ទាក់ មានប្រាជ្ញា មិនរឹងរូស មានចិត្តនឹងនួន ភិក្ខុទាំងនោះ ទើបលូតលាស់ក្នុងធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងបាន ។ សូត្រទី ៩ ។

# អដ្ឋកថា

## កុហានសូត្រ

[ ១១០ ] ក្នុងកុហានសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **កុហា** បានដល់ ជាអ្នកបោកបញ្ឆោត ដោយរឿងកុហក មានការរាយមន្តជាដើម អធិប្បាយថា ជាអ្នកធ្វើនូវការបោកបញ្ឆោត ដើម្បីប្រកាសគុណដែលខ្លួនមិនមានឲ្យអ្នកដទៃជឿ ។ បទថា **ថទ្ធា** សេចក្តីថា ជាអ្នកមានចិត្តរឹងត្អឹង

ដោយកោធៈ និងមានៈ គឺជាអ្នកមិនធ្វើនូវការកោតក្រែងក្នុងគ្រូទាំងឡាយ ដែលគួរធ្វើសេចក្តីគោរព មិនឱនលំទោន ត្រាច់ទៅមក ដូចលេបចម្រៀក ដែកចូលទៅហើយ ឈររឹងខ្លួន ដូច្នោះ ព្រោះសេចក្តីក្រោធដែលត្រាស់ អង្គុត្តរនិកាយ តិកនិបាតហើយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេពោល តែបន្តិចបន្តួច ក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្តឲ្យកើតប្រាកដឡើង ដូច្នេះ ។ ព្រោះភាព ជាបុគ្គលប្រដៅក្រ ដូចព្រះតម្រាស់ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកយ៉ាង នេះថា ភិក្ខុនោះ នៅជាអ្នកដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ ជាអ្នកមិនកាន់យកនូវ ពាក្យប្រដៅដោយចំណែកខាងស្តាំ ដូច្នេះ ។ ព្រោះការស្រវឹង មានការស្រវឹង ក្នុងជាតិជាដើម ដូចព្រះតម្រាស់ក្នុងវិភង្គថា សេចក្តីស្រវឹងព្រោះជាតិ សេចក្តី ស្រវឹងព្រោះគោត្រ សេចក្តីស្រវឹងព្រោះការមិនមានរោគ សេចក្តីស្រវឹងព្រោះ វ័យ សេចក្តីស្រវឹងព្រោះជីវិត ដូច្នេះ ។ បទថា **លបា** សេចក្តីថា ជាអ្នក រាក់ទាក់ គឺសង្គ្រោះត្រកូលដោយអំណាចមិច្ឆាជីពម្យ៉ាងទៀត អធិប្បាយថា ជាអ្នកពោលដើម្បីបច្ច័យ ដោយអំណាចពាក្យដូចខ្មោស និងដោយអំណាច ការបោកបញ្ឆោត ។

បទថា **សិង្គី** សេចក្តីថា វាចាដែលប្រកបដោយកិលេសដែលប្រាកដ ច្បាស់ ដូចគ្នានឹងស្នែងសត្វ ដូចព្រះតម្រាស់ត្រាស់ក្នុងវិភង្គថា កិលេសជាត

ដូចស្នែង សេចក្ដីស្រឡាញ់ ការឈ្លាសវៃ ការឆ្លៀវឆ្លាស អាការប៉ិនប្រសប់ សេចក្ដីប៉ិនប្រសប់ណា នេះហៅថា កិលេសជាតដូចស្នែង ។ បទថា **ឧន្នឡា** សេចក្ដីថា ដូចដើមបបុសដែលខំដុះឡើង គឺលើកខ្លួន ដែលមានចិត្តទទេចាក គុណវិសេស ដូចដើមបបុសខំលូតឡើង ។ បទថា **អសមាហិតា** សេចក្ដីថា ជាអ្នកមិនបានសូម្បីត្រឹមឯកគ្គតាចិត្ត ។

បទថា **ន មេ តេ ភិក្ខវេ ភិក្ខូ មាមកា** សេចក្ដីថា ភិក្ខុទាំងនោះ ឈ្មោះថា មិនរាប់អានតថាគត ។ ព្រះមានព្រះភាគត្រាស់ពាក្យថា **មយ្ហំ** នេះ ព្រោះភិក្ខុទាំងនោះបួសឧទ្ទិសចំពោះព្រះអង្គ ។ តែព្រោះហេតុដែលភិក្ខុទាំងនោះ មិនបដិបត្តិប្រពៃ ដោយប្រកបការបោកបញ្ឆោតជាដើម ដូច្នោះ ទើបមិនត្រាស់ ហៅថា **មាមក** ប្រែថា ជាមនុស្សរបស់តថាគត ។ ដោយបទថា **អបគតា** ព្រះមានព្រះភាគទ្រង់សម្ដែងថា ទោះបីភិក្ខុទាំងនោះបួសហើយក្នុងសាសនា របស់តថាគត តែព្រោះមិនបដិបត្តិតាមតថាគតទូន្មាន ទើបស្មើគ្នានឹងទៅ ហើយចាកព្រះធម្មវិន័យនេះឯង គឺភិក្ខុទាំងនោះ ឈ្មោះថា នៅឆ្ងាយចាក សាសនានេះ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា

ម្នាលភិក្ខុទាំងឡាយ មេឃ និងផែនដីនេះ ជារបស់ឆ្ងាយ ក្រៃលែងឆ្ងាយទី ១ ម្នាលភិក្ខុទាំងឡាយ ត្រើយសមុទ្ទ ខាងអាយ និងត្រើយសមុទ្ទខាងនាយនេះ ជារបស់ឆ្ងាយ ក្រៃលែងឆ្ងាយទី ២ ម្នាលភិក្ខុទាំងឡាយ ព្រះអាទិត្យរះ

ឡើង អំពីទិសណា អស្តង្គតទៅក្នុងទិសណា នេះជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៣ ម្នាលភិក្ខុទាំងឡាយ ធម៌របស់ពួកសប្បុរស និងធម៌របស់ពួកអសប្បុរសនេះ ជារបស់ឆ្ងាយក្រៃលែងឆ្ងាយទី ៤ ។

បទថា **វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជន្តិ** សេចក្តីថា នូវសេចក្តីចម្រើនតាមអំណាចនៃសេចក្តីចម្រើនដោយគុណ មានសីលជាដើម នូវការដុះដាលតាមសភាវៈដោយមិនញាប់ញ័រនៅក្នុងគុណ មានសីលជាដើមនោះ នូវការបរិបូណ៌ ដោយសេចក្តីបរិបូណ៌ដោយធម្មក្ខន្ធ មានសីលជាដើម ដោយការផ្សាយទៅក្នុងទិសតូចធំ ភិក្ខុទាំងនោះ ដែលមានសភាពបោកបញ្ឆោតជាដើម មិនចូលដល់ អធិប្បាយថា មិនជួប ។

បទថា **តេ ច ខោ មេ ភិក្ខវេ ភិក្ខូ មាមកា** សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយក្រៅអំពីនេះថា **មេ** ព្រោះបួសឧទ្ទិសចំពោះព្រះអង្គ ។ មួយវិញទៀត ត្រាស់ហៅថា **មាមក** ព្រោះជាអ្នកបដិបត្តិប្រពៃហើយ ធម៌ចំណែកស គប្បីជ្រាបដោយបរិយាយដែលផ្ទុយតាមដែលពោលមកហើយ ភិក្ខុទាំងនោះ ឈ្មោះថា ដុះដាលក្នុងធម៌ មានសីលជាដើម រហូតដល់អរហត្តមគ្គ ។ តែកាលសម្រេចអរហត្តផលហើយ ទើបឈ្មោះថាដល់នូវការដុះដាលបរិបូណ៌ ។ ឯគាថា មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា កុហនសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## នទីសោតសូត្រ

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស ត្រូវខ្សែទឹកស្ទឹងបន្សាត់ទៅ ដោយទាំងវត្ថុជាទីស្រឡាញ់ និងវត្ថុជាទីត្រេកអរ បុរសមានចក្ខុ ឈរនៅទៀបច្រាំង បានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកត្រូវខ្សែទឹកស្ទឹងបន្សាត់ទៅ ដោយទាំងវត្ថុជាទីស្រឡាញ់ និងវត្ថុជាទីត្រេកអរក៏ពិតមែនហើយ តែថា ក្នុងស្ទឹងនេះ មានអន្លង់នៅខាងក្រោមដ៏ប្រកបដោយរលក និងទឹកក្ដួចវិល មានសត្វសាហាវ និងអារក្សទឹក ( នៅចាំ ) នែបុរសដ៏ចម្រើន លុះអ្នកអណ្ដែតដល់អន្លង់នោះហើយ មុខជាដល់នូវសេចក្ដីស្លាប់ ឬនូវទុក្ខស្មើរស្លាប់មិនខាន ។ ម្នាលភិក្ខុទាំងឡាយ លុះបុរសនោះ បានឮសំឡេងបុរសនោះហើយ ក៏ព្យាយាមហែលដោយដៃ ដោយជើង ច្រាសទឹកមកវិញ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីឧបមានេះឯង តថាគតធ្វើ ដើម្បីឲ្យអ្នកទាំងឡាយ ដឹងច្បាស់នូវសេចក្ដី ។ សេចក្ដីអធិប្បាយនេះក្នុងពាក្យឧបមានុ៎ះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ខ្សែទឹកស្ទឹងនេះ ជាឈ្មោះនៃតណ្ហា ម្នាលភិក្ខុទាំងឡាយ ពាក្យថា វត្ថុជាទីស្រឡាញ់ និងវត្ថុជាទីត្រេកអរនេះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អន្លង់នៅខាងក្រោមនេះ ជាឈ្មោះនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកបដោយរលកនេះ ជាឈ្មោះនៃសេចក្ដីក្រោធ និងសេចក្ដីចង្អៀតចង្អល់ចិត្ត ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកបដោយទឹកក្ដួចវិលនេះ ជាឈ្មោះនៃកាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកប

ដោយសត្វសាហាវ និងអារក្សទឹកនេះ ជាឈ្មោះនៃមាតុគ្រាម ម្នាលភិក្ខុទាំង-ឡាយ ពាក្យថា ហែលប្រាសទឹកនេះ ជាឈ្មោះនៃនេក្ខម្មៈ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្យាយាមហែលដោយដៃ ដោយជើងនេះ ជាឈ្មោះនៃការប្រារព្ធព្យាយាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុរសមានចក្ខុឈរនៅទៀបច្រាំងនេះ ជាឈ្មោះនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

បុគ្គលណា កាលប្រាថ្នា នូវការក្សេមចាកយោគៈ ទៅខាងមុខ ត្រូវលះបង់នូវកាមទាំងឡាយ ព្រមទាំងសេចក្តីទុក្ខ ជាអ្នកមានសេចក្តីដឹងខ្លួន មានចិត្តផុតស្រឡះ ដោយប្រពៃហើយ បាននូវវិមុត្តិ ក្នុងអារម្មណ៍នោះៗ បុគ្គលនោះ តថាគតហៅថា អ្នកដល់នូវវេទ គឺមគ្គញាណ ហៅថា អ្នកមានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ ហៅថា អ្នកដល់នូវទីបំផុតនៃលោក ហៅថា អ្នកដល់នូវត្រើយ គឺព្រះនិព្វាន ។ សូត្រទី ១០ ។

# អដ្ឋកថា

## នទីសោតសូត្រទី ១០

ក្នុងនទីសោតសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១១១ ] សព្ទថា **សេយ្យថាបិ** ជានិបាត ប្រើក្នុងអត្ថនៃការប្រៀបធៀប សេចក្តីថា ដូចម្តេច ។ បទថា **នទិយា សោតេន ឱវុយ្ហេយ្យ** សេចក្តីថា គប្បីត្រូវខ្សែទឹករបស់ស្ទឹង ដែលមានក្រសែហូរខ្លួលខ្លាញ់បន្សាត់ទៅខាងក្រោម គឺនាំចុះទៅខាងក្រោម ។ បទថា **បិយរូបសាតរូបេន** សេចក្តីថា បុគ្គលនោះគិតថា អញនឹងកាច់យកកែវមណី និងមាស ឬរបស់ដែលគួរស្រឡាញ់ គឺទ្រព្យដែលជាឧបករណ៍ដល់ទ្រព្យដែលជាគ្រឿងត្រេកអរនៃចិត្ត ដែលមាននៅក្នុងស្ទឹងនោះ ឬលើត្រើយនាយនៃស្ទឹងនោះ លោតចុះទៅក្នុងស្ទឹងហើយ ត្រូវរសាត់ទៅតាមក្រសែទឹក ដែលមានសភាពគួរស្រឡាញ់ គួរពេញចិត្ត ។ សព្ទថា **កិញ្ចាបិ** ជានិបាត ប្រើក្នុងអត្ថថា រមែងទទួល តែមិនសរសើរ ។ សួរថា ទទួលដូចម្តេច មិនសរសើរអ្វី ឆ្លើយថា រមែងទទួលទ្រព្យដែលខ្លួនស្រឡាញ់ ដែលបុរសនោះប្រាថ្នាថា មាននៅក្នុងទីនោះ តែមិនសរសើរការទៅយ៉ាងនោះ ព្រោះជារបស់មានទោស មានពាក្យអធិប្បាយនេះថា នៃបុរសដ៏ចម្រើន សូម្បីរបស់ជាទីស្រឡាញ់ដែលអ្នកប្រាថ្នារកបានក្នុងទីនោះសោត តែព្រោះការទៅយ៉ាងនេះ នឹងមានទោសយ៉ាងនេះ គឺអ្នកនឹងត្រូវធ្លាក់ដល់អន្លង់ទឹកខាងក្រោម ហើយដល់នូវការស្លាប់ ឬសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ។

បទថា **អត្ថិ ចេត្ថ ហេដ្ឋា រហទោ** សេចក្តីថា ក្នុងភូមិភាគតាមក្រសែទឹកខាងក្រោមស្ទឹងនេះ ហូរទៅដល់ស្រះធំមួយ មានជម្រៅ និងទំហំធំពន់ពេក

ស្រះនោះ ឈ្មោះថា **សឩមិ** ព្រោះរលក គឺរលកធំៗ ដូចគ្នានឹងកំពូលភ្នំកែវមណីដែលបង្ហាញខ្លួនឡើង ត្រូវខ្យល់ផាត់មកជុំទិស ឈ្មោះថា **សាវដ្តោ** ព្រោះដល់ព្រមដោយខ្សែទឹក ដែលដូចគ្នានឹងមាត់ដ៏មានកម្លាំង ( ចាំត្របាក់ ) ព្រោះមានអន្លង់ទឹកធំបរិបូណ៌ ហូរក្ដួចវិលក្នុងទីនោះៗ ដោយអន្លង់ទឹកធំរបស់ស្ទឹងដែលហូរខ្លាំងមកអំពីមុន ក្នុងទីដែលមិនស្មើ ។ ឈ្មោះថា **សគ្គហោ សរក្ខសោ** ដោយអារក្ខទឹកដែលមានចិត្តកាច គួរខ្លាចពន់ពេក គ្រប់គ្រង ធ្វើសត្វទាំងឡាយដែលចុះក្នុងអន្លង់ទឹកនោះ ឲ្យជាចំណីរបស់ខ្លួនជាប្រចាំ ។

ម្យ៉ាងទៀត ឈ្មោះថា **សគ្គហោ** បានដល់ ត្រី និងមករកាចជាដើម ឈ្មោះថា **សរក្ខសោ** ព្រោះមានអារក្ខទឹកតាមដែលពោលហើយ ។ បទថា **យំ** បានដល់ អន្លង់ទឹកដែលមានភ័យចំពោះមុខយ៉ាងនេះ ។ បទថា **អម្ភោ បុរិស** ជាអាលបនៈ គឺត្រឹមតែពាក្យហៅ ។ បទថា **មរណំ វា និគច្ឆសិ** សេចក្ដីថា បុរសនោះត្រូវរលកទាំងនោះបន្សាត់ហើយ ឬធ្លាក់ទៅក្នុងទឹកវិលទាំងនោះហើយ មិនអាចងើបក្បាលឡើងបាន ដល់នូវការស្លាប់ ធ្លាក់ចូលក្នុងមាត់ត្រីកាច ឬមករទាំងនោះ ឬធ្លាក់ក្នុងកណ្ដាប់ដៃអារក្ខនោះហើយ នឹងដល់នៅការស្លាប់ខ្វះ ។ ម្យ៉ាងទៀត បើនៅមានអាយុ គឺនៅមានជីវិត រួចផុតអំពីសេចក្ដីស្លាប់ទៅបាន ក៏ដល់នូវភាពជាទុក្ខស្មើរតែនឹងស្លាប់ គឺសេចក្ដីទុក្ខមានការស្លាប់ជាប្រមាណ ព្រោះត្រូវរលកជាដើមនោះដែលកើតឡើងហើយ និងបោកបក់ហើយ ។ បទថា **បដិសោតំ វាយមេយ្យ** សេចក្ដីថា បុគ្គលនោះកាលមុនអណ្ដែតទៅតាមក្រសែទឹក តែលុះបានឮពាក្យពោលរបស់បុរសនោះ

ហើយ ក៏កើតសេចក្ដីខ្លាចជាកម្លាំង បានជ្រាបថា អនត្ថៈប្រាកដដល់ខ្លួនហើយ ដូចជាខ្លួនរមៀលចូលមាត់មច្ចុហើយ ទើបគួរបង្វិលខ្លួនត្រឡប់ ព្យាយាមប្រើដៃ និងជើង ដោយបន្ថែមឧស្សាហ៍ឡើងជាទ្វេគុណ មិនយូរ មិនឆាប់ ក៏នឹងដល់ត្រើយ ។ បទថា **អត្ថស្ស វិញ្ញាបនាយ** សេចក្ដីថា តថាគតធ្វើនូវការប្រៀបធៀប ដើម្បីឲ្យយល់អត្ថដែលឧបការៈដល់ការចាក់ធ្លុះនូវសច្ចៈទាំង ៤ ។ បទថា **អយមេវេត្ថ អត្ថោ** បានដល់ ការឧបមេយ្យដែលទាញយកឧបមាមកដើម្បីយល់នេះឯង គឺដែលកំពុងពោលក្នុងឥឡូវនេះ បានដល់ ដែលតថាគតបំណាងយកហើយក្នុងទីនេះ ។

ក្នុងពាក្យថា **តណ្ហាយេតំ អធិវចនំ** នេះ គប្បីជ្រាបការបេបាសអន្ទើលនៃក្រសែតណ្ហាដោយអាការ ៤ យ៉ាង គឺដោយការហូរចេញមកតាមលំដាប់ ១ ដោយការហូរទៅមិនដាច់ ១ ដោយជាហេតុឲ្យលិចចុះ ១ ដោយធ្វួងបានកម្រ ១ ។ ឧបមាទី ១ ថា កាលមហាមេឃខាងលើបង្អុរនូវភ្លៀងមក ទឹកក៏ពេញជ្រោះជ្រងជ្រលងដងអូរជាដើមនោះហើយ ក៏ពេញអូរ ឃ្លាតចាកអូរនោះហើយ ក៏ពេញស្ទឹង ចេញអំពីស្ទឹងនោះ ក៏ហូរទៅកាន់ទន្លេ ក្លាយជាជំនន់ទឹកធំហូរទៅ សត្វលោកហៅថា **នទីសោត** គឺក្រសែទឹក យ៉ាងណាកាលលោកក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម មានប្រភេទជាអនេកដោយអំណាចនៃអារម្មណ៍ ដែលមានខាងក្នុង និងខាងក្រៅជាដើម ក៏ដូច្នោះដូចគ្នា កើតឡើងហើយ ដល់នូវសេចក្ដីចម្រើនក្រៃលែងតាមលំដាប់ ព្រះមានព្រះភាគត្រាស់ហៅថា ក្រសែតណ្ហា ។ មួយវិញទៀត ក្រសែទឹកតាំងពីហូរមក

រហូតដល់សមុទ្រ កាលមិនមានបច្ច័យដែលឲ្យក្រសែទឹកនោះដាច់ ក៏មិនដាច់ ហូរជាប់តាមគ្នាទៅតាមលំដាប់ យ៉ាងណា សូម្បីក្រសែតណ្ហា ក៏ដូច្នោះដូចគ្នា ផ្តើមតាំងពីហូរមក កាលមិនមានបច្ច័យឲ្យខ្សែទឹកដាច់ ក៏មិនដាច់ បែរមុខទៅសមុទ្រ គឺអបាយ ហូរទៅជាប់គ្នាមិនដាច់ ។ តែក្រសែទឹកឲ្យសត្វដែលធ្លាក់ចុះទៅក្នុងក្រសែលិចចុះ មិនឲ្យងើបក្បាលឡើងបាន ឲ្យដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខទៀបនឹងស្លាប់ យ៉ាងណា សូម្បីក្រសែតណ្ហា ក៏ដូច្នោះ នឹងឲ្យសត្វដែលធ្លាក់ចុះទៅក្នុងក្រសែរបស់ខ្លួនលិចចុះទៅ មិនឲ្យងើបក្បាល គឺបញ្ញាឡើងបាន ឲ្យដល់នូវការស្លាប់ខ្លះ សេចក្តីទុក្ខស្មើនឹងស្លាប់ខ្លះ ដោយការកាត់ឫសកុសលធម៌ឲ្យដាច់ទៅ និងដោយការចូលទៅកាន់សង្កិលេសធម៌ ។

ម្យ៉ាងទៀត ក្រសែរបស់ស្ទឹងហូរទៅដោយភាពជាអន្លង់មហាណ្ណព ឈ្មោះថា ឆ្លងបានដោយលំបាក ព្រោះបុគ្គលឆ្លងត្រូវអាស្រ័យបុរសឈ្លាស ដើម្បីចងក្បូន ឬធ្វើទូកដើម្បីឆ្លង សាងអធ្យាស្រ័យដើម្បីទៅកាន់ត្រើយនាយ ហើយធ្វើនូវសេចក្តីព្យាយាមដែលកើតអំពីអធ្យាស្រ័យនោះ ទើបឆ្លងទៅបាន មិនមែនបុគ្គលដែលមានព្យាយាមធូរថយឆ្លងទៅបានឡើយ យ៉ាងណា ក្រសែតណ្ហា ដែលដូចជាអន្លង់ទឹក គឺកាម និងអន្លង់ទឹក គឺភព ក៏ដូច្នោះ ឈ្មោះថាឆ្លងបានដោយក្រ ព្រោះជាអ្នកមានបញ្ញាជាគ្រឿងរក្សាខ្លួន ដើម្បីបំពេញសីលសិវរៈ សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ត្រូវតាំងនូវអធ្យាស្រ័យថា អញនឹងសម្រេចអរហត្តផល ហើយអាស្រ័យកល្យាណមិត្រឡើងទូក គឺសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ធ្វើនូវសេចក្តីព្យាយាមដោយប្រពៃ ទើបឆ្លងបាន

មិនមែនបុគ្គលដែលមានព្យាយាមថោកថយ ឆ្លងទៅបានឡើយ ។ គួរយល់ភាពដែលតណ្ហា ដូចគ្នានឹងក្រសែរបស់ស្ទឹង ដោយអាការ ៤ យ៉ាង គឺដោយការហូរចេញទៅតាមលំដាប់ ១ ដោយហូរជាប់គ្នាមិនដាច់ ១ ដោយការឲ្យលិចចុះ ១ ដោយការឆ្លងបានដោយកម្រ ១ ដូចពណ៌នាមកនេះឯង ។

បទថា **បិយរូបំសាតរូបំ** សេចក្តីថា រូបដែលមានសភាពគួរស្រឡាញ់ក្នុងកំណើតដែលគួរស្រឡាញ់ ឈ្មោះថា **បិយរូប** រូបដែលមានសភាពឆ្ងាញ់ក្នុងកំណើតដែលឆ្ងាញ់ ឈ្មោះថា **សាតរូប** អធិប្បាយថា មានសភាពគួរប្រាថ្នា ។ បទថា **ឆន្នេតំ** កាត់បទជា **ឆន្នំ ឯតំ** ពាក្យនេះជាឈ្មោះរបស់អាយតនៈខាងក្នុង ៦ យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អជ្ឈត្តិកានំ** នេះ ដូចតទៅ អាយតនៈទាំងឡាយ ឈ្មោះថា **អជ្ឈត្តិក** ព្រោះដូចប្រព្រឹត្តទៅហើយ ដោយធ្វើខ្លួនឯងឲ្យជាធំ ដោយបំណងថា យើងទាំងឡាយនឹងដល់នូវការប្រកាន់ថាជាអត្តាយ៉ាងនេះ ។ ក្នុងពាក្យថា **អជ្ឈត្តិកានំ** នោះ អជ្ឈត្តខាងក្នុងមាន ៤ យ៉ាង គឺគោចរអជ្ឈត្ត ( អារម្មណ៍ខាងក្នុង ) ១ និយកអជ្ឈត្ត ( ខាងក្នុងជារបស់ខ្លួន ) ១ វិសយអជ្ឈត្ត ( វិស័យខាងក្នុង ) ១ អជ្ឈត្តអជ្ឈត្ត ( ខាងក្នុង ) ១ បណ្តាអជ្ឈត្ត ៤ នោះ អជ្ឈត្តដែលត្រាស់ក្នុងពាក្យទាំងឡាយយ៉ាងនេះថា **អជ្ឈត្តរតោ សមាហិតោ** ជាអ្នកត្រេកអរក្នុងការចម្រើនកម្មដ្ឋាន ដែលមានក្នុងខ្លួន ជាអ្នកមានចិត្តតម្កល់មាំ ឈ្មោះថា **គោចរអជ្ឈត្ត** អជ្ឈត្តនេះដែលមកហើយថា **អជ្ឈត្តំ សម្បសាទនំ** ការជ្រះថ្លាខាងក្នុង ឈ្មោះថា **និយក-**

**អជ្ឈត្ត** ។ *អជ្ឈត្តដែលមកហើយយ៉ាងនេះថា* **សព្វនិមិត្តានំ អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរតិ** *បានសម្រេចនូវសុញ្ញតផលសមាបត្តិក្នុងសន្តាន ព្រោះមិនធ្វើទុកក្នុងចិត្តនូវសង្ខតនិមិត្តទាំងអស់ ( មានរូបជាដើម ) ឈ្មោះថា* **វិសយអជ្ឈត្ត** ។ *អជ្ឈត្តដែលត្រាស់ក្នុងពាក្យនេះថា* **អជ្ឈត្តិកា ធម្មា ពាហិរា ធម្មា** *ធម៌ទាំងឡាយដែលជាខាងក្នុង ធម៌ទាំងឡាយដែលជាខាងក្រៅ ឈ្មោះថា* **អជ្ឈត្តអជ្ឈត្ត** ។ *ក្នុងទីនេះ ទ្រង់បំណងយកអជ្ឈត្តចុងក្រោយនេះប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកពោលថា អជ្ឈត្តនោះឯង ឈ្មោះថា* **អជ្ឈត្តិក** ។ *ម្យ៉ាងទៀត អាយតនៈទាំងឡាយ មានចក្ខុជាដើម មាននៅខាងក្នុងប៉ុណ្ណោះ ដូចក្នុងប្រយោគទាំងឡាយថា* **អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា** *ធម៌ទាំងឡាយជាខាងក្នុង ធម៌ទាំងឡាយជាខាងក្រៅ ឈ្មោះថា* **អជ្ឈត្តិក** *ព្រោះអត្ថតាមដែលពោលមកហើយនោះឯង ។ បទថា* **អាយតនានំ** *នោះ ជាឈ្មោះរបស់អាយតនៈ ដែលប្រព្រឹត្តទៅខាងក្នុងទាំងនោះ ។*

*ក្នុងពាក្យថា* **អាយតនានំ** *នេះ មានអធិប្បាយថា ធម្មជាតទាំងឡាយ ឈ្មោះថា អាយតនៈ ព្រោះជាទីកើត ១ ព្រោះជាទីសាយកាយទៅនៃវត្ថុដែលគួរត្រេកអរ ព្រោះនាំទៅកាន់វដ្តៈដែលយឺតយូរ ១ ព្រោះថា ធម៌ទាំងឡាយ គឺចិត្ត និងចេតសិកមានទ្វារនោះៗ បណ្តាចក្ខុទ្វារជាដើមដែលជាទីតាំង ចិត្តរមែងកើតឡើង គឺតាំងឡើង បានដល់ បន្ត ដោយអត្ថថា ព្យាយាមតាមកិច្ចរៀងៗ ខ្លួន មានការសោយអារម្មណ៍ជាដើម អាយតនៈទាំងនេះ រមែងបន្ត គឺពង្រីកធម៌ទាំងនោះ ដែលជាវត្ថុគួរត្រេកអរ ម្យ៉ាងទៀត វដ្តទុក្ខណាដែល*

វិលទៅក្នុងសង្សារដែលមានទីបំផុតខាងដើម ដែលបុគ្គលតាមដឹងមិនបាន គឺយូរក្រៃលែង អាយតនៈទាំងឡាយនឹងនាំទៅ គឺវិលទៅកាន់វដ្តទុក្ខនោះ ធម៌ទាំងនេះ ព្រះមានព្រះភាគត្រាស់ហៅថា **អាយតន** ដោយប្រការទាំងពួង ព្រោះជាទីកើត ព្រោះពង្រីកវត្ថុដែលគួរត្រេកអរ និងព្រោះនាំទៅកាន់វដ្ដៈដែលវែងឆ្ងាយ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាទីនៅអាស្រ័យ ១ ព្រោះអត្ថថា ជាប្រភពកើត ១ ព្រោះអត្ថថា ជាទីប្រជុំគ្នា ១ ព្រោះអត្ថថា ជាដែនកំណើត ១ ព្រោះអត្ថថា ជាហេតុ ១ ។ ពិតហើយ ក្នុងផ្លូវលោក ទីនៅអាស្រ័យ ហៅថា **អាយតន** ដូចក្នុងប្រយោគទាំងឡាយថា **ឥស្សរាយតន** គឺទីកដីនៃព្រះឥស្សរ **ទេវាយតន** ទីកដីរបស់ទេវតា ។ ប្រភពកើត ហៅថា **អាយតន** ដូចក្នុងប្រយោគទាំងឡាយថា **សុវណ្ណាយតនំ** ប្រភពកើតមាស **រតនាយតនំ** ប្រភពកើតនៃកែវ ។

តែក្នុងផ្លូវសាសនា ទីដែលប្រជុំគ្នា ហៅថា **អាយតន** ដូចក្នុងគាថាទាំងឡាយថា

បក្សីទាំងឡាយ ប្រជុំគ្នាក្នុងទីដែលគួរជាទីត្រេកអរនៃចិត្ត ។

ដែនកំណើត ហៅថា **អាយតន** ដូចក្នុងប្រយោគទាំងឡាយថា **ទក្ខិណាបថ** ជាទីកើតនៃគោទាំងឡាយ ។ ហេតុ ហៅថា **អាយតន** ដូចក្នុងប្រយោគទាំងឡាយថា ចូលដល់ការៈដែលនឹងត្រូវសិក្សាក្នុងទីនោះៗ ឯងកាលបើមានហេតុដែលសមគួរ ។ ម្យ៉ាងទៀត ធម៌ គឺចិត្ត និងចេតសិកនោះ

អាស្រ័យចក្ខុទ្វារជាដើម ព្រោះមានព្រឹត្តិកម្ម ទាក់ទងនឹងចក្ខុទ្វារជាដើមនោះ ព្រោះហេតុនោះ ទើបចក្ខុទ្វារជាដើមនោះ ឈ្មោះថា ជាទីនៅអាស្រ័យនៃធម៌ គឺចិត្ត និងចេតសិកទាំងនោះ ធម៌ទាំងនោះ ដេរជាសក្កុងចក្ខុទ្វារជាដើមនោះ ព្រោះអាស្រ័យចក្ខុទ្វារជាដើមនោះ ព្រោះហេតុនោះ ទើបចក្ខុទ្វារជាដើម ឈ្មោះថា ជាប្រភពកើតនៃធម៌ទាំងនោះ ។ **អាយតន** ឈ្មោះថា ជាស្ថានទីប្រជុំ ព្រោះជាទីមករួមគ្នានៃធម៌ទាំងឡាយក្នុងចក្ខុទ្វារជាដើមនោះ ដោយជាវត្ថុ និងជាទ្វារ និងឈ្មោះថា ជាដែនកំណើត ព្រោះធម៌ទាំងនោះកើតឡើងត្រង់ចក្ខុ-ទ្វារជាដើមនោះឯង ដោយជាទីអាស្រ័យនៃធម៌ទាំងនោះ ទាំងឈ្មោះថាជាហេតុ ព្រោះកាលចក្ខុជាដើមមិនមាន ធម៌ គឺចិត្ត និងចេតសិកទាំងនោះ ក៏មិនមាន ទើបឈ្មោះថា ចក្ខុទ្វារជាដើម ព្រះមានព្រះភាគត្រាស់ហៅថា អាតយន ព្រោះហេតុទាំងនេះ គឺព្រោះអត្ថថា ជាទីនៅអាស្រ័យ ១ ព្រោះអត្ថថា ជាប្រភពកើត ១ ព្រោះអត្ថថា ជាទីប្រជុំ ១ ព្រោះអត្ថថា ជាដែនកំណើត ១ ព្រោះអត្ថថា ជាហេតុ ១ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ពាក្យថា **អាយតនាធំ** នេះ ជាឈ្មោះរបស់អាយតនៈខាងក្នុងទាំង ៦ ដូច្នេះ ។

បើធម៌ទាំងឡាយ មានរូបជាដើម ព្រះមានព្រះភាគត្រាស់ ដោយជាបិយរូប សាតរូប ព្រោះជាទីតាំងនៃតណ្ហាថា តណ្ហានេះ កាលនឹងកើតក៏កើតឡើងត្រង់រូបដែលជាបិយរូប សាតរូប ក្នុងលោកហើយសោត ទោះជាដូច្នោះ ព្រះមានព្រះភាគក៏ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា វត្ថុជាទីស្រឡាញ់ និងវត្ថុជាទីត្រេកអរនេះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ដូច្នេះ ។ ដើម្បីទ្រង់សម្តែងថា ចក្ខុជាដើមសមនឹងពង្រីកសេចក្តីថា ជាបិយរូប

សាតរូបដែលល្អពន់ពេក ព្រោះជាទីតាំងនៃសេចក្ដីស្នេហាយ៉ាងក្រៃលែង ដោយន័យជាដើមថា ចក្ខុរបស់អញ សោតៈរបស់អញ ព្រោះផុតចក្ខុជាដើមទៅហើយ ការបញ្ញត្តថាអត្តា ក៏មិនមាន ។

កាមធាតុ ព្រះមានព្រះភាគត្រាស់ហៅថា ជារបស់ទាប ក្នុងពាក្យថា **ឱរម្ភាគិយានំ** នេះ ។ អកុសលធម៌ដែលទាក់ទងដោយកាមធាតុនោះ ឈ្មោះថា **ឱរម្ភាគ** ។ សំយោជនៈដែលប្រកបដោយចំណែកខាងក្រោមនោះ ដោយភាពជាបច្ច័យ ព្រោះដូច្នោះ ទើបឈ្មោះថា **ឱរម្ភាគិយ** ។ កិលេសជាត ឈ្មោះថា **សំយោជន** ព្រោះប្រកបបុគ្គលដែលមានកិលេសជាតក្នុងវដ្ដៈ ។ ពាក្យនេះ ជាឈ្មោះរបស់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស កាមរាគ និងព្យាបាទ អធិប្បាយថា សំយោជនៈទាំងនោះ ជាបច្ច័យនៃសង្ខារទាំងឡាយដែលចូលដល់កាមភព ចងសត្វទាំងឡាយ ដោយកាមភពដែលជាផ្នែកខាងក្រោម ព្រោះជារបស់ទាប ជារបស់អាក្រក់ជាងរូបធាតុ និងអរូបធាតុ ដោយពាក្យថា **ឱរម្ភាគិយា** នោះឯង គប្បីជ្រាបថា ទ្រង់សម្ដែងដល់ភាពដែលសំយោជនៈទាំងនោះ ដូចគ្នានឹងអន្ទង់ទឹកដែលនៅខាងក្រោម ។

ម្នាលភិក្ខុទាំងឡាយ បទថា **ឧម្មិភយន្តិ ខោ ភិក្ខវេ កោធុបាយាសស្សេតំ អធិវចនំ** ឈ្មោះថា ភ័យ ព្រោះជាដែនគួរឲ្យខ្លាច ។ ភ័យ គឺរលក ព្រោះដូច្នោះ ទើបឈ្មោះថា **ឧម្មិភយំ** ។ ឈ្មោះថា **កោធំ** ព្រោះអត្ថថា អាក់អន់ ។ សេចក្ដីក្រោធនោះឯង ឈ្មោះថា **ឧបាយាស** ព្រោះអត្ថថា

---

១- បិដកខ្មែរ ជាសឧមិ ។

តោងយ៉ាងស្អិត ដោយការបង្អៀតបង្អល់ចិត្ត និងកាយ និងការកើតនូវការញាប់ញ័រ ។ ក្នុងពាក្យថា **ឧបាយាស** នេះ គប្បីជ្រាបភាពដែលសេចក្តីក្រោធ និងការបង្អៀតបង្អល់ ដូចគ្នានឹងរលក ព្រោះរមៀលទៅសង្កត់សត្វដែលមានកម្លាំងស្មើខ្លួនច្រើនវារៈ មិនឲ្យងើបក្បាលឡើងមកបាន ហើយឲ្យដល់នូវការវិនាសអន្តរាយ ។

ម្យ៉ាងទៀត គប្បីជ្រាបភាពដែលកាមគុណទាំងឡាយ ដូចគ្នានឹងទឹកក្តួច ព្រោះឲ្យសត្វទាំងឡាយ ដែលត្រូវកិលេសគ្របសង្កត់ហើយ អន្ទោលទៅក្នុងអត្តា ពោល គឺអារម្មណ៍ មានរូបដែលត្រេកអរជាដើមយ៉ាងនេះ គឺចាករូបនេះទៅរូបនោះ និងចាករូបនោះមករូបនេះ ហើយឲ្យវិលទៅ ដោយមិនឲ្យចិត្តកើតឡើងក្នុងនេក្ខម្មៈដែលជាវត្ថុខាងក្រៅចាកកាមគុណនោះ ហើយឲ្យដល់នូវសេចក្តីវិនាសទៅ ។ ឧបមាដូចអារក្ខទឹកចាប់សត្វបរិភោគ និងសមុទ្ទចាប់មនុស្ស ដែលចូលទៅកាន់ដែនរបស់ខ្លួន ដែលមិនមានការរវាំងប្រយ័ត្ន ទោះបីមនុស្សដែលមិនទៅក្នុងដែនរបស់ខ្លួន ក៏នាំចូលទៅកាន់ដែនដោយមាយារបស់អារក្ខ ហើយធ្វើបុគ្គលដែលអស់អំណាច មិនឲ្យជួយខ្លួនឯងបាន ដោយសម្តែងរូបដែលគួរខ្លាចជាដើម ឬ ថ្វិតថ្វម ប្រណិប័តន៍ដោយពណ៌សម្បុរ កម្លាំង ភោគៈ យស និងសេចក្តីសុខ ហើយឲ្យដល់នូវសេចក្តីវិនាសធំយ៉ាងណា សូម្បីមាតុគ្រាម ក៏ដូច្នោះ រមែងចាប់បុរសដែលមិនរឹងប៉ឹង វៀរចាកយោនិសោមនសិការ ដោយអាកប្បកិរិយា មានការញញឹមរបស់ខ្លួន ដែលជាមាយារបស់ស្ត្រី ទោះបីបុរសដែលមានជាតិរឹងប៉ឹង ក៏លួងលោម

ដោយមាយាស្រ្តី ដោយការលួងលោម ដោយរូបរបស់ខ្លួនជាដើម ធ្វើបុរស ដែលអស់អំណាចឲ្យជាបុគ្គលមិនអាចញ៉ាំងធម៌ដែលជាឧបការៈដល់ខ្លួន មាន សីលជាដើមឲ្យដល់ព្រមបាន ទំនុកបម្រុងដោយការសរសើរគុណជាដើម រួច ឲ្យដល់នូវសេចក្តីវិនាសយ៉ាងធំ គប្បីជ្រាបភាពដែលមាតុគ្រាម ដូចគ្នានឹង អារក្ខចាប់សត្វ ដូចពណ៌នាមកនេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ប្រកបដោយទឹកកួចវិលនេះឯង ជា ឈ្មោះរបស់កាមគុណ ៥ ឯពាក្យថា ប្រកបដោយសត្វសាហាវ និងអារក្ស ទឹកនេះឯង ជាឈ្មោះរបស់មាតុគ្រាម ។

បទថា **បដិសោតោតិ ខោ ភិក្ខវេ នេក្ខម្មស្សេតំ អធិវចនំ** នេះ ការ បួស បឋមជ្ឈានមួយអន្លើដោយឧបចារៈ វិបស្សនាបញ្ញា និព្វាន ឈ្មោះថា នេក្ខម្មៈ ។ កុសលធម៌ទាំងអស់ ក៏ឈ្មោះថា នេក្ខម្មៈ សមដូចព្រះតម្រាស់ថា កុសលធម៌ទាំងអស់ គឺបព្វជ្ជា បឋមជ្ឈាន និព្វាន និងវិបស្សនា តថាគត ហៅថា នេក្ខម្មៈ ។

អ្នកសិក្សាគប្បីជ្រាបភាពដែលបព្វជ្ជាជាដើមនេះ ដូចគ្នានឹងការប្រព្រឹត្ត ប្រាសក្រសែ ដោយការប្រាសក្រសែនៃតណ្ហា ព្រោះថា ដោយការមិនប្លែក គ្នាហើយ ធម្មវិន័យនេះ ឈ្មោះថា នេក្ខម្មៈ ។ ការតាំងចិត្តរបស់បុគ្គលនោះ ១ បព្វជ្ជារបស់បុគ្គលនោះ ១ ធម្មវិន័យ ១ ព្រះមានព្រះភាគត្រាស់ហៅថា ប្រាសនូវក្រសែតណ្ហា សមតាមព្រះមានព្រះភាគត្រាស់ពាក្យនេះនៅក្នុង សំយុត្តនិកាយ សគាថវគ្គថា

សត្វទាំងឡាយត្រេកអរដោយរាគៈ មានគំនរងងឹត គឺអវិជ្ជាបិទបាំង រមែងមិនឃើញនូវធម៌ ដែលប្រព្រឹត្តច្រាសខ្សែទឹក ជាធម៌ល្អិតជ្រាលជ្រៅ សត្វឃើញបានដោយកម្រ ជាធម៌ដ៏តូចឆ្មារ ដូច្នេះ ។

បទថា **វីរិយារម្ភស្ស** សេចក្តីថា ជាអ្នកមានសេចក្តីព្យាយាម ប្រកបដោយសម្មប្បធាន ៤ យ៉ាង ការប្រហាក់ប្រហែលគ្នា នៃការឆ្លងផុតក្រសែតណ្ហា បែកចេញជាកាមោឃៈជាដើមនៃព្រះយោគាវចរនោះ និងសេចក្តីព្យាយាមដើម្បីឆ្លងផុតក្រសែទឹករបស់ចតុរង្គិកសេនា ដោយដៃ ដោយជើងប្រាកដច្បាស់ហើយនោះឯង ។ ការដូចគ្នានៃបុរសដែលមានភ្នែក ឈរត្រង់មាត់ស្ទឹងដែលមានក្រសែខ្វល់ខ្វាញ់ ជាមួយនឹងព្រះមានព្រះភាគ ដែលមានចក្ខុ ៥ ប្រការ ដែលយើងឆ្លងឱឃៈទាំង ៤ មានកាមោឃៈជាដើមបានហើយ ប្រថាប់ឈរលើគោក គឺព្រះនិព្វានដែលជាត្រើយនាយនៃអន្លង់ទឹកនោះ ជាវត្ថុដែលជាក់ច្បាស់ហើយដូចគ្នា ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចក្ខុមា បុរិសោ ។បេ។ សម្ពុទ្ធស្ស** ដូច្នេះ ។

ក្នុងរឿងនោះ មានពាក្យប្រៀបធៀប និងឧបមេយ្យដូចតទៅនេះ ក្រសែតណ្ហាកំពុងហូរទៅ ដោយការហូរជាប់តគ្នា ដូចក្រសែទឹកក្នុងស្ទឹង ។ សត្វដែលត្រូវក្រសែតណ្ហាបន្សាត់ទៅ ដោយការវិលវល់ក្នុងសង្សារវដ្ត ដែលមិនមានទីបំផុតខាងដើម ដូចបុរសត្រូវក្រសែទឹកបន្សាត់ទៅ ។ ការប្រកាន់ក្នុងចក្ខុជារបស់ព្រះយោគាវចរនោះ ដូចគ្នានឹងការប្រកាន់មាំក្នុងបិយរូប សាតរូបនោះ

របស់បុរសនោះ ។ ការជំនុំនៃសំយោជនៈខាងដើម ៥ យ៉ាង ដែលចង្អៀត ចង្អល់ទៅដោយការក្រោធ ការអាក់អន់ចិត្ត កាមគុណ ៥ និងមាតុគ្រាម ដូចអន្ទង់ទឹកខាងក្រោម ដែលមានរលក មានទឹកក្ខួច និងអារក្ខទឹក ។ ព្រះមានព្រះភាគទ្រង់មានសមន្តចក្ខុ ទ្រង់ជ្រាបទោសនៃសង្សារវដ្តទាំងអស់ និងញេយ្យធម៌ទាំងមូល ហើយទ្រង់ប្រថាប់ឈរលើគោក គឺព្រះនិព្វាន ដែលជាត្រើយនាយនៃក្រសែតណ្ហា ដូចបុរសមានភ្នែកដឹងអត្ថនោះ តាមសេចក្ដីពិត ហើយឈរត្រង់ត្រើយនាយនៃក្រសែស្ទឹងនោះ ។ ការដែលព្រះមានព្រះភាគទ្រង់អធិប្បាយតណ្ហាជាដើម និងទោសរបស់តណ្ហានោះឲ្យជាក់ច្បាស់ ដោយព្រះមហាករុណាដល់សត្វ ដែលត្រូវក្រសែតណ្ហាបន្សាត់ទៅ ដូចការដែលបុរសមានចក្ខុប្រាប់អន្ទង់ទឹក និងទោសរបស់អន្ទង់ទឹកដោយសេចក្ដីករុណាដល់បុរសនោះ ដែលត្រូវបន្សាត់ទៅក្នុងក្រសែនៃស្ទឹងនោះ ។ ការចូលដល់អបាយក្ដី ការចូលដល់ទុក្ខក្នុងសុគតិក្ដី របស់បុគ្គលដែលមិនទទួលយកព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចការដល់នូវសេចក្ដីស្លាប់ និងការជួបនូវសេចក្ដីទុក្ខស្មើរនឹងស្លាប់ក្នុងអន្ទង់ទឹកនោះ របស់បុរសនោះ ដែលមិនជឿពាក្យរបស់បុរសដែលមានភ្នែកនោះ ហើយទៅតាមក្រសែទឹក ។ ម្យ៉ាងទៀត ការទទួលយកព្រះតម្រាស់របស់ព្រះមានព្រះភាគ ហើយប្រារព្ធសេចក្ដីព្យាយាមដោយអំណាចនៃនេក្ខម្មៈ មានការពិចារណាទោសក្នុងតណ្ហាជាដើម ហើយបួស ប្រព្រឹត្តប្រាសនៃក្រសែតណ្ហាជាដើម និងការឈានកន្លងផុតក្រសែតណ្ហា ដោយការប្រារព្ធនូវសេចក្ដីព្យាយាមនោះឯង របស់អ្នកប្រារព្ធ

*សេចក្ដីព្យាយាម គឺការដល់ត្រើយ ពោល គឺព្រះនិព្វាន ហើយនៅជាសុខតាមគាប់ចិត្ត ដោយអំណាចអរហត្តផលសមាបត្តិ ដូចការជឿពាក្យរបស់បុរសនោះ ដែលចង្អុលបង្ហាញនូវទោសឲ្យឃើញហើយ ធ្វើសេចក្ដីព្យាយាមដោយដៃ និងជើង និងដូចការដល់ត្រើយនាយ ដោយសេចក្ដីព្យាយាមនោះហើយ ទៅកាន់ទីដែលខ្លួនត្រូវការបានយ៉ាងស្រួល ដូច្នេះ ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា* **សហាបិ ទុក្ខេន ជហេយ្យ កាមេ** *សេចក្ដីថា ភិក្ខុ កាលធ្វើសេចក្ដីព្យាយាមរឿយៗ ក្នុងសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដើម្បីសម្រេចឈាន និងមគ្គ បើបណ្ដាបដិបទាទាំងនោះ បុព្វភាគបដិបទាសម្រេចបានដោយលំបាកដោយកម្រ គឺចុះកាន់វិថីមិនបានដោយងាយ ដោយបុព្វភាគភាវនា ព្រោះកិលេសទាំងឡាយនៅមានកម្លាំង ឬព្រោះឥន្ទ្រិយទាំងឡាយ មិនទាន់ចាស់ក្លាសោត កាលបើដូច្នោះ គប្បីលះកាមបាន មួយអន្លើដោយសេចក្ដីលំបាក គឺគប្បីប្រើបឋមជ្ឈានសង្កត់បណ្ដើរៗ ប្រើតតិយមគ្គកាត់ផ្ដាច់ទៅបណ្ដើរ នឹងលះកាម-កិលេសបាន ។ ពាក្យថា* **សហាបិ ទុក្ខេន ជហេយ្យ កាមេ** *នោះ ព្រះមានព្រះភាគទ្រង់សម្ដែងឈាន និងមគ្គ ដែលជាទុក្ខាបដិបទា ។ បទថា* **យោគក្ខេមំ អាយតឹ បត្ថយានោ** *សេចក្ដីថា ប្រាថ្នា គឺបំណងអរហត្តផលដែលខ្លួនមិនទាន់ដល់ ។*

*ពិតហើយ ក្នុងសេចក្ដីនេះ មានអធិប្បាយដូចតទៅនេះ ភិក្ខុនោះប្រាថ្នាថា បើអាត្មាអញសម្រេចឈាន និងមគ្គខាងលើបានដោយកម្រ ដោយលំបាក*

ក្នុងឥឡូវនេះសោត អញនឹងអាស្រ័យឈាននេះ និងមគ្គខាងលើនេះហើយ សម្រេចអរហត្តផល ហើយនឹងជាបុគ្គលដែលសម្រេចកិច្ច លះទុក្ខទាំងពួង បាន ដូច្នេះហើយ គប្បីលះកាមទាំងឡាយដោយឈានជាដើមបាន ដោយមិន លំបាក ។ ម្យ៉ាងទៀត បុគ្គលណាច្រើនដោយកាមវិតក្ក បួសបដិបត្តិជម្រះនូវ សីល ឬបដិបទាខាងដើមនៃឈានជាដើម ដោយអំណាចកល្យាណមិត្ត មាន ទឹកភ្នែកដោកមុខ សង្កត់នូវវិតក្កដោយកម្រ ដោយលំបាក ព្រះមានព្រះភាគ ត្រាស់សំដៅយកបុគ្គលនោះថា គប្បីលះកាមដោយសេចក្ដីលំបាក ព្រោះថា កុលបុត្រនោះ កាលលះកាមបានដោយលំបាក ឲ្យឈានកើតឡើងហើយ ធ្វើឈាននោះឲ្យជាបាទ ពិចារណាឃើញ គប្បីតាំងនៅក្នុងអរហត្តផលតាម លំដាប់ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាលប្រាថ្នានូវ ការក្សេមចាកយោគៈទៅខាងមុខ ។

បទថា **សម្មប្បជានោ** សេចក្ដីថា ដឹងទូទៅដោយប្រពៃនោះឯង ដោយមគ្គបញ្ញា ដែលប្រកបដោយវិបស្សនា ។ បទថា **សុវិមុត្តចិត្តោ** បានដល់ ជាអ្នកមានចិត្តរួចផុតហើយដោយល្អ ដោយផលវិមុត្តិក្នុងលំដាប់នៃ ការសម្រេចអរិយមគ្គនោះ ។ បទថា **វិមុត្តិយា ផស្សយេ តត្ថ តត្ថ** សេចក្ដីថា គប្បីសម្ផស្ស គឺពាល់ត្រូវ បានដល់ សម្រេច ដោយអត្ថថា ធ្វើ ឲ្យជាក់ច្បាស់នូវវិមុត្តិ គឺព្រះនិព្វានក្នុងពេលសម្រេចមគ្គផលនោះៗ ។ ពិត ហើយ ពាក្យថា **វិមុត្តិយា** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថទុតិយាវិភត្តិ ។ ម្យ៉ាងទៀត គប្បីសម្ផស្ស គឺពាល់ត្រូវ បានដល់ ដល់នូវមគ្គចិត្តរបស់ខ្លួន

ដោយវិមុត្តិ ដែលជាអារម្មណ៍នោះ ក្នុងពេលនោះៗ គឺក្នុងពេលចូលផលសមាបត្តិនោះៗ អធិប្បាយថា គប្បីនៅដោយផលសមាបត្តិដែលឈមចុះកាន់ក្នុងព្រះនិព្វាន ។ បទថា **ស វេទគូ** សេចក្តីថា បុគ្គលនោះ ឈ្មោះថា ជាអ្នកចប់វេទ ព្រោះដល់ គឺចាក់ធ្លុះនូវសច្ចៈ ៤ ដោយមគ្គញាណ ពោល គឺវេទ ។ បទថា **លោកន្តគូ** សេចក្តីថា ជាអ្នកដល់នូវទីបំផុតដែនខន្ធលោក ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថានីវរណសូត្រទី ១០ ចប់**

# សុត្តន្តបិដក

## ចរសូត្រ

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុកំពុងដើរទៅ បើមានកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើង បើភិក្ខុទទួលនូវវិតក្កនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងដើរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមិនមានព្យាយាមដុតកម្តៅកិលេស មិនជាអ្នកក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរ បើមានកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើង បើភិក្ខុទទួលនូវវិតក្កនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យ

វិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុ កំពុងឈរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមិនមាន ព្យាយាមដុតកម្តៅកិលេស មិនជាអ្នកក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ច-កាល មិនមានព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយ បើ មានកាមវិតក្កី ព្យាបាទវិតក្កី វិហឹសាវិតក្កី កើតឡើង បើភិក្ខុទទួល នូវវិតក្កនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការ សាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងអង្គុយក៏ដោយ តែមាន សភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមិនមានព្យាយាមដុតកម្តៅកិលេស មិន ជាអ្នកក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។ ម្នាល ភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេក កំពុងភ្ញាក់ ( ដឹងខ្លួន ) បើមានកាមវិតក្កី ព្យាបាទវិតក្កី វិហឹសាវិតក្កី កើតឡើង បើភិក្ខុទទួលនូវវិតក្កនោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវការសាបសូន្យទេ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុ កំពុងដេក ភ្ញាក់ក៏ដោយ តែមានសភាពយ៉ាង នេះហើយ ហៅថា ជាអ្នកមិនមានព្យាយាមដុតកម្តៅកិលេស មិនជាអ្នក ក្តៅនឹងបាប ជាអ្នកខ្ជិលច្រអូសជានិច្ចកាល មិនមានព្យាយាម ។

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដើរទៅ បើមានកាមវិតក្កី ព្យាបាទវិតក្កី វិហឹសាវិតក្កី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្ក នោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសាបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងដើរទៅក៏ដោយ តែមានសភាពយ៉ាងនេះ

ហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរ បើមានកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្កនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសោបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងឈរក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុះ ទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយ បើមានកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើង ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទទួល នូវវិតក្កនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសោបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងអង្គុយក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេក ភ្ញាក់ បើមានកាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី កើតឡើងហើយ បើភិក្ខុមិនទទួលនូវវិតក្កនោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យដល់នូវការសោបសូន្យហើយ ម្នាលភិក្ខុទាំងឡាយ ទុកជាភិក្ខុកំពុងដេក កំពុងភ្ញាក់ក៏ដោយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ជាអ្នកក្តៅនឹងបាប ជាអ្នកប្រារព្ធព្យាយាមជានិច្ចកាល មាន

ចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។

ភិក្ខុណា កំពុងដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី ត្រិះរិះនូវវិតក្កដ៏លាមក ដែលអាស្រ័យនូវផ្ទះ គឺតណ្ហា ភិក្ខុបែបនោះឯង ហៅថា ដើរទៅរកផ្លូវខុស ជ្រប់នៅក្នុង ( អារម្មណ៍មានរូបជាដើម ) ជាទីតាំងនៃសេចក្តីប្រព្រឹត្តទៅនៃមោហៈ មិនគួរបាននូវសម្ពោធិញ្ញាណដ៏ឧត្តមឡើយ ។ ភិក្ខុណាកំពុងដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី បានញុំាងអកុសលវិតក្ក ឲ្យស្ងប់រម្ងាប់ ត្រេកអរក្នុងកិរិយារម្ងាប់នូវវិតក្ក ភិក្ខុបែបនោះឯង គួរបាននូវសម្ពោធិញ្ញាណដ៏ឧត្តម ។ សូត្រទី ១១ ។

# អដ្ឋកថា

## ចរសូត្រ

ក្នុងចរសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

[ ១១២-១១៣ ] បទថា **ចរតោ** បានដល់ កំពុងដើរ ឬកំពុងចង្ក្រម ។ បទថា **អប្បជ្ជតិ កាមវិតក្កោ វា** សេចក្តីថា បើ គឺប្រសិនបើវិតក្កដែលប្រកបដោយកាម ឬ ... នឹងកើតឡើង ព្រោះបច្ច័យបែបនោះ ព្រោះមិនទាន់ប្រាសចាករាគៈក្នុងវត្ថុកាមទាំងឡាយសោត ។ បទថា **ព្យាបាទវិតក្កោ វា**

**វិហឹសាវិតក្កោ វា** មានការភ្ជាប់ សេចក្តីថា បើវិតក្កដែលប្រកបដោយព្យាបាទ ដែលមានអាឃាតជានិមិត្ត ឬវិតក្កដែលប្រកបដោយវិហិង្សា ដោយអំណាចការបៀតបៀនអ្នកដទៃ ដោយដុំដី និងដំបងជាដើមកើតឡើងសោត ។ បទថា **អធិវាសេតិ** សេចក្តីថា បើញ៉ាំងកាមវិតក្កតាមដែលពោលហើយនោះ ដែលកើតឡើងក្នុងចិត្តរបស់ខ្លួន តាមបច្ច័យឲ្យអាស្រ័យ គឺលើកចិត្តរបស់ខ្លួនឡើងហើយ ឲ្យវាស្នាក់នៅ អាស្រ័យ ព្រោះមិនមានការពិចារណា ដោយន័យជាដើមថា វិតក្កនេះជារបស់អាក្រក់ ដោយហេតុនេះ ជាអកុសល ដោយហេតុនេះ ជាធម៌មានទោស ដោយហេតុនេះ វិតក្កនោះឯង រមែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនខ្លះ ដូច្នេះសោត កាលឲ្យវានៅអាស្រ័យនោះឯង ក៏មិនទាន់លះបាន គឺនៅរលាស់ចេញមិនទាន់បាន ដោយអំណាចតទង្គប្បហានជាដើម ព្រោះរលាស់ចេញមិនទាន់បាននោះឯង ក៏នឹងបន្ទោបង់មិនបាន បានដល់ នាំចេញទៅចាកចិត្តសន្តានមិនបាន ព្រោះបន្ទោបង់មិនបានយ៉ាងនោះ ធ្វើឲ្យសូន្យអស់ទៅមិនបាន គឺធ្វើកាមវិតក្កជាដើមនោះឲ្យប្រាសចាកទីបំផុតមិនបាន អធិប្បាយថា ជាអ្នកមានសេចក្តីព្យាយាម មានចិត្តស្ទុះ នឹងធ្វើដោយវិធីដែលទីបំផុត របស់វិតក្កទាំងនោះ មិនសល់នៅ ដោយទីបំផុតត្រឹមតែការបែកធ្លាយ តែភិក្ខុនេះ មិនមែនដូច្នោះឡើយ ។ ភិក្ខុបែបនោះ មិនឲ្យដល់នូវការមិនមាន គឺមិនឲ្យដល់នូវការមិនមាន ក្នុងកាលជាខាងក្រោយ ។ អ្នកសិក្សាគួរជ្រាបអត្ថដោយប្រកប ចេ សព្ទ ចូលដោយពាក្យជាដើមថា **ឧប្បជ្ជតិ ចេ ន វិនោទេតិ ចេ** ។ បទថា **ចរំ** បានដល់ **ចរន្តោ** ប្រែថា

ដើរទៅ ។ បទថា **ឋរិក្ខតោ** បានដល់ ជាអ្នកដល់ព្រមដោយវិតក្កដែល អាក្រក់ មានកាមវិតក្កជាដើមយ៉ាងនេះ ។ បទថា **អនាតាបី អនោត្តប្បី** សេចក្តីថា បុគ្គលឈ្មោះថា មិនមានសេចក្តីព្យាយាម ព្រោះមិនមានព្យាយាមដែលជាហេតុដុតនូវកិលេស ឈ្មោះថា មិនមានឱត្តប្បៈ ព្រោះមិនមានការខ្លាចក្រែង ដែលមានលក្ខណៈខ្លាចចំពោះបាប ក្តៅក្រហាយចំពោះបាប ។ បទថា **សតតំ សមិតំ** សេចក្តីថា អស់កាលជានិច្ច ។ បទថា **កុសីតោ ហីនវីរិយោ** សេចក្តីថា ភិក្ខុនោះ តថាគតហៅ គឺពោលថា ឈ្មោះថា **កុសីតោ** ព្រោះសាបសូន្យចាកកុសលធម៌ទាំងឡាយ ហើយលិចចុះក្នុងធម៌ចំណែកនៃអកុសល និងព្រោះប្រកបព្រមដោយការខ្ជិលច្រអូស ឈ្មោះថា **ហីនវីរិយោ** គឺវៀរចាកសេចក្តីព្យាយាមហើយ ព្រោះមិនមានសេចក្តីព្យាយាម គឺសម្មប្បធាន ។ បទថា **ឋិតស្ស** សេចក្តីថា ជាអ្នកឈរ ព្រោះវៀរការដើរ ដើម្បីទ្រង់សម្តែងវិធីដែលវិតក្កទាំងឡាយកើតឡើងដល់បុគ្គល ដែលដល់ព្រមដោយការខ្ជិលច្រអូសនោះ ទើបត្រាស់ថា **ជាគរស្ស** ព្រោះបន្ថែមនូវឥរិយាបថដេកចូលក្នុងសេចក្តីខ្ជិលច្រអូសជាពិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ចំណែក-សុតទៅ បទថា **តញ្ចេ ភិក្ខុ នាធិវាសេតិ** សេចក្តីថា បើកាមវិតក្កជាដើមកើតឡើងដល់ភិក្ខុនោះ បុគ្គលសូម្បីប្រារព្ធសេចក្តីព្យាយាម ហើយស្នាក់នៅ ព្រោះប្រកបដោយសម្បត្តិ ដោយបច្ច័យបែបនោះ ដែលអប់រំមកអស់កាលយូរ ក្នុងសង្សារដែលមិនមានខាងដើម ឬព្រោះវាយមាយស្មារតីសោត គឺបើភិក្ខុលើកចិត្តរបស់ខ្លួនឡើងហើយ

តែមិនឲ្យកាមវិតក្កជាដើមនោះឈប់ធ្វើសកម្មភាពសោត អធិប្បាយថា មិនឲ្យកាមវិតក្កជាដើមនោះផ្អាកនៅខាងក្នុងសោត ។ សួរថា កាលមិនឲ្យកាម-វិតក្កជាដើមបញ្ឈប់ នឹងធ្វើដូចម្តេច ឆ្លើយថា លះ គឺបោល ។ សួរថា បោលដូចចាក់សំរាម ដោយបង្គីដូច្នោះឬ ឆ្លើយថា មិនមែនដូច្នោះឡើយ ។ ម្យ៉ាងទៀត បន្ទោបង់ គឺកម្ចាត់ បានដល់ នាំចេញទៅនូវកាមវិតក្កនោះ ។ សួរថា នាំចេញទៅដូចនាំគោចេញទៅដោយជន្ទួញឬ ឆ្លើយថា មិនមែនដូច្នោះឡើយ ដោយពិត ធ្វើឲ្យសូន□ទៅ គឺធ្វើឲ្យប្រាសចាកទីបំផុត បានដល់ ធ្វើកិលេសទាំងនោះដោយវិធី ដែលសូម្បីតែទីបំផុតរបស់វិតក្កទាំងនោះក៏មិននៅសល់ ដោយហោចសូម្បីត្រឹមតែការបែកធ្លាយ ។

សួរថា ភិក្ខុនោះ ធ្វើវិតក្កទាំងនោះឲ្យប្រព្រឹត្តទៅយ៉ាងនោះបានដូចម្តេច ឆ្លើយថា ឲ្យដល់នូវការមិនមាន គឺឲ្យដល់នូវការមិនមានខាងក្រោយ អធិប្បាយថា មិនធ្វើដោយកាមវិតក្កជាដើមត្រូវសង្កត់ហើយ យ៉ាងសប្បាយ ដោយវិក្ខម្ភនប្បហាន ។

ក្នុងពាក្យទាំងឡាយជាដើមថា **ឯវំភូតោ** មានអត្ថថា កាលបើដូច្នោះ ភិក្ខុនោះ ឈ្មោះថា ជាអ្នកមានអាសយក្កិលេសបរិសុទ្ធល្អហើយ ព្រោះកាម-វិតក្កជាដើមមិនដក់នៅក្នុងចិត្ត ឈ្មោះថា ជាអ្នកមានសីលបរិសុទ្ធហើយ ព្រោះអាសយសម្បត្តិនោះផង ព្រោះប្រយោគសម្បត្តិដែលមានអាសយ-សម្បត្តិនោះជានិមិត្តផង ជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ដែលប្រកបដោយសតិសម្បជញ្ញៈ ប្រកប

រឿយៗ នូវសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭក តថាគតហៅ គឺពោលថា ឈ្មោះថា **អាតាបី** ព្រោះប្រកបដោយសេចក្តីព្យាយាម មានលក្ខណៈដុត នូវកិលេសទាំងឡាយ ដោយអំណាចតទង្គប្បហានជាដើម ឈ្មោះថា **ឱត្តាបី សតតំ** ព្រោះប្រកបដោយការតក់ស្លុតចំពោះបាប ដោយប្រការទាំងពួង ឈ្មោះថា **អារទ្ធវីរិយោ បហិតត្តោ** ព្រោះការសម្រេចនៃសម្មប្បធាន ៤ ដោយអំណាចនៃការប្រកបរឿយៗ នូវសមថភាវនា និងវិបស្សនាភាវនាជាប់តគ្នា ទាំងយប់ ទាំងថ្ងៃជានិច្ចនិរន្តរ៍ ឈ្មោះថា **វុច្ចតិ** គឺជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ វត្ថុកាម ទ្រង់ត្រាស់ហៅថា **គេហា** ក្នុងពាក្យថា **គេហានិស្សិតំ** នេះ ព្រោះអ្នកគ្រប់គ្រងផ្ទះទាំងឡាយ មិនទាន់លះបាន គឺព្រោះជាសភាវៈរបស់អ្នកគ្រប់គ្រងផ្ទះទាំងឡាយ ឬព្រោះជាទំនៀមប្រចាំផ្ទះ ។ម្យ៉ាងទៀត កាមវិតក្កជាដើម ឈ្មោះថា **គេហានិស្សិត** ព្រោះជាទីអាស្រ័យ ឬជាទីតាំងរបស់កិលេសកាមទាំងឡាយ ដោយជាវត្ថុចងជាប់នឹងផ្ទះ ។ បទថា **កុម្មគ្គំ បដិបន្នោ** សេចក្តីថា ព្រោះហេតុដែលអភិជ្ឈាជាដើម និងធម៌ដែលតាំងនៅក្នុងទីជាមួយគ្នា មួយអន្លើ ដោយអភិជ្ឈាជាដើម ជាផ្លូវដែលថោកថយ ព្រោះក្រៅគន្លងអរិយមគ្គ ដូច្នោះ បុគ្គលច្រើនដោយកាមវិតក្កជាដើម ឈ្មោះថា ដើរក្នុងផ្លូវថោកទាប ។ បទថា **មោហនេយ្យេសុ មុច្ឆិតោ** សេចក្តីថា ងប់ជ្រប់ គឺស្រវឹង បានដល់ ងប់ងល់ ហើយក្នុងរូបជាដើម ដែលប្រព្រឹត្តទៅព្រមនឹងមោហៈ ។ បទថា **សម្ពោធិ**

*បានដល់ អរិយមគ្គញ្ញាណ ។ បទថា* **ផុដ្ឋុំ** *បានដល់ ដើម្បីសម្ផស្ស គឺដើម្បីដល់ អធិប្បាយថា បុគ្គលបែបនោះ មានការត្រិះរិះខុសជាគោចរ ជាអ្នកមិនគួរ គឺទោះជាក្នុងកាលណា ក៏មិនសម្រេចសម្ពោធិញ្ញាណនោះ ។*

*បទថា* **វិតក្កំ សមយិត្វាន** *សេចក្តីថា រម្ងាប់មិច្ឆាវិតក្កតាមដែលពោលហើយ ដោយកម្លាំងនៃភាវនា មានបដិសង្ខានជាអារម្មណ៍ ។ បទថា* **វិតក្កូបសមេ រតោ** *សេចក្តីថា ត្រេកអរហើយ គឺត្រេកអរចំពោះហើយ ដោយអធ្យាស្រ័យក្នុងអរហត្តផល ឬព្រះនិព្វាននោះឯង ដែលជាធម៌រម្ងាប់នូវមហាវិតក្កទាំង ៩ ប្រការ ។ បទថា* **ភព្វោ សោ តាទិសោ** *សេចក្តីថា បុគ្គលបដិបត្តិប្រពៃ តាមដែលពោលមកហើយនោះ រម្ងាប់វិតក្កគ្រប់យ៉ាងបានដោយកម្លាំងនៃសមថៈ និងវិបស្សនាក្នុងចំណែកខាងដើម ដោយអំណាចនៃតទង្គប្បហានជាដើមតាមសមគួរ តាំងនៅ កាលផ្សាស់ប្តូរវិបស្សនាឲ្យខ្ពស់ឡើង និងជាបុគ្គលគួរ គឺអាចពាល់ត្រូវ គឺសម្រេចសម្ពោធិញ្ញាណដ៏កំពូល ពោលគឺអរហត្តមគ្គញ្ញាណ និងពោល គឺព្រះនិព្វានតាមលំដាប់នៃមគ្គដូច្នេះឯង ។*

**អដ្ឋកថាចរសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## សីលសម្បន្នសូត្រ

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាបុគ្គលបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ជាបុគ្គលបរិបូណ៌ដោយសីល បរិបូណ៌ដោយបាតិមោក្ខ សង្រួមដោយការសង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខា-បទទាំងឡាយហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរធ្វើដូចម្តេចតទៅទៀត ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដើរទៅក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាម មិនធូរថយ ប្រុងស្មារតី មិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូលនឹងនួន ក្នុងអារម្មណ៍តែ ១ ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបើទុកជាកំពុងដើរទៅ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ភ្លៀននឹងបាប ប្រារព្ធព្យាយាម ជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងឈរក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតី មិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូល

នឹងនួនក្នុងអារម្មណ៍តែ ១ ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងឈរ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងអង្គុយក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតី មិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំមួន នឹងនួនក្នុងអារម្មណ៍តែមួយហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងអង្គុយ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ច-កាល មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុកំពុងដេកក្តី កំពុងភ្ញាក់ក្តី បើប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ប្រាសចាកថីនមិទ្ធៈ ប្រាសចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ប្រារព្ធព្យាយាមមិនធូរថយ ប្រុងស្មារតី មិនភ្លេចភ្លាំង មានកាយស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ មានចិត្តតាំងមាំ មូលនឹងនួន ក្នុងអារម្មណ៍តែមួយហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទុកជាកំពុងដេក កំពុងភ្ញាក់ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមានព្យាយាម ដុតកម្តៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ។

ភិក្ខុគួរដើរទៅឲ្យមានព្យាយាម ( រារាំងបាប ) គួរឈរ
ឲ្យមានព្យាយាម គួរអង្គុយឲ្យមានព្យាយាម គួរដេក

ឲ្យមានព្យាយាម គួរបត់ចូល ( នូវអវយវៈ ) ឲ្យមានព្យាយាម គួរលាចេញ ( នូវអវយវៈ ) ឲ្យមានព្យាយាម ការប្រព្រឹត្តទៅនៃលោក ក្នុងខាងលើ ក្នុងទីជុំវិញ ក្នុងទិសខាងក្រោម ត្រឹមណា ភិក្ខុគួរជាអ្នកពិចារណានូវការកើត និងការរលត់ នៃខន្ធទាំងឡាយដែលមានការសោបសូនទ្យជាធម្មតា ត្រឹមណោះ អ្នកប្រាជ្ញទាំងឡាយ បានសរសើរ នូវភិក្ខុអ្នកសម្រេចសម្រាន្តនៅយ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស មានការប្រព្រឹត្តិស្ងប់រម្ងាប់ មានចិត្តមិនរាយមាយ សិក្សាឲ្យសមគួរដល់ធម៌ជាគ្រឿងស្ងប់ចិត្ត មានស្មារតីគ្រប់កាលថែបនោះថា ជាបុគ្គលមានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ។

សូត្រទី ១២ ។

# អដ្ឋកថា

## សីលសម្បន្នសូត្រ

*ក្នុងសីលសម្បន្នសូត្រទី ១២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

[ ១១៤ ] *ក្នុងបទថា* **សម្បន្នសីលា** *នេះ* **សម្បន្ន** *សព្ទមានអត្ថ ៣ យ៉ាង គឺពេញបរិបូណ៌ ១ ដល់ព្រម ១ ផ្អែមឆ្ងាញ់ ១ ។ បណ្ដា* **សម្បន្ន** *សព្ទទាំង ៣ នោះ* **សម្បន្ន** *សព្ទដែលមានអត្ថថា ពេញបរិបូណ៌ ដូចក្នុងប្រយោគនេះថា*

**សម្បន្នំ សាលិកេទារំ　　សុវា ភុញ្ជន្តិ កោសិយ**
**បដិវេទេមិ តេ ព្រហ្មេ　　ន តេ វារេតុមុស្សហេ។**

*បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែ*
*ពួកសេកតែងស៊ី បពិត្រព្រហ្ម ខ្ញុំសូមជម្រាបលោក*
*ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ ។*

**សម្បន្ន** *សព្ទ មានអត្ថថា ដល់ព្រម ដូចក្នុងប្រយោគនេះថា*

**ឥមិនា ចាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ** *គឺជាអ្នកព្រមព្រៀងមូលមិត្រ ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ... ដូច្នេះ ។*

**សម្បន្ន** *សព្ទដែលមានអត្ថថា ផ្អែមឆ្ងាញ់ ដូចក្នុងប្រយោគនេះថា*

**ឥមិស្សា ភន្តេ មហាបឋវិយា ហេដ្ឋិមតលំ សម្បន្នំ សេយ្យថាបិ ខុទ្ទកមធុំ អនីលកំ ឯវមស្សាទំ** *សូមទ្រង់ព្រះមេត្តាប្រោស ផ្ទៃខាងក្រោមនៃ*

ផែនដីនេះ មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយប្រឡាំដោយមេឃ ។

តែក្នុងទីនេះ **សម្បន្ន** សព្ទ សមក្នុងអត្ថថា ពេញបរិបូណ៌ក៏បាន ក្នុងអត្ថថា ដល់ព្រមក៏បាន ព្រោះដូច្នោះ គប្បីជ្រាបអត្ថយ៉ាងនេះថា បទថា **សម្បន្ន-សីលា** បានដល់ ជាអ្នកមានសីលបរិបូណ៌ខ្លះ ជាអ្នកដល់ព្រមដោយសីលខ្លះ តាមអត្ថនេះថា មានសីលបរិបូណ៌ហើយ មានអធិប្បាយថា សីល ឈ្មោះថា ជាសីលបរិបូណ៌ហើយ ដូចការបរិបូណ៌នៃស្រែ ព្រោះប្រាសចាកទោសរបស់ស្រែ ដោយហេតុនោះ ទើបលោកពោលថា ការបរិបូណ៌នៃសីល ព្រះមានព្រះភាគត្រាស់ ព្រោះប្រាសចាកទោសរបស់សីល ដូចការបរិបូណ៌នៃស្រែ ព្រោះប្រាសចាកទោសរបស់ស្រែ ។ ចំណែកតាមអត្ថនេះថា **សីលសម្បន្នា** មានពុទ្ធាធិប្បាយថា អ្នកទាំងឡាយ ចូរជាអ្នកដល់ព្រមដល់នូវការសង្រួម ជាអ្នកប្រកបដោយសីលចុះ ។ បណ្តា ២ យ៉ាងនោះ ភាពជាអ្នកមានសីលបរិបូណ៌ មានដោយហេតុ ២ គឺដោយការឃើញទោសរបស់សីលវិបត្តិ ១ ដោយការឃើញអានិសង្សនៃសីលសម្បត្តិ ១ ទោស និងអានិសង្សទាំង ២ យ៉ាងនោះ គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ពាក្យណាដែលខ្ញុំគួរពោលក្នុងទីនេះ ដោយន័យជាដើមថា បណ្តាបទទាំងនោះ ដោយបទត្រឹមប៉ុណ្ណោះថា ជាអ្នកមានសីលបរិបូណ៌ហើយ បានឮថា ព្រះមានព្រះភាគកាលទ្រង់សម្តែងបារិសុទ្ធិសីល ៤ ទើបទ្រង់សម្តែងសីលដែលជាគោល ដោយពាក្យនេះថា ជាអ្នកសង្រួមហើយ ដោយបាតិមោក្ខសំវរៈ ពាក្យ

នោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។

បទថា **កិមស្ស ឧត្តរឹ ករណីយំ** មានអត្ថថា បើមានពាក្យសួរថា អ្នកទាំងឡាយមានសីលសម្បូរហើយយ៉ាងនេះ គប្បីមានអ្វីដែលត្រូវធ្វើ គឺត្រូវបដិបត្តិឲ្យក្រៃលែងឡើង ឆ្លើយថា ព្រះមានព្រះភាគ កាលទ្រង់ប្រកបភិក្ខុទាំងឡាយក្នុងសីលសម្បទា មួយអន្លើដោយឧបាយដែលជាហេតុឲ្យដល់ព្រមដោយពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរនាំគ្នាមានសីលបរិបូណ៌យ៉ាងនេះចុះ ដូច្នេះ ទ្រង់បានផ្តើមព្រះធម្មទេសនា លើកបុគ្គលជាច្រើនឡើងជាទីតាំងហើយ ឥឡូវនេះ កាលទ្រង់សម្តែងព្រះធម្មទេសនានោះ ដោយអំណាចនៃការលើកបុគ្គលម្នាក់ឡើងជាទីតាំង ព្រោះហេតុដែលព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ទោះប្រព្រឹត្តទៅហើយ ដោយការលើកបុគ្គលម្នាក់ឡើងជាទីតាំង តែក៏ជាព្រះធម្មទេសនា ដែលលើកបុគ្គលជាច្រើនឡើងជាទីតាំង ព្រោះជាសាធារណៈដល់សព្វសត្វ ទើបត្រាស់ពាក្យជាដើមថា **ចរតោ ចេបិ ភិក្ខវេ ភិក្ខុនោ ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងនោះដូចតទៅ កិលេសជាត ឈ្មោះថា អភិជ្ឈា ព្រោះជាហេតុសម្លឹង ។ ពាក្យថា **អភិជ្ឈា** នេះ ជាឈ្មោះរបស់លោភៈដែលមានលក្ខណៈសម្លឹងនូវទ្រព្យអ្នកដទៃ ។ អកុសលធម៌ ឈ្មោះថា ព្យាបាទ ព្រោះជាហេតុឲ្យចិត្តដល់នូវសេចក្តីវិនាស គឺជាចិត្តខូច ។ ពាក្យនេះជាឈ្មោះរបស់ទោសៈដែលមានអាឃាតវត្ថុ ១៩ ជាអារម្មណ៍ ប្រព្រឹត្តទៅហើយដោយន័យជាដើមថា បុគ្គលនោះ បានប្រព្រឹត្តមិនជាប្រយោជន៍ដល់អញ

ហើយ ។ គប្បីជ្រាបសេចក្ដីពិស្ដាររបស់អភិជ្ឈា និងព្យាបាទទាំង ២ យ៉ាង នោះ ដោយន័យក្នុងវិភង្គថា

បណ្ដានីវរណៈទាំងនោះ កាមច្ឆន្ទនីវរណៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាចំពោះកាម សេចក្ដីត្រេកអរចំពោះកាម សេចក្ដីរីករាយចំពោះកាម សេចក្ដីអន្ទះសាចំពោះកាម សេចក្ដីស្រឡាញ់ចំពោះកាម សេចក្ដីរោលរាលចំពោះកាម សេចក្ដីជ្រុលជ្រប់ចំពោះកាម សេចក្ដីងប់ចិត្តចំពោះកាម ក្នុងកាមទាំងឡាយណា ដូច្នេះ ។ ការចង់បាន ការជាប់ចំពាក់ សេចក្ដីជាប់ចំពាក់ តម្រេកខ្លាំង ត្រេកត្រអាល សេចក្ដីត្រេកត្រអាល ការសម្ងំរំពៃ គឺលោភៈ ដូច្នេះ ។ សេចក្ដីខឹង ការប្រទូស្ត ភាពប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពព្យាបាទ សេចក្ដីខុស សេចក្ដីក្ដាត់ សេចក្ដីកាច សម្ដីអសុរោះ សេចក្ដីមិនត្រេកអរនៃចិត្តណា ដូច្នេះ ។

បទថា **វិគតោ ហោតិ** សេចក្ដីថា អភិជ្ឈាក្ដី ព្យាបាទក្ដី ជារបស់ប្រាសទៅហើយ គឺទៅប្រាសហើយ អធិប្បាយថា លះបានហើយ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់សម្ដែងដល់ការលះកាមច្ឆន្ទៈ និងព្យាបាទនីវរណៈបានហើយ ។

បទថា **ថីនមិទ្ធំ** បានដល់ ទាំងថីនៈ ទាំងមិទ្ធៈ ។ បណ្ដាថីនមិទ្ធៈទាំង ២ យ៉ាងនោះ ភាវៈដែលចិត្តមិនគួរដល់ការងារ ឈ្មោះថា **ថីន** ។ ពាក្យថា

ថីនៈនេះ ជាឈ្មោះនៃការខ្ជិលច្រអូស ។ ភាពដែលខន្ធទាំង ៣ មានវេទនាខន្ធជាដើម មិនគួរដល់ការងារ ឈ្មោះថា **មិទ្ធ** ។ ពាក្យថា **មិទ្ធ** នេះ ជាឈ្មោះនៃភាពជាបុគ្គលងក់ងុយ ។

អ្នកសិក្សាគប្បីជ្រាបសេចក្ដីពិស្ដាររបស់ថីនៈ និងមិទ្ធៈទាំង ២ សព្វដោយន័យក្នុងធម្មសង្គណីជាដើមថា បណ្ដាធម៌ទាំងនោះ **ថីន** តើដូចម្ដេច ។ ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់នៅ ការសម្ងំនៅ ... ដូច្នេះ ។ បណ្ដាធម៌ទាំងនោះ **មិទ្ធ** តើដូចម្ដេច ។ ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់ ការស្រពោន ... ដូច្នេះ ។

បទថា **ឧទ្ធច្ចកុក្កុច្ចំ** បានដល់ រាយមាយផង ក្ដៅក្រហាយចិត្តផង ។ បណ្ដាឧទ្ធច្ចៈ និងកុក្កុច្ចៈនោះ អាការរបស់ចិត្តដែលរាយមាយ ឈ្មោះថា **ឧទ្ធច្ច** ។ ការក្ដៅក្រហាយព្រោះបាបដែលធ្វើជាបច្ច័យរបស់បុគ្គល មិនបានធ្វើសេចក្ដីល្អ ធ្វើតែអំពើអាក្រក់ ឈ្មោះថា **កុក្កុច្ច** ។ អ្នកសិក្សាគប្បីជ្រាបសេចក្ដីពិស្ដាររបស់ឧទ្ធច្ចៈ និងកុក្កុច្ចៈទាំងនោះ ដោយន័យក្នុងធម្មសង្គណីជាដើមថា បណ្ដាធម៌ទាំងនោះ **ឧទ្ធច្ច** តើដូចម្ដេច ។ ការអណ្ដែតអណ្ដូង ការមិនស្ងប់រម្ងាប់ ការរាយមាយ ការភ័ន្តភាំងណា ... ដូច្នេះ ។ គប្បីជ្រាបការដែលប្រព្រឹត្តទៅ ដោយន័យក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកជាដើមថា អីហ្ន៎ អាត្មាអញមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើបុណ្យ សម្រាប់ការពារភ័យសោះ អាត្មាអញ ធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើក្ដៅក្រហាយ ... ដូច្នេះ ។

បទថា **វិចិកិច្ឆា** បានដល់ សេចក្តីសង្ស័យក្នុងព្រះពុទ្ធជាដើម អ្នកសិក្សាគប្បីជ្រាបសេចក្តីពិស្តាររបស់វិចិកិច្ឆានោះ ដោយន័យក្នុងវិភង្គថា ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពងឿងឆ្ងល់ ការប្រាសចាកបញ្ញា ការតេងតាងគំនិត ការបែកគំនិតជាពីរ ផ្លូវពីរ ការសង្ស័យ ការកាន់យកចំណែកច្រើន ការអង្គឹអង្គែ ការអល់អែក ការមិនចុះចិត្តស៊ប់ ភាពរឹងរូស ការរសេមរសាមណានៃចិត្ត ... ដូច្នេះ ។ និងដោយន័យក្នុងក្នុងធម្មសង្គណីជាដើមថា វិចិកិច្ឆា តើដូចម្តេច ។ ការឆ្ងល់ អាការឆ្ងល់ ភាពឆ្ងល់ សេចក្តីយល់ស្មាក់ស្មើរ សេចក្តីងឿងឆ្ងល់ ចិត្តបែកជាពីរ ចិត្តញែកជា ២ ផ្លូវ សេចក្តីសង្ស័យ ការប្រកាន់ដោយចំណែកច្រើន ការដកថយមិនរួច ការទម្លុះទម្លាយទៅមិនបាន ការប្រកាន់មិនមាំ សេចក្តីរឹងត្អឹងរបស់ចិត្ត ការរសេម-រសាមចិត្តណា ។

ក្នុងទីនេះ ទ្រង់បំណងយកការសង្កត់សង្កិនអភិជ្ឈា និងព្យាបាទជាដើមនោះប៉ុណ្ណោះ ដោយអំណាចនៃការប្រាសចេញទៅ និងដោយអំណាចការលះនៃអភិជ្ឈា និងព្យាបាទជាដើម ដែលទ្រង់ត្រាស់ក្នុងវិភង្គថា ភិក្ខុនោះ លះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់ព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះនូវប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់ជាពន្លឺ ជាអ្នកមានសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ

លះបង់ឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ ខាងក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ដូច្នេះ ។ បណ្តាការលះ និងការកើតឡើងនោះ ការលះនីវរណៈ មានដោយវិធីណា គួរជ្រាបវិធីនោះដូចតទៅនេះ

ការលះនីវរណៈទាំងនោះមានដូចម្តេច ការលះកាមច្ឆន្ទៈដោយយោនិសោមនសិការក្នុងអសុភនិមិត្ត ។ ឯការកើតឡើងនៃកាមច្ឆន្ទៈ មានដោយអយោនិសោមនសិការក្នុងសុភនិមិត្ត ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តរមែងមានការធ្វើទុកក្នុងចិត្តខុសទំនង និងការធ្វើឲ្យក្រាស់ក្រែលក្នុងសុភនិមិត្តនោះ នេះជាអាហារដែលញ៉ាំងកាមច្ឆន្ទៈមិនទាន់កើតឡើង ឲ្យកើតឡើង ឬញ៉ាំងកាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យរឹតតែកើតជំទូលាយទៅ ដូច្នេះ ។

ការលះកាមច្ឆន្ទៈ ដែលកើតឡើងដោយអយោនិសោមនសិការ ក្នុងសុភនិមិត្តយ៉ាងនេះ មានដោយយោនិសោមនសិការ ក្នុងអសុភនិមិត្ត ដោយការផ្ទុយគ្នានឹងអយោនិសោមនសិការក្នុងសុភនិមិត្តនោះ ។ បណ្តានិមិត្តទាំង ២ យ៉ាងនោះ អសុភខ្លះ អសុភារម្មណ៍ខ្លះ ឈ្មោះថា **អសុភនិមិត្ត** ។ ការធ្វើទុកក្នុងចិត្តដោយឧបាយ គឺមនសិការក្នុងផ្លូវ បានដល់ មនសិការថា មិនទៀងក្នុងវត្ថុដែលមិនទៀងខ្លះ ថាជាទុក្ខក្នុងវត្ថុដែលជាទុក្ខខ្លះ ថាជាអនត្តាក្នុងវត្ថុដែលជាអនត្តាខ្លះ ថាមិនស្អាតក្នុងវត្ថុដែលមិនស្អាតខ្លះ ឈ្មោះថា **យោនិ-**

**សោមនសិការ** ។ *កាលឲ្យមនសិការនោះ ប្រព្រឹត្តទៅច្រើនដងក្នុងនិមិត្តនោះ រមែងលះកាមច្ឆន្ទៈបាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀតអសុភនិមិត្ត ការធ្វើឲ្យច្រើននូវយោនិសោមនសិការក្នុងអសុភនិមិត្តនោះ នេះជាហេតុនាំផលមកដើម្បីការមិនកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងខ្លះ ដើម្បីលះកាមច្ឆន្ទៈដែលកើតឡើងហើយខ្លះ ។*

## ធម៌សម្រាប់លះកាមច្ឆន្ទៈ ៦ យ៉ាង

*ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ* **អសុភនិមិត្តស្សឧគ្គហោ** *គឺការរៀនយកអសុភនិមិត្ត ១* **អសុភភាវនានុយោគោ** *ការប្រកបព្យាយាមរឿយៗ ក្នុងអសុភភាវនា ១* **ឥន្ទ្រិយេសុគុត្តទ្វារតា** *ភាពជាអ្នកមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ ១* **ភោជនេមត្តញ្ញុតា** *ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១* **កល្យាណមិត្តតា** *ភាពជាអ្នកមានកល្យាណមិត្ត ១* **សប្បាយកថា** *ពោលពាក្យជាទីសប្បាយ ១ ។*

*អធិប្បាយថា បុគ្គលកំពុងរៀនយកអសុភនិមិត្ត ១០ តែងលះកាមច្ឆន្ទៈបាន បុគ្គលកំពុងចម្រើនអសុភនិមិត្តក៏លះកាមច្ឆន្ទៈបាន បុគ្គលបិទទ្វារក្នុងឥន្ទ្រិយទាំងឡាយហើយក៏លះបាន បុគ្គលដឹងប្រមាណក្នុងការឆាន់អាហារព្រោះភាពជាអ្នកមានប្រក្រតី ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយផឹកទឹកក្នុងឱកាសដែលអាចឆាន់ ៤-៥ ពំនូត ក៏លះកាមច្ឆន្ទៈបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងថេរគាថាថា*

*ភិក្ខុឈប់បរិភោគ ៤-៥ ពំនូត ( ក្នុងកាលជិតឆ្អែត )*
*ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ*
*នៃភិក្ខុអ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ។*

*បុគ្គលកំពុងគប់រកកល្យាណមិត្ត ដូចគ្នានឹងព្រះតិស្សត្ថេរ ដែលចម្រើនអសុភកម្មដ្ឋាន លះកាមច្ឆន្ទៈបានក៏មាន ។ លះបានដោយកថាដែលជាទីសប្បាយ អាស្រ័យអសុភ ១០ ក្នុងទីដែលឈរ ទីដែលអង្គុយជាដើមក៏មាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ យ៉ាង ប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ។*

*ការកើតឡើងនៃព្យាបាទ មានដោយអយោនិសោមនសិការក្នុងបដិឃនិមិត្ត ។ បដិឃៈ ឈ្មោះថា* **បដិឃនិមិត្ត** *ក្នុងពាក្យថា ដោយអយោនិសោមនសិការ ក្នុងបដិឃនិមិត្តនោះ សូម្បីបដិឃារម្មណ៍ គឺបដិឃនិមិត្តនោះឯង អយោនិសោមនសិការក្នុងបដិឃនិមិត្តនោះ មានលក្ខណៈតែមួយ ដូចគ្នាក្នុងទីគ្រប់អន្ទើនោះឯង ។ ព្យាបាទកើតឡើងដល់បុគ្គលឲ្យអយោនិសោមនសិការប្រព្រឹត្តទៅច្រើនដងក្នុងនិមិត្តនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្ត ( និមិត្តនាំឲ្យចង្អៀតចង្អល់ចិត្ត ) រមែងមានការធ្វើទុកក្នុងចិត្តខុសទំនង និងធ្វើឲ្យក្រាស់ក្រែលក្នុងបដិឃនិមិត្តនោះ នេះជាអាហារដែលញុំាងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើង ឬញុំាងព្យាបាទដែលកើតឡើងហើយ ឲ្យរឹងរឹតតែកើតធំទូលាយទៅ ដូច្នេះ ។*

*ឯបុគ្គលធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញានូវមេត្តាចេតោវិមុត្តិ នឹងមានការលះព្យាបាទបាន ។ បណ្តាពាក្យថា* **មេត្តា** *និង* **ចេតោវិមុត្តិ** *នោះ កាលពោលពាក្យថា* **មេត្តា** *ក៏ប្រើបានទាំងអប្បនា ទាំងឧបចារៈ តែបើពោលថា ចេតោវិមុត្តិក៏ប្រើបាន ចំពោះអប្បនាប៉ុណ្ណោះ ។ យោនិសោមនសិការ មានលក្ខណៈដូចពោលមកហើយនេះឯង ។ កាលឲ្យយោនិសោមនសិការនោះប្រព្រឹត្តទៅច្រើនដងក្នុងមេត្តានោះ ក៏លះព្យាបាទបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងក្នុងសំយុត្តនិកាយ មហាវារវគ្គថា*

*ម្នាលភិក្ខុទាំងឡាយ មានតែចេតោវិមុត្តិ និងការធ្វើនូវ*
*យោនិសោមនសិការឲ្យច្រើន ក្នុងចេតោវិមុត្តិនោះ*
*នេះធម៌ដែលមិនមែនជាអាហាររបស់ព្យាបាទ ដែលមិន*
*ទាន់កើត ឲ្យកើតឡើងបាន ឬរបស់ព្យាបាទដែលកើត*
*ហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូចេ□ះ*

## ធម៌សម្រាប់លះព្យាបាទ ៦ យ៉ាង

*ម្យ៉ាងទៀត ធម៌ ៦ ប្រការ ដែលប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ* **មេត្តានិមិត្តស្សឧគ្គហោ** *គឺការរៀននូវមេត្តានិមិត្ត ១* **មេត្តាភាវនា** *ការចម្រើនមេត្តា ១* **កម្មស្សកតបច្ចវេក្ខណា** *ពិចារណាភាពដែលសត្វទាំងឡាយ មានកម្មជារបស់ខ្លួន ១* **បដិសង្ខានពហុលតា** *ជាអ្នកច្រើនទៅដោយការពិចារណា ១* **កល្យាណមិត្តតា** *មានកល្យាណមិត្រ ១* **សប្បាយកថា** *ពោលពាក្យដែលជាសប្បាយ ១ ។*

អធិប្បាយថា បុគ្គលកំពុងរៀនមេត្តាដោយអំណាចនៃការផ្សាយទៅគ្រប់ទិសក្តី ដោយចំពោះក្តី មិនចំពោះក្តីណាមួយ រមែងលះព្យាបាទបាន ។ បុគ្គលកំពុងចម្រើនមេត្តា ដោយអំណាចមេត្តាផ្សាយទៅគ្រប់ទិសដោយចំពោះ ដោយមិនចំពោះ ក៏លះព្យាបាទបាន ដែលកំពុងពិចារណាដល់ភាវៈមានកម្មជារបស់ខ្លួននៃបុគ្គលទាំង ២ គឺខ្លួនឯង និងអ្នកដទៃយ៉ាងនេះថា ឯងខឹងនឹងបុគ្គលនោះហើយ តើបានអ្វី អាចធ្វើឲ្យគុណទាំងឡាយ មានសីលជាដើមរបស់បុគ្គលនោះឲ្យវិនាសទៅឬ ខ្លួនឯងមកហើយដោយកម្មរបស់ខ្លួន នឹងទៅតាមកម្មរបស់ខ្លួន មិនមែនឬ ធម្មតា ការក្រោធនឹងបុគ្គលដទៃ ក៏ដូចនឹងការចាប់រងើកភ្លើងដែលប្រាសចាកអណ្តាត ដុំដែកដែលក្តៅ និងឧច្ចារៈ គ្រវែងទៅអ្នកដទៃ ទោះបីបុគ្គលនោះក្រោធនឹងឯង តើឯងបានអ្វី បុគ្គលនោះ អាចធ្វើឲ្យធម៌ទាំងឡាយ មានសីលជាដើមរបស់ឯង ឲ្យវិនាសបានឬ បុគ្គលនោះមកតាមកម្មរបស់ខ្លួន ទៅក៏តាមកម្មរបស់ខ្លួននោះឯង សេចក្តីក្រោធនោះ នឹងធ្លាក់លើអំបែងក្បាលរបស់បុគ្គលនោះឯង ដូចមិនទទួលយកបណ្ណាការ និងដូចបាចធូលីប្រាសខ្យល់ដូច្នេះ ពិចារណាហើយ ឈរក្នុងទីដែលពិចារណារមែងលះព្យាបាទបាន គប់រកកល្យាណមិត្ត ដែលត្រេកអរក្នុងមេត្តាភាវនាដូចព្រះអស្សគុត្តត្ថេរ រមែងលះព្យាបាទបាន ។ រមែងលះព្យាបាទបានដោយកថាដែលជាសប្បាយ អាស្រ័យមេត្តាក្នុងទីដែលឈរ និងទីដែលអង្គុយជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការប្រព្រឹត្តទៅដើម្បីលះព្យាបាទ ។

ការកើតឡើងនៃថីនមិទ្ធៈ មានដោយអយោនិសោមនសិការក្នុងអកុ-សលធម៌ មានអរតិជាដើម ។ ការមិនត្រេកអរ ឈ្មោះថា **អរតិ** ការខ្ជិលប្រអូសតាមកាយ ឈ្មោះថា **តន្ទិ** ។ ការមីតពត់កាយ ឈ្មោះថា **វិជម្ភិកា** ការស្រវឹងក្នុងភត្ត គឺការធ្ងន់កាយព្រោះភត្ត ឈ្មោះថា **ភត្តសម្មទ** ។ អាការដែលចិត្តរួញរា ឈ្មោះថា **ចេតសោលីនត្តំ** កាលញ៉ាំងអយោនិសោមនិការឲ្យប្រព្រឹត្តទៅច្រើនដងក្នុងអកុសលធម៌ទាំងនេះ ថីនមិទ្ធៈ រមែងកើតឡើង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ សេចក្តីធុញទ្រាន់ សេចក្តីខ្ជិល មីតពត់កាយ ពុលបាយ រួញរាចិត្តរមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនង និងការធ្វើក្រាស់ក្រែល ក្នុងការទាំងនោះ នេះជាអាហារដែលញ៉ាំងថីនមិទ្ធៈ មិនទាន់កើត ឲ្យកើតឡើង ឬញ៉ាំងថីនមិទ្ធៈ ដែលកើតឡើងហើយ ឲ្យរឹតតែកើតជំទូលាយទៅ ដូច្នេះ ។ ចំណែកការលះថីនមិទ្ធៈ មានដោយយោនិសោមនសិការ ក្នុងអារម្ភធាតុជាដើម ។ សេចក្តីព្យាយាមដែលចាប់ផ្តើម ឈ្មោះថា **អារម្ភធាតុ** ។ សេចក្តីព្យាយាម ដែលមានកម្លាំងច្រើនជាងនោះ ព្រោះចេញទៅហើយចាកការខ្ជិលប្រអូស ឈ្មោះថា **និក្កមធាតុ** ។ សេចក្តីព្យាយាម ដែលមានកម្លាំងច្រើនជាងនោះ ព្រោះឈានទៅកាន់ទីខាងមុខ ឈ្មោះថា **បរក្កមធាតុ** ។

បុគ្គលញ៉ាំងយោនិសោមនសិការឲ្យប្រព្រឹត្តទៅច្រើនដង ក្នុងវីរិយៈ ៣ ប្រភេទនេះ លះនូវថីនមិទ្ធៈបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែការតាំងផ្តើមការខ្នះខ្នែង ការប្រឹងប្រែង និង

ការធ្វើទុកក្នុងចិត្តដោយមិនសោមនស្សិការឲ្យច្រើន ក្នុងការតាំងផ្ដើមជាដើមនោះ នេះធម៌មិនមែនជាអាហាររបស់ថីនមិទ្ធៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ថីនមិទ្ធៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

## ធម៌សម្រាប់លះថីនមិទ្ធៈ ៦ យ៉ាង

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ **អតិភោជនេនិម្មិត្តគ្គាហោ** គឺការបរិភោគភោជនល្មមប្រមាណ ១ **ឥរិយាបថសម្បរិវត្តនតា** ការផ្លាស់ប្ដូរឥរិយាបថ ១ **អាលោកសញ្ញាមនសិការោ** មនសិការអាលោកសញ្ញា ១ **អព្ភោកាសវាសោ** នៅក្នុងទីវាល ១ **កល្យាណមិត្តតា** ការមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលពាក្យដែលជាទីសប្បាយ ១ ។

អធិប្បាយថា អ្នកបរិភោគភោជន ដូចជាអាហារហត្ថកព្រាហ្មណ៍ ភុត្តវម្មិកព្រាហ្មណ៍ តត្ថវដ្ដកព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍ និងកាកមាសកព្រាហ្មណ៍ ហើយអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ការងោកងុយនឹងមកគ្របសង្កត់ ដូចដំរីធំមកជាន់ តែកាលភិក្ខុវៀរដុំបាយ ៤-៥ ពំនូត ហើយផឹកទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតាមប្រក្រតី ការងោកងុយនោះ នឹងមិនមាន។ បុគ្គលទទួលភោជនដ៏សេសល្មមប្រមាណយ៉ាងនេះ រមែងលះថីនមិទ្ធៈបាន ជាអ្នកផ្លាស់ឥរិយាបថ ចាកឥរិយាបថដែលខ្ជិលច្រអូសឈានចុះកាន់ការងុកងុយ ក្នុងពេលយប់ មនសិការដល់ព្រះចន្ទ្រ ពន្លឺប្រទីប និងពន្លឺគប់ភ្លើង ក្នុងពេលថ្ងៃ មនសិការដល់ពន្លឺព្រះ

អាទិត្យខ្លះ ទីវាលខ្លះ គប់រកកល្យាមិត្រ ដែលប្រាសចាកការងងុយ ដូចព្រះមហាកស្សបត្ថេរខ្លះ រមែងលះថីនមិទ្ធៈបាន ។ រមែងលះថីនមិទ្ធៈបាន ដោយកថាដែលជាសប្បាយ អាស្រ័យធុតង្គ ក្នុងទីអង្គុយ និងទីដេកជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីមិទ្ធៈ ។

ឧទ្ធច្ចកុក្កុច្ចៈកើតឡើង ព្រោះអយោនិសោមនសិការក្នុងការមិនស្ងប់នៃចិត្ត ។ អាការនៃចិត្តដែលមិនស្ងប់ ឈ្មោះថា **អវូបសម** ដោយអត្ថ បានដល់ ឧទ្ធច្ចកុក្កុច្ចៈនោះឯង ។ បុគ្គលញ៉ាំងអយោមនសិការក្នុងការមិនស្ងប់នៃចិត្តឲ្យប្រព្រឹត្តទៅច្រើនដង ឧទ្ធច្ចកុក្កុច្ចៈនឹងកើតឡើង ។ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែការមិនស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើន ក្នុងការមិនស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។

កាលមនសិការដោយឧបាយប្រាជ្ញា ក្នុងការស្ងប់នៃចិត្ត ពោល គឺសមាធិកាលលះឧទ្ធច្ចកក្កុច្ចៈក៏នឹងមាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានតែការស្ងប់ស្ងាត់ចិត្ត និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងការស្ងប់ស្ងាត់ចិត្តនោះ នេះធម៌ដែលមិនមែនជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់ឧទ្ធច្ចកុក្កុច្ចៈដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

# ធម៌សម្រាប់លះឧទ្ធច្ចកុក្កុច្ចៈ ៦ យ៉ាង

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ **ពហុស្សុតតា** គឺភាពជាពហូសូត ១ **បរិបុច្ឆកតា** ការសាកសួរ ១ **វិនយេបកតញ្ញុតា** ការដឹងដោយជុំវិញក្នុងវិន័យ ១ **វុឌ្ឍសេវិតា** ការគប់រក និងការសមាគមអ្នកមានសេចក្ដីចម្រើន ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ការពោលពាក្យជាទីសប្បាយ ១ ។

អធិប្បាយថា បុគ្គលអ្នករៀនក្នុង ១ និកាយ ២ និកាយ ៣ និកាយ ៤ ឬ ៥ និកាយ ដោយអំណាចនៃបាលី និងដោយអំណាចនៃអដ្ឋកថា ដោយភាពជាពហូសូត រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ បុគ្គលច្រើនទៅដោយការសាកសួរនូវធម៌ដែលជាកប្បិយ និងអកប្បិយ បុគ្គលដឹងដោយជុំវិញព្រោះភាពជាអ្នកប្រព្រឹត្តរហូតជំនាញក្នុងព្រះវិនយបញ្ញត្តិខ្លះ ចូលទៅរកព្រះថេរៈ គឺអ្នកមានសេចក្ដីចម្រើនខ្លះ ជាអ្នកគប់រកកល្យាណមិត្ត ដែលទ្រទ្រង់នូវព្រះវិន័យ ដូចព្រះឧបាលិត្ថេរខ្លះ តែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ ឧទ្ធច្ចកុក្កុច្ចៈ រមែងលះបាន ដោយពោលពាក្យជាទីសប្បាយ អាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងទីឈរ និងទីអង្គុយជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ តែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។

វិចិកិច្ឆា មានការកើតឡើងដោយអយោនិសោមនសិការក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃវិចិកិច្ឆា គឺការសង្ស័យនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា ព្រោះជាហេតុសង្ស័យរឿយៗ កាលឲ្យអយោនិសោមនសិការក្នុងវិចិកិច្ឆានោះប្រព្រឹត្តទៅរឿយៗ វិចិកិច្ឆាក៏កើតឡើង ដោយហេតុនោះ ទើប

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានធម៌ទាំងឡាយដែលបណ្តាលឲ្យកើតវិចិកិច្ឆា និងការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌ជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ដូច្នេះ ។ ឯការលះវិចិកិច្ឆា មានដោយយោនិសោមនសិការក្នុងធម៌ទាំងឡាយ មានកុសលជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានពួកធម៌ជាកុសល និងអកុសល ពួកធម៌ដែលប្រកបដោយទោស និងឥតទោស ពួកធម៌ដែលថោកទាប និងថ្លៃថ្លា ពួកធម៌ជាចំណែកខ្មៅ និងស និងការធ្វើនូវយោនិសោមនសិការឲ្យច្រើនក្នុងធម៌ទាំងនោះ នេះធម៌មិនមែនជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើត ឲ្យកើតឡើងបាន ឬរបស់វិចិកិច្ឆាដែលកើតហើយ ឲ្យរឹងរឹតតែកើតច្រើនឡើង ។

## ធម៌សម្រាប់លះវិចិកិច្ឆា ៦ យ៉ាង

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ **ពហុស្សុតតា** ជាពហូសូត ១ **បរិបុច្ឆកតា** ការសាកសួរ ១ **វិនយេបកតញ្ញុតា** ការដឹងជុំវិញក្នុងព្រះវិន័យ ១ **អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនទៅដោយអធិមោក្ខ ១ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ១ **សប្បាយកថា** ពោលនូវពាក្យជាទីសប្បាយ ១ ។

បុគ្គលអ្នករៀនយក ១ និកាយខ្លះ ។បេ។ ៥ និកាយខ្លះ ដោយអំណាចនៃបាលី និងអដ្ឋកថា រមែងលះវិចិកិច្ឆាបាន ។ បុគ្គលសាកសួរច្រើន ក្នុងធម៌

ទាំងឡាយ មានប្រភេទកុសលជាដើម ប្រារព្ធរតនៈទាំង ៣ ខ្លះ ជាអ្នកដឹងព្រោះភាពជាអ្នកប្រព្រឹត្តជំនាញក្នុងព្រះវិន័យខ្លះ ជាអ្នកច្រើនដោយអធិមោក្ខ ពោល គឺការជឿដើម្បីកំណត់ក្នុងព្រះរតនត្រ័យខ្លះ ជាអ្នកសមាគម គប់រកកល្យាណមិត្តដែលបង្អោនទៅក្នុងសទ្ធា ដូចព្រះវក្កលិត្ថេរខ្លះ រមែងលះវិចិកិច្ឆាបាន ។ រមែងលះវិចិកិច្ឆាបាន ដោយការពោលពាក្យជាទីសប្បាយ អាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងទីដែលឈរ និងទីដែលអង្គុយជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ។

ក្នុងអធិការនេះ បណ្ដានីវរណៈទាំងនេះ ដែលលះបានហើយ ដោយអំណាចវិក្ខម្ភនប្បហានដោយធម៌ទាំងនោះ តាមដែលពោលមកហើយ កាមច្ឆន្ទនីវរណៈ មានការលះបានជាសមុច្ឆេទ ដោយអរហត្តមគ្គ ។ ថីនមិទ្ធនីវរណៈ និងឧទ្ធច្ចនីវរណៈក៏យ៉ាងនោះ គឺលះបានជាសមុច្ឆេទដោយអរហត្តមគ្គ ។ ឯព្យាបាទនីវរណៈ និងកុក្កុច្ចនីវរណៈ មានការលះបានជាសមុច្ឆេទដោយអនាគាមិមគ្គ វិចិកិច្ឆានីវរណៈ មានការលះបានជាសមុច្ឆេទ ដោយសោតាបត្តិមគ្គ ។ ព្រោះដូច្នោះ កាលទ្រង់សម្ដែងធម៌ដែលជាឧបការៈដល់ការលះនីវរណៈទាំងនោះ ទើបទ្រង់ប្រារព្ធពាក្យជាដើមថា **អារទ្ធំ ហោតិ វីរិយំ** ដូច្នេះ ។ ម្យ៉ាងទៀត ការលះនីវរណៈ មានអភិជ្ឈាជាដើម តាមដែលបានពោលមកហើយ គឺវីរិយៈដែលបានប្រារព្ធហើយនោះឯង ព្រោះតាំងអំពីកាលណាមក បុគ្គលឈ្មោះថា ខ្ជិលច្រអូសហើយ ព្រោះប្រាសចាកសេចក្តី

ព្យាយាម ឈ្មោះថា មានស្មារតីបាត់បង់ហើយ ព្រោះមិនចូលទៅតម្កល់នូវស្មារតី ឈ្មោះថា មានកាយក្រវល់ក្រវាយ ព្រោះថា រម្ងាប់នូវការក្រវល់ក្រវាយមិនទាន់បាន ឈ្មោះថា មានចិត្តរាយមាយ ព្រោះថា មានចិត្តមិនទាន់តាំងមាំហើយ មិនអាចញុំាងធម៌នោះឲ្យកើតឡើងបានឡើយ នឹងពោលថ្វីដល់ទៅញុំាងធម៌ក្រៅអំពីនេះឲ្យកើតឡើងបាន ដូច្នោះ ដើម្បីទ្រង់សម្តែងដល់វិធីដែលការទៅប្រាស គឺការលះអភិជ្ឈាជាដើមនោះ និងសម្រេចដល់អ្នកបដិបត្តិបាន ទើបទ្រង់ប្រារព្ធពាក្យជាដើមថា **អារទ្ធំ ហោតិ វីរិយំ** មានវីរិយៈប្រារព្ធហើយ ។

ពាក្យនេះ មានអត្ថថា សេចក្តីព្យាយាមដែលភិក្ខុនោះប្រារព្ធហើយ គឺផ្តងហើយ មានអធិប្បាយថា ប្រព្រឹត្តទៅហើយដោយមិនធូរថយ ដើម្បីលះនីវរណៈទាំងនោះ គឺដើម្បីជាប្រយោជន៍ដល់ការកាត់សង្កិលេសធម៌ទាំងអស់ ។ សេចក្តីព្យាយាម ឈ្មោះថា មិនធូរថយ ព្រោះមិនរួញរាក្នុងចន្លោះ ព្រោះប្រារព្ធហើយនោះឯង ។ បទថា **ឧបដ្ឋិតា សតិ អប្បមុដ្ឋា** សេចក្តីថា មិនមែនត្រឹមតែសេចក្តីព្យាយាមដែលប្រារព្ធហើយតែម្យ៉ាងនោះទេ ទោះបីសតិក៏ឈ្មោះថា ចូលទៅតម្កល់ហើយ ព្រោះមានមុខចំពោះអារម្មណ៍ ម្យ៉ាងទៀត ឈ្មោះថា មិនវង្វេងហើយ ព្រោះបានចូលទៅតម្កល់ហើយនោះឯង និងព្រោះអាចរឭកដល់រឿងដែលធ្វើ និងពាក្យដែលនិយាយ ទោះបីយូរហើយបាន ។ បទថា **បស្សទ្ធោ** សេចក្តីថា សូម្បីកាយរបស់ភិក្ខុនោះ ក៏ស្ងប់រម្ងាប់ហើយ ព្រោះរម្ងាប់នូវការក្រវល់ក្រវាយកាយ និងចិត្តបាន ។ ព្រោះហេតុដែលបណ្តា

នាមកាយ និងរូបកាយទាំង ២ យ៉ាងនោះ កាលនាមកាយស្ងប់ហើយ សូម្បីរូបកាយក៏ស្ងប់ទៅដែរ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **បស្សទ្ធោ កាយោ** ដោយការមិនប្លែកថា **នាមកាយោ រូបកាយោ**។ បទថា **អសារទ្ធោ** សេចក្តីថា បុគ្គលនោះឈ្មោះថា មិនរសាប់រសល់ហើយ ព្រោះជាអ្នកស្ងប់ហើយនោះឯង អធិប្បាយថា ជាអ្នកមានការក្រវល់ក្រវាយប្រាសទៅហើយ ។ បទថា **សមាហិតំ ចិត្តំ ឯកគ្គំ** សេចក្តីថា សូម្បីចិត្តរបស់ភិក្ខុនោះតាំងមាំហើយដោយប្រពៃ គឺតាំងទុកហើយដោយល្អ បានដល់ ចុះស៊ប់ហើយ និងព្រោះតាំងមាំហើយនោះឯង ទើបមានឯកគ្គតារម្មណ៍ គឺមិនញាប់ញ័រ បានដល់មិនអន្ទះអន្ទែង ដោយអត្ថថា មិនកម្រើក ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់ត្រាស់ដល់បដិបទាដែលជាខាងដើមនៃឈាន និងមគ្គ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុបើទុកជាកំពុងដើរទៅ តែមានសភាពយ៉ាងនេះហើយ ហៅថា ជាអ្នកមាន ព្យាយាមដុតកំដៅកិលេស ក្តៅនឹងបាប ប្រារព្ធព្យាយាមជានិច្ចកាល មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ដូច្នេះ ។ អត្ថនៃពុទ្ធវចនៈនោះ បានពោលខាងដើមហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **យតំ ចរេ** សេចក្តីថា ភិក្ខុគប្បីដើរទៅ គឺព្យាយាមទៅ អធិប្បាយថា កំពុងសម្រេចការដើរដោយអំណាចនៃការដើរចង្ក្រមជាដើម គឺព្យាយាមតជាប់ជានិច្ច ដោយអំណាចនៃសេចក្តីព្យាយាម គឺសម្មប្បធានតាមដែលពោលមកហើយ ក្នុងវិភង្គ ដោយន័យជាដើមថា ភិក្ខុ ឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាតប្រារព្ធ

ព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ដូច្នេះ ។ គួរសម្រេចការដើរទៅជាដើម ដោយវិធីដែលនឹងលះអកុសលធម៌ទាំងឡាយបាន កុសលធម៌ទាំងឡាយ ដល់នូវការបរិបូណ៌ ដោយការនា ក្នុងបទដ៏សេសទាំងឡាយ ក៏មានន័យនេះឯង ។

ឯអាចារ្យពួកខ្លះ ពោលអត្ថរបស់បទ **យតំ** នេះថា បានដល់ **សំយតោ** គឺសង្រួមហើយ ។ បទថា **តិដ្ឋេ** បានដល់ គប្បីឈរ គឺគប្បីសម្រេចការឈរ ។ បទថា **អច្ឆេ** បានដល់ គប្បីអង្គុយ ។ បទថា **សយេ** បានដល់ គប្បីដេក ។ បទថា **យតមេតំ បសារយេ** សេចក្តីថា ភិក្ខុព្យាយាម បានដល់ ជាអ្នកដល់ព្រមដោយសេចក្តីព្យាយាមតាមដែលពោលមកហើយ គប្បីលាចេញទៅនូវដៃ និងជើងជាដើមនោះ ដែលគួរលាចេញទៅ អធិប្បាយថា គប្បីលះនូវសេចក្តីប្រមាទក្នុងទីគ្រប់អន្លើ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងបដិបទាដែលភិក្ខុកាលបដិបត្តិ ឈ្មោះថា ជាអ្នកព្យាយាម គឺប្រឹងប្រែង ទើបបានត្រាស់ពាក្យជាដើមថា **ឧទ្ធំ** ។ បណ្តាបទទាំងនោះ បទថា **ឧទ្ធំ** បានដល់ ខាងលើ ។ បទថា **តិរិយំ** បានដល់ ទិសទទឹង អធិប្បាយថា ក្នុងទិសាភាគដោយជុំវិញ មានទិសខាងកើតជាដើម ។ បទថា **អបាចីនំ** បានដល់ ទិសខាងក្រោម ។ បទថា **យាវតា ជគតោ គតិ** សេចក្តីថា ការប្រព្រឹត្តទៅរបស់សត្វលោកដែលចែកជាសត្វ និងសង្ខារ មានប្រមាណប៉ុនណា ក្នុងការប្រព្រឹត្តទៅមានប្រមាណប៉ុណ្ណោះ អធិប្បាយថា ក្នុងទីសព្វអន្លើ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ព្រះមានព្រះភាគ ទ្រង់

*សម្តែងដោយសង្គ្រោះយកអារម្មណ៍របស់សមសនញ្ញាណ ដោយមិនសេសសល់ ។ បទថា* **សមវេក្ខិតា** *សេចក្តីថា បានពិចារណាហើយដោយប្រពៃ គឺដោយហេតុ បានដល់ ដោយន័យ អធិប្បាយថា ជាអ្នកពិចារណាឃើញច្បាស់ ដោយអំណាចនៃអនិច្ចលក្ខណៈជាដើម ។ បទថា* **ធម្មានំ** *បានដល់ សភាវៈដែលសូន្យចាកសត្វ ។ បទថា* **ខន្ធានំ** *បានដល់ ខន្ធ ៥ មានរូបជាដើម ។ បទថា* **ឧទយព្វយំ** *បានដល់ ទាំងការកើតឡើង ទាំងការវិនាសទៅ ។ មានពាក្យអធិប្បាយដូច្នេះថា ភិក្ខុគប្បីពិចារណា គឺពិចារណាឃើញរឿយៗ នូវការកើត ដោយអាការ ២៥ យ៉ាង និងការអស់ទៅដោយអាការ ២៥ យ៉ាង ដោយឧទយព្វយញ្ញាណ ដែលសម្រេចបានដោយការពិចារណានូវការមិនទៀងជាដើមនៃរូបធម៌ និងអរូបធម៌ទាំងឡាយ ពោល គឺឧបាទានក្ខន្ធ ៥ ដែលមានដោយការចែកចេញជាអតីតជាដើមក្នុងសត្វលោកទាំងអស់ ដែលសង្គ្រោះជា ៣ គឺខាងលើ ទទឹង និងខាងក្រោម ។*

*បទថា* **ចេតោសមថសាមីចិ** *បានដល់ មាននូវទស្សនវិសុទ្ធិដែលជាបដិបទា សមគួរដល់អរិយមគ្គ ពោល គឺចេតោសមថៈ ព្រោះស្ងប់រម្ងាប់សង្កិលេសនៃចិត្តដោយឥតសេសសល់ ។ បទថា* **សិក្ខមានំ** *សេចក្តីថា បដិបត្តិ គឺចម្រើន ដោយអត្ថថា ញុំាងញាណខ្ពស់ៗ ឲ្យកើតឡើង ។ បទថា* **សទា** *សេចក្តីថា សព្វកាលទាំងពួង គឺពេលយប់ផង ពេលថ្ងៃផង ។ បទថា* **សតំ** *សេចក្តីថា បុគ្គលធ្វើសតិ ដោយសតិដែលប្រកបដោយសម្បជញ្ញៈ ៤ ។ បទថា* **សតតំ បហិតត្តោ** *សេចក្តីថា ព្រះអរិយៈទាំងឡាយ មានព្រះ*

សមុទ្ទជាដើមត្រាស់ហើយ គឺរមែងប្រាប់ បានដល់ រមែងហៅភិក្ខុដែលមានសភាពបែបនោះយ៉ាងនេះថា ជាបុគ្គលមានចិត្តស្ងប់សព្វកាល គឺជាអ្នកបញ្ជូនចិត្តទៅកាន់ព្រះនិព្វាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ល។

**អដ្ឋកថា សីលសម្បន្នសូត្រទី ១២ ចប់**

# សុត្តន្តបិដក

## លោកសូត្រ

[ ១១៥ ] ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ លោក ( ទាំងមូល ) តថាគតបានត្រាស់ដឹងច្បាស់ហើយ តថាគតជាបុគ្គលប្រាសចាកលោក ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងបណ្តាលឲ្យកើតលោក តថាគតបានត្រាស់ដឹងច្បាស់ហើយ ធម៌ជាគ្រឿងបណ្តាលឲ្យកើតលោក តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងរលត់ទៅនៃលោក តថាគតបានត្រាស់ដឹងច្បាស់ហើយ ធម៌ជាគ្រឿងរលត់ទៅនៃលោក តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ បដិបទាប្រព្រឹត្តទៅកាន់ទីរលត់ទៅនៃលោក តថាគតបានត្រាស់ដឹងច្បាស់ហើយ បដិបទាប្រព្រឹត្តទៅកាន់ទីរលត់ទៅនៃលោក តថាគតបានអប់រំហើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលលោក ព្រមទាំង

ទេវតា មារ និងព្រហ្ម ពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ បានឮ បានប៉ះពាល់ បានដឹង បានដល់ បានស្វះស្វែងរក បានរាវរក ដោយចិត្តហើយ របស់នោះ តថាគតបានត្រាស់ដឹងច្បាស់ហើយ ព្រោះហេតុណា ហេតុនោះ បានជាហៅថាព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងរាត្រីណាផង បរិនិព្វានទៅដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណាផង សម្តែង ចរចា ពន្យល់នូវសត្ថុសាសនា ក្នុងចន្លោះរាត្រីទាំងពីរនុ៎ះ សត្ថុសាសនាទាំងអស់នោះ ក៏នៅជាយ៉ាងនោះដដែល មិនប្រែទៅជាយ៉ាងដទៃឡើយ ព្រោះហេតុនោះ បានជាហៅថា ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះតែពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះឯង ព្រោះហេតុនោះ បានជាហៅថា ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតជាអ្នកគ្របសង្កត់លើសត្វឯទៀត ( ដោយគុណ ) សត្វឯទៀត គ្របសង្កត់ ( តថាគតវិញ ) មិនបាន ជាអ្នកឃើញហេតុសព្វគ្រប់ ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ បានជាហៅថា ព្រះតថាគត ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា

អ្នកប្រាជ្ញ បានដឹងច្បាស់ នូវលោកទាំងពួង ក្នុងលោកទាំងពួង ដោយពិត ជាអ្នកប្រាសចាកលោកទាំងពួង ក្នុងលោកទាំងពួង មិនមាននរណាប្រៀបបាន ជាអ្នកគ្របសង្កត់លោកទាំងអស់ ( ដោយគុណ ) ជាអ្នកញុំាងលោកទាំងអស់ ឲ្យផុតចាកគ្រឿងចំពាក់ទាំងពួង ព្រះនិព្វានជាទីស្ងប់រម្ងាប់យ៉ាងក្រៃលែង មិនមានភ័យអំពីទីណាៗ ដល់អ្នកប្រាជ្ញដែលបានហើយ អ្នកប្រាជ្ញនុ៎ះ ជាព្រះខីណាស្រពត្រាស់ដឹងនូវសច្ចៈ ៤ ជាបុគ្គលមិនមានទុក្ខ បានកាត់ផ្តាច់នូវសេចក្តីសង្ស័យ ដល់នូវការអស់ទៅនៃកម្មទាំងពួង មានចិត្តផុតស្រឡះ ក្នុងធម៌ជាគ្រឿងអស់ទៅនៃកិលេស អ្នកប្រាជ្ញនុ៎ះ ជាព្រះពុទ្ធលែងវិលមកកាន់កពថ្មីទៀត អ្នកប្រាជ្ញនុ៎ះ ជាសីហៈ ( អ្នកកម្ចាត់នូវកិលេស ) ដ៏ប្រសើរ ញុំាងចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ដល់លោក ព្រមទាំងទេវលោក ។ ពួកទេវតា និងមនុស្សណា បានដល់ព្រះពុទ្ធ ជាទីរឭកទេវតា និងមនុស្សទាំងនោះ ក៏មកប្រជុំនមស្ការចំពោះព្រះពុទ្ធដែលមានព្រះហឫទ័យក្លៀវក្លាដ៏ប្រសើរនោះ ។ ព្រះពុទ្ធ ព្រះអង្គទូន្មានខ្លួនដ៏ប្រសើរ ជាងពួកជនអ្នកទូន្មានខ្លួន ព្រះអង្គស្ងប់រម្ងាប់ដ៏ប្រសើរ ជាងពួកជន

អ្នកស្ងប់រម្ងាប់ ព្រះអង្គស្វែងរកនូវគុណ មានសីល-
គុណជាដើម ព្រះអង្គមានចិត្តរួចស្រឡះ ដ៏ប្រសើរ
ជាងពួកជនអ្នកមានចិត្តរួចស្រឡះ ព្រះអង្គឆ្លងផុតដ៏
ប្រសើរជាងជន អ្នកឆ្លងទាំងឡាយ ។ ព្រោះហេតុ
នោះឯង ទើបពួកទេវតា និងមនុស្ស តែងនមស្ការ
ចំពោះព្រះពុទ្ធ ដែលមានព្រះហឫទ័យក្លៀវក្លាដ៏ប្រសើរ
អង្គនុ៎ះ ។ ក្នុងលោក ព្រមទាំងទេវលោក ឥតមាន
បុគ្គលណា ប្រៀបផ្ទឹមនឹងព្រះអង្គបានឡើយ ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ សូត្រទី ១៣ ។

ចតុក្កនិបាត ចប់

## ឧទ្ទាននៃចតុក្កនិបាតនោះ គឺ

និយាយអំពីព្រះមានព្រះភាគជាព្រាហ្មណ៍ ១ វត្ថុងាយ
បាន ៤ យ៉ាង ១ ការអស់ទៅនៃអាសវៈ របស់បុគ្គល
អ្នកដឹង ១ ពួកសមណព្រាហ្មណ៍ ១ ពួកភិក្ខុមានសីល
១ តណ្ហា ១ ត្រកូលដែលនៅរួមនឹងព្រហ្មជាដើម ១
ពួកព្រាហ្មណ៍ និងគហបតីមានឧបការៈច្រើន ១ ពួក
ភិក្ខុអ្នកធ្វើឲ្យគេស្ញើបជាដើម ១ បុរសត្រូវទឹកស្ទឹងក្ឈួច
១ អកុសលវិតក្កកើតដល់ភិក្ខុកំពុងដើរទៅជាដើម ១

ភិក្ខុមានសីលបរិបូណ៌ជាដើម ១ ព្រះតថាគតត្រាស់
ដឹងនូវលោក ១ រួមជា ១៣ រឿង ។

ក្នុងឥតិវុត្តកៈ មានសូត្រ ១១២

ឥតិវុត្តកៈ ចប់

# អដ្ឋកថា

## លោកសូត្រ

[ ១១៥ ] ក្នុងលោកសូត្រទី ១៣ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **លោកោ** សេចក្តីថា ឈ្មោះថា **លោក** ព្រោះអត្ថថា វិនាសទៅ បែកធ្លាយទៅ ។ ដោយអត្ថ បានដល់ អរិយសច្ច ២ ខាងដើម តែក្នុងទីនេះ គប្បីជ្រាបថា បានដល់ ទុក្ខអរិយសច្ច ។ លោកទាំងនេះ បានពោលហើយខាងដើមនោះឯង ទាំងដោយការបែកចេញទៅ និងដោយសរុបថា សត្វលោក សង្ខារលោក និងឱកាសលោក ។

ម្យ៉ាងទៀត លោកមានច្រើនយ៉ាង ដោយអំណាចខន្ធលោកជាដើម ( ដូចលោកពោលក្នុងបដិសម្ភិទាមគ្គ ) ថា ពាក្យថា **លោក** បានដល់ ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក គឺអបាយលោក វិបត្តិសម្ភវលោក គឺអកុសលកម្មដែលនាំទៅកើតក្នុងអបាយ សម្បត្តិភវលោក គឺសុគតិលោក សម្បត្តិសម្ភវលោក គឺកុសលកម្មដែលនាំទៅកើតក្នុងសុគតិ-

លោក លោក ១ បានដល់ ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់ វេទនា ៣ លោក ៤ បានដល់ អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ ទីតាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់ លោកធម៌ ៨ លោក ៩ បានដល់ ទីនៅរបស់សត្វ ៩ លោក ១០ បានដល់ អាយតនៈទាំង ១០ លោក ១២ បានដល់ អាយតនៈ ១២ លោក ១៨ បានដល់ ធាតុ ១៨ ។ លោក ទោះបីចែកទៅច្រើនយ៉ាង ដូចពណ៌នាមកនេះ រមែងដល់នូវការសង្គ្រោះ គឺសមោធានចូលក្នុងខន្ធ ៥ ប៉ុណ្ណោះ ។ ឯឧបាទានក្ខន្ធ ក៏ជាជាទុក្ខអរិយសច្ច គឺជាតិទុក្ខ ។បេ។ ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ ដោយហេតុនោះ ទើបលោកពោលថា ដោយអត្ថ បានដល់ អរិយសច្ច ២ ខាងដើម តែក្នុងព្រះសូត្រនេះ គប្បីជ្រាបថា បានដល់ ទុក្ខអរិយសច្ច ។ សួរថា អត្ថថា វិនាសទៅ បែកធ្លាយទៅ រមែងមានក្នុងខន្ធ ៥ ដោយមិនប្លែកគ្នាមិនមែនឬ ឆ្លើយថា មានពិត តែវត្ថុណាដែលប្រកាន់ថា មិនបែកធ្លាយទៅ វត្ថុនោះ មិនមែនយ៉ាងនោះឡើយ រមែងវិនាស និងបែកធ្លាយទៅដោយចំណែកមួយប៉ុណ្ណោះ ព្រោះដូច្នោះ ទើបសភាវៈនោះ ឈ្មោះថា **លោក ។ លោក** សព្ទ គប្បីជ្រាបថា កំណត់ពិតប្រាកដហើយ ក្នុងឧបាទានក្ខន្ធទាំងឡាយប៉ុណ្ណោះ ។ ព្រោះហេតុនោះ ពាក្យថា **លោក** ទើបជាទុក្ខសច្ចប៉ុណ្ណោះ ។ បើអត្ថនៃ **តថាគត** សព្ទ ខ្ញុំបានចែកហើយ ដោយន័យផ្សេងៗ យ៉ាងពិស្តារ ក្នុងតថាគតសូត្រខាងដើមសោត

ទោះបីជាយ៉ាងនោះ ក្នុងទីនេះ គប្បីមានការពង្រីកសេចក្ដីឲ្យជាក់ច្បាស់ដោយមុខ គឺពណ៌នាអត្ថនៃបាលីដូចតទៅនេះ

បទថា **អភិសម្ពុទ្ធោ** សេចក្ដីថា ជាបឋម ដោយមិនប្លែកគ្នាតាមការចែកដែលបានពោលហើយខាងដើមថា **អភិញ្ញេយ្យតោ** គឺការដឹងក្រៃលែង **បរិញ្ញេយ្យតោ** គឺដោយការកំណត់ដឹង ឬដោយការចែកកុសល អកុសលជាដើមដែលចែកជាអាសយក្កិលេស អនុសយក្កិលេស ចរិយា និងអធិមុត្តិជាដើម ឬថា ពោលដោយប្លែកគ្នាដែលចែកជាប្រមាណនៃវណ្ណៈ និងសណ្ឋានជាដើម ព្រះមានព្រះភាគ ទ្រង់ដឹង គឺទ្រង់ជ្រាប បានដល់ ទ្រង់ធ្វើប្រយោជន៍ដែលមនុស្សទាំងឡាយគប្បីដឹងដោយប្រការណាមួយ ឲ្យប្រចក្សដល់ព្រះអង្គដោយប្រការនោះៗ ដោយប្រពៃ គឺមិនខុសក្លាំងក្លាត់ ដោយសយម្ភូញាណដ៏កំពូលជាដើមថា បុគ្គលនេះ មានអាសយៈទៀង បុគ្គលនេះ មានអាសយៈដាច់សូន្យ និងទ្រង់ដឹងនូវបឋវីធាតុថា មានលក្ខណៈរឹង អាបោធាតុ មានលក្ខណៈហូរទៅ ព្រោះដូច្នោះ ទើបព្រះនាមថា **អភិសម្ពុទ្ធ** ។

បទថា **លោកស្មា** សេចក្ដីថា ចាកលោកតាមដែលពោលហើយ ។ បទថា **វិសំយុត្តោ** សេចក្ដីថា មិនជាប់ជំពាក់ហើយ អធិប្បាយថា ផុតអំពីលោកនោះ ព្រោះកាត់នូវសំយោជនៈទាំងអស់ដែលទាក់ទងដោយលោកនោះចេញ ដោយប្រពៃនោះឯង ។

បទថា **លោកសមុទយោ** បានដល់ តណ្ហាតាមសុត្តន្តន័យ តែតាមអភិធម្មន័យ បានដល់ កិលេស ១៥០០ មួយអន្លើដោយអភិសង្ខារទាំងឡាយ

បទថា **បហីនោ** បានដល់ ទ្រង់លះកិលេស មួយអន្លើដោយវាសនាបាន ដោយសមុច្ឆេទប្បហាន ដោយអរហត្តមគ្គញ្ញាណ ត្រង់ពោធិមណ្ឌល ។ បទថា **លោកនិរោធោ** បានដល់ ព្រះនិព្វាន ។ បទថា **សច្ឆិកតោ** បានដល់ ធ្វើឲ្យប្រចក្សដល់ព្រះអង្គឯង ។ បទថា **លោកនិរោធគាមិនី បដិបទា** បានដល់ អដ្ឋង្គិកមគ្គដ៏ប្រសើរ សង្គ្រោះក្នុងខន្ធ ៣ មានសីលក្ខន្ធជាដើម ។ ព្រោះថា ផ្លូវនោះនាំទៅដល់ គឺសម្រេចនិព្វានដែលជាលោកនិរោធ ឬដែលអរិយៈទាំងឡាយដើរទៅដើម្បីនិព្វាននោះ ព្រោះដូច្នោះ ទើបហៅថា លោកនិរោធ-គាមិនីបដិបទា ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់សម្តែងអត្ថនេះថា ឈ្មោះថា តថាគត ព្រោះត្រាស់ដឹងក្រៃលែង គឺតាមសេចក្តីពិត នូវវត្ថុដែលពិត អធិប្បាយថា អរិយសច្ច ៤ ឈ្មោះថា **តថ** គឺធម៌ពិត ។ សមដូចព្រះមានព្រះភាគត្រាស់ក្នុងសំយុត្តនិកាយ មហាវារវគ្គថា ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាងនេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ។ ធម្មជាត ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ដូច្នេះ ។ គប្បីជ្រាបសេចក្តីពិស្តារតទៅ

ម្យ៉ាងទៀត ឈ្មោះថា តថាគត ព្រោះយាងទៅដើម្បីវត្ថុដែលពិត ឈ្មោះថា តថាគត ព្រោះទ្រង់ដល់វត្ថុដែលពិត ម្យ៉ាងទៀត បទថា **គតោ** បានដល់ ទ្រង់សម្រេចហើយ គឺទ្រង់ចូលមកហើយ សេចក្តីថា ទ្រង់ដល់ហើយ

អធិប្បាយថា ទ្រង់បដិបត្តិហើយ ។ មានពាក្យអធិប្បាយដូច្នេះថា ព្រោះព្រះមានព្រះភាគយាងដល់ គឺសម្រេចហើយនូវសកលលោក ដោយតីរណប្បរិញ្ញា ដែលជាសេចក្តីពិត មិនខុសក្លាំងក្លាត់ ដូច្នោះ ទើបទ្រង់ព្រះនាមថា តថាគត ព្រោះព្រះតថាគតត្រាស់ដឹងនូវលោកហើយ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ដល់ គឺយាងឆ្លងលោកសមុទយៈហើយ ដោយបហានប្បរិញ្ញា ដែលជាសេចក្តីពិត មិនខុសក្លាំងក្លាត់ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងដល់ គឺសម្រេចដល់លោកនិរោធ ដោយការធ្វើឲ្យជាក់ច្បាស់តាមសេចក្តីពិត ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ដល់ គឺទ្រង់បដិបត្តិនូវបដិបទាដែលឲ្យដល់ការរម្ងត់លោក ដែលជាសេចក្តីពិត មិនខុសក្លាំងក្លាត់ អ្នកសិក្សាគប្បីជ្រាបអត្ថនៃព្រះបាលីនេះ ដោយអំណាចការសម្តែងដល់ភាពដែលព្រះមានព្រះភាគជាព្រះតថាគត ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសភាពដែលព្រះអង្គជាព្រះតថាគត ដោយអំណាចនៃការត្រាស់ដឹងអរិយសច្ច ៤ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់ភាពដែលទ្រង់ជាព្រះតថាគតនោះ ដោយអំណាចនៃការត្រាស់ដឹងធម៌ដែលទ្រង់ឃើញហើយជាដើមក្នុងសច្ចៈ ៤ នោះ ទើបត្រាស់ពាក្យជាដើមថា **យំ ភិក្ខវេ** ។ តែក្នុងអដ្ឋកថាអង្គុត្តរនិកាយ លោកពោលពាក្យជាដើមថា កាលត្រាស់ភាពដែលព្រះអង្គជាព្រះពុទ្ធ ព្រោះសច្ចៈទាំង ៤ ហើយដូច្នេះ ។ ពាក្យនោះ លោកពោលដើម្បីសម្តែងថា សព្ទថា **តថាគត** និងសព្ទថា **ពុទ្ធ** ដោយអត្ថហើយ មិនមានសេចក្តីប្លែកគ្នាឡើយ ម្យ៉ាងទៀត

សេចក្តីពិត ព្រះបាលី ក៏ប្រព្រឹត្តទៅហើយយ៉ាងនោះដូចគ្នា ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋំ** បានដល់ អាយតនៈ គឺរូប ។ បទថា **សុតំ** បានដល់ អាយតនៈ គឺសំឡេង ។ បទថា **មុតំ** បានដល់ អាយតនៈ គឺក្លិន អាយតនៈ គឺរស អាយតនៈ គឺផោដ្ឋព្វៈ ព្រោះត្រូវជួបយ៉ាងជិត ទើបទទួលយកបាន ។ បទថា **វិញ្ញាតំ** បានដល់ ធម្មារម្មណ៍ មានសុខទុក្ខជាដើម ។ បទថា **បត្តំ** បានដល់ ដែលមកជួប ដោយបានស្វែងរក ឬមិនបានស្វែងរកក៏ដោយ ។ បទថា **បរិយេសិតំ** បានដល់ ស្វែងរកអារម្មណ៍ដែលមកជួបខ្លះ ដែលមិនមកជួបខ្លះ ។ បទថា **អនុវិចរិតំ មនសា** បានដល់ អារម្មណ៍ដែលពិចារណាដោយចិត្ត ។ គួរភ្ជាប់សេចក្តីថា សួរថា ពិចារណាដោយចិត្តរបស់អ្នកណា ឆ្លើយថា ពិចារណាដោយចិត្ត របស់លោក ព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សទេវកស្ស លោកស្ស** តទៅ សត្វលោកមួយអន្លើដោយទេវលោកទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា **សទេវ-លោក** ប្រែថា នៃសត្វលោក ព្រមទាំងទេវលោកនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនោះដូចគ្នា ។ ដោយពាក្យថា **សទេវក** ក្នុងសូត្រនេះ គប្បីជ្រាបដល់ការដែលទ្រង់កាន់យកទេវតាជាន់កាមាវចរ ៥ ជាន់ ។ ដោយពាក្យថា **សមារក** គប្បីជ្រាបដល់ការដែលទ្រង់កាន់យកទេវតាជាន់កាមា-វចរទី ៦ ។ ដោយពាក្យថា **សព្រហ្មក** គប្បីជ្រាបដល់ការដែលទ្រង់សំដៅយកព្រហ្ម មានព្រហ្មកាយិកជាដើម ។ ដោយពាក្យថា **សស្សមណព្រាហ្មណា**

គប្បីជ្រាបថា ទ្រង់កាន់យកសមណព្រាហ្មណ៍ដែលជាសត្រូវចំពោះសាសនា ព្រោះទ្រង់កាន់យកសមណព្រាហ្មណ៍ដែលរម្ងាប់បាប និងបានបន្សាត់បាបហើយ ។ ដោយពាក្យថា **បជា** គប្បីជ្រាបថា ទ្រង់កាន់យកសត្វលោក ។ ដោយពាក្យថា **សទេវមនុស្ស** គប្បីជ្រាបថា ទ្រង់កាន់យកសម្មតិទេព និងមនុស្សដ៏សេស កាលបើដូច្នេះ សត្វលោក ព្រមដោយទេវតា មារ ព្រហ្មក្នុងសូត្រនេះ គប្បីជ្រាបថា ទ្រង់កាន់យកហើយ ដោយបទទាំង ៣ សត្វ-លោកប៉ុណ្ណោះ គប្បីជ្រាបថា ទ្រង់កាន់យកហើយ ដោយបទទាំង ២ ដោយអំណាចបជា ។ ម្យ៉ាងទៀត ទេវលោកជាន់អរូបាវចរ ទ្រង់កាន់យកហើយដោយសព្ទថា **សទេវក**។ ទេវលោកជាន់កាមាវចរ ដោយពាក្យថា **សមារក** ព្រហ្មលោកដែលមានរូប ដោយពាក្យថា **សព្រហ្មក** សត្វលោកដ៏សេសព្រមដោយសម្មតិទេព ទ្រង់កាន់យកហើយ ដោយពាក្យថា **សស្សមណ-ព្រាហ្មណា** សព្ទជាដើម ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់មានសត្វលោកទាំងអស់ជាអារម្មណ៍ ទ្រង់បានប្រកាសភាពដែលជាអ្នកបានត្រាស់ដឹងហើយ ដោយការកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា **សទេវក** ក្នុងព្រះសូត្រនេះ កាលបើដូច្នេះជនពួកណា គប្បីមានការយល់ខុសថា មារ ឈ្មោះ **វសវត្តី** មានអានុភាពច្រើន ជាធំក្នុងស្ថានសួគ៌ជាន់កាមាវចរមាន ។ តែព្រះព្រហ្មមានអានុភាពច្រើនជាងមារនោះ ប្រើម្រាមទាំង ១០ បំភ្លឺទៅក្នុងមួយម៉ឺនចក្រវាល សោយសុខដែលកើតអំពីឈានសមាបត្តិជាន់ខ្ពស់មាន ។ សមណព្រាហ្មណ៍ជាច្រើន ជា

អ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តរបស់អ្នកដទៃ មានអានុភាពច្រើននៅមាន ទាំងពួកសត្វនេះ ដែលមិនមានទីបំផុត មិនមានប្រមាណក៏នៅមាន អារម្មណ៍ របស់សត្វទាំងនោះឯង ព្រះមានព្រះភាគ ទ្រង់បានដឹងហើយ ដោយមិនមាន សេសសល់ ឬព្រះមានព្រះភាគ កាលទ្រង់កម្ចាត់ការយល់ខុសរបស់ជនទាំង នោះ ទើបបានត្រាស់ពាក្យជាដើមថា **សទេវកស្ស លោកស្ស**។ ឯបុរាណាចារ្យ បានពោលថា បទថា **សទេវកស្ស** គ្របដណ្តប់ដល់សត្វលោកមិនមាន សេសសល់ ព្រមដោយទេវតាទាំងឡាយ ។ បទថា **សមារកស្ស** គ្រប ដណ្តប់ដល់សត្វលោក មិនមានសេសសល់ មួយអន្លើដោយមារ ។ បទថា **សព្រហ្មកស្ស** គ្របដណ្តប់ដល់សត្វលោកមិនមានសេសសល់ ព្រមដោយ ព្រហ្មទាំងឡាយ ព្រះមានព្រះភាគ កាលទ្រង់ដាក់សត្វទាំងអស់ដែលចូល ដល់ភពទាំង ៣ ក្នុងបទ ៣ នោះហើយ កាលទ្រង់ប្រើ ២ បទ មកគ្រប ដណ្តប់ទៀត ទើបត្រាស់ថា **សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ** ។ ព្រះមានព្រះភាគ ទ្រង់គ្របដណ្តប់សត្វទាំងអស់ដែលកំណត់ ដោយខន្ធទាំង ៣ ដោយបទទាំង ៥ យ៉ាងនេះ ។

ដោយបទថា **យស្មា តំ តថាគតេន អភិសម្ពុទ្ធំ** ព្រះមានព្រះភាគ ទ្រង់សម្តែងពាក្យនេះ គឺរូបារម្មណ៍ឯណាមានពណ៌ខៀវ និងពណ៌លឿង ជាដើម មកកាន់គន្លងក្នុងចក្ខុទ្វាររបស់សត្វលោក ព្រមទាំងទេវលោក ក្នុង លោកធាតុដែលមានប្រមាណមិនបាន រូបារម្មណ៍ទាំងអស់ ព្រះតថាគតទ្រង់ បានដឹងហើយយ៉ាងនេះថា សត្វនេះឃើញរូបារម្មណ៍នេះ ក្នុងខណៈនេះហើយ

ត្រេកអរ ឬទោមនស្ស ឬកើតមានចិត្តជាកណ្តាល ។ សទ្ទារម្មណ៍ មាន សំឡេងស្គរ សំឡេងសម្ភោរជាដើមឯណា ក៏ដូច្នោះ មកកាន់គន្លងនៃសោត-ទ្វាររបស់សត្វលោក ព្រមទាំងទេវលោក ក្នុងលោកធាតុដែលប្រមាណមិនបាន គន្ធារម្មណ៍ មានក្លិនកើតអំពីឫស គល់ និងសម្បកជាដើមឯណានីមួយ មកកាន់គន្លងក្នុងឃានទ្វារ ... រសារម្មណ៍ មានរសកើតអំពីមើម រសកើតអំពីដើមជាដើម មកកាន់គន្លងក្នុងជិវ្ហាទ្វារ ... ផោដ្ឋព្វារម្មណ៍ ចែកជាបឋវីធាតុ តេជោធាតុ និងវាយោធាតុ មានរឹង និងទន់ជាដើមឯណានីមួយ មកកាន់គន្លង ក្នុងកាយទ្វាររបស់សត្វលោក ព្រមទាំងទេវលោក ក្នុងលោកធាតុដែលប្រមាណ មិនបាន ព្រះតថាគតទ្រង់ជ្រាបនូវផោដ្ឋព្វារម្មណ៍នោះ យ៉ាងនេះថា សត្វនេះ ពាល់ត្រូវនូវផោដ្ឋព្វៈឈ្មោះនេះ ក្នុងខណៈនេះហើយ ជាអ្នកត្រេកអរ ឬ ទោមនស្ស ឬកើតមានចិត្តជាកណ្តាល ។ ធម្មារម្មណ៍ដែលចែកជាសុខជាដើម ដែលមកកាន់គន្លងក្នុងមនោទ្វាររបស់សត្វលោក ព្រមទាំងទេវលោកនេះ ក្នុង លោកធាតុមិនមានប្រមាណ ធម្មារម្មណ៍ទាំងអស់នោះ ព្រះតថាគតបានត្រាស់ ដឹងហើយ យ៉ាងនេះថា សត្វនេះ ដឹងធម្មារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ ហើយ ជាអ្នកត្រេកអរ ឬទោមនស្ស ឬមានចិត្តជាកណ្តាល ។ កាលបើដូច្នេះ វត្ថុដែលសត្វលោក ព្រមទាំងទេវលោកនេះឃើញហើយ បានឮហើយ បាន ជ្រាបហើយ បានដឹងហើយ ព្រះតថាគតទ្រង់មិនឃើញ ទ្រង់មិនបានឮ ទ្រង់ មិនបានជ្រាប ឬត្រង់មិនដឹង មិនមាន ។ តែរូបជាដើមដែលមហាជននេះ ស្វែងរកហើយ តែមិនបានជួបមានខ្លះ ដែលមិនបានស្វែងរក ក៏មិនជួបមានខ្លះ

ដែលស្វែងរកហើយ បានជួបមានខ្លះ ដែលមិនបានស្វែងរក តែបានជួបមានខ្លះ ។ រូបជាដើមទាំងអស់ ដែលឈ្មោះថា ព្រះតថាគតទ្រង់មិនជួបហើយ គឺទ្រង់មិនធ្វើឲ្យជាក់ច្បាស់ដោយញាណហើយ មិនមាន ព្រោះហេតុនោះឯង ឈ្មោះថា រូបារម្មណ៍ឯណា ដែលមកកាន់គន្លងក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយប្រមាណមិនបាន ក្នុងលោកធាតុទាំងឡាយប្រមាណមិនបាន មានរូបារម្មណ៍នោះ ព្រះមានព្រះភាគ ទ្រង់ឃើញដោយអាការឥតសេសសល់ ។ រូបារម្មណ៍នោះ ដែលព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ឃើញយ៉ាងនេះ កាលទ្រង់ចែកចេញទៅតាមឈ្មោះជាច្រើន តាមវារៈ ១៣ វារៈ តាមន័យ ៥២ ន័យ ដោយន័យក្នុងធម្មសង្គណីជាដើមថា រូបជារូបាយតនៈនោះ តើដូចម្ដេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតរូបទាំង ៤ ជាវត្ថុដែលអាចឃើញបាន ប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ លឿង ... ដូច្នេះ ដោយអំណាចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ឬដោយអំណាចនៃបទដែលបានក្នុងរូបដែលបានឃើញ សំឡេង ដែលបានឮ ក្លិន រស និងផោដ្ឋព្វៈដែលបានជ្រាប ឯធម្មារម្មណ៍ដែលបានដឹងហើយ ក៏យ៉ាងនោះឯង មិនមានខុសអំពីនោះ ក្នុងសំឡេងជាដើម ដែលមកកាន់គន្លងក្នុងសោតទ្វារជាដើម ក៏មានន័យដូចគ្នា ។

បទថា **តស្មា តថាគតោតិ វុច្ចតិ** សេចក្ដីថា ព្រះសម្ពុទ្ធ បណ្ឌិតហៅថា **តថាគត** ព្រោះសត្វលោកពោលហើយ ដោយប្រការណា ក៏ត្រាស់ដោយប្រការនោះដូចគ្នា ។ ពាក្យណាដែលត្រាស់ក្នុងព្រះបាលីថា **អភិសម្ពុទ្ធំ** ពាក្យនោះមានអត្ថស្មើគ្នានឹង **តថាគត** សព្ទ ។ ដោយពាក្យថា **តថាគតោ**

នេះ ជាការដែលទ្រង់សម្ដែងសេចក្ដីនេះថា ឈ្មោះថា **តថាគត** ព្រោះភាព ជាបុគ្គលដែលទ្រង់សម្ដែងយ៉ាងនេះជាប្រក្រតី សមដូចពាក្យដែលព្រះធម្ម- សេនាបតីសារីបុត្របានពោលក្នុងខុទ្ទកនិកាយ មហានិទ្ទេសហើយថា

ហេតុទីមួយ ក្នុងលោកនេះ ដែលព្រះមានព្រះភាគនោះ ទ្រង់មិនឃើញ ឬថា មិនជ្រាប មិនយល់ មិនមានទេ ហេតុណា ដែលត្រូវដឹង ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវ ហេតុ ( នោះ ) ទាំងអស់ ព្រោះហេតុនោះ ទើបព្រះ តថាគត ឈ្មោះថា សមន្តចក្ខុ ដូច្នេះ ។

សូម្បីក្នុងព្រះសូត្រ ព្រះមានព្រះភាគ ក៏បានត្រាស់ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាតថា

ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំង ទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រម ទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្ស ដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់ នូវអារម្មណ៍នោះ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែល លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និង ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ និងមនុស្សជា សម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ

*ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងនូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹង ប្រាកដហើយ អារម្មណ៍នោះ មិនស្ថិតនៅក្នុងតថាគតទេ ។*

*បទថា* **យញ្ច ភិក្ខវេ រត្តឹ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ** *សេចក្តីថា ក្នុងរាត្រីដែលមានព្រះចន្ទ្រពេញវង់ ក្នុងខែវិសាខណា ព្រះមានព្រះភាគទ្រង់ព្រះនាមថា* **តថាគត** *ព្រោះអត្ថថា ទ្រង់យាងមកហើយ យ៉ាងនោះជាដើម គង់ប្រថាប់លើបល្ល័ង្កដែលមិនមានអ្នកដទៃផ្ចាញ់បាន ត្រង់មណ្ឌលពោធិព្រឹក្ស ទ្រង់ទម្លាយសីសៈរបស់មារទាំង ៣ ហើយទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណដ៏កំពូល ព្រោះមិនមានញាណដទៃក្រៃលែងជាង គឺសព្វញ្ញុតញ្ញាណ មួយអន្លើដោយអាសវក្ខយញ្ញាណ ។ បទថា* **យញ្ច រត្តឹ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ** *សេចក្តីថា ក្នុងរាត្រីដែលមានព្រះចន្ទ្រពេញវង់ ខែពិសាខនោះឯង ព្រះមានព្រះភាគទ្រង់បានបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមរាំងទាំងគូ ត្រង់សាលវនោទ្យានដែលជាទីសម្រាករបស់អ្នកមល្លៈ ក្នុងនគរកុសិនារា ។ បទថា* **យំ ឯតស្មឹ អន្តរេ** *សេចក្តីថា ក្នុងកណ្តាលរវាងសឧបាទិសេសនិព្វានធាតុ និងអនុបាទិសេសនិព្វានធាតុទាំង ២ យ៉ាងនេះ គឺក្នុងបឋមពោធិកាលខ្លះ ក្នុងមជ្ឈិមពោធិកាលខ្លះ ក្នុងបច្ឆិមពោធិកាលខ្លះ ក្នុងរយៈកាល ៤៥ ឆ្នាំ ព្រះមានព្រះភាគបានត្រាស់ព្រះធម៌ ចែកប្រភេទជាសុត្តៈ គេយ្យៈជាដើម ដោយអំណាចនៃការចង្អុលបង្ហាញ គឺត្រាស់ប្រាប់ដោយអំណាចនៃការលើកឡើងសម្តែង*

ទ្រង់លម្អិតសេចក្តីដោយអំណាចនៃការចែក ។ បទថា **សព្វំ តំ តថេវ ហោតិ** សេចក្តីថា ព្រះពុទ្ធវចនៈទាំងអស់ គឺដែលមានអង្គ ៩ មានសុត្តៈ និង គេយ្យៈជាដើមនោះ គឺដែលទ្រង់សម្តែងហើយក្នុងរវាងនេះ ដោយអត្ថ និង ដោយព្យញ្ជនៈហើយ មិនមានទីដែលគួរតិះដៀល មិនខ្វះខាត មិនលើស បរិបូណ៌ដោយអាការសព្វយ៉ាង ស្វាងចាកស្រវឹង គឺរាគៈ ។បេ។ ស្វាងចាក ស្រវឹង គឺមោហៈ មិនមានប្រការក្លែងក្លាយសូម្បីត្រឹមតែប៉ុនចុងរោមទ្រាយ ក្នុង ព្រះពុទ្ធវចនៈនោះយ៉ាងនោះប៉ុណ្ណោះ ដូចរបស់ដែលប្រថាប់ដោយត្រាតែមួយ ដូចរបស់ដែលវាល់ដោយនាឡិតែមួយ ដូចរបស់ដែលថ្លឹងដោយជញ្ជីងតែមួយ មិនជាដទៃ ព្រោះត្រាស់ទូន្មានដើម្បីជាប្រយោជន៍ដល់បុគ្គលណា ក៏ញ៉ាំង ប្រយោជន៍ឲ្យសម្រេចដល់បុគ្គលនោះ ដោយចំណែកមួយនោះឯង ព្រោះដូច្នោះ ពុទ្ធវចនៈនោះ ទើបជារបស់ពិត មិនប្រែប្រួល មិនទៅជាដទៃ ។ លោក សម្តែងថា ឈ្មោះថា **តថាគត** ព្រោះជាអ្នកមានប្រក្រតីត្រាស់យ៉ាងនោះ ។ **គត** សព្ទនេះ មានអត្ថស្មើគ្នានឹង **គទ** ព្រោះផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ឈ្មោះថា **តថាគត** ព្រោះត្រាស់យ៉ាង នោះ ។ ម្យ៉ាងទៀត ការពោល ឈ្មោះថា **អាគទោ** ដោយអត្ថថា ការ ត្រាស់ ។ ការត្រាស់យ៉ាងនោះ គឺមិនខុស មានដល់ព្រះមានព្រះភាគអង្គនោះ ហេតុនោះ ទើបព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **តថាគត** ព្រោះផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ។ អ្នកសិក្សាគួរជ្រាបបទសម្រេចរូបក្នុងពាក្យថា **តថាគត** នេះ តាមដែលពណ៌នាមកនេះចុះ ។ បទថា **យថាវាទី តថាការី**

*សេចក្ដីថា ព្រះមានព្រះភាគ កាលទ្រង់សម្ដែងធម៌ដល់ជនដទៃ ត្រាស់ធម៌ឯណាថា ធម៌ទាំងនេះ ជាអកុសល មានទោស វិញ្ញូជនតិះដៀល ដែលបុគ្គលសមាទានគ្រប់គ្រាន់ហើយ ប្រព្រឹត្តទៅដើម្បីវត្ថុដែលមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ទ្រង់លះនូវធម៌ទាំងនោះបានឯង ដោយចំណែកមួយនោះឯង ។ ឯធម៌ពួកណា ព្រះមានព្រះភាគត្រាស់ថា ធម៌ទាំងនេះ ជាកុសល មិនមានទោស វិញ្ញូជនសរសើរ ដែលអ្នកសមាទានគ្រប់គ្រាន់ហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ធម៌ទាំងនោះ ទ្រង់ចូលដល់ដោយព្រះអង្គឯងហើយ ដោយចំណែកមួយ ព្រោះហេតុនោះ ព្រះមានព្រះភាគបុគ្គលគប្បីជ្រាបថា ទ្រង់ត្រាស់យ៉ាងណា ទ្រង់ក៏ធ្វើយ៉ាងនោះ ។ បទថា* **យថាការី តថាវាទី** *សេចក្ដីថា ព្រះមានព្រះភាគទ្រង់បដិបត្តិប្រពៃហើយ ដោយអំណាចនៃការញ៉ាំងសីលជាដើមឲ្យបរិបូណ៌ ដោយប្រពៃនោះឯង ឈ្មោះថា ទ្រង់ធ្វើយ៉ាងណា ដោយព្រះអង្គឯង ក៏ត្រាស់យ៉ាងនោះ ដោយអំណាចនៃការញ៉ាំងអ្នកដទៃឲ្យតាំងនៅក្នុងធម៌ មានសីលជាដើមនោះ ដោយព្រះធម្មទេសនា អធិប្បាយថា ព្រះវរកាយរបស់ព្រះមានព្រះភាគ អនុលោមតាមព្រះវាចា សូម្បីព្រះវាចា ក៏អនុលោមតាមព្រះកាយ ព្រោះហេតុនោះ ទើបទ្រង់ឈ្មោះថា ទ្រង់ត្រាស់យ៉ាងណា ទ្រង់ក៏ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ក៏ត្រាស់យ៉ាងនោះ ។ ម្យ៉ាងទៀត អធិប្បាយថា ព្រះមានព្រះភាគទ្រង់មានសភាពយ៉ាងនោះ មានព្រះវាចាយ៉ាងណា សូម្បីព្រះកាយក៏ទៅហើយ គឺប្រព្រឹត្តទៅហើយយ៉ាងនោះ ព្រះកាយរបស់ទ្រង់ប្រព្រឹត្តទៅហើយយ៉ាងណា*

សូម្បីវាចា ក៏ទៅហើយ គឺប្រព្រឹត្តទៅហើយយ៉ាងនោះ ។

បទថា **អភិភូ អនភិភូតោ** សេចក្ដីថា ខាងលើទល់នឹងភវគ្គព្រហ្ម ខាងក្រោមទល់គ្នានឹងអវីចីនរក ទទឹងក្នុងលោកធាតុមិនមានប្រមាណ ព្រះមានព្រះភាគទ្រង់គ្របសង្កត់សត្វទាំងអស់ ដោយសីលផង ដោយសមាធិផង ដោយបញ្ញាផង ដោយវិមុត្តិផង ដោយវិមុត្តិញ្ញាណទស្សនៈផង ទ្រង់មិនមានអ្នកណាធ្ងន់ស្មើ ជាអប្បមាណបុគ្គល ជាអសមបុគ្គល មិនមានបុគ្គលស្មើ មិនមានបុគ្គលស្មើដូច មិនមានបុគ្គលផ្ទឹម មិនមានបុគ្គលផ្ទឹមស្មើ មិនមានបុគ្គលប្រដូច មិនមានបុគ្គលប្រៀបប្រដូច ទ្រង់ជាព្រះរាជាមិនមានអ្នកដទៃក្រៃលែងជាង ទ្រង់ជាទេវតាក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ព្រោះហេតុនោះឯង ទើបមិនមានបុគ្គលណាគ្របសង្កត់ព្រះអង្គបាន ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **អនភិភូតោ** គឺមិនមានបុគ្គលគ្របសង្កត់បាន ។ សព្ទថា **អញ្ញទត្ថុ** ជានិបាត ប្រើក្នុងអត្ថថា ដោយពិត អធិប្បាយថា វត្ថុណាមួយ ឈ្មោះថា **ទេយ្យ** វត្ថុទាំងអស់នោះនឹងឃើញបានដូចផ្លែកន្ទួតព្រៃ ដែលនៅលើបាតដៃ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាម **ទសោ** គឺជាអ្នកឃើញ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វសវត្តី** ព្រោះទ្រង់ឲ្យសត្វទាំងឡាយ ប្រព្រឹត្តទៅក្នុងអំណាច ដោយទ្រង់ជ្រាបអាសយៈជាដើមមិនខុស និងដោយទ្រង់នាំចូលទៅរកប្រយោជន៍ ទ្រង់ឲ្យសង្ខារទាំងឡាយ ប្រព្រឹត្តទៅក្នុងអំណាចដោយការនាំចូលទៅកាន់ភាពដទៃតាមភាវៈ គឺទ្រង់បង្គាប់កាយបាន ទ្រង់ញុំាងសមាបត្តិ និងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច

ព្រោះទ្រង់ប្រព្រឹត្តមក រហូតជំនាញ ដោយអាការគ្រប់យ៉ាង ។ ដោយហេតុប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់សម្តែងភាពដែលទ្រង់ជាព្រះតថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបបទសម្រេចរូបដូចតទៅ ព្រះមានព្រះភាគទ្រង់ដូចជាមានថ្នាំវិសេស ទើបទ្រង់ព្រះនាមថា **អគទ** ឯថ្នាំពិសេសនោះបានដល់អ្វី បានដល់ លម្អនៃព្រះធម្មទេសនា និងការច្រើនដោយបុណ្យ អធិប្បាយថា ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់មានពុទ្ធានុភាពច្រើន ទ្រង់គ្របសង្កត់សត្វលោកទាំងអស់ មួយអន្លើដោយទេវលោកបាន ដូចគ្រូពស់ បង្ក្រាបពស់ដោយទិព្វឱសថ ដូច្នោះ ។ ថ្នាំវិសេស គឺលម្អនៃព្រះធម្មទេសនា និងបុញ្ញាធិការ ដែលជាថ្នាំវិសេសពិត គឺមិនក្លែងក្លាយ ក្នុងការគ្របសង្កត់ គឺរក្សាសត្វលោករបស់ព្រះមានព្រះភាគអង្គនោះមាន ព្រោះដូច្នោះព្រះមានព្រះភាគអង្គនោះ គប្បីជ្រាបថា ទ្រង់ព្រះនាមថា **តថាគត** ដោយផ្លាស់ **ទ** អក្ខរៈ ជា **ត** អក្ខរៈ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងលោក ព្រមទាំងទេវលោក ។បេ។ តថាគតជាអ្នកគ្របសង្កត់លើសត្វឯទៀត ( ដោយគុណ ) សត្វឯទៀតគ្របសង្កត់ ( តថាគតវិញ ) មិនបាន ជាអ្នកឃើញហេតុសព្វគ្រប់ ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ព្រោះហេតុនោះ បានជាហៅថា **ព្រះតថាគត** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយ បទថា **សព្វលោកំ អភិញ្ញាយ** សេចក្តីថា ទ្រង់ដឹងនូវខន្ធដែលនៅអាស្រ័យក្នុងលោកធាតុទាំង ៣ ។ បទថា

**សព្វលោកេ យថាតថំ** សេចក្តីថា ទ្រង់ដឹងវត្ថុគ្រប់យ៉ាងដែលគួរដឹងក្នុងខន្ធ ដែលជាទីនៅអាស្រ័យក្នុងលោកធាតុទាំង ៣ នោះ តាមសេចក្តីពិត គឺមិនខុស ។ បទថា **សព្វលោកវិសំយុត្តោ** សេចក្តីថា ទ្រង់ប្រាសទៅ គឺផុតទៅហើយចាកលោកទាំងអស់ ដោយទ្រង់លះយោគៈ ៤ ណាមួយដោយមិនសេសសល់ ។ បទថា **អនូបយោ** សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់មិនមានអនុសយក្កិលេស ដោយអនុសយក្កិលេស គឺតណ្ហា និងទិដ្ឋិ គឺទ្រង់វៀរចាកអនុសយក្កិលេសទាំងនោះក្នុងលោកទាំងពួង ។ បទថា **សព្វាភិភូ** សេចក្តីថា ទ្រង់គ្របសង្កត់អារម្មណ៍ទាំងអស់ មានរូបជាដើម គឺសង្ខារទាំងអស់ បានដល់ មារទាំងអស់ហើយតាំងនៅ ។ បទថា **ធីរោ** បានដល់ ទ្រង់ដល់ព្រមដោយបញ្ញា ។ បទថា **សព្វគន្ថប្បមោចនោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ដោះនូវកិលេស មានកាយគន្ថៈ គឺអភិជ្ឈាជាដើម ទ្រង់តាំងនៅហើយ ឈ្មោះថា ទ្រង់ដោះកិលេស គឺគន្ថៈទាំងឡាយចេញបាន ព្រោះទ្រង់ដោះកិលេសទាំងនោះចេញចាកសន្តានរបស់វេនេយ្យសត្វ ដោយព្រះធម្មទេសនាដ៏ពីរោះរបស់ព្រះអង្គ ។ បទថា **ផុដ្ឋស្ស** កាត់បទជា **ផុដ្ឋា អស្ស** ។ ពាក្យថា **អស្ស** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ដោយអត្ថថា ដែលព្រះសម្មាសម្ពុទ្ធអង្គនោះទ្រង់ពាល់ត្រូវហើយ ។ បទថា **បរមា សន្តិ** បានដល់ ព្រះនិព្វាន ។ ព្រោះថា ព្រះនិព្វាននោះ ព្រះមានព្រះភាគ ទ្រង់ពាល់ត្រូវហើយដោយញាណសម្ផស្ស ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ព្រះនិព្វាននឹងមានភ័យមកអំពីណា ។

*ម្យ៉ាងទៀត បទថា* **បរមា សន្តិ** *បានដល់ ការស្ងប់ដ៏កំពូល ។ សួរថា ការស្ងប់ដ៏កំពូលនោះ គឺអ្វី ឆ្លើយថា គឺព្រះនិព្វាន ព្រោះហេតុក្នុងព្រះនិព្វាន នឹងមានភ័យមកអំពីណា ដូច្នោះ ទើបព្រះនិព្វាននោះ ព្រះមានព្រះភាគត្រាស់ថា នឹងមានភ័យមកអំពីណា ។ បទថា* **អនីឃោ** *បានដល់ ទ្រង់មិនមានទុក្ខ ។ បទថា* **សព្វកម្មក្ខយំ បត្តោ** *សេចក្ដីថា ទ្រង់ដល់នូវការអស់ទៅ បានដល់ ការមិនមានដោយចំណែកមួយនៃកម្មទាំងមូល ។ បទថា* **វិមុត្តោ ឧបធិសង្ខយេ** *សេចក្ដីថា ទ្រង់រួចផុតហើយដោយផលវិមុត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ក្នុងព្រះនិព្វាន ពោល គឺធម៌ជាទីអស់ទៅនៃឧបធិ ។ បទថា* **ឯសោ** *ស្មើគ្នានឹង* **ឯសោ សោ** *ប្រែថា នោះៗ ។ បទថា* **សីហោ អនុត្តរោ** *សេចក្ដីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា ជាកំពូលសីហៈ ព្រោះអត្ថថា ទ្រង់ញាំញីនូវអន្តរាយទាំងឡាយបាន និងព្រោះអត្ថថា ទ្រង់សម្លាប់កិលេសបាន ។ បទថា* **ព្រហ្មំ** *សេចក្ដីថា ប្រសើរបំផុត ។ បទថា* **ចក្កំ** *បានដល់ ព្រះធម្មចក្រ ។ បទថា* **បវត្តយិ** *សេចក្ដីថា ទ្រង់បង្វិលព្រះធម្មចក្រ ៣ ជុំ មានអាការ ១២ ។ បទថា* **ឥតិ** *បានដល់ ជ្រាបព្រះគុណរបស់ព្រះតថាគតយ៉ាងនេះហើយ ។ បទថា* **សង្គម្ម** *បានដល់ ប្រជុំគ្នា ។ បទថា* **តំ នមស្សន្តិ** *សេចក្ដីថា ទេវតា និងមនុស្សទាំងឡាយនោះ ដល់ព្រះពុទ្ធជាសរណៈ នាំគ្នានមស្ការព្រះតថាគតអង្គនោះ ដែលឈ្មោះថា* **មហន្តំ** *ព្រោះទ្រង់ប្រកបដោយគុណ មានសីលជាដើមដ៏ច្រើន ដែលឈ្មោះថា* **វីតសារទំ** *ព្រោះទ្រង់ប្រកបដោយធម៌ដែលធ្វើឲ្យទ្រង់ក្លៀវក្លា ៤ យ៉ាង ។*

ឥឡូវនេះ ដើម្បីសម្តែងដល់ព្រះសម្មាសម្ពុទ្ធ ដែលមានទេវតា និងមនុស្សទាំងឡាយនោះ នាំគ្នាសរសើរខ្លះ នមស្ការខ្លះ ទើបបានត្រាស់ពាក្យជាដើមថា **ឥត្ថេ** ពាក្យនេះ មានអត្ថងាយយល់ហើយ ។

ក្នុងចតុក្កនិបាតនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ បានត្រាស់វដ្តៈ ក្នុងសូត្រទី ៦ ទី ៧ ត្រាស់វិវដ្ត ក្នុងសូត្រទី ១ ទី ២ ទី ៣ ទី ១២ និងទី ១៣ ត្រាស់វដ្តៈផង វិវដ្តៈផង ក្នុងសូត្រដ៏សេស ដោយប្រការដូច្នេះ ៕

**អដ្ឋកថា លោកសូត្រទី ១៣ ចប់**

**ពណ៌នាចតុក្កនិបាត ឥតិវុត្តក ចប់**

**អដ្ឋកថាឥតិវុត្តក ចតុក្កនិបាត ឈ្មោះបរមត្ថទីបនី**

**ចប់ ដោយប្រការដូច្នេះឯង**

# និគមគាថា

ដោយកថាមគ្គ មានប្រមាណប៉ុណ្ណេះ ព្រះអរិយៈអ្នកស្វែងរកគុណធំទាំងឡាយ ជាអ្នកជំនាញក្នុងអភិញ្ញា ៦ បែកធ្លាយក្នុងបដិសម្ភិទា ជាអ្នកទទួលនូវធុរៈព្រះពុទ្ធសាសនា ចងក្រងព្រះធម្មវិន័យក្នុងកាលមុន បានប្រមូលសូត្រ ១១២ សូត្រ ចងក្រង ដែលព្រះមហេសីសម្មាសម្ពុទ្ធ ជាធម្មិស្សរាធិបតីក្នុងផែនដី ទ្រង់ឃើញច្បាស់នូវធម៌ផង លោកផង ទ្រង់ជ្រាបវិធីសម្ដែងធម៌ដល់សត្វដែលគួរដឹងធម៌ទាំងឡាយ ដែលទ្រង់ស្វែងរកប្រយោជន៍ដល់សត្វលោកទាំងពួង ទ្រង់អាស្រ័យហេតុនោះហើយ ទ្រង់សម្ដែង ដោយចែកជាឯកនិបាតជាដើម តាមប្រភេទធម៌ដែលពោលថា ឥតិវុត្តកៈនេះ ។ ដើម្បីប្រកាសអត្ថរបស់ឥតិវុត្តកៈនោះ ពណ៌នាអត្ថឯណា ដែលខ្ញុំ **ធម្មបាលាចារ្យ** បានប្រារព្ធល្អហើយ ដោយអាស្រ័យន័យបុរាណដ្ឋកថា ។ ពណ៌នានោះ ដោយឈ្មោះឈ្មោះថា **បរមត្ថទីបនី** ជាគ្រឿងប្រកាសបរមត្ថធម៌ ក្នុងព្រះសូត្រទាំងឡាយក្នុងឥតិវុត្តកៈនោះតាមសមគួរ មិនមានការវិនិច្ឆ័យជំទាស់ ដល់នូវសេចក្ដីសម្រេចសព្វគ្រប់ហើយ ដោយភាណវារបាលីប្រមាណ ៣៨ ភាណវារ ។

ព្រោះហេតុនេះ ដោយអានុភាពនៃបុណ្យ ដែលខ្ញុំអ្នកចងអដ្ឋកថាបានទទួលហើយ សូមសត្វទាំងឡាយ ញុំាងសាសនារបស់ព្រះលោកនាថឲ្យភ្លឺស្វាង ដោយបដិបទា មានសីលជាដើមដ៏បរិសុទ្ធ ចូរជាអ្នកមានចំណែក

នៃវិមុត្តិរស សូមសាសនារបស់ព្រះសម្ពុទ្ធ ស្ថិតក្នុងលោកអស់កាលជានិច្ច សូមសត្វទាំងពួងមានសេចក្តីគោរពក្នុងសាសនានេះ សព្វកាល សូមភ្លៀងធ្លាក់តាមរដូវកាល សូមព្រះរាជាជាធំក្នុងផែនដី ត្រេកអរក្នុងធម៌ ចូរគ្រប់គ្រងលោកដោយធម៌ហោង ៕□

អដ្ឋកថា ឥតិវុត្តកៈ ដែលខ្ញុំ **ធម្មធាលាចារ្យ**
វត្តកំពង់ពទរតិដ្ឋវិហារ ( វត្តកំពង់ពុទ្រា )
រចនាចប់ហើយ ដោយប្រការដូច្នេះ

# ក្បាលទី ៣៦

# សុត្តន្តបិដក បាលីប្រែ -៥៣

## សន្ទឹកបង្អួលប្រាប់មាតិកា

| មាតិកា | លេខទំព័រ |
| --- | --- |

### ឯកនិបាត បឋមវគ្គ


| | | |
| --- | --- | --- |
| លោកសូត្រ | ...... ...... ...... ...... | ២ |
| និទានវណ្ណនា | ...... ...... ...... ...... | ៧ |
| អត្ថរបស់វុត្តសព្ទ | ...... ...... ...... ...... | ៧ |
| អត្ថរបស់ឥតិសព្ទ | ...... ...... ...... ...... | ៤២ |
| អដ្ឋកថាលោកសូត្រ | ...... ...... ...... ...... | ៧៦ |
| អត្ថរបស់ឯកសព្ទ | ...... ...... ...... ...... | ៨០ |
| អត្ថរបស់ធម្មសព្ទ | ...... ...... ...... ...... | ៨០ |
| ទោសសូត្រ | ...... ...... ...... ...... | ៩៩ |
| អដ្ឋកថាទោសសូត្រ | ...... ...... ...... ...... | ១០០ |
| មោហសូត្រ | ...... ...... ...... ...... | ១០៧ |
| អដ្ឋកថាមោហសូត្រ | ...... ...... ...... ...... | ១០៨ |
| កោធសូត្រ | ...... ...... ...... ...... | ១១០ |
| អដ្ឋកថាកោធសូត្រ | ...... ...... ...... ...... | ១១១ |
| មក្ខសូត្រ | ...... ...... ...... ...... | ១១២ |
| អដ្ឋកថាមក្ខសូត្រ | ...... ...... ...... ...... | ១១៣ |
| មានសូត្រ | ...... ...... ...... ...... | ១១៤ |

អដ្ឋកថាមានសូត្រ ...... ...... ...... ...... ១១៥
សព្វសូត្រ ...... ...... ...... ...... ១២០
អដ្ឋកថាសព្វសូត្រ ...... ...... ...... ...... ១២១
អត្ថរបស់សព្វសព្ទ ...... ...... ...... ...... ១២២
មានបរិញ្ញាសូត្រ ...... ...... ...... ...... ១២៧
អដ្ឋកថាមានបរិញ្ញាសូត្រ ...... ...... ...... ...... ១២៨
លោភបរិញ្ញាសូត្រ ...... ...... ...... ...... ១៣០
អដ្ឋកថាលោភបរិញ្ញាសូត្រ ...... ...... ...... ...... ១៣១
ទោសបរិញ្ញាសូត្រ ...... ...... ...... ...... ១៣១
អដ្ឋកថាទោសបរិញ្ញាសូត្រ ...... ...... ...... ...... ១៣៣

## ទុតិយវគ្គ

មោហបរិញ្ញាសូត្រជាដើម ...... ...... ...... ...... ១៣៤
អដ្ឋកថាមោហបរិញ្ញាសូត្រជាដើម ...... ...... ...... ...... ១៣៧
អវិជ្ជានីវរណសូត្រ ...... ...... ...... ...... ១៣៧
អដ្ឋកថាអវិជ្ជានីវរណសូត្រ ...... ...... ...... ...... ១៣៨
តណ្ហាសំយោជនសូត្រ ...... ...... ...... ...... ១៤៣
អដ្ឋកថាតណ្ហាសំយោជនសូត្រ ...... ...... ...... ...... ១៤៤
បឋមសេក្ខសូត្រ ...... ...... ...... ...... ១៤៨
អដ្ឋកថាបឋមសេក្ខសូត្រ ...... ...... ...... ...... ១៤៩
ទុតិយសេក្ខសូត្រ ...... ...... ...... ...... ១៥៧
អដ្ឋកថាទុតិយសេក្ខសូត្រ ...... ...... ...... ...... ១៥៨
ភេទសូត្រ ...... ...... ...... ...... ១៦៣
អដ្ឋកថាភេទសូត្រ ...... ...... ...... ...... ១៦៤
មោទសូត្រ ...... ...... ...... ...... ១៧០

អដ្ឋកថាមោទសូត្រ ...... ...... ...... ...... ១៧១

បុគ្គលសូត្រ ...... ...... ...... ...... ១៧៤

អដ្ឋកថាបុគ្គលសូត្រ ...... ...... ...... ...... ១៧៥

អត្ថរបស់ឥធសព្ទ ...... ...... ...... ...... ១៧៦

តតិយវគ្គ

ចិត្តឈាយីសូត្រ ...... ...... ...... ...... ១៨០

អដ្ឋកថាចិត្តឈាយីសូត្រ ...... ...... ...... ...... ១៨១

បុញ្ញសូត្រ ...... ...... ...... ...... ១៨២

អដ្ឋកថាបុញ្ញសូត្រ ...... ...... ...... ...... ១៨៤

អត្ថរបស់បុញ្ញសព្ទ ...... ...... ...... ...... ១៨៤

ឧភោអត្ថសូត្រ ...... ...... ...... ...... ១៩៦

អដ្ឋកថាឧភោអត្ថសូត្រ ...... ...... ...... ...... ១៩៧

វេបុល្លបព្វតសូត្រ ...... ...... ...... ...... ២០៣

អដ្ឋកថាវេបុល្លបព្វតសូត្រ ...... ...... ...... ...... ២០៤

សម្បជានមុសាវាទសូត្រ ...... ...... ...... ...... ២១២

អដ្ឋកថាសម្បជានមុសាវាទសូត្រ ...... ...... ...... ...... ២១៣

ទានសូត្រ ...... ...... ...... ...... ២១៥

អដ្ឋកថាទានសូត្រ ...... ...... ...... ...... ២១៧

មេត្តាភាវនាសូត្រ ...... ...... ...... ...... ២២០

អដ្ឋកថាមេត្តាភាវនាសូត្រ ...... ...... ...... ...... ២២៤

## ទុកនិបាត

### បឋមវគ្គ

បឋមភិក្ខុសូត្រ ...... ...... ...... ...... ២៣៨

អដ្ឋកថាបឋមភិក្ខុសូត្រ ...... ...... ...... ...... ២៣៩

ចក្ខុ ៥ យ៉ាង ...... ...... ...... ...... ២៤៥

ទុតិយភិក្ខុសូត្រ ...... ...... ...... ...... ២៤៩

អដ្ឋកថាទុតិយភិក្ខុសូត្រ ...... ...... ...... ...... ២៥០

តបនីយសូត្រ ...... ...... ...... ...... ២៥១

អដ្ឋកថាតបនីយសូត្រ ...... ...... ...... ...... ២៥២

អតបនីយសូត្រ ...... ...... ...... ...... ២៥៦

អដ្ឋកថាអតបនីយសូត្រ ...... ...... ...... ...... ២៥៧

បឋមសីលសូត្រ ...... ...... ...... ...... ២៥៧

អដ្ឋកថាបឋមសីលសូត្រ ...... ...... ...... ...... ២៥៨

ទុតិយសីលសូត្រ ...... ...... ...... ...... ២៦០

អដ្ឋកថាទុតិយសីលសូត្រ ...... ...... ...... ...... ២៦១

អាតាបីសូត្រ ...... ...... ...... ...... ២៦២

អដ្ឋកថាអាតាបីសូត្រ ...... ...... ...... ...... ២៦៣

បឋមនកុហនាសូត្រ ...... ...... ...... ...... ២៦៨

អដ្ឋកថាបឋមនកុហនាសូត្រ ...... ...... ...... ...... ២៦៩

អត្ថរបស់ព្រហ្មចរិយសព្ទ ...... ...... ...... ...... ២៧០

ទុតិយនកុហនាសូត្រ ...... ...... ...... ...... ២៧៩

អដ្ឋកថាទុតិយនកុហនាសូត្រ ...... ...... ...... ...... ២៨០

សោមនស្សសូត្រ ...... ...... ...... ...... ២៨១

អដ្ឋកថាសោមនស្សសូត្រ ...... ...... ...... ...... ២៨៣

អត្ថរបស់យោនិសព្ទ ...... ...... ...... ...... ២៨៤

អត្ថរបស់អាសវក្ខយសព្ទ ...... ...... ...... ...... ២៨៧

**ទុតិយវគ្គ**

វិតក្កសូត្រ ...... ...... ...... ...... ២៩១
អដ្ឋកថាវិតក្កសូត្រ ...... ...... ...... ...... ២៩៣
អត្ថរបស់តថាគតសព្ទ ...... ...... ...... ...... ២៩៣
ទេសនាសូត្រ ...... ...... ...... ...... ៣៦៦
អដ្ឋកថាទេសនាសូត្រ ...... ...... ...... ...... ៣៦៧
អត្ថរបស់បរិយាយសព្ទ ...... ...... ...... ...... ៣៦៧
វិជ្ជាសូត្រ ...... ...... ...... ...... ៣៧១
អដ្ឋកថាវិជ្ជាសូត្រ ...... ...... ...... ...... ៣៧២
បញ្ញាសូត្រ ...... ...... ...... ...... ៣៧៤
អដ្ឋកថាបញ្ញាសូត្រ ...... ...... ...... ...... ៣៧៦
សុក្កធម្មសូត្រ ...... ...... ...... ...... ៣៧៩
អដ្ឋកថាសុក្កធម្មសូត្រ ...... ...... ...... ...... ៣៨០
អជាតសូត្រ ...... ...... ...... ...... ៣៨៨
អដ្ឋកថាអជាតសូត្រ ...... ...... ...... ...... ៣៨៩
ធាតុសូត្រ ...... ...... ...... ...... ៣៩៦
អដ្ឋកថាធាតុសូត្រ ...... ...... ...... ...... ៣៩៨
បដិសល្លានសូត្រ ...... ...... ...... ...... ៤០៥
អដ្ឋកថាបដិសល្លានសូត្រ ...... ...... ...... ...... ៤០៦
សិក្ខានិសំសសូត្រ ...... ...... ...... ...... ៤១១
អដ្ឋកថាសិក្ខានិសំសសូត្រ ...... ...... ...... ...... ៤១២
ជាគរិយសូត្រ ...... ...... ...... ...... ៤១៦

អដ្ឋកថាជាគរិយសូត្រ ...... ...... ...... ...... ៤១៨
អបាយិកសូត្រ ...... ...... ...... ...... ៤២៥
អដ្ឋកថាអបាយិកសូត្រ ...... ...... ...... ...... ៤២៦
ទិដ្ឋិសូត្រ ...... ...... ...... ...... ៤២៩
អដ្ឋកថាទិដ្ឋិសូត្រ ...... ...... ...... ...... ៤៣២

## តិកនិបាត

### បឋមវគ្គ

អកុសលមូលសូត្រ ...... ...... ...... ...... ៤៣៩
អដ្ឋកថាអកុសលមូលសូត្រ ...... ...... ...... ...... ៤៤០
ធាតុសូត្រ ...... ...... ...... ...... ៤៤៤
អដ្ឋកថាធាតុសូត្រ ...... ...... ...... ...... ៤៤៥
បឋមវេទនាសូត្រ ...... ...... ...... ...... ៤៤៩
អដ្ឋកថាបឋមវេទនាសូត្រ ...... ...... ...... ...... ៤៥០
អត្ថរបស់ទុក្ខសព្ទ ...... ...... ...... ...... ៤៥០
ទុតិយវេទនាសូត្រ ...... ...... ...... ...... ៤៧០
អដ្ឋកថាទុតិយវេទនាសូត្រ ...... ...... ...... ...... ៤៧១
បឋមឯសនាសូត្រ ...... ...... ...... ...... ៤៧៧
អដ្ឋកថាបឋមឯសនាសូត្រ ...... ...... ...... ...... ៤៧៨
ទុតិយឯសនាសូត្រ ...... ...... ...... ...... ៤៨១
អដ្ឋកថាទុតិយឯសនាសូត្រ ...... ...... ...... ...... ៤៨២
បឋមអាសវសូត្រ ...... ...... ...... ...... ៤៨៤
អដ្ឋកថាបឋមអាសវសូត្រ ...... ...... ...... ...... ៤៨៥
ទុតិយអាសវសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៤៨៦

តណ្ហាសូត្រ ...... ...... ...... ...... ៤៨៧
អដ្ឋកថាតណ្ហាសូត្រ ...... ...... ...... ...... ៤៨៨
មារធេយ្យសូត្រ ...... ...... ...... ...... ៤៩២
អដ្ឋកថាមារធេយ្យសូត្រ ...... ...... ...... ...... ៤៩៣
អត្ថរបស់ខន្ធសព្វ ...... ...... ...... ...... ៤៩៧

## ទុតិយវគ្គ

បុញ្ញកិរិយាវត្ថុសូត្រ ...... ...... ...... ...... ៥០០
អដ្ឋកថាបុញ្ញកិរិយាវត្ថុសូត្រ ...... ...... ...... ...... ៥០១
ចក្ខុសូត្រ ...... ...... ...... ...... ៥០៧
អដ្ឋកថាចក្ខុសូត្រ ...... ...... ...... ...... ៥០៨
ឥន្ទ្រិយសូត្រ ...... ...... ...... ...... ៥១១
អដ្ឋកថាឥន្ទ្រិយសូត្រ ...... ...... ...... ...... ៥១២
អទ្ធាសូត្រ ...... ...... ...... ...... ៥១៧
អដ្ឋកថាអទ្ធាសូត្រ ...... ...... ...... ...... ៥១៨
ទុច្ចរិតសូត្រ ...... ...... ...... ...... ៥២៥
អដ្ឋកថាទុច្ចរិតសូត្រ ...... ...... ...... ...... ៥២៦
សុចរិតសូត្រ ...... ...... ...... ...... ៥២៧
អដ្ឋកថាសុចរិតសូត្រ ...... ...... ...... ...... ៥២៨
សោចេយ្យសូត្រ ...... ...... ...... ...... ៥២៩
អដ្ឋកថាសោចេយ្យសូត្រ ...... ...... ...... ...... ៥៣០
មោនេយ្យសូត្រ ...... ...... ...... ...... ៥៣១
អដ្ឋកថាមោនេយ្យសូត្រ ...... ...... ...... ...... ៥៣២
បឋមរាគសូត្រ ...... ...... ...... ...... ៥៣៤

អដ្ឋកថាបឋមរាគសូត្រ ...... ...... ...... ...... ៥៣៥

ទុតិយរាគសូត្រ ...... ...... ...... ...... ៥៣៨

អដ្ឋកថាទុតិយរាគសូត្រ ...... ...... ...... ...... ៥៤០

## តតិយវគ្គ

មិច្ឆាទិដ្ឋិកសូត្រ ...... ...... ...... ...... ៥៤៣

អដ្ឋកថាមិច្ឆាទិដ្ឋិកសូត្រ ...... ...... ...... ...... ៥៤៥

សម្មាទិដ្ឋិកសូត្រ និងអដ្ឋកថា ...... ...... ...... ...... ៥៤៨

និស្សរណិយសូត្រ ...... ...... ...... ...... ៥៥០

អដ្ឋកថានិស្សរណិយសូត្រ ...... ...... ...... ...... ៥៥២

សន្តតរសូត្រ ...... ...... ...... ...... ៥៥៤

អដ្ឋកថាសន្តតរសូត្រ ...... ...... ...... ...... ៥៥៥

បុត្តសូត្រ ...... ...... ...... ...... ៥៥៧

អដ្ឋកថាបុត្តសូត្រ ...... ...... ...... ...... ៥៥៩

អានិសង្សការមិនសម្លាប់សត្វជាដើម ...... ...... ...... ...... ៥៩០

អវុដ្ឋិកសូត្រ ...... ...... ...... ...... ៥៩៦

អដ្ឋកថាអវុដ្ឋិកសូត្រ ...... ...... ...... ...... ៥៩៨

សុខបត្ថនាសូត្រ ...... ...... ...... ...... ៦០៤

អដ្ឋកថាសុខបត្ថនាសូត្រ ...... ...... ...... ...... ៦០៦

ភិទុរសូត្រ ...... ...... ...... ...... ៦១២

អដ្ឋកថាភិទុរសូត្រ ...... ...... ...... ...... ៦១៣

ធាតុសោសំសន្ទនសូត្រ ...... ...... ...... ...... ៦១៦

អដ្ឋកថាធាតុសោសំសន្ទនសូត្រ ...... ...... ...... ...... ៦១៨

បរិហានសូត្រ ...... ...... ...... ...... ៦២៣

អដ្ឋកថាបរិហានសូត្រ ...... ...... ...... ...... ៦២៥

**ចតុត្ថវគ្គ**

វិតក្កសូត្រ ...... ...... ...... ...... ៦៣០
អដ្ឋកថាវិតក្កសូត្រ ...... ...... ...... ...... ៦៣១
សក្ការសូត្រ ...... ...... ...... ...... ៦៣៤
អដ្ឋកថាសក្ការសូត្រ ...... ...... ...... ...... ៦៣៦
ទេវសទ្ទសូត្រ ...... ...... ...... ...... ៦៣៩
អដ្ឋកថាទេវសទ្ទសូត្រ ...... ...... ...... ...... ៦៤១
បញ្ចបុព្វនិមិត្តសូត្រ ...... ...... ...... ...... ៦៤៨
អដ្ឋកថាបញ្ចបុព្វនិមិត្តសូត្រ ...... ...... ...... ...... ៦៥០
ពហុជនហិតសូត្រ ...... ...... ...... ...... ៦៦២
អដ្ឋកថាពហុជនហិតសូត្រ ...... ...... ...... ...... ៦៦៥
អសុភានុបស្សីសូត្រ ...... ...... ...... ...... ៦៧៧
អដ្ឋកថាអសុភានុបស្សីសូត្រ ...... ...... ...... ...... ៦៧៨
ធម្មានុធម្មប្បដិបន្នសូត្រ ...... ...... ...... ...... ៦៨៤
អដ្ឋកថាធម្មានុធម្មប្បដិបន្នសូត្រ ...... ...... ...... ...... ៦៨៥
អន្ធករណសូត្រ ...... ...... ...... ...... ៦៨៩
អដ្ឋកថាអន្ធករណសូត្រ ...... ...... ...... ...... ៦៩២
អន្តរាមលសូត្រ ...... ...... ...... ...... ៦៩៧
អដ្ឋកថាអន្តរាមលសូត្រ ...... ...... ...... ...... ៦៩៩
ទេវទត្តសូត្រ ...... ...... ...... ...... ៧០៩
អដ្ឋកថាទេវទត្តសូត្រ ...... ...... ...... ...... ៧១១

**បញ្ចមវគ្គ**

| | | |
|---|---|---|
| អគ្គប្បសាទសូត្រ | ...... ...... ...... ...... | ៧១៨ |
| អដ្ឋកថាអគ្គប្បសាទសូត្រ | ...... ...... ...... ...... | ៧២១ |
| អត្ថរបស់អគ្គសព្ទ | ...... ...... ...... ...... | ៧២១ |
| ជីវិតសូត្រ | ...... ...... ...... ...... | ៧៤១ |
| អដ្ឋកថាជីវិតសូត្រ | ...... ...... ...... ...... | ៧៤២ |
| អត្ថរបស់អន្ធសព្ទ | ...... ...... ...... ...... | ៧៤៣ |
| សង្ឃាដិកណ្ណសូត្រ | ...... ...... ...... ...... | ៧៥២ |
| អដ្ឋកថាសង្ឃាដិកណ្ណសូត្រ | ...... ...... ...... ...... | ៧៥៣ |
| អគ្គិសូត្រ | ...... ...... ...... ...... | ៧៥៧ |
| អដ្ឋកថាអគ្គិសូត្រ | ...... ...... ...... ...... | ៧៥៩ |
| ឧបបរិក្ខសូត្រ | ...... ...... ...... ...... | ៧៦៤ |
| អដ្ឋកថាឧបបរិក្ខសូត្រ | ...... ...... ...... ...... | ៧៦៥ |
| កាមូបបត្តិសូត្រ | ...... ...... ...... ...... | ៧៦៨ |
| អដ្ឋកថាកាមូបបត្តិសូត្រ | ...... ...... ...... ...... | ៧៧០ |
| កាមយោគសូត្រ | ...... ...... ...... ...... | ៧៧៣ |
| អដ្ឋកថាកាមយោគសូត្រ | ...... ...... ...... ...... | ៧៧៤ |
| កល្យាណសីលសូត្រ | ...... ...... ...... ...... | ៧៧៩ |
| អដ្ឋកថាកល្យាណសីលសូត្រ | ...... ...... ...... ...... | ៧៨១ |
| អធិប្បាយពាក្យថា បាតិមោក្ខ | ...... ...... ...... ...... | ៧៨៣ |
| ទានសូត្រ | ...... ...... ...... ...... | ៧៩៤ |
| អដ្ឋកថាទានសូត្រ | ...... ...... ...... ...... | ៧៩៥ |
| តេវិជ្ជសូត្រ | ...... ...... ...... ...... | ៨០១ |
| អដ្ឋកថាតេវិជ្ជសូត្រ | ...... ...... ...... ...... | ៨០៥ |

## ចតុក្កនិបាត

ព្រាហ្មណធម្មយាគសូត្រ …… …… …… …… ៨១៨
អដ្ឋកថាព្រាហ្មណធម្មយាគសូត្រ …… …… …… …… ៧២០
សុលកសូត្រ …… …… …… …… ៨៣២
អដ្ឋកថាសុលកសូត្រ …… …… …… …… ៨៣៤
អាសវក្ខយសូត្រ …… …… …… …… ៨៣៨
អដ្ឋកថាអាសវក្ខយសូត្រ …… …… …… …… ៨៤០
សមណព្រាហ្មណសូត្រ …… …… …… …… ៨៤៦
អដ្ឋកថាសមណព្រាហ្មណសូត្រ …… …… …… …… ៨៤៨
សីលសម្បន្នសូត្រ …… …… …… …… ៨៤៩
អដ្ឋកថាសីលសម្បន្នសូត្រ …… …… …… …… ៨៥១
តណ្ហុប្បាទសូត្រ …… …… …… …… ៨៦០
អដ្ឋកថាតណ្ហុប្បាទសូត្រ …… …… …… …… ៨៦១
សព្រហ្មកសូត្រ …… …… …… …… ៨៦៣
អដ្ឋកថាសព្រហ្មកសូត្រ …… …… …… …… ៨៦៤
ពហុការសូត្រ …… …… …… …… ៨៧៥
អដ្ឋកថាពហុការសូត្រ …… …… …… …… ៨៧៦
កុហនសូត្រ …… …… …… …… ៨៨០
អដ្ឋកថាកុហនសូត្រ …… …… …… …… ៨៨១
នទីសោតសូត្រ …… …… …… …… ៨៨៥
អដ្ឋកថានទីសោតសូត្រ …… …… …… …… ៨៨៧
ចរសូត្រ …… …… …… …… ៩០២
អដ្ឋកថាចរសូត្រ …… …… …… …… ៩០៥

សីលសម្បន្នសូត្រ ...... ...... ...... ...... ៩១១

អដ្ឋកថាសីលសម្បន្នសូត្រ ...... ...... ...... ...... ៩១៤

អត្តរបស់សម្បន្នសត្តុ ...... ...... ...... ...... ៩១៥

ធម៌សម្រាប់លះកាមច្ឆន្ទជាដើម ...... ...... ...... ...... ៩២១

លោកសូត្រ ...... ...... ...... ...... ៩៣៥

អដ្ឋកថា លោកសូត្រ ...... ...... ...... ...... ៩៣៩